# ព្រះ
# ត្រៃបិដក

## ប្រែរួមនឹង
## ព្រះអដ្ឋកថា

## ភាគ៥៣

បាលីប្រែ ៦៤ - ៦៥

ពុទ្ធសករាជ ២៥៥៣

ច្បាប់ពិនិត្យ លើកទី២

# ព្រះ

# សុត្តន្តបិដក

## និង

# សទ្ធម្មប្បជោតិកា  អដ្ឋកថា

### សេចក្តីប្រែជាភាសាខ្មែរ

## ខុទ្ទកនិកាយ  មហានិទ្ទេស

## បឋមភាគ-ទុតិយភាគ

## ៥៣

## បាលីប្រែ  ៦៤-៦៥



*បោះពុម្ពលើកទី  ១  ពុទ្ធសករាជ  ២៥៥៣*

# ក្បាលទី៨៣

# ខុទ្ទកនិកាយ មហានិទ្ទេស

## តេរសមភាគ

*សូមនមស្ការព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ។*

## អដ្ឋវគ្គិកៈ

## កាមសុត្តនិទ្ទេសទី ១

[ ១ ] *( ព្រះមានព្រះភាគត្រាស់ថា ) កាលសត្វប្រាថ្នាកាម បើវត្ថុនោះ សម្រេចដល់សត្វនោះ សត្វរមែងមានចិត្តប្រកបដោយបីតិពិត ( ព្រោះ ) សត្វប្រាថ្នានូវវត្ថុណា បាន ( នូវវត្ថុនោះ ) ។*

[ ២ ] *ពាក្យថា កាម ក្នុងពាក្យថា កាលសត្វប្រាថ្នាកាម ដូច្នេះ បើតាមឧទ្ទាន បានដល់ កាមពីរ គឺ វត្ថុកាម ១ កិលេសកាម ១ ។*

*ពួកវត្ថុកាមដូចម្តេច ។ រូបជាទីគាប់ចិត្ត សំឡេងជាទីគាប់ចិត្ត ក្លិនជាទីគាប់ចិត្ត រសជាទីគាប់ចិត្ត ផ្សព្វជាទីគាប់ចិត្ត កម្រាល គ្រឿងស្លៀកពាក់ ខ្ញុំស្រី ខ្ញុំប្រុស ពពែ ចៀម មាន់ ជ្រូក ដំរី គោ សេះឈ្មោល សេះញីស្រែ ចម្ការ ប្រាក់ មាស ស្រុក និគម រាជធានី ដែន ជនបទ បន្ទាយឃ្លាំងនិងវត្ថុដែលគួរត្រេកអរណាមួយ ឈ្មោះថា វត្ថុកាម ។ មួយទៀត កាមទាំងឡាយជាអតីតៈ កាមទាំងឡាយជាអនាគត កាមទាំងឡាយជាបច្ចុប្បន្នកាមទាំងឡាយជាខាងក្នុង កាមទាំងឡាយជាខាងក្រៅ កាមទាំងឡាយទាំងខាងក្នុងទាំងខាងក្រៅ កាមទាំងឡាយថោកទាប កាមទាំងឡាយជាកណ្តាល*

កាមទាំងឡាយដ៏ខ្ពង់ខ្ពស់ កាមទាំងឡាយមានក្នុងអបាយ កាមទាំងឡាយមានក្នុងមនុស្ស កាមទាំងឡាយជាទិព្វ កាមទាំងឡាយដែលតាំងឡើងឯង កាមទាំងឡាយដែលខ្លួននិម្មិត កាមទាំងឡាយដែលអ្នកដទៃនិម្មិត កាមទាំងឡាយដែលបុគ្គលហួងហែង កាមទាំងឡាយដែលបុគ្គលមិនបានហួងហែង កាមទាំងឡាយដែលបុគ្គលរាប់អានថាជារបស់អញ កាមទាំងឡាយដែលបុគ្គលមិនរាប់អានថាជារបស់អញ ពួកធម៌ជាកាមាវចរទាំងអស់ក្តី ពួកធម៌ជារូបាវចរទាំងអស់ក្តី ពួកធម៌ជាអរូបាវចរទាំងអស់ក្តី ដែលជាវត្ថុនៃតណ្ហាជាអារម្មណ៍នៃតណ្ហា ឈ្មោះថា កាម ដោយអត្ថថា គួរប្រាថ្នា ដោយអត្ថថា គួរត្រេកអរ ដោយអត្ថថា គួរស្រវឹងទាំងនេះហៅថា វត្ថុកាម ។

ពួកកិលេសកាមដូចម្តេច ។ សេចក្តីប្រាថ្នា ឈ្មោះថាកាម សេចក្តីត្រេកអរ ឈ្មោះថាកាម សេចក្តីត្រេកអរដ៏មានកម្លាំងឈ្មោះថាកាម សេចក្តីត្រិះរិះ ឈ្មោះថាកាម តម្រេក ឈ្មោះថាកាម តម្រេកដោយការត្រិះរិះ ឈ្មោះថា កាម បានដល់ សេចក្តីប្រាថ្នាក្នុងកាម ក្នុងកាមទាំងឡាយ សេចក្តីត្រេកអរក្នុងកាម សេចក្តីរីករាយក្នុងកាម តណ្ហាក្នុងកាម សេចក្តីស្នេហាក្នុងកាម សេចក្តីអន្ទះអន្ទែងក្នុងកាម ការជ្រប់ក្នុងកាម ការងប់ចុះក្នុងកាម អន្ទង់គឺកាម គ្រឿងប្រកបគឺកាម ការថ្ពក់ជាប់គឺកាម នីវរណៈគឺកាមច្ឆន្ទៈ ( នឹងពាក្យដែលព្រះមានព្រះភាគត្រាស់ថា )

នៃកាម តថាគតបានឃើញឫសគល់របស់អ្នកហើយ នៃកាម អ្នកឯងកើតអំពីសេចក្តីត្រិះរិះ តថាគតមិនត្រិះរិះចំពោះអ្នកទេ នៃកាម អ្នកនឹងមិនមាន

យ៉ាងនេះទេ ។

ទាំងនេះ លោកហៅថា កិលេសកាម ។ ពាក្យថា កាលសត្វប្រាថ្នាកាម គឺកាលត្រូវការ កាលចង់បាន កាលត្រេកអរ កាលតាំងទុក កាលស្រឡាញ់ កាលជាប់ជំពាក់ចំពោះកាម ព្រោះហេតុនោះ ( ទ្រង់ត្រាស់ថា ) កាលសត្វប្រាថ្នាកាម ។

[ ៣ ] អធិប្បាយពាក្យថា បើវត្ថុនោះ សម្រេចដល់សត្វនោះ ត្រង់ពាក្យថា បើដល់សត្វនោះ គឺដល់សត្វនោះ ទោះក្សត្រក្តី ព្រាហ្មណ៍ក្តី វេស្សៈក្តី សូទ្រៈក្តី គ្រហស្ថក្តី បព្វជិតក្តី ទេវតាក្តី មនុស្សក្តី ។ ពាក្យថា វត្ថុនោះ លោកសំដៅយកវត្ថុកាម គឺរូបជាទីគាប់ចិត្ត សំឡេងជាទីគាប់ចិត្ត ក្លិនជាទីគាប់ចិត្ត រសជាទីគាប់ចិត្ត ផ្សព្វជាទីគាប់ចិត្ត ។ ពាក្យថា សម្រេច គឺស្រេច ស្រេចបាច់បាន បានចំពោះ បានស៊ប់ បានប្រទះ ព្រោះហេតុនោះ ( ទ្រង់ត្រាស់ថា ) បើវត្ថុនោះ សម្រេចដល់សត្វនោះ ។

[ ៤ ] អធិប្បាយពាក្យថា សត្វរមែងមានចិត្តប្រកបដោយបីតិពិត ត្រង់ពាក្យថា ពិត គឺជាពាក្យប្រាប់សេចក្តីដោយដាច់ខាត ប្រាប់សេចក្តីដោយមិនមានសង្ស័យ ប្រាប់សេចក្តីមិនមានងឿងឆ្ងល់ ប្រាប់ដំណើរមិនមានពីរ ប្រាប់ហេតុមិនបែកជាពីរ ប្រាប់ការប្រកបដោយទៀងទាត់ ប្រាប់ហេតុមិនខុស ពាក្យថាពិត នុ៎ះជាពាក្យប្រាប់សេចក្តីកំណត់ ។ ពាក្យថា បីតិ បានដល់ បីតិ ភាពនៃចិត្តរីករាយ ការរីករាយទូទៅ ការរីករាយសព្វគ្រប់ សេចក្តីស្រស់ស្រាយ សេចក្តីស្រស់ស្រាយសព្វគ្រប់ សេចក្តីត្រេកអរ សេចក្តីពេញចិត្ត ភាពនៃចិត្ត

អបអរ ភាពនៃចិត្តត្រេកត្រអាល ភាពនៃចិត្តដ៏ពេញលេញក្រៃលែង ដែលប្រកបដោយកាមគុណ ៥ ។ ពាក្យថា ចិត្ត គឺចិត្ត មនៈ មានសៈ ហទយៈ បណ្ឌរៈ មនៈ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោវិញ្ញាណធាតុ ដែលសមគួរដល់ធម៌ មានផស្សៈជាដើមនោះណា នេះលោកហៅថា ចិត្ត ។ ចិត្តនេះជាធម្មជាតិទៅជាមួយ កើតជាមួយ ច្រឡំ ប្រកប មានការកើតឡើងក្នុងទីជាមួយ មានការរលត់ក្នុងទីមួយ មានវត្ថុតែមួយ មានអារម្មណ៍តែមួយ ជាមួយនឹងបីតិនេះ ។ ពាក្យថា មានចិត្តប្រកបដោយបីតិ គឺមានចិត្តត្រេកអរ មានចិត្តរីករាយ មានចិត្តរីករាយខ្លាំង មានចិត្តជារបស់ខ្លួន មានចិត្តខ្ពស់ មានចិត្តស្រស់ស្រាយ ព្រោះហេតុនោះ ( ទ្រង់ត្រាស់ថា ) មានចិត្តប្រកបដោយបីតិពិត ។

[ ៥ ] អធិប្បាយពាក្យថា សត្វប្រាថ្នានូវវត្ថុណា បាន ( នូវវត្ថុនោះ ) ត្រង់ពាក្យថា បាន គឺបានហើយ បានរួចហើយ បានស៊ប់ហើយ បានសម្រេចហើយ បានប្រាកដហើយ ។ ពាក្យថា សត្វ គឺសត្វ ជន មាណព បុរស បុគ្គល សត្វមានជីវិត សត្វមានជាតិ សត្វមានជរា សត្វទៅដោយឥន្ទ្រិយ សត្វកើតអំពីមនុស្ស ។ ពាក្យថា សត្វប្រាថ្នានូវវត្ថុណា គឺសត្វប្រាថ្នាវត្ថុណា ត្រេកអរវត្ថុណា ក្ដួចកាន់វត្ថុណា ស្រឡាញ់វត្ថុណា ជាប់ចំពាក់ចំពោះវត្ថុណា ទោះជារូបក្ដី សំឡេងក្ដី ក្លិនក្ដី រសក្ដី ផោដ្ឋព្វក្ដី ហេតុនោះ ( ទ្រង់ត្រាស់ថា ) សត្វប្រាថ្នានូវវត្ថុណា បាន ( នូវវត្ថុនោះ ) ។ ព្រោះហេតុនោះ ព្រះមានព្រះភាគទ្រង់ត្រាស់ថា

កាលសត្វប្រាថ្នាកាម បើវត្ថុនោះសម្រេចដល់សត្វនោះ សត្វរមែងមានចិត្តប្រកបដោយបីតិពិត ( ព្រោះ ) សត្វប្រាថ្នានូវវត្ថុណា បាន ( នូវវត្ថុនោះ ) ។

[ ៦ ] កាលបើសត្វនោះ មានឆន្ទៈកើតហើយ កំពុងប្រាថ្នា កាមទាំងឡាយនោះ សាបសូន្យទៅវិញ សត្វរមែងក្តៅក្រហាយ ដូចត្រូវព្រួញមុត ។

[ ៧ ] អធិប្បាយពាក្យថា បើកាលសត្វនោះ កំពុងប្រាថ្នា ត្រង់ពាក្យថា បើកាលសត្វនោះ គឺកាលសត្វនោះ ទោះជាក្សត្រិយ៍ក្តី ព្រាហ្មណ៍ក្តី វេស្សៈក្តី សូទ្រៈក្តី គ្រហស្ថក្តី បព្វជិតក្តី ទេវតាក្តី មនុស្សក្តី ។ ពាក្យថា កំពុងប្រាថ្នា គឺកំពុងត្រូវការ កំពុងចង់បាន កំពុងត្រេកអរ កំពុងតាំងទុក កំពុងស្រឡាញ់ កំពុងជាប់ចំពាក់ ។ មួយទៀត សត្វរមែងទៅ ចេញទៅ រសាត់ទៅ ប្រមូលទៅតាមកាមតណ្ហា ។ បុគ្គលតែងទៅ ចេញទៅ រសាត់ទៅ ប្រមូលទៅដោយយានដំរី យានសេះ យានគោ យានពពែ យានចៀម យានឱដ្ឋ ឬយានលាយ៉ាងណា សត្វរមែងទៅ ចេញទៅ រសាត់ទៅ ប្រមូលទៅ ដោយកាមតណ្ហាយ៉ាងនោះដែរ ព្រោះហេតុនោះ ( ទ្រង់ត្រាស់ថា ) បើកាលសត្វនោះកំពុងប្រាថ្នា ។

[ ៨ ] ពាក្យថា ឆន្ទៈ ក្នុងពាក្យថា កាលសត្វមានឆន្ទៈកើតហើយ គឺសេចក្តីប្រាថ្នាក្នុងកាម សេចក្តីត្រេកអរក្នុងកាម សេចក្តីរីករាយក្នុងកាម តណ្ហាក្នុងកាម សេចក្តីស្នេហាក្នុងកាម សេចក្តីអន្ទះអន្ទែងក្នុងកាម ការជ្រប់ក្នុងកាម ការងប់ចុះក្នុងកាម អន្ទង់គឺកាម គ្រឿងប្រកបគឺកាម ការជ្ពក់ជាប់គឺកាម នីវ-

វណៈគឺកាមឆន្ទៈក្នុងកាមទាំងឡាយណា កាមឆន្ទៈនោះរបស់សត្វនោះជាសភាពកើតហើយ កើតព្រមហើយ កើតឡើងហើយ កើតចំពោះហើយ កើតប្រាកដហើយ ។ ពាក្យថា កាលសត្វ គឺកាលសត្វ ជន មាណព បុរស បុគ្គល ជីវសត្វ សត្វមានជាតិ សត្វមានជរា សត្វទៅដោយឥន្ទ្រិយ សត្វកើតអំពីមនុស្ស ព្រោះហេតុនោះ ( ទ្រង់ត្រាស់ថា ) កាលសត្វមានឆន្ទៈកើតហើយ ។

[ ៩ ] ពាក្យថា កាមទាំងឡាយនោះ សាបសូន្យទៅ អធិប្បាយថា កាមទាំងឡាយនោះ សាបសូន្យ ឬសត្វនោះសាបសូន្យចាកកាមទាំងឡាយ ។

កាមទាំងឡាយនោះ សាបសូន្យដោយប្រការដូចម្តេច ។ ព្រះរាជាទាំងឡាយ នាំយកភោគៈទាំងឡាយនោះ របស់សត្វនោះ ដែលកំពុងរស់នៅ ឬពួកចោរនាំយកទៅ ឬភ្លើងឆេះ ឬទឹកបន្សាត់យកទៅ ឬញាតិ សាច់មិនជាទីគាប់ចិត្តដណ្តើមយក ឬសត្វនោះមិនបានកំណប់ដែលខ្លួនកប់ទុក ការងារទាំងឡាយ ដែលប្រកបខុសទំនង ខូចខាតទៅ បុគ្គលសម្លាប់ត្រកូលកើតឡើងក្នុងត្រកូល បុគ្គលណា ( ជាខាងក្រោយ ) ខ្ជះខ្ជាយ បំផ្លាញ កំចាត់បង់នូវភោគៈទាំងនោះ បុគ្គលនោះឈ្មោះថា អ្នកមានសេចក្តីវិនាស ព្រោះភាពនៃការមិនទៀង កាមទាំងឡាយនោះ សាបសូន្យ សាបសូន្យស្រឡះ ខ្ចាត់ខ្ចាត់ លះបង់ បាត់បង់ រលាយរលត់ទៅ យ៉ាងនេះ ។

បុគ្គលនោះ សាបសូន្យចាកកាមទាំងឡាយ ដោយប្រការដូចម្តេច ។ ភោគៈទាំងឡាយនោះ ឋិតនៅ តែបុគ្គលនោះ ឃ្លាត ស្លាប់ អន្តរធាន វិនាសទៅ បុគ្គលនោះឈ្មោះថាសាបសូន្យ សាបសូន្យស្រឡះ ខ្ចាត់ខ្ចាត់ បាត់បង់ អន្តរ

ជាន វិនាសទៅ យ៉ាងនេះ ។

ចោរទាំងឡាយ ព្រះរាជាទាំងឡាយ នាំយកទ្រព្យទៅ ភ្លើងឆេះទ្រព្យ ប្រយោជន៍វិនាសទៅ បុគ្គលលះបង់សរីរៈ ព្រមទាំងរបស់ដែលហួងហែង ដោយមរណៈ អ្នកប្រាជ្ញជ្រាបសេចក្តីនេះហើយ គប្បីបរិភោគផង ឲ្យទានផង លុះបានឲ្យទាន និងបរិភោគតាមសមគួរដល់អានុភាពហើយ រមែងជាបុគ្គលដែលមិនត្រូវគេនិន្ទា ហើយចូលទៅកាន់ឋានសួគ៌ ។ កាមទាំងឡាយនោះ ឈ្មោះថា រមែងសាបសូន្យ ។

[ ១០ ] ពាក្យថា សត្វរមែងក្តៅក្រហាយ ដូចត្រូវព្រួញមុត គឺសត្វដែលត្រូវព្រួញដែកមុត ឬត្រូវព្រួញឆ្អឹង ត្រូវព្រួញភ្លុក ត្រូវព្រួញស្នែង ឬត្រូវព្រួញឈើមុត រមែងក្តៅក្រហាយ ញាប់ញ័រ ចង្អៀតចង្អល លំបាក ឈឺចាប់ តូចចិត្ត យ៉ាងណា សេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស នឹងសេចក្តីចង្អៀតចង្អល់ចិត្តទាំងឡាយ រមែងកើតឡើង ព្រោះប្រែប្រួល ព្រាត់ប្រាសចាកវត្ថុកាមទាំងឡាយ បុគ្គលនោះត្រូវព្រួញគឺកាមមុត រមែងក្តៅក្រហាយ ញាប់ញ័រ ចង្អៀតចង្អល់ លំបាក ឈឺចាប់ តូចចិត្ត យ៉ាងនោះឯង ហេតុនោះ ( ទ្រង់ត្រាស់ថា ) សត្វក្តៅក្រហាយដូចត្រូវព្រួញមុត ។ ហេតុនោះ ព្រះ-មានព្រះភាគត្រាស់ថា

បើកាលសត្វនោះ មានឆន្ទៈកើតហើយ កំពុងប្រាថ្នា កាមទាំងឡាយនោះសាបសូន្យទៅវិញ សត្វរមែងក្តៅក្រហាយ ដូចត្រូវព្រួញមុត ។

[ ១១ ] បុគ្គលណា វៀរកាមទាំងឡាយ ដូចបុគ្គលវៀរក្បាលពស់

ដោយជើង បុគ្គលនោះ ជាអ្នកមានសតិ រមែងកន្លងវិសត្តិកាតណ្ហានេះក្នុងលោក ។

[ ១២ ] អធិប្បាយពាក្យថា បុគ្គលណាវៀរកាមទាំងឡាយ ត្រង់ពាក្យថា បុគ្គលណា គឺជនណា បែបណា ប្រកបដោយប្រការណា តាំងនៅដោយប្រការណា មានប្រការយ៉ាងណា ដល់ឋានៈណា ប្រកបដោយធម៌ណា ទោះជាក្សត្រ ព្រាហ្មណ៍ វេស្សៈ សូទ្រៈ គ្រហស្ថ បព្វជិត ទេវតា ឬមនុស្ស ។ ពាក្យថា កាមទាំងឡាយ ក្នុងពាក្យថា វៀរកាមទាំងឡាយ ដូច្នេះ បើតាមឧទ្ទាន បានដល់កាមពីរ គឺវត្ថុកាម ១ កិលេសកាម ១ ។បេ។ ទាំងនេះលោកហៅថា វត្ថុកាម ។បេ។ ទាំងនេះ លោកហៅថា កិលេសកាម ។ ត្រង់ពាក្យថា វៀរកាមទាំងឡាយ គឺបុគ្គលវៀរកាមទាំងឡាយ ដោយហេតុពីរ គឺដោយកិរិយាសង្កត់សង្កិន ឬដោយការផ្តាច់ផ្តិល ។

បុគ្គលវៀរកាម ដោយកិរិយាសង្កត់សង្កិន តើដូចម្តេច ។ បុគ្គលកាលឃើញថា កាមទាំងឡាយ មានឧបមាដូចរាងឆ្អឹង ដោយសេចក្តីថា មានសេចក្តីត្រេកអរតិច ឈ្មោះថាវៀរកាម ដោយកិរិយាសង្កត់សង្កិន កាលឃើញថា កាមទាំងឡាយ មានឧបមាដូចដុំសាច់ ដោយសេចក្តីថា ជារបស់សាធារណ៍ដល់សត្វ មានប្រមាណច្រើន ឈ្មោះថាវៀរកាម ដោយកិរិយាសង្កត់សង្កិន កាលឃើញថា កាមទាំងឡាយ មានឧបមាដូចគប់ស្មៅ ដោយសេចក្តីថា ដុតកំដៅរឿយ ៗ ឈ្មោះថាវៀរកាមដោយកិរិយាសង្កត់សង្កិន កាលឃើញថា កាមទាំងឡាយ មានឧបមាដូចរណ្តៅរងើកភ្លើង ដោយសេចក្តីថា មានកិរិយា

ក្តៅរោលរាលខ្លាំង ឈ្មោះថាវៀរកាមដោយកិរិយាសង្កត់សង្កិន កាលឃើញថា កាមទាំងឡាយ មានឧបមាដូចការយល់សប្តិ ដោយសេចក្តីថា មានកិរិយាតាំងឡើង ដ៏ផ្តេសផ្តាស ឈ្មោះថាវៀរកាមដោយកិរិយាសង្កត់សង្កិន កាលឃើញថា កាមទាំងឡាយមានឧបមាដូចរបស់ដែលខ្ចីគេ ដោយសេចក្តីថា ជារបស់ប្រព្រឹត្តទៅ មួយដងមួយកាលប៉ុណ្ណោះ ឈ្មោះថា វៀរកាមដោយកិរិយាសង្កត់សង្កិន កាលឃើញថា កាមទាំងឡាយមានឧបមាដូចឈើមានផ្លែ ដោយសេចក្តីថា មានកិរិយាបាក់ខ្ទេចខ្ទី ឬបាក់ដាច់អស់ ឈ្មោះថា វៀរកាមដោយកិរិយាសង្កត់សង្កិន កាលឃើញថា កាមទាំងឡាយមានឧបមា ដូចកាំបិតនិងជ្រញ់ ដោយសេចក្តីថា ដាច់រេចរិល ឈ្មោះថាវៀរកាមដោយកិរិយាសង្កត់សង្កិន កាលឃើញថាកាមទាំងឡាយ មានឧបមាដូចមុខលំពែង ដោយសេចក្តីថា ចាក់ទម្លុះ ឈ្មោះថាវៀរកាមដោយកិរិយាសង្កត់សង្កិន កាលឃើញថា កាមទាំងឡាយមានឧបមាដូចក្បាលពស់វែក ដោយសេចក្តីថា ប្រកបដោយភ័យចំពោះមុខ ឈ្មោះថាវៀរកាមដោយកិរិយាសង្កត់សង្កិន កាលឃើញថា កាមទាំងឡាយមានឧបមាដូចគំនរភ្លើង ដោយសេចក្តីថា ក្តៅរោលរាលដោយភ្លើងធំ ឈ្មោះថាវៀរកាមដោយកិរិយាសង្កត់សង្កិន ។ បុគ្គលកំពុងចម្រើនពុទ្ធានុស្សតិក្តី ឈ្មោះថាវៀរកាមដោយកិរិយាសង្កត់សង្កិន កំពុងចម្រើនធម្មានុស្សតិក្តី កំពុងចម្រើនសង្ឃានុស្សតិក្តី កំពុងចម្រើនសីលានុស្សតិក្តី កំពុងចម្រើនចាគានុស្សតិក្តី កំពុងចម្រើនទេវតានុស្សតិក្តី កំពុងចម្រើនអានាបានស្សតិក្តី កំពុងចម្រើនមរណានុស្សតិក្តី កំពុងចម្រើនកាយគតាសតិក្តី កំពុង

ចម្រើនឧបសមានុស្សតិក្តី ឈ្មោះថាវៀរកាមដោយកិរិយាសង្កត់សង្កិន ។ បុគ្គលកំពុងចម្រើនបឋមជ្ឈានក្តី ឈ្មោះថា វៀរកាមដោយកិរិយាសង្កត់សង្កិន កំពុងចម្រើនទុតិយជ្ឈានក្តី កំពុងចម្រើនតតិយជ្ឈានក្តី កំពុងចម្រើនចតុត្ថជ្ឈានក្តី កំពុងចម្រើនអាកាសានញ្ចាយតនសមាបត្តិក្តី កំពុងចម្រើនវិញ្ញាណញ្ចាយ-តនសមាបត្តិក្តី កំពុងចម្រើនអាកិញ្ចញ្ញាយតនសមាបត្តិក្តី កំពុងចម្រើនវេនវ-សញ្ញានាសញ្ញាយតនសមាបត្តិក្តី ឈ្មោះថា វៀរកាមដោយកិរិយាសង្កត់សង្កិន បុគ្គលវៀរកាមដោយកិរិយាសង្កត់សង្កិនយ៉ាងនេះ ។

បុគ្គលវៀរកាម ដោយការផ្តាច់ផ្តិល តើដូចម្តេច ។ បុគ្គលកាលចម្រើនសោតាបត្តិមគ្គក្តី ឈ្មោះថាវៀរកាមដែលជាហេតុទៅកាន់អបាយ ដោយកិរិ-យាផ្តាច់ផ្តិល កាលចម្រើនសកទាគាមិមគ្គក្តី ឈ្មោះថា វៀរកាមដ៏គ្រោតគ្រាត ដោយកិរិយាផ្តាច់ផ្តិល កាលចម្រើនអនាគាមិមគ្គក្តី ឈ្មោះថា វៀរកាមដ៏ល្អិត ដោយកិរិយាផ្តាច់ផ្តិល កាលចម្រើនអរហត្តមគ្គក្តី ឈ្មោះថាវៀរកាមដោយសព្វគ្រប់ គ្រប់ទាំងអស់ មិនមានសេសសល់ ឥតសេសសល់ ដោយកិរិយាផ្តាច់ផ្តិល ។ បុគ្គលវៀរកាម ដោយការផ្តាច់ផ្តិលយ៉ាងនេះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលណា វៀរកាមទាំងឡាយ ។

[ ១៣ ] ពាក្យថា ដូចបុគ្គលវៀរក្បាលពស់ដោយជើង អធិប្បាយថា អហិសត្វ លោកហៅថាពស់ ។ ដែលហៅថាពស់ ដោយសេចក្តីដូចម្តេច ។ សត្វណាលូនទៅ ហេតុនោះ សត្វនោះ ឈ្មោះថាពស់ ។ សត្វណា ពត់ពេន ហេតុនោះ សត្វនោះ ឈ្មោះថា ភុជគៈ ។ សត្វណាទៅដោយទ្រូង ហេតុនោះ

សត្វនោះ ឈ្មោះថា ពស់ ។ សត្វណាមានក្បាលឱនរាប ហេតុនោះ សត្វនោះ ឈ្មោះថា ពស់ សត្វណាលូនទៅដោយក្បាល ហេតុនោះ សត្វនោះ ឈ្មោះថា ពស់ ។ សត្វណាដេកក្នុងរន្ធ ហេតុនោះ សត្វនោះ ឈ្មោះថា វិលាស័យ ។ សត្វណា ដេកក្នុងគុហា ហេតុនោះ សត្វនោះ ឈ្មោះថា គុហាស័យ ។ សត្វនោះមានចង្កូមជាអាវុធ ហេតុនោះ សត្វនោះ ឈ្មោះថា ទាឍាវុធ ។ សត្វនោះមានពិសដ៏ពន្លឹក ហេតុនោះ សត្វនោះ ឈ្មោះថា ឃោរវិសៈ ។ សត្វនោះមានអណ្តាតពីរ ហេតុនោះ សត្វនោះ ឈ្មោះថា ទុជ្ជិវ្ហា ។ សត្វណា ជញ្ជក់រសដោយអណ្តាតពីរ ហេតុនោះ សត្វនោះ ឈ្មោះថា ទិរសញ្ញូ ។ បុរសអ្នកចង់រស់ មិនចង់ស្លាប់ ប្រាថ្នាសេចក្តីសុខ ខ្ពើមសេចក្តីទុក្ខ គួរវៀរ គួរចៀសចេញ គួរគេចចេញ គួរវៀរស្រឡះចេញនូវក្បាលពស់ដោយជើង យ៉ាងណា បុគ្គលអ្នកប្រាថ្នា សេចក្តីសុខ ខ្ពើមសេចក្តីទុក្ខ គួរវៀរ គួរចៀសចេញ គួរគេចចេញ គួរវៀរស្រឡះចេញនូវកាមទាំងឡាយ ក៏យ៉ាងនោះដែរ ហេតុនោះ (ទ្រង់ត្រាស់ថា ) ដូចបុគ្គលវៀរក្បាលពស់ដោយជើង ។

[ ១៤ ] អធិប្បាយពាក្យថា បុគ្គលនោះ ជាអ្នកមានសតិ រមែងកន្លងវិសត្តិកាតណ្ហានេះក្នុងលោក ត្រង់ពាក្យថា បុគ្គលនោះ គឺបុគ្គលដែលវៀរកាម ។ តណ្ហា លោកហៅថា វិសត្តិកា បានដល់ តម្រេក តម្រេកមានកម្លាំង សេចក្តីក្ងួចកាន់ សេចក្តីត្រេកអរ សេចក្តីរីករាយ សេចក្តីរីករាយក្នុងតម្រេក តម្រេកមានកម្លាំងរបស់ចិត្ត សេចក្តីប្រាថ្នា សេចក្តីជ្រប់ចុះ កិរិយាងប់ចុះ សេចក្តីចំពាក់ចិត្ត សេចក្តីចំពាក់មាំ កិលេសជាគ្រឿងជាប់ កិលេសដូចភក់

កិរិយាស្វែងរក ការលោភពុត កិលេសជាតិជាគ្រឿងញុំាងសត្វឲ្យកើត គ្រឿងញុំាងទុក្ខឲ្យកើត គ្រឿងចាក់ស្រែះ កិលេសជាតិដូចជាបណ្ដាញ កិលេសជាតិហូរទៅផ្សាយទៅ ក្រសែគឺតណ្ហា កិលេសជាតិដ៏ទូលាយ គ្រឿងញុំាងអាយុឲ្យវិនាស តណ្ហាជាគម្រប់ពីរ គ្រឿងតម្កល់ទុក គ្រឿងនាំសត្វទៅកាន់ភព កិលេសជាតិដូចជាព្រៃធំ ដូចជាព្រៃតូច ការស្និទ្ធស្នាល សេចក្ដីស្នេហា សេចក្ដីអាល័យ សេចក្ដីជាប់ចំពាក់ សេចក្ដីប៉ុនប៉ង សេចក្ដីទឹកជញ្ជីង ភាពនៃចិត្តទឹកជញ្ជីង បំណងរូប បំណងសំឡេង បំណងក្លិន បំណងរស បំណងផ្សព្វ បំណងលាភ បំណងទ្រព្យ បំណងបុត្ត បំណងជីវិត ការជាប់ ការជាប់ទូទៅ ការជាប់ក្រៃលែង ការជាប់ កិរិយាជាប់ ភាពនៃចិត្តជាប់ ការជក់ស្អិត កិរិយាជក់ស្អិត ភាពនៃចិត្តជក់ស្អិត ភាពនៃចិត្តរឡិបរឡប់ ភាពនៃចិត្តប្រាថ្នាក្រៃពេកតម្រេកខុសគន្លងធម៌ សេចក្ដីលោភមិនស្មើ សេចក្ដីអាល័យ កិលេសជាតិជាទីអាល័យ សេចក្ដីប្រាថ្នា សេចក្ដីស្រឡាញ់ សេចក្ដីប្រាថ្នាគ្រប់យ៉ាង កាមតណ្ហា ភវតណ្ហា វិភវតណ្ហា រូបតណ្ហា អរូបតណ្ហា និរោធតណ្ហា រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា អន្លង់គ្រឿងប្រកបទុក្ខ គ្រឿងចាក់ស្រែះ គ្រឿងប្រកាន់ទុក កិរិយាពាំង កិរិយាទប់ កិរិយាប្រក់ កិរិយាចង កិរិយាសៅហ្មង កិរិយាដេកនៅរឿយៗ កិរិយាស្ទាក់ វល្លិ គឺតណ្ហា សេចក្ដីប្រាថ្នាផ្សេងៗ ឫសគល់នៃទុក្ខ ហេតុនៃទុក្ខ ដែនកើតនៃទុក្ខ អន្ទាក់នៃមារ សន្ទូចនៃមារ វិស័យនៃមារ ស្ទឹងគឺតណ្ហា បណ្ដាញគឺតណ្ហា ដងដោយគឺតណ្ហា សមុទ្ទគឺតណ្ហា អភិជ្ឈា លោភៈ អកុសលមូល ។

សំណួរត្រង់ពាក្យថា វិសត្តិកា តើវិសត្តិកា ដោយសេចក្តីដូចម្តេច ។ តណ្ហាណា ផ្សាយទៅ ព្រោះហេតុនោះ តណ្ហានោះ ឈ្មោះថា វិសត្តិកា ។ តណ្ហាណាដ៏ទូលាយ ព្រោះហេតុនោះ តណ្ហានោះ ឈ្មោះថា វិសត្តិកា ។ តណ្ហាណា ជ្រួតជ្រាបទៅ ព្រោះហេតុនោះ តណ្ហានោះ ឈ្មោះថា វិសត្តិកា ។ តណ្ហាណា អត់ទ្រាំ ព្រោះហេតុនោះ តណ្ហានោះ ឈ្មោះថា វិសត្តិកា ។ តណ្ហាណា ប្រមូលផ្សេងៗ ព្រោះហេតុនោះ តណ្ហានោះ ឈ្មោះថា វិសត្តិកា ។ តណ្ហាណា ញុំាងសត្វឲ្យពោលខុស ព្រោះហេតុនោះ តណ្ហានោះ ឈ្មោះថា វិសត្តិកា ។ តណ្ហាណា មានឫសគល់ជាពិស ព្រោះហេតុនោះ តណ្ហានោះ ឈ្មោះថា វិសត្តិកា ។ តណ្ហាណា មានផ្លែជាពិស ព្រោះហេតុនោះ តណ្ហានោះ ឈ្មោះថា វិសត្តិកា ។ តណ្ហាណា មានគ្រឿងបរិភោគជាពិស ព្រោះហេតុនោះ តណ្ហានោះ ឈ្មោះថា វិសត្តិកា ។ មួយទៀត តណ្ហានោះ ជាកិលេសជាតិទូលាយ បាចសាចទៅ ផ្សាយទៅ ក្នុងរូប សំឡេង ក្លិន រស ផ្សព្វ ក្នុងត្រកូល គណៈ អាវាស លាភ យស សេចក្តីសរសើរ សុខ ក្នុងចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ច័យភេសជ្ជបរិក្ខារ ក្នុងកាមធាតុ រូបធាតុ អរូបធាតុ ក្នុងកាមភព រូបភព អរូបភព ក្នុងសញ្ញាភព អសញ្ញាភព នេវ-សញ្ញានាសញ្ញាភព ឯកវោការភព ចតុវោការភព បញ្ចវោការភព ក្នុងកាលជាអតីតៈ អនាគត បច្ចុប្បន្ន ក្នុងអារម្មណ៍ ទាំងឡាយដែលខ្លួនឃើញ ឮ ប៉ះពាល់ ឬគប្បីដឹង ព្រោះហេតុនោះ តណ្ហានោះ ឈ្មោះថា វិសត្តិកា ។

ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក មនុស្សលោក ទេវលោក

*ខន្ធលោក ធាតុលោក អាយតនលោក ។*

*ពាក្យថា ជាអ្នកមានសតិ គឺមានសតិ ដោយហេតុ ៤ យ៉ាងគឺ មានសតិកាលចម្រើនកាយានុបស្សនាសតិប្បដ្ឋានក្នុងកាយ ក្នុងវេទនាទាំងឡាយ ក្នុងចិត្ត មានសតិកាលចម្រើនធម្មានុបស្សនាសតិប្បដ្ឋានក្នុងធម៌ទាំងឡាយ ។ មានសតិ ដោយហេតុ ៤ យ៉ាងទៀត គឺមានសតិដោយការវៀរចាកការមិនមានសតិ មានសតិដោយការបានធ្វើធម៌ទាំងឡាយដែលខ្លួនគប្បីធ្វើដោយសតិ មានសតិដោយការបានកម្ចាត់នូវធម៌ទាំងឡាយជាទំនាស់ដល់សតិ មានសតិដោយការមិនភ្លេចភ្លាំងនូវធម៌ទាំងឡាយជានិមិត្តរបស់សតិ ។ មានសតិដោយហេតុ ៤ យ៉ាងទៀត គឺមានសតិដោយការបានប្រកបដោយសតិ មានសតិព្រោះជាអ្នកស្ទាត់ក្នុងសតិ មានសតិព្រោះជាអ្នកប៉ិនក្នុងសតិ មានសតិព្រោះជាអ្នកមិនឃ្លៀងឃ្លាតចាកសតិ ។ មានសតិដោយហេតុ ៤ យ៉ាង ផ្សេងទៀត គឺមានសតិព្រោះជាអ្នកមានស្មារតី មានសតិព្រោះជាអ្នកស្ងប់ មានសតិព្រោះជាអ្នករម្ងាប់ មានសតិព្រោះជាអ្នកប្រកបដោយសប្បុរិសធម៌ ។ មានសតិព្រោះការរឭករឿយៗចំពោះព្រះពុទ្ធ មានសតិព្រោះការរលឹករឿយៗចំពោះព្រះធម៌ មានសតិព្រោះការរឭករឿយៗចំពោះព្រះសង្ឃ មានសតិព្រោះការរឭករឿយៗចំពោះសីល មានសតិព្រោះការរឭករឿយៗចំពោះការលះ មានសតិព្រោះការរឭករឿយៗចំពោះគុណធម៌នៃទេវតា មានសតិព្រោះការរឭករឿយ ៗ ចំពោះខ្យល់ដង្ហើមចេញចូល មានសតិព្រោះការរឭករឿយៗ ចំពោះមរណៈ មានសតិព្រោះការរឭករឿយៗចំពោះកាយ មានសតិ*

ព្រោះការរឭករឿយៗចំពោះឧបសមៈ គឺនិព្វាន ។ កិរិយារឭក រឭករឿយៗ រឭកចំពោះឈ្មោះថាសតិ ភាពនៃកិរិយារឭក ភាពនៃកិរិយាចាំទុក ភាពនៃកិរិយាមិនភ្លេចភ្លាំង ភាពនៃកិរិយាមិនវង្វេងឈ្មោះថាសតិ សតិន្ទ្រិយ សតិពល សម្មាសតិ សតិសម្ពោជ្ឈង្គ ឯកាយនមគ្គ ( ផ្លូវជាទីប្រព្រឹត្តទៅនៃបុគ្គលម្នាក់ឯង ) នេះ លោកហៅថា សតិ ។ បុគ្គលណា កៀកកើយ អែបនែប ចូលទៅជិត ចូលផ្ដេកផ្ដិច មូលមិត្ត បរិបូណ៌ ប្រកបដោយសតិនេះ បុគ្គលនោះ លោកហៅថា អ្នកមានស្មារតី ។

ពាក្យថា បុគ្គលនោះ ជាអ្នកមានស្មារតី រមែងកន្លងនូវវិសត្តិកាតណ្ហានេះក្នុងលោក សេចក្ដីថា តណ្ហាឈ្មោះវិសត្តិកាណាក្នុងលោក បុគ្គលមានស្មារតី រមែងឆ្លង ឆ្លងឡើង ឆ្លងកាត់ ឈានកន្លង ប្រព្រឹត្តកន្លងនូវតណ្ហា ឈ្មោះវិសត្តិកានេះក្នុងលោក ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលនោះ ជាអ្នកមានស្មារតី រមែងកន្លងនូវវិសត្តិកាតណ្ហានេះក្នុងលោក ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

បុគ្គលណា វៀរកាមទាំងឡាយ ដូចបុគ្គលវៀរក្បាលពស់
ដោយជើង បុគ្គលនោះ ជាអ្នកមានស្មារតី រមែងកន្លងនូវ
វិសត្តិកាតណ្ហានេះក្នុងលោក ។

[ ១៥ ] ជនណា ប្រាថ្នារឿយៗនូវស្រែ ទីកន្លែង ប្រាក់ គោ សេះ ទាសៈនឹងពួកបុរស ស្ត្រី ផៅពង្ស ឬកាមទាំងឡាយច្រើន ។

[ ១៦ ] អធិប្បាយពាក្យថា ស្រែ ទីកន្លែង ប្រាក់ ត្រង់ពាក្យថា ស្រែ

គឺស្រែស្រូវសាលី ស្រែស្រូវធម្មតា ចម្ការសណ្តែកបាយ ចម្ការសណ្តែករាជមាស ស្រែស្រូវដំណើប ស្រែស្រងែ ចម្ការល្ង ។ ពាក្យថា ទីកន្លែង គឺទីផ្ទះ ទីជម្រក ទីមុខ ( ផ្ទះ ) ទីក្រោយ ( ផ្ទះ ) ទីសួន ទីកន្លែងនៅ ។ កហាបណលោកហៅថា ប្រាក់ ក្នុងបទថា ប្រាក់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ស្រែ ទីកន្លែង ប្រាក់ ។

[ ១៧ ] ពាក្យថា គោ សេះ ទាសៈ និងពួកបុរស អធិប្បាយថា គោទាំងឡាយ លោកហៅថា គោ ។ ពួកសត្វ មានសត្វចិញ្ចឹមជាដើម លោកហៅថា សេះ ។ ពាក្យថា ទាសៈ បានដល់ខ្ញុំ ៤ ពួក គឺខ្ញុំដែលកើតខាងក្នុងផ្ទះ ១ ខ្ញុំដែលលោះដោយទ្រព្យ ១ បុគ្គលដែលចូលមកជាខ្ញុំដោយខ្លួនឯង ១ បុគ្គលដែលមិនមានប្រាថ្នា តែចូលមកជាខ្ញុំ ១ ។

បុគ្គលពួក ១ ជាខ្ញុំកើតអំពីទាសីក៏មាន ជាខ្ញុំដែលគេលោះ
ដោយទ្រព្យក៏មាន បុគ្គលពួក ១ ចូលមកជាខ្ញុំដោយខ្លួនឯង
ក៏មាន បុគ្គលដែលត្រូវភ័យគ្របសង្កត់មកធ្វើជាខ្ញុំក៏មាន ។

ពាក្យថា ពួកបុរស បានដល់បុរស ៣ ពួកគឺ អ្នករាជការ ១ កម្មករ ១ អ្នកជំនួញ ១ ហេតុនោះ ( ទ្រង់ត្រាស់ថា ) គោ សេះ ទាសៈ នឹងពួកបុរស ។

[ ១៨ ] ពាក្យថា ស្ត្រី ផៅពង្ស ឬកាមទាំងឡាយច្រើន អធិប្បាយថា ស្ត្រីជាភរិយា លោកហៅថា ស្ត្រី ។ ពាក្យថា ផៅពង្ស បានដល់ផៅពង្ស ៤ ពួក គឺផៅពង្សជាប់ដោយញាតិ ១ ផៅពង្សជាប់ដោយគោត្ត ១ ផៅពង្សជាប់ដោយមន្ត ១ ផៅពង្សជាប់ដោយសិល្បសាស្ត្រ ១ ។ ពាក្យថា កាមទាំង

ឡាយច្រើន គឺកាមមានប្រមាណច្រើន ។ កាមមានប្រមាណច្រើនទុ៎ះ គឺរូបទាំងឡាយជាទីគាប់ចិត្ត ។បេ។ ផស្សទាំងឡាយជាទីគាប់ចិត្ត ហេតុនោះ (ទ្រង់ត្រាស់ថា ) ស្ត្រីផៅពង្ស កាមទាំងឡាយច្រើន ។

[ ១៩ ] អធិប្បាយពាក្យថា ជនណាប្រាថ្នារឿយៗ ត្រង់ពាក្យថា ជនណា គឺបុគ្គលណា បែបណា ប្រកបដោយប្រការណា តាំងនៅដោយប្រការណា មានប្រការយ៉ាងណា ដល់នូវឋានៈណា ប្រកបដោយធម៌ណា ទោះបីជាក្សត្រ ឬព្រាហ្មណ៍ ជាវេស្សៈ ឬសូទ្រៈ ជាគ្រហស្ថ ឬបព្វជិត ជាទេវតា ឬមនុស្ស ។ ពាក្យថា ជន បានដល់ សត្វ ជន មាណព បុរស បុគ្គល សត្វមានជីវិត សត្វមានជាតិ សត្វមានជរា សត្វទៅដោយឥន្ទ្រិយ សត្វកើតអំពីមនុស្ស ។ ពាក្យថា ប្រាថ្នារឿយៗ គឺចង់បាន ប្រាថ្នារឿយៗ ជាប់ចិត្តញុំាមក្នុងវត្ថុកាមទាំងឡាយ ដោយសារកិលេសកាម ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជនណាប្រាថ្នារឿយៗ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគទ្រង់ត្រាស់ថា

ជនណាប្រាថ្នារឿយៗនូវស្រែ ទីកន្លែង ប្រាក់ គោ សេះ ទាសៈ
នឹងពួកបុរស ស្ត្រី ផៅពង្ស ឬកាមទាំងឡាយច្រើន ។

[ ២០ ] កិលេសមិនមានកម្លាំងទាំងឡាយ រមែងសង្កត់សង្កិនបុគ្គលនោះ អន្តរាយទាំងឡាយ រមែងញាំញីបុគ្គលនោះ

ទុក្ខរមែងជាប់តាមបុគ្គលនោះ ព្រោះអន្តរាយនោះ ដូចជាទឹក
កាលជ្រាបចូលកាន់នាវា ដែលបែកធ្លាយ ។

[ ២១ ] អធិប្បាយពាក្យថា កិលេសមិនមានកម្លាំងទាំងឡាយ រមែងសង្កត់សង្កិនបុគ្គលនោះ ត្រង់ពាក្យថា កិលេសមិនមានកម្លាំងទាំងឡាយ គឺកិលេសទាំងឡាយ មិនមានកម្លាំង មានកម្លាំងថយ មានកម្លាំងតិច មានសេចក្ដីប្រឹងប្រែងតិច ថោកទាប ស្ដួចស្ដើង អន់ថយ ជ្រោកជ្រាក លាមកអាក្រក់ តិចតួច ។ កិលេសទាំងឡាយនោះ រមែងញាំញី ទន្រ្ទាន សង្កត់ គ្របសង្កត់ រួបរឹត ឈ្លបឈ្លីបុគ្គលនោះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) កិលេសមិនមានកម្លាំងទាំងឡាយ រមែងសង្កត់សង្កិនបុគ្គលនោះ យ៉ាងនេះខ្លះ ។ មួយទៀត កិលេសទាំងឡាយនោះ រមែងញាំញី ទន្រ្ទាន សង្កត់ គ្របសង្កត់ រួបរឹត ឈ្លបឈ្លីនូវបុគ្គលមិនមានកម្លាំង មានកម្លាំងថយ មានកម្លាំងតិច មានសេចក្ដីប្រឹងប្រែងតិច ថោកទាប ស្ដួចស្ដើង អន់ថយ ជ្រោកជ្រាក លាមកអាក្រក់ តិចតួច នូវបុគ្គលដែលមិនមានកម្លាំងគឺសទ្ធា កម្លាំងគឺព្យាយាម កម្លាំងគឺសតិ កម្លាំងគឺសមាធិ កម្លាំងគឺបញ្ញា កម្លាំងគឺហិរិ កម្លាំងគឺឱត្តប្បៈ ហេតុនោះ ( ទ្រង់ត្រាស់ថា ) កិលេសមិនមានកម្លាំងទាំងឡាយ រមែងសង្កត់សង្កិនបុគ្គលនោះ យ៉ាងនេះខ្លះ ។

[ ២២ ] អធិប្បាយពាក្យថា អន្តរាយទាំងឡាយ រមែងញាំញីបុគ្គលនោះ ត្រង់ពាក្យថា អន្តរាយទាំងឡាយ សំដៅយកអន្តរាយពីរយ៉ាង គឺអន្តរាយប្រាកដ ១ អន្តរាយកំបាំង ១ ។

អន្តរាយប្រាកដ តើដូចម្ដេច ។ សីហៈ ខ្លាធំ ខ្លាដំបង ខ្លាឃ្មុំ ទីទុយខ្លាត្រី ឆ្កែគោ ក្របី ដំរី ពស់ ខ្ទួយ ក្អែប ពួកមាណព កំពុងលួចក្ដី ធ្វើចោរកម្មហើយក្ដី

*មិនទាន់ធ្វើចោរកម្មហើយក្តី រោគក្នុងភ្នែក រោគក្នុងត្រចៀក រោគក្នុងច្រមុះ រោគក្នុងអណ្តាត រោគក្នុងកាយ រោគក្នុងក្បាល រោគត្រង់ស្លឹកត្រចៀក រោគក្នុងមាត់ រោគត្រង់ធ្មេញ រោគក្អក រោគហឺត រោគក្តៅច្រមុះ រោគគ្រុនក្តៅក្រហាយ រោគរីងរៃ រោគក្នុងពោះ រោគខ្យល់ចាប់ រោគធ្លាក់ឈាម រោគចុកសៀត ចុះរាកឃ្លង់ រោគពក ស្រែង ស្រកីអណ្តែង ឆ្កួតជ្រូក ដំនួចពិស រមាស់ កម រោគអេះក្លាយ ឃ្លង់ដែក មួលឈាម រោគប្រមាត់ ប្រមេះទឹកបាយ ឫសដូងដុះក្អកឈាម ឫសដូងបាត អាពាធកើតអំពីប្រមាត់ អាពាធកើតអំពីស្លេស្ម អាពាធកើតអំពីខ្យល់ អាពាធកើតអំពីប្រជុំនៃ ( ខ្យល់ប្រមាត់ស្លេស្ម ) អាពាធកើតអំពីការផ្លាស់ប្តូររដូវ អាពាធកើតអំពីការរក្សាឥរិយាបថមិនស្មើគ្នា អាពាធកើតអំពីសេចក្តីព្យាយាមខ្លាំង អាពាធកើតអំពីផលកម្ម ត្រជាក់ ក្តៅ ឃ្លាន ស្រេកឧច្ចារៈ បស្សាវៈ សម្ផស្ស របោម មូស ខ្យល់ កម្តៅថ្ងៃ និងពស់តូច ពស់ធំទាំងឡាយ ទាំងនេះ លោកហៅថា អន្តរាយប្រាកដ ដូច្នេះឯង ។*

*អន្តរាយកំបាំង តើដូចម្តេច ។ កាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត កាមច្ឆន្ទនីវរណៈ ព្យាបាទនីវរណៈ ថីនមិទ្ធនីវរណៈ ឧទ្ធច្ចកុក្កុច្ចនីវរណៈ វិចិកិច្ឆានីវរណៈ រាគៈ ទោសៈ មោហៈ សេចក្តីក្រោធ ការចងក្រោធទុក ការលុបលាងគុណអ្នកដទៃ ការលើកខ្លួន សេចក្តីឈ្នានីស សេចក្តីកំណាញ់ ពុតត្បុត ការអួតអាង ការរឹងត្អឹង ការប្រណាំងប្រជែង ការប្រកាន់ខ្លួន ការមើលងាយគេ សេចក្តីស្រវឹង សេចក្តីប្រហែសធ្វេស កិលេសទាំងអស់ ទុច្ចរិតទាំងអស់ សេចក្តីក្រវល់ក្រវាយទាំងអស់ សេចក្តីអន្ទះអន្ទែងទាំងអស់ សេចក្តីក្តៅក្រហាយ*

ទាំងអស់ ការតាក់តែងអកុសលទាំងអស់ ទាំងនេះ លោកហៅថា អន្តរាយកំបាំង ។

សំណួរត្រង់ពាក្យថា អន្តរាយ តើអន្តរាយ ដោយអត្ថថាដូចម្តេច ។ អន្តរាយ ព្រោះហេតុទន្ទ្រាន អន្តរាយព្រោះហេតុប្រព្រឹត្តទៅ ដើម្បីសេចក្តីវិនាស អន្តរាយព្រោះហេតុអាស្រ័យក្នុងសរីរៈនោះ ។

អន្តរាយព្រោះហេតុទន្ទ្រាន តើដូចម្តេច ។ អន្តរាយទាំងឡាយនោះ ញាំញីទន្ទ្រាន គ្របសង្កត់ រួបរឹត បំផ្លាញ ញីញក់នូវបុគ្គលនោះ ។ អន្តរាយ ព្រោះហេតុទន្ទ្រាន យ៉ាងនេះ ។

អន្តរាយ ព្រោះហេតុប្រព្រឹត្តទៅដើម្បីសេចក្តីវិនាស តើដូចម្តេច ។ អន្តរាយទាំងនោះ ប្រព្រឹត្តទៅដើម្បីសេចក្តីវិនាស ដើម្បីអន្តរាយដល់ធម៌ទាំងឡាយជាកុសល ។ ធម៌ទាំងឡាយជាកុសល តើដូចម្តេច ។ អន្តរាយទាំងឡាយនោះប្រព្រឹត្តទៅដើម្បីសេចក្តីវិនាស ដើម្បីអន្តរាយដល់ធម៌ទាំងឡាយ ជាកុសលទាំងនេះ គឺសេចក្តីប្រតិបត្តិដោយប្រពៃ សេចក្តីប្រតិបត្តិដ៏សមគួរ សេចក្តីប្រតិបត្តិមិនជាសត្រូវ សេចក្តីប្រតិបត្តិសមគួរដល់អត្ថ សេចក្តីប្រតិបត្តិតាមធម៌ សមគួរដល់ធម៌ ភាពនៃបុគ្គលអ្នកធ្វើឲ្យបរិបូណ៌ក្នុងសីលទាំងឡាយ ភាពនៃបុគ្គលអ្នកមានទ្វារគ្រប់គ្រងក្នុងឥន្ទ្រិយទាំងឡាយ ភាពនៃបុគ្គលអ្នកដឹងប្រមាណក្នុងភោជន ការប្រកបរឿយៗនូវធម៌ជាគ្រឿងភ្ញាក់រឭក សតិនិងសម្បជញ្ញៈ ការប្រកបរឿយៗក្នុងកិរិយាចម្រើនសតិប្បដ្ឋាន ៤ ការប្រកបរឿយៗក្នុងកិរិយាចម្រើនសម្មប្បធាន ៤ ការប្រកបរឿយៗក្នុងកិរិយាចម្រើនឥទ្ធិបាទ ៤ ការ

ប្រកបរឿយៗក្នុងកិរិយាចម្រើនឥន្ទ្រិយ ៥ ការប្រកបរឿយៗក្នុងកិរិយាចម្រើនពលៈ ៥ ការប្រកបរឿយៗក្នុងកិរិយាចម្រើនពោជ្ឈង្គ ៧ ការប្រកបរឿយៗក្នុងកិរិយាចម្រើនអដ្ឋង្គិកមគ្គដ៏ប្រសើរ ។ អន្តរាយ ព្រោះហេតុប្រព្រឹត្តទៅដើម្បីសេចក្តីវិនាសយ៉ាងនេះ ។

អន្តរាយ ព្រោះហេតុអាស្រ័យក្នុងសរីរៈនោះ តើដូចម្តេច ។ ធម៌ទាំងឡាយដ៏លាមកជាអកុសលនោះ អាស្រ័យនៅក្នុងអត្តភាព កើតឡើងក្នុងសរីរៈនោះ ។ ពួកសត្វអាស្រ័យនៅក្នុងរន្ធ ដេកនៅក្នុងរន្ធ ពួកសត្វអាស្រ័យនៅក្នុងទឹក ដេកនៅក្នុងទឹក ពួកសត្វអាស្រ័យនៅក្នុងព្រៃ ដេកនៅក្នុងព្រៃ ពួកសត្វអាស្រ័យនៅលើដើមឈើ ដេកនៅលើដើមឈើ យ៉ាងណាមិញ ធម៌ទាំងឡាយដ៏លាមក ជាអកុសលទាំុះ អាស្រ័យនៅក្នុងអត្តភាពកើតឡើង ក្នុងសរីរៈនោះ យ៉ាងនោះដែរ ព្រោះហេតុនោះ អន្តរាយ ព្រោះអាស្រ័យក្នុងសរីរៈនោះ យ៉ាងនេះខ្លះ ។

សមដូចពាក្យនេះ ដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅជាមួយអន្តេវាសិក អ្នកនៅជាមួយអាចារ្យ រមែងនៅជាទុក្ខ មិនសប្បាយទេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅជាមួយអន្តេវាសិក អ្នកនៅជាមួយអាចារ្យ រមែងនៅជាទុក្ខ មិនសប្បាយ តើដោយប្រការដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយដ៏លាមក ជាអកុសលណា ជាសេចក្តីត្រិះរិះដោយអំណាចនៃកិរិយារឭកឃើញ ជាទីតាំងនៃសំយោជនៈ កើតឡើងដល់ភិក្ខុក្នុងសាសនានេះ ព្រោះឃើញរូបដោយចក្ខុ ធម៌ទាំងឡាយដ៏លាមក ជា

អកុសលនោះ រមែងនៅ រមែងជាប់តាមក្នុងនៃភិក្ខុនោះ ព្រោះហេតុនោះ ភិក្ខុនោះ តថាគតហៅថា អ្នកនៅជាមួយអន្តេវាសិក ធម៌ទាំងឡាយដ៏លាមក ជាអកុសលនោះ រមែងត្រួតត្រាភិក្ខុនោះ ព្រោះហេតុនោះ ភិក្ខុនោះ តថាគតហៅថា អ្នកនៅជាមួយអាចារ្យ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ធម៌ទាំងឡាយដ៏លាមក ជាអកុសលណា ជាសេចក្តីត្រិះរិះដោយកិរិយារឭកឃើញ ជាទីតាំងនៃសំយោជនៈ កើតឡើងដល់ភិក្ខុ ព្រោះស្តាប់សំឡេងដោយត្រចៀក ហិតក្លិនដោយច្រមុះ លិទ្ធរសដោយអណ្តាត ប៉ះពាល់ផ្សព្វដោយកាយ ដឹងធម្មារណ៍ដោយចិត្ត ធម៌ទាំងឡាយដ៏លាមក ជាអកុសលនោះ រមែងនៅ រមែងជាប់តាមក្នុងនៃភិក្ខុនោះ ព្រោះហេតុនោះ ភិក្ខុនោះ តថាគតហៅថា អ្នកនៅជាមួយអន្តេវាសិក ធម៌ទាំងឡាយដ៏លាមក ជាអកុសលនោះ រមែងត្រួតត្រាភិក្ខុនោះ ព្រោះហេតុនោះ ភិក្ខុនោះ តថាគតហៅថា អ្នកនៅជាមួយអាចារ្យ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅជាមួយអន្តេវាសិក អ្នកនៅជាមួយអាចារ្យ រមែងនៅជាទុក្ខ មិនសប្បាយដោយប្រការយ៉ាងនេះឯង ។ អន្តរាយ ព្រោះហេតុអាស្រ័យក្នុងសរីរៈនោះ យ៉ាងនេះខ្ញុំ ។

មួយទៀត ពាក្យនេះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ ៣ នេះ ជាមន្ទិលខាងក្នុង ជាអមិត្តខាងក្នុង ជាសត្រូវខាងក្នុង ជាពេជ្ឈឃាតខាងក្នុង ជាបច្ចាមិត្តខាងក្នុង ។ ធម៌ទាំងឡាយ ៣ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ លោភៈជាមន្ទិលខាងក្នុង ជាអមិត្តខាងក្នុង ជាសត្រូវខាងក្នុង ជាពេជ្ឈឃាតខាងក្នុង ជាបច្ចាមិត្តខាងក្នុង ម្នាលភិក្ខុទាំងឡាយ

ទោសៈ ជាមន្ទិលខាងក្នុង ជាអមិត្តខាងក្នុង ជាសត្រូវខាងក្នុង ជាពេជ្ឈឃាតខាងក្នុង ជាបច្ចាមិត្តខាងក្នុង ម្នាលភិក្ខុទាំងឡាយ មោហៈ ជាមន្ទិលខាងក្នុង ជាអមិត្តខាងក្នុង ជាសត្រូវខាងក្នុង ជាពេជ្ឈឃាតខាងក្នុង ជាបច្ចាមិត្តខាងក្នុង ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៣ នេះឯង ជាមន្ទិលខាងក្នុង ជាអមិត្តខាងក្នុង ជាសត្រូវខាងក្នុង ជាពេជ្ឈឃាតខាងក្នុង ជាបច្ចាមិត្តខាងក្នុង ។

លោភៈជាកិលេស ញុំាងសេចក្ដីវិនាសឲ្យកើត លោភៈជាកិលេស ញុំាងចិត្តឲ្យកម្រើក ភ័យកើតហើយខាងក្នុង ជនរមែងមិនយល់ច្បាស់នូវភ័យនោះទេ បុគ្គលអ្នកលោភរមែងមិនដឹងអត្ថ បុគ្គលអ្នកលោភរមែងមិនឃើញធម៌ លោភៈគ្របសង្កត់ជនណា សេចក្ដីងងឹតឈឹងសូន្យ ( នៃជននោះ ) ក៏រមែងមានក្នុងកាលនោះ ទោសៈ ជាកិលេសញុំាងសេចក្ដីវិនាសឲ្យកើត ទោសៈជាកិលេសញុំាងចិត្តឲ្យកម្រើក ភ័យកើតហើយខាងក្នុង ជនរមែងមិនយល់ច្បាស់នូវភ័យនោះទេ បុគ្គលអ្នកក្រោធ រមែងមិនដឹងអត្ថ បុគ្គលអ្នកក្រោធ រមែងមិនឃើញធម៌ សេចក្ដីក្រោធគ្របសង្កត់ជនណា សេចក្ដីងងឹតឈឹងសូន្យ ( នៃជននោះ ) ក៏រមែងមានក្នុងកាលនោះ ។ មោហៈជាកិលេសញុំាងសេចក្ដីវិនាសឲ្យកើត មោហៈជាកិលេសញុំាងចិត្តឲ្យកម្រើក ភ័យកើតហើយខាងក្នុង ជនរមែងមិនយល់ច្បាស់នូវភ័យនោះទេ បុគ្គលអ្នកវង្វេង រមែងមិនដឹងអត្ថ បុគ្គល

អ្នកវង្វេង រមែងមិនឃើញធម៌ មោហៈគ្របសង្កត់ជនណា
សេចក្ដីឈឹងសូន្យ (នៃជននោះ) ក៏រមែងមានក្នុងកាលនោះ ។

អន្តរាយ ព្រោះហេតុអាស្រ័យក្នុងសរីរៈនោះ យ៉ាងនេះខ្វះ ។

ន័យមួយទៀត ពាក្យនេះ ព្រះមានព្រះភាគត្រាស់ថា បពិត្រមហារាជ បុរិសធម៌ ( ធម៌របស់បុរស ) ៣ កាលកើតឡើង រមែងកើតឡើងដើម្បីមិនជាប្រយោជន៍ ដើម្បីទុក្ខ ដើម្បីការនៅមិនសប្បាយ ។ បុរិសធម៌ ៣ តើដូចម្ដេច ។ បពិត្រមហារាជ លោភៈជាបុរិសធម៌ កាលកើតឡើង រមែងកើតឡើង ដើម្បីមិនជាប្រយោជន៍ ដើម្បីទុក្ខ ដើម្បីការនៅមិនសប្បាយ បពិត្រមហារាជ ទោសៈ ជាបុរិសធម៌ កាលកើតឡើង រមែងកើតឡើង ដើម្បីមិនជាប្រយោជន៍ ដើម្បីទុក្ខ ដើម្បីការនៅមិនសប្បាយ បពិត្រមហារាជ មោហៈជាបុរិសធម៌ កាលកើតឡើង រមែងកើតឡើង ដើម្បីមិនជាប្រយោជន៍ ដើម្បីទុក្ខ ដើម្បីការនៅមិនសប្បាយ ។ បពិត្រមហារាជ បុរិសធម៌ ៣ នេះឯង កាលកើតឡើង រមែងកើតឡើងដើម្បីមិនជាប្រយោជន៍ ដើម្បីជាទុក្ខ ដើម្បីការនៅមិនសប្បាយ ។

លោភៈ ទោសៈ និងមោហៈ កើតអំពីខ្លួន រមែងបៀតបៀន
នូវបុរស អ្នកមានចិត្តអាក្រក់ ដូចជាឈើមានសម្បកជាខ្លឹម
( ឫស្សី ) ដែលវិនាសដោយសារផ្លែរបស់ខ្លួន ។

អន្តរាយ ព្រោះហេតុអាស្រ័យក្នុងសរីរៈនោះ យ៉ាងនេះខ្វះ ។ មួយវិញទៀត ពាក្យនោះ ព្រះមានព្រះភាគត្រាស់ថា

រាគៈនិងទោសៈ មានអត្តភាពនេះជាហេតុ សេចក្តីមិនត្រេកអរ
និងសេចក្តីត្រេកអរ និងការព្រឺរោម កើតអំពីអត្តភាពនេះ
មនោវិតក្កៈទាំងឡាយតាំងឡើងហើយអំពីអត្តភាពនេះ លែង
ទៅ ( នូវចិត្ត ) ដូចជាកុមារចងបន្ទាយនូវក្អែក ។

អន្តរាយ ព្រោះហេតុអាស្រ័យក្នុងសរីរៈនោះ យ៉ាងនេះខ្លះ ។

ពាក្យថា អន្តរាយទាំងឡាយ រមែងញាំញីបុគ្គលនោះ បានសេចក្តីថា អន្តរាយទាំងឡាយនោះ រមែងទន្រ្ទាន ជិះជាន់ គ្របសង្កត់ រួបរឹត បំផ្លាញ ញីញក់នូវបុគ្គលនោះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) អន្តរាយទាំងឡាយរមែងញាំញីបុគ្គលនោះ ។

[ ២៣ ] ពាក្យថា ទុក្ខ រមែងជាប់តាមបុគ្គលនោះ ព្រោះអន្តរាយនោះ អធិប្បាយថា ទុក្ខ រមែងជាប់តាម ទៅតាម ប្រព្រឹត្តតាមនូវបុគ្គលនោះ ព្រោះសេចក្តីអន្តរាយនោះៗ គឺជាតិទុក្ខរមែងជាប់តាម ទៅតាម ប្រព្រឹត្តតាម ជរាទុក្ខរមែងជាប់តាម ទៅតាម ប្រព្រឹត្តតាម ព្យាធិទុក្ខរមែងជាប់តាម ទៅតាម ប្រព្រឹត្តតាម មរណទុក្ខរមែងជាប់តាម ទៅតាម ប្រព្រឹត្តតាម សោកបរិទេវទុក្ខទោមនស្សុបាយាសទុក្ខរមែងជាប់តាម ទៅតាម ប្រព្រឹតតាម ទុក្ខក្នុងនរក ទុក្ខក្នុងកំណើតតិរច្ឆាន ទុក្ខក្នុងបិត្តិវិស័យ រមែងជាប់តាម ទៅតាម ប្រព្រឹត្តតាម ទុក្ខក្នុងពួកមនុស្ស ទុក្ខមានកិរិយាចុះកាន់គភ៌ជាមូល ទុក្ខមានកិរិយាតាំងនៅក្នុងគភ៌ជាមូល ទុក្ខមានកិរិយាចេញចាកគភ៌ជាមូល ទុក្ខប្រកបដោយគ្រឿងចង ( ថែទាំ ) របស់សត្វដែលកើតហើយ ទុក្ខព្រោះអាស្រ័យអ្នកដទៃ របស់

សត្វដែលកើតហើយ ទុក្ខព្រោះការព្យាយាមរបស់ខ្លួន ទុក្ខព្រោះការព្យាយាមរបស់អ្នកដទៃ រមែងជាប់តាម ទៅតាម ប្រព្រឹត្តតាម ទុក្ខទុក្ខរមែងជាប់តាមទៅតាម ប្រព្រឹត្តតាម សង្ខារទុក្ខ វិបរិណាមទុក្ខ រោគក្នុងភ្នែក រោគក្នុងត្រចៀក រោគក្នុងច្រមុះ រោគក្នុងអណ្ដាត រោគក្នុងកាយ រោគក្នុងក្បាល រោគត្រង់ស្លឹកត្រចៀក រោគក្នុងមាត់ រោគត្រង់ធ្មេញ រោគក្អក រោគហឺត រោគក្រៅច្រមុះ រោគគ្រុនក្ដៅក្រហាយ រោគរីងរៃ រោគក្នុងពោះ ខ្យល់ចាប់ រោគធ្លាក់ឈាម ចុកសៀត ចុះរាក ឃ្លង់ រោគពក ស្រែង ស្រកីអណ្ដែង ក្ដួតជ្រូក ដំនួចពិសរមាស់ កម រោគអេះក្លាយ ឃ្លង់ដែក មួលឈាម រោគប្រមាត់ ប្រមេះទឹកបាយ ឫសដូងដុះ ក្អកឈាម ឫសដូងបាត អាពាធកើតអំពីប្រមាត់ អាពាធអំពីស្លេស្ម អាពាធកើតអំពីខ្យល់ អាពាធកើតអំពីប្រជុំ ( នៃខ្យល់ប្រមាត់ស្លេស្ម ) អាពាធកើតអំពីការផ្លាស់ប្ដូររដូវ អាពាធកើតអំពីរក្សាឥរិយាបថ មិនស្មើគ្នា អាពាធកើតអំពីសេចក្ដីព្យាយាមខ្លាំង អាពាធកើតអំពីផលកម្ម ត្រជាក់ក្ដៅ ឃ្លាន ស្រេក ឧច្ចារៈ បស្សាវៈ សម្ផស្សនៃរបោម មូស ខ្យល់ កម្ដៅថ្ងៃនិងពស់តូចពស់ធំ ទុក្ខព្រោះកិរិយាស្លាប់នៃមាតា ទុក្ខព្រោះកិរិយាស្លាប់នៃបិតា ទុក្ខព្រោះកិរិយាស្លាប់នៃបងប្អូនប្រុស ទុក្ខព្រោះកិរិយាស្លាប់នៃបងប្អូនស្រី ទុក្ខព្រោះកិរិយាស្លាប់កូនប្រុស ទុក្ខព្រោះកិរិយាស្លាប់កូនស្រី ទុក្ខព្រោះវិនាសញាតិ ទុក្ខព្រោះវិនាសភោគសម្បត្តិ ទុក្ខព្រោះវិនាសគឺរោគ ទុក្ខព្រោះវិនាសសីល ទុក្ខព្រោះវិនាសគឺទិដ្ឋិ រមែងជាប់តាម ទៅតាម ប្រព្រឹត្តតាម ( នូវបុគ្គលនោះ ) ហេតុនោះ ( ទ្រង់ត្រាស់ថា ) ទុក្ខរមែងជាប់តាមបុគ្គលនោះ ព្រោះ

អន្តរាយនោះ ។

[ ២៤ ] ពាក្យថា ដូចជាទឹកកាលជ្រាបចូលកាន់នាវាដែលបែកធ្លាយ សេចក្តីថា ទឹកប្រព្រឹត្តតាមទូកដែលបែកធ្លាយ គឺទឹករមែងជាប់តាម ទៅតាម ប្រព្រឹត្តតាម ត្រង់ទីដែលធ្លាយនោះៗ ទឹករមែងជាប់តាម ទៅតាម ប្រព្រឹត្តតាម ត្រង់ទីខាងមុខខ្លះ ទឹករមែងជាប់តាម ទៅតាម ប្រព្រឹត្តតាម ត្រង់ទីខាងក្រោយខ្លះ ត្រង់ទីខាងក្រោមខ្លះ ត្រង់ទីខាងខ្លះ យ៉ាងណាមិញ សេចក្តីទុក្ខរមែងជាប់តាម ទៅតាម ប្រព្រឹត្តតាមនូវបុគ្គលនោះ ព្រោះសេចក្តីអន្តរាយនោះៗ ជាតិទុក្ខ រមែងជាប់តាម ទៅតាម ប្រព្រឹត្តតាម ។បេ។ ទុក្ខព្រោះកិរិយាវិនាស គឺទិដ្ឋិ រមែងជាប់តាម ទៅតាម ប្រព្រឹត្តតាម ក៏យ៉ាងនោះដែរ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ដូចជាទឹកកាលជ្រាបចូលកាន់នាវា ដែលបែកធ្លាយ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគទ្រង់ត្រាស់ថា

កិលេសមិនមានកម្លាំងទាំងឡាយ រមែងសង្កត់សង្កិនបុគ្គល
នោះ អន្តរាយទាំងឡាយ រមែងញាំញីបុគ្គលនោះ ទុក្ខរមែង
ជាប់តាមបុគ្គលនោះ ព្រោះអន្តរាយនោះ ដូចជាទឹកកាលជ្រាប
ចូលកាន់នាវា ដែលបែកធ្លាយ ។

[ ២៥ ] ព្រោះហេតុនោះ ជនអ្នកមានស្មារតីគ្រប់កាល គប្បីវៀរស្រឡះនូវកាមទាំងឡាយ ជនលុះលះបង់កាមទាំងនោះ ទើបឆ្លងឱឃៈបាន ដូចបុគ្គលអ្នកដល់ត្រើយ ព្រោះស្តារនាវា ។

[ ២៦ ] អធិប្បាយពាក្យថា ព្រោះហេតុនោះ ជនអ្នកមានស្មារតីគ្រប់

កាលត្រង់ពាក្យថា ព្រោះហេតុនោះ គឺព្រោះហេតុដូច្នោះ ព្រោះដំណើរនោះ ព្រោះហេតុនោះ ព្រោះបច្ច័យនោះ ព្រោះអំពើនោះជាហេតុ ជនកាលឃើញច្បាស់នូវទោសទុំះ ក្នុងកាមទាំងឡាយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ព្រោះហេតុនោះ ។ ពាក្យថា ជនគឺ សត្វ នរៈ មាណព បុរស បុគ្គល សត្វមានជីវិត សត្វមានជាតិ សត្វមានជរា សត្វទៅដោយឥន្ទ្រិយ សត្វកើតអំពីមនុស្ស ។ ពាក្យថា គ្រប់កាល គឺសព្វកាល រាល់វេលា អស់កាលទាំងពួង អស់កាលជានិច្ច អស់កាលដ៏ទៀងទាត់ ឋិតថេរ រឿយៗ ប៉ុកប៉ុន ញឹកញាប់ មានសភាពដូចជារលកទឹក មិនដាច់ ជាប់ត ប្រព្រឹត្តទៅជាមួយគ្នា ប៉ះជាប់គ្នា កាលមុនភត្ត កាលក្រោយភត្ត យាមខាងដើម យាមកណ្តាល យាមទីបំផុត ក្នុងកាលរនោច ខ្នើត វស្សានរដូវ ហេមន្តរដូវ គិម្ហរដូវ គំនរវ័យខាងដើម គំនរវ័យកណ្តាល គំនរវ័យទីបំផុត ។ ពាក្យថា មានសតិ គឺមានសតិដោយហេតុ ៤ យ៉ាង គឺមានសតិ កាលចម្រើនកាយានុបស្សនាសតិប្បដ្ឋានក្នុងកាយ ក្នុងវេទនាទាំងឡាយ ក្នុងចិត្ត មានសតិ កាលចម្រើនធម្មានុបស្សនាសតិប្បដ្ឋានក្នុងធម៌ទាំងឡាយ ។ មានសតិ ដោយហេតុ ៤ យ៉ាងដទៃទៀត ។បេ។ បុគ្គលនោះ លោកហៅថា អ្នកមានសតិ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ព្រោះហេតុនោះ ជនអ្នកមានស្មារតីគ្រប់កាល ។

[ ២៧ ] អធិប្បាយពាក្យថា គប្បីវៀរស្រឡះនូវកាមទាំងឡាយ ត្រង់ពាក្យថា កាម បើតាមឧទ្ទាន បានដល់កាមពីរយ៉ាង គឺវត្ថុកាម ១ កិលេសកាម ១ ។បេ។ ទាំងនេះ ហៅថា វត្ថុកាម ។បេ។ ទាំងនេះ ហៅថា កិលេស

កាម ។ ពាក្យថា គប្បីវៀរស្រឡះនូវកាមទាំងឡាយ គឺគប្បីវៀរនូវកាមដោយហេតុ ២ យ៉ាង គឺកិរិយាសង្កត់សង្កិន ១ កិរិយាផ្តាច់បង់ ១ ។ បុគ្គលវៀរកាមដោយកិរិយាសង្កត់សង្កិន តើដូចម្តេច ។ បុគ្គលកាលឃើញថា កាមទាំងឡាយ មានឧបមាដូចរាងឆ្អឹង ដោយសេចក្តីថា មានសេចក្តីត្រេកអរតិច ឈ្មោះថា វៀរកាមដោយកិរិយាសង្កត់សង្កិន កាលឃើញថា កាមទាំងឡាយមានឧបមាដោយដុំសាច់ ដោយសេចក្តីថាជារបស់សាធារណ៍ ដល់សត្វមានប្រមាណច្រើន ឈ្មោះថា វៀរកាមដោយកិរិយាសង្កត់សង្កិន កាលឃើញថា កាមទាំងឡាយ មានឧបមាដូចគប់ភ្លើងស្មៅ ដោយសេចក្តីថា ដុតកម្តៅរឿយៗ ឈ្មោះថា វៀរកាមដោយកិរិយាសង្កត់សង្កិន ។បេ។ កំពុងចម្រើននេវសញ្ញានាសញ្ញាយតនសមាបត្តិក្តី ឈ្មោះថា វៀរកាមដោយកិរិយាសង្កត់សង្កិន ។ បុគ្គលវៀរកាមដោយកិរិយាសង្កត់សង្កិន ដោយប្រការយ៉ាងនេះ ។បេ។ បុគ្គលវៀរកាមដោយកិរិយាផ្តាច់បង់ ដោយប្រការយ៉ាងនេះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) គប្បីវៀរស្រឡះនូវកាមទាំងឡាយ ។

[ ២៨ ] ពាក្យថា កាមទាំងនោះ ក្នុងបទថា ជនលុះលះបង់កាមទាំងនោះ ទើបឆ្លងឱឃៈបាន គឺជនកំណត់ដឹងនូវវត្ថុកាមទាំងឡាយ លះបង់ កម្ចាត់បង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាននូវកិលេសកាមទាំងឡាយ លះបង់ កម្ចាត់បង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាន នូវកាមច្ឆន្ទនីវរណៈ លះបង់ កម្ចាត់បង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាននូវព្យាបាទនីវរណៈ ថីនមិទ្ធនីវរណៈ ឧទ្ធច្ចកុក្កុច្ចនីវរណៈ វិចិកិច្ឆានីវរណៈ គប្បីឆ្លង គប្បី

ឆ្លងឡើង គប្បីឆ្លងកាត់ ឈានកន្លង ប្រព្រឹត្តកន្លងនូវឱឃៈគឺកាម ឱឃៈគឺភព ឱឃៈគឺទិដ្ឋិ ឱឃៈគឺអវិជ្ជា ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជនលុះលះបង់កាមទាំងនោះ ទើបឆ្លងឱឃៈបាន ។

[ ២៩ ] ពាក្យថា ដូចបុគ្គលអ្នកដល់ត្រើយ ព្រោះស្តារនាវា អធិប្បាយថា បុគ្គលបាច ស្តារ ជះបោលនូវទឹកក្នុងនាវា មានគ្រឿងផុកដ៏ធ្ងន់ ហើយដល់ត្រើយឆាប់រហ័ស មិនលំបាក ដោយសារនាវាស្រាល យ៉ាងណាមិញ បុគ្គលកំណត់ដឹងនូវវត្ថុកាមទាំងឡាយ លះបង់ កម្ចាត់បង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាននូវកិលេសកាមទាំងឡាយ លះបង់ កម្ចាត់បង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាននូវកាមច្ឆន្ទនីវរណៈ ព្យាបាទនីវរណៈ ថីនមិទ្ធនីវរណៈ ឧទ្ធច្ចកុក្កុច្ចនីវរណៈ វិចិកិច្ឆានីវរណៈ ហើយដល់ត្រើយឆាប់រហ័សដោយមិនលំបាក ក៏យ៉ាងនោះដែរ ។ អមតនិព្វាន ការរម្ងាប់សង្ខារទាំងពួងកិរិយាលះបង់កិលេសទាំងពួង ការអស់តណ្ហា ការប្រាសចាកតម្រេក ការរលត់ ( នៃកិលេស ) ការចេញចាកតណ្ហា លោកពោលថា ត្រើយ បុគ្គលគប្បីដល់ត្រើយ បានត្រើយ ប៉ះពាល់ត្រើយ ធ្វើឲ្យជាក់ច្បាស់នូវត្រើយនោះ ។ ពាក្យថា បុគ្គលអ្នកដល់ត្រើយ គឺបុគ្គលណា ប្រាថ្នាដើម្បីទៅកាន់ត្រើយ បុគ្គលនោះ ឈ្មោះថា អ្នកទៅកាន់ត្រើយ បុគ្គលណា កំពុងទៅកាន់ត្រើយ បុគ្គលនោះ ឈ្មោះថា អ្នកទៅកាន់ត្រើយ បុគ្គលណា ដល់ហើយនូវត្រើយ បុគ្គលនោះ ឈ្មោះថា អ្នកទៅកាន់ត្រើយ ។ សមដូចពាក្យនេះ ដែលព្រះមានព្រះភាគទ្រង់ត្រាស់ថា ព្រាហ្មណ៍ឆ្លងដល់ត្រើយ ឋិតនៅលើគោក ។ ម្នាល

ភិក្ខុទាំងឡាយ ពាក្យថា ព្រាហ្មណ៍ នេះជាឈ្មោះនៃព្រះអរហន្ត ព្រះអរហន្ត នោះ ឈ្មោះថា អ្នកដល់ត្រើយ ដោយការត្រាស់ដឹង អ្នកដល់ត្រើយដោយការកំណត់ដឹង អ្នកដល់ត្រើយដោយការលះបង់ អ្នកដល់ត្រើយដោយការចម្រើន អ្នកដល់ត្រើយដោយការធ្វើឲ្យជាក់ច្បាស់ អ្នកដល់ត្រើយដោយសមាបត្តិ អ្នកដល់ត្រើយដោយការត្រាស់ដឹងធម៌ទាំងពួង អ្នកដល់ត្រើយដោយការកំណត់ដឹងទុក្ខទាំងពួង អ្នកដល់ត្រើយដោយការលះបង់កិលេសទាំងពួង អ្នកដល់ត្រើយដោយការចម្រើនអរិយមគ្គទាំង ៤ អ្នកដល់ត្រើយ ដោយការធ្វើឲ្យជាក់ច្បាស់នូវនិរោធសច្ចៈ អ្នកដល់ត្រើយដោយការចូលទៅកាន់សមាបត្តិទាំងពួង ព្រះអរហន្តនោះដល់នូវភាពដ៏ស្ទាត់ ដល់នូវឧត្តមភាពក្នុងសីលដ៏ប្រសើរ ដល់នូវភាពដ៏ស្ទាត់ ដល់នូវឧត្តមភាពក្នុងសមាធិដ៏ប្រសើរ ដល់នូវភាពដ៏ស្ទាត់ ដល់នូវឧត្តមភាពក្នុងបញ្ញាដ៏ប្រសើរ ដល់នូវភាពដ៏ស្ទាត់ ដល់នូវឧត្តមភាពដោយវិមុត្តិដ៏ប្រសើរ ព្រះអរហន្តនោះ ឈ្មោះថា ទៅកាន់ត្រើយ ដល់ត្រើយ ទៅកាន់ទីបំផុត ( នៃសង្ខារ ) ដល់ទីបំផុត ទៅកាន់ទីខាងចុង ដល់ទីខាងចុង ទៅកាន់ទីបំផុតជុំវិញ ដល់ទីបំផុតជុំវិញ ទៅកាន់ទីអវសាន ដល់ទីអវសាន ទៅកាន់ទីពំនាក់ ដល់ទីពំនាក់ ទៅកាន់ទីពឹងពួន ដល់ទីពឹងពួន ទៅកាន់ទីជាទីពឹង ដល់ទីជាទីពឹង ទៅកាន់ទីមិនមានភ័យ ដល់ទីមិនមានភ័យ ទៅកាន់ទីមិនច្យុត ដល់ទីមិនច្យុត ទៅកាន់ទីមិនស្លាប់ ដល់ទីមិនស្លាប់ ទៅកាន់និព្វាន ដល់និព្វាន ព្រះអរហន្តនោះ មានធម៌ជាគ្រឿងអប់រំនៅស្រេចហើយ មានកិរិយាប្រព្រឹត្តប្រព្រឹត្តហើយ មានផ្លូវឆ្ងាយ គឺសង្សារកន្លងហើយ មានទិស គឺព្រះនិព្វាន ដល់

ហើយ មានទីបំផុតនៃព្រះនិព្វានដល់ហើយ មានព្រហ្មចរិយធម៌រក្សាហើយ ដល់ហើយនូវការឃើញដ៏ឧត្តម មានមគ្គចម្រើនហើយ មានកិលេសលះបង់ហើយ មានអរហត្តផលជាធម្មជាតិមិនកម្រើកត្រាស់ដឹងហើយ មាននិរោធ គឺព្រះនិព្វានធ្វើឲ្យជាក់ច្បាស់ហើយ ទុក្ខព្រះអរហន្តនោះកំណត់ដឹងហើយ សមុទយៈលះបង់ហើយ មគ្គចម្រើនហើយ និរោធធម៌បានធ្វើឲ្យជាក់ច្បាស់ហើយ ត្រាស់ដឹងហើយនូវហេតុដែលគួរត្រាស់ដឹង កំណត់ដឹងហើយនូវហេតុដែលគួរកំណត់ដឹង លះបង់ហើយនូវហេតុដែលគួរលះបង់ ចម្រើនហើយនូវហេតុដែលគួរចម្រើន ធ្វើឲ្យជាក់ច្បាស់ហើយនូវហេតុដែលគួរធ្វើឲ្យជាក់ច្បាស់ ។ ព្រះអរហន្តនោះ មានសសរគោល គឺអវិជ្ជាដកចេញហើយ មានស្នាមភ្លោះ គឺជាតិសង្សារលុបអស់ហើយ មានសសរខឿន គឺតណ្ហាដកចេញហើយ មិនមានគន្លឹះទ្វារ គឺឱរម្ភាគិយសំយោជន៍ ជាអរិយៈមិនមានកិលេស មានទង់គឺមានះទម្លាក់ហើយ មានគ្រឿងធ្ងន់ទម្លាក់ចេញហើយ ជាអ្នកប្រាសចាកកិលេស លះបង់អង្គ ៥ គឺនីវរណៈហើយ ប្រកបព្រមហើយដោយអង្គ ៦ មានការរក្សាដោយធម៌តែមួយគឺ សតិ មានធម៌ជាគ្រឿងពឹងផ្អែក ៤ ប្រការ មានទិដ្ឋិសច្ចដោយឡែកលះបង់ហើយ មានការស្វែងរកទាំងពួងលះបង់ហើយដោយប្រពៃ មានសេចក្តីត្រិះរិះមិនមានល្អក់ មានកាយសង្ខារស្ងប់រម្ងាប់ហើយ មានចិត្តផុតស្រឡះហើយដោយប្រពៃ មានបញ្ញាផុតស្រឡះហើយដោយប្រពៃ ជាបុគ្គលបរិបូណ៌ មានព្រហ្មចរិយធម៌ប្រព្រឹត្តចប់ស្រេចហើយ ជាឧត្តមបុរស ជាបរមបុរស ដល់នូវការដល់ដ៏ប្រសើរ ព្រះអរហន្តនោះ មិនសន្សំ មិនកម្ចាត់បង់

លោកនឹងធឹងព្រោះកម្ចាត់បង់ មិនលះបង់ មិនប្រកាន់ លោកនឹងធឹងព្រោះលះបង់ មិនចាក់ស្រែះ មិនតម្កើង ( ដោយតណ្ហានិងមានះ ) លោកនឹងធឹងព្រោះមិនចាក់ស្រែះ មិនរំលត់ មិនបង្កាត់ ( នូវភ្លើងគឺកិលេស ) លោកនឹងធឹងព្រោះរំលត់ លោកខ្ជាប់ខ្ជួនព្រោះប្រកបដោយសីលក្ខន្ធជាអសេក្ខៈ លោកខ្ជាប់ខ្ជួនព្រោះប្រកបដោយសមាធិក្ខន្ធជាអសេក្ខៈ ដោយបញ្ញាខន្ធជាអសេក្ខៈ ដោយវិមុត្តិក្ខន្ធជាអសេក្ខៈ ដោយវិមុត្តិញាណទស្សនក្ខន្ធជាអសេក្ខៈ លោកខ្ជាប់ខ្ជួនព្រោះយល់ច្បាស់នូវសច្ចធម៌ លោកខ្ជាប់ខ្ជួនព្រោះកន្លងផុត យ៉ាងនេះ លោកខ្ជាប់ខ្ជួនព្រោះរំលត់ភ្លើងគឺកិលេស លោកខ្ជាប់ខ្ជួនព្រោះមិនមានដំណើរតទៅទៀត លោកខ្ជាប់ខ្ជួនព្រោះចាប់បាននូវកំពូល ( ជ័យជម្នះ ) លោកខ្ជាប់ខ្ជួនព្រោះកិរិយាសេពនូវធម៌ជាគ្រឿងផុតស្រឡះ លោកខ្ជាប់ខ្ជួនព្រោះមេត្តាជាគុណជាតិដ៏បរិសុទ្ធ លោកខ្ជាប់ខ្ជួនព្រោះករុណា មុទិតា ឧបេក្ខា ជាគុណជាតិដ៏បរិសុទ្ធ លោកខ្ជាប់ខ្ជួនព្រោះដល់ទីបំផុតនៃសេចក្តីបរិសុទ្ធ លោកខ្ជាប់ខ្ជួនព្រោះសេចក្តីបរិសុទ្ធ មិនគួរដល់ការងារ ( នៃតណ្ហាទិដ្ឋិមានះ ) លោកខ្ជាប់ខ្ជួនព្រោះផុតស្រឡះ លោកខ្ជាប់ខ្ជួនព្រោះជាបុគ្គលសន្តោស លោកខ្ជាប់ខ្ជួនក្នុងទីបំផុតនៃខន្ធ លោកខ្ជាប់ខ្ជួនក្នុងទីបំផុតនៃធាតុ លោកខ្ជាប់ខ្ជួនក្នុងទីបំផុតនៃអាយតនៈ លោកខ្ជាប់ខ្ជួនក្នុងទីបំផុតនៃគតិ លោកខ្ជាប់ខ្ជួនក្នុងទីបំផុតនៃឧបបត្តិភព លោកខ្ជាប់ខ្ជួនក្នុងទីបំផុតនៃបដិសន្ធិ លោកខ្ជាប់ខ្ជួនក្នុងទីបំផុតនៃភព លោកខ្ជាប់ខ្ជួនក្នុងទីបំផុតនៃសង្សារ លោកខ្ជាប់ខ្ជួនក្នុងទីបំផុតនៃវដ្តៈ លោកខ្ជាប់ខ្ជួនក្នុងភពជាទីបំផុត លោកខ្ជាប់ខ្ជួនក្នុងសរីរៈជាទីប្រជុំក្នុងទីបំផុត ទ្រទ្រង់រាង

កាយជាទីបំផុតជាព្រះអរហន្ត ។

កពនេះជាទីបំផុតរបស់ព្រះអរហន្តនោះ អត្តភាពនេះជាខាង ក្រោយបង្អស់ ការអន្ទោលទៅដោយជាតិនិងមរណៈ កពថ្មី របស់ព្រះអរហន្តនោះ មិនមានទេ ។

ហេតុនោះ ( ទ្រង់ត្រាស់ថា ) ដូចជាបុគ្គលអ្នកដល់ត្រើយ ព្រោះស្ពានោវា៉។

ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ព្រោះហេតុនោះ ជនអ្នកមានស្មារតីគ្រប់កាល គប្បីវៀរ ស្រឡះនូវកាមទាំងឡាយ ជនលុះលះបង់នូវកាមទាំងនោះ ទើបឆ្លងឱឃៈបាន ដូចបុគ្គលអ្នកដល់នូវត្រើយ ព្រោះស្ពារ នាវា ។

**ចប់ កាមសុត្តនិទ្ទេស ទី ១ ។**

# សទ្ធម្មប្បជោតិកា
# អដ្ឋកថា ខុទ្ទកនិកាយ
# មហានិទ្ទេស

### នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

## អារម្ភកថា

ព្រះជិនស្រីអង្គណាទ្រង់កម្ចាត់បង់នូវទុក្ខ គឺអវិជ្ជានិងភគៈ ដោយអំណាចការត្រេកអរ ទ្រង់ដកទាំងឫស ទ្រង់ចម្រើនអដ្ឋង្គិកមគ្គ ពាល់ត្រូវនូវអមតបទ ទ្រង់សម្រេចពោធិញ្ញាណ ទ្រង់យាងទៅកាន់ព្រៃឥសិបតនមិគទាយវ័ន ប្រកាសធម្មចក្ក ញ៉ាំងវេនេយ្យសត្វ ១៨ កោដិ មានព្រះកោណ្ឌញ្ញត្ថេរជាដើម ឲ្យសម្រេចនូវធម៌ក្នុងថ្ងៃនោះ ក្នុងទីនោះ ។

ខ្ញុំសូមនមស្ការដោយសិរសា គឺត្បូងនូវព្រះជិនស្រីអង្គនោះ ទ្រង់ឧត្តមជាងសត្វទាំងពួងនិងព្រះធម៌ដ៏ឧត្តម មួយអន្លើដោយព្រះសង្ឃ មិនមានបុគ្គលដទៃក្រៃលែងជាង ។

ធម្មចក្កណា ដែលព្រះដ៏មានព្រះភាគត្រាស់ទុកដោយសង្ខេប ព្រះសារីបុត្តជាអ្នកមានបញ្ញាច្រើន ប្រហែលនឹងព្រះសាស្ដា ជាអ្នកកើតអំពីអង្គព្រះជិន-ស្រី ចែកធម្មចក្កនោះជាចំណែកៗ ពោលមហានិទ្ទេសដែលឈ្មោះថាជាបាឋៈប្រសើរនិងវិសេស ។

ម្យ៉ាងទៀត ខ្ញុំសូមនមស្ការព្រះសារីបុត្ត ដែលជាពុទ្ធជិនោរសអង្គនោះ ដែលជាព្រះថេរៈ មានថេរគុណមិនមែនតិច ជាទីត្រេកអរក្រៃលែង ជាអ្នក

មានកិត្តិគុណឧត្តម ព្រោះសភាពនៃបញ្ញានិងជាអ្នកមានការប្រព្រឹត្តឱនលំទោន យ៉ាងល្អ ខ្ញុំកាលព្រះទេវត្ថេរដែលជាពហុស្សូតប្រកបដោយគុណ មានខន្តិជាដើម មានប្រក្រតីពោលពាក្យដែលសមគួរនិងល្មមប្រមាណជាដើម អារាធនាហើយ តាំងនៅក្នុងគន្លងនៃការស្វាធ្យាយរបស់ព្រះថេរៈអ្នកមហាវិហារ កាន់យកបទវិនិច្ឆ័យបុរាណ ដែលគួរកាន់យក ។

ខ្ញុំមិនបោះបង់លទ្ធិរបស់ខ្លួន និងមិនធ្វើលទ្ធិអ្នកដទៃឲ្យវិនាស រួបរួមន័យរបស់អដ្ឋកថាទាំងខាងដើម ខាងចុង តាមសមគួរ ពណ៌នាតាមអត្ថដែលមិនធ្លាប់ពណ៌នារបស់មហានិទ្ទេសនោះ ដែលនាំមកនូវប្រភេទនៃញាណ ដែលព្រះយោគាវចរទាំងឡាយមិនមែនតិច អាស្រ័យសេពហើយ មិនបោះបង់ព្រះសូត្រនិងអដ្ឋកថា ផ្តើមពណ៌នាមហានិទ្ទេសដោយសង្ខេប ដោយការរាប់អានច្រើនក្នុងព្រះសទ្ធម្ម មិនមែនបំណងលើកខ្លួន ។

ខ្ញុំនឹងពោលអដ្ឋកថាដើម្បីប្រយោជន៍ដល់មហាជន និងដើម្បីការតាំងនៅយូរនៃព្រះសទ្ធម្ម សូមសប្បុរសទាំងឡាយស្តាប់សទ្ធម្មប្បជោតិកា ដោយគោរពនិងចាំទុកដោយល្អចុះ ។

ព្រោះបានពោលទុកហើយក្នុងអារម្ភកថានោះថា មហានិទ្ទេសដែលឈ្មោះថា ជាបាឋៈប្រសើរនិងវិសេស បាឋៈមានពីរយ៉ាង គឺព្យញ្ជនបាឋៈ ១ អត្ថបាឋៈ ១ ។

ក្នុងបាឋៈពីរយ៉ាងនោះ ព្យញ្ជនបាឋៈមាន ៦ យ៉ាងគឺ អក្ខរៈ ១ បទ ១ ព្យញ្ជនៈ ១ អាការៈ ១ និរុត្តិ ១ និទ្ទេស ១ ។

អត្ថបាឋៈមាន ៦ យ៉ាងគឺ សង្កាសនៈ ១ បកាសនៈ ១ វិវរណៈ ១ វិភជនៈ ១ ឧត្តានីករណៈ ១ បញ្ញត្តិ ១ ។

ក្នុងព្យញ្ជនបាឋៈនោះ ទេសនាដែលប្រព្រឹត្តទៅដោយចិត្តដែលគិតដល់ហេតុដ៏បរិសុទ្ធិ ដោយអំណាចនៃការប្រកបដ៏បរិសុទ្ធិ ក្នុងទ្វារទាំង ៣ រមែងដឹងបានថា អក្ខរៈ ព្រោះមិនបានសម្តែង គឺមិនបានសេពដោយវាចា ។ អក្ខរៈនោះគប្បីកាន់យកថា ឈ្មោះថា អក្ខរៈ ព្រោះអំណាចនៃបញ្ញាដែលបណ្តាព្រាហ្មណ៍ក្នុងបារាយនិកវគ្គសួរដោយចិត្ត និងដោយអំណាចនៃបដ្ឋានមហាបករណ៍ ដែលព្រះដ៏មានព្រះភាគប្រថាប់គង់ពិចារណាហើយ ត្រង់រតនឃរចេតិយ ។

ម្យ៉ាងទៀត បទដែលមិនបរិបូណ៌ ក៏គប្បីដឹងថា អក្ខរៈ ដូចក្នុងពាក្យជាដើមយ៉ាងនេះថា **សដ្ឋីវស្សសហស្សានិ** ប្រែថា ៦ ម៉ឺនឆ្នាំ ដូច្នោះ ។ ក្នុងពាក្យនេះ អាចារ្យពួកមួយពោលថា **ស** អក្ខរៈ និង **ទុ** អក្ខរៈ ឈ្មោះថា អក្ខរៈ ឬបទដែលមានអក្ខរៈ ១ ក៏ឈ្មោះថា អក្ខរៈ ។

អក្ខរសន្និបាត គឺការប្រជុំនៃអក្ខរៈ ដែលចុះបញ្ចាំងក្នុងការចែក ដូចក្នុងពាក្យថា **យាយំ តណ្ហា ពោនោព្ភវិកា** ដូច្នេះ ឈ្មោះថា បទ ពាក្យដែលប្រកបដោយអក្ខរៈច្រើន ដូចក្នុងពាក្យជាដើមថា **នាមញ្ច រូបញ្ច** ក៏ឈ្មោះថា បទ ។

ឈ្មោះថា ព្យញ្ជនៈ ព្រោះអត្ថថា ញុំាងបទដែលលោកពោលទុកដោយសង្ខេបឲ្យជាក់ច្បាស់ គឺធ្វើអត្ថដែលប្រជុំដោយបទឲ្យប្រាកដ បានដល់ ធ្វើ

ឲ្យជាក់ច្បាស់ ធ្វើឲ្យប្រាកដ សំដៅដល់ប្រយោគនោះឯង ។

អត្ថដែលត្រាស់ដោយសង្ខេបថា **ចត្តារោ ឥទ្ធិបាទា** ក៏ឈ្មោះថា ព្យញ្ជនៈ ព្រោះធ្វើអត្ថឲ្យប្រាកដ ដូចក្នុងពាក្យថា ឥទ្ធិបាទ ៤ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើនឥទ្ធិបាទប្រកបដោយឆន្ទសមាធិ និងបធានសង្ខារ ១ ។ ចម្រើនឥទ្ធិបាទប្រកបដោយវីរិយសមាធិនិងបធានសង្ខារ ១ ។ ចម្រើនឥទ្ធិបាទប្រកបដោយចិត្តសមាធិនិងបធានសង្ខារ ១ ។ ចម្រើនឥទ្ធិបាទប្រកបដោយវិមំសាសមាធិនិងបធានសង្ខារ ១ ដូច្នេះ ។

ការប្រកាសវិភាគនៃព្យញ្ជនៈ ឈ្មោះថា អាការៈ ។ ការធ្វើវិភាគច្រើនយ៉ាងនូវព្យញ្ជនៈ ដែលត្រាស់ទុកក្នុងពាក្យជាដើមយ៉ាងនេះថា បណ្ដាធម៌ទាំងនោះ ឆន្ទៈ តើដូចម្ដេច ។ សេចក្ដីប្រាថ្នា ភាពនៃបុគ្គលមានសេចក្ដីប្រាថ្នា ភាពនៃបុគ្គលប្រាថ្នាដើម្បីធ្វើ ការប្រាថ្នាធម៌ជាកុសល ... ដូច្នេះ ឈ្មោះថា អាការៈ ។

ពាក្យអធិប្បាយអត្ថ ដែលប្រកបដោយអាការៈ ឈ្មោះថា និរុត្តិ ។ ពាក្យដែលលោកពោលទុកដោយអាការៈក្នុងពាក្យថា **ផស្សោ វេទនា** ជាដើម ហើយប្រាប់ថា ដែលហៅថា ផស្សៈ ព្រោះអត្ថថា ប៉ះខ្ទប់នូវអារម្មណ៍ ។ ដែលហៅថា វេទនា ព្រោះអត្ថថា សោយនូវអារម្មណ៍ ដូច្នេះ ឈ្មោះថានិរុត្តិ ។

សេចក្ដីពិស្ដារនៃពាក្យអធិប្បាយ ឈ្មោះថានិទ្ទេស ព្រោះអត្ថថា សម្ដែងអត្ថដោយមិនសេសសល់ ។ បទដែលមានសេចក្ដីពង្រីក ដូចប្រយោគថា ឈ្មោះថា វេទនា ព្រោះអត្ថថា សោយនូវអារម្មណ៍ដូច្នេះ ។ ក៏ឈ្មោះថា

និទ្ទេស ព្រោះលោកពោលទុកដោយអំណាចសេចក្តីពិស្តារនៃអត្ថជាដើមថា សុខ ទុក្ខ អទុក្ខមសុខ ។ ឈ្មោះថា សុខ ព្រោះអត្ថថា ប្រព្រឹត្តទៅសប្បាយ ឈ្មោះថា ទុក្ខ ព្រោះអត្ថថា ប្រព្រឹត្តទៅលំបាក ឈ្មោះថា អទុក្ខមសុខ ព្រោះអត្ថថា មិនប្រព្រឹត្តទៅលំបាក មិនប្រព្រឹត្តទៅសប្បាយ ។

ការដឹងបទនៃព្យញ្ជនបាឋៈ ៦ យ៉ាងដោយប្រការដូច្នេះហើយ ប្រកាសសម្តែងក្នុងបទនៃអត្ថបាឋៈ ៦ យ៉ាងដោយសង្ខេប ឈ្មោះថា **សង្កាសន** ប្រែថា ប្រកាសឲ្យដឹងច្បាស់ ។ ការសម្តែងសេចក្តីដោយសង្ខេប ដូចក្នុងពាក្យថា ភិក្ខុកាលសម្គាល់នោះឯង រមែងត្រូវមារចង កាលមិនសម្គាល់ រមែងផុតចាកមារដែលមានចិត្តបាបដូច្នោះជាដើម ក៏ឈ្មោះថា **សង្កាសន** គឺឲ្យដឹងច្បាស់ ។ ព្រះថេរៈនេះ ជាអ្នកអាចដើម្បីពោលនូវអត្ថ ដែលព្រះមានព្រះភាគត្រាស់ទុកដោយសង្ខេបយ៉ាងនេះ ដោយពាក្យថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គបានដឹងទូទៅហើយ បពិត្រព្រះសុគត ខ្ញុំព្រះអង្គបានដឹងទូទៅហើយ ដូច្នេះ ចាក់ធ្លុះហើយ ។

ការប្រកាស ការសម្តែងអំពីខាងដើមនូវអត្ថដែលគួរពោលខាងចុង ឈ្មោះថា បកាសនៈ ។ ការសម្តែងការប្រកាសនូវអត្ថ ដែលគួរពោលខាងក្រោយដោយពាក្យដំបូង ដូចក្នុងពាក្យថា **សព្វំ ភិក្ខវេ អាទិត្តំ** ប្រែថា ម្នាលភិក្ខុទាំងឡាយ ធម្មជាតទាំងអស់ជារបស់ក្តៅ ដូច្នេះជាដើម ឈ្មោះថា បកាសនៈ ។ កាលបើប្រយោគយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ធម្មជាតទាំងអស់ជារបស់ក្តៅ ( នោះ ) តើគឺអ្វី ម្នាលភិក្ខុទាំងឡាយ ចក្ខុជារបស់ក្តៅ រូបទាំងឡាយ

*ជារបស់ក្តៅជាដើម ដែលព្រះមានព្រះភាគត្រាស់ហើយ ដោយការសម្តែងអត្ថ ដែលទ្រង់សម្តែងលើកដំបូង ឲ្យប្រាកដទៀត បទនៃអត្ថទាំងពីរ ឈ្មោះថាទ្រង់ត្រាស់ហើយ ដើម្បីឧបការៈដល់ភិក្ខុដែលមានឥន្ទ្រិយចាស់ក្លា ព្រោះត្រាស់ទុកថា ភិក្ខុមានឥន្ទ្រិយចាស់ក្លា រមែងចាក់ធ្លុះអត្ថតាមដែលត្រាស់ទុក ដោយសង្ខេបបានដូច្នេះ ។*

*ការចែកដោយពិស្តារ នូវអត្ថតាមដែលពោលហើយដោយសង្ខេប និងការទ្រទ្រង់ទុកបាននូវអត្ថដែលពោលហើយត្រឹមតែម្តង ឈ្មោះថា វិវរណៈ ការពង្រីកអត្ថដែលតាំងទុកដោយសង្ខេបថា* **កុសលា ធម្មា** *ដូច្នេះ ដោយអំណាចនៃការអធិប្បាយថា* **កតមេ ធម្មា កុសលា យស្មឹ សមយេ កាមាវចរំ កុសលំ ចិត្តំ ឧប្បន្នំ ហោតិ**[១]*ដូច្នេះជាដើម ជាការពោលដោយពិស្តារទៀត ក៏ឈ្មោះថា វិវរណៈ គឺការបើកផ្ទារ ។*

*ការធ្វើអត្ថនោះឲ្យជាចំណែកៗ ឈ្មោះថា វិភជនៈ ។ ការធ្វើកុសលធម៌ទាំងឡាយដែលលម្អិតហើយថា* **យស្មឹ សមយេ** *ប្រែថា ក្នុងសម័យណា ដូច្នេះ ឲ្យជាចំណែកៗថា សម័យនោះផស្សៈក៏កើត វេទនាក៏កើត ដូច្នេះ ក៏ឈ្មោះថា វិភជនៈ គឺការចែក ។*

*ការធ្វើអត្ថឲ្យដល់ព្រម ដោយការចែកដោយពិស្តារ នូវអត្ថដែលចែកហើយ និងដោយការតាំងទុកនូវអត្ថដែលចែកហើយដោយឧបមា ឈ្មោះថា ឧត្តានីករណៈ ។ ការពោលលម្អិតសេចក្តីយ៉ាងល្អិតល្អន់នូវអត្ថដែលលម្អិត*

---

*១-បិ.៧៨ ទំ.១៦ ។*

ហើយ ដោយវិវរណៈថា ផស្សៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ផស្សៈ ការពាល់ត្រូវ ការប៉ះពាល់ ការទង្គិកទង្គិចណា ដូច្នេះ និងការពោលឧបមានូវអត្ថដែលចែកហើយដោយវិភជនៈថា ម្នាលភិក្ខុទាំងឡាយ ផស្សាហារ តើត្រូវយល់ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ដូចជាមេគោដែលមិនមានស្បែក ដូច្នេះ ក៏ឈ្មោះថា ឧត្តានីករណៈ គឺធ្វើឲ្យងាយ ។

ការញ៉ាំងសោមនស្សឲ្យកើតឡើងដល់ចិត្តដោយវិធីជាច្រើន គឺដោយការសម្តែងធម៌ដល់សាធុជនដែលកំពុងស្តាប់ធម៌ និងការធ្វើនូវការមុតស្រួចនៃញាណដោយវិធីជាច្រើន ឲ្យដល់សាធុជនដែលមានបញ្ញាមិនទាន់មុតស្រួច ឈ្មោះថា បញ្ញត្តិ ។ ឈ្មោះថា បញ្ញត្តិ ព្រោះអត្ថថា ធ្វើសេចក្តីឲ្យប្រាកដដល់សាធុជនដែលស្តាប់ទាំងនោះ ដោយការត្រេកអរនៃចិត្តដែលប្រកបដោយសោមនស្សនោះ និងដោយការពិចារណារបស់ចិត្ត ដែលប្រកបដោយសោមនស្សនោះ ។

ក្នុងបាឋៈទាំងពីរនោះ ព្រះមានព្រះភាគទ្រង់ប្រកាសសង្ខេបដោយអក្ខរៈ ទ្រង់ប្រកាសដោយបទ ទ្រង់លម្អិតដោយព្យញ្ជនៈ ទ្រង់ចែកដោយអាការៈ ទ្រង់ធ្វើឲ្យងាយដោយនិរុត្តិ ទ្រង់បញ្ញត្តិដោយនិទ្ទេស ។ ពាក្យនេះមានអធិប្បាយដូចម្តេច

ព្រះមានព្រះភាគទាំងឡាយ ក្នុងការសម្តែងធម៌ម្តង ក្នុងវេនេយ្យសត្វពួកខ្លះ ទ្រង់រមែងធ្វើអត្ថសង្ខេបដោយអក្ខរៈ ។បេ។ ទ្រង់បញ្ញត្តិអត្ថដោយនិទ្ទេស នេះជាអធិប្បាយក្នុងបាឋៈទាំងពីរនោះ ។

*ម្យ៉ាងទៀត ព្រះមានព្រះភាគ ទ្រង់ប្រកាសសង្ខេបដោយអក្ខរៈ ទាំងឡាយ ហើយទ្រង់ប្រកាសដោយបទទាំងឡាយ ទ្រង់លម្អិតដោយព្យញ្ជនៈ ទាំងឡាយ ហើយទ្រង់ចែកដោយអាការៈទាំងឡាយ ទ្រង់ធ្វើឲ្យងាយដោយនិរុត្តិ ទាំងឡាយ ហើយទ្រង់បញ្ញត្តិដោយនិទ្ទេសទាំងឡាយ មានអធិប្បាយដូចម្ដេច*

*មានអធិប្បាយថា ព្រះដ៏មានព្រះភាគ ទ្រង់ទូន្មានវេនេយ្យសត្វពួកខ្លះ ក្នុងឋានៈណាមួយដោយព្រះធម្មទេសនាបែបនេះ ម្យ៉ាងទៀត ព្រះដ៏មានព្រះភាគ កាលទ្រង់លើកសេចក្ដីសង្ខេបឡើង ដោយអក្ខរៈទាំងឡាយ ហើយទ្រង់ប្រកាសដោយបទទាំងឡាយ ឈ្មោះថា ទ្រង់ទូន្មានពួកឧគ្ឃដិតញ្ញូ កាលទ្រង់លម្អិតដោយព្យញ្ជនៈទាំងឡាយ ហើយទ្រង់ចែកដោយអាការៈទាំងឡាយ ឈ្មោះថា ទ្រង់ទូន្មានពួកវិបចិតញ្ញូ កាលទ្រង់ធ្វើឲ្យងាយដោយនិរុត្តិ ទាំងឡាយ ហើយទ្រង់បញ្ញត្តិដោយនិទ្ទេសទាំងឡាយ ឈ្មោះថា ទ្រង់រមែងទូន្មានពួកនេយ្យៈដោយអំណាចនៃវេនេយ្យសត្វ គប្បីប្រកបដោយប្រការដូច្នេះឯង ។*

*តែដោយអត្ថ ក្នុងទីនេះថា ព្យញ្ជនៈបាឋៈដូចម្ដេច អត្ថបាឋៈដូចម្ដេច គប្បីជ្រាបថា ព្រះសូរសៀងដែលប្រព្រឹត្តទៅដោយវិញ្ញត្តិ ជាទីមកនៃអត្ថ របស់ព្រះដ៏មានព្រះភាគទាំងឡាយ ទ្រង់សម្ដែងធម៌ឯណា នោះឈ្មោះថា ព្យញ្ជនបាឋៈ ។ ព្រះធម៌ដែលប្រកបដោយលក្ខណៈនិងរសជាដើម ដែលអ្នកស្ដាប់នោះគប្បីសម្រេចឯណា នោះឈ្មោះថា អត្ថបាឋៈ ។*

*ម្យ៉ាងទៀត បាឋៈ មាន ៦ យ៉ាង គឺសន្ធាយភាសិតបាឋៈ ១ ព្យញ្ជន*

កាសិតបាឋៈ ១ សាវសេសបាឋៈ ១ អនវសេសបាឋៈ ១ នីតបាឋៈ ១ និងនេយ្យបាឋៈ ១ ។

ក្នុងបាឋៈទាំងនោះ បាឋៈដែលពោលអត្ថមិនតិចមានយ៉ាងនេះថា បុគ្គលសម្លាប់តណ្ហាដូចជាមាតាផង សម្លាប់អស្មិមានៈដូចបិតាផង សម្លាប់សស្សតទិដ្ឋិនិងឧច្ឆេទទិដ្ឋិ ដូចជាស្តេចជាព្រាហ្មណ៍ទាំង ២ ផង ដូច្នេះ ឈ្មោះថា សន្ទាយកាសិតបាឋៈ ។

បាឋៈដែលពោលអត្ថតែម្យ៉ាង យ៉ាងនេះថា **មនោបុព្វង្គមា ធម្មា** ធម៌ទាំងឡាយមានចិត្តដល់មុនជាប្រធាន ដូច្នេះឈ្មោះថា ព្យញ្ជនកាសិតបាឋៈ ។

បាឋៈជាដើមយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ធម្មជាតទាំងអស់ជារបស់ក្តៅ ដូច្នេះ ឈ្មោះថា សាវសេសបាឋៈ ។

បាឋៈដែលផ្ទុយគ្នាយ៉ាងនេះថា ធម៌ទាំងអស់ រាប់ទាំងអតីត អនាគតនិងបច្ចុប្បន្ន រមែងមកកាន់វង្វង់ក្នុងប្រធាននៃព្រះញាណរបស់ព្រះពុទ្ធមានព្រះភាគដោយអាការៈសព្វគ្រប់ ដូច្នេះ ឈ្មោះថា អនវសេសបាឋៈ ។

បាឋៈដែលគប្បីដឹង ដូចដែលពោលយ៉ាងនេះថា **អនិច្ចំ ទុក្ខំ អនត្តា** ដូច្នេះជាដើម ឈ្មោះថា នីតបាឋៈ ។

បាឋៈដែលគប្បីរំពឹងដល់តាមសមគួរយ៉ាងនេះថា **ឯកបុគ្គលោ ភិក្ខវេ** ម្នាលភិក្ខុទាំងឡាយ បុគ្គលឯកដូច្នេះ ឈ្មោះថា នេយ្យបាឋៈ ។

ម្យ៉ាងទៀត អត្ថមានប្រការមិនមែនតិច គឺបាឋត្ថៈ ១ សការត្ថៈ ១ ញាយត្ថៈ ១ បាឋានុរូប ១ នបាឋានុរូប ១ សាវសេសត្ថៈ ១ និរវសេសត្ថៈ ១ នីតត្ថៈ

*១ និងនេយ្យត្ថៈ ១ ក្នុងអត្ថទាំងនោះ បាឋៈណាដែលលោកលើកឡើង ដើម្បីឲ្យដឹងអត្ថ ត្រង់បាឋៈនោះ ឈ្មោះថា បាឋត្ថៈ ដូចក្នុងប្រយោគជាដើមថា* **សាត្ថំ សព្យញ្ជនំ** *ព្រមទាំងអត្ថនិងព្យញ្ជនៈ ដូច្នេះ ។*

*លក្ខណៈនិងរសជាដើមនៃរូបធម៌ និងអរូបធម៌ទាំងឡាយ ឈ្មោះថា សភាវត្ថៈ ដូចក្នុងប្រយោគជាដើមថា* **សម្មាទិដ្ឋឹ ភាវេតិ** *ចម្រើននូវសម្មាទិដ្ឋិ ដូច្នេះ ។*

*អត្ថណាដែលបុគ្គលដឹង រមែងប្រព្រឹត្តទៅដើម្បីប្រយោជន៍ រមែងគួរដើម្បីឲ្យដឹងព្រមដូច្នេះ អត្ថនោះឈ្មោះថា ញាយត្ថៈ ដូចក្នុងប្រយោគជាដើមថា* **អត្ថវាទី ធម្មវាទី** *ពោលតែពាក្យដែលជាអត្ថ ពោលតែពាក្យដែលជាធម៌ ដូច្នេះ ។*

*អត្ថដែលសមគួរតាមបាឋៈ ឈ្មោះថា បាឋានុរូប ។ អត្ថដែលត្រាស់ទុកបដិសេធសេចក្តីនៃស្រមោលព្យញ្ជនៈថា ព្រះមានព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ ចក្ខុជាកម្មចាស់ ដូច្នេះ ព្រោះហេតុនោះ សូម្បីចក្ខុក៏ជាកម្ម ដូច្នេះឈ្មោះថា នបាឋានុរូប ។*

*ព្រះដ៏មានព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ ចក្ខុជាកម្មចាស់ ដូច្នេះ ព្រោះហេតុនោះ សូម្បីចក្ខុក៏ជាកម្ម ដូច្នេះឈ្មោះថា នបាឋានុរូប ។*

*អត្ថនោះដោយបាឋៈ ទ្រង់មិនបានអនុញ្ញាត មិនបានបដិសេធ មិនបានប្រកប ។ អត្ថនោះសូម្បីគួរសង្គ្រោះ ក៏ទ្រង់មិនបានសង្គ្រោះ ឬដែលគួរវៀរ ទ្រង់ក៏មិនបានវៀរអ្វីមួយឡើយ ត្រាស់មិនឲ្យសេសសល់ ឈ្មោះថា សាវ-*

សេសត្ថៈ ដូចក្នុងប្រយោគជាដើមថា ចក្ខុវិញ្ញាណកើត ព្រោះអាស្រ័យចក្ខុនិងរូបដូច្នេះ សត្វទាំងឡាយគ្រប់ប្រាណ តែងតក់ស្លុតនឹងអាជ្ញា សត្វទាំងឡាយតែងខ្លាចចំពោះសេចក្ដីស្លាប់គ្រប់ៗរូប ដូច្នេះ ។

អត្ថដែលផ្ទុយ ឈ្មោះថា និរវសេសត្ថៈ ដូចក្នុងប្រយោគជាដើមថា ម្នាលភិក្ខុទាំងឡាយ តថាគតក្ដី អ្នកទាំងឡាយក្ដី ដែលអន្ទោលទៅ ត្រាច់រង្គាត់ទៅ ( ក្នុងសង្សារវដ្ដ ) ដូច្នេះ និងដូចពុទ្ធដីកាមួយកន្លែងទៀតថា ម្នាលភិក្ខុទាំងឡាយ នរណាដឹង នរណាជឿក្នុងសង្ខារនោះថា ផែនដីនេះក្ដី ស្ដេចក្នុំឈ្មោះសិនេរុក្ដី គង់នឹងឆេះរលាយ គង់នឹងវិនាស មិនមានប្រាកដយ៉ាងនេះ វៀរលែងតែអរិយសាវកទាំងឡាយ អ្នកមានបទ គឺធម៌ឃើញហើយ ដូច្នេះ ។

អត្ថដែលគប្បីជ្រាបដោយអំណាចនៃសព្ទនោះឯង ឈ្មោះថា នីតត្ថៈ ដូចក្នុងប្រយោគជាដើមថា រូប សំឡេង ក្លិន រស ផ្សព្វ ដែលជាទីត្រេកអររបស់ចិត្ត ដូច្នេះ ។

អត្ថដែលគប្បីជ្រាបតាមសន្ទូត ឈ្មោះថា នេយ្យត្ថៈ ដូចក្នុងប្រយោគជាដើមថា ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលឧបមាដោយមេឃនេះមាន ៤ ពួករមែងមាននៅក្នុងលោកដូច្នោះដែរ ដូច្នេះ ។ បុគ្គលដឹងច្បាស់នូវបាឋៈផង នូវអត្ថផង តាំងនៅយ៉ាងនេះ រមែងមិនរសេមរសាម អំពីពួកដែលពោលផ្ទុយទាំងឡាយ ដោយការសិក្សាក្នុងសំណាក់របស់គ្រូអស់កាលយូរ ។

បុគ្គលអាចពោលរហូតដល់ព្រមដោយអាគមនិងអធិគម ដោយមិនឃ្លៀងឃ្លាតដោយប្រការដូច្នេះ អាចយល់ដោយហេតុនិងឧទាហរណ៍ជាដើម ដោយ

ន័យសង្ខេបនិងពិស្តារ ។ កាលដឹងច្បាស់យ៉ាងនេះហើយ រមែងជាអ្នកស្អាត ព្រោះវៀរចាកមន្ទិល គឺការទ្រុស្តសីលនិងទិដ្ឋិអាក្រក់ ដោយភាពជាអ្នកអាច ជម្រះខ្លួននិងអ្នកដទៃឲ្យបរិសុទ្ធបាន ដ្បិតថា បុគ្គលទ្រុស្តសីល រមែងបៀតបៀនខ្លួន ជាអ្នកមានវាចាមិនគួរជឿ ព្រោះការទ្រុស្តសីលនោះ មិនអាចនាំអាហារមកបាន ក្តៅក្រហាយជានិច្ចក្នុងលោកនេះ ដូចកូនគោ បុគ្គលមានទិដ្ឋិអាក្រក់ រមែងបៀតបៀនអ្នកដទៃនឹងជាទីពឹងអាស្រ័យមិនបាន ដូចផ្កាឈូកដែលដុះក្នុងគុហារបស់សត្វសាហាវ ឯបុគ្គលដែលវិបត្តិទាំងពីរយ៉ាង ជាអ្នកមិនគួរអង្គុយជិតដោយប្រការទាំងពួង ដូចឈើដុតខ្មោចនៅក្នុងលាមកនិងដូចពស់វែកនៅក្នុងលាមក ។ ចំណែកបុគ្គលសម្បូរទាំងពីរយ៉ាង ជាអ្នកស្អាតដែលវិញ្ញូជនទាំងឡាយគួរអង្គុយជិត និងគួរគប់រកដោយប្រការទាំងពួងដូចអណ្តូងរតនៈប្រាសចាកអន្តរាយ ។ បុគ្គលយ៉ាងនេះ មិនកំណាញ់យ៉ាងនេះ ជាអាចារ្យដែលមិនបិទបាំងពាក្យប្រៀនប្រដៅ ជាអ្នកមិនលះបង់សូត្រ ៤ យ៉ាង គឺសុត្តៈ សុត្តានុលោម អាចរិយវាទនិងអត្តនោមតិ ពោលដោយអំណាចសូត្រ ៤ យ៉ាងនោះថា

ឯកំសព្យាករ ១ វិភជ្ជព្យាករជាគម្រប់ ២ បដិបុច្ឆាព្យាករជាគម្រប់ ៣ ឋបនីយព្យាករជាគម្រប់ ៤ ដូច្នេះ ។

មួយវិញទៀត ឈ្មោះថា ជាអ្នកមិនលះបង់សូត្រ ៤ យ៉ាងនោះ ព្រោះប្រកបអ្នកស្តាប់ទុកក្នុងប្រយោជន៍អំពីសូត្រ ៤ យ៉ាងនោះ ។ ការយល់ក្នុងសូត្រ ៤ យ៉ាងនោះ រមែងជាការមិនសាំញ៉ាំដូច្នេះឯង ។ ក្នុងសេចក្តីនេះ លោក

ពោលទុកថា

បុគ្គលអ្នកពោល ជាអ្នកមិនសេមសោមព្រោះដឹងអត្ថនៃបាឋៈ ជាអ្នកស្អាត មិនកំណាញ់ មិនលះសូត្រ ៤ យ៉ាង ជាអ្នកសម្តែងទៅតាមប្រយោជន៍ ។

ពាក្យថា ជាអ្នកសម្តែងក្នុងគាថានេះ សេចក្តីថា គប្បីជាអ្នកសម្តែង ។ ពាក្យថា ទៅតាមប្រយោជន៍ សេចក្តីថា ដែលទៅតាមដោយប្រយោជន៍ ជាអ្នកទៅតាមប្រយោជន៍ គឺដែលមានចិត្តប្រកបដោយប្រយោជន៍ ។

បុគ្គលនេះជាទីស្រឡាញ់ ព្រោះជាអ្នកស្អាត ជាទីគោរព ព្រោះជាអ្នកមិនលះបង់សូត្រ ៤ យ៉ាង គួរសរសើរ ព្រោះជាអ្នកមិនសេមសោម ជាអ្នកអត់ធន់ចំពោះពាក្យសម្តី ព្រោះជាអ្នកទៅតាមប្រយោជន៍ ជាអ្នកពោលចន្លុលបង្ហាញនូវរឿងដែលជ្រាលជ្រៅបាន ព្រោះជាអ្នកដឹងអត្ថនៃបាឋៈ ជាអ្នកដឹកនាំក្នុងឋានៈដែលគួរ ព្រោះជាអ្នកមិនកំណាញ់ដូច្នេះ ។

ព្រះដ៏មានព្រះភាគត្រាស់ ( ទុកក្នុងអង្គុត្តរនិកាយសត្តកនិបាត ) ថា

កិក្ខុជាអ្នក ( ធ្វើខ្លួន ) ឲ្យជាទីស្រឡាញ់ផង គួរគោរពផង គួរសរសើរផង ឧស្សាហ៍ប្រៀនប្រដៅផង អត់ធន់ចំពោះពាក្យផង ជាអ្នកនិយាយពាក្យជ្រៅផង ទាំងមិនដឹកនាំក្នុងហេតុដែលមិនគួរផង... ដូច្នេះ ។

អ្នកសម្តែងជាបុគ្គលប្រាថ្នាប្រយោជន៍ក្រៃលែង យើងនឹងសិក្សាដល់អ្នកសម្តែងក្នុងកាលឥឡូវនេះមុន អ្នកសម្តែងរមែងមិនមើលងាយនូវពាក្យសម្តី

ព្រោះគោរពធម៌ ៤ ប្រការ រមែងមិនមើលងាយនូវពាក្យដែលពោលហើយ ព្រោះគោរពអាចារ្យ រមែងមិនមើលងាយខ្លួន ព្រោះជាអ្នកប្រដាប់ដោយគុណមានសទ្ធានិងបញ្ញាជាដើម ជាអ្នកមានចិត្តមិនរាយមាយ ព្រោះជាអ្នកមិនអួតអាងនិងជាអ្នកមិនមានមាយា ព្រោះជាអ្នកប្រាថ្នាព្រះនិព្វាន រមែងមនសិការដោយឧបាយ ព្រោះជាអ្នកមានបញ្ញាល្អ សមដូចព្រះតម្រាស់ ដែលត្រាស់ទុក ( ក្នុងអង្គុត្តរនិកាយបញ្ចកនិបាត ) ថា

ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៥ យ៉ាង កាលស្តាប់ព្រះសទ្ធម្ម គួរដើម្បីឈានចុះកាន់និយាម ជាសភាពដ៏ប្រពៃ ក្នុងកុសលធម៌ទាំងឡាយបាន ។ ប្រកបដោយធម៌ ៥ យ៉ាង ដូចម្តេចខ្លះ ។ គឺមិនមើលងាយពាក្យពោល ១ មិនមើលងាយបុគ្គលអ្នកពោល ១ មិនមើលងាយខ្លួនឯង ១ មានចិត្តមិនរវើរវាយស្តាប់ធម៌ ១ មានចិត្តនឹងនួននៅក្នុងអារម្មណ៍តែមួយ គឺយកចិត្តទុកដាក់ដោយឧបាយប្រាជ្ញា ១ ដូច្នេះ ។

ការបែកពាក្យរមែងមានព្រោះដល់លក្ខណៈនោះឯង ក្នុងរឿងនេះ ព្រះដ៏មានព្រះភាគត្រាស់ទុកថា បុគ្គលគោរពអាចារ្យអ្នកសម្តែងធម៌ ដែលប្រដាប់ដោយគុណ មានសទ្ធានិងបញ្ញាជាដើម ជាអ្នកមិនអួតអាង មិនមានមាយា មានបញ្ញាល្អ ប្រាថ្នាព្រះនិព្វាន ជាអ្នកពោលនិងជាអ្នកស្តាប់ ដោយប្រការដូច្នេះ ។

កាលសម្តែងព្យញ្ជនៈនិងអត្ថដែលមានប្រការដូចពោល យ៉ាងនេះហើយ ឥឡូវនេះ ខ្ញុំនឹងពណ៌នាមហានិទ្ទេសនោះ ដែលលោកហៅថា មហានិទ្ទេស ព្រោះអត្ថថា ជានិទ្ទេសធំ ដូចមហាសមុទ្ទនិងមហាប្រឹថពី លោកពោលធ្វើឲ្យប្រសើរ ព្រះអានន្ទស្តាប់មហានិទ្ទេសបែបនេះ ដែលសម្បូរដោយអត្ថ សម្បូរដោយព្យញ្ជនៈជ្រាលជ្រៅ មានអត្ថជ្រៅ ប្រកាសលោកុត្តរបដិសំយុត្តដោយសុញ្ញតា ឲ្យសម្រេចការបដិបត្តិនិងគុណវិសេស គឺមគ្គផល បដិសេធធម៌ដែលជាសត្រូវ ជាទីកើតនៃរតនៈ គឺញាណរបស់ព្រះយោគាវចរទាំងឡាយជាហេតុវិសេស ដែលឲ្យកើតលម្អនៃធម្មកថារបស់ធម្មកថិកទាំងឡាយ ជាគ្រឿងចេញអំពីទុក្ខ ជារបស់បុគ្គលដែលខ្លាចសង្សារទុក្ខ មានអត្ថឲ្យកើតនូវការស្រឡះចិត្ត ដោយការសម្តែងឧបាយនៃការចេញទៅចាកទុក្ខនោះ មានអត្ថកម្ចាត់ធម៌ដែលជាបដិបក្ខចំពោះការចេញអំពីទុក្ខនោះ និងមានអត្ថឲ្យកើតនូវការត្រេកអរនៃហទយៈរបស់សាធុជន ដោយការបើកផ្សារនូវអត្ថនៃសុត្តបទទាំងឡាយ មិនមែនតិច ដែលមានអត្ថជ្រាលជ្រៅ ដែលព្រះសារីបុត្តត្ថេរ អ្នកប្រាជ្ញាក្នុងមហាប្រទីប គឺព្រះសទ្ធម្មដែលព្រះអរហន្តសម្មាសម្ពុទ្ធ ជាអ្នកមានពន្លឺនៃមហាប្រទីប គឺសព្វញ្ញុតញ្ញាណ ដែលមិនមានវត្ថុណាមួយកម្ចាត់បានក្នុងទីទាំងពួង ជាអ្នកមានសិនេហៈ គឺមហាករុណា ផ្សាយទៅក្នុងជនទាំងអស់ ឲ្យរុងរឿងហើយ ដើម្បីកម្ចាត់នូវងងឹត គឺកិលេសដែលកប់ក្នុងហទយៈរបស់វេនេយ្យជន បានរុងរឿងអស់កាលយូរជាង ៥ ពាន់ឆ្នាំ ដោយការឈមចុះនៃសិនេហៈ ពង្រីកពាក្យអធិប្បាយព្រះសទ្ធម្មនោះ ដែលអនុគ្រោះនូវលោក ប្រហាក់ប្រហែល

នឹងព្រះសាស្តា ជាធម្មសេនាបតីរបស់ធម្មរាជាពោលទុក បានលើកឡើងកាន់សង្គីតិតាមដែលបានស្តាប់មកនោះឯងក្នុងគ្រាបឋមសង្គាយនា ។

បណ្តាបិដក ៣ គឺវិន័យបិដក សុត្តន្តបិដកនិងអភិធម្មបិដក មហានិទ្ទេសនេះ សង្គ្រោះក្នុងសុត្តន្តបិដក ។

បណ្តានិកាយធំ ៥ គឺទីឃនិកាយ មជ្ឈិមនិកាយ សំយុត្តនិកាយ អង្គុត្តរនិកាយ ខុទ្ទកនិកាយ មហានិទ្ទេស សង្គ្រោះក្នុងនិកាយធំ គឺខុទ្ទកនិកាយ ។

បណ្តាអង្គនៃសាសនៈ ៩ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានឥតិវុត្តកៈ ជាតក អព្ភូតធម៌ វេទល្លៈ លោកសង្គ្រោះមហានិទ្ទេសដោយអង្គ ២ គឺគាថានិងវេយ្យាករណៈតាមសមគួរ ។

លោកសង្គ្រោះមហានិទ្ទេសនេះ ចូលក្នុងព្រះធម្មក្ខន្ធច្រើនរយ ក្នុងចំនួនធម្មក្ខន្ធ ២ ពាន់ ដែលព្រះអានន្ទរៀនអំពីភិក្ខុក្នុងចំនួន ៨៤០០០ ព្រះធម្មក្ខន្ធដែលព្រះអានន្ទត្រេរជាឃ្លាំងធម៌បានទទួលនូវការសរសើរថា ជាឯតទគ្គៈ ៥ តំណែង ប្រជ្ញាថា

> ធម៌ទាំងឡាយនេះ ដែលប្រព្រឹត្តទៅមាន ៨៤០០០ ព្រះធម្មក្ខន្ធ
> ខ្ញុំ ( អានន្ទ ) រៀនអំពីព្រះសម្ពុទ្ធ ៨២០០០ ព្រះធម្មក្ខន្ធ រៀន
> អំពីភិក្ខុ ២០០០ ព្រះធម្មក្ខន្ធ ដូច្នេះ ។

មហានិទ្ទេសមាន ២ វគ្គ គឺអដ្ឋកវគ្គ បារាយនិកវគ្គ មួយអន្ទើដោយខគ្គវិសាណសូត្រ ។ មហានិទ្ទេសមាន ៣៣ សូត្រ មានកាមសូត្រជាដើម មានខគ្គវិសាណសូត្រជាទីបំផុត ចែកជាវគ្គ ១ វគ្គមាន ១៦ សូត្រ មួយ

អន្ទើដោយខគ្គវិសាណសូត្រ ខ្ញុំនឹងពណ៌នាអត្ថ តាមលំដាប់បទរបស់មហានិទ្ទេសនេះ ដែលលោកកំណត់ទុកច្រើនប្រការយ៉ាងនេះ ឯមហានិទ្ទេសនេះ ជាឧទ្ទេសនិងនិទ្ទេស ក៏គប្បីឧទ្ទេសគឺលើកឡើង និងនិទ្ទេសគឺការពោលដោយគោរព ទាំងដោយបាឋៈនិងអត្ថ ដែលអ្នកសិក្សាគប្បីរៀន គប្បីទ្រទ្រង់ចាំដោយគោរព សេចក្តីនោះ ព្រោះហេតុអ្វី ព្រោះមហានិទ្ទេសនេះ ជាគម្ពីរជ្រាលជ្រៅ និងដើម្បីឲ្យគម្ពីរមហានិទ្ទេសនេះ តាំងនៅក្នុងលោកអស់កាលយូរ ដើម្បីឧបការដល់សត្វលោក ក្នុងមហានិទ្ទេសនោះ កាមសូត្រជាសូត្រដំបូង ។ ក្នុងកាមសូត្រនោះ គាថាថា **កាមំ កាមយមានស្ស** ដូច្នេះ ជាគាថាទី ១ ការពណ៌នានោះ តាំងទុក ៣ ចំណែក គឺឧទ្ទេស ១ និទ្ទេស ១ បដិនិទ្ទេស ១ ។

# មហានិទ្ទេស

## អដ្ឋកថា អដ្ឋកវគ្គ

### កាមសុត្តនិទ្ទេស

[ ១ ] បទយ៉ាងនេះថា **កាមំ កាមយមានស្ស** ដូច្នេះជាដើម ឈ្មោះថា ឧទ្ទេស ។ បទថា **កាមាតិ ឧទ្ទានតោ ទ្វេ កាមា វត្ថុកាមា ច កិលេសកាមា ច** ដូច្នេះឈ្មោះថា និទ្ទេស ។ បទថា **កតមេ វត្ថុកាមា មនាបិកា រូបា** ដូច្នេះជាដើម ឈ្មោះថា បដិនិទ្ទេស ។

បណ្ដាបទទាំងនោះ បទថា **កាមំ** បានដល់ វត្ថុកាម ពោលគឺធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ មានរូបដែលជាទីពេញចិត្តជាដើម ។

បទថា **កាមយមានស្ស** បានដល់ ប្រាថ្នា ។ បទថា **តស្ស ចេ តំ សមិជ្ឈតិ** សេចក្ដីថា បើវត្ថុ ពោលគឺកាមនោះ សម្រេចដល់សត្វដែលប្រាថ្នានោះ លោកអធិប្បាយទុកថា បើសត្វនោះបានវត្ថុកាមនោះ ។

បទថា **អទ្ធា បីតិមនោ ហោតិ** សេចក្ដីថា រមែងជាអ្នកមានចិត្តត្រេកអរដោយចំណែកមួយ ។ បទថា **លទ្ធា** បានដល់ បានហើយ ។ បទថា **មច្ចោ** បានដល់ សត្វ គឺអ្នកជាប់ចំពាក់ ។

បទថា **យទិច្ឆតិ** សេចក្ដីថា ប្រាថ្នាកាមណា តែបទនេះ ត្រឹមតែភ្ជាប់អត្ថរបស់បទដោយសង្ខេបប៉ុណ្ណោះ ចំណែកសេចក្ដីពិស្ដារ គប្បីជ្រាបដោយន័យដែលមកក្នុងបាលីខាងលើនោះឯង ។ ក្នុងបទទាំងពួងបន្ទាប់អំពីនេះ ក៏ដូចក្នុងបទនេះឯង ។

[ ២ ] បទថា **កាមា** ជាឧទ្ទេសបទ គឺបទដែលលើកឡើងដើម្បីសម្តែង ។ បទថា **ឧទ្ទានតោ** ជានិទ្ទេសបទ ។ បទថា **ឧទ្ទានតោ** សេចក្តីថា ជាពួក ដូចក្នុងប្រយោគជាដើមថា **មច្ឆុទ្ទានំ ករេយ្យ** ចូរទិញនូវចង្កោមត្រីដូច្នេះ ។ ម្យ៉ាងទៀត ឈ្មោះថា **ឧទ្ទានតោ** ព្រោះឲ្យខ្ពស់ឡើង ដូចក្នុងប្រយោគជាដើមថា **ឧទ្ធុំសោធនតោ ព្យាធានដ្ឋេន វោធានំ វិយ** ផូរផង់ ព្រោះអត្ថថាស ជាពិសេសដោយជម្រះឲ្យខ្ពស់ឡើង ។ ឬថា ព្រោះមានហេតុពិសេស ។ បទថា **ឧទ្ទានតោ** លោកពោលលះពាក្យថា កាមទុក ។ បទថា **ទ្វេ** ជាការកំណត់ចំនួន ១ ក៏មិនមែន ៣ ក៏មិនមែន ។ បទថា **វត្ថុកាមា ច** បានដល់វត្ថុកាម មានរូបជាទីពេញចិត្តជាដើម និងកិលេសកាមដោយអត្ថថា ឲ្យក្តៅក្រហាយនិងដោយអត្ថថា បៀតបៀន ។

ក្នុងកាម ២ នោះ វត្ថុកាមគួរកំណត់ដឹង កិលេសកាមគួរលះ ។ ក្នុងកាមទាំង ២ នោះ បុគ្គលប្រាថ្នាវត្ថុកាមព្រោះកិលេសកាម ។ ឈ្មោះថាកាមព្រោះអត្ថថា ដែលបុគ្គលប្រាថ្នា កិលេសកាមឈ្មោះថាកាម ព្រោះអត្ថថា ជាហេតុឲ្យបុគ្គលប្រាថ្នា ដោយភាពជាហេតុឲ្យសង្ឃឹមវត្ថុកាម ។ ក្នុងកាម ២ នោះ វត្ថុកាម លោកសង្គ្រោះចូលក្នុងខន្ធ មានរូបជាដើម កិលេសកាម លោកសង្គ្រោះចូលក្នុងសង្ខារក្ខន្ធ វត្ថុកាមដឹងច្បាស់បានដោយវិញ្ញាណទាំង ៦ ។ កិលេសកាម ដឹងបានដោយមនោវិញ្ញាណ ។ ឈ្មោះថា វត្ថុកាម ព្រោះអត្ថថា ជាទីតាំងនៃកិលេសទាំងឡាយ ព្រោះអត្ថថា ជាហេតុនៃកិលេសទាំងឡាយ និងព្រោះអត្ថថា ជាអារម្មណ៍នៃកិលេសទាំងឡាយ ។

( សមដូចព្រះតម្រាស់ក្នុងអង្គុត្តរនិកាយឆក្កនិបាតថា )

សេចក្តីត្រេកអរកើតឡើង ដោយអំណាចការត្រិះរិះ ជាកាមរបស់បុរស អារម្មណ៍ដ៏វិចិត្រក្នុងលោក មិនមែនកាមទេ សេចក្តីត្រេកអរកើតឡើង ដោយអំណាចការត្រិះរិះ ជាកាមរបស់បុរស អារម្មណ៍ដ៏វិចិត្រទាំងឡាយ តែងឋិតនៅក្នុងលោកដោយប្រការ ដូច្នោះ តែអ្នកប្រាជ្ញទាំងឡាយ រមែងកម្ចាត់បង់នូវសេចក្តីគាប់ចិត្តក្នុងអារម្មណ៍ទាំងឡាយនុ៎ះចេញ ដូច្នេះ ។

ក្នុងសេចក្តីនេះ មានរឿងនន្ទមាណព និងបុត្តរបស់សោរេយ្យសេដ្ឋីជាដើម ជាឧទាហរណ៍ ។

កិលេសកាម ឈ្មោះថា កាម ព្រោះអត្ថថា ឲ្យប្រាថ្នាឯង ដោយអត្ថ គឺឲ្យក្តៅ ដោយអត្ថ គឺបៀតបៀន សមដូចព្រះតម្រាស់ត្រាស់ទុក ( ក្នុងអង្គុត្តរនិកាយតិកនិបាត ) ថា ម្នាលព្រាហ្មណ៍ បុគ្គលត្រេកអរ ដែលរាគៈគ្របសង្កត់ មានចិត្តប្រកាន់មាំ តែងគិតដើម្បីបៀតបៀនខ្លួនឯងខ្លះ គិតដើម្បីបៀតបៀនអ្នកដទៃខ្លះ គិតដើម្បីបៀតបៀនខ្លួនឯងនិងអ្នកដទៃខ្លះ ដូច្នេះ ។ និងពុទ្ធវចនៈមួយកន្លែងទៀតថា

ម្នាលព្រាហ្មណ៍ បុគ្គលត្រេកអរដែលរាគៈគ្របសង្កត់ ។បេ។ រមែងសម្លាប់នូវសត្វមានជីវិតខ្លះ កាន់យកនូវទ្រព្យដែលបុគ្គលដទៃមិនបានឲ្យខ្លះ គប់រកនូវភរិយាអ្នកដទៃខ្លះ និយាយកុហកខ្លះ ដូច្នេះ ។ ឧទាហរណ៍មានយ៉ាងនេះជាដើម ។ ព្រះសារីបុត្តត្ថេរ បំណងនឹងពោលមហានិទ្ទេសនោះឯងឲ្យពិស្តារ

*ដោយបដិនិទ្ទេស ទើបពោលពាក្យជាដើមថា* **កតមេ វត្ថុកាមា** *ដូច្នេះ ជាដើម ។*

*បណ្ដាបទទាំងនោះ បទថា* **កតមេ** *ជាកថេតុកម្យតាបុច្ឆា ។ សេចក្ដីពិតបុច្ឆាមាន ៥ យ៉ាង វិភាគនៃបុច្ឆាទាំងនោះ នឹងមានច្បាស់ក្នុងបាលីខាងមុខនោះឯង ។ បណ្ដាបុច្ឆា ៥ យ៉ាងនោះ នេះជាកថេតុកម្យតាបុច្ឆា ។*

*បណ្ដាបទទាំងនោះ បទថា* **មនាបិកា** *សេចក្ដីថា ឈ្មោះថា* **មនាបា** *ព្រោះអត្ថថា ញុំាងចិត្តឲ្យត្រេកអរ គឺឲ្យចម្រើន មនាបានោះឯងជាមនាបិកា ។*

*បទថា* **រូបា** *បានដល់ រូបារម្មណ៍ ដែលមានសមុដ្ឋាន ៤ គឺកម្ម ចិត្ត ឧតុ អាហារ ឈ្មោះថា រូប ព្រោះអត្ថថា បែកធ្លាយ អធិប្បាយថា កាលវណ្ណរូបប្រែប្រួលទៅ រមែងសម្ដែងដល់ហទយៈ ។*

*បណ្ដាវត្ថុកាមទាំងនោះ ឈ្មោះថា រូប ព្រោះអត្ថដូចម្ដេច ព្រោះអត្ថថា បែកធ្លាយ សមដូចព្រះដ៏មានព្រះភាគត្រាស់ទុក ( ក្នុងសំយុត្តនិកាយខន្ធវារវគ្គ ) ថា*

> *ម្នាលភិក្ខុទាំងឡាយ ចុះអ្នកទាំងឡាយហៅថា រូប តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយរបស់ណាវិនាស របស់នោះ ហៅថា រូប ។ ចុះវិនាសដោយអ្វី ។ វិនាសដោយត្រជាក់ក៏មាន វិនាសដោយក្ដៅក៏មាន វិនាសដោយឃ្លានក៏មាន វិនាសដោយស្រេកក៏មាន វិនាសដោយសម្ផស្សនៃរបោម មូស ខ្យល់និងកម្ដៅថ្ងៃ ពស់តូចពស់ធំក៏មាន ។ ម្នាលភិក្ខុទាំងឡាយ*

របស់ណាវិនាស របស់នោះ ហៅថា រូប ដូច្នេះ ។

បណ្តាពាក្យទាំងនោះ ពាក្យថា វិនាស សេចក្តីថា រមែងកម្រើក គឺរមែងញាប់ញ័រ ត្រូវបៀតបៀន បែកធ្លាយ ។ ការវិនាសដោយរងា ប្រាកដក្នុងលោកន្តរនរក ការរងាប្រាកដក្នុងប្រទេសដែលរងា ដែលមានសន្សើមធ្លាក់មានមហិស្សរដ្ឋជាដើម ក្នុងមហិស្សរដ្ឋជាដើមនោះ សត្វទាំងឡាយមានសរីរៈវិនាសព្រោះរងា គឺដល់នូវការស្លាប់ក៏មាន ។

ការបែកធ្លាយដោយការក្តៅ ប្រាកដក្នុងអវិចិមហានរក ។ ក្នុងអវិចិមហានរកនោះ សត្វទាំងឡាយសោយទុក្ខធំ ក្នុងកាលដែលត្រូវឲ្យដេកលើផែនដីដែកដែលក្តៅ ហើយត្រូវចងដោយចំណង ៥ ប្រការជាដើម ។

ការបែកធ្លាយដោយការស្រេក ប្រាកដក្នុងភូមិនៃប្រេត និងក្នុងពេលកើតទុព្ភិក្ខភ័យ ពួកសត្វក្នុងភូមិនៃប្រេត យកដៃចាប់ចំណីណាមួយដាក់ក្នុងមាត់មិនបាន អស់កាល ២-៣ ពុទ្ធន្តរ ខាងក្នុងពោះហាក់ដូចជាព្រន់ឈើដែលភ្លើងឆេះពេញ ក្នុងគ្រាដែលកើតទុព្ភិក្ខភ័យ ពួកសត្វមិនបានត្រឹមតែទឹកបាយដល់នូវការស្លាប់ប្រមាណមិនបាន ។ ការបែកធ្លាយដោយការស្រេក ប្រាកដក្នុងកំណើតកាឡកញ្ជិកាសូរៈជាដើម ។

ក្នុងកំណើតនោះ ពួកសត្វមិនអាចបានដំណក់ទឹកសូម្បីត្រឹមតែសើមហទយៈឬត្រឹមតែសើមអណ្តាត អស់ ២-៣ ពុទ្ធន្តរ កាលពួកសត្វទៅកាន់ស្ទឹងដោយគិតថា អញនឹងផឹកទឹក ទឹកក៏ក្លាយជាខ្សាច់ កាលស្ទុះទៅកាន់មហាសមុទ្ទ មហាសមុទ្ទក៏ក្លាយជាថ្មដា សត្វទាំងនោះស្គាំងស្គម ត្រូវសេចក្តីទុក្ខគ្របសង្កត់ ស្រែក

ថូរមិនដាច់ ។

ការវិនាសដោយរបោមជាដើម ប្រាកដក្នុងប្រទេសដែលច្រើនទៅដោយរបោមនិងរុយជាដើម ។ រូបនោះ លោកឲ្យពិស្តារហើយក្នុងអភិធម្ម ដោយន័យជាដើមថា រូបនោះដូចម្តេច គឺសនិទស្សនរូប សប្បដិឃរូប ដូច្នេះ ។ ឈ្មោះថា **សទ្ទា** ព្រោះអត្ថថា ធ្វើឲ្យបានឮ អធិប្បាយថា បន្លឺចេញ ។ សម្លេងមានសមុដ្ឋាន ២ គឺឧតុនិងចិត្ត ។ ឈ្មោះថា **គន្ធា** ព្រោះអត្ថថា ផ្សាយទៅ អធិប្បាយថា ប្រកាសទីលំនៅរបស់ខ្លួន ឈ្មោះថា **រសា** ព្រោះអត្ថថា ពួកសត្វជាប់ជំពាក់ អធិប្បាយថា ត្រេកអរ ។ ឈ្មោះថា **ផោដ្ឋព្វា** ព្រោះអត្ថថា ពាល់ត្រូវ ។ ក្លិន ជាដើមនេះ មានសមុដ្ឋាន ៤ ការបែកនៃសម្លេងជាដើមនោះ លោកឲ្យពិស្តារហើយក្នុងអភិធម្មនោះឯង ។ ព្រះសារីបុត្តត្ថេរ កាលសម្តែងសេចក្តីនោះដោយពិស្តារ ទើបពោលពាក្យជាដើមថា **អត្ថរណា ចាបុរណា** ដូច្នេះ ។

បណ្តាបទទាំងនោះ ដែលឈ្មោះថា **អត្ថរណា** ព្រោះអត្ថថា ក្រាលហើយដេក ។ ឈ្មោះថា **ចាបុរណា** ព្រោះអត្ថថា រុំព័ទ្ធសរីរៈ ទាសីផង ទាសាផង ឈ្មោះថា **ទាសីទាសា** មាន ៤ ប្រភេទ មានទាសៈដែលកើតក្នុងផ្ទះជាដើម ទីដែលដុះឡើងនៃបុព្វណ្ណជាតិ ឈ្មោះថា **ខេត្តំ** ។ ទីដែលដុះឡើងនៃអបរណ្ណជាតិ ឈ្មោះថា **វត្ថុ** ។ ម្យ៉ាងទៀត ទីដែលដុះឡើងនៃបុព្វណ្ណជាតិនិងអបរណ្ណជាតិទាំងពីរ ឈ្មោះថា **ខេត្តំ** ដីដែលមិនបានធ្វើប្រយោជន៍យ៉ាងនោះ ឈ្មោះថា **វត្ថុ** ។ ម្យ៉ាងទៀត ក្នុងទីនេះ បឹងនិងស្រះជាដើម ក៏លោកសង្គ្រោះដោយ

មាតិកា គឺខេត្តនិងវត្ថុ ។

បទថា **ហិរញ្ញំ** បានដល់ កហាបណៈ ។ បទថា **សុវណ្ណំ** បានដល់ មាស ។ មាសកៈគ្រប់យ៉ាង គឺមាសកលោហៈ មាសកជ័រ មាសកឈើ ក៏សង្គ្រោះចូលដោយសព្ទថា **ហិរញ្ញ** និង **សុវណ្ណ** ទាំងនោះ ។

បទថា **គាមនិគមរាជធានិយោ** សេចក្ដីថា ផ្ទះមួយខ្នងជាដើម ឈ្មោះថាគាម ទីដែលមានផ្សារ ឈ្មោះថានិគម ទីដែលជាអាណាខេត្តរបស់ព្រះរាជាមួយអង្គ ឈ្មោះថារាជធានី ។ ជនបទឯកទេស ១ ឈ្មោះថា **រដ្ឋំ** ចំណែកមួយនៃជនបទកាសីនិងជនបទកោសលជាដើម ឈ្មោះថា **ជនបទោ** ។

បទថា **កោសោ** បានដល់ កងពលអ្នកចម្បាំង ៤ ពួក គឺពលដំរី ពលសេះ ពលរថ ពលថ្មើរជើង ។ បទថា **កោដ្ឋាគារំ** បានដល់ ផ្ទះ គឺឃ្លាំង ៣ យ៉ាង មានឃ្លាំងទ្រព្យ ឃ្លាំងស្រូវនិងឃ្លាំងសំពត់ ។ បទថា **យំកិញ្ចិ** ជាពាក្យកំណត់ថា មិនមានអ្វីសេសសល់ ។ បទថា **រជនីយំ** ដោយអត្ថថា គួរត្រេកអរ ។ បន្ទាប់អំពីនោះ ព្រះសារីបុត្តត្ថេរ ដើម្បីសម្ដែងជាតិកៈ ទើបពោលតិកៈ ៦ គឺអតីតតិកៈ អជ្ឈត្តតិកៈ ហីនតិកៈ ឱកាសតិកៈ បយោគតិកៈ និងកាមាវចរតិកៈ ។

បណ្ដាតិកៈទាំងនោះ គប្បីជ្រាបវិនិច្ឆ័យក្នុងអតីតតិកៈមុន ។ ឈ្មោះថា **អតីតា** ព្រោះអត្ថថា ដល់សភាវៈរបស់ខ្លួន ឬខណៈមានឧប្បាទៈជាដើមហើយកន្លងទៅ ។ ឈ្មោះថា **អនាគតា** ព្រោះអត្ថថា មិនទាន់មកដល់ទាំងពីរយ៉ាងនោះ ។ ឈ្មោះថា **បច្ចុប្បន្នា** ព្រោះអត្ថថា អាស្រ័យ ហេតុការណ៍នោះៗ

កើតឡើង ។ បទនេះ លោកកំណត់ដោយភព ដ្បិតថា ចាប់តាំងពីបដិសន្ធិ កាមដែលកើតក្នុងអតីតភពក្តី ក្នុងភពដែលជាប់តគ្នាក្តី ឬក្នុងទីបំផុតនៃសែនកោដិកប្បក្តី ទាំងអស់ឈ្មោះថា កាមដែលជាអតីតៈទាំងអស់ ។ ចាប់តាំងពីចុតិ កាមដែលកើតក្នុងភពអនាគត កំពុងកើតក្នុងភពជាប់តគ្នាក្តី ក្នុងទីបំផុតសែនកោដិកប្បក្តី ទាំងអស់ឈ្មោះថា កាមដែលជាអនាគតទាំងអស់ កាមដែលប្រព្រឹត្តទៅបន្ទាប់អំពីចុតិបដិសន្ធិ ឈ្មោះថា កាមដែលជាបច្ចុប្បន្ន ។

ក្នុងអជ្ឈត្តតិកៈ មានវិនិច្ឆ័យថា កាម ចំពោះបុគ្គលដែលប្រព្រឹត្តទៅយ៉ាងនេះ គឺប្រព្រឹត្តទៅធ្វើខ្លួនជាធំ បានដល់ ប្រព្រឹត្តទៅក្នុងរបស់ខ្លួន ដោយបំណងដូចជាបំណងថា ពួកយើងនឹងប្រកាន់ថាខ្លួន ឈ្មោះថា អជ្ឈត្តតិកៈ ។ ចំណែកដែលជាខាងក្រៅអំពីនោះ ទាក់ទងដោយឥន្ទ្រិយក្តី មិនទាក់ទងដោយឥន្ទ្រិយក្តី ឈ្មោះថា ពហិទ្ធ ។ បទទី ៣ លោកពោលដោយអំណាចនៃបទទាំងពីរនោះ ។

ក្នុងហីនតិកៈ មានវិនិច្ឆ័យថា បទថា **ហីនា** បានដល់ ថោកថយ ។ បទថា **មជ្ឈិមា** សេចក្តីថា ឈ្មោះថា មជ្ឈិមា ព្រោះអត្ថថា ជាកណ្តាលនៃកាមប្រភេទថោកទាបនិងកាមប្រភេទប្រណីត កាមដ៏សេស ឈ្មោះថា ប្រណីត ព្រោះអត្ថថា ឧត្តម ។

ម្យ៉ាងទៀត គប្បីជ្រាបថា ជាប្រភេទថោកទាប ប្រភេទកណ្តាល ប្រភេទប្រណីតដោយប្រៀបធៀបគ្នា មែនពិត កាមរបស់ពួកសត្វនរក ឈ្មោះថា អាក្រក់បំផុត ។ បើប្រៀបធៀបសត្វនរកទាំងនោះ កាមរបស់នាគនិងគ្រុឌទាំង

ឡាយក្នុងតិរច្ឆានទាំងឡាយ ឈ្មោះថា ប្រណីត កាមរបស់តិរច្ឆានដ៏សេស ឈ្មោះ ថាជាកណ្ដាល សូម្បីកាមរបស់តិរច្ឆានទាំងនោះ ក៏ឈ្មោះថា ថោក ថយ ។ បើប្រៀបធៀបតិរច្ឆានទាំងនោះ កាមរបស់ប្រេត ដែលមានសក្តិធំ ឈ្មោះថា ប្រណីត កាមរបស់ពួកប្រេតដ៏សេស ឈ្មោះថា កណ្ដាល សូម្បី កាមរបស់ប្រេតទាំងនោះ ក៏ឈ្មោះថាអាក្រក់ ។ កាលប្រៀបធៀបប្រេតទាំង នោះ កាមរបស់អ្នកជនបទឈ្មោះថា ប្រណីត កាមរបស់អ្នកជាយដែន ឈ្មោះថា កណ្ដាល កាមរបស់ពួកជនទាំងឡាយនោះ ឈ្មោះថា អាក្រក់ ។ បើប្រៀប ធៀបពួកគេទាំងនោះ កាមរបស់ពួកមេស្រុក ឈ្មោះថា ប្រណីត កាមរបស់ អ្នកបម្រើរបស់មេស្រុកទាំងនោះ ឈ្មោះថា ជាកណ្ដាល កាមរបស់ពួកគេទាំង នោះ ឈ្មោះថា អាក្រក់ ។ បើប្រៀបធៀបពួកគេទាំងនោះ កាមរបស់ពួក អ្នកគ្រប់គ្រងជនបទ ឈ្មោះថាប្រណីត កាមរបស់ពួកអ្នកបម្រើរបស់អ្នកគ្រប់ គ្រងជនបទទាំងនោះ ឈ្មោះថា កណ្ដាល កាមរបស់ពួកគេទាំងនោះ ក៏ឈ្មោះ ថា អាក្រក់ ។ បើប្រៀបធៀបពួកគេទាំងនោះ កាមរបស់ពួកស្ដេចបទេសរាជ ឈ្មោះថា ប្រណីត កាមរបស់ពួកអាមាត្យ ឈ្មោះថា កណ្ដាល កាមរបស់ពួក ជនទាំងនោះ ក៏ឈ្មោះថា ថោកទាប ។ បើប្រៀបធៀបពួកគេទាំងនោះ កាម របស់ស្ដេចចក្កពត្តិឈ្មោះថា ប្រណីត កាមរបស់ពួកអាមាត្យឈ្មោះថា កណ្ដាល កាមសូម្បីរបស់ស្ដេចចក្រពត្តិ ក៏ឈ្មោះថា អាក្រក់ ។ កាលប្រៀបធៀបពួក គេទាំងនោះ កាមពួកកុម្មទេវតា ឈ្មោះថា ប្រណីត កាមរបស់ពួកទេវតាអ្នក បម្រើរបស់កុម្មទេវតាទាំងនោះ ឈ្មោះថា កណ្ដាល សូម្បីកាមរបស់កុម្មទេវតា

ទាំងនោះ ក៏ឈ្មោះថា ថោកថយ ។ បើប្រៀបធៀប កុម្មទេវតាទាំងនោះ កាមរបស់ទេវតាជាន់ចាតុម្មហារាជិកា ឈ្មោះថា ប្រណីត រហូតដល់កាមរបស់ពួកទេវតាជាន់អកនិដ្ឋកៈ ឈ្មោះថា ប្រណីតបំផុត ដោយន័យជាដើមដូច្នេះ ។ គប្បីជ្រាបកាមប្រភេទថោកទាប ប្រភេទកណ្តាលនិងប្រភេទប្រណីត ដោយប្រៀបធៀបដោយប្រការដូច្នេះ ។

ក្នុងឱកាសតិកៈ មានវិនិច្ឆ័យថា បទថា **អាបាយិកា កាមា** សេចក្តីថា កាមរបស់សត្វដែលកើតក្នុងអបាយ ៤ ដែលប្រាសចាកសេចក្តីចម្រើន ពោលគឺមិនចម្រើន ឈ្មោះថា **អាបាយិកា** ។ កាមរបស់សត្វដែលកើតក្នុងពួកមនុស្ស ឈ្មោះថា **មានុសិកា** ។ កាមរបស់សត្វដែលកើតក្នុងពួកទេវតា ឈ្មោះថា **ទិព្វា** ។

ក្នុងបយោគតិកៈ មានវិនិច្ឆ័យថា កាមរបស់ពួកសត្វក្នុងអបាយដ៏សេសក្រៅអំពីពួកសត្វនរក របស់ពួកមនុស្ស និងរបស់ពួកទេវតា តាំងអំពីជាន់ចាតុម្មហារាជិកា រហូតដល់ពួកទេវតាជាន់តុសិត ឈ្មោះថា **បច្ចុបដ្ឋិតា កាមា** ព្រោះបរិភោគកាមទាំងឡាយដែលប្រាកដចំពោះមុខ ។

ទេវតាទាំងឡាយ ក្នុងពេលដែលត្រូវការនិងត្រេកអរដោយអារម្មណ៍ដែលប្រសើរជាងអារម្មណ៍ ដែលតាក់តែងទុកតាមប្រក្រតី រមែងនិម្មិតអារម្មណ៍តាមដែលគាប់ចិត្តហើយត្រេកអរ ហេតុនោះ កាមរបស់ពួកទេវតាជាន់និម្មានរតី ទើបឈ្មោះថា **និម្មិតា កាមា** ។

ទេវតាទាំងឡាយ រមែងសេពអារម្មណ៍ដែលទេវតាដទៃដឹងអធ្យាស្រ័យ

របស់ខ្លួននិម្មិតឲ្យ ព្រោះហេតុនោះ កាមរបស់ពួកទេវតាជាន់បរនិម្មិតវសវត្តី ទើបឈ្មោះថា **បរនិម្មិតា កាមា** ។

បទថា **បរិគ្គហិតា** បានដល់ កាមដែលហួងហែងថា នុ៎ះរបស់អញ ។ បទថា **អបរិគ្គហិតា** បានដល់ កាមរបស់អ្នកឧត្តរកុរុទ្វីប ដែលមិនបានហួងហែងយ៉ាងនោះ ។

បទថា **មមាយិតា** បានដល់ ដែលប្រកាន់ថា នុ៎ះរបស់អញដោយអំណាចតណ្ហា ។ បទថា **អមមាយិតា** បានដល់ ដែលផ្ទុយគ្នាតាមដែលពោលហើយ ។ បទថា **សព្វេបិ កាមាវចរា ធម្មា** សេចក្តីថា ធម៌ដែលទាក់ទងក្នុងកាមាវចរធម៌ ដែលពោលទុកដោយន័យជាដើមថា ដោយខាងក្រោម ធ្វើនរកអវីចិឲ្យជាទីបំផុត ។ ក្នុងសេចក្តីនោះ មានអត្ថនៃពាក្យដូចតទៅនេះថា កាមដោយសង្ខេបមាន ២ គឺវត្ថុកាម ១ កិលេសកាម ១ ។

ក្នុង ២ យ៉ាងនោះ កិលេសកាម ដោយអត្ថ បានដល់ ឆន្ទរាគៈ វត្ថុកាម បានដល់ វដ្តៈ ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។ ម្យ៉ាងទៀត កិលេសកាម ឈ្មោះថា កាម ព្រោះអត្ថថា ជាទីប្រាថ្នា ។ វត្ថុកាមក្រៅអំពីនេះ ឈ្មោះថា កាម ព្រោះអត្ថថា ដែលសត្វរមែងប្រាថ្នា ។ ភូមិជាទីត្រាច់ទៅនៃកាមទាំងពីរនោះ មាន ១១ ភូមិ គឺអបាយភូមិ ៤ មនុស្សភូមិ ១ ទេវភូមិ ៦ ។

ឈ្មោះថាកាមាវចរ ព្រោះអត្ថថា ជាទីត្រាច់ទៅនៃកាម ។ លោកពោលថា **សព្វេបិ កាមាវចរា ធម្មា** ក្នុងទីនោះ សំដៅយកធម៌ដែលទាក់ទងគ្នា ។ ឈ្មោះថា ធម៌ ព្រោះអត្ថថា ទ្រទ្រង់ទុកនូវសភាវៈរបស់ខ្លួន ។

បទថា **រូបាវចរា ធម្មា** សេចក្តីថា ធម៌ទាំងអស់ ជារូបាវចរធម៌ដោយអំណាចនៃរូបាវចរធម៌ ដែលពោលទុកដោយន័យជាដើមថា ខាងក្រោមមានព្រហ្មលោកជាទីបំផុត ។

បទថា **អរូបាវចរា ធម្មា** សេចក្តីថា ធម៌ទាំងអស់ដែលពោលទុកដោយន័យជាដើមថា ខាងក្រោមចាប់ពីពួកទេវតាដែលចូលដល់អាកាសានញ្ចាយតនៈ ដូច្នេះ ជាអរូបាវចរធម៌ ។

បណ្តាធម៌ ២ យ៉ាងនោះ ឈ្មោះថា រូបាវចរធម៌ ព្រោះអត្ថថា អន្ទោលទៅក្នុងរូបភព ។ ឈ្មោះថា អរូបាវចរធម៌ ព្រោះអត្ថថា អន្ទោលទៅក្នុងអរូបភព ។

បទថា **តណ្ហាវត្ថុកា** សេចក្តីថា ជាទីតាំងនៃតណ្ហា ព្រោះអត្ថថា ជាទីតាំងនិងព្រោះអត្ថថា ជាហេតុ ។

បទថា **តណ្ហារម្មណា** សេចក្តីថា ជាអារម្មណ៍នៃតណ្ហា ដោយអំណាចនៃការប្រព្រឹត្តទៅនៃតណ្ហា ហួងហែងនូវធម៌ទាំងនោះ ។

បទថា **កាមនីយដ្ឋេន** បានដល់ ព្រោះអត្ថថា គប្បីសង្ឃឹមចំពោះ ។ បទថា **រជនីយដ្ឋេន** បានដល់ ព្រោះអត្ថថា គួរត្រេកអរ ។ បទថា **មទនីយដ្ឋេន** ព្រោះអត្ថថា ជាទីកើតឡើងនៃការស្រវឹង មានការស្រវឹងត្រកូលជាដើម ។

ក្នុងនិទ្ទេសនេះ ព្រះសារីបុត្តត្ថេរពោលពាក្យជាដើមថា **កតមេ វត្ថុកាមា មនាបិកា រូបា** ហើយពោលពាក្យចុងក្រោយថា **យំកិញ្ចិ រជនីយវត្ថុ** ដូច្នេះ ពោលដល់ទាំងវត្ថុដែលមានវិញ្ញាណនិងមិនមានវិញ្ញាណ ពាក្យដ៏សេសគប្បី

*ជ្រាបថាតិក: ៦ ដែលលើសទៅទៀត ៤ ពួក មួយពួក ។ ព្រះសារីបុត្តត្ថេរ សម្តែងវត្ថុកាមយ៉ាងនោះហើយ ដើម្បីសម្តែងកិលេសកាម ទើបពោលពាក្យជាដើមថា* **ករតមេ កិលេសកាមា** *ដូច្នេះ ។*

*បណ្តាបទទាំងនោះ បទថា* **ឆន្ទោ** *បានដល់ តម្រេកយ៉ាងទន់ ។ បទថា* **រាគោ** *បានដល់ តម្រេកដែលខ្លាំងក្លាជាងការពេញចិត្តនោះ ។ តម្រេកទាំង ៣ តទៅ មានកម្លាំងខ្លាំងក្លាជាងតម្រេកទាំងនេះ ។ បទថា* **កាមេសុ** *បានដល់ ក្នុងកាមគុណ ៥ ។*

*បទថា* **កាមច្ឆន្ទោ** *បានដល់ ការពេញចិត្ត ពោលគឺការប្រាថ្នា មិនមែនប្រាថ្នាដើម្បីធ្វើការងារ មិនមែនប្រាថ្នាក្នុងធម៌ ។ តម្រេក គឺកាមដោយអំណាចនៃការប្រាថ្នានិងដោយអំណាចការត្រេកអរ ឈ្មោះថា* **កាមរាគោ** *។*

*ការត្រេកអរ គឺកាម ដោយអំណាចនៃសេចក្តីប្រាថ្នានិងដោយអំណាចនៃការត្រេកអរ ដូច្នោះទើបឈ្មោះថា* **កាមនន្ទិ** *។ ក្នុងបទទាំងពួង គប្បីជ្រាបយ៉ាងនេះ ។*

*ឈ្មោះថា* **កាមតណ្ហា** *ព្រោះអត្ថថា ដឹងប្រយោជន៍របស់កាម ហើយទើបប្រាថ្នា ។ ឈ្មោះថា* **កាមស្នេហោ** *ព្រោះអត្ថថា ទាញឲ្យស្រឡាញ់ ។ ឈ្មោះថា* **កាមបរិឡាហោ** *ព្រោះអត្ថថា ក្តៅក្រហាយ ។ ឈ្មោះថា* **កាមមុច្ឆា** *ព្រោះអត្ថថា ងប់ជ្រប់ ។ ឈ្មោះថា* **កាមជ្ឈោសានំ** *ព្រោះអត្ថថា លេបត្របាក់សម្រេច ។ ឈ្មោះថា* **កាមោឃោ** *ព្រោះអត្ថថា លិចលង់ គឺលិចចុះក្នុងវដ្ត: ។ ឈ្មោះថា* **កាមយោគោ** *ព្រោះអត្ថថា ប្រកបសត្វទុកក្នុងវដ្ត: ។*

ការប្រកាន់មាំដោយតណ្ហានិងទិដ្ឋិយ៉ាងមាំ ឈ្មោះថា **ឧទានាធំ** ។ ឈ្មោះថា **នីវរណំ** ព្រោះអត្ថថា រារាំងនូវចិត្ត គឺរិតរុំនូវចិត្ត ។ បទថា **អទ្ទសំ** បានដល់ បានឃើញហើយ ។ បទថា **កាម** ជាអាលបនៈ ។ បទថា **តេ** បានដល់ របស់អ្នក ។ បទថា **មូលំ** បានដល់ ទីតាំង ។ បទថា **សង្កប្បា** ប្រែថា ព្រោះការត្រិះរិះ ។ បទថា **ន តំ សង្កប្បយិស្សាមិ** សេចក្តីថា មិនធ្វើនូវការត្រិះរិះដល់អ្នក ។ បទថា **ន ហោហិសិ** ប្រែថា នឹងមិនមាន ។ បទថា **ឥច្ឆមានស្ស** បានដល់ សង្ឃឹមចំពោះ ។ បទថា **សាទិយមានស្ស** បានដល់ ពេញចិត្ត ។ បទថា **បត្ថយមានស្ស** បានដល់ ញុំាងសេចក្តីប្រាថ្នាឲ្យកើតឡើង ។ បទថា **បិហាយមានស្ស** បានដល់ ញុំាងនូវការចង់បានដើម្បីនឹងសម្រេចឲ្យកើតឡើង ។ បទថា **អភិជប្បមានស្ស** បានដល់ មិនឲ្យកើតនូវការផ្អែតដោយអំណាចតណ្ហា ។

[ ៣ ] ម្យ៉ាងទៀត កាលព្រះសារីបុត្តត្ថេរពោល លោកពោលបទថា **ខត្តិយស្ស វា** ជាដើម ដោយអំណាចនៃជាតិ ៤ ។ ពោលបទថា **គហដ្ឋស្ស វា បព្វជិតស្ស វា** ដោយអំណាចនៃភេទ ។

ពោលបទថា **ទេវស្ស វា មនុស្សស្ស វា** ដោយអំណាចនៃកំណើត ។ បទថា **ឥជ្ឈតិ** បានដល់ រមែងសម្រេច ។ បទថា **សមិជ្ឈតិ** បានដល់ រមែងសម្រេចដោយប្រពៃ គឺរមែងសម្រេចដោយអំណាចនៃការបានចំពោះនូវរូបវិសេស ។ រមែងបានដោយអំណាចនៃការបានចំពោះនូវរូបដែលគួរមើល ។ រមែងបានចំពោះ ដោយអំណាចនៃការបានចំពោះនូវរូបដែលគួរជ្រះថ្លា ។ រមែង

បានស៊ប់ដោយអំណាចនៃការបានចំពោះនូវរូបមានសណ្ឋានល្អ ។ រមែងប្រទះដោយអំណាចនៃការបានចំពោះនូវរូប ដែលមានពណ៌សម្បុរគួរជ្រះថ្លា ។ម្យ៉ាងទៀត រមែងសម្រេចដោយភាពជាបុគ្គលធំដោយការស្អាតដ៏ក្រៃលែង រមែងបានដោយភាពជាបុគ្គលធំក្រៃលែងដោយជាតិ រមែងបានចំពោះដោយភាពជាធំក្រៃលែងដោយភាពជាធំ ។ រមែងបានស៊ប់ដោយភាពជាបុគ្គលធំក្រៃលែងដោយសេចក្ដីសុខ ។ រមែងប្រទះដោយភាពជាបុគ្គលធំក្រៃលែងដោយសម្បត្តិដូច្នេះឯង ។

[ ៤ ] បទថា **ឯកំសវចនំ** បានដល់ ជាពាក្យពោលដោយចំណែកមួយហាមនូវការកាន់យកច្រើនចំណែក ដូចក្នុងប្រយោគជាដើមថា **ឯកំសំ ឧត្តរាសង្គំ ករិត្វា** ធ្វើឧត្តរាសង្គ ( ចីវរ ) ឆៀងស្មាម្ខាង **ឯកំសព្យាករណីយោ បញ្ហោ** ប្រស្នាដែលគួរឆ្លើយទៅតែម្ដង ដូច្នេះ ។

បទថា **និស្សំសយវចនំ** បានដល់ ជាពាក្យវៀរចាកសេចក្ដីសង្ស័យអធិប្បាយថា ជាពាក្យហាមនូវការសន្និះសង្ស័យ ។

បទថា **និក្កង្ខវចនំ** បានដល់ ជាពាក្យហាមនូវសេចក្ដីរង្កៀសថា នេះដូចម្ដេចហ្ន៎ នេះដូចម្ដេចហ្ន៎ ។

បទថា **អទ្វេជ្ឈវចនំ** បានដល់ ជាពាក្យពោលមិនជាពីរចំណែក ព្រោះមិនមានភាពជាពីរចំណែកនោះ គឺវៀរចាកភាពជាពីរចំណែក ហាមសេចក្ដីសង្ស័យ ដូចក្នុងប្រយោគជាដើមថា **អទ្វេជ្ឈវចនា ពុទ្ធា** ធម្មតាព្រះពុទ្ធទាំងឡាយ មិនដែលមានព្រះពុទ្ធដីកាបែកជាពីរទេ ដូច្នេះ ។

បទថា **អទ្វេជ្ឈការវចនំ** បានដល់ ជាពាក្យពោលមិនពីរយ៉ាង ព្រោះមិនមានហទយៈ ២ ជាពាក្យពោលហាមនូវភាពជាពីរយ៉ាងថា បានឮមកថា បានឮមកថា ។

បទថា **និយោគវចនំ** សេចក្តីថា ឈ្មោះថាជាពាក្យពោលមិនរួមគ្នា ព្រោះអត្ថថា មិនប្រកបពីររឿងទុកក្នុងសេចក្តីតែមួយ គឺហាមនូវពាក្យដែលមានកំណួចពីរ ក៏ព្រោះមិនប្រកបក្នុងរឿងដទៃ ទើបជាពាក្យដែលមកថា មិនមានអារម្មណ៍អនាគត ។

បទថា **អបណ្ណកវចនំ** បានដល់ ជាពាក្យពោលដែលមានសារៈ វៀរចាកការពោលផ្តេសផ្តាស ជាពាក្យពោលដែលមានហេតុមិនខុស ទើបឈ្មោះថា មិនខុស ដូចក្នុងប្រយោគជាដើមថា **អបណ្ណកំ ឋានមេកេ** បុគ្គលពួកខ្លះជាបណ្ឌិត រមែងប្រកាន់ហេតុដែលមិនខុស ដូច្នេះ ជាពាក្យពោលមានគោលដូចហេតុនៃការធ្វើដែលមិនខុស ។

បទថា **អវត្ថាបនវចនមេតំ** សេចក្តីថា ពាក្យនេះ ជាពាក្យឈមចុះ គឺជាពាក្យកំណត់ពិតប្រាកដ ។ ពាក្យទាំងឡាយណាដែលព្រះសារីបុត្តត្ថេរលើកឡើងចែកទុកក្នុងមហានិទ្ទេសនេះ ពាក្យទាំងនោះ កាលដល់នូវការចែក រមែងដល់នូវការចែកដោយហេតុ ៣ ប្រការ ។ កាលបើផ្សេងៗគ្នា រមែងផ្សេងៗគ្នាដោយហេតុ ៤ ប្រការ ។ ឯការសម្តែងដោយន័យដទៃ ក្នុងមហានិទ្ទេសនេះ មាន ២ បែប ២ បែបគឺអ្វី គឺពាក្យទាំងនោះ រមែងដល់នូវការចែកដោយហេតុ ៣ ប្រការ គឺចែកដោយព្យញ្ជនៈ ១ ឧបសគ្គ ១ អត្ថ ១ ។

*ក្នុងការចែកនោះ គប្បីជ្រាបការចែកដោយព្យញ្ជនៈយ៉ាងនេះថា សេចក្ដីក្រោធ ( **កោធោ** ) កិរិយាដែលក្រោធ ( **កុជ្ឈនា** ) ភាពជាអ្នកក្រោធ ( **កុជ្ឈិតត្តំ** ) ការប្រទូស្ត ( **ទោសោ** ) កិរិយាដែលប្រទូស្ត ( **ទុស្សនា** ) ភាពជាអ្នកប្រទូស្ត ( **ទុស្សិតត្តំ** ) ក្នុងការចែកនេះ សេចក្ដីក្រោធតែម្យ៉ាងប៉ុណ្ណោះ ដល់នូវការចែកជាពួកមួយដោយអំណាចព្យញ្ជនៈ ។ ម្យ៉ាងទៀត គប្បីជ្រាបការដល់នូវការចែក ដោយឧបសគ្គយ៉ាងនេះថា សម្រេច ( **ឥជ្ឈតិ** ) ស្រេចបាច់ ( **សមិជ្ឈតិ** ) បាន ( **លភតិ** ) បានចំពោះ ( **បដិលភតិ** ) បានស៊ប់ ( **អធិគច្ឆតិ** ) ។ គប្បីជ្រាបការដល់នូវការចែកដោយអត្ថយ៉ាងនេះថា ភាពជាបណ្ឌិត ( **បណ្ឌិច្ចំ** ) ភាពជាអ្នកឈ្លាស ( **កោសល្លំ** ) ការដឹង ( **នេបញ្ញំ** ) បញ្ញាជាគ្រឿងចែក ( **វេភព្យា** ) ការគិត ( **ចិន្តា** ) ការស្ទាបស្ទង់ ( **ឧបបរិក្ខា** ) ។*

*បណ្ដាបទទាំងនោះ ក្នុងនិទ្ទេសនៃបីតិបទ រមែងបាននូវការចែក ៣ យ៉ាងនេះជាមុន ។ បទថា **បីតិ** និង **ចាមុជ្ជំ** ជាការចែកដោយព្យញ្ជនៈ ។ បទថា **អាមោទនា បមោទនា ហាសោ បហាសោ** ជាការចែកដោយឧបសគ្គ ។ បទថា **វិត្តិ តុដ្ឋិ ឱទគ្យំ អត្តមនតា** ជាការចែកដោយអត្ថ ។ គប្បីជ្រាបដល់ការចែកក្នុងនិទ្ទេសនៃបទទាំងអស់ដោយន័យនេះ ។ បទទាំងឡាយកាលបើផ្សេងៗគ្នា ក៏ជាការផ្សេងៗគ្នាដោយហេតុ ៤ ប្រការទាំងនេះ គឺដោយការផ្សេងគ្នាដោយឈ្មោះ ១ ដោយការផ្សេងគ្នាដោយលក្ខណៈ ១ ដោយការផ្សេងគ្នាដោយកិច្ច ១ ដោយការផ្សេងគ្នាដោយភាពផ្ទុយគ្នា ១ ។ បណ្ដាការផ្សេងគ្នា ៤ យ៉ាងនោះ គប្បីជ្រាបការផ្សេងគ្នាដោយឈ្មោះយ៉ាងនេះថា*

ធម៌ ២ ប្រការនេះ គឺការព្យាបាទ ឬការប្រទូស្ត ក៏ដូចគ្នានិងសេចក្តីក្រោធ នោះឯង ដូចក្នុងប្រយោគថា ព្យាបាទកើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីខឹង ការប្រទូស្ត... ។ ធម៌ទាំងនោះ ដល់នូវការផ្សេងគ្នាដោយឈ្មោះ ។ ខន្ធ ៥ ជាខន្ធមួយនោះឯង ដោយអត្ថថា គំនរ តែក្នុងទីនេះ ខន្ធ ៥ រមែង ផ្សេងគ្នាដោយលក្ខណៈនេះ គឺរូប មានការបែកធ្លាយទៅជាលក្ខណៈ វេទនា មានការសោយអារម្មណ៍ជាលក្ខណៈ សញ្ញាមានការចាំបានជាលក្ខណៈ ចេតនា មានការផ្តោតចិត្តជាលក្ខណៈ វិញ្ញាណមានការដឹងច្បាស់ជាលក្ខណៈ គប្បី ជ្រាបការផ្សេងគ្នាដោយលក្ខណៈយ៉ាងនេះ ។

សេចក្តីព្យាយាមតែមួយ៉ាងប៉ុណ្ណោះ មកក្នុងឋានៈ ៤ យ៉ាង ដោយការ ផ្សេងគ្នាដោយកិច្ចថា សម្មប្បធានមាន ៤ ប្រការ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ក្នុងសាសនានេះ ញុំាងឆន្ទៈឲ្យកើត ប្រឹងប្រែងប្រារព្ធនូវការព្យាយាមផ្គងនូវ ចិត្តទុក តាំងព្យាយាមមាំ ដើម្បីញុំាងធម៌ទាំងឡាយជាអកុសលដ៏លាមកដែល មិនទាន់កើតឡើង មិនឲ្យកើតឡើងបាន ដូច្នេះជាដើម គប្បីជ្រាបការផ្សេង គ្នាដោយកិច្ចយ៉ាងនេះ ។ គប្បីជ្រាបការផ្សេងគ្នាដោយការផ្ទុយគ្នា ក្នុងបទ ជាដើមយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ អសទ្ធម្មទាំងឡាយនេះមាន ៤ យ៉ាង ។ អសទ្ធម្ម ៤ យ៉ាង តើដូចម្តេចខ្លះ ។ គឺភាពនៃបុគ្គលជាអ្នកធ្ងន់ក្នុងសេចក្តី ក្រោធ មិនធ្ងន់ក្នុងព្រះសទ្ធម្ម ១ ភាពនៃបុគ្គលជាអ្នកធ្ងន់ក្នុងសេចក្តីលុបគុណ មិនធ្ងន់ក្នុងព្រះសទ្ធម្ម ១ ភាពនៃបុគ្គលជាអ្នកធ្ងន់ក្នុងលាភ មិនធ្ងន់ក្នុងព្រះ សទ្ធម្ម ១ ភាពនៃបុគ្គលជាអ្នកធ្ងន់ក្នុងសក្ការៈ មិនធ្ងន់ក្នុងព្រះសទ្ធម្ម ១ ដូច្នេះ ។

ការផ្សេងគ្នា ៤ យ៉ាងនេះ មិនមានក្នុងបីតិឡើយ ។ ការផ្សេងគ្នា ៤ យ៉ាង ក្នុងបទទាំងពួង ក៏រមែងបានតាមដែលមាន ។ បទថា **បីតិ** ជាឈ្មោះរបស់បីតិ ។ បទថា **ចិត្តំ** ជាឈ្មោះរបស់ចិត្ត ។ បីតិ មានការផ្សាយទៅជាលក្ខណៈ វេទនាមានការសោយអារម្មណ៍ជាលក្ខណៈ សញ្ញាមានការចាំជាលក្ខណៈ ចេតនាមានការតាំងចិត្តក្នុងអារម្មណ៍ជាលក្ខណៈ វិញ្ញាណមានការដឹងច្បាស់ជាលក្ខណៈ ។ ម្យ៉ាងទៀត គប្បីជ្រាបការផ្សេងគ្នាដោយកិច្ចយ៉ាងនេះថា បីតិមានការផ្សាយទៅជាកិច្ច វេទនាមានការសោយអារម្មណ៍ជាកិច្ច សញ្ញាមានការចាំជាកិច្ច ចេតនាមានការផ្តោតចិត្តជាកិច្ច វិញ្ញាណមានការដឹងច្បាស់ជាកិច្ច ។

ការផ្សេងគ្នាដោយការផ្ទុយគ្នា មិនមានក្នុងបទថាបីតិ តែគប្បីជ្រាបការផ្សេងគ្នា ដោយការផ្សេងគ្នា ដោយការផ្ទុយគ្នាយ៉ាងនេះថា ក្នុងនិទ្ទេសនៃអលោភៈជាដើម រមែងបានដោយន័យជាដើមថា ការមិនលោភ កិរិយាមិនលោភ ភាពជាអ្នកមិនលោភ ដូច្នេះ គប្បីជ្រាបការផ្សេងគ្នាទាំង ៤ យ៉ាង តាមដែលមានក្នុងនិទ្ទេសនៃបទទាំងពួង ដោយអាការៈយ៉ាងនេះ ។

ការសម្តែងដោយន័យដទៃទៀត មាន ២ បែបយ៉ាងនេះ គឺលើកតម្កើងពាក្យ ១ ធ្វើឲ្យមាំ ១ ដ្បិតថា កាលពោលបទថា **បីតិ** តែម្តងប៉ុណ្ណោះ ដូចគ្កោះដោយចុងឈើច្រត់ បទនោះរមែងមិនឈ្មោះថាពង្រីកហើយ ប្រជាប់ហើយ តាក់តែងហើយ ដោយអាការៈយ៉ាងនេះ កាលពោលថា សេចក្តីឆ្អែតចិត្ត សេចក្តីរីករាយ សេចក្តីសប្បាយ សេចក្តីស្រួល សេចក្តីស្រស់ស្រាយ ការ

ញញឹមញញែម ការបាននូវអំណរ... ដូច្នេះ ដោយអំណាចព្យញ្ជនៈ ដោយអំណាចឧបសគ្គ ដោយអត្ថរឿយៗ បទនោះរមែងឈ្មោះថា ពង្រីកហើយ ប្រដាប់ហើយ តាក់តែងហើយ ដូចជាឲ្យក្មេងងូតទឹក ឲ្យស្លៀកសំពត់ដែលពេញចិត្ត ឲ្យប្រដាប់តាក់តែងនូវផ្កាទាំងឡាយ បន្តក់ក្អែកឲ្យ បន្ទាប់អំពីនោះក៏ធ្វើនូវចំណុចមនោសិលាលើថ្ងាសរបស់កុមារដោយចំណុចមួយប៉ុណ្ណោះ កុមារមិនទាន់ឈ្មោះថា មានស្នាមចុចដោយល្អ ដោយហេតុត្រឹមប៉ុណ្ណោះឡើយ តែកាលចុចតៗ ចុចជុំវិញដោយពណ៌ផ្សេងៗ រមែងមានឈ្មោះថា ស្នាមចុចល្អ យ៉ាងណា ឧបមេយ្យក៏គប្បីជ្រាបដូច្នោះ នេះឈ្មោះថា លើកតម្កើងពាក្យ ។ ការពោលរឿយៗនោះឯង ដោយអំណាចព្យញ្ជនៈ ដោយអំណាចឧបសគ្គ និងដោយអំណាចអត្ថ ឈ្មោះថា ធ្វើឲ្យមាំ ដូចកាលពោលថា **អាវុសោ** ក្តី **ភន្តេ** ក្តី **យក្ខោ** ក្តី **សប្បោ** ក្តី រមែងមិនឈ្មោះថាធ្វើឲ្យមាំឡើយ តែកាលពោលថា **អាវុសោ អាវុសោ ភន្តេ ភន្តេ យក្ខោ យក្ខោ សប្បោ សប្បោ** ( ពស់ ពស់ ) រមែងឈ្មោះថា ធ្វើឲ្យមាំយ៉ាងណា បើគ្រាន់តែពោលថាបីតិតែម្តងប៉ុណ្ណោះ ដូចគ្គោះដោយចុងឈើប្រត់ រមែងមិនឈ្មោះថាធ្វើឲ្យមាំ កាលពោលថា សេចក្តីឆ្អែតចិត្ត សេចក្តីរីករាយ សេចក្តីសប្បាយ សេចក្តីស្រួល សេចក្តីស្រស់ស្រាយ ការញញឹមញញែម ការបាននូវអំណរ... ដូច្នេះ ដោយអំណាចព្យញ្ជនៈ ដោយអំណាចឧបសគ្គ ដោយអំណាចអត្ថរឿយៗនោះឯង ទើបឈ្មោះថា ធ្វើឲ្យមាំ ការសម្តែងដោយន័យដទៃទៀត មាន ២ បែប ដោយប្រការដូច្នេះ គប្បីជ្រាបអត្ថក្នុងបទទាំងពួងក្នុងនិទ្ទេសនៃបទដែលបានដោយ

អំណាចនៃការសម្តែងដោយន័យដទៃនេះ ។

បណ្តាបទទាំងនោះ ដែលឈ្មោះថា **បីតិ** ព្រោះអត្ថថា ឆ្អែត បីតិនោះ មានការបង្ហាញនូវសេចក្តីស្រឡាញ់ជាលក្ខណៈ មានការឆ្អែតកាយឆ្អែតចិត្តជាកិច្ច ឬមានការផ្សាយជ្រួតជ្រាបជាកិច្ច មានការត្រេកអរជាក់ចិត្តជាបច្ចុប្បដ្ឋាន គប្បីប្រកបកាមគុណ ៥ ជាបីតិដែលប្រកបដោយចំណែកនៃកាម ៥ មានរូបជាដើម ។ បទថា **បីតិ** នោះ ឈ្មោះថាបីតិ ព្រោះអត្ថថា ឆ្អែត នេះជាបទសម្តែងសភាវៈ ។ ភាពជាអ្នកត្រេកអរ ឈ្មោះថា **ចាមុជ្ជំ** អាការៈដែលត្រេកអរ ឈ្មោះថា **អាមោទនា** ។ អាការៈរីករាយ ឈ្មោះថា **បមោទនា** ។

ម្យ៉ាងទៀត ការយកភេសជ្ជៈ ប្រេង ឬទឹកក្តៅ ទឹកត្រជាក់ដាក់លាយគ្នា ហៅថា **មោទនា** យ៉ាងណា សេចក្តីនេះក៏យ៉ាងនោះ ហៅថា **មោទនា** ព្រោះរួមធម៌ទាំងឡាយទុកជាមួយគ្នា ។ ដែលពោលថា **អមោទនា បមោទនា** ព្រោះប្រដាប់ដោយឧបសគ្គ ។

ឈ្មោះថា **ហាសោ** ព្រោះអត្ថថា រីករាយ ឈ្មោះថា **បហាសោ** ព្រោះអត្ថថា សប្បាយ បទពីរនេះជាឈ្មោះនៃអាការៈដែលរីករាយហើយ សប្បាយហើយ ។

ឈ្មោះថា **វិត្តិ** ព្រោះអត្ថថា ជាទីត្រេកអរនៃចិត្ត បទនេះជាឈ្មោះរបស់ទ្រព្យ ។ បីតិនេះ ឈ្មោះថា **វិត្តិ** ព្រោះភាពជារបស់ដែលបុគ្គលឃើញស្មើដោយការត្រេកអរជាបច្ច័យនៃសោមនស្ស ។ ដូចសោមនស្សរមែងកើតឡើងដល់បុគ្គលមានទ្រព្យ ព្រោះអាស្រ័យទ្រព្យយ៉ាងណា សោមនស្សរមែងកើត

ឡើងដល់អ្នកមានបីតិ ព្រោះអាស្រ័យបីតិ ក៏យ៉ាងនោះ ។ ព្រោះហេតុនោះ ទើបលោកពោលថា **វិត្តិ** ។ បទនេះជាឈ្មោះរបស់បីតិ ដែលតាំងនៅដោយសភាវៈនៃការត្រេកអរ ។ បុគ្គលអ្នកមានបីតិ លោកហៅថា មានការត្រេកអរ ព្រោះមានកាយនិងចិត្តផ្សាយឡើង ។ ភាវៈនៃការត្រេកអរ ឈ្មោះថា **ឱទគ្យំ** ។ ភាពជាអ្នកមានចិត្តជារបស់ខ្លួន ឈ្មោះថា **អត្តមនតា** ។ ចិត្តរបស់បុគ្គលមិនពេញចិត្ត រមែងមិនឈ្មោះថា **អត្តមនតា** ព្រោះជាទីតាំងនៃទុក្ខ ។ ដូច្នោះ ភាពជាអ្នកមានចិត្តជារបស់ខ្លួន ទើបឈ្មោះថា **អត្តមនតា** ព្រោះជាទីតាំងនៃសេចក្ដីសុខ ។ ដូច្នោះភាពជាអ្នកមានចិត្តជារបស់ខ្លួន ទើបឈ្មោះថា **អត្ត-មនតា** អធិប្បាយថា ភាវៈនៃចិត្តរបស់ខ្លួន ក៏ព្រោះការពេញចិត្តនោះ មិនមែនជាការពេញចិត្តរបស់បុគ្គលដទៃ តែជាចេតសិកធម៌ដែលជាការស្អាតនៃចិត្តប៉ុណ្ណោះ ដូច្នោះ ទើបព្រះសារីបុត្តពោលថា **អត្តមនតា ចិត្តស្ស** ដូច្នេះ ។

ឈ្មោះថា **ចិត្តំ** ព្រោះចិត្តវិចិត្រ ។ ឈ្មោះថា **មនោ** ព្រោះដឹងគឺជ្រាបអារម្មណ៍ **មនោ** នោះឯង ឈ្មោះថា **មានសំ** ។ ធម៌ដែលសម្បយុត្តជាមួយ **មនោ** លោកពោលថា **មានសំ** ដូចក្នុងពាក្យ ( សំយុត្តនិកាយសគាថវគ្គ ) នេះថា **អន្តលិក្ខចរោ ចាសោ យ្វាយំ ចរតិ មានសោ** អន្ទាក់គឺរាគៈណាដែលត្រាច់ទៅលើអាកាស តែងតែប្រព្រឹត្តទៅក្នុងចិត្ត ដូច្នេះ ។ ព្រះអរហត្តលោកពោល **មានសំ** ក្នុងគាថានេះថា

**កថំ ហិ ភគវា តុយ្ហំ សាវកោ សាសនេ រតោ អប្បត្ត-**
**មានសោ សេក្ខោ កាលំ កយិរា ជនេសុតា ។**

បពិត្រព្រះមានព្រះភាគ អ្នកល្បីក្នុងប្រជុំជន សាវ័ករបស់ព្រះអង្គ
ជាសេក្ខបុគ្គល មានបំណងមិនទាន់សម្រេច នៅត្រេកអរក្នុង
សាសនា គប្បីធ្វើមរណកាលដូចម្ដេចបាន ដូច្នេះ ។

តែក្នុងទីនេះ **មានស** គឺចិត្តនោះឯង ពាក្យថា **មានស** នេះ លោកពង្រីកចេញដោយអំណាចព្យញ្ជនៈ ។

បទថា **ហទយំ** បានដល់ ចិត្ត ដើមទ្រូង លោកពោលថា ហទយៈ ដូចក្នុងប្រយោគនេះថា **ចិត្តំ វា តេ ខិបិស្សាមិ ហទយំ វា តេ ផាលេស្សាមិ** យើងនឹងធ្វើចិត្តលោកឲ្យរវើរវាយ ឬហែកហឫទ័យ ( ដើមទ្រូង ) របស់លោក ដូច្នេះ ។ ចិត្ត លោកពោលថា ហទយៈ ដូចក្នុងប្រយោគជាដើមថា ( សមីតិមាណពនេះ ) ហាក់ជាដឹងចិត្តដោយចិត្ត ដូច្នេះ ។ ហទយវត្ថុ លោកពោលថា ហទយៈ ដូចក្នុងបយោគជាដើមថា **វក្កំ ហទយំ** ទាច បេះដូង ដូច្នេះ ។ តែក្នុងទីនេះ ចិត្តនោះឯងលោក ពោលថា ហទយៈ ព្រោះអត្ថថា នៅខាងក្នុង ។ ចិត្តនោះឯង ឈ្មោះថា **បណ្ឌរំ** ព្រោះអត្ថថា បរិសុទ្ធិ ។ **បណ្ឌរំ** នោះ លោកពោលសំដៅយកភវង្គចិត្ត ដូចព្រះដ៏មានព្រះភាគត្រាស់ទុក ( ក្នុងអង្គុត្តរ-និកាយ ឯកនិបាត ) ថា ម្នាលភិក្ខុទាំងឡាយ ភវង្គចិត្តនេះមានរស្មីផ្សាយចេញ ប៉ុន្តែចិត្តនោះឯង ត្រូវឧបក្កិលេសទាំងឡាយជាអាគន្តុកៈចូលមក ធ្វើឲ្យសៅហ្មង ដូច្នេះ ។ សូម្បីកុសល លោកក៏ពោលថាជាបណ្ឌរៈដូចគ្នា ព្រោះចេញអំពីចិត្តនោះ ដូចទឹកគង្គាហូរអំពីស្ទឹងគង្គា និងដូចទឹកគោធាវរីហូរចេញអំពីស្ទឹងគោធាវរីដូច្នោះ ។

តែសព្ទថា **មនោ** ក្នុងទីនេះថា **មនោ មនាយតនំ** ដូច្នេះ លោកពោល ដើម្បីសម្តែងភាពជាអាយតនៈនៃចិត្តប៉ុណ្ណោះ ។

ព្រោះហេតុនោះ ទើបលោកសម្តែង **មនោ** សព្ទនោះថា **មនោ** សព្ទនេះឈ្មោះថា **មនាយតន** ព្រោះជាទីនៅនៃចិត្ត ដូចទីនៅនៃទេវតា ក៏មិនមែនដែលពិត អាយតនៈ គឺ **មន** ជាមនាយតនៈដូច្នេះ ។ ក្នុងពាក្យនេះ គប្បីជ្រាបថា ឈ្មោះថា **អាយតន** ដោយអត្ថថា ជាទីនៅអាស្រ័យ ដោយអត្ថថា ជាប្រភពកើត ដោយអត្ថថា ជាទីប្រជុំ ដោយអត្ថថា ជាដែនកើតនិងដោយអត្ថថា ជាហេតុ ។ ពិតយ៉ាងនោះ ទីនៅអាស្រ័យក្នុងលោកពោលថា អាយតនៈ ដូចក្នុងបយោគជាដើមថា **ឥស្សរាយតនំ វាសុទេវាយតនំ** ទីនៅអាស្រ័យរបស់អ្នកធំ ទីលំនៅរបស់ទេវតា ដូច្នេះ ។

ប្រភពកើត លោកពោលថាជាអាយតនៈ ដូចក្នុងបយោគជាដើមថា **សុវណ្ណាយតនៈ** ប្រភពមាស **រជតាយតន** ប្រភពប្រាក់ ដូច្នេះ ។

ទីប្រជុំលោកពោលថា **អាយតនៈ** ដូចក្នុងបយោគជាដើមថា **មនោរមេ អាយតនេ សេវន្តិ នំ វិហង្គមា** ពួកសត្វតែងអាស្រ័យនឹងដើមឈើនោះ ដែលនៅក្នុងព្រៃរំលោងជាទីរីករាយចិត្ត ដូច្នេះ ។

ដែនកើតលោកពោលថា អាយតនៈ ដូចក្នុងបយោគជាដើមថា **ទក្ខិណាបថោ គុន្នមាយតនំ** ទក្ខិណាជនបទជាដែនកើតរបស់គោទាំងឡាយ ដូច្នេះ ។

ហេតុ លោកពោលថា អាយតនៈ ដូចក្នុងបយោគជាដើមថា **តត្រ តត្រេវ សក្ខិភព្វតំ បាបុណាតិ សតិ សតិ អាយតនេ** កាលបើហេតុមាន រមែង

គួរដល់នូវភាពគួរជាបន្ទាល់ក្នុងធម៌នោះៗ ដូច្នេះ ។

ក្នុងទីនេះ គួរដោយអត្ថទាំង ៣ គឺដោយអត្ថថា ជាដែនកើត ដោយអត្ថថា ជាទីប្រជុំ ដោយអត្ថថា ជាហេតុ ។

**មនាយតន** នេះ ជាអាយតនៈដោយអត្ថថា ជាដែនកើត ដូចពាក្យថា ធម៌ទាំងឡាយ មានផស្សៈជាដើម រមែងកើតក្នុង **មន** នេះ ដូច្នេះ ។ ជាអាយតនៈដោយអត្ថថា ជាទីប្រជុំចុះ ដូចក្នុងបយោគជាដើមថា រូប សំឡេង ក្លិន រស ផោដ្ឋព្វៈខាងក្រៅ រមែងប្រជុំចុះក្នុង **មន** នេះ ដោយភាពជាអារម្មណ៍ ដូច្នេះ ។ **មនាយតន** បណ្ឌិតគប្បីជ្រាបថាជាអាយតនៈ ដោយអត្ថថា ជាហេតុ ព្រោះជាហេតុ ដោយអត្ថថា ជាបច្ច័យ មានសហជាតបច្ច័យជាដើម ដល់ធម៌ទាំងឡាយមានផស្សៈជាដើម ។ ចិត្តនោះឯងឈ្មោះថា ឥន្ទ្រិយ ព្រោះអត្ថថា សាងនូវភាពជាធំក្នុងលក្ខណៈនៃការដឹង ។ ឥន្ទ្រិយ គឺមនោ ឈ្មោះថា **មនិន្ទ្រិយ** ។ ឈ្មោះថា វិញ្ញាណ ព្រោះអត្ថថា ដឹងអារម្មណ៍ផ្សេងៗ ។ ខន្ធ គឺវិញ្ញាណ ឈ្មោះថា វិញ្ញាណក្ខន្ធោ ។ គប្បីជ្រាបអត្ថនៃវិញ្ញាណក្ខន្ធនោះថា ជាគំនរជាដើម ។ មែនពិត ខន្ធ លោកពោលថា ខន្ធ ដោយអត្ថថា ជាគំនរ ដូចក្នុងបយោគនេះថា **មហាឧទកក្ខន្ធោត្វេវ សង្ខំ គច្ឆតិ** តាមពិតនោះ គឺដល់នូវការរាប់ថា គំនរទឹកធំ ដូច្នេះ ។ លោកពោលថា ខន្ធ ដោយអត្ថថា គុណ ដូចក្នុងប្រយោគជាដើមថា **សីលក្ខន្ធោ សមាធិក្ខន្ធោ** សីលក្ខន្ធ សមាធិក្ខន្ធ ( គុណគឺសីល គុណគឺសមាធិ ) ដូច្នេះ ។ លោកពោលថា ខន្ធ ដោយអត្ថថា ត្រឹមតែជាបញ្ញត្តិប៉ុណ្ណោះ ដូចក្នុងបយោគជាដើមថា **អទ្ទសា ខោ ភគវា**

**មហន្តំ ទារុក្ខន្ធំ** ព្រះមានព្រះភាគទ្រង់បានទតឃើញកំណាត់ឈើដ៏ធំ ដូច្នេះ ។

តែក្នុងទីនេះ លោកពោលខន្ធដោយការបន្ថែមចូលមក ។ ចំណែកមួយនៃវិញ្ញាណក្ខន្ធ ឈ្មោះថាវិញ្ញាណមួយ ព្រោះអត្ថថា ជាគំនរ ។ ព្រោះដូច្នោះ ទើបលោកពោលវិញ្ញាណមួយ ដែលជាចំណែកមួយនៃវិញ្ញាណក្ខន្ធថា វិញ្ញា-ណក្ខន្ធដោយការបន្ថែមចូលមក ដូចបុគ្គលកាត់ចំណែកមួយនៃដើមឈើ ក៏ហៅថា កាត់ដើមឈើ ដូច្នោះ ។

បទថា **តជ្ជា មនោវិញ្ញាណធាតុ** បានដល់ មនោវិញ្ញាណធាតុដែលសមគួរដល់ធម៌ទាំងនោះ មានផស្សៈជាដើម ។ ក្នុងបទនេះ ចិត្តតែម្យ៉ាងប៉ុណ្ណោះ លោកពោលដោយឈ្មោះនៃមនោទុក ៣ ពាក្យគឺ ឈ្មោះថា **មនោ** ព្រោះអត្ថថា ដឹង ១ ឈ្មោះថា **វិញ្ញាណ** ព្រោះអត្ថថា ដឹងអារម្មណ៍ផ្សេងៗ ១ ឈ្មោះថា **ធាតុ** ព្រោះអត្ថថា ត្រឹមតែជាសភាវៈ ឬព្រោះអត្ថថា មិនមែនសត្វ ១ ។

បទថា **សហគតោ** បានដល់ មិនលះ ។ បទថា **សហជាតោ** បានដល់ ចូលទៅរួមគ្នា ។ បទថា **សំសដ្ឋោ** បានដល់ លាយឡំគ្នាតាំងនៅ ។ បទថា **សម្បយុត្តោ** បានដល់ ប្រកបព្រមហើយដោយប្រការទាំងឡាយគ្រប់ចំណែក ។ ប្រកបដោយប្រការទាំងឡាយដូចម្តេច ឆ្លើយថា ប្រកបដោយប្រការទាំងឡាយ មាន **ឯកុប្បាទ** គឺកើតឡើងព្រមគ្នាជាដើម ។ ធម៌ពួកខ្លះ ប្រកបជាមួយធម៌ពួកខ្លះ មិនមានមិនមែនឬ ដោយការបដិសេធបញ្ហានេះថា មែន ទើបលោកពោលអត្ថនៃការប្រកបដោយអំណាចនៃលក្ខណៈមាន **ឯកុប្បាទ** ជាដើមទុកយ៉ាងនេះថា ធម៌ពួកខ្លះ ជាសហគតៈ ជាសហជាតៈ ជាសំសដ្ឋៈ ជា

ឯកុប្បាទៈ ជាឯកនិរោធៈ ជាឯកវត្ថុកៈ ជាឯការម្មណៈ ដោយធម៌ពួកខ្លះ មាន មិនមែនឬ ឆ្លើយថា ធម៌ ដែលប្រកបព្រមដោយប្រការទាំងឡាយនេះ មាន **ឯកុប្បាទ** ជាដើមឈ្មោះថា **សម្បយុត្ត** គឺប្រកបព្រមហើយដោយប្រការ ដូច្នេះ ។

បទថា **ឯកុប្បាទោ** បានដល់ កើតឡើងជាមួយគ្នា អធិប្បាយថា មិនប្រាសចាកគ្នា ។

បទថា **ឯកនិរោធោ** បានដល់ រលត់ព្រមគ្នា ។ បទថា **ឯកវត្ថុកោ** បានដល់ មានវត្ថុ គឺទីអាស្រ័យតែមួយ ដោយអំណាចនៃហទយវត្ថុ ។

បទថា **ឯការម្មណោ** បានដល់ មានអារម្មណ៍ជាមួយគ្នាដោយអំណាចនៃរូបារម្មណ៍ជាដើម ។

ក្នុងទីនេះ **សហគត** សព្ទ ប្រាកដក្នុងអត្ថ ៥ ប្រការគឺ ក្នុងអត្ថដើមនោះ ក្នុងអត្ថថា លាយឡំហើយ ក្នុងអត្ថថា អារម្មណ៍ ក្នុងអត្ថថា អាស្រ័យ ក្នុងអត្ថថា ប្រឡូកប្រឡំ ។

សព្ទថា **សហគត** ក្នុងអត្ថដើមនោះ គប្បីជ្រាបក្នុងពាក្យនេះ ដែលជាពុទ្ធវចនៈថា **យាយំ តណ្ហា ពោនោព្ភវិកា នន្ទិរាគសហគតា** អរិយសច្ច គឺតណ្ហានេះឯង ជាធម្មជាតិនាំសត្វឲ្យកើតទៀត ប្រកបដោយសេចក្តីរីករាយនឹងសេចក្តីត្រេកត្រអាល ដូច្នេះ អធិប្បាយថា ជាការត្រេកត្រអាល ក្លើតក្លើន ។

មកក្នុងអត្ថថា លាយឡំហើយ គប្បីជ្រាបក្នុងពាក្យនេះថា **យា ភិក្ខវេ វីមំសា កោសជ្ជសហគតា កោសជ្ជសម្បយុត្តា** ម្នាលភិក្ខុទាំងឡាយ វីមំសា

ឯណាប្រកបដោយកោសជ្ជៈ សម្បយុត្តដោយកោសជ្ជៈ ដូច្នេះ អធិប្បាយថា លាយឡំហើយដោយកោសជ្ជៈដែលកើតក្នុងចន្លោះ ។

មកក្នុងអត្ថថា អារម្មណ៍ គប្បីជ្រាបក្នុងពាក្យនេះថា **លាភី ហោតិ រូប-សហគតានំ វា សមាបត្តីនំ អរូបសហគតានំ វា សមាបត្តីនំ** ជាអ្នកបានសមាបត្តិដែលសហគតដោយរូប ឬសមាបត្តិដែលសហគតដោយអរូប ដូច្នេះ អធិប្បាយថា សមាបត្តិមានរូបជាអារម្មណ៍ សមាបត្តិមានអរូបជាអារម្មណ៍ ។

មកក្នុងអត្ថថា អាស្រ័យ គប្បីជ្រាបក្នុងពាក្យនេះថា **អដ្ឋិកសញ្ញាសហ-គតំ សតិសម្ពោជ្ឈង្គំ ភាវេតិ** ( ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ) ចម្រើនសតិសម្ពោជ្ឈង្គ ប្រកបដោយអដ្ឋិកសញ្ញា ដូច្នេះ អធិប្បាយថា សតិសម្ពោជ្ឈង្គៈ ដែលព្រះយោគាវចរបានហើយ ព្រោះអាស្រ័យអដ្ឋិកសញ្ញា ព្រោះចម្រើនអដ្ឋិកសញ្ញា ។

មកក្នុងអត្ថថា ច្រឡូកច្រឡំ គប្បីជ្រាបក្នុងពាក្យនេះថា សេចក្តីសុខនេះជាធម្មជាតប្រព្រឹត្តទៅជាមួយ កើតជាមួយ ច្រឡំ ប្រកបដោយបីតិនេះ ដូច្នេះ អធិប្បាយថា លាយឡំ ។ ក្នុងទីនេះ សព្ទថា **សហគត** ប្រើក្នុងអត្ថថា លាយឡំ ។

បទថា **សហជាត** មកក្នុងអត្ថថា កើតរួម ដូចក្នុងពាក្យនេះថា **សហជាតំ បុរេជាតំ បច្ឆាជាតំ** ។

សព្ទថា **សំសដ្ឋ** មកក្នុងអត្ថថា ច្រឡូកច្រឡំ ដូចក្នុងប្រយោគជាដើម

ថា **គិហីហិ សំសដ្ឋោ** ជាអ្នកប្រឡូកប្រឡំដោយពួកគ្រហស្ថ ដូច្នេះ ។

មកក្នុងអត្ថថា ដូចគ្នា ដូចក្នុងប្រយោគជាដើមថា **កិសេ ថូលេ វិវជ្ជេត្វា សំសដ្ឋា យោជិតា ហយា** អ្នកទាំងឡាយ ត្រូវវៀរបង់នូវពួកសេះស្គមនិងសេះធាត់ចេញហើយទឹមតែពួកសេះដែលប្រកប ( ដោយវ័យ សម្បុរ សន្ទុះ កម្លាំង ) វិញ ដូច្នេះ ។ មកក្នុងអត្ថថា ប្រឡូកប្រឡំ ដូចក្នុងប្រយោគជាដើមថា

**បុចិមន្ទបរិវារោ អម្ពោ តេ ទធិវាហន**
**មូលំ មូលេន សំសដ្ឋំ សាខា សាខា និសេវរេ ។**

បពិត្រព្រះរាជាទ្រង់ព្រះនាមទធិវាហនៈ ស្វាយរបស់ព្រះអង្គ មានដើមស្ដៅដុះរួបរឹតជុំវិញ ឫសប្រឡំគ្នាដោយឫស មែកពាក់ព័ន្ធគ្នានឹងមែក ដូច្នេះ ។

មកក្នុងអត្ថថា ធម៌ដែលសម្បយុត្តជាមួយចិត្ត ដូចក្នុងប្រយោគជាដើមថា **ចិត្តសំសដ្ឋា ធម្មា** ពួកធម៌ប្រឡូកប្រឡំដោយចិត្ត ដូច្នេះ ។ តែក្នុងទីនេះ ធម៌ណាមិនបែកគ្នា ជាធម៌មានការកើតឡើងព្រមជាមួយខ្លួន ដូចធម៌ដែលមិនបែកចាកគ្នា ក្នុងការឲ្យផល ធម៌នោះលោកហៅថា សម្បយុត្ត ។

ម្យ៉ាងទៀត លោកពោលពាក្យថា **សហគត** ហើយពោលពាក្យថា **សហជាត** ក៏ដើម្បីសម្ដែងថា ចិត្តនោះមិនមានដោយកាលខាងក្រោយ ដូចសំឡេងដែលមកហើយខាងក្រោយ ។ លោកពោលពាក្យថា **សំសដ្ឋ** ក៏ដើម្បីសម្ដែងថា ចិត្តនោះមិនដូចរូបនិងនាមដែលកើតឡើងព្រមគ្នា ។

លោកពោលពាក្យថា **សម្បយុត្ត** ដើម្បីសម្តែងថា ចិត្តនោះមិនដូចទឹកជាមួយទឹកដោះ ( ដែលបំបែកមិនចេញ ) ។ លោកពោលពាក្យជាដើមថា **ឯកុប្បាទ** ក៏ដើម្បីសម្តែងថា ព្រោះថា ធម៌ទាំងឡាយដែលកើតរួមគ្នា ដោយអត្ថថា មិនអាចធ្វើឲ្យបែកចាកគ្នាបាន សូម្បីជាធម៌សម្បយុត្តក៏មាន ដូចទឹកដោះនិងប្រេង ជាធម៌ដែលវិប្បយុត្តយ៉ាងនោះក៏មាន ដូចនវនីត ដែលបែកចេញអំពីទឹកដោះ ធម៌ដែលដល់នូវលក្ខណៈយ៉ាងនេះ ឈ្មោះថា មានការកើតព្រមគ្នាជាលក្ខណៈនោះឯង ។ ក្នុងនិទ្ទេសនេះ ធម៌ដែលជាឯកុប្បាទនិងសហជាតមានការផ្សេងគ្នា ដូចម្តេច ធម៌ដែលមិនមានរវាងចន្លោះក្នុងខណៈកើតឡើង ឈ្មោះថា **ឯកុប្បាទ** ធម៌ដែលជា **ឯកុប្បាទ** នោះ រមែងមិនដូចនវនីតដែលប្រាកដក្នុងខណៈកូរទឹកដោះជូរ ដែលហួសកាលជាទីរៈហើយ មិនដូចកើតក្នុងថ្ងៃតែមួយ ដោយអំណាចនៃបុរេកត្តនិងបច្ឆាកត្ត ។ ធម៌ដែលឈ្មោះថា **សហជាត** ព្រោះអត្ថថា កើតក្នុងខណៈជាមួយគ្នា ។ បទថា **ឯកវត្ថុកោ** សេចក្តីថា មានវត្ថុជាមួយគ្នា ដោយកំណត់រួមគ្នា ព្រោះអត្ថថា ជាទីតាំង ជាទីតាំងវៀររវាងចន្លោះ ដូចទីតាំងជាមួយគ្នារបស់ភិក្ខុពីររូប ។

បទថា **ឯការម្មណោ** សេចក្តីថា អាចារ្យពួកមួយពណ៌នាទុកយ៉ាងនេះថា មានអារម្មណ៍ដូចគ្នា ដោយមិនពិតប្រាកដ មិនដូចចក្ខុវិញ្ញាណ ។

[ ៥ ] បទថា **មនោ** ជាមូលបទ គឺបទដែលតាំងឡើង ។ ឈ្មោះថា **សត្តោ** ព្រោះអត្ថថា ជាប់ ជាប់ជំពាក់ ជំពាក់ហើយក្នុងអារម្មណ៍ទាំងឡាយមានរូបារម្មណ៍ជាដើម សមដូចពាក្យដែលលោកពោលទុកថា បពិត្រព្រះអង្គ

ដ៏ចម្រើន ពាក្យដែលហៅថា សត្វ សត្វ ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន ដែលហៅថា សត្វ តើដោយហេតុដូចម្ដេច ។ ម្នាលរាធៈ សេចក្ដីពេញចិត្តណា សេចក្ដីត្រេកអរណា សេចក្ដីរីករាយណា សេចក្ដីប្រាថ្នាណាក្នុងរូប បុគ្គលដែលជាប់នៅក្នុងសេចក្ដីពេញចិត្តជាដើមនោះ ចំពាក់នៅក្នុងសេចក្ដីពេញចិត្តជាដើមនោះ លោកហៅថា សត្វ ដូច្នេះ ។ ម្យ៉ាងទៀត ឈ្មោះថា សត្វ ព្រោះប្រកបដោយការជាប់ជំពាក់ ។ ឈ្មោះថា **នរោ** ព្រោះអត្ថថា នាំទៅកាន់សុគតិនិងទុគ្គតិ ។ ឈ្មោះថា **មាណវោ** ព្រោះអត្ថថា ជាកូន គឺជាបុត្ររបស់ព្រះបាទមនូ ។ ឈ្មោះថា **បោសោ** ព្រោះអត្ថថា ដែលបុគ្គលដទៃចិញ្ចឹមដោយគ្រឿងប្រើ ។ នរកលោកហៅថា **បុំ** ។ ឈ្មោះថា **បុគ្គលោ** ព្រោះអត្ថថា លេបត្រ-បាក់នូវនរកនោះ ។ ឈ្មោះថា **ជីវោ** ព្រោះអត្ថថា ទ្រទ្រង់ទុកនូវជីវិតិន្ទ្រិយ ។ ឈ្មោះថា **ជាតុ** ព្រោះអត្ថថា ទៅកាន់ការកើតអំពីចុតិ ។ ឈ្មោះថា **ជន្តុ** ព្រោះអត្ថថា រមែងទ្រុឌទ្រោម ។ ឈ្មោះថា **ឥន្ទគូ** ព្រោះអត្ថថា ដល់ដោយភាពជាធំ ។ ម្យ៉ាងទៀត ឈ្មោះថា **ឥន្ទគូ** ព្រោះអត្ថថា ដល់ដោយកម្មដែលជាធំ ។ បាលីថា **ហិន្ទគូ** ដូច្នេះក៏មាន ។

បទថា **ហិន្ទុំ** បានដល់ ការស្លាប់ ឈ្មោះថា **ហិន្ទគូ** ព្រោះអត្ថថា ទៅកាន់ការស្លាប់នោះ ។

ឈ្មោះថា **មនុជោ** ព្រោះអត្ថថា កើតអំពីព្រះបាទមនូ ។ បទថា **យំ សាធិយតិ** សេចក្ដីថា ត្រេកអរក្នុងអារម្មណ៍ មានរូបជាដើមណា បទដ៏សេសមានន័យដូចពោលហើយនោះឯង ។

បន្ទាប់អំពីនេះទៅ ព្រះដ៏មានព្រះភាគកាលទ្រង់សរុបភាពដែលត្រាស់ហើយឲ្យយល់ងាយ ទើបត្រាស់ថា **កាមំ កាមយមានស្ស ។បេ។ យទិច្ឆតិ** ដូច្នេះ បន្ទាប់អំពីនេះ ខ្ញុំនឹងមិនពោលដល់ភាពដែលពោលមកមានប្រមាណប៉ុណ្ណេះ នឹងពោលតែសេចក្តីដែលប្លែកគ្នាប៉ុណ្ណោះ ។

[ ៦ ] បទថា **តស្ស ចេ កាមយមានស្ស** សេចក្តីថា កាលបុគ្គលនោះប្រាថ្នាកាម ឬទៅដោយកាម ។

បទថា **ឆន្ទជាតស្ស** បានដល់ មានតណ្ហាកើតហើយ ។ បទថា **ជន្តុនោ** បានដល់ សត្វ ។ បទថា **តេ កាមា បរិហាយន្តិ** សេចក្តីថា បើកាមទាំងនោះវិនាសទៅ ។ បទថា **សល្លវិទ្ធោវ រុប្បតិ** សេចក្តីថា កាលបើដូច្នោះ សត្វនោះរមែងសោប់សេល់ ដូចសត្វដែលត្រូវព្រួញដែលធ្វើដោយដែកជាដើម មុតហើយ ។ បន្ទាប់អំពីនេះ ខ្ញុំនឹងវៀរបង់ពាក្យដែលពោលទុកហើយ នឹងពោលតែបទដែលលំបាកៗ បណ្តាបទដែលមិនទាន់បានពោលទុកប៉ុណ្ណោះ ។

[ ៧ ] បទថា **យាយតិ** សេចក្តីថា សត្វរមែងទៅ គឺរមែងដល់ដោយអំណាចដល់អារម្មណ៍ ដែលជាការត្រេកអរនៃចិត្ត ព្រោះចក្ខុ ។

ឈ្មោះថា **និយ្យតិ** ព្រោះអត្ថថា ញុំាងចិត្តឲ្យដល់ព្រមដោយអំណាចនៃអារម្មណ៍ សូម្បីដោយអំណាចនៃអារម្មណ៍ដែលគួរទស្សនា ។

ឈ្មោះថា **វុយ្ហតិ** ព្រោះអត្ថថា កំណាត់ការផ្អែតចិត្ត ព្រោះបានឮដោយត្រចៀក ដោយអំណាចនៃអារម្មណ៍ដែលគួរសេព ។

ឈ្មោះថា **សំហារិយតិ** ព្រោះអត្ថថា ចូលទៅប្រកាន់នូវការផ្អែតចិត្តស្មុះទៅ

ដោយអំណាចនៃអារម្មណ៍ដែលគួរត្រាច់ទៅ ។

បទថា **យថា** ជានិបាត ចុះក្នុងអត្ថនៃឧបមា ។ ឈ្មោះថា **ហត្ថិយានេន វា** ព្រោះអត្ថថា ទៅ គឺដល់ដោយដំរី ។ **វា** សព្ទ ចុះក្នុងអត្ថវិកប្ប ។

ឈ្មោះថា **អស្សយានេន វា** ព្រោះអត្ថថា ទៅ គឺដល់ដោយសេះ ។ យាន មានយានដែលទឹមដោយគោជាដើម ឈ្មោះថា **គោយានេន** ។ ដោយយាន គោនោះ ។ ក្នុងយានពពែជាដើមក៏ន័យនេះឯង ។

[ ៨ ] ការពេញចិត្តក្នុងកាម ដែលកើតឡើងដោយអំណាចអារម្មណ៍ ដែលប្រាថ្នា ឈ្មោះថា **សញ្ញាតោ** ដែលកើតដោយភាពជាអារម្មណ៍ ដែល ស្រឡាញ់ ឈ្មោះថា **ឆិព្យន្តោ អភិឆិព្យន្តោ** ។ ដែលកើតដោយភាពជាអា-រម្មណ៍ ដែលពេញចិត្ត ឈ្មោះថា **ចាតុរុទ្ធោ** ។

ម្យ៉ាងទៀត គប្បីជ្រាបថា ការពេញចិត្តក្នុងកាមដែលកើតដោយកាមរាគៈ ឈ្មោះថា **សញ្ញាតោ** ដែលកើតដោយកាមនន្ទិ ឈ្មោះថា **ឆិព្យន្តោ អភិឆិព្យន្តោ** ។ ដែលកើតដោយកាមតណ្ហាដោយកាមសិនេហា ដោយកាមឆន្ទៈ និងដោយ កាមបរិឡាហៈ ឈ្មោះថា **ចាតុរុទ្ធោ** ។

[ ៩ ] បទថា **តេ វា កាមា បរិហាយន្តិ** សេចក្តីថា កាមទាំងនោះ គឺមានវត្ថុកាមជាដើមវិនាសទៅ គឺឃ្លាតទៅ ។

បទថា **សោ វា កាមេហិ បរិហាយតិ** សេចក្តីថា សត្វនោះ គឺបុគ្គល មានក្សត្រជាដើម រមែងវិនាស គឺឃ្លាតទៅចាកកាមទាំងឡាយ មានវត្ថុកាមជា ដើម ដូចក្នុងគាថាយ៉ាងនេះថា

កោគៈទាំងឡាយ លះបង់សត្វមុនក៏មាន សត្វលះបង់កោគៈ
ទាំងនោះមុនក៏មាន ដូច្នេះ ។

បទថា **កថំ** បានដល់ ដោយប្រការដូចម្តេច ។ បទថា **តិដ្ឋន្តស្សេវ** បានដល់ តាំងនៅនោះឯង ។ បទថា **តេ ភោគេ** បានដល់ កោគៈទាំងឡាយនោះ មានវត្ថុកាមជាដើម ។ បទថា **រាជានោ វា** បានដល់ ពួកព្រះរាជាក្នុងផែនដីជាដើម ។ បទថា **ហរន្តិ** បានដល់ ដណ្តើមយកទៅ ឬរឹបអូសយកទៅ ។ បទថា **ចោរា វា** បានដល់ ពួកអ្នកកាត់ទីតជាដើម ។ បទថា **អគ្គិ វា** បានដល់ ភ្លើងព្រៃជាដើម ។ បទថា **ឌហតិ** បានដល់ មិនធូរថយ គឺធ្វើឲ្យជាផេះ ។ បទថា **ឧទកំ វា** បានដល់ ទឹក មានទឹកជំនន់ជាដើម ។ បទថា **វហតិ** បានដល់ កួចយកទៅកាន់មហាសមុទ្ទ ។ បទថា **អប្បិយា វា** បានដល់ មិនប្រាថ្នា មិនពេញចិត្ត ។ បទថា **ទាយាទា ហរន្តិ** សេចក្តីថា មិនមែនម្ចាស់ទ្រព្យ វៀរចាកភាពជាទាយាទនាំទៅ ។ បទថា **និហិតំ វា** បានដល់ ដែលធ្វើការកប់ទុក ។ បទថា **នាធិគច្ឆតិ** បានដល់ មិនជួប គឺមិនបានត្រឡប់ អធិប្បាយថា មិនបានឃើញ ។

បទថា **ទុប្បយុត្តា** បានដល់ ការងារ មានកសិកម្មនិងពាណិជ្ជកម្មជាដើមដែលប្រកប គឺប្រព្រឹត្តទៅមិនរៀបរយ ។

បទថា **ភិជ្ជន្តិ** បានដល់ ដល់នូវការបែកធ្លាយ អធិប្បាយថា ដំណើរការទៅមិនបាន ។ គប្បីជ្រាបការកើតក្នុងគាថាជាដើមថា បុគ្គលមិនដឹងវមែងទម្លាយការងារនោះដូច្នេះ ។

បទថា **កុលេ វា កុលជ្ឈាបកោ ឧប្បជ្ជតិ** សេចក្ដីថា បុគ្គលបំផ្លាញត្រកូល គឺបុគ្គលចុងក្រោយក្នុងត្រកូល កើតក្នុងត្រកូលក្សត្រជាដើម ។

បាលីថា **កុលេ វា កុលង្គារោ** ដូច្នេះក៏មាន ។ បទថា **យោ តេ ភោគេ វិកិរតិ** សេចក្ដីថា ជាបុគ្គលចុងក្រោយក្នុងត្រកូលនេះ ញុំាងភោគៈ មានប្រាក់ជាដើមទាំងនោះឲ្យអស់ទៅ ។

បទថា **វិធមេតិ** បានដល់ បែកជាចំណែកៗ គ្រវែងចោលទៅឆ្ងាយ ។ បទថា **វិទ្ធំសេតិ** បានដល់ ឲ្យវិនាស គឺឲ្យមើលមិនបាន ។ ម្យ៉ាងទៀត អ្នកលេងស្រីរមែងខ្ជះខ្ជាយ អ្នកលេងស្រាររមែងបំផ្លាញ អ្នកលេងល្បែងភ្នាល់រមែងកម្ចាត់បង់ ។ ម្យ៉ាងទៀត គប្បីប្រកបអត្ថដោយពាក្យជាដើមយ៉ាងនេះថា បុគ្គលនេះ រមែងខ្ជះខ្ជាយភោគៈដែលកើតឡើង ព្រោះការមិនដឹង រមែងបំផ្លាញភោគៈដែលកើតឡើង ព្រោះមិនចេះចាយវាយ រមែងកម្ចាត់បង់ភោគៈដែលកើតឡើង ព្រោះប្រាសចាកការរក្សាក្នុងទីដែលរក្សាទុក ។

បទថា **អនិច្ចតាយេវ អដ្ឋមី** សេចក្ដីថា សេចក្ដីវិនាសនោះឯង ជាគម្រប់ ៨ ។

បទថា **ហាយន្តិ** បានដល់ ដល់នូវការមើលមិនបាន ។ បទថា **បរិហាយន្តិ** បានដល់ មិនប្រាកដទៀត ។ បទថា **បរិធំសេន្តិ** បានដល់ ឃ្លាតចាកទី ។ បទថា **បរិច្ចជន្តិ** បានដល់ បាត់បង់ ។ បទថា **អន្តរធាយន្តិ** បានដល់ ដល់នូវការអន្តរធាន គឺមើលមិនឃើញ ។ បទថា **វិប្បលុជ្ជន្តិ** បានដល់ ខូចខ្ទីអស់ទៅ ។ បទថា **តិដ្ឋន្តេវ តេ ភោគា** សេចក្ដីថា ក្នុងពេលដែលភោគៈទាំង

នោះតាំងនៅ ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា កាលព្រះតថាគតឋិតនៅក្តី បរិញ្ញានទៅក្តី ដូច្នេះជាដើម ។

បទថា **សោ** បានដល់ បុគ្គលជាម្ចាស់របស់កោគៈនោះ ឃ្លាតចាកទៅលោក ស្លាប់អំពីមនុស្សលោក វិនាសចាកលោកនៃនាគនិងគ្រុឌជាដើម ម្យ៉ាងទៀត អាចារ្យពួកមួយពណ៌នាទុកដូច្នេះថា សាបសូន្យដោយអំណាចនៃឃ្លាំងស្រូវ សាបសូន្យស្រឡះដោយអំណាចនៃឃ្លាំងទ្រព្យ ខ្ចាត់ខ្ចាត់ដោយអំណាចនៃគោបម្រើ ដំរី សេះ ជាដើម បាត់បង់ ដោយអំណាចនៃទាសានិងទាសីអន្តរធានដោយអំណាចនៃទារៈនិងអាភរណៈ វិនាសទៅដោយអំណាចនៃទឹកជាដើម ។

[ ១០ ] បទថា **អយោមយេន** បានដល់ ដែលកើតអំពីលោហៈពណ៌ខ្មៅ គឺដែកជាដើម ។ បទថា **សល្លេន** បានដល់ ដោយព្រួញ ។ បទថា **អដ្ឋិមយេន** បានដល់ ដោយឆ្អឹងដ៏សេស វៀរឆ្អឹងមនុស្ស ។ បទថា **ឧន្តមយេន** បានដល់ ដោយភ្លុកដំរីជាដើម ។ បទថា **វិសាណមយេន** បានដល់ ដោយស្នែងគោជាដើម ។ បទថា **កដ្ឋមយេន** បានដល់ ដោយឫស្សីជាដើម ។ បទថា **វិទ្ធោ** បានដល់ ចាក់ដោយព្រួញមានប្រការដូចពោលហើយណាមួយ ។

បទថា **រុប្បតិ** បានដល់ រសាប់រសល់ គឺដល់នូវវិការៈ ។ បទថា **កុប្បតិ** បានដល់ ញាប់ញ័រ គឺញ៉ាំងសេចក្តីក្រោធឲ្យកើតឡើង ។ បទថា **ឃដ្ដិយតិ** បានដល់ ជាអ្នកបម្រះនទៀល ។ បទថា **បីឡិយតិ** បានដល់ ជាអ្នកចាក់ដោត ។ បុគ្គលដែលត្រូវប្រហាររមែងញាប់ញ័រ រមែងលំបាកក្នុងពេលដាក់ឧបករណ៍

ចូលទៅលានដំបៅក្នុងថ្ងៃទី ៣ រមែងចុកចាប់ក្នុងកាលលាបថ្នាំ ។ អាចារ្យពួកមួយពណ៌នាទុកយ៉ាងនេះថា រមែងក្ដៅក្រហាយ កាលលាងនូវដំបៅដែលត្រូវចាក់ រមែងញាប់ញ័រព្រោះកើតទុក្ខនោះ រមែងចង្អៀតចង្អល់ព្រោះដាក់ឧបករណ៍លាងដំបៅចូលទៅ រមែងលំបាកក្នុងកាលលាបថ្នាំ ។

បទថា **ព្យាធិតោ** បានដល់ ជាអ្នកត្រូវប្រហារហើយឈឺចាប់ ។ បទថា **ទោមនស្សិតោ** បានដល់ ដល់នូវទោមនស្ស ។ បទថា **វិបរិណាមញ្ញថាភាវា** បានដល់ ព្រោះលះភាពជាប្រក្រតីហើយចូលដល់ភាពដទៃ ។ ការក្រៀមស្ងួតខាងក្នុង ឈ្មោះថា **សោក** ។ ការរវើរវាយដោយវាចាឈ្មោះថា **បរិទេវ** ការបៀតបៀនផ្លូវកាយជាដើម ឈ្មោះថា **ទុក្ខ** ការបៀតបៀនផ្លូវចិត្ត ឈ្មោះថា **ទោមនស្ស** ការចង្អៀតចង្អល់ចិត្ត យ៉ាងខ្លាំងក្លា ឈ្មោះថា **ឧបាយាសា** ។ សេចក្ដីសោកជាដើម មានប្រការដូចពោលហើយទាំងនោះ រមែងកើតឡើង គឺរមែងដល់នូវសេចក្ដីប្រាកដ ។

[ ១១-១២ ] ក្នុងគាថាទី ៣ មានសេចក្ដីសង្ខេបដូចតទៅនេះថា បុគ្គលណាវៀរកាមទាំងនេះ ដោយការសង្កត់ធនូរាគៈក្នុងកាមនោះ ឬដោយការកាត់ផ្ដាច់ ដូចបុគ្គលវៀរនូវក្បាលពស់ដោយជើងរបស់ខ្លួន បុគ្គលនោះជាអ្នកឃើញភ័យ ជាអ្នកមានសតិ រមែងកន្លងផុតតណ្ហា ពោលគឺវិសត្តិកាក្នុងលោក ព្រោះផ្សាយទូទៅក្នុងលោក ។

បទថា **យោ** ជាបទដែលគប្បីចែក ។ បទថា **យោ យាទិសោ** ជាដើម ជាបទចែកបទនោះ ។ ក្នុងគាថានេះ ព្រោះព្រះមានព្រះភាគទ្រង់សម្ដែងបទ

ដែលមានអត្ថថា **យោ** និងបុគ្គលនោះដោយមិនកំណត់ ។ ហេតុនោះ កាលនឹងសម្តែងអត្ថរបស់បទនោះ ទើបទ្រង់ត្រាស់សព្ទថា **យោ** ប៉ុណ្ណោះ ដែលសម្តែងបុគ្គលដោយមិនកំណត់ ព្រោះហេតុនោះ ក្នុងគាថានេះ គប្បីជ្រាបអត្ថយ៉ាងនេះថា បទថា **យោ** បានដល់ បុគ្គលណាមួយ ។ ព្រោះបុគ្គលនោះ គឺបុគ្គលដែលឈ្មោះថា បុគ្គលណាមួយនោះ រមែងប្រាកដដោយអាការៈនោះ ដោយអំណាចនៃភេទ ការប្រកប មានប្រភេទដូចម្តេច មានប្រការដូចម្តេច ដល់នូវឋានៈណា ប្រកបដោយធម៌ណាដោយពិត ដូច្នោះព្រះសារីបុត្តត្ថេរ កាលនឹងប្រកាសប្រភេទនោះ ដើម្បីឲ្យដឹងបុគ្គលនោះក្នុងទីនោះ ទើបពោលពាក្យជាដើមថា **យាទិសោ** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យាទិសោ** សេចក្តីថា ជាបុគ្គលបែបណា ឬបែបនោះក៏ដោយដោយអំណាចនៃភេទ គឺខ្ពស់ ទាប ខ្មៅ ស ស្បែកគគ្រិះ ស្គមឬធាត់ក៏ដោយ ។

បទថា **យថាយុត្តោ** សេចក្តីថា ជាអ្នកប្រកបដោយអ្វីក៏បាន ដោយអំណាចនៃការប្រកប គឺប្រកបការងារកសាងក្តី ប្រកបការរៀនក្តី ការបង្រៀនក្តី ប្រកបធុរៈគ្រឿងស្លៀកដណ្តប់ក្តី ។

បទថា **យថាវិហិតោ** សេចក្តីថា ជាអ្នកបានទទួលតែងតាំងយ៉ាងណា ដោយអំណាចភាពជាអ្នកឲ្យនូវការកសាងជាដើម ។

បទថា **យថាបការោ** សេចក្តីថា ជាអ្នកតាំងនៅដោយប្រការណា ដោយអំណាចជាអ្នកនាំបរិស័ទជាដើម ។

បទថា **យំ ឋានប្បត្តោ** សេចក្តីថា ជាអ្នកដល់នូវតំណែងណា ដោយអំណាចតំណែងសេនាបតី និងតំណែងសេដ្ឋីជាដើម ។

បទថា **យំ ធម្មសមន្នាគតោ** សេចក្តីថា ជាអ្នកចូលដល់ដោយធម៌ណា ដោយអំណាចធុតង្គជាដើម ។

បទថា **វិក្ខម្ភនតោ វា** សេចក្តីថា ដោយការធ្វើឲ្យឆ្ងាយចាកកិលេសទាំងឡាយដោយឧបចារសមាធិនិងអប្បនាសមាធិ ដូចប្រើក្អមទឹកសង្កត់នូវចក ។

បទថា **សមុច្ឆេទតោ វា** សេចក្តីថា ឬដោយការកាត់ផ្តាច់ដោយអំណាចនៃការលះ ដោយដកនូវឫសកិលេសទាំងឡាយជាសមុច្ឆេទ ធ្វើឲ្យប្រព្រឹត្តទៅមិនបានដោយមគ្គ ។

បទ ១១ មានបទថា **អដ្ឋិកង្កលូបមា កាមា** ជាដើម លោកពោលដោយអំណាចនៃវិបស្សនា ។

បទថា **ពុទ្ធានុស្សតឹ ភាវេន្តោបិ** ជាដើម និងបទថា **មរណានុស្សតឹ ភាវេន្តោបិ** លោកពោលដោយអំណាចនៃឧបចារជ្ឈាន ។

បទថា **អានាបានស្សតឹ ភាវេន្តោបិ កាយគតាសតឹ ភាវេន្តោបិ បឋមំ ឈានំ ភាវេន្តោបិ** ជាដើម និងបទថា **នេវសញ្ញានាសញ្ញាយតនសមាបត្តឹ ភាវេន្តោបិ** ជាទីបំផុត លោកពោលដោយអំណាចនៃអប្បនាឈាន ។

បណ្តាបទទាំងនោះ បទថា **អដ្ឋិកង្កលូបមា កាមា** សេចក្តីថា កាមទាំងឡាយ ប្រៀបដូចគ្រោងឆ្អឹង ព្រោះអត្ថថា កាមទាំងនោះមានគ្រោងឆ្អឹងដែលមិនគួរត្រេកអរ មិនមានសាច់និងឈាមជាប់ ជាគ្រឿងប្រៀបធៀប ។

*បទថា* **អប្បស្សាទដ្ឋេន** *សេចក្តីថា ព្រោះអត្ថថា ឃើញថាក្នុងកាមនេះ មានការត្រេកអរនិងសេចក្តីសុខតិច គឺបន្តិចបន្តួច មានទោសច្រើន ។*

*បទថា* **បស្សន្តោ** *សេចក្តីថា ឃើញដោយចក្ខុ គឺញាណថា ក្តៅនោះគង់មានចំណែកនៃសេចក្តីលំបាក គឺការចង្អៀតចង្អល់យ៉ាងនោះឯង ។*

*បទថា* **បរិវជ្ជេតិ** *បានដល់ ទៅឲ្យឆ្ងាយ សមដូចព្រះដ៏មានព្រះភាគត្រាស់ទុក ( ក្នុងមជ្ឈិមនិកាយមជ្ឈិមបណ្ណាសក ) ថា*

*ម្នាលគហបតី ដូចសុនខ ដែលអស់កម្លាំង ព្រោះសេចក្តីឃ្លានគ្របសង្កត់ ក៏ដើរចូលទៅកាន់ទីសម្រាប់អារសាច់លក់របស់គោឃាតកៈ ឯគោឃាតកៈក្តី កូនឈ្នួលរបស់គោឃាតកៈក្តីដែលឈ្លាស យករាងឆ្អឹងដែលពន្លះសាច់ចេញស្អាត ឥតមានសាច់ គ្រាន់តែប្រឡាក់ដោយឈាម បោះទៅឲ្យក្តៅនោះ ម្នាលគហបតី អ្នកសម្គាល់សេចក្តីនោះថាដូចម្តេច ក្តៅនោះកាលអង្អៀមនូវរាងឆ្អឹងឯណោះ ដែលគេពន្លះសាច់ចេញស្អាត ឥតមានសាច់ គ្រាន់តែប្រឡាក់ដោយឈាម នឹងបន្ទោបង់សេចក្តីអស់កម្លាំង ព្រោះការឃ្លានដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ការបន្ទោបង់នូវសេចក្តីអស់កម្លាំង ព្រោះការឃ្លានទុំះមិនបានទេ ដំណើរនោះព្រោះហេតុអ្វី បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថារាងឆ្អឹងឯណោះ ដែលគេពន្លះសាច់ចេញស្អាត ឥតមានសាច់ គ្រាន់តែប្រឡាក់ដោយឈាម ឯសុនខ*

នោះ ជាសត្វគ្រាន់តែមានចំណែក នៃសេចក្ដីលំបាកកាយ លំបាកចិត្តប៉ុណ្ណោះឯង ។ ម្នាលគហបតី អរិយសាវកតែង ពិចារណាដូច្នេះថា ព្រះមានព្រះភាគទ្រង់សម្ដែងហើយថា កាម ទាំងឡាយ មានឧបមាដោយរាងឆ្អឹង មានទុក្ខច្រើន មាន សេចក្ដីចង្អៀតចង្អល់ច្រើន ទោសមានច្រើនប្រការក្នុងកាម ទាំងនោះ យ៉ាងនោះឯង អរិយសាវកឃើញសេចក្ដីនេះតាម ពិតដោយប្រាជ្ញាដ៏ប្រពៃយ៉ាងនេះហើយ ក៏លះបង់នូវឧបេក្ខា ( ក្នុងបញ្ចកាមគុណ ) ដែលមានសភាពផ្សេងគ្នា អាស្រ័យ នូវអារម្មណ៍មានសភាពផ្សេងគ្នា ហើយចម្រើនឧបេក្ខាដែល មានសភាពតែមួយ អាស្រ័យនូវអារម្មណ៍មានសភាពតែមួយ និងឧបេក្ខា ជាទីរលត់នៃឧបាទានជាលោកាមិសៈ មិនមាន សេសសល់ ដោយប្រការទាំងពួង ដូច្នេះ ។

កាមទាំងឡាយឈ្មោះថា **មំសបេសូបមា កាមា** ព្រោះអត្ថថា មានដុំសាច់ដែលជារបស់សាធារណៈ ដល់ត្មាតជាដើម ជាគ្រឿងប្រៀបធៀប ឈ្មោះថា **ពហុសាធារណា** ព្រោះអត្ថថា ជារបស់សាធាដល់ជនទាំងឡាយ ជាច្រើន ។ ឈ្មោះថា **តិណុក្កូបមា** ព្រោះអត្ថថា មានគប់ភ្លើងស្មៅដែលឆេះទូទៅហើយជាគ្រឿងប្រៀបធៀប ។

បទថា **អនុទហានផ្ដេង** បានដល់ ព្រោះអត្ថថា ដុតដៃជាដើម ។ ឈ្មោះថា **អង្គារកាសូបមា** ព្រោះអត្ថថា មានរណ្ដៅរងើកភ្លើងជ្រៅជាងមួយជួរ

បុរស ពេញដោយរងើកភ្លើងដែលប្រាសចាកអណ្តាត ប្រាសចាកផ្សែងជាគ្រឿងប្រៀបធៀប ។

បទថា **មហាបរិឡាហាដ្ឋេន** បានដល់ ព្រោះអត្ថថា ធ្វើឲ្យក្តៅក្រហាយច្រើន ឈ្មោះថា **សុបិនកូបមា** ព្រោះអត្ថថា មានការយល់សប្តិថា អារាមគួរជាទីត្រេកអរជាដើម ជាគ្រឿងប្រៀបធៀប ។

បទថា **ឥត្តរបច្ចុបដ្ឋានដ្ឋេន** បានដល់ ព្រោះអត្ថថា ចូលទៅតាំងទុកមិនដល់ ។ ឈ្មោះថា **យាចិតកូបមា** ព្រោះអត្ថថា មានគណ្ឌៈ មានយានជាដើម ដែលបានមកដោយការខ្ចី ជាគ្រឿងប្រៀបធៀប ។

បទថា **តាវកាលិកដ្ឋេន** បានដល់ ព្រោះអត្ថថា មិនឋិតថេរ ឈ្មោះថា **រុក្ខផលូបមា** ព្រោះអត្ថថា មានដើមឈើមានផ្លែច្រើនជាគ្រឿងប្រៀបធៀប ។

បទថា **សម្ភញ្ជនបរិភញ្ជនដ្ឋេន** បានដល់ ព្រោះអត្ថថា ធ្វើឲ្យបាក់មែក ព្រោះអត្ថថា ធ្វើឲ្យបាក់ដោយជុំវិញ ហើយឲ្យដើមរលំ ។ ឈ្មោះថា **អសិសូនូបមា** ព្រោះអត្ថថា មានកាំបិតនិងជ្រញ់ជាគ្រឿងប្រៀបធៀប ។

បទថា **អធិកុដ្ដនដ្ឋេន** បានដល់ ព្រោះអត្ថថា កាត់ ឈ្មោះថា **សត្តិសូលូបមា** ព្រោះអត្ថថា មានលំពែងជាគ្រឿបប្រៀបធៀប ។

បទថា **វិធិវិជ្ឈនដ្ឋេន** បានដល់ ព្រោះអត្ថថា ឲ្យដួលចុះទៅ ព្រោះអត្ថថា ឲ្យកើតភ័យ ឈ្មោះថា **សប្បសិរូបមា** ព្រោះអត្ថថា មានក្បាលពស់ជាគ្រឿងប្រៀបធៀប ។

បទថា **សប្បដិភយដ្ឋេន** បានដល់ ព្រោះអត្ថថា មានភ័យចំពោះមុខ ឈ្មោះ

ថា **អគ្គិក្ខន្ធូបមា** ព្រោះអត្ថថា មានគំនរភ្លើងដែលឲ្យកើតទុក្ខជាគ្រឿងប្រៀបធៀប ។

បទថា **មហាគ្គិតាបនដ្ឋេន** បានដល់ ព្រោះអត្ថថា ឲ្យកើតនូវការក្ដៅក្រហាយ ព្រោះដូចគំនរភ្លើងធំឲ្យក្ដៅ ដូច្នោះទើបវៀរចាកកាម សមដូចព្រះតម្រាស់ដែលត្រាស់ទុក ( ក្នុងមជ្ឈិមនិកាយមជ្ឈិមបណ្ណាសក ) ថា

ម្នាលគហបតី ដូចជាសត្វត្មាត ខ្លែងក្រហមឬខ្លែងខ្មៅ ពាំនាំដុំសាច់ហើរទៅ មានពួកត្មាតខ្លះ ពួកខ្លែងក្រហមខ្លះ ពួកខ្លែងខ្មៅខ្លះ នាំគ្នាហើរដេញតាមសត្វត្មាតជាដើមនោះ ចឹកជញ្ជែងដណ្ដើមយក ម្នាលគហបតី អ្នកសម្គាល់សេចក្ដីនោះថាដូចម្ដេច បើសត្វត្មាត ខ្លែងក្រហម ឬខ្លែងខ្មៅនោះ មិនលះបោលដុំសាច់នោះដោយឆាប់ទេ ក៏ត្មាតជាដើមនោះនឹងដល់នូវសេចក្ដីស្លាប់ ឬសេចក្ដីទុក្ខជិតនឹងស្លាប់ ព្រោះដុំសាច់នោះជាហេតុ មែនឬទេ ។ ព្រះករុណាព្រះអង្គ ។ ម្នាលគហបតី អរិយសាវកតែងពិចារណា ដូច្នេះថា ព្រះមានព្រះភាគទ្រង់សម្ដែងហើយថា កាមទាំងឡាយ មានឧបមាដោយដុំសាច់ មានទុក្ខច្រើន មានសេចក្ដីចង្អៀតចង្អល់ច្រើន ទោសមានច្រើនប្រការ ក្នុងកាមទាំងនេះយ៉ាងនោះឯង អរិយសាវកឃើញសេចក្ដីនេះ តាមពិតដោយប្រាជ្ញាដ៏ប្រពៃ យ៉ាងនេះហើយ ក៏លះបង់នូវឧបេក្ខាដែលមានសភាពផ្សេងគ្នា អាស្រ័យនូវ

អារម្មណ៍មានសភាពផ្សេងគ្នា ចម្រើននូវឧបេក្ខា ដែលមានសភាពតែមួយ អាស្រ័យនូវអារម្មណ៍មានសភាពតែមួយនិងឧបេក្ខាជាទីរលត់នៃឧបាទានជាលោកាមិសៈ មិនមានសេសសល់ដោយប្រការទាំងពួង ។

ម្នាលគហបតី ដូចជាបុរសកាន់នូវគប់ស្មៅដែលភ្លើងឆេះដើរប្រាសខ្យល់ ម្នាលគហបតី អ្នកសម្គាល់សេចក្តីនេះថាដូចម្តេច បើបុរសនោះ មិនលះចោលគប់ស្មៅដែលភ្លើងឆេះនោះ ដោយឆាប់ទេ គប់ស្មៅដែលភ្លើងឆេះនោះ នឹងរោលរាលដៃឬកំភួនដៃ ឬរោលរាលអវយវៈតូចធំនីមួយ បុរសនោះនឹងដល់នូវសេចក្តីស្លាប់ ឬសេចក្តីទុក្ខជិតនឹងស្លាប់ ព្រោះគប់ស្មៅដែលភ្លើងឆេះនោះ ជាហេតុមែនឬទេ ។ ព្រះករុណាព្រះអង្គ ។ ម្នាលគហបតី អរិយសាវកតែងពិចារណាដូច្នេះថា ព្រះមានព្រះភាគទ្រង់សម្តែងហើយថា កាមទាំងឡាយ មានឧបមាដោយគប់ស្មៅមានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសមានច្រើនប្រការក្នុងកាមទាំងនេះ យ៉ាងនោះឯង អរិយសាវកឃើញសេចក្តីនេះតាមពិត ដោយប្រាជ្ញាដ៏ប្រពៃយ៉ាងនេះ ។បេ។ ក៏ចម្រើននូវឧបេក្ខានោះឯង ។

ម្នាលគហបតី ដូចជារណ្តៅរងើកភ្លើង មានជម្រៅមួយជំហរបុរសដ៏ពេញដោយរងើកភ្លើងឥតមានអណ្តាត ឥតមានផ្សែង

កាលនោះ មានបុរសម្នាក់មានប្រាថ្នាដើម្បីរស់នៅ មិនប្រាថ្នាដើម្បីស្លាប់ ប្រាថ្នាសេចក្ដីសុខ ខ្ពើមសេចក្ដីទុក្ខ ដើរមក ( កាន់រណ្ដៅនោះ ) មានបុរសខ្លាំងពូកែពីរនាក់ ចាប់បុរសនោះ ត្រង់កំភួនដៃម្ខាងម្នាក់ ទាញទម្លាក់ទៅក្នុងរណ្ដៅ ម្នាលគហបតី អ្នកសម្គាល់សេចក្ដីនោះថាដូចម្ដេច តើបុរសនោះគួរបង្អោនកាយ ( ទៅកាន់រណ្ដៅ ) នោះដូច្នេះខ្លះ ដូច្នោះខ្លះដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន បុរសនោះ មិនគួរបង្អោនកាយទៅឡើយ ដំណើរនោះ ព្រោះហេតុអ្វី បពិត្រព្រះអង្គដ៏ចម្រើន ព្រោះបុរសនោះដឹងច្បាស់ថា បើអាត្មាអញនឹងធ្លាក់រណ្ដៅរងើកភ្លើងនេះ អាត្មាអញនឹងដល់នូវសេចក្ដីស្លាប់ ឬសេចក្ដីទុក្ខជិតស្លាប់ ព្រោះរណ្ដៅរងើកភ្លើងនោះជាហេតុ ។ ម្នាលគហបតី អរិយសាវកតែងពិចារណាដូច្នេះថា ព្រះមានព្រះភាគទ្រង់សម្ដែងហើយថា កាមទាំងឡាយ មានឧបមាដោយរណ្ដៅរងើកភ្លើង មានទុក្ខច្រើន មានសេចក្ដីចង្អៀតចង្អល់ច្រើន ទោសមានច្រើនប្រការក្នុងកាមទាំងនេះយ៉ាងនោះឯង អរិយសាវកឃើញសេចក្ដីនេះតាមពិតដោយប្រាជ្ញាដ៏ប្រពៃយ៉ាងនេះហើយ ។បេ។ ក៏ចម្រើននូវឧបេក្ខានោះឯង ។

ម្នាលគហបតី ដូចជាបុរសយល់សប្ដិឃើញអារាមជាទីសប្បាយ ព្រៃជាទីសប្បាយ ផែនដីជាទីសប្បាយ និងស្រះ

បោក្ខរណីជាទីសប្បាយ លុះបុរសនោះភ្ញាក់ឡើង មិនឃើញអ្វីមួយឡើយ ម្នាលគហបតី អរិយសាវកតែងពិចារណាដូច្នេះថា ព្រះមានព្រះភាគទ្រង់សម្តែងហើយថា កាមទាំងឡាយ មានឧបមាដោយយល់សប្តិ មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសមានច្រើនប្រការក្នុងកាមទាំងនេះយ៉ាងនោះឯង ។បេ។ ក៏ចម្រើននូវឧបេក្ខានោះឯង ។

ម្នាលគហបតី ដូចជាបុរសខ្ចីទ្រព្យគេជារបស់បណ្តោះអាសន្ន គឺកែវមណីនិងកុណ្ឌល ( គ្រឿងប្រដាប់ត្រចៀក ) ដ៏ប្រសើរ ហើយឡើងកាន់យាន បុរសនោះ បានប្រដាប់តាក់តែងដោយទ្រព្យជារបស់ខ្ចីគេបណ្តោះអាសន្នទាំងនោះ ដើរទៅកាន់រានផ្សារ អ្នកផងបានឃើញបុរសនោះហើយ ក៏និយាយយ៉ាងនេះថា អើហ្ន៎ បុរសនេះ មានភោគសម្បត្តិច្រើនណាស់ បានឮថា ពួកជនអ្នកមានភោគសម្បត្តិ រមែងបរិភោគសម្បត្តិយ៉ាងហ្នឹងតើ បើពួកជនជាម្ចាស់គប្បីឃើញបុរសនោះក្នុងទីណាៗ ក៏គប្បីយកទ្រព្យដែលជារបស់ខ្លួន ក្នុងទីនោះទៅ ម្នាលគហបតី អ្នកសម្គាល់សេចក្តីនោះថាដូចម្តេច បុរសនោះគួរអាក់អន់ចិត្តឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន បុរសនោះមិនគួរនឹងអាក់អន់ចិត្តទេ ដំណើរនោះព្រោះហេតុអ្វី បពិត្រព្រះអង្គដ៏ចម្រើន ព្រោះពួកជនជាម្ចាស់ទ្រព្យ នាំយកទ្រព្យ

ដែលជារបស់ខ្ចីនទៅ ។ ម្នាលគហបតី អរិយសាវកតែង ពិចារណា ដូច្នេះថា ព្រះមានព្រះភាគទ្រង់សម្ដែងហើយថា កាមទាំងឡាយ មានឧបមាដោយរបស់ខ្ចីគេ មានទុក្ខច្រើន មានសេចក្ដីចង្អៀតចង្អល់ច្រើន ទោសមានច្រើនប្រការ ក្នុងកាមទាំងនេះ យ៉ាងនោះឯង ។បេ។ ក៏ចម្រើននូវឧបេក្ខានោះឯង ។

ម្នាលគហបតី ដូចជាជនព្រៃស្តុក នៅជិតស្រុកឬនិគមមាន ដើមឈើក្នុងព្រៃនោះ ជាឈើមានផ្លែផ្អែមផង មានផ្លែដ៏ច្រើន ផង សូម្បីផ្លែណាមួយ ក៏មិនជ្រុះចុះលើផែនដីឡើយ ទើប មានបុរសម្នាក់ជាអ្នកត្រូវការដោយផ្លែ ស្វែងរកផ្លែ ត្រាច់ទៅ ស្វែងរកផ្លែ ក៏ដើរមកដល់ បុរសនោះដើរចូលទៅកាន់ជង ព្រៃនោះ ឃើញដើមឈើនោះមានផ្លែផ្អែមផង មានផ្លែច្រើន ផង ទើបបុរសនោះគិតយ៉ាងនេះថា ឈើនេះឯង មានផ្លែផ្អែម ផង មានផ្លែច្រើនផង សូម្បីផ្លែណាមួយ ក៏មិនជ្រុះចុះលើផែន ដីឡើយ ឯអាត្មាអញក៏ចេះឡើងឈើដែរ បើដូច្នោះ មាន តែអាត្មាអញឡើងកាន់ដើមឈើនេះ ហើយទំពាស៊ីត្រាតែឆ្អែត ផង ដក់ថ្នក់ផង លុះបុរសនោះគិតហើយ ក៏ឡើងកាន់ដើម ឈើនោះ ទំពាស៊ីត្រាតែឆ្អែតផង ដក់ថ្នក់ផង កាលនោះ មាន បុរសជាគម្រប់ពីរ ជាអ្នកត្រូវការដោយផ្លែ ស្វែងរកផ្លែត្រាច់

ទៅស្វែងរកផ្លែ ក៏កាន់យកដីងដ៏មុត ដើរមកដល់បុរសនោះ ចូលទៅកាន់ដងព្រៃនោះ ហើយឃើញនូវដើមឈើនោះ មានផ្លែផ្អែមផង មានផ្លែច្រើនផង ទើបបុរសនោះគិតយ៉ាងនេះថា ឈើនេះឯងមានផ្លែផ្អែមផង មានផ្លែច្រើនផង សូម្បីផ្លែណាមួយ ក៏មិនជ្រុះចុះលើផែនដីឡើយ ឯអាត្មាអញមិនចេះឡើងដើមឈើឡើយ បើដូច្នោះ មានតែអាត្មាអញកាប់ដើមឈើនេះត្រង់គល់ ហើយទំពាស៊ីត្រាតែឆ្អែតផង ដក់ថ្នក់ផង លុះបុរសនោះគិតហើយ ក៏កាប់ដើមឈើនោះត្រង់គល់ ម្នាលគហបតី អ្នកសម្គាល់សេចក្តីនោះថាដូចម្តេច បុរសដែលឡើងដើមឈើមុនគេនោះ បើមិនចុះមកដោយរហ័សទេ ដើមឈើនោះកាលរលំចុះ គប្បីបំបាក់ដៃ បំបាក់ជើង បំបាក់អវយវៈតូចធំណានីមួយរបស់បុរសនោះ បុរសនោះគប្បីដល់នូវសេចក្តីស្លាប់ ឬសេចក្តីទុក្ខជិតនឹងស្លាប់ ព្រោះផ្លែឈើនោះជាហេតុមែនឬទេ ។ ព្រះករុណាព្រះអង្គ ។ ម្នាលគហបតី អរិយសាវក តែងពិចារណាដូច្នេះថា ព្រះមានព្រះភាគទ្រង់សម្តែងហើយថា កាមទាំងឡាយមានឧបមាដោយផ្លែឈើ មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសមានច្រើនប្រការក្នុងកាមទាំងនេះ យ៉ាងនោះឯង អរិយសាវក ឃើញសេចក្តីនេះតាមពិត ដោយប្រាជ្ញាដ៏ប្រពៃយ៉ាងនេះហើយ ក៏លះបង់

ឧបេក្ខា ដែលមានសភាពផ្សេងគ្នា អាស្រ័យអារម្មណ៍មាន
សភាពផ្សេងគ្នា ហើយចម្រើនឧបេក្ខា ដែលមានសភាពតែ
មួយ អាស្រ័យអារម្មណ៍មានសភាពតែមួយ និងឧបេក្ខាជាទី
រលត់ទៅនៃឧបាទានជាលោកាមិសៈ មិនមានសេសសល់
ដោយប្រការទាំងពួង ដូច្នេះ ។

ព្រះសារីបុត្តត្ថេរ សម្តែងវិបស្សនា ដោយប្រៀបនឹងគ្រោងឆ្អឹងជាដើមនិង
ប្រៀបដូចគំនរភ្លើងជាទីបំផុតដូច្នេះហើយ ឥឡូវនេះ កាលសម្តែងឧបចារសមាធិ
ទើបពោលពាក្យថា **ពុទ្ធានុស្សតឹ ភាវេន្តោ** ជាដើម ។

បណ្តាបទទាំងនោះ សតិនោះឯង ឈ្មោះថា **អនុស្សតិ** ព្រោះកើតឡើង
រឿយៗ ។ម្យ៉ាងទៀត ឈ្មោះថា **អនុស្សតិ** ព្រោះអត្ថថា សតិដែលសមគួរ
ដល់កុលបុត្តដែលបួសដោយសទ្ធា ព្រោះប្រព្រឹត្តទៅក្នុងឋានៈដែលគួរឲ្យ
ប្រព្រឹត្តទៅនោះឯងដូច្នេះក៏មាន ។ **អនុស្សតិ** ដែលកើតឡើងប្រារព្ធព្រះពុទ្ធ
ឈ្មោះថា **ពុទ្ធានុស្សតឹ** ។ ពាក្យថា **ពុទ្ធានុស្សតឹ** នេះ ជាឈ្មោះរបស់សតិ
ដែលមានពុទ្ធគុណ មាន **អរហំ** ជាដើមជាអារម្មណ៍ ។ នូវពុទ្ធានុស្សតិ
នោះ ។ បទថា **ភាវេន្តោ** បានដល់ ចម្រើន គឺកពូន ។

**អនុស្សតិ** ដែលកើតឡើងប្រារព្ធព្រះធម៌ ឈ្មោះថា **ធម្មានុស្សតឹ** ពាក្យ
ថា **ធម្មានុស្សតឹ** នេះ ជាឈ្មោះរបស់សតិដែលមានព្រះធម្មគុណ មានភាព
ជាធម៌ដែលព្រះដ៏មានព្រះភាគត្រាស់ល្អហើយ ជាដើមជាអារម្មណ៍ ។ **អនុស្សតិ**
ដែលកើតឡើងប្រារព្ធព្រះសង្ឃ ឈ្មោះថា **សង្ឃានុស្សតឹ** ពាក្យថា **សង្ឃា-**

**នុស្សតិ** នេះ ជាឈ្មោះរបស់សតិដែលមានព្រះសង្ឃគុណ មានភាពជាអ្នកបដិបត្តិល្អជាដើមជាអារម្មណ៍ ។ **អនុស្សតិ** ដែលកើតឡើងប្រារព្ធសីល ឈ្មោះថា **សីលានុស្សតិ** ។ ពាក្យថា **សីលានុស្សតិ** នេះជាឈ្មោះរបស់សតិដែលមានសីលគុណ មានការមិនដាច់នៃសីលជាដើម របស់ខ្លួនជាអារម្មណ៍ ។ **អនុស្សតិ** ដែលកើតឡើងប្រារព្ធចាគៈ ឈ្មោះថា **ចាគានុស្សតិ** ។ ពាក្យថា **ចាគានុស្សតិ** នេះ ជាឈ្មោះរបស់សតិ ដែលមានចាគគុណ មានភាពជាអ្នកមានចាគៈដែលលះហើយរបស់ខ្លួនជាដើមជាអារម្មណ៍ ។ **អនុស្សតិ** ដែលកើតឡើងប្រារព្ធទេវតា ឈ្មោះថា **ទេវតានុស្សតិ** ។ ពាក្យថា **ទេវតា-នុស្សតិ** នេះជាឈ្មោះរបស់សតិ ដែលមានគុណមានសទ្ធារបស់ខ្លួនជាដើមតម្កល់ទេវតាទាំងឡាយទុកក្នុងឋានៈជាបន្ទាល់ជាអារម្មណ៍ ។ **អនុស្សតិ** ដែលកើតឡើងប្រារព្ធខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញ ឈ្មោះថា **អានាបា-នស្សតិ** ។ ពាក្យថា **អានាបានស្សតិ** នេះជាឈ្មោះរបស់សតិដែលមាននិមិត្តនៃខ្យល់ដង្ហើមចេញចូលជាអារម្មណ៍ ។ **អនុស្សតិ** ដែលកើតឡើងប្រារព្ធការស្លាប់ ឈ្មោះថា **មរណានុស្សតិ** ពាក្យថា **មរណានុស្សតិ** នេះជាឈ្មោះរបស់សតិដែលមានការស្លាប់ពោល គឺការបែកធ្លាយនៃជីវិតិន្ទ្រិយដែលទាក់ទងក្នុងភពមួយជាអារម្មណ៍ ។

សតិដែលទៅ គឺប្រព្រឹត្តទៅក្នុងសរីរៈដែលរាប់ថាកាយ ព្រោះជាការចម្រើន គឺជាអណ្តូងកើតនៃវត្ថុបដិកូលទាំងឡាយ មានសក់ជាដើមដែលគួរខ្ពើម ឈ្មោះថា **កាយគតាសតិ** កាលគួរពោលថា **កាយគតសតិ** លោក

ពោលថា **កាយគតាសតិ** ព្រោះមិនធ្វើរស្សៈ ក្នុងទីនេះលោកពោលពាក្យនេះជា **កាយគតាសតិ** ដូចគ្នា ។ ពាក្យថា **កាយគតាសតី** នេះជាឈ្មោះរបស់សតិ ដែលមាននិមិត្តបដិកូលក្នុងចំណែកនៃរាងកាយ មានសក់ជាដើមជាអារម្មណ៍ ។ **អនុស្សតិ** ដែលកើតឡើងប្រារព្ធការស្ងប់ ឈ្មោះថា **ឧបសមានុស្សតី** ពាក្យថា **ឧបសមានុស្សតី** នេះជាឈ្មោះរបស់សតិដែលមានព្រះនិព្វានជាទីចូលទៅស្ងប់ទុក្ខទាំងពួងជាអារម្មណ៍ ។

បុគ្គលចម្រើនបឋមជ្ឈាន ដែលប្រកបដោយវិតក្ក វិចារៈ បីតិ សុខៈនិងចិត្តេកគ្គតា ។ បុគ្គលចម្រើនទុតិយជ្ឈានដែលប្រកបដោយបីតិ សុខៈ និងចិត្តេកគ្គតា ។ បុគ្គលចម្រើនតតិយជ្ឈាន ដែលប្រកបដោយសុខៈ និងចិត្តេកគ្គតា ។ បុគ្គលចម្រើនចតុត្ថជ្ឈានដែលប្រកបដោយឧបេក្ខា និងចិត្តេកគ្គតា ។បេ។ សូម្បីបុគ្គលចម្រើននេវសញ្ញានាសញ្ញាយតនសមាបត្តិ រមែងវៀរចាកកាមទាំងឡាយ ។ កាលព្រះសារីបុត្តត្ថេរសម្តែងការលះនូវកាម ដោយការសង្កត់ទុកដោយប្រការដូច្នេះ ឥឡូវនេះ ដើម្បីសម្តែងនូវការលះកាមទាំងឡាយដោយការកាត់ផ្តាច់ ទើបពោលពាក្យថា **សោតាបត្តិមគ្គំ ភាវេន្តោបិ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ ការដល់ក្រសែនៃមគ្គ ឈ្មោះថា **សោតាបត្តិ** ។ មគ្គនៃការដល់ក្រសែនៃព្រះនិព្វាន ឈ្មោះថា **សោតាបត្តិមគ្គំ** ។

បទថា **អបាយគមនីយេ កាមេ** សេចក្តីថា កាលចម្រើនសោតាបត្តិមគ្គរមែងវៀរចាកកាមដែលឲ្យទៅកាន់អបាយ ដែលជាគ្រឿងឲ្យសត្វទៅកាន់

អបាយទាំងនោះ ដោយការកាត់ផ្តាច់ ។

ឈ្មោះថា **សកទាគាមិ** ព្រោះអត្ថថា មកបដិសន្ធិក្នុងលោកនេះអស់វារៈម្តងប៉ុណ្ណោះ មគ្គនៃសកទាគាមីនោះ ឈ្មោះថា **សកទាគាមិមគ្គំ** ។ បុគ្គលចម្រើនមគ្គនោះ ។

បទថា **ឱឡារិកេ** បានដល់ ដល់នូវការក្តៅក្រហាយ ឈ្មោះថា **អនាគាមី** ព្រោះអត្ថថា មិនមកបដិសន្ធិកាន់កាមភពឡើយ ។ មគ្គនៃអនាគាមីនោះ ឈ្មោះថា **អនាគាមិមគ្គ** ។ បុគ្គលចម្រើនមគ្គនោះ ។

បទថា **អណុសហគតេ** បានដល់ ដល់នូវភាពល្អិត ។ ឈ្មោះថា **អរហត្ត** ព្រោះឆ្ងាយចាកកិលេសទាំងឡាយ ព្រោះកម្ចាត់សត្រូវគឺកិលេស ព្រោះកាច់បំបាក់នូវកម្មនៃសង្សារវដ្ត ព្រោះមិនធ្វើបាបក្នុងទីកំបាំង និងព្រោះជាអ្នកគួរដល់បច្ច័យជាដើម ភាពនៃព្រះអរហន្ត ឈ្មោះថា **អរហត្ត** ។ អរហត្តនោះគឺអ្វី គឺអរហត្តផល ។ មគ្គនៃអរហត្ត ឈ្មោះថា **អរហត្តមគ្គំ** ។ បុគ្គលចម្រើនអរហត្តមគ្គនោះ ។

បទថា **សព្វេន សព្វំ** បានដល់ ទាំងពួង ដោយអាការទាំងពួង ។ បទថា **សព្វថា សព្វំ** បានដល់ ទាំងពួង ដោយប្រការទាំងពួង ។ បទថា **អសេសំ និស្សេសំ** បានដល់ មិនមានចំណែកដ៏សេស គឺមិនសេសសល់សូម្បីត្រឹមតែខន្ធ ។

ម្យ៉ាងទៀត បទថា **សព្វេន សព្វំ** ពោលដល់ឫសគល់ ។ បទថា **សព្វថា សព្វំ** ពោលចង្អុលដល់អាការៈ ។ បទថា **អសេសំ និស្សេសំ** ពោលចង្អុល

ដល់ការបំពេញ ។ម្យ៉ាងទៀតដោយបទដំបូង ពោលព្រោះមិនមានទុច្ចរិត ដោយបទទីពីរ ពោលព្រោះមិនមានការគ្របសង្កត់ ដោយបទទី ៣ ពោលព្រោះមិនមានអនុស័យ អាចារ្យពួកខ្លះពណ៌នាទុកយ៉ាងនេះ ។

[ ១៣ ] បទថា **សប្បោ វុច្ចតិ អហិ** សេចក្ដីថា ពស់ណាមួយលូនទើបទៅបាន ។ បទថា **កេនឌ្ឋេន** បានដល់ ព្រោះអត្ថថា អ្វី ។

បទថា **សំសប្បន្តោ គច្ឆតិ** សេចក្ដីថា ព្រោះជៀសវាងទៅ ដូច្នោះ ទើបហៅថា **សត្ត** ។ បទថា **ភុជន្តោ** សេចក្ដីថា លូនទៅ ។ បទថា **បន្នសិរោ** បានដល់ ជាសត្វមានក្បាលធ្លាក់ ។ បទថា **សិរេន សុបតិ** សេចក្ដីថា ឈ្មោះថា **សិរីសយោ** ព្រោះអត្ថថា ដេកដោយក្បាល ដោយភាពជាប្រហោង យកក្បាលទុកក្នុងរង្វេល ។ ឈ្មោះថា **វិលាសយោ** ព្រោះអត្ថថា ដេកក្នុងរន្ធ បាលីថា **ពិលសយោ** ក៏មាន ពាក្យនោះឯងល្អ ។ ឈ្មោះថា **គុហាសយោ** ព្រោះអត្ថថា ដេកក្នុងគុហា ។

បទថា **ទាឍា តស្ស អាវុធោ** សេចក្ដីថា ចង្កូមទាំងពីរជាអាវុធ ពោលគឺសស្ត្រាជាគ្រឿងប្រហាររបស់ពស់នោះ ។

បទថា **វិសំ តស្ស ឃោរំ** សេចក្ដីថា ពិស ពោលគឺទឹកដែលជាពិសរបស់ពស់នោះ ពន្លឹក ។ បទថា **ជិវ្ហា តស្ស ទ្វិធា** សេចក្ដីថា ពស់នោះមានអណ្ដាតបែកជាពីរ ។ បទថា **ទ្វីហិ ជិវ្ហាហិ រសំ សាយតិ** សេចក្ដីថា រមែងដឹងរស គឺរមែងជួបនូវការត្រេកអរ គឺរមែងត្រេកអរដោយអណ្ដាតដែលបែកជាពីរ ។

ឈ្មោះថា **ជីវិតុកាមោ** ព្រោះអត្ថថា ប្រាថ្នាដើម្បីនឹងរស់នៅ ។ ឈ្មោះថា **អមរិតុកាមោ** ព្រោះអត្ថថា មិនចង់ស្លាប់ ។ ឈ្មោះថា **សុខកាមោ** ព្រោះអត្ថថា ប្រាថ្នានូវសេចក្ដីសុខ ។ បទថា **ទុក្ខប្បដិក្កូលោ** បានដល់ មិនប្រាថ្នាសេចក្ដីទុក្ខ ។ បទថា **ចាគេន** បានដល់ ដោយជើងរបស់ខ្លួន ។ បទថា **សប្បសិរំ** បានដល់ ក្បាលរបស់ពស់ ។ បទថា **វជ្ជេយ្យ** បានដល់ គប្បីវៀរខាងមុខ ។ បទថា **វិវជ្ជេយ្យ** បានដល់ គប្បីវៀរដោយប្រមាណរបស់ពស់នោះ ។ បទថា **បរិវជ្ជេយ្យ** បានដល់ គប្បីវៀរដោយជុំវិញ ។ បទថា **អភិនិវជ្ជេយ្យ** បានដល់ គប្បីវៀរប្រមាណ ៤ ( ហត្ថ ) ។ ម្យ៉ាងទៀត ដោយបទដំបូង គប្បីវៀរអំពីក្បាល ។ បទទី ២ និងទី ៣ គប្បីវៀរទាំងសងខាង បទទី ៤ គប្បីវៀរខាងក្រោយ ។

ម្យ៉ាងទៀត អាចារ្យពួកមួយពណ៌នាទុកយ៉ាងនេះ គប្បីវៀរ ព្រោះភាពជាវត្ថុនៃទុក្ខ មានការស្វែងរកជាមូលរបស់បុគ្គលដែលមិនទាន់ដល់កាមទាំងឡាយ ។ គប្បីចៀសចេញ ព្រោះភាពជាវត្ថុនៃទុក្ខដែលមានការរក្សាជាមូលរបស់បុគ្គលដែលដល់នូវកាមហើយ ។ គប្បីគេចចេញ ព្រោះភាពជាវត្ថុនៃទុក្ខដែលក្ដៅក្រហាយ ព្រោះការមិនដឹង ។ គប្បីវៀរស្រឡះចេញ ព្រោះភាពជាវត្ថុនៃទុក្ខដែលកើតអំពីការព្រាត់ប្រាសចាករបស់ជាទីស្រឡាញ់ ក្នុងមាត់នៃសេចក្ដីវិនាស ដោយប្រការដូច្នេះ ។

[ ១៤ ] ឈ្មោះថា **រាគោ** ដោយអំណាចសេចក្ដីត្រេកអរ ។ ឈ្មោះថា **សារាគោ** ដោយអត្ថថា សេចក្ដីត្រេកអរដែលមានកម្លាំង ។ ឈ្មោះថា **អនុ-**

**ឆយោ** ព្រោះភាពជាសម្ងាញ់របស់ពួកសត្វក្នុងអារម្មណ៍ទាំងឡាយ ។ ឈ្មោះថា **អនុរាគោ** ព្រោះអត្ថថា ត្រេកអរ អធិប្បាយថា ប្រាថ្នា ។ ឈ្មោះថា **ឆន្ទិ** ព្រោះអត្ថថា ជាគ្រឿងត្រេកអរក្នុងកពណាមួយរបស់ពួកសត្វ ឬរមែងត្រេកអរឯង ។

តណ្ហាឈ្មោះថា **ឆន្ទិរាគោ** ព្រោះជាការត្រេកអរផង ជាតម្រេកផង អត្ថថា ត្រេកអរផង ។

ក្នុងបទទាំងពីរនោះ តណ្ហាដែលកើតឡើងម្តងក្នុងអារម្មណ៍មួយ ហៅថា **ឆន្ទិ** ដែលកើតឡើងរឿយៗហៅថា **ឆន្ទិរាគោ** ។

បទថា **ចិត្តស្ស សារាគោ** សេចក្តីថា តម្រេកណាក្នុងខាងដើម ដែលចូលមក លោកហៅថា **សារាគោ** ព្រោះអត្ថថា ការត្រេកអរដែលមានកម្លាំងខាងក្រោយ ការត្រេកអរនោះមិនមែនរបស់សត្វ ជាតម្រេកខ្លាំងក្លានៃចិត្តប៉ុណ្ណោះ ។ ឈ្មោះថា **ឥច្ឆា** ព្រោះអត្ថថា ជាគ្រឿងប្រាថ្នាអារម្មណ៍ទាំងឡាយ ។

ឈ្មោះថា **មុច្ឆា** ព្រោះអត្ថថា ជាគ្រឿងវង្វេងរបស់ពួកសត្វ ព្រោះភាពជាកិលេសក្រាស់ ។

ឈ្មោះថា **អជ្ឈោសានំ** ព្រោះលេបឲ្យសម្រេចហើយប្រកាន់ ។ ឈ្មោះថា **គេធោ** ព្រោះអត្ថថា ជាគ្រឿងត្រូវការ គឺដល់នូវការត្រេកអររបស់ពួកសត្វ ។ម្យ៉ាងទៀត ឈ្មោះថា **គេធោ** ព្រោះអត្ថថា ក្រាស់ ។ លោកពោលថា ម្យ៉ាងទៀត ការជាប់នោះឯង ជាព្រៃក្រាស់ធំ ព្រោះអត្ថថា ក្រាស់ដូចគ្នា លោកបន្ថែមពាក្យបន្ទាប់ទៅដោយឧបសគ្គ ។

ឈ្មោះថា **បលិគោធោ** ព្រោះអត្ថថា គ្រកអរគ្រប់យ៉ាង ឬតាមចំណែក ។ ឈ្មោះថា **សង្គោ** ព្រោះអត្ថថា ជាគ្រឿងជាប់ជំពាក់របស់ពួកសត្វ ម្យ៉ាងទៀត ឈ្មោះថា **សង្គោ** ព្រោះអត្ថថា ជាគ្រឿងជាប់ជំពាក់ ។

ឈ្មោះថា **បង្គោ** ព្រោះអត្ថថា លិចចុះ ។ ឈ្មោះថា **ឯជា** ព្រោះអូសទាញ សមដូចពាក្យដែលលោកពោលទុកថា តណ្ហា ឈ្មោះថា **ឯជា** រមែងអូសទាញបុរសនេះ ដើម្បីកើតឡើងក្នុងភពនោះៗឯង ។

ឈ្មោះថា **មាយា** ព្រោះអត្ថថា បោកបញ្ឆោត ។

ឈ្មោះថា **ជនិកា** ព្រោះអត្ថថា ញុាំងសត្វទាំងឡាយឲ្យកើតក្នុងវដ្តៈ សមដូចព្រះតម្រាស់ត្រាស់ទុក ( ក្នុងសំយុត្តនិកាយសគាថវគ្គ ) ថា តណ្ហាតែងញុាំងបុរសឲ្យកើត ចិត្តរបស់បុរសនោះ តែងស្ទុះទៅ ដូច្នេះ ។

ឈ្មោះថា **សញ្ជននី** ព្រោះអត្ថថា ញុាំងសត្វឲ្យកើត ប្រកបទុកដោយទុក្ខ ។ ឈ្មោះថា **សិព្វិនី** ព្រោះអត្ថថា ជាប់ណែន ។ ព្រោះតណ្ហានេះ ដេរភ្ជាប់ គឺធ្វើសត្វឲ្យជាប់ណែនក្នុងវដ្តៈ ដោយអំណាចនៃចុតិនិងបដិសន្ធិ ដូចជាងដេរ ដេរសំពត់ចាស់ដោយសំពត់ចាស់ដូច្នោះ ទើបលោកពោលថា ឈ្មោះថា ដេរ ព្រោះអត្ថថា ជាប់ស្អិត ។

ឈ្មោះថា **ជាលិនី** ព្រោះអត្ថថា មានសំណាញ់ គឺអារម្មណ៍មានប្រការមិនមែនតិច ឬសំណាញ់ ពោលគឺការប្រកាន់មាំដោយការអន្ទះអន្ទែងនៃតណ្ហា ។

ឈ្មោះថា **សរិតា** ព្រោះអត្ថថា ដូចក្រសែទឹកដែលហូររហ័ស ព្រោះ

អត្ថថា អួសទាញ ។ មយ៉ាងទៀត ឈ្មោះថា **សរិតា** ព្រោះអត្ថថា ទទឹក សមដូចព្រះតម្រាស់ដែលលោកពោលទុក ( ក្នុងធម្មបទ ) ថា **សរិតានិ សិនេហិតានិ ច សោមនស្សានិ ភវន្តិ ជន្តុនោ** សោមនស្សទាំងឡាយ ដែលផ្សាយទៅហើយផង ដែលប្រព្រឹត្តទៅដោយសេចក្ដីស្រឡាញ់ផង រមែងមានដល់សត្វ ដូច្នេះ ។ ក្នុងសេចក្ដីនេះមានអត្ថដូច្នេះថា ទាំងត្រេកអរ ទាំងគួរស្រឡាញ់ ។

ឈ្មោះថា **សុត្តំ** ព្រោះអត្ថថា ដូចសរសៃអំបោះចងអណ្ដើក ព្រោះអត្ថថា ឲ្យដល់នូវសេចក្ដីវិនាស មិនមែនសេចក្ដីចម្រើន សមដូចព្រះតម្រាស់ដែលត្រាស់ទុក ( ក្នុងសំយុត្តនិកាយនិទានវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ ពាក្យថា ខ្សែន្ទុះជាឈ្មោះនៃនន្ទិរាគ ( តម្រេកដោយសេចក្ដីត្រេកត្រអាល ) ដូច្នេះ ។ ឈ្មោះថា **វិសដា** ព្រោះអត្ថថា ផ្សាយទៅក្នុងរូបជាដើម ។

ឈ្មោះថា **អាយូហានី** ព្រោះអត្ថថា សត្វរមែងញ៉ាំងអាយុឲ្យវិនាសទៅ ដើម្បីបានចំពោះនូវអារម្មណ៍នោះៗ ។

ឈ្មោះថា **ទុតិយា** ព្រោះអត្ថថាជាសម្លាញ់ ព្រោះមិនឲ្យក្រវល់ក្រវាយ តណ្ហានេះរមែងមិនឲ្យសត្វទាំងឡាយក្រវល់ក្រវាយក្នុងវដ្តៈ រមែងឲ្យត្រេកអរក្រៃលែង ដូចសម្លាញ់ជាទីស្រឡាញ់ក្នុងទីដែលទៅហើយ ព្រោះហេតុនោះឯង ទើបលោកពោលទុក ( ក្នុងខុទ្ទកនិកាយឥតិវុត្តក ) ថា

បុរសមានតណ្ហាជាគម្រប់ពីរ កាលអន្ទោលទៅកាន់សង្សារ
អស់កាលដ៏វែង រមែងមិនកន្លងនូវសង្សារវដ្ដ ដែលមាន

សភាពយ៉ាងនេះ និងយ៉ាងដទៃបានឡើយ ដូច្នេះ ។

ឈ្មោះថា **បណិធិ** ដោយអំណាចនៃការតាំងមាំ ។ បទថា **ភវនេត្តិ** បានដល់ ខ្សែជាគ្រឿងនាំទៅកាន់ភព ។ មែនពិត សត្វទាំងឡាយដែលតណ្ហានេះនាំទៅកាន់ទីប្រាថ្នាហើយ ដូចគោទាំងឡាយត្រូវខ្សែចងកនាំទៅ ។

ឈ្មោះថា **វនំ** ព្រោះអត្ថថា ជាប់ គឺគប់ គឺសើមក្នុងអារម្មណ៍នោះៗ ពង្រីកបទដោយព្យញ្ជនៈជា **វនថោ** ។ម្យ៉ាងទៀត ឈ្មោះថា **វនំ** ព្រោះអត្ថថា ហាក់បីដូចជាព្រៃ ដោយអត្ថថា ញុំាងទុក្ខដែលមិនមែនប្រយោជន៍ឲ្យតាំងឡើង និងដោយអត្ថថា ព្រៃក្រាស់ ពាក្យនេះជាឈ្មោះរបស់តណ្ហាដែលមានកម្លាំង តែតណ្ហាដែលមានកម្លាំងជាងនោះ ឈ្មោះថា **វនថោ** ដោយអត្ថថា ព្រៃក្រាស់ ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគ ត្រាស់ទុក ( ក្នុងខុទ្ទកនិកាយធម្មបទ ) ថា

> អ្នកទាំងឡាយចូរកាត់កិលេសដូចជាព្រៃចេញ ចូរកុំកាត់ដើមឈើ ( ព្រោះ ) ភ័យកើតអំពីកិលេសដូចជាព្រៃ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរកាត់កិលេសដូចជាព្រៃផង កិលេសដូចជាដើមឈើដុះក្នុងព្រៃផង ហើយចូរជាអ្នកកុំមានកិលេសដូចជាព្រៃឡើយ ដូច្នេះ ។

ឈ្មោះថា **សន្ថវោ** ដោយអំណាចនៃការស្និទ្ធស្នាល អធិប្បាយថា ជាប់ជំពាក់ សន្ថវៈនោះមានពីរយ៉ាង គឺតណ្ហាសន្ថវៈ ១ មិត្តសន្ថវៈ ១ ក្នុងពីរយ៉ាងនោះ ក្នុងទីនេះបំណងយកតណ្ហាសន្ថវៈ ។

ឈ្មោះថា **ស្នេហោ** ប្រែថា ដោយអំណាចនៃសេចក្តីស្រឡាញ់ ។ ឈ្មោះថា **អបេក្ខា** ព្រោះអត្ថថា សម្លឹងដោយអំណាចធ្វើនូវសេចក្តីអាល័យ សមដូចលោកពោលទុក ( ក្នុងទីឃនិកាយ មហាវគ្គ ) ថា បពិត្រព្រះសម្មតិទេព នគរទាំង ៨៤០០០ របស់ព្រះអង្គនេះ មាននគរកុសាវតីរាជធានីជាប្រធាន បពិត្រព្រះសម្មតិទេព សូមព្រះអង្គបង្កើតនូវសេចក្តីស្រឡាញ់ចំពោះនគរទាំងនុ៎ះ សូមព្រះអង្គធ្វើនូវសេចក្តីអាល័យក្នុងជីវិត ដូច្នេះ ។ ក្នុងសេចក្តីនេះ មានអត្ថដូច្នេះថា ចូរធ្វើនូវសេចក្តីអាល័យ ។

ឈ្មោះថា **បដិពន្ធា** ព្រោះអត្ថថា ចងក្នុងអារម្មណ៍មួយបែបៗ ឬដែលមានអារម្មណ៍ចំពោះឲ្យជាប់ជំពាក់ ដោយអត្ថថា ជាញាតិ ។ ឈ្មោះថា ញាតិ ដែលស្មើដោយតណ្ហារបស់សត្វទាំងឡាយ ដោយអត្ថថា អាស្រ័យជានិច្ចរមែងមិនមាន ។

ឈ្មោះថា **អាសា** ព្រោះជាអាហារនៃអារម្មណ៍ទាំងឡាយ អធិប្បាយថា ព្រោះលិចលង់ផង ព្រោះការពេញចិត្តបរិភោគផង ។

ឈ្មោះថា **អាសីសនា** ដោយអំណាចនៃចំណង់ ភាវៈនៃចំណង់ឈ្មោះថា **អាសីសិតត្តំ** ។ ឥឡូវនេះ ដើម្បីសម្តែងឋានៈដែលប្រព្រឹត្តទៅរបស់តណ្ហានោះ ទើបព្រះសារីបុត្តត្ថេរពោលពាក្យជាដើមថា **រូបាសា** ដូច្នេះ ។

ក្នុងបទទាំងនោះ គប្បីកាន់យកអត្ថនៃ **អាសា** ដោយអំណាចនៃការប៉ុនប៉ង ហើយជ្រាបបទទាំង ៩ យ៉ាងនេះថា ការប៉ុនប៉ងក្នុងរូប ឈ្មោះថា **រូបាសា** ។ ក្នុងបទនេះ ៥ បទដំបូង លោកពោលដោយអំណាចនៃកាមគុណ ៥ ។

បទទី ៦ លោកពោលដោយអំណាចនៃសេចក្ដីលោភក្នុងបរិក្ខារ ។ បទទី ៦ នោះ ពោលសម្រាប់បព្វជិតជាពិសេស ។

៣ បទក្រៅអំពីនោះ ពោលសម្រាប់គ្រហស្ថ ដោយអំណាចវត្ថុដែលមិនជាទីពេញចិត្ត ព្រោះគ្រហស្ថទាំងឡាយ វត្ថុដែលជាទីស្រឡាញ់ជាងទ្រព្យ បុត្តនិងជីវិត រមែងមិនមាន ។ ឈ្មោះថា **ជប្បា** ព្រោះអត្ថថា ញុំាងសត្វទាំងឡាយឲ្យប្រាថ្នាយ៉ាងនេះថា នេះជារបស់អញ ឬថាបុគ្គលនោះឲ្យនូវវត្ថុនេះៗដល់អញ ។ ២ បទតទៅ លោកបន្ថែមឧបសគ្គ ។ បន្ទាប់អំពីនោះ លោកពោលពាក្យថា **ជប្បា** ទៀត ព្រោះប្រារព្ធនឹងចែកសេចក្ដីដោយអាការៈដទៃ ។ អាការៈនៃ **ជប្បា** ឈ្មោះថា **ជប្បានា** ។ ភាវៈនៃ **ជប្បា** ឈ្មោះថា **ជប្បិតត្តំ** ។

ឈ្មោះថា **លោលុប្បា** ព្រោះអត្ថថា ញាប់ញ័រ គឺទាញទុកក្នុងអារម្មណ៍រឿយៗ ។ ភាវៈដែលញាប់ញ័រ ឈ្មោះថា **លោលុប្បា** អាការៈនៃ **លោលុប្បា** ឈ្មោះថា **លោលុប្បាយនា** ភាពជាបុគ្គលមានការដល់ព្រមដោយ **លោលុប្បា** ឈ្មោះថា **លោលុប្បាយិតត្តំ** ។

បទថា **បុច្ឆញ្ជិកតា** បានដល់ តណ្ហាជាគ្រឿងឲ្យសត្វទាំងឡាយញាប់ញ័រ គឺញាប់ញ័រត្រាច់ទៅក្នុងទីមានលាភដូចសុនខ ។ បទនេះជាឈ្មោះនៃតណ្ហាជាគ្រឿងញាប់ញ័រនោះ ។

បទថា **សាធុកម្យតា** មានវិគ្គហថា ឈ្មោះថា អ្នកប្រាថ្នាល្អ ព្រោះអត្ថថា ប្រាថ្នាក្នុងអារម្មណ៍ដែលល្អ គឺដែលគួរពេញចិត្ត ។ ភាពនៃបុគ្គលប្រាថ្នាល្អ

នោះឈ្មោះថា **សាធុកម្យតា** ។ ឈ្មោះថា **អធម្មរាគោ** ព្រោះអត្ថថា តម្រេកក្នុងឋានៈមិនសមគួរ មានមាតានិងអ៊ុំស្រីជាដើម ។ សេចក្តីលោភដែលកើតឡើងមានកម្លាំងក្នុងឋានៈ ដែលសមគួរ ឈ្មោះថា **វិសមលោភោ** ។ ម្យ៉ាងទៀត ព្រោះព្រះបាលីថា រាគៈជាធម្មជាតមិនរាបស្មើ ទើបគប្បីជ្រាបថា ឆន្ទរាគដែលកើតឡើងក្នុងឋានៈដែលសមគួរក្តី ក្នុងឋានៈដែលមិនសមគួរក្តី ឈ្មោះថា **អធម្មរាគោ** ព្រោះអត្ថថា ខុសធម៌និងឈ្មោះថា **វិសមលោភោ** ព្រោះអត្ថថា មិនស្មើ ។

ឈ្មោះថា **និកន្តិ** ដោយអំណាចនៃការប្រាថ្នាអារម្មណ៍ទាំងឡាយ ។ អាការៈនៃការប្រាថ្នា ឈ្មោះថា **និកាមនា** ។ ឈ្មោះថា **បត្ថនា** ដោយអំណាចនៃការប្រាថ្នាវត្ថុ ។ ឈ្មោះថា **បិហនា** ដោយអំណាចនៃសេចក្តីត្រូវការ ។ ការប្រាថ្នាល្អ ឈ្មោះថា **សម្បត្ថនា** ។ តណ្ហាក្នុងកាមគុណ ៥ ឈ្មោះថា **កាមតណ្ហា** ។ តណ្ហាក្នុងរូបភពនិងអរូបភព ឈ្មោះថា **ភវតណ្ហា** ។ តណ្ហាក្នុងការមិនមាន ពោលគឺដាច់សូន្យ ឈ្មោះថា **វិភវតណ្ហា** ។ តណ្ហាក្នុងរូបភពដែលបរិសុទ្ធនោះឯងឈ្មោះថា **រូបតណ្ហា** ។ តណ្ហាក្នុងអរូបភព ឈ្មោះថា **អរូបតណ្ហា** បានដល់ តម្រេកដែលប្រកបដោយឧច្ឆេទទិដ្ឋិ ។ តណ្ហាក្នុងនិរោធ ឈ្មោះថា **និរោធតណ្ហា** ។ តណ្ហាក្នុងសំឡេង ឈ្មោះថា **សទ្ទតណ្ហា** ក្នុង **គន្ធតណ្ហា** ជាដើម ក៏ន័យនេះឯង ។ បទថា **ឱឃោ** ជាដើម មានអត្ថបានពោលទុកហើយ ។

ឈ្មោះថា **អាវរណំ** ព្រោះអត្ថថា រាំងកុសលធម៌ទាំងឡាយ ។ ឈ្មោះ

ថា **ជននំ** ដោយអំណាចជាគ្រឿងបិទ ។ ឈ្មោះថា **ពន្ធនំ** ព្រោះអត្ថថា ចង សត្វទាំងឡាយទុកក្នុងវដ្តៈ ។ ឈ្មោះថា **ឧបក្កិលេសោ** ព្រោះអត្ថថា បៀតបៀនចិត្ត សៅហ្មង គឺធ្វើឲ្យសៅហ្មង ។

ឈ្មោះថា **អនុសយោ** ព្រោះអត្ថថា ដេកត្រាំ ដោយអត្ថថា មានកម្លាំង ។ ឈ្មោះថា **បរិយុដ្ឋានំ** ព្រោះអត្ថថា កើតឡើងគ្របសង្កត់ចិត្ត ។ សេចក្តីថា ទាញយកអាចារៈដែលជាកុសល ដោយការមិនឲ្យកើតឡើង អធិប្បាយថា ទាញយកមគ្គទុកក្នុងអត្ថជាដើមថា **ចោរា មគ្គេ បរិយុដ្ឋឹសុ ធុត្តា មគ្គេ បរិយុដ្ឋឹសុ** ពួកចោរគ្រប់គ្រងក្នុងមាគ៌ា ពួកអ្នកលេងគ្រប់គ្រងក្នុងមាគ៌ា ។ ក្នុងទីនេះ គប្បីជ្រាបការគ្របសង្កត់ដោយអត្ថថា ប្រកាន់ដោយអាការៈយ៉ាងនេះ ។

ឈ្មោះថា **លតា** ព្រោះអត្ថថា ដូចជាវល្លិ ដោយអត្ថថា រឹតរុំ ដូចក្នុងអាគតដ្ឋានថា ដូចជាវល្លិ៍ដែលបែកខ្នែងឡើង តាំងនៅដូច្នោះ ។ តណ្ហានេះ លោកពោលថា **លតា** ដូចគ្នា ។

ឈ្មោះថា **វេវិច្ឆំ** ព្រោះអត្ថថា ប្រាថ្នាវត្ថុផ្សេងៗ ។ ឈ្មោះថា **ទុក្ខមូលំ** ព្រោះអត្ថថា ជាមូលនៃទុក្ខក្នុងវដ្តៈ ។ ឈ្មោះថា **ទុក្ខនិទានំ** ព្រោះអត្ថថា ជាហេតុនៃទុក្ខនោះឯង ។ ឈ្មោះថា **ទុក្ខប្បភវោ** ព្រោះអត្ថថា ទុក្ខនោះកើតអំពីតណ្ហានេះ ។

ឈ្មោះថា **បាសោ** ព្រោះអត្ថថា ដូចអន្ទាក់ ដោយអត្ថថា ចងទុកអន្ទាក់នៃមារ ឈ្មោះថា **មារបាសោ** ។

ឈ្មោះថា **ពឡិសំ** ព្រោះអត្ថថា ដូចសន្ទូច ដោយអត្ថថា លេបលំបាក

សន្ទូចនៃមារ ឈ្មោះថា **មារពឡិសំ** ។

ឈ្មោះថា **មារវិសយោ** ព្រោះអត្ថថា ជាវិស័យនៃមារដោយបរិយាយនេះថា សត្វទាំងឡាយដែលត្រូវតណ្ហាគ្របសង្កត់ហើយ រមែងមិនកន្លងផុតវិស័យរបស់មារទៅបាន មាររមែងប្រើអំណាចលើសត្វទាំងនោះ ។

ស្ទឹងគឺតណ្ហា ដោយអត្ថថា ហូរទៅ ឈ្មោះថា **តណ្ហានទី** ។ សំណាញ់គឺតណ្ហា ដោយអត្ថថា គ្របសង្កត់ ឈ្មោះថា **តណ្ហាជាលំ** ។ សុនខទាំងឡាយ ដែលចងទុកយ៉ាងខ្ជាប់ មនុស្សនាំទៅតាមប្រាថ្នាបាន យ៉ាងណា សត្វទាំងឡាយដែលតណ្ហាចងទុកហើយ ក៏យ៉ាងនោះ ។

ឈ្មោះថា **គទ្ទូលំ** ព្រោះអត្ថថា ដូចជាប្រវាក់ ដោយអត្ថថា ចងទុកយ៉ាងខ្ជាប់ខ្ជួន ប្រវាក់ គឺតណ្ហា ឈ្មោះថា **តណ្ហាគទ្ទូលំ** ។

សមុទ្ទគឺតណ្ហា ដោយអត្ថថា ឲ្យពេញបានដោយលំបាក ឈ្មោះថា **តណ្ហាសមុទ្ទោ** ។ ឈ្មោះថា **អភិជ្ឈា** ដោយអត្ថថា សម្ លឹង ។ ឈ្មោះថា **លោភោ** ព្រោះអត្ថថា ជាគ្រឿងបាន ឬបានឯង ឬត្រឹមតែបានប៉ុណ្ណោះ ។ ឈ្មោះថា **មូលំ** ដោយអត្ថថា ជាទីតាំងនៃអកុសលទាំងឡាយដែលប្រកបគ្នា ។

បទថា **វិសត្តិកាតិ** កាត់បទជា **វិសត្តិកា ឥតិ** ។ បទថា **កេនដ្ឋេន** បានដល់ ដោយសភាវៈណាមួយ ។ បទថា **វិសតា** បានដល់ ផ្សាយទៅហើយ ។ ឈ្មោះថា **វិសាលា** ព្រោះអត្ថថា ផ្សាយទៅក្នុងអារម្មណ៍មានរូបជាដើម ។ បទថា **វិសដា** បានដល់ ស្ទុះទៅដោយអំណាចផ្សាយទៅគ្រប់កន្លែងក្នុងភូមិ ៣ ឯពាក្យដំបូង ( **វិសតា** ) នេះ លោកពោលបែកព្យញ្ជនៈ ផ្លាស់ **ត** អក្ខរៈ

ជា ៨ អក្ខរៈ ។

បទថា **វិសត្តិកា** បានដល់ គ្រប់គ្រង គឺអត់ធន់ ។ បុគ្គលដែលត្រេកត្រអាល សូម្បីធាក់ដោយជើងដែលជាវត្ថុនៃរាគៈរមែងអត់ធន់បាន លោកពោលនូវការឃើតឃូរ ឬការអន្ទះអន្ទែងថា **វិសត្តិកា** ក៏មាន អាចារ្យពួកខ្លះពណ៌នាថា ជាធំរបស់កុសលនិងអកុសលទាំងឡាយ ។

បទថា **វិសំហរតិ** សេចក្តីថា ឃើញអានិសង្សក្នុងកាមទាំងឡាយយ៉ាងនោះៗ រមែងរួបរួម គឺដកចិត្តចាកការប្រព្រឹត្តទៅក្នុងនេក្ខម្មៈ ដោយអាការច្រើនយ៉ាង ។ ម្យ៉ាងទៀត សេចក្តីថា នាំទៅនូវសេចក្តីទុក្ខដែលមានពិស ។

បទថា **វិសំវាទិកា** សេចក្តីថា ជាហេតុឲ្យនិយាយខុសថា ចូរអ្នកកាន់យករបស់ដែលមិនទៀងជាដើម ថាជារបស់ទៀង ។

ឈ្មោះថា **វិសមូលា** ព្រោះភាពជាហេតុនៃកម្មដែលឲ្យកើតទុក្ខ ម្យ៉ាងទៀត ឈ្មោះថា **វិសមូលា** ព្រោះអត្ថថា មានទុក្ខដែលមានពិស គឺវេទនាដែលជាទុក្ខជាដើមជាឫសគល់ ។

ឈ្មោះថា **វិសផលា** ព្រោះអត្ថថា មានផលជាពិស ព្រោះជាហេតុកើតនៃទុក្ខ ការបរិភោគវត្ថុដែលជាទុក្ខ មានរូបជាដើមដែលមិនមែនអមតៈ រមែងមានដោយតណ្ហាណា ព្រោះហេតុនោះ តណ្ហានោះ ទើបពោលថា **វិសបរិ-ភោគា** បទដែលសម្រេចរូបក្នុងទីទាំងពួង គប្បីជ្រាបតាមគោលភាសា ។

ព្រះសារីបុត្តត្ថេរ បំណងនឹងសម្តែងវិស័យនៃតណ្ហានោះ ទើបពោលពាក្យជាដើមថា **វិសាលា វា បន សា រូបេ តណ្ហា** ដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ បទថា **វិសាលា វា បន** បានដល់ ឈ្មោះថា តណ្ហា ដោយអត្ថថា ប្រព្រឹត្តទៅដើម្បីការចង់បានខ្លាំងនោះឯង ។ រូបជាដើម លោកពោលដោយអំណាចនៃតម្រេកដែលប្រព្រឹត្តទៅក្នុងកាមគុណ ៥ ។ បទ ១១ មានបទថា **កុសេ គណោ** ជាដើម លោកពោលដោយអំណាចនៃការកើតឡើងនៃសេចក្ដីលោភ ។

តិកៈនៃកាមធាតុ លោកចែកដោយអំណាចនៃកម្មវដ្ដៈ តិកៈនៃកាមភព លោកចែកដោយអំណាចនៃវិបាកវដ្ដៈ តិកៈនៃសញ្ញាភព លោកចែកដោយអំណាចនៃសញ្ញា តិកៈនៃឯកវោការភព លោកចែកដោយអំណាចនៃខន្ធ តិកៈនៃអតីតៈ លោកចែកដោយអំណាចនៃកាល ។

ចតុកៈនៃទិដ្ឋិ លោកចែកដោយអំណាចនៃអារម្មណ៍ ។ តិកៈនៃអបាយ លោកចែកដោយអំណាចនៃឱកាស ។ តិកៈនៃខន្ធ លោកចែកដោយអំណាចនៃនិស្សន្ទ និជ្ជីវៈ គប្បីជ្រាបដូច្នេះ ។

ក្នុងបទទាំងនោះ មានការសម្ដែងអត្ថនិងការពង្រីកអត្ថដោយសង្ខេប ដូចតទៅនេះថា

បណ្ដាបទទាំងនោះ កាមធាតុដូចម្ដេច កាមធាតុដែលអន្ទោលទៅក្នុងរវាងនេះ គឺខាងក្រោមមានអវីចិជាទីបំផុត ខាងលើមានឋានសួគ៌ជាន់បរនិម្មិតវសវត្តីជាទីបំផុត ខន្ធ ធាតុ អាយតនៈ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណដែលទាក់ទងក្នុងរវាងនេះ ហៅថា **កាមធាតុ** ។

បណ្ដាបទទាំងនោះ រូបធាតុដូចម្ដេច រូបធាតុដែលអន្ទោលទៅក្នុងរវាងនេះ

គឺខាងក្រោមមានព្រហ្មលោកជាទីបំផុត ខាងលើមានឋានសួគ៌ជាន់អកនិដ្ឋៈជាទីបំផុតធម៌គឺចិត្ត និងចេតសិករបស់បុគ្គលអ្នកចូលឈានក្តី របស់អ្នកកើតហើយក្តី របស់អ្នកមានសុខវិហារធម៌ក្នុងបច្ចុប្បន្នក្តី ដែលទាក់ទងក្នុងរវាងនេះ នេះហៅថា **រូបធាតុ** ។

បណ្តាបទទាំងនោះ អរូបធាតុដូចម្តេច អរូបធាតុដែលអន្ទោលទៅក្នុងរវាងនេះ គឺខាងក្រោមរាប់ពីឋានសួគ៌ជាន់អាកាសានញ្ចាយតនៈជាទីបំផុត ខាងលើ មានឋានសួគ៌ជាន់នេវសញ្ញានាសញ្ញាយតនៈជាទីបំផុត ធម៌គឺចិត្តនិងចេតសិករបស់បុគ្គលដែលចូលឈានក្តី របស់បុគ្គលដែលកើតហើយក្តី របស់បុគ្គលដែលជាសុខក្នុងបច្ចុប្បន្នក្តី ដែលទាក់ទងក្នុងរវាងនេះ នេះហៅថា **អរូបធាតុ** ដូច្នេះ ។

តែក្នុងអដ្ឋកថា លោកពោលថា បទថា **កាមធាតុ** បានដល់ ខន្ធ ៥ ក្នុងកាមភព ។ បទថា **រូបធាតុ** បានដល់ ខន្ធ ៥ ក្នុងរូបភព ។ បទថា **អរូប-ធាតុ** បានដល់ ខន្ធ ៤ ក្នុងអរូបភពដូច្នេះ ។

ម្យ៉ាងទៀត ធាតុដែលប្រកបដោយកាម ពោលគឺកាមភព ឈ្មោះថា **កាម-ធាតុ** ឬធាតុពោលគឺកាម ឈ្មោះថា **កាមធាតុ** ។ ធាតុដែលលះកាមហើយប្រកបដោយរូប ឈ្មោះថា **រូបធាតុ** ឬធាតុពោលគឺរូបឈ្មោះថា **រូបធាតុ** ។ ធាតុដែលលះទាំងកាមនិងរូប ហើយប្រកបដោយអរូប ឈ្មោះថា **អរូបធាតុ** ។ ម្យ៉ាងទៀត ធាតុពោលគឺអរូប ឈ្មោះថា **អរូបធាតុ** ។ ធាតុទាំងនោះឯងលោកពោលទុកដោយបរិយាយនៃភពទៀត ។ លោកហៅថា **ភព៣** ព្រោះអត្ថ

ថា រស់នៅ ។ ភពដែលប្រកបដោយសញ្ញា ឈ្មោះថា **សញ្ញាភព** ។ម្យ៉ាងទៀត ឈ្មោះថា **សញ្ញាភព** ព្រោះអត្ថថា ជាភពរបស់អ្នកមានសញ្ញា ឬសញ្ញាមានក្នុងភពនេះ ។ សញ្ញាភពនោះជាកាមភពផង ជារូបភពដែលផុតចាកអសញ្ញាភពផង ជាអរូបភពដែលផុតចាកនេវសញ្ញានាសញ្ញាភពផង ។

ភពដែលមិនមានសញ្ញា ឈ្មោះថា **អសញ្ញាភព** អសញ្ញាភពនោះ ជាឯកទេសនៃរូបភព ។

ឈ្មោះថា **នេវសញ្ញានាសញ្ញា** ព្រោះអត្ថថា មានសញ្ញាក៏មិនមែន ព្រោះមិនមានភាពជារបស់គ្រោតគ្រាត មិនមានសញ្ញាក៏មិនមែន ព្រោះភាវៈជារបស់ល្អិត ។ ភពដែលប្រកបដោយនេវសញ្ញានាសញ្ញានោះ ឈ្មោះថា **នេវសញ្ញា-នាសញ្ញាភព** ។ ម្យ៉ាងទៀត ឈ្មោះថា **នេវសញ្ញានាសញ្ញាភព** ព្រោះអត្ថថា ក្នុងភពនេះមានសញ្ញាក៏មិនមែន មិនមានសញ្ញា ព្រោះមិនមានសញ្ញាដែលគ្រោតគ្រាតនិងព្រោះមានសញ្ញាដែលល្អិត ។ នេវសញ្ញានាសញ្ញាភពនោះជាចំណែកមួយនៃអរូបភព ។

ឈ្មោះថា **ឯកវោការភព** ព្រោះអត្ថថា ភពដែលដេរដាសទៅដោយរូបក្ខន្ធមួយ ម្យ៉ាងទៀត ភពនោះមានវោការៈ ( ខន្ធ ) មួយ ។ ឯកវោការភពនោះ គឺអសញ្ញាភពនោះឯង ។

ឈ្មោះថា **ចតុវោការភព** ព្រោះអត្ថថា ភពដែលដេរដាសទៅដោយអរូបក្ខន្ធបួន ឬភពនោះមានវោការៈបួន ។ ចតុវោការភពនោះ គឺអរូបភពនោះឯង ។

ឈ្មោះថា **បញ្ចវោការភព** ព្រោះអត្ថថា ភពដែលដេរដាសទៅដោយខន្ធ ៥ ឬភពនោះមានវោការៈប្រាំ ។ បញ្ចវោការភពនោះ ជាកាមភពផង ជាចំណែកមួយនៃរូបភពផង ។ តិកៈនៃអតីតៈ មានន័យដូចពោលហើយខាងដើមនោះឯង ។ បទថា **ទិដ្ឋំ** បានដល់ អារម្មណ៍ដែលមានសមុដ្ឋាន ៤ ។ បទថា **សុតំ** បានដល់ សទ្ទារម្មណ៍ដែលមានសមុដ្ឋាន ២ ។

បទថា **មុតំ** បានដល់ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ដែលមានសមុដ្ឋាន ៤ ដែលបុគ្គលដឹងហើយគប្បីកាន់យក ។

ធម្មារម្មណ៍ដែលគប្បីដឹងដោយចិត្ត ឈ្មោះថា **វិញ្ញាតព្វំ** ។ ក្នុងធម៌ទាំងឡាយដែលឃើញហើយ ឮហើយ ជ្រាបហើយនិងគប្បីដឹងច្បាស់ទាំងនោះ ។

បទថា **វិសដា វិត្ថតា** សេចក្តីថា ផ្សាយទៅច្រើន ។ បទថា **អបាយលោកេ** បានដល់ ឈ្មោះថា អបាយ ព្រោះមិនមានការរុងរឿង ពោលគឺសេចក្តីចម្រើន ។ ក្នុងអបាយលោកនោះ ។

បទថា **ខន្ធលោកេ** បានដល់ លោក គឺខន្ធ ៥ មានរូបជាដើម ដោយអត្ថថា ជាគំនរ ។

បទថា **ធាតុលោកេ** បានដល់ លោកធាតុ ១៨ មានចក្ខុធាតុជាដើម ដោយអត្ថថា ទទេ ។ បទថា **អាយតនលោកេ** បានដល់ លោកគឺអាយតនៈ ១២ ដោយហេតុមានអាយតនៈជាដើម ។ ទាំងអស់ ឈ្មោះថា លោកដោយអត្ថថា បែកធ្លាយ ។ តណ្ហាឈ្មោះថា **វិសត្តិកា** ព្រោះអត្ថថា ស្អុះទៅ ផ្សាយទៅក្នុងលោក មានប្រការដូចពោលហើយ ។

បទថា **សតោ** សេចក្តីថា ឈ្មោះថា **សតោ** ព្រោះអត្ថថា រឭកបាន ។ លោកពោលសតិដោយភាពជាបុគ្គល ។ **សតិ** ក្នុងបទនោះ មានការរឭកបាន ជាលក្ខណៈ ។ ឈ្មោះថា **សតិ** ព្រោះអត្ថថា ជាគ្រឿងរឭកបានរបស់ពួកសត្វ ឬរឭកបានឯង ឬត្រឹមតែរឭកប៉ុណ្ណោះ ។ សតិនោះ មានការធ្វើម្តងហើយម្តងទៀតជាលក្ខណៈ មានការមិនភ្លេចជាកិច្ច មានការរក្សាជាបច្ចុប្បដ្ឋាន ឬមានភាវៈឆ្ពោះទៅកាន់អារម្មណ៍ជាបច្ចុប្បដ្ឋាន មានការចាំមាំទាំជាបទដ្ឋាន ឬមានសតិប្បដ្ឋាន មានកាយានុបស្សនាសតិប្បដ្ឋានជាដើមជាបទដ្ឋាន គប្បីឃើញថា ដូចសសរខឿន ព្រោះតាំងមាំក្នុងអារម្មណ៍ និងដូចឆ្មាំទ្វារ ព្រោះរក្សាចក្ខុទ្វារជាដើម ។

ព្រះសារីបុត្តត្ថេរកាលសម្តែងឋានៈ ការប្រព្រឹត្តទៅរបស់សតិនោះ បានពោលសតិប្បដ្ឋាន ៤ ដោយន័យជាដើមថា **កាយេ កាយានុបស្សនាសតិប្បដ្ឋានំ ភាវេន្តោ សតោ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **កាយេ** បានដល់ ក្នុងរូបកាយ ពិតហើយ ក្នុងទីនេះ រូបកាយលោកបំណងយកថា **កាយ** ( ពួកឬក្រុម ) ដូចជា **ហត្ថិកាយ** ពួកដំរី **រថកាយ** ពួករថជាដើម ដោយអត្ថថា ពួកនៃធម៌ទាំងឡាយមានអវយវៈតូចធំ មានសក់ជាដើម ដោយអត្ថថា ពួកយ៉ាងណា ដោយអត្ថថា ប្រជុំនៃវត្ថុគួរខ្ពើមក៏យ៉ាងនោះ ។ ឈ្មោះថា **កាយ** ព្រោះអត្ថថា ជាទីប្រជុំនៃវត្ថុគួរខ្ពើមដែលគួរខ្ញើសក្រៃលែង ដូច្នេះក៏មាន ។

ប្រទេសជាទីកើតឡើង ឈ្មោះថា **អាយ** ។ ក្នុងពាក្យនោះ មានអត្ថរបស់

ពាក្យដូចតទៅនេះថា ឈ្មោះ **អាយ** ព្រោះអត្ថថា ប្រជុំគ្នាក្នុងទីនោះ ។ អ្វីប្រជុំគ្នា វត្ថុដែលគួរខ្ពើមមានសក់ជាដើមប្រជុំគ្នា ។ ឈ្មោះថា **កាយ** ព្រោះអត្ថថា ជាទីប្រជុំនៃវត្ថុគួរខ្ពើមទាំងឡាយដោយប្រការដូច្នេះ ។

បទថា **កាយានុបស្សនា** បានដល់ ការពិចារណាកាយ ។ គប្បីជ្រាបថា លោកពោលថា **កាយេ** ទុកហើយ ក៏គង់ធ្វើសព្ទថា **កាយ** ក្នុងពាក្យថា **កាយានុបស្សនា** ទុកទៀត ដើម្បីសម្ដែងការចែកឃនសញ្ញាដោយការកំណត់ដោយមិនលាយឡំគ្នា ។ ហេតុនោះ ទើបលោកមិនសម្ដែងថា **កាយេ វេទនា-នុបស្សនា** ( ពិចារណាវេទនាក្នុងកាយ ) ឬថា **កាយេ ចិត្តធម្មានុប-ស្សនា** ( ពិចារណាចិត្តនិងធម៌ក្នុងកាយ ) ដែលពិត លោកសម្ដែងការកំណត់ដោយមិនលាយឡំគ្នា ដោយការសម្ដែងអាការៈ ពិចារណាកាយក្នុងវត្ថុពោលគឺកាយថា **កាយានុបស្សនា** ប៉ុណ្ណោះ ។ ម្យ៉ាងទៀត មិនមែនជាការពិចារណាធម៌ណាមួយ ដែលផុតចាកអវយវៈតូចធំក្នុងកាយ ទាំងមិនមែនជាការពិចារណាស្ត្រីនិងបុរស ដែលផុតចាកអវយវៈ មានសក់និងរោមជាដើម ។

កាយណា ពោលគឺពួកនៃមហាភូតរូបនិងឧបាទាយរូប មានសក់និងរោមជាដើមក្នុងទីនោះ ក្នុងកាយនោះ ព្រះសារីបុត្តត្ថេរកាលសម្ដែងដោយប្រការផ្សេងៗរបស់វត្ថុ ពោលគឺកាយ ឈ្មោះថាលោកសម្ដែងការចែកឃនសញ្ញាដោយអំណាចនៃពួកនោះឯងថា មិនមែនជាការពិចារណាធម៌ណាមួយដែលផុតចាកមហាភូតរូប និងឧបាទាយរូប ដែលពិត ជាការពិចារណាពួកអវយវៈតូចធំ ដូចការពិចារណារបស់អ្នកពិចារណាគ្រឿងប្រកបគឺរថ ជាការពិចារណា

ពួកនៃសក់និងរោមជាដើម ដូចការពិចារណារបស់អ្នកពិចារណាគ្រឿងប្រកប នៃព្រះនគរ ជាការពិចារណាពួកនៃមហាភូតរូប និងឧបាទាយរូបនោះឯង ដូចការពិចារណារបស់អ្នកបែកដើម ស្លឹកនិងធាងរបស់ដើមចេក និងដូចរបស់បុគ្គលដែលចាក់ធ្លុះ ដៃដែលក្តាប់ទទេ ។ ធម៌ណាមួយជាកាយក្តី ស្រ្តីក្តី បុរសក្តី ឬដទៃក្តី ដែលផុតចាកពួកតាមដែលពោលហើយ រមែងមិនប្រាកដក្នុងទីនេះ ។ តែសត្វទាំងឡាយ រមែងធ្វើនូវការប្រកាន់ខុសយ៉ាងនោះៗ ក្នុងវត្ថុត្រឹមតែពួកនៃធម៌ តាមដែលពោលហើយនោះឯង ។ ដោយហេតុនោះ ទើបបុរាណាចារ្យទាំងឡាយពោលថា

បុគ្គលរមែងឃើញវត្ថុណា វត្ថុនោះឈ្មោះថា ដែលបុគ្គលនោះ
ឃើញហើយក៏មិនមែន វត្ថុណាដែលបុគ្គលនោះឃើញហើយ
បុគ្គលឈ្មោះថា រមែងមិនឃើញវត្ថុនោះ កាលមិនឃើញ
រមែងជាប់ កាលជាប់ ក៏វង្វេង រមែងមិនផុតទៅបានឡើយ
ដូច្នេះ ។

អត្ថក្នុងទីនេះ គប្បីជ្រាបដោយ **អាទិ** សព្ទដែលពោលទុកថា ដើម្បីសម្តែងការបែកពួកជាដើមដូច្នេះ ។ ការពិចារណាកាយក្នុងកាយនោះឯង មិនមែនជាការពិចារណាធម៌ដទៃ ។ លោកអធិប្បាយទុកដូចម្តេច លោកអធិប្បាយទុកថា ការពិចារណាឃើញថា មានទឹកក្នុងថ្ងៃបណ្តើរកូន ដែលមិនមានទឹកយ៉ាងណា ការពិចារណាថាជារបស់ទៀង ជាសុខ ជាអត្តានិងជារបស់ស្អាតក្នុងកាយនេះដែលមិនទៀង ជាទុក្ខ ជាអនត្តានិងមិនស្អាតនោះឯង មិនមានទៅ

បានឡើយ ដែលពិត ការពិចារណាកាយ គឺការពិចារណាពួកនៃអាការៈដែលជាអនិច្ចំ ទុក្ខំ អនត្តានិងមិនស្អាតនោះឯង ។

ម្យ៉ាងទៀត កាយនេះកើតអំពីវត្ថុដែលល្អិត មានខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលជាដើម មានឆ្អឹងជាទីបំផុត ដែលព្រះដ៏មានព្រះភាគត្រាស់ទុកក្នុងមហាសតិប្បដ្ឋាន ដោយន័យជាដើមថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ នៅក្នុងព្រៃក្តី ។បេ។ ជាអ្នកមានស្មារតីដកដង្ហើមចេញដូច្នេះ និងកាយណាដែលព្រះសារីបុត្តត្ថេរពោលទុកក្នុងសតិប្បដ្ឋានកថា ក្នុងបដិសម្ភិទាមគ្គ ខុទ្ទកនិកាយថា បុគ្គលពួកមួយក្នុងលោកនេះ ពិចារណាឃើញនូវពួកដីថា មិនទៀង មិនមែនថាទៀងទេ បុគ្គលពួកមួយក្នុងលោកនេះ ពិចារណាឃើញនូវពួកទឹក ពួកភ្លើង ពួកខ្យល់ ពួកសក់ ពួករោម ពួកសម្បុរថ្ងៃ ពួកស្បែក ពួកសាច់ ពួកសរសៃ ពួកឆ្អឹង ពួកខួរក្នុងឆ្អឹងថាមិនទៀង មិនមែនថាទៀងទេ ដូច្នេះ ។ គប្បីជ្រាបអត្ថនៃកាយទាំងអស់នោះយ៉ាងនេះថា ការពិចារណាកាយដោយការពិចារណាក្នុងកាយនេះប៉ុណ្ណោះ ។

ម្យ៉ាងទៀត គប្បីជ្រាបអត្ថយ៉ាងនេះថា ការពិចារណាកាយ ពោលគឺពួកនៃសក់ជាដើមក្នុងកាយ ដោយការមិនពិចារណាពួកនៃធម៌ផ្សេងៗ ដែលគប្បីប្រកាន់ក្នុងកាយយ៉ាងនេះថា អញ ឬថារបស់អញ តែពិចារណាពួកនៃធម៌ផ្សេងៗ មានសក់និងរោមដើមនោះៗឯង ។ ម្យ៉ាងទៀត គប្បីជ្រាបសេចក្តីយ៉ាងនេះថា ការពិចារណាកាយក្នុងកាយ ដោយការពិចារណាកាយ ពោលគឺពួកនៃអាការៈ មានអនិច្ចលក្ខណៈជាដើមទាំងអស់នោះឯង ដែលមានន័យ

មកហើយ ក្នុងបដិសម្ភិទាមគ្គតាមលំដាប់ជាដើមថា រមែងពិចារណាក្នុងកាយនេះ ដោយភាពជារបស់មិនទៀង មិនពិចារណាដោយភាពជារបស់ទៀង ដូច្នេះ អត្ថនេះ ទូទៅដល់សតិប្បដ្ឋានទាំង ៤ ។

បទថា **សតិប្បដ្ឋានំ** បានដល់ សតិប្បដ្ឋាន ៣ យ៉ាង គឺសតិគោចរ ១ ភាពដែលព្រះសាស្តា ជាអ្នកប្រព្រឹត្តកន្លងនូវការត្រេកអរក្នុងពួកសាវ័កដែលជាអ្នកបដិបត្តិ ៣ យ៉ាង ១ តួសតិ ១ ។ អារម្មណ៍របស់សតិ ហៅថា សតិប្បដ្ឋានក្នុងសេចក្តីជាដើមថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវសេចក្តីកើតឡើងនិងសូន្យទៅនៃសតិប្បដ្ឋាន ៤ អ្នកទាំងឡាយចូរស្តាប់នូវធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីកើតឡើងនៃកាយដូចម្តេច ។ ការកើតឡើងនៃកាយ ព្រោះកើតឡើងនៃអាហារ ដូច្នេះ ។ ក្នុងសេចក្តីជាដើមថា កាយឈ្មោះថាឧបដ្ឋាន មិនមែនឈ្មោះថាសតិទេ សតិឈ្មោះថាឧបដ្ឋានផង ឈ្មោះថាសតិផង ដូច្នេះក៏ដូចគ្នា ។ សេចក្តីនោះ មានអត្ថដូច្នេះ ឈ្មោះថា **បដ្ឋាន** ព្រោះអត្ថថា ជាទីតាំង ។ អ្វីជាទីតាំង គឺសតិជាទីតាំង ទីតាំងនៃសតិ ឈ្មោះថា **សតិប្បដ្ឋាន** ។

ម្យ៉ាងទៀត ឈ្មោះថា ទីតាំង ព្រោះអត្ថថា សេចក្តីព្យាយាម ។ ទីតាំងនៃសតិឈ្មោះថា **សតិប្បដ្ឋាន** ដូចទីតាំងនៃដំរី ទីតាំងនៃសេះជាដើម ។ ភាពដែលព្រះសាស្តាជាអ្នកប្រព្រឹត្តកន្លងនូវការត្រេកអរ ការប្រទូស្តក្នុងពួកសាវ័កដែលបដិបត្តិ ៣ យ៉ាង ទើបលោកពោលថា ពាក្យថា សតិប្បដ្ឋានមាន ៣ ប្រការ ដែលសាស្តាដ៏ប្រសើរតែងសេព កាលសាស្តាដ៏ប្រសើរសេពហើយ

ទើបគួរនឹងប្រៀនប្រដៅគណៈបាន ដូច្នេះ ។

សេចក្តីនោះមានអត្ថដូចតទៅនេះថា ឈ្មោះថា **បដ្ឋាន** ព្រោះគប្បីឲ្យតាំងឡើង សេចក្តីថា គប្បីឲ្យប្រព្រឹត្តទៅ សួរថា គប្បីឲ្យតាំងឡើងដោយអ្វី ឆ្លើយថា គប្បីឲ្យតាំងឡើងដោយសតិ ។ ទីតាំងនៃសតិឈ្មោះថា **សតិប្បដ្ឋាន** ។ សតិនោះឯងលោកហៅថា **សតិប្បដ្ឋាន** ដូចក្នុងប្រយោគ ( មជ្ឈិមនិកាយ ឧបរិបណ្ណាសក ) ជាដើមថា សតិប្បដ្ឋានទាំង ៤ ដែលបុគ្គលបានចម្រើន បានធ្វើឲ្យរឿយៗហើយ រមែងញ៉ាំងពោជ្ឈង្គទាំង ៧ ឲ្យពេញបរិបូណ៌បាន ដូច្នេះ ។

សេចក្តីនោះមានអត្ថដូចតទៅនេះថា ឈ្មោះថា **បដ្ឋាន** ព្រោះអត្ថថា តាំងនៅ ។ សេចក្តីថា តាំងឡើង គឺស្ទុះជាប់តគ្នាប្រព្រឹត្តទៅ ។ សតិដែលតាំងឡើងនោះឯង ឈ្មោះថា **សតិប្បដ្ឋាន** ។ ម្យ៉ាងទៀត ឈ្មោះថា **សតិ** ដោយអត្ថថា រឭកបាន ។ ឈ្មោះថា **បដ្ឋាន** ដោយអត្ថថា តាំងទុកមាំ ។ សតិផង ការតាំងទុកមាំផង ហេតុនោះទើបឈ្មោះថា **សតិប្បដ្ឋាន** ដោយប្រការដូច្នេះ ។ ក្នុងទីនេះលោកបំណងយកសេចក្តីនេះ ។ នូវសតិប្បដ្ឋាននោះ ។

បទថា **ភាវេន្តោ** បានដល់ កាលឲ្យចម្រើន ។ ក្នុងទីនេះពាក្យណាដែលលោកពោលហើយថា ភាពដែលព្រះសាស្តាប្រព្រឹត្តកន្លងនូវការត្រេកអរ និងមិនត្រេកអរក្នុងពួកសាវកដែលបដិបត្តិដោយចំណែក ៣ ឈ្មោះថា **សតិប្បដ្ឋាន** ពាក្យនោះគប្បីកាន់យកតាមសូត្រនេះ ។ សមដូចព្រះដ៏មានព្រះភាគត្រាស់ទុកថា សតិប្បដ្ឋានមាន ៣ ប្រការ ដែលសាស្តាដ៏ប្រសើរតែងសេព កាលសាស្តាដ៏ប្រសើរសេពហើយ ទើបគួរនឹងប្រៀនប្រដៅគណៈបានដូច្នេះ ពាក្យ

*នេះ លោកបានពោលទុកហើយដោយប្រការដូច្នេះឯង ។ លោកពោលពាក្យនេះព្រោះអាស្រ័យអ្វី ឆ្លើយថា ព្រោះអាស្រ័យពាក្យនេះថា*

*ពាក្យថា សតិប្បដ្ឋានមាន ៣ ប្រការ ដែលសាស្ដាដ៏ប្រសើរតែងសេព កាលសាស្ដាដ៏ប្រសើរសេពហើយ ទើបគួរនឹងប្រៀនប្រដៅគណៈបាន ដូច្នេះ នេះតថាគតបានពោលហើយ ។ ចុះពាក្យនុ៎ះ តថាគតពោលព្រោះអាស្រ័យអ្វី ។ ម្នាលភិក្ខុទាំងឡាយ សាស្ដាជាអ្នកអនុគ្រោះជាអ្នកស្វែងរកប្រយោជន៍ តែងសម្ដែងធម៌ដល់ពួកសាវក ព្រោះអាស្រ័យនូវសេចក្ដីអនុគ្រោះដូច្នេះថា ធម្មជាតិនេះប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់អ្នកទាំងឡាយ ធម្មជាតិនេះប្រព្រឹត្តទៅដើម្បីសេចក្ដីសុខដល់អ្នកទាំងឡាយ ។ តែពួកសាវករបស់សាស្ដានោះមិនចង់ស្ដាប់ មិនផ្ទង់ត្រចៀក មិនតាំងចិត្តដើម្បីឲ្យដឹងសេចក្ដី ក៏ប្រព្រឹត្តកន្លងពាក្យប្រៀនប្រដៅរបស់សាស្ដាទៅវិញ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងដំណើរនោះ ព្រះតថាគតមិនមានចិត្តរីករាយ មិនទទួលនូវសេចក្ដីរីករាយ មានចិត្តមិនប្រឡាក់ដោយរាគៈ មានតែសតិសម្បជញ្ញៈ ប្រព្រឹត្តទៅគ្រប់ឥរិយាបថ ម្នាលភិក្ខុទាំងឡាយនេះហៅថាសតិប្បដ្ឋានទី ១ ដែលសាស្ដាដ៏ប្រសើរតែងសេព កាលសាស្ដាដ៏ប្រសើរសេពហើយ ទើបគួរនឹងប្រៀនប្រដៅគណៈបាន ។*

ម្នាលភិក្ខុទាំងឡាយ មួយទៀត សាស្តា ។បេ។ ធម្មជាតិនេះប្រព្រឹត្តទៅដើម្បីសេចក្តីសុខដល់អ្នកទាំងឡាយ ។ សាវ័កពួកខ្លះរបស់សាស្តានោះមិនចង់ស្តាប់ ។បេ។ ក៏ប្រព្រឹត្តកន្លងពាក្យប្រៀនប្រដៅរបស់សាស្តា ។ សាវ័កពួកខ្លះចង់ស្តាប់ ។បេ។ មិនហ៊ានប្រព្រឹត្តកន្លងនូវពាក្យប្រៀនប្រដៅរបស់សាស្តាឡើយ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងដំណើរនោះព្រះតថាគតក៏មិនមានចិត្តរីករាយ មិនទទួលនូវសេចក្តីរីករាយ មិនមានតូចចិត្ត មិនទទួលនូវសេចក្តីតូចចិត្ត វៀរបង់នូវសេចក្តីរីករាយនិងសេចក្តីតូចចិត្តទាំងពីរនោះ ជាអ្នកប្រងើយ ប្រកបដោយសតិសម្បជញ្ញៈ ប្រព្រឹត្តទៅគ្រប់ឥរិយាបថ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សតិប្បដ្ឋានទី ២ ។បេ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ។បេ។ ធម្មជាតិនេះ ប្រព្រឹត្តទៅដើម្បីសេចក្តីសុខដល់អ្នកទាំងឡាយ ។ តែពួកសាវ័ករបស់សាស្តានោះចង់ស្តាប់ ។បេ។ ទាំងមិនបានប្រព្រឹត្តកន្លងពាក្យប្រៀនប្រដៅរបស់សាស្តា ។ ម្នាលភិក្ខុទាំងឡាយ ក្នុងដំណើរនោះព្រះតថាគតរមែងមានចិត្តរីករាយ ទទួលនូវសេចក្តីរីករាយ តែថា មានចិត្តមិនប្រឡាក់ដោយរាគៈ ជាអ្នកមានសតិសម្បជញ្ញៈប្រព្រឹត្តទៅគ្រប់ឥរិយាបថ ម្នាលភិក្ខុទាំងឡាយ នេះហៅថាសតិប្បដ្ឋានទី ៣ ។

*ការផុតចាកកិលេសជាគ្រឿងលិចស្រោច គឺការប្រទូស្ត និងការត្រេកអរទាំងឡាយ និងការកន្លងផុតនូវការប្រទូស្ត និងសេចក្តីត្រេកអរទាំងពីរនោះ ព្រោះមានសតិតាំងមាំជានិច្ច លោកពោលថា* **សតិប្បដ្ឋាន** *ដោយប្រការដូច្នេះ ។*

*បានឮថា ភាពជាអ្នកមានសតិតាំងមាំជានិច្ច មានដល់ព្រះពុទ្ធទាំងឡាយប៉ុណ្ណោះ មិនមានដល់ព្រះបច្ចេកពុទ្ធជាដើមឡើយ ។*

*ក្នុងការចម្រើនវេទនានុបស្សនាសតិប្បដ្ឋាន ក្នុងវេទនាទាំងឡាយជាដើម គប្បីជ្រាបថា ត្រូវប្រកបពាក្យថា វេទនាជាដើមចូលជាមួយពាក្យថា អនុបស្សនា តាមដែលគួរប្រកប ដោយន័យដែលពោលហើយ ក្នុងកាយានុបស្សនានោះឯង ។ អត្ថនេះក៏ជាអត្ថទូទៅ គឺពិចារណាវេទនានីមួយៗ ក្នុងវេទនាច្រើនប្រភេទ មានសុខវេទនាជាដើមដោយភាពជារបស់មិនទៀងជាដើមមួយបែបៗ ។ ការពិចារណាចិត្តនីមួយៗក្នុងចិត្ត ១៦ ប្រភេទ មានសរាគចិត្តជាដើម ដោយភាពជារបស់មិនទៀងជាដើមដោយប្រការផ្សេងៗ ។*

*ការពិចារណាធម៌នីមួយៗក្នុងធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដ៏សេសចេញអំពីកាយវេទនានិងចិត្តដោយភាពជារបស់មិនទៀងជាដើម ដោយប្រការផ្សេងៗ ការពិចារណាធម៌ មាននីវរណៈជាដើមដោយន័យដែលពោលហើយ ក្នុងសតិប្បដ្ឋានសូត្រនិងក្នុងទីនេះពាក្យថា* **កាយេ** *ជាឯកវចនៈ ព្រោះសរីរៈមានមួយ ។ បទថា* **ចិត្តេ** *ឯកវចនៈ ព្រោះចិត្តមានមួយ គប្បីជ្រាបថា លោកធ្វើដោយការកាន់យកការកើត ព្រោះមិនមានសភាវៈផ្សេងគ្នាដោយភាវៈនៃ*

ចិត្ត ។ ម្យ៉ាងទៀត ការពិចារណាដូចដែលគប្បីពិចារណាវេទនាជាដើម គប្បីជ្រាបថា ជាការពិចារណាវេទនាក្នុងវេទនាទាំងឡាយ ជាការពិចារណាចិត្តក្នុងចិត្ត ជាការពិចារណាធម៌ក្នុងធម៌ទាំងឡាយ ។ សួរថា វេទនា គប្បីពិចារណា ដូចម្តេច ឆ្លើយថា គប្បីពិចារណាសុខវេទនាដោយភាពជាទុក្ខមុន ។ គប្បីពិចារណាទុក្ខវេទនា ដូចត្រូវព្រួញ ។ គប្បីពិចារណាអទុក្ខមសុខវេទនាដោយភាពជារបស់មិនទៀង ដូចព្រះតម្រាស់ទុក ( ក្នុងសំយុត្តនិកាយសឡាយតនវគ្គ ) ថា

អ្នកឯណាបានឃើញសុខវេទនាថាជាទុក្ខវេទនាវិញ បានឃើញ
ទុក្ខវេទនាថាជាកូនសរ បានឃើញអទុក្ខមសុខវេទនានោះថា
ជាសភាវៈមិនទៀងទៅវិញ ។ បើភិក្ខុបានឃើញដោយប្រពៃ
កំណត់ដឹងនូវវេទនាទាំងឡាយ ... ដូច្នេះ ។

ម្យ៉ាងទៀត វេទនាទាំងអស់នោះគប្បីពិចារណាដោយភាពជាទុក្ខ សមដូចព្រះតម្រាស់ដែលត្រាស់ទុកថា អារម្មណ៍ឯណានីមួយដែលបុគ្គលសោយហើយ អារម្មណ៍នោះក៏ជាទុក្ខ ដូច្នេះ ។ គប្បីពិចារណាសុខវេទនាដោយភាពជាទុក្ខ ដូចព្រះនាងធម្មទិន្នាថេរីពោលទុក ( ក្នុងមជ្ឈិមនិកាយមូលបណ្ណាសក ) ថា សុខវេទនាមានកិរិយាឋិតនៅដែលជាសុខ មានការប្រែប្រួលទៅវិញជាទុក្ខ ទុក្ខវេទនាមានកិរិយាឋិតនៅជាទុក្ខ មានកិរិយាប្រែប្រួលទៅវិញជាសុខ ឯអទុក្ខមសុខវេទនា មានការដឹងច្បាស់ជាសុខ មានការមិនដឹងជាទុក្ខ ដូច្នេះ ។ ម្យ៉ាងទៀត គប្បីពិចារណាវេទនាទាំងនោះ ដោយអំណាចនៃអនុបស្សនា ៧ មានអនិច្ចានុបស្សនាជាដើម ។ ក្នុងចិត្តនិងធម៌ទាំងឡាយ គប្បីពិចារណា

ចិត្ត ដោយអំណាចនៃការផ្សេងគ្នានិងប្រភេទនៃអារម្មណ៍ ដែលជាអធិបតី សហជាត ភូមិ កម្ម និងកិរិយាជាដើមនៃអនុបស្សនា៧ មានអនិច្ចានុបស្សនាជាដើម និងនៃចិត្ត ១៦ ប្រភេទ មានសរាគចិត្តជាដើម ។ គប្បីពិចារណាធម៌ទាំងឡាយ ដោយអំណាចនៃលក្ខណៈចំពោះខ្លួន និង សាមញ្ញលក្ខណៈនៃសុញ្ញតធម៌នៃអនុបស្សនា ៧ មានអនិច្ចានុបស្សនាជាដើម និងនៃធម៌ដែលមាន និងមិនមានជាដើម ។

សតិប្បដ្ឋាន ៤ នេះ រមែងបានក្នុងចិត្តផ្សេងៗ ក្នុងចំណែកខាងដើម ព្រោះថា បុគ្គលរមែងកំណត់កាយដោយចិត្ត ១ ដួង កំណត់វេទនាទាំងឡាយដោយចិត្តទៀត ១ ដួង កំណត់ចិត្តដោយចិត្តទៀត ១ ដួង កំណត់ធម៌ទាំងឡាយដោយចិត្តទៀត ១ ដួង តែក្នុងខណៈនៃលោកុត្តរមគ្គ រមែងបានក្នុងចិត្ត ១ ដួងប៉ុណ្ណោះ ហេតុនោះ សតិដែលសម្បយុត្តដោយវិបស្សនារបស់បុគ្គលដែលកំណត់កាយមកអំពីដើម ទើបឈ្មោះថា **កាយានុបស្សនា** បុគ្គលដែលប្រកបដោយសតិនោះ ឈ្មោះថា **កាយានុបស្សី** ។

សតិដែលសម្បយុត្តដោយមគ្គ ក្នុងខណៈនៃមគ្គរបស់បុគ្គលដែលខ្វល់ខ្វាយចម្រើនវិបស្សនា ហើយសម្រេចអរិយមគ្គ ឈ្មោះថា **កាយានុបស្សនា** ។ បុគ្គលប្រកបដោយសតិនោះ ឈ្មោះថា **កាយានុបស្សី** ។ សតិដែលសម្បយុត្តដោយវិបស្សនារបស់បុគ្គលដែលកំណត់វេទនា... កំណត់ចិត្ត... កំណត់ធម៌ទាំងឡាយមកហើយ ឈ្មោះថា **ធម្មានុបស្សនា** ។ បុគ្គលដែលប្រកបដោយសតិនោះ ឈ្មោះថា **ធម្មានុបស្សី** ។

សតិដែលសម្បយុត្តដោយមគ្គ ក្នុងមគ្គខណៈរបស់បុគ្គលដែលខ្វល់ខ្វាយចម្រើនវិបស្សនាហើយ សម្រេចអរិយមគ្គ ឈ្មោះថា **ធម្មានុបស្សនា** ។ បុគ្គលប្រកបដោយសតិនោះ ឈ្មោះថា **ធម្មានុបស្សី** ។ ទេសនាជាបុគ្គលាធិដ្ឋានប៉ុណ្ណោះសិន ។

សតិកំណត់កាយ លះវិបល្លាសថាស្អាតក្នុងកាយ រមែងសម្រេចបានដោយមគ្គ ដូច្នេះទើបឈ្មោះថា **កាយានុបស្សនា** ។

សតិកំណត់វេទនា លះវិបល្លាសថាសុខក្នុងវេទនា រមែងសម្រេចបានដោយមគ្គ ដូច្នោះ ទើបឈ្មោះថា **វេទនានុបស្សនា** ។ សតិកំណត់ចិត្ត លះវិបល្លាសថាទៀងក្នុងចិត្ត រមែងសម្រេចបានដោយមគ្គ ដូច្នោះ ទើបឈ្មោះថា **ចិត្តានុបស្សនា** ។ សតិកំណត់ធម៌ លះវិបល្លាសថាជាតួខ្លួនក្នុងធម៌ទាំងឡាយ រមែងសម្រេចបានដោយមគ្គ ហេតុនោះ ទើបឈ្មោះថា **ធម្មានុបស្សនា** ។

សតិតែម្យ៉ាងនោះឯងដែលសម្បយុត្តដោយមគ្គ រមែងបានឈ្មោះ ៤ យ៉ាង ដោយអត្ថថា ញុំាងកិច្ច ៤ ឲ្យសម្រេចដោយប្រការដូច្នេះ ។ ព្រោះហេតុនោះ ទើបលោកពោលថា ក្នុងខណៈនៃលោកុត្តរមគ្គ សតិប្បដ្ឋាន ៤ រមែងបានក្នុងចិត្ត ១ ដូងនោះឯង លោកពោលចតុក្កៈ ៣ ដទៃដោយអំណាចនៃឧបការៈ ដោយអំណាចនៃការមិនវិនាសនិងដោយអំណាចនៃគុណ ។

បណ្តាបទទាំងនោះ បទថា **អសតិបរិវជ្ជនាយ** សេចក្តីថា មិនមានសតិ ឈ្មោះថា **អសតិ** ។ ម្យ៉ាងទៀត ឈ្មោះថា **អសតិ** ព្រោះអត្ថថា សតិ មិនមានក្នុងបុគ្គលនេះ ។ បទថា **អសតិ** នេះ ជាឈ្មោះរបស់ការមិនមានសតិ ។

បទថា **បរិវជ្ជនាយ** បានដល់ ព្រោះការវៀរដោយជុំវិញ ។ សតិរមែងកើតឡើង ព្រោះការវៀរបុគ្គលដែលមិនមានស្មារតី ដូចជាក្អែកលាក់ដុំបាយ ព្រោះគប់រកបុគ្គលដែលមានសតិតាំងមាំ និងព្រោះភាពជាអ្នកមានចិត្តបង្អោនទៅទោរទន់ទៅ ឈមទៅ ដើម្បីឲ្យសតិតាំងឡើង ព្រមក្នុងការឈរនិងអង្គុយជាដើម ។

បទថា **សតិករណីយានំ ធម្មានំ** បានដល់ ធម៌ទាំងឡាយដែលបុគ្គលគប្បីធ្វើដោយសតិ ។

បទថា **កតត្តា** បានដល់ ព្រោះភាពជាអ្នកធ្វើ អធិប្បាយថា ព្រោះភាពជាអ្នកធ្វើ គឺចម្រើនមគ្គ ៤ ។

បទថា **សតិប្បដិបក្ខានំ ធម្មានំ ហតត្តា** បានដល់ ព្រោះភាពជាអ្នកធ្វើឲ្យកាមឆន្ទៈជាដើមវិនាស ។

បទថា **សតិនិមិត្តានំ ធម្មានំ អប្បមុដ្ឋត្តា** បានដល់ ព្រោះភាពជាអ្នកមិនភ្លេចភ្លាំងអារម្មណ៍ផ្លូវកាយជាដើម ដែលជាហេតុនៃសតិ ។

បទថា **សតិយា សមន្នាគតត្តា** បានដល់ ព្រោះភាពជាបុគ្គលដែលមក គឺមិនវិនាសចាកធម៌ទាំងឡាយដោយសតិ ។

បទថា **វសិតត្តា** បានដល់ ដល់នូវភាពថ្នឹក ។ បទថា **ធាតុញ្ញតាយ** បានដល់ ព្រោះភាពជាអ្នកស្ទាត់ជំនាញ ។ បទថា **អបច្ចោរោហណតាយ** បានដល់ ព្រោះការមិនវិលត្រឡប់ គឺព្រោះការមិនត្រឡប់ថយក្រោយ ។ បទថា **សតត្តា** បានដល់ ព្រោះមានដោយសភាវៈ ។ បទថា **សន្តត្តា** បាន

ដល់ ព្រោះមានសភាវៈរលត់ ។ បទថា **សមិតត្តា** បានដល់ ព្រោះភាពជាអ្នករម្ងាប់កិលេសទាំងឡាយបាន ។ បទថា **សន្តធម្មសមង្គាគតត្តា** បានដល់ ព្រោះជាអ្នកមិនវិនាសចាកធម៌របស់សប្បុរស ។ ពុទ្ធានុស្សតិជាដើម មានន័យដូចពោលហើយខាងដើមនោះឯង ។

ឈ្មោះថា **សតិ** ដោយអំណាចរឭកបាន នេះជាបទសម្តែងសភាវៈរបស់សតិ ។ ឈ្មោះថា **អនុស្សតិ** ដោយអំណាចរឭកដល់ ដោយរឭកដល់រឿយៗ ។ ឈ្មោះថា **បដិស្សតិ** ដោយអំណាចរឭកចំពោះ ដោយរឭកហាក់បីដូចបែរមុខទៅ ។ បទនេះលោកគ្រាន់តែពង្រីកដោយឧបសគ្គ ។ អាការៈដែលរឭកឈ្មោះថា **សរណតា** ។

ព្រោះបទថា **សរណតា** ជាឈ្មោះរបស់សរណៈ ៣ ដូច្នោះ ទើបលោកប្រើ **សតិ** សព្ទទៀត ដើម្បីការពារសរណៈ ៣ នោះ ។ អត្ថក្នុងបទនេះមានដូច្នោះថា ការរឭកបានពោលគឺសតិ ។

ឈ្មោះថា **ធារណតា** ព្រោះការទ្រទ្រង់ចាំការរៀនព្រះសូត្រ ។ ការមិនអណ្តែតអណ្តូង ឈ្មោះថា **អបិលាបនតា** ដោយអត្ថថា ឈមចុះ ពោលគឺចូលទៅដោយលំដាប់ ឧបមាដូចសម្បកឃ្លោកជាដើម រមែងអណ្តែតទៅ មិនចូលទៅដោយលំដាប់យ៉ាងណា សតិក្នុងអារម្មណ៍មិនដូច្នោះឡើយ ដ្បិតថា សតិនោះ រមែងចូលកាន់អារម្មណ៍ដោយលំដាប់ ដូច្នោះទើបលោក ពោលថា ការមិនអណ្តែងអណ្តូង ។

ឈ្មោះថា **អបមុស្សនតា** ព្រោះការមិនភ្លេចរឿងដែលធ្វើទុកយូរ និង

ពាក្យដែលពោលទុកយូរ ។

ឈ្មោះថា **ឥន្ទ្រិយំ** ព្រោះអត្ថថា ឲ្យធ្វើអត្ថថាជាធំក្នុងលក្ខណៈដែលតាំងឡើង ។ ឥន្ទ្រិយគឺសតិ ឈ្មោះថា **សតិន្ទ្រិយំ** ។

ឈ្មោះថា **សតិពលំ** ព្រោះអត្ថថា មិនញាប់ញ័រក្នុងសេចក្តីប្រមាទ ។ ឈ្មោះថា **សម្មាសតិ** ព្រោះអត្ថថា សតិពិតប្រាកដ សតិនាំឲ្យផុតទុក្ខ សតិជាកុសល ។

ឈ្មោះថា **ពោជ្ឈង្គោ** ព្រោះអត្ថថា ជាអង្គនៃការត្រាស់ដឹង ។ ពោជ្ឈង្គៈដែលគេសរសើរនិងជាធម៌ល្អ ឈ្មោះថា **សម្ពោជ្ឈង្គោ** ។ សម្ពោជ្ឈង្គ គឺសតិ ឈ្មោះថា **សតិសម្ពោជ្ឈង្គោ** ។

បទថា **ឯកាយនមគ្គោ** បានដល់ ផ្លូវឯក ។ គប្បីឃើញអត្ថយ៉ាងនេះថា ផ្លូវនេះមិនមែនផ្លូវបែកជាពីរ ។ ម្យ៉ាងទៀត ឈ្មោះថា **ឯកាយន** ព្រោះអត្ថថា គប្បីទៅម្នាក់ឯង ។ ពាក្យថា ម្នាក់ឯង សេចក្តីថា គប្បីលះនូវការប្រឡូកប្រឡំដោយពួកគណៈហើយទៅ គឺប្រព្រឹត្តទៅដោយសេចក្តីស្ងាត់ ដែលមានអត្ថថា វិវេក ។

ម្យ៉ាងទៀត ឈ្មោះថា **អយន** ព្រោះអត្ថថា ជាគ្រឿងទៅរបស់ពួកសត្វ អធិប្បាយថា ពួកសត្វចាកសង្សារវដ្តទៅកាន់ព្រះនិព្វាន ។ ផ្លូវទៅរបស់បុគ្គលឯក ឈ្មោះថា **ឯកាយន** ។ ពាក្យថារបស់បុគ្គលឯក បានដល់ របស់បុគ្គលប្រសើរបំផុត ។ ព្រះដ៏មានព្រះភាគជាបុគ្គលប្រសើរបំផុតរបស់សត្វទាំងពួង ដូច្នោះទើបលោកពោលថា របស់ព្រះដ៏មានព្រះភាគ ។ សេចក្តីពិតសត្វដទៃៗ

ក៏ទៅដោយផ្លូវនោះដោយពិត ។ ទោះជាយ៉ាងនោះ ផ្លូវនោះក៏ជារបស់ព្រះដ៏មានព្រះភាគនោះឯង ព្រោះព្រះអង្គទ្រង់ឲ្យកើតឡើង ដូចលោកពោលទុក ( ក្នុងមជ្ឈិមនិកាយឧបរិបណ្ណាសក ) ថា ម្នាលព្រាហ្មណ៍ព្រោះថា ព្រះមានព្រះភាគអង្គនោះ ជាអ្នកបង្កើតផ្លូវដែលមិនទាន់កើតឡើង ដូច្នេះជាដើម ។ ម្យ៉ាងទៀត ឈ្មោះថា **អយន** ព្រោះអត្ថថា ទៅ អធិប្បាយថា ទៅ គឺប្រព្រឹត្តទៅ ។ ផ្លូវទៅក្នុងទីតែមួយ ឈ្មោះថា **ឯកាយន** លោកអធិប្បាយទុកថា ប្រព្រឹត្តទៅក្នុងធម្មវិន័យនេះប៉ុណ្ណោះ មិនមែនដទៃឡើយ ដូចព្រះតម្រាស់ត្រាស់ទុក ( ក្នុងទីឃនិកាយមហាវគ្គ ) ថា ម្នាលសុភទ្ទ អរិយមគ្គប្រកបដោយអង្គ ៨ មានតែក្នុងធម្មវិន័យនេះឯង ដូច្នេះ នេះជាការផ្សេងគ្នានៃទេសនាប៉ុណ្ណោះ តែអត្ថក៏ដូចគ្នាតែមួយ ។

ម្យ៉ាងទៀត ឈ្មោះថា **ឯកាយន** ព្រោះអត្ថថា ទៅកាន់ទីតែមួយ លោកអធិប្បាយទុកថា ដំបូង ប្រព្រឹត្តទៅដោយន័យភាវនាផ្សេងៗខាងក្រោយក៏ទៅកាន់ព្រះនិព្វានជាមួយគ្នាដូច្នេះ ។ ដូចសហម្បតីព្រហ្ម បានក្រាបទូលដល់ព្រះសម្ពុទ្ធថា

> ព្រះមានព្រះភាគឃើញការអស់ជាតិ និងទីបំផុតនៃជាតិទ្រង់
> អនុគ្រោះដោយប្រយោជន៍ ទ្រង់ជ្រាបផ្លូវឯកដែលជាទីទៅ
> ក្នុងកាលមុន ពួកបណ្ឌិតបានឆ្លងឱឃៈហើយនិងឆ្លង ( ក្នុង
> អនាគត ) ឆ្លងដោយផ្លូវនេះ ក្នុងកាលឥឡូវនេះ ដូច្នេះ ។

បទថា **មគ្គោ** មានវិនិច្ឆ័យថា ឈ្មោះថា **មគ្គ** ព្រោះអត្ថដូចម្តេច ឆ្លើយ

ថា ដោយអត្ថថា ទៅកាន់ព្រះនិព្វាន និងដោយអត្ថថា បុគ្គលត្រូវការព្រះនិព្វាន គប្បីស្វែងរក ។

បទថា **ឧបេតោ** សេចក្តីថា ទៅក្បែរ ។ បទថា **សមុបេតោ** សេចក្តីថា ទៅក្បែរជាងនោះ ។ អធិប្បាយថា មិនវិនាសបាកសតិទាំងពីរបទ ។

បទថា **ឧបគតោ** សេចក្តីថា ចូលទៅតាំងនៅ ។ បទថា **សមុបគតោ** សេចក្តីថា ប្រកបព្រមតាំងនៅ បាលីថា **ឧចាគតោ សមុចាគតោ** ដូច្នេះក៏មានសេចក្តីថា មកកាន់ទីជិតសតិដោយបទទាំងពីរ ។

បទថា **ឧបបន្នោ** បានដល់ មិនបែកចាកគ្នា ។ បទថា **សមុបបន្នោ** បានដល់ សម្បូរហើយ ។ បទថា **សមន្នាគតោ** បានដល់ មិនដាច់ គឺមិនខ្វះខាត ។ អាចារ្យពួកមួយពណ៌នាយ៉ាងនេះថា លោកពោលដល់ការប្រព្រឹត្តទៅដោយបទពីរថា **ឧបេតោ សមុបេតោ** ។ ពោលដល់បដិវេធដោយបទពីរថា **ឧបគតោ សមុបគតោ** ។ ពោលដល់ការបានចំពោះដោយបទ ៣ ថា **ឧបបន្នោ សមុបបន្នោ សមន្នាគតោ** ដោយប្រការដូច្នេះ ។

បទថា **លោកេ វេសា វិសត្តិកា** សេចក្តីថា តណ្ហានេះ ដែលបានពោលហើយដោយប្រការមិនមែនតិច តណ្ហានេះ ឈ្មោះថា **វិសត្តិកា** ។ រមែងប្រព្រឹត្តទៅក្នុងខន្ធលោកនោះឯង មិនវៀរចាកខន្ធទាំងឡាយ ។ បទថា **លោកេ វេតំ វិសត្តិកំ** សេចក្តីថា តណ្ហាពោលគឺ ដែលឈ្មោះថា **វិសត្តិកា** នោះ ដែលប្រព្រឹត្តទៅក្នុងខន្ធលោកនោះឯង ។ ឈ្មោះថា **តរតិ** ព្រោះវៀរកាមទាំងឡាយបាន ឈ្មោះថា **ឧត្តរតិ** ព្រោះលះកិលេសទាំងឡាយបាន ឈ្មោះថា

**បតរតិ** ព្រោះកាត់ហេតុជាទីតាំងរបស់កិលេសទាំងនោះបាន ឈ្មោះថា **សមតិក្កមតិ** ព្រោះឈានកន្លងសង្សារវដ្តបាន ឈ្មោះថា **វីតិវត្តតិ** ព្រោះធ្វើបដិសន្ធិឲ្យមិនសមគួរនឹងកើតឡើង ។

ម្យ៉ាងទៀត គប្បីប្រកបដោយន័យជាដើមយ៉ាងនេះថា រមែងឆ្លង ឆ្លងឡើងដោយកាយានុបស្សនា ឆ្លងកាត់ដោយវេទនានុបស្សនា ឈានកន្លងដោយចិត្តានុបស្សនា ប្រព្រឹត្តកន្លងគ្រប់យ៉ាងដោយធម្មានុបស្សនា ។

ម្យ៉ាងទៀត រមែងឆ្លងដោយសីល ឆ្លងឡើងដោយសមាធិ ឆ្លងកាត់ដោយវិបស្សនា ឈានកន្លងដោយមគ្គ ប្រព្រឹត្តកន្លងដោយផល ។

[ ១៥ ] គាថាទី ៤ មានអត្ថសង្ខេបដូចតទៅនេះថា បុគ្គលណា រមែងប្រាថ្នាស្រែ មានស្រែស្រូវសាលីជាដើមក្តី ដីដែលមានផ្ទះជាដើមក្តី ប្រាក់ពោលគឺកហាបណៈក្តី គោនិងសេះផ្សេងៗក្តី ទាសៈដែលកើតខាងក្នុងជាដើមក្តី កម្មករអ្នកស៊ីឈ្នួលក្តី ពួកស្រីដែលហៅថាស្រីក្តី ពួកញាតិជាដើមក្តី ឬកាមដទៃៗជាច្រើន មានរូបដែលគួរពេញចិត្តក្តី ។

[ ១៦ ] បទថា **សាលិក្ខេត្តំ** បានដល់ ដែលជាទីដុះឡើងនៃស្រូវសាលីក្នុងស្រូវខ្សាយជាដើម ក៏ន័យនេះឯង ។

បទថា **វីហិ** បានដល់ ស្រូវដំណើបដ៏សេស ។ ឈ្មោះថា **មុគ្គោ** ព្រោះអត្ថថា ឲ្យត្រេកអរ ។ បទថា **យវវត្ថុ** បានដល់ ភូមិភាគដែលធ្វើសម្រាប់សង់ផ្ទះ សូម្បីបទថា **កោដ្ឋវត្ថុ** ជាដើម ក៏ន័យនេះឯង ។

បទថា **កោដ្ឋកោ** បានដល់ ខ្លោងទ្វារជាដើម ។ បទថា **បុរេ** បានដល់

មុខផ្ទះ ។ បទថា **បច្ឆា** បានដល់ ក្រោយផ្ទះ ។

ឈ្មោះថា **អារាមោ** ព្រោះអត្ថថា ជាទីត្រេកអរ គឺធ្វើចិត្តឲ្យត្រេកអរបាន ។ សេចក្តីថា ត្រេកអរដោយផ្កាខ្លះ ដោយផ្លែខ្លះ ដោយម្លប់ខ្លះ ដោយទស្សនៈខ្លះ ។

[១៧] បទថា **បសុកាគយោ** បានដល់ ចៀមជាដើម ។ បទថា **អន្តោ-ជាតកោ** បានដល់ កើតក្នុងផ្ទៃរបស់ទាសីខាងក្នុងផ្ទះ ។ បទថា **ធនក្កីតកោ** បានដល់ លោះដោយទ្រព្យដូរម្ចាស់ទ្រព្យយកមក ។ បទថា **សាមំ វា** បានដល់ រមែងជាទាសៈឯងក្តី ។

បទថា **ទាសវិយំ** សេចក្តីថា ភាពនៃទាសៈ ឈ្មោះថា **ទាសវិយំ** ។ នូវភាពជាទាសៈនោះ ។ បទថា **ឧបេតិ** បានដល់ ចូលទៅរហូតដល់ ។ បទថា **អកាមកោ វា** បានដល់ បុគ្គលត្រូវនាំមកជាឈ្លើយ ដោយការមិនពេញចិត្តរបស់ខ្លួន ។ ដើម្បីសម្តែងទាសៈទាំង ៤ នោះទៀត ទើបលោកពោលថា **អាមាយ ទាសាបិ ភវន្តិ ហេកេ** ដូច្នេះ ។

បទថា **អាមាយ ទាសា** បានដល់ ទាសៈដែលកើតខាងក្នុង ។ ទាសៈទាំងនោះឯង លោកពោលទុកក្នុង ( ជាតកឯកនិបាត ) ថា ជាកូនរបស់ខ្ញុំស្រីឈ្មោះអាមា ឈរពោលនូវពាក្យអាក្រក់នោះ ដូច្នេះ ។ បទថា **ធនេន កីតា** បានដល់ ទាសីដែលទិញមកដោយទ្រព្យ ។ បទថា **សាមញ្ច ឯកេ** បានដល់ ជាទាសៈឯង ។ បទថា **ភយាបនុណ្ណា** បានដល់ ព្រមធ្វើជាទាសៈដោយការមិនស្ម័គ្រចិត្ត គឺត្រូវការខ្លាចគំរាមទើបទៅជាទាសៈ ។

បទថា **ភតកា** បានដល់ ពួកអ្នកចិញ្ចឹមជីវិតដោយការស៊ីឈ្នួល ។ ឈ្មោះ

ថា **កម្មករា** ព្រោះអត្ថថា ធ្វើការងារ មានកសិកម្មជាដើម ។ បទថា **ឧបជីវិនោ** បានដល់ ឈ្មោះថា អ្នកនៅអាស្រ័យ ព្រោះអត្ថថាចូលទៅរកដោយកិច្ចមានការប្រឹក្សាជាដើម ហើយសូមនៅអាស្រ័យ ។

[ ១៨ ] បទថា **ឥត្ថី** បានដល់ ឈ្មោះថា ស្រី ព្រោះអត្ថថា ជាទីតាំងគភ៌ ។ បទថា **បរិគ្គហោ** បានដល់ មានប្តី ។

ញាតិមិត្តខាងមាតាបិតា ឈ្មោះថា **ញាតិពន្ធុ** ។ អ្នកជាប់ដោយគោត្ត ឈ្មោះថា **គោត្តពន្ធុ** ។ អ្នករៀនមន្តក្នុងសម្នាក់អាចារ្យជាមួយគ្នា ឈ្មោះថា **មន្តពន្ធុ** អ្នករៀនសិប្បៈផ្ទួរមគ្នាជាដើម ឈ្មោះថា **សិប្បពន្ធុ** ។ បាឋៈក្នុងគម្ពីរខ្លះប្រាកដថា សូម្បី **មិត្តពន្ធុ** ក៏ឈ្មោះថា **ពន្ធុ** ។

[ ១៩ ] បទថា **គិជ្ឈតិ** បានដល់ ប្រាថ្នាដោយកិលេសកាម ។ បទថា **អនុគិជ្ឈតិ** បានដល់ ប្រាថ្នារឿយៗ គឺប្រាថ្នារឿយៗ ។ បទថា **បលិគិជ្ឈតិ** បានដល់ ប្រាថ្នាដោយជុំវិញ ។ បទថា **បលិពជ្ឈតិ** បានដល់ ប្រាថ្នាដោយពិសេស ។

អាចារ្យពួកមួយពណ៌នាទុកយ៉ាងនេះថា ប្រាថ្នា តាមប្រាថ្នា ដោយអំណាចការកាន់យកដោយនិមិត្ត ដោយភាពជារបស់ខ្ញុំ ប្រាថ្នាទូទៅ ជាប់ជំពាក់ដោយអំណាចការកាន់យក ដោយអនុព្យញ្ជនៈ ។

[ ២០ ] គាថាទី ៥ មានន័យដោយសង្ខេបដូចតទៅនេះថា កិលេសទាំងឡាយ រមែងគ្របសង្កត់ បង្កាប់បញ្ញា ញ៉ាំញីនូវបុគ្គលនោះ ឬកិលេសដែលមិនមានកម្លាំង រមែងគ្របសង្កត់បុគ្គលនោះ ដែលមិនមានកម្លាំង ព្រោះវៀរ

ចាកកម្លាំង គឺសទ្ធាជាដើម អធិប្បាយថា រមែងគ្របសង្កត់បាន ព្រោះមិនមាន កម្លាំង កាលនោះអន្តរាយដែលប្រាកដ មានរាជសីហ៍ជាដើម និងអន្តរាយ ដែលមិនប្រាកដ មានកាយទុច្ចរិតជាដើម រមែងគ្របសង្កត់បុគ្គលនោះ ដែល ប្រាថ្នាកាម រក្សាកាមនិងស្វែងរកកាម បន្ទាប់អំពីនោះ ទុក្ខមានការកើតជាដើម រមែងទៅតាមបុគ្គលនោះ ដែលអន្តរាយមិនប្រាកដគ្របសង្កត់ហើយ ដូចទឹក ហូរចូលទូកដែលធ្លុះធ្លោះ ។

[ ២១ ] បទថា **អពលា** សេចក្តីថា កម្លាំងនៃកិលេសទាំងនោះ មិនមាន ព្រោះហេតុនោះ ទើបកិលេសទាំងនោះ ឈ្មោះថា មិនមានកម្លាំង គឺវៀរចាក កម្លាំង ។ បទថា **ទុព្វលា** បានដល់ ប្រកបដោយភាពទន់ខ្សោយ គឺវៀរកិច្ច ដែលគប្បីធ្វើដោយកម្លាំង ។ បទថា **អប្បពលា** សេចក្តីថា កម្លាំងនៃកិលេស ទាំងនោះតិច គឺបន្តិចបន្តួច ព្រោះហេតុនោះ ទើបកិលេសទាំងនោះ ឈ្មោះ ថា មានកម្លាំងតិច គឺមិនអាចប្រកបកម្មបាន ។

បទថា **អប្បថាមកា** សេចក្តីថា កម្លាំងសេចក្តីព្យាយាម ភាពឧស្សាហៈ របស់កិលេសទាំងនោះតិច គឺបន្តិចបន្តួច ហេតុនោះ ទើបកិលេសទាំងនោះ ឈ្មោះថាមានកម្លាំងតិច ។

កិលេសទាំងនោះ ឈ្មោះថា **ហីនា និហីនា បរិហីនា** ព្រោះមានសេចក្តី ព្យាយាមអាក្រក់ ។ ឈ្មោះថា **ឱមកា** ព្រោះមានកម្លាំងអាក្រក់ ។ ឈ្មោះថា **លាមកា** ព្រោះមានបច្ច័យអាក្រក់ ។ ឈ្មោះថា **ឆតុក្កា** ព្រោះមានអជ្ឈា ស្រ័យអាក្រក់ ។ ឈ្មោះថា **បរិត្តា** ព្រោះមានសតិអាក្រក់ ។

បទថា **សហាន្តិ** បានដល់ ញុំាញី គឺញុំាំងនូវការប៉ះខ្ទប់ឲ្យកើតឡើង ។ បទថា **បរិសហាន្តិ** បានដល់ ញុំាញីដោយប្រការទាំងពួង ។ បទថា **អភិភវន្តិ** បានដល់ដោយអំណាចនៃការកើតឡើងម្តងហើយម្តងទៀត ។ បទថា **អជ្ឈោត្ថរន្តិ** បានដល់ ដោយអំណាចនៃការកើតឡើងរឿយៗ ។ បទថា **បរិយាទិយន្តិ** បានដល់ កម្ចាត់ដោយការឲ្យជឿហើយតាំងនៅ ។ បទថា **មទ្ទន្តិ** បានដល់ ញុំាញីដោយការហាមកុសលកើតឡើង ។

បទថា **សទ្ធាពលំ** បានដល់ ឈ្មោះថា សទ្ធា ព្រោះអត្ថថា ជាហេតុជឿរបស់ពួកសត្វ ឬជឿឯង ឬត្រឹមតែការជឿប៉ុណ្ណោះ ។ សទ្ធានោះ មានការជឿជាលក្ខណៈ ឬមានការដាក់ចិត្តជាលក្ខណៈ ។ មានការផូរផង់ជាកិច្ច ដូចកែវមណីធ្វើឲ្យទឹកថ្លា ឬមានការស្ទុះទៅជាកិច្ច ដូចទូកស្ទុះឆ្លងអន្លង់ទឹក មានការមិនល្អក់ជាបច្ចុប្បដ្ឋាន ឬមានការបង្អោនចិត្តជឿជាបច្ចុប្បដ្ឋាន មានវត្ថុដែលគប្បីជឿជាបទដ្ឋាន ឬមានអង្គនៃការដល់នូវក្រសែនៃធម៌ជាបទដ្ឋាន សទ្ធានោះគប្បីឃើញដូចដៃ ទ្រព្យសម្បត្តិនិងគ្រាប់ពូជ ។ ឈ្មោះថា **សទ្ធាពលំ** ព្រោះអត្ថថា មិនញាប់ញ័រក្នុងការមិនជឿ ។ បទថា **វីរិយពលំ** បានដល់ ភាវៈរបស់មនុស្សក្លៀវក្លាឈ្មោះថាវីរិយៈ ឬកម្មរបស់បុគ្គលក្លាហាន ឈ្មោះថាវីរិយៈ ។ម្យ៉ាងទៀត ឈ្មោះថាវីរិយៈ ព្រោះអត្ថថាគប្បីឲ្យកម្រើក គឺឲ្យប្រព្រឹត្តទៅដោយវិធី ដោយន័យ ដោយឧបាយ ។

វីរិយៈនោះ មានការឧបត្ថម្ភជាលក្ខណៈ ឬមានការផ្គងទុកជាលក្ខណៈ ។ មានការឧបត្ថម្ភសហជាតធម៌ជាកិច្ច មានការមិនរាថយជាបច្ចុប្បដ្ឋាន មាន

សេចក្ដីសង្វេគជាបទដ្ឋាន ។ ដោយព្រះបាលីថា ជាអ្នកតក់ស្លុត តម្កល់ព្យាយាមដោយឧបាយនៃប្រាជ្ញា ដូច្នេះ ឬមានរឿងប្រារព្ធសេចក្ដីព្យាយាមជាបទដ្ឋាន គប្បីឃើញថា សេចក្ដីព្យាយាម ដែលផ្ដើមហើយដោយប្រពៃជាមូលនៃសម្បត្តិសព្វយ៉ាង ឈ្មោះថា **វីរិយពលំ** ព្រោះអត្ថថា មិនញាប់ញ័រក្នុងការខ្ជិលប្រអូស ។

លក្ខណៈជាដើមរបស់សតិ បានពោលទុកហើយ ។ ឈ្មោះថា **សតិពលំ** ព្រោះអត្ថថា មិនញាប់ញ័រក្នុងការមិនមានស្មារតី ។

ឈ្មោះថា **សមាធិ** ព្រោះអត្ថថា ឲ្យប្រកាន់មាំ គឺឲ្យតាំងទុកនូវសហជាតបច្ច័យទាំងឡាយដោយប្រពៃ ។ សមាធិនោះ មានភាពជាប្រធានជាលក្ខណៈ ឬមានការមិនរវើរវាយជាលក្ខណៈ ឬមានការមិនរាយមាយជាលក្ខណៈ ។ មានការប្រមូលសហជាតធម៌ទាំងឡាយទុកក្នុងអារម្មណ៍ជាកិច្ច ដូចទឹកប្រមូលលម្អិតសម្រាប់ងូតទុក ( ធ្វើឲ្យស្អិតជាប់គ្នា ) ។ មានការស្ងប់ ឬមានញាណៈជាបច្ចុប្បដ្ឋាន សមដូចព្រះតម្រាស់ថា បុគ្គលមានចិត្តតាំងមាំហើយ រមែងដឹងរមែងឃើញតាមសេចក្ដីពិតដោយវិសេស មានសេចក្ដីសុខជាបទដ្ឋាន ។ គប្បីឃើញថា ការតាំងមាំនៃចិត្ត ដូចការឈប់ស្ងៀមរបស់អណ្ដាតប្រទីបក្នុងទីមិនមានខ្យល់ ឈ្មោះថា **សមាធិពលំ** ព្រោះអត្ថថា មិនញាប់ញ័រក្នុងការរាយមាយ ។ ឈ្មោះថា **បញ្ញា** ព្រោះអត្ថថា ដឹងច្បាស់ ដឹងច្បាស់នូវអ្វី គឺដឹងច្បាស់នូវអរិយសច្ចៈទាំងឡាយ ដោយន័យជាដើមថា នេះទុក្ខដូច្នេះ ។ បញ្ញានោះ មានការចាក់ធ្លុះតាមសភាវៈជាលក្ខណៈ ឬមានការចាក់ធ្លុះ មិនភ្លាំងភ្លាត់

ជាលក្ខណៈ ដូចការចាក់ដោះរបស់នាយខ្មាន់ធ្នូ មានការចុះបញ្ចាំងនូវអារម្មណ៍ជាកិច្ច ដូចប្រទីបមានការមិនវង្វេងជាបច្ចុប្បដ្ឋាន ដូចបុគ្គលចង្អុលបង្ហាញយ៉ាងល្អ ដល់បុគ្គលអ្នកទៅព្រៃ ។ ឈ្មោះថា **បញ្ញាពលំ** ព្រោះអត្ថថា មិនញាប់ញ័រក្នុងអវិជ្ជា ។

បទថា **ហិរិពលំ ឱត្តប្បពលំ** សេចក្តីថា ឈ្មោះថា ហិរិពលៈ ព្រោះអត្ថថា មិនញាប់ញ័រក្នុងការមិនមានហិរិ ឈ្មោះថា ឱត្តប្បពលៈ ព្រោះអត្ថថា មិនញាប់ញ័រក្នុងការមិនមានឱត្តប្បៈ ។

ពណ៌នាអត្ថរបស់បទទាំងពីរ មានដូចតទៅនេះថា ឈ្មោះថា ហិរិ ព្រោះអត្ថថា ខ្មាសចំពោះកាយទុច្ចរិតជាដើម ។ ពាក្យថា ហិរិ នេះជាឈ្មោះរបស់ការខ្មាស ឈ្មោះថា ឱត្តប្បៈ ព្រោះអត្ថថា ខ្លាចក្រែងចំពោះកាយទុច្ចរិតជាដើមនោះឯង ។ បទថា **ឱត្តប្ប** នេះ ជាឈ្មោះនៃការតក់ស្លុតចំពោះបាប ។

ដើម្បីសម្តែងការផ្សេងគ្នារបស់ហិរិនិងឱត្តប្បៈនោះ ទើបលោកតាំងមាតិកានេះថា សមុដ្ឋាន ភាពជាធំនិងដោយលក្ខណៈ មានការខ្មាសជាដើមហើយ ពោលពាក្យពិស្តារដូចតទៅនេះថា

ឈ្មោះថា **ហិរិ** មានសមុដ្ឋានខាងក្នុង ឈ្មោះថា **ឱត្តប្ប** មានសមុដ្ឋានខាងក្រៅ ។ ឈ្មោះថា **ហិរិ** មានខ្លួនជាធំ ឈ្មោះថា **ឱត្តប្ប** មានលោកជាធំ ។ ឈ្មោះថា **ហិរិ** តាំងនៅដោយសភាវៈនៃការខ្មាស ឈ្មោះថា **ឱត្តប្ប** តាំងនៅដោយសភាវៈនៃការខ្លាច ។ ឈ្មោះថា **ហិរិ** មានការគោរពជឿស្តាប់ជាលក្ខណៈ ឈ្មោះថា **ឱត្តប្ប** មានភាពជាអ្នកខ្លាចទោសនិងឃើញភ័យជា

លក្ខណៈ ។

បណ្ដាហិរិ និងឱត្តប្បៈទាំងពីរនោះ បុគ្គលញ៉ាំងហិរិមានសមុដ្ឋានខាងក្នុងឲ្យតាំងឡើងដោយហេតុ ៤ យ៉ាងគឺ ពិចារណាជាតិ ពិចារណាវ័យ ពិចារណាភាពជាអ្នកក្លៀវក្លា ពិចារណាភាពជាពហុស្សូត សួរថា ពិចារណា ដូចម្ដេច ឆ្លើយថា បុគ្គលពិចារណាជាតិយ៉ាងនេះថា ឈ្មោះថាការធ្វើបាប មិនមែនជាការធ្វើរបស់បុគ្គលដែលសម្បូរដោយជាតិ ការធ្វើបាបនេះ ជាការធ្វើរបស់បុគ្គលមានជាតិថោកថយ មានពួកអ្នកប្រមង់ជាដើម ការធ្វើកម្មអាក្រក់នេះ មិនសមគួរ ដល់បុគ្គលដែលសម្បូរដោយជាតិដូចអ្នកឡើយ ដូច្នេះ មិនធ្វើបាប មានបាណាតិបាតជាដើម ញ៉ាំងហិរិឲ្យតាំងឡើង ។

បុគ្គលពិចារណាវ័យយ៉ាងនេះថា ឈ្មោះថា ការធ្វើបាបយ៉ាងនោះៗ ជាកម្មដែលបុគ្គលក្មេងៗគប្បីធ្វើ ការធ្វើកម្មនោះមិនសមគួរដល់បុគ្គលដែលតាំងនៅក្នុងវ័យដូចអ្នកឡើយដូច្នេះ មិនធ្វើបាប មានបាណាតិបាតជាដើម ញ៉ាំងហិរិឲ្យតាំងឡើង ។

បុគ្គលពិចារណាភាពជាអ្នកក្លៀវក្លាយ៉ាងនេះថា ឈ្មោះថា ការធ្វើបាបនោះៗ ជាការធ្វើរបស់ពួកអ្នកមានជាតិទុព្វល ការធ្វើកម្មនេះ មិនសមគួរដល់បុគ្គលដែលសម្បូរដោយភាពជាអ្នកក្លៀវក្លា ដូចអ្នកឡើយដូច្នេះ មិនធ្វើបាប មានបាណាតិបាតជាដើម ញ៉ាំងហិរិឲ្យតាំងឡើង ។

បុគ្គលពិចារណាភាពជាពហុស្សូតយ៉ាងនេះថា ឈ្មោះថា ការធ្វើបាបយ៉ាងនោះៗ ជាការធ្វើរបស់ពួកអន្ធពាល មិនមែនរបស់ពួកបណ្ឌិត ការធ្វើកម្មនេះ

មិនសមគួរដល់បណ្ឌិតជាពហុស្សូតដូចអ្នកដូច្នេះ មិនធ្វើបាប មានបាណាតិបាតជាដើម ញុំាងហិរិឲ្យតាំងឡើង បុគ្គលញុំាងហិរិមានសមុដ្ឋានខាងក្នុងឲ្យតាំងឡើងដោយហេតុ ៤ យ៉ាង ដោយប្រការដូច្នេះ កាលឲ្យហិរិតាំងឡើងហើយ ញុំាងហិរិឲ្យចូលទៅក្នុងចិត្តរបស់ខ្លួន ក៏មិនធ្វើបាបកម្ម ។ ឈ្មោះថា ហិរិ មានសមុដ្ឋានខាងក្នុងដូចពណ៌នាមកដោយប្រការដូច្នេះ ។

ឈ្មោះថា ឱត្តប្បៈ មានសមុដ្ឋានខាងក្រៅដូចម្តេច ឆ្លើយថា បុគ្គលពិចារណាយ៉ាងនេះថា បើអ្នកធ្វើកម្មលាមក អ្នកក៏នឹងត្រូវតិះដៀលក្នុងបរិស័ទ ៤ ។

វិញ្ញូជនទាំងឡាយនឹងតិះដៀលអ្នក ដូចអ្នករាជវាំងតិះដៀល
បុគ្គលមិនស្អាត នែភិក្ខុ អ្នកត្រូវបុគ្គលអ្នកមានសីលទាំងឡាយ
បោះបង់ហើយ នឹងធ្វើដូចម្តេច ដូច្នេះ ។

រមែងមិនធ្វើបាបកម្ម ព្រោះឱត្តប្បៈដែលមានសមុដ្ឋានខាងក្រៅ ឈ្មោះថា ឱត្តប្បៈ មានសមុដ្ឋានខាងក្រៅយ៉ាងនេះ ។

ឈ្មោះថា ហិរិ មានខ្លួនជាធំដូចម្តេច កុលបុត្តពួកខ្លះក្នុងលោកនេះ ធ្វើខ្លួនឲ្យជាធំគឺចម្រើនបំផុត រមែងមិនធ្វើបាបដោយពិចារណាថា ការធ្វើបាបកម្មមិនសមគួរដល់អ្នកបួសដោយសទ្ធាដូចអ្នក ដែលជាពហុស្សូត ទ្រទ្រង់នូវធុតង្គ ។ ឈ្មោះថា ហិរិ មានខ្លួនជាធំយ៉ាងនេះ ។ ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ទុក ( ក្នុងអង្គុត្តរនិកាយតិកនិបាត ) ថា លុះភិក្ខុនោះប្រារព្ធលោកឲ្យជាអធិបតេយ្យហើយ តែងលះបង់អកុសល ចម្រើនកុសល លះបង់អំពើដែលប្រកបដោយទោស ចម្រើនតែអំពើដែលមិនមានទោស រក្សាខ្លួន

ឲ្យស្អាត ដូច្នេះ ។ ឈ្មោះថា ឱត្តប្បៈ មានលោកជាធំដូចម្តេច កុលបុត្ត ពួកខ្លះក្នុងលោកនេះ ធ្វើលោកឲ្យជាធំ គឺចម្រើនបំផុត រមែងមិនធ្វើបាបកម្ម ដូចព្រះតម្រាស់ត្រាស់ទុក ( ក្នុងអង្គុត្តរនិកាយតិកនិបាត ) ថា

លោកសន្និវាសនេះសោតក៏ធំ ទោះក្នុងលោកសន្និវាសធំមែន ក៏គង់មានសមណព្រាហ្មណ៍ជាអ្នកមានឫទ្ធិ មានទិព្វចក្ខុ ដឹងចិត្តបុគ្គលដទៃ ពួកសមណព្រាហ្មណ៍ទាំងនោះ រមែងឃើញអំពីចម្ងាយ ទោះនៅជិតក៏មិនប្រាកដ រមែងដឹងច្បាស់នូវចិត្តដោយចិត្ត ពួកសមណព្រាហ្មណ៍ទាំងនោះ គង់ដឹងអាត្មាអញយ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន សូមអ្នកមើលកុលបុត្តនេះចេញចាកផ្ទះមកបួសដោយសទ្ធាហើយ នៅតែច្របូកច្របល់ដោយធម៌ជាអកុសលដ៏លាមក ។ ម្យ៉ាងទៀត គង់មានពួកទេវតាដែលមានឫទ្ធិ មានទិព្វចក្ខុដឹងចិត្តបុគ្គលដទៃ ពួកទេវតាទាំងនោះ តែងឃើញអំពីចម្ងាយ ទោះនៅជិតក៏មិនប្រាកដ រមែងដឹងចិត្តដោយចិត្ត ពួកទេវតាទាំងនោះ គង់ដឹងអាត្មាអញយ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន សូមអ្នកមើលកុលបុត្តនេះចេញចាកផ្ទះមកបួសដោយសទ្ធាហើយ នៅតែច្របូកច្របល់ដោយធម៌ជាអកុសលដ៏លាមក ។ ភិក្ខុនោះពិចារណាដូច្នេះថា អាត្មាអញនឹងប្រារព្ធព្យាយាម មិនឲ្យធូរថយ នឹងប្រុងសតិ មិនឲ្យវង្វេងភ្លេច ឲ្យកាយស្ងប់រម្ងាប់ មិនឲ្យធូរ

ថយ ឲ្យចិត្តតម្កល់មាំ មានអារម្មណ៍តែមួយ ។ លុះភិក្ខុ
នោះប្រារព្ធលោកឲ្យជាអធិបតេយ្យហើយ តែងលះបង់
អកុសល ចម្រើនកុសល លះបង់អំពើដែលប្រកបដោយ
ទោស ចម្រើនតែអំពើដែលមិនមានទោស រក្សាខ្លួនឲ្យស្អាត
ដូច្នេះ ។ ឈ្មោះថា ឱត្តប្បៈ មានលោកជាធំយ៉ាងនេះ ។

ឈ្មោះថា **ហិរិ** តាំងនៅដោយសភាវៈនៃការខ្មាស ឈ្មោះថា **ឱត្តប្ប** តាំង
នៅដោយសភាវៈនៃការខ្លាចនេះ ។ ពាក្យថា **លជ្ជា** ( ខ្មាស ) បានដល់
អាការៈដែលខ្មាស ។ ហិរិតាំងនៅដោយសភាវៈនោះ ។ ពាក្យថា **ភយំ** ( ខ្លាច )
បានដល់ ភ័យក្នុងអបាយ ឱត្តប្បៈតាំងនៅក្នុងសភាវៈនោះ ។

ហិរិនិងឱត្តប្បៈទាំងពីរនោះ រមែងប្រាកដក្នុងការវៀរចាកបាប ដូចបុគ្គល
ពួកខ្លះ ឈានចុះកាន់លជ្ជីធម៌ដែលប្រព្រឹត្តទៅខាងក្នុងហើយ រមែងមិនធ្វើបាប
កម្ម ដូចបុរសម្នាក់កំពុងបន្ទោបង់ឧច្ចារៈបស្សាវៈ ឃើញមនុស្សម្នាក់ដែលគួរ
ខ្មាស គប្បីដល់នូវអាការៈខ្មាស ជាអ្នកខ្មាសអៀនដូច្នោះ ។ បុគ្គលខ្លះជាអ្នក
ខ្លាចភ័យក្នុងអបាយ រមែងមិនធ្វើបាប ក្នុងសេចក្ដីនោះ មានឧបមាដូច្នេះថា

មានដុំដែកពីរដុំ មួយដុំត្រជាក់ ប្រឡាក់លាមក មួយដុំក្ដៅ ភ្លើងឆេះ
ក្រហមប្រាល ។ ក្នុងដុំដែកពីរដុំនោះ បុគ្គលអ្នកឈ្លាសរមែងរង្កៀស មិនចាប់
ដុំដែកត្រជាក់ ព្រោះប្រឡាក់លាមក មិនចាប់ដុំដែកក្ដៅ ព្រោះខ្លាចក្ដៅ ក្នុង
សេចក្ដីនោះគប្បីជ្រាបថា ការឈានចុះកាន់លជ្ជីធម៌ខាងក្នុង មិនធ្វើបាប ដូច
ការមិនចាប់ដែកត្រជាក់ ព្រោះរង្កៀសការប្រឡាក់លាមក ការមិនធ្វើបាប ព្រោះ

ខ្លាចភ័យក្នុងអបាយ ដូចការមិនចាប់ដុំដែកក្តៅ ព្រោះខ្លាចក្តៅ ។

ក្នុងពាក្យទាំងពីរថា ឈ្មោះថា **ហិរិ** មានការគោរពជឿស្តាប់ជាលក្ខណៈ ឈ្មោះថា **ឱត្តប្បំ** មានភាពជាអ្នកខ្លាចទោសនិងឃើញភ័យជាលក្ខណៈ រមែងប្រាកដក្នុងការវៀរចាកបាបនោះឯង ។

បុគ្គលពួកខ្លះ ញុំាងហិរិដែលមានការគោរពជឿស្តាប់ជាលក្ខណៈ ឲ្យតាំងឡើងហើយ មិនធ្វើបាបដោយហេតុ ៤ ប្រការ គឺពិចារណាភាពជាធំរបស់ជាតិ ១ ពិចារណាភាពជាធំរបស់ព្រះសាស្តា ១ ពិចារណាភាពជាធំនៃភាពជាបុគ្គលទទួលមត៌ក ១ ពិចារណាភាពជាធំរបស់សព្រហ្មចារី ១ ។

បុគ្គលពួកខ្លះញុំាងឱត្តប្បៈ ដែលមានការឃើញទោសនិងឃើញភ័យជាលក្ខណៈឲ្យតាំងឡើងហើយ មិនធ្វើបាបដោយអាការៈ ៤ យ៉ាង គឺខ្លាចនូវការតិះដៀលខ្លួនឯង ១ ខ្លាចអ្នកដទៃតិះដៀល ១ ខ្លាចអាជ្ញា ១ ខ្លាចទុគ្គតិ ១ ។ ក្នុងហេតុ ៤ និងអាការៈ ៤ នោះ ការពិចារណាភាពជាធំរបស់ជាតិជាដើម និងការខ្លាចនូវការតិះដៀលខ្លួនឯងជាដើម គប្បីពោលឲ្យពិស្តារ ។

ពលៈ ៧ ដែលពោលហើយយ៉ាងនេះមិនមានដល់បុគ្គលណា កិលេសទាំងឡាយនោះ រមែងញុំាញី ។បេ។ រួបរឹតឈ្លចឈ្លីបុគ្គលនោះឯង ។

[ ២២ ] បទថា **ទ្វេ បរិស្សយា** សេចក្តីថា អន្តរាយមានពីរយ៉ាង គឺអន្តរាយដែលប្រាកដនិងអន្តរាយដែលកំបាំង មិនមែន ១ មិនមែន ៣ ។ ដើម្បីសម្តែងអន្តរាយទាំងនោះជាចំណែកៗ ទើបព្រះសារីបុត្តត្រេរពោលពាក្យជាដើមថា **កតមេ បាកដបរិស្សយា** ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កោរកា** ស្មើគ្នានឹង **កោរកា** ប្រែថា ក្ដៅព្រៃ ។ ម្យ៉ាងទៀត បាឋៈជា **កោរកា** ក៏មាន ។ បទថា **មាណវា** បានដល់ ជាអ្នកប្រកបការងាររួសរាន់ ។ បទថា **កតកម្មា** បានដល់ បុគ្គលធ្វើចោរកម្ម មានកាត់ទីតជាដើម ។ បទថា **អកតកម្មា** បានដល់ អ្នកចេញដើម្បីធ្វើចោរកម្មនោះ ។ បទថា **អស្សុ** ក្នុងទីនេះ ប្រែថា គប្បីជា ។ បទថា **ចក្ខុរោគោ** បានដល់ រោគដែលកើតក្នុងភ្នែក ។ ឈ្មោះថា រោគ ដោយអត្ថថា ចាក់ដោត ។

បទថា **ចក្ខុរោគោ** ជាដើមគប្បីជ្រាបដោយអំណាចនៃវត្ថុ ។ ធម្មតា រោគរមែងមិនមានដល់បុគ្គលដែលមានបសាទល្អ ។

បទថា **កណ្ណរោគោ** បានដល់ រោគត្រចៀកខាងក្រៅ ។ បទថា **មុខរោគោ** បានដល់ រោគដែលកើតក្នុងមាត់ ។ បទថា **ទន្តរោគោ** បានដល់ រោគដែលកើតក្នុងធ្មេញ ។ បទថា **កាសោ** បានដល់ រោគក្អក ។ បទថា **សាសោ** បានដល់ រោគក្អួតដែលច្រើន ។ បទថា **បិនាសោ** បានដល់ រោគប្រមុះខាងក្រៅ ។ បទថា **ឌហោ** បានដល់ រោគក្ដៅដែលកើតខាងក្នុង ។ បទថា **មុច្ឆា** បានដល់ រោគដែលអស់សតិ ។ បទថា **បក្ខន្ទិកា** បានដល់ រោគចុះឈាម ។ បទថា **សុលា** បានដល់ រោគសៀតផ្ទៃ ។ បទថា **វិសូចិកា** បានដល់ រោគចុកផ្ទៃយ៉ាងខ្លាំងក្លា ។ បទថា **កិលាសោ** បានដល់ រោគស្រែង ។ បទថា **សោសោ** បានដល់ រោគក្អករីងរៃ ។ បទថា **អបមារោ** បានដល់ រោគឆ្កួតជ្រូក ជារោគដែលកើតចំពោះអ្នកមានពៀរ ឬយក្សបៀតបៀន ។ បទថា **ទទ្ទុ** បានដល់ រោគដំបៅរលួយ ( ដំណួចពិស ) ។ បទថា **កណ្ឌុ**

*បានដល់ រោគរមាស់ ។ បទថា* **កច្ឆុ** *បានដល់ រោគកម ។ បទថា* **រខសា** *បានដល់ រោគដែលកើតត្រង់ក្រចក បាលីថា* **ឆខសា** *ដូច្នេះក៏មាន ។ បទថា* **វិតច្ឆិកា** *បានដល់ រោគដែលកើតត្រង់បាតដៃ បាតជើងប្រេះជាចង្អូរ ។ បទថា* **លោហិតបិត្តំ** *បានដល់ រោគប្រមាត់កម្រើក លោកអធិប្បាយថា រោគប្រមាត់ក្រហម ។ បទថា* **ធមុមេហោ** *បានដល់ រោគប្រទូស្តខាងក្នុងកាយ ( ទឹកនោមផ្អែម ) សមដូចលោកពោលទុកថា ម្យ៉ាងទៀត រោគទឹកនោមផ្អែមជារោគធ្ងន់ ។ បទថា* **អំសា** *បានដល់ រោគឫសដូងដុះ ។ បទថា* **បិឡកា** *បានដល់ រោគពងបែក ( រលកកែវ ) ។ បទថា* **ភគន្ទលា** *បានដល់ រោគឫសដូងបាត ព្រោះអត្ថថា ទម្លាយអវយវៈ អធិប្បាយថា ទម្លាយវច្ចមគ្គ ។*

*បទថា* **បិត្តសមុដ្ឋានា** *សេចក្តីថា មានប្រមាត់ជាសមុដ្ឋាន គឺជាទីកើតឡើងនៃអាពាធទាំងនោះ បានឮថា អាពាធទាំងនោះមាន ៣២ ប្រភេទ ក្នុងអាពាធ មានស្លេស្មជាសមុដ្ឋានជាដើម ក៏ន័យនេះឯង ។*

*បទថា* **សន្និបាតិកា** *បានដល់ អាពាធដែលកើតឡើងដោយខ្យល់ ប្រមាត់និងស្លេស្មប្រជុំគ្នា គឺរួមគ្នា ឈ្មោះថាអាពាធដោយអត្ថថា បៀតបៀន ។*

*បទថា* **ឧតុបរិណាមជា** *បានដល់ រោគដែលកើតឡើង ព្រោះឧតុប្រែប្រួល គឺក្តៅពេក រងាពេក ។*

*បទថា* **វិសមបរិហារជា** *បានដល់ អាពាធដែលកើតអំពីការបរិហារមិនស្មើ មានឈរពេក អង្គុយពេកជាដើម ។*

*បទថា* **ឱបក្កមិកា** *បានដល់ ដែលកើតដោយសេចក្តីព្យាយាម មានការ*

សម្លាប់និងការចងជាដើម ។

បទថា **កម្មវិបាកជា** បានដល់ អាពាធដែលកើតអំពីវិបាកនៃកម្មដែលមានកម្លាំង ។ អាពាធក្នុងបទថា **សីតំ ឧណ្ហំ ។បេ។ សម្ផស្សា** ទាំងនេះ ប្រាកដច្បាស់ហើយនោះឯង ។ បទថា **ឥតិវា** បានដល់ ដោយប្រការដូច្នេះឯង ។ បទថា **ឥមេ វុច្ចន្តិ** បានដល់ ពោលសរុប ។ បទថា **កតមេ បដិច្ឆន្ន-បរិស្សយា** សេចក្តីថា ព្រះសារីបុត្តត្រាស់សួរថា អន្តរាយមិនប្រាកដដូចម្តេច ។

បណ្តាបទទាំងនោះ បទថា **កាយទុច្ចរិតំ** គប្បីជ្រាបថា បានដល់ ចេតនាក្នុងបាណាតិបាត អទិន្នាទាននិងកាមេសុមិច្ឆាចារៈ ។ បទថា **វចីទុច្ចរិតំ** គប្បីជ្រាបថា បានដល់ ចេតនាក្នុងការពោលកុហក ពោលញុះញង់ ពោលនូវពាក្យគ្រោតគ្រាត និងពោលឥតប្រយោជន៍ ។ បទថា **មនោទុច្ចរិតំ** គប្បីជ្រាបថា បានដល់ អភិជ្ឈា ព្យាបាទ និងមិច្ឆាទិដ្ឋិ ។

ឈ្មោះថា កាយទុច្ចរិត ព្រោះអត្ថថា ការប្រព្រឹត្តអាក្រក់ដែលប្រព្រឹត្តទៅក្នុងកាយ ឬការប្រព្រឹត្តអាក្រក់ ដែលប្រព្រឹត្តទៅផ្លូវកាយ ឬការប្រព្រឹត្តអាក្រក់ ព្រោះភាពជាអ្នកប្រទូស្តដោយកិលេស ក្នុងវចីទុច្ចរិតជាដើម ក៏ន័យនេះឯង ។

ឈ្មោះថា កាម ព្រោះអត្ថថា ដែលបុគ្គលប្រាថ្នា បានដល់ កាមគុណ ៥ ។ ការពេញចិត្តក្នុងកាមទាំងឡាយ ឈ្មោះថា **កាមឆន្ទ** ។ម្យ៉ាងទៀត ឈ្មោះថា កាម ព្រោះអត្ថថា ប្រាថ្នា ។ ការពេញចិត្ត គឺការប្រាថ្នាឈ្មោះថា **កាម-ឆន្ទ** សេចក្តីថា មិនមែនការពេញចិត្តប្រាថ្នានឹងធ្វើការងារ ។ កាមតណ្ហានោះ

ឯង មានឈ្មោះយ៉ាងនេះ ។ ឈ្មោះថា **នីវរណំ** ព្រោះអត្ថថា រារាំងនូវកុសលធម៌ទាំងឡាយ ។ នីវរណៈ គឺកាមច្ឆន្ទៈ ឈ្មោះថា **កាមច្ឆន្ទនីវរណំ** ។ ក្នុងបទដ៏សេស ក៏មានន័យយ៉ាងនេះ ។ ឈ្មោះថា **ព្យាបាទ** ព្រោះអត្ថថា ជាគ្រឿងដល់នូវសេចក្ដីវិនាស គឺចិត្តចូលដល់ការវិនាស ឬឲ្យដល់សេចក្ដីវិនាស គឺញុំាងសម្បត្តិ គឺ វិន័យ និងអាចារៈ ឬប្រយោជន៍ និងសេចក្ដីសុខជាដើមឲ្យវិនាស ។

ការរួញរាឈ្មោះថា **ថីន** ការងោកងុយ ឈ្មោះថា **មិទ្ធ** អធិប្បាយថា ការមិនខ្មីឃ្មាតនិងការទម្លាយសម្បត្តិ ។ ថីនៈផង មិទ្ធៈផងឈ្មោះថា **ថីនមិទ្ធ** ក្នុងពីរយ៉ាងនោះ **ថីន** មានការមិនខ្មីឃ្មាតជាលក្ខណៈ មានការបន្ទោបង់នូវការព្យាយាមជាកិច្ច មានការរួញរាជាបច្ចុប្បដ្ឋាន ។ **មិទ្ធ** មានការមិនគួរដល់ការងារជាលក្ខណៈ មានការធ្លាក់ចុះជាកិច្ច មានសេចក្ដីប្រអូស ឬការងងុយងោកងក់ជាបច្ចុប្បដ្ឋាន ។ ថីនៈក្ដី មិទ្ធៈក្ដី មានអយោនិសោមនសិការៈក្នុងការមិនត្រេកអរ ក្នុងការទម្រន់ និងការប្រអូសជាដើម ជាបទដ្ឋាន ។

ភាពនៃបុគ្គលរាយមាយ ឈ្មោះថា **ឧទ្ធច្ច** ។ ឧទ្ធច្ចៈនោះ មានការមិនស្ងប់ជាលក្ខណៈ មានការមិនតាំងមាំដូចពពុះទឹកត្រូវខ្យល់បក់ជាកិច្ច ។ មានចិត្តដែលឆ្វេឆ្វា ដូចទង់ជ្វាលាបោកបក់ព្រោះត្រូវខ្យល់ផាត់ ជាបច្ចុប្បដ្ឋាន ។ មានអយោនិសោមនសិការៈក្នុងការមិនស្ងប់ចិត្ត ដូចផេះហុយឡើង ព្រោះត្រូវគប់ដោយដុំថ្មជាបទដ្ឋាន គប្បីឃើញថា ជាការរាយមាយនៃចិត្តនោះឯង ។

អំពើគួរខ្ពើមដែលបុគ្គលធ្វើហើយ ឈ្មោះថា **កុក្កុត** ភាពនៃកុក្កតៈនោះ

ឈ្មោះថា **កុក្កុច្ចំ** ។ កុក្កុច្ចនោះ មានការតាមក្តៅក្រហាយខាងក្រោយជាលក្ខណៈ មានសេចក្តីសោកដល់វត្ថុដែលធ្វើហើយនិងមិនទាន់បានធ្វើជាកិច្ច មានការក្តៅក្រហាយជាបច្ចុប្បដ្ឋាន មានវត្ថុដែលធ្វើហើយនិងមិនទាន់បានធ្វើជាបទដ្ឋាន ។ គប្បីឃើញឧទ្ធច្ចៈ និងកុក្កុច្ចៈដូចជាទាសៈ ។

ឈ្មោះថា **វិចិកិច្ឆា** ព្រោះអត្ថថា ជាហេតុឲ្យបុគ្គលកាលគិតសភាវៈធម៌រមែងលំបាក ។ វិចិកិច្ឆានោះ មានការសង្ស័យជាលក្ខណៈ មានការមិនដាច់ស្រេចជាកិច្ច មានការកាត់សម្រេចមិនបាន ឬមានការកាន់យកច្រើនចំណែកជាបច្ចុប្បដ្ឋាន វិចិកិច្ឆាមានអយោនិសោមនសិការៈជាបទដ្ឋាន គប្បីឃើញថាជាធម៌ធ្វើឲ្យអន្តរាយដល់ការបដិបត្តិ ។

**រាគោ** មានការត្រេកត្រអាលជាលក្ខណៈ **ទោសោ** មានការប្រទូស្តជាលក្ខណៈ **មោហោ** មានការវង្វេងជាលក្ខណៈ ។

**កោធោ** មានការក្រោធ ឬការកាចជាលក្ខណៈ មានការធ្វើនូវអាឃាតជាកិច្ច មានការប្រទូស្តជាបច្ចុប្បដ្ឋាន ។

**ឧបនាហោ** មានការចងចិត្តដែលឈឺចាប់ជាលក្ខណៈ មានការចងពៀរជាកិច្ច មានការចូលទៅចងសេចក្តីក្រោធជាបច្ចុប្បដ្ឋាន សមដូចលោកពោលទុក ( ក្នុងព្រះអភិធម្មវិភង្គ ) ថា សេចក្តីក្រោធក្នុងកាលជាដើម ការចងសេចក្តីក្រោធទុកក្នុងកាលជាខាងក្រោយ[១]ដូច្នេះជាដើម ។

**មក្ខោ** មានការលុបគុណជាលក្ខណៈ មានការធ្វើឲ្យគុណរបស់លោក

១-ការខឹងជាដំបូង ឈ្មោះថា កោធៈ ការខឹងក្រោយៗ ឈ្មោះថា ឧបនាហៈ ។

ទាំងនោះវិនាសជាកិច្ច មានការបិទនូវគុណជាបច្ចុប្បដ្ឋាន ។

**បលាសោ** មានការប្រៀបផ្ទឹមជាលក្ខណៈ មានការធ្វើគុណរបស់ខ្លួនឲ្យស្មើនឹងគុណរបស់អ្នកដទៃជាកិច្ច មានការលើកឡើងប្រៀបធៀបនូវគុណរបស់បុគ្គលដទៃជាបច្ចុប្បដ្ឋាន ។

**ឥស្សា** មានការធ្វើសម្បត្តិរបស់អ្នកដទៃឲ្យអស់ទៅ ឬអត់ធន់មិនបានចំពោះសម្បត្តិនោះជាលក្ខណៈ មានការមិនត្រេកអរក្រៃលែងក្នុងសម្បត្តិនោះជាកិច្ច មានការបែរមុខចាកសម្បត្តិនោះជាបច្ចុប្បដ្ឋាន ។

**មច្ឆេរំ** មានការលាក់នូវសម្បត្តិរបស់ខ្លួនជាលក្ខណៈ មានការអត់ធន់មិនបានក្នុងសម្បត្តិរបស់ខ្លួនដែលជាសាធារណៈដល់អ្នកដទៃជាកិច្ច មានការមិនពេញចិត្តជាបច្ចុប្បដ្ឋាន ។

**មាយា** មានការបិទនូវអំពើអាក្រក់ដែលខ្លួនធ្វើជាលក្ខណៈ មានការធ្វើមិនឲ្យច្បាស់នូវអំពើអាក្រក់ដែលខ្លួនធ្វើជាកិច្ច មានការបិទកំបាំងនូវអំពើអាក្រក់ដែលខ្លួនធ្វើនោះជាបច្ចុប្បដ្ឋាន ។

**សាឋេយ្យំ** មានការប្រកាសគុណរបស់ខ្លួនដែលមិនមានជាលក្ខណៈ មានការបន្ទឹដល់គុណទាំងនោះជាកិច្ច មានការធ្វើគុណទាំងនោះឲ្យប្រាកដដោយអាកប្បកិរិយាជាបច្ចុប្បដ្ឋាន ។

**ថម្ភោ** មានភាពរឹងត្អឹងនៃចិត្តជាលក្ខណៈ មានការប្រព្រឹត្តមិនជឿ មិនស្តាប់ជាកិច្ច មានការមិនទន់ភ្លន់ជាបច្ចុប្បដ្ឋាន ។

**សារម្ភោ** មានការធ្វើក្រៃលែងឡើង ( ផ្តើន ) ជាលក្ខណៈ មានភាព

ជាសត្រូវជាកិច្ច មានការមិនគោរពជាបច្ចុប្បដ្ឋាន ។

**មានោ** មានភាពក្រៃលែងជាលក្ខណៈ មានការលើកខ្លួនជាកិច្ច មានការរឹងត្អឹងជាបច្ចុប្បដ្ឋាន ។

**អតិមានោ** មានសភាពក្រៃលែងជាលក្ខណៈ មានការតម្កើងខ្លួនក្រៃលែងជាកិច្ច មានការរឹងត្អឹងនៃចិត្តក្រៃលែងជាបច្ចុប្បដ្ឋាន ។

**មទោ** មានការស្រវឹងជាលក្ខណៈ មានការនាំទៅនូវការស្រវឹងជាកិច្ច មានការឆ្កួតជាបច្ចុប្បដ្ឋាន ។

**បមាទោ** មានការបណ្តោយចិត្តទៅក្នុងកាមគុណ ៥ ជាលក្ខណៈ មានការបន្ថែមនូវការបណ្តោយចិត្តជាកិច្ច មានការខ្វះស្មារតីជាបច្ចុប្បដ្ឋាន ។ គប្បីជ្រាបលក្ខណៈជាដើមរបស់ធម៌ទាំងនេះ ដោយប្រការដូច្នេះ នេះជាសេចក្តីសង្ខេបក្នុងរឿងនេះ ។

ចំណែកសេចក្តីពិស្តារ គប្បីជ្រាបតាមន័យដែលពោលទុកក្នុងគម្ពីរ អភិធម្មវិភង្គ មានជាដើមថា **តត្ថ កតមោ កោធោ** ដូច្នេះជាដើម ។ តែក្នុងទីនេះគប្បីជ្រាបជាពិសេសដូចតទៅនេះថា បុគ្គលប្រាថ្នាអាមិស កាលខ្លួនឯងមិនបាន រមែងក្រោធនឹងអ្នកដទៃដែលបាន ។ សេចក្តីក្រោធរបស់បុគ្គលដែលកើតម្តងជាសេចក្តីក្រោធនោះឯង ដែលកើតឡើងក្រៃលែងជានោះ ជាការចងសេចក្តីក្រោធទុក ( ឧបនាហៈ ) បុគ្គលនោះក្រោធយ៉ាងនេះ និងចងសេចក្តីក្រោធទុក រមែងលុបគុណដែលមានរបស់អ្នកដទៃដែលបានលាភ និងវាយស្មើថា សូម្បីអាត្មាអញក៏ដូច្នោះ ។ នេះជាការលុបគុណនិងវាយឫកស្មើរបស់

បុគ្គលនោះ ។ បុគ្គលដែលមានការលុបគុណ មានការវាយឫកស្មើនោះ រមែង ប្រណែន រមែងប្រទូស្តក្នុងលាភសក្ការៈជាដើមរបស់អ្នកដទៃថា វត្ថុនេះជា ប្រយោជន៍អ្វីដល់បុគ្គលនេះ នេះជាការប្រណែនរបស់បុគ្គលនោះ បើបុគ្គល នោះមានសម្បត្តិណាមួយ បុគ្គលនោះមិនអាចចំណាយសម្បត្តិរបស់ខ្លួនឲ្យជា សាធារណៈបាន នេះជាការកំណាញ់របស់បុគ្គលនោះ ។ បុគ្គលនោះបិទបាំង ទោសទាំងឡាយដែលមានរបស់ខ្លួន ព្រោះហេតុនៃលាភ នេះជាមាយារបស់ បុគ្គលនោះ ។ បុគ្គលនោះប្រកាសគុណទាំងឡាយដែលមិនមាន នេះជា សាឋេយ្យៈរបស់បុគ្គលនោះ ។ បុគ្គលនោះបដិបត្តិយ៉ាងនេះ បើបានលាភតាម បំណង ជាការរឹងត្អឹង មានចិត្តមិនទន់ភ្លន់ ដោយហេតុនោះមិនអាចពោលប្រៀន ប្រដៅថា រឿងនេះមិនគួរធ្វើយ៉ាងនេះ នេះជាភាពរឹងត្អឹងរបស់បុគ្គលនោះ ។ បើបុគ្គលណាមួយពោលនូវពាក្យណាមួយថា រឿងនេះ អ្នកមិនគួរធ្វើយ៉ាងនេះ រមែងមានចិត្តរំជើបរំជួល ព្រោះហេតុនោះ ទើបមានមុខក្រញូវ ពោលកំហែងថា ឯងជាអ្វីរបស់អញ នេះជាការប្រណាំង វាសនារបស់បុគ្គលនោះ បន្ទាប់ អំពីនោះ បុគ្គលនោះមានការរឹងត្អឹងសម្គាល់ខ្លួនថា អាត្មាអញប៉ុណ្ណោះប្រសើរ ជាងគេ ជាបុគ្គលមានការតម្កើងខ្លួន មើលងាយអ្នកដទៃដោយការប្រណាំង ប្រជែងថា អ្នកទាំងនេះជាអ្វី ជាអ្នកមើលងាយ នេះជាមានះនិងអតិមានះរបស់ បុគ្គលនោះ ។ បុគ្គលនោះញ៉ាំងសេចក្តីស្រវឹងច្រើនយ៉ាង មានស្រវឹងដោយ ជាតិជាដើម ឲ្យកើតដោយការប្រកាន់ខ្លួននិងមើលងាយលោកទាំងនោះ ដែល ជាអ្នកស្រវឹង រមែងប្រមាទក្នុងវត្ថុទាំងឡាយ មានកាមគុណជាដើម នេះជា

ការស្រវឹងនិងការប្រមាទរបស់បុគ្គលនោះ ។

បទថា **សព្វេ កិលេសា** សេចក្តីថា អកុសលធម៌ទាំងពួង ឈ្មោះថា កិលេស ដោយអត្ថថា ដុតរោល និងដោយអត្ថថា បៀតបៀន ឈ្មោះថា **ទុច្ចរិតា** ព្រោះត្រូវកិលេសប្រទូស្ត ឈ្មោះថា **ទរថា** ដោយអត្ថថា ធ្វើនូវការក្រវល់ក្រវាយ ឈ្មោះថា **បរិឡាហា** ដោយអត្ថថា ធ្វើនូវការដុតខាងក្នុងជាដើម ។ ឈ្មោះថា **សន្តាបា** ដោយអត្ថថា ឆេះសព្វកាល ។ ឈ្មោះថា **សព្វាកុសលាភិសង្ខារា** ដោយអត្ថថា កើតអំពីការៈនៃអកុសលនិងដោយអត្ថថា តាក់តែង ។

បទថា **កេនត្ថេន** បានដល់ ដោយអត្ថដូចម្តេច ដើម្បីនឹងសម្តែងអត្ថ ៣ យ៉ាង មានការគ្របសង្កត់ជាដើម ព្រះសារីបុត្តត្ថេរពោលពាក្យជាដើមថា **បរិសហន្តីតិ បរិស្សយា** ដូច្នេះ ។

បទថា **បរិសហន្តិ** សេចក្តីថា រមែងញ៉ាំងទុក្ខឲ្យកើតឡើង រមែងគ្របសង្កត់ ។ បទថា **បរិហានាយ សំវត្តន្តិ** សេចក្តីថា រមែងប្រព្រឹត្តទៅដើម្បីលះបង់កុសលធម៌ទាំងឡាយ ។

បទថា **តត្រាសយា** សេចក្តីថា អកុសលធម៌ទាំងឡាយរមែងអាស្រ័យគឺរមែងនៅក្នុងសរីរៈនោះ អធិប្បាយថា រមែងកើតឡើង ។

បទថា **តេ បរិស្សយា** បានដល់ ដែលអន្តរាយ មានកាយទុច្ចរិតជាដើម ។

បទថា **កុសលានំ ធម្មានំ អន្តរាយាយ** សេចក្តីថា រមែងប្រព្រឹត្តទៅ

ដើម្បីការអន្តរធានទៅ គឺឃើញមិនបាននៃធម៌ទាំងឡាយដែលកើតអំពីការៈ ដែលជាកុសល មានសមាបដិបទាជាដើម ដែលគប្បីពោលខាងមុខ ។

បទថា **សម្មាបដិបទាយ** បានដល់ បដិបទាដែលល្អ ដែលបណ្ឌិតសរសើរ មិនមែនមិច្ឆាបដិបទា ។

បទថា **អនុលោមប្បដិបទាយ** បានដល់ បដិបទាដែលមិនប្រឆាំង មិនមែនបដិបទាដែលវិលត្រឡប់ ។

បទថា **អបច្ចនីកប្បដិបទាយ** បានដល់ មិនមែនបដិបទាដែលជាសត្រូវ គឺមិនមែនបដិបទាដែលជាម្ចាស់ ។

បទថា **អន្វត្ថប្បដិបទាយ** បានដល់បដិបទាដែលអនុលោមតាមប្រយោជន៍ គឺបដិបទាដែលឲ្យចម្រើនក្រៃលែងឡើង លោកអធិប្បាយទុកថា បដិបទាដែលគប្បីបដិបត្តិឲ្យកើតប្រយោជន៍ ។ បាលីថា **អត្តត្ថបដិបទាយ** ដូច្នេះក៏មានតែសេចក្តីនោះមិនល្អ ។

បទថា **ធម្មានុធម្មប្បដិបទាយ** សេចក្តីថា លោកុត្តរធម៌ ៩ ឈ្មោះថា ធម៌ វិបស្សនាជាដើម ឈ្មោះថា អនុធម៌ បដិបទាដែលសមគួរដល់ធម៌នោះ ឈ្មោះថា អនុធម្មប្បដិបទា ។ នៃការបដិបត្តិធម៌សមគួរដល់ធម៌នោះ ។

បទថា **សីលេសុ បរិបូរិការិតាយ** បានដល់ ភាពជាអ្នកតាំងនៅក្នុងសីល គឺបាតិមោក្ខ ធ្វើឲ្យបរិបូណ៌ ។

បទថា **ឥន្ទ្រិយេសុ គុត្តទ្វារតាយ** បានដល់ ភាពជាបុគ្គលមានទ្វារគ្រប់គ្រងល្អហើយក្នុងឥន្ទ្រិយ មានចិត្តជាគម្រប់ ៦ ដែលត្រាស់ទុកដោយន័យថា

**ចក្ខុនា រូបំ ទិស្វា** ជាដើម ។

បទថា **ភោជនេ មត្តញ្ញុតាយ** បានដល់ ភាពជាអ្នកប្រកបដោយប្រមាណក្នុងការទទួលជាដើម និងភាពជាអ្នកកំណត់ក្នុងភោជនមិនដូចនាយអលង្សា-ដក[1]ជាដើម ។

បទថា **ជាគរិយានុយោគស្ស** បានដល់ ប្រកបរឿយៗនូវធម៌ជាគ្រឿងភ្ញាក់រឭក ៥ ប្រការ ដោយន័យ ( ក្នុងអង្គុត្តរនិកាយតិកនិបាត ) ជាដើម យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ រមែងធ្វើចិត្តឲ្យស្អាតចាកអាវរណីយធម៌ ( ធម៌ជាគ្រឿងរាំង ) ដោយការចង្ក្រម ដោយការអង្គុយអស់ ១ ថ្ងៃ ដូច្នេះ ។ បទថា **សតិសម្បជញ្ញស្ស** បានដល់ សតិនិងសម្បជញ្ញៈ ដែលជាឧបការៈសព្វកាលដល់ព្រះយោគាវចរគ្រប់អង្គ ដែលប្រកបដោយការចម្រើនកម្មដ្ឋានទាំងពួង ។

បទថា **សតិប្បដ្ឋានានំ** បានដល់ ឈ្មោះថា បដ្ឋាន ព្រោះពិចារណា ហៅចូលទៅតាំងទុកក្នុងអារម្មណ៍ទាំងឡាយ ទីតាំងគឺសតិ ឈ្មោះថា សតិប្បដ្ឋាន ។ ឯសតិនោះមាន ៤ យ៉ាង ព្រោះប្រព្រឹត្តទៅក្នុងកាយ វេទនា ចិត្ត ធម៌ ដោយអំណាចនៃការកាន់យក ដោយជាអាការៈដែលមិនស្អាត ជាទុក្ខ មិនទៀង មិនមែនតួខ្លួននិងដោយអំណាចនៃការឲ្យសម្រេចកិច្ច ដោយការលះការសម្គាល់ថា ស្អាត សុខ ទៀង ជាតួខ្លួន ។ នូវសតិប្បដ្ឋានទាំង ៤ នោះ ។ បទថា **ចតុន្នំ សម្មប្បធានានំ** សេចក្តីថា ឈ្មោះថា បធាន ព្រោះអត្ថថា ជាគ្រឿងផ្តើម

---

១-មានក្នុងអដ្ឋកថាធម្មសង្គិណីនិក្ខេបកណ្ឌ សុត្តន្តិកទុកៈ ។

*តម្កល់ចិត្ត ។ ឈ្មោះថា សម្មប្បធាន ព្រោះអត្ថថា ការផ្តើមល្អ ឬជាគ្រឿងផ្តើមដោយប្រពៃ ម្យ៉ាងទៀត ការផ្តើមនោះឈ្មោះថាល្អ ព្រោះវៀរចាកកិលេសប្រភេទផ្សេងៗនិងឈ្មោះថា បធាន ព្រោះនាំមកនូវភាវៈប្រសើរបំផុត ដោយភាពជាគុណឲ្យសម្រេចប្រយោជន៍និងសេចក្តីសុខ ព្រោះធ្វើនូវភាពជាប្រធាន ព្រោះហេតុនោះ ទើបឈ្មោះថា* **សម្មប្បធាន** *។ ពាក្យថា* **សម្មប្បធានំ** *នេះជាឈ្មោះនៃសេចក្តីព្យាយាម ។ សម្មប្បធាននោះមាន ៤ ព្រោះប្រព្រឹត្តទៅដោយឲ្យសម្រេចកិច្ច គឺលះអកុសលដែលកើតឡើងហើយ ធ្វើអកុសលដែលមិនទាន់កើតមិនឲ្យកើត ធ្វើកុសលដែលមិនទាន់កើតឲ្យកើតឡើង ធ្វើកុសលដែលកើតហើយឲ្យតាំងនៅ ។ នូវសម្មប្បធាន ៤ នោះ ។*

*បទថា* **ចតុន្នំ ឥទ្ធិបាទានំ** *នេះមានវិនិច្ឆ័យថា បណ្តាឆន្ទៈ វិរិយៈ ចិត្តៈ និងវិមំសាទាំងឡាយនីមួយៗ ឈ្មោះថា* **ឥទ្ធិ** *ព្រោះអត្ថថា សម្រេច អធិប្បាយថា រមែងរុងរឿង គឺរមែងសម្រេចផល ។ ម្យ៉ាងទៀត ឈ្មោះថា* **ឥទ្ធិ** *ព្រោះអត្ថថា ជាគ្រឿងសម្រេច គឺមាំទាំ ចម្រើន ដល់នូវភាពដ៏ល្អក្រៃលែងរបស់សត្វទាំងឡាយ ដោយអត្ថទី ១ គ្រឿងសម្រេច គឺការសម្រេចដែលឈ្មោះថា* **ឥទ្ធិបាទ** *អធិប្បាយថា ចំណែកគឺការសម្រេច ដោយអត្ថទី ២ ឈ្មោះថា* **ឥទ្ធិបាទ** *ព្រោះជាគ្រឿងដល់នូវការសម្រេច ។*

*បទថា* **បាទ** *បានដល់ ទីតាំង អធិប្បាយថា ឧបាយជាគ្រឿងសម្រេច ព្រោះថា ធម៌ទាំងឡាយ រមែងញុំាងការសម្រេច ពោលគឺការវិសេសក្រៃលែងឡើង ឲ្យកើតឡើង គឺរមែងសម្រេចដោយឥទ្ធិបាទនោះ ។ ហេតុនោះ ទើប*

លោកហៅថា ជាគ្រឿងសម្រេចនូវឥទ្ធិបាទ ៤ នោះ ។

បទថា **សត្តន្នំ ពោជ្ឈង្គានំ** សេចក្តីថា ឈ្មោះថា ពោជ្ឈង្គៈ ព្រោះអត្ថថា ជាអង្គនៃបញ្ញាជាគ្រឿងត្រាស់ដឹង ឬនៃការត្រាស់ដឹង ។ លោកអធិប្បាយទុកថា ធម្មសាមគ្គី នេះលោកហៅថា **ពោធិ** ព្រោះធ្វើវិគ្គហៈថា ព្រះអរិយសាវករមែងត្រាស់ដឹងដោយធម្មសាមគ្គី ពោលគឺសតិ ធម្មវិចយៈ វីរិយៈ បីតិ បស្សទ្ធិ សមាធិនិងឧបេក្ខាដែលកើតឡើងក្នុងខណៈនៃលោកុត្តរមគ្គ ដែលជាបដិបក្ខចំពោះឧបទ្ទវៈទាំងឡាយមិនមែនតិច មានការរួញរា ការរាយមាយ ការជាប់ជំពាក់ ការប្រមូលមក កាមសុខ អត្តកិលមថានុយោគ ឧច្ឆេទទិដ្ឋិ សស្សតទិដ្ឋិ និងការប្រកាន់មាំជាដើម ។

ពាក្យថា រមែងត្រាស់ដឹង សេចក្តីថា ក្រោកឡើងចាកការដេកលក់ដែលជាការបន្តនៃកិលេស គឺចាក់ធ្លុះអរិយសច្ចៈ ៤ ឬធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាននោះឯង ។ ឈ្មោះថា **ពោជ្ឈង្គ** ព្រោះជាអង្គនៃបញ្ញាជាគ្រឿងត្រាស់ដឹង ពោលគឺធម្មសាមគ្គីនោះ ដូចអង្គនៃឈាននិងអង្គនៃមគ្គជាដើម ព្រោះអរិយសាវកនេះលោកហៅថា ត្រាស់ដឹង ព្រោះធ្វើវិគ្គហៈថា ត្រាស់ដឹងដោយប្រពៃនូវធម្មសាមគ្គីនោះ ដែលមានប្រការតាមដែលពោលហើយ ឈ្មោះថា **ពោជ្ឈង្គ** ព្រោះជាអង្គនៃព្រះអរិយសាវកអ្នកត្រាស់ដឹងនោះ ដូចអង្គនៃសេនា ជាដើម ព្រោះហេតុនោះ ទើបព្រះអដ្ឋកថាចារ្យទាំងឡាយពោលទុកថា ម្យ៉ាងទៀតឈ្មោះថា **ពោជ្ឈង្គ** ព្រោះជាអង្គនៃបុគ្គលអ្នកត្រាស់ដឹងដូច្នេះ ។ នូវពោជ្ឈង្គៈទាំង ៧ នោះ ។

*បទថា* **អរិយស្ស អដ្ឋង្គិកស្ស មគ្គស្ស** *មានវិនិច្ឆ័យថា ក្នុងបទថា* **អរិយ** *នោះ ឈ្មោះថា* **អរិយ** *ព្រោះឆ្ងាយចាកកិលេសដែលគប្បីសម្លាប់ដោយមគ្គនោះៗ ព្រោះការធ្វើនូវភាពជាអរិយៈ និងព្រោះជាអ្នកបានចំពោះនូវអរិយផល ។ ផ្លូវ ឈ្មោះថា* **អដ្ឋង្គ** *ព្រោះអត្ថថា មានអង្គ ៨ ។ អង្គ ៨ នោះ ត្រឹមតែអង្គប៉ុណ្ណោះ ដូចសេនាមានអង្គ ៤ តន្ត្រីមានអង្គ ៥ មគ្គដែលផុតចាកអង្គរមែងមិនមាន ។ ឈ្មោះថា មគ្គ ព្រោះអត្ថថា ស្វែងរក គឺសម្លាប់នូវកិលេសទាំងអស់ទៅកាន់ព្រះនិព្វាន ។ ( នូវ ) ការប្រកបរឿយៗ ក្នុងការចម្រើនអរិយមគ្គមានអង្គ ៨ ( នោះ ) ។*

*បទថា* **ឥមេសំ កុសលានំ ធម្មានំ** *បានដល់ កុសលធម៌ដែលជាលោកុត្តរដែលមានប្រការដូចពោលហើយ ។*

*បទថា* **អន្តរាយាយ** *បានដល់ ដើម្បីជាអន្តរាយ គឺដើម្បីអន្តរធាននៃលោកុត្តរធម៌ទាំងឡាយ គឺដើម្បីលះបង់កុសលធម៌ ដែលជាលោកិយៈ និងលោកុត្តរ ។ ក្នុងអន្តរាយទាំងនោះ ឈ្មោះថា* **បរិស្សយា** *ព្រោះអត្ថថា មិនឲ្យលោកុត្តរធម៌ទាំងឡាយកើតឡើង ។ ពិតហើយ អន្តរាយទាំងនោះកើតឡើងហើយ ក៏រលត់ទៅ មិននាំឧបទ្រវៈមកឲ្យ ។*

*បទថា* **តត្ថេតេ** *បានដល់ អកុសលធម៌ទាំងនោះក្នុងអត្តភាពនោះ ។ បទថា* **បាបកា** *ប្រែថា លាមក ។ បទថា* **អត្តភាវសន្និស្សយា** *សេចក្តីថា អកុសលធម៌ដ៏លាមកទាំងនោះ ឈ្មោះថាជាធម៌នៅអាស្រ័យក្នុងអត្តភាព ព្រោះអត្ថថា ចូលទៅអាស្រ័យអត្តភាពដែលកើតឡើងជាអារម្មណ៍ ទើបឈ្មោះ*

ថា អន្តរាយ ។

បទថា **ឱកេ** ប្រែថា ក្នុងទឹក ។ បទថា **វុត្តញ្ហេតំ** ស្មើគ្នានឹង **ភាសិតំ ហិ ឯតំ** ( សមដូចព្រះមានព្រះភាគត្រាស់ទុក ) ។

បទថា **សាន្តេវាសិកោ** សេចក្ដីថា ឈ្មោះថា សាន្តេវាសិកៈ ព្រោះអត្ថថា នៅរួមជាមួយកិលេសដែលនៅអាស្រ័យក្នុងខាងក្នុង ។ ឈ្មោះថា **សា-ចរិយកោ** ព្រោះអត្ថថា នៅរួមជាមួយកិលេសដែលរាយមាយ ។

បទថា **ចក្ខុនា រូបំ ទិស្វា** បានដល់ ឃើញរូបដោយចក្ខុវិញ្ញាណ ។ ក្នុងបទថា **សោតេន សទ្ទំ សុត្វា** ជាដើមខាងមុខ ក៏មានន័យដូច្នេះឯង ។

បទថា **ឧប្បជ្ជន្តិ** បានដល់ រមែងប្រាកដឡើង ។ បទថា **សរសង្កប្បា** បានដល់ មានការត្រិះរិះកើតឡើងដោយអំណាចផ្សាយទៅក្នុងអារម្មណ៍ផ្សេងៗ ។

បទថា **សញ្ញោជនិយា** បានដល់ ឧបការៈដល់សំយោជនៈទាំងឡាយ ដោយការចូលដល់ភាពជាអារម្មណ៍ ហើយចម្រើននៃសំយោជនៈ ។

បទថា **ត្យស្ស** សេចក្ដីថា អកុសលធម៌ដ៏លាមកទាំងនោះ... នៃភិក្ខុនោះ ។ បទថា **អន្តោ វសន្តិ** សេចក្ដីថា រមែងនៅអាស្រ័យក្នុងខាងក្នុង គឺក្នុងចិត្ត ។ បទថា **អន្វាស្សវន្តិ** សេចក្ដីថា រមែងជ្រួតជ្រាប គឺជាប់តាមទៅយ៉ាង ខ្លាំងក្លា តាមការបន្តនៃកិលេស ។ បទថា **នំ** សេចក្ដីថា អកុសលធម៌ ទាំងនោះ ... នូវបុគ្គលនោះ ។ បទថា **សមុទាចរន្តិ** បានដល់ រមែង ប្រព្រឹត្តអើពើ គឺរមែងប្រព្រឹត្តទៅដោយប្រពៃ ។

ឈ្មោះថា **មលោ** ព្រោះអត្ថថា សៅហ្មង ។ ឈ្មោះថា **អមិត្តោ** ព្រោះ

អត្ថថា ជាសត្រូវ ។ ឈ្មោះថា **សបត្តោ** ព្រោះអត្ថថា ជាអ្នកចងពៀរ ។ ឈ្មោះថា **វធកោ** ព្រោះអត្ថថា សម្លាប់ ។ ឈ្មោះថា **បច្ចត្ថិកោ** ព្រោះអត្ថថា ជាបច្ចាមិត្ត ។ ម្យ៉ាងទៀត ឈ្មោះថា **មលោ** ដូចគ្នានឹងពពកជាគ្រឿងសៅហ្មងរបស់ព្រះអាទិត្យ ។ ឈ្មោះថា **អមិត្តោ** ព្រោះផ្សែងជាអមិត្តរបស់ព្រះអាទិត្យ ។ ឈ្មោះថា **សបត្តោ** ព្រោះដូចអ័ព្ទជារបស់ព្រះអាទិត្យ ។ ឈ្មោះថា **វធកោ** ដូចធូលីជាពេជ្ឈឃាដរបស់ព្រះអាទិត្យ ។ ឈ្មោះថា **បច្ចត្ថិកោ** ដូចរាហូជាសត្រូវរបស់ព្រះអាទិត្យ ។

អាចារ្យពួកមួយពណ៌នាយ៉ាងនេះថា ឈ្មោះថា **មលោ** ព្រោះទម្លាយភាពភ្លឺស្វាងនៃចិត្ត ដូចមន្ទិលទម្លាយភាពភ្លឺថ្លារបស់មាស ។ ឈ្មោះថា **អមិត្តោ** ព្រោះទម្លាយសេចក្ដីស្នេហាក្នុងចិត្ត ដូចមន្ទិលគឺលោហៈ ស្មោកគ្រោក ទម្លាយភាពគួរស្រឡាញ់របស់មាស ។ ឈ្មោះថា **សបត្តោ** ព្រោះជាសត្រូវកម្ចាត់ធម៌ដែលតាំងនៅក្នុងចិត្តដូចសត្រូវពីរពួកច្បាំងគ្នា ។ ឈ្មោះថា **វធកោ** ព្រោះដូចពេជ្ឈឃាដសម្លាប់ធម៌ ដូចបុគ្គលសម្លាប់មនុស្ស ។ ឈ្មោះថា **បច្ចត្ថិកោ** ព្រោះជាសត្រូវហាមផ្លូវព្រះនិព្វាន ដូចសត្រូវជាសេចក្ដីវិនាសរបស់ព្រះរាជាដែលចូលជិត ។

បទថា **អនត្ថជននោ** សេចក្ដីថា មានវិនិច្ឆ័យថា មិនមែនវត្ថុដែលជាប្រយោជន៍ ឈ្មោះថា វត្ថុដែលមិនជាប្រយោជន៍ ឈ្មោះថា **អនត្ថជននោ** ព្រោះអត្ថថា ញ៉ាំងវត្ថុដែលមិនជាប្រយោជន៍នោះឲ្យកើតឡើង ។ ធម៌ដែលញ៉ាំងវត្ថុមិនជាប្រយោជន៍ឲ្យកើតឡើងនោះគឺអ្វី គឺលោភៈ ។

បទថា **ចិត្តប្បកោបនោ** សេចក្តីថា ធ្វើចិត្តឲ្យកម្រើក គឺកម្ចាត់ អធិប្បាយថា រារាំងចិត្តមិនឲ្យសម្រេចសេចក្តីល្អ ។

បទថា **ភយមន្តរតោ ជាតំ** សេចក្តីថា ភ័យច្រើនយ៉ាងកើតក្នុងខាងក្នុង គឺក្នុងចិត្តរបស់ខ្លួននោះឯង គឺជាហេតុនៃភ័យ មានការញុំាងវត្ថុដែលមិនជាប្រយោជន៍ឲ្យកើតជាដើម ។ បទថា **តំ ជនោ នាវពុជ្ឈតិ** សេចក្តីថា មហាជនដែលជាបុគ្គលពាល រមែងមិនដឹងដល់ភ័យនោះ ។

បទថា **អត្ថំ** សេចក្តីថា បុគ្គលដែលលោភ រមែងមិនដឹងនូវប្រយោជន៍ដែលជាលោកិយៈនិងលោកុត្តរ ។ បទថា **ធម្មំ** បានដល់ ហេតុនៃប្រយោជន៍នោះ ។ បទថា **អន្ធតមំ** បានដល់ ការងងឹត ។ បទថា **យំ** កែជា **យស្មា** ប្រែថា ព្រោះហេតុណា ។ ឬបានដល់បុគ្គលណា ។ បទថា **សហតេ** ប្រែថា គ្របសង្កត់ ។

បទថា **អជ្ឈត្តំ** បានដល់ ក្នុងរបស់ខ្លួន ។ បទថា **ឧប្បជ្ជមានា ឧប្បជ្ជន្តិ** សេចក្តីថា លុះកើតឡើងដំបូង ក៏កើតឡើងដើម្បីមិនជាប្រយោជន៍ ដើម្បីទុក្ខ ។ ដោយបទទាំងពីរនោះ សំដៅដល់ដើម្បីការនៅមិនផាសុក ។ បទថា **អហិតាយ** បានដល់ ដើម្បីទុក្ខផ្លូវចិត្ត ។ បទថា **ទុក្ខាយ** បានដល់ ដើម្បីទុក្ខផ្លូវកាយ ។ បទថា **អផាសុវិហារាយ** សេចក្តីថា ដោយបទទាំងពីរនោះ មិនមែនដើម្បីការនៅជាសុខ ។

ម្យ៉ាងទៀត បទថា **ឧប្បជ្ជមានា ឧប្បជ្ជន្តិ** សេចក្តីថា តាំងអំពីកវគ្គ-ចលនចិត្តរហូតដល់វោដ្ឋពនចិត្តឈ្មោះថា កាលកើតឡើង ។ លុះដល់វោដ្ឋពន

ចិត្តហើយ ឈ្មោះថារមែងកើតឡើង ព្រោះមិនវិលត្រឡប់ អាចារ្យពួកមួយពណ៌នាយ៉ាងនេះ ដោយប្រការដូច្នេះ ។

បទថា **តចសារំ វសម្ពលំ** សេចក្តីថា ដូចឫស្សីគឺរុក្ខជាតិមានសម្បកជាខ្លឹម ត្រូវវិនាសទៅដោយផ្លែរបស់ខ្លួនដូច្នោះ ។ បទថា **អរតី** បានដល់ មិនពេញចិត្តក្នុងកុសលធម៌ទាំងឡាយ ។ បទថា **រតិ** បានដល់ ត្រេកអរក្រេ-លែងក្នុងកាមគុណ ៥ ។ បទថា **លោមហំសោ** បានដល់ មានរោមបះឡើងដូចបន្លា ។ បទថា **ឥតោនិទានា** សេចក្តីថា ឈ្មោះថា **ឥតោនិទានា** ព្រោះអត្តថា មានអត្តភាពនេះជាហេតុ គឺជាបច្ច័យ ។ បទថា **ឥតោ ជាតា** សេចក្តីថា កើតអំពីអត្តភាពនេះ ។ បទថា **ឥតោ សមុដ្ឋាយ មនោវិតក្កា** សេចក្តីថា អកុសលវិតក្ក តាំងឡើងអំពីអត្តភាពនេះហើយ រមែងបណ្តាយចិត្ត ដូចពួកក្មេងយកអំបោះវែងចងជើងក្អែក យកចុងអំបោះនោះចងត្រង់ម្រាមដៃ ហើយលែងក្អែកទៅ ក្អែកនោះសូម្បីហើរទៅឆ្ងាយ ក៏ត្រឡប់មកធ្លាក់ទៀបជើងរបស់ពួកក្មេងទាំងនោះវិញ ។

ព្រះសូត្រដំបូងដែលនាំមកអាងថា **សាន្តេវាសិកោ** លោកពោលសំដៅយកការនៅរួមដោយកិលេស ។ ព្រះសូត្រទី ២ ដែលនាំមកអាងថា **តយោ-មេ ភិក្ខវេ អន្តរាមលា** លោកពោលដោយអំណាចធ្វើកុសលធម៌ឲ្យសៅហ្មងនិងដោយអំណាចនៃការមិនដឹងវត្ថុដែលជាប្រយោជន៍និងមិនជាប្រយោជន៍ ។

ព្រះសូត្រទី ៣ ដែលនាំមកអាងថា **តយោ ខោ មហារាជ បុរិសស្ស ធម្មា អជ្ឈត្តំ ឧប្បជ្ជមានា** លោកពោលដោយអំណាចកម្ចាត់និស្ស័យរបស់

ខ្លួន ។ ព្រះសូត្រទី ៤ ដែលនាំមកអាងថា **រាគោ ច ទោសោ ច អវិជ្ជា-និវាណា** លោកពោលដោយអំណាច សម្តែងទីតាំងរបស់កិលេសទាំងឡាយ ។

[ ៤៣ ] បទថា **តតោ តតោ បរិស្សយតោ** បានដល់ ព្រោះឧបទ្រវៈនោះៗ ។ បទថា **តំ បុគ្គលំ** បានដល់ បុគ្គលដែលមានការព្រមព្រៀងដោយកិលេស មានប្រការដូចពោលមកហើយ ។ បទថា **ទុក្ខំ អន្វេតិ** សេចក្តីថា ទុក្ខរមែងជាប់តាម ដូចកូនម្រឹគដែលមិនទាន់ដាច់ដោះ រមែងតាមមេទៅ ដូច្នោះ ។ បទថា **អនុគច្ឆតិ** សេចក្តីថា រមែងទៅក្បែរ ដូចអ្នកសម្លាប់ចោរ តាមចោរដែលត្រូវបញ្ជាឲ្យសម្លាប់ដូច្នោះ ។ បទថា **អន្វាយិកំ ហោតិ** សេចក្តីថា រមែងដល់ព្រម ដូចការកំណត់មាតិកាធម៌ ។ បទថា **ជាតិទុក្ខំ** អត្ថជាច្រើនរបស់ជាតិសព្ទ លោកប្រកាសទុកហើយ ។

អត្ថរបស់ជាតិសព្ទ លោកប្រកាសទុកថា ភព ត្រកូល និកាយ សីលបញ្ញត្តិ លក្ខណៈ ប្រសូតនិងបដិសន្ធិ ។

ពិតយ៉ាងនោះ សព្ទថា **ជាតិ** មកក្នុងអត្ថថា ភព ដូចក្នុងប្រយោគជាដើមថា **ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ** ព្រឹកបាន ១ ជាតិខ្លះ ២ ជាតិ ដូច្នេះ ។ មកក្នុងអត្ថថា ត្រកូល ដូចក្នុងប្រយោគជាដើមថា **អក្ខិត្តោ អនុបក្កុដ្ឋោ ជាតិវាទេន** មិនដែលនរណាមួយ ពោលទោសតិះដៀលដោយពោលដល់ជាតិកំណើតឡើយ ដូច្នេះ ។ មកក្នុងអត្ថថា និកាយ ដូចក្នុងប្រយោគជាដើមថា **អត្ថិ វិសាខេ និគណ្ឋា នាម សមណជាតិ** ម្នាលនាងវិសាខា ចុះនិគណ្ឋុបោសថៈ តើដូចម្តេច ។ ម្នាលនាងវិសាខា មានពួកសមណៈហៅថា

*និគណ្ឋៈ ដូច្នេះ ។ មកក្នុងអត្ថថា អរិយសីល ដូចក្នុងប្រយោគជាដើមថា* **យតោហំ ភគិនិ អរិយាយ ជាតិយា ជាតោ នាភិជានាមិ** *នែនាងតាំង អំពីអាត្មាកើតហើយក្នុងអរិយជាតិ ( បានជាអរិយបុគ្គល ) មិនដែលក្លែង ផ្ដាច់ផ្ដិលជីវិតសត្វឡើយ ដូច្នេះ ។ មកក្នុងអត្ថថា បញ្ញត្តិ ដូចក្នុងប្រយោគ ជាដើមថា* **តិរិយា នាម តិណជាតិ នាភិយា ឧគ្គន្ត្វា នភំ អាហច្ច ឋិតា អហោសិ** *មានស្មៅចិញ្ចៀន ១ សរសៃដុះលេចអំពីផ្ចិតទៅទល់នឹងអាកាស ដូច្នេះ ។ មកក្នុងអត្ថថា សង្ខតលក្ខណៈ ដូចក្នុងប្រយោគជាដើមថា* **ជាតិ ទ្វីហិ ខន្ធេហិ សង្គហិតា** *ជាតិសង្គ្រោះដោយខន្ធ ២ ដូច្នេះ ។ មកក្នុងអត្ថថា ប្រសូត ដូចក្នុងបយោគជាដើមថា* **សម្បតិ ជាតោ អានន្ទ ពោធិសត្តោ** *ម្នាល អានន្ទ ពោធិសត្វប្រសូតមកភ្លាម ដូច្នេះ ។ មកក្នុងអត្ថថា បដិសន្ធិខណៈ ដោយអម ដូចក្នុងបយោគជាដើមថា* **ភវបច្ចយា ជាតិ** *ជាតិកើតមានព្រោះ មានភពជាហេតុ ដូច្នេះ ។ និងបទមួយទៀតថា* **ជាតិបិ ទុក្ខា** *កំណើត ( ទាំង ៤ មានជលាពុជជាដើម ) ជាកងទុក្ខ ដូច្នេះ ។ តែដោយត្រង់មានអត្ថថា ការប្រាកដគ្រាដំបូងនៃខន្ធនោះៗ ដែលប្រាកដដល់ពួកសត្វដែលកើតក្នុងភព នោះៗ ។*

*បើសួរថា ព្រោះហេតុអ្វីទើបជាតិជាទុក្ខ គប្បីឆ្លើយថា ព្រោះជាទីតាំង របស់ទុក្ខមិនមែនតិច ឯទុក្ខមិនមែនតិច បានដល់* **ទុក្ខទុក្ខ វិបរិណាមទុក្ខ សង្ខារទុក្ខ បដិច្ឆន្នទុក្ខ អប្បដិច្ឆន្នទុក្ខ បរិយាយទុក្ខ និប្បរិយាយទុក្ខ** ។

*បណ្ដាទុក្ខទាំងនេះ ទុក្ខវេទនាផ្លូវកាយនិងផ្លូវចិត្ត លោកហៅថា* **ទុក្ខទុក្ខ**

ព្រោះជាទុក្ខដោយសភាវៈផង ដោយឈ្មោះផង ។

សុខវេទនា លោកហៅថា **វិបរិណាមទុក្ខ** ព្រោះជាហេតុឲ្យកើតទុក្ខក្នុងកាលប្រែប្រួលទៅ ។

ឧបេក្ខាវេទនាផង សង្ខារដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដ៏សេសផង លោកហៅថា **សង្ខារទុក្ខ** ព្រោះត្រូវសេចក្ដីចម្រើននិងសេចក្ដីវិនាសគ្របសង្កត់ ។

អាពាធផ្លូវកាយ ផ្លូវចិត្ត គឺឈឺត្រចៀក ឈឺធ្មេញ ការក្ដៅក្រហាយ កើតព្រោះរាគៈ ការក្ដៅក្រហាយកើតព្រោះទោសៈនិងមោហៈ លោកហៅថា **បដិច្ឆន្នទុក្ខ** ព្រោះសួរទើបដឹង និងព្រោះមានសេចក្ដីព្យាយាមមិនប្រាកដ ។

អាពាធដែលមានការដាក់ទោស ៣២ យ៉ាងជាដើមជាសមុដ្ឋាន លោកហៅថា **អប្បដិច្ឆន្នទុក្ខ** ព្រោះមិនត្រូវសួរក៏ដឹងនិងព្រោះមានសេចក្ដីព្យាយាមប្រាកដ ។

ទុក្ខដ៏សេសក្រៅអំពីទុក្ខទុក្ខ មកហើយក្នុងសច្ចវិភង្គ ទុក្ខទាំងអស់មានជាតិជាដើម លោកហៅថា **បរិយាយទុក្ខ** ព្រោះជាទីតាំងរបស់ទុក្ខនោះៗ ចំណែក **ទុក្ខទុក្ខ** លោកហៅថា **និប្បរិយាយទុក្ខ** ( ទុក្ខដោយត្រង់ ) ។

បណ្ដាទុក្ខទាំងនោះ ទុក្ខណាដែលប្រព្រឹត្តទៅក្នុងអបាយ ដែលព្រះដ៏មានព្រះភាគត្រាស់ជាឧបមាទុកក្នុងពាលបណ្ឌិតសូត្រជាដើម និងទុក្ខមានការកើតក្នុងគភ៌ជាមូលជាដើម ក្នុងមនុស្សលោកណា រមែងកើតសូម្បីក្នុងសុគតិ ការកើតនេះជាទុក្ខ ព្រោះជាទីតាំងនៃទុក្ខនោះ ។ ក្នុងទុក្ខទាំងនោះ ទុក្ខមានការកើតក្នុងគភ៌ជាមូលជាដើម មានអធិប្បាយដូចតទៅនេះថា

សេចក្តីពិត សត្វនេះមានការកើតឡើងក្នុងផ្ទៃរបស់មាតា មិនមែនកើតក្នុងផ្កាឧប្បល ផ្កាបទុមនិងផ្កាបុណ្ឌរិកៈជាដើមឡើយ ដែលពិតកើតក្នុងចំណែករបស់រាងកាយដែលជាឧទរ ត្រង់កណ្តាលពោះនិងឆ្អឹងខ្នង ក្បាលទូលអាហារថ្មី អន្តុយលើអាហារចាស់ ជាទីដែលចង្អៀតក្រៃលែង ជាទីងងឹត អប់ទៅដោយក្លិនសាកសពផ្សេងៗ មានក្លិនស្អុយក្រៃលែង គួររង្កៀសក្រៃលែង ដូចដង្កូវក្នុងត្រីស្អុយក្នុងទំផ្អមនិងក្នុងបង្គន់ជាដើម សត្វដែលកើតក្នុងផ្ទៃនោះ ត្រូវនៅក្នុងផ្ទៃមាតាអស់ ១០ ខែ ទើបក្តៅដូចអាហារដែលចម្អិនអំពីកម្តៅ ញើសហូរចេញ ដូចដុំម្សៅ វៀរចាកការបត់អន្តញនិងការលាតសណ្តូកជាដើម រមែងសោយទុក្ខមានប្រមាណក្រៃលែង ទុក្ខមានការកើតក្នុងផ្ទៃជាមូល មានប្រមាណប៉ុណ្ណេះសិន ។

សត្វនោះ ពេលដែលមាតាដួល ដើរ អង្គុយ ក្រោកនិងកម្រើកខ្លួនដោយរួសរាន់ជាដើម ហាក់បីដូចជាកូនចៀមនៅក្នុងដៃរបស់អ្នកលេងសុរា និងដូចកូនពស់នៅក្នុងដៃរបស់អ្នកលេងពស់ រមែងសោយទុក្ខមានប្រមាណក្រៃ-លែងដោយការព្យាយាម មានការអូស ការទាញជាដើម ។ សត្វនោះ ពេលមាតាផឹកទឹកត្រជាក់ ក៏ដូចធ្លាក់ក្នុងសីតនរក ពេលមាតាបរិភោគបបរនិងភត្តដែលក្តៅ ក៏ដូចត្រូវរោយដោយរងើកភ្លើង ពេលមាតាបរិភោគរបស់ប្រៃ របស់ជូរជាដើម ក៏ដូចត្រូវដាក់ទោស មានស្រោចដោយទឹកក្បុងជាដើម រមែងសោយទុក្ខធ្ងន់ នេះជាទុក្ខដែលមានការបរិហារគព្ភជាមូល ។

ម្យ៉ាងទៀត ទុក្ខរមែងកើតឡើងដល់សត្វនោះដោយការកាត់ និងការវះជា

ដើម ក្នុងទីដែលកើតទុក្ខរបស់មាតាដែលវង្វេងគភ៌ ( ប្រសូតមិនរួច ) សូម្បីមិត្តអាមាត្យនិងសម្លាញ់ជាដើម ក៏មិនគួរឃើញ នេះជាទុក្ខដែលមានការវិបត្តិនៃគភ៌ជាមូល ។

កាលមាតាប្រសូត ទុក្ខរមែងកើតដល់សត្វនោះ ដែលត្រូវខ្យល់កម្មជវាតបក់ផាត់ឲ្យធ្លាក់ត្រង់ទ្វារកំណើត ដែលគួរខ្លាចក្រៃលែងដូចធ្លាក់ជ្រោះ ត្រូវចាប់ទាញចេញតាមទ្វារកំណើតដែលចង្អៀតក្រៃលែង ដូចដំរីត្រូវទាញចេញតាមប្រហោងសោ ដូចសត្វនរកដែលត្រូវភ្នំកិនកម្ទេច នេះជាទុក្ខដែលមានការប្រសូតជាមូល ។

ម្យ៉ាងទៀត ក្នុងពេលដែលគេចាប់ដៃឲ្យងូតទឹក ធ្វើនូវការសម្អាតនិងជូតដោយសំពត់ទុក្ខដូចគ្នានិងការចាក់ដោយដែកស្រួចនិងវះដោយកាំបិត កោររមែង កើតឡើងដល់សត្វដែលកើតមក ដែលមានរាងកាយទន់ខ្ចីដូចគ្នា និងមុខដំបៅជាដើម នេះជាទុក្ខដែលមានការចេញខាងក្រៅគភ៌មាតាជាមូល ។

ក្នុងការប្រព្រឹត្តទៅបន្ទាប់អំពីនោះ សេចក្តីទុក្ខរមែងមានដល់សត្វដែលសម្លាប់ខ្លួនដោយខ្លួនឯង ដែលប្រកបព្យាយាមដោយការទូន្មានខ្លួន និងការដុតកិលេស ដោយការប្រព្រឹត្តវត្តរបស់អចេលកៈជាដើម ដែលមិនបរិភោគអាហារនិងចងកស្លាប់ព្រោះក្រោធ ។ នេះជាទុក្ខព្រោះមានការខ្វល់ខ្វាយរបស់ខ្លួនជាមូល ។

ម្យ៉ាងទៀត ទុក្ខរមែងកើតដល់សត្វដែលសោយកម្ម មានការសម្លាប់និងការចងជាដើមរបស់អ្នកដទៃនេះ ជាទុក្ខដែលមានការខ្វល់ខ្វាយរបស់អ្នកដទៃ

ជាមូល ។ ទុក្ខទាំងអស់នេះ សុទ្ធតែមានជាតិជាទីតាំងទាំងអស់ ដោយប្រការដូច្នេះ ជាតិទុក្ខនេះ រមែងជាប់តាមទៅ ។

បទថា **ជរាទុក្ខំ** បានដល់ ជរា ២ យ៉ាង គឺលក្ខណៈដែលតាក់តែង ១ ការចាស់នៃខន្ធដែលទាក់ទងក្នុងភពឯណានីមួយក្នុងការបន្តដែលហៅថា ធ្មេញបាក់ជាដើម ១ ។ ជរានោះ លោកបំណងយកក្នុងទីនេះ ជរានេះ ជាទុក្ខ ព្រោះភាពជាទុក្ខក្នុងសង្សារវដ្តនិងព្រោះជាទីតាំងនៃទុក្ខ ទុក្ខផ្លូវកាយនិងផ្លូវចិត្តដែលមានបច្ច័យមិនមែនតិចជាដើមថា ការជ្រីវជ្រួញនៃអវយវៈតូចធំ ការមានរូបប្រែប្រួលទៅ ព្រោះមានការប្រែប្រួលនៃឥន្ទ្រិយ ភាពជាកំលោះក្រមុំអស់ទៅ សេចក្តីព្យាយាមថយចុះ ការប្រាសចាកសតិនិងការគិត និងការមើលងាយអំពីអ្នកដទៃរមែងកើតឡើង ។ ជរាជាទីតាំងនៃទុក្ខនោះ ។ ព្រោះហេតុនោះទើបលោកពោលទុកថា

> សត្វរមែងដល់នូវទុក្ខផ្លូវកាយនិងទុក្ខផ្លូវចិត្ត ព្រោះអវយវៈ
> យុរយារ ឥន្ទ្រិយទាំងឡាយពិការ ភាពជាកំលោះក្រមុំអស់
> ទៅ ការថមថយកម្លាំង ប្រាសចាកសតិជាដើម កូននិងប្រពន្ធ
> របស់ខ្លួន មិនជ្រះថ្លា ដល់នូវការខ្សោយក្រៃលែងជាលំដាប់
> ទុក្ខទាំងអស់ នេះមានជរាជាហេតុ ដូច្នោះទើបជរាជាទុក្ខ ។

ភ្ជាប់សេចក្តីថា ជរាទុក្ខនេះ រមែងជាប់តាម ។

បទថា **ព្យាធិ** មានវិនិច្ឆ័យថា ឈ្មោះថា ព្យាធិ ព្រោះនាំទុក្ខផ្សេងៗមក ។ ម្យ៉ាងទៀត ឈ្មោះថា **ព្យាធិ** ព្រោះអត្ថថា ឲ្យលំបាក ឲ្យក្តៅក្រហាយ

ឲ្យញាប់ញ័រ ។

ក្នុងបទថា **មរណទុក្ខំ** នេះ ការស្លាប់មាន ២ យ៉ាង គឺលក្ខណៈដែលកាត់តែងដែលលោកពោលសំដៅយកថា ជរា សង្គ្រោះដោយខន្ធ ២ មរណៈសង្គ្រោះដោយខន្ធ ២ ដូច្នេះ ១ ការកាត់ផ្តាច់នៃការទាក់ទងគ្នារបស់ជីវិតិន្ទ្រិយដែលទាក់ទងក្នុងភពឯណានីមួយ ដែលលោកសំដៅយកថា ( សត្វទាំងឡាយដែលកើតហើយ ) តែងមានសេចក្តីភ័យអំពីសេចក្តីស្លាប់ អស់កាលជានិច្ចដូច្នេះ ១ ។ ក្នុងទីនេះបំណងយកមរណៈនោះ សូម្បីពាក្យថា **មរណ** ព្រោះជាតិជាបច្ច័យ គឺមរណៈព្រោះការខ្វល់ខ្វាយរបស់អ្នកដទៃ មរណៈព្រោះអស់អាយុ មរណៈព្រោះអស់បុណ្យ ក៏ជាឈ្មោះរបស់មរណៈនោះឯង គប្បីជ្រាបប្រភេទនេះទៀតថា **ខណិកមរណ សម្មតិមរណ** និង **សមុច្ឆេទមរណ** ។

កាលជីវិតនៅប្រព្រឹត្តទៅ ការបែកធ្លាយនូវរូបធម៌និងនាមធម៌ ឈ្មោះថា **ខណិកមរណ** ។ ពាក្យនេះថា តិស្សៈស្លាប់ ផុស្សៈស្លាប់ ដូច្នេះឈ្មោះថា **សម្មតិមរណ** ព្រោះដោយបរមត្ថសត្វមិនមាន សូម្បីពាក្យនេះថា សន្ទូងស្លាប់ ដើមឈើស្លាប់ ដូច្នេះក៏ឈ្មោះថា **សម្មតិមរណ** ព្រោះមិនមានជីវិតិន្ទ្រិយ ។ កាលកិរិយាដែលមិនមានបដិសន្ធិរបស់ព្រះខីណាស្រព ឈ្មោះថា **សមុច្ឆេទ-មរណ** ។

វៀរសម្មតិមរណៈខាងក្រៅចេញ សម្មតិមរណៈក្រៅអំពីនេះលោកសង្គ្រោះក្នុងទីនេះដោយការកាត់ផ្តាច់នៃការទាក់ទងគ្នាតាមដែលពោលហើយ ។ ឈ្មោះថាជាទុក្ខ ព្រោះជាទីតាំងនៃទុក្ខ ព្រោះហេតុនោះ ទើបលោកពោលថា

ព្រោះការស្លាប់នេះ ដែលអត់ធន់មិនបាន កែខៃមិនបាន ជាទីតាំងនៃទុក្ខផ្លូវចិត្តរបស់បុគ្គលអ្នកជិតស្លាប់ បុគ្គលជាមនុស្សអាក្រក់ដែលតាមឃើញនិមិត្តមានកម្មអាក្រក់ជាដើម បុគ្គលជាមនុស្សល្អ ជាអ្នកអត់ធ្មត់នូវសេចក្តីសោយសោក ដែលមានរបស់ស្រឡាញ់ជាទីតាំងដោយមិនផ្សេងគ្នា សូម្បីទុក្ខកើតក្នុងរាងកាយ មានត្រូវខ្យល់កាត់ទីតនិងសរសៃជាដើមរបស់សត្វទាំងពួងដែលត្រូវចាក់ដោត ( គឺបេះដូងត្រូវចាក់ដោតដោយខ្យល់ ) ដូច្នោះ មរណៈនេះព្រះមានព្រះភាគត្រាស់ថាជាទុក្ខដូចគ្នា ។

ក្នុងបទថា **សោកបរិទេវទុក្ខទោមនស្សុបាយាសទុក្ខំ** នេះ មានវិនិច្ឆ័យដូចតទៅនេះ បណ្តាសេចក្តីសោកជាដើម ការក្តៅក្រហាយចិត្តរបស់បុគ្គលដែលត្រូវសេចក្តីវិនាសនៃញាតិជាដើមពាល់ត្រូវ ដោយលក្ខណៈមានការដុតខាងក្នុង ឈ្មោះថា **សោក** ។ ឯសេចក្តីសោកមានសេចក្តីទុក្ខជាអត្ថ ព្រោះសេចក្តីសោកនោះជាទុក្ខទុក្ខនិងព្រោះជាទីតាំងនៃទុក្ខ ។ ព្រោះហេតុនោះ ទើបលោកពោលថា

សេចក្តីសោក រមែងចាក់ដោតហទយៈរបស់សត្វទាំងឡាយដូចព្រួញលាបថ្នាំពិសនិងរមែងដុតសត្វយ៉ាងខ្លាំងក្លាទៀត ដូចលំពែងដែកដែលភ្លើងឆេះ ព្រោះសេចក្តីសោករមែងនាំមកនូវការទម្លាយ ពោលគឺព្យាធិ ជរានិងមរណៈ និងនាំមកនូវទុក្ខ

មានបែបផ្សេងៗ ដូច្នោះ ទើបសេចក្តីសោកព្រះមានព្រះភាគ
ត្រាស់ថាជាទុក្ខ ។

ការយំរៀបរាប់របស់បុគ្គល ដែលត្រូវសេចក្តីវិនាសនៃញាតិជាដើមពាល់ត្រូវ ឈ្មោះថា **បរិទេវ** ។ បរិទេវៈនោះមានសេចក្តីទុក្ខជាអត្ថ ព្រោះមានទុក្ខក្នុងសង្សារវដ្តនិងព្រោះជាទីតាំងនៃទុក្ខ ព្រោះហេតុនោះ ទើបលោកពោលថា

ព្រោះបុគ្គលត្រូវសរ គឺសេចក្តីសោកមុតហើយ កន្ទក់កន្ទេញ
រមែងដល់នូវទុក្ខដែលអត់ធន់មិនបាន ដែលកើតអំពីរោគស្ងួត
ក ស្ងួតបបូរមាត់ ស្ងួតពិតាន ស្ងួតបំពង់ក ដែលមានប្រមាណ
ក្រៃលែងទើបបរិទេវៈ ព្រះដ៏មានព្រះភាគត្រាស់ថាជាទុក្ខ ។

សេចក្តីទុក្ខផ្លូវកាយ មានលក្ខណៈបៀតបៀនកាយ ឈ្មោះថា **ទុក្ខ** ។ ទុក្ខនោះមានសេចក្តីទុក្ខជាអត្ថ ព្រោះទុក្ខនោះ ជាទុក្ខទុក្ខ គឺព្រោះនាំមកនូវទុក្ខផ្លូវកាយផង នាំមកនូវទុក្ខផ្លូវចិត្តផង ព្រោះហេតុនោះ ទើបលោកពោលថា

ព្រោះទុក្ខផ្លូវកាយនេះរមែងបៀតបៀននិងរមែងឲ្យកើតទុក្ខ
ផ្លូវចិត្តក្រៃលែង ហេតុនោះទើបលោកពោលថា ទុក្ខដោយ
ការផ្សេងគ្នា ។

សេចក្តីទុក្ខផ្លូវចិត្ត មានលក្ខណៈបៀតបៀនចិត្ត ឈ្មោះថា **ទោមនស្ស** ឯទោមនស្សនោះ មានសេចក្តីទុក្ខជាអត្ថ ព្រោះទោមនស្សនោះជាទុក្ខទុក្ខ និងព្រោះនាំមកនូវទុក្ខផ្លូវកាយ ។ ពិតហើយ បុគ្គលដែលដល់ព្រមដោយទុក្ខផ្លូវចិត្ត រមែងរំសាយសក់ គក់ទ្រូង បម្រះនទៀលទៅមក លោតចូលជ្រោះ នាំ

សស្ត្រាមក ផឹកនូវថ្នាំពិស ចងកស្លាប់ លោតចូលភ្លើង រមែងសោយទុក្ខមានប្រការផ្សេងៗ ព្រោះហេតុនោះទើបលោកពោលថា

ព្រោះទោមនស្ស រមែងបៀតបៀនចិត្តនិងនាំមកនូវការបៀតបៀនកាយ ហេតុនោះ ទើបលោកពោលទោមនស្សថា ជាទុក្ខ ។

ការចង្អៀតចង្អល់ ដែលកើតអំពីសេចក្តីទុក្ខផ្លូវចិត្ត ដែលមានប្រមាណក្រៃលែងរបស់បុគ្គលដែលត្រូវសេចក្តីវិនាសនៃញាតិជាដើមពាល់ត្រូវនោះឯង ឈ្មោះថា **ឧបាយាស** អាចារ្យពួកមួយពោលថា ជាធម៌ណាមួយដែលទាក់ទងដោយសង្ខារក្ខន្ធ ឧបាយាសនោះ មានសេចក្តីទុក្ខជាអត្ថ ព្រោះឧបាយាសនោះជាសង្ខារទុក្ខ គឺព្រោះដុតចិត្តនិងព្រោះធ្វើកាយឲ្យវិនាស ព្រោះហេតុនោះទើបលោកពោលថា

ការចង្អៀតចិត្តឲ្យកើតទុក្ខណា ដែលមានប្រមាណក្រៃលែង ព្រោះដុតចិត្តនិងព្រោះធ្វើកាយឲ្យវិនាស ទើបលោកពោលថា ទុក្ខព្រោះទុក្ខនោះ ដូច្នេះ ។

ម្យ៉ាងទៀត ក្នុងបទនេះសេចក្តីសោក គប្បីឃើញដូចការស្ងោរក្នុងភាជនៈដោយភ្លើងតិចៗ បរិទេវៈគប្បីឃើញដូចការផុះចេញអំពីភាជនៈរបស់អាហារដែលដាំដោយភ្លើងក្តៅខ្លាំង ឧបាយាសៈគប្បីឃើញដូចការរម្ងាស់អាហារដែលសល់អំពីផុះចេញ ផុះចេញមិនបានទៀត រម្ងាស់ខាងក្នុងភាជនៈនោះឯងទម្រាំនឹងអស់ ។

បទថា **នេរយិកទុក្ខំ** សេចក្តីថា ទុក្ខក្នុងនរក មានចំណង ៥ ប្រការជាដើមរមែងជាប់តាម ។ ទុក្ខនោះ គប្បីសម្តែងដោយទេវទូតសូត្រ ព្រោះហេតុនោះទើបលោកពោលទុកថា

បើសត្វមិនគប្បីកើតក្នុងនរកទាំងឡាយ គប្បីបានទីតាំងដែលជាទុក្ខ មានត្រូវភ្លើងនរកឆេះជាដើម ដែលអត់ធន់មិនបានក្នុងទីនោះៗអំពីទីណាបាន ព្រោះហេតុនោះ ទើបមុនីក្នុងលោកនេះពោលការកើតថា ជាទុក្ខ ។

បទថា **តិរច្ឆានយោនិកទុក្ខំ** សេចក្តីថា ទុក្ខច្រើនយ៉ាង មានការវាត់ដោយរំពាត់ ចាក់ដោយជន្ទញជាដើមក្នុងពួកតិរច្ឆានរមែងជាប់តាម ។ ទុក្ខនោះគប្បីកាន់យកអំពីពាលបណ្ឌិតសូត្រ ព្រោះហេតុនោះ ទើបលោកពោលទុកថា

ទុក្ខក្នុងតិរច្ឆានទាំងឡាយ កើតអំពីត្រូវពិឃាតដោយរំពាត់ ជន្ទញនិងដំបងជាដើមមិនតិចនោះ វៀរជាតិចេញហើយគប្បីមាន តិរច្ឆាននោះដូចម្តេច ព្រោះហេតុនោះ ការកើតក្នុងតិរច្ឆាននោះជាទុក្ខ ។

បទថា **បិត្តិវិសយិកទុក្ខំ** សេចក្តីថា ទុក្ខដែលកើតអំពីការស្រេកឃ្លានខ្យល់ និងកម្តៅថ្ងៃជាដើមក្នុងប្រេតទាំងឡាយផង ទុក្ខដែលកើតអំពីរងាររហូតអត់ធន់មិនបានក្នុងលោកន្តរៈដែលងងឹតផង រមែងជាប់តាម ព្រោះហេតុនោះទើបលោកពោលទុកថា

ទុក្ខក្នុងប្រេតទាំងឡាយ កើតអំពីសេចក្តីស្រេកឃ្លាន ខ្យល់និង

កម្តៅថ្ងៃជាដើមដោយប្រការច្រើនយ៉ាង មិនមានដល់បុគ្គល ដែលមិនកើតក្នុងប្រេតនោះ ដូច្នោះ ទើបព្រះមហាមុនីត្រាស់ថា ជាតិជាទុក្ខ ។ ទុក្ខក្នុងអសុរៈទាំងឡាយ ក្នុងលោកន្តរៈដែល ងងឹតនិងរងាទ្រាំមិនបាន មិនគប្បីមានក្នុងទីនោះ បើមិនមាន ការកើត ហេតុនោះទើបជាតិជាទុក្ខ ។

បទថា **មានុសិកទុក្ខំ** បានដល់ ទុក្ខមានការសម្លាប់និងការចងជាដើម ក្នុងមនុស្សទាំងឡាយ ។ បទថា **គព្ភោក្កន្តិមូលកទុក្ខំ** បានដល់ ជាតិទុក្ខ ដែលពោលទុកដោយន័យជាដើមថា សេចក្តីពិត សត្វនេះកាលកើត កើតក្នុង ផ្ទៃរបស់មាតា មិនមែនកើតក្នុងផ្កាឧប្បល ផ្កាបទុម ឬផ្កាបុណ្ឌរិកៈជាដើម ឡើយដូច្នេះ ។ ជាដំបូង ទុក្ខមានការកើតក្នុងផ្ទៃជាមូលនេះរមែងជាប់តាម ។

បទថា **គព្ភេ ឋិតិមូលកទុក្ខំ** បានដល់ ទុក្ខដ៏ខ្លាំងក្លា ដែលពោលទុក ដោយន័យជាដើមថា សត្វនោះ ពេលដែលមាតាដួល ដើរ អង្គុយ ក្រោកនិង ប្រែខ្លួនដោយរហ័សជាដើម ។ ទុក្ខមានការតាំងនៅក្នុងផ្ទៃជាមូលនេះ រមែង ជាប់តាមទៅ ។

បទថា **គព្ភាវុដ្ឋានមូលកទុក្ខំ** បានដល់ ទុក្ខដែលពោលទុកដោយន័យ ជាដើមថា ក្នុងទីជាទីកើតនៃទុក្ខនៃសត្វនោះ សូម្បីមិត្តអាមាត្យនិងសម្លាញ់របស់ មាតាដែលវង្វេងគភ៌ជាដើម ក៏មិនគួរឃើញ ។ ទុក្ខមានការចេញចាកផ្ទៃមាតា ជាមូលនេះ រមែងជាប់តាមទៅ ។ ព្រោះហេតុនោះទើបលោកពោលថា

ម្យ៉ាងទៀត សត្វនៅក្នុងផ្ទៃមាតា ដែលដូចជាគូថនរកអស់

កាលយូរនិងចេញចាកផ្ទៃរមែងដល់នូវសេចក្តីទុក្ខដែលគួរខ្លាចក្រៃលែង ទុក្ខនេះវៀរជាតិហើយរមែងមិនមាន ព្រោះហេតុនោះ ទើបជាតិគឺការកើតនេះជាទុក្ខពិត ។ និយាយច្រើន ក៏មិនបានប្រយោជន៍ សូម្បីទុក្ខណាមួយមានក្នុងលោកនេះ ក្នុងទីណាមួយ បើវៀរជាតិហើយ ទុក្ខនេះមិនមាន ព្រោះហេតុនោះ ទើបព្រះមហេសីត្រាស់ជាតិគឺការកើតនេះថា ជាទុក្ខមុនគេបង្អស់ ដូច្នេះ ។

បទថា **ជាតស្ស បណិពន្ធិកទុក្ខំ** សេចក្តីថា ទុក្ខគឺការចិញ្ចឹម មានការផ្ដួតលាប បរិភោគ ផឹកជាដើម ដែលជាប់តាមសត្វដែលកើតហើយ រមែងជាប់តាមទៅ ។

បទថា **ជាតស្ស បរាធេយ្យកទុក្ខំ** សេចក្តីថា ទុក្ខដែលមិនមានឥស្សរៈត្រូវអាស្រ័យអ្នកដទៃ គឺបុគ្គលដទៃរមែងជាប់តាមទៅ មានអធិប្បាយថា ទុក្ខដែលធ្លាក់នូវក្នុងអំណាចរបស់អ្នកដទៃគ្រប់យ៉ាង ។

បទថា **អត្តូបក្កមទុក្ខំ** បានដល់ ទុក្ខដែលមានដល់សត្វអ្នកសម្លាប់ខ្លួនដោយខ្លួននោះឯង ដែលប្រកបសេចក្តីព្យាយាមដោយការទូន្មានខ្លួននិងការដុតកិលេស ដោយការប្រព្រឹត្តវត្តរបស់អាចេលកៈជាដើម ដែលមិនបរិភោគអាហារ និងព្យួរខ្លួនឯងព្រោះសេចក្តីក្រោធ ទុក្ខដែលកើតអំពីការខ្វល់ខ្វាយរបស់ខ្លួននេះ រមែងជាប់តាមទៅ ។

បទថា **បរូបក្កមទុក្ខំ** បានដល់ ទុក្ខដែលកើតឡើងដល់សត្វដែលសោយ

កម្ម មានការសម្លាប់និងការចងជាដើមអំពីអ្នកដទៃ ទុក្ខដែលកើតអំពីសេចក្តីខ្វល់ខ្វាយរបស់អ្នកដទៃនេះ រមែងជាប់តាមទៅ ។

បទថា **ទុក្ខទុក្ខំ** សេចក្តីថា ទុក្ខវេទនាផ្លូវកាយនិងផ្លូវចិត្ត លោកហៅថា ទុក្ខដែលកើតអំពីទុក្ខវេទនា ព្រោះជាទុក្ខដោយសភាវៈនិងដោយឈ្មោះ ទុក្ខដែលកើតអំពីទុក្ខវេទនានេះ រមែងជាប់តាមទៅ ។

បទថា **សង្ខារទុក្ខំ** បានដល់ ឧបេក្ខាវេទនានិងសង្ខារធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដ៏សេសឈ្មោះថា ទុក្ខដែលកើតអំពីសង្ខារ ព្រោះត្រូវការកើតឡើងនិងការវិនាសបៀតបៀន ទុក្ខដែលកើតអំពីសង្ខារនេះ រមែងជាប់តាមទៅ ។

បទថា **វិបរិណាមទុក្ខំ** បានដល់ សុខវេទនា ឈ្មោះថាទុក្ខដែលកើតអំពីការប្រែប្រួល ព្រោះជាហេតុនៃទុក្ខក្នុងកាលប្រែប្រួល ឯទុក្ខទុក្ខដែលកើតអំពីការប្រែប្រួលនេះរមែងជាប់តាមទៅ ។

បទថា **មាតុមរណំ** បានដល់ ការស្លាប់របស់មាតា ។ បទថា **បិតុមរណំ** បានដល់ ការស្លាប់របស់បិតា ។ បទថា **ភាតុមរណំ** បានដល់ ការស្លាប់របស់បងប្រុស ប្អូនប្រុស ។ បទថា **ភគិនីមរណំ** បានដល់ ការស្លាប់របស់បងស្រី ប្អូនស្រី ។ បទថា **បុត្តមរណំ** បានដល់ ការស្លាប់របស់កូនប្រុសទាំងឡាយ ។ បទថា **ធីតុមរណំ** បានដល់ ការស្លាប់របស់កូនស្រីទាំងឡាយ ។

បទថា **ញាតិព្យសនទុក្ខំ** សេចក្តីថា ការវិនាសញាតិទាំងឡាយ ឈ្មោះ

ថា ញាតិព្យសនៈ អធិប្បាយថា ការអស់ទៅនៃញាតិ ការវិនាសទៅនៃញាតិ ដោយចោរភ័យនិងរោគភ័យជាដើម ។ ទុក្ខដែលកើតឡើងដល់សត្វដែលត្រូវសេចក្តីវិនាសនៃញាតិនោះពាល់ត្រូវ គឺលិចលង់គ្របសង្កត់ឈ្មោះថាទុក្ខ ព្រោះការវិនាសនៃញាតិ ទុក្ខព្រោះការវិនាសនៃញាតិនោះ រមែងជាប់តាមទៅ ។ ក្នុងបទដ៏សេសទាំងឡាយ ក៏មានន័យនេះឯង ចំណែកសេចក្តីផ្សេងគ្នា មានដូច្នេះថា

ការវិនាសនៃភោគៈទាំងឡាយ ឈ្មោះថា **ភោគព្យសន** អធិប្បាយថា ការអស់ទៅនៃភោគៈ ការវិនាសទៅនៃភោគៈ ព្រោះរាជភ័យ និងចោរភ័យជាដើម ។ ទុក្ខ គឺការវិនាសនៃភោគៈនោះ ដោយន័យដែលពោលហើយ រមែងជាប់តាមទៅ ។

បទថា **រោគព្យសនំ** សេចក្តីថា ការវិនាស គឺរោគ ឈ្មោះថា រោគ-ព្យសនៈ រោគ ឈ្មោះថាការវិនាស ព្រោះអត្ថថា ញុំាងការមិនមានរោគឲ្យវិនាស គឺឲ្យអន្តរធាន ទុក្ខ គឺការវិនាសដែលកើតអំពីរោគនោះ ដោយន័យដូចពោលហើយរមែងជាប់តាមទៅ ។

បទថា **សីលព្យសនទុក្ខំ** សេចក្តីថា ការវិនាសនៃសីល ឈ្មោះថា សីលព្យសនៈ បទនេះជាឈ្មោះរបស់បុគ្គលអ្នកទ្រុស្តសីល ទុក្ខគឺការវិនាសនៃសីលនោះ ដោយន័យដែលពោលហើយរមែងជាប់តាមទៅ ។

ការវិនាស គឺទិដ្ឋិដែលកើតឡើង ញុំាងសម្មាទិដ្ឋិឲ្យវិនាស ឈ្មោះថា **ទិដ្ឋិ-ព្យសន** ទុក្ខគឺការវិនាសនៃទិដ្ឋិនោះ ដោយន័យដែលពោលហើយ រមែងជាប់តាមទៅ ។

បណ្ដាការវិនាសទាំងនេះ ២ បទដំបូងមិនសម្រេច ( មិនទាន់ពិត ) ៣ បទក្រោយសម្រេច ( វិនាសពិត ) កំណត់ត្រៃលក្ខណ៍បាន ។ ម្យ៉ាងទៀត ៣ បទដំបូងជាកុសលក៏មិនមែន ជាអកុសលក៏មិនមែន ការវិនាសនៃសីល និងទិដ្ឋិទាំងពីរជាអកុសល ។

[ ២៤ ] បទថា **យថា** ចុះក្នុងអត្ថនៃឧបមា ។ បទថា **ភិន្នំ នាវំ** បានដល់ ទូកដែលមានគ្រឿងចងធូររលុង ជាទូកដែលគ្រាំគ្រា ឬមានបន្ទះក្ដារពុកផុយ ។

បទថា **ឩទេសី**[១]បានដល់ ទឹកហូរ គឺជ្រាបចូលទៅ ។ បទថា **តតោ តតោ ឧទកំ អន្វេតិ** សេចក្ដីថា ទឹករមែងចូលទៅត្រង់ទីដែលបែកនោះៗ ។

បទថា **បុរតោបិ** បានដល់ ផ្លូវចំណែកខាងមុខរបស់ទូកក្ដី ។ បទថា **បច្ឆតោបិ** បានដល់ ផ្លូវចំណែកខាងក្រោយរបស់ទូកនោះក្ដី ។

បទថា **ហេដ្ឋតោបិ** បានដល់ ផ្លូវខាងក្រោមនៃទូកក្ដី ។ បទថា **បស្ស-តោបិ** បានដល់ ផ្លូវទាំងសងខាងក្ដី ។ បទណាដែលមិនបានពោលទុកក្នុងចន្លោះៗ បទនោះគប្បីជ្រាបដោយទំនងនៃព្រះបាលី ។

[ ២៥-២៧ ] ព្រោះដូច្នោះ សត្វដែលជាអ្នកមានសតិសព្វកាល ដោយការចម្រើនកាយគតាសតិជាដើម កាលវៀរកិលេសកាម សូម្បីមានប្រការទាំងពួង ក្នុងវត្ថុកាមទាំងឡាយមានរូបជាដើម គប្បីវៀរកាមទាំងឡាយដោយការសង្កត់ទុកនិងដោយការកាត់ផ្ដាច់ លះនូវកាមទាំងឡាយនោះដោយអាការៈ

---

១-បិដកខ្មែរមិនមានបទនេះ ។

យ៉ាងនេះហើយ គប្បីឆ្លង គប្បីអាចនឹងឆ្លងឱឃៈទាំង ៤ ដោយមគ្គជាគ្រឿងធ្វើនូវការលះនូវកាមនោះៗឯង ។ បន្ទាប់អំពីនោះ គប្បីស្ដារទូក គឺអត្តភាពដែលធ្ងន់ដោយទឹក គឺកិលេស គប្បីជាអ្នកដល់នូវត្រើយដោយអត្តភាពស្រាលដូចបុរសស្ដារទូកធ្ងន់ ។ គប្បីជាអ្នកដល់ត្រើយ គប្បីដល់នូវត្រើយដោយទូកស្រាលដោយការលំបាកតិចតួចនោះឯង ជាអ្នកដល់នូវត្រើយនៃធម៌ទាំងពួង គឺព្រះនិព្វាន គប្បីដល់ដោយការសម្រេចអរហត្ត គឺដោយអនុបាទិសេសនិព្វានធាតុព្រះសារីបុត្តត្ថេរបញ្ចប់ទេសនាដោយកាន់យកកំពូល គឺអរហត្តដោយប្រការដូច្នេះ ។

បទថា **តស្មា** សេចក្ដីថា ព្រោះត្រូវទុក្ខមានជាតិជាដើមជាប់តាមបុគ្គលនោះ ដូច្នោះ គឺព្រោះហេតុនោះ ។ បទថា **តំហេតុ** ជាដើម ក៏ន័យនេះឯង ។ គប្បីប្រកបពាក្យយ៉ាងនេះថា ព្រោះទុក្ខមានប្រការដូចពោលហើយ រមែងជាប់តាមបុគ្គលនោះ ហេតុនោះ ព្រោះបច្ច័យណា ទុក្ខរមែងជាប់តាម ព្រោះបច្ច័យនោះ ព្រោះដើមរឿងណា ទុក្ខរមែងជាប់តាម ព្រោះដើមរឿងនោះ ។ បទថា **និទាន** ជាដើម ជាវេវចនៈរបស់បទថា **ការណា** ។ ឯ **ការណា** ឈ្មោះថា **និទាន** ព្រោះអត្ថថា មានផលកើតឡើង គឺប្រព្រឹត្តទៅដោយហេតុនោះ ។

ឈ្មោះថា **បច្ចយ** ព្រោះអត្ថថា ផលអាស្រ័យធម៌នោះកើត គឺប្រព្រឹត្តទៅ ។ ឈ្មោះថា **និទាន** ព្រោះអត្ថថា ប្រគល់ឲ្យនូវផលរបស់ខ្លួន ដូចប្រាប់ថា អញ្ជើញលោកទាំងឡាយកាន់យកវត្ថុនោះចុះ ។

បទថា **តំការណា** បានដល់ បដិសេធធម៌ដែលមិនជាហេតុនិងមិនមាន

ហេតុ ។ បទថា **តំហេតុ** បានដល់ បដិសេធវត្ថុដែលមិនមែនហេតុនិងមាន មហាភូតជាហេតុ ។ បទថា **តប្បច្ចយា** បានដល់បដិសេធបច្ច័យ ដែលមិនទូទៅព្រមគ្នានិងធម៌ដែលមិនមែនជាបច្ច័យ ។ បទថា **តំនិធានា** បានដល់ហាមហេតុក្នុងអាគមនិងនិគម មួយអន្ទើដោយធម៌ដែលមិនមែនហេតុ អាចារ្យពួកមួយពណ៌នាទុកយ៉ាងនេះ ដោយប្រការដូច្នេះ ។

បទថា **ឯតំ អាទីនវំ សម្បស្សមានោ** សេចក្ដីថា មើល គឺឃើញដោយប្រពៃនូវអន្តរាយនោះ ដែលមានប្រការដូចពោលហើយ ដោយវិបស្សនាញាណ ។ បទថា **សទា** ជានិក្ខេបបទ ។ បទថា **សទា** មួយពាក្យទៀតជាពាក្យពង្រីកសេចក្ដី ។ បទថា **សទា** បានដល់ រាល់ថ្ងៃ ។ បទថា **សព្វទា** បានដល់ សព្វកាល ។ បទថា **សព្វកាលំ** បានដល់ អស់កាលទាំងពួងមានពេលព្រឹកជាដើម ។ បទថា **និច្ចកាលំ** បានដល់ រាល់ៗថ្ងៃ ។ បទថា **ធុវកាលំ** បានដល់ អស់កាលមិនដាច់ ។ បទថា **សតតំ** បានដល់ មិនមានចន្លោះ ។ បទថា **សមិតំ** បានដល់ ដូចគ្នាតែមួយ ។ បទថា **អព្វោកិណ្ណំ** បានដល់ មិនលាយឡំដោយរបស់ដទៃ ។ បទថា **ពោង្ខានុពោង្ខំ** សេចក្ដីថា បន្តដោយលំដាប់ ដូចក្នុងប្រយោគជាដើមថា **ពោង្ខានុពោង្ខំ អវិរាធិតំ ឧបដ្ឋាតិ** ( កំពុងបាញ់សរតាមរន្ធចន្លោងដ៏តូចអំពីចម្ងាយ ) ឲ្យចេញទៅតៗគ្នា មិនឲ្យដាច់ឡើយ ដូច្នេះ ។ បទថា **ឧទកុម្មិកជាតំ** បានដល់ ដូចរលកក្នុងទឹកដែលកើតឡើង ។ បទថា **អវីចិ** បានដល់ មិនធូរស្រោល ។ បទថា **សន្តតិ** បានដល់ មិនដាច់រយៈ ។ បទថា **សហិតំ** បានដល់ បន្តជាមួយគ្នា ដូចក្នុង

ប្រយោគជាដើមថា **សហិតំ មេ អសហិតន្តេ** ពាក្យរបស់ខ្ញុំទើបប្រកបដោយប្រយោជន៍ ពាក្យរបស់អ្នកមិនប្រកបដោយប្រយោជន៍ទេ ដូច្នេះ ។ បទថា **ផុសិតំ** បានដល់ ប៉ះជាប់គ្នា ដូចក្នុងប្រយោគជាដើមថា **និវាតេ ផុសិតគ្គលេ** ក្នុងទីដែលខ្យល់ចូលទៅ មិនបានខ្ទាស់នូវគន្លឹះយ៉ាងណែន ដូច្នេះ ។ ពីរបទថា **បុរេភត្តំ បច្ឆាភត្តំ** ពោលចែកកាលក្នុងពេលថ្ងៃ ។ បទ ៣ ថា **បុរិមយាមំ មជ្ឈិមយាមំ បច្ឆិមយាមំ** ពោលចែកពេលវេលាក្នុងពេលយប់ ។ ពីរបទថា **កាឡេ ជុណ្ហេ** ពោលដល់កន្លះខែ ។ បទ ៣ ថា **វស្សេ ហេមន្តេ គិម្ហេ** ពោលដល់រដូវ ។ បទ ៣ ថា **បុរិមេ វយោខន្ធេ មជ្ឈិមេ វយោខន្ធេ បច្ឆិមេ វយោខន្ធេ** លោកពោលបែងចែកវ័យ គប្បីជ្រាបដោយប្រការដូច្នេះ ។

បទផ្ដើមថា **សតោតិ កាយេ កាយានុបស្សនាសតិប្បដ្ឋានំ ភាវេន្តោ តតោ** រហូតដល់បទចុងក្រោយថា **ឯវំ សមុច្ចេនតោ កាមេ បរិវជ្ជេយ្យ** ដូច្នេះ មានអត្ថតាមដែលបានពោលហើយនោះឯង ។ ម្យ៉ាងទៀត បទថា **សតត្តា សតោ**[១] សេចក្ដីថា ឈ្មោះថា **សតត្តា សតោ** ដោយភាពជាបុគ្គលជាប់ចំពាក់ក្នុងវត្ថុ ៣ ឬដោយភាពជាអ្នកអាចឈានកន្លងនូវកិលេស ៣ ។

បទថា **សន្តត្តា** សេចក្ដីថា ឈ្មោះថា **សន្តត្តា** ដោយការញ៉ាំងកិលេសនិងឧបក្កិលេសឲ្យអន្តរធានទៅហើយតាំងនៅ និងព្រោះដោះចាកអារម្មណ៍ហើយស្ងប់ ។ បទថា **សមិតត្តា** សេចក្ដីថា ឈ្មោះថា **សមិតត្តា** ព្រោះជាអ្នកស្ងប់ដោយបុណ្យគួរប្រាថ្នា និងចាកបាបដែលឲ្យផលមិនគួរប្រាថ្នា ។

---

១-បទនេះមានក្នុងលេខឃ្លាប ១៤ ឯបទបន្ទាប់ទៅក៏ដូចគ្នា ។

បទថា **សន្តធម្មសមន្នាគតត្តា** សេចក្តីថា ឈ្មោះថា **សន្តធម្មសមន្នា-គតត្តា** ព្រោះជាអ្នកប្រកបដោយធម៌របស់សប្បុរស ដោយសេពសប្បុរិសធម៌និងសេពគប់ជាមួយព្រះអរិយបុគ្គលមានព្រះពុទ្ធជាដើម ។

[ ២៨ ] បទថា **វត្ថុកាមេ បរិជានិត្វា** សេចក្តីថា ដឹងនូវវត្ថុកាមដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដែលមានប្រការដូចពោលហើយទាំងនោះ ដោយតីរណបរិញ្ញា ។

បទថា **បហាយ** បានដល់ លះកាត់នូវកិលេសកាមដោយបហានបរិញ្ញា ។ បទថា **បជហិត្វា** បានដល់ បោះបង់ហើយ ។ សួរថា បោះបង់ដូចចោលសំរាមដោយល្អីឬ ឆ្លើយថា មិនមែនឡើយ ដែលពិត លះបង់កិលេសកាមនោះ គឺបន្ទោនាំចេញ ។ សួរថា នាំចេញ ដូចនាំចេញនូវគោកៀចដោយជន្ទញ ឬ ឆ្លើយថា មិនមែនដូច្នោះឡើយ ដោយពិត ធ្វើឲ្យអស់នូវកិលេសកាមនោះ គឺធ្វើឲ្យមានទីបំផុតទៅប្រាសហើយ គឺធ្វើកិលេសកាមនោះ ដោយប្រការដោយហោច ក៏មិនមានសេសសល់ត្រឹមតែការទម្លាយដោយកំណត់មានក្នុងទីបំផុត ។ សួរថា ធ្វើកិលេសកាមនោះឲ្យអស់ទៅដោយប្រការនោះបានដូចម្តេច គឺឲ្យដល់នូវការមិនមានក្នុងកាលជាខាងក្រោយ អធិប្បាយថា ធ្វើដោយប្រការដែលកាត់ផ្តាច់កិលេសកាម ដោយសមុច្ឆេទប្បហានដូច្នេះ សូម្បីក្នុងកាមឆន្ទនីវរណៈជាដើម ក៏មានន័យដូច្នេះឯង ។

ក្នុងបទថា **កាមោឃំ** ជាដើម មានវិនិច្ឆ័យដូចតទៅនេះថា តម្រេកដែលប្រព្រឹត្តទៅក្នុងកាមគុណ ៥ លោកហៅថា កាមោឃៈ ព្រោះអត្ថថា លិចចុះ ។

បទថា **ភវោឃំ** បានដល់ ឆន្ទរាគៈ ក្នុងរូបភពនិងអរូបភព និងការជាប់ចិត្តក្នុងឈាន ។

បទថា **ទិដ្ឋោឃំ** បានដល់ ការប្រាថ្នាក្នុងភព ដែលប្រកបដោយសស្សតទិដ្ឋិជាដើមនោះឯងទិដ្ឋោឃៈរមែងដល់នូវការសង្រ្គោះចូលក្នុងភវោឃៈនោះឯង ។ បទថា **អវិជ្ជោឃំ** បានដល់ ការមិនដឹងក្នុងអរិយសច្ច ៤ ។

ក្នុងឱឃៈទាំងនោះ គប្បីជ្រាបថា កាលបុគ្គលត្រេកអរក្នុងកាមគុណទាំងឡាយ កាមោឃៈទាំងដែលមិនទាន់កើត ក៏កើតឡើង និងដែលកើតឡើងហើយក៏ចម្រើនក្រៃលែងឡើង ។

កាលបុគ្គលត្រេកអរក្នុងមហគ្គតធម៌ទាំងឡាយភវោឃៈដែលមិនទាន់កើតក៏កើតឡើង ដែលកើតហើយក៏ចម្រើនក្រៃលែងឡើង ។ អវិជ្ជោឃៈអាស្រ័យកាមោឃៈដែលមិនទាន់កើត ក៏កើតឡើងនិងដែលកើតហើយ ក៏ចម្រើនក្រៃលែងឡើង ដោយភាពជាបទដ្ឋាននៃវិបល្លាស ៤ ក្នុងធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។ ធម៌ចំណែកស គប្បីឲ្យពិស្តារដោយផ្ទុយគ្នា តាមន័យដែលពោលហើយ ។

បុគ្គលបដិបត្តិនូវអប្បណិហិតវិមោក្ខ គប្បីឆ្លងនូវកាមោឃៈបាន ។ អ្នកបដិបត្តិនូវអនិមិត្តវិមោក្ខ គប្បីឆ្លងភវោឃៈបាន ។ បុគ្គលបដិបត្តិសុញ្ញតវិមោក្ខ គប្បីឆ្លងអវិជ្ជោឃៈបាន ។ គប្បីឆ្លងដោយបឋមមគ្គ គប្បីឆ្លងឡើងដោយទុតិយមគ្គ គប្បីឆ្លងកាត់ដោយតតិយមគ្គ គប្បីឈានកន្លងដោយចតុត្ថមគ្គ គប្បីប្រព្រឹត្តកន្លងដោយផលដូច្នេះឯង ។ ម្យ៉ាងទៀត អាចារ្យពួកមួយពណ៌នាយ៉ាង

នេះថា គប្បីចូងដោយកាមោយៈ គប្បីចងឡើងដោយភវោយៈ គប្បីចងកាត់ដោយទិដ្ឋោយៈ គប្បីឈានកន្ទងដោយអវិជ្ជោយៈ គប្បីប្រព្រឹត្តកន្ទងដោយឱយៈទាំងពួង ។

[ ២៩ ] បទថា **គរុកំ** បានដល់ មិនស្រាល ។ បទថា **ភារិកំ** សេចក្តីថា ឈ្មោះថា **ភារិកំ** ព្រោះអត្ថថា មានកណ្ឌៈដែលផ្ទុនក្នុងទូកនោះ ។ បទថា **ឧទកំ សិញ្ចិត្វា** បានដល់ បាចទឹក ។ បទថា **ឱសិញ្ចិត្វា** បានដល់ បាចឲ្យក្រៃលែងឡើង ។ បទថា **ឆឌ្ឌេត្វា** បានដល់ ឲ្យធ្លាក់ទៅ ។ បទថា **លហុ-កាយ** បានដល់ ស្រាលព្រម ។ បទថា **ខិប្បំ** ប្រែថា រួសរាន់ ។ បទថា **លហុំ** បានដល់ ខណៈនោះ ។ បទថា **អប្បកសិរេនេវ** បានដល់ ដោយមិនលំបាក ។ បទថា **ចារំ វុច្ចតិ អមតំ និព្វានំ** សេចក្តីថា ត្រើយនាយអំពីត្រើយអាយនៃសក្កាយទិដ្ឋិ ។ ព្រោះហេតុនោះ និព្វានដែលចេញចាកគ្រឿងរួបរឹត គឺតណ្ហាលោកពោលថាជា **ចារំ** ( ត្រើយ ) ។

បទថា **យោ សោ** បានដល់ នេះ ។ បទទាំងពួង មានបទថា **សព្វ-សង្ខារសមថោ** ជាដើម សំដៅដល់ព្រះនិព្វានទាំងអស់ ។ ក៏ព្រោះការកម្រើកនៃសង្ខារទាំងពួង ការញាប់ញ័រនៃសង្ខារទាំងពួង ការអន្ទះអន្ទែងនៃសង្ខារទាំងពួង រមែងស្ងប់ រមែងរម្ងាប់ព្រោះអាស្រ័យនិព្វាននោះ ព្រោះហេតុនោះ ទើបលោកពោលនិព្វានថា **សព្វសង្ខារសមថោ** ។

ម្យ៉ាងទៀត ព្រោះឧបធិទាំងពួង រមែងជាការលះបង់បាន តណ្ហាទាំងពួងរមែងអស់ទៅ តម្រេកគឺកិលេសទាំងពួងរមែងប្រាសទៅ ទុក្ខទាំងពួងរមែង

វលត់ទៅ ព្រោះអាស្រ័យនិព្វាននោះ ព្រោះហេតុនោះ ទើបលោកពោលនិព្វានថា កិរិយាលះបង់កិលេសទាំងពួង ការអស់តណ្ហា ការប្រាសចាកតម្រេក ការរលត់ ។ តណ្ហានេះលោកហៅថា **វាន** ព្រោះវិគ្គហៈថា រមែងដោតក្រង រមែងដេរភ្ជាប់នូវភពនិងភព កម្មនិងផល ។ ឈ្មោះថា និព្វាន ព្រោះចេញចាកវានៈនោះ ។ បទថា **ឋានំ គច្ឆេយ្យ** គឺគប្បីដល់នូវត្រើយ គឺនិព្វានដោយគោត្រភូញាណ ដែលចេញដោយចំណែកមួយ ដោយអំណាចនៃនិមិត្ត ។ បទថា **អធិគច្ឆេយ្យ** គឺគប្បីដល់ត្រើយ គឺព្រះនិព្វានដោយមគ្គញាណដែលចេញដោយចំណែកពីរ ជាពិសេសដោយការប្រព្រឹត្តទៅនៃនិមិត្ត ។ បទថា **ផុសេយ្យ** គឺគប្បីប៉ះនូវត្រើយគឺព្រះនិព្វាន ដោយផលចិត្តដែលមាននិព្វានជាអារម្មណ៍ ។ បទថា **សច្ឆិករេយ្យ** សេចក្តីថា គប្បីពាល់ត្រូវដោយអំណាចនៃគុណ ហើយធ្វើនូវត្រើយ គឺព្រះនិព្វានឲ្យប្រចក្សដោយបច្ចវេក្ខណញ្ញាណ ម្យ៉ាងទៀត អាចារ្យពួកមួយពណ៌នាថា គប្បីដល់ត្រើយដោយសោតាបត្តិមគ្គ គប្បីបានត្រើយដោយសកទាគាមិមគ្គ គប្បីប៉ះពាល់ត្រើយដោយអនាគាមិមគ្គ គប្បីធ្វើឲ្យជាក់ច្បាស់នូវត្រើយដោយអរហត្តមគ្គ ដូច្នេះ ។

បទថា **យោបិ ឋានំ គន្តុកាមោ** សេចក្តីថា បុគ្គលណាមួយដែលតាំងនៅក្នុងវិបស្សនាញាណ ដែលជាអ្នកប្រាថ្នានឹងដល់នូវត្រើយ គឺព្រះនិព្វាន បុគ្គលនោះនឹងទៅក្នុងនិព្វាននោះដោយពិត ដូច្នោះ ទើបឈ្មោះថា **ឋានគូ** សមដូចព្រះតម្រាស់ត្រាស់ទុកជាដើមថា ខ្ញុំជាបុគ្គលឆ្លងផុតចាកជាតិ ជរា មរណៈ សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្ស ឧបាយាសៈ ដូច្នេះ ។ បុគ្គលនោះ ឈ្មោះ

ថា ជាអ្នកដល់នូវត្រើយ ដោយអំណាចនៃអធ្យាស្រ័យ ក្នុងចំណែកខាងដើម និងដោយប្រកបវិបស្សនា ។

បទថា **យោបិ ចារំ គច្ឆតិ** សេចក្តីថា បុគ្គលណាមានការព្រមព្រៀង ដោយមគ្គ រមែងដល់នូវត្រើយគឺព្រះនិព្វាន បុគ្គលនោះឈ្មោះថាជាអ្នកដល់នូវត្រើយ ។

បទថា **យោបិ ចារំ គតោ** សេចក្តីថា បុគ្គលណាឲ្យសម្រេចកិច្ចដោយមគ្គហើយតាំងនៅក្នុងផល ទៅហើយកាន់ត្រើយគឺព្រះនិព្វាន បុគ្គលនោះ ក៏ឈ្មោះថា ជាអ្នកដល់នូវត្រើយ ។ ដើម្បីសម្តែងសេចក្តីនោះ ដោយព្រះតម្រាស់របស់ព្រះជិនស្រី ទើបព្រះសារីបុត្តត្ថេរពោលពាក្យជាដើមថា សមដូចពាក្យនេះ ដែលព្រះមានព្រះភាគទ្រង់ត្រាស់ថា ព្រាហ្មណ៍ឆ្លងដល់ត្រើយ ឋិតនៅលើគោក ដូច្នេះ ។

បទថា **អភិញ្ញាចារគូ** សេចក្តីថា ឈ្មោះថា **ចារគូ** ព្រោះអត្ថថា ប្រាថ្នានឹងដល់នូវត្រើយ គឺព្រះនិព្វាន រមែងដល់គឺដល់ហើយដោយញាណដែលសម្រេចហើយ គឺញាតបរិញ្ញា ។

បទថា **បរិញ្ញាចារគូ** សេចក្តីថា ឈ្មោះថា **ចារគូ** ដោយន័យដែលពោលហើយ ព្រោះឈានកន្លងនូវធម៌ទាំងពួងដោយតីរណបរិញ្ញា ។

បទថា **បហានចារគូ** សេចក្តីថា ឈ្មោះថា **ចារគូ** ដោយន័យដែលពោលហើយ ព្រោះឈានកន្លងនូវកិលេសទាំងឡាយដែលជាចំណែកសមុទយៈដោយបហានបរិញ្ញា ។ ពិតហើយ បុគ្គលណាកំណត់ដឹងនូវធម៌ទាំងពួង បុគ្គលនោះ

រមែងកំណត់ដឹងដោយបរិញ្ញា ៣ គឺញាតបរិញ្ញា តីរណបរិញ្ញា បហានបរិញ្ញា ។ បណ្តាបរិញ្ញា ៣ នោះ ញាតបរិញ្ញាដូចម្តេច បុគ្គលដឹងនូវធម៌ទាំងពួងថា ធម៌ទាំងនេះមានក្នុងខាងក្នុង ទាំងនេះមានខាងក្រៅ នេះជាលក្ខណៈរបស់ធម៌នេះ នេះជាកិច្ច ជាបច្ចុប្បដ្ឋាន ជាបទដ្ឋានដូច្នេះ នេះឈ្មោះថា **ញាតបរិញ្ញា** ។

តីរណបរិញ្ញាដូចម្តេច បុគ្គលកាលធ្វើនូវការដឹងយ៉ាងនេះហើយពិចារណាធម៌ទាំងពួង ដោយអំណាចតាមដែលប្រព្រឹត្តទៅបាន ដោយន័យជាដើមថាជា អនិច្ចំ ទុក្ខំ អនត្តា ដូច្នេះ ឈ្មោះថា **តីរណបរិញ្ញា** ។

បហានបរិញ្ញាដូចម្តេច បុគ្គលពិចារណាយ៉ាងនេះហើយ លះនូវឆន្ទរាគៈក្នុងធម៌ទាំងពួងដោយមគ្គដ៏ប្រសើរ នេះឈ្មោះថា **បហានបរិញ្ញា** ព្រះសារីបុត្តត្ថេរពោលថា ព្រះអរហន្តនោះដល់នូវត្រើយដោយការដឹងក្រៃលែង ដល់នូវត្រើយ ដោយការប្រព្រឹត្តដឹង ដល់នូវត្រើយដោយការលះ ដូច្នេះ សំដៅយកបរិញ្ញាទាំងនេះ ។

បទថា **ភាវនាបារគូ** សេចក្តីថា បុគ្គលដល់ទីបំផុតហើយ ដល់នូវត្រើយគឺនិព្វានដោយមគ្គដោយការនា ។ បទថា **សច្ឆិកិរិយាបារគូ** សេចក្តីថា ដល់នូវត្រើយគឺផលនិងនិព្វាន ដែលធ្វើឲ្យជាក់ច្បាស់ដោយអំណាចនៃផល និងនិព្វាន ។ បទថា **សមាបត្តិបារគូ** សេចក្តីថា ដល់នូវត្រើយនៃសមាបត្តិ ៨ ។ បទថា **សព្វធម្មានំ** បានដល់ ធម៌ទាំងពួង មានខន្ធ ៥ ជាដើម ។ បទថា **សព្វទុក្ខានំ** បានដល់ ទុក្ខទាំងពួង មានជាតិទុក្ខជាដើម ។ បទថា **សព្វក្កិ-**

**លេសានំ** បានដល់ កិលេសទាំងពួង មានកាយទុច្ចរិតជាដើម ។ បទថា **អរិយ-មគ្គានំ** បានដល់ អរិយមគ្គ ៤ មានសោតាបត្តិមគ្គជាដើម ។ បទថា **និរោ-ធស្ស** បានដល់ និព្វាន ។ បទថា **សព្វសមាបត្តីនំ** បានដល់ រូបសមាបត្តិ និងអរូបសមាបត្តិ ៨ ។ បទថា **សោ** បានដល់ ព្រះអរិយៈនោះ ។ បទថា **វសិប្បត្តោ** បានដល់ ដល់នូវភាពជាអ្នកជំនាញ ម្យ៉ាងទៀត បានដល់ ដល់នូវភាពជាធំ គឺភាពជាអ្នកសម្រេច ។ បទថា **ចារមិប្បត្តោ** បានដល់ ដល់នូវទីបំផុត គឺសេចក្តីសម្រេច គឺភាពឧត្តម ដែលហៅថាបារមី ។ ដើម្បីឆ្លើយនូវពាក្យសួរថា ដល់ក្នុងអ្វី ទើបព្រះសារីបុត្តត្រេរពោលពាក្យជាដើមថា **អរិយ-ស្មឹ សីលស្មឹ** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **អរិយស្មឹ សីលស្មឹ** បានដល់ ក្នុងសីលដែលប្រាសចាកទោស ។ បទថា **អរិយស្មឹ សមាធិស្មឹ** បានដល់ ក្នុងសមាធិដែលប្រាសចាកទោស ។ បទថា **អរិយាយ បញ្ញាយ** បានដល់ ក្នុងបញ្ញាដែលប្រាសចាកទោស ។ បទថា **អរិយាយ វិមុត្តិយា** បានដល់ ក្នុងផលវិមុត្តិដែលប្រាសចាកទោស ។ គប្បីជ្រាបថា សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ លោកកាន់យកដោយបទទីមួយ សម្មាវាយាមៈ សម្មាសតិ សម្មា-សមាធិ លោកកាន់យកដោយបទទី ២ សម្មាសង្កប្បៈនិងសម្មាទិដ្ឋិ លោកកាន់យកដោយបទទី ៣ ។ ធម៌ដ៏សេសដែលសម្បយុត្តដោយអរិយមគ្គនោះ លោកកាន់យកដោយបទទី ៤ ។

បទថា **អន្តគតោ** សេចក្តីថា ទៅកាន់ចំណែកទីបំផុតនៃសង្ខារលោកដោយមគ្គ ។ បទថា **អន្តប្បត្តោ** សេចក្តីថា ដល់ចំណែកទីបំផុតនៃលោក

នោះឯងដោយផល ។ បទថា **កោដិគតោ** សេចក្តីថា ទៅកាន់ទីបំផុតនៃសង្ខារលោកដោយមគ្គ ។ បទថា **កោដិប្បត្តោ** សេចក្តីថា ដល់នូវទីបំផុតនោះឯងដោយផល ។ បទថា **បរិយន្តគតោ** សេចក្តីថា ធ្វើផ្លូវទៅកាន់ការកំណត់ទីបំផុតនៃលោកមានខន្ធលោកនិងអាយតនលោកជាដើមដោយមគ្គ ។ បទថា **បរិយន្តប្បត្តោ** សេចក្តីថា ដល់នូវលោកនេះឯង ធ្វើឲ្យជាទីបំផុតដោយជុំវិញបានដោយផល ។ បទថា **វោសានគតោ** សេចក្តីថា ទៅកាន់ទីបំផុតដោយមគ្គ ។ បទថា **វោសានប្បត្តោ** សេចក្តីថា ដល់នូវទីបំផុតដោយផល ។ បទថា **តាណគតោ** សេចក្តីថា ទៅកាន់ទីជ្រកកោន បានដោយមគ្គ ។ បទថា **តាណប្បត្តោ** សេចក្តីថា ដល់នូវទីជ្រកកោនបានដោយផល ។ បទថា **លេណគតោ** សេចក្តីថា ទៅកាន់ទីពួនសម្ងំបានដោយមគ្គ ។ បទថា **លេណប្បត្តោ** សេចក្តីថា ដល់នូវទីពួនបានដោយផល ។ បទថា **សរណគតោ** សេចក្តីថា ចូលទៅកាន់ទីពឹងបានដោយមគ្គ ។ បទថា **សរណប្បត្តោ** សេចក្តីថា ដល់នូវទីពឹងបានដោយផល ។ បទថា **អភយគតោ** សេចក្តីថា ទៅកាន់ទីមិនមានភ័យបានដោយមគ្គ ។ បទថា **អភយប្បត្តោ** សេចក្តីថា ដល់នូវទីមិនមានភ័យ គឺនិព្វានបានដោយផល ។ បទថា **អច្ចុតិគតោ** សេចក្តីថា ទៅកាន់ទីមិនស្លាប់ គឺនិព្វានបានដោយមគ្គ ។ បទថា **អច្ចុតិប្បត្តោ** សេចក្តីថា ដល់នូវការមិនស្លាប់នោះបានដោយផល ។ បទថា **អមតគតោ** សេចក្តីថា ទៅកាន់ទីមិនស្លាប់ គឺនិព្វានបានដោយមគ្គ ។ បទថា **អមតប្បត្តោ** សេចក្តីថា ដល់នូវទីមិនស្លាប់នោះបានដោយផល ។ បទថា **និព្វានគតោ** សេចក្តី

*ថា ទៅកាន់និព្វានដែលចេញចាកគ្រឿងរួបរឹតគឺតណ្ហា បានដោយមគ្គ ។ បទថា* **និព្វានប្បត្តោ** *សេចក្ដីថា ដល់នូវនិព្វាន នោះឯងបានដោយផល ។ បទថា* **សោ វុដ្ឋវាសោ** *សេចក្ដីថា ព្រះអរហន្តនោះឈ្មោះថានៅចប់ហើយ ព្រោះអត្ថថា នៅហើយ នៅជុំវិញហើយ នៅចប់ហើយក្នុងអរិយវាសធម៌ ១០ ។ បទថា* **ចិណ្ណាចរណោ** *សេចក្ដីថា ឈ្មោះថា* **ចិណ្ណាចរណោ** *ព្រោះអត្ថថា មានការជំនាញ ប្រព្រឹត្តហើយក្នុងសមាបត្តិ ៨ និងសីល ។ បទថា* **គតទ្ធោ** *សេចក្ដីថា ឈានកន្លងនូវផ្លូវឆ្ងាយ គឺសង្សារវដ្ដ ។ បទថា* **គតទិសោ** *សេចក្ដីថា ដល់នូវទិស គឺនិព្វានដែលមិនធ្លាប់ទៅ សូម្បីក្នុងការយល់សប្ដិ ។ បទថា* **គតកោដិកោ** *សេចក្ដីថា ជាអ្នកដល់នូវទីបំផុត គឺអនុបាទិសេសនិព្វានតាំងនៅ ។ បទថា* **បាលិតព្រហ្មចរិយោ** *សេចក្ដីថា មានព្រហ្មចរិយៈដែលរក្សាហើយ ។ បទថា* **ឧត្តមទិដ្ឋិប្បត្តោ** *សេចក្ដីថា ដល់នូវសម្មាទិដ្ឋិឧត្ដម ។ បទថា* **បដិវិទ្ធាកុប្បោ** *សេចក្ដីថា ចាក់ធ្លុះនូវអរហត្តផលមិនកម្រើក មិនញាប់ញ័រតាំងនៅហើយ ។ បទថា* **សច្ឆិកតនិរោធោ** *សេចក្ដីថា ធ្វើឲ្យជាក់ច្បាស់នូវនិរោធ គឺនិព្វានតាំងនៅហើយ ។*

*បទថា* **ទុក្ខំ តស្ស បរិញ្ញាតំ** *សេចក្ដីថា ទុក្ខ ៣ យ៉ាងដែលព្រះអរហន្តឈានកន្លង កាត់ផ្ដាច់ហើយ ។ បទថា* **អភិញ្ញេយ្យំ** *សេចក្ដីថា គប្បីដឹងដោយអាការៈដ៏ល្អ ដោយអំណាចនៃការឈមចុះកាន់សភាវលក្ខណៈ ។ បទថា* **អភិញ្ញាតំ** *សេចក្ដីថា ដឹងហើយដោយញាណដ៏ក្រៃលែង ។ បទថា* **បរិញ្ញេយ្យំ** *សេចក្ដីថា គប្បីកំណត់ដឹងដោយអំណាចនៃការឈមចុះកាន់សាមញ្ញលក្ខណៈ*

និងដោយអំណាចនៃភាពជាអ្នកមានកិច្ចដល់ព្រម ។ បទថា **បរិញ្ញាតំ** សេចក្តីថា ដឹងហើយដោយជុំវិញ ។ បទថា **ភាវេតព្វំ** បានដល់ គប្បីឲ្យចម្រើន ។ បទថា **សច្ឆិកាតព្វំ** បានដល់ គប្បីធ្វើឲ្យប្រចក្ស គឺធ្វើឲ្យជាក់ច្បាស់ ។ ឯការធ្វើឲ្យជាក់ច្បាស់មានពីរយ៉ាងគឺ ការធ្វើឲ្យជាក់ច្បាស់ដោយការបានចំពោះ និងការធ្វើឲ្យជាក់ច្បាស់នូវអារម្មណ៍ ។

ក្នុងបទថា **ឧក្ខិត្តបលិឃោ** នេះ មានវិនិច្ឆ័យដូចតទៅនេះថា បទថា **បលិឃោ** បានដល់ អវិជ្ជាដែលជាឫសគល់នៃវដ្ដៈ អវិជ្ជានេះលោកហៅថា សសរគោល ដោយអត្ថថា ដកបានលំបាក ។ ដោយហេតុនោះ លោកហៅព្រះអរហន្តថា ជាអ្នកមានអវិជ្ជាជាសសរគោលដកចេញហើយ ព្រោះអវិជ្ជានោះ ព្រះអរហន្តដកបានហើយ ។

ដែលហៅថា **បរិខា** ក្នុងបទថា **សង្កិណ្ណបរិខោ** បានដល់ អភិសង្ខារ គឺកម្មដែលឲ្យកពព្ភ គឺជាបច្ច័យនៃខន្ធទាំងឡាយ ក្នុងភពថ្មីដែលបាននាមថា ជាតិសង្សារ ដោយអំណាចឲ្យកើតក្នុងភពទាំងឡាយនិងដោយអំណាចនៃការអន្ទោលទៅ ។ អភិសង្ខារគឺកម្មនោះ លោកហៅថា **បរិខា** ព្រោះព័ទ្ធជុំវិញដោយអំណាចធ្វើនូវការកើតឡើងរឿយៗ លោកហៅព្រះអរហន្តថា ជាអ្នកមានកម្មដូចគូទឹកកម្ចាត់ហើយ ព្រោះកម្មដែលជាគូទឹកនោះ ដែលព្រះអរហន្តកម្ចាត់ចេញហើយ គឺខ្ទាក់ចោលហើយ ។ បទថា **ឯសិកា** ក្នុងបទថា **អព្ពូឡ្ហេសិកោ** បានដល់ តណ្ហាដែលជាមូលនៃវដ្ដៈ ព្រោះតណ្ហានេះជ្រាលជ្រៅ ដែលលោកហៅថា សសរខឿន ព្រោះអត្ថថា ធ្ងន់ទៅបានលំបាក ដោយហេតុនោះ លោក

ហៅព្រះអរហន្តថា ជាអ្នកមានតណ្ហាជាសសរខឿនដែលដកហើយ ព្រោះតណ្ហានោះ ព្រះអរហន្តនោះដកបានហើយ គឺដកចោលបានហើយ ។

បទថា **អគ្គឡោ** ក្នុងបទថា **ឆិរគ្គឡោ** បានដល់ សំយោជនៈដែលឲ្យកើតកិលេសយ៉ាងគ្រោតគ្រាត គឺឱរម្ភាគិយសំយោជនៈ ដែលជាបច្ច័យឲ្យកើតក្នុងកាមភព សំយោជនៈទាំងនេះ លោកហៅថា គន្ទឹះទ្វារ ព្រោះរាំងចិត្តដូចសន្ទះទ្វារធំដែលប្រើជាទ្វារនគរដូច្នោះ ដោយហេតុនោះ លោកហៅព្រះអរហន្តថា ជាអ្នកមិនមានសំយោជនៈជាសន្ទះទ្វារ ព្រោះមិនមានសំយោជនៈជាសន្ទះទ្វារ គឺសំយោជនៈទាំងនោះ ដែលព្រះអរហន្តទម្លាយបានហើយ ។

បទថា **អរិយោ** បានដល់ មិនមានកិលេស គឺបរិសុទ្ធិ ។ បទថា **បន្នទ្ធជោ** បានដល់ មានទង់ គឺមានះដាក់ចុះហើយ ។

បទថា **បន្នភារោ** បានដល់ ឈ្មោះថាមានភារៈដាក់ចុះហើយ ព្រោះអត្ថថា ភារៈគឺខន្ធ ភារៈគឺកិលេស ភារៈគឺអភិសង្ខារ ភារៈគឺកាមគុណ ៥ ដែលព្រះអរហន្តដាក់ហើយ គឺដាក់ចុះហើយ ។ មួយវិញទៀត ក្នុងទីនេះលោកបំណងថា មានមានះដាក់ចុះហើយ ព្រោះភារៈ គឺមានះនោះឯងព្រះអរហន្តដាក់ចុះហើយ ។

បទថា **វិសំយុត្តោ** សេចក្តីថា មិនទាក់ទងដោយយោគៈ ៤ និងកិលេសទាំងពួង តែក្នុងទីនេះលោកបំណងថា ឈ្មោះថាមិនទាក់ទង ព្រោះមិនជាប់ជំពាក់ដោយកិលេសជាគ្រឿងជាប់ជំពាក់ គឺមានះនោះឯង ។

ដោយពាក្យមានប្រមាណប៉ុណ្ណេះ ព្រះសារីបុត្តត្ថេរសម្តែងកាលដែលឲ្យ

កិលេសទាំងឡាយអស់ទៅដោយមគ្គ ហើយចុះស៊ប់ក្នុងផលសមាបត្តិ ដែលមាននិព្វានជាអារម្មណ៍របស់ព្រះទីណាស្រេព ដែលជាអ្នកសម្រេចនិរោធ ដែលជាវិហារធម៌ដ៏ប្រសើរ ដូចនគរពីរ គឺចោរនគរ ១ ខេមនគរ ១ កាលណោះនាយទាហានធំម្នាក់ កើតនូវការប្រាថ្នាឡើងថា ចោរនគរនេះតាំងនៅដរាបណា ខេមនគររមែងមិនផុតភ័យដរាបនោះ អញនឹងធ្វើនគរចោរ ឲ្យមិនជានគរ ទាហាននោះពាក់គ្រោះ កាន់ដាវចូលទៅកាន់នគរចោរ យកដាវកាប់នូវសសរខឿនដែលគេដាំទុកត្រង់ទ្វារនគរ ទម្លាយសន្ទះទ្វារនិងសន្ទះបង្អួចដកនូវសសរគោល ទម្លាយកំពែង លុបនូវគូទឹក យកទង់ ដែលលើកឡើងដើម្បីលម្អរបស់នគរហើយដាក់ចុះ យកភ្លើងដុតនគរ ហើយវិលចូលខេមនគរ ឡើងលើប្រាសាទ ចោមរោមដោយពួកញាតិ បរិភោគភោជនាហារដែលមានរសឆ្ងាញ់ យ៉ាងណា ឧបមេយ្យនេះក៏ដូច្នោះ សក្កាយទិដ្ឋិដូចចោរនគរ និព្វានដូចខេមនគរ ព្រះយោគាវចរដូចទាហានធំ ព្រះយោគាវចរនោះ មានការគិតយ៉ាងនេះថា ចំណង គឺសក្កាយទិដ្ឋិនៅចងដរាបណា ការរួចផុតចាកកម្មករណ: ៣២ រោគ ៩៨ និងចាកមហាភ័យ ២៥ រមែងមិនមាន ។ ព្រះយោគាវចរនោះដូចជានាយទាហានធំ ពាក់នូវគ្រោះគឺសីល កាន់នូវដាវគឺបញ្ញា កាប់នូវសសរខឿនគឺតណ្ហាដោយអរហត្តមគ្គ ដូចកាត់សសរខឿនដោយដាវ ដកគន្លឹះគឺសំយោជន: ដែលប្រព្រឹត្តទៅក្នុងចំណែកខាងក្រោម ៥ ដូចនាយទាហាននោះ ទម្លាយបង្អួចនគរ ព្រមទាំងសន្ទះទ្វារ ដកនូវសសរគោលគឺអវិជ្ជា ដូចទាហាននោះដកសសរគោល ទម្លាយនូវអភិសង្ខារគឺកម្ម លុបនូវគូទឹកគឺជាតិសង្សារ ដូច

នាយទាហានទម្លាយកំពែង គូទឹក យកទង់គឺមានះដាក់ចុះហើយ ដុតព្រះនគរ គឺសក្កាយទិដ្ឋិ ដូចនាយទាហាននោះ យកទង់ដែលលើកឡើងដើម្បីលម្អនគរដាក់ចុះ ចូលកាន់និព្វាននគរដោយសុខដែលកើតអំពីផលសមាបត្តិ ដែលមានអមតនិរោធជាអារម្មណ៍ ញ៉ាំងកាលឲ្យកន្លងទៅ ដូចនាយទាហាននោះចូលកាន់ខេមនគរ បរិភោគភោជនាហារដែលមានរសឆ្ងាញ់លើប្រាសាទដូច្នោះ ។

សមដូចព្រះតម្រាស់ ដែលព្រះដ៏មានព្រះភាគត្រាស់ទុក ( ក្នុងអង្គុត្តរនិកាយបញ្ចកនិបាត ) ថា

ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុដែលហៅថា លើកឡើងនូវជើងគុល គឺអវិជ្ជាតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានលះបង់នូវអវិជ្ជាចោលចេញហើយ បានគាស់រម្លើងឫសគល់អស់ហើយ បានធ្វើឲ្យនៅសល់តែទីនៅដូចជាទីនៅនៃដើមត្នោត បានធ្វើមិនឲ្យមានបែបភាពជាសភាវៈមិនកើតឡើងតទៅទៀត ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកលើកឡើងនូវជើងគុលគឺអវិជ្ជាយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយចុះភិក្ខុជាអ្នកបំផ្លិចបំផ្លាញនូវគូ គឺសង្សារវដ្តតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះបានលះបង់នូវជាតិនិងសង្សារ ដែលសម្រាប់តាក់តែងនូវភពថ្មីទៀត ចោលចេញហើយ ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបំផ្លិចបំផ្លាញនូវគូ គឺសង្សារវដ្តយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំង

ឡាយ ចុះភិក្ខុជាអ្នកដកឡើងនូវសសរគឺតណ្ហា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានលះបង់តណ្ហា ចោលចេញអស់ហើយ ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកដកឡើងនូវសសរ គឺតណ្ហាយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកបើកនូវសន្ទះទ្វារ គឺនីវរណៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនេះ បានលះបង់នូវសំយោជនៈ ដែលជាចំណែកខាងក្រោម ៥ ចោលចេញហើយ ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបើកនូវសន្ទះទ្វារគឺនីវរណៈយ៉ាងនេះឯង ។

ម្នាលភិក្ខុទាំងឡាយ ពួកទេវតាព្រមទាំងព្រះឥន្ទ ព្រះព្រហ្មនិងបជាបតិទេវរាជ នាំគ្នាតាមស្វែងរកភិក្ខុ ដែលមានចិត្តរួចស្រឡះយ៉ាងនេះ ក៏មិនបានប្រទះថា វិញ្ញាណរបស់សត្វអាស្រ័យហើយនូវអារម្មណ៍នេះ ដូច្នេះ ។

បទថា **បញ្ចង្គវិប្បហីនោ** សេចក្តីថា លះនូវអង្គ ៥ មានកាមច្ឆន្ទៈជាដើម ដោយឧបាយមានប្រការផ្សេងៗ ហើយតាំងនៅ សមដូចព្រះតម្រាស់ដែលត្រាស់ទុក ( ក្នុងទីឃនិកាយបាដិកវគ្គ ) ថា

ម្នាលអាវុសោទាំងឡាយ ឯភិក្ខុមានអង្គ ៥ លះបង់ហើយ តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកលះបង់កាមច្ឆន្ទៈ ១ លះបង់ព្យាបាទ ១ លះបង់

ថីនមិទ្ធៈ ១ លះបង់ឧទ្ធច្ចកុក្កុច្ចៈ ១ លះបង់វិចិកិច្ឆា ១ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានអង្គ ៥ លះបង់ហើយ ដោយអាការយ៉ាងនេះឯង ដូច្នេះ ។

បទថា **ឆឡង្គសមន្នាគតោ** សេចក្តីថា លោកពោលថា ប្រកបដោយអង្គ ៦ ព្រោះលះអនុស័យ គឺបដិឃៈក្នុងអារម្មណ៍ មានរូបជាដើមក្នុងទ្វារ ៦ ជាអ្នកមានសតិសម្បជញ្ញៈ ដោយអំណាចនៃឧបេក្ខា ធ្វើអង្គ ៦ ឲ្យពេញបរិបូរតាំងនៅហើយដោយអំណាចនៃការនៅ សមដូចព្រះតម្រាស់ដែលត្រាស់ទុក ( ក្នុងទីឃនិកាយបាដិកវគ្គ ) ថា

ម្នាលអាវុសោទាំងឡាយ ភិក្ខុប្រកបដោយឆឡង្គុបេក្ខា តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ឃើញរូបដោយចក្ខុ ក៏មិនសោមនស្ស មិនទោមនស្ស ជាបុគ្គលព្រងើយកន្តើយ មានសតិនិងសម្បជញ្ញៈ ។ ឮសំឡេងដោយត្រចៀក ។ ធុំក្លិនដោយច្រមុះ ។ ទទួលរសដោយអណ្តាត ។ ពាល់ត្រូវផោដ្ឋព្វៈដោយកាយ ។ ដឹងធម្មារម្មណ៍ដោយចិត្ត ក៏មិនសោមនស្ស មិនទោមនស្ស ជាបុគ្គលព្រងើយកន្តើយ មានសតិនិងសម្បជញ្ញៈ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុប្រកបដោយឆឡង្គុបេក្ខា ដោយអាការយ៉ាងនេះឯង ដូច្នេះ ។

បទថា **ឯការក្ខោ** សេចក្តីថា ឈ្មោះថា **ឯការក្ខោ** ព្រោះអត្ថថា មាន

ការរក្សាយ៉ាងឯក គឺឧត្តមដោយធម៌ជាគ្រឿងរក្សាគឺសតិ សមដូចព្រះតម្រាស់ដែលត្រាស់ទុក ( ក្នុងទីឃនិកាយបាដិកវគ្គ ) ថា

ម្នាលអាវុសោទាំងឡាយ ភិក្ខុមានកិរិយារក្សាធម៌តែមួយ តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ប្រកបដោយចិត្ត មានសតិជាគ្រឿងរក្សាទុក ម្នាលអាវុសោទាំងឡាយ ភិក្ខុមានកិរិយារក្សាធម៌តែមួយ ដោយអាការយ៉ាងនេះឯង ដូច្នេះ ។

បទថា **ចតុរាបស្សេនោ** សេចក្តីថា ជាអ្នកមានធម៌ជាគ្រឿងអាស្រ័យ ៤ ដោយអំណាចនៃធម៌ជាគ្រឿងអាស្រ័យ ៤ យ៉ាង គឺការសេពចំពោះ ១ ការវៀរ ១ ការបន្ទោបង់ ១ ការលះ ១ ដោយបញ្ញាដែលមិនប្រព្រឹត្តទៅក្នុងទីផ្សេងៗ គឺសម្រេចធម៌ទាំងនោះតាំងនៅ សមដូចព្រះតម្រាស់ដែលត្រាស់ទុក ( ក្នុងទីឃនិកាយបាដិកវគ្គ ) ថា គប្បីឲ្យពិស្តារដោយន័យជាដើមថា

ម្នាលអាវុសោទាំងឡាយ ភិក្ខុមានធម៌ជាគ្រឿងពឹងផ្អែក ៤ យ៉ាងតើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាហើយទើបសេពវត្ថុដែលគួរសេព ១ ពិចារណាហើយ ទើបអត់សង្កត់វត្ថុដែលគួរអត់សង្កត់ ១ ពិចារណាហើយ ទើបវៀរវត្ថុដែលគួរវៀរ ១ ពិចារណាហើយទើបបន្ទោបង់វត្ថុដែលគួរបន្ទោបង់ ១ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានធម៌ជាគ្រឿងពឹងផ្អែក ៤ យ៉ាង ដោយអាការយ៉ាង

នេះឯង ដូច្នេះ ។

បទថា **បន្នព្ភារបច្ចេកសច្ចោ** សេចក្តីថា ឈ្មោះថា **បន្នព្ភារបច្ចេកសច្ចោ** ព្រោះអត្ថថា ទិដ្ឋិសច្ចៈដែលរាប់ថាដោយចំពោះ ព្រោះកាន់យកចំពោះតែម្យ៉ាង យ៉ាងនេះថា ទស្សនៈនេះប៉ុណ្ណោះពិត ទស្សនៈនេះប៉ុណ្ណោះ ពិតដូច្នេះ ដែលព្រះអរហន្តទាំងឡាយបន្ទោបង់ហើយ គឺនាំចេញហើយ លះហើយ ។

ក្នុងបទថា **សមវយសដ្ឋេសនោ** បទថា **អវយ** បានដល់ មិនខ្វះខាត ។ បទថា **សដ្ឋ** បានដល់ លះបង់ហើយ ។ ឈ្មោះថា **សមវយសដ្ឋេសនោ** ព្រោះអត្ថថា មានការស្វែងរកដែលលះបង់ហើយដោយប្រពៃ មិនខ្វះខាត អធិប្បាយថា មានការស្វែងរកទាំងពួង ដែលលះបង់ហើយដោយប្រពៃ ។

បទថា **អនាវិលោ** បានដល់ ជាអ្នកបរិបូណ៌ ។ បទថា **វុសិតវា** បានដល់ ជាអ្នកមានព្រហ្មចរិយៈនៅចប់ហើយ គឺជាអ្នកនៅចប់ក្នុងអរិយមគ្គ ដែលជាគ្រឿងនៅដ៏សមគួរ ដោយយោគៈខ្វះក្នុងអរិយវាសធម៌ ១០ យ៉ាងខ្វះ ។

បទថា **ឧត្តមបុរិសោ** បានដល់ ជាបុរសវិសេស គឺបុរសអាជានេយ្យ ព្រោះមានកិលេសអស់ហើយ ។ បទថា **បរមបុរិសោ** បានដល់ ជាបុរសដ៏ឧត្តម គឺជាអ្នកដល់នូវការសម្រេចបរមត្ថ ព្រោះដល់នូវការបានចំពោះនូវប្រយោជន៍យ៉ាងក្រៃលែង គឺដល់នូវការបានចំពោះនូវព្រះអរហត្តដ៏ឧត្តមដែលគប្បីដល់ ជាបុញ្ញខេត្តដ៏កំពូល ទើបឈ្មោះថាជាបុរសឧត្តម ជាបរមបុរសដោយអត្ថនេះឯង គឺជាអ្នកដល់នូវការសម្រេចបរមត្ថ ព្រោះជាអ្នកដល់នូវការបានចំពោះនូវអមតៈ ដើម្បីចូលសមាបត្តិដ៏កំពូល ។

ម្យ៉ាងទៀត អាចារ្យពួកមួយពណ៌នាយ៉ាងនេះថា ជាឧត្តមបុរសដោយអំណាចដីងល្អដល់ទោសក្នុងការគ្រប់គ្រងផ្ទះហើយ ទើបចូលកាន់សាសនាជាបរមបុរស ដោយអំណាចដីងល្អដល់ទោសក្នុងអត្តភាពហើយ ទើបចូលកាន់វិបស្សនា ជាអ្នកដីងល្អដល់ទោសក្នុងកិលេសហើយចូលកាន់អរិយភូមិ ទើបជាអ្នកដល់នូវការសម្រេចបរមត្ថ ។

បទថា **នេវ អាចិនាតិ** សេចក្តីថា មិនបន្ថែមវិបាកនៃកុសលនិងអកុសលទាំងនោះ ព្រោះលះកុសលនិងអកុសលបានហើយ ។ បទថា **ន អបចិនាតិ** សេចក្តីថា មិនបានកម្ចាត់ ព្រោះតាំងនៅក្នុងផលហើយ ។ បទថា **អបចិនិត្វា ឋិតោ** សេចក្តីថា ញុំាងតំណក់នៃកិលេសទាំងឡាយឲ្យវិងស្ងួតហើយតាំងនៅ ព្រោះតាំងនៅក្នុងការលះដោយស្ងប់រម្ងាប់ ។ ខាងមុខអំពីនេះ គប្បីប្រកបដោយអំណាចនៃមគ្គនិងផលនោះឯង ជាមួយពាក្យ ៣ ពាក្យ ។

អាចារ្យពួកមួយពណ៌នាយ៉ាងនេះថា បទថា **នេវ បជហាតិ** សេចក្តីថា មិនបានលះកិលេសទាំងឡាយ ព្រោះមិនមានកិលេសដែលត្រូវលះ ។

បទថា **ន ឧបាទិយតិ** សេចក្តីថា មិនបានកាន់យកដោយតណ្ហា មានះ ទិដ្ឋិទាំងនោះ ព្រោះមិនមានវត្ថុដែលគប្បីកាន់យកដោយតណ្ហា មានះនិងទិដ្ឋិ ។

បទថា **បជហិត្វា ឋិតោ** សេចក្តីថា លះហើយ ទើបតាំងនៅ ។ បទថា **នេវ វិសិនេតិ** សេចក្តីថា មិនបានដេរភ្ជាប់ ( ដោតក្រង ) ដោយអំណាចនៃតណ្ហា ។ បទថា **ន ឧស្សិនេតិ** សេចក្តីថា មិនបានលើកឡើង ដោយអំណាចនៃមានះ ។ បទថា **វិសិនេត្វា ឋិតោ** សេចក្តីថា មិនបានធ្វើនូវការ

*ដេរក្លាប់ដោយតណ្ហាហើយតាំងនៅ ។ បទថា* **នេវ វិធុបេតិ** *សេចក្តីថា មិនបានឲ្យក្លើងគឺកិលេសរលត់ ។ បទថា* **ន សន្ធុបេតិ** *សេចក្តីថា មិនបានឲ្យក្លើងគឺកិលេសឆេះ ។ បទថា* **វិធុបេត្វា ឋិតោ** *សេចក្តីថា ឲ្យរលត់ហើយតាំងនៅ ។ បទថា* **អសេក្ខេន សីលក្ខន្ធេន** *សេចក្តីថា តាំងនៅ គឺតាំងនៅដោយភាពជាបុគ្គលមិនសាបសូន្យ ព្រោះជាអ្នកប្រកបដោយសីលក្ខន្ធ គឺសម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ គឺដោយគំនរនៃសីលដែលជាអសេក្ខៈ ព្រោះមិនមានបទដែលត្រូវសិក្សា ។*

*បទថា* **សមាធិក្ខន្ធេន** *បានដល់ ដោយសមាធិដែលសម្បយុត្តដោយសម្មាវាយាមៈនិងសម្មាសតិ ។*

*បទថា* **វិមុត្តិក្ខន្ធេន** *បានដល់ ដោយខន្ធដែលសម្បយុត្តដោយផលវិមុត្តិ ។ បទថា* **វិមុត្តិញ្ញាណទស្សនក្ខន្ធេន** *បានដល់ ដោយបច្ចវេក្ខណញ្ញាណ ។ បទថា* **សច្ចំ បដិចានយិត្វា** *សេចក្តីថា ញ៉ាំងអរិយសច្ចៈ ៤ ឲ្យដល់ព្រមក្នុងរបស់ខ្លួន ដោយអំណាចនៃសភាវៈ គឺចាក់ធ្លុះហើយតាំងនៅ ។ បទថា* **ឯវំ សមតិក្កមិត្វា** *បានដល់ ឈានកន្លងតណ្ហាដែលជាគ្រឿងញាប់ញ័រ ។ បទថា* **កិលេសគ្គឹ** *បានដល់ ភ្លើង គឺកិលេសមានរាគៈជាដើម ។ បទថា* **បរិយាទយិត្វា** *បានដល់ ឲ្យអស់ហើយ គឺឲ្យរលត់ហើយ ។ បទថា* **អបរិគមនតាយ** *បានដល់ ដោយការមិនទៅក្នុងសង្សារវដ្ត អធិប្បាយថា មិនមានការត្រឡប់មកទៀត ។ បទថា* **ក្លដំ សមាទាយ** *បានដល់ កាន់យកហើយនូវការកាន់យកការឈ្នះ ។ បទថា* **មុត្តិប្បដិសេវនតាយ** *បានដល់*

ដោយការៈដែលផុតចាកកិលេសទាំងពួង សេពនូវអារម្មណ៍មានរូបជាដើម ម្យ៉ាងទៀត ដោយអំណាចសេពនូវផលសមាបត្តិ ដែលផុតចាកកិលេសទាំងពួង ។

បទថា **មេត្តាយ ចារិសុទ្ធិយា** បានដល់ តាំងនៅដោយមេត្តា ដែលតាំងនៅក្នុងសេចក្តីបរិសុទ្ធ ព្រោះផុតចាកឧបក្កិលេស សូម្បីក្នុងករុណាជាដើម ក៏ន័យនេះឯង ។

បទថា **អច្ចន្តចារិសុទ្ធិយា** បានដល់ សម្រេចដល់ទីបំផុតនៃសេចក្តីបរិសុទ្ធ ហើយតាំងនៅដោយភាពជាបុគ្គលឈានកន្លងហើយបរិសុទ្ធ ។

បទថា **អតម្មយតាយ** មានវិនិច្ឆ័យថា តណ្ហា ទិដ្ឋិ មានះ លោកហៅ **តម្មយា** ការមិនមាននៃតណ្ហា ទិដ្ឋិ មានះទាំងនោះ ឈ្មោះថា **អតម្មយតា** ។ តាំងនៅដោយការវៀរចាកតណ្ហា មានះ ទិដ្ឋិនោះ ។ សមដូចពាក្យដែលលោកពោលទុក ( ក្នុងអង្គុត្តរនិកាយតិកនិបាត ) ថា

បុគ្គលបែបនោះ ជាអ្នកជ្រាបច្បាស់នូវលោក មានប្រាជ្ញា
ល្អ ជាអ្នកប្រាជ្ញ មិនមានចំណង់ក្នុងធម៌ទាំងអស់ ដូច្នេះ ។

ជាអ្នកវៀរចាកតណ្ហា មានះ និងទិដ្ឋិនោះឯង ។

បទថា **វិមុត្តត្តា** បានដល់ ដោយភាពជាអ្នកផុតចាកកិលេសទាំងពួង ។ បទថា **សន្តុសិតត្តា** សេចក្តីថា តាំងនៅដោយភាពជាអ្នកសន្តោស ដោយអំណាចយថាលាភសន្តោស យថាពលសន្តោស យថាសារុប្បសន្តោស ។

បទថា **ខន្ធបរិយន្តេ** សេចក្តីថា ផុតនូវខន្ធ ១ ខន្ធ ៤ និងខន្ធ ៥ ដោយ

ភ្លើង គឺបរិញ្ញា ៣ ហើយតាំងនៅក្នុងចំណែកបំផុត គឺទីបំផុត សូម្បីក្នុងចំណែកទីបំផុតជុំវិញនៃធាតុជាដើម ក៏ន័យនេះឯង ចំណែកការផ្សេងគ្នាមានដូច្នេះថា បទថា **ធាតុបរិយន្តេ** បានដល់ ក្នុងចំណែកទីបំផុតជុំវិញនៃធាតុ ១៨ ។ បទថា **អាយតនបរិយន្តេ** បានដល់ អាយតនៈ ១២ ។ បទថា **គតិបរិយន្តេ** បានដល់ គតិ ៥ មាននរកជាដើម ។ បទថា **ឧបបត្តិបរិយន្តេ** បានដល់ ក្នុងការកើតក្នុងសុគតិនិងទុគ្គតិ ។ បទថា **បដិសន្ធិបរិយន្តេ** បានដល់ ក្នុងបដិសន្ធិក្នុងកាមភព រូបភពនិងអរូបភព ។ បទថា **ភវបរិយន្តេ** បានដល់ ឯកវោការភព ចតុវោការភព បញ្ចវោការភព សញ្ញាភព នេវសញ្ញានាសញ្ញាភព កាមភព រូបភពនិងអរូបភព ។ បទថា **សំសារបរិយន្តេ** បានដល់ ក្នុងការប្រព្រឹត្តទៅមិនដាច់ខ្សែនៃខន្ធ ធាតុ អាយតនៈ ។

បទថា **វដ្តបរិយន្តេ** បានដល់ ក្នុងចំណែកទីបំផុតជុំវិញនៃកម្មវដ្តៈ វិបាកវដ្តៈ និងកិលេសវដ្តៈ ។ បទថា **អន្តិមភវេ** បានដល់ ក្នុងឧបបត្តិភពដែលជាទីបំផុត ។ បទថា **អន្តិមសមុស្សយេ ឋិតោ** បានដល់ តាំងនៅក្នុងរាងកាយដែលកម្មលើកឡើងគឺក្នុងសរីរៈដែលជាទីបំផុត ( សរីរៈចុងក្រោយ ) ។ បទថា **អន្តិមទេហធរោ** សេចក្តីថា ឈ្មោះថា ទ្រទ្រង់ទុកនូវសរីរៈក្នុងទីបំផុត ព្រោះអត្ថថា ទ្រទ្រង់ទុកនូវរាងកាយគឺសរីរៈ ដែលមានក្នុងទីបំផុត គឺចុងក្រោយ ។ បទថា **អរហា** សេចក្តីថា ឈ្មោះថា **អរហា** ព្រោះឆ្ងាយចាកសឹកសត្រូវ ព្រោះកម្ចាត់សត្រូវ ព្រោះគួរដល់បច្ច័យជាដើម និងព្រោះមិនធ្វើបាបក្នុងទីស្ងាត់ ។

បទថា **តស្សាយំ បច្ឆិមកោ** សេចក្តីថា រាងកាយ គឺអត្តភាពនេះ ជាទីបំផុតរបស់ព្រះខីណាស្រពនោះ ។ បទថា **ចរិមោ** បានដល់ តូច ឃើតឃូរ ដូចពំនូតបាយតូច ព្រះសារីបុត្តត្រេរពោលថា ការអន្ទោលទៅដោយជាតិមរណៈ កពថ្មីរបស់ព្រះអរហន្តនោះ មិនមានទេ ដូច្នេះ សំដៅយកភាពដែលបដិសន្ធិមិនមានតទៅទៀត ។

ការកើតឈ្មោះថា **ជាតិ** ។ ឈ្មោះថា **មរណា** ព្រោះអត្ថថា ជាហេតុស្លាប់របស់សត្វទាំងឡាយ កាលទ្រង់សរុបការៈដែលត្រាស់ទុកថា ការប្រព្រឹត្តទៅក្នុងសង្សារវដ្តមិនដាច់នៃខន្ធជាដើម រមែងមិនមានដល់ព្រះខីណាស្រពនោះទៀតដូច្នេះ ទើបព្រះសារីបុត្តពោលថា **តស្មា ជន្តុ ។បេ។ ឆាវំ សិត្វាវចារគូ** ដូច្នេះ ។

ក្នុងព្រះសូត្រនេះ បទណាមិនបានពោលទុកក្នុងចន្លោះៗ បទនោះគប្បីកាន់យកតាមគន្លងនៃព្រះបាលីនោះចុះ ។

## អដ្ឋកថា កាមសុត្តនិទ្ទេសទី ១ ចប់

# គុហដ្ឋកសុត្តនិទ្ទេស ទី ២

[ ៣០ ] ( ព្រះមានព្រះភាគត្រាស់ថា ) នរជនណា កាល ឋិតនៅ ជាប់នៅក្នុងគុហា ត្រូវកិលេសដ៏ច្រើនបិទបាំង លិច ចុះក្នុងមោហៈ ( អារម្មណ៍ជាគ្រឿងវង្វេង ) នរជន មាន សភាពដូច្នោះនោះ រមែងឋិតនៅក្នុងទីឆ្ងាយអំពីវិវេក ដ្បិតកាម ទាំងឡាយក្នុងលោក បុគ្គលមិនមែនលះបង់បានដោយងាយ ទេ ។

[ ៣១ ] អធិប្បាយពាក្យថា ជាប់នៅក្នុងគុហា ត្រូវកិលេសដ៏ច្រើនបិទបាំង ត្រង់ពាក្យថា ជាប់នៅ ព្រះអង្គពោលក៏ពិតហើយ ។ តែខ្ញុំសូមពោល ត្រង់ពាក្យថា គុហា ជាមុនសិន ។ កាយ លោកហៅថា គុហា ។ ពាក្យថា កាយក្តី គុហាក្តី ទេហៈក្តី សន្ទេហៈក្តី នាវាក្តី រថក្តី ទង់ក្តី ដំបូកក្តី សំបុកក្តី នគរក្តី កុដិក្តី បូសក្តី ក្អមក្តី នេះជាឈ្មោះនៃកាយ ។ ពាក្យថា ជាប់នូវក្នុង គុហា គឺជាប់នៅផ្សេងៗ ជាប់ទូទៅ ទាក់នៅ ជ្លក់នៅ ព័ន្ធព័ទ្ធនៅក្នុងគុហា ។ ភណ្ឌៈដែលជាប់នៅ ជាប់ផ្សេងៗ ជាប់ទូទៅ ទាក់នៅ ជ្លក់នៅ ព័ន្ធព័ទ្ធនៅ ឮដ៏ចម្រើងដែលដោតនឹងជញ្ជាំងក្តី ឮដ៏ដៃកែវក្តី យ៉ាងណា នរជនជាប់នៅ ជាប់ផ្សេងៗ ជាប់ទូទៅ ទាក់នៅ ជ្លក់នៅ ព័ន្ធព័ទ្ធនៅក្នុងគុហា ក៏យ៉ាងនោះ ដែរ ។ សមដូចព្រះពុទ្ធដីកានេះ ដែលព្រះមានព្រះភាគត្រាស់ថា សេចក្តីពេញ ចិត្តណា តម្រេកណា សេចក្តីត្រេកត្រអាលណា សេចក្តីប៉ុនប៉ងណា សេចក្តី ប្រកាន់ដោយឧបាយ ដែលមានការតាំងចិត្ត នឹងការប្រកាន់ជាអនុស័យណា ក្នុងរូប នរជនជាប់ក្នុងកិលេសនោះៗ ហេតុនោះ ( លោកពោលថា ) ជាប់

នៅ ។ ពាក្យថា ជាប់នៅ ជាឈ្មោះនៃការជាប់ជំពាក់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជាប់នៅក្នុងគុហា ។ ពាក្យថា ត្រូវកិលេសដ៏ច្រើនបិទបាំង គឺត្រូវកិលេសទាំងឡាយដ៏ច្រើនបិទបាំង គឺរាគៈបិទបាំង ទោសៈបិទបាំង មោហៈបិទបាំង កោធៈបិទបាំង ឧបនាហៈបិទបាំង មក្ខៈបិទបាំង បឡាសៈបិទបាំង ឥស្សាបិទបាំង មច្ឆរិយៈបិទបាំង មាយាបិទបាំង សាឋេយ្យៈបិទបាំង ថម្ភៈបិទបាំង សារម្ភៈបិទបាំង មានះបិទបាំង អតិមានះបិទបាំង មទៈបិទបាំង បមាទៈបិទបាំង កិលេសទាំងពួង ទុច្ចរិតទាំងពួង សេចក្ដីក្រវល់ក្រវាយទាំងពួង សេចក្ដីអន្ទះអន្ទែងទាំងពួង សេចក្ដីក្ដៅក្រហាយទាំងពួង អកុសលាភិសង្ខារទាំងពួងបិទបាំង ប្រក់ព្រំ ខ្ទប់ រាំង ហ៊ុមភ្ជិត គ្រប បង្រួម ផ្កាប់ហើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជាប់នៅក្នុងគុហា ត្រូវកិលេសដ៏ច្រើនបិទបាំង ។

[ ៣២ ] អធិប្បាយពាក្យថា នរជនកាលឋិតនៅ... លិចចុះក្នុងមោហៈ ត្រង់ពាក្យថា នរជនកាលឋិតនៅ បានដល់នរជនកាលជំអក់ គឺត្រេកត្រអាលដោយអំណាចរាគៈ ហើយជំអក់ ប្រទូស្តដោយអំណាចទោសៈ ហើយជំអក់វង្វេងដោយអំណាចមោហៈ ហើយជំអក់ ជាប់ក្នុងអារម្មណ៍ផ្សេងៗ ដោយអំណាចមានះ ហើយជំអក់ ស្ទាបអង្អែលដោយអំណាចទិដ្ឋិ ហើយជំអក់ រាយមាយដោយអំណាចឧទ្ធច្ចៈ ហើយជំអក់ មិនដល់នូវសេចក្ដីចូលចិត្តដោយអំណាចវិចិកិច្ឆា ហើយជំអក់ មានកម្លាំងដោយអំណាចអនុស័យ ហើយជំអក់ នរជនកាលឋិតនៅយ៉ាងនេះខ្លះ ។

សមដូចព្រះពុទ្ធដីកានេះ ដែលព្រះមានបុណ្យត្រាស់ថា ម្នាលភិក្ខុទាំង

ទ្បាយ រូបទាំងឡាយគប្បីដឹងច្បាស់ដោយចក្ខុ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាមគួររីករាយ បើភិក្ខុត្រេកអរ រីករាយនឹងរូបនោះហើយ រមែងដំអក់ក្នុងសេចក្តីប្រាថ្នាមិនខាន ម្នាលភិក្ខុទាំងឡាយ សំឡេងទាំងឡាយដែលគប្បីដឹងច្បាស់ដោយត្រចៀក ក្លិនទាំងឡាយដែលគប្បីដឹងច្បាស់ដោយច្រមុះ រសទាំងឡាយដែលគប្បីដឹងច្បាស់ដោយអណ្តាត ផ្សព្វទាំងឡាយដែលគប្បីដឹងច្បាស់ដោយកាយ ធម្មារម្មណ៍ទាំងឡាយដែលគប្បីដឹងច្បាស់ដោយចិត្ត ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាមគួររីករាយ បើភិក្ខុត្រេកអរ រីករាយនឹងអារម្មណ៍នោះហើយ រមែងដំអក់ក្នុងសេចក្តីប្រាថ្នាមិនខាន ។ នរជនកាលឋិតនៅយ៉ាងនេះខ្វះ ។

មួយទៀត ព្រះពុទ្ធដីកានេះ ដែលព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ វិញ្ញាណមានរូបជាឧបាយក្តី មានរូបជាអារម្មណ៍ តាំងនៅក្នុងរូប សេពនូវសេចក្តីត្រេកអរ កាលសម្ងំ រមែងសម្ងំ ( ក្នុងអារម្មណ៍នោះ ) ក៏ដល់នូវសេចក្តីចម្រើន លូតលាស់ ធំទូលាយម្នាលភិក្ខុទាំងឡាយ វិញ្ញាណមានវេទនាជាឧបាយក្តី ម្នាលភិក្ខុទាំងឡាយ វិញ្ញាណមានសញ្ញាជាឧបាយក្តី ម្នាលភិក្ខុទាំងឡាយ វិញ្ញាណមានសង្ខារជាឧបាយក្តី មានសង្ខារជាអារម្មណ៍ តាំងនៅក្នុងសង្ខារ សេពសេចក្តីត្រេកអរ កាលសម្ងំ រមែងសម្ងំ ( ក្នុងអារម្មណ៍នោះ ) ដល់នូវសេចក្តីចម្រើន លូតលាស់ ធំទូលាយ ។ នរជនកាលឋិតនៅយ៉ាងនេះខ្វះ ។

ន័យមួយទៀត ព្រះពុទ្ធដីកានេះ ដែលព្រះមានព្រះភាគត្រាស់ថា ម្នាល ភិក្ខុទាំងឡាយ បើមានរាគៈ មានសេចក្តីត្រេកអរ មានតណ្ហាក្នុងកវឡិង្ការាហារ វិញ្ញាណតាំងនៅលូតលាស់ក្នុងទីណា វិញ្ញាណតាំងនៅ លូតលាស់ក្នុងទីនោះ ការចុះកាន់នៃនាមរូបមានក្នុងទីណា ការចុះកាន់នៃនាមរូប ក៏មានក្នុងទីនោះ សេចក្តីចម្រើនឡើងនៃសង្ខារទាំងឡាយមានក្នុងទីណា សេចក្តីចម្រើនឡើងនៃ សង្ខារទាំងឡាយ ក៏មានក្នុងទីនោះ ការកើតឡើងនៃភពថ្មីតទៅមានក្នុងទីណា ការកើតឡើងនៃភពថ្មីតទៅ ក៏មានក្នុងទីនោះ ជាតិ ជរា មរណៈតទៅមាន ក្នុងទីណា ជាតិ ជរា មរណៈ តទៅមានក្នុងទីនោះ ម្នាលភិក្ខុទាំងឡាយ តថាគត ពោលនូវជាតិ ជរា មរណៈនោះថា ប្រកបដោយសេចក្តីសោកប្រកបដោយ ធូលី ប្រកបដោយសេចក្តីចង្អៀតចង្អល់ ម្នាលភិក្ខុទាំងឡាយ បើក្នុងផស្សាហារ ម្នាលភិក្ខុទាំងឡាយ បើក្នុងមនោសញ្ចេតនាហារ ម្នាលភិក្ខុទាំងឡាយ បើមាន រាគៈ មានសេចក្តីត្រេកអរ មានតណ្ហាក្នុងវិញ្ញាណាហារ វិញ្ញាណតាំងនៅ ដុះ ដាលឡើងក្នុងទីណា វិញ្ញាណក៏តាំងនៅដុះដាល ក្នុងទីនោះ ការចុះកាន់នៃនាម រូប មានក្នុងទីណា ការចុះកាន់នៃនាមរូប ក៏មានក្នុងទីនោះ សេចក្តីចម្រើននៃ សង្ខារទាំងឡាយ មានក្នុងទីណា សេចក្តីចម្រើននៃសង្ខារទាំងឡាយ ក៏មាន ក្នុងទីនោះ ការកើតនៃភពថ្មីតទៅ មានក្នុងទីណា ការកើតនៃភពថ្មីតទៅ ក៏មាន ក្នុងទីនោះ ជាតិ ជរា មរណៈ តទៅ មានក្នុងទីណា ជាតិ ជរា មរណៈ តទៅ ក៏មានក្នុងទីនោះ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវជាតិ ជរា មរណៈនោះ ថា ប្រកបដោយសេចក្តីសោក ប្រកបដោយធូលី ប្រកបដោយសេចក្តីចង្អៀត

ចន្លល់ ។ នរជនកាលឋិតនៅយ៉ាងនេះខ្វះ ។

ពាក្យថា លិចចុះក្នុងមោហៈ សេចក្ដីថា កាមគុណ ៥ ហៅថា មោហៈ បានដល់រូបដែលដឹងដោយចក្ខុជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាមគួររីករាយ សំឡេងដែលគប្បីដឹងដោយត្រចៀក ក្លិនដែលគប្បីដឹងដោយច្រមុះ រសដែលគប្បីដឹងដោយអណ្ដាត ផ្សព្វដែលគប្បីដឹងដោយកាយជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាមគួររីករាយ ។ កាមគុណ ៥ លោកហៅថា មោហៈ តើព្រោះហេតុអ្វី ។ ទេវតានឹងមនុស្សជោយច្រើនវង្វេង ភ្លេចស្មារតី កាន់កាំងគំនិតក្នុងកាមគុណទាំង ៥ ជាអ្នកវង្វេងភ្លេចស្មារតី កាន់កាំងគំនិតត្រូវអវិជ្ជាធ្វើឲ្យងងឹត ខ្ទប់ រាំង ហ៊ុម ក្ដិត គ្រប សង្រួម ផ្កាប់ហើយ ព្រោះហេតុនោះ កាមគុណទាំង ៥ លោកហៅថា មោហៈ ។ ត្រង់ពាក្យថា លិចចុះក្នុងមោហៈ គឺចូលទៅផ្កាប់ចុះ ចូលទៅស៊ប់ ជ្រមុជចុះក្នុងមោហៈ ហេតុនោះ ( ទ្រង់ត្រាស់ថា ) នរជនកាលឋិតនៅ លិចចុះក្នុងមោហៈ ។

[ ៣៣ ] អធិប្បាយពាក្យថា នរជនមានសភាពដូច្នោះនោះ ( ឋិតនៅ ) ក្នុងទីឆ្ងាយអំពីវិវេក ត្រង់ពាក្យថា វិវេក បានដល់វិវេក ៣ គឺកាយវិវេក ១ ចិត្តវិវេក ១ ឧបធិវិវេក ១ ។

កាយវិវេក តើដូចម្ដេច ។ ភិក្ខុក្នុងសាសានានេះ គប់រកសេនាសនៈស្ងាត់ គឺព្រៃ គល់ឈើ ភ្នំ ល្អាង គុហា ព្រៃស្មសាន ព្រៃឆ្ងាយ ទីវាល និងគំនរចំបើង ជាអ្នកនៅស្ងប់ស្ងាត់ដោយកាយ ភិក្ខុនោះទៅម្នាក់ឯង ឈរម្នាក់ឯង

អង្គុយម្នាក់ឯង ដេកម្នាក់ឯង ចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាតម្នាក់ឯង ត្រឡប់មកវិញម្នាក់ឯង អង្គុយនៅក្នុងទីស្ងាត់ម្នាក់ឯង អធិដ្ឋានទីចង្រ្កមម្នាក់ឯង ត្រាច់ទៅ នៅ ( ញុំាងឥរិយាបថ ) ឲ្យប្រព្រឹត្តទៅ ប្រព្រឹត្ត រក្សា ( ឥរិយាបថ ) ប្រព្រឹត្តទៅ ដើរទៅម្នាក់ឯង នេះឈ្មោះថា កាយវិវេក ។

ចិត្តវិវេក តើដូចម្តេច ។ ភិក្ខុចូលបឋមជ្ឈាន ចិត្តស្ងាត់ចាកនីវរណៈទាំងឡាយ ភិក្ខុចូលទុតិយជ្ឈាន ចិត្តស្ងាត់ចាកវិតក្កៈនិងវិចារៈ ចូលតតិយជ្ឈាន ចិត្តស្ងាត់ចាកបីតិ ភិក្ខុចូលចតុត្ថជ្ឈាន ចិត្តស្ងាត់ចាកសុខនិងទុក្ខ ភិក្ខុចូលអាកាសានញ្ចាយតនជ្ឈាន ចិត្តស្ងាត់ចាករូបសញ្ញា បដិឃសញ្ញា នានត្តសញ្ញា ភិក្ខុចូលវិញ្ញាណញ្ចាយតនជ្ឈាន ចិត្តស្ងាត់ចាកអាកាសានញ្ចាយតនសញ្ញា ភិក្ខុចូលអាកិញ្ចញ្ញាយតនជ្ឈាន ចិត្តស្ងាត់ចាកវិញ្ញាណញ្ចាយតនសញ្ញា ភិក្ខុចូលនេវសញ្ញានាសញ្ញាយតនជ្ឈាន ចិត្តស្ងាត់ចាកអាកិញ្ចញ្ញាយតនសញ្ញា ភិក្ខុដល់សោតៈ ចិត្តស្ងាត់ចាកសក្កាយទិដ្ឋិ ចាកវិចិកិច្ឆា ចាកសីលព្វតបរាមាសៈចាកទិដ្ឋានុស័យ ចាកវិចិកិច្ឆានុស័យ និងកិលេសដែលឋិតនៅជាមួយនឹងកិលេសទាំងនោះ ភិក្ខុដល់សកទាគាមិ ចិត្តស្ងាត់ចាកកាមរាគសញ្ញោជនៈ ចាកបដិឃ-សញ្ញោជនៈដ៏គ្រោតគ្រាតផង ចាកកាមរាគានុស័យ ចាកបដិឃានុស័យយ៉ាងគ្រោតគ្រាត ចាកកិលេសទាំងឡាយដែលឋិតនៅជាមួយនឹងកិលេសទាំងនោះផង ភិក្ខុដល់អនាគាមិ ចិត្តស្ងាត់ចាកកាមរាគសញ្ញោជនៈ ចាកបដិឃសញ្ញោជនៈយ៉ាងល្អិតផង ចាកកាមរាគានុស័យ ចាកបដិឃានុស័យយ៉ាងល្អិតផង ចាកកិលេសទាំងឡាយ ដែលឋិតនៅជាមួយគ្នានឹងកិលេសទាំងនោះផង ភិក្ខុដល់

ព្រះអរហត្ត ចិត្តស្ងាត់ចាករូបរាគៈ អរូបរាគៈ មានៈ ឧទ្ធច្ចៈ អវិជ្ជា មានានុស័យ ភវរាគានុស័យ អវិជ្ជានុស័យផង ចាកកិលេសទាំងឡាយដែលឋិតនៅជាមួយនឹងកិលេសទាំងនោះផង ចាកនិមិត្តគ្រប់យ៉ាងខាងក្រៅផង នេះឈ្មោះថា ចិត្តវិវេក ។

ឧបធិវិវេក តើដូចម្តេច ។ កិលេសទាំងឡាយ ខន្ធទាំងឡាយ និងអភិសង្ខារទាំងឡាយ លោកហៅថាឧបធិ ។ អមតនិព្វាន លោកហៅថាឧបធិវិវេក បានដល់ការរម្ងាប់សង្ខារទាំងពួង ការលះបង់ឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាករាគៈ ការរលត់ ( កង់ទុក្ខ ) ការចេញចាកតណ្ហា នេះឈ្មោះថា ឧបធិវិវេក ។

កាយវិវេក ( កើតមាន ) ដល់ពួកបុគ្គលដែលចេញចាកពួក ត្រេកអរក្នុងការចេញចាកកាមផង ចិត្តវិវេក ( កើតមាន ) ដល់ពួកបុគ្គលដែលមានចិត្តបរិសុទ្ធ ដល់នូវសេចក្តីផូរផង់ក្រៃលែងផង ឧបធិវិវេក ( កើតមាន ) ដល់ពួកបុគ្គលដែលមិនមានកិលេស ដល់នូវព្រះនិព្វានដែលប្រាសចាកសង្ខារផង ។

ពាក្យថា ក្នុងទីឆ្ងាយអំពីវិវេក បានដល់នរជនណា ជាប់ចំពាក់ក្នុងគុហាយ៉ាងនេះ ត្រូវពួកកិលេសដ៏ច្រើនបិទបាំងយ៉ាងនេះ លិចចុះក្នុងមោហៈយ៉ាងនេះ នរជននោះ ( ឈ្មោះថាឋិតនៅ ) ក្នុងទីឆ្ងាយ អំពីកាយវិវេកផង ក្នុងទីឆ្ងាយអំពីចិត្តវិវេកផង ក្នុងទីឆ្ងាយ ឆ្ងាយពេក ឆ្ងាយពេកណាស់ មិនមែនជិត មិនមែននៅក្បែរ មិនមែននៅប្រកៀក ឃ្លាតអំពីឧបធិវិវេកផង ។ ពាក្យ

ថា មានសភាពដូច្នោះ គឺមានប្រការដូច្នោះ ប្រាកដដូច្នោះ ឋិតនៅដោយអាការនោះ ឋិតនៅដោយប្រការនោះ ជាចំណែកនៃប្រការនោះ ដែលលិចចុះក្នុងមោហៈនោះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) នរជនមានសភាពដូច្នោះនោះ ( ឋិតនៅ ) ក្នុងទីឆ្ងាយអំពីវិវេក ។

[ ៣៤ ] អធិប្បាយពាក្យថា ដ្បិតកាមទាំងឡាយក្នុងលោក បុគ្គលមិនមែនលះបង់បានដោយងាយទេ ត្រង់ពាក្យថា កាម បើតាមឧទ្ទានបានដល់កាមពីរយ៉ាង គឺវត្ថុកាម ១ កិលេសកាម ១ ។

វត្ថុកាម តើដូចម្តេច ។ រូបជាទីគាប់ចិត្ត សំឡេងជាទីគាប់ចិត្ត ក្លិនជាទីគាប់ចិត្ត រសជាទីគាប់ចិត្ត ផ្សព្វជាទីគាប់ចិត្ត កម្រាល គ្រឿងស្លៀកពាក់ ខ្ញុំស្រី ខ្ញុំប្រុស ពពែ ចៀម មាន់ ជ្រូក ដំរី គោ សេះ លា ស្រែ ចម្ការ ប្រាក់ មាស ស្រុក និគម រាជធានី ដែន ជនបទ បន្ទាយ ឃ្លាំង និងវត្ថុដែលគួរត្រេកអរណាមួយ ហៅថា វត្ថុកាម ។ មួយទៀត កាមទាំងឡាយជាអតីត កាមទាំងឡាយជាអនាគត កាមទាំងឡាយជាបច្ចុប្បន្ន កាមទាំងឡាយជាខាងក្នុង កាមទាំងឡាយជាខាងក្រៅ កាមទាំងឡាយទាំងខាងក្នុងទាំងខាងក្រៅ កាមទាំងឡាយថោកទាប កាមទាំងឡាយជាកណ្តាល កាមទាំងឡាយដ៏ឧត្តម កាមទាំងឡាយមានក្នុងអបាយ កាមទាំងឡាយមានក្នុងមនុស្ស កាមទាំងឡាយជាទិព្វ កាមទាំងឡាយដែលតាំងឡើងឯង កាមទាំងឡាយដែលខ្លួននិម្មិត កាមទាំងឡាយដែលអ្នកដទៃនិម្មិត កាមទាំងឡាយដែលគេហួងហែង កាមទាំងឡាយដែលគេមិនហួងហែង កាមទាំងឡាយដែលគេប្រកាន់ថារបស់

អញ កាមទាំងឡាយដែលគេមិនប្រកាន់ថារបស់អញ ពួកធម៌ជាកាមាវចរទាំងអស់ក្តី ពួកធម៌ជារូបាវចរទាំងអស់ក្តី ពួកធម៌ជាអរូបាវចរទាំងអស់ក្តី ដែលជាវត្ថុនៃតណ្ហា ជាអារម្មណ៍នៃតណ្ហា ឈ្មោះថា កាម ដោយអត្ថថា គួរប្រាថ្នា ដោយអត្ថថា គួរត្រេកអរ ដោយអត្ថថា ជាហេតុញុំាំងសេចក្តីស្រវឹងឲ្យកើត ទាំងនេះហៅថា វត្ថុកាម ។

កិលេសកាម តើដូចម្តេច ។ សេចក្តីពេញចិត្ត ឈ្មោះថា កាម សេចក្តីត្រេកអរ ឈ្មោះថា កាម សេចក្តីត្រេកអរមានកម្លាំង ឈ្មោះថា កាម សេចក្តីត្រិះរិះ ឈ្មោះថា កាម តម្រេក ឈ្មោះថា កាម សេចក្តីត្រេកអរដោយការត្រិះរិះ ឈ្មោះថា កាម បានដល់សេចក្តីពេញចិត្តគឺកាម សេចក្តីត្រេកអរគឺកាម សេចក្តីត្រេកត្រអាលគឺកាម សេចក្តីប្រាថ្នាគឺកាម សេចក្តីស្រឡាញ់គឺកាម សេចក្តីក្តៅក្រហាយគឺកាម ការជ្រប់គឺកាម សេចក្តីចូលចិត្តមាំគឺកាម អន្លង់គឺកាម យោគៈគឺកាម ឧបាទានគឺកាម នីវរណៈគឺកាមច្ឆន្ទៈ ក្នុងកាមទាំងឡាយ ( និងពាក្យដែលព្រះមានព្រះភាគត្រាស់ថា )

> ម្នាលកាម តថាគតបានឃើញដើមកំណើតអ្នកហើយ ម្នាលកាម អ្នកឯងកើតអំពីសេចក្តីត្រិះរិះ តថាគតមិនត្រិះរិះចំពោះអ្នកទៀតទេ ម្នាលកាម កាលបើយ៉ាងនេះ អ្នកនឹងមិនមានឡើយ ដូច្នេះ ។

ទាំងនេះ លោកហៅថា កិលេសកាម ។ ពាក្យថា ក្នុងលោកគឺក្នុងអបាយលោក ក្នុងមនុស្សលោក ក្នុងទេវលោក ក្នុងខន្ធលោក ក្នុងធាតុលោក ក្នុង

អាយតនលោក ។ ពាក្យថា ដ្បិតកាមទាំងឡាយក្នុងលោក បុគ្គលមិនមែនលះបង់បានដោយងាយទេ បានសេចក្តីថា ដ្បិតកាមទាំងឡាយក្នុងលោកគេលះបង់បានដោយក្រ បោះបង់បានដោយក្រ លះលែងបានដោយក្រ ញុំាំញីបានដោយក្រ ដោះស្រាយបានដោយក្រ ធ្លងបានដោយក្រ ធ្លងកាត់បានដោយក្រ កន្លងបានដោយក្រ រំលងបានដោយក្រ ហេតុនោះ ( ទ្រង់ត្រាស់ថា ) កាមទាំងឡាយក្នុងលោក បុគ្គលមិនមែនលះបង់បានដោយងាយទេ ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

នរជនកាលឋិតនៅ ជាប់នៅក្នុងគុហា ត្រូវកិលេសដ៏ច្រើនបិទ
បាំង លិចចុះក្នុងមោហៈ នរជនមានសភាពដូច្នោះនោះ ( ឋិត
នៅ ) ក្នុងទីឆ្ងាយអំពីវិវេក ដ្បិតកាមទាំងឡាយក្នុងលោក
បុគ្គលមិនមែនលះបង់បានដោយងាយទេ ដូច្នេះ ។

[ ៣៥ ] ពួកសត្វទាំងនោះ មានសេចក្តីប្រាថ្នាជាហេតុជាប់ចំពាក់ដោយសេចក្តីត្រេកអរក្នុងការបម្រើន អាលោះអាល័យក្នុងកាលជាខាងក្រោយ ឬក្នុងកាលមុន ប្រាថ្នានូវកាមទាំងនេះ ឬនូវកាមក្នុងកាលមុន រមែងរួចបានដោយក្រ ទាំងញុំាំងបុគ្គលដទៃឲ្យរួចមិនបាន ។

[ ៣៦ ] ពាក្យថា មានសេចក្តីប្រាថ្នាជាហេតុជាប់ជំពាក់ ដោយសេចក្តីត្រេកអរក្នុងការបម្រើន អធិប្បាយថា តណ្ហា លោកហៅថា សេចក្តីប្រាថ្នាបានដល់តម្រេក តម្រេកមានកម្លាំង សេចក្តីក្តួចកាន់ សេចក្តីត្រេកអរ សេចក្តីរីករាយ សេចក្តីរីករាយនិងតម្រេក តម្រេកដ៏មានកម្លាំងរបស់ចិត្ត សេចក្តីប្រាថ្នា

សេចក្ដីជ្រប់ចុះ កិរិយាងប់ចុះ សេចក្ដីជំពាក់ចិត្ត សេចក្ដីចំពាក់មាំ គ្រឿងជាប់ កក់ កិរិយាស្វែងរក ការលោក់ពុត កិលេសជាតិជាគ្រឿងញុំាងសត្វឲ្យកើតជា គ្រឿងញុំាងទុក្ខឲ្យកើត ជាគ្រឿងចាក់ស្រែះ កិលេសជាតិដូចជាសំណាញ់ ជា គ្រឿងហូរទៅ ផ្សាយទៅ ក្រសែគឺតណ្ហា កិលេសជាតិដ៏ទូលាយ ជាគ្រឿង ញុំាងអាយុឲ្យវិនាស ( របស់សត្វ ) ជាគម្រប់ពីរ ជាគ្រឿងតម្កល់ទុក ជា គ្រឿងនាំសត្វទៅកាន់ភព កិលេសជាតិដូចជាព្រៃធំ ដូចជាព្រៃតូច សេចក្ដី ស្និទ្ធស្នាល សេចក្ដីស្នេហា សេចក្ដីអាល័យ សេចក្ដីជាប់ចំពាក់ សេចក្ដីប៉ុន ប៉ង សេចក្ដីទឹកជញ្ជីង ភាពនៃចិត្តទឹកជញ្ជីង បំណងរូប បំណងសំឡេង បំណង ក្លិន បំណងរស បំណងផ្សព្វ បំណងលាភ បំណងទ្រព្យ បំណងកូន បំណង ជីវិត ការជាប់ ការជាប់ទូទៅ ការជាប់ក្រៃលែង ការជាប់ កិរិយាជាប់ ភាព នៃចិត្តជាប់ ការជក់ស្អិត កិរិយាជក់ស្អិត ភាពនៃចិត្តជក់ស្អិត ភាពនៃចិត្តរឡិប រឡប់ ភាពនៃចិត្តប្រាថ្នាខ្វាំងក្លា តម្រេកមិនត្រូវតាមធម៌ សេចក្ដីលោភ មិនស្មើ សេចក្ដីអាល័យ កិលេសជាតិជាទីអាល័យ សេចក្ដីប្រាថ្នា សេចក្ដីស្រឡាញ់ សេចក្ដីប្រាថ្នាគ្រប់យ៉ាង ចំណង់ក្នុងកាម ចំណង់ក្នុងសេចក្ដីចម្រើន ចំណង់ក្នុង សេចក្ដីវិនាស ចំណង់ក្នុងរូប ចំណង់ក្នុងអរូប ចំណង់ក្នុងនិរោធ ចំណង់ក្នុង រូប ចំណង់ក្នុងសំឡេង ចំណង់ក្នុងក្លិន ចំណង់ក្នុងរស ចំណង់ក្នុងផ្សព្វ ចំណង់ ក្នុងធម៌ អន្លង់ គ្រឿងប្រកបទុក គ្រឿងដោតក្រង គ្រឿងប្រកាន់ កិរិយារាំង កិរិយាទប់ កិរិយាប្រក់ កិរិយាចង កិរិយាសៅហ្មង កិរិយាដេកត្រាំ កិរិយា ស្ទាក់វល្លិ៍គឺតណ្ហា សេចក្ដីប្រាថ្នាផ្សេងៗ ឫសគល់នៃសេចក្ដីទុក្ខ ហេតុនៃសេចក្ដី

ទុក្ខ ដែនកើតនៃសេចក្តីទុក្ខ អន្ទាក់នៃមារ សន្ទូចនៃមារ វិស័យនៃមារ ស្ទឹង គឺតណ្ហា បណ្តាញគឺតណ្ហា ជង់ដោយគឺតណ្ហា សមុទ្ទគឺតណ្ហា អភិជ្ឈា លោភៈ ឫសគល់នៃអកុសល ។ ពាក្យថា មានសេចក្តីប្រាថ្នាជាហេតុ គឺមានសេចក្តីប្រាថ្នាជានិទាន មានសេចក្តីប្រាថ្នាជាហេតុ មានសេចក្តីប្រាថ្នាជាបច្ច័យ មានសេចក្តីប្រាថ្នាជាការណ៍ មានសេចក្តីប្រាថ្នាជាដែនកើតមុន ហេតុនោះ ( ទ្រង់ត្រាស់ថា ) មានសេចក្តីប្រាថ្នាជាហេតុ ។ ពាក្យថា ជាប់ចំពាក់ដោយសេចក្តីត្រេកអរក្នុងការចម្រើន គឺសេចក្តីត្រេកអរក្នុងការចម្រើន ១ គឺសុខវេទនា ។ សេចក្តីត្រេកអរក្នុងការចម្រើន ២ គឺសុខវេទនា ១ វត្ថុជាទីប្រាថ្នា ១ ។ សេចក្តីត្រេកអរក្នុងការចម្រើន ៣ គឺភាពនូវក្មេង ១ ការមិនមានរោគ ១ ជីវិត ១ ។ សេចក្តីត្រេកអរក្នុងការចម្រើន ៤ គឺលាភ ១ យស ១ សេចក្តីសរសើរ ១ សុខ ១ ។ សេចក្តីត្រេកអរក្នុងការចម្រើន ៥ គឺរូបជាទីគាប់ចិត្ត ១ សំឡេងជាទីគាប់ចិត្ត ១ ក្លិនជាទីគាប់ចិត្ត ១ រសជាទីគាប់ចិត្ត ១ ផ្សព្វជាទីគាប់ចិត្ត ១ ។ សេចក្តីត្រេកអរក្នុងការចម្រើន ៦ គឺចក្ខុសម្បទា ១ សោតសម្បទា ១ ឃានសម្បទា ១ ជិវ្ហាសម្បទា ១ កាយសម្បទា ១ មនោសម្បទា ១ ។ ពាក្យថា ជាប់ជំពាក់ដោយសេចក្តីត្រេកអរក្នុងការចម្រើន គឺជាប់ក្នុងសុខវេទនា ជាប់ក្នុងវត្ថុជាទីប្រាថ្នា ជាប់ក្នុងភាពនៅក្មេង ជាប់ក្នុងការមិនមានរោគ ជាប់ក្នុងជីវិត ជាប់ក្នុងលាភ ជាប់ក្នុងយស ជាប់ក្នុងសេចក្តីសរសើរ ជាប់ក្នុងសុខ ជាប់ក្នុងរូបជាទីគាប់ចិត្ត ក្នុងសំឡេង ក្នុងក្លិន ក្នុងរស ជាប់ក្នុងផ្សព្វជាទីគាប់ចិត្ត ជាប់ក្នុងចក្ខុសម្បទា ជាប់ចំពាក់ជាប់ដោយអាការផ្សេងៗ ស្អិត ទាក់ ជ្ពក់ ពន្ធ

ព័ន្ធក្នុងសោតសម្បទា ឃានសម្បទា ជិវ្ហាសម្បទា កាយសម្បទា មនោសម្បទា ហេតុនោះ ( ទ្រង់ត្រាស់ថា ) មានសេចក្តីប្រាថ្នាជាហេតុ ជាប់ចំពាក់ដោយសេចក្តីត្រេកអរក្នុងការចម្រើន ។

[ ៣៧ ] ពាក្យថា ពួកសត្វទាំងនោះ រមែងរួចបានដោយក្រ ទាំងញុំាងបុគ្គលដទៃឲ្យរួចមិនបាន អធិប្បាយថា អារម្មណ៍ជាវត្ថុនៃសេចក្តីត្រេកអរក្នុងការចម្រើនទាំងនោះ ពួកសត្វដោះបានដោយក្រ ឬពួកសត្វរួចបានដោយក្រចាកអារម្មណ៍នុ៎ះ ។

អារម្មណ៍ជាវត្ថុនៃសេចក្តីត្រេកអរក្នុងការចម្រើនទាំងនោះ ពួកសត្វដោះបានដោយក្រ តើដូចម្តេច ។ សុខវេទនា សត្វដោះបានដោយកម្រ វត្ថុជាទីប្រាថ្នា សត្វដោះបានដោយកម្រ ភាពនៅក្មេង សត្វដោះបានដោយកម្រ ការមិនមានរោគ សត្វដោះបានដោយកម្រ ជីវិត សត្វដោះបានដោយកម្រ លាភ សត្វដោះបានដោយកម្រ យស សត្វដោះបានដោយកម្រ សេចក្តីសរសើរ សត្វដោះបានដោយកម្រ សុខ សត្វដោះបានដោយកម្រ រូបទាំងឡាយជាទីគាប់ចិត្ត សត្វដោះបានដោយកម្រ សំឡេង ក្លិន រស ផ្សព្វជាទីគាប់ចិត្តសត្វដោះបានដោយកម្រ ចក្ខុសម្បទា សត្វដោះបានដោយកម្រ សោតសម្បទា ឃានសម្បទា ជិវ្ហាសម្បទា កាយសម្បទា មនោសម្បទា សត្វដោះបានដោយកម្រ ដោះស្រឡះបានដោយកម្រ ដោះចេញបានដោយកម្រ ដោះចេញស្រឡះបានដោយកម្រ ញុំាញីបានដោយកម្រ ដោះចេញបានដោយកម្រ ឆ្លងបានដោយកម្រ ឆ្លងកាត់បានដោយកម្រ កន្លងបានដោយកម្រ រំលងបានដោយកម្រ ។

អារម្មណ៍ជាវត្ថុនៃសេចក្តីត្រេកអរក្នុងការបម្រើនទាំងនោះ សត្វរួចបានដោយក្រយ៉ាងនេះ ។

ពួកសត្វរួចបានដោយក្រចាកធម៌ទុំះ តើដូចម្តេច ។ ពួកសត្វរួចបានដោយកម្រចាកសុខវេទនា រួចបានដោយកម្រចាកវត្ថុជាទីប្រាថ្នា រួចបានដោយកម្រចាកភាពនៅក្មេង រួចបានដោយកម្រចាកការមិនមានរោគ រួចបានដោយកម្រចាកជីវិត រួចបានដោយកម្រចាកលាភ រួចបានដោយកម្រចាកយស រួចបានដោយកម្រចាកសេចក្តីសរសើរ រួចបានដោយកម្រចាកសុខ រួចបានដោយកម្រចាករូបទាំងឡាយជាទីគាប់ចិត្ត រួចបានដោយកម្រចាកសំឡេង ក្លិន រស ផ្សព្វជាទីគាប់ចិត្ត រួចបានដោយកម្រចាកចក្ខុសម្បទា រួចបានដោយកម្រ រួចស្រឡះបានដោយកម្រ រើចេញបានដោយកម្រ ស្ទុះឡើងបានដោយកម្រ ក្រោកឡើងបានដោយកម្រ លោតឡើងបានដោយកម្រ ចាកសោតសម្បទា ឃានសម្បទា ជិវ្ហាសម្បទា កាយសម្បទា មនោសម្បទា ។ ពួកសត្វរួចបានដោយក្រចាកធម៌ទុំះ យ៉ាងនេះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ពួកសត្វទាំងនោះ រួចបានដោយក្រ ។

ពាក្យថា ទាំងញុំាងអ្នកដទៃឲ្យរួចមិនបាន សេចក្តីថា សត្វទាំងនោះជាអ្នកលិចកប់ក្នុងភក់ដោយខ្លួនឯង មិនអាចនឹងស្រង់បុគ្គលដទៃ ដែលលិចកប់ក្នុងភក់បានទេ ។ សមដូចពាក្យនេះ ដែលព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលចុន្ទ បុគ្គលនោះឯង លិចកប់ក្នុងភក់ដោយខ្លួនឯង នឹងស្រង់បុគ្គលដទៃដែលលិចកប់ក្នុងភក់បាន ហេតុដូច្នេះនេះមិនមានទេ ម្នាលចុន្ទ បុគ្គលនោះឯង មិន

ទាន់ទូន្មានខ្លួន មិនទាន់ប្រៀនប្រដៅខ្លួន មិនទាន់រលត់កិលេសដោយខ្លួនឯងទេ នឹងទូន្មានប្រៀនប្រដៅបុគ្គលដទៃ ( នឹងញ៉ាំងបុគ្គលដទៃ ) ឲ្យរលត់កិលេសបាន ហេតុដូច្នេះនេះមិនមានទេ ។ ពួកសត្វមិនអាចញ៉ាំងអ្នកដទៃឲ្យរួចបាន យ៉ាងនេះខ្លះ ។ ម្យ៉ាងទៀត បុគ្គលដទៃណាមួយ អាចញ៉ាំងបុគ្គលដទៃឲ្យរួចបានមិនមានទេ ប្រសិនបើពួកសត្វនោះគប្បីរួច លុះតែប្រតិបត្តិនូវសម្មាបដិបទា អនុលោមប្បដិបទា អបច្ចនីកប្បដិបទា អន្វត្ថប្បដិបទា ធម្មានុធម្មប្បដិបទា ដោយខ្លួនឯង ដោយកម្លាំងញាណរបស់ខ្លួន ដោយពលញ្ញាណរបស់ខ្លួន ដោយព្យាយាមរបស់ខ្លួន ដោយការប្រឹងប្រែងរបស់ខ្លួន ដោយកម្លាំងបុរសរបស់ខ្លួន ដោយពលញ្ញាណនៃបុរសរបស់ខ្លួន ដោយព្យាយាមនៃបុរសរបស់ខ្លួន ដោយការប្រឹងប្រែងនៃបុរសរបស់ខ្លួនទើបរួចបាន ។ ពួកសត្វមិនអាចញ៉ាំងអ្នកដទៃឲ្យរួចបាន យ៉ាងនេះខ្លះ ។

មួយទៀត ពាក្យនេះ ព្រះមានព្រះភាគត្រាស់ហើយថា

ម្នាលធោតកៈ តថាគតមិនអាចញ៉ាំងបុគ្គលណាមួយ ដែល
មានសេចក្តីសង្ស័យក្នុងលោកឲ្យរួចបានទេ អ្នកកាលដឹងច្បាស់
នូវធម៌ដ៏ប្រសើរ នឹងឆ្លងអន្លង់នេះ យ៉ាងនេះបាន ។

ពួកសត្វ មិនអាចនឹងញ៉ាំងអ្នកដទៃឲ្យរួចបានយ៉ាងនេះខ្លះ ។ មួយទៀត ពាក្យនេះព្រះមានព្រះភាគត្រាស់ហើយថា

បុគ្គលធ្វើបាបដោយខ្លួនឯង នឹងសៅហ្មងដោយខ្លួន មិនធ្វើបាប
ដោយខ្លួនឯង រមែងបរិសុទ្ធិដោយខ្លួនឯង សេចក្តីបរិសុទ្ធនិង

មិនបរិសុទ្ធ កើតចំពោះខ្លួន បុគ្គលដទៃនឹងញ៉ាំងបុគ្គលដទៃឲ្យ
បរិសុទ្ធមិនបានទេ ដូច្នេះ ។

ពួកសត្វមិនអាចញ៉ាំងបុគ្គលដទៃឲ្យរួចបានយ៉ាងនេះខ្លះ ។ មួយវិញទៀត ពាក្យនេះ ព្រះមានព្រះភាគត្រាស់ហើយថា ម្នាលព្រាហ្មណ៍ ព្រះនិព្វានក៏តាំងនៅ ផ្លូវជាទីទៅកាន់ព្រះនិព្វានក៏តាំងនៅ តថាគតជាអ្នកណែនាំក៏ឋិតនៅយ៉ាងនេះឯង ប៉ុន្តែសាវ័កទាំងឡាយរបស់តថាគត ដែលតថាគតកាលទូន្មានយ៉ាងនេះ កាលប្រៀនប្រដៅយ៉ាងនេះ ពួកខ្លះបានព្រះនិព្វានជាទីសម្រេចទីបំផុត ពួកខ្លះមិនបាន ម្នាលព្រាហ្មណ៍ តថាគតនឹងធ្វើដូចម្តេចចំពោះសាវ័កទាំងនោះ ម្នាលព្រាហ្មណ៍ ព្រះតថាគតជាអ្នកប្រាប់ផ្លូវ ព្រះពុទ្ធរមែងប្រាប់ផ្លូវ ពួកសត្វកាលប្រតិបត្តិគប្បីរួចដោយខ្លួនឯង ។ ពួកសត្វមិនអាចញ៉ាំងអ្នកដទៃឲ្យរួចយ៉ាងនេះខ្លះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ពួកសត្វទាំងនោះ រួចបានដោយក្រ ទាំងញ៉ាំងអ្នកដទៃឲ្យរួចមិនបាន ។

[ ៣៨ ] ពាក្យថា កាលប្រាថ្នាកាមក្នុងកាលជាខាងក្រោយ ឬក្នុងកាលមុន អធិប្បាយថា អនាគតលោកហៅថា កាលជាខាងក្រោយ អតីតលោកហៅថា កាលមុន ។ ម្យ៉ាងទៀត អនាគតនិងបច្ចុប្បន្ន ដែលអាស្រ័យនឹងអតីតៈ ឈ្មោះថា កាលខាងក្រោយ អតីតៈនិងបច្ចុប្បន្ន ដែលអាស្រ័យនឹងអនាគត ឈ្មោះថា កាលមុន ។

នរជនធ្វើនូវសេចក្តីប្រាថ្នាក្នុងកាលមុន តើដោយប្រការដូចម្តេច ។ នរជនញ៉ាំងសេចក្តីត្រេកអរឲ្យកើតក្នុងរូបារម្មណ៍នោះថា អាត្មាអញមានរូបយ៉ាងនេះ

ហើយក្នុងអតីតកាល ដល់ព្រមនូវសេចក្តីត្រេកអរក្នុងវេទនាជាដើមនោះថា អាត្មាអញមានវេទនាយ៉ាងនេះហើយ មានសញ្ញាយ៉ាងនេះហើយ មានសង្ខារយ៉ាងនេះហើយ មានវិញ្ញាណយ៉ាងនេះហើយក្នុងអតីតកាល ។ នរជនធ្វើនូវសេចក្តីប្រាថ្នាក្នុងកាលមុនយ៉ាងនេះខ្លះ ។ មួយវិញទៀត វិញ្ញាណជាប់ចំពាក់ដោយឆន្ទរាគក្នុងអាយតនៈនោះថា អញមានចក្ខុដូចនេះ មានរូបដូចនេះហើយក្នុងអតីតកាល នរជនតែងត្រេកអរនឹងអាយតនៈនោះ ព្រោះវិញ្ញាណជាប់ចំពាក់ដោយឆន្ទរាគៈ កាលត្រេកអរនឹងអាយតនៈនោះ ឈ្មោះថា ធ្វើនូវសេចក្តីប្រាថ្នាក្នុងកាលមុនយ៉ាងនេះខ្លះ ។ ថាអញមានសោតៈដូចនេះ មានសំឡេងដូចនេះហើយក្នុងអតីតកាល ។ ថាអញមានឃានៈដូចនេះ មានក្លិនដូចនេះហើយក្នុងអតីតកាល ។ ថាអញមានជិវ្ហាដូចនេះ មានរសដូចនេះហើយក្នុងអតីតកាល ។ ថាអញមានកាយដូចនេះ មានផោដ្ឋព្វដូចនេះហើយក្នុងអតីតកាល ។ វិញ្ញាណជាប់ចំពាក់ដោយឆន្ទរាគក្នុងអាយតនៈនោះថា អញមានចិត្តដូចនេះ មានធម្មារម្មណ៍ដូចនេះហើយក្នុងអតីតកាល នរជនរមែងត្រេកអរនឹងអាយតនៈនោះ ព្រោះវិញ្ញាណជាប់ជំពាក់ដោយឆន្ទរាគៈ កាលត្រេកអរនឹងអាយតនៈនោះ ឈ្មោះថាធ្វើនូវសេចក្តីប្រាថ្នាក្នុងកាលមុនយ៉ាងនេះខ្លះ ។ម្យ៉ាងទៀត នរជននោះ សើច ចរចា ឬលេងជាមួយនឹងមាតុគ្រាមក្នុងកាលមុន ក៏ត្រេកអរនឹងអារម្មណ៍នោះ ប្រាថ្នានូវអារម្មណ៍នោះ ដល់នូវសេចក្តីត្រេកអរដោយអារម្មណ៍នោះ ។ នរជនធ្វើនូវសេចក្តីប្រាថ្នាក្នុងកាលមុនយ៉ាងនេះខ្លះ ។

នរជនធ្វើនូវសេចក្តីប្រាថ្នាក្នុងកាលជាខាងក្រោយ តើដូចម្តេច ។ នរជន

ញុំាំងសេចក្ដីត្រេកអរឲ្យកើតក្នុងរូបារម្មណ៍នោះថា អាត្មាអញជាអ្នកមានរូបយ៉ាងនេះក្នុងអនាគតកាល ដល់ព្រមនូវសេចក្ដីត្រេកអរក្នុងវេទនាជាដើមនោះថា អាត្មាអញគប្បីជាអ្នកមានវេទនាយ៉ាងនេះ មានសញ្ញាយ៉ាងនេះ មានសង្ខារយ៉ាងនេះ មានវិញ្ញាណយ៉ាងនេះក្នុងអនាគតកាល ។ នរជនធ្វើនូវសេចក្ដីប្រាថ្នាក្នុងកាលជាខាងក្រោយយ៉ាងនេះខ្លះ ។ មួយទៀត នរជនតម្កល់ចិត្តដើម្បីបានចំពោះនូវអាយតនៈ ដែលមិនទាន់បានថា អញគប្បីមានចក្ខុដូចនេះ មានរូបដូចនេះក្នុងអនាគតកាលដូច្នេះ រមែងត្រេកអរនឹងអាយតនៈនោះ ព្រោះការតម្កល់ចិត្តជាបច្ច័យ កាលត្រេកអរនឹងអាយតនៈនោះ ឈ្មោះថាធ្វើនូវសេចក្ដីប្រាថ្នាក្នុងកាលជាខាងក្រោយយ៉ាងនេះខ្លះ ។ ថាអញគប្បីមានសោតៈដូចនេះ មានសំឡេងដូចនេះក្នុងអនាគតកាល ។ ថាអញគប្បីមានឃានៈដូចនេះ មានគន្ធដូចនេះក្នុងអនាគតកាល ។ ថាអញគប្បីមានជិវ្ហាដូចនេះ មានរសដូចនេះក្នុងអនាគតកាល ។ ថាអញគប្បីមានកាយដូចនេះ មានផ្សព្វដូចនេះក្នុងអនាគតកាល ។ នរជនតម្កល់ចិត្តដើម្បីបានចំពោះនូវអាយតនៈដែលខ្លួនមិនទាន់បានថា អញគប្បីមានចិត្តដូចនេះ មានធម្មារម្មណ៍ដូចនេះក្នុងអនាគតកាលដូច្នេះ រមែងត្រេកអរនឹងអាយតនៈនោះ ព្រោះការតម្កល់ចិត្តជាបច្ច័យ កាលត្រេកអរនឹងអាយតនៈនោះ ឈ្មោះថាធ្វើនូវសេចក្ដីប្រាថ្នាក្នុងកាលជាខាងក្រោយយ៉ាងនេះខ្លះ ។ មួយទៀត នរជនតម្កល់ចិត្តដើម្បីបានចំពោះនូវអត្តភាពដែលខ្លួនមិនទាន់បានថា អាត្មាអញនឹងបានជាទេវតា ( មានអានុភាពច្រើន ) ឬជាទេវតាណាមួយដោយសារសីលក្ដី វត្តក្ដីតបៈក្ដី ព្រហ្មចរិយៈនេះក្ដី ដូច្នេះ

រមែងត្រេកអរនឹងអត្តភាពនោះ ព្រោះការតម្កល់ចិត្តជាបច្ច័យ កាលត្រេកអរនឹងអត្តភាពនោះ ឈ្មោះថាធ្វើនូវសេចក្ដីប្រាថ្នាក្នុងកាលជាខាងក្រោយយ៉ាងនេះខ្លះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ពួកសត្វកាលប្រាថ្នា ( កាម ) ក្នុងកាលជាខាងក្រោយ ឬក្នុងកាលមុន ។

[ ៣៩ ] អធិប្បាយពាក្យថា ប្រាថ្នានូវកាមទាំងនេះ ឬនូវកាមក្នុងកាលមុន ត្រង់ពាក្យថា កាមទាំងនេះ បានដល់ពួកសត្វកាលចង់បាន កាលត្រេកអរ កាលប្រាថ្នា កាលស្រឡាញ់ កាលជាប់ចិត្តនូវកាមគុណទាំង ៥ ជាបច្ចុប្បន្ន ។ ពាក្យថា ប្រាថ្នានូវកាមក្នុងកាលមុន បានដល់ពួកសត្វកាលសរសើរ សរសើរសព្វ សរសើរក្រៃពេកនូវកាមគុណទាំង ៥ ជាអតីតៈ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ប្រាថ្នានូវកាមទាំងនេះ ឬនូវកាមក្នុងកាលមុន ។ ហេតុនោះព្រះមានព្រះភាគ ត្រាស់ថា

ពួកសត្វទាំងនោះ មានសេចក្ដីប្រាថ្នាជាហេតុ ជាប់ចំពាក់ដោយ
សេចក្ដីត្រេកអរក្នុងសេចក្ដីចម្រើន អាឡោះអាល័យកាមក្នុង
កាលជាខាងក្រោយ ឬក្នុងកាលមុន ប្រាថ្នានូវកាមទាំងនេះ
ឬនូវកាមក្នុងកាលមុន រមែងរួចបានដោយក្រ ទាំងញ៉ាំងអ្នក
ដទៃឲ្យរួចមិនបាន ។

[ ៤០ ] ជនអ្នកជាប់ចំពាក់ អ្នកខ្វល់ខ្វាយ អ្នកវង្វេងក្នុងកាមទាំងឡាយ អ្នកប្រកាន់ថោកទាប អ្នកតាំងនៅក្នុងអំពើមិនស្មើ អ្នកដល់សេចក្ដីទុក្ខទាំងនោះ រមែងខ្សឹកខ្សួលថា យើងទាំងឡាយច្យុតចាកអត្តភាពនេះទៅនឹងកើតជា

អ្វីហ្ន៎ ។

[ ៤១ ] អធិប្បាយពាក្យថា អ្នកជាប់ចំពាក់ អ្នកខ្វល់ខ្វាយ អ្នកវង្វេង ក្នុងកាមទាំងឡាយ ត្រង់ពាក្យថា កាម បើតាមឧទ្ទានបានដល់កាម ២ យ៉ាង គឺ វត្ថុកាម ១ កិលេសកាម ១ ។បេ។ ទាំងនេះ លោកហៅថា វត្ថុកាម ។បេ។ ទាំងនេះ លោកហៅថា កិលេសកាម ។ តណ្ហា លោកហៅថា ការជាប់ចំពាក់ បានដល់ សេចក្តីត្រេកអរ សេចក្តីត្រេកអរមានកម្លាំង ។បេ។ អភិជ្ឈា លោភៈ អកុសលមូល ។ ពួកសត្វជាអ្នកត្រេកអរ ជាប់ចំពាក់ ធ្លាក់ចុះ ងុលងប់ ជ្រុលជ្រប់ ទាក់ ជ្លក់ ពន្ធព័ទ្ធក្នុងវត្ថុកាម ព្រោះកិលេសកាម ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកជាប់ចំពាក់ក្នុងកាមទាំងឡាយ ។ ពាក្យថា អ្នកខ្វល់ខ្វាយ សេចក្តីថា ពួកសត្វណា ប៉ុនប៉ង ស្វែងរក ស្វះស្វែងនូវកាមទាំងឡាយ ជាអ្នកត្រាច់ទៅរកកាមនោះ ច្រើនដោយកាមនោះ ធ្ងន់ក្នុងកាមនោះ ឱនទៅរកកាមនោះ សសៀរទៅរកកាមនោះ ឈមទៅរកកាមនោះ ស្ងុងទៅរកកាមនោះ ធ្វើនូវកាមនោះឲ្យជាធំ ពួកសត្វនោះឯង ឈ្មោះថា អ្នកខ្វល់ខ្វាយក្នុងកាម ។ ពួកសត្វណា ប៉ុនប៉ង ស្វែងរក ស្វះស្វែងនូវរូបទាំងឡាយ ប៉ុនប៉ង ស្វែងរក ស្វះស្វែងនូវសំឡេង ក្លិន រស ផស្សទាំងឡាយដោយអំណាចតណ្ហា ជាអ្នកត្រាច់ទៅរកអារម្មណ៍នោះ ច្រើនដោយអារម្មណ៍នោះ ធ្ងន់ក្នុងអារម្មណ៍នោះ ឱនទៅរកអារម្មណ៍នោះ សសៀរទៅរកអារម្មណ៍នោះ ឈមទៅរកអារម្មណ៍នោះ ស្ងុងទៅរកអារម្មណ៍នោះ ធ្វើអារម្មណ៍នោះឲ្យជាធំ ពួកសត្វនោះឯង ឈ្មោះថាអ្នកខ្វល់ខ្វាយក្នុងកាម ។ មួយទៀត ពួកសត្វណាបានចំពោះនូវរូប

ទាំងឡាយ បានចំពោះនូវសំឡេង ក្លិន រស ផ្សព្វទាំងឡាយដោយអំណាចតណ្ហា ជាអ្នកត្រាច់ទៅរកអារម្មណ៍នោះ ច្រើនដោយអារម្មណ៍នោះ ធ្ងន់ក្នុងអារម្មណ៍នោះ ឱនទៅរកអារម្មណ៍នោះ សសៀរទៅរកអារម្មណ៍នោះ ឈមទៅរកអារម្មណ៍នោះ ស្ទុងទៅរកអារម្មណ៍នោះ ធ្វើអារម្មណ៍នោះឲ្យជាធំ ពួកសត្វនោះឯង ឈ្មោះថាអ្នកខ្វល់ខ្វាយក្នុងកាម ។ មួយទៀត ពួកសត្វណា បរិភោគនូវរូបទាំងឡាយ បរិភោគនូវសំឡេង ក្លិន រស ផ្សព្វទាំងឡាយដោយអំណាចតណ្ហា ជាអ្នកត្រាច់ទៅរកអារម្មណ៍នោះ ច្រើនដោយអារម្មណ៍នោះ ធ្ងន់ក្នុងអារម្មណ៍នោះ ឱនទៅរកអារម្មណ៍នោះ សសៀរទៅរកអារម្មណ៍នោះ ឈមទៅរកអារម្មណ៍នោះ ស្ទុងទៅរកអារម្មណ៍នោះ ធ្វើអារម្មណ៍នោះឲ្យជាធំ ពួកសត្វនោះឯង ឈ្មោះថាអ្នកខ្វល់ខ្វាយក្នុងកាម ។ ជនអ្នកធ្វើនូវការឈ្មោះ ឈ្មោះថាអ្នកខ្វល់ខ្វាយក្នុងការឈ្មោះ អ្នកធ្វើនូវការងារ ឈ្មោះថាអ្នកខ្វល់ខ្វាយក្នុងការងារ អ្នកប្រព្រឹត្តក្នុងគោចរ ឈ្មោះថាអ្នកខ្វល់ខ្វាយក្នុងគោចរ អ្នកមានឈាន ឈ្មោះថាអ្នកខ្វល់ខ្វាយក្នុងឈានយ៉ាងណា ពួកសត្វណា ប៉ុនប៉ងស្វែងរក ស្វះស្វែងនូវកាមទាំងឡាយ ជាអ្នកត្រាច់ទៅរកកាមនោះ ច្រើនដោយកាមនោះ ធ្ងន់ក្នុងកាមនោះ ឱនទៅរកកាមនោះ សសៀរទៅរកកាមនោះ ឈមទៅរកកាមនោះ ស្ទុងទៅរកកាមនោះ ធ្វើកាមនោះឲ្យជាធំ ពួកសត្វនោះ ឈ្មោះថាអ្នកខ្វល់ខ្វាយក្នុងកាម ។ មួយទៀត ពួកសត្វណា ប៉ុនប៉ង ស្វែងរក ស្វះស្វែងនូវរូបទាំងឡាយ ប៉ុនប៉ង ស្វែងរក ស្វះស្វែងនូវសំឡេង ក្លិន រស ផ្សព្វទាំងឡាយដោយអំណាចតណ្ហា ជាអ្នកត្រាច់ទៅរកអារម្មណ៍នោះ ច្រើនដោយ

អារម្មណ៍នោះ ជ្ជន់ក្នុងអារម្មណ៍នោះ ឱនទៅរកអារម្មណ៍នោះ សសៀរទៅរក អារម្មណ៍នោះ ឈមទៅរកអារម្មណ៍នោះ ស្ទុងទៅរកអារម្មណ៍នោះ ធ្វើអារម្មណ៍នោះឲ្យជាធំ ពួកសត្វនោះឈ្មោះថា អ្នកខ្វល់ខ្វាយក្នុងកាម ។ មួយទៀត ពួកសត្វណា បានចំពោះនូវរូបទាំងឡាយ បានចំពោះនូវសំឡេង ក្លិន រស ផ្សព្វទាំងឡាយដោយអំណាចតណ្ហា ជាអ្នកត្រាច់ទៅរកអារម្មណ៍នោះ ច្រើនដោយអារម្មណ៍នោះ ជ្ជន់ក្នុងអារម្មណ៍នោះ ឱនទៅរកអារម្មណ៍នោះ សសៀរទៅរក អារម្មណ៍នោះ ឈមទៅរកអារម្មណ៍នោះ ស្ទុងទៅរកអារម្មណ៍នោះ ធ្វើអារម្មណ៍នោះឲ្យជាធំ ពួកសត្វទាំងនោះឈ្មោះថា អ្នកខ្វល់ខ្វាយក្នុងកាម ។ មួយទៀត ពួកសត្វណា បរិភោគនូវរូបទាំងឡាយ បរិភោគនូវសំឡេង ក្លិន រស ផ្សព្វទាំងឡាយដោយអំណាចតណ្ហា ជាអ្នកត្រាច់ទៅរកអារម្មណ៍នោះ ច្រើនដោយអារម្មណ៍នោះ ជ្ជន់ក្នុងអារម្មណ៍នោះ ឱនទៅរកអារម្មណ៍នោះ សសៀរទៅរក អារម្មណ៍នោះ ឈមទៅរកអារម្មណ៍នោះ ស្ទុងទៅរកអារម្មណ៍នោះ ធ្វើអារម្មណ៍នោះឲ្យជាធំ ពួកសត្វនោះ ឈ្មោះថាអ្នកខ្វល់ខ្វាយក្នុងកាម ។ ពាក្យថា អ្នកវង្វេង បានដល់ទេវតានិងមនុស្សទាំងឡាយដោយច្រើនវង្វេងភ្លេចស្មារតី កាន់កាំងគំនិតក្នុងកាមគុណទាំង ៥ ជាអ្នកវង្វេងភ្លេចស្មារតី កាន់កាំងគំនិត ត្រូវអវិជ្ជាធ្វើឲ្យងងឹត ខ្វប់ រាំង ហ៊ុម ក្តិត គ្រប បង្រួម ផ្កាប់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកជាប់ចំពាក់ អ្នកខ្វល់ខ្វាយ អ្នកវង្វេងក្នុងកាមទាំងឡាយ ។

[ ៤២ ] អធិប្បាយពាក្យថា អ្នកប្រកាន់ថោកទាប អ្នកតាំងនៅក្នុងអំពើមិនស្មើទាំងនោះ ត្រង់ពាក្យថា អ្នកប្រកាន់ថោកទាប គឺអ្នកប្រកាន់ថោកទាប

ព្រោះហេតុទៅកាន់ទីថោកទាបក៏បាន ។ ពួកជនមានសេចក្តីកំណាញ់ លោកហៅថា អ្នកប្រកាន់ថោកទាបក៏បាន ។ អ្នកប្រកាន់ថោកទាប ព្រោះហេតុមិនកាន់យកនូវសំដីនូវគន្ធពាក្យ នូវទេសនា នូវពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងឡាយ របស់សាវកនៃព្រះពុទ្ធទាំងឡាយក៏បាន ។

អ្នកប្រកាន់ថោកទាប ព្រោះហេតុទៅកាន់ទីថោកទាប តើដូចម្តេច ។ ត្រង់ពាក្យថា ទៅកាន់ទីថោកទាប គឺទៅកាន់នរក ទៅកាន់កំណើតតិរច្ឆាន ទៅកាន់បិត្តិវិស័យ ព្រោះហេតុនោះ អ្នកប្រកាន់ទីថោកទាប ព្រោះហេតុទៅកាន់ទីថោកទាបយ៉ាងនេះ ។

ពួកជនមានសេចក្តីកំណាញ់ លោកហៅថា អ្នកប្រកាន់ថោកទាប តើដូចម្តេច ។ សេចក្តីកំណាញ់ ៥ យ៉ាង គឺសេចក្តីកំណាញ់អាវាស ១ សេចក្តីកំណាញ់ត្រកូល ១ សេចក្តីកំណាញ់លាភ ១ សេចក្តីកំណាញ់វណ្ណៈ ១ ( សម្បុរឬគុណ ) ១ សេចក្តីកំណាញ់ធម៌ ១ សេចក្តីកំណាញ់ អាការៈនៃសេចក្តីកំណាញ់ ភាពនៃសេចក្តីកំណាញ់ ភាពនៃសេចក្តីកំណាញ់យ៉ាងល្មមភាពនៃសេចក្តីកំណាញ់រឹង សេចក្តីរួញរា ភាវៈនៃការមិនយកចិត្តយកថ្លើមគេមានសភាពយ៉ាងនេះ នេះលោកហៅថា សេចក្តីកំណាញ់ ។ មួយទៀត សេចក្តីកំណាញ់ខន្ធក្តី ក៏ឈ្មោះថាកំណាញ់ សេចក្តីកំណាញ់ធាតុក្តី ក៏ឈ្មោះថាកំណាញ់សេចក្តីកំណាញ់អាយតនៈក្តី ក៏ឈ្មោះថាកំណាញ់ សេចក្តីប្រកាន់ ( ដោយអំណាចនៃសេចក្តីប្រាថ្នា ) នេះលោកហៅថា សេចក្តីកំណាញ់ ។ ពួកជនប្រកបដោយសេចក្តីកំណាញ់នេះ ព្រោះមិនដឹងនូវការប្រកាន់ថោកទាប ឈ្មោះ

ថា អ្នកប្រមាទ ពួកជនមានសេចក្តីកំណាញ់ លោកហៅថា អ្នកប្រកាន់ថោកទាបយ៉ាងនេះ ។

អ្នកប្រកាន់ថោកទាប ព្រោះហេតុមិនកាន់យកនូវសំដី នូវគន្លងពាក្យ នូវទេសនា នូវពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងឡាយ របស់សាវ័កនៃព្រះពុទ្ធទាំងឡាយ តើដូចម្តេច ។ ពួកជនមិនកាន់យក មិនស្តាប់ មិនប្រុងត្រចៀក មិនតាំងចិត្តដើម្បីឲ្យដឹងនូវសំដី គន្លងពាក្យ ទេសនា ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងឡាយ របស់សាវ័កនៃព្រះពុទ្ធទាំងឡាយ ជាអ្នកមិនស្តាប់ឱវាទ មិនធ្វើតាមពាក្យ ប្រព្រឹត្តទទឹង បែរមុខទៅ កាន់ទីដទៃវិញ មិនជឿកាន់សំដី គន្លងពាក្យ ទេសនានឹងពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងឡាយ របស់សាវ័កនៃព្រះពុទ្ធទាំងឡាយ ព្រោះហេតុនោះ ឈ្មោះថា អ្នកប្រកាន់ថោកទាបយ៉ាងនេះ ។

ពាក្យថា ទាំងនោះ ... អ្នកតាំងនៅក្នុងអំពើមិនស្មើ អធិប្បាយថា ពួកសត្វតាំងនៅក្នុងកាយកម្មមិនស្មើ តាំងនៅក្នុងវចីកម្មមិនស្មើ តាំងនៅក្នុងមនោ-កម្មមិនស្មើ តាំងនៅក្នុងបាណាតិបាតមិនស្មើ តាំងនៅក្នុងអទិន្នាទានមិនស្មើ តាំងនៅក្នុងកាមេសុមិច្ឆាចារៈមិនស្មើ តាំងនៅក្នុងមុសាវាទមិនស្មើ តាំងនៅក្នុងបិសុណាវាចាមិនស្មើ តាំងនៅក្នុងផរុសវាចាមិនស្មើ តាំងនៅក្នុងសម្ផប្ប-លាបមិនស្មើ តាំងនៅក្នុងអភិជ្ឈាមិនស្មើ តាំងនៅក្នុងព្យាបាទមិនស្មើ តាំងនៅក្នុងមិច្ឆាទិដ្ឋិមិនស្មើ តាំងនៅក្នុងសង្ខារទាំងឡាយមិនស្មើ តាំងនៅក្នុងកាមគុណទាំង ៥ មិនស្មើ តាំងនៅក្នុងនីវរណៈទាំង ៥ មិនស្មើ តាំងនៅ តម្កល់នៅ ស្អិតជាប់ ចូលទៅជិតដល់ ជ្រុលជ្រប់ បង្អោនទៅ ជាប់នៅ ទាក់ ជ្លក់

ព័ន្ធព័ទ្ធក្នុងចេតនាមិនស្មើ ក្នុងសេចក្ដីប្រាថ្នាមិនស្មើ ក្នុងការតាំងចិត្តមិនស្មើ ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកប្រកាន់ថោកទាប អ្នកតាំងនៅក្នុងអំពើមិនស្មើ ។

[ ៤៣ ] អធិប្បាយពាក្យថា អ្នកដល់សេចក្ដីទុក្ខ រមែងខ្សឹកខ្សួល ត្រង់ពាក្យថា អ្នកដល់សេចក្ដីទុក្ខ គឺអ្នកចូលទៅដល់ទុក្ខ ដល់នូវទុក្ខ ដល់ព្រមនូវទុក្ខ ចូលទៅរកទុក្ខ ដល់នូវមារ ដល់ព្រមនូវមារ ចូលទៅរកមារ ដល់នូវសេចក្ដីស្លាប់ ដល់ព្រមនូវសេចក្ដីស្លាប់ ចូលទៅរកសេចក្ដីស្លាប់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកដល់សេចក្ដីទុក្ខ ។ ពាក្យថា រមែងខ្សឹកខ្សួល គឺរមែងយំរៀបរាប់ យំអណ្ដឺតអណ្ដក សោកសៅ លំបាក ខ្សឹកខ្សួល គក់ទ្រូង កន្ទក់កន្ទេញ ដល់នូវសេចក្ដីវង្វេង ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកដល់សេចក្ដីទុក្ខ រមែងខ្សឹកខ្សួល ។

[ ៤៤ ] ពាក្យថា យើងទាំងឡាយ ច្យុតចាកអត្តភាពនេះទៅ នឹងកើតជាអ្វីហ្ន៎ សេចក្ដីថា ពួកយើងច្យុតចាកអត្តភាពនេះទៅ តើទៅកើតជាអ្វី គឺទៅកើតជាសត្វនរក ឬកើតជាសត្វតិរច្ឆាន កើតជាបិត្តិវិស័យ កើតជាមនុស្ស កើតជាទេវតា កើតជារូបព្រហ្ម កើតជាអរូបព្រហ្ម កើតជាសញ្ញីព្រហ្ម កើតជាអសញ្ញីព្រហ្ម កើតជានេវសញ្ញីនាសញ្ញីព្រហ្ម យើងទាំងឡាយនឹងកើតក្នុងអនាគតកាលឬហ្ន៎ ឬនឹងមិនកើតក្នុងអនាគតកាលទេ នឹងជាអ្វីហ្ន៎ក្នុងអនាគតកាល នឹងកើតក្នុងអនាគតកាលដោយសណ្ឋានដូចម្ដេចហ្ន៎ យើងទាំងឡាយនឹងបានជាអ្វី កើតជាអ្វីក្នុងអនាគតកាល ពួកជនអ្នកកន្ទះរាដោយសេចក្ដី

សង្ស័យ អ្នកច្នេញ្ជា ដោយសេចក្តីងឿងឆ្ងល់ អ្នកបែកចេញជាពីរចំណែក រមែងយំរៀបរាប់ យំអណ្តឺតអណ្តក សោកសៅ លំបាក ខ្សឹកខ្សួល គក់ទ្រូង កន្ទក់កន្ទេញ ដល់នូវសេចក្តីវង្វេង ហេតុនោះ ( ទ្រង់ត្រាស់ថា ) យើងទាំងឡាយច្យុតចាកអត្តភាពនេះទៅ នឹងកើតជាអ្វីហ្ន៎ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ជនអ្នកជាប់ជំពាក់ អ្នកខ្វល់ខ្វាយ អ្នកវង្វេងក្នុងកាមទាំងឡាយ
អ្នកប្រកាន់ថោកទាប អ្នកតាំងនៅក្នុងអំពើមិនស្មើ អ្នកដល់
សេចក្តីទុក្ខទាំងនោះ រមែងខ្សឹកខ្សួលថា យើងទាំងឡាយច្យុត
ចាកអត្តភាពនេះទៅ នឹងកើតជាអ្វីហ្ន៎ ។

[ ៤៥ ] ព្រោះហេតុនោះ ជនក្នុងសាសនានេះ គប្បីសិក្សា គប្បីដឹងនូវកម្មណាមួយក្នុងលោកថាមិនស្មើ មិនគប្បីប្រព្រឹត្តនូវកម្មមិនស្មើ ព្រោះហេតុនៃកម្មមិនស្មើនោះទេ ដ្បិតថា ធីរជនទាំងឡាយ បានពោលនូវជីវិតនេះថាតិច ។

[ ៤៦ ] អធិប្បាយពាក្យថា ព្រោះហេតុនោះ ជនក្នុងសាសនានេះ គប្បីសិក្សា ត្រង់ពាក្យថា ព្រោះហេតុនោះ គឺព្រោះដំណើរនោះ ព្រោះការណ៍នោះ ព្រោះហេតុនោះ ព្រោះបច្ច័យនោះ ព្រោះនិទាននោះ ជនកាលឃើញច្បាស់នូវទោសទុ៎ះក្នុងកាមទាំងឡាយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ព្រោះហេតុនោះ ។ ពាក្យថា គប្បីសិក្សា បានដល់សិក្ខា ( ការសិក្សា ) ៣ គឺអធិសីលសិក្ខា ១ អធិចិត្តសិក្ខា ១ អធិប្បញ្ញាសិក្ខា ១ ។

អធិសីលសិក្ខា តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល

សង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈនិងគោចារៈ ឃើញភ័យក្នុងទោសមានប្រមាណតិច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ សីលក្ខន្ធតូច សីលក្ខន្ធធំ សីល ទីតម្កល់ ទីខាងដើម ការប្រព្រឹត្ត ការសង្រួម ការរវាំង ប្រធាន ប្រមុខនៃការបានទូវកុសលធម៌ទាំងឡាយ នេះឈ្មោះថា អធិសីលសិក្ខា ។

អធិចិត្តសិក្ខា តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ហើយចូលកាន់បឋមជ្ឈានប្រកបដោយវិតក្កៈនិងវិចារៈ មានបីតិនិងសុខ ដែលកើតអំពីសេចក្តីស្ងាត់ ។ ព្រោះរម្ងាប់វិតក្កៈ វិចារៈ ចូលកាន់ទុតិយជ្ឈានជាទីផូរផង់ប្រព្រឹត្តទៅខាងក្នុង ញុំាងសមាធិចិត្តឲ្យកើត ឥតមានវិតក្កៈនិងវិចារៈ មានតែបីតិនិងសុខៈដែលកើតអំពីសមាធិ ។ ព្រោះប្រាសចាកបីតិផង ជាអ្នកប្រកបដោយឧបេក្ខាផង មានសតិនិងសម្បជញ្ញៈផង សោយសុខដោយនាមកាយផង ចូលកាន់តតិយជ្ឈានដែលព្រះអរិយៈទាំងឡាយសរសើរ បុគ្គលអ្នកបានតតិយជ្ឈាននោះ ថាជាអ្នកមានឧបេក្ខា មានសតិនៅជាសុខ ដូច្នេះ ។ ព្រោះលះបង់សុខផង លះបង់ទុក្ខផង រំលត់សោមនស្សនិងទោមនស្សទាំងឡាយក្នុងកាលមុនផង ចូលកាន់ចតុត្ថជ្ឈានឥតទុក្ខ ឥតសុខ មានសតិដ៏បរិសុទ្ធដោយឧបេក្ខា នេះឈ្មោះថា អធិចិត្តសិក្ខា ។

អធិប្បញ្ញាសិក្ខា តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានបញ្ញាប្រកបដោយបញ្ញា ប្រព្រឹត្តក្នុងកិរិយាកើតឡើងនិងវិនាសទៅ ជាបញ្ញាដ៏ប្រសើរ ជាគ្រឿងទម្លុះទម្លាយ ជាគ្រឿងដឹងនូវការអស់ទៅនៃទុក្ខដោយប្រពៃ ភិក្ខុនោះ តែងដឹងច្បាស់តាមពិតថា នេះទុក្ខ ដឹងច្បាស់តាមពិតថា នេះហេតុនាំឲ្យ

កើតទុក្ខ ដឹងច្បាស់តាមពិតថា នេះទីរលត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះសេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរលត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះសេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរលត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះអាសវៈ ដឹងច្បាស់តាមពិតថា នេះធម៌ឲ្យកើតអាសវៈ ដឹងច្បាស់តាមពិតថា នេះទីរលត់អាសវៈ ដឹងច្បាស់តាមពិតថា នេះសេចក្តីប្រតិបត្តិជាដំណើរ ទៅកាន់ទីរលត់អាសវៈ នេះឈ្មោះថា អធិប្បញ្ញាសិក្ខា ។

ភិក្ខុកាលនឹក ឈ្មោះថាសិក្សា កាលដឹងឈ្មោះថាសិក្សា កាលឃើញឈ្មោះថាសិក្សា កាលពិចារណា ឈ្មោះថាសិក្សា កាលតម្កល់ចិត្ត ឈ្មោះថាសិក្សា កាលបង្អោនចិត្តដោយសទ្ធា ឈ្មោះថាសិក្សា កាលផ្គងនូវព្យាយាមឈ្មោះថាសិក្សា កាលតម្កល់ស្មារតី ឈ្មោះថាសិក្សា កាលតម្កល់ចិត្ត ឈ្មោះថាសិក្សា កាលដឹងច្បាស់ដោយបញ្ញា ឈ្មោះថាសិក្សា កាលដឹងច្បាស់នូវអភិញ្ញេយ្យធម៌ ឈ្មោះថាសិក្សា កាលកំណត់ដឹងនូវបរិញ្ញេយ្យធម៌ ឈ្មោះថាសិក្សា កាលលះបង់នូវបហាតព្វធម៌ ឈ្មោះថាសិក្សា កាលចម្រើននូវភាវេតព្វធម៌ ឈ្មោះថាសិក្សា កាលធ្វើឲ្យជាក់ច្បាស់នូវសច្ឆិកាតព្វធម៌ ឈ្មោះថាសិក្សា ប្រព្រឹត្តទូទៅ ប្រព្រឹត្តដោយល្អ ប្រព្រឹត្តសមាទាននូវសិក្ខាទាំង ៣ នេះ ។ ពាក្យថា ក្នុងសាសនានេះ គឺក្នុងទិដ្ឋិនេះ ក្នុងសេចក្តីគួរនេះ ក្នុងសេចក្តីគាប់ចិត្តនេះ ក្នុងសេចក្តីប្រកាន់នេះ ក្នុងធម៌នេះ ក្នុងវិន័យនេះ ក្នុងធម្មវិន័យនេះ ក្នុងពាក្យជាប្រធាននេះ ក្នុងព្រហ្មចរិយៈនេះ ក្នុងសាសនានៃព្រះសាស្តានេះ ក្នុងអត្តភាពនេះ ក្នុងមនុស្សលោកនេះ ។ ពាក្យថា ជន បានដល់សត្វនរជន ។បេ។ សត្វ

កើតអំពីមនុស្ស ហេតុនោះ ( ទ្រង់ត្រាស់ថា ) ព្រោះហេតុនោះ ជនក្នុងសាសនានេះគប្បីសិក្សា ។

[ ៤៧ ] អធិប្បាយពាក្យថា គប្បីដឹងនូវកម្មណាមួយក្នុងលោកថា មិនស្មើ ត្រង់ពាក្យថា ណាមួយ គឺទាំងអស់ ដោយអាការទាំងអស់ ទាំងពួងដោយប្រការទាំងពួង មិនមានសេសសល់ ឥតសេសសល់ ពាក្យថា ណាមួយនុ៎ះ ជាពាក្យប្រមូល ។ ពាក្យថា គប្បីដឹងថា មិនស្មើ គឺគប្បីដឹងនូវកាយកម្មមិនស្មើ ថាមិនស្មើ គប្បីដឹងនូវវចីកម្មមិនស្មើ ថាមិនស្មើ គប្បីដឹងនូវមនោ-កម្មមិនស្មើ ថាមិនស្មើ គប្បីដឹងនូវបាណាតិបាតមិនស្មើ ថាមិនស្មើ គប្បីដឹងនូវអទិន្នាទានមិនស្មើ ថាមិនស្មើ គប្បីដឹងនូវកាមេសុមិច្ឆាចារៈមិនស្មើ ថាមិនស្មើ គប្បីដឹងនូវមុសាវាទមិនស្មើ ថាមិនស្មើ គប្បីដឹងនូវបិសុណាវាចាមិនស្មើ ថាមិនស្មើ គប្បីដឹងនូវផរុសវាចាមិនស្មើ ថាមិនស្មើ គប្បីដឹងនូវសម្ផប្បលាបៈមិនស្មើ ថាមិនស្មើ គប្បីដឹងនូវអភិជ្ឈាមិនស្មើ ថាមិនស្មើ គប្បីដឹងនូវព្យាបាទមិនស្មើ ថាមិនស្មើ គប្បីដឹងនូវមិច្ឆាទិដ្ឋិមិនស្មើ ថាមិនស្មើ គប្បីដឹងនូវសង្ខារទាំងឡាយមិនស្មើ ថាមិនស្មើ គប្បីដឹងនូវកាមគុណទាំង ៥ មិនស្មើ ថាមិនស្មើ គប្បីដឹងនូវនីវរណៈទាំង ៥ មិនស្មើ ថាមិនស្មើ គប្បីដឹងនូវចេតនាមិនស្មើ ថាមិនស្មើ គប្បីដឹងនូវសេចក្តីប្រាថ្នាមិនស្មើ ថាមិនស្មើ គប្បីដឹងគប្បីដឹងទូទៅ គប្បីដឹងវិសេស គប្បីដឹងប្រាកដ គប្បីចាក់ធ្លុះនូវកិរិយាតម្កល់ ( ចិត្ត ) មិនស្មើ ថាមិនស្មើ ។ ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក ។បេ។ ក្នុងអាយតនលោក ហេតុនោះ ( ទ្រង់ត្រាស់ថា ) គប្បីដឹងនូវកម្មណាមួយក្នុង

លោក ថាមិនស្មើ ។

[ ៤៨ ] ពាក្យថា មិនគប្បីប្រព្រឹត្តនូវកម្មមិនស្មើ ព្រោះហេតុនៃកម្មមិនស្មើនោះ អធិប្បាយថា មិនគប្បីប្រព្រឹត្តកាយកម្មមិនស្មើ ព្រោះហេតុនៃកាយកម្មមិនស្មើ មិនគប្បីប្រព្រឹត្តវចីកម្មមិនស្មើ ព្រោះហេតុនៃវចីកម្មមិនស្មើ មិនគប្បីប្រព្រឹត្តមនោកម្មមិនស្មើ ព្រោះហេតុនៃមនោកម្មមិនស្មើ មិនគប្បីប្រព្រឹត្តបាណាតិបាតមិនស្មើ ព្រោះហេតុនៃបាណាតិបាតមិនស្មើ មិនគប្បីប្រព្រឹត្តអទិន្នាទានមិនស្មើ ព្រោះហេតុនៃអទិន្នាទានមិនស្មើ មិនគប្បីប្រព្រឹត្តកាមេសុមិច្ឆាចារៈមិនស្មើ ព្រោះហេតុនៃកាមេសុមិច្ឆាចារៈមិនស្មើ មិនគប្បីប្រព្រឹត្តមុសាវាទមិនស្មើ ព្រោះហេតុនៃមុសាវាទមិនស្មើ មិនគប្បីប្រព្រឹត្តបិសុណាវាចាមិនស្មើ ព្រោះហេតុនៃបិសុណាវាចាមិនស្មើ មិនគប្បីប្រព្រឹត្តផរុសវាចាមិនស្មើ ព្រោះហេតុនៃផរុសវាចាមិនស្មើ មិនគប្បីប្រព្រឹត្តសម្ផប្បលាបៈមិនស្មើ ព្រោះហេតុនៃសម្ផប្បលាបៈមិនស្មើ មិនគប្បីប្រព្រឹត្តអភិជ្ឈាមិនស្មើ ព្រោះហេតុនៃអភិជ្ឈាមិនស្មើ មិនគប្បីប្រព្រឹត្តព្យាបាទមិនស្មើ ព្រោះហេតុនៃព្យាបាទមិនស្មើ មិនគប្បីប្រព្រឹត្តមិច្ឆាទិដ្ឋិមិនស្មើ ព្រោះហេតុនៃមិច្ឆាទិដ្ឋិមិនស្មើ មិនគប្បីប្រព្រឹត្តសង្ខារទាំងឡាយមិនស្មើ ព្រោះហេតុនៃសង្ខារទាំងឡាយមិនស្មើ មិនគប្បីប្រព្រឹត្តកាមគុណទាំង ៥ មិនស្មើ ព្រោះហេតុនៃកាមគុណទាំង ៥ មិនស្មើ មិនគប្បីប្រព្រឹត្តនីវរណៈទាំង ៥ មិនស្មើ ព្រោះហេតុនៃនីវរណៈទាំង ៥ មិនស្មើ មិនគប្បីប្រព្រឹត្ត មិនគប្បីប្រព្រឹត្តទូទៅ មិនគប្បីប្រព្រឹត្តដោយប្រពៃ មិនគប្បីប្រព្រឹត្តសមាទាន (នូវចេតនាជាដើម)មិនស្មើ ព្រោះហេតុនៃចេតនាមិនស្មើ ព្រោះហេតុនៃសេចក្តី

ប្រាថ្នាមិនស្មើ ព្រោះហេតុនៃកិរិយាតម្កល់ ( ចិត្ត ) មិនស្មើ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនគប្បីប្រព្រឹត្តនូវកម្មមិនស្មើ ព្រោះហេតុនៃកម្មមិនស្មើនោះទេ ។

[ ៤៩ ] អធិប្បាយពាក្យថា ធីរជនទាំងឡាយ បានពោលនូវជីវិតនេះថាតិច ត្រង់ពាក្យថា ជីវិត បានដល់អាយុ ការតាំងនៅ ការទៅ ការញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ការដើរទៅ ការប្រព្រឹត្តទៅ ការរក្សា ការរស់នៅ ឥន្ទ្រិយ គឺការរស់នៅ ។ មួយវិញទៀត ជីវិតតិច ដោយហេតុពីរយ៉ាង គឺជីវិតតិច ព្រោះធម្មជាតិតាំងនៅតិច ជីវិតតិច ព្រោះកិច្ចរបស់ខ្លួនតិច ។

ជីវិតតិច ព្រោះជាធម្មជាតិតាំងនៅតិច តើដូចម្ដេច ។ សត្វដែលរស់នៅហើយក្នុងខណៈចិត្តជាអតីតៈ មិនរស់នៅ នឹងមិនរស់នៅ ។ សត្វនឹងរស់នៅក្នុងខណៈចិត្តជាអនាគត មិនរស់នៅ មិនរស់នៅហើយ ។ សត្វកំពុងរស់នៅក្នុងខណៈចិត្តជាបច្ចុប្បន្ន មិនបានរស់នៅហើយ នឹងមិនរស់នៅ ។ ជីវិត អត្តភាពសុខនិងទុក្ខទាំងអស់ ប្រកបដោយខណៈចិត្តតែមួយ ព្រោះខណៈប្រព្រឹត្តទៅរហ័ស ពួកទេវតាណា ឋិតនៅអស់ ៨៤.០០០ កប្ប ទេវតាទាំងនោះ មិនមែនប្រកបដោយចិត្តពីរហើយរស់នៅទេ ខន្ធទាំងឡាយណារបស់បុគ្គលដែលស្លាប់ទៅក្តី រស់នៅក្តី រលត់ហើយក្នុងលោកនេះ ខន្ធទាំងអស់នោះ ក៏ដូចគ្នាទៅបដិសន្ធិទៀតមិនបាន ខន្ធទាំងឡាយណា ដែលកន្លងជាលំដាប់ បែកធ្លាយហើយផង ខន្ធទាំងឡាយណា ជាអនាគតនឹងបែកធ្លាយផង សេចក្តីផ្សេងគ្នានៃខន្ធទាំងឡាយជាបច្ចុប្បន្ន ដែលរលត់ហើយក្នុងចន្លោះនៃខន្ធទាំងពីរនោះ រមែងមិនមានក្នុងលក្ខណៈ សត្វលោកមិនមែនកើតដោយអនាគតខន្ធដែលមិនទាន់

កើត មិនមែនរស់នៅក្នុងបច្ចុប្បន្នទេ សត្វលោកស្លាប់ដោយការបែកធ្លាយនៃចិត្ត ការបញ្ញត្តិ ប្រកបដោយបរមត្ថ ប្រែប្រួលទៅ ដោយធម្មៈ ដូចជាទីទាបរមែងប្រព្រឹត្ត ទៅដូច្នោះ វេទនាទាំងឡាយមានសឡាយតនៈជាបច្ច័យ មានវារៈមិនដាច់តែងប្រព្រឹត្តទៅ ខន្ធទាំងឡាយដែលបែកធ្លាយហើយ ក៏មិនដល់នូវកិរិយាតម្កល់ទុកទេ គំនរនៃខន្ធក្នុងអនាគត ក៏មិនមាន ខន្ធទាំងឡាយដែលកើតឡើងហើយ រមែងតាំងនៅ ឧបមាដូចជាគ្រាប់ស្ពៃ ដែលជាប់នឹងចុងដែកស្រួច កាលបើខន្ធទាំងឡាយកើតឡើងហើយ ការបែកធ្លាយនៃខន្ធទាំងនោះ ក៏ឋិតនៅក្នុងខាងមុខ ឯសង្ខារៈដែលត្រូវវិនាសទាំងឡាយ ( ខន្ធ ) កំពុងឋិតនៅ មិនច្រឡូកច្រឡំដោយខន្ធចាស់ទេ ពួកសត្វមកអំពីទីមើលមិនឃើញ តែងទៅកាន់ទីមើលមិនឃើញ មុនអំពីការបែកធ្លាយតែងកើតឡើងទាំងតែងវិនាសទៅវិញ ដូចជាផ្លេកបន្ទោរឰដ៏អាកាស ។ ជីវិតតិច ព្រោះការតាំងនៅតិចយ៉ាងនេះ ។

ជីវិតតិច ព្រោះកិច្ចរបស់ខ្លួនតិច តើដូចម្តេច ។ ជីវិតជាប់ចំពាក់ដោយដង្ហើមចូល ជីវិតជាប់ចំពាក់ដោយដង្ហើមចេញ ជីវិតជាប់ចំពាក់ដោយដង្ហើមចូលនិងដង្ហើមចេញ ជីវិតជាប់ចំពាក់ដោយមហាភូតរូប ជីវិតជាប់ចំពាក់ដោយភ្លើងធាតុ ជីវិតជាប់ចំពាក់ដោយកវឡិង្ការាហារ ជីវិតជាប់ចំពាក់ដោយវិញ្ញាណ ។ មូលនៃធម៌ទាំងនេះ ក៏មានកម្លាំងថយ ។ បុព្វហេតុទាំងឡាយនៃធម៌ទាំងនេះ ក៏មានកម្លាំងថយ ។ សូម្បីធម៌ទាំងឡាយណាជាបច្ច័យ ធម៌ទាំងនោះ ក៏មានកម្លាំងថយ ។ សូម្បីធម៌ទាំងឡាយណាជាដែនកើតមុន ធម៌ទាំងនោះ ក៏

មានកម្លាំងថយ ។ ពួកធម៌ដែលកើតជាមួយនឹងធម៌ទាំងនេះ ក៏មានកម្លាំងថយដូចគ្នា ។ ពួកធម៌ដែលសម្បយោគនឹងធម៌ទាំងនេះ មានកម្លាំងថយ ។ សហជាតធម៌នៃធម៌ទាំងនេះ មានកម្លាំងថយ ។ តណ្ហាណាជាគ្រឿងប្រកប តណ្ហានោះ មានកម្លាំងថយ ។ ធម៌ទាំងនេះ មានកម្លាំងថយជានិច្ចចំពោះគ្នានឹងគ្នា ។ ធម៌ទាំងនេះមិនឱនរកគ្នានឹងគ្នា ។ ធម៌ទាំងនេះញ៉ាំងគ្នានឹងគ្នាឲ្យធ្លាក់ចុះ ។ ព្រោះថា មិនបានជាទីពឹងដល់គ្នានឹងគ្នា ។ មួយទៀត ធម៌ទាំងនេះមិនលើកតម្កើងគ្នានឹងគ្នា ។ ធម៌ណា ជាអ្នកបង្កើត ធម៌នោះមិនមានទេ ។ ធម៌នីមួយមិនមែនសាបសូន្យដោយធម៌ណាមួយទេ ។ ព្រោះថា ធម៌ទាំងនេះបែកធ្លាយទៅទាំងអស់ ។ ធម៌ទាំងនេះកើតហើយដោយសារហេតុនិងបច្ច័យជាដើម ។ ហេតុនិងបច្ច័យទាំងឡាយណាដែលកើតមុន ហេតុនិងបច្ច័យទាំងនោះ ក៏ស្លាប់មុនទៅហើយ ។ ធម៌ទាំងឡាយខាងដើមនិងខាងចុង មិនបានឃើញគ្នានឹងគ្នាក្នុងកាលណាឡើយ ។ ជីវិតតិច ព្រោះកិច្ចរបស់ខ្លួនតិចយ៉ាងនេះ ។

មួយវិញទៀត មនុស្សទាំងឡាយមានជីវិតតិច ជីវិតស្តួចស្តើង ជីវិតខ្លី ជីវិតមានក្នុងមួយខណៈ ជីវិតរហ័ស ជីវិតបាត់ ជីវិតមិនមាំមួន ជីវិតមិនតាំងនៅអស់កាលយូរ បើប្រៀបធៀបនឹងជីវិតរបស់ពួកទេវតាជាន់ចាតុម្មហារាជិកា ។ របស់ពួកទេវតាជាន់តាវត្តិង្ស ។ របស់ពួកទេវតាជាន់យាមៈ ។ របស់ពួកទេវតាជាន់តុសិត ។ របស់ពួកទេវតាជាន់និម្មានរតី ។ របស់ពួកទេវតាជាន់បរនិម្មិតវសវត្តី ។ មនុស្សទាំងឡាយមានជីវិតតិច ជីវិតស្តួចស្តើង ជីវិតខ្លី ជីវិតមានក្នុងមួយខណៈ ជីវិតរហ័ស ជីវិតធាប់ ជីវិតមិនមាំមួន ជីវិតមិនតាំង

នៅអស់កាលយូរ បើប្រៀបធៀបនឹងជីវិតរបស់ពួកទេវតាព្រហ្មកាយិកៈ ។ សមដូចពាក្យនេះ ដែលព្រះមានព្រះភាគត្រាស់ហើយថា ម្នាលភិក្ខុទាំងឡាយ អាយុរបស់មនុស្សទាំងឡាយនេះតិច បរលោកត្រូវទៅដោយពិត បុគ្គលគប្បីប៉ះពាល់ដោយបញ្ញា ត្រូវធ្វើកុសល ត្រូវប្រព្រឹត្តព្រហ្មចរិយៈ បុគ្គលដែលកើតហើយមិនមែនមិនស្លាប់ទេ ម្នាលភិក្ខុទាំងឡាយ បុគ្គលណារស់នៅយ៉ាងយូរ បុគ្គលនោះគប្បីរស់នៅ ១០០ ឆ្នាំតិចជាងនេះ ឬច្រើនជាងនេះ ( មានខ្លះ ) ។

អាយុរបស់មនុស្សទាំងឡាយតិច បុរសអ្នកមានប្រាជ្ញាគួរ
ធុញទ្រាន់នឹងអាយុនុ៎ះ គប្បីប្រព្រឹត្តឲ្យដូចបុគ្គលដែលត្រូវ
ភ្លើងឆេះក្បាល ការមិនមកនៃមច្ចុមិនមានទេ ថ្ងៃនិងយប់រមែង
កន្លងទៅ ជីវិតក៏រលត់ទៅដែរ អាយុនៃសត្វទាំងឡាយរមែង
អស់ទៅ ដូចទឹកនៃស្ទឹងតូចៗ ។

អធិប្បាយពាក្យថា ធីរជនទាំងឡាយ ពោលនូវជីវិតនេះថា តិច ត្រង់ពាក្យថា ធីរជនទាំងឡាយ គឺឈ្មោះថាធីរជន ព្រោះហេតុជាអ្នកមានប្រាជ្ញា ។ ឈ្មោះថាធីរជន ព្រោះហេតុជាអ្នកបរិបូណ៌ដោយប្រាជ្ញា ។ ឈ្មោះថាធីរជន ព្រោះហេតុជាអ្នកតិះដៀលបាប ។ បញ្ញាលោកហៅថា ធី បានដល់ ប្រាជ្ញា ការដឹង ការពិចារណា ការពិចារណាសព្វ ការពិចារណាធម៌ ការកំណត់ ការកំណត់មាំ ការកំណត់មាំមួន ភាពជាបណ្ឌិត ភាពជាអ្នកឈ្លាស ភាពជាអ្នកល្អិតល្អន់ ភាពជាអ្នកវាងវៃ ការគិត ការត្រិះរិះ ប្រាជ្ញាដូចផែនដី ប្រាជ្ញាជាគ្រឿងទម្លាយបង់ ( នូវកិលេស ) ប្រាជ្ញាជាគ្រឿងដឹកនាំ ការឃើញច្បាស់ ការដឹងខ្លួន ចន្ទញ

គឺបញ្ញា បញ្ញា បញ្ញិន្ទ្រិយ កម្លាំងគឺបញ្ញា សស្ត្រាគឺបញ្ញា ប្រាសាទគឺបញ្ញា ពន្លឺគឺបញ្ញា រស្មីគឺបញ្ញា ប្រទីបគឺបញ្ញា កែវគឺបញ្ញា ការមិនភាន់ច្រឡំ ការពិចារណាធម៌ ការយល់ត្រូវ ឈ្មោះថា ធីរជន ព្រោះប្រកបព្រមដោយបញ្ញានោះ ។ មួយទៀត ពួកធីរជនខាងខន្ធ ធីរជនខាងធាតុ ធីរជនខាងអាយតនៈ ធីរជនខាងបដិច្ចសមុប្បាទ ធីរជនខាងសតិប្បដ្ឋាន ធីរជនខាងសម្មប្បធាន ធីរជនខាងឥទ្ធិបាទ ធីរជនខាងឥន្ទ្រិយ ធីរជនខាងពល ធីរជនខាងពោជ្ឈង្គ ធីរជនខាងមគ្គ ធីរជនខាងផល ធីរជនខាងព្រះនិព្វាន ។ ពួកធីរជនទាំងនោះ បានពោលយ៉ាងនេះថា មនុស្សទាំងឡាយមានជីវិតតិច ជីវិតស្តួចស្តើង ជីវិតខ្លី ជីវិតប្រកបដោយខណៈ ជីវិតរហ័ស ជីវិតដាច់ ជីវិតមិនមាំមួន ជីវិតមិនតាំងនៅអស់កាលយូរ ធីរជនទាំងឡាយបានពោលយ៉ាងនេះ សម្តែងយ៉ាងនេះ ពណ៌នាយ៉ាងនេះ បំភ្លឺយ៉ាងនេះ ថ្លែងយ៉ាងនេះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ធីរជនទាំងឡាយបានពោលនូវជីវិតនេះថា តិច ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

> ព្រោះហេតុនោះ ជនក្នុងសាសនានេះ គប្បីសិក្សា គប្បីដឹង
> នូវកម្មណានីមួយក្នុងលោកថា មិនស្មើ មិនគប្បីប្រព្រឹត្តនូវកម្ម
> មិនស្មើ ព្រោះហេតុនៃកម្មមិនស្មើនោះទេ ដ្បិតថា ធីរជនទាំង
> ឡាយបានពោលនូវជីវិតនេះថា តិច ។

[ ៥០ ] តថាគតឃើញនូវពពួកសត្វនេះ ដែលលុះក្នុងអំណាចតណ្ហាក្នុងភពទាំងឡាយ កំពុងញាប់ញ័រក្នុងលោក នរជនទាំងឡាយថោកទាបមិនទាន់កន្លងតណ្ហាក្នុងភពតូច និងភពធំទាំងឡាយទេ រមែងយំរៀបរាប់ក្នុង

មាត់មច្ឆ ។

[ ៥១ ] អធិប្បាយពាក្យថា ឃើញ ( នូវពពួកសត្វ ) កំពុងញាប់ញ័រក្នុងលោក ត្រង់ពាក្យថា ឃើញ គឺឃើញដោយមំសចក្ខុក្តី ឃើញដោយទិព្វចក្ខុក្តី ឃើញដោយបញ្ញាចក្ខុក្តី ឃើញដោយពុទ្ធចក្ខុក្តី មើលឃើញ ក្រឡេកមើល សម្លឹងមើល ពិចារណាមើល ដោយសមន្តចក្ខុក្តី ។ ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក មនុស្សលោក ទេវលោក ខន្ធលោក ធាតុលោក អាយតនលោក ។ ពាក្យថា កំពុងញាប់ញ័រ គឺកំពុងញាប់ញ័រ ដោយការញាប់ញ័រព្រោះតណ្ហា កំពុងញាប់ញ័រ ដោយការញាប់ញ័រព្រោះទិដ្ឋិ កំពុងញាប់ញ័រ ដោយការញាប់ញ័រព្រោះកិលេស កំពុងញាប់ញ័រ ដោយការញាប់ញ័រព្រោះធម៌ជាគ្រឿងប្រកប កំពុងញាប់ញ័រ ដោយការញាប់ញ័រព្រោះវិបាក កំពុងញាប់ញ័រ ដោយការញាប់ញ័រព្រោះទុច្ចរិត កំពុងញាប់ញ័រ ដោយតម្រេកដែលត្រេកអរហើយ កំពុងញាប់ញ័រ ដោយទោសៈដែលប្រទូស្តហើយ កំពុងញាប់ញ័រ ដោយមោហៈដែលវង្វេងហើយ ញាប់ញ័រដោយមានះដែលជាប់ចំពាក់ហើយ ញាប់ញ័រដោយទិដ្ឋិដែលស្ទាបអង្អែលហើយ ញាប់ញ័រដោយឧទ្ធច្ចៈដែលដល់នូវសេចក្តីរាយមាយ ញាប់ញ័រដោយវិចិកិច្ឆាដែលដល់នូវសេចក្តីមិនដាច់ស្រេច ញាប់ញ័រដោយអនុស័យដែលដល់នូវកម្លាំង ញាប់ញ័រដោយលាភ ញាប់ញ័រដោយអលាភ ញាប់ញ័រដោយយស ញាប់ញ័រដោយការមិនមានយស ញាប់ញ័រដោយសេចក្តីសរសើរ ញាប់ញ័រដោយនិន្ទា ញាប់ញ័រដោយសុខ ញាប់ញ័រដោយទុក្ខ ញាប់ញ័រដោយជាតិ ញាប់ញ័រដោយជរា ញាប់ញ័រ

ដោយព្យាធិ ញាប់ញ័រដោយមរណៈ ញាប់ញ័រដោយសោកបរិទេវទុក្ខទោមនស្ស ឧបាយាសទាំងឡាយ ញាប់ញ័រដោយទុក្ខដែលកើតក្នុងនរក ញាប់ញ័រដោយទុក្ខ ដែលកើតក្នុងកំណើតតិរច្ឆាន ញាប់ញ័រដោយទុក្ខ ដែលកើតក្នុងបិត្តិវិស័យ ញាប់ញ័រដោយទុក្ខដែលកើតជាមនុស្ស ញាប់ញ័រដោយទុក្ខមានចុះកាន់គភ៌ជាហេតុ ញាប់ញ័រដោយទុក្ខ មានការឋិតនៅក្នុងគភ៌ជាហេតុ ញាប់ញ័រដោយទុក្ខ មានការចេញចាកគភ៌ជាហេតុ ញាប់ញ័រដោយទុក្ខដែលជាប់ចំពាក់របស់សត្វដែលកើតហើយ ញាប់ញ័រដោយទុក្ខដែលបណ្តាលអំពីបុគ្គលដទៃរបស់សត្វដែលកើតហើយ ញាប់ញ័រដោយទុក្ខ ព្រោះព្យាយាមសម្លាប់ខ្លួន ញាប់ញ័រដោយទុក្ខ ព្រោះព្យាយាមសម្លាប់អំពីបុគ្គលដទៃ ញាប់ញ័រដោយទុក្ខទុក្ខ ( កាយិកទុក្ខនិងចេតសិកទុក្ខ ) ញាប់ញ័រដោយសង្ខារទុក្ខ ញាប់ញ័រដោយទុក្ខ ព្រោះការប្រែប្រួល ញាប់ញ័រដោយទុក្ខ ព្រោះចក្ខុរោគ ញាប់ញ័រដោយទុក្ខ ព្រោះសោតរោគ ដោយទុក្ខ ព្រោះឃានរោគ ដោយទុក្ខ ព្រោះជិវ្ហារោគ ដោយទុក្ខ ព្រោះកាយរោគ ដោយទុក្ខ ព្រោះសីសរោគ ដោយទុក្ខ ព្រោះកណ្ណរោគ មុខរោគ ទន្តរោគ ក្អក ហឺត ឫសដូងច្រមុះ ក្តៅក្រហាយ គ្រាំគ្រា រោគក្នុងផ្ទៃ ជ្រប់ ចុះឈាម ចុកសៀត ចុះរាគ ឃ្លង់ ពក ស្រែង រីងរៃ ឆ្កួតជ្រូក ដំណួចពិស រមាស់ កម រោគក្នុងទីខ្វារដោយក្រចក ឃ្លង់ដែក ឈាមប្រមាត់ ទឹកមូត្រផ្អែម ឫសដូងដុះ បូស ឫសដូងបាត អាពាធតាំងឡើងអំពីប្រមាត់ អាពាធតាំងឡើងអំពីស្លេស្ម អាពាធតាំងឡើងអំពីខ្យល់ អាពាធកើតអំពីធាតុទាំង ៤ ប្រជុំគ្នា អាពាធកើតអំពីរដូវប្រែប្រួល អាពាធកើតអំពីរក្សា

ឥរិយាបថមិនស្មើ អាពាធកើតអំពីសេចក្តីព្យាយាម ( របស់គេមានវាយ ចង ជាដើម ) អាពាធ កើតអំពីផលនៃកម្ម ត្រជាក់ ក្តៅ ឃ្លាន ស្រេក ឧច្ចារៈ បស្សាវៈ ទុក្ខដោយសម្ផស្សនៃរបោម មូស ខ្យល់ កម្តៅថ្ងៃ ពស់តូចនិងពស់ធំ ទុក្ខព្រោះស្លាប់មាតា ទុក្ខព្រោះស្លាប់បិតា ទុក្ខព្រោះស្លាប់បងប្អូនប្រុស ទុក្ខព្រោះស្លាប់បងប្អូនស្រី ទុក្ខព្រោះស្លាប់កូនប្រុស ទុក្ខព្រោះស្លាប់កូនស្រី ទុក្ខព្រោះវិនាសពួកញាតិ វិនាសភោគៈ វិនាសគឺរោគ វិនាសសីល វិនាសទិដ្ឋិ តថាគតឃើញ មើល ក្រឡេកមើល សម្លឹងមើល ពិចារណាឃើញ ( នូវពួកសត្វ ) កំពុងញាប់ញ័រ ញាប់ញ័រចំប្រប់ ញាប់ញ័រផ្សេងៗ រន្ធត់ រន្ធត់ខ្លាំង រន្ធត់ក្រៃលែង ហេតុនោះ ( ទ្រង់ត្រាស់ថា ) ឃើញ ( នូវពួកសត្វ ) កំពុងញាប់ញ័រក្នុងលោក ។

[ ៥២ ] អធិប្បាយពាក្យថា ពួកសត្វនេះ ដែលលុះក្នុងអំណាចតណ្ហាក្នុងភពទាំងឡាយ ត្រង់ពាក្យថា ពួកសត្វ គឺជាឈ្មោះនៃសត្វ ។ ពាក្យថា តណ្ហា បានដល់ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ ពាក្យថា លុះក្នុងតណ្ហា គឺនៅក្នុងតណ្ហា ទៅតាមតណ្ហា ផ្សាយទៅតាមតណ្ហា លិចចុះក្នុងតណ្ហា ធ្លាក់ក្នុងតណ្ហា ( ត្រូវតណ្ហា ) គ្របសង្កត់ហើយ មានចិត្ត ( ត្រូវតណ្ហា ) សង្កត់សង្កិនហើយ ។ ពាក្យថា ភពទាំងឡាយ បានដល់ កាមភព រូបភព អរូបភព ហេតុនោះ ( ទ្រង់ត្រាស់ថា ) ពួកសត្វនេះ ដែលលុះក្នុងអំណាចតណ្ហាក្នុងភពទាំងឡាយ ។

[ ៥៣ ] អធិប្បាយពាក្យថា នរជនទាំងឡាយ ថោកទាប រមែងយំរៀបរាប់

ក្នុងមាត់នៃមច្ចុ ត្រង់ពាក្យថា នរជនទាំងឡាយថោកទាប គឺនរជនថោកទាប ព្រោះហេតុជាអ្នកប្រកបដោយកាយកម្មដ៏ថោកទាប ។ នរជនថោកទាប ព្រោះហេតុជាអ្នកប្រកបដោយវចីកម្មដ៏ថោកទាប ។ នរជនថោកទាប ព្រោះហេតុជាអ្នកប្រកបដោយមនោកម្មដ៏ថោកទាប ។ នរជនថោកទាប ព្រោះហេតុជាអ្នកប្រកបដោយបាណាតិបាតដ៏ថោកទាប ។ ដោយអទិន្នាទានដ៏ថោកទាប ។ ដោយកាមេសុមិច្ឆាចារៈដ៏ថោកទាប ។ ដោយមុសាវាទដ៏ថោកទាប ។ ដោយបិសុណាវាចាដ៏ថោកទាប ។ ដោយផរុសវាចាដ៏ថោកទាប ។ ដោយសម្ផប្ប-លាបៈដ៏ថោកទាប ។ ដោយអភិជ្ឈាដ៏ថោកទាប ។ ដោយព្យាបាទដ៏ថោកទាប ។ ដោយមិច្ឆាទិដ្ឋិដ៏ថោកទាប ។ ដោយសង្ខារទាំងឡាយដ៏ថោកទាប ។ ដោយកាមគុណទាំង ៥ ដ៏ថោកទាប ។ ដោយនីវរណៈទាំង ៥ ដ៏ថោកទាប ។ ដោយចេតនាដ៏ថោកទាប ។ ដោយសេចក្តីប្រាថ្នាដ៏ថោកទាប ។ នរជនថោកទាប ថោកទាបពេក ទន់ទាប លាមក អាក្រក់ កម្ទេចកំទី ព្រោះហេតុជាអ្នកប្រកបដោយការតម្កល់ចិត្តដ៏ថោកទាប ហេតុនោះ ( ទ្រង់ត្រាស់ថា ) នរជនទាំងឡាយថោកទាប ។ ពាក្យថា រមែងយំរៀបរាប់ ក្នុងមាត់នៃមច្ចុ សេចក្តីថា ពួកជនដល់នូវមច្ចុ ដល់ព្រមនូវមច្ចុ ចូលទៅរកមច្ចុ ដល់នូវមារ ដល់ព្រមនូវមារ ចូលទៅរកមារ ដល់នូវមរណៈ ដល់ព្រមនូវមរណៈ ចូលទៅរកមរណៈ រមែងយំ យំរៀបរាប់ សៅសោក លំបាក ខ្សឹកខ្សួល គក់ទ្រូង ដល់នូវសេចក្តីវង្វេងក្នុងមាត់នៃមច្ចុ ក្នុងមាត់នៃមារ ក្នុងមាត់នៃមរណៈ ហេតុនោះ ( ទ្រង់ត្រាស់ថា ) នរជនទាំងឡាយថោកទាប រមែងយំរៀបរាប់ក្នុង

មាត់នៃមច្ចុ ។

[ ៥៤ ] អធិប្បាយពាក្យថា មិនទាន់កន្លងនូវតណ្ហា ក្នុងភពតូចនិងភពធំទាំងឡាយ ត្រង់ពាក្យថា តណ្ហា បានដល់ រូបតណ្ហា ។បេ។ ធម្មតណ្ហា ។ ពាក្យថា ក្នុងភពតូចនិងភពធំទាំងឡាយ គឺក្នុងកម្មភព បុនព្ភព ឈ្មោះថា ក្នុងភពតូចនឹងភពធំ គឺថាក្នុងកាមភពឈ្មោះកម្មភព ក្នុងកាមភពឈ្មោះបុនព្ភព ក្នុងរូបភពឈ្មោះកម្មភព ក្នុងរូបភពឈ្មោះបុនព្ភព ក្នុងអរូបភពឈ្មោះកម្មភព ក្នុងអរូបភពឈ្មោះបុនព្ភព គឺថាក្នុងការកើតរឿយៗ ការទៅរឿយៗ ឧប្បត្តិរឿយៗ បដិសន្ធិរឿយៗ ការញុំាងអត្តភាពឲ្យកើតឡើងរឿយៗ ។ ពាក្យថា មិនកន្លងតណ្ហា គឺមិនកន្លងតណ្ហា មិនប្រាសចាកតណ្ហា មានតណ្ហាមិនឃ្លាតចេញ មានតណ្ហាមិនខ្ជាក់ចោល មិនរួចចាកតណ្ហា មិនលះបង់តណ្ហា មិនរលាស់ចោលតណ្ហា ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនកន្លងតណ្ហាក្នុងភពតូចនិងភពធំទាំងឡាយ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

តថាគតឃើញនូវពួកសត្វនេះ ដែលលុះក្នុងអំណាចតណ្ហាក្នុង
ភពទាំងឡាយ កំពុងញាប់ញ័រក្នុងលោក នរជនទាំងឡាយ
ថោកទាប មិនកន្លងតណ្ហាក្នុងភពតូច និងភពធំទាំងឡាយ
រមែងយំរៀបរាប់ក្នុងមាត់នៃមច្ចុ ដូច្នេះ ។

[ ៥៥ ] អ្នកទាំងឡាយ ចូរមើលពួកសត្វដែលមានសេចក្តីអាល័យ កំពុងញាប់ញ័រ ដូចពួកត្រីក្នុងទីមានទឹកតិច ទាំងមានខ្សែទឹកអស់ហើយ បុគ្គលមិនមានអាល័យ លុះឃើញទោសនេះហើយ គប្បីប្រព្រឹត្ត មិនធ្វើ

ការជាប់ចំពាក់ក្នុងភពទាំងឡាយ ដូច្នេះ ។

[ ៥៦ ] អធិប្បាយពាក្យថា អ្នកទាំងឡាយ ចូរមើលពួកសត្វដែលមានសេចក្តីអាល័យ កំពុងញាប់ញ័រ ត្រង់ពាក្យថា អាល័យ បានដល់អាល័យពីរយ៉ាង អាល័យគឺតណ្ហា ១ អាល័យគឺទិដ្ឋិ ១ ។

អាល័យគឺតណ្ហា តើដូចម្តេច ។ កំណត់ដែន កំណត់ទី កំណត់ជួរ កំណត់ជុំវិញ ការហួងហែង ការអាល័យដោយចំណែកនៃតណ្ហា មានប្រមាណណាថា នេះរបស់អញ នុ៎ះរបស់អញ ប៉ុណ្ណេះរបស់អញ មានប្រមាណប៉ុណ្ណេះរបស់អញ រូប សទ្ទ គន្ធ រស ផោដ្ឋព្វ របស់អញ គ្រឿងកម្រាល គ្រឿងស្លៀកពាក់ ខ្ញុំស្រី ខ្ញុំប្រុស ពពែ ចៀម មាន់ ជ្រូក ដំរី គោ សេះ លា ស្រែចម្ការ ប្រាក់ មាស ស្រុក និគម រាជធានី ដែក ជនបទ បន្ទាយ ឃ្លាំងរបស់អញ សូម្បីបុគ្គលប្រកាន់ផែនដីធំទាំងអស់ដោយអំណាចនៃតណ្ហា ទាំងតណ្ហាវិបរិត ១០៨ ជាកំណត់ នេះឈ្មោះថា អាល័យគឺតណ្ហា ។

អាល័យគឺទិដ្ឋិ តើដូចម្តេច ។ សក្កាយទិដ្ឋិមានវត្ថុ ២០ មិច្ឆាទិដ្ឋិ មានវត្ថុ ១០ អន្តគ្គាហិកទិដ្ឋិមានវត្ថុ ១០ ទិដ្ឋិណាមានសភាពយ៉ាងនេះ ដំណើរគឺទិដ្ឋិ ការសាំញ៉ាំគឺទិដ្ឋិ ផ្លូវលំបាកគឺទិដ្ឋិ ចម្រូងគឺទិដ្ឋិ ការញាប់ញ័រ គឺទិដ្ឋិសញ្ញោជនៈគឺទិដ្ឋិ ការកាន់ ការប្រកាន់ ប្រកាន់មាំ ការស្ទាបអង្អែល ផ្លូវអាក្រក់ ផ្លូវខុស ភាពខុស កំពង់និងអណ្តូង ការកាន់ដោយការស្វែងរកខុស ការប្រកាន់វិបរិត ការវិបល្លាស ការកាន់ខុស ការប្រកាន់ក្នុងវត្ថុមិនពិត ថាជារបស់ពិតទិដ្ឋិទាំង ៦២ ទាំងប៉ុន្មាន នេះឈ្មោះថា អាល័យគឺទិដ្ឋិ ។

ពាក្យថា ចូរមើលពួកសត្វដែលមានសេចក្តីអាល័យ កំពុងតែញាប់ញ័រ សេចក្តីថា ពួកនរជនមានសេចក្តីរវើរវាយ ក្នុងការដណ្តើមយកវត្ថុ ដែលខ្លួនអាល័យញាប់ញ័រខ្លះ កាលគេកំពុងដណ្តើមយកញាប់ញ័រខ្លះ កាលវត្ថុដែលគេដណ្តើមយកហើយញាប់ញ័រខ្លះ មានសេចក្តីរវើរវាយក្នុងការប្រែប្រួលនៃវត្ថុដែលខ្លួនអាល័យញាប់ញ័រខ្លះ កាលវត្ថុដែលកំពុងប្រែប្រួលញាប់ញ័រខ្លះ កាលវត្ថុដែលប្រែប្រួលហើយញាប់ញ័រខ្លះ ញាប់ញ័រខ្លាំង ញាប់ញ័រផ្សេងៗ រន្ធត់ រន្ធត់ខ្លាំង រន្ធត់ដោយអាការទាំងពួង អ្នកទាំងឡាយចូរមើល ចូរឃើញ ចូរក្រឡេកមើល ចូរសម្លឹងមើល ចូរពិចារណាមើលនូវពួកសត្វកំពុងញាប់ញ័រ ញាប់ញ័រដោយអាការទាំងពួង ញាប់ញ័រផ្សេងៗ រន្ធត់ រន្ធត់ខ្លាំង រន្ធត់ដោយអាការទាំងពួងយ៉ាងនេះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកទាំងឡាយចូរមើលពួកសត្វដែលមានសេចក្តីអាល័យកំពុងញាប់ញ័រ ។

[ ៥៧ ] ពាក្យថា ដូចពួកត្រីក្នុងទីមានទឹកតិចទាំងមានខ្សែទឹកអស់ហើយ សេចក្តីថា ពួកត្រីក្នុងទីមានទឹកតិច មានទឹកស្ងួតស្តើង មានទឹកអស់ហើយ ត្រូវពួកក្អែកក្តី ពួកត្រដក់ក្តី ពួកកុកក្តី បៀតបៀន ចឹកលើកឡើង ពាំស៊ី ក៏ញាប់ញ័រ ញាប់ញ័រសព្វ ញាប់ញ័រផ្សេងៗ រន្ធត់ រន្ធត់ខ្លាំង រន្ធត់សព្វសាច់ យ៉ាងណាមិញ ពួកសត្វដែលមានសេចក្តីរវើរវាយ ក្នុងការដណ្តើមយកវត្ថុដែលខ្លួនអាល័យញាប់ញ័រខ្លះ កាលគេកំពុងដណ្តើមញាប់ញ័រខ្លះ កាលវត្ថុដែលគេដណ្តើមហើយញាប់ញ័រខ្លះ មានសេចក្តីរវើរវាយក្នុងការប្រែប្រួលនៃវត្ថុដែលខ្លួនអាល័យញាប់ញ័រខ្លះ កាលវត្ថុដែលកំពុងប្រែប្រួលញាប់ញ័រខ្លះ កាលវត្ថុដែល

ប្រែប្រួលហើយ ញាប់ញ័រខ្លះ ញាប់ញ័រសព្វ ញាប់ញ័រផ្សេងៗ រន្ធត់ រន្ធត់ខ្លាំង រន្ធត់សព្វសាច់ ក៏យ៉ាងនោះដែរ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ដូចពួកត្រីក្នុងទីមានទឹកតិចទាំងមានខ្សែទឹកអស់ហើយ ។

[ ៥៨ ] ពាក្យថា បុគ្គលមិនមានអាល័យ លុះឃើញទោសនេះហើយ គប្បីប្រព្រឹត្ត គឺឃើញ មើល ថ្លឹង ពិចារណា សម្តែងឲ្យច្បាស់ ធ្វើឲ្យប្រាកដនូវទោសនេះក្នុងអាល័យទាំងឡាយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ឃើញទោសនេះ ។ ពាក្យថា អាល័យ ក្នុងបទថា បុគ្គលមិនមានអាល័យ គប្បីប្រព្រឹត្ត បានដល់អាល័យ ២ អាល័យគឺតណ្ហា ១ អាល័យគឺទិដ្ឋិ ១ ។បេ។ នេះអាល័យគឺតណ្ហា ។បេ។ នេះអាល័យគឺទិដ្ឋិ ។ បុគ្គលលះអាល័យគឺតណ្ហា រលាស់ចោលអាល័យគឺទិដ្ឋិ មិនប្រកាន់ចក្ខុ មិនប្រកាន់សោតៈ មិនប្រកាន់ឃានៈ មិនប្រកាន់ជិវ្ហា មិនប្រកាន់កាយ មិនប្រកាន់ចិត្ត មិនប្រកាន់ មិនទទួល មិនស្ទាបអង្អែល មិនប្រកាន់ស្អិតនូវរូប សំឡេង ក្លិន រស ផ្សព្វទាំងឡាយ ត្រកូល ពួកអាវាស លាភ យស សេចក្តីសរសើរ សុខ ចីវរ បិណ្ឌបាត សេនាសនៈ បរិក្ខារគឺថ្នាំជាបច្ច័យដល់ជំងឺ កាមធាតុ រូបធាតុ អរូបធាតុ កាមភព រូបភព អរូបភព សញ្ញាភព អសញ្ញាភព នេវសញ្ញានាសញ្ញាភព ឯកវោការភព ចតុវោការភព បញ្ចវោការភព អតីត អនាគត បច្ចុប្បន្ន ធម៌ដែលគេគប្បីឃើញ ឮ ប៉ះពាល់ ឬដឹង គប្បីប្រព្រឹត្ត គប្បីនៅដោយស្ងប់ស្ងាត់ គប្បីញ៉ាំងឥរិយាបថឲ្យប្រព្រឹត្តទៅ គប្បីញ៉ាំងឥរិយាបថឲ្យកើតឡើង គប្បីរក្សាឥរិយាបថ គប្បីបំពេញឥរិយាបថ គប្បីបង្គ្រប់ឥរិយាបថ ហេតុនោះ ( ទ្រង់ត្រាស់ថា )

បុគ្គលអ្នកមិនមានអាល័យ លុះឃើញទោសនេះហើយគប្បីប្រព្រឹត្ត ។

[ ៥៩ ] ពាក្យថា ក្នុងភពទាំងឡាយ ក្នុងបទថា មិនធ្វើការជាប់ចំពាក់ក្នុងភពទាំងឡាយ គឺក្នុងកាមភព រូបភព អរូបភព ។ តណ្ហា លោកហៅថា ការជាប់ចំពាក់ បានដល់សេចក្តីត្រេកអរ សេចក្តីរីករាយដ៏មានកម្លាំង ។បេ។ អភិជ្ឈា លោភៈ អកុសលមូល ។ ពាក្យថា មិនធ្វើការជាប់ចំពាក់ ក្នុងភពទាំងឡាយ បានសេចក្តីថា មិនធ្វើការជាប់ចំពាក់ក្នុងភពទាំងឡាយ មិនធ្វើសេចក្តីពេញចិត្ត សេចក្តីស្រឡាញ់ សេចក្តីត្រេកអរ សេចក្តីអត់ធន់ មិនឲ្យកើត មិនឲ្យកើតព្រម មិនបង្កើត មិនបង្កើតចំពោះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនធ្វើការជាប់ចំពាក់ក្នុងភពទាំងឡាយ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

អ្នកទាំងឡាយចូរមើលពួកសត្វ ដែលមានសេចក្តីអាល័យ
កំពុងញាប់ញ័រ ដូចពួកត្រីក្នុងទីមានទឹកតិច ទាំងមានខ្សែទឹក
អស់ហើយ បុគ្គលមិនមានអាល័យ លុះឃើញទោសនេះ
ហើយ គប្បីប្រព្រឹត្តមិនធ្វើការជាប់ចំពាក់ក្នុងភពទាំងឡាយ ។

[ ៦០ ] អ្នកប្រាជ្ញរមែងបន្ទោបង់នូវសេចក្តីពេញចិត្ត ក្នុងទីបំផុតទាំងពីរ រមែងកំណត់ដឹងផស្សៈ ហើយជាអ្នកមិនជាប់ចំពាក់ជាអ្នកតិះដៀលអំពើណាដោយខ្លួនឯង តែងមិនធ្វើអំពើនោះ មិនប្រឡាក់ក្នុងអារម្មណ៍ទាំងឡាយដែលខ្លួនធ្វើហើយឮហើយឡើយ ដូច្នេះ ។

[ ៦១ ] អធិប្បាយពាក្យថា រមែងបន្ទោបង់នូវសេចក្តីពេញចិត្តក្នុងទីបំផុត

ទាំងពីរ ត្រង់ពាក្យថា ទីបំផុតគឺផស្សៈជាទីបំផុតទី ១ ហេតុដែលកើតផស្សៈ ជាទីបំផុតទី ២ ។ អតីតកាលជាទីបំផុតទី ១ អនាគតកាលជាទីបំផុតទី ២ ។ សុខវេទនាជាទីបំផុតទី ១ ទុក្ខវេទនាជាទីបំផុតទី ២ ។ នាមជាទីបំផុតទី ១ រូបជាទីបំផុតទី ២ ។ អាយតនៈខាងក្នុង ៦ ជាទីបំផុតទី ១ អាយតនៈខាងក្រៅ ៦ ជាទីបំផុតទី ២ ។ សក្កាយជាទីបំផុតទី ១ ហេតុជាដែនកើតនៃសក្កាយជាទីបំផុតទី ២ ។ ពាក្យថា សេចក្ដីពេញចិត្ត បានដល់ សេចក្ដីពេញចិត្ត គឺកាម សេចក្ដីត្រេកអរគឺកាម សេចក្ដីរីករាយគឺកាម ចំណង់គឺកាម សេចក្ដីស្រឡាញ់គឺកាម សេចក្ដីក្ដៅក្រហាយគឺកាម សេចក្ដីងប់ងល់គឺកាម សេចក្ដីជ្រុលជ្រប់គឺកាម អន្ទង់គឺកាម យោគៈគឺកាម ឧបាទានគឺកាម នីវរណៈគឺកាមច្ឆន្ទៈក្នុងកាមទាំងឡាយ ។ ពាក្យថា រមែងបន្ទោបង់នូវសេចក្ដីពេញចិត្តក្នុងទីបំផុតទាំងពីរ បានសេចក្ដីថា រមែងបន្ទោបង់ បន្ទោបង់ចំពោះ លះបង់ កម្ចាត់បង់ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាននូវសេចក្ដីពេញចិត្តក្នុងទីបំផុតទាំងពីរ ហេតុនោះ ( ទ្រង់ត្រាស់ថា ) រមែងបន្ទោបង់សេចក្ដីពេញចិត្តក្នុងទីបំផុតទាំងពីរ ។

[ ៦២ ] អធិប្បាយពាក្យថា រមែងកំណត់ដឹងផស្សៈហើយជាអ្នកមិនជាប់ចំពាក់ ត្រង់ពាក្យថា ផស្សៈ បានដល់ចក្ខុសម្ផស្ស សោតសម្ផស្ស ឃានសម្ផស្ស ជិវ្ហាសម្ផស្ស កាយសម្ផស្ស មនោសម្ផស្ស អធិវចនសម្ផស្ស បដិឃសម្ផស្ស សុខវេទនីយសម្ផស្ស ទុក្ខវេទនីយសម្ផស្ស អទុក្ខមសុខវេទនីយសម្ផស្ស កុសលផស្សៈ អកុសលផស្សៈ អព្យាកតផស្សៈ កាមាវចរផស្សៈ រូបាវចរផស្សៈ អរូបាវចរផស្សៈ សុញ្ញតផស្សៈ អនិមិត្តផស្សៈ អប្បណិហិត

ផស្សៈ លោកិយផស្សៈ លោកុត្តរផស្សៈ អតីតផស្សៈ អនាគតផស្សៈ បច្ចុប្បន្នផស្សៈ ការប៉ះពាល់ អាការនៃការប៉ះពាល់ ការពាល់ត្រូវព្រម ភាពនៃការពាល់ត្រូវព្រមណា មានសភាពយ៉ាងនេះ នេះហៅថា ផស្សៈ ។ ពាក្យថា កំណត់ដឹងផស្សៈ គឺកំណត់ដឹងផស្សៈ ដោយបរិញ្ញា ៣ គឺញាតបរិញ្ញា ១ តិរណបរិញ្ញា ១ បហានបរិញ្ញា ១ ។ ញាតបរិញ្ញា តើដូចម្តេច ( ភិក្ខុក្នុងសាសនានេះ ) ដឹងនូវផស្សៈ គឺដឹង ឃើញថា នេះចក្ខុសម្ផស្ស នេះសោតសម្ផស្ស នេះឃានសម្ផស្ស នេះជិវ្ហាសម្ផស្ស នេះកាយសម្ផស្ស នេះមនោសម្ផស្ស នេះអធិវចនសម្ផស្ស នេះបដិឃសម្ផស្ស នេះសុខវេទនីយផស្សៈ នេះទុក្ខវេទនីយ-ផស្សៈ នេះអទុក្ខមសុខវេទនីយផស្សៈ នេះកុសលផស្សៈ នេះអកុសលផស្សៈ នេះអព្យាកតផស្សៈ នេះកាមាវចរផស្សៈ នេះរូបាវចរផស្សៈ នេះអរូបាវចរ-ផស្សៈ នេះសុញ្ញតផស្សៈ នេះអនិមិត្តផស្សៈ នេះអប្បណិហិតផស្សៈ នេះលោកិយផស្សៈ នេះលោកុត្តរផស្សៈ នេះអតីតផស្សៈ នេះអនាគតផស្សៈ នេះបច្ចុប្បន្នផស្សៈ នេះឈ្មោះថាញាតបរិញ្ញា ។

តិរណបរិញ្ញា តើដូចម្តេច ។ ( ភិក្ខុសាសនានេះ ) លុះធ្វើនូវការដឹងយ៉ាងនេះហើយ ពិចារណាផស្សៈ គឺពិចារណាថា មិនទៀង ថាជាទុក្ខ ជារោគ ជាបូស ជាព្រួញ ជាសេចក្តីលំបាក ជាអាពាធ ជារបស់អ្នកដទៃ ជារបស់ទ្រុឌទ្រោម ជាចង្រៃ ជាឧបទ្រព ជាភ័យ ជាឧបសគ្គ ជារបស់ញាប់ញ័រ ជារបស់ពុករលួយ ជារបស់មិនយឺនយូរ ជារបស់គ្មានទីពឹង គ្មានទីជ្រក គ្មានទីរឭក ជារបស់ទទេ ជារបស់រលីងធេង ជារបស់សោះសូន្យ មិនមែនជារបស់

ខ្ទួន ជាទោស ជារបស់ប្រែប្រួលធម្មតា ជារបស់ឥតខ្លឹម ជាឫសនៃទុក្ខ ជាពេជ្ឈឃាដ គ្មានសេចក្តីចម្រើន ប្រកបដោយអាសវៈ មានបច្ច័យតាក់តែងជាអាមិសៈនៃមារ មានជាតិជាធម្មតា មានជរាជាធម្មតា មានព្យាធិជាធម្មតា មានមរណៈជាធម្មតា មានសោកៈ បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាសជាធម្មតា ប្រកបដោយគ្រឿងសៅហ្មងជាធម្មតា ជារបស់កើតឡើង ជារបស់វិនាសទៅវិញ ជារបស់គួរត្រេកអរ ជាទោស ជាគ្រឿងរលាស់ចេញ នេះឈ្មោះថា តិរណបរិញ្ញា ។

បហានបរិញ្ញា តើដូចម្តេច ។ ( ភិក្ខុក្នុងសាសនានេះ ) លុះពិរណាយ៉ាងនេះហើយ ក៏លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាននូវឆន្ទរាគក្នុងផស្សៈ ។ សមដូចជាព្រះពុទ្ធដីកានេះ ដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឆន្ទរាគណា ក្នុងផស្សៈទាំងឡាយ អ្នកទាំងឡាយចូរលះបង់ឆន្ទរាគនោះចេញ កាលបើធ្វើយ៉ាងនេះបាន ផស្សៈនោះឈ្មោះថា អ្នកទាំងឡាយ បានលះបង់ហើយ ផ្តាច់ផ្តិចឫសគល់ហើយ ធ្វើមិនឲ្យមានទីកើត ដូចជាមិនមានទីកើតនៃដើមត្នោត ធ្វើមិនឲ្យកើតមាន ធ្វើឲ្យជាធម៌លែងកើតតទៅទៀតហើយ ។ នេះឈ្មោះថា បហានបរិញ្ញា ។

ពាក្យថា កំណត់ដឹងផស្សៈហើយ គឺកំណត់ដឹងផស្សៈ ដោយបរិញ្ញាទាំង ៣ នេះ ពាក្យថា មិនជាប់ចំពាក់ អធិប្បាយថា តណ្ហា លោកហៅថា ការជាប់ចំពាក់ បានដល់សេចក្តីត្រេកអរ សេចក្តីត្រេកអរមានកម្លាំង ។បេ។ អភិជ្ឈា លោភៈ អកុសលមូល ។ ការជាប់ចំពាក់នុ៎ះ បុគ្គលណាបានលះបង់ហើយ

បានផ្តាច់ផ្តិលហើយ បានរម្ងាប់ហើយ បានរលាស់ចោលហើយ ធ្វើមិនឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ បុគ្គលនោះលោកហៅថា អ្នកមិនជាប់ចំពាក់ ។ បុគ្គលនោះ មិនជាប់ចំពាក់ក្នុងរូប មិនជាប់ចំពាក់ក្នុងសំឡេង មិនជាប់ចំពាក់ក្នុងក្លិន មិនជាប់ចំពាក់ក្នុងរស មិនជាប់ចំពាក់ក្នុងផ្សព្វ មិនជាប់ចំពាក់ក្នុងត្រកូល ពួក អាវាស លាភ យស សេចក្តីសរសើរ សុខ ចីវរ បិណ្ឌបាត សេនាសនៈ គ្រឿងបរិក្ខារ គឺថ្នាំជាបច្ច័យដល់ជំងឺ កាមធាតុ រូបធាតុ អរូបធាតុ កាមភព រូបភព អរូបភព សញ្ញាភព អសញ្ញាភព នេវ-សញ្ញានាសញ្ញាភព ឯកវោការភព ចតុវោការភព បញ្ចវោការភព អតីត អនាគត បច្ចុប្បន្ន ក្នុងធម៌ទាំងឡាយដែលឃើញ ឮ ប៉ះពាល់ ឬគប្បីដឹង មិនធ្លាក់ចុះ មិនជ្រុលជ្រប់ មិនឆ្លល់ឆប់ មានការជាប់ចំពាក់ កន្លងហើយ មានការជាប់ចំពាក់ទៅប្រាសហើយ មានការជាប់ចំពាក់លះហើយ មានការជាប់ចំពាក់ខ្ជាក់ចោលហើយ មានការជាប់ចំពាក់រួចហើយ មានការជាប់ចំពាក់ លះបង់ហើយ មានការជាប់ចំពាក់រលាស់ចោលហើយ មានរាគៈកន្លងហើយ មានរាគៈទៅប្រាសហើយ មានរាគៈលះហើយ មានរាគៈខ្ជាក់ចោលហើយ មានរាគៈរួចស្រឡះហើយ មានរាគៈលះបង់ហើយ មានរាគៈរលាស់ចោលហើយ មិនមានសេចក្តីប្រាថ្នា មានទុក្ខរលត់ហើយ មានសេចក្តីត្រជាក់ ទទួលចំពោះសេចក្តីសុខ សម្រេចនៅដោយចិត្តដ៏ប្រសើរ ហេតុនោះ ( ទ្រង់ត្រាស់ថា ) កំណត់ដឹងផស្សៈហើយ ជាអ្នកមិនជាប់ចំពាក់ ។

[ ៦៣ ] អធិប្បាយពាក្យថា តិះដៀលអំពើណាដោយខ្លួនឯង មិនធ្វើ

អំពើនោះ ត្រង់ពាក្យថា អំពើណា គឺតិះដៀលអំពើណាដោយខ្លួនឯង ។ តិះដៀលខ្លួន ព្រោះហេតុ ២ យ៉ាង គឺព្រោះអំពើដែលខ្លួនធ្វើហើយ នឹងអំពើដែលខ្លួនមិនបានធ្វើហើយ ។

តិះដៀលខ្លួនឯង ព្រោះអំពើដែលខ្លួនធ្វើហើយ នឹងអំពើដែលខ្លួនមិនបានធ្វើហើយ តើដូចម្តេច ។ បុគ្គលតិះដៀលខ្លួនឯងថា កាយទុច្ចរិតអាត្មាអញបានធ្វើហើយ កាយសុចរិតអាត្មាអញមិនបានធ្វើទេ តិះដៀលខ្លួនឯងថា វចីទុច្ចរិតអាត្មាអញបានធ្វើហើយ វចីសុចរិតអាត្មាអញមិនបានធ្វើទេ ។ តិះដៀលខ្លួនឯងថា មនោទុច្ចរិតអាត្មាអញបានធ្វើហើយ មនោសុចរិតអាត្មាអញមិនបានធ្វើទេ ។ តិះដៀលខ្លួនឯងថា បាណាតិបាតអាត្មាអញបានធ្វើហើយ ការវៀរចាកបាណាតិបាតអាត្មាអញមិនបានធ្វើទេ តិះដៀលខ្លួនឯងថា អទិន្នាទានអាត្មាអញបានធ្វើហើយ ការវៀរចាកអទិន្នាទានអាត្មាអញមិនបានធ្វើទេ ។ តិះដៀលខ្លួនឯងថា កាមេសុមិច្ឆាចារៈ អាត្មាអញបានធ្វើហើយ ការវៀរចាកកាមេសុមិច្ឆាចារៈ អាត្មាអញមិនបានធ្វើទេ ។ តិះដៀលខ្លួនឯងថា មុសាវាទអាត្មាអញបានធ្វើហើយ ការវៀរចាកមុសាវាទអាត្មាអញមិនបានធ្វើទេ ។ តិះដៀលខ្លួនឯងថា បិសុណាវាចាអាត្មាអញបានធ្វើហើយ ការវៀរចាកបិសុណាវាចាអាត្មាអញមិនបានធ្វើទេ ។ តិះដៀលខ្លួនឯងថា ផរុសវាចាអាត្មាអញបានធ្វើហើយ ការវៀរចាកផរុសវាចាអាត្មាអញមិនបានធ្វើទេ ។ តិះដៀលខ្លួនឯងថា សម្ផប្បលាបៈ អាត្មាអញបានធ្វើហើយ ការវៀរចាកសម្ផប្បលាបៈ អាត្មាអញមិនបានធ្វើទេ ។ តិះដៀលខ្លួនឯងថា អភិជ្ឈាអាត្មាអញបានធ្វើហើយ អនភិជ្ឈាអាត្មាអញមិន

បានធ្វើទេ ។ តិះដៀលខ្លួនឯងថា ព្យាបាទអាត្មាអញបានធ្វើហើយ អព្យាបាទអាត្មាអញមិនបានធ្វើទេ ។ តិះដៀលខ្លួនឯងថា មិច្ឆាទិដ្ឋិអាត្មាអញបានធ្វើហើយ សម្មាទិដ្ឋិអាត្មាអញមិនបានធ្វើទេ ។ តិះដៀលខ្លួនឯងព្រោះអំពើដែលខ្លួនបានធ្វើហើយ និងអំពើដែលខ្លួនមិនបានធ្វើហើយ យ៉ាងនេះឯង ។ម្យ៉ាងទៀត បុគ្គលតិះដៀលខ្លួនឯងថា អាត្មាអញជាអ្នកមិនបានធ្វើឲ្យពេញលេញក្នុងសីលទាំងឡាយ ។ តិះដៀលខ្លួនឯងថា អាត្មាអញជាអ្នកមិនបានគ្រប់គ្រងទ្វារក្នុងឥន្រ្ទិយទាំងឡាយ ។ តិះដៀលខ្លួនឯងថា អាត្មាអញជាអ្នកមិនដឹងប្រមាណក្នុងភោជន ។ តិះដៀលខ្លួនឯងថា អាត្មាអញជាអ្នកមិនប្រកបរឿយៗនូវការភ្ញាក់រឭក ។ តិះដៀលខ្លួនឯងថា អាត្មាអញជាអ្នកមិនប្រកបដោយសតិសម្បជញ្ញៈ ។ តិះដៀលខ្លួនឯងថា សតិប្បដ្ឋានទាំង ៤ អាត្មាអញមិនបានចម្រើនទេ ។ តិះដៀលខ្លួនឯងថា សម្មប្បធានទាំង ៤ អាត្មាអញមិនបានចម្រើនទេ ។ តិះដៀលខ្លួនឯងថា ឥទ្ធិបាទទាំង ៤ អាត្មាអញមិនបានចម្រើនទេ ។ តិះដៀលខ្លួនឯងថា ឥន្រ្ទិយទាំង ៥ អាត្មាអញមិនបានចម្រើនទេ ។ តិះដៀលខ្លួនឯងថា ពលៈទាំង ៥ អាត្មាអញមិនបានចម្រើនទេ ។ តិះដៀលខ្លួនឯងថា ពោជ្ឈង្គទាំង ៧ អាត្មាអញមិនបានចម្រើនទេ ។ តិះដៀលខ្លួនឯងថា អរិយមគ្គប្រកបដោយអង្គ ៨ អាត្មាអញមិនបានចម្រើនទេ ។ តិះដៀលខ្លួនឯងថា ទុក្ខអាត្មាអញមិនបានកំណត់ទេ ។ តិះដៀលខ្លួនឯងថា សមុទយៈអាត្មាអញមិនបានលះបង់ទេ ។ តិះដៀលខ្លួនឯងថា មគ្គអាត្មាអញមិនបានចម្រើនទេ ។ តិះដៀលខ្លួនឯងថា និរោធអាត្មាអញមិនបានធ្វើឲ្យជាក់ច្បាស់ទេ ។ តិះដៀលខ្លួនឯង

ព្រោះអំពើដែលបានធ្វើហើយ និងអំពើដែលខ្លួនមិនបានធ្វើហើយយ៉ាងនេះឯង ។ អ្នកប្រាជ្ញមិនធ្វើ គឺមិនឲ្យកើត មិនឲ្យកើតព្រម មិនបង្កើត មិនបង្កើតចំពោះនូវអំពើដែលគួរតិះដៀលខ្លួនយ៉ាងនេះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកប្រាជ្ញជាអ្នកតិះដៀលអំពើណាដោយខ្លួនឯង តែងមិនធ្វើអំពើនោះ ។

[ ៦៤ ] អធិប្បាយពាក្យថា អ្នកប្រាជ្ញមិនប្រឡាក់ក្នុងអារម្មណ៍ទាំងឡាយដែលខ្លួនឃើញហើយ ឮហើយ ត្រង់ពាក្យថា ការប្រឡាក់ បានដល់ ការប្រឡាក់ពីរ ការប្រឡាក់គឺតណ្ហា ១ ការប្រឡាក់គឺទិដ្ឋិ ១ ។បេ។ នេះឈ្មោះថាការប្រឡាក់គឺតណ្ហា ។បេ។ នេះឈ្មោះថាការប្រឡាក់គឺទិដ្ឋិ ។ អ្នកមានប្រាជ្ញា បណ្ឌិតអ្នកមានការដឹងសព្វ អ្នកមានការត្រាស់ដឹង អ្នកមានញាណ អ្នកមានប្រាជ្ញាភ្លឺច្បាស់ អ្នកមានប្រាជ្ញាជាគ្រឿងទម្លាយបង់នូវកិលេស ឈ្មោះថាអ្នកប្រាជ្ញ ។ អ្នកប្រាជ្ញបានលះបង់នូវការប្រឡាក់គឺតណ្ហា រលាស់ចោលនូវការប្រឡាក់គឺទិដ្ឋិ មិនប្រឡាក់ក្នុងអារម្មណ៍ដែលឃើញហើយ មិនប្រឡាក់ក្នុងអារម្មណ៍ដែលឮហើយ មិនប្រឡាក់ក្នុងអារម្មណ៍ដែលទទួលហើយ មិនប្រឡាក់ មិនសៅហ្មង មិនចូលទៅជិតលាបក្នុងអារម្មណ៍ដែលដឹងច្បាស់ហើយ គឺជាអ្នកមិនប្រឡាក់ មិនសៅហ្មង មិនចូលទៅជិតលាប ឃ្លាតចេញ រលាស់ចេញរួចស្រឡះ ប្រាសចេញ សម្រេចនៅដោយចិត្ត ដែលប្រាសចាកដែនគឺកិលេស ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកប្រាជ្ញមិនប្រឡាក់ក្នុងអារម្មណ៍ដែលខ្លួនឃើញហើយ ឮហើយ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

អ្នកប្រាជ្ញរមែងបន្ទោបង់នូវសេចក្ដីពេញចិត្តក្នុងទីបំផុតទាំងពីរ

រមែងកំណត់ដឹងផស្សៈ ហើយជាអ្នកមិនជាប់ចំពាក់ ជាអ្នកតិះដៀលអំពើណាដោយខ្លួនឯង តែងមិនធ្វើអំពើនោះ មិនប្រឡាក់ក្នុងអារម្មណ៍ដែលខ្លួនឃើញហើយ ឮហើយ ។

[ ៦៥ ] មុនីកំណត់ដឹងសញ្ញាហើយ គប្បីឆ្លងឱឃៈបាន ជាអ្នកមិនប្រឡាក់ក្នុងសេចក្តីហួងហែងទាំងឡាយ ជាអ្នកមានព្រួញដកឡើងហើយ ប្រព្រឹត្តមិនប្រហែស មិនប្រាថ្នានូវលោកនេះនិងលោកដទៃ ។

[ ៦៦ ] អធិប្បាយពាក្យថា កំណត់ដឹងសញ្ញាហើយគប្បីឆ្លងឱឃៈបាន ត្រង់ពាក្យថា សញ្ញា បានដល់កាមសញ្ញា ព្យាបាទសញ្ញា វិហឹសាសញ្ញា នេក្ខម្មសញ្ញា អព្យាបាទសញ្ញា អវិហឹសាសញ្ញា រូបសញ្ញា សទ្ទសញ្ញា គន្ធសញ្ញា រសសញ្ញា ផោដ្ឋព្វសញ្ញា ធម្មសញ្ញា សេចក្តីសម្គាល់ អាការនៃសេចក្តីសម្គាល់ ភាពនៃអារម្មណ៍ ដែលបុគ្គលសម្គាល់ណា មានសភាពយ៉ាងនេះ នេះលោកហៅថា សញ្ញា ។ ពាក្យថា កំណត់ដឹងនូវសញ្ញា គឺកំណត់ដឹងនូវសញ្ញាដោយបរិញ្ញា ៣ គឺញាតបរិញ្ញា ១ តិរណបរិញ្ញា ១ បហានបរិញ្ញា ១ ។

ញាតបរិញ្ញា តើដូចម្តេច ។ ភិក្ខុដឹងនូវសញ្ញា គឺដឹង ឃើញថា នេះកាមសញ្ញា នេះព្យាបាទសញ្ញា នេះវិហឹសាសញ្ញា នេះនេក្ខម្មសញ្ញា នេះអព្យាបាទសញ្ញា នេះអវិហឹសាសញ្ញា នេះរូបសញ្ញា នេះសទ្ទសញ្ញា នេះគន្ធសញ្ញា នេះរសសញ្ញា នេះផោដ្ឋព្វសញ្ញា នេះធម្មសញ្ញា ដូច្នេះ នេះឈ្មោះថា ញាតបរិញ្ញា ។

តិរណបរិញ្ញា តើដូចម្តេច ។ ( ភិក្ខុ ) លុះធ្វើនូវការដឹងយ៉ាងនេះហើយ

ពិចារណានូវសញ្ញា គឺ ពិចារណាថា មិនទៀង ជាទុក្ខ ជារោគ ជាពក ជាព្រួញ ជាសេចក្ដីលំបាក ជាអាពាធ ជារបស់បុគ្គលដទៃ ជារបស់វិនាស ជាចង្រៃ ជាឧបទ្រព ជាភ័យ ជាឧបសគ្គ ជារបស់កម្រើក ជារបស់ពុករលួយ ។បេ។ ជាគ្រឿងកើតឡើង ជាគ្រឿងដល់នូវសេចក្ដីវិនាស ជាគ្រឿងត្រេកអរ ជាទោស ជាការរលាស់ចេញ នេះឈ្មោះថា តីរណបរិញ្ញា ។

បហានបរិញ្ញា តើដូចម្ដេច ។ ( ភិក្ខុ ) លុះពិចារណាយ៉ាងនេះហើយ ក៏លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមានឆន្ទរាគៈក្នុងសញ្ញា ។ សមដូចពាក្យនេះ ដែលព្រះមានព្រះភាគត្រាស់ហើយថា ម្នាលភិក្ខុទាំងឡាយ ឆន្ទរាគៈណាក្នុងសញ្ញា អ្នកទាំងឡាយចូរលះបង់ឆន្ទរាគៈនោះចេញ កាលបើធ្វើយ៉ាងនេះបាន សញ្ញានោះ ឈ្មោះថាអ្នកទាំងឡាយលះបង់ហើយ ផ្ដាច់ផ្ដិលឫសគល់ហើយ ធ្វើមិនឲ្យមានទីកើត ដូចជាទីកើតនៃដើមត្នោត ធ្វើឲ្យលែងកើតមាន ធ្វើឲ្យជាធម៌លែងកើតតទៅទៀត ។ នេះឈ្មោះថា បហានបរិញ្ញា ។

ពាក្យថា កំណត់ដឹងសញ្ញា គឺកំណត់ដឹងសញ្ញាដោយបរិញ្ញា ៣ នេះ ។ ពាក្យថា គប្បីឆ្លងឱឃៈបាន គឺគប្បីឆ្លង ឆ្លងឡើង កន្លង ប្រព្រឹត្តកន្លងនូវកាមោឃៈ ភវោឃៈ ទិដ្ឋោឃៈ អវិជ្ជោឃៈ ហេតុនោះ ( ទ្រង់ត្រាស់ថា ) កំណត់ដឹងសញ្ញាហើយគប្បីឆ្លងឱឃៈបាន ។

[ ៦៧ ] អធិប្បាយពាក្យថា មុនិជាអ្នកមិនប្រឡាក់ក្នុងសេចក្ដីហួងហែងទាំងឡាយ ត្រង់ពាក្យថា សេចក្ដីហួងហែងទាំងឡាយ បានដល់សេចក្ដីហួងហែង ២ គឺសេចក្ដីហួងហែងគឺតណ្ហា ១ សេចក្ដីហួងហែងគឺទិដ្ឋិ ១ ។បេ។

នេះឈ្មោះថាសេចក្តីហួនហែនគឺតណ្ហា ។បេ។ នេះឈ្មោះថា សេចក្តីហួនហែនគឺទិដ្ឋិ ។ ពាក្យថា មុនិ អធិប្បាយថា ការដឹងលោកហៅថា មោនៈ បានដល់ បញ្ញាការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការសន្សំធម៌ ការយល់ឃើញត្រូវ មុនិប្រកបព្រមដោយការដឹងនោះ ឈ្មោះថា អ្នកដល់នូវមោនៈ ។ មោនេយ្យៈមាន ៣ គឺកាយមោនេយ្យៈ ១ វចីមោនេយ្យៈ ១ មនោមោនេយ្យៈ ១ ។

កាយមោនេយ្យៈ តើដូចម្តេច ។ ការលះបង់កាយទុច្ចរិត ៣ យ៉ាង ឈ្មោះថា កាយមោនេយ្យៈ ។ កាយសុចរិត ៣ យ៉ាង ឈ្មោះថា កាយ-មោនេយ្យៈ ។ ញាណមានកាយជាអារម្មណ៍ ឈ្មោះថា កាយមោនេយ្យៈ ។ ការកំណត់ដឹងកាយ ឈ្មោះថា កាយមោនេយ្យៈ ។ មគ្គប្រព្រឹត្តទៅមួយអន្លើដោយការកំណត់ដឹង ឈ្មោះថា កាយមោនេយ្យៈ ។ ការលះបង់ឆន្ទរាគក្នុងកាយ ឈ្មោះថា កាយមោនេយ្យៈ ។ ចតុត្ថជ្ឈានសមាបត្តិដែលរំលត់កាយសង្ខារ ឈ្មោះថា កាយមោនេយ្យៈ ។ នេះឈ្មោះថា កាយមោនេយ្យៈ ។

វចីមោនេយ្យៈ តើដូចម្តេច ។ ការលះបង់វចីទុច្ចរិត ៤ យ៉ាង ឈ្មោះថា វចីមោនេយ្យៈ ។ វចីសុចរិត ៤ យ៉ាង ឈ្មោះថា វចីមោនេយ្យៈ ។ ញាណមានវាចាជាអារម្មណ៍ ឈ្មោះថា វចីមោនេយ្យៈ ។ ការកំណត់ដឹងវាចា ឈ្មោះថា វចីមោនេយ្យៈ ។ មគ្គប្រព្រឹត្តទៅមួយអន្លើដោយការកំណត់ដឹង ឈ្មោះថា វចីមោនេយ្យៈ ។ ការលះបង់ឆន្ទរាគក្នុងវាចា ឈ្មោះថា វចីមោ-នេយ្យៈ ។ ទុតិយជ្ឈានសមាបត្តិដែលរលត់វចីសង្ខារ ឈ្មោះថា វចីមោ-នេយ្យៈ ។ នេះឈ្មោះថា វចីមោនេយ្យៈ ។

មនោមោនេយ្យៈ តើដូចម្តេច ។ ការលះបង់មនោទុច្ចរិត ៣ យ៉ាង ឈ្មោះថា មនោមោនេយ្យៈ ។ មនោសុចរិត ៣ យ៉ាង ឈ្មោះថា មនោ-មោនេយ្យៈ ។ ញាណមានចិត្តជាអារម្មណ៍ ឈ្មោះថា មនោមោនេយ្យៈ ។ ការកំណត់ដឹងចិត្ត ឈ្មោះថា មនោមោនេយ្យៈ ។ មគ្គប្រព្រឹត្តទៅមួយអន្លើដោយការកំណត់ដឹង ឈ្មោះថា មនោមោនេយ្យៈ ។ ការលះបង់ឆន្ទរាគក្នុងចិត្ត ឈ្មោះថា មនោមោនេយ្យៈ ។ សញ្ញាវេទយិតនិរោធសមាបត្តិដែលរលត់ចិត្តសង្ខារ ឈ្មោះថា មនោមោនេយ្យៈ ។ នេះឈ្មោះថា មនោមោនេយ្យៈ ។

អ្នកប្រាជ្ញទាំងឡាយ បានពោលនូវកាយមុនិ វាចាមុនិ មនោ-
មុនិ អនាសវៈមុនិ អ្នកបរិបូណ៌ដោយមោនេយ្យធម៌ ថាជា
អ្នកលះបង់បាបទាំងអស់ ។ អ្នកប្រាជ្ញទាំងឡាយបានពោល
នូវកាយមុនិ វាចាមុនិ មនោមុនិ អនាសវមុនិ អ្នកបរិបូណ៌
ដោយមោនេយ្យធម៌ ថាជាអ្នកលាងជម្រះបាបហើយ ។

មុនិដែលប្រកបដោយមោនេយ្យធម៌ ៣ នេះ មាន ៦ គឺអាគារមុនិ ១ អនាគារមុនិ ១ សេក្ខមុនិ ១ អសេក្ខមុនិ ១ បច្ចេកមុនិ ១ មុនិមុនិ ១ ។ ពួកអាគារមុនិ តើដូចម្តេច ។ បុគ្គលទាំងឡាយណា ជាអ្នកនៅគ្រប់គ្រងផ្ទះ ឃើញបទគឺព្រះនិព្វាន ដឹងច្បាស់សាសនា បុគ្គលទាំងឡាយនេះ ឈ្មោះថា អាគារមុនិ ។ ពួកអនាគារមុនិ តើដូចម្តេច ។ បុគ្គលទាំងឡាយណា ជាអ្នកបួស ឃើញបទគឺព្រះនិព្វាន ដឹងច្បាស់សាសនា បុគ្គលទាំងឡាយនេះ ឈ្មោះថា អនាគារមុនិ ។ សេក្ខបុគ្គល ៧ ពួក ឈ្មោះថា សេក្ខមុនិ ។ ព្រះអរហន្ត

ទាំងឡាយ ឈ្មោះថា អសេក្ខមុនិ ។ ព្រះបច្ចេកពុទ្ធទាំងឡាយ ឈ្មោះថា បច្ចេកមុនិ ។ ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ លោកហៅថា មុនិមុនិ ។ បុគ្គលមានសភាពជាអ្នកល្ងង់ខ្លៅ មិនចេះដឹង មិនមែនឈ្មោះថា មុនិ ដោយការស្ងៀមទេ លុះតែបុគ្គលណាជាបណ្ឌិត កាន់យកធម៌ដ៏ប្រសើរហើយ វៀរបង់បាបទាំងឡាយ ដូចជាបុគ្គលអ្នកកាន់ជញ្ជីង បុគ្គលនោះ ឈ្មោះថា មុនិ ដោយហេតុនោះ បុគ្គលណាដឹងប្រយោជន៍ទាំង ២ ក្នុងលោក បុគ្គលនោះ ឈ្មោះថា មុនិ បុគ្គលដែលលោកហៅថា មុនិ ដោយហេតុនោះ ។

បុគ្គលណា ដឹងធម៌របស់ពួកអសប្បុរសផង ពួកសប្បុរសផង
ខាងក្នុងផង ខាងក្រៅផង ក្នុងលោកទាំងអស់ ជាបុគ្គលដែល
ទេវតានិងមនុស្សបូជាហើយ បានកន្លងបណ្តាញ គឺគ្រឿងជំពាក់
បុគ្គលនោះ ឈ្មោះថា មុនិ ។

ពាក្យថា ប្រឡាក់ បានដល់ការប្រឡាក់ ២ គឺ ការប្រឡាក់គឺតណ្ហា ១ ការប្រឡាក់គឺទិដ្ឋិ ១ ។បេ។ នេះឈ្មោះថា ការប្រឡាក់គឺតណ្ហា ។បេ។ នេះឈ្មោះថា ការប្រឡាក់គឺទិដ្ឋិ ។ មុនិលះបង់ការប្រឡាក់គឺតណ្ហា រលាស់ចោលការប្រឡាក់គឺទិដ្ឋិ មិនប្រឡាក់ មិនជាប់ មិនចូលទៅប្រឡាក់ក្នុងសេចក្តីហួងហែងទាំងឡាយ គឺជាអ្នកមិនប្រឡាក់ មិនជាប់ មិនចូលទៅប្រឡាក់ ឃ្លាតចេញ រលាស់ចេញ រួចស្រឡះ ប្រាសចេញ សម្រេចដោយចិត្តដែលប្រាសចាកដែនគឺកិលេស ហេតុនោះ ( ទ្រង់ត្រាស់ថា ) មុនិមិនប្រឡាក់ក្នុងសេចក្តីហួងហែងទាំងឡាយ ។

[ ៦៨ ] អធិប្បាយពាក្យថា មានព្រួញដកហើយ ប្រព្រឹត្តមិនប្រមាទ ត្រង់ពាក្យថា ព្រួញ បានដល់ព្រួញ ៧ គឺ ព្រួញគឺរាគៈ ព្រួញគឺទោសៈ ព្រួញគឺមោហៈ ព្រួញគឺមានះ ព្រួញគឺទិដ្ឋិ ព្រួញគឺសោក ព្រួញគឺសេចក្តីសង្ស័យ ។ ព្រួញទាំងឡាយនេះ បុគ្គលណាបានលះបង់ហើយ បានផ្តាច់ផ្តិលហើយ បានរម្ងាប់ហើយ បានគ្របសង្កត់ហើយ មិនគួរឲ្យកើតបាន បានដុតដោយភ្លើងគឺញាណហើយ បុគ្គលនោះ លោកហៅថា អ្នកមានព្រួញដកហើយ មានព្រួញកើចឡើងហើយ មានព្រួញគាស់ឡើងហើយ មានព្រួញរំលើងឡើងហើយ មានព្រួញហូតឡើងហើយ មានព្រួញហូតឡើងព្រមហើយ មានព្រួញលះចេញហើយ មានព្រួញខ្ជាក់ចោលហើយ មានព្រួញរួចស្រឡះហើយ មានព្រួញលះបង់ហើយ មានព្រួញរលាស់ចោលហើយ មិនមានសេចក្តីស្រេកឃ្លាន មានទុក្ខរលត់ហើយ មានសេចក្តីត្រជាក់ ទទួលសុខ សម្រេចនៅដោយចិត្តដ៏ប្រសើរ ហេតុនោះ ទ្រង់ត្រាស់ថា មានព្រួញដកឡើងហើយ ។ ពាក្យថា ប្រព្រឹត្តគឺចរទៅ នៅ ដើរទៅ រក្សា ត្រាច់ទៅ ញុំាងឥរិយាបថឲ្យត្រាច់ទៅ ។ ពាក្យថា មិនប្រហែស គឺធ្វើគោរពធ្វើរឿយៗ ធ្វើមិនឈប់ ប្រព្រឹត្តមិនធូរថយ មិនទម្លាក់ចោលនូវឆន្ទៈ មិនដាក់ធុរៈចោលក្នុងកុសលធម៌ទាំងឡាយ ។ សេចក្តីពេញចិត្ត ការព្យាយាម ការឧស្សាហ៍ សេចក្តីប្រឹងប្រែង ការមិនប្រព្រឹត្តត្រឡប់វិញ សតិសម្បជញ្ញៈ ការព្យាយាមដុតកម្តៅកិលេស ការព្យាយាមដ៏ឧត្តម អធិដ្ឋាន និងការប្រកបរឿយៗណាក្នុងកុសលធម៌ទាំងឡាយនោះថា ធ្វើម្តេចហ្ន៎ អាត្មាអញនឹងបំពេញសីលក្ខន្ធដែលមិនទាន់ពេញលេញ

ឬនឹងអនុគ្រោះសីលក្ខន្ធ ដែលពេញលេញស្រាប់ហើយដោយបញ្ញាក្នុងកិច្ចនោះៗ ដូច្នេះ នេះឈ្មោះថា ការមិនប្រហែសក្នុងកុសលធម៌ទាំងឡាយ ។ ថា ធ្វើម្តេចហ្ន៎ អាត្មាអញនឹងបំពេញសមាធិក្ខន្ធ ដែលមិនទាន់ពេញលេញ ឬនឹងអនុគ្រោះសមាធិក្ខន្ធ ដែលពេញលេញស្រាប់ហើយដោយបញ្ញាក្នុងកិច្ចនោះៗ ។បេ។ ក្នុងកុសលធម៌ទាំងឡាយ ។ សេចក្តីពេញចិត្ត ការព្យាយាមការឧស្សាហ៍ សេចក្តីប្រឹងប្រែង ការមិនប្រព្រឹត្តត្រឡប់វិញ សតិសម្បជញ្ញៈ ការព្យាយាមដុតកម្តៅកិលេស ការព្យាយាមដ៏ឧត្តម អធិដ្ឋាននិងការប្រកបរឿយៗណាក្នុងកុសលធម៌ទាំងឡាយនោះថា ធ្វើម្តេចហ្ន៎ អាត្មាអញគប្បីបំពេញបញ្ញាខន្ធ វិមុត្តិក្ខន្ធ វិមុត្តិញាណទស្សនក្ខន្ធ ដែលមិនទាន់ពេញលេញ ឬនឹងអនុគ្រោះវិមុត្តិញាណទស្សនក្ខន្ធ ដែលពេញលេញស្រាប់ហើយដោយបញ្ញាក្នុងកិច្ចនោះៗ ដូច្នេះ នេះឈ្មោះថា ការមិនប្រហែសក្នុងកុសលធម៌ទាំងឡាយ ។ សេចក្តីពេញចិត្ត ការព្យាយាម ការឧស្សាហ៍ សេចក្តីប្រឹងប្រែង ការមិនប្រព្រឹត្តត្រឡប់វិញ សតិសម្បជញ្ញៈ ការព្យាយាមដុតកម្តៅកិលេស ការព្យាយាមដ៏ឧត្តម អធិដ្ឋាននិងការប្រកបរឿយៗណាក្នុងកុសលធម៌ទាំងឡាយនោះថា ធ្វើម្តេចហ្ន៎ អាត្មាអញនឹងកំណត់ដឹងទុក្ខដែលមិនបានកំណត់ដឹងហើយ នឹងលះបង់កិលេសទាំងឡាយដែលមិនទាន់លះ នឹងចម្រើនមគ្គដែលមិនទាន់ចម្រើន ឬនឹងធ្វើឲ្យជាក់ច្បាស់នូវនិរោធដែលមិនទាន់ធ្វើឲ្យជាក់ ដូច្នេះ នេះឈ្មោះថា ការមិនប្រហែសក្នុងកុសលធម៌ទាំងឡាយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មានព្រួញដកហើយ ប្រព្រឹត្តមិនប្រហែស ។

[ ៦៩ ] ពាក្យថា មិនប្រាថ្នានូវលោកនេះនិងលោកដទៃ សេចក្តីថា មិនប្រាថ្នាលោកនេះ គឺអត្តភាពរបស់ខ្លួន មិនប្រាថ្នាលោកដទៃ គឺអត្តភាពដទៃ ។ មិនប្រាថ្នាលោកនេះ គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណរបស់ខ្លួន មិនប្រាថ្នាលោកដទៃ គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណដទៃ ។ មិនប្រាថ្នាលោកនេះ គឺអាយតនៈខាងក្នុង ៦ មិនប្រាថ្នាលោកដទៃ គឺអាយតនៈខាងក្រៅ ៦ ។ មិនប្រាថ្នាលោកនេះ គឺមនុស្សលោក មិនប្រាថ្នាលោកដទៃ គឺទេវលោក ។ មិនប្រាថ្នាលោកនេះ គឺកាមធាតុ មិនប្រាថ្នាលោកដទៃ គឺរូបធាតុនិងអរូបធាតុ ។ មិនប្រាថ្នាលោកនេះ គឺកាមធាតុ រូបធាតុ មិនប្រាថ្នាលោកដទៃ គឺអរូបធាតុ ។ មិនប្រាថ្នា មិនត្រូវការ មិនត្រេកអរ មិនប៉ុនប៉ង មិនស្រឡាញ់ មិនជាប់ចិត្តនូវគតិ ឧបបត្តិ បដិសន្ធិ ភព សំសារៈ ឬវដ្តៈទៀតទេ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនប្រាថ្នានូវលោកនេះនិងលោកដទៃ ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

មុនិកំណត់ដឹងសញ្ញាហើយ គប្បីឆ្លងឱឃៈបាន ជាអ្នកមិន
ប្រឡាក់ក្នុងសេចក្តីហួងហែងទាំងឡាយ ជាអ្នកមានព្រួញដក
ឡើងហើយ ប្រព្រឹត្តមិនប្រហែស មិនប្រាថ្នានូវលោកនេះ
និងលោកដទៃ ដូច្នេះ ។

**ចប់ គុហដ្ឋកសុត្តនិទ្ទេស ទី ២ ។**

# អដ្ឋកថា

# គុហដ្ឋកសុត្តនិទ្ទេសទី ២

ក្នុងគុហដ្ឋកសុត្តនិទ្ទេសទី ២ មានវិនិច្ឆ័យដូចតទៅនេះថា

[ ៣០ ] បទថា **សត្តោ** បានដល់ អ្នកជាប់ចំពាក់ ។ បទថា **គុហាយំ** បានដល់ ក្នុងកាយ ។ កាយលោកហៅថា គុហា ព្រោះជាបន្ទប់ គឺលំនៅរបស់កិលេសកាចៗ មានរាគៈជាដើម ។

បទថា **ពហុនាភិឆន្នោ** បានដល់ ដែលកិលេសមានរាគៈជាដើមបិទបាំង ដោយបទនេះ លោកពោលដល់ចំណងខាងក្នុង ។ បទថា **តិដ្ឋំ** បានដល់ តាំងនៅដោយអំណាចរាគៈជាដើម ។ កាមគុណលោកពោលថា **មោហន** ក្នុងបទថា **មោហនស្មឹ បគាឡ្ហោ** ។ ព្រោះថា ទេវតានិងមនុស្សទាំងឡាយរមែងវង្វេងក្នុងកាមគុណនេះ ទើបជាបុគ្គលឈមចុះក្នុងកាមគុណទាំងនោះ ។ ដោយបទថា **មោហនស្មឹ បគាឡ្ហោ** នេះ លោកពោលដល់ចំណងខាងក្រៅ ។

បទថា **ទូរេ វិវេកា ហិ តថាវិធោ សោ** សេចក្តីថា នរជននោះ ដែលមានយ៉ាងនោះ ជារូបនៅឆ្ងាយ គឺមិនជិតអំពីវិវេកទាំង ៣ មានកាយវិវេកជាដើម ។ ព្រោះហេតុអ្វី ព្រោះកាមទាំងឡាយក្នុងលោកមិនជារបស់ដែលនរជនលះបានដោយងាយ លោកអធិប្បាយថា ព្រោះកាមទាំងឡាយក្នុងលោករមែងមិនជារបស់ដែលនរជនលះបានងាយឡើយ ។

[ ៣១ ] បទថា **សត្តោតិ ហិ ខោ វុត្តំ** សេចក្តីថា ពាក្យថា **សត្តោ** ព្រះអង្គត្រាស់ហើយ ដោយន័យជាដើមយ៉ាងនេះថា សត្វ នរជន មាណព ។ ក្នុង

ពុទ្ធវចនៈថា **គុហាយ** ព្រះសារីបុត្តត្ថេរ អធិប្បាយថា បទថា **គុហា សាវ វត្តព្វា** សេចក្ដីថា គួរពោលដល់គុហាមុន ។ បទថា **កាយោតិ វា** ជាដើម ប្រកបបទដូច្នេះមុនថា កាយក្ដី គុហាក្ដី ។បេ។ ឆ្មាំងក្ដី ។

បណ្ដាបទទាំងនោះ បទថា **កាយោ** បានពោលទុកហើយក្នុងសតិប្បដ្ឋានកថាខាងដើម ដោយន័យជាដើមថា ឈ្មោះថា **កាយ** ព្រោះអត្ថថា ជាទីប្រជុំនៃវត្ថុគួរខ្ពើមទាំងឡាយ ។

ឈ្មោះថា **គុហា** ព្រោះអត្ថថា ជាបន្ទប់ គឺលំនៅរបស់កិលេសកាចៗ មានរាគៈជាដើម ។ អាចារ្យពួកមួយពោលថា ព្រោះអត្ថថា បិទបាំងក៏មាន ដូចក្នុងប្រយោគជាដើមថា **ទូរង្គមំ ឯកចរំ អសរីរំ គុហាសយំ** ( អ្នកទាំងឡាយណានឹងសង្រួមចិត្ត ) ដែលនៅឆ្ងាយ ជាចិត្តត្រាច់ទៅតែឯង មិនមានសរីរៈ មានគុហាគឺមហាភូតរូប ៤ ជាទីអាស្រ័យនៅ ដូច្នេះ ។

ឈ្មោះថា **ទេហោ** ព្រោះអត្ថថា ត្រូវកិលេស មានរាគៈជាដើមដុតរោល ដូចក្នុងប្រយោគជាដើមថា **តេ ហិត្វា មានុសំ ទេហំ** បុគ្គលទាំងនោះ លុះលះបង់រាងកាយជារបស់មនុស្សទៅហើយ ដូច្នេះ ។

ឈ្មោះថា **សន្ទេហោ** ព្រោះអត្ថថា ធ្វើឲ្យដឹងបាន ដូចក្នុងប្រយោគជាដើមថា **ភិជ្ជតិ បូតិ សន្ទេហោ មរណន្តំ ហិ ជីវិតំ** រាងកាយជារបស់ស្អុយ ( នេះ ) តែងបែកធ្លាយទៅវិញ ព្រោះថា ជីវិតមានសេចក្ដីស្លាប់ជាទីបំផុត ដូច្នេះ ។

ឈ្មោះថា **នាវា** ព្រោះអត្ថថា សញ្ចរទៅក្នុងសង្សារវដ្ដ ដូចក្នុងប្រយោគជាដើមថា **សិញ្ច ភិក្ខុ ឥមំ នាវំ សិត្តា តេ លហុមេស្សតិ** ម្នាលភិក្ខុ ចូរ

អ្នកស្តារទុកគឺអត្តភាពនេះ ទុកដែលអ្នកស្តារហើយនឹងដល់ត្រើយឆាប់ដូច្នេះ ។

ឈ្មោះថា **រថោ** ព្រោះអត្ថថា មានឥរិយាបថ ដូចក្នុងប្រយោគជាដើមថា **រថោ សីលបរិក្ខារោ ឈានក្ខោ ចក្កវីរិយោ** រថគឺអត្តភាព មានសីលជាគ្រឿងពាស មានឈានជាភ្លៅ មានវីរិយៈជាកង់ ដូច្នេះ ។

ឈ្មោះថា **ធជោ** ព្រោះអត្ថថា អណ្តែតប្រាកដ ដូចក្នុងប្រយោគជាដើមថា **ធជោ រថស្ស បញ្ញាណំ** ទង់ជាគ្រឿងប្រាកដរបស់រថ ដូច្នេះ ។

ឈ្មោះថា **វម្មិកោ** ព្រោះជាលំនៅរបស់ពួកកិមិជាតិ ( ដង្កូវ ) ទាំងឡាយ ដូចក្នុងប្រយោគជាដើមថា **វម្មិកោតិ ខោ ភិក្ខុ ឥមស្សេតំ ចាតុម្មហាភូតិកស្ស កាយស្ស អធិវចនំ** ម្នាលភិក្ខុ ត្រង់ពាក្យថាដំបូក នេះជាឈ្មោះរបស់កាយនេះ ដែលប្រកបដោយមហាភូតរូប ៤ ដូច្នេះ ។ ដូចដំបូកខាងក្រៅលោកហៅថា ដំបូកដោយហេតុ ៤ ប្រការ គឺរមែងខ្ជាក់ចេញ ១ ជាអ្នកខ្ជាក់ចេញ ១ ជាអ្នកសាងឡើងដោយការខ្ជាក់ចេញ ១ ជាអ្នកជាប់ស្អិតដោយជ័រដែលខ្ជាក់ចេញ ១ ពិតណាស់ ដំបូកនោះ ឈ្មោះថា ដំបូក ព្រោះអត្ថថា ខ្ជាក់នូវសត្វផ្សេងៗ មានពស់ ស្ការ កណ្តុរនិងតុកកែជាដើមចេញមក ។ ឈ្មោះថា ដំបូក ព្រោះអត្ថថា កណ្តៀរទាំងឡាយខ្ជាក់ចេញហើយ ឈ្មោះថា ដំបូក ព្រោះអត្ថថា កណ្តៀរទាំងឡាយប្រើមាត់ពាំនូវដុំដីតូចៗ មកក្អែចេញសាងឡើងកម្ពស់ប្រមាណស្មើចង្កេះខ្លះ ប្រមាណមួយជួរបុរសខ្លះ សូម្បីភ្លៀងធ្លាក់អស់ ៧ សប្តាហ៍ ក៏មិនបែកធ្លាយ ព្រោះជ័រស្អិតគឺទឹកមាត់ ដែលកណ្តៀរទាំងឡាយខ្ជាក់ចេញផ្សារភ្ជាប់ ។ ក្នុងរដូវក្តៅ កាលយកដីមួយក្តាប់អំពីដំបូកនោះ មក

ប្របាច់ដោយដៃជាវស្អិតក៏ហូរចេញ ។ ឈ្មោះថា ជំបូក ព្រោះអត្ថថា ខ្ជាក់នូវជាវស្អិតសម្រាប់ផ្សារភ្ជាប់ចេញមក ដោយប្រការដូច្នេះ ។ សូម្បីកាយនេះក៏ដូច្នោះ ឈ្មោះថា ជំបូក ព្រោះអត្ថថា ខ្ជាក់ចេញនូវរបស់មិនស្អាត មានប្រការផ្សេងៗដោយន័យជាដើមថា ខ្ជាក់ពពីកភ្នែកចេញអំពីភ្នែក ។ ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធនិងព្រះខីណាស្រពទាំងឡាយ លះនូវអត្តភាពដោយលះនូវការប្រាថ្នាក្នុងអត្តភាពនេះ ហេតុនោះទើបឈ្មោះថា ជំបូក ព្រោះអត្ថថា ជារបស់ដែលព្រះអរិយៈទាំងឡាយខ្ជាក់ហើយក៏មាន ។

ម្យ៉ាងទៀត កាយនេះដែលឆ្អឹង ៣០០ កំណាត់តាំងទុក មានសរសៃជាគ្រឿងចង មានសាច់ជាគ្រឿងបូកលាប ខ្ទប់ដោយស្បែកស្រស់ ជ្រលក់ដោយពណ៌សម្បុរ បោកបញ្ឆោតពួកសត្វទាំងអស់នោះ ដែលព្រះអរិយៈទាំងឡាយខ្ជាក់ហើយនោះឯង ដូច្នោះ ទើបឈ្មោះថា ជំបូក ព្រោះអត្ថថា ខ្ជាក់ចេញនូវការសាងឡើងក៏មាន ។ កាយនេះផ្សារភ្ជាប់ដោយជាវស្អិតគឺតណ្ហា ដែលព្រះអរិយៈទាំងឡាយខ្ជាក់ហើយនោះឯង ព្រោះតណ្ហាឲ្យកើតហើយ យ៉ាងនេះថា តណ្ហាតែងញុំាងបុរសឲ្យកើត ចិត្តរបស់បុរសនោះតែងស្ទុះទៅ ហេតុនោះទើបឈ្មោះថា ជំបូក ព្រោះអត្ថថា ខ្ជាក់ចេញនូវជាវស្អិតសម្រាប់ផ្សារក៏មាន ។

ពួកសត្វផ្សេងៗខាងក្នុងជំបូក រមែងកើត បន្ទោបង់នូវឧច្ចារៈ បស្សាវៈ ដេកឈឺ ស្លាប់ ធ្លាក់ទៅក្នុងជំបូកនោះឯង ជំបូកនោះជាផ្ទះសព្វកាល ជាបន្ទន់ ជាមន្ទីរពេទ្យ ជាទីដាក់នូវសាកសពរបស់សត្វទាំងនោះ ដោយប្រការដូច្នេះ យ៉ាងណា សូម្បីរាងកាយរបស់ក្សត្រមហាសាលជាដើមក៏ដូច្នោះ មានជន្លូវ

ប្រមាណ ៨ ម៉ឺនត្រកូល ដោយការរាប់យ៉ាងនេះគឺ ពួកសត្វដែលអាស្រ័យសម្បុរថ្ងៃ ពួកសត្វដែលអាស្រ័យស្បែក ពួកសត្វដែលអាស្រ័យសាច់ ពួកសត្វដែលអាស្រ័យសរសៃ ពួកសត្វដែលអាស្រ័យឆ្អឹង ពួកសត្វដែលអាស្រ័យខួរក្នុងឆ្អឹង រមែងកើត បន្ទាបង់ឧច្ចារៈ បស្សាវៈ ដេករសាប់រសល់ដោយជំងឺស្លាប់ធ្លាក់ទៅក្នុងកាយនោះឯង ដោយមិនគិតថា នេះជាកាយរបស់អ្នកមានអានុភាពច្រើន ដែលគ្រប់គ្រងរក្សាហើយ ប្រដាប់តាក់តែងហើយ កាយនេះជាផ្ទះប្រសូតិ ជាបង្គន់ ជាមន្ទីរពេទ្យ ជាព្រៃស្មសានរបស់សត្វទាំងនោះដោយប្រការដូច្នេះ ហេតុនោះ ទើបហៅថា ដំបូក ។

ឈ្មោះថា **និទ្ធំ** ព្រោះជាទីទុកដាក់ គឺជាសម្បុកនៃរោគជាដើម ដូចក្នុងប្រយោគជាដើមថា **រោគនិទ្ធំ បភង្គុណំ** ( រូបនេះ ) ជាទីសំណាក់នៃរោគជារបស់ពុកផុយ ដូច្នេះ ។

ឈ្មោះថា **នគរំ** ព្រោះអត្ថថា ជាទីត្រាច់ទៅនៃរបស់គាប់ចិត្តនិងមិនគាប់ចិត្ត ដូចក្នុងប្រយោគជាដើមថា **សក្កាយនគរំ** នគរគឺកាយរបស់ខ្លួនដូច្នេះ ។

ឈ្មោះថា **កុដិ** ព្រោះអត្ថថា ជាខ្ទមនៅអាស្រ័យនៃបដិសន្ធិ ដូចក្នុងប្រយោគជាដើមថា **បញ្ចទ្វារាយំ កុដិកាយំ បសក្កិយា** ( ស្វាគឺចិត្ត ) តែងចូលទៅក្នុងខ្ទមគឺអត្តភាព មានទ្វារ ៥ ដូច្នេះ ។

ឈ្មោះថា **គណ្ឌោ** ព្រោះជារបស់ស្អុយ ដូចក្នុងប្រយោគជាដើមថា **រោគោតិ ភិក្ខវេ គណ្ឌោតិ ភិក្ខវេ សល្លោតិ ភិក្ខវេ កាយស្សេតំ អធិវចនំ** ម្នាលភិក្ខុទាំងឡាយ ពាក្យថារោគ បូស សរ នេះជាឈ្មោះរបស់កាយ ដូច្នេះ ។

ឈ្មោះថា **កុម្ភោ** ព្រោះអត្ថថា បែក ដូចក្នុងប្រយោគជាដើមថា **កុម្ភូបមំ កាយមិមំ វិទិត្វា** បុគ្គលគប្បីដឹងច្បាស់នូវកាយនេះថា ដូចជាឆ្នាំង ដូច្នេះ ។

បទថា **កាយស្សេតំ អធិវចនំ** សេចក្តីថា ការពោលនេះ គឺមានប្រការដូចពោលហើយ  ជាឈ្មោះរបស់ទីប្រជុំនៃវត្ថុដែលគួរខ្ពើមទាំងឡាយដែលសម្រេចអំពីមហាភូតរូប ៤ ។

បទថា **គុហាយំ** បានដល់ ក្នុងសរីរៈ ។ បទថា **សត្តោ** បានដល់ ជាប់ចំពាក់ ។ បទថា **វិសត្តោ** បានដល់ ជាប់ចំពាក់ដោយវត្ថុផ្សេងៗមានតម្រេកក្នុងពណ៌សម្បុរជាដើម ។

ឈ្មោះថា **អាសត្តោ** ដោយអំណាចនៃតម្រេកក្នុងសណ្ឋាន ។ ឈ្មោះថា **លគ្គោ** ដោយអំណាចនៃការប្រកាន់ក្នុងកាយនោះថាស្អាត ថាសុខ ។ ឈ្មោះថា **លគ្គិតោ** ដោយអំណាចនៃការប្រកាន់ថាជាខ្លួន ។

បទថា **បលិពុទ្ធោ** បានដល់ មិនលែងដោយអំណាចនៃតម្រេកក្នុងផស្សៈតាំងនៅ ។ បទថា **ភិត្តិខីលេ** បានដល់ ចម្រឹងដែលបោះភ្ជាប់នឹងជញ្ជាំង ។ បទថា **នាគទន្តេ** បានដល់ ឈើដូចភ្លុកដំរីនោះឯង ( ដៃកែវ ) ។ បទថា **សត្តំ** បានដល់ ជាប់ត្រង់ចម្រឹងដែលបោះភ្ជាប់ត្រង់ជញ្ជាំង ។ បទថា **វិសត្តំ** បានដល់ ជាប់ត្រង់ដៃកែវ ។ បទថា **អាសត្តំ** បានដល់ ជាប់ត្រង់ស្នូចីវរ ។ បទថា **លគ្គំ** បានដល់ ជាប់ត្រង់ខ្សែស្បៀងហាលចីវរ ។ បទថា **លគ្គិតំ** បានដល់ ជាប់ត្រង់ជើងតាំង ។ បទថា **បលិពុទ្ធំ** បានដល់ ជាប់ត្រង់ជើងគ្រែ គប្បីប្រកបសេចក្តីដោយន័យជាដើមយ៉ាងនេះឯង ។

បទថា **លគ្គនាធិវចនំ** បានដល់ ការពោលដល់ការជាប់ស្អិតជាពិសេស ។ បទថា **ជដ្ឋោ** បានដល់ ដែលកិលេសទាំងឡាយមានប្រការដូចពោលបិទបាំងទុក ។ ឈ្មោះថា **ឧច្ឆន្នោ** ព្រោះបិទបាំងទុកខាងលើដោយកើតឡើងរឿយៗ ។ បទថា **អាវុតោ** បានដល់ ខ្ទប់ទុក ។ បទថា **និវុតោ** បានដល់ រាំងទុក ។ បទថា **ឱផុតោ** បានដល់ បិទគ្របទុក ។ បទថា **បិហិតោ** បានដល់ គ្របទុក ដូចគ្របថ្នាំងបាយដោយភាជនៈ ។ បទថា **បដិច្ឆន្នោ** បានដល់ បិទក្តិត ។ បទថា **បដិកុជ្ជិតោ** បានដល់ ធ្វើឲ្យមានមុខចុះក្រោម គឺផ្កាប់ ។

បណ្តាបទទាំងនោះ បទថា **ជដ្ឋោ** ដូចស្មៅនិងស្លឹកឈើជាដើមបាំងទុក ។ ឈ្មោះថា **ឧច្ឆន្នោ** ដូចស្ពានគ្របនូវស្ទឹង ។ ឈ្មោះថា **អាវុតោ** ដូចរាំងផ្លូវសញ្ចររបស់មហាជន ។

[ ៣២ ] បទថា **វិនិពទ្ធោ មានវសេន** សេចក្តីថា ជាអ្នកជាប់ចំពាក់ក្នុងអារម្មណ៍ផ្សេងៗ តាំងនៅដោយមានះនិងអតិមានះ មានបែបផ្សេងៗ ។

បទថា **បរាមដ្ឋោ ទិដ្ឋិវសេន** សេចក្តីថា ជាអ្នកប្រកាន់ គឺស្ទាបអង្អែលកាន់យកដោយទិដ្ឋិ ៦២ ។

បទថា **វិក្ខេបគតោ ឧទ្ធច្ចវសេន** សេចក្តីថា ជាអ្នកដល់ គឺចូលដល់នូវការរាយមាយនូវចិត្តដោយមិនតាំងមាំក្នុងអារម្មណ៍ ។

បទថា **អនិដ្ឋង្គតោ វិចិកិច្ឆាវសេន** សេចក្តីថា ជាបុគ្គលមិនដល់នូវការដាច់ស្រេចដោយវិចិកិច្ឆា ពោលគឺសេចក្តីសង្ស័យក្នុងព្រះរតនត្រ័យជាដើម ។

បទថា **ថាមគតោ អនុសយវសេន** សេចក្តីថា ជាអ្នកដល់ គឺចូលដល់ការៈមាំទាំ រមែងតាំងនៅដោយអំណាចកិលេសដែលដេកត្រាំ ដែលមិនទាន់លះបាន ព្រោះនាំចេញបានលំបាក ។

បទថា **រូបូបាយំ** សេចក្តីថា ចូលដល់រូបហើយ ធ្វើឲ្យជាអារម្មណ៍ដោយអំណាចចូលដល់តណ្ហានិងទិដ្ឋិ ។ បទថា **វិញ្ញាណំ តិដ្ឋមានំ** សេចក្តីថា វិញ្ញាណដែលមានរូបជាអារម្មណ៍ កាលតាំងនៅ រមែងតាំងនៅក្នុងអារម្មណ៍នោះ ។ បទថា **រូបារម្មណំ រូបប្បតិដ្ឋំ** សេចក្តីថា ហួងហែងនូវរូបនោះឯងឲ្យជាអារម្មណ៍ ធ្វើរូបនោះឯងឲ្យជាទីតាំង ។ បទថា **នន្ទូបសេវនំ** បានដល់វិញ្ញាណដែលស្រោចដោយទឹក គឺតណ្ហារបស់បុគ្គលដែលមានបីតិ ។

បទថា **វុឌ្ឍឹ** បានដល់ សេចក្តីចម្រើន ។ បទថា **វិរូឡ្ហឹ** បានដល់ ការដុះដាលតទៅដោយអំណាចនៃជវន ។

បទថា **វេបុល្លំ** បានដល់ ការបរិបូណ៌ដោយអំណាចតទារម្មណៈ ។ បទថា **អត្ថិ រាគោ** ជាដើម ជាឈ្មោះរបស់លោភៈនោះឯង ដ្បិតថាសេចក្តីលោភនោះ លោកហៅថា **រាគៈ** ដោយអំណាចនៃការត្រេកអរ ហៅថា **នន្ទិ** ដោយអំណាចនៃការត្រេកត្រអាល ហៅថា **តណ្ហា** ដោយអំណាចនៃការប្រព្រឹត្តទៅដោយការចង់បាន ។

បទថា **បតិដ្ឋិតំ តត្ថ វិញ្ញាណំ វិរូឡ្ហំ** សេចក្តីថា តាំងនៅនិងដុះដាលដោយភាពជាធម្មជាតិ អាចញ៉ាំងកម្មឲ្យស្ទុះទៅ ហើយទាញបដិសន្ធិមក ។ បទថា **យត្ថ** ជាសត្តមីវិភត្តិ ចុះក្នុងអត្ថថា វដ្តៈប្រព្រឹត្តទៅក្នុងភូមិ ៣ ។ ម្យ៉ាង

ទៀត បទថា **យត្ថ** នេះ ក្នុងបទដំបូងគ្រប់ៗបទ ជាសត្តមីវិភត្តិ ។

បទថា **អត្ថិ តត្ថ សង្ខារានំ វុឌ្ឍិ** នេះ លោកពោលសំដៅយកសង្ខារទាំងឡាយដែលជាហេតុនៃវដ្តៈតទៅ នៃនាមរូបដែលតាំងនៅក្នុងវិបាកវដ្តៈនេះ ។ បទថា **យត្ថ អត្ថិ អាយតឹ បុនព្ភវាភិនិព្វត្តិ** សេចក្ដីថា ការកើតក្នុងភពថ្មីតទៅមានក្នុងឋានៈណា ។

បណ្ដាសូត្រទាំងនោះ គប្បីជ្រាបថា សូត្រដំបូងពោលដោយអំណាចការបានអារម្មណ៍មានរូបជាដើម ។ សូត្រទី ២ ពោលដោយអំណាចការត្រេកអរក្រៃលែងក្នុងអារម្មណ៍នោះឯង ។ សូត្រទី ៣ ពោលដោយអំណាចជាទីតាំងនៃវិញ្ញាណ ។ សូត្រទី ៤ ពោលដោយអំណាចអាហារ ៤ យ៉ាង និងដោយអំណាចជាទីតាំងនៃវិញ្ញាណដែលជាកុសលនិងអកុសល ។

បទថា **យេភុយ្យេន** បានដល់ ច្រើនសន្ធឹកសន្ធាប់ ។ បទថា **មុយ្ហន្តិ** បានដល់ រមែងដល់នូវការវង្វេង ។ បទថា **សម្មុយ្ហន្តិ** បានដល់ រមែងវង្វេងដោយពិសេស ។ បទថា **សម្បមុយ្ហន្តិ** បានដល់ រមែងវង្វេងដោយអាការៈទាំងពួង ។ម្យ៉ាងទៀត រមែងវង្វេង ព្រោះអាស្រ័យរូបារម្មណ៍ រមែងភ្លេចស្មារតី ព្រោះអាស្រ័យសទ្ទារម្មណ៍ រមែងភាន់កាំងគំនិត ព្រោះអាស្រ័យមុត្តារម្មណ៍ គឺអារម្មណ៍ដែលជ្រាបហើយ ។

បទថា **អវិជ្ជាយ អន្ធីកតា** សេចក្ដីថា ដែលអវិជ្ជាគឺការមិនដឹងក្នុងឋានៈ ៨ ធ្វើឲ្យខ្វាក់ ។ ម្យ៉ាងទៀត បាឋៈថា **គតា** ក៏មានសេចក្ដីថា ចូលដល់នូវការខ្វាក់ ។

បទថា **បគាឡ្ហោ** បានដល់ ចូលទៅហើយ ។ បទថា **ឱគាឡ្ហោ** បានដល់ ចូលទៅកាន់ចំណែកខាងក្រោម ។ បទថា **អជ្ឈោគាឡ្ហោ** បានដល់ ចូលទៅសិក្សា គឺគ្របសង្កត់ជាពិសេស ។ បទថា **និន្នោ** បានដល់ ឱនមុខចូលទៅ ។ម្យ៉ាងទៀត ឈ្មោះថា **ឱគាឡ្ហោ** ដោយការជាប់ជំពាក់ដោយការឃើញ ឈ្មោះថា **អជ្ឈោគាឡ្ហោ** ដោយការជាប់ជំពាក់ដោយការស្តាប់ឈ្មោះថា **និន្នោ** ដោយការជាប់ជំពាក់ដោយការពោល ម្យ៉ាងទៀត វៀរនូវការជាប់ជំពាក់ជាមួយសប្បុរស ឈ្មោះថា **ឱគាឡ្ហោ** វៀរនូវការស្តាប់ព្រះសទ្ធម្ម ឈ្មោះថា **អជ្ឈោគាឡ្ហោ** ឬវៀរការបដិបត្តិធម៌សមគួរដល់ធម៌ ឈ្មោះថា **និន្នោ** ។

[ ៣៣ ] បទថា **វិវេកា** បានដល់ ស្ងាត់គឺទទេ ។ បទថា **តយោ** ជាពាក្យប្រាប់ចំនួនរាប់ ។ បទថា **កាយវិវេកោ** បានដល់ ការស្ងាត់គឺវៀរ គឺមិនខ្វល់ខ្វាយផ្លូវកាយ ។ សូម្បីក្នុងចិត្តវិវេកជាដើមក៏ន័យនេះឯង ។

បទថា **ឥធ ភិក្ខុ** សេចក្តីថា ឈ្មោះថា **ភិក្ខុ** ព្រោះឃើញភ័យក្នុងសង្សារវដ្តក្នុងសាសនានេះ ។

បទថា **វិវិត្តំ** បានដល់ ស្ងាត់ គឺប្រាសចាកសំឡេង សេចក្តីថា មានសំឡេងគឹកកងតិច ។ ក្នុងគម្ពីរវិភង្គ លោកក៏សំដៅយកការស្ងាត់នេះឯងពោលថា ត្រង់ពាក្យថា ស្ងាត់ សេចក្តីថា បើសេនាសនៈនៅក្នុងទីជិត តែសេនាសនៈនោះ មិនច្រឡូកច្រឡំដោយពួកគ្រហស្ថនិងពួកបព្វជិត ព្រោះហេតុនោះ ទីនោះឈ្មោះថា ស្ងាត់... ដូច្នេះ ។ ឈ្មោះថា **សេនាសនំ** ព្រោះ

អត្ថថា ជាទីដេកនិងទីអង្គុយ ពាក្យថា សេនាសនៈនេះជាឈ្មោះរបស់គ្រែនិងតាំងជាដើម ។ ព្រោះហេតុនោះ ទើបលោកពោលទុក ( ក្នុងអភិធម្មវិភង្គ ) ថា ត្រង់ពាក្យថា សេនាសនៈ គឺគ្រែឈ្មោះថា សេនាសនៈ តាំងឈ្មោះថា សេនាសនៈ ពូកឈ្មោះថា សេនាសនៈ ខ្នើយឈ្មោះថា សេនាសនៈ វិហារឈ្មោះថា សេនាសនៈ អឌ្ឍយោគឈ្មោះថា សេនាសនៈ ប្រាសាទឈ្មោះថា សេនាសនៈ ប៉មឈ្មោះថា សេនាសនៈ រោងឈ្មោះថា សេនាសនៈ ទីពួនឈ្មោះថា សេនាសនៈ គុហាឈ្មោះថា សេនាសនៈ គល់ឈើឈ្មោះថា សេនាសនៈ គុម្ពប្ញស្សីក៏ឈ្មោះថា សេនាសនៈ ពុំនោះសោត ពួកភិក្ខុដើរចូលទៅក្នុងទីណា ទីទាំងអស់នុ៎ះ ក៏ឈ្មោះថា សេនាសនៈដែរ ដូច្នេះ ។ មួយវិញទៀត សេនាសនៈមាន ៤ ប្រភេទគឺ ទីនេះគឺវិហារ អឌ្ឍយោគ ប្រាសាទ ប្រាសាទត្រង់ល គុហាឈ្មោះថា សេនាសនៈ គឺវិហារ របស់ប្រើ នេះគឺគ្រែ តាំង ពូក ខ្នើយ ឈ្មោះថា សេនាសនៈ គឺគ្រែនិងតាំង របស់ប្រើ នេះគឺស្រោមខ្នើយ កម្រាលស្បែក កម្រាលធ្វើអំពីស្មៅ កម្រាលស្លឹកឈើ ឈ្មោះថា សេនាសនៈគឺសន្ថត ឬថាភិក្ខុទាំងឡាយចូលទៅក្នុងទីណា ទីនោះឈ្មោះថា សេនាសនៈ គឺឱកាស ។ សេនាសនៈទាំងអស់នោះ លោកកាន់យកដោយសព្ទថា សេនាសនៈទាំងអស់ ។ ព្រះសារីបុត្តត្ថេរ កាលសម្តែងសេនាសនៈ ដែលសមគួរដល់ភិក្ខុដែលមកអំពីទិសទាំង ៤ ក្រៅអំពីនេះ ទើបពោលពាក្យថា **អរញ្ញំ រុក្ខមូលំ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **អរញ្ញំ** សេចក្តីថា ព្រៃដែលមកដោយអំណាចនៃភិក្ខុនីទាំងឡាយថា ត្រង់ពាក្យថា ព្រៃ គឺទីទាំងអស់នុ៎ះ ដែលចេញផុត

អំពីសសរគោលខាងក្រៅ ឈ្មោះថា ព្រៃ ដូច្នេះ ។ សេនាសនៈដែលតាំងនៅក្នុងព្រៃ មានចម្ងាយពីស្រុក ៥០០ ជួរធ្នូកំណត់យ៉ាងជិតបំផុត ដូច្នេះ ។ លក្ខណៈនៃសេនាសនៈព្រៃនោះ បានពោលទុកហើយក្នុងធុតង្គនិទ្ទេសក្នុងវិសុទ្ធិមគ្គ ។

បទថា **រុក្ខមូលំ** សេចក្ដីថា ទីស្ងាត់ មានម្លប់ក្រាស់ណាមួយ ឈ្មោះថា គល់ឈើ ។

បទថា **បព្វតំ** បានដល់ ភ្នំថ្ម ។ ភ្នំថ្មនោះ ភិក្ខុធ្វើកិច្ចដោយទឹកត្រង់ថ្មដែលដក់ទឹក ហើយនៅត្រង់ម្លប់ដើមឈើដែលត្រជាក់ ឲ្យខ្យល់ត្រជាក់ដែលបក់មកអំពីទិសផ្សេងៗពាល់ត្រូវហើយចិត្តរមែងចុះស៊ប់ ។ ទឹកលោកហៅថា **កំ** ក្នុងបទថា **កន្ទរំ** ។ ប្រទេសត្រង់ភ្នំ ដែលទឹកនោះទ្រោះហើយ គឺដែលទឹកទម្លាយហើយ លោកហៅថា ញកភ្នំ លោកហៅថា ជ្រោះភ្នំ លោកហៅថា រូងភ្នំ ត្រង់ញកភ្នំនោះមានខ្សាច់ដូចគ្នានឹងជុំប្រាក់ ។ មានដងព្រៃ ដូចពិដាននៃកែវមណីខាងលើ មានទឹកហូរដូចគ្នានឹងដុំកែវមណី កាលភិក្ខុឡើងកាន់ញកភ្នំបែបនេះ ផឹកនូវទឹក ជម្រះនូវរាងកាយ ពូនខ្សាច់ ក្រាលសំពត់បំសុកូលចីវរ អង្គុយធ្វើសមណធម៌ ចិត្តរមែងចុះស៊ប់ ។

បទថា **គិរិគុហំ** បានដល់ រវាងភ្នំពីរ ឬញកភ្នំធំ ដូចគ្នានឹងឧម្មង្គក្នុងទីមួយនោះឯង ។ លក្ខណៈរបស់ **សុសានំ** ( ព្រៃស្មសាន ) បានពោលទុកហើយក្នុងវិសុទ្ធិមគ្គ ។

បទថា **វនបត្ថំ** បានដល់ ដែលរំលងដែនស្រុកចេញទៅ មិនជាទីចូល

ទៅរបស់មនុស្សទាំងឡាយ មិនមែនជាទីក្ជួររាស់ សាបព្រោះមិនកើត ព្រោះហេតុនោះឯង ទើបលោកពោលពាក្យជាដើមថា ពាក្យថា **វនបត្ថំ** នេះជាឈ្មោះរបស់សេនាសនៈទាំងឡាយដែលឆ្ងាយ ។

បទថា **អព្ភោកាសំ** បានដល់ មិនមានអ្វីប្រក់បាំង កាលភិក្ខុត្រូវការក៏បោះក្លស់នៅក្នុងទីនេះបាន ។

បទថា **បលាលបុញ្ជំ** បានដល់ ពំនូកចំបើង ។ ភិក្ខុទាញយកចំបើងចេញព័ទ្ធចំបើងធំធ្វើទីលំនៅ ដូចគ្នានឹងញកភ្នំ សូម្បីយកចំបើងដាក់ខាងលើគុម្ពឈើជាដើម អង្គុយធ្វើសមណធម៌ខាងក្រោម ( ក៏ឈ្មោះថាពំនូកចំបើង ) ។ ពាក្យជាដើមថា **កាយេន ច វិវិត្តោ** ដូច្នេះ លោកពោលសំដៅយកសេនាសនៈទាំងអស់ មានអធិប្បាយថា ភិក្ខុណាមួយអធិដ្ឋានចង្ក្រមឲ្យប្រព្រឹត្តទៅ ។

បទថា **ឥរិយតិ** បានដល់ ឲ្យឥរិយាបថប្រព្រឹត្តទៅ ។ បទថា **វត្តតិ** បានដល់ ញុំាងការប្រព្រឹត្តទៅនៃឥរិយាបថឲ្យកើតឡើង ។ បទថា **ចាលេតិ** បានដល់ រក្សាឥរិយាបថ ។ បទថា **យបេតិ** បានដល់ ប្រព្រឹត្តទៅ ។ បទថា **យាបេតិ** បានដល់ ឲ្យប្រព្រឹត្តទៅ ។ បទថា **បឋមជ្ឈានំ សមាបន្នស្ស** បានដល់ ជាអ្នកមានការដល់ព្រមដោយឈានកុសល ។

បទថា **នីវរណេហិ ចិត្តំ វិវិត្តំ** សេចក្តីថា លោកពោលថា ភិក្ខុចូលបឋមជ្ឈាន ចិត្តស្ងាត់ចាកនីវរណៈទាំងឡាយដើម្បីសម្តែងថា ចិត្តសូម្បីស្ងាត់ចាកនីវរណៈដោយឧបចារៈ ក៏ឈ្មោះថា ស្ងាត់ដោយល្អខាងក្នុងអប្បនា ។

ពាក្យថា ភិក្ខុអ្នកសម្រេចទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន មានចិត្ត

*ស្ងាត់ចាកវិតក្ក វិចារៈ បីតិ សុខនិងទុក្ខ ក៏មានន័យដូចគ្នា ។*

*បទថា* **រូបសញ្ញាយ** *បានដល់ ចាកសញ្ញាក្នុងរូបឈាន ១៥ ដោយអំណាចកុសលវិបាកនិងកិរិយា ។ បទថា* **បដិឃសញ្ញាយ** *បានដល់ បដិឃសញ្ញា ពោលគឺទ្វិបញ្ចវិញ្ញាណ ១០ ដោយអំណាចកុសលវិបាកនិងអកុសលវិបាកដែលកើតឡើង ព្រោះចក្ខុនិងរូបជាដើមប៉ះខ្ទប់គ្នា ។*

*បទថា* **នានត្តសញ្ញាយ** *សេចក្ដីថា ចិត្តរមែងស្ងាត់ គឺទទេចាកកាមាវចរសញ្ញា ៤៤ ដែលប្រព្រឹត្តទៅក្នុងអារម្មណ៍ផ្សេងៗ ។*

*ក្នុងបទថា* **អាកាសានញ្ចាយតនំ សមាបន្នស្ស** *នេះឈ្មោះថា* **អនន្ត** *ព្រោះអត្ថថា វត្ថុនោះមិនមានទីបំផុត ។ អាកាសមិនមានទីបំផុត ឈ្មោះថា* **អាកាសានន្ត** *។ អាកាសានន្តៈនោះឯងជា* **អាកាសានញ្ច** *។ អាកាសានញ្ចៈនោះផង ជាអាយតនៈនៃឈានមួយអន្លើដោយសម្បយុត្តធម៌នោះ ដោយអត្ថថា តាំងមាំផង ដូចលំនៅនៃទេវតាទាំងឡាយ ឈ្មោះថា ទេវាយតនៈ ហេតុនោះទើបឈ្មោះថា* **អាកាសានញ្ចាយតន** *។ ពាក្យនេះជាឈ្មោះរបស់ឈានដែលមានកសិណុគ្ឃាដិមាកាសជាអារម្មណ៍ ភិក្ខុដែលសម្រេចអាកាសានញ្ចាយតនឈាននោះគឺបុគ្គលអ្នកសម្រេចអរូបឈានកុសលនិងអរូបឈានកិរិយា ។*

*បទថា* **រូបសញ្ញាយ** *បានដល់ ចាករូបាវចរឈាន និងចាកអារម្មណ៍នៃរូបាវចរឈាននោះដោយមាតិកា គឺសញ្ញា ។ ដ្បិតថាសូម្បីរូបាវចរឈានលោកក៏ហៅថា រូប ដូចក្នុងប្រយោគជាដើមថា* **រូបី រូបានិ បស្សតិ** *បុគ្គលមានរូបាវចរឈានរមែងឃើញរូប ដូច្នេះ សូម្បីអារម្មណ៍នៃរូបាវចរឈាននោះ ក៏*

លោកហៅថា រូប ដូចក្នុងប្រយោគជាដើមថា **ពហិទ្ធា រូបានិ បស្សតិ សុវណ្ណ-ទុព្វណ្ណានិ** ឃើញរូបខាងក្រៅដែលមានពណ៌ល្អនិងមានពណ៌មិនល្អ ដូច្នេះ ។ ព្រោះហេតុនោះ ក្នុងទីនេះ ទើបពាក្យនេះជាឈ្មោះរបស់រូបាវចរឈានដោយមាតិកា គឺសញ្ញាយ៉ាងនេះថា សញ្ញាក្នុងរូប ឈ្មោះថា **រូបសញ្ញា** ។ ឈ្មោះថា **រូបសញ្ញា** ព្រោះអត្ថថា ឈាននោះមានសញ្ញាក្នុងរូប អធិប្បាយថា រូបជាឈ្មោះរបស់ឈាននោះ ។ម្យ៉ាងទៀត ពាក្យនេះគប្បីជ្រាបថាជាឈ្មោះនៃអារម្មណ៍របស់ឈាននោះ មានបឋវីកសិណជាដើមដោយប្រការដូច្នេះ ។ ចាកសញ្ញា ពោលគឺឈាន ១៥ យ៉ាង ដោយអំណាចកុសល វិបាក កិរិយានេះ និងចាករូបសញ្ញា ពោលគឺអារម្មណ៍ ៨ យ៉ាង ដោយអំណាចបឋវីកសិណជាដើមនេះ ។

បទថា **បដិឃសញ្ញាយ** បានដល់ សញ្ញាដែលកើតដោយការប៉ះខ្ទប់គ្នានៃវត្ថុមានចក្ខុវត្ថុជាដើម និងអារម្មណ៍មានរូបជាដើម ឈ្មោះបដិឃសញ្ញា ។ ពាក្យនេះជាឈ្មោះរបស់រូបសញ្ញាជាដើម ដូចព្រះតម្រាស់ ( ក្នុងអភិធម្មវិភង្គ ) ថា បដិឃសញ្ញា តើដូចម្ដេច ។ រូបសញ្ញា សទ្ទសញ្ញា គន្ធសញ្ញា រសសញ្ញា ផោដ្ឋព្វសញ្ញា នេះហៅថា បដិឃសញ្ញា ដូច្នេះ ។ សញ្ញាទាំងនោះជាកុសលវិបាក ៥ ជាអកុសលវិបាក ៥ ។ ចាកបដិឃសញ្ញានោះ ។

បទថា **នានត្តសញ្ញាយ** បានដល់ ចាកសញ្ញាដែលប្រព្រឹត្តទៅក្នុងអារម្មណ៍ផ្សេងៗ ឬចាកសញ្ញាដែលមានអារម្មណ៍ផ្សេងៗ ដូចព្រះតម្រាស់ថា នានត្ត-សញ្ញា តើដូចម្ដេច ។ ការសម្គាល់ អាការសម្គាល់ភាពនៃការ សម្គាល់ណា

របស់បុគ្គលអ្នកមិនចូលកាន់ ( រូបសមាបត្តិ ) ជាអ្នកព្រមព្រៀងដោយមនោ-ធាតុក្តី ព្រមព្រៀងដោយមនោវិញ្ញាណធាតុក្តី នេះហៅថា នានត្តសញ្ញា ដូច្នេះ ។ ព្រះមានព្រះភាគត្រាស់ចែកទុកក្នុងគម្ពីរវិភង្គដោយប្រការដូច្នេះ ។ សញ្ញាទាំងនោះ លោកបំណងយកក្នុងទីនេះ សញ្ញាដែលសង្គ្រោះដោយមនោធាតុនិងមនោវិញ្ញាណធាតុរបស់ភិក្ខុដែលមិនទាន់បានសម្រេច រមែងប្រព្រឹត្តទៅក្នុងអារម្មណ៍ដែលមានការផ្សេងគ្នា គឺមានសភាវៈផ្សេងគ្នា មានរូបនិងសំឡេងជាដើម ។

ព្រោះសញ្ញា ៤៤ គឺ កាមាវចរកុសលសញ្ញា ៗ អកុសលសញ្ញា ១២ កាមាវចរកុសលវិបាកសញ្ញា ១១ អកុសលវិបាកសញ្ញា ២ កាមាវចរកិរិយាសញ្ញា ១១ ទាំងនេះ មានសេចក្តីផ្សេងគ្នា មានសភាវៈផ្សេងគ្នា មិនដូចគ្នាដូច្នេះទើបហៅថា **នានត្តសញ្ញា** ។ ចាកនានត្តសញ្ញានោះ ។

បទថា **ចិត្តំ វិវិត្តំ ហោតិ** សេចក្តីថា ភិក្ខុដែលសម្រេចអាកាសានញ្ចាយតនឈាន មានចិត្តស្ងាត់ គឺវៀរ គឺប្រាសចាកការខ្វល់ខ្វាយ ចាកសញ្ញាទាំងឡាយ ពោលគឺរូបសញ្ញា បដិឃសញ្ញានិងនានត្តសញ្ញា ។

បទថា **វិញ្ញាណញ្ចាយតនំ** សេចក្តីថា ឈានឈ្មោះថា វិញ្ញាណញ្ចា-យតនៈ ព្រោះអត្ថថា មានវិញ្ញាណនោះឯងជាអារម្មណ៍ដោយអត្ថថា ជាអារម្មណ៍ដែលតាំងមាំ ។ ពាក្យនេះជាឈ្មោះរបស់ឈាន ដែលមានវិញ្ញាណ ដែលប្រព្រឹត្តទៅក្នុងអាកាសជាអារម្មណ៍ ។ ភិក្ខុអ្នកសម្រេចឈាននោះ មានចិត្តស្ងាត់ចាកអាកាសានញ្ចាយតនសញ្ញា ដែលមានប្រការដូចពោលហើយ ។

ក្នុងបទថា **អាកិញ្ចញ្ញាយតនំ** នេះ ឈានឈ្មោះថា អាកិញ្ចនៈ ព្រោះអត្ថថា មិនមានសេចក្តីកង្វល់ មានអធិប្បាយថា ឈាននោះមិនមានអ្វីមួយដែលសេសសល់ ដោយហោចសូម្បីត្រឹមតែកង្គខណៈ ។ ភាវៈនៃឈានដែលមិនមានសេចក្តីកង្វល់ ឈ្មោះថា អាកិញ្ចញ្ញៈ ពាក្យនេះជាឈ្មោះរបស់អាកាសានញ្ចាយតនឈាន ដែលប្រាសចាកវិញ្ញាណ ។ ឈាន ឈ្មោះថា អាកិញ្ចញ្ញាយតនៈ ព្រោះអត្ថថា មានអាកិញ្ចញ្ញៈនោះជាអារម្មណ៍ ដោយអត្ថថា ជាអារម្មណ៍ដែលតាំងមាំ ។ ពាក្យនេះជាឈ្មោះរបស់ឈាន ដែលមានការទៅប្រាសនៃវិញ្ញាណដែលប្រព្រឹត្តទៅក្នុងអាកាសជាអារម្មណ៍ ភិក្ខុសម្រេចអាកិញ្ចញ្ញាយតនឈាននោះ មានចិត្តស្ងាត់ចាកអាកិញ្ចញ្ញាយតនសញ្ញានោះ ។

ក្នុងបទថា **នេវសញ្ញានាសញ្ញាយតនំ** មានវិនិច្ឆ័យដូចតទៅនេះថា ឈាននោះលោកហៅថា នេវសញ្ញានាសញ្ញាយតនៈ ព្រោះមិនមានសញ្ញាណា សញ្ញានោះ រមែងមានដល់ភិក្ខុដែលបដិបត្តិហើយយ៉ាងណា ដើម្បីសម្តែងនូវសញ្ញានោះមុន ព្រះមានព្រះភាគទ្រង់តាំងមាតិកាទុកក្នុងវិភង្គថា មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ហើយត្រាស់ថា ភិក្ខុមនសិការដល់អាកិញ្ចញ្ញាយតនៈនោះឯង ដោយភាពជារបស់ល្អិត ចម្រើនសមាបត្តិដែលមានសង្ខារដ៏សេសហេតុនោះទើបហៅថា មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ។

បណ្តាពាក្យទាំងនោះ ពាក្យថា មនសិការៈ... ដោយភាពជារបស់ល្អិត សេចក្តីថា ភិក្ខុមនសិការៈនូវអាកិញ្ចញ្ញាយតនសមាបត្តិនោះថា ជារបស់ល្អិត ព្រោះមានអារម្មណ៍ល្អិតយ៉ាងនេះថា ភិក្ខុធ្វើទុកក្នុងចិត្តនូវភាពមិនមាន ឲ្យជា

អារម្មណ៍ហើយ ក្នុងសមាបត្តិណា សមាបត្តិនេះល្អិតហ្ន៎ ។ ភិក្ខុអន្ធយសម្រេចនេវសញ្ញានាសញ្ញាយតននោះ រមែងមានឈានចិត្តសូន្យចាកអាកិញ្ចញ្ញាយតនសញ្ញានោះ ។

បទថា **សោតាបន្នស្ស** បានដល់ សម្រេចសោតាបត្តិផល ។ បទថា **សក្កាយទិដ្ឋិយា** បានដល់ ចាកសក្កាយទិដ្ឋិដែលមានវត្ថុ ២០ ។ បទថា **វិចិកិច្ឆាយ** បានដល់ ចាកសេចក្តីសង្ស័យក្នុងឋានៈ ៨ យ៉ាង ។

បទថា **សីលព្វតបរាមាសា** បានដល់ ទិដ្ឋិដែលកើតឡើងស្ទាបអង្អែលថា បរិសុទ្ធិដោយសីល បរិសុទ្ធិដោយវត្ត ។

បទថា **ទិដ្ឋានុសយា** បានដល់ ទិដ្ឋានុស័យដែលដេកត្រាំក្នុងសន្តានដោយអត្ថថា លះមិនទាន់បាន ។ វិចិកិច្ឆានុស័យក៏ដូចគ្នា ។

បទថា **តទេកដ្ឋេហិ ច** បានដល់ ដែលតាំងនៅដោយភាពតែមួយជាមួយសក្កាយទិដ្ឋិនោះ ។ ឈ្មោះថា **កិលេសេហិ** ព្រោះអត្ថថា ឲ្យក្តៅក្រហាយនិងឲ្យលំបាក ។ បទថា **ចិត្តំ វិរិត្តំ** គឺស្ងាត់ចាកកិលេសមានសក្កាយទិដ្ឋិជាដើមទាំងនោះ ។

ក្នុងទីនេះ បទថា **តទេកដ្ឋំ** សេចក្តីថា តាំងនៅក្នុងឋានៈជាមួយគ្នា មាន ២ គឺ តាំងនៅក្នុងឋានៈតែមួយដោយការលះ និងតាំងនៅក្នុងឋានៈតែមួយដោយការកើតរួមគ្នា ។

កិលេសទាំងឡាយដែលឲ្យដល់អបាយ ឈ្មោះថា តាំងនៅក្នុងឋានៈតែមួយដោយការលះ ព្រោះអត្ថថា តាំងនៅក្នុងបុគ្គលតែមួយ ដោយទិដ្ឋិនិងវិចិកិច្ឆា

ដរាបណាមិនទាន់លះបានដោយសោតាបត្តិមគ្គ ។ បណ្តាកិលេស ១០ យ៉ាង ទិដ្ឋិនិងវិចិកិច្ឆាប៉ុណ្ណោះមកហើយក្នុងទីនេះ ។ ទិដ្ឋានុស័យនិងវិចិកិច្ឆានុស័យមកហើយក្នុងកិលេសានុស័យទាំងឡាយ ។ ចំណែកកិលេសដែលឲ្យដល់អបាយដ៏សេស ៨ យ៉ាង គឺលោភៈ ទោសៈ មោហៈ មានះ ថីនៈ ឧទ្ធច្ចៈ អហិរិកៈ អនោត្តប្បៈ ជាកិលេសដែលតាំងនៅក្នុងឋានៈតែមួយជាមួយទិដ្ឋិនិងវិចិកិច្ឆា រមែងលះបានមួយអន្លើដោយអនុស័យទាំងពីរដោយសោតាបត្តិមគ្គ ។

ម្យ៉ាងទៀត បណ្តាកិលេស ១៥០០ ដែលមានរាគៈ ទោសៈ មោហៈជាប្រធាន កាលលះនូវទិដ្ឋិបានដោយសោតាបត្តិមគ្គ ក៏ឈ្មោះថាលះវិចិកិច្ឆាបានមួយអន្លើដោយទិដ្ឋិ កិលេសទាំងពួងដែលឲ្យដល់អបាយ មួយអន្លើដោយទិដ្ឋានុស័យនិងវិចិកិច្ឆានុស័យ រមែងលះបានដោយអំណាចតាំងនៅក្នុងឋានៈតែមួយដោយការលះ ។ ចំណែកកិលេសដែលតាំងនៅក្នុងឋានៈតែមួយដោយកើតរួមគ្នា បានដល់ កិលេសដ៏សេសដែលតាំងនៅក្នុងចិត្តតែមួយដូងមួយអន្លើដោយទិដ្ឋិនិងព្រមដោយវិចិកិច្ឆា កាលចិត្តដែលជាទិដ្ឋិសម្បយុត្តនិងជាអសង្ខារិកៈទាំងពីរ លះបានហើយដោយសោតាបត្តិមគ្គ កិលេសទាំងនេះគឺលោភៈ ទោសៈ មោហៈ ឧទ្ធច្ចៈ អហិរិកៈ អនោត្តប្បៈដែលកើតរួមជាមួយចិត្តទាំងនោះ រមែងលះបានដោយអំណាចតាំងនៅក្នុងឋានៈតែមួយដោយកើតរួមគ្នា ។ កាលលះចិត្តដែលជាទិដ្ឋិសម្បយុត្តនិងជាអសង្ខារិកៈទាំងពីរបាន កិលេសទាំងនេះគឺលោភៈ មោហៈ ថីនៈ ឧទ្ធច្ចៈ អហិរិកៈ អនោត្តប្បៈដែលកើតរួមជាមួយចិត្តទាំងនោះ រមែងលះបានដោយអំណាចតាំងនៅក្នុងឋានៈតែមួយ ដោយកើតរួម

*គ្នា ។ កាលលះនូវចិត្តដែលសហគតៈដោយវិចិកិច្ឆាបាន កិលេសទាំងនេះ គឺ មោហៈ ឧទ្ធច្ចៈ អហិរិកៈ អនោត្តប្បៈដែលកើតរួមជាមួយចិត្តនោះ រមែងលះ បាន ដោយអំណាចតាំងនៅក្នុងឋានៈតែមួយដោយកើតរួមគ្នា ។ ចិត្តរមែងស្ងាត់ ចាកកិលេស ដែលតាំងនៅក្នុងឋានៈតែមួយពីរយ៉ាងនោះ អធិប្បាយថា មគ្គ ចិត្តរមែងស្ងាត់ ផលចិត្តរមែងស្ងាត់ គឺមិនប្រកប មិនខ្វល់ខ្វាយ គឺស្ងាត់ដោយ ប្រការដូច្នេះ ។*

*បទថា* **សកទាគាមិស្ស ឱឡារិកា កាមរាគសញ្ញោជនា** *សេចក្ដីថា សញ្ញោជនៈ ពោលគឺតម្រេកក្នុងមេថុនជាកិលេសគ្រោតគ្រាត គឺជាកិលេស គ្រោតគ្រាត ព្រោះជាបច្ច័យនៃការឈានកន្លងក្នុងកាយទ្វារ ។ ឯកាមរាគៈនោះ លោកហៅថា សំយោជនៈ ព្រោះអត្ថថា ប្រកបសត្វទុកក្នុងកាមភព ។*

*បទថា* **បដិឃសញ្ញោជនា** *បានដល់ សំយោជនៈ គឺព្យាបាទៈ ។ ព្យាបាទៈ នោះលោកហៅថា បដិឃៈ ព្រោះអត្ថថា ប៉ះខ្ទប់អារម្មណ៍ ។ កិលេសទាំងនោះ ឯងឈ្មោះថា អនុស័យ ព្រោះអត្ថថា ដេកសម្ងំក្នុងខន្ធ ដោយអត្ថថា មាន កម្លាំង ។*

*បទថា* **អណុសហគតា** *បានដល់ ល្អិតគឺសុខុម ។ កាមរាគសំយោជនៈ បដិឃសំយោជនៈយ៉ាងល្អិត ។*

*បទថា* **កាមរាគានុសយា បដិឃានុសយា** *បានដល់ កាមរាគានុស័យ និងបដិឃានុស័យយ៉ាងល្អិត ដោយអំណាចដេកត្រាំក្នុងសន្តាន ដោយអត្ថថា មិនទាន់លះបាន ។*

បទថា **តនេកាដ្ឋេហិ ច** សេចក្ដីថា ចិត្តរមែងស្ងាត់ គឺទទេចាកកិលេសទាំងឡាយដែលតាំងនៅក្នុងឋានៈជាមួយគ្នាពីរយ៉ាង ដែលមានអត្ថដូចពោលហើយ ។

បទថា **អរហតោ** បានដល់ បុគ្គលបានឈ្មោះថា ព្រះអរហន្ត ព្រោះកម្ចាត់សត្រូវ គឺកិលេសទាំងឡាយបាន ។

បទថា **រូបរាគា** បានដល់ ឆន្ទរាគៈក្នុងរូបភព ។ បទថា **អរូបរាគា** បានដល់ ឆន្ទរាគៈក្នុងអរូបភព ។ បទថា **មានា** បានដល់ មានះដែលសម្លាប់បានដោយអរហត្តមគ្គនោះឯង ឧទ្ធច្ចៈ អវិជ្ជានិងមានានុស័យជាដើម ក៏សម្លាប់បានដោយអរហត្តមគ្គដូចគ្នា ។ បណ្ដាកិលេសទាំងនោះ មានះ មានលក្ខណៈប៉ោងឡើង ឧទ្ធច្ចៈមានលក្ខណៈមិនស្ងប់ អវិជ្ជាមានលក្ខណៈងងឹត ភវរាគានុស័យប្រព្រឹត្តទៅដោយអំណាចរូបរាគៈនិងអរូបរាគៈ ។

បទថា **តនេកាដ្ឋេហិ ច** បានដល់ ចាកកិលេសទាំងឡាយដែលតាំងនៅរួមគ្នាទាំងនោះ ។ បទថា **ពហិទ្ធា ច សព្វនិមិត្តេហិ** សេចក្ដីថា មគ្គចិត្តរមែងស្ងាត់ គឺវៀរ មិនខ្វល់ខ្វាយ ផលចិត្តមិនប្រកប គឺមិនខ្វល់ខ្វាយចាកសង្ខារនិមិត្តទាំងពួងដែលដល់នូវការរាប់ថាខាងក្រៅ គឺផុតខាងក្នុងហើយប្រព្រឹត្តទៅខាងក្រៅ ព្រោះអាស្រ័យអកុសលក្ខន្ធខាងក្នុងចិត្ត ។

បណ្ដាអនុស័យទាំងនោះ គប្បីជ្រាបការមិនមាននៃអនុស័យ ២ យ៉ាង គឺដោយលំដាប់កិលេសនិងដោយលំដាប់មគ្គ ។ ដោយលំដាប់កិលេស កាមរាគានុស័យនិងបដិឃានុស័យ មិនមានដោយមគ្គទី ៣ ។ មានានុស័យមិន

មានដោយមគ្គទី ៤ ទិដ្ឋានុស័យនិងវិចិកិច្ឆានុស័យ មិនមានដោយមគ្គទី ១ ភវរាគានុស័យនិងអវិជ្ជានុស័យ មិនមានដោយមគ្គទី ៤ នោះឯង ។ បែកដោយលំដាប់មគ្គ ទិដ្ឋានុស័យនិងវិចិកិច្ឆានុស័យ មិនមានដោយមគ្គទី ១ កាមរាគានុស័យនិងបដិឃានុស័យស្រាលស្តើងដោយមគ្គទី ២ ។ កាមរាគានុស័យនិងបដិឃានុស័យ មិនមានដោយប្រការទាំងពួងដោយមគ្គទី ៣ ។ មានានុស័យភវរាគានុស័យនិងអវិជ្ជានុស័យ មិនមានដោយមគ្គទី ៤ ។

បទថា **ចិត្តវិវេកោ** សេចក្តីថា ភាពដែលមហគ្គតចិត្តនិងលោកុត្តរចិត្តស្ងាត់គឺទទេចាកកិលេសទាំងឡាយ ។

បទថា **ឧបធិវិវេកោ** បានដល់ ទទេចាកឧបធិ ពោលគឺកិលេស ខន្ធនិងអភិសង្ខារ ។

ដើម្បីសម្តែងឧបធិមុន ទើបព្រះសារីបុត្តត្រូវពោលពាក្យជាដើមថា **ឧបធិ វុច្ចន្តិ កិលេសា** ច ដូច្នេះ ។

ឈ្មោះថា កិលេស មានរាគៈជាដើម ព្រោះអត្ថថា កើតឡើងដល់បុគ្គលណា រមែងធ្វើបុគ្គលនោះឲ្យក្តៅក្រហាយ ឲ្យលំបាកផង បញ្ចក្ខន្ធមានរូបជាដើមជាអារម្មណ៍របស់ឧបាទានផង បុញ្ញាភិសង្ខារ អបុញ្ញាភិសង្ខារនិងអនេញ្ជាភិសង្ខារដែលជាទីកើតរបស់ឧបាទានផង ឈ្មោះថា **ឧបធិ** ។

បទថា **អមតំ** សេចក្តីថា ឈ្មោះថា **អមតំ** ព្រោះអត្ថថា មិនមានមតៈពោលគឺការស្លាប់ ។

ឈ្មោះថា **អមតំ** ព្រោះអត្ថថា ជាថ្នាំ ព្រោះជាបដិបក្ខចំពោះពិស គឺ

កិលេសក៏មាន ។

តណ្ហាលោកហៅថា **វាន** ព្រោះអត្ថថា ដោតក្រង គឺរឹតរួតពួកសត្វទុកក្នុងសង្សារ កំណើត គតិ ឧប្បត្តិ វិញ្ញាណដ្ឋិតិនិងសត្តាវាសទាំងឡាយ ។ ឈ្មោះថា និព្វាន ព្រោះអត្ថថា មិនមានតណ្ហាជាគ្រឿងដោតក្រងក្នុងនិព្វាននោះ ។

បទថា **វូបកដ្ឋកាយានំ** បានដល់ ជាអ្នកមានសរីរៈ ប្រាសចាកការប្រឡូកប្រឡំក្នុងពួកគណៈ ។

បទថា **នេក្ខម្មាភិរតានំ** បានដល់ ជាអ្នកត្រេកអរក្រៃលែងក្នុងនេក្ខម្មៈ គឺបឋមឈានជាដើមដែលចេញចាកកាមជាដើម គឺដែលបង្អោនទៅក្នុងនេក្ខម្មៈនោះ ។

បទថា **បរមវោទានប្បត្តានំ** បានដល់ ជាអ្នកសម្រេចផល គឺភាពជាអ្នកបរិសុទ្ធ ឧត្តមតាំងនៅ ។ អាចារ្យពួកខ្លះពណ៌នាយ៉ាងនេះថា ឈ្មោះថា **បរិសុទ្ធចិត្តានំ** ព្រោះមិនមានឧបក្កិលេស ឈ្មោះថា **បរមវោទានប្បត្តានំ** ព្រោះភាពជាអ្នកផុតចាកកិលេសទាំងឡាយ ឈ្មោះថា **បរិសុទ្ធចិត្តានំ** ដោយ ( អំណាច ) វិក្ខម្ភនប្បហាន ឈ្មោះថា **បរមវោទានប្បត្តានំ** ដោយ ( អំណាច ) សមុច្ឆេទប្បហាន ។

បទថា **និរូបធីនំ** បានដល់ មានឧបធិទៅប្រាសហើយ ។ បទថា **វិសង្ខារគតានំ** បានដល់ ដែលកាត់អារម្មណ៍សង្ខារហើយចូលដល់និព្វានដែលប្រាសចាកសង្ខារដោយអំណាចអារម្មណ៍ ។ ព្រះនិព្វាននោះឯងលោកហៅថា វិសង្ខារ ក្នុងបទថា **វិសង្ខារគតំ ចិត្តំ** នេះ ។

បទថា **វិទូរេ** បានដល់ ឆ្ងាយដោយប្រការផ្សេងៗ ។ បទថា **សុវិទូរេ** បានដល់ ឆ្ងាយដោយល្អ ។ បទថា **ន សន្តិកេ** បានដល់ មិនឆ្ងាយ ។ បទថា **ន សាមន្តា** បានដល់ មិនមែននៅក្បែរ ។ បទថា **អនាសន្នេ** បានដល់ មិននៅជិតពេក ។ បទថា **វូបកដ្ឋេ** បានដល់ មិនឆ្ងាយ សេចក្តីថា ទៅប្រាស ។ បទថា **តាទិសោ** បានដល់ បុគ្គលបែបនោះ ។ បទថា **តស្សណ្ឋិតោ** បានដល់ តាំងនៅដោយអាការៈនោះ ។ បទថា **តប្បការោ** បានដល់ តាំងនៅដោយប្រការនោះ ។ បទថា **តប្បដិភាគោ** បានដល់ ជាអ្នកមានចំណែកដូច្នោះ ។ ម្យ៉ាងទៀត អាចារ្យពួកមួយពណ៌នាយ៉ាងនេះថា ឈ្មោះថា **តាទិសោ** ព្រោះជាប់ជំពាក់ក្នុងគុហាគឺអត្តភាព ឈ្មោះថា **តស្សណ្ឋិតោ** ព្រោះកិលេសទាំងឡាយបិទបាំងទុក ឈ្មោះថា **តប្បការោ** ព្រោះឈមចុះក្នុងទីវង្វេង ឈ្មោះថា **តប្បដិភាគោ** ព្រោះឆ្ងាយចាកវិវេក ៣ ។

[ ៣៤ ] បទថា **ទុប្បហាយា** បានដល់ មិនជារបស់ដែលនរជនគប្បីលះបានដោយងាយ ។

បទថា **ទុច្ចជា** បានដល់ មិនអាចលះបានដោយងាយ ។ បទថា **ទុប្បវិច្ចជា** បានដល់ មិនអាចលះបានដោយអាការៈទាំងពួង ។ បទថា **ទុន្និម្មទយា** បានដល់ មិនអាចធ្វើឲ្យមិនស្រវឹង គឺឲ្យមានសេចក្តីស្រវឹងប្រាសចេញហើយ ។

បទថា **ទុព្វិនិវេឋយា** បានដល់ មិនអាចធ្វើនូវការកែខ្វែ គឺដោះចេញបាន ។ បទថា **ទុត្តរា** បានដល់ មិនអាចឆ្លងឡើង ឈានកន្លងទៅបាន ។ បទថា **ទុប្បតរា** បានដល់ មិនអាចឆ្លងដោយពិសេសបាន ។ បទថា **ទុស្សម-**

**តិក្កមា** បានដល់ ឈានកន្លងបានដោយលំបាក ។ បទថា **ទុត្តីតិវត្តា** បានដល់ លំបាកនឹងឲ្យប្រព្រឹត្តទៅ ។

ម្យ៉ាងទៀត អាចារ្យពួកខ្លះពណ៌នាយ៉ាងនេះថា ឈ្មោះថា **ទុប្បរិច្ចជា** ដោយអំណាចតាមប្រក្រតី ឈ្មោះថា **ទុន្និម្មុជយា** ដូចអាសិរពិសដែលមានពិសកាច ឈ្មោះថា **ទុត្តិនិវេជយា** ដូចនាគបាសៈ ( អន្ទាក់របស់នាគ ) ឈ្មោះថា **ទុត្តរា** និង **ទុប្បតរា** ដូចផ្លូវកន្តារ គឺសមុទ្ទខ្សាច់ក្នុងវដ្តវក្តៅ ឈ្មោះថា **ទុស្សមតិក្កមា** ដូចព្រៃដែលមានខ្លាធំហួងហែង ឈ្មោះថា **ទុត្តីតិវត្តា** ដូចរលកក្នុងមហាសមុទ្ទ ។

[ ៣៥ ] ព្រះមានព្រះភាគឲ្យសម្រេចសេចក្តីថា នរជនបែបនោះ រមែងនៅឆ្ងាយចាកវិវេកដោយគាថាទី ១ យ៉ាងនេះហើយ កាលទ្រង់ធ្វើឲ្យជាក់ច្បាស់នូវធម្មតារបស់ពួកសត្វយ៉ាងនោះទៀត ទើបត្រាស់ថា **ឥច្ឆានិទានា** ជាដើម ។

បណ្តាបទទាំងនោះ បទថា **ឥច្ឆានិទានា** បានដល់ មានតណ្ហាជាហេតុ ។ បទថា **ភវសាតពទ្ធា** បានដល់ ដែលជាប់ជំពាក់ដោយការត្រេកអរក្នុងភពមានសុខវេទនាជាដើម ។ បទថា **តេ ទុប្បមុញ្ចា** បានដល់ ធម៌ដែលជាទីតាំងនៃការត្រេកអរក្នុងភពទាំងនោះ ម្យ៉ាងទៀត សត្វទាំងនោះ គឺជាអ្នកជាប់ជំពាក់ក្នុងការត្រេកអរក្នុងភពនោះ ជាអ្នកមានសេចក្តីប្រាថ្នាជានិទាន ជាអ្នករួចផុតបានដោយក្រ ។

បទថា **ន ហិ អញ្ញមោក្ខា** សេចក្តីថា មិនអាចដោះបុគ្គលដទៃឲ្យរួចផុត ។ ម្យ៉ាងទៀត បទនោះ ( អញ្ញ សត្ត ) ជាតតិយាវិភត្តិ សត្វទាំងនោះជា

អ្នករួចផុតបានដោយក្រ ព្រោះហេតុអ្វី ព្រោះជាបុគ្គលដែលបុគ្គលដទៃឲ្យផុតមិនបាន បើសត្វទាំងឡាយគប្បីផុត ក៏គប្បីផុតដោយកម្លាំងរបស់ខ្លួន អត្ថនៃបទនោះ មានដូចពណ៌នាមកដូច្នេះ ។

បទថា **បច្ឆា បុរេ វាបិ អបេក្ខមានា** សេចក្ដីថា សង្ឃឹមនូវកាមទាំងឡាយក្នុងអនាគតខ្លះ ក្នុងអតីតៈខ្លះ ។

បទថា **ឥមេវ កាមេ បុរិមេវ ជប្បំ** សេចក្ដីថា ប្រាថ្នានូវកាមទាំងនេះដែលជាបច្ចុប្បន្ន ឬកាមដែលមានក្នុងកាលមុន គឺដែលជាអតីតៈនិងអនាគតទាំងពីរយ៉ាងដោយតណ្ហាមានកម្លាំង ។

ម្យ៉ាងទៀត គប្បីជ្រាបថា បាទគាថាទាំងពីរនេះភ្ជាប់នឹងបទនេះថា **តេ ទុប្បមុញ្ចា ន ហិ អញ្ញមោក្ខា** នោះឯង ។

[ ៣៦ ] ក្រៅអំពីនេះ ក៏មិនប្រាកដថា សត្វទាំងនោះ សូម្បីសង្ឃឹម ឬប្រាថ្នា រមែងធ្វើអ្វី ឬបានធ្វើអ្វីហើយ ។ បទថា **កវសាតបន្នា** សេចក្ដីថា កាលត្រេកអរក្នុងភព ឈ្មោះថា កវសាតៈ សត្វទាំងនោះ ជាអ្នកជាប់ជំពាក់ដោយការត្រេកអរក្នុងភពនោះ គឺដោយការត្រេកអរក្នុងសេចក្ដីសុខតាំងនៅ ។ ដើម្បីសម្ដែងចែកការត្រេកអរនោះ ទើបព្រះសារីបុត្តត្ថេរពោលពាក្យថា **ឯកំ កវសាតំ សុខាវេទនា** ជាដើម ។

ភាវៈនៃក្រមុំកំលោះឈ្មោះថា **យោព្វញ្ញំ** ។ ការមិនមាននៃរោគៈឈ្មោះថា **អារោគ្យំ** ។ ការប្រព្រឹត្តទៅនៃជីវិតិន្ទ្រិយ ឈ្មោះថា **ជីវិតំ** ។ បទថា **លាភោ** បានដល់ ការបានបច្ច័យ ៤ ។ បទថា **យសោ** បានដល់ បរិវារ ។ បទថា

**បសំសា** បានដល់ កេរ្តិ៍ឈ្មោះ ។ បទថា **សុខំ** បានដល់ សុខផ្លូវកាយនិងផ្លូវចិត្ត ។ បទថា **មនាបិកា រូបា** បានដល់ រូបដែលជាទីត្រេកអរនៃចិត្ត ។ ក្នុងបទដ៏សេសទាំងឡាយក៏មានន័យដូច្នេះឯង ។

បទថា **ចក្ខុសម្បទា** បានដល់ ការដល់ព្រមនៃចក្ខុ ។ លោកពោលពាក្យថា ចក្ខុសម្បទា សំដៅដល់ការត្រេកអរដោយសេចក្តីសុខដែលកើតឡើងថា ចក្ខុរបស់អញសម្បូរ ប្រាកដដូចសីហបញ្ជរដែលតាំងទុកត្រង់វិមានកែវមណី សូម្បីបទថា **សោតសម្បទា** ជាដើម ក៏ន័យនេះឯង ។

បទថា **សុខាយ វេទនាយ សាតពទ្ធា ។បេ។ វិនិពទ្ធា** ជាមាតិកា ។

បទថា **វិនិពទ្ធា** បានដល់ ជាប់ជំពាក់ដោយអាការៈមានបែបផ្សេងៗ ។ បទថា **អាពទ្ធា** បានដល់ ជាប់ជំពាក់អំពីដើមដោយពិសេស ។ បទថា **លគ្គា** បានដល់ អែបស្អិតនឹងអារម្មណ៍ ។ បទថា **លគ្គិតា** បានដល់ ពាក់ទុកដូចបំពង់ទឹកអំពៅដែលគេព្យួរទុកត្រង់ដៃកែវ ។

បទណាមិនបានពោលទុកក្នុងទីនេះ បទនោះ គប្បីកាន់យកដោយន័យដែលពោលទុកក្នុងបទថា **សត្តោ វិសត្តោ** ជាដើម ។

[ ៣៧ ] បទថា **ន ហិ អញ្ញមោក្ខា** សេចក្តីថា មិនញ៉ាំងបុគ្គលដទៃឲ្យរួចផុត ។ បទថា **តេ វា ភវសាតវត្ថុ ទុប្បមុញ្ចា** សេចក្តីថា ធម៌ដែលជាវត្ថុនៃការត្រេកអរជាមួយសេចក្តីសុខក្នុងភព លំបាកនឹងរួចផុតបាន ។

បទថា **សត្តា វា ឃេត្តា ទុម្មោចយា** សេចក្តីថា ពួកសត្វនោះឯងលំបាកនឹងរួចផុតចាកវត្ថុនៃការត្រេកអរក្នុងភពនេះ ។

បទថា **ឧរុទ្ធរា** សេចក្តីថា លំបាកនឹងលើកឡើង ។ បទថា **ឧស្សមុទ្ធរា** សេចក្តីថា លំបាកនឹងលើកឡើងទុកខាងលើ ដូចធ្លាក់ក្នុងរណ្តៅដែលមានជ្រុងដាច់ហើយដោយជុំវិញ ។ បទថា **ឧព្វដ្ឋាបនា** សេចក្តីថា លំបាកនឹងឲ្យក្រោកចេញទៅ ។ បទថា **ឧស្សមុដ្ឋាបនា** សេចក្តីថា លំបាកនឹងលើកឡើង ដូចការលើកអត្តភាពល្អិតឲ្យតាំងឡើងលើផែនដី ។

បទថា **តេ អត្តនា បលិបបលិបន្នា** សេចក្តីថា លិចចុះក្នុងភក់ដែលជ្រៅត្រឹមក្បាល ។ បទថា **ន សក្កោន្តិ បរំ បលិបបលិបន្នំ ឧទ្ធរិតុំ** សេចក្តីថា មិនអាចចាប់ដៃ ឬក្បាលលើកអ្នកដទៃដែលលិចចុះយ៉ាងនោះឯងឡើងមកឲ្យឈរលើគោកបាន ។ បទថា **សោ** ក្នុងបទថា **សោ វត ចុន្ទ** ជាការសម្តែងដោយបុគ្គល ដោយអាការៈដែលគប្បីពោល ។ និទ្ទេសនោះ គប្បីជ្រាបថានាំនូវពាក្យឧទ្ទេសថា **យោ** ( បុគ្គលណា ) មកភ្ជាប់ក្នុងបទដ៏សេសទាំងឡាយយ៉ាងនេះថា ម្នាលចុន្ទៈ បុគ្គលណាលិចកប់ក្នុងភក់ដោយខ្លួនឯង នឹងស្រង់បុគ្គលដទៃដែលលិចកប់ក្នុងភក់បាន ហេតុដូច្នេះ នេះមិនមានទេ ។ បទថា **បលិបបលិបន្នោ** ទ្រង់ត្រាស់បុគ្គលដែលលិចក្នុងភក់ដែលជ្រៅ សេចក្តីថា ម្នាលចុន្ទៈ ដូចបុរសខ្លះលិចចុះក្នុងភក់រហូតដល់ក្បាល នឹងចាប់ដៃឬក្បាលទាញអ្នកដទៃដែលលិចយ៉ាងនោះដូចគ្នាឡើងបានដូច្នេះនេះមិនមាន ។ អធិប្បាយថា ការដែលបុគ្គលនោះ គប្បីទាញបុគ្គលដទៃឲ្យឡើងមកតាំងនៅលើគោកនោះមិនមែនជាហេតុឡើយ ។

ក្នុងបទថា **អទន្តោ អវិនីតោ អបរិនិព្វុតោ** នេះ មានវិនិច្ឆ័យដូចតទៅ

នេះថា បុគ្គលនោះឈ្មោះថា **អនេត្តា** ព្រោះមានការសេពខុស ឈ្មោះថា **អវិនីតោ** ព្រោះមិនសិក្សាវិន័យ ឈ្មោះថា **អបរិនិព្វុតោ** ព្រោះមិនទាន់រំលត់កិលេសបាន បុគ្គលនោះគឺដូច្នោះ នឹងទូន្មានអ្នកដទៃ នឹងធ្វើឲ្យមានការសេពខុសប្រាសចាកហើយ នឹងដឹកនាំ នឹងឲ្យសិក្សាសិក្ខា ៣ នឹងឲ្យរំលត់ដោយជុំវិញ គឺនឹងឲ្យកិលេសទាំងឡាយរបស់បុគ្គលនោះរលត់ ។

បទថា **ឧត្តញ្ញោ កោចិ** សេចក្តីថា បុគ្គលដទៃណាមួយដែលឈ្មោះថា អាចនឹងឲ្យផុតបានរមែងមិនមាន ។

បទថា **សកេន ថាមេន** បានដល់ ដោយកម្លាំងនៃញាណរបស់ខ្លួន ។ បទថា **ពលេន** បានដល់ ដោយកម្លាំងនៃញាណ ។ បទថា **វីរិយេន** បានដល់ ដោយសេចក្តីព្យាយាមផ្លូវចិត្តដែលសម្បយុត្តដោយញាណ ។

បទថា **បុរិសបរក្កមេន** បានដល់ ដោយសេចក្តីព្យាយាមធំដែលមិនប៉ះពាល់ឋានៈដទៃៗ ។

បទថា **នាហំ សហិស្សាមិ** មានអធិប្បាយថា អាត្មាអញមិនអាច គឺមិនអាច គឺនឹងមិនព្យាយាម ។

បទថា **បមោចនាយ** បានដល់ ដើម្បីឲ្យរួចផុត ។ បទថា **កថំកថី** បានដល់ ដែលមានសេចក្តីសង្ស័យ ។ បទថា **ធោតក** ជាអាលបនៈ ។ បទថា **តរេសិ** សេចក្តីថា គប្បីឆ្លងបាន ។

ព្រះដ៏មានព្រះភាគត្រាស់ថា

បុគ្គលធ្វើបាបដោយខ្លួនឯង នឹងសៅហ្មងដោយខ្លួនឯង មិនធ្វើ

បាបដោយខ្លួនឯង រមែងបរិសុទ្ធដោយខ្លួនឯង សេចក្ដីបរិសុទ្ធ
និងមិនបរិសុទ្ធកើតចំពោះខ្លួន បុគ្គលដទៃនឹងញុំាងបុគ្គលដទៃ
ឲ្យបរិសុទ្ធិមិនបានទេ ដូច្នេះ ។

ក្នុងព្រះពុទ្ធវចនៈនេះ មានអត្ថដូច្នេះថា អកុសលកម្មដែលបុគ្គលណា ធ្វើដោយខ្លួនឯង បុគ្គលនោះនឹងសោយទុក្ខក្នុងអបាយ ៤ សៅហ្មងដោយខ្លួនឯង តែអំពើអាក្រក់ដែលបុគ្គលណាមិនធ្វើដោយខ្លួនឯង បុគ្គលនោះរមែងទៅកាន់ឋានសួគ៌និងព្រះនិព្វាន បរិសុទ្ធិបានដោយខ្លួនឯង សេចក្ដីបរិសុទ្ធ ពោលគឺកុសលកម្ម ការមិនបរិសុទ្ធ ពោលគឺអកុសលកម្មជារបស់ចំពោះខ្លួន គឺរមែងឲ្យផលក្នុងខ្លួននោះឯងដល់សត្វដែលធ្វើ បុគ្គលដទៃមិនគប្បីញុំាងបុគ្គលដទៃឲ្យបរិសុទ្ធិបាន មានអធិប្បាយថា ឲ្យបរិសុទ្ធិមិនបាន ឲ្យសៅហ្មងមិនបាន ។

បទថា **តិដ្ឋតេវ និព្វានំ** សេចក្ដីថា អមតមហានិព្វានក៏តាំងនៅនោះឯង ។ បទថា **និព្វានគាមិមគ្គោ** បានដល់ អរិយមគ្គ ផ្ដើមអំពីវិបស្សនាដែលជាចំណែកខាងដើម ។

បទថា **តិដ្ឋាមហំ សមាទបេតា** សេចក្ដីថា តថាគតឲ្យកាន់យក ឲ្យឋិតនៅចំពោះ ក៏ឋិតនៅចំពោះ ។

បទថា **ឯវំ ឱវទិយមានា ឯវំ អនុសាសិយមានា** បានដល់ ដែលតថាគតពោលទូន្មានយ៉ាងនេះ ប្រៀនប្រដៅយ៉ាងនេះ ។ ក្នុងបទពីរនេះ កាលពោលក្នុងរឿងដែលកើតឡើងហើយ ឈ្មោះថា **ឱវទិយមានា** ។ កាលប្រៀនប្រដៅក្នុងរឿងដែលមិនទាន់កើតឡើង សម្ដែងអនាគតជាដើមថា សូម្បីការ

វិនាសយសក៏នឹងមានដល់អ្នក ដូច្នេះឈ្មោះថា **អនុសាសិយមានា** ។ កាល ពោលចំពោះមុខ ឈ្មោះថា **ឱវទិយមានា** កាលបញ្ជូនទូត ឬសំបុត្រទៅ ឈ្មោះថា **អនុសាសិយមានា** កាលពោលម្តង ឈ្មោះថា **ឱវទិយមានា** កាល ពោលរឿយៗ ឈ្មោះថា **អនុសាសិយមានា** ម្យ៉ាងទៀត កាលទូន្មាននោះ ឯង ឈ្មោះថា ប្រៀនប្រដៅ ។

បទថា **អប្បេកច្ចេ** បានដល់ បុគ្គលពួកខ្លះ សេចក្តីថា ពួកមួយ ។ បទ ថា **អច្ចន្តនិដ្ឋំ និព្វានំ អារាធេន្តិ** សេចក្តីថា ឈ្មោះថា អច្ចន្តៈ ព្រោះអត្ថថា ចំណែកបំផុត ពោលគឺការអស់ទៅនិងការវិនាសទៅ កន្លងទៅហើយ ចំណែក កន្លងទៅហើយនោះផង ចប់ហើយព្រោះមិនជាទីប្រព្រឹត្តទៅនៃសង្ខារទាំងពួង ផង ព្រោះហេតុនោះ ទើបឈ្មោះថា មានចំណែកទីបំផុតកន្លងទៅហើយ សេចក្តី ថា ចប់ដោយចំណែកមួយ ។ សាវកពួកខ្លះសម្រេច គឺដល់នូវនិព្វានដែលចប់ ដោយចំណែកមួយនោះ ។

បទថា **ណារាធេន្តិ** បានដល់ មិនដល់ព្រម សេចក្តីថា មិនបានចំពោះ ។ បទថា **ឯត្ថ ក្យាហំ** សេចក្តីថា ក្នុងរឿងទាំងនេះ តថាគតនឹងធ្វើអ្វី នឹងធ្វើអ្វី បាន ។ បទថា **មគ្គក្ខាយី** បានដល់ ជាអ្នកប្រាប់ផ្លូវបដិបត្តិ ។ បទថា **អាចិក្ខតិ** បានដល់ រមែងពោល ។ បទថា **អត្តនា បដិបជ្ជមានា** មុញ្ចេយ្យុំ សេចក្តី ថា អ្នកបដិបត្តិគប្បីរួចផុតឯង ។

[ ៣៨ ] បទថា **អតីតំ ឧទាធាយ** បានដល់ អាស្រ័យអតីតៈ ។ បទថា **កប្បំ បុរេ អបេក្ខំ ករោតិ** សេចក្តីថា ធ្វើនូវការឃើញ គឺការសម្លឹងមើល

ដោយប្រការណា ។ បទថា **ឯវំរូបោ អហោសឹ** សេចក្តីថា អាត្មាអញមាន ជាតិយ៉ាងនេះ មានរូបយ៉ាងនេះ គឺខ្ពស់ ទាប ស្គម ធាត់ជាដើម ។ បទថា **តត្ថ ឆន្ទំ សមន្នានេតិ** សេចក្តីថា នាំមក គឺនាំចូលមកយ៉ាងពេញកម្លាំងនូវតណ្ហា ក្នុងរូបារម្មណ៍នោះ ។ ក្នុងបទថា **វេទនា** ជាដើម ក៏ន័យនេះដូចគ្នា ។

កាលនឹងសម្តែងការកើតឡើងនៃតណ្ហាដោយអំណាចវត្ថុ និងអារម្មណ៍ ទើបព្រះសារីបុត្តត្រូវពោលពាក្យថា **ឥតិ មេ ចក្ខុ** ជាដើម ។

បទថា **ឥតិ រូបា** បានដល់ មានរូបយ៉ាងនេះ ។ បទថា **តត្ថ ឆន្ទរាគប្បដិពទ្ធំ** សេចក្តីថា ឆន្ទៈ ពោលគឺដែលមានកម្លាំងខ្សោយ និងរាគៈដែលមានកម្លាំងខ្លាំងក្នុងចក្ខុនិងរូបទាំងនោះ ពាក់ព័ន្ធគឺជាប់ណែនដោយឆន្ទរាគៈនោះ ។

បទថា **វិញ្ញាណំ** បានដល់ ជវនចិត្ត ។ បទថា **ឆន្ទរាគប្បដិពទ្ធត្តា វិញ្ញាណស្ស** សេចក្តីថា ព្រោះជវនចិត្តនោះ ពាក់ព័ន្ធដោយឆន្ទរាគៈ ។

បទថា **តទភិនន្ទតិ** សេចក្តីថា រមែងត្រេកអរក្នុងអារម្មណ៍នោះ ដោយអំណាចតណ្ហា កាលត្រេកអរដោយអារម្មណ៍នោះ ដោយអំណាចតណ្ហានោះឯង ។

បទថា **យានិស្ស តានិ** កាត់បទជា **យានិ អស្ស តានិ** ។ បទថា **បុព្វេ** បានដល់ ក្នុងអតីតៈ ។ បទថា **សទ្ធឹ** បានដល់ រួមគ្នា ។ បទថា **ហសិតលបិតកីឡិតានិ** បានដល់ ការសើច មានការបង្ហាញធ្មេញជាដើម ការបន្ទីវាចារបោចនិងការលេង មានការលេងផ្លូវកាយជាដើម ។

បទថា **តទស្សាទេតិ** សេចក្តីថា រមែងត្រេកអរ គឺបាននូវការត្រេកអរ គឺត្រេកអរក្នុងការសើចជាដើម ។

បទថា **តំ និកាមេតិ** សេចក្តីថា រមែងសង្ឃឹម គឺសង្ឃឹមចំពោះការសើចជាដើមនោះ ។ បទថា **វិត្តឹ អាបជ្ជតិ** សេចក្តីថា រមែងដល់នូវការត្រេកអរ ។

បទថា **សិយំ** បានដល់ គប្បីកើត ។ បទថា **អប្បដិលទ្ធស្ស បដិលាភាយ** បានដល់ ដើម្បីប្រយោជន៍ដល់ការ ដល់អារម្មណ៍ដែលមិនទាន់ដល់ ។ បទថា **ចិត្តំ បណិទហតិ** សេចក្តីថា តាំងចិត្តទុក ។ បទថា **ចេតសោ បណិធាន ប្បច្ចយា** បានដល់ ព្រោះហេតុនៃការតាំងចិត្តទុក ។ បទថា **សីលេន វា** បានដល់ ដោយសីល មានសីល ៥ ជាដើម ។ បទថា **វតេន វា** បានដល់ ដោយសមាទានធុតង្គ ។ បទថា **តបេន វា** បានដល់ ដោយសមាទានសេចក្តីព្យាយាម ។ បទថា **ព្រហ្មចរិយេន វា** បានដល់ ដោយមេថុនវិរតិ ។ បទថា **ទេវោ វា** បានដល់ ទេវរាជដែលមានអានុភាពច្រើន ។ បទថា **ទេវញ្ញតរោ វា** បានដល់ ទេវតាណាមួយ បណ្តាទេវតាទាំងនោះ ។

[ ៣៩ ] បទថា **ជប្បន្តា** បានដល់ ពោលដោយអំណាចនៃគុណ ។ បទថា **បជប្បន្តា** បានដល់ ពោលដោយប្រការ ។ បទថា **អភិជប្បន្តា** បានដល់ ពោលដោយពិសេស ។ម្យ៉ាងទៀត ពង្រីកសេចក្តីដោយអំណាចនៃឧបសគ្គ ។

[ ៤០ ] ព្រះមានព្រះភាគទ្រង់សម្តែងថា នរជនមានសភាពដូច្នោះនោះ ( ឋិតនៅ ) ក្នុងទីឆ្ងាយអំពីវិវេក[១] ដោយគាថាទី ១ ហើយទ្រង់ធ្វើឲ្យជាក់

---

១-ឃ្នាប ៣៣ ។

ច្បាស់នូវធម្មតារបស់ពួក នរជនបែបនោះដោយគាថាទី ២ យ៉ាងនោះហើយ ឥឡូវនេះ កាលទ្រង់ធ្វើឲ្យជាក់ច្បាស់ដល់ការ ធ្វើកម្មអាក្រក់របស់នរជនទាំងនោះ ទើបត្រាស់ថា **កាមេសុ គិទ្ធា** ជាដើម ។

អត្ថនៃគាថានោះថា សត្វទាំងនោះជាអ្នកជាប់ក្នុងកាមទាំងឡាយព្រោះតណ្ហាក្នុងការបរិភោគ ជាអ្នកខ្វល់ខ្វាយក្នុងកាមទាំងឡាយ ព្រោះខ្វល់ខ្វាយដោយការស្វែងរកជាដើម ជាអ្នកវង្វេងក្នុងកាមទាំងឡាយ ព្រោះដល់នូវការវង្វេងព្រម ជាបុគ្គលថោកថយ ព្រោះមានការទៅថោកថយ ព្រោះមានសេចក្តីកំណាញ់និងព្រោះមិនប្រកាន់មាំក្នុងព្រះពុទ្ធវចនៈជាដើម តាំងនៅក្នុងកម្មដែលមិនស្មើ មានកម្មដែលមិនស្មើផ្លូវកាយជាដើម ក្នុងកាលដែលជាទីបំផុតចូលដល់ទុក្ខ គឺការស្លាប់ រមែងកន្ទក់កន្ទេញថា យើងទាំងឡាយឃ្លាតចាកភពនេះហើយនឹងកើតជាអ្វីហ្ន៎ ដូច្នេះ ។

[៤១] បទថា **គិទ្ធា** បានដល់ ជាប់ដោយកាមរាគៈ ។ បទថា **គធិតា** សេចក្តីថា ជាអ្នកសង្ឃឹមចំពោះដោយតម្រេក ព្រោះការត្រិះរិះ ។ បទថា **មុច្ឆិតា** សេចក្តីថា ជាអ្នកមានការជាប់ចិត្ត ប្រព្រឹត្តទៅខាងមុខដោយកាមតណ្ហា ។ បទថា **អជ្ឈោបន្នា** សេចក្តីថា វង្វេង វង្វេងជ្រប់ដោយការត្រេកអរក្នុងកាម ។

បទថា **លគ្គា** សេចក្តីថា ជាប់ស្អិតដោយសេចក្តីស្នេហាក្នុងកាម ។ បទថា **លគ្គិតា** សេចក្តីថា ដូចគ្នាដោយការក្តៅក្រហាយក្នុងកាម ។ បទថា **បលិពុទ្ធា** សេចក្តីថា ពាក់ព័ន្ធដោយការសម្គាល់ក្នុងកាម ។

ម្យ៉ាងទៀត អាចារ្យពួកមួយពណ៌នាយ៉ាងនេះថា ត្រេកអរព្រោះឃើញនូវ

វត្ថុដែលឃើញហើយជាប់ចំពាក់ ព្រោះឃើញរឿយៗធ្លាក់ចុះ ព្រោះធ្វើនូវការជាប់ជំពាក់ ងប់ងល់ ព្រោះការធ្វើនូវការស្និទ្ធស្នាល ជ្រុលជ្រប់ ព្រោះស្នាមស្នេហ៍ ទាក់ថ្ពក់ ព្រោះការចូលដល់ជាគូៗ ព័ន្ធព័ទ្ធ គឺជាបុគ្គល មិនព្រមលែងនោះឯង ។

បទថា **ឯសន្តិ** បានដល់ សង្ឃឹមចំពោះ ។ បទថា **គវេសន្តិ** បានដល់ ស្វែងរក ។ បទថា **បរិយេសន្តិ** បានដល់ ត្រូវការ គឺប្រាថ្នាដោយអាការៈទាំងពួង ។ ម្យ៉ាងទៀត បទថា **ឯសន្តិ** សេចក្តីថា ក្នុងអារម្មណ៍ដែលឃើញហើយ ការស្អាត ការមិនស្អាត មាន ឬមិនមានដូច្នេះ កាលធ្វើឲ្យប្រចក្សក្នុងសុភារម្មណ៍និងអសុភារម្មណ៍ហើយ ធ្វើឲ្យជាទីស្រឡាញ់ដើម្បីប្រើប្រាស់ ឈ្មោះថា **គវេសន្តិ** ។ ប៉ុនប៉ងដោយអំណាចនៃចិត្ត ស្វែងរកដោយអំណាចនៃការប្រកប ស្វះស្វែងដោយអំណាចនៃការធ្វើ ។ ឈ្មោះថា **តច្ចរិតា** ព្រោះអត្ថថា ត្រាច់ទៅអាស្រ័យ គឺឈានចុះក្នុងកាម ២ យ៉ាងនោះ ។ ឈ្មោះថា **តព្ពហុលា** ព្រោះអត្ថថា ញុំាងកាមទាំងនោះឲ្យចម្រើន ឲ្យប្រព្រឹត្តទៅច្រើន គឺដោយច្រើន ។ ឈ្មោះថា **តគ្គរុកា** ព្រោះអត្ថថា ធេះ ធ្វើកាមទាំងនោះឯងឲ្យជាអារម្មណ៍យ៉ាងធ្ងន់ ។ ឈ្មោះថា **តន្និន្នា** ព្រោះអត្ថថា ជាអ្នកទោរទន់ គឺបង្អោនទៅក្នុងកាមទាំងនោះ ។ ឈ្មោះថា **តប្បោណា** ព្រោះអត្ថថា ជាអ្នកបង្អោនទៅក្នុងកាមទាំងនោះ ។ ឈ្មោះថា **តប្បព្ភារា** ព្រោះអត្ថថា ជាអ្នកសំយុងចុះក្នុងកាមទាំងនោះឯង ជាអ្នកទោរទន់ ហើយត្រង់កាមទាំងនោះ ។ ឈ្មោះថា **តទ-ធិមុត្តា** ព្រោះអត្ថថា ជាអ្នកជាប់ចំពាក់ដោយការវង្វេងក្នុងកាមទាំងនោះឯង

ត្រាច់ទៅ ។ ឈ្មោះថា **តទាធិបតេយ្យា** ព្រោះអត្ថថា ធ្វើកាមទាំងនោះឯង ឲ្យជាធំ ឲ្យជាប្រធានត្រាច់ទៅ ។ ម្យ៉ាងទៀត អាចារ្យពួកមួយពណ៌នាយ៉ាង នេះថា ឈ្មោះថា **តច្ចរិតា** ព្រោះគួរប្រាថ្នាអារម្មណ៍ ឈ្មោះថា **តព្ពហុលា** ព្រោះអារម្មណ៍គួរប្រាថ្នា ឈ្មោះថា **តគ្គរុកា** ព្រោះអារម្មណ៍គួរពេញចិត្ត ឈ្មោះថា **តន្និន្នា** ព្រោះមានអារម្មណ៍គួរស្រឡាញ់ ឈ្មោះថា **តប្បោណា** ព្រោះមានអារម្មណ៍ប្រកបដោយកាម ឈ្មោះថា **តប្បព្ភារា** ព្រោះមានអារម្មណ៍ ជាទីតាំងនៃតម្រេក ឈ្មោះថា **តទធិមុត្តា** ព្រោះមានអារម្មណ៍ជាទីតាំងនៃ សេចក្តីវង្វេង ឈ្មោះថា **តទាធិបតេយ្យា** ព្រោះមានអារម្មណ៍ជាទីតាំងនៃ ចំណង ។

ក្នុងបទថា **រូបេ បរិយេសន្ត** ជាដើមគប្បីជ្រាបថា លោកពោលបទ **បរិយេសន្តិ** ដោយអំណាចការស្វែងរកដើម្បីបានវត្ថុដែលមិនទាន់បាន ។ លោក ពោលបទ **បដិលភន្តិ** ដោយអំណាចមានរបស់នៅក្នុងដៃហើយ ។ លោក ពោលបទថា **បរិភុញ្ជន្តិ** ដោយអំណាចការប្រើប្រាស់ ។

ឈ្មោះថា **កលហការកោ** ព្រោះអត្ថថា ធ្វើនូវវិវាទ ឈ្មោះថា **កលហប្បសុតោ** ព្រោះអត្ថថា ប្រកបក្នុងជម្លោះនោះ ក្នុងបទថា **កម្មការកោ** ជា ដើមក៏ន័យនេះឯង ។

បទថា **គោចរេ ចរន្តោ** សេចក្តីថា ត្រាច់ទៅក្នុងអគោចរ មានកន្លែង ស្រីពេស្យាជាដើម ឬក្នុងគោចរមានសតិប្បដ្ឋានជាដើម ។ បុគ្គលប្រកបក្នុង គោចរទាំងនោះ ឈ្មោះថា **គោចរប្បសុតោ** ។

ឈ្មោះថា **ឈាយី** ព្រោះអត្ថថា មានឈានដោយអំណាចចូលទៅសម្រឹងអារម្មណ៍ ។ បុគ្គលប្រកបក្នុងឈាននោះ ឈ្មោះថា **ឈានប្បសុតោ** ។

[៤២] បទថា **អវគច្ឆន្តិ** បានដល់ ទៅកាន់អបាយ ។ បទថា **មច្ឆរិនោ** បានដល់ ជាអ្នកលាក់នូវសម្បត្តិរបស់ខ្លួន ។ បទថា **វចនំ** បានដល់ វាចា ។ បទថា **ព្យប្បថំ** បានដល់ ពាក្យសម្តី ។ បទថា **ទេសនំ** បានដល់ ឱវាទ ។ បទថា **អនុសិដ្ឋឹ** បានដល់ ពាក្យប្រៀនប្រដៅ ។ បទថា **ន អាទិយន្តិ** បានដល់ មិនទទួល មិនធ្វើការគោរព បាឋៈថា **ន អស្សិយន្តិ** ដូច្នេះក៏មាន ឯសេចក្តីក៏ដូចគ្នា ។

ដើម្បីសម្តែងសេចក្តីកំណាញ់ដោយវត្ថុ ទើបលោកពោលថា **បញ្ច មច្ឆរិយានិ អាវាសមច្ឆរិយំ** ជាដើម បណ្តាសេចក្តីកំណាញ់ទាំងនោះ សេចក្តីកំណាញ់ក្នុងទីលំនៅ ឈ្មោះថា **អាវាសមច្ឆរិយំ** ។ ក្នុងបទដ៏សេសទាំងឡាយក៏មានន័យនេះឯង ។ អារាមទាំងមូលក្តី បរិវេណក្តី បន្ទប់ដេកតែមួយក្តី ទីសម្រាកពេលយប់ជាដើមក្តី ឈ្មោះថាលំនៅ ។ បុគ្គលនៅសប្បាយ បានបច្ច័យទាំងឡាយក្នុងទីណា ទីនោះគប្បីជ្រាបថា អាវាស ។

ភិក្ខុមួយរូបមិនត្រូវការឲ្យភិក្ខុអ្នកមានសីលជាទីស្រឡាញ់ ជាអ្នកសម្បូរដោយវត្ត មកក្នុងអាវាសនោះ គិតថា សូម្បីភិក្ខុដែលមកហើយ ក៏សូមឲ្យប្រញាប់ទៅ នេះឈ្មោះថា អាវាសមច្ឆរិយៈ តែភិក្ខុដែលមិនត្រូវការឲ្យពួកភិក្ខុដែលបង្កនូវជម្លោះជាដើម នៅក្នុងទីលំនៅនោះ មិនជាអាវាសមច្ឆរិយៈឡើយ ។

បទថា **កុលំ** បានដល់ ត្រកូលឧបដ្ឋាកខ្ទះ ត្រកូលញាតិខ្ទះ ភិក្ខុមិនត្រូវការឲ្យភិក្ខុដទៃចូលទៅក្នុងត្រកូលនោះ ជា **កុលមច្ឆរិយំ** តែបើមិនត្រូវការឲ្យបុគ្គលលាមកចូលទៅ មិនឈ្មោះថាជាមច្ឆរិយៈឡើយ ព្រោះថាបុគ្គលលាមកនោះរមែងបដិបត្តិដើម្បីទម្លាយនូវការជ្រះថ្លារបស់ឧបដ្ឋាកនិងញាតិទាំងនោះ តែកាលមិនត្រូវការឲ្យភិក្ខុដែលអាចរក្សាសេចក្ដីជ្រះថ្លាទុកបាន ចូលទៅក្នុងត្រកូលនោះ ឈ្មោះថា ជាមច្ឆរិយៈ ។

បទថា **លាភ** បានដល់ លាភ គឺបច្ច័យ ៤ នោះឯង កាលភិក្ខុអ្នកមានសីលរូបដទៃបានលាភនោះឯង ភិក្ខុគិតថា ចូរកុំបានដូច្នេះ រមែងជា **លាភមច្ឆរិយំ** តែភិក្ខុណាធ្វើសទ្ធាទេយ្យឲ្យធ្លាក់ចុះ ឲ្យវិនាសដោយមិនបរិភោគនិងបរិភោគមិនល្អជាដើម សូម្បីរបស់ស្អុយក៏មិនឲ្យដល់អ្នកដទៃ ភិក្ខុឃើញភិក្ខុនោះហើយគិតថា បើភិក្ខុនេះមិនបានលាភនេះ ភិក្ខុអ្នកមានសីលរូបដទៃ គប្បីបានគប្បីបរិភោគ ដូច្នេះរមែងមិនជាមច្ឆរិយៈ ។

វណ្ណៈនៃសរីរៈក្តី វណ្ណៈគឺគុណក្តី ឈ្មោះថា **វណ្ណ** ក្នុងវណ្ណៈ ២ យ៉ាងនោះ បុគ្គលកាលគេពោលថា បុគ្គលដទៃមានរូបគួរជ្រះថ្លាដូច្នេះ មិនបំណងនឹងពោល ឈ្មោះថា កំណាញ់វណ្ណៈនៃសរីរៈ ។ បុគ្គលដែលមិនបំណងនឹងពោលសរសើរអ្នកដទៃដោយសីល ធុតង្គ បដិបទា អាចារៈ ឈ្មោះថាវណ្ណមច្ឆរិយៈ ។

បទថា **ធម្ម** បានដល់ បរិយត្តិធម៌និងបដិវេធធម៌ ។ បណ្ដាធម៌ ២ យ៉ាងនោះ ព្រះអរិយសាវកទាំងឡាយ រមែងមិនកំណាញ់បដិវេធធម៌ រមែង

ប្រាថ្នាឲ្យលោក ព្រមទាំងទេវលោក ចាក់ធ្លុះនូវធម៌ដែលខ្លួនចាក់ធ្លុះហើយ រមែងប្រាថ្នាថា សូមបុគ្គលដទៃៗចូរដឹងនូវបដិវេធធម៌នោះផង ។ ឈ្មោះថា ធម្មមច្ឆរិយៈ ព្រោះធម៌គឺព្រះពុទ្ធវចនៈនោះឯងមាន បុគ្គលដែលប្រកបដោយធម្មមច្ឆរិយៈនោះ ដឹងនូវគន្ថៈ ឬកថាមគ្គដែលកំបាំងឯណា មិនបំណាំងឲ្យអ្នកដទៃដឹងនូវគន្ថៈ ឬកថាមគ្គនោះ តែបុគ្គលណា មិនឲ្យដោយពិចារណាបុគ្គលហើយ ឃើញដល់ធម៌ ឬដោយពិចារណាធម៌ហើយ ឃើញដល់បុគ្គល បុគ្គលនេះមិនឈ្មោះថា ធម្មមច្ឆរិយៈ ។

ក្នុងសេចក្តីនេះ បុគ្គលពួកខ្លះជាបុគ្គលឡេះឡោះ ពេលខ្លះជាសមណៈ ពេលខ្លះជាព្រាហ្មណ៍ ពេលខ្លះជានិគ្រន្ថ ភិក្ខុណាមិនឲ្យដោយគិតថា បុគ្គលនេះនឹងទម្លាយធម៌ដែលជាព្រះពុទ្ធវចនៈ ដែលមានមកដោយបវេណីស្អាតស្អំល្អិតសុខុមឲ្យវិកវរ ភិក្ខុនេះឈ្មោះថា មិនឲ្យដោយពិចារណាបុគ្គល ហើយឃើញដល់ធម៌ ។ ចំណែកភិក្ខុណាមិនឲ្យដោយគិតថា ធម៌នេះជាធម៌ស្អាតស្អំល្អិតសុខុម បើបុគ្គលនេះកាន់យកនឹងព្យាករណ៍អរហត្តផល ធ្វើឲ្យជាក់ច្បាស់នូវខ្លួន ( លើកតម្កើងខ្លួន ) បុគ្គលនេះនឹងវិនាស ភិក្ខុនេះ ឈ្មោះថា មិនឲ្យដោយពិចារណាធម៌ ហើយឃើញដល់បុគ្គល ។ តែភិក្ខុណាមិនឲ្យដោយគិតថា បើបុគ្គលនេះរៀនធម៌នេះ ក៏នឹងអាចបែកធ្លាយ ( ចាក់ធ្លុះ ) ក្នុងលទ្ធិរបស់ពួកយើងបាន ភិក្ខុនេះឈ្មោះថា ធម្មមច្ឆរិយៈដោយពិត ។

បណ្តាសេចក្តីកំណាញ់ ៥ ប្រការនេះ ខាងដើមព្រោះអាវាសមច្ឆរិយៈ ទើបបុគ្គលកើតជាយក្ខខ្លះ ជាប្រេតខ្លះ ដើរកើបសំរាមក្នុងវត្តនោះ លើកឡើង

ដាក់លើក្បាលទូលទៅ ។

កាលត្រកូលនោះ ធ្វើការឲ្យទាននិងការរាប់អានជាដើម ដល់បុគ្គលដទៃ ភិក្ខុឃើញហើយគិតថា ត្រកូលរបស់អញនេះបែកហើយហ្ន៎ ដល់នូវការឈាម ខ្ជាក់ចេញតាមមាត់ក៏មាន អំពីពោះក៏មាន ពោះវៀនធំចេញមកជាចំរៀកតូចធំក៏មាន ព្រោះកុលមច្ឆរិយៈ ។

បុគ្គលកំណាញ់លាភដែលមាន ជារបស់សង្ឃក្តី របស់គណៈក្តី បរិភោគដូចបរិភោគចំណែកបុគ្គល រមែងកើតជាយក្ខក៏មាន ជាប្រេតក៏មាន ជាពស់ថ្លាន់ធំក៏មាន ព្រោះលាភមច្ឆរិយៈ ។

បុគ្គលសរសើរគុណដែលគួរសរសើររបស់ខ្លួន មិនសរសើរគុណរបស់អ្នកដទៃ ពោលនូវទោសនោះៗថា បុគ្គលនេះមានគុណអ្វី មិនឲ្យនូវបរិយត្តិណាមួយដល់បុគ្គលណាមួយ រមែងមានពណ៌សម្បុរអាក្រក់ មានត្រចៀកថ្លង់ជាមនុស្សគ ព្រោះការកំណាញ់វណ្ណៈនៃសរីរៈ និងវណ្ណៈគឺគុណ និងព្រោះកំណាញ់បរិយត្តិធម៌ ។ម្យ៉ាងទៀត បុគ្គលរមែងឆេះក្នុងខ្ទះលោហៈ ព្រោះការកំណាញ់ទីលំនៅ ជាអ្នកមានលាភតិច ព្រោះការកំណាញ់ត្រកូល កើតក្នុងគូថនរក ព្រោះការកំណាញ់លាភ ។ កាលកើតក្នុងភព រមែងមិនមានពណ៌សម្បុរ ព្រោះការកំណាញ់វណ្ណៈ កើតក្នុងកុក្កុលនរក គឺនរករងើកភ្លើង ព្រោះការកំណាញ់ធម៌ ។

ឈ្មោះថា **មច្ឆរិយំ** ដោយអំណាចនៃបុគ្គលកំណាញ់ អាការៈនៃសេចក្តីកំណាញ់ ឈ្មោះថា **មច្ឆរាយនា** ភាវៈនៃបុគ្គលប្រព្រឹត្តដោយការកំណាញ់ គឺ

 ៣០៨

បុគ្គលមានការដល់ព្រមដោយការកំណាញ់ ឈ្មោះថា **មច្ឆរាយិតត្តំ** ឈ្មោះថា បុគ្គលកំណាញ់យ៉ាងល្មម ព្រោះអត្ថថា ប្រាថ្នា និងការពារសម្បត្តិរបស់ខ្លួនទាំងអស់ថា សម្បត្តិទាំងនេះ ចូរជារបស់អាត្មាអញប៉ុណ្ណោះ កុំជារបស់អ្នកដទៃឡើយ ភាវៈនៃបុគ្គលកំណាញ់ល្មម ឈ្មោះថា **វេវិច្ឆំ** ពាក្យនេះជាឈ្មោះរបស់សេចក្តីកំណាញ់យ៉ាងទន់ ។ បុគ្គលមិនអើពើ លោកហៅថា បុគ្គលកំណាញ់រឹង ភាវៈនៃបុគ្គលកំណាញ់រឹងនោះ ឈ្មោះថា **កទរិយំ** ពាក្យនេះជា ឈ្មោះរបស់សេចក្តីកំណាញ់យ៉ាងខ្លាំងក្លា បុគ្គលដែលប្រកបដោយសេចក្តីកំណាញ់យ៉ាងខ្លាំងក្លានោះ រមែងហាមបុគ្គលដទៃដែលឲ្យទានដល់អ្នកដទៃ សមដូចលោកពោលទុក ( ក្នុងសំយុត្តនិកាយសគាថវគ្គ ) ថា

**កទរិយោ ចាបសង្កប្បោ មិច្ឆាទិដ្ឋិ អនាទរោ**
**ទទមានំ និវារេតិ យាចមានាន ភោជនំ ។**

បុរសមានតែសេចក្តីស្មូរកន្ទ្រឹស មានតម្រិះអាក្រក់ យល់ខុស
មិនអើពើ រមែងហាមឃាត់ជនដែលកំពុងឲ្យនូវភោជនដល់
ពួកស្មូម ដូច្នេះ ។

ឈ្មោះថា **កដុកញ្ចុកតា** ព្រោះអត្ថថា ចិត្តរមែងប្រព្រឹត្តទៅដោយការក្តៅផ្សា គឺអាក់អន់ព្រោះឃើញនូវពួកយាចក ។ ភាវៈនៃបុគ្គលមានចិត្តរួញរាក្នុងការឲ្យ ឈ្មោះថា **កដុកញ្ចុកតា** ។

ន័យម្យ៉ាងទៀត ការកាន់វែក លោកហៅថា **កដុក** កាលបុគ្គលដួសបាយអំពីឆ្នាំងបាយឲ្យពេញដល់កណ្តាប់មាត់ ប្រើវែកសម្រាប់ដួសបាយដែល

ក្រពឹតគ្រប់ចំណែកដែលជួស រមែងមិនអាចដាក់ឲ្យពេញវែកបាន ចិត្តរបស់បុគ្គលដែលមានសេចក្ដីកំណាញ់ក៏យ៉ាងនោះ រមែងរួញរា កាលចិត្តរួញរា កាយរបស់បុគ្គលនោះក៏រួញរា ជាកាយកោង ជាកាយមិនត្រង់ ជាកាយក្រពឹត មិនរលាចេញបាន យ៉ាងនោះដូចគ្នា ព្រោះហេតុនោះ ទើបលោកពោលថា ភាពជាអ្នកមានចិត្តរួញរាក្នុងការឲ្យ ឈ្មោះថា **កដុកញ្ចុកតា** ។

បទថា **អគ្គហិតត្តំ ចិត្តស្ស** សេចក្ដីថា ភាពដែលចិត្តត្រូវរាំងហើយហួងហែងយ៉ាងស្អិតដោយអាការៈមិនបានឲ្យទានជាដើម ក្នុងការធ្វើឧបការៈដល់បុគ្គលដទៃ ។ ក៏ព្រោះបុគ្គលមានសេចក្ដីកំណាញ់ ជាអ្នកមិនបំណងនឹងឲ្យនូវសម្បត្តិរបស់ខ្លួនដល់អ្នកដទៃ បំណងនឹងកាន់យកសម្បត្តិរបស់អ្នកដទៃដូច្នោះ គប្បីជ្រាបថា សេចក្ដីកំណាញ់នេះ មានការលាក់នូវសម្បត្តិរបស់ខ្លួនជាលក្ខណៈនិងមានការកាន់យកសម្បត្តិរបស់អ្នកដទៃជាលក្ខណៈ ដោយអំណាចនៃសេចក្ដីកំណាញ់ដែលប្រព្រឹត្តទៅថា សម្បត្តិនេះចូរជារបស់អញប៉ុណ្ណោះ កុំជារបស់អ្នកដទៃឡើយ ។

បទថា **ខន្ធមច្ឆរិយម្បិ មច្ឆរិយំ** សេចក្ដីថា សេចក្ដីកំណាញ់ ឧបបត្តិភពពោលគឺបញ្ចក្ខន្ធរបស់ខ្លួន មិនសាធារណៈដល់អ្នកដទៃដែលប្រព្រឹត្តទៅថា សូមការអស្ចារ្យនេះមានដល់អញប៉ុណ្ណោះ កុំមានដល់អ្នកដទៃឡើយ ឈ្មោះថា សេចក្ដីកំណាញ់ខន្ធ ។ ក្នុងការកំណាញ់ធាតុនិងកំណាញ់អាយតនៈ ក៏ន័យនេះឯង ។

បទថា **គាហោ** បានដល់ការប្រកាន់ដោយសំដៅនឹងគ្រប់គ្រងទុក ( ឃើញ

តែខ្លួន ) ។ បទថា **អវេទញ្ញុតាយ** បានដល់ ដោយការមិនដឹងព្រះតម្រាស់ដែលព្រះសព្វញ្ញុពុទ្ធទាំងឡាយត្រាស់ទុក ។ បុគ្គលកាលមិនឲ្យដល់យាចកទាំងឡាយ ឈ្មោះថា រមែងមិនដឹងនូវពាក្យដែលយាចកទាំងនោះពោល ។ បទថា **ជនា បមត្តា** បានដល់ ជនដែលប្រាសចាកសតិ ។

បទថា **វេចនំ** បានដល់ ពាក្យពោលយ៉ាងសង្ខេប ។ បទថា **ព្យប្បថំ** បានដល់ ពាក្យពោលយ៉ាងពិស្តារ ។ បទថា **ទេសនំ** បានដល់ ពាក្យដែលសម្តែងឧបមាចង្អុលបង្ហាញអត្ថឲ្យជាក់ច្បាស់ ។ បទថា **អនុសិដ្ឋី** បានដល់ ពាក្យដែលឲ្យកំណត់រឿយៗ ។

ម្យ៉ាងទៀត ការពោលចង្អុលបង្ហាញ ឈ្មោះថា **វេចនំ** ការពោលឲ្យកាន់យក ឈ្មោះថា **ព្យប្បថំ** ។ ការពោលសម្តែងអត្ថ ឈ្មោះថា **ទេសនំ** ការពោលសម្តែងដោយបទ ឈ្មោះថា **អនុសិដ្ឋី** ។

ម្យ៉ាងទៀត ការពោលឲ្យទុក្ខ គឺការតក់ស្លុតវិនាសទៅ ឈ្មោះថា **វេចនំ** ការពោលឲ្យទុក្ខ គឺការក្តៅក្រហាយវិនាសទៅ ឈ្មោះថា **ព្យប្បថំ** ។ ការពោលឲ្យទុក្ខក្នុងអបាយវិនាសទៅ ឈ្មោះថា **ទេសនំ** ។ ការពោលឲ្យទុក្ខក្នុងភពវិនាសទៅ ឈ្មោះថា **អនុសិដ្ឋី** ។

ម្យ៉ាងទៀត អាចារ្យពួកមួយពណ៌នាដោយន័យជាដើមយ៉ាងនេះថា ពាក្យដែលប្រកបដោយការចាក់ធ្លុះ ដោយការកំណត់ដឹងទុក្ខសច្ចៈ ឈ្មោះថា **វេចនំ** ។ ពាក្យដែលប្រកបដោយការចាក់ធ្លុះដោយការលះសមុទយសច្ចៈ ឈ្មោះថា **ព្យប្បថំ** ។ ពាក្យដែលប្រកបដោយការចាក់ធ្លុះដោយការធ្វើឲ្យជាក់ច្បាស់នូវ

និរោធសច្ចៈ ឈ្មោះថា **ទេសនំ** ។ ពាក្យដែលប្រកបដោយការចាក់ធ្លុះដោយការធ្វើមគ្គសច្ចៈឲ្យកើត ឈ្មោះថា **អនុសិដ្ឋី** ។

បទថា **ន សុស្សុសន្តិ** សេចក្ដីថា មិនព្រមស្ដាប់ ។ បទថា **ន សោតំ ឱទហន្តិ** សេចក្ដីថា មិនផ្ទៀងសោតៈ គឺត្រចៀកដើម្បីស្ដាប់ ។ បទថា **ន អញ្ញា ចិត្តំ ឧបដ្ឋបេន្តិ** សេចក្ដីថា មិនតាំងចិត្តដើម្បីដឹង ។

បទថា **អនស្សវា** សេចក្ដីថា មិនស្ដាប់ឱវាទ ។ បទថា **អវចនករា** មានវិគ្គហៈថា ឈ្មោះថា **អវចនករា** ព្រោះអត្ថថា សូម្បីស្ដាប់ក៏មិនធ្វើតាមពាក្យ ។ បទថា **បដិលោមវុត្តិនោ** សេចក្ដីថា ជាអ្នកទទឹងប្រព្រឹត្តទៅ ។ បទថា **អញ្ញេនេវ មុខំ ករោន្តិ** សេចក្ដីថា សូម្បីធ្វើក៏មិនឲ្យឃើញមុខ ។

បទថា **វិសមេ** សេចក្ដីថា ឈ្មោះថា **វិសមេ** ព្រោះជាបដិបក្ខចំពោះកម្មដែលស្មើ ដែលសន្មតថាជាកាយសុចរិតជាដើម ។ ក្នុងកម្មដែលមិនស្មើនោះ ។ បទថា **និវិដ្ឋា** សេចក្ដីថា ចូលទៅហើយ នាំចេញបានដោយលំបាក ។ បទថា **កាយកម្មេ** សេចក្ដីថា ក្នុងកាយកម្មដែលប្រព្រឹត្តទៅផ្លូវកាយក្ដី ប្រព្រឹត្តទៅដោយកាយក្ដី សូម្បីក្នុងវចីកម្មជាដើមក៏ន័យនេះដូចគ្នា ។

បណ្ដាកម្មទាំងនោះ កាយកម្ម វចីកម្ម មនោកម្ម លោកចែកដោយអំណាចនៃទុច្ចរិត ។ គប្បីជ្រាបថា បាណាតិបាតជាដើម លោកចែកដោយអំណាចនៃអកុសលកម្មបថ ១០ ។ ពណ៌នាបទដែលជាសាធារណៈក្នុងទីនេះប៉ុណ្ណេះសិន ។

ក្នុងបទដែលជាអសាធារណៈទាំងឡាយ ការធ្វើសត្វមានជីវិតឲ្យធ្លាក់កន្លងទៅ ឈ្មោះថា បាណាតិបាត លោកអធិប្បាយថា ការទម្លាយជីវិតសត្វការ

*សម្លាប់សត្វ ។ ក្នុងបទថា* **ឆាណោ** *នេះ ដោយវោហារបានដល់សត្វ ដោយបរមត្ថ បានដល់ជីវិតិន្ទ្រិយ ។ ចេតនាសម្លាប់ដែលប្រព្រឹត្តទៅតាមកាយទ្វារនិងវចីទ្វារ ទ្វារណាមួយដែលតាំងឡើងដោយសេចក្តីព្យាយាមចូលទៅកាត់ជីវិតិន្ទ្រិយរបស់បុគ្គល ដែលមានការសម្គាល់ក្នុងសត្វមានជីវិតនោះថាជាសត្វមានជីវិត ឈ្មោះថា បាណាតិបាត ។ បាណាតិបាតនោះ បណ្តាសត្វមានជីវិតទាំងឡាយ មានតិរច្ឆានជាដើមដែលវៀរចាកគុណ ក្នុងសត្វតូចមានទោសតិច ក្នុងសត្វធំមានទោសច្រើន ព្រោះហេតុអ្វី ព្រោះបយោគធំ សូម្បីកាលបយោគប៉ុនគ្នា ក៏ព្រោះវត្ថុធំ ។ បណ្តាសត្វដែលមានគុណ មានមនុស្សជាដើម សត្វដែលមានគុណតិច មានទោសតិច ដែលមានគុណច្រើន មានទោសច្រើន កាលសរីរៈនិងគុណស្មើគ្នា មានទោសតិច ព្រោះកិលេសនិងសេចក្តីព្យាយាមតិច មានទោសច្រើន ព្រោះកិលេសនិងសេចក្តីព្យាយាមខ្លាំងក្លា គប្បីជ្រាបដូចពណ៌នាមកដូច្នេះ ។*

*បាណាតិបាតនោះ មានអង្គ ៥ គឺសត្វមានជីវិត ១ ដឹងថាសត្វមានជីវិត ១ ចិត្តគិតនឹងសម្លាប់ ១ ធ្វើសេចក្តីព្យាយាមដើម្បីសម្លាប់ ១ សត្វស្លាប់ដោយព្យាយាមនោះ ១ ។ មានបយោគ ៦ គឺសាហត្ថិកប្បយោគ ១ អាណត្តិកប្បយោគ ១ និស្សគ្គិយប្បយោគ ១ ថាវរប្បយោគ ១ វិជ្ជាមយប្បយោគ ១ ឥទ្ធិមយប្បយោគ ១ ។ កាលអធិប្បាយអត្ថនេះឲ្យពិស្តារ ក៏នាំឲ្យយឺតយូរដូច្នោះ នឹងមិនអធិប្បាយរឿងនោះឲ្យពិស្តារទេ សប្បុរសត្រូវការជ្រាបសេចក្តីដទៃ ក្នុងសេចក្តីនេះ គប្បីរកមើលក្នុងសាមន្តប្បាសាទិកា អដ្ឋកថាព្រះវិន័យ*

*ហើយកាន់យកចុះ ។*

*ការកាន់យករបស់ដែលម្ចាស់គេមិនឲ្យ ឈ្មោះថា* **អទិន្នាទានំ** *លោកអធិប្បាយថា ការលួច ការប្លន់ ការធ្វើចោរកម្ម ។*

*ក្នុងបទថា* **អទិន្នាទានំ** *នោះ បទថា* **អទិន្នំ** *បានដល់ របស់ដែលម្ចាស់គេហួងហែង ដែលម្ចាស់របស់ធ្វើបានតាមប្រាថ្នា មិនគួរដល់អាជ្ញានិងមិនមានទោស ។ ចេតនាគិតនឹងលួចដែលតាំងឡើងដោយសេចក្ដីព្យាយាមកាន់យកវត្ថុនោះ របស់បុគ្គលអ្នកមានសេចក្ដីសម្គាល់ក្នុងរបស់ដែលម្ចាស់គេហួងហែងនោះ ថាជាទ្រព្យដែលម្ចាស់ទ្រព្យហួងហែង ឈ្មោះថា អទិន្នាទានៈ ។ អទិន្នាទាននោះ ក្នុងវត្ថុដែលជារបស់អ្នកដទៃដែលជារបស់អាក្រក់មានទោសតិច ដែលប្រណីតមានទោសច្រើន ព្រោះហេតុអ្វី ព្រោះវត្ថុប្រណីត ។ កាលវត្ថុស្មើគ្នា ក្នុងវត្ថុដែលជារបស់អ្នកក្រៃលែងដោយគុណមានទោសច្រើន ក្នុងវត្ថុដែលជារបស់អ្នកមានគុណថោកថយជាងគុណនោះៗ ដោយការប្រៀបធៀបបុគ្គលក្រៃលែងដោយគុណនោះៗ មានទោសតិច ។*

*អទិន្នាទានៈនោះមានអង្គ ៥ គឺរបស់ដែលម្ចាស់គេហួងហែង ១ ដឹងថាមានម្ចាស់ហួងហែង ១ ចិត្តគិតនឹងលួច ១ ធ្វើសេចក្ដីព្យាយាមដើម្បីនឹងលួច ១ បានរបស់នោះមកដោយសេចក្ដីព្យាយាមនោះ ១ ។ មានបយោគ ៦ មានសាហត្ថិកប្បយោគជាដើមនោះឯង បយោគទាំងនោះ ប្រព្រឹត្តទៅដោយអំណាចអវហារទាំងនេះ គឺថេយ្យាវហារ ១ បសយ្ហាវហារ ១ បដិច្ឆន្នាវហារ ១ បរិកប្បាវហារ ១ កុសាវហារ ១ តាមសមគួរ នេះជាសេចក្ដីសង្ខេបក្នុង*

អទិន្នាទាននេះ ។ ចំណែកសេចក្តីពិស្តារ បានពោលហើយក្នុងអដ្ឋកថាឈ្មោះសាមន្តប្បាសាទិកា ។

ក្នុងបទថា **កាមេសុ មិច្ឆាចារោ** នេះ មានវិនិច្ឆ័យដូចតទៅនេះថា បទថា **កាមេសុ** បានដល់ ការប្រព្រឹត្តមេថុន ឬវត្ថុនៃមេថុន ។ បទថា **មិច្ឆា-ចារោ** បានដល់ ការប្រព្រឹត្តលាមកដែលត្រូវតិះដៀលដោយចំណែកមួយ ។ តែដោយលក្ខណៈ ចេតនាឈានកន្លងនូវអគមនីយដ្ឋានដែលប្រព្រឹត្តទៅតាមកាយទ្វារដោយបំណងអសទ្ធម្ម ឈ្មោះថា កាមេសុមិច្ឆាចារៈ ។ ក្នុងកាមេសុមិច្ឆាចារៈនោះ នឹងពោលដល់អគមនីយដ្ឋានរបស់ពួកបុរសមុន ដែលបានដល់ ស្រីដែលមាតារក្សា ១ ស្រីដែលបិតារក្សា ១ ស្រីដែលមាតាបិតារក្សា ១ ស្រីដែលបងប្រុសប្អូនប្រុសរក្សា ១ ស្រីដែលបងស្រីប្អូនស្រីរក្សា ១ ស្រីដែលញាតិរក្សា ១ ស្រីដែលគោត្តរក្សា ១ ស្រីដែលធម៌រក្សា ១ ស្រីដែលមានអារក្ខា ១ ស្រីដែលមានអាជ្ញា ១ រួមជាស្រី ១០ ប្រភេទ មានស្រីដែលមាតារក្សាជាដើម ។ ស្រីដែលប្រុសទិញមកដោយទ្រព្យ ១ ស្រីដែលនៅដោយការពេញចិត្ត ១ ស្រីដែលនៅដោយភោគៈ ១ ស្រីដែលនៅដោយសំពត់ ១ ស្រីដែលអ្នកធំចាប់ដៃជនទាំងពីរជ្រមុជក្នុងទឹកហើយប្រគល់ឲ្យ ១ ស្រីដែលបុរសជួយដាក់ការៈធូន់ ( ទ្រនូល ) ហើយមកនៅជាមួយ ១ ស្រីដែលជាទាសីហើយលើកឡើងជាភរិយា ១ ស្រីដែលជាកូនឈ្នួល ហើយបានជាភរិយា ១ ស្រីដែលបុរសទៅច្បាំងឈ្នះបានមក ១ ស្រីដែលជាភរិយាម្តងម្កាល ១ រួមជាស្រី ១០ ប្រភេទ មានស្រីដែលទិញមកដោយទ្រព្យជាដើម

រួមទាំងអស់ជាស្រី ២០ ពួក ។

បុរសដទៃ ឈ្មោះថាជាអគមនីយដ្ឋានរបស់ស្ត្រី ១២ ពួក បណ្ដាស្រី ២០ ពួក គឺស្រីដែលមានអារក្ខានិងស្រីដែលមានអាជ្ញា រួមជា ២ ពួក និង ស្រីដែលទិញមកដោយទ្រព្យជាដើម ១០ ពួក ។ មិច្ឆាចារនេះក្នុងអគមនីយដ្ឋាន ដែលវៀរចាកគុណ មានសីលជាដើម មានទោសតិចក្នុងអគមនីយដ្ឋានដែល សម្បូរដោយគុណ មានសីលជាដើមមានទោសច្រើន ។

កាមេសុមិច្ឆាចារនោះ មានអង្គ ៤ គឺវត្ថុដែលមិនគប្បីដល់ ១ ចិត្តគិត នឹងសេពក្នុងវត្ថុនោះ ១ ព្យាយាមក្នុងការសេព ១ ញុំាងមគ្គនឹងមគ្គឲ្យដល់ គ្នា ១ ។ មានបយោគ ១ គឺសាហត្ថិកប្បយោគ ( ធ្វើដោយផ្ទាល់ ) នោះ ឯង ។

បទថា **មុសា** បានដល់ វចីបយោគ ឬកាយបយោគរបស់បុគ្គលដែល ប្រាថ្នានឹងពោលឲ្យខុសដែលកាច់បំបាក់នូវប្រយោជន៍ ។ ចេតនាដែលតាំងឡើង ដោយកាយប្បយោគ ឬវចីបយោគដែលពោលឲ្យខុសរបស់បុគ្គលដែលប្រាថ្នា នឹងពោលឲ្យខុសនោះ ដោយបំណងនឹងពោលឲ្យខុស ឈ្មោះថា មុសាវាទ ។ ម្យ៉ាងទៀត បទថា **មុសា** បានដល់ រឿងមិនពិត មិនប្រាកដ ។ បទថា **វាទោ** បានដល់ ការឲ្យដឹងរឿងមិនពិត មិនប្រាកដនោះ ថាមែន ថាពិត ។ ដោយ លក្ខណៈ ចេតនាដែលតាំងឡើងដោយវិញ្ញត្តិយ៉ាងនោះ របស់បុគ្គលដែល បំណងឲ្យអ្នកដទៃដឹងរឿងមិនពិត ថាពិត ឈ្មោះថា មុសាវាទ ។ មុសាវាទ មានទោសតិច ព្រោះប្រយោជន៍ដែលកាច់បំបាក់នោះតិច មានទោសច្រើន

ព្រោះប្រយោជន៍ដែលកាច់បំបាក់នោះច្រើន ។

ម្យ៉ាងទៀត សម្រាប់ពួកគ្រហស្ថ មុសាវាទដែលប្រព្រឹត្តទៅដោយន័យជាដើមថា របស់ខ្លួនមិនមាន ដោយបំណងនឹងមិនឲ្យវត្ថុរបស់ខ្លួន ដូច្នេះមានទោសតិច មុសាវាទដែលបុគ្គលជាសាក្សី ពោលដើម្បីកាច់បំបាក់នូវប្រយោជន៍មានទោសច្រើន ។ សម្រាប់បព្វជិត មុសាវាទដែលប្រព្រឹត្តទៅដោយន័យដែលបានប្រេងឬសប្បិតិចតួចមក តែពោលឲ្យពេញដោយបំណងសើចលេងថា ថ្ងៃនេះក្នុងស្រុកមានប្រេងហូរដូចស្ទឹង ដូច្នេះមានទោសតិច តែកាលពោលដល់វត្ថុដែលមិនបានឃើញដោយន័យជាដើមថា ខ្ញុំឃើញ ដូច្នេះ មានទោសច្រើន ។ មុសាវាទមានអង្គ ៤ គឺរឿងមិនពិត ១ ចិត្តគិតនឹងពោលឲ្យខុស ១ ព្យាយាមពោលកុហក ១ អ្នកដទៃដឹងសេចក្តីដែលខ្លួនពោលនោះ ១ ។ មានបយោគ ១ គឺសាហត្ថិកប្បយោគនោះឯង ។ សាហត្ថិកប្បយោគនោះគប្បីឃើញក្នុងការធ្វើកិរិយាដោយបំណងឲ្យអ្នកដទៃយល់ខុសដោយកាយ ឬដោយរបស់ទាក់ទងដោយកាយ ឬដោយវាចា ។ បើអ្នកដទៃដឹងសេចក្តីនោះដោយកិរិយានោះ បុគ្គលនេះរមែងត្រូវកម្មពន្ធ ( ជាប់ដោយចំណងកម្ម ) គឺមុសាវាទក្នុងខណៈនៃចេតនាដែលញុំាងកិរិយានោះឲ្យកើតឡើង ។

ក្នុងបទថា **បិសុណាវាចា** ជាដើម មានវិនិច្ឆ័យដូចតទៅនេះថា បុគ្គលពោលវាចានោះដល់បុគ្គលណា ធ្វើនូវសេចក្តីស្រឡាញ់ដល់ខ្លួន និងធ្វើការស្អប់ដល់អ្នកដទៃក្នុងហទយៈរបស់បុគ្គលនោះដោយវាចាណា វាចានោះឈ្មោះថា **បិសុណាវាចា** ។ បុគ្គលធ្វើខ្លួនខ្លះ អ្នកដទៃខ្លះ ឲ្យគ្រោតគ្រាតដោយវាចា

*ណា វាចាណាជាវាចាគ្រោតគ្រាតឯង មិនពីរោះត្រចៀក មិនសប្បាយចិត្ត វាចានេះ ឈ្មោះថា* **ផរុសវាចា** *។ បុគ្គលពោលពាក្យឡេះឡោះ ឥតប្រយោជន៍ដោយវាទៈណា វាទៈនោះ ឈ្មោះថា* **សម្ផប្បលាបោ** *។ ចេតនាដែលជាមូលនៃវាចាទាំងនោះ ក៏បានឈ្មោះថា បិសុណវាចាជាដើមដូចគ្នា ។ ចេតនានោះឯង លោកបំណងក្នុងទីនេះដូច្នេះឯង ។*

*ក្នុងបទថា* **បិសុណវាចា** *នោះ ចេតនាដែលតាំងឡើងដោយកាយបយោគ ឬវចីបយោគដើម្បីធ្វើអ្នកដទៃឲ្យបែកគ្នាក្តី ដើម្បីធ្វើសេចក្តីស្រឡាញ់ក្នុងខ្លួនក្តី របស់បុគ្គលដែលមានចិត្តសៅហ្មង ឈ្មោះថា បិសុណវាចា បិសុណវាចានោះមានទោសតិច ព្រោះអ្នកធ្វើឲ្យបែកគ្នានោះមានគុណតិច ។ មានទោសច្រើន ព្រោះបុគ្គលដែលត្រូវធ្វើឲ្យបែកគ្នាមានគុណច្រើន ។*

*បិសុណវាចានេះមានអង្គ ៤ គឺអ្នកដទៃគប្បីឲ្យបែកគ្នា ១ ការប្រាថ្នាធ្វើឲ្យបែកគ្នាថា បុគ្គលទាំងនេះនឹងបែកគ្នា នឹងប្រេះឆាអំពីគ្នា ដោយប្រការដូច្នេះក្តី ការប្រាថ្នាធ្វើខ្លួនឲ្យជាទីស្រឡាញ់ថា អញនឹងជាទីស្រឡាញ់ ជាទីរាប់អានដោយប្រការដូច្នេះក្តី ១ ព្យាយាមពោលញុះញង់ ១ បុគ្គលនោះដឹងសេចក្តីដែលខ្លួនពោលនោះ ១ ។*

*ចេតនាដែលគ្រោតគ្រាតដោយចំណែកមួយ ដែលតាំងឡើងដោយកាយ-បយោគ ឬវចីបយោគ ប្រទូស្តចិត្តរបស់អ្នកដទៃ ឈ្មោះថា* **ផរុសវាចា** *បយោគ សូម្បីធ្វើនូវការប្រទូស្តចិត្តក៏មិនជាផរុសវាចា ព្រោះចិត្តទន់ភ្លន់ ដូចមាតាបិតាក្នុងកាលខ្លះពោលនឹងកូនតូចៗយ៉ាងនេះថា ពួកចោរចូរធ្វើអាឲ្យជា*

កំណាត់តូចធំដូច្នេះ តែមិនប្រាថ្នាសូម្បីត្រឹមតែគ្របកឈូក ដែលធ្លាក់លើកូនតូចៗទាំងនោះ ។ អាចារ្យនិងឧបជ្ឈាយ៍ទាំងឡាយ ជួនកាលក៏ពោលនឹងពួកសិស្សយ៉ាងនេះថា ពួកទាំងនេះមិនមានហិរិ មិនមានឱត្តប្បៈឬ ចូរបណ្តេញពួកគេចេញទៅ សេចក្តីពិតលោកទាំងនោះរមែងប្រាថ្នាឲ្យពួកសិស្សទាំងនោះដល់ព្រមដោយការរៀននិងការសម្រេចមគ្គផលដោយពិត នេះមិនមែនជាផរុសវាចា ព្រោះចិត្តទោរទន់យ៉ាងណា សូម្បីវាចាទន់ផ្អែម ក៏មិនឈ្មោះថាមិនមែនជាផរុសវាចា ដូចពាក្យថា អ្នកទាំងឡាយចូរឲ្យបុរសនេះដេកជាសុខចុះ តែក្នុងចិត្តបំណងឲ្យសម្លាប់ ចាត់ថាមិនមែនផរុសវាចាក៏មិនមែន វាចានេះជាផរុសវាចាពិត ព្រោះចិត្តគ្រោតគ្រាត ។ ផរុសវាចានោះ ឈ្មោះថា មានទោសតិច ព្រោះបុគ្គលដែលខ្លួនប្រាថ្នានឹងពោល មានគុណតិច មានទោសច្រើន ព្រោះបុគ្គលនោះមានគុណច្រើន ។

ផរុសវាចានោះ មានអង្គ ៣ គឺអ្នកដទៃដែលគប្បីជេរ ១ ចិត្តក្រោធ ១ បានជេរ ១ ។

អកុសលចេតនាដែលតាំងឡើងដោយកាយបយោគ ឬវចីបយោគឲ្យដឹងរឿងមិនជាប្រយោជន៍ ឈ្មោះថា **សម្ផប្បលាប** ព្រោះអត្ថថា ជាគ្រឿងពោលពាក្យឡេះឡោះឥតប្រយោជន៍ ។ សម្ផប្បលាបៈនោះ មានទោសតិច ព្រោះមានការសេពតិច មានទោសច្រើន ព្រោះមានការសេពច្រើន ។

សម្ផប្បលាបៈនោះមានអង្គ ២ គឺពោលសំដៅដល់រឿងឥតប្រយោជន៍ មានរឿងការតយុទ្ធនិងរឿងព្រះរាមដណ្តើមនាងសិតាជាដើម ពោលកថា មាន

សភាពយ៉ាងនោះ ១ ។

ឈ្មោះថា **អភិជ្ឈា** ព្រោះអត្ថថា សម្លឹង អធិប្បាយថា សំដៅដល់ទ្រព្យរបស់អ្នកដទៃប្រព្រឹត្តទៅដោយភាពជាអ្នកបង្អោនទៅក្នុងវត្ថុនោះ ។ អភិជ្ឈានោះ មានលក្ខណៈសម្លឹងនូវទ្រព្យរបស់អ្នកដទៃថា ឱហ្ន៎ វត្ថុនេះគប្បីជារបស់អញហ្ន៎ មានទោសតិចនិងមានទោសច្រើន ដូចគ្នានឹងអទិន្នាទាន ។

អភិជ្ឈានោះមានអង្គ ២ គឺទ្រព្យជារបស់អ្នកដទៃ ១ ការបង្អោនមកដើម្បីខ្លួន ១ ព្រោះថាកាលសេចក្ដីលោភដែលមានវត្ថុរបស់អ្នកដទៃជាទីតាំង សូម្បីកើតឡើងហើយ កម្មបថក៏មិនទាន់បែកដរាបណា មិនបង្អោនមកដើម្បីខ្លួនថា ឱហ្ន៎ វត្ថុនេះគប្បីជារបស់អញហ្ន៎ ។

ឈ្មោះថា **ព្យាបាទ** ព្រោះអត្ថថា ញុំាំងប្រយោជន៍និងសេចក្ដីសុខឲ្យដល់សេចក្ដីវិនាស ។ ព្យាបាទនោះ មានលក្ខណៈប្រទូស្តដោយចិត្ត ដើម្បីឲ្យបុគ្គលដទៃវិនាស មានទោសតិចនិងមានទោសច្រើនដូចគ្នានឹងផរុសវាចា ។

**ព្យាបាទ** នោះមានអង្គ ២ គឺសត្វដទៃ ១ គិតឲ្យសត្វដទៃនោះវិនាស ១ កាលសេចក្ដីក្រោធដែលមានសត្វដទៃជាវត្ថុកើតឡើងហើយ កម្មបថក៏គង់មិនបែក ដរាបមិនទាន់បានគិតឲ្យបុគ្គលនោះវិនាសថា ឱហ្ន៎ បុគ្គលនេះគប្បីត្រូវបំផ្លាញ គប្បីវិនាសហ្ន៎ ។

ឈ្មោះថា **មិច្ឆាទិដ្ឋិ** ព្រោះអត្ថថា ឃើញខុស ព្រោះមិនមានសេចក្ដីប្រកាន់តាមពិត មិច្ឆាទិដ្ឋិនោះមានលក្ខណៈជាទស្សនៈវិបរិត ដោយន័យជាដើមថា ទានដែលឲ្យហើយមិនមានផល មានទោសតិច និងមានទោសច្រើនដូច

គ្មានឹងសម្មប្បលាបៈ ។

[៤៤-៤៦ ] សត្វទាំងនោះ រមែងសន្សំយដោយអំណាចនៃរូបជាដើមថា យើងទាំងឡាយនឹងជាសត្វមានសញ្ញា នឹងជាសត្វមិនមានសញ្ញា នឹងជាសត្វមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន រមែងសន្សំយខ្លួនដោយន័យជាដើមថា យើងទាំងឡាយនឹងមានឬហ្ន៎ រមែងសន្សំយកាលដែលខ្លួនមាននិងមិនមានក្នុងអនាគត ព្រោះអាស្រ័យអាការៈនៃសស្សតទិដ្ឋិនិងអាការៈនៃឧច្ឆេទ-ទិដ្ឋិក្នុងសេចក្តីនោះថា យើងទាំងឡាយនឹងមានឬហ្ន៎ ឬនឹងមិនមាន ។

បទថា **កឹ នុ ខោ ភវិស្សាម** សេចក្តីថា សត្វទាំងនោះ អាស្រ័យការចូលដល់ជាតិនិងភេទ រមែងសន្សំយថា យើងទាំងឡាយនឹងជាក្សត្រ ព្រាហ្មណ៍ វេស្សៈ សូទ្រៈ គ្រហស្ថ បព្វជិត ទេវតាឬមនុស្សឯណាមួយ ឬហ្ន៎ ។

បទថា **កថំ នុ ខោ ភវិស្សាម** សេចក្តីថា សត្វទាំងនោះអាស្រ័យអាការៈនៃទ្រង់ទ្រាយ រមែងសន្សំយថា យើងទាំងឡាយនឹងជាបុគ្គលខ្ពស់ ទាប ស ខ្មៅ មានប្រមាណនិងមិនមានប្រមាណជាដើមណាមួយឬហ្ន៎ តែអាចារ្យពួកខ្លះពោលថា អាស្រ័យកាពជាធំនិងប្រាសចាកមានះជាដើម រមែងសន្សំយដោយហេតុថា យើងទាំងឡាយនឹងកើតដោយហេតុអ្វីហ្ន៎ ។

បទថា **កឹ ហុត្វា កឹ ភវិស្សាម នុ ខោ មយំ** សេចក្តីថា អាស្រ័យជាតិជាដើម រមែងសន្សំយកពជទៃៗរបស់ខ្លួនថា យើងទាំងឡាយជាក្សត្រហើយនឹងជាព្រាហ្មណ៍ឬហ្ន៎ ។បេ។ ជាទេវតាហើយនឹងជាមនុស្សឬហ្ន៎ ។

បទថា **អទ្ធានំ** ក្នុងទីទាំងពួងនោះឯង ជាឈ្មោះរបស់កាលវេលា ។

ព្រោះមានសេចក្តីសង្ស័យនោះឯង ព្រោះហេតុនោះ ជនក្នុងសាសនានេះ គប្បីសិក្សា ។បេ។ ធីរជនទាំងឡាយបានពោលនូវជីវិតនេះថាតិច បណ្តាបទទាំងនោះ បទថា **សិក្ខេថ** សេចក្តីថា គប្បីរៀនពកដល់សិក្ខា ៣ ។ បទថា **ឥធ** បានដល់ ក្នុងសាសនានេះឯង ។

ក្នុងបទទាំងនោះ ឈ្មោះថា **សិក្ខា** ព្រោះអត្ថថា គប្បីសិក្សា ។ បទថា **តិស្សោ** បានដល់ ជាការកំណត់ចំនួន ( គឺ ៣ ) ។ បទថា **អធិសីលសិក្ខា** សេចក្តីថា ឈ្មោះថាអធិសីល ព្រោះអត្ថថា សីលក្រៃលែងគឺឧត្តម សីលក្រៃលែងនោះផង ឈ្មោះថា **សិក្ខា** ព្រោះគប្បីសិក្សាផង ទាំងអស់នោះឈ្មោះថា **អធិសីលសិក្ខា** ក្នុងអធិសីលសិក្ខានិងអធិបញ្ញាសិក្ខាក៏ន័យនេះឯង ។

ក្នុងសិក្ខា ៣ នេះ សីលដូចម្តេច សីលជាអ្វី ចិត្តដូចម្តេច ចិត្តជាអ្វី បញ្ញាដូចម្តេច បញ្ញាជាអ្វី មានអធិប្បាយដូចតទៅនេះថា

អធិប្បាយសីលមុន បានដល់ សីល ៥ សីល ១០ នោះឯង កាលព្រះពុទ្ធកើតឡើងក្តី ទ្រង់មិនកើតឡើងក្តី សីលនោះក៏ប្រព្រឹត្តទៅក្នុងលោក កាលព្រះពុទ្ធកើតឡើងហើយ ព្រះពុទ្ធក្តី សាវកពុទ្ធក្តី ក៏ឲ្យមហាជនសមាទានក្នុងសីលនោះ កាលព្រះពុទ្ធមិនបានកើតឡើង ព្រះបច្ចេកពុទ្ធទាំងឡាយផង សមណព្រាហ្មណ៍តាំងនៅក្នុងធម៌ជាកម្មវាទីផង ស្តេចចក្កពត្តិមហារាជផង ព្រះពោធិសត្វទាំងឡាយផង ឲ្យមហាជនសមាទាន ។ សមណព្រាហ្មណ៍ដែលជាបណ្ឌិត ក៏សមាទានដោយខ្លួនឯង ពួកជនទាំងនោះបំពេញកុសលធម៌នោះហើយ រមែងសោយនូវសម្បត្តិក្នុងទេវតានិងមនុស្សទាំងឡាយ ។

សីល គឺការសង្រួមក្នុងបាតិមោក្ខ លោកហៅថា **អធិសីល** ។ អធិសីល នោះក្រៃលែងផង ឧត្តមផង នៃលោកិយសីលទាំងអស់ ដូចព្រះអាទិត្យជាកំពូលក្រៃលែងជាងពន្លឺទាំងឡាយ ដូចភ្នំសិនេរុ ឧត្តមជាងភ្នំទាំងឡាយ ដូច្នោះ រមែងប្រព្រឹត្តទៅក្នុងពុទ្ធុប្បាទកាលប៉ុណ្ណោះ ក្រៅអំពីពុទ្ធុប្បាទកាល រមែងមិនប្រព្រឹត្តទៅ ព្រោះថាសត្វដទៃ រមែងមិនអាចលើកបញ្ញត្តិនោះឡើងសម្តែងបាន ។ តែព្រះពុទ្ធទាំងឡាយប៉ុណ្ណោះ ទ្រង់កាត់ក្រសែនៃអជ្ឈាចារកាយទ្វារនិងវចីទ្វារដោយប្រការទាំងពួង ទ្រង់បញ្ញត្តសីលសំវរៈនោះដែលសមគួរដល់ការល្មើសនោះៗ សីលរបស់បុគ្គលសង្រួមក្នុងបាតិមោក្ខដែលសម្បយុត្តដោយមគ្គផលនោះឯង ក៏ឈ្មោះថា **អធិសីល** ។

កុសលចិត្ត ៨ ដួងដែលជាកាមាវចរនិងចិត្តដែលសម្បយុត្តដោយសមាបត្តិ ៨ ដួងដែលជាលោកិយៈរួមគ្នាហើយ គប្បីជ្រាបថា ចិត្តនោះឯង ។ ការប្រព្រឹត្តទៅរបស់ចិត្តនោះផង ការបបួលឲ្យសមាទាននិងការសមាទានផង ក្នុងកាលដែលព្រះពុទ្ធកើតឡើងនិងមិនបានកើតឡើង គប្បីជ្រាបតាមន័យដែលពោលហើយក្នុងសីលនោះឯង ។ ចិត្តដែលសម្បយុត្តដោយសមាបត្តិ ៨ ដែលជាបាទនៃវិបស្សនា លោកហៅថា **អធិចិត្ត** ។ អធិចិត្តនោះក្រៃលែងផង ឧត្តមផង នៃលោកិយចិត្តទាំងឡាយ ដូចអធិសីលក្រៃលែងផង ឧត្តមផង នៃសីលទាំងឡាយដូច្នោះ មានក្នុងពុទ្ធុប្បាទកាលប៉ុណ្ណោះ ក្រៅអំពីពុទ្ធុប្បាទកាល មិនមានឡើយ ។ ម្យ៉ាងទៀត ក្រៃលែងជាងនោះ មគ្គចិត្តនិងផលចិត្ត ឈ្មោះថា **អធិចិត្ត** ។

**កម្មស្សកតាញាណ** *ដែលប្រព្រឹត្តទៅដោយន័យជាដើមថា ទានដែលឲ្យហើយមានផល យញ្ញដែលបូជាហើយមានផល ដូច្នេះឈ្មោះថា* **បញ្ញា** *។ បញ្ញានោះ កាលព្រះពុទ្ធកើតឡើងក្តី មិនកើតឡើងក្តី រមែងប្រព្រឹត្តទៅក្នុងលោក កាលព្រះពុទ្ធកើតឡើងហើយ ព្រះពុទ្ធក្តី សាវកក្តី ក៏ឲ្យមហាជនសមាទានក្នុងបញ្ញានោះ ។ កាលព្រះពុទ្ធមិនទាន់កើតឡើង ព្រះបច្ចេកពុទ្ធទាំងឡាយក្តី សមណព្រាហ្មណ៍ដែលតាំងនៅក្នុងធម៌ ជាកម្មវាទីក្តី ស្តេចចក្កពត្តិមហារាជក្តី ព្រះមហាពោធិសត្វទាំងឡាយក្តី ឲ្យមហាជនសមាទាន បណ្ឌិតទាំងឡាយក៏សមាទានដោយខ្លួនឯង ។ ពិតយ៉ាងនោះ អង្កុរទេវបុត្ត បានឲ្យមហាទាន ២ ម៉ឺនឆ្នាំ វេលាមព្រាហ្មណ៍ ព្រះវេស្សន្តរនិងមនុស្ស ដែលជាបណ្ឌិតដទៃៗ ជាច្រើន បានឲ្យមហាទានទាំងឡាយ ។ ជនទាំងនោះ បំពេញកុសលធម៌នោះហើយ បានសោយសម្បត្តិក្នុងទេវតានិងមនុស្សទាំងឡាយ ។ ឯវិបស្សនាញាណដែលកំណត់អាការៈដោយត្រៃលក្ខណ៍ លោកហៅថា* **អធិ-ប្បញ្ញា** *។ អធិប្បញ្ញានោះក្រៃលែងផង ឧត្តមផង នៃលោកិយបញ្ញាទាំងអស់ ដូចអធិសីលនិងអធិចិត្តក្រៃលែងផង ឧត្តមផង នៃសីលនិងចិត្តទាំងឡាយនិងក្រៅអំពីពុទ្ធុប្បាទកាល រមែងមិនប្រព្រឹត្តទៅក្នុងលោក ។ ម្យ៉ាងទៀត ក្រៃលែងជាងនោះ បញ្ញាដែលសម្បយុត្តដោយមគ្គផលនោះឯង ឈ្មោះថា* **អធិប្បញ្ញា** *។*

*ឥឡូវនេះ ព្រះសារីបុត្តត្ថេរកាលនឹងសម្តែងសិក្ខាជាបែបផ្សេងៗ ទើបពោលថា អធិសីលសិក្ខា ដូចម្តេច ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីលសង្រួមក្នុងបាតិមោក្ខសំវរៈ ដូច្នេះជាដើម ។*

បទថា **៩៨** ជាពាក្យសម្ដែងពាក្យសួរដែលជាទីអាស្រ័យរបស់បុគ្គលដែលដល់ព្រមដោយករណីយកិច្ច ដែលជាចំណែកខាងដើម ជាអ្នកបំពេញសីលដោយប្រការទាំងពួង និងជាពាក្យបដិសេធការៈយ៉ាងនោះរបស់សាសនាដទៃ សមដូចព្រះតម្រាស់ដែលត្រាស់ទុក ( ក្នុងមជ្ឈិមនិកាយមូលបណ្ណាសក ) ថា ម្នាលភិក្ខុទាំងឡាយសមណៈ ( ទី ១ ) ( គឺសោតាបន្ន ) មានតែក្នុងសាសនានេះ ។បេ។ វាទៈ ( គឺទិដ្ឋិ ៦២ ) របស់សាសនាដទៃសូន្យចាកសមណៈទាំងឡាយ ដូច្នេះ ។

បទថា **ភិក្ខុ** ជាពាក្យសម្ដែងបុគ្គលដែលបំពេញសីលនោះ បទថា **ចាដិ-មោក្ខសំវរសំវុតោ** នេះជាពាក្យសម្ដែងភាពដែលបុគ្គលនោះតាំងនៅក្នុងការសង្រួមក្នុងបាតិមោក្ខ ។

បទថា **វិហរតិ** នេះជាពាក្យសម្ដែងភាពដែលបុគ្គលនោះ មានការដល់ព្រមដោយវិហារធម៌ ដែលសមគួរដល់បាតិមោក្ខសំវរៈនោះ ។

បទថា **អាចារគោចរសម្បន្នោ** នេះជាពាក្យសម្ដែងធម៌ដែលជាឧបការៈដល់បាតិមោក្ខសំវរៈរបស់បុគ្គលនោះ ។

បទថា **អណុមត្តេសុ វជ្ជេសុ ភយទស្សាវី** នេះជាពាក្យសម្ដែងនូវការមិនឃ្លៀងឃ្លាតចាកបាតិមោក្ខជាធម្មតារបស់បុគ្គលនោះ ។

បទថា **សមាទាយ** នេះ ជាពាក្យសម្ដែងនូវការកាន់យកសិក្ខាបទទាំងឡាយដោយគ្រប់គ្រាន់របស់បុគ្គលនោះ ។

បទថា **សិក្ខតិ** នេះជាពាក្យសម្ដែងភាពជាបុគ្គលដែលមានការដល់ព្រម

ដោយសិក្ខារបស់បុគ្គលនោះ ។

បទថា **សិក្ខាបទេសុ** នេះជាពាក្យសម្ដែងធម៌ដែលគប្បីសិក្សារបស់បុគ្គលនោះ ។

បណ្ដាបទទាំងនោះ បទថា **ភិក្ខុ** សេចក្ដីថា ឈ្មោះថា **ភិក្ខុ** ព្រោះអត្ថថា ឃើញភ័យក្នុងសង្សារវដ្ដ ឈ្មោះថា **សីលវា** ព្រោះអត្ថថា សីលរបស់ភិក្ខុនោះមាន ។ បទថា **សីលំ** ក្នុងទីនេះគឺអ្វី ឈ្មោះថា **សីលំ** ព្រោះអត្ថថា ការបដិបត្តិ ។ ឈ្មោះថាការបដិបត្តិនេះគឺអ្វី គឺការសមាទាន សេចក្ដីថា ភាពជាអ្នកមានកាយកម្មជាដើម មិនគ្នាំគ្នងដោយអំណាចនៃភាពជាបុគ្គលមានសីលល្អ ឬថាជាទីទទួល សេចក្ដីថា ជាទីទទួលកុសលធម៌ទាំងឡាយដោយអំណាចជាទីតាំង ។ ក្នុងបទនេះ អ្នកប្រាជ្ញដឹងនូវលក្ខណសព្ទ រមែងព្រមទទួលនូវអត្ថទាំងពីរនោះឯង តែអាចារ្យដទៃៗពណ៌នាទុកថា ឈ្មោះថា **សីលំ** ដោយអត្ថថា ប្រព្រឹត្តតឹងរឹង ដោយអត្ថថា អាចារៈ ដោយអត្ថថា ការបដិបត្តិដោយអត្ថថា សីសៈ ដោយអត្ថថា ត្រជាក់ ដោយអត្ថថា ជាទីផុតភ័យ ។

ការបដិបត្តិជាលក្ខណៈរបស់សីល សូម្បីពង្រីកទៅជាច្រើនប្រការដូចភាពជាវត្ថុដែលឃើញបានជាលក្ខណៈរបស់រូប ដែលពង្រីកទៅជាច្រើនប្រការដូច្នោះ ។

ដូចភាពជាវត្ថុដែលឃើញបាន ជាលក្ខណៈរបស់រូបាយតនៈ ដូចពង្រីកចេញទៅជាប្រភេទផ្សេងៗ មានខៀវនិងលឿងជាដើម ព្រោះមិនផុតទៅអំពីភាវៈជាវត្ថុដែលឃើញបាន ដែលពង្រីកចេញទៅដោយប្រភេទ មានពណ៌ខៀវ

ជាដើមយ៉ាងណា ការបដិបត្តិដែលពោលទុកដោយអំណាចសមាទាន កាយកម្ម ជាដើម និងដោយអំណាចជាទីតាំងនៃកុសលធម៌ទាំងឡាយនោះឯង ជាលក្ខណៈរបស់សីល សូម្បីពង្រីកជាច្រើនប្រការ មានប្រភេទចេតនាជាដើម ព្រោះមិនកន្លងផុតការសមាទាននិងភាពជាទីតាំងនៃសីល សូម្បីពង្រីកជាប្រភេទ ចេតនាជាដើមដូច្នោះ ( សមដូចគាថាថា )

ការកម្ចាត់ភាពជាអ្នកទ្រុស្តសីលនិងគុណដែលមិនមានទោស
លោកពោលថា ជារសរបស់សីល ដែលមានលក្ខណៈយ៉ាង
នេះ ដោយអត្ថថា ជាកិច្ចនិងសម្បត្តិ ដូច្នេះ ។

ព្រោះដូច្នោះ ឈ្មោះថា សីលនេះ គប្បីជ្រាបថា មានការកម្ចាត់ភាពជាអ្នកទ្រុស្តសីលជារស ដោយរសដែលមានអត្ថថាជាកិច្ច ( និង ) មានគុណមិនមានទោសជារស ដោយរសដែលមានអត្ថថាជាសម្បត្តិ ។

អ្នកប្រាជ្ញទាំងឡាយពណ៌នាសីលនោះថា មានការស្អាតជា
បច្ចុប្បដ្ឋាន មានឱត្តប្បៈនិងហិរិជាបទដ្ឋានរបស់សីលនោះ
ដូច្នេះ ។

សីលនោះមានការស្អាត ដែលលោកពោលទុកយ៉ាងនេះថា ការស្អាតកាយ ការស្អាតវាចា ការស្អាតក្នុងចិត្ត ជាបច្ចុប្បដ្ឋានរមែងប្រាកដ គឺដល់នូវការទទួលយកដោយការស្អាត ។ ហិរិនិងឱត្តប្បៈ អ្នកប្រាជ្ញទាំងឡាយពណ៌នាថា ជាបទដ្ឋានរបស់សីលនោះ អធិប្បាយថា ជាហេតុជិត ព្រោះថា កាលហិរិនិងឱត្តប្បៈមាន សីលរមែងកើតឡើងនិងតាំងនៅ កាលហិរិនិងឱត្តប្បៈមិនមាន

*សីលរមែងមិនកើតឡើង រមែងមិនតាំងនៅដូច្នេះឯង ។ បុគ្គលជាអ្នកមានសីល ដោយសីលដូចអធិប្បាយមកនេះ ។ ធម៌មានចេតនាជាដើមរបស់បុគ្គលដែលវៀរចាកបាណាតិបាតជាដើមក្តី របស់បុគ្គលដែលបំពេញវត្តបដិបត្តិក្តី គប្បីជ្រាបថា ឈ្មោះថា* **សីល** *សមដូចលោកពោលទុកក្នុងបដិសម្ភិទាមគ្គថា សំណួរថា អ្វីឈ្មោះថាសីល ចេតនា ឈ្មោះថាសីល ចេតសិក ឈ្មោះថាសីល សេចក្តីសង្រួម ឈ្មោះថាសីល ការមិនប្រព្រឹត្តកន្លង ឈ្មោះថាសីល ដូច្នេះ ។*

*បណ្តាសីលទាំងនោះ ចេតនារបស់បុគ្គលដែលវៀរចាកបាណាតិបាត ជាដើមក្តី របស់បុគ្គលដែលបំពេញវត្តបដិបត្តិក្តី ឈ្មោះថា* **ចេតនាសីល** *។ ការវៀរចាករបស់បុគ្គល ដែលវៀរចាកបាណាតិបាតជាដើម ឈ្មោះថា ចេតសិកសីល ។ម្យ៉ាងទៀត ចេតនាក្នុងកម្មបថ ៧ របស់បុគ្គលដែលលះបាណាតិ-បាតជាដើម ឈ្មោះថា* **ចេតនាសីល** *។ ធម៌គឺការមិនសម្លឹងរំពៃ មិនព្យាបាទ និងសម្មាទិដ្ឋិដែលត្រាស់ទុកក្នុងសំយុត្តនិកាយមហាវគ្គ ដោយន័យជាដើម ជាភិក្ខុនោះ រមែងលះបង់នូវអភិជ្ឈាក្នុងលោកនៅដោយចិត្តគ្មានអភិជ្ឈា*[១] *ដូច្នេះ ឈ្មោះថា* **ចេតសិកសីល** *។ ពាក្យថា សេចក្តីសង្រួម ក្នុងពាក្យថា សេចក្តីសង្រួមឈ្មោះថាសីល នេះគប្បីជ្រាបថា មាន ៥ យ៉ាងគឺ បាតិមោក្ខសំវរៈ ១ សតិសំវរៈ ១ ញាណសំវរៈ ១ ខន្តិសំវរៈ ១ វីរិយសំវរៈ ១ ការធ្វើសំវរៈនោះផ្សេងៗគ្នានឹងមានច្បាស់ខាងមុខ ។*

---

*១-ក្នុងទីនេះលោកប្រាប់ថាជាន័យក្នុងសំយុត្តនិកាយ មហាវគ្គ តែព្រះតម្រាស់នេះ មានក្នុងទីឃនិកាយ សាមញ្ញផលសូត្រ ។*

ពាក្យថា ការមិនប្រព្រឹត្តកន្លង ឈ្មោះថាសីល សេចក្តីថា ការមិនឈ្លានកន្លងផ្លូវកាយ ផ្លូវវាចារបស់បុគ្គលអ្នកសមាទានសីល ក្នុងទីនេះគប្បីជ្រាបថា ពាក្យថា សេចក្តីសង្រួមឈ្មោះថាសីល ការមិនប្រព្រឹត្តកន្លង ឈ្មោះថាសីលនេះឯង ជាសីលដោយត្រង់ ពាក្យថាចេតនា ឈ្មោះថាសីល ចេតសិកឈ្មោះថាសីល ជាសីលដោយបរិយាយ គឺដោយអម ។

បទថា **ធាតិមោក្ខំ** បានដល់ សីលចំណែកដែលជាសិក្ខាបទ ព្រោះសីលនោះដោះ គឺដោះបុគ្គលដែលរក្សាសីលនោះឲ្យផុតចាកទុក្ខទាំងឡាយ មានទុក្ខដែលប្រព្រឹត្តទៅក្នុងអបាយជាដើម ដូច្នោះ ទើបលោកហៅថា **ធាតិមោក្ខ** ។

បទថា **ធាតិមោក្ខសំវរសំវុតោ** បានដល់ ដែលប្រកបដោយការសង្រួមក្នុងបាតិមោក្ខ ។

បទថា **អាចារគោចរសម្បន្នោ** បានដល់ ជាអ្នកដល់ព្រមដោយអាចារៈនិងគោចរៈ ។

បទថា **អណុមត្តេសុ** បានដល់ មានប្រមាណតិចតួច ។ បទថា **វជ្ជេសុ** បានដល់ ក្នុងអកុសលធម៌ទាំងឡាយ ។ បទថា **ភយទស្សាវី** បានដល់ ឃើញនូវភ័យ ។ បទថា **សមាទាយ** បានដល់ កាន់យកដោយប្រពៃ ។ បទថា **សិក្ខតិ សិក្ខាបទេសុ** បានដល់ សមាទានសិក្សានូវសិក្ខាបទនោះៗ ។

ម្យ៉ាងទៀតបទថា **សមាទាយ សិក្ខតិ សិក្ខាបទេសុ** សេចក្តីថា សមាទានសិក្សារបស់ណាមួយដែលគួរសិក្សាក្នុងសិក្ខាបទទាំងឡាយ គឺក្នុងចំណែកនៃសិក្ខាទាំងឡាយ ផ្លូវកាយក្តី ផ្លូវវាចាក្តី ទាំងអស់នោះ ។

*បទថា* **ខុទ្ទកោ សីលក្ខន្ធោ** *បានដល់ សីលក្ខន្ធដែលជាចំណែកសេសសល់ មានសង្ឃាទិសេសជាដើម ។*

*បទថា* **មហន្តោ** *បានដល់ ដែលមិនមានចំណែកសេសសល់ មានបារាជិកជាដើម ។*

*ព្រោះភិក្ខុ ឈ្មោះថារមែងតាំងនៅក្នុងសាសនាដោយបាតិមោក្ខសីល ដូច្នោះ បាតិមោក្ខសីលនោះ ទើបលោកពោលថា* **បតិដ្ឋា** *។ ឈ្មោះថា* **បតិដ្ឋា** *ព្រោះអត្ថថា ជាទីតាំងនៃភិក្ខុ ឬជាទីតាំងនៃកុសលធម៌ទាំងឡាយប៉ុណ្ណោះ អត្ថនេះគប្បីជ្រាបដោយអំណាចនៃសូត្រ ( សំយុត្តនិកាយសគាថវគ្គ ) ជាដើមថា* **សីលេ បតិដ្ឋាយ នរោ សបញ្ញោ** *នរជនមានប្រាជ្ញា បានតាំងមាំក្នុងសីលហើយ ដូច្នេះ ឬថា បពិត្រមហារាជ សីលជាទីតាំងនៃកុសលធម៌ទាំងពួង ដូច្នេះ ឬថា បពិត្រមហារាជ ។បេ។ កុសលធម៌ទាំងពួងរបស់បុគ្គលដែលតាំងនៅក្នុងសីល រមែងមិនវិនាសទៅ ដូច្នេះ ។*

*សីលនោះឈ្មោះថា* **អាទិ** *ដោយអត្ថថា កើតឡើងមុន សមដូចព្រះតម្រាស់ត្រាស់ទុក ( ក្នុងសំយុត្តនិកាយមហាវារវគ្គ ) ថា ម្នាលឧត្តិយៈ បើដូច្នោះ ក្នុងសាសនានេះ អ្នកចូរជម្រះនូវដើមនៃកុសលធម៌ទាំងឡាយសិន ។ ចុះអ្វី ជាដើមនៃកុសលធម៌ទាំងឡាយ ។ គឺសីលស្អាតល្អ ១ ទិដ្ឋិត្រង់ ១ ដូច្នេះ ។ ដូចនាយជាងសាងនគរ បំណងនឹងសាងនគរ ទើបជម្រះទីតាំងរបស់នគរមុន បន្ទាប់អំពីនោះ ទើបសាងនគរ បែងចែកជាវិថី ផ្លូវបែកជា ៤ ផ្លូវបែកជា ៣ ក្នុងខាងក្រោយ យ៉ាងណា ព្រះយោគាវចរ ជម្រះសីលជាខាង

ដើម បន្ទាប់អំពីនោះ ទើបធ្វើឲ្យជាក់ច្បាស់នូវសមាធិ វិបស្សនា មគ្គ ផល និងនិព្វានក្នុងកាលជាខាងក្រោយ យ៉ាងនោះដូចគ្នា ។ ឬថា ជាងជ្រលក់សំពត់ បោកសំពត់ដោយទឹកក្បុង ៣ [១]យ៉ាងជាមុន កាលសំពត់ស្អាតហើយ ទើបដាក់ពណ៌តាមដែលត្រូវការយ៉ាងណា ឬថាជាងគំនូរអ្នកឈ្លាស ត្រូវការគូររូបភាព ទើបដុសខាត់សំពត់ជាខាងដើម បន្ទាប់អំពីនោះ ទើបសាងរូបភាពឡើងក្នុងកាលជាក្រោយយ៉ាងណា ព្រះយោគាវចរ ជម្រះសីលឲ្យបរិសុទ្ធអំពីខាងដើមនោះឯង ហើយធ្វើឲ្យជាក់ច្បាស់នូវធម៌ទាំងឡាយ មានសមថៈនិងវិបស្សនាជាដើម ក្នុងកាលខាងក្រោយ ក៏យ៉ាងនោះដូចគ្នា ព្រោះហេតុនោះ ទើបលោកពោលថា សីលជាខាងដើមដូច្នេះ ។

សីលនោះ ឈ្មោះថា **ចរណំ** ព្រោះជាគុណដែលគប្បីឃើញស្មើដោយចរណៈ ។ ជើងក៏លោកហៅថា ចរណៈ ដូចពាក្យថា អភិសង្ខារ គឺការចូលទៅកាន់ទិស រមែងមិនកើតដល់បុគ្គលដែលមានជើងដាច់ រមែងកើតដល់បុគ្គលដែលមានជើងបរិបូណ៌ប៉ុណ្ណោះយ៉ាងណា ការទៅដោយញាណ ដើម្បីសម្រេចនិព្វាន រមែងមិនសម្រេចដល់បុគ្គលដែលមានសីលដាច់ សីល ពព្រុស សីលពពាល មិនបរិបូណ៌នោះ ។ តែការទៅដោយញាណដើម្បីសម្រេចនិព្វាន រមែងសម្រេចដល់បុគ្គលដែលមានសីលមិនដាច់ មិនពព្រុស បរិបូណ៌ដូច្នោះ ព្រោះហេតុនោះ ទើបលោកពោលសីលថា **ចរណំ** ។

សីលនោះ ឈ្មោះថា **សំយមោ** ដោយអំណាចនៃការសង្រួម ឈ្មោះថា

---

១-ទឹកក្បុង ៣ យ៉ាងគឺ ទឹកក្បុងធ្វើអំពីអំពិល ១ ទឹកក្បុងធ្វើអំពីផេះ ១ ទឹកក្បុងធ្វើអំពីគោម័យ ១ ។

**សំវរោ** ដោយអំណាចនៃការរាំងប្រយ័ត្ន ហេតុនោះ ទើបលោកពោលសីល គឺសំយមៈនិងសំវរៈដោយបទទាំងពីរ ក្នុងបទនេះ មានអត្ថនៃពាក្យថា ដូច្នេះថា ឈ្មោះថា **សំយមោ** ព្រោះអត្ថថា សង្រួមនូវការអន្ទះអន្ទែង ដើម្បីឈានកន្លង ឬញ៉ាំងបុគ្គលឲ្យសង្រួម គឺមិនឲ្យបុគ្គលនោះអន្ទះអន្ទែងដោយអំណាចការឈានកន្លង ។

ឈ្មោះថា **សំវរោ** ព្រោះអត្ថថា រាំងប្រយ័ត្ន គឺបិទនូវទ្វារដោយការសង្រួមការឈានកន្លង ។

បទថា **មុខំ** បានដល់ ឧត្តម ឬជាប្រមុខ ដូចអាហារ ៤ របស់សត្វទាំងឡាយ ចូលតាមមាត់ហើយ ផ្សាយទៅកាន់អវយវៈផ្សេងៗយ៉ាងណា កុសលដែលប្រព្រឹត្តទៅក្នុងភូមិ ៤ របស់ព្រះយោគាវចរទាំងឡាយក៏យ៉ាងនោះ ចូលតាមមាត់ គឺសីល ហើយញ៉ាំងនូវការសម្រេចនៃប្រយោជន៍ឲ្យដល់ព្រម ព្រោះហេតុនោះ ពាក្យថា ប្រមុខ ទើបមានសេចក្តីថា ជាធំ ជាសភាវៈដល់មុន ប្រសើរបំផុតជាប្រធាន ។

បទថា **កុសលានំ ធម្មានំ សមាបត្តិយា** សេចក្តីថា គប្បីជ្រាបថាជាប្រមុខ ជាប្រធាន ជាសភាវៈដល់មុន ជាវត្ថុប្រសើរបំផុត ជាប្រធាន ដើម្បីប្រយោជន៍ដល់ការបានចំពោះនូវកុសលដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ។ បទថា **វិវិច្ចេវ កាមេហិ** សេចក្តីថា ស្ងាត់ គឺវៀរ គឺជៀសចេញចាកកាមទាំងឡាយ **ឯវ** សព្ទ ក្នុងបទថា **វិវិច្ចេវ** នេះ គប្បីជ្រាបថា មានការពិតប្រាកដព្រោះមានអត្ថទៀងទាត់ ហេតុនោះ ទើបលោកសម្តែងភាពដែលកាមទាំងឡាយមិនមាន

ក្នុងពេលចូលបឋមជ្ឈាន ជាបដិបក្ខចំពោះបឋមជ្ឈាននោះ និងការសម្រេចបឋមជ្ឈាននោះ ដោយការលះកាមនោះឯង សេចក្តីនោះដូចម្តេច កាលធ្វើនូវការពិតប្រាកដ យ៉ាងនេះថា **វិវិច្ចេវ កាមេហិ** ដូច្នេះបឋមជ្ឈាននេះ រមែងប្រាកដ ។ កាមទាំងឡាយនៅជាបដិបក្ខចំពោះឈាននេះពិត កាលកាមពួកណាមានបឋមជ្ឈាននេះរមែងមិនប្រព្រឹត្តទៅ ដូចកាលងងឹតមាន ពន្លឺនៃប្រទីបក៏មិនមានការសម្រេចនូវបឋមជ្ឈាននោះ រមែងមានដោយការលះនូវកាមទាំងនោះឯង ដូចបុគ្គលលះនូវត្រើយអាយ ដល់នូវត្រើយនាយដូច្នោះ ព្រោះហេតុនោះទើបធ្វើនូវការពិតប្រាកដ ។ ក្នុងរឿងនោះ គប្បីមានពាក្យសួរថា ហេតុអ្វីការពិតប្រាកដនេះ ទើបលោកពោលទុកក្នុងបទដំបូងប៉ុណ្ណោះ មិនពោលក្នុងបទក្រោយ បុគ្គលមិនស្ងាត់ចាកអកុសលធម៌ទាំងឡាយ គប្បីចូលបឋមជ្ឈានឬក្នុងសេចក្តីនេះ មិនគប្បីឃើញយ៉ាងនោះឡើយ ដ្បិតថា លោកពោលការពិតប្រាកដក្នុងបទដំបូងប៉ុណ្ណោះ ដោយការចេញទៅចាកកាមនោះ ឈាននេះ ជាគ្រឿងចេញទៅរបស់កាមទាំងឡាយនោះឯង ព្រោះឈានកន្លងដោយល្អ នូវកាមធាតុនិងព្រោះជាបដិបក្ខចំពោះកាមរាគៈ ដូចព្រះតម្រាស់ ( ក្នុងខុទ្ទកនិកាយឥតិវុត្តក ) ថា ការរលាស់ចេញចាកកាមទាំងឡាយនេះ បានដល់នេក្ខម្មៈ ដូច្នេះ ។ ក្នុងបទក្រោយលោកគប្បីពោលដូចដែលព្រះមានព្រះភាគទ្រង់នាំ **ឯវ** អក្ខរៈមកត្រាស់ទុកក្នុងសេចក្តីនេះថា **ឥធេវ ភិក្ខវេ បឋមោ សមណោ ឥធ ទុតិយោ សមណោ** ម្នាលភិក្ខុទាំងឡាយ សមណៈ ( ទី១ ) ( គឺសោតាបន្ន ) មានតែក្នុងសាសនានេះ សមណៈ ទី ២ ( គឺសកទា-

គាមី ) ក៏មានតែក្នុងសាសនានេះ ដូច្នេះ ។ ព្រោះមិនអាចមិនស្ងាត់ចាក អកុសលធម៌ ពោលគឺនីវរណៈដទៃៗអំពីនេះហើយ ចូលឈានបាន ដូច្នោះ គប្បីឃើញសេចក្តីនេះ ទាំងពីរបទយ៉ាងនេះថា ស្ងាត់ចាកកាមទាំងឡាយស្ងាត់ ចាកអកុសលធម៌ទាំងឡាយ ។ តទង្គវិវេក វិក្ខម្ភនវិវេក សមុច្ឆេទវិវេក បដិបស្សទ្ធិវិវេក និស្សរណវិវេកនិងចិត្តវិវេក កាយវិវេក ឧបធិវិវេក រមែង ដល់នូវការសង្គ្រោះ ដោយពាក្យដែលជាសាធារណៈនេះថា ស្ងាត់ក៏ពិត តែ ទោះជាដូច្នោះកាយវិវេក ចិត្តវិវេក វិក្ខម្ភនវិវេក គប្បីឃើញក្នុងកាលដែលជា ចំណែកខាងដើម ។ កាយវិវេក ចិត្តវិវេក សមុច្ឆេទវិវេកនិងនិស្សរណវិវេក គប្បីឃើញក្នុងខណៈនៃលោកុត្តរមគ្គ ។

វត្ថុកាមពួកណា ដែលលោកពោលទុកក្នុងទីនេះជាដើមថា វត្ថុកាមដូចម្តេច គឺរូបដែលគួរពេញចិត្តដូច្នេះ និងកិលេសកាមពួកណា ដែលពោលទុកក្នុងទី នេះយ៉ាងនេះថា កាមគឺឆន្ទៈ កាមគឺរាគៈ កាមគឺឆន្ទរាគៈ កាមគឺសង្កប្បៈ កាម គឺរាគៈ កាមគឺសង្កប្បរាគៈដូច្នេះ វត្ថុកាមនិងកិលេសកាមទាំងអស់នោះ គប្បី ឃើញថា លោកសង្គ្រោះដោយបទ នេះថា **កាមេហិ** ដូច្នេះទាំងអស់ ។

កាលបើយ៉ាងនោះ បទថា **វិវិច្ចេវ កាមេហិ** មានអត្ថថា ស្ងាត់ហើយ ចាកវត្ថុកាមទាំងឡាយ ក៏ត្រឹមត្រូវ ។ ដោយបទនោះ កាយវិវេក ឈ្មោះថា ពោលទុកហើយ ។

បទថា **វិវិច្ច អកុសលេហិ ធម្មេហិ** សេចក្តីថា ស្ងាត់ហើយចាកកិលេស កាមទាំងឡាយ ឬចាកអកុសលទាំងពួងក៏ត្រឹមត្រូវ ។ ដោយបទនោះ ចិត្តវិវេក

ឈ្មោះថាពោលហើយក្នុងសេចក្តីនេះ ការលះកាមសុខ ជាការដែលលោកធ្វើឲ្យជាក់ច្បាស់ហើយដោយពាក្យថា ស្ងាត់ចាកវត្ថុកាមទាំងឡាយនោះឯងដោយបទដំបូង ។ ការកំណត់នេក្ខម្មសុខ ឈ្មោះថាលោកធ្វើឲ្យជាក់ច្បាស់ហើយដោយពាក្យថា ស្ងាត់ចាកកិលេសកាមទាំងឡាយដោយបទទី ២ ។ ព្រោះពាក្យថា ស្ងាត់ចាកវត្ថុកាមនិងកិលេសកាមទាំងឡាយយ៉ាងនេះនោះឯង កាលលះសង្កិលេសវត្ថុនៃកាមទាំងនោះ ឈ្មោះថា លោកធ្វើឲ្យជាក់ច្បាស់ហើយដោយពាក្យដំបូង កាលលះសង្កិលេសឈ្មោះថា លោកធ្វើឲ្យជាក់ច្បាស់ហើយដោយបទទី ២ កាលលះហេតុនៃការល្មោភ ឈ្មោះថាលោកធ្វើឲ្យជាក់ច្បាស់ហើយដោយបទដំបូង កាលលះហេតុនៃភាពជាបុគ្គលពាល ឈ្មោះថាលោកធ្វើឲ្យជាក់ច្បាស់ហើយដោយបទទី ២ ។ សេចក្តីបរិសុទ្ធនៃសេចក្តីព្យាយាម ឈ្មោះថា លោកធ្វើឲ្យជាក់ច្បាស់ហើយដោយបទដំបូង ការជម្រះអាសយៈដែលអាស្រ័យឲ្យស្អាត ឈ្មោះថា លោកធ្វើឲ្យជាក់ច្បាស់ហើយដោយបទទី ២ គប្បីជ្រាបដោយប្រការដូច្នេះ ។ បណ្តាកាមទាំងឡាយដែលលោកពោលទុកក្នុងបទថា **កាមេហិ** នេះ ក្នុងចំណែកវត្ថុកាម មានន័យប៉ុណ្ណេះសិន ។

តែក្នុងចំណែកកិលេសកាម កាមឆន្ទៈនោះឯងដែលមានប្រភេទមិនតិចជាដើមថា ឆន្ទៈនិងរាគៈ លោកបំណងថាកាម កាមនោះ សូម្បីទាក់ទងក្នុងអកុសល ព្រះមានព្រះភាគក៏ចែកត្រាស់ទុកក្នុងវិភង្គដោយជាបដិបក្ខចំពោះឈាន ដោយន័យថា **តត្ថ កតមោ កាមច្ឆន្ទោ កាមោ** ដូច្នេះ ជាដើម ។

ម្យ៉ាងទៀត លោកពោលកាមទុកក្នុងបទដំបូង ព្រោះជាកិលេសកាម

ពោលទុកក្នុងបទទី ២ ព្រោះទាក់ទងក្នុងអកុសល ម្យ៉ាងទៀត លោកមិនពោលថា **កាមតោ** តែពោលថា **កាមេហិ** ព្រោះកាមមានប្រភេទមិនមែនតិច ម្យ៉ាងទៀត កាលធម៌ដទៃជាអកុសលមាន ព្រះមានព្រះភាគក៏ត្រាស់ដល់នីវរណៈនោះឯង ដោយសម្ដែងភាពជាសត្រូវ និងជាបដិបក្ខចំពោះអង្គឈានខាងលើ ៗ ទុកក្នុងវិភង្គដោយន័យជាដើមថា បណ្ដាធម៌ទាំងនោះ ពួកធម៌ជាអកុសល តើដូចម្ដេច ។ កាមច្ឆន្ទៈ ដូច្នេះ ។ នីវរណៈទាំងឡាយជាសត្រូវចំពោះអង្គឈានទាំងឡាយ លោកពោលអធិប្បាយទុកថា អង្គឈានទាំងឡាយនោះឯងជាបដិបក្ខ ជាអ្នកទម្លាយ ជាអ្នកពិឃាតនីវរណៈទាំងនោះ ។ ពិតយ៉ាងនោះ លោកពោលទុកក្នុងគម្ពីរបិដកថា សមាធិជាបដិបក្ខចំពោះកាមច្ឆន្ទៈ បីតិជាបដិបក្ខចំពោះព្យាបាទៈ វិតក្កជាបដិបក្ខចំពោះថីនមិទ្ធៈ សុខៈជាបដិបក្ខចំពោះឧទ្ធច្ចកុក្កុច្ចៈ វិចារៈជាបដិបក្ខចំពោះវិចិកិច្ឆា ។ ដោយប្រការដូច្នេះ ក្នុងពាក្យទាំងពីរនោះ ការស្ងាត់ដោយការសង្កត់សង្កិនកាមច្ឆន្ទៈ ឈ្មោះថាលោកពោលហើយដោយពាក្យថា **វិវិច្ចេវ កាមេហិ** នេះ ។ ការស្ងាត់ដោយការសង្កត់សង្កិននីវរណៈទាំង ៥ ឈ្មោះថាលោកពោលហើយដោយបទថា **វិវិច្ច អកុសលេហិ ធម្មេហិ** នេះ ។ ម្យ៉ាងទៀត គប្បីជ្រាបថា ដោយការកំណត់ដល់វត្ថុ ដែលមិនបានកំណត់យកការស្ងាត់ ដោយការសង្កត់កាមច្ឆន្ទៈ ឈ្មោះថាលោកពោលហើយដោយបទដំបូង ការស្ងាត់ដោយការសង្កត់នីវរណៈដ៏សេស ឈ្មោះថា លោកពោលហើយដោយបទទី ២ ។

ដោយប្រការនោះ ក្នុងអកុសលមូល ៣ ការស្ងាត់ដោយការសង្កត់លោកៈ

ដែលមានប្រភេទនៃកាមគុណ ៥ ជាអារម្មណ៍ ឈ្មោះថាលោកពោលហើយដោយបទដំបូង ការស្វាត់ដោយការសង្កត់ទោសៈនិងមោហៈដែលមានប្រភេទនៃអឃាតវត្ថុជាដើមជាអារម្មណ៍ រមែងឈ្មោះថា លោកពោលហើយដោយបទទី ២ ។

ម្យ៉ាងទៀត ក្នុងធម៌ទាំងឡាយមានឱឃៈជាដើម ការស្វាត់ដោយភាពជាអ្នកសង្កត់នូវកាមោឃៈ កាមយោគៈ កាមាសវៈ កាមុបាទាន អភិជ្ឈាកាយគន្ថៈនិងកាមរាគសំយោជនៈ ឈ្មោះថាលោកពោលហើយដោយបទដំបូង ។ ការស្វាត់ដោយការសង្កត់នូវឱឃៈ យោគៈ អាសវៈ ឧបាទាន គន្ថៈ និងសំយោជនៈដ៏សេស ឈ្មោះថាលោកពោលហើយដោយបទទី ២ ។

ការស្វាត់ដោយការសង្កត់នូវតណ្ហា និងធម៌ដែលសម្បយុត្តដោយតណ្ហានោះ ឈ្មោះថាលោកពោលហើយដោយបទដំបូង ការស្វាត់ដោយការសង្កត់នូវអវិជ្ជា និងធម៌ដែលសម្បយុត្តដោយអវិជ្ជានោះ ឈ្មោះថាលោកពោលហើយដោយបទទី ២ ។

ម្យ៉ាងទៀត ការស្វាត់ដោយការសង្កត់នូវចិត្តុប្បាទៈ ៨ ដែលសម្បយុត្តដោយលោភៈ ឈ្មោះថាលោកពោលហើយដោយបទដំបូង ការស្វាត់ដោយការសង្កត់នូវចិត្តុប្បាទៈដែលជាអកុសលទី ៤ ដ៏សេស ឈ្មោះថាលោកពោលហើយដោយបទទី ២ ។

ព្រះសារីបុត្តត្ថេរ សម្តែងអត្ថនៃការលះនៃបឋមជ្ឈាន ដោយពាក្យមានប្រមាណប៉ុណ្ណេះហើយ ឥឡូវនេះ ដើម្បីសម្តែងអត្ថនៃការប្រកប ទើបពោលពាក្យជាដើមថា **សវិតក្កំ សវិចារំ** ដូច្នេះ ។

បណ្ដាវិតក្ក និងវិចារៈទាំងនោះ វិតក្កមានលក្ខណៈលើកចិត្តឡើងកាន់អារម្មណ៍ វិចារៈមានលក្ខណៈផ្គងចិត្តទុកក្នុងអារម្មណ៍ ។ កាលវិតក្កនិងវិចារៈទាំងនោះ មិនបែកគ្នាក្នុងអារម្មណ៍ណាមួយ វិតក្កចូលដល់ចិត្តមុន ដោយអត្ថថា គ្រោតគ្រាតនិងជាធម្មជាតិដល់មុន ដូចការគោះជួង វិចារៈ តាមពាក់ព័ន្ធ ដោយអត្ថថា ល្អិតនិងដោយសភាវៈតាមបពោសអង្អែល ដូចសំឡេងលាន់ឮរបស់ជួង ។

វិតក្កមានការផ្សាយទៅក្នុងអារម្មណ៍ នេះជាការញាប់ញ័ររបស់ចិត្តក្នុងពេលដែលកើតឡើងគ្រាដំបូង ដូចការទទះស្លាបរបស់បក្សីដែលត្រូវការនឹងហើរទៅក្នុងអាកាសនិងដូចការសម្ទុះស្លាបចុះត្រង់ផ្កាឈូក របស់ភមរៈដែលមានចិត្តជាប់ជំពាក់ក្នុងក្លិន ។ វិចារៈមានការប្រព្រឹត្តទៅស្ងប់ មិនជាការញាប់ញ័រពេករបស់ចិត្ត ដូចការសំកាំងស្លាបរបស់បក្សីដែលបង្អន់ក្នុងអាកាស និងដូចការក្រឡឹងរបស់ភមរៈត្រង់គុម្ពឈូកនិងខាងលើផ្កាឈូក ។

តែក្នុងអដ្ឋកថា ទុកនិបាត លោកពោលថា វិតក្កប្រព្រឹត្តទៅដោយភាវៈលើកចិត្តឡើងកាន់អារម្មណ៍ ដូចបក្សីធំហើរទៅក្នុងអាកាស ស្លាបទាំងពីរជក់ខ្យល់ ហើយក៏ឈប់ទទះស្លាបហើរទៅដូច្នោះ វិចារៈប្រព្រឹត្តទៅដោយភាវៈតាមបពោសអង្អែលនូវអារម្មណ៍ ដូចការហើរទៅរបស់បក្សីដែលទទះស្លាបដើម្បីឲ្យជក់ខ្យល់ដូច្នោះ ពាក្យនោះរមែងគួរក្នុងការប្រព្រឹត្តទៅដោយការតាមពាក់ព័ន្ធ ។ ការប្លែកគ្នារបស់វិតក្កនិងវិចារៈទាំងនោះ រមែងប្រាកដក្នុងបឋមឈាននិងទុតិយជ្ឈាន ។

ម្យ៉ាងទៀត កាលបុគ្គលប្រើដៃម្ខាង ចាប់ភាជនៈសំរិទ្ធិដែលមានច្រែះយ៉ាងមាំ ប្រើដៃម្ខាងទៀតដុសដោយប្រាស់ ដែលធ្វើដោយរោមកន្ទុយសេះដែលជ្រលក់ដោយប្រេង ផ្សំដោយលម្អិត វិតក្កដូចដៃដែលចាប់យ៉ាងមាំ វិចារៈដូចដៃដែលដុសខាត់ ។ ឧបមាម្យ៉ាងទៀត ដូចស្មូនឆ្នាំង ប្រើកំណាត់ឈើបង្វិលធ្វើភាជនៈ វិតក្កដូចដៃដែលសង្កត់ វិចារៈដូចដៃដែលជំផ្សំខាងនោះ ខាងនេះ និងដូចបុគ្គលធ្វើកង់រទេះ វិតក្កលើកចិត្តឡើងកាន់អារម្មណ៍ ដូចជើងដែលដោតត្រង់កណ្តាល វិចារៈតាមបបោសអង្អែលដូចជើងដែលវិលជុំវិញខាងក្រៅ ។ ឈាននេះលោកពោលថា **សវិតក្កំ សវិចារំ** ព្រោះអត្ថថា រមែងប្រព្រឹត្តទៅដោយវិតក្កនេះផង ដោយវិចារៈនេះផង ដូចដើមឈើមានទាំងផ្កានិងផ្លែដោយប្រការដូច្នេះ ។

ក្នុងបទថា **វិវេកជំ** នេះ ការស្ងាត់ឈ្មោះថា វិវេក សេចក្តីថា ប្រាសចាកនីវរណៈ ។ ម្យ៉ាងទៀត ឈ្មោះថាវិវេក ព្រោះអត្ថថា ស្ងាត់ អធិប្បាយថា គំនរធម៌ដែលសម្បយុត្តដោយឈានដែលស្ងាត់ចាកនីវរណៈ ឈ្មោះថា **វិវេកជំ** ព្រោះអត្ថថា កើតអំពីវិវេកនោះ ឬកើតក្នុងវិវេកនោះ ។

ក្នុងបទថា **បីតិសុខំ** នេះ ឈ្មោះថា **បីតិ** ព្រោះអត្ថថា ឆ្អែត បីតិនោះមានលក្ខណៈឆ្អែតស្កប់ស្កល់ បីតិមាន ៥ យ៉ាងគឺខុទ្ទកាបីតិ គឺបីតិបន្តិចបន្តួច ១ ខណិកាបីតិ គឺបីតិម្តងម្កាល ១ ឱក្កន្តិកាបីតិ គឺបីតិដូចរលក ១ ឧព្វេង្គាបីតិ គឺបីតិដែលអណ្តែត ១ ផរណាបីតិ គឺបីតិដែលជ្រួតជ្រាប ១ ។

បណ្តាបីតិ ៥ យ៉ាងនោះ ខុទ្ទកាបីតិ អាចធ្វើឲ្យរោមបះក្នុងសរីរៈនោះ

*ឯង ខណិកាបីតិ ដូចគ្នានឹងផ្លេកបន្ទោរជាខណៈៗ ឱកន្តិកាបីតិឲ្យដឹង គឺកើតចុះឡើងក្នុងកាយ ដូចទឹករលកបោកនូវច្រាំងសមុទ្ទ ឧព្វេគ្គាបីតិ ជាបីតិមានកម្លាំង រហូតដល់ធ្វើកាយឲ្យអណ្តែតឡើងទៅក្នុងអាកាស ។ ផរណាបីតិជាបីតិមានកម្លាំងក្រៃលែង កាលផរណាបីតិនោះកើតឡើងហើយ សរីរៈទាំងមូលនឹងត្រជាក់ជ្រួតជ្រាប ដូចពេញទៅដោយគ្រាប់ភ្លៀង និងដូចរត់ចូលទៅកាន់អន្លង់ទឹកធំដែលជន់មកដូច្នោះ បីតិទាំង ៥ យ៉ាងនេះ កាលកាន់យកបន្ទប់ដល់នូវការចាស់ក្លា រមែងញ៉ាំងបស្សទ្ធិទាំង ២ គឺកាយបស្សទ្ធិនិងចិត្តបស្សទ្ធិឲ្យបរិបូណ៌ ។ បស្សទ្ធិកាលកាន់យកបន្ទប់ ដល់នូវការចាស់ក្លា រមែងញ៉ាំងសុខទាំង ២ គឺសុខកាយនិងសុខចិត្តឲ្យបរិបូណ៌ ។*

*សុខដែលកាន់យកបន្ទប់ ដល់នូវភាពចាស់ក្លា រមែងញ៉ាំងសមាធិ ៣ យ៉ាង គឺខណិកសមាធិ ឧបចារសមាធិនិងអប្បនាសមាធិឲ្យបរិបូណ៌ ។*

*បណ្តាបីតិទាំងនោះ ផរណាបីតិ ដែលជាមូលនៃអប្បនាសមាធិ កាលចម្រើនដល់ការប្រកបដោយសមាធិ នេះលោកបំណងយកថា បីតិ ក្នុងអត្ថនេះ ។*

*ម្យ៉ាងទៀត បទមួយ ឈ្មោះថា សុខៈ ព្រោះអត្ថថា សប្បាយ អធិប្បាយថា សុខកើតឡើងដល់បុគ្គលណា រមែងធ្វើបុគ្គលនោះឲ្យដល់នូវសេចក្តីសប្បាយ ម្យ៉ាងទៀត ការសប្បាយ ឈ្មោះថា សុខ ។ ធម្មជាតណារមែងទំពាស៊ី និងជីកចេញបានដោយងាយនូវអាពាធផ្លូវកាយ ផ្លូវចិត្ត ព្រោះហេតុនោះ ធម្មជាតនោះឈ្មោះថា សុខៈ ។ ពាក្យនេះជាឈ្មោះរបស់សោមនស្សវេទនា ។ សុខ*

នោះមានការពេញចិត្តជាលក្ខណៈ កាលបីតិនិងសុខៈទាំងនោះ មិនបែកគ្នាក្នុងអារម្មណ៍ណាមួយ សេចក្តីត្រេកអរដោយការបានចំពោះនូវអារម្មណ៍ដែលគួរប្រាថ្នា ឈ្មោះថា បីតិ ការសោយរសនៃអារម្មណ៍ដែលបានចំពោះហើយ ឈ្មោះថា សុខៈ ទីណាមានបីតិ ទីនោះមានសុខៈ ទីណាមានសុខៈ ទីនោះមិនប្រាកដថា មានបីតិ ។

បីតិ សង្គ្រោះចូលក្នុងសង្ខារក្ខន្ធ សុខៈ សង្គ្រោះចូលក្នុងវេទនាក្ខន្ធ បុគ្គលដែលលំបាកក្នុងផ្លូវកន្តារ បីតិ ដូចកាលឃើញ ឬបានស្តាប់ដល់ព្រៃឈើនិងទឹក ។ សុខៈ ដូចកាលចូលទៅកាន់ម្លប់របស់ព្រៃនិងបរិភោគទឹក បទនេះគប្បីជ្រាបថា លោកពោលទុកហើយ ព្រោះភាវៈដែលប្រាកដក្នុងសម័យនោះៗ ។

ឈាននេះលោកពោលថា មានបីតិ សុខៈ ព្រោះអត្ថថា បីតិផង សុខៈផង មានដល់ឈាននេះ ឬក្នុងឈាននេះ ដោយប្រការដូច្នេះ ។ មា៉្យងទៀត បីតិផង សុខផង ឈ្មោះថា បីតិនិងសុខៈ ដូចធម៌និងវិន័យជាដើម ។ ឈ្មោះថា មានបីតិនិងសុខៈដែលកើតអំពីវិវេកយ៉ាងនេះ ព្រោះអត្ថថា បីតិនិងសុខៈកើតអំពីវិវេក មានដល់ឈាននេះ ឬក្នុងឈាននេះ ។ ឈានកើតអំពីវិវេកយ៉ាងណា បីតិនិងសុខៈក្នុងឈាននេះក៏យ៉ាងនោះ រមែងកើតអំពីវិវេកទាំងនោះ ។ បីតិនិងសុខៈកើតអំពីវិវេកនោះ មានដល់ឈាននេះ ព្រោះហេតុនោះ ទោះពោលថា **វិវេកជំបីតិសុខំ** រួមជាបទតែមួយដោយធ្វើសមាសមិនលុបវិភត្តិក៏គួរ ។ បទថា **បឋមំ** សេចក្តីថា ឈ្មោះថា **បឋមំ** ព្រោះជាលំដាប់នៃការរាប់ ឈ្មោះថា **បឋមំ** ព្រោះអត្ថថា ឈាននេះកើតឡើងជាទីមួយក៏មាន ។

*បទថា **ឈានំ** បានដល់ ឈាន ២ យ៉ាង គឺអារម្មណូបនិជ្ឈាន និង លក្ខណូបនិជ្ឈាន ។ ក្នុងឈាន ២ យ៉ាងនោះ សមាបត្តិ ៨ ដល់នូវការរាប់ថា អារម្មណូបនិជ្ឈាន ព្រោះអត្ថថា ចូលទៅសម្ងឹងអារម្មណ៍ មានបឋវីកសិណជាដើម ។ វិបស្សនា មគ្គនិងផល ឈ្មោះថា លក្ខណូបនិជ្ឈាន ។*

*ក្នុងវិបស្សនា មគ្គនិងផលទាំងនោះ វិបស្សនា ឈ្មោះថា លក្ខណូបនិជ្ឈាន ព្រោះចូលទៅសម្ងឹងអនិច្ចលក្ខណៈជាដើម ។ មគ្គ ឈ្មោះថាលក្ខណូបនិជ្ឈាន ព្រោះកិច្ចដែលវិបស្សនាធ្វើហើយសម្រេចដោយមគ្គ ។ ចំណែកផល ឈ្មោះថា លក្ខណូបនិជ្ឈាន ព្រោះអត្ថថា ចូលទៅសម្ងឹងនិរោធសច្ចៈដែលជាលក្ខណៈពិត ។*

*ក្នុងឈាន ២ យ៉ាងនោះ ក្នុងទីនេះបំណងយកអារម្មណូបនិជ្ឈានក្នុងកាលជាចំណែកខាងដើម បំណងយកលក្ខណូបនិជ្ឈានក្នុងខណៈនៃលោកុត្តរមគ្គ ព្រោះហេតុនោះគប្បីជ្រាបថា ឈ្មោះថាឈាន ព្រោះចូលទៅសម្ងឹងអារម្មណ៍ផង ព្រោះចូលទៅសម្ងឹងលក្ខណៈផង ព្រោះដុតនូវសត្រូវគឺកិលេសផង ។*

*បទថា **ឧបសម្បជ្ជ** បានដល់ ចូលដល់ហើយ អធិប្បាយថា សម្រេចហើយ ។ម្យ៉ាងទៀត ឲ្យចូលដល់ព្រមហើយ អធិប្បាយថា ឲ្យសម្រេចហើយ ។*

*បទថា **វិហរតិ** សេចក្ដីថា រមែងកម្រើកដោយការនៅនៃឥរិយាបថដែលសមគួរដល់ឈាននោះ គឺជាបុគ្គលមានការព្រមព្រៀងដោយឈាន ដែលមានប្រការដូចពោលហើយ ញុំាងការកម្រើក គឺការប្រព្រឹត្តទៅនៃអត្តភាពឲ្យ*

សម្រេច ។

បឋមជ្ឈាននេះលះអង្គ ៥ ប្រកបដោយអង្គ ៥ មានការស្អាត ៣ យ៉ាង ដល់ព្រមដោយលក្ខណៈ ១០ ។ ក្នុងបឋមជ្ឈាននោះ គប្បីជ្រាបការលះអង្គ ៥ ដោយអំណាចលះនីវរណៈទាំង ៥ គឺកាមច្ឆន្ទៈ ព្យាបាទៈ ថីនមិទ្ធៈ ឧទ្ធច្ចកុក្កុច្ចៈ វិចិកិច្ឆា ព្រោះថា ការលះនីវរណៈទាំងនោះមិនបាន បឋមជ្ឈាននោះ រមែងមិនកើតឡើង ព្រោះហេតុនោះ ទើបលោកពោលនីវរណៈទាំងនេះថាជាអង្គនៃការលះ របស់បឋមជ្ឈាននោះ ។

អកុសលធម៌ដទៃ ទោះលះបានក្នុងខណៈនៃឈានក៏ពិត ទោះជាយ៉ាងនោះ នីវរណៈទាំងនោះឯង ក៏ញុំាងអន្តរាយដល់ឈានបានដោយវិសេស ព្រោះថា ចិត្តដែលត្រូវកាមច្ឆន្ទៈលួងលោមដោយអារម្មណ៍ផ្សេងៗ រមែងមិនតាំងមាំក្នុងអារម្មណ៍ដែលជាទីតាំងនៃការចុះស៊ប់ ឬចិត្តនោះត្រូវកាមច្ឆន្ទៈគ្របសង្កត់រមែងមិនប្រព្រឹត្តទៅដើម្បីលះកាមធាតុ ត្រូវព្យាបាទៈប៉ះខ្ទប់ក្នុងអារម្មណ៍ រមែងមិនប្រព្រឹត្តទៅជាប់ត ត្រូវថីនមិទ្ធៈគ្របសង្កត់ រមែងជាចិត្តមិនគួរដល់ការងារ ត្រូវឧទ្ធច្ចកុក្កុច្ចៈនាំទៅខាងមុខ ជាចិត្តមិនស្ងប់ រមែងវិលទៅជុំវិញ ត្រូវវិចិកិច្ឆាចូលទៅប៉ះខ្ទប់ រមែងមិនឡើងកាន់បដិបទាដែលឲ្យនូវការសម្រេចឈាន នីវ-រណៈទាំងនេះឯង លោកពោលថា អង្គនៃការលះ ព្រោះធ្វើអន្តរាយដល់ឈានដោយវិសេសដោយប្រការដូច្នេះ ។

ព្រោះវិតក្កលើកចិត្តឡើងកាន់អារម្មណ៍ វិចារៈផ្គងចិត្តទុកក្នុងអារម្មណ៍ បីតិកើតអំពីបយោគសម្បត្តិនៃចិត្តដែលមានសំយោគ ដែលវិតក្កៈ វិចារៈទាំង

នោះឲ្យសម្រេចហើយដោយការមិនរាយមាយ ធ្វើនូវការឆ្អែតនិងសេចក្ដីសុខឲ្យចម្រើនឡើង ។ លំដាប់នោះ ឯកគ្គតាដែលជាសម្បយុត្តធម៌ដ៏សេសរបស់បឋមជ្ឈាននោះ ដែលការលើកចិត្តឡើងកាន់អារម្មណ៍ ( វិតក្ក ) ការតាមបញ្ចោសអង្អែល ( វិចារៈ ) ការឆ្អែត ( បីតិ ) និងការចម្រើន ( សុខៈ ) ទាំងនេះអនុគ្រោះហើយ រមែងតាំងមាំជានិច្ចនិងដោយប្រពៃក្នុងអារម្មណ៍ដែលមានភាពជាឯកគ្គតា ហេតុនោះ គប្បីជ្រាបភាពដែលបឋមជ្ឈានប្រកបដោយអង្គ ៥ ដោយអំណាចការកើតឡើងនៃអង្គ ៥ នេះគឺ វិតក្ក វិចារៈ បីតិ សុខៈ ឯកគ្គតាចិត្ត ព្រោះថាកាលអង្គ ៥ នេះកើតឡើង ឈានឈ្មោះថារមែងកើតឡើង ។ ព្រោះហេតុនោះ អង្គទាំង ៥ នេះ ទើបលោកពោលថា ជាអង្គប្រកប ៥ ប្រការរបស់បឋមជ្ឈាននោះ ។

ព្រោះហេតុនោះ មិនគប្បីកាន់យកថា មានឈានដទៃដែលប្រកបដោយអង្គ ៥ ទាំងនេះ ដូចលោកពោលថា សេនាមានអង្គ ៤ តន្ត្រីមានអង្គ ៥ មគ្គមានអង្គ ៨ ក៏ដោយអំណាចមានអង្គជាប្រមាណនោះឯងយ៉ាងណា សូម្បីបឋម-ជ្ឈាននេះ ក៏យ៉ាងនោះ គប្បីជ្រាបថា លោកពោលថា មានអង្គ ៥ ក្ដី ប្រកបដោយអង្គ ៥ ក្ដី ក៏ដោយអំណាចមានអង្គជាប្រមាណនោះឯង អង្គ ៥ មានក្នុងខណៈនៃឧបចារៈក៏ពិត តែទោះជាយ៉ាងនេះ ក្នុងឧបចារៈក៏មានកម្លាំងជាងចិត្តប្រក្រតី តែក្នុងបឋមជ្ឈាននេះ សូម្បីមានកម្លាំងជាងឧបចារៈ ក៏សម្រេចដល់នូវលក្ខណៈនៃរូបាវចរ ។

បឋមជ្ឈាននេះ កើតឡើង លើកចិត្តឡើងកាន់អារម្មណ៍ដោយអាការៈ

ដែលផូរផង់ល្អ ។ វិចារៈផ្គងចិត្តទុកក្នុងអារម្មណ៍ក្រៃលែង បីតនិងសុខៈផ្សាយទៅកាន់កាយជាទីបំផុតនៃសភាវៈ ព្រោះហេតុនោះ ទើបលោកពោលទុក ( ក្នុងទីឃនិកាយសីលក្ខន្ធវគ្គ ) ថា សរីរដ្ឋានបន្តិចបន្តួចនៃកាយទាំងអស់របស់ភិក្ខុនោះ ឈ្មោះថា មិនបានផ្សព្វផ្សាយដោយបីតិនិងសុខៈ ដែលកើតអំពីវិវេកមិនមានឡើយ ដូច្នេះ ។ ឯកគ្គតាចិត្តកើតឡើង ពាល់ត្រូវដោយល្អក្នុងអារម្មណ៍ ដូចផ្ទៃប្រអប់ខាងលើពាល់ត្រូវផ្ទៃប្រអប់ខាងក្រោមដូច្នោះ អង្គទាំងនោះផ្សេងចាកអង្គទាំងនេះដូច្នេះ ។ នេះជាការផ្សេងគ្នាចាកធម៌ពួកដទៃនៃអង្គទាំង ៥ នេះ ។

ក្នុងអង្គទាំងនោះ ឯកគ្គតាចិត្តមិនបានសម្តែងទុកក្នុងបាឋៈនេះថា **សវិតក្កំ សវិចារំ** ដូច្នេះក៏ពិត តែក៏ជាអង្គដូចគ្នា ព្រោះទ្រង់ត្រាស់ទុកក្នុងវិភង្គយ៉ាងនេះថា ( ក្នុងសម័យនោះ ) ឈានមានអង្គ ៥ គឺ វិតក្កៈ វិចារៈ បីតិ សុខ ចិត្តេកគ្គតា ក៏កើតមាន ដូច្នេះ ។ ព្រះដ៏មានព្រះភាគទ្រង់ធ្វើឧទ្ទេសដោយបំណងណា ឧទ្ទេសនោះឯង ទ្រង់ប្រកាសហើយក្នុងវិភង្គដោយបំណងនោះដូច្នេះឯង ។

( បឋមឈាន ) មានលម្អ ៣ ដល់ព្រមដោយលក្ខណៈ ១០ គប្បីជ្រាបភាពដែលបឋមឈាន មានលម្អ ៣ យ៉ាង គឺខាងដើម កណ្តាលនិងទីបំផុតនិងគប្បីជ្រាបភាពដែលបឋមឈានដល់ព្រមដោយលក្ខណៈ ១០ ដោយអំណាចនៃលក្ខណៈខាងដើម កណ្តាលនិងខាងចុងទាំងនោះឯង ។

ក្នុងសេចក្តីនោះ មានបាលី ( ក្នុងបដិសម្ភិទាមគ្គ ) ដូច្នេះថា

បឋមជ្ឈាន មានបដិបទាវិសុទ្ធិជាខាងដើម តើបដិបទាវិសុទ្ធិជាខាងដើម មានលក្ខណៈប៉ុន្មានយ៉ាង ។ បដិបទាវិសុទ្ធិជាខាងដើម មានលក្ខណៈ ៣ យ៉ាងគឺ ធម៌ណាជាសត្រូវនៃបឋមជ្ឈាននោះ ចិត្តរមែងបរិសុទ្ធចាកធម៌នោះ ចិត្តរមែងដើរឆ្ពោះទៅកាន់សមថនិមិត្តជាកណ្តាល ព្រោះសេចក្តីស្អាត ចិត្តរមែងស្ទុះទៅក្នុងសមថនិមិត្តនោះ ព្រោះការដើរឆ្ពោះ គឺត្រង់ដែលចិត្តបរិសុទ្ធចាកធម៌ជាសត្រូវ ១ ត្រង់ដែលចិត្តដើរឆ្ពោះទៅកាន់សមថនិមិត្តជាកណ្តាល ព្រោះសេចក្តីស្អាត ១ ត្រង់ដែលចិត្តស្ទុះទៅក្នុងសមថនិមិត្តនោះ ព្រោះការដើរឆ្ពោះ ១ ( ទាំង ៣ នេះ ) ឈ្មោះថា បដិបទាវិសុទ្ធិជាខាងដើមរបស់បឋមជ្ឈាននេះឯង លក្ខណៈ ៣ យ៉ាងរបស់បដិបទាវិសុទ្ធិជាខាងដើម ហេតុនោះ លោកពោលថា បឋមជ្ឈានមានលម្អខាងដើមផង បរិបូណ៌ដោយលក្ខណៈផង ។

បឋមជ្ឈាន មានការចម្រើនរឿយៗ នៃការសម្លឹងពិនិត្យជាកណ្តាល តើការសម្លឹងពិនិត្យជាកិច្ចកណ្តាលមានលក្ខណៈប៉ុន្មានយ៉ាង ។ ការសម្លឹងពិនិត្យទុកជាកិច្ចកណ្តាល មានលក្ខណៈ ៣ យ៉ាង គឺចិត្តដែលបរិសុទ្ធ រមែងសម្លឹងផ្ទៀងផ្ទាត់ ចិត្តដែលដើរឆ្ពោះទៅរកសមថៈ រមែងសម្លឹងផ្ទៀងផ្ទាត់ ចិត្តដែលតាំងឡើងក្នុងឯកត្តៈ រមែងសម្លឹងផ្ទៀងផ្ទាត់ គឺត្រង់

ដែលចិត្តបរិសុទ្ធសម្ងឹងផ្ទៀងផ្ទាត់ ១ ត្រង់ដែលចិត្តដើរឆ្ពោះទៅរកសមថៈ សម្ងឹងផ្ទៀងផ្ទាត់ ១ ត្រង់ដែលចិត្តតាំងឡើងក្នុងឯកត្តៈសម្ងឹងផ្ទៀងផ្ទាត់ ១ ( ទាំង ៣ នេះ ) ឈ្មោះថា ការចម្រើនរឿយៗនៃការសម្ងឹងពិនិត្យ ទុកជាកិច្ចកណ្តាលនៃបឋមជ្ឈាននេះឯង លក្ខណៈ ៣ យ៉ាង របស់ការចម្រើនរឿយៗនៃការសម្ងឹងពិនិត្យជាកិច្ចកណ្តាល ហេតុនោះ លោកពោលថា បឋមជ្ឈានមានលម្អក្នុងកណ្តាលផង បរិបូណ៌ដោយលក្ខណៈផង ។

បឋមជ្ឈាន មានការរីករាយព្រមជាខាងចុង តើការរីករាយព្រមជាខាងចុង មានលក្ខណៈប៉ុន្មានយ៉ាង ។ ការរីករាយព្រមជាខាងចុងមានលក្ខណៈ ៤ យ៉ាង គឺការរីករាយព្រម ដោយអត្ថថា មិនប្រព្រឹត្តកន្លងនូវពួកធម៌ដែលកើតក្នុងបឋមជ្ឈាននោះ ១ ការរីករាយព្រមដោយអត្ថថា ឥន្ទ្រិយទាំងឡាយមានរសតែមួយ ១ ការរីករាយព្រម ដោយអត្ថថា នាំទៅនូវព្យាយាមគួរដល់ឥន្ទ្រិយនោះ ១ ការរីករាយព្រម ដោយអត្ថថា សេព ១ ( ទាំង ៤ នេះ ) ឈ្មោះថា ការរីរាយព្រមជាខាងចុងរបស់បឋមជ្ឈាន នេះឯងការរីករាយព្រមជាខាងចុង មានលក្ខណៈ ៤ យ៉ាង ហេតុនោះ លោកពោលថា បឋមជ្ឈានមានលម្អខាងចុងផង បរិបូណ៌ដោយលក្ខណៈផង

ដូច្នេះ ។

អាចារ្យពួកមួយពណ៌នាយ៉ាងនេះថា ក្នុងបាលីនោះ ឧបចារៈដែលប្រព្រឹត្តទៅជាមួយសម្ភារ ឈ្មោះថា បដិបទាវិសុទ្ធិ អប្បនាឈ្មោះថា ការចម្រើន-ឧបេក្ខា ការពិចារណាឈ្មោះថា ការត្រេកអរ ។

ព្រោះលោកពោលទុកក្នុងបាលីថា ឯកគ្គតាចិត្ត មានបដិបទាវិសុទ្ធិជាលក្ខណៈផង ចម្រើនឧបេក្ខាផង ត្រេកអរដោយញាណផងដូច្នេះ ហេតុនោះគប្បីជ្រាបបដិបទាវិសុទ្ធិដោយអំណាចនៃការមកខាងក្នុងអប្បនានោះឯង គប្បីជ្រាបការចម្រើនឧបេក្ខា ដោយអំណាចនៃកិច្ចរបស់តត្រមជ្ឈត្តុបេក្ខា និងគប្បីជ្រាបនូវការត្រេកអរ ដោយអំណាចនៃការសម្រេចកិច្ចនៃញាណដែលផូរផង់ដោយការញុំាងការមិនឈានកន្លងនូវធម៌ទាំងឡាយជាដើមឲ្យសម្រេច សេចក្តីនេះដូចម្តេច ក្នុងវារៈដែលអប្បនាកើតឡើងនោះ ពួកកិលេសពោលគឺនីវរណៈណា ជាអន្តរាយចំពោះឈាននោះ ចិត្តរមែងបរិសុទ្ធចាកពួកកិលេសនោះ ។ ព្រោះចិត្តបរិសុទ្ធិ ទើបចិត្តវៀរចាកគ្រឿងរារាំង ប្រព្រឹត្តទៅកាន់សមថនិមិត្តដែលមានក្នុងកណ្តាលអប្បនាសមាធិ ដែលប្រព្រឹត្តទៅព្រមនោះឯង ឈ្មោះថា សមថនិមិត្តដែលមានក្នុងកណ្តាល ។ លំដាប់នោះ បុរិមចិត្តដែលចូលដល់នូវភាពយ៉ាងនោះ ដោយការបង្អោនទៅកាន់សន្តតិក្នុងខណៈចិត្ត ១ ឈ្មោះថា រមែងប្រព្រឹត្តទៅកាន់សមថនិមិត្តដែលមានក្នុងកណ្តាល ព្រោះចិត្តប្រព្រឹត្តទៅយ៉ាងនោះ ទើបឈ្មោះថា រមែងស្ទុះទៅក្នុងបឋមជ្ឈាននោះដោយការចូលដល់ភាពយ៉ាងនោះ ។ បដិបទាវិសុទ្ធិ ដែលញុំាងអាការៈដែលមានក្នុងបុរិម

ចិត្តឲ្យសម្រេច គប្បីជ្រាបដោយអំណាចនៃការសម្រេចក្នុងឧប្បាទក្ខណៈនៃបឋមជ្ឈានមុនដោយប្រការដូច្នេះ ។

ព្រោះមិនត្រូវធ្វើចិត្តដែលបរិសុទ្ធយ៉ាងនេះ ឲ្យបរិសុទ្ធិទៀត ទើបបុគ្គលមិនខ្វល់ខ្វាយក្នុងការឲ្យបរិសុទ្ធិ ទើបចិត្តដែលបរិសុទ្ធ ឈ្មោះថា សម្លឹងព្រងើយ ។ ចិត្តកាលមិនខ្វល់ខ្វាយក្នុងការតាំងចិត្ត ដែលប្រព្រឹត្តទៅក្នុងសមថៈដោយការចូលដល់ភាវៈនៃសមថៈ ប្រព្រឹត្តទៅក្នុងសមថៈ ទើបឈ្មោះថា សម្លឹងព្រងើយ ។ ព្រោះចិត្តនោះប្រព្រឹត្តទៅក្នុងសមថៈនោះឯង ទើបចិត្តលះនូវការជាប់ជំពាក់ដោយកិលេស មិនចាំបាច់ខ្វល់ខ្វាយទៀត ក្នុងការតាំងឡើងជាឯកត្តារម្មណ៍របស់ចិត្តដែលតាំងមាំហើយដោយឯកត្តារម្មណ៍ តាំងឡើងជាឯកត្តារម្មណ៍ទើបឈ្មោះថា សម្លឹងព្រងើយ ។ គប្បីជ្រាបការចម្រើនឧបេក្ខាដោយអំណាចនៃកិច្ចរបស់តត្រមជ្ឈត្តុបេក្ខាដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត ធម៌ដែលទាក់ទងជាគូ ពោលគឺសមាធិនិងបញ្ញាដែលកើតក្នុងបឋមជ្ឈាននោះ ដែលឧបេក្ខាឧបត្ថម្ភហើយយ៉ាងនេះ មិនប្រព្រឹត្តទៅកន្លងគ្នានឹងគ្នា ។ ឥន្ទ្រិយមានសទ្ធាជាដើមដែលមានរសតែមួយដោយវិមុត្តិរស ព្រោះផុតចាកកិលេសផ្សេងៗប្រព្រឹត្តទៅ សេចក្ដីព្យាយាមដែលដល់នូវការប្រព្រឹត្តទៅដោយរូប មិនប្រព្រឹត្តទៅកន្លងនូវធម៌ទាំងនោះដែលសមគួរដល់ភាវៈដែលមានរសតែមួយប្រព្រឹត្តទៅ ការគប់រកដែលប្រព្រឹត្តទៅ ក្នុងខណៈនោះនៃបឋមជ្ឈាននោះ អាការៈទាំងនោះ ព្រោះសម្រេច ព្រោះឃើញទោសនោះៗ អានិសង្សនោះៗ ក្នុងការសៅហ្មងនិងការផូរផង់ ដោយញាណ ទើបត្រេកអរ

បរិសុទ្ធិ ផូរផង់ដោយប្រការនោះៗ ហេតុនោះ គប្បីជ្រាបការត្រេកអរដោយអំណាចនៃការសម្រេចកិច្ចនៃញាណដែលផូរផង់ ដោយការញ៉ាំងនូវការមិនប្រព្រឹត្តទៅកន្លងនូវធម៌ទាំងឡាយជាដើមឲ្យសម្រេច លោកពោលទុកដូច្នេះ ។

បទថា **វិតក្កវិចារានំ វូបសមា** សេចក្តីថា ព្រោះអង្គទាំង ២ គឺវិតក្កផង វិចារៈផងស្ងប់ទៅ មានអធិប្បាយថា ព្រោះមិនប្រាកដក្នុងខណៈនៃទុតិយជ្ឈាន ។

ក្នុងទុតិយជ្ឈាននោះ គប្បីជ្រាបថា ធម៌នៃបឋមជ្ឈានទាំងអស់ មិនមានក្នុងទុតិយជ្ឈានក៏ពិត ព្រោះផស្សៈជាដើមក្នុងបឋមជ្ឈានមួយបែប ក្នុងទុតិយជ្ឈានមួយបែប ទោះយ៉ាងនោះ ដើម្បីសម្តែងការសម្រេចទុតិយជ្ឈានជាដើមដទៃអំពីបឋមជ្ឈាន រមែងមានព្រោះឈានកន្លងអង្គដែលគ្រោតគ្រាត ទើបលោកពោលយ៉ាងនេះថា **វិតក្កវិចារានំ វូបសមា** ដូច្នេះ ។

ក្នុងបទថា **អជ្ឈត្តំ** នេះ លោកបំណងខាងក្នុងខ្លួន អធិប្បាយថា កើតក្នុងខ្លួន គឺកើតក្នុងរបស់ខ្លួន ។

បទថា **សម្បសាទនំ** សេចក្តីថា សទ្ធា លោកហៅថា សម្បសាទនៈ គឺការផូរផង់ សូម្បីឈាន ក៏ឈ្មោះថា សម្បសាទនៈ ព្រោះប្រកបដោយការផូរផង់ ដូចសំពត់ខៀវ ព្រោះប្រកបដោយពណ៌ខៀវ ។

ម្យ៉ាងទៀត ព្រោះឈាននោះញ៉ាំងចិត្តឲ្យផូរផង់ ព្រោះប្រកបដោយការផូរផង់ ព្រោះញ៉ាំងនូវការកម្រើកនៃវិតក្ក វិចារៈឲ្យស្ងប់ ហេតុនោះ ទើបលោកហៅថា សម្បសាទនៈ ។ ក្នុងអត្ថវិកប្បនេះ គប្បីជ្រាបការភ្ជាប់បទយ៉ាងនេះថា **សម្ប-**

**សាទនំ ចេតសោ** ដូច្នេះ ក្នុងអត្ថវិកប្បដំបូង គប្បីប្រកបបទ **ចេតសោ** នេះ ជាមួយបទ **ឯកោទិភាវំ** ។ ក្នុងអត្ថវិកប្បនោះ មានអត្ថយោជនាដូចតទៅនេះថា

ឈ្មោះថា **ឯកោទិ** ព្រោះអត្ថថា ជាធម៌ឯកផុសឡើង អធិប្បាយថា ជាធម៌ដ៏លើស គឺប្រសើរផុសឡើង ព្រោះមិនត្រូវវិតក្ក វិចារៈគ្របសង្កត់ សេចក្ដីពិត សូម្បីធម៌ដ៏ប្រសើរ លោកក៏ហៅថាជាឯកក្នុងលោក ។

ម្យ៉ាងទៀត ធម៌ដែលវៀរចាកវិតក្ក វិចារៈ ជាធម៌ឯក គឺមិនមានធម៌ដែលប្រព្រឹត្តទៅរួម រមែងប្រព្រឹត្តទៅដូច្នេះក៏មាន ។

ម្យ៉ាងទៀត ឈ្មោះថា **ឧទិ** ព្រោះអត្ថថា ញុំាងសម្បយុត្តធម៌ទាំងឡាយឲ្យកើត សេចក្ដីថា ឲ្យតាំងឡើង ។ ធម៌នោះជាឯក ព្រោះអត្ថថា ប្រសើរផង តាំងឡើងផង ព្រោះហេតុនោះ ទើបឈ្មោះថា **ឯកោទិ** ។ ពាក្យថា **ឯកោទិ** នេះ ជាឈ្មោះរបស់សមាធិ ទុតិយជ្ឈាននេះមានភាពជាធម៌ឯកផុសឡើង ព្រោះអត្ថថា ញុំាងធម៌ឯកផុសឡើងនេះឲ្យកើត គឺឲ្យចម្រើន ។ បណ្ដាធម៌ឯកដែលផុសឡើងនោះ ព្រោះជារបស់ចិត្ត មិនមែនរបស់សត្វ មិនមែនរបស់ជីវិត ព្រោះហេតុនោះ ទើបលោកពោលទុតិយជ្ឈាននេះថា **ចេតសោ ឯកោទិ–ភាវំ** ដូច្នេះ ។

ម្យ៉ាងទៀត សទ្ធានេះនិងសមាធិដែលឈ្មោះថា **ឯកោទិ** នេះ មានក្នុងបឋមជ្ឈានមិនមែនឬ កាលបើដូច្នោះ ហេតុអ្វីទើបពោលទុកក្នុងទុតិយជ្ឈាននេះប៉ុណ្ណោះថា **សម្បសាទនំ ចេតសោ ឯកោទិភាវំ** ដូច្នេះ សេចក្ដីនោះ មានអធិប្បាយដូចតទៅនេះថា

បឋមជ្ឈានទេះរមែងមិនផូរផង់ដោយល្អ ព្រោះវិតក្ក វិចារៈកម្រើកបាន ដូចទឹករំជួលព្រោះរលក ព្រោះហេតុនោះ កាលមានសទ្ធា លោកក៏មិនពោលថា **សម្បសាទនំ** ព្រោះមិនផូរផង់ដោយល្អនោះឯង សូម្បីសមាធិក៏មិនប្រាកដដោយល្អក្នុងឈានទេះ ព្រោះហេតុនោះ ទើបលោកមិនពោលថា **ឯកោទិភាវំ** តែក្នុងឈានទេះ សទ្ធាមានកម្លាំងបានឱកាស ព្រោះមិនមានវិតក្ក វិចារៈជាគ្រឿងកន្ទល់ ។ ទាំងសមាធិក៏ប្រាកដ ព្រោះបានទូវសទ្ធាដែលមានកម្លាំងជាសម្លាញ់នោះឯង ព្រោះហេតុនោះគប្បីជ្រាបថា ឈានទេះប៉ុណ្ណោះ លោកពោលទុកយ៉ាងនេះ ។

បទថា **អវិតក្កំ អវិចារំ** សេចក្តីថា ឈ្មោះថា **អវិតក្កំ** ព្រោះអត្ថថា វិតក្កមិនមានក្នុងឈានទេះ ឬដល់ឈានទេះ ព្រោះលះបានដោយភាវនា ។ ឈ្មោះថា **អវិចារំ** ក៏ដោយន័យនេះឯង ក្នុងទីនេះលោកពោលចោទថា ដោយបទថា **វិតក្កវិចារានំ វូបសមា** សេចក្តីនេះក៏សម្រេចហើយមិនមែនឬ កាលបើដូច្នោះ ហេតុអ្វីទើបពោលថា **អវិតក្កំ អវិចារំ** ទៀត សេចក្តីនោះ មានអធិប្បាយដូច្នេះថា

សេចក្តីនេះ សម្រេចហើយយ៉ាងនេះនោះឯង តែបទថា **អវិតក្កំ អវិចារំ** នេះ មិនបានសម្តែងសេចក្តីថា មិនមានវិតក្កៈ មិនមានវិចារៈនោះ ពួកយើងបានពោលហើយមិនមែនឬថា ដើម្បីសម្តែងអង្គដែលគ្រោតគ្រាតថា ការសម្រេចទុតិយជ្ឈានជាដើម ដទៃចាកបឋមជ្ឈានរមែងមាន ព្រោះឈានកន្លងអង្គដែលគ្រោតគ្រាត ទើបលោកពោលយ៉ាងនេះថា **វិតក្កវិចារានំ វូបសមា** ដូច្នេះ ។

ម្យ៉ាងទៀត ពាក្យថា **វិតក្កវិចារានំ វូបសមា** នេះ ជាពាក្យសម្តែងហេតុនៃការផូរផង់និងភាពជាធម៌ឯកផុសឡើងយ៉ាងនេះថា ព្រោះវិតក្កៈ វិចារៈស្ងប់ទៅ ទើបទុតិយជ្ឈាននេះមានសេចក្តីផូរផង់ មិនមែនព្រោះការស្មោកគ្រោករបស់កិលេសអស់ទៅនិងព្រោះវិតក្កៈ វិចារៈស្ងប់ទៅ ទើបជាធម៌ឯកផុសឡើង មិនមែនព្រោះលះនីវរណៈដូចឧបចារឈានឡើយ និងមិនមែនព្រោះអង្គឈានប្រាកដដូចបឋមជ្ឈានឡើយ ។ បទថា **វិតក្កវិចារានំ វូបសមា** ជាពាក្យសម្តែងហេតុនៃភាពជាឈានមិនមានវិតក្កៈ មិនមានវិចារៈយ៉ាងនេះថា ទុតិយជ្ឈាននេះ មិនមានវិតក្កៈ មិនមានវិចារៈ ព្រោះវិតក្កៈនិងវិចារៈស្ងប់ទៅ មិនមែនព្រោះមិនមាន ដូចតតិយជ្ឈាន និងចតុត្ថជ្ឈាន និងដូចចក្ខុវិញ្ញាណជាដើម ។ មិនមែនសម្តែងដល់ការមិនមានវិតក្កៈនិងវិចារៈឡើយ ។

បទថា **អវិតក្កំ អវិចារំ** ជាពាក្យសម្តែងដល់ការ មិនមាននៃវិតក្កនិងវិចារៈ ព្រោះហេតុនោះ សូម្បីពោលពាក្យដំបូងហើយ ក៏គប្បីពោលពាក្យក្រោយទៀតនោះឯង ។

បទថា **សមាធិជំ** សេចក្តីថា កើតអំពីសមាធិក្នុងបឋមជ្ឈានឬអំពីសមាធិដែលជាសម្បយុត្តធម៌ ។ ក្នុងបទនោះ សូម្បីបឋមជ្ឈានកើតអំពីសមាធិជាសម្បយុត្តធម៌ក៏ពិត ទោះជាដូច្នោះ សមាធិនេះក៏គួរនឹងពោលថា **សមាធិជំ** ព្រោះមាំទាំបំផុត ដោយវៀរចាកការកម្រើកនៃវិតក្កៈនិងវិចារៈ និងព្រោះផូរផង់ដោយល្អ ។ ព្រោះហេតុនោះ ទើបលោកពោលឈាននេះប៉ុណ្ណោះថា **សមាធិជំ** ដើម្បីពោលសរសើរឈាននេះ ។

បទថា **បីតិសុខំ** នេះ មានន័យដូចពោលហើយនោះឯង ។ បទថា **ទុតិយំ** បានដល់ ទី ២ ដោយលំដាប់ការរាប់ ឈ្មោះថា **ទុតិយំ** ព្រោះអត្ថថា ឈាននេះកើតជាទី ២ ដូច្នេះក៏មាន ។

បទថា **បីតិយា ច វិរាគា** សេចក្ដីថា ការស្អប់ខ្ពើមក្ដី ការឈានកន្លងក្ដីនូវបីតិមានប្រការដូចពោលហើយ ឈ្មោះថាវិរាគៈ ច សព្ទរវាងបទទាំងពីរមានអត្ថថាប្រមូល ។ ច សព្ទនោះ រមែងប្រមូលនូវការស្ងប់ ឬនូវការស្ងប់នៃវិតក្កនិងវិចារៈ ក្នុងបទនោះ ច សព្ទ រមែងប្រមូលសេចក្ដីស្ងប់នោះឯងក្នុងកាលណា ក្នុងកាលនោះគប្បីជ្រាបការប្រកបសេចក្ដីយ៉ាងនេះថា ព្រោះបីតិអស់ទៅផង ព្រោះស្ងប់បន្ថែមឡើងបន្តិចបន្តួចផង ។ ដោយការប្រកបសេចក្ដីនេះ វិរាគៈរមែងមានអត្ថថា ស្អប់ខ្ពើម ព្រោះហេតុនោះ គប្បីឃើញសេចក្ដីដូច្នេះថា ព្រោះស្អប់ខ្ពើមនូវបីតិផង ព្រោះឈានកន្លងនូវបីតិផង ។ ច សព្ទ រមែងប្រមូលនូវភាពស្ងប់នៃវិតក្កនិងវិចារៈក្នុងកាលណា ក្នុងកាលនោះ គប្បីជ្រាបការប្រកបសេចក្ដីយ៉ាងនេះថា ព្រោះបីតិអស់ទៅផង ព្រោះស្ងប់វិតក្កៈនិងវិចារៈបន្ថែមឡើងទៀតបន្តិចបន្តួចផង ដោយការប្រកបសេចក្ដីនេះ វិរាគៈរមែងមានអត្ថថា ឈានកន្លង ព្រោះហេតុនោះ គប្បីឃើញសេចក្ដីដូចតទៅនេះថា ព្រោះឈានកន្លងនូវបីតិផង ព្រោះវិតក្កៈនិងវិចារៈស្ងប់ទៅផង ។

វិតក្កនិងវិចារៈទាំងនេះស្ងប់ហើយក្នុងទុតិយជ្ឈាននោះឯងក៏ពិត ទោះជាយ៉ាងនោះ លោកក៏ពោលបទនេះ ដើម្បីសម្ដែងមគ្គរបស់ឈាននេះនិងដើម្បីពោលសរសើរឈាននេះ ។ ពិតហើយ កាលពោលថា ព្រោះវិតក្កនិងវិចារៈ

ស្ងប់ទៅដូច្នេះ តតិយជ្ឈានេនះរមែងប្រាកដថា ការស្ងប់នៃវិតក្កនិងវិចារៈជាមគ្គនៃឈាននេះពិតមែន ដូចការលះសក្កាយទិដ្ឋិជាដើម ដែលមិនបានលះហើយក្នុងអរិយមគ្គទី ៣ យ៉ាងនេះថា ព្រោះលះសំយោជនៈខាងក្រោម ៥ កាលពោល រមែងជាការពោលសរសើរ ដើម្បីឲ្យកើតឧស្សាហៈដល់បុគ្គលដែលខ្វល់ខ្វាយដើម្បីសម្រេចអរិយមគ្គទី ៣ នោះ យ៉ាងណា ការស្ងប់វិតក្កៈនិងវិចារៈដែលមិនទាន់ស្ងប់ ក្នុងទីនេះ កាលពោលរមែងជាការពោលសរសើរក៏យ៉ាងនោះដូចគ្នា ព្រោះហេតុនោះ ទើបខ្ញុំពោលថា ព្រោះឈានកន្លងនូវបីតិផង ព្រោះវិតក្កនិងវិចារៈស្ងប់ទៅផង ដូច្នេះ ។

ក្នុងបទថា **ឧបេក្ខកោ ច វិហរតិ** នេះ ឈ្មោះថា ឧបេក្ខា ព្រោះអត្ថថាឃើញដោយការចូលដល់ អធិប្បាយថា ឃើញជានិច្ច គឺជាបុគ្គលមិនធ្លាក់ទៅក្នុងចំណែកខាងណាមួយ ( ព្រោះ ) ឃើញ ។ បុគ្គលដល់ព្រមដោយតតិយជ្ឈានលោកហៅថា អ្នកមានឧបេក្ខា ព្រោះជាអ្នកប្រកបដោយឧបេក្ខានោះដែលបរិសុទ្ធិបរិបូណ៌មានកម្លាំង ។ ឧបេក្ខាមាន ១០ យ៉ាង គឺឆឡង្គុបេក្ខា ១ ព្រហ្មវិហារុបេក្ខា ១ ពោជ្ឈង្គុបេក្ខា ១ វីរិយុបេក្ខា ១ សង្ខារុបេក្ខា ១ វេទនុបេក្ខា ១ វិបស្សនុបេក្ខា ១ តត្រមជ្ឈត្តុបេក្ខា ១ ឈានុបេក្ខា ១ និងបារិសុទ្ធិឧបេក្ខា ១ ។

បណ្តាឧបេក្ខាទាំងនោះ ឧបេក្ខាដែលមានសភាវៈប្រក្រតី គឺបរិសុទ្ធិមានអាការៈលះក្នុងគន្លងនៃអារម្មណ៍ ៦ ទាំងដែលគួរប្រាថ្នានិងមិនគួរប្រាថ្នាក្នុងទ្វារ ៦ របស់ព្រះខីណាស្រព ដែលមកក្នុងបាលីអាគតដ្ឋាន ( អង្គុត្តរនិកាយឆក្ក-

*និបាត ) យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ឃើញរូបដោយភ្នែក ជាអ្នកមិនត្រេកអរ មិនអាក់អន់ ជាអ្នកព្រងើយកន្តើយ ប្រកបដោយសតិសម្បជញ្ញៈ ដូច្នេះ នេះឈ្មោះថា* **ឆឡង្គុបេក្ខា** *។*

*ឧបេក្ខាមានអាការៈជាកណ្តាលក្នុងសត្វទាំងឡាយដែលមកក្នុងបាលីអាគតដ្ឋាន ( មជ្ឈិមនិកាយមូលបណ្ណាសក ) យ៉ាងនេះថា មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិស ១ ដូច្នេះ នេះឈ្មោះថា* **ព្រហ្មវិហារុបេក្ខា** *។*

*ឧបេក្ខា មានអាការៈជាកណ្តាលនៃសហជាតធម៌ទាំងឡាយ មកក្នុងបាលីអាគតដ្ឋាន ( មជ្ឈិមនិកាយមូលបណ្ណាសក ) យ៉ាងនេះថា ចម្រើននូវឧបេក្ខាសម្ពោជ្ឈង្គៈ ដែលអាស្រ័យនៅសេចក្តីស្ងប់ស្ងាត់ ដូច្នេះ នេះឈ្មោះថា* **ពោជ្ឈង្គុបេក្ខា** *។*

*ឧបេក្ខា ពោលគឺសេចក្តីព្យាយាម មិនប្រារព្ធពេក មិនធូរថយពេក មកក្នុងបាលីអាគតដ្ឋាន ( អង្គុត្តរនិកាយតិកនិបាត ) យ៉ាងនេះថា ធ្វើទុកក្នុងចិត្តនូវឧបេក្ខានិមិត្តក្នុងកាលដ៏គួរ ដូច្នេះ នេះឈ្មោះថា* **វីរិយុបេក្ខា** *។*

*ឧបេក្ខាដែលពិចារណានីវរណៈជាដើម ហើយជាកណ្តាលក្នុងការកាន់យកនូវការយល់ស្រប មកក្នុងបាលីអាគតដ្ឋាន ( ខុទ្ទកនិកាយបដិសម្ភិទាមគ្គ ) យ៉ាងនេះថា សង្ខារុបេក្ខាប៉ុន្មានកើតដោយអំណាចសមថៈ សង្ខារុបេក្ខាប៉ុន្មានកើតដោយអំណាចនៃវិបស្សនា ។ សង្ខារុបេក្ខា ៨ កើតដោយអំណាចសមថៈសង្ខារុបេក្ខា ១០ កើតដោយអំណាចវិបស្សនា ដូច្នេះ នេះឈ្មោះថា* **សង្ខារុបេក្ខា** *។*

ឧបេក្ខាដែលហៅថាមិនសុខ មិនទុក្ខ មកក្នុងបាលីអាគតដ្ឋាន ( អភិធម្មវិភង្គ ) យ៉ាងនេះថា ក្នុងសម័យណា កាមាវចរកុសលចិត្ត ប្រកបដោយឧបេក្ខា ដូច្នេះ នេះឈ្មោះថា **វេទនុបេក្ខា** ។

ឧបេក្ខាដែលជាកណ្តាលក្នុងការពិចារណា មកក្នុងបាលីអាគតដ្ឋាន (មជ្ឈិមនិកាយ ឧបរិបណ្ណាសក ) យ៉ាងនេះថា អាត្មាអញលះបង់នូវខន្ធបញ្ចកៈនោះ ភិក្ខុនោះបាននូវឧបេក្ខាយ៉ាងនេះ ដូច្នេះ នេះឈ្មោះថា **វិបស្សនុបេក្ខា** ។

ឧបេក្ខាដែលមកក្នុងយេវាបនកធម៌ទាំងឡាយ មានឆន្ទៈជាដើម ដែលសហជាតធម៌នាំទៅដោយល្អហើយ នេះឈ្មោះថា **តត្រមជ្ឈត្តុបេក្ខា** ។

ឧបេក្ខាដែលមិនឲ្យនូវការធ្លាក់ទៅក្នុងចំណែកដែលកើតឡើងក្នុងអារម្មណ៍នោះ សូម្បីជាសុខដ៏កំពូល មកក្នុងបាលីអាគតដ្ឋាន ( ធម្មសង្គណិ ) យ៉ាងនេះថា ជាបុគ្គលប្រកបដោយឧបេក្ខា ដូច្នេះ នេះឈ្មោះថា **ឈានុបេក្ខា** ។

ឧបេក្ខាដែលបរិសុទ្ធចាកសត្រូវគឺកិលេសទាំងពួង មិនចាំបាច់ខ្វល់ខ្វាយក្នុងការញ៉ាំងសត្រូវ គឺកិលេសឲ្យស្ងប់ មកក្នុងបាលីអាគតដ្ឋាន ( ធម្មសង្គណិ ) យ៉ាងនេះថា បានដល់នូវចតុត្ថជ្ឈាន ( ឈ្មោះបបវីកសិណមានអារម្មណ៍មិនជាទុក្ខ មិនជាសុខ ) មានសតិដ៏បរិសុទ្ធដោយឧបេក្ខាដូច្នេះ នេះឈ្មោះថា **បារិសុទ្ធិឧបេក្ខា** ។

បណ្តាឧបេក្ខាទាំងនោះ ឆឡង្គុបេក្ខា ព្រហ្មវិហារុបេក្ខា ពោជ្ឈង្គុបេក្ខា តត្រមជ្ឈត្តុបេក្ខា ឈានុបេក្ខានិងបារិសុទ្ធិឧបេក្ខា ដោយសេចក្តីក៏គឺជាតត្រមជ្ឈត្តុបេក្ខានោះឯង តែតត្រមជ្ឈត្តុបេក្ខានោះ មានប្រភេទដូច្នេះ ព្រោះប្រភេទ

*នៃតំណែងនោះៗ ដូចបុគ្គលតែម្នាក់ មានប្រភេទជាកុមារ កំលោះ ក្រមុំ អ្នកធំ សេនាបតីនិងជាព្រះរាជាជាដើម ព្រោះហេតុនោះ ក្នុងឧបេក្ខាទាំងនោះ គប្បីជ្រាបថា ក្នុងទីណាមានធម្មុទ្ធច្ចុបេក្ខា ក្នុងទីនោះ មិនមានពោជ្ឈង្គុបេក្ខាជាដើម ឬក្នុងទីណាមានពោជ្ឈង្គុបេក្ខា ក្នុងទីនោះ មិនមានធម្មុទ្ធច្ចុបេក្ខាជាដើម ។*

*ឧបេក្ខាទាំងនោះដោយសេចក្តីក៏តែមួយដូចគ្នាយ៉ាងណា សង្ខារុបេក្ខានិងវិបស្សនុបេក្ខា ដោយសេចក្តីក៏តែមួយដូចគ្នាយ៉ាងនោះ ។ បញ្ញានោះឯងចែកជាពីរ ដោយអំណាចនៃកិច្ច ឧបមាដូចបុរសកាន់កំណាត់ឈើ ដែលមានចុងបែកជាពីរ ដូចក្រចកជើងពពែស្វែងរកពស់ ដែលចូលផ្ទះក្នុងពេលល្ងាច ឃើញពស់ដេកក្នុងជង្រុកអង្ករ ពិចារណាមើលថា ពស់ឬមិនមែនហ្ន៎ ឃើញលក្ខណៈរបស់ពស់ ៣ យ៉ាង ក៏អស់សេចក្តីសង្ស័យ កើតនូវភាពជាកណ្តាលក្នុងការពិចារណាថា ពស់ឬមិនមែនពស់យ៉ាងណា កាលបុគ្គលប្រារព្ធវិបស្សនាឃើញត្រៃលក្ខណ៍ដោយវិបស្សនាញាណ ភាពជាកណ្តាលក្នុងការពិចារណាការមិនទៀងរបស់សង្ខារទាំងឡាយជាដើម រមែងកើតឡើងយ៉ាងនោះឯង ភាពជាកណ្តាលនេះឈ្មោះថា* **វិបស្សនុបេក្ខា** *។ កាលបុរសនោះ សង្កត់ពស់ទុកយ៉ាងមាំដោយកំណាត់ឈើ មានលក្ខណៈដូចជើងពពែគិតថា អញមិនបៀតបៀនពស់នេះ នឹងមិនឲ្យពស់នេះខាំអញ គប្បីលែងដូចម្តេច រមែងមានភាពជាកណ្តាលក្នុងការចាប់ពស់ទុកយ៉ាងណា កាលបុគ្គលឃើញភពទាំងបីដូចត្រូវភ្លើងឆេះ ព្រោះឃើញត្រៃលក្ខណ៍ហើយ ភាពជាកណ្តាលក្នុងការប្រកាន់នូវសង្ខារ ក៏យ៉ាងនោះដូចគ្នា ភាពជាកណ្តាលនេះឈ្មោះថា* **សង្ខារុបេក្ខា** *។*

សង្ខារុបេក្ខា ក៏រមែងសម្រេចដោយការសម្រេចនៃវិបស្សនុបេក្ខា ដោយប្រការដូច្នេះ ។ ទើបសង្ខារុបេក្ខានេះចែកជាពីរ ដោយកិច្ចពោលគឺភាពជាកណ្តាលក្នុងការពិចារណានិងការកាន់យក ។ ចំណែកវីរិយុបេក្ខានិងវេទនុបេក្ខាផ្សេងគ្នានឹងគ្នា និងផ្សេងអំពីឧបេក្ខាដ៏សេសទាំងឡាយដោយសេចក្តីប៉ុណ្ណោះឯង ។

លោកសរុបទុកក្នុងទីនេះដូច្នេះថា

ឧបេក្ខាដោយពិស្តារមាន ១០ គឺតត្រមជ្ឈត្តុបេក្ខា ព្រហ្មវិហារុបេក្ខា ពោជ្ឈង្គុបេក្ខា ឆឡង្គុបេក្ខា ឈានុបេក្ខា បារិសុទ្ធិឧបេក្ខា វិបស្សនុបេក្ខា សង្ខារុបេក្ខា វេទនុបេក្ខា វីរិយុបេក្ខា ចែកជាកណ្តាលជាដើម ៦ បន្ទាប់អំពីនោះ ដែលជាបញ្ញាពីរយ៉ាង បន្ទាប់អំពីនោះចែកជា ២ យ៉ាងទៀត រួមជា ៤ ដូច្នេះ ។

បណ្តាឧបេក្ខាទាំងនេះ ឈានុបេក្ខា លោកបំណងយកក្នុងទីនេះដោយប្រការដូច្នេះ ឈានុបេក្ខានោះ មានខ្លួនជាកណ្តាលជាលក្ខណៈ ក្នុងសេចក្តីនេះ លោកពោលទុកថា ឈានុបេក្ខានេះដោយសេចក្តី គឺតត្រមជ្ឈត្តុបេក្ខានោះឯង ឈានុបេក្ខានោះ ក៏មាននៅសូម្បីក្នុងបឋមជ្ឈាននិងទុតិយជ្ឈាន ដូច្នោះឈានុបេក្ខានេះ ទើបគួរពោលក្នុងបឋមឈាននិងទុតិយជ្ឈាននោះ យ៉ាងនេះថា **ឧបេក្ខកោ ច វិហរតិ** មិនមែនឬ ព្រោះហេតុអ្វី ទើបលោកមិនពោលទុក ព្រោះការប្រកបកិច្ចមិនទាន់ជាក់ច្បាស់ ដ្បិតថា ឈានុបេក្ខានោះ មានកិច្ច ក្នុងឈាននោះមិនទាន់ជាក់ច្បាស់ ព្រោះវិតក្កជាដើមគ្របសង្កត់ តែក្នុង

ឈាននេះ ព្រោះវិតក្ក វិចារៈនិងបីតិមិនបានគ្របសង្កត់ ទើបហាក់ដូចជាងើបក្បាលឡើង មានកិច្ចដែលជាក់ច្បាស់ហើយ ព្រោះហេតុនោះ ទើបលោកពោលទុក ។

ក្នុងបទថា **សតោ ច សម្បជានោ** នេះ មានវិនិច្ឆ័យដូច្នេះថា ឈ្មោះថា **សតោ** ព្រោះអត្ថថា រឭកបាន ។ ឈ្មោះថា **សម្បជានោ** ព្រោះអត្ថថា ដឹងខ្លួន ដឹងទូទៅព្រម ។ សតិនិងសម្បជញ្ញៈ លោកពោលដោយបុគ្គលាធិដ្ឋានក្នុងសតិនិងសម្បជញ្ញៈនោះ សតិមានការរឭកបានជាលក្ខណៈ សម្បជញ្ញៈមានការមិនវង្វេងជាលក្ខណៈ ។ សេចក្ដីនោះ សតិនិងសម្បជញ្ញៈនេះ មានក្នុងឈានខាងដើមៗ កាលបុគ្គលមិនមានស្មារតី ខ្វះសម្បជញ្ញៈ សូម្បីត្រឹមតែឧបចារៈ ក៏មិនសម្រេច នឹងពោលថ្វីដល់អប្បនា តែទោះជាយ៉ាងនោះ ព្រោះឈានទាំងនោះមានអង្គគ្រោតគ្រាត ការទៅនៃចិត្តរបស់បុរសរមែងជារបស់ងាយ ដូចការទៅលើផែនដី ។ ទើបកិច្ចនៃសតិសម្បជញ្ញៈក្នុងឈានទាំងនោះមិនប្រាកដច្បាស់ តែព្រោះឈានទី ៣ នេះ សុខុមដោយការលះនូវអង្គដែលគ្រោតគ្រាតបាន ទើបត្រូវប្រាថ្នាគតិនៃចិត្តដែលមានកិច្ចដែលសតិសម្បជញ្ញៈផ្គងទុកហើយប៉ុណ្ណោះ ដូចការទៅរបស់បុរសក្នុងទីមានរបស់មុត ព្រោះហេតុនោះ ទើបលោកពោលទុកក្នុងទីនេះ ( តតិយជ្ឈាន ) ដោយប្រការដូច្នេះ ។

គប្បីជ្រាបឲ្យក្រៃលែងឡើងទៅបន្តិចទៀតថា កូនគោដែលនូវបៅដោះត្រូវបំបែកចាកមេគោ កាលមិនរាំងរក្សា ក៏ចូលទៅរកមេគោទៀតរឿយៗ យ៉ាងណា សុខក្នុងតតិយជ្ឈាននេះក៏យ៉ាងនោះ ត្រូវបែកអំពីបីតិ កាលមិនរក្សាដោយ

សតិសម្បជញ្ញៈ គប្បីចូលទៅរកបីតិទៀតនោះឯង គប្បីសម្បយុត្តដោយបីតិនោះឯង ។ ម្យ៉ាងទៀត ពួកសត្វក៏នៅត្រេកត្រអាលក្នុងសុខនោះឯង ដើម្បីសម្ដែងអត្ថវិសេសនេះថា សុខនេះជាសុខដែលផ្អែមក្រៃលែង មិនមានសុខដទៃក្រៃលែងជាងនោះ ឯការមិនត្រេកត្រអាលក្នុងសុខក្នុងឈាននេះ រមែងមានដោយអានុភាពនៃសតិសម្បជញ្ញៈ មិនមែនមានដោយធម៌ដទៃឡើយ ដូច្នេះទើប លោកពោលពាក្យនេះទុកក្នុងទីនោះឯង ។

ឥឡូវនេះ នឹងវិនិច្ឆ័យក្នុងបទនេះថា **សុខញ្ច កាយេន បដិសំវេទេតិ** ដូចតទៅនេះថា ការចង់ចិត្តក្នុងការសោយសុខរបស់បុគ្គលដែលមានការដល់ព្រមដោយតតិយជ្ឈាន រមែងមិនមានក៏ពិត កាលបើដូច្នោះ ព្រោះហេតុដែលបុគ្គលមានការដល់ព្រមដោយតតិយជ្ឈាននោះ រមែងមានសុខ ( ចេតសិក-សុខ ) ដែលសម្បយុត្តដោយនាមកាយ ឬព្រោះហេតុដែលរូបកាយរបស់បុគ្គលដែលមានការដល់ព្រមដោយតតិយជ្ឈាននោះ ត្រូវរូបដែលប្រណីតយ៉ាងក្រៃលែងដែលតាំងឡើងអំពីសុខ ដែលសម្បយុត្តដោយនាមកាយនោះជ្រួតជ្រាបហើយព្រោះកាយត្រូវជ្រួតជ្រាបហើយ ។ សូម្បីលោកចេញហើយចាកឈាន ក៏គប្បីសោយសុខ ( កាយិកសុខ ) បាន ដូច្នោះកាលសម្ដែងសេចក្ដីនោះ ទើបលោកពោលថា **សុខញ្ច កាយេន បដិសំវេទេតិ** ដូច្នេះ ។

ឥឡូវនេះ នឹងវិនិច្ឆ័យក្នុងបទនេះថា **យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិហារី** ដូចតទៅនេះថា ព្រះអរិយៈទាំងឡាយ មានព្រះពុទ្ធជាដើម រមែងប្រាប់សម្ដែង បញ្ញត្ត តែងតាំង បើកផ្សាយ ចែកធ្វើឲ្យរាក់ឡើង ប្រកាស

*អធិប្បាយថា  សរសើរនូវបុគ្គលដែលមានការដល់ព្រមដោយតតិយជ្ឈាន នោះ ព្រោះហេតុនៃឈានណា ។ សរសើរដូចម្ដេច សរសើរថា ជាអ្នក មានឧបេក្ខា មានសតិនៅជាសុខ ដូច្នេះ ។ គប្បីជ្រាបការប្រកបសេចក្ដី ក្នុងបទនេះយ៉ាងនេះថា ចូលតតិយជ្ឈាននោះហើយនៅ ។ ព្រោះហេតុអ្វីទើប ព្រះអរិយៈទាំងនោះ សរសើរបុគ្គលនោះយ៉ាងនេះ ព្រោះជាបុគ្គលគួរដល់ ការសរសើរ ។ មែនពិត ព្រោះបុគ្គលមានឧបេក្ខាក្នុងតតិយជ្ឈាន សូម្បីដល់ បារមី គឺសុខដែលជាសុខមានរសឆ្ងាញ់ក្រៃលែង ក៏មិនត្រូវការជាប់ដោយ សេចក្ដីសុខក្នុងឈាននោះ អូសទាញទុកនិងជាអ្នកមានសតិ ព្រោះភាពជាអ្នក មានសតិតាំងមាំ ដោយអាការៈដែលបីតិនឹងកើតឡើងមិនបាននិងព្រោះសោយ សុខដែលព្រះអរិយៈត្រេកអរ គឺដែលអរិយជនសេពនោះឯងនិងជាសុខមិន សៅហ្មងដោយនាមកាយ  ហេតុនោះទើបជាបុគ្គលគួរដល់នូវភាពសរសើរ ។ ដោយប្រការដូច្នេះ គប្បីជ្រាបថា ព្រះអរិយៈទាំងឡាយ កាលប្រកាសគុណ ដែលជាហេតុ គួរដល់ការសរសើរយ៉ាងនេះ រមែងសរសើរបុគ្គលនោះដោយ ជាបុគ្គលគួរដល់ការសរសើរយ៉ាងនេះថា  ជាអ្នកមានឧបេក្ខា  មានសតិនៅ ជាសុខ ដូច្នេះ ។*

*បទថា* **តតិយំ** *បានដល់ ទី ៣ ដោយលំដាប់នៃការរាប់ ។ ឈាននេះ ឈ្មោះថា* **តតិយំ** *ព្រោះអត្ថថា កើតឡើងជាទី ៣ ដូច្នេះក៏មាន ។*

*បទថា* **សុខស្ស ច បហានា ទុក្ខស្ស ច បហានា** *សេចក្ដីថា ព្រោះ សុខផ្លូវកាយនិងទុក្ខផ្លូវកាយ ។*

បទថា **បុព្វេវ** បានដល់ សុខនិងទុក្ខនោះឯងក្នុងកាលមុន មិនមែនក្នុងខណៈនៃចតុត្ថជ្ឈានឡើយ ។

បទថា **សោមនស្សទោមនស្សានំ អត្ថង្គមា** សេចក្ដីថា ព្រោះដល់នូវការរលត់នៃសោមនស្សនិងទោមនស្សទាំងពីរនេះ គឺសុខផ្លូវចិត្តនិងទុក្ខផ្លូវចិត្តក្នុងកាលមុននោះឯង លោកអធិប្បាយថា ព្រោះលះនោះឯង ។ ការលះសុខជាដើមនោះមានក្នុងកាលណា មានក្នុងខណៈនៃឧបចារៈរបស់ឈានទាំង ៤ ។ មែនពិត លះសោមនស្សបានក្នុងខណៈនៃឧបចារៈរបស់ឈានទី ៤ នោះឯង ។

លះទុក្ខ ទោមនស្ស និងសុខៈបាន ក្នុងខណៈនៃឧបចារៈរបស់ឈានទី ១ ទី ២ និងទី ៣ ។ គប្បីជ្រាបការលះនូវសុខ ទុក្ខ សោមនស្សនិងទោមនស្សដែលមិនបានពោលទុកតាមលំដាប់នៃការលះដោយប្រការដូច្នេះ តែគប្បីជ្រាបការលះសុខ ទុក្ខ សោមនស្សនិងទោមនស្ស ដែលពោលទុកក្នុងទីនេះ តាមលំដាប់ឧទ្ទេសនៃឥន្ទ្រិយទាំងឡាយក្នុងឥន្ទ្រិយវិភង្គ ។

បើសុខ ទុក្ខ សោមនស្សនិងទោមនស្សទាំងនេះ ដែលភិក្ខុលះបានក្នុងខណៈនៃឧបចារៈរបស់ឈាននោះៗប៉ុណ្ណោះ កាលបើដូច្នោះ ហេតុអ្វីទើបព្រះដ៏មានព្រះភាគ ត្រាស់នូវការរលត់ក្នុងឈានទាំងឡាយនោះឯងទុក ( ក្នុងសំយុត្តនិកាយមហាវារវគ្គ ) យ៉ាងនេះថា ចុះទុក្ខិន្ទ្រិយកើតឡើងក្នុងទីដូចម្ដេច ទើបរលត់ទៅឥតមានសេសសល់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ រមែងចូលកាន់បឋមជ្ឈាន... ទុក្ខិន្ទ្រិយកើតឡើងក្នុងបឋមជ្ឈាននេះ តែងរលត់ទៅឥតមានសេសសល់ ទោមនស្សិ-

ន្ទ្រិយ... សុខិន្ទ្រិយ... សោមនស្សិន្ទ្រិយកើតឡើងក្នុងទីឯណា រមែងរលត់ទៅឥត មានសេសសល់ ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ព្រោះលះបង់នូវសុខផង ។បេ។ ចូលកាន់ចតុត្ថជ្ឈាន ។បេ។ សោមនស្សិន្ទ្រិយកើតឡើងហើយក្នុងចតុត្ថជ្ឈាននោះ ទើបរលត់ទៅឥតមានសេសសល់[១] ដូច្នេះ ព្រោះរំលត់យ៉ាងសម្បូរ ឯការរំលត់យ៉ាងបរិបូរនូវសុខ ទុក្ខ សោមនស្សនិងទោមនស្ស ទាំងនោះ រមែងមានក្នុងបឋមជ្ឈានជាដើម មិនមែនត្រឹមតែការរលត់ប៉ុណ្ណោះ ។ ម្យ៉ាងទៀត ការរលត់នោះឯងក្នុងខណៈនៃឧបចារៈ មិនមែនការរលត់ដោយបរិបូណ៌ឡើយ ពិតយ៉ាងនោះ ទុក្ខិន្ទ្រិយដែលរលត់ក្នុងឧបចារៈនៃបឋមជ្ឈាន ក្នុងអាវជ្ជនៈផ្សេងៗ គប្បីកើតឡើងបាន ព្រោះសម្ផស្សនៃរបោមមូសជាដើមក៏មាន ព្រោះលំបាកដោយអាសនៈមិនរាបស្មើក៏មាន តែខាងក្នុងអប្បនាមិនមានឡើយ ។ ម្យ៉ាងទៀត ទុក្ខិន្ទ្រិយដែលរលត់ក្នុងឧបចារៈនេះ រមែងមិនជាការរលត់ដោយល្អ ព្រោះមិនត្រូវធម៌ដែលជាបដិបក្ខកម្ចាត់ ។ តែក្នុងអប្បនា កាយទាំងពួងឈមចុះកាន់សេចក្តីសុខដោយការផ្សាយទៅនៃបីតិ ។ ទុក្ខិន្ទ្រិយរបស់បុគ្គលមានកាយដែលឈមចុះកាន់សេចក្តីសុខ រមែងជាការរំលត់ដោយល្អ ព្រោះត្រូវធម៌ដែលជាបដិបក្ខកម្ចាត់ ។ ម្យ៉ាងទៀត ក្នុងអាវជ្ជនៈផ្សេងៗនោះឯង កាលទោមនស្សិន្ទ្រិយ ដែលសូម្បីត្រូវលះបានក្នុងឧបចារៈនៃទុតិយជ្ឈាន ព្រោះកាលមានសេចក្តីលំបាកកាយ និងការក្តៅក្រហាយចិត្តដែលមានវិតក្ក វិចារៈជាបច្ច័យ ទោមនស្សិន្ទ្រិយនោះរមែងកើតឡើងនឹងកើតឡើងមិនបាន ព្រោះមិន

---

*១-ក្នុងទីនេះព្រះអដ្ឋកថាចារ្យ លោកលើកមកដោយសង្ខេប លោកអ្នកត្រូវការសេចក្តីពិស្តារ សូមមើលក្នុងបិដកខ្មែរលេខ ៣៨ ទំព័រ ១៨១ ឯណោះចុះ ។*

មានវិតក្កវិចារៈ ។ ឯទោមនស្សិន្ទ្រិយនោះកើតឡើងបានក្នុងទីដែលនៅមានវិតក្កវិចារៈ ។ម្យ៉ាងទៀត វិតក្កវិចារៈមិនទាន់ត្រូវលះក្នុងឧបចារៈនៃទុតិយជ្ឈានឡើយ ហេតុនោះ ទោមនស្សិន្ទ្រិយនោះ គប្បីកើតឡើងក្នុងឧបចារៈនៃទុតិយជ្ឈាននោះបាន ព្រោះមិនទាន់លះបច្ច័យបាន តែកើតឡើងមិនបានក្នុងទុតិយជ្ឈាន ព្រោះលះបច្ច័យបានហើយ ។សុខិន្ទ្រិយ សូម្បីលះបានក្នុងឧបចារៈនៃតតិយជ្ឈាន ក៏យ៉ាងនោះ គប្បីកើតឡើងដល់បុគ្គលមានកាយដែលមានរូបដ៏ប្រណីត ដែលមានបីតិជាសមុដ្ឋានជ្រួតជ្រាបហើយ តែកើតឡើងមិនបានក្នុងតតិយជ្ឈាន ដ្បិតថា បីតិដែលជាបច្ច័យដល់សុខៈក្នុងតតិយជ្ឈានរលត់ដោយប្រការទាំងពួងនោះ ឯង សោមនស្សិន្ទ្រិយដែលលះបានក្នុងឧបចារៈនៃចតុត្ថជ្ឈានក៏យ៉ាងនោះ គប្បីកើតឡើងបានព្រោះជិតនិងព្រោះមិនឈានកន្លងហើយដោយប្រពៃ ព្រោះមិនមានឧបេក្ខាដែលដល់អប្បនា តែកើតឡើងមិនបានក្នុងចតុត្ថជ្ឈាន ។

ព្រោះហេតុនោះឯង ទើបព្រះមានព្រះភាគទ្រង់ធ្វើនូវការកាន់យកមិនសេសសល់ក្នុងឈាននោះៗថា ទុក្ខិន្ទ្រិយដែលកើតឡើងក្នុងបឋមជ្ឈាននេះរមែងរលត់មិនសេសសល់ ។ ក្នុងរឿងនេះមានអ្នកចោទសួរថា កាលបើយ៉ាងនោះ វេទនាទាំងនេះ សូម្បីលះបានហើយក្នុងឧបចារៈនៃឈាននោះៗ ហេតុអ្វីទើបនាំមករួបរួមទុកក្នុងទីនេះ ឆ្លើយថា ដើម្បីឲ្យយល់បានងាយ ។

អទុក្ខមសុខវេទនាដែលលោកពោលថា **អទុក្ខមសុខំ** នេះ អទុក្ខមសុខវេទនានោះសុខុម ដឹងច្បាស់បានដោយលំបាក បុគ្គលណាមួយមិនអាចយល់បានដោយងាយ ព្រោះហេតុនោះ ទើបនាំវេទនាទាំងអស់មករួបរួមទុក ដើម្បីយល់

បានដោយងាយ ដូចអ្នកចិញ្ចឹមគោ នាំគោទាំងអស់មកប្រមូលទុកក្នុងក្រោល មួយ ដើម្បីចាប់គោកាចដែលបុគ្គលណាមួយមិនអាចចូលទៅចាប់បានដោយ វិធីណាមួយ ហើយគេនាំគោចេញម្តងមួយៗ ឲ្យមនុស្សចាប់គោកាចនោះដែល មកតាមលំដាប់ ដោយពាក្យថា គោមួយនេះជាគោកាច អ្នកទាំងឡាយចូរចាប់ វាដូច្នេះឯង ។ កាលសម្តែងវេទនាទាំងនេះ ដែលនាំមកប្រមូលទុកយ៉ាងនេះ ហើយ ក៏អាចកាន់យកវេទនានេះថា ដែលមិនមែនសុខមិនមែនទុក្ខ មិនមែន សោមនស្ស មិនមែនទោមនស្ស គឺអទុក្ខមសុខវេទនា ។

ម្យ៉ាងទៀត វេទនាទាំងនេះគប្បីជ្រាបថា លោកពោលទុកដើម្បីសម្តែង បច្ច័យនៃចេតោវិមុត្តិដែលជាអទុក្ខមសុខ ។ ឯការលះសុខទុក្ខជាដើមជាបច្ច័យ ដល់ចេតោវិមុត្តិនោះ ដូចដែលពោលទុក ( ក្នុងមជ្ឈិមនិកាយមូលបណ្ណាសក ) ថា ម្នាលអាវុសោ អទុក្ខមសុខាចេតោវិមុត្តិសមាបត្តិមានបច្ច័យ ៤ ម្នាល អាវុសោ ភិក្ខុក្នុងសាសនានេះ ព្រោះលះបង់នូវសេចក្តីសុខ ១ ។បេ។ ចូលកាន់ ចតុត្ថជ្ឈាន... ម្នាលអាវុសោ អទុក្ខមសុខាចេតោវិមុត្តិសមាបត្តិមានបច្ច័យ ៤ នេះឯង ដូច្នេះ ។

ម្យ៉ាងទៀត សក្កាយទិដ្ឋិជាដើមដែលលះបានក្នុងទីដទៃ លោកក៏ពោលថា លះហើយក្នុងតតិយមគ្គនោះ ដើម្បីពោលសរសើរតតិយមគ្គយ៉ាងណា វេទនា ទាំងនោះគប្បីជ្រាបថា លោកពោលទុកក្នុងឈានទី ៤ នេះ ដើម្បីពោលសរសើរ ឈាននោះ យ៉ាងនោះ ។

ម្យ៉ាងទៀត វេទនាទាំងនេះគប្បីជ្រាបថា លោកពោលដើម្បីសម្តែងថា រាគៈ

និងទោសៈនៅជិតក្រៃលែងក្នុងឈានទី ៤ នេះ ដោយការកម្ចាត់បច្ច័យបាន ហើយ ។ ព្រោះថាក្នុងវេទនាទាំងនេះ សុខជាបច្ច័យដល់សោមនស្ស សោមនស្ស ជាបច្ច័យដល់រាគៈ ទុក្ខជាបច្ច័យដល់ទោមនស្ស ទោមនស្សជាបច្ច័យដល់ ទោសៈ រាគៈទោសៈមួយអន្លើដោយបច្ច័យ ក៏ត្រូវកម្ចាត់ដោយការទម្លាយ សេចក្តីសុខជាដើម ហេតុនោះទើបមានក្នុងទីឆ្ងាយក្រៃលែងដូច្នេះឯង ។

បទថា **អទុក្ខមសុខំ** សេចក្តីថា ឈ្មោះថា **អទុក្ខំ** ព្រោះការមិនមាននៃទុក្ខ ឈ្មោះថា **អសុខំ** ព្រោះការមិនមាននៃសេចក្តីសុខ ។ ដោយបទនេះ ក្នុង ឈាននេះលោកសម្តែងវេទនាទី ៣ ដែលជាបដិបក្ខចំពោះទុក្ខនិងសុខ មិនមែន សម្តែងត្រឹមតែការមិនមានទុក្ខនិងសុខ ។ អទុក្ខមសុខ ឈ្មោះថា វេទនាទី ៣ លោកហៅថា ឧបេក្ខាក៏មាន ។ ឧបេក្ខានោះ គប្បីជ្រាបថា មានការសោយ អារម្មណ៍ដែលផ្សេងគ្នាអំពីឥដ្ឋារម្មណ៍និងអនិដ្ឋារម្មណ៍ជាលក្ខណៈ មានភាព ជាកណ្តាលក្នុងអារម្មណ៍ជាកិច្ច មានការមិនប្រាកដច្បាស់ជាបច្ចុប្បដ្ឋាន មាន ការរលត់នៃសុខនិងទុក្ខជាបទដ្ឋាន ។

បទថា **ឧបេក្ខាសតិបារិសុទ្ធឹ** បានដល់ មានសតិបរិសុទ្ធដែលឲ្យកើត ដោយឧបេក្ខា ។ សតិក្នុងឈាននេះបរិសុទ្ធិល្អ ។ សេចក្តីបរិសុទ្ធិនៃសតិនោះ ធ្វើដោយឧបេក្ខា មិនមែនដោយដទៃ ។ ព្រោះហេតុនោះទើបឈាននេះលោក ពោលថា មានសតិបរិសុទ្ធព្រោះឧបេក្ខា ។ ការបរិសុទ្ធិនៃសតិក្នុងឈាននេះ មានដោយឧបេក្ខាណា ឧបេក្ខានោះគប្បីជ្រាបថា ដោយអត្ថ ក៏គឺតត្រមជ្ឈត្ត- បេក្ខា ។ម្យ៉ាងទៀត ក្នុងឈាននេះមិនមែនសតិតែម្យ៉ាងប៉ុណ្ណោះដែលបរិសុទ្ធិ

*ដោយឧបេក្ខានោះ នៅមានសម្បយុត្តធម៌ទាំងពួងផងដែរ តែលោកលើកសតិឡើងសម្តែងជាបទសំខាន់ ។*

*ក្នុងឈានទាំងនោះ ឧបេក្ខានេះ មានក្នុងឈានទាំង ៣ ខាងដើមក៏ពិត ឧបមាដូចព្រះចន្ទ ទោះបីមានក្នុងពេលថ្ងៃ ក៏មិនបរិសុទ្ធផូរផង់ ព្រោះត្រូវរស្មីព្រះអាទិត្យក្នុងពេលថ្ងៃគ្របសង្កត់ និងព្រោះមិនបានរាត្រីដែលជាធម្មជាតសមគួរដោយភាពជារាត្រីផូរផង់ ឬដោយជាឧបការៈដល់ខ្លួនយ៉ាងណា ព្រះចន្ទគឺតត្រមជ្ឈត្តុបេក្ខានេះក៏យ៉ាងនោះ ទោះបីមាន ក៏មិនបរិសុទ្ធិក្នុងប្រភេទនៃបឋមជ្ឈានជាដើម ព្រោះត្រូវតេជៈនៃធម៌ដែលជាសត្រូវមានវិតក្កជាដើមគ្របសង្កត់ និងព្រោះមិនបាននូវរាត្រី គឺឧបេក្ខាវេទនាដែលជាធម្មជាតសមគួរ ។ ម្យ៉ាងទៀត កាលឧបេក្ខានោះមិនបរិសុទ្ធិ សតិជាដើមសម្បយុត្តិគឺតរួមគ្នា ក៏មិនបរិសុទ្ធិទៅដែរ ដូចរស្មីនៃព្រះចន្ទមិនបរិសុទ្ធក្នុងពេលថ្ងៃដូច្នោះ ព្រោះហេតុនោះ ទើបមិនបានពោល សូម្បីឈានតែមួយក្នុងឈានទាំងនោះថា មានសតិបរិសុទ្ធព្រោះឧបេក្ខាតែក្នុងចតុត្ថជ្ឈាននេះ ព្រះចន្ទគឺតត្រមជ្ឈត្តុបេក្ខានេះបរិសុទ្ធិក្រៃលែង ព្រោះមិនមានតេជៈនៃធម៌ដែលជាសត្រូវ មានវិតក្កជាដើមគ្របសង្កត់ និងព្រោះបាននូវរាត្រី គឺឧបេក្ខាវេទនាដែលជាធម្មជាតិសមគួរ ។*

*សតិជាដើមសម្បយុត្តិគឺតរួមគ្នា រមែងបរិសុទ្ធិផូរផង់ ព្រោះតត្រមជ្ឈត្តុបេក្ខានោះបរិសុទ្ធិ ដូចរស្មីនៃព្រះចន្ទបរិសុទ្ធដូច្នោះ ព្រោះហេតុនោះ ចតុត្ថជ្ឈាននេះប៉ុណ្ណោះគប្បីជ្រាបថា លោកពោលថា មានសតិបរិសុទ្ធព្រោះឧបេក្ខា ។*

*បទថា* **ចតុត្ថំ** *សេចក្តីថា ទី ៤ ដោយលំដាប់នៃការរាប់ ឈាននេះឈ្មោះ*

ថា **ចតុត្ថំ** ព្រោះអត្ថថា កើតឡើងជាទី ៤ ដូច្នេះក៏មាន ។

បទថា **បញ្ញវា ហោតិ** មានវិគ្គហថា ឈ្មោះថា ជាអ្នកមានបញ្ញា ព្រោះអត្ថថា បញ្ញារបស់ភិក្ខុនោះមាន ។

បទថា **ឧទយត្ថគាមិនិយា** បានដល់ ដែលឲ្យដឹងដល់ការកើតផង ឲ្យដឹងដល់ការរលត់ផង ( នៃខន្ធ ៥ ) ។

បទថា **សមន្នាគតោ** បានដល់ បរិបូណ៌ ។ បទថា **អរិយាយ** បានដល់ ប្រាសចាកទោស ។ បទថា **និព្វេធិកាយ** បានដល់ ប្រព្រឹត្តទៅក្នុងចំណែកនៃការបំបែកកិលេស ។ បទថា **ទុក្ខក្ខយគាមិនិយា** បានដល់ គ្រឿងឲ្យដល់នូវព្រះនិព្វាន ។ ក្នុងបទជាដើមយ៉ាងនេះថា **សោ ឥទំ ទុក្ខំ** ដូច្នេះ គប្បីជ្រាបសេចក្តីយ៉ាងនេះថា រមែងដឹងច្បាស់ គឺចាក់ធ្លុះនូវទុក្ខសច្ចៈទាំងពួងតាមសេចក្តីពិត ដោយការចាក់ធ្លុះនូវលក្ខណៈ ព្រមទាំងកិច្ចថា ទុក្ខមានប្រមាណប៉ុណ្ណេះ ទុក្ខមិនក្រៃលែងជាងនេះ រមែងដឹងច្បាស់ គឺចាក់ធ្លុះនូវតណ្ហាដែលជាហេតុកើតនៃទុក្ខនោះតាមសេចក្តីពិត ដោយការចាក់ធ្លុះលក្ខណៈ ព្រមទាំងរសថា នេះហេតុកើតនៃទុក្ខ រមែងដឹងច្បាស់ គឺចាក់ធ្លុះនូវនិព្វានដែលជាឋានៈដែលទុក្ខនិងទុក្ខសមុទយៈទាំងពីរនោះ ដល់ហើយរលត់ទៅនូវទុក្ខនិងទុក្ខសមុទយៈទាំងពីរនោះ មិនមានការប្រព្រឹត្តទៅទៀតតាមសេចក្តីពិត ដោយការចាក់ធ្លុះលក្ខណៈព្រមទាំងកិច្ចថា នេះការរលត់នៃទុក្ខ នឹងរមែងដឹងច្បាស់ គឺចាក់ធ្លុះនូវអរិយមគ្គ ជាគ្រឿងឲ្យដល់នូវការរលត់នៃទុក្ខនោះ តាមសេចក្តីពិត ដោយការចាក់ធ្លុះលក្ខណៈព្រមទាំងកិច្ចថា នេះបដិបទាជាគ្រឿងឲ្យដល់នូវការរលត់នៃ

*ទុក្ខ ។*

*ព្រះសារីបុត្តត្ថេរ កាលសម្តែងសច្ចៈទាំងឡាយដោយសង្ខេបយ៉ាងនេះហើយ ឥឡូវនេះ កាលនឹងសម្តែងដោយបរិយាយដោយអំណាចនៃកិលេស ទើបពោលពាក្យថា* **ឥមេ អាសវា** *ដូច្នេះជាដើម ។ អាសវៈទាំងនោះ គប្បីជ្រាបតាមន័យដែលពោលហើយ ។*

*ព្រះសារីបុត្តត្ថេរ កាលសម្តែងសិក្ខា ៣ យ៉ាងនេះហើយ ឥឡូវនេះ ដើម្បីនឹងសម្តែងលំដាប់សិក្ខា ៣ ទាំងនោះយ៉ាងបរិបូណ៌ ទើបពោលពាក្យថា* **ឥមា តិស្សោ សិក្ខាយោ អាវជ្ជន្តោ សិក្ខេយ្យ** *ដូច្នេះជាដើម ពាក្យនោះមានសេចក្តីដូចតទៅនេះ សត្វដែលកើតមក សូម្បីកាលទឹកដល់គប្បីសិក្សា ដើម្បីឲ្យបរិបូណ៌ជាបែបផែន កាលទឹកដល់ហើយ កាលដឹងថាសិក្ខាឈ្មោះនេះ គប្បីសិក្សា កាលដឹងហើយ កាលឃើញរឿយៗ គប្បីសិក្សា កាលឃើញហើយ កាលពិចារណាតាមដែលឃើញហើយគប្បីសិក្សា កាលពិចារណាហើយ កាលអធិដ្ឋានចិត្តឲ្យមាំក្នុងសិក្ខា ៣ នោះឯងគប្បីសិក្សា កាលធ្វើកិច្ចរៀងៗខ្លួនដែលសម្បយុត្តដោយសិក្ខានោះៗដោយសទ្ធា វីរិយៈ សតិ សមាធិ បញ្ញាគប្បីសិក្សា កាលធ្វើកិច្ចនោះៗ សូម្បីក្នុងកាលដែលត្រាស់ដឹងក្រៃលែងនូវធម៌ដែលគួរដឹងក្រៃលែង ឈ្មោះថាគប្បីសិក្សាសិក្ខា ៣ ដូច្នេះ ។ គប្បីប្រព្រឹត្តនូវអធិសីល គប្បីប្រព្រឹត្តអើពើនូវអធិចិត្ត គប្បីសមាទានប្រព្រឹត្តនូវអធិប្បញ្ញា ។*

*បទថា* **ឥធ** *ជាមូលបទ ។ ពាក្យប្រៀនប្រដៅរបស់ព្រះសព្វញ្ញុពុទ្ធ ពោល*

គឺត្រៃសិក្ខានោះឯង ព្រះសារីបុត្តត្ថេរពោលហើយដោយបទ ១០ មានបទថា **ឥមិស្សា ទិដ្ឋិយា** ជាដើម ។ ពាក្យប្រៀនប្រដៅនោះ លោកហៅថា **ទិដ្ឋិយា** ព្រោះព្រះដ៏មានព្រះភាគសម្ពុទ្ធទ្រង់ឃើញហើយ ។ ពាក្យប្រៀនប្រដៅនោះឯង លោកហៅថា **ខន្តិយា** ដោយអំណាចការអត់ធន់ ហៅថា **រុចិយា** ដោយអំណាចការពេញចិត្ត ហៅថា **អាទាយេ** ដោយអំណាចនៃការប្រកាន់ ហៅថា **ធម្មេ** ដោយអត្ថថា សភាវៈ ហៅថា **វិនយេ** ដោយអត្ថថា គប្បីសិក្សា ហៅថា **ធម្មវិនយេ** ដោយហេតុទាំងពីរនោះ ហៅថា **ចាវចនេ** ដោយអំណាចពោលគ្របដណ្តប់ ហៅថា **ព្រហ្មចរិយេ** ព្រោះអត្ថថា ការប្រព្រឹត្តធម៌ដ៏ប្រសើរហៅថា **សត្ថុសាសនេ** ដោយអំណាចប្រទាននូវពាក្យប្រៀនប្រដៅ ។

ព្រោះហេតុនោះក្នុងបទថា **ឥមិស្សា ទិដ្ឋិយា** ជាដើម គប្បីជ្រាបសេចក្តីយ៉ាងនេះថា ក្នុងទិដ្ឋិរបស់ព្រះពុទ្ធនេះ ក្នុងសេចក្តីគួររបស់ព្រះពុទ្ធនេះ ក្នុងសេចក្តីគាប់ចិត្តរបស់ព្រះពុទ្ធនេះ ក្នុងសេចក្តីប្រកាន់របស់ព្រះពុទ្ធនេះ ក្នុងធម៌របស់ព្រះពុទ្ធនេះ ក្នុងវិន័យរបស់ព្រះពុទ្ធនេះ ក្នុងធម្មវិន័យរបស់ព្រះពុទ្ធនេះ ដែលត្រាស់ទុក ( ក្នុងអង្គុត្តរនិកាយ អដ្ឋកនិបាត ) យ៉ាងនេះថា

ម្នាលនាងគោតមី នាងគប្បីដឹងនូវធម៌ទាំងឡាយណា ធម៌ទាំងនេះ រមែងប្រព្រឹត្តទៅដើម្បីប្រកបដោយតម្រេក មិនប្រព្រឹត្តទៅដើម្បីប្រាសចាកតម្រេក ប្រព្រឹត្តទៅដើម្បីប្រកបក្នុងវដ្តៈ មិនប្រព្រឹត្តទៅដើម្បីប្រាសចាកការប្រកបក្នុងវដ្តៈ ប្រព្រឹត្តទៅដើម្បីការសន្សំកិលេសវដ្តៈ មិនប្រព្រឹត្តទៅដើម្បីមិនមានការ

សន្សំកិលេសវដ្ដៈ ប្រព្រឹត្តទៅដើម្បីសេចក្ដីប្រាថ្នាច្រើន មិនប្រព្រឹត្តទៅដើម្បីសេចក្ដីប្រាថ្នាតិច ប្រព្រឹត្តទៅដើម្បីសេចក្ដីមិនសន្ដោស មិនប្រព្រឹត្តទៅដើម្បីសេចក្ដីសន្ដោស ប្រព្រឹត្តទៅដើម្បីប្រឡូកប្រឡំដោយពួក មិនប្រព្រឹត្តទៅដើម្បីស្ងាត់ចាកពួក ប្រព្រឹត្តទៅដើម្បីសេចក្ដីខ្ជិលច្រអូស មិនប្រព្រឹត្តទៅដើម្បីប្រារព្ធសេចក្ដីព្យាយាម ប្រព្រឹត្តទៅដើម្បីឲ្យគេចិញ្ចឹមក្រ មិនប្រព្រឹត្តទៅដើម្បីឲ្យគេចិញ្ចឹមងាយ ។ ម្នាលនាងគោតមី នាងគប្បីចាំទុកដោយពិតចុះថា នេះមិនមែនជាធម៌ នេះមិនមែនជាវិន័យ នេះជាមិនមែនជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្ដាទេ ។ ម្នាលនាងគោតមី មួយទៀត នាងគប្បីដឹងនូវធម៌ទាំងឡាយណា ធម៌ទាំងនេះរមែងប្រព្រឹត្តទៅដើម្បីប្រាសចាកតម្រេក ។បេ។ ដើម្បីឲ្យគេចិញ្ចឹមងាយ មិនប្រព្រឹត្តទៅដើម្បីឲ្យគេចិញ្ចឹមក្រ ។ ម្នាលនាងគោតមី នាងគប្បីចាំទុកដោយពិតចុះថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្ដាហើយ ដូច្នេះ ។ ក្នុងពុទ្ធបាវចនានេះ ក្នុងពុទ្ធព្រហ្មចរិយៈនេះ ក្នុងពុទ្ធសត្ថុសាសនានេះ ដូច្នេះ ។

ម្យ៉ាងទៀត ពាក្យប្រៀនប្រដៅទាំងមូល ពោលគឺត្រៃសិក្ខា ឈ្មោះថា ទិដ្ឋិ ព្រោះព្រះដ៏មានព្រះភាគសម្ពុទ្ធទ្រង់ឃើញហើយ ព្រោះមានសម្មាទិដ្ឋិជាបច្ច័យ និងព្រោះមានសម្មាទិដ្ឋិជាសភាវៈដល់មុនឈ្មោះថា **ខន្តិយា** ដោយការអត់ធន់

របស់ព្រះដ៏មានព្រះភាគ ឈ្មោះថា **រុចិយា** ដោយអំណាចការពេញចិត្ត ឈ្មោះថា **អាទាយេ** ដោយអំណាចការកាន់យក ឈ្មោះថា **ធម្មេ** ព្រោះអត្ថថា ទ្រទ្រង់នូវការកៈរបស់ខ្លួន មិនធ្លាក់ទៅក្នុងអបាយទាំងឡាយ ឈ្មោះថា **វិនយេ** ព្រោះអត្ថថា កម្ចាត់ចំណែកសង្កិលេសរបស់ធម៌នោះៗឯង ឈ្មោះថា **ធម្មវិនយេ** ព្រោះអត្ថថា ជាធម៌ផង ជាវិន័យផង ។ ម្យ៉ាងទៀត ឈ្មោះថា **ធម្មវិនយេ** ព្រោះអត្ថថា កម្ចាត់នូវអកុសលធម៌ទាំងឡាយដោយកុសលធម៌ ។

ព្រោះហេតុនោះឯងទើបត្រាស់ថា ម្នាលនាងគោតមី មួយទៀត នាងគប្បីដឹងនូវធម៌ទាំងឡាយណា ធម៌ទាំងនេះ រមែងប្រព្រឹត្តទៅដើម្បីប្រាសចាកតម្រេក ។បេ។ ម្នាលនាងគោតមី នាងគប្បីចាំទុកដោយពិតចុះថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្តាហើយ ដូច្នេះ ។ ម្យ៉ាងទៀត ឈ្មោះថា **ធម្មវិនយេ** ព្រោះអត្ថថា នាំទៅដោយវិសេសដោយធម៌ មិនមែនដោយអាជ្ញាជាដើម សមដូចលោកពោលទុក ( ក្នុងវិន័យបិដកចុល្លវគ្គ ) ថា

> ជនពួកមួយតែងទូន្មាន ( ដំរី ) ដោយដំបងខ្លះ ដោយកង្វេរខ្លះ ដោយរំពាត់ខ្លះ ( ចំណែក ) ព្រះពុទ្ធដែលព្រះអង្គស្វែងរកនូវគុណធំ ឥតមានដំបង ឥតមានគ្រឿងសស្ត្រាអ្វីទេ តែអាចទូន្មានហត្ថិនាគបាន ដូច្នេះ ។

និងពុទ្ធដិកា ( វិន័យបិដកមហាវគ្គ ) ថា

> ហេតុដូចម្តេច ក៏មានសេចក្តីចំណេននឹងពួកអ្នកប្រាជ្ញ ដែល

ជាអ្នកណែនាំសត្វដោយធម៌ ( នោះឯង ) ដូច្នេះ ។

ធម៌ឬវិន័យ ឈ្មោះថា **ធម្មវិនយេ** សេចក្ដីពិត ធម៌នេះនាំទៅឲ្យវិសេស នូវប្រយោជន៍ គឺធម៌ដែលមិនមានទោស មិនមែននាំប្រយោជន៍ មានភោគសម្បត្តិក្នុងភពជាដើមឡើយ ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ទុក ( ក្នុងអង្គុត្តរនិកាយចតុក្កនិបាត ) ថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងប្រព្រឹត្តព្រហ្មចរិយធម៌នេះ ដើម្បីកុហកមហាជនក៏ទេ ដូច្នេះ ។ សេចក្ដីពិស្ដារនៅមានតទៀត ។ សូម្បីព្រះបុណ្ណត្ថេរក៏ពោលទុក ( ក្នុងមជ្ឈិមនិកាយមូលបណ្ណាសក ) ថា ម្នាលអាវុសោ ព្រហ្មចរិយធម៌ដែលខ្ញុំប្រព្រឹត្តក្នុងសំណាក់ព្រះមានព្រះភាគដើម្បីអនុបាទាបរិនិព្វានទេតើ ដូច្នេះ ។ម្យ៉ាងទៀត ឈ្មោះថា **វិនយេ** ព្រោះអត្ថថា នាំទៅឲ្យប្រសើរ ។ នាំទៅដោយធម៌ ឈ្មោះថា **ធម្មវិនយេ** ។ មែនពិត ធម៌វិន័យនេះ រមែងនាំទៅកាន់និព្វានដ៏ប្រសើរចាកធម៌មានសង្ខារវដ្ដជាដើម ឬចាកធម៌ មានសេចក្ដីសោកជាដើម ។

ម្យ៉ាងទៀត ឈ្មោះថា **ធម្មវិនយេ** ព្រោះអត្ថថា នាំទៅឲ្យវិសេសដើម្បីធម៌ មិនមែនរបស់មេលទ្ធិទាំងឡាយ ។ ព្រះដ៏មានព្រះភាគទ្រង់កើតដោយធម៌នាំទៅឲ្យវិសេសដល់ធម៌នោះឯង ។

ម្យ៉ាងទៀត ព្រោះធម៌ទាំងឡាយនោះឯង ជាធម៌គួរដឹងក្រៃលែង គួរកំណត់ដឹង គួរលះ គួរចម្រើន និងគួរធ្វើឲ្យជាក់ច្បាស់ ដូច្នោះឯងទើបឈ្មោះថា **ធម្មវិនយេ** ព្រោះអត្ថថា នាំទៅឲ្យវិសេសក្នុងធម៌ទាំងឡាយ មិនមែនក្នុងសត្វនិងមិនមែនក្នុងជីវៈទាំងឡាយ ។

ឈ្មោះថា **ធាវចនេ** ព្រោះអត្ថថា ពាក្យជាប្រធានក្រៃលែងជាងពាក្យរបស់ជនពួកដទៃ ដោយការដល់ព្រមទាំងអត្ថនិងព្យញ្ជនៈជាដើម ពាក្យជាប្រធាននោះឯង គឺបាវចនៈ ។

ឈ្មោះថា **ព្រហ្មចរិយេ** ព្រោះជាការប្រព្រឹត្តប្រសើរជាងការប្រព្រឹត្តទាំងពួង ។

ឈ្មោះថា **សត្ថុសាសនេ** ព្រោះអត្ថថា ជាពាក្យប្រៀនប្រដៅរបស់ព្រះដ៏មានព្រះភាគដែលជាសាស្តារបស់ទេវតានិងមនុស្សទាំងឡាយ ឬឈ្មោះថា **សត្ថុសាសនេ** ព្រោះអត្ថថា ពាក្យប្រៀនប្រដៅជាសាស្តាដូច្នេះក៏មាន មែនពិតធម៌វិន័យនោះឯង ឈ្មោះថាជាសាស្តា ព្រោះអត្ថថា ព្រះដ៏មានព្រះភាគត្រាស់ទុក ( ក្នុងទីឃនិកាយមហាវគ្គ ) ថា ម្នាលអានន្ទ ធម៌ណាក្តី វិន័យណាក្តីដែលតថាគតសំដែងហើយ បញ្ញត្តហើយដល់អ្នកទាំងឡាយ លុះអំណើះតត អំពីតថាគតទៅ ធម៌និងវិន័យនោះជាគ្រូរបស់អ្នកទាំងឡាយ ដូច្នេះ ។ គប្បីជ្រាបសេចក្តីរបស់បទទាំងនោះយ៉ាងនេះ ដោយប្រការដូច្នេះ ។

ព្រោះភិក្ខុអ្នកបំពេញសិក្ខា ៣ ដោយប្រការទាំងពួង រមែងប្រាកដក្នុងសាសនានេះប៉ុណ្ណោះ មិនប្រាកដក្នុងសាសនាដទៃ ហេតុនោះ គប្បីជ្រាបថាលោក ធ្វើការកំណត់នេះថា **ឥមិស្សា** និង **ឥមស្មឹ** ក្នុងបទនោះៗ ។

[ ៤៩ ] ឈ្មោះថា **ជីវិតំ** ព្រោះអត្ថថា ជាគ្រឿងរស់នៅនៃសម្បយុត្តធម៌នោះៗ ឈ្មោះថា **ឥន្ទ្រិយំ** ព្រោះអត្ថថា ឲ្យធ្វើនូវអត្ថថា ជាធំក្នុងលក្ខណៈតាមរក្សា ។ ឥន្ទ្រិយ គឺជីវិត ឈ្មោះថា **ជីវិតិន្ទ្រិយំ** ។ ជីវិតិន្ទ្រិយនោះ ជា

*ជំនួនការបន្តក្នុងខណៈប្រព្រឹត្តទៅ ។ បើពោលដោយលក្ខណៈជីវិតិន្ទ្រិយនោះ មានការរក្សាធម៌ដែលបែកចេញអំពីខ្លួន មិនបានជាលក្ខណៈ មានការប្រព្រឹត្តទៅនៃធម៌ទាំងនោះជាកិច្ច មានការតាំងនៅនៃធម៌ទាំងនោះជាបច្ចុប្បដ្ឋាន មានធម៌ដែលគប្បីញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅជាបទដ្ឋាន ។ បណ្ឌិតគប្បីឃើញថា កាលការទ្រទ្រង់ទុក មានការតាមរក្សាជាលក្ខណៈជាដើមមាន ជីវិតិន្ទ្រិយនោះរមែងតាមរក្សាធម៌ទាំងនោះ ក្នុងខណៈមាននោះឯង ដូចទឹកតាមរក្សាផ្កាឧប្បលជាដើម និងរមែងរក្សាធម៌ដែលកើតឡើងហើយអំពីបច្ច័យទាំងឡាយតាមសមគួរដល់ខ្លួន ដូចគីលៀងរក្សាកុមារ រមែងប្រព្រឹត្តទៅដោយការជាប់ជំពាក់ក្នុងធម៌ដែលខ្លួនឲ្យប្រព្រឹត្តទៅឯង ដូចអ្នកថែវទូក ញ៉ាំងទូកឲ្យស្ទុះទៅ មិនប្រព្រឹត្តទៅកន្លងកន្លខណៈ ព្រោះមិនមានធម៌ដែលគប្បីឲ្យប្រព្រឹត្តទៅរបស់ខ្លួន មិនតាំងនៅក្នុងកន្លខណៈ ព្រោះបែកធ្លាយឯង ដូចប្រេងក្នុងប្រឆេះចង្កៀង កាលអស់ទៅរមែងញ៉ាំងអណ្តាតប្រទីបឲ្យអស់ទៅដូច្នោះ និងមិនវៀរចាកអានុភាពនៃការប្រព្រឹត្តទៅនិងការតាំងនៅ ព្រោះញ៉ាំងកិច្ចនោះៗឲ្យសម្រេចក្នុងខណៈតាមដែលពោលហើយ ។*

*បទថា* **ឋិតិបរិត្តតាយ វា** *បានដល់ ព្រោះឋិតិខណៈតិច គឺតិចតួច ។ បទថា* **អប្បកំ** *បានដល់ តិច គឺលាមក ។ បទថា* **សរសបរិត្តតាយ វា** *បានដល់ ព្រោះកិច្ច ឬសម្បត្តិទាំងឡាយដែលជាបច្ច័យរបស់ខ្លួនតិច គឺមានកម្លាំងតិច ដើម្បីសម្តែងហេតុទាំងពីរនោះដោយការចែក ទើបព្រះសារីបុត្តពោលថា* **កថំ ឋិតិបរិត្តតាយ** *ជាដើម ។*

បណ្ដាបទទាំងនោះ បទជាដើមយ៉ាងនេះថា **អតីតេ ចិត្តក្ខណេ ជីវិត្ថ** គប្បីជ្រាបថា លោកពោលសំដៅដល់អរូបជីវិត ដោយភាពដែលអរូបសំខាន់ជាងរូប កាលរូបធម៌និងអរូបធម៌ទាំងអស់មិនទាន់រលត់ ក្នុងកាលជាទីរលត់នៃចិត្ត ក្នុងការប្រព្រឹត្តទៅក្នុងបញ្ចវោការភព ឬសំដៅដល់ចុតិចិត្តក្នុងបញ្ចវោ-ការភពដោយការរលត់នៃរូបធម៌និងអរូបធម៌ទាំងពួងជាមួយចុតិចិត្ត ឬសំដៅដល់ចតុវោការភព ព្រោះការមិនមាននៃរូបក្នុងចតុវោការភព ។

បទថា **អតីតេ ចិត្តក្ខណេ** សេចក្ដីថា បុគ្គលមានការព្រមព្រៀងដោយជីវិតនោះពោលបានថា រស់នៅហើយក្នុងកាលដែលមានការព្រមព្រៀងដោយកន្លខណៈនៃចិត្តជាអតីតៈ ។

បទថា **ន ជីវតិ** សេចក្ដីថា ពោលមិនបានថា រស់នៅក្នុងបច្ចុប្បន្ន ។ បទថា **ន ជីវិស្សតិ** សេចក្ដីថា ពោលមិនបានថា នឹងរស់នៅក្នុងអនាគត ។

បទថា **អនាគតេ ចិត្តក្ខណេ ជីវិស្សតិ** សេចក្ដីថា ពោលបានថា នឹងរស់នៅក្នុងកាលដែលមានការព្រមព្រៀងដោយខណៈ ជាទីកើតឡើងនៃចិត្តជាអនាគត ។

បទថា **ន ជីវតិ** សេចក្ដីថា ពោលមិនបានថា កំពុងរស់នៅ ។ បទថា **ន ជីវិត្ថ** សេចក្ដីថា ពោលមិនបានថា ធ្លាប់រស់នៅហើយក្នុងអតីតៈ ។

បទថា **បច្ចុប្បន្នេ ចិត្តក្ខណេ ជីវតិ** សេចក្ដីថា ពោលបានថា រមែងរស់នៅក្នុងកាលដែលមានការព្រមព្រៀងដោយខណៈនៃចិត្តដែលជាបច្ចុប្បន្ន ។

បទថា **ន ជីវិត្ថ** សេចក្ដីថា ពោលមិនបានថា ធ្លាប់រស់នៅហើយក្នុង

អតីតៈ ។ បទថា **ន ជីវិស្សតិ** សេចក្តីថា ពោលមិនបានថា នឹងរស់នៅក្នុងអនាគត ។

គាថានេះថា **ជីវិតំ អត្តភាវោ ច សុខទុក្ខា ច** ដូច្នេះ លោកពោលសំដៅយកបច្ចុប្បន្នកាលនោះឯង ព្រោះត្រូវទុក្ខវេទនាដែលបានមក ព្រោះមិនទាន់ផុតបច្ចុប្បន្នកាលប្រកាន់ទុក សួរថា សេចក្តីនេះដូចម្តេច ។ ( ឆ្លើយថា ) បទថា **ជីវិតំ** បានដល់ សង្ខារក្ខន្ធដោយមាតិកា គឺជីវិត ។ បទថា **អត្តភាវោ** បានដល់ រូបក្ខន្ធ សុខនិងទុក្ខរួមឧបេក្ខាវេទនាទុកខាងក្នុង ហេតុនោះទើបឈ្មោះថា **វេទនាខន្ធ** ព្រោះលោកពោលទុកថា **ឧបេក្ខា** លោកពោលថា សុខនោះឯង ព្រោះស្ងប់ ។

វិញ្ញាណក្ខន្ធ លោកពោលថា ចិត្ត ។ សូម្បីសញ្ញាខន្ធ ក៏គប្បីជ្រាបថាលោកពោលទុកហើយ ដោយអំណាចនៃការប្រាថ្នាលក្ខណៈ ដោយជាលក្ខណៈណាមួយ ដោយលក្ខណៈនៃខន្ធ ព្រោះភាពដែលខន្ធទាំងឡាយ ៤ នេះលោកបានពោលទុកហើយ ។

ភាពជាប្រធាននៃអរូបធម៌ ឈ្មោះថា លោកពោលហើយថា **ឯកចិត្ត-សមាយុត្តា** ព្រោះលះអរូបធម៌ក្នុងខន្ធ ៥ ដែលពោលហើយយ៉ាងនេះ រូបដែលមានកម្មជាសមុដ្ឋានជាដើមនិងប្រព្រឹត្តទៅមិនបាន ។ សេចក្តីនេះ ដូចម្តេច សេចក្តីថា សូម្បីរូបក្នុងអសញ្ញីសត្ត រមែងប្រព្រឹត្តទៅមិនផុតនូវកម្លាំងកម្មដែលចូលទៅសន្សំទុកក្នុងចិត្តដួងមួយនេះ ។ សូម្បីរូបរបស់អ្នកចូលនិរោធទាំងឡាយក៏ប្រព្រឹត្តទៅមិនផុតកម្លាំងនៃបឋមសមាបត្តិឡើយ ។

ភាពដែលចិត្តជាប្រធាន គប្បីជ្រាបថា លោកពោលហើយថា **ឯកចិត្ត-សមាយុត្តា** ដោយភាពជាហេតុនៃប្រធាននៃការប្រព្រឹត្តទៅនៃរូប ក្នុងឋានៈដែលប្រព្រឹត្តទៅនៃខ្លួន របស់អរូបធម៌ដែលមានសភាវៈធ្វើនូវការប្រព្រឹត្តទៅនៃរូប ក្នុងឋានៈដែលប្រព្រឹត្តទៅមិនបានរបស់ខ្លួនយ៉ាងនេះ ឲ្យជារបស់មានរបស់ខ្លួននោះឯងប្រព្រឹត្តទៅ ។ កាលរូបតាំងនៅនោះឯង ឈ្មោះថា ការរលត់របស់សត្វទាំងឡាយ រមែងមានដោយការរលត់នៃចិត្តដែលជាប្រធានរបស់ការប្រព្រឹត្តទៅនៃរូប ក្នុងបវត្តិកាល ក្នុងបញ្ចវោការភពដោយប្រការដូច្នេះ ហេតុនោះ ទើបលោកពោលថា **លហុសោ វត្តតេ ខណោ** ដោយអំណាចនៃអរូបធម៌ នោះឯង ។

ម្យ៉ាងទៀតគប្បីជ្រាបថា លោកពោលសំដៅដល់ជីវិតជាដើមជាធម៌ប្រកបព្រមជាមួយចិត្តមួយដួង សំដៅយកចុតិចិត្តក្នុងបញ្ចវោការភព ។ កាលលោកពោលយ៉ាងនេះ សុខវេទនាដែលប្រព្រឹត្តទៅផ្លូវកាយនិងផ្លូវចិត្ត និងទុក្ខវេទនាដែលប្រព្រឹត្តទៅផ្លូវកាយនិងផ្លូវចិត្ត ក្នុងបទថា **សុខទុក្ខា ច** សូម្បីមិនមានក្នុងខណៈនៃចុតិចិត្ត លោកក៏ពោលថា រមែងរលត់ព្រមជាមួយចុតិចិត្តដោយមានសន្និរុមគ្នា ។ គប្បីជ្រាបថា លោកពោល សំដៅដល់ចតុវោការភពក៏-មាន សេចក្តីនេះដូចម្តេច សេចក្តីថា សញ្ញាខន្ធ លោកប្រើពាក្យថា អត្តភាព ព្រោះក្នុងទីដទៃលោកក៏ហៅសញ្ញាខន្ធថា អត្តភាពផងដែរ សុខទុក្ខផ្លូវកាយនិងទោមនស្ស សូម្បីមិនមានក្នុងព្រហ្មលោក ក៏គប្បីជ្រាបថា លោកកាន់យកថាវេទនាខន្ធ ដែលបានដោយឈ្មោះថា ក្នុងបទថា **សុខទុក្ខា ច** ដូច្នេះ ។ បទ

ដ៏សេសដូចគ្នាតាមដែលពោលហើយនោះឯង ។ម្យ៉ាងទៀត ក្នុងវិកប្បទាំង ៣ នេះ ដោយពាក្យថា **កោវលា** រមែងមិនមានការឋិតថេរ សេចក្ដីសុខសេចក្ដីស្អាត និងអត្តាគឺមិនលាយឡំដោយការឋិតថេរ សេចក្ដីសុខ ការស្អាតនិងអត្តានោះទាំងអស់ ។ ខណៈនៃជីវិតជាដើម រហ័ស គឺតិចតួចពន់ពេក ប្រព្រឹត្តទៅមួយដួរខណៈនោះឯង រមែងប្រព្រឹត្តទៅដោយន័យដែលពោលហើយថា **លហុសោ វត្តតិក្ខណោ** ។

ព្រះសារីបុត្តត្ថេរ កាលនឹងសម្ដែងការមិនប្រព្រឹត្តទៅរួមគ្នានៃចិត្ត ២ ដួង ទើបពោលគាថាថា **ចុល្លាសីតិ សហស្សានិ** ជាដើម ។

បទថា **ចុល្លាសីតិ សហស្សានិ កប្បា តិដ្ឋន្តិ យេ មរូ** សេចក្ដីថា ពួកទេវតាទាំងឡាយណាមានអាយុ ៨៤០០០ កប្ប រមែងតាំងនៅក្នុងភពជាន់នេវសញ្ញានាសញ្ញាយតនៈ ។ បាលីថា **យេ ឆភា** ដូច្នេះក៏មាន ។

បទថា **ន ត្វេវ តេបិ ជីវន្តិ ទ្វីហិ ចិត្តេហិ សមោហិតា** សេចក្ដីថា ទេវតាទាំងនោះ ជាអ្នកប្រកបដោយចិត្ត ២ ដួង ដោយភាពតែមួយ ជាអ្នកនៅដោយចិត្តដែលទាក់ទងគ្នាជាគូមិនបានឡើយ តែរមែងជាអ្នករស់នៅដោយចិត្តមួយដួងប៉ុណ្ណោះ ។

ឥឡូវនេះព្រះសារីបុត្តត្ថេរ កាលសម្ដែងមរណកាល ទើបពោលគាថាថា **យេ និរុទ្ធា** ជាដើម ។

បណ្ដាបទទាំងនោះ បទថា **យេ និរុទ្ធា** សេចក្ដីថា ខន្ធទាំងឡាយណារលត់ហើយ គឺដល់នូវការតាំងនៅមិនបាន ។

បទថា **មរន្តស្ស** បានដល់ របស់សត្វដែលស្លាប់ហើយ ។ បទថា **តិដ្ឋ-មានស្ស វា** បានដល់ ឬកំពុងតាំងនៅ ។ បទថា **សព្វេបិ សទិសា ខន្ធា** សេចក្តីថា ខន្ធទាំងពួង ជាខន្ធដែលរលត់បន្តអំពីចុតិក្តី ជាខន្ធដែលរលត់ក្នុងកាលប្រព្រឹត្តទៅក្តី ឈ្មោះថា ដូចគ្នា ដោយអត្ថថា មិនអាចបន្តបានទៀត ។

បទថា **គតា អប្បដិសន្ធិកា** សេចក្តីថា ខន្ធទាំងនោះលោកពោលថា រលត់ទៅហើយ មិនបានបន្តគ្នា ព្រោះមិនមានខន្ធដែលរលត់ហើយមកកើតបន្តទៀត ។

ឥឡូវនេះ ព្រះសារីបុត្តត្ថេរដើម្បីនឹងសម្តែងថា ខន្ធដែលរលត់ក្នុងកាលទាំង ៣ មិនមានការផ្សេងគ្នា ទើបពោលគាថាថា **អនន្តរា** ជាដើម ។

បណ្តាបទទាំងនោះ បទថា **អនន្តរា ច យេ ភគ្គា យេ ច ភគ្គា អនាគតា** សេចក្តីថា ខន្ធទាំងឡាយណាជាអតីតៈជាប់តគ្នាបែកហើយ គឺរលត់ហើយ ខន្ធទាំងឡាយណាជាអនាគតក៏នឹងបែក ។

បទថា **តទន្តរេ** បានដល់ ខន្ធដែលជាបច្ចុប្បន្នដែលរលត់ក្នុងរវាងខន្ធទាំងដែលជាអតីតៈនិងខន្ធដែលជាអនាគតទាំងនោះ ។

បទថា **វេសម្មំ នត្ថិ លក្ខណេ** សេចក្តីថា ការមិនស្មើ ឈ្មោះថា ប្លែកគ្នា ។ ការប្លែកនោះមិនមាន ។ អធិប្បាយថា មិនមានការផ្សេងគ្នាចាកខន្ធទាំងនោះ ឈ្មោះថា លក្ខណៈ ព្រោះអត្ថថា កំណត់ក្នុងលក្ខណៈនោះ ។

ឥឡូវនេះ ព្រះសារីបុត្តត្ថេរ កាលពោលភាពដែលខន្ធក្នុងអនាគត មិនលាយឡំដោយខន្ធដែលជាបច្ចុប្បន្ន ទើបពោលគាថាថា **អនិព្វត្តេន ន ជាតោ**

ជាដើម ។

បទថា **អនិព្វត្តេន ន ជាតោ** សេចក្តីថា មិនកើតហើយ គឺមិនកើតឡើងហើយដោយខន្ធដែលជាអនាគត ដែលមិនទាន់កើត គឺមិនប្រាកដ ។ ដោយពាក្យនេះ ព្រះថេរៈពោលដល់កាលដែលខន្ធជាអនាគត មិនឈ្មោះយទ្បឺ ដោយខន្ធជាបច្ចុប្បន្ន ។

បទថា **បច្ចុប្បន្នេន ជីវតិ**(១) សេចក្តីថា រមែងជាអ្នករស់នៅដោយខន្ធដែលជាបច្ចុប្បន្នក្នុងបច្ចុប្បន្នខណៈ ។ ដោយបទនេះ លោកពោលថា សត្វរមែងមិនរស់នៅដោយចិត្ត ២ ដួងក្នុងខណៈតែមួយ ។

បទថា **ចិត្តភង្គមតោ** សេចក្តីថា ស្លាប់ហើយ ព្រោះការរលត់នៃចិត្ត ព្រោះការរស់នៅមិនបានដោយចិត្ត ២ ដួងក្នុងខណៈតែមួយ បាលីថា **ឧបរិតោ ចិត្តភង្គា** ដូច្នេះក៏មាន បទបាលីនោះ មានន័យត្រង់នោះឯង ។

បទថា **បញ្ញត្តិ បរមត្ថិយា** សេចក្តីថា ត្រឹមតែជាបញ្ញត្តិតាមលំដាប់ពាក្យ ( ក្នុងសំយុត្តនិកាយសគាថវគ្គ ) ថា រូបរបស់សត្វទាំងឡាយ រមែងចាស់ជរា នាមនិងគោត្តមិនចាស់ជរាឡើយ ដូច្នេះ ។ ឈ្មោះថា ដោយបរមត្ថ ព្រោះអត្ថថា បញ្ញត្តិនោះមានការតាំងមាំយ៉ាងក្រៃលែង ព្រោះជាសភាពមិនជរា អធិប្បាយថា តាំងមាំដោយសភាវៈ ។ សេចក្តីពិត តាំងនៅត្រឹមតែបញ្ញត្តិប៉ុណ្ណោះថា នាយទត្តៈស្លាប់ នាយមិត្តៈស្លាប់ ។

---

១-បទនេះ ក្នុងបិដកខ្មែរលោកសរសេរថា បច្ចុប្បន្នេ ន ជីវតិ ហើយលោកប្រែថា មិនមែនរស់នៅក្នុងបច្ចុប្បន្នទេ តែក្នុងអដ្ឋកថាលោករចនាទុកថា បច្ចុប្បន្នេន ជីវតិ ( អក្សរ ន មិនដកឃ្លា ) ទើបប្រែថា សត្វលោករមែងរស់នៅក្នុងខន្ធដែលជាបច្ចុប្បន្ន បណ្ឌិតគប្បីពិចារណា ។

ម្យ៉ាងទៀត បទថា **បរមត្ថិយា** បានដល់ **បរមត្ថិកា** ( មានបរមត្ថ ) បញ្ញត្តិឈ្មោះថា **បរមត្ថិកា** ព្រោះអត្ថថា មានអត្ថយ៉ាងក្រៃលែង បញ្ញត្តិថា ស្លាប់ហើយ មិនបានពោលព្រោះអាស្រ័យនត្ថិធម៌ ( ធម៌ដែលមិនមាន ) ដូចការពោលអាស្រ័យនត្ថិធម៌នៃបញ្ញត្តិថា **អជដាកាស** ប្រែថា លំហាមេឃ លោកពោលអាស្រ័យធម៌ ពោលគឺការបែកធ្លាយនៃជីវិតិន្ទ្រិយ ។

បទថា **អនិធានគតា ភគ្គា** សេចក្តីថា ខន្ធទាំងឡាយបែកធ្លាយហើយ ខន្ធទាំងនោះរមែងមិនដល់នូវការទ្រទ្រង់នៅ គឺការតាំងនៅ គឺការតម្កល់នៅ ហេតុនោះទើបឈ្មោះថា មិនបានដល់នូវការតាំងនៅ ។

បទថា **បុញ្ជោ នត្ថិ អនាគតេ** សេចក្តីថា ភាពជាក្រុម គឺភាពជាគំនរនៃខន្ធទាំងនោះ រមែងមិនមានសូម្បីក្នុងអនាគត ។

បទថា **និព្វត្តាយេវ តិដ្ឋន្តិ** សេចក្តីថា ខន្ធទាំងឡាយដែលកើតឡើងជាបច្ចុប្បន្ន ជាខន្ធដែលមានការវិនាសទៅជាធម្មតា ក្នុងឋិតិខណៈរមែងតាំងនៅ ។ សេចក្តីនេះដូចម្តេច សេចក្តីថា ដូចគ្រាប់ស្ពៃដែលតាំងនៅលើចុងដែកស្រួច ដូច្នោះ ។

ឥឡូវនេះ ព្រះថេរៈកាលសម្តែងនូវការវិនាសរបស់ខន្ធទាំងឡាយ ទើបពោលគាថាថា **និព្វត្តានំ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **និព្វត្តានំ ធម្មានំ** បានដល់ ខន្ធបច្ចុប្បន្ន ។ បទថា **ភង្គោ នេសំ បុរក្ខតោ** សេចក្តីថា ការបែកធ្លាយតាំងនៅខាងមុខនៃសត្វទាំងនោះ ។ បទថា **បលោកធម្មា** បានដល់ ធម៌ដែលមានសេចក្តីវិនាស

ជាសភាវៈ ។ បទថា **បុរាណោហិ អមិស្សិតា** សេចក្ដីថា មិនលាយឡំ គឺ មិនទាក់ទងដោយខន្ធទាំងឡាយដែលកើតឡើងក្នុងកាលមុន ។

ឥឡូវនេះ ព្រះថេរៈកាលសម្ដែងការមិនប្រាកដនៃខន្ធទាំងឡាយ ទើបពោលគាថាថា **អទស្សនតោ អាយន្តិ** ជាដើម ។

បណ្ដាបទទាំងនោះ បទថា **អទស្សនតោ អាយន្តិ** សេចក្ដីថា មក គឺ កើតឡើង ទាំងដែលមិនប្រាកដឡើយ ។

បទថា **ភគ្គា គច្ឆន្តិ ទស្សនំ** សេចក្ដីថា បែកហើយ ក៏ទៅកាន់ការមិនប្រាកដបន្ទាប់អំពីបែក ។

បទថា **វិជ្ជុប្បាទោវ អាកាសេ** បានដល់ ដូចផ្លេកបន្ទោរក្នុងអាកាសកណ្ដាលវាល ។

បទថា **ឧប្បជ្ជន្តិ វយន្តិ ច** សេចក្ដីថា រមែងកើតឡើង និងរមែងបែកទៅបន្ទាប់អំពីចាប់ផ្ដើម អធិប្បាយថា វិនាស ដូចសេចក្ដី ( ក្នុងមណិកុណ្ឌលជាតក ) ជាដើមថា ព្រះចន្ទរមែងរះឡើងពេញវង់ រួចអស់ទៅ ដូច្នោះ ។

កាលសម្ដែងការតាំងនៅត្រឹមបន្តិចបន្តួចយ៉ាងនេះហើយ ឥឡូវនេះ ព្រះថេរៈកាលនឹងសម្ដែងភាពជាអ្នកមានកិច្ចតិច ទើបពោលពាក្យថា **កាជំ សរស-បរិត្តតាយ** ជាដើម ។

បទថា **អស្សាសូបនិពទ្ធំ ជីវិតំ** សេចក្ដីថា ជីវិតិន្ទ្រិយទាក់ទងដោយខ្យល់ប្រមុះដែលចូលទៅខាងក្នុង ។ បទថា **បស្សាសោ** បានដល់ ខ្យល់ប្រមុះដែលចេញទៅខាងក្រៅ ។ បទថា **អស្សាសបស្សាសា** បានដល់

ខ្យល់ទាំងពីរនោះ ។ បទថា **មហាភូតូបនិពទ្ធំ** សេចក្តីថា មានជីវិតទាក់ទង ដោយមហាភូតរូប ដែលមានសមុដ្ឋាន ៤ គឺដី ទឹក ភ្លើង ខ្យល់ ។

បទថា **កវឡិង្ការាហារូបនិពទ្ធំ** បានដល់ ទាក់ទងដោយអាហារ គឺ ពំនូតបាយ មានគ្រឿងបរិភោគនិងគ្រឿងផឹកជាដើម ។

បទថា **ឧស្មូបនិពទ្ធំ** បានដល់ ទាក់ទងដោយតេជោធាតុ ដែលកើតអំពី កម្ម ។ បទថា **វិញ្ញាណូបនិពទ្ធំ** សេចក្តីថា ទាក់ទងដោយវិញ្ញាណក្នុងកវត្ត គឺដែលលោកសំដៅពោលទុកក្នុងពាក្យថា អាយុក្តី ភ្លើងធាតុក្តី វិញ្ញាណក្តី តែងលះបង់នូវកាយនេះ ដែលជាចំណីនៃសត្វដទៃ មិនមានចេតនាក្នុងកាល ណាហើយ ដូច្នេះ ។

ឥឡូវនេះ ព្រះថេរៈកាលសម្តែងហេតុឲ្យមានកម្លាំងថយនៃធម៌មានខ្យល់ ដង្ហើមចូលជាដើមនោះ ទើបពោលពាក្យជាដើមថា **មូលម្បិ ឥមេសំ ទុព្វលំ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **មូលម្បិ** សេចក្តីថា ឈ្មោះថា **មូលម្បិ** ដោយ អត្ថថា ជាទីតាំង មែនពិត ករជកាយជាមូលនៃខ្យល់ដង្ហើមចូលនិងខ្យល់ដង្ហើម ចេញ អវិជ្ជា កម្ម តណ្ហានិងអាហារជាមូលនៃមហាភូតរូប ។ បទថា **ឥមេសំ** បានដល់ ខ្យល់ដង្ហើមចេញចូលជាដើម ដែលមានប្រការដូចពោលហើយ គឺ ដែលពោលហើយដោយអំណាចនៃហេតុដែលទាក់ទងដោយជីវិតិន្ទ្រិយ បណ្តា ខ្យល់ដង្ហើមចេញចូលជាដើមនោះនីមួយៗ មិនមានជីវិតិន្ទ្រិយ ក៏រមែងតាំងនៅ មិនបាន ។ បទថា **ទុព្វលំ** បានដល់ មានកម្លាំងតិច ។ បទថា **បុព្វហេតូបិ**

សេចក្តីថា សូម្បីអវិជ្ជា សង្ខារ តណ្ហា ឧបាទាននិងកព ពោលគឺហេតុដែលជាហេតុនៃវិបាកវដ្តៈនេះ ក្នុងអតីតជាតិនៃខ្យល់ដង្ហើមចូលជាដើមនេះ មានកម្លាំងខ្សោយ ។

បទថា **យេបិ បច្ចយា តេបិ ទុព្វលា** បានដល់ សាធារណប្បច្ច័យមានអារម្មណប្បច្ច័យជាដើម ។ បទថា **បភាវិកា** បានដល់ តណ្ហាដែលជាប្រធានកើតឡើង ។ បទថា **សហភូបិ** បានដល់ រូបធម៌និងអរូបធម៌ សូម្បីដែលរួមកពគ្នា ។ បទថា **សម្បយោគាបិ** បានដល់ អរូបធម៌ដែលប្រកបរួមគ្នា ។ បទថា **សហជាបិ** បានដល់ កើតឡើងជាមួយគ្នាក្នុងចិត្តតែមួយ ។ បទថា **យាបិ បយោជិកា** បានដល់ តណ្ហាដែលជាមូលនៃវដ្តៈ ។ ឈ្មោះថា **បយោជិកា** ព្រោះអត្ថថា ប្រកបហើយដើម្បីប្រកបដោយអំណាចនៃចុតិនិងបដិសន្ធិ សមដូចព្រះតម្រាស់ ( ក្នុងខុទ្ទកនិកាយឥតិវុត្តក ) ថា បុរសមានតណ្ហាជាគម្រប់ពីរដូច្នេះ ។ បទថា **និច្ចទុព្វលា** បានដល់ មានកម្លាំងទុព្វលដោយមិនមានចន្លោះ ។ បទថា **អនវត្ថិតា** បានដល់ មិនតាំងចុះ គឺមិនបង្អោនចុះ បិតនៅ ។ បទថា **បរិបាតយន្តិ ឥមេ** សេចក្តីថា ធម៌ទាំងនេះ រមែងញ៉ាំងគ្នានឹងគ្នាឲ្យធ្លាក់ទៅ គឺឲ្យបន្សាត់ទៅ ។ បទថា **អញ្ញមញ្ញស្ស** ប្រែថា ដល់គ្នានឹងគ្នា សេចក្តីថា អ្នកដទៃ... ដល់អ្នកដទៃ ឬថា មួយដល់មួយទៀត ។ **ហិ** សព្ទជានិបាតចុះក្នុងអត្ថនៃហេតុ ។

បទថា **នត្ថិ តាយិតា** សេចក្តីថា ការជ្រកកោន គឺរក្សាមិនមាន ។ បទថា **ន ចាបិ ឋបេន្តិ អញ្ញមញ្ញំ** សេចក្តីថា ធម៌ដទៃមិនអាចតាំងធម៌ដទៃទុក

បាន ។ បទថា **យោបិ និព្វត្តកោ សោ ន វិជ្ជតិ** សេចក្តីថា ធម៌ណា ដែលកើតឡើងនៃធម៌ទាំងនេះ ធម៌នោះ មិនមានក្នុងកាលឥឡូវនេះ ។

បទថា **ន ច កេនចិ កោចិ ហាយតិ** សេចក្តីថា ធម៌ណាមួយ សូម្បីតែម្យ៉ាង រមែងមិនវិនាសទៅ ព្រោះអំណាចនៃធម៌ណាមួយ ។ បទថា **ភគ្គព្យា ច ឥមេ ហិ សព្វសោ** សេចក្តីថា ខន្ធទាំងអស់នេះ ក៏គួរដល់នូវការរលត់ទៅដោយអាការៈទាំងពួង ។ បទថា **បុរិមេហិ បភាវិតា** សេចក្តីថា ខន្ធទាំងនេះ ដែលហេតុបច្ច័យមានក្នុងកាលមុននេះ ឲ្យប្រព្រឹត្តទៅ គឺឲ្យកើតឡើង ។ បទថា **យេបិ បភាវកា** បានដល់ ហេតុបច្ច័យក្នុងកាលមុនដែលឲ្យប្រព្រឹត្តទៅ គឺឲ្យកើតឡើងទាំងនេះ ។ បទថា **តេ បុរេ មតា** សេចក្តីថា បច្ច័យមានប្រការដូចពោលហើយនោះ មិនដល់បច្ចុប្បន្ន ដល់នូវការស្លាប់ហើយមុននោះឯង ។

បទថា **បុរិមាបិ ច បច្ឆិមាបិ ច** សេចក្តីថា ខន្ធដែលកើតមុន គឺដែលមានហេតុបច្ច័យមុនក្តី ខន្ធដែលកើតក្រោយ គឺដែលកើតឡើងមួយអន្លើដោយបច្ច័យ ក្នុងកាលហេតុបច្ច័យប្រព្រឹត្តទៅក្តី ។ បទថា **អញ្ញមញ្ញំ ន កទាចិ មទ្ទសំសុ** សេចក្តីថា មិនធ្លាប់ឃើញគ្នានឹងគ្នាក្នុងកាលណា **ម** អក្ខរៈ លោកពោលដោយអំណាចនៃបទសន្ធិ ។ បទថា **ចាតុម្មហារាជិកានំ ទេវានំ** សេចក្តីថា ទេវតាទាំងនោះឈ្មោះថា ចាតុម្មហារាជិកា ព្រោះអត្ថថា មានមហារាជទាំង ៤ ពោលគឺស្តេចធតរដ្ឋ ស្តេចវិរុឡ្ហកៈ ស្តេចវិរូបក្ខៈនិងស្តេចកុវេរៈជាធំ ។ ឈ្មោះថា **ទេវានំ** ព្រោះអត្ថថា រុងរឿងដោយរូបជាដើម ។ ទេវតាជាន់ចាតុ-

ម្មហារាជិកាទាំងនោះ នៅកណ្ដាលភ្នំសិនេរុ បណ្ដាទេវតាទាំងនោះ ពួកដែលនៅត្រង់បព៌តក៏មាន ពួកដែលនៅក្នុងអាកាសក៏មាន នៅតៗគ្នាទៅរហូតដល់ភ្នំកណ្ដាប់ចក្កវាឡ ។ ទេវតាទាំងនេះ គឺពួកខិឌ្ឌាបទោសិកៈ ពួកមនោបទោសិកៈ ពួកសីតវលាហកៈ ពួកឧណ្ហវលាហកៈ ចន្ទិមទេវបុត្ត សុរិយទេវបុត្តទាំងអស់នៅក្នុងទេវលោកជាន់ចាតុម្មហារាជិកា ។ ជីវិតរបស់ទេវតាជាន់ចាតុម្មហារ-ជិកាទាំងនោះ ។

បទថា **ឧបាទាយ** បានដល់ អាស្រ័យ ។ បទថា **បរិត្តកំ** បានដល់ បដិសេធនូវសេចក្ដីចម្រើន ដូចក្នុងសេចក្ដី ( ក្នុងទីឃនិកាយមហាបរិនិព្វានសូត្រ ) ថា វ័យរបស់តថាគតចាស់ហើយ ជីវិតរបស់តថាគតមានប្រមាណតិចជាដើម ។ បទថា **ថោកំ** បានដល់ សល់នៅពេលបន្តិចបន្តួច បដិសេធថ្ងៃវែងឆ្ងាយ ។ បទថា **ខណិកំ** បានដល់ សល់ពេលតិច គឺបដិសេធរយៈពេល ដូចក្នុងសេចក្ដីថា មរណៈមួយជួរខណៈ ឈានមួយជួរខណៈជាដើម ។

បទថា **លហុកំ** បានដល់ ស្រាលព្រម បដិសេធនូវការខ្ជិលច្រអូស ដូចក្នុងប្រយោគជាដើមថា ប្រព្រឹត្តទៅរហ័សយ៉ាងនេះជាដើម ។ បទថា **ឥត្តរំ** បានដល់ រហ័ស បដិសេធយ៉ាងខ្លាំងក្លា ដូចក្នុងសេចក្ដីថា ភក្តីមួយរំពេច សទ្ធាមួយរំពេច ជាដើម ។

បទថា **អនទ្ធនិយំ** បានដល់ អត់ធន់មិនបានយូរដោយអំណាចនៃកាល ដូចក្នុងប្រយោគជាដើមថា អស់កាលយូរ ជាដើម ។

បទថា **ន ចិរដ្ឋិតិកំ** សេចក្ដីថា ឈ្មោះថា **ន ចិរដ្ឋិតិកំ** ព្រោះអត្ថថា

តាំងនៅមិនយូររាល់ៗថ្ងៃ បដិសេធដល់ថ្ងៃ ដូចក្នុងប្រយោគថា ព្រះសទ្ធម្ម តាំងនៅមិនយូរ ជាដើម ។

បទថា **តាវត្តឹសានំ** សេចក្តីថា ឈ្មោះថា **តាវត្តឹសានំ** ព្រោះអត្ថថា ជន ៣៣ នាក់ កើតឡើងក្នុងភពនោះ ម្យ៉ាងទៀត លោកពោលពាក្យថា តាវត្តិង្ស ថាជាឈ្មោះរបស់ទេវតាទាំងនោះ ដូច្នេះក៏មាន ទេវតាទាំងនោះ នៅលើបពិត ក៏មាននៅក្នុងអាកាសក៏មាន នៅតៗគ្នារហូតដល់ភ្នំកណ្តាប់ចក្កវាឡក៏មាន ជាន់ យាមាជាដើមក៏ដូចគ្នា សូម្បីក្នុងទេវលោកមួយជាន់ ពួកទេវតាដែលនៅតៗ គ្នា មិនដល់ភ្នំកណ្តាប់ចក្កវាឡរមែងមិនមាន ។

ឈ្មោះថា **យាមា** ព្រោះអត្ថថា ទៅ គឺដល់ បានដល់ សម្រេចដល់ នូវទិព្វសុខ ។ ឈ្មោះថា **តុសិតា** ព្រោះអត្ថថា ត្រេកអរហើយ រីករាយ ហើយ ។ ឈ្មោះថា **និម្មានរតី** ព្រោះអត្ថថា និម្មិតភោគៈទាំងឡាយតាម ដែលពេញចិត្ត ហើយត្រេកអរក្នុងកាលដែលបំណងនឹងត្រេកអរដោយភោគៈ ដែលក្រៃលែងជាងអារម្មណ៍ដែលតាក់តែងទុកតាមប្រក្រតី ។

ឈ្មោះថា **បរនិម្មិតវសវត្តី** ព្រោះអត្ថថា ញុំាងអំណាចឲ្យប្រព្រឹត្តទៅ ក្នុងភោគៈទាំងឡាយដែលទេវតាដទៃដឹងវារៈចិត្តហើយនិម្មិតឲ្យ ។

ឈ្មោះថា **ព្រហ្មកាយិកា** ព្រោះអត្ថថា ប្រកបហើយដោយធម៌ជាគ្រឿង បន្តឲ្យជាព្រហ្មក្នុងពួកព្រហ្ម ។ លោកសង្គ្រោះយកពួកព្រហ្មទាំងអស់ទុកផង ដែរ ។

បទថា **គមនីយោ** ប្រែថា ត្រូវទៅ ។ បទថា **សម្បរាយោ** បានដល់

លោកដទៃ ។ បទថា **យោ ភិក្ខវេ ចិរំ ជីវតិ សោ វស្សសតំ** សេចក្តីថា បុគ្គលណារមែងរស់នៅយូរ បុគ្គលនោះក៏រស់នៅបានត្រឹមមួយរយឆ្នាំ ។

បទថា **អប្បំ វា ភិយ្យោ** សេចក្តីថា ដែលតាំងនៅជាងមួយរយឆ្នាំ មានតែឈ្មោះថា តាំងនៅអស់ ២០០ ឆ្នាំមិនមាន ។

បទថា **ហិឡេយ្យ នំ** សេចក្តីថា គប្បីមើលងាយជីវិតនោះ គឺគប្បីគិតជាវត្ថុថោកថយ លោកពោលថា **ហិឡេយ្យានំ** ដូច្នេះ ក៏មាន ។

បទថា **អច្ចយន្តិ** បានដល់ រមែងឈានកន្លង ។ បទថា **អហោរត្តា** បានដល់ កំណត់យប់និងថ្ងៃ ។

បទថា **ឧបរុជ្ឈតិ** សេចក្តីថា ជីវិតិន្ទ្រិយ រមែងរលត់ គឺចូលដល់នូវភាពមិនមាន ។

បទថា **អាយុ ខីយតិ មច្ចានំ** សេចក្តីថា អាយុសង្ខាររបស់សត្វទាំងឡាយ រមែងដល់នូវការអស់ទៅ ។

បទថា **កុន្នទីនំវ ឱទកំ** សេចក្តីថា ទឹកក្នុងស្ទឹងតិចដែលដាច់ទឹករមែងអស់ទៅយ៉ាងណា អាយុរបស់សត្វទាំងឡាយ រមែងអស់ទៅយ៉ាងនោះ ។ ដោយបរមត្ថ ខណៈនៃជីវិតរបស់សត្វទាំងឡាយតិចពន់ពេក ត្រឹមតែប្រព្រឹត្តទៅមួយជួរខណៈចិត្តនោះឯងប៉ុណ្ណោះ កង់រថកាលវិលក៏វិលដោយប្រទេសនៃខ្នងកង់តែម្យ៉ាងប៉ុណ្ណោះ កាលតាំងនៅ តាំងនៅដោយប្រទេសនៃខ្នងកង់នោះឯងយ៉ាងណា ជីវិតរបស់សត្វទាំងឡាយនោះ ប្រព្រឹត្តទៅមួយជួរខណៈចិត្តនោះឯង ហេតុនោះ លុះចិត្តដួងនោះរលត់ លោកហៅសត្វថា រលត់ គឺស្លាប់ ។

បទថា **ធីរា** បានដល់ អ្នកប្រាជ្ញ **ធីរា** មួយបទទៀត បានដល់ បណ្ឌិត ។ បទថា **ធិតិមា** សេចក្តីថា ឈ្មោះថា **ធិតិមា** ព្រោះអត្ថថា មានបញ្ញាជាគ្រឿងទ្រទ្រង់ ។

បទថា **ធិតិសម្បន្នា** សេចក្តីថា ប្រកបដោយភាពជាបណ្ឌិត ។ បទថា **ធិក្កតបាបា** សេចក្តីថា ជាអ្នកតិះដៀលបាប ដើម្បីសម្តែងបរិយាយរបស់បទនោះឯង ទើបព្រះសារីបុត្តត្ថេរពោលថា **ធី វុច្ចតិ បញ្ញា** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ ឈ្មោះថា **បញ្ញា** ព្រោះអត្ថថា ដឹងទូទៅ សួរថា ដឹងទូទៅនូវអ្វី ឆ្លើយថា ដឹងទូទៅនូវអរិយសច្ចៈទាំងឡាយដោយន័យថា នេះទុក្ខជាដើម តែក្នុងអដ្ឋកថាលោកពោលថា ឈ្មោះថា **បញ្ញា** ដោយអំណាចប្រកាសឲ្យដឹងទូទៅ ប្រកាសឲ្យដឹងទូទៅថាដូចម្តេច ប្រកាសឲ្យដឹងទូទៅថា **អនិច្ចំ ទុក្ខំ អនត្តា** បញ្ញានោះ ឈ្មោះថា **ឥន្ទ្រិយំ** ដោយអត្ថថា ជាធំ ព្រោះគ្របសង្កត់អវិជ្ជាបាន ។ ម្យ៉ាងទៀត ឈ្មោះថា **ឥន្ទ្រិយំ** ព្រោះអត្ថថា ឲ្យធ្វើនូវភាពជាធំក្នុងលក្ខណៈនៃការឃើញ ។ ឥន្ទ្រិយ គឺបញ្ញា ឈ្មោះថា **បញ្ញិន្ទ្រិយំ** ។

បញ្ញានេះមានការភ្លឺជាលក្ខណៈ ឬមានការដឹងទូទៅជាលក្ខណៈ ដូចផ្ទះមានជញ្ជាំង ៤ ពេលយប់ កាលអុជប្រទីបងងឹតរមែងវិនាសទៅ ពន្លឺរមែងប្រាកដយ៉ាងណា បញ្ញាមានការភ្លឺស្វាងជាលក្ខណៈក៏យ៉ាងនោះ ។ ឈ្មោះថាពន្លឺដែលភ្លឺស្មើដោយបញ្ញា រមែងមិនមាន កាលបុគ្គលមានបញ្ញាអង្គុយដោយភ្លែន ១ លោកធាតុ ១ ម៉ឺនរមែងមានពន្លឺតែមួយ ព្រោះហេតុនោះ ទើបព្រះថេរៈពោលថា មហាបពិត្រ បុរសកាន់ប្រទីបប្រេងចូលទៅក្នុងផ្ទះដែលងងឹត ប្រទីប

*ចូលទៅហើយ រមែងកម្ចាត់ងងឹត ឲ្យកើតនូវពន្លឺភ្លឺស្វាង ធ្វើរូបទាំងឡាយឲ្យប្រាកដ បានយ៉ាងណា មហាបពិត្រ បញ្ញាក៏ដូច្នោះដូចគ្នា កាលកើតឡើង រមែងកម្ចាត់នូវងងឹតគឺអវិជ្ជា ឲ្យកើតនូវពន្លឺគឺវិជ្ជា ពន្លឺនៃញាណធ្វើអរិយសច្ចៈឲ្យប្រាកដបាន ។ មហាបពិត្រ បញ្ញាមានការភ្លឺស្វាងជាលក្ខណៈយ៉ាងនេះឯង ។*

*ម្យ៉ាងទៀត ដូចគ្រូពេទ្យអ្នកឈ្លាស រមែងដឹងភោជនជាដើម ដែលជាសប្បាយនិងមិនជាសប្បាយរបស់បុគ្គលអ្នកឈឺទាំងឡាយយ៉ាងណា បញ្ញាក៏យ៉ាងនោះ កាលកើតឡើង រមែងដឹងទូទៅនូវធម៌ទាំងឡាយដែលជាកុសលនិងអកុសល ដែលគួរសេពនិងមិនគួរសេព ដែលអាក្រក់និងប្រណីតដែលខ្មៅនិងសនិងមានចំណែកប្រៀប ។ សមដូចពាក្យដែលព្រះធម្មសេនាបតីពោលទុក ( ក្នុងមជ្ឈិមនិកាយ មូលបណ្ណាសក ) ថា ម្នាលអាវុសោ បុគ្គលដែលចេះដឹងច្បាស់ហ្នឹងឯងដែលហៅថា អ្នកមានប្រាជ្ញា ចុះបុគ្គលនោះដឹងច្បាស់នូវអ្វីដឹងច្បាស់ថា នេះទុក្ខ ដូច្នេះ ។ គប្បីឲ្យពិស្តារ ។ គប្បីជ្រាបភាពដែលបញ្ញានោះ មាននូវការដឹងទូទៅជាលក្ខណៈយ៉ាងនេះ ។*

*ន័យម្យ៉ាងទៀត បញ្ញាមានការចាក់ធ្លុះតាមសភាវៈជាលក្ខណៈ ឬមានការចាក់ធ្លុះមិនខុសជាលក្ខណៈ ដូចការចាក់ធ្លុះរបស់ព្រួញដែលនាយខ្មាន់ធ្នូអ្នកឈ្លាសបាញ់ចេញទៅ មានការបំភ្លឺក្នុងអារម្មណ៍ជាកិច្ច ដូចប្រទីបមានការមិនវង្វេងជាបច្ចុប្បដ្ឋាន ដូចអ្នកជំនាញក្នុងការដើរព្រៃដូច្នោះ ។*

*បទថា* **ខន្ធធីរា** *សេចក្តីថា ឈ្មោះថា ជាអ្នកមានបញ្ញាក្នុងខន្ធ ព្រោះអត្ថថា ញ៉ាំងញាណឲ្យប្រព្រឹត្តទៅក្នុងខន្ធ ៥ ឈ្មោះថា ជាអ្នកមានបញ្ញាក្នុងធាតុ*

ព្រោះអត្ថថា ញ៉ាំងញាណឲ្យប្រព្រឹត្តទៅក្នុងធាតុ ១៨ ក្នុងបទដ៏សេសទាំងឡាយ ក៏គប្បីយល់អត្ថដោយន័យនេះ ។

បទថា **តេ ធីរា ឯវមាហំសុ** សេចក្តីថា បណ្ឌិតទាំងនោះ ពោលទុកហើយយ៉ាងនេះ ។

បទថា **ផរេន្តិ** បានដល់ ពោលថាតិច បន្តិចបន្តួច ។ បទថា **ភណន្តិ** បានដល់ ពោលថា បន្តិចបន្តួច ប្រព្រឹត្តទៅមួយជួរខណៈ ។ បទថា **ទីបយន្តិ** បានដល់ សម្តែងថា ប្រព្រឹត្តទៅរហ័ស ប្រព្រឹត្តទៅមួយរំពេច ។ បទថា **វោហរន្តិ** បានដល់ ថ្លែងដោយវិធីផ្សេងៗថា តាំងនៅមិនវែងឆ្ងាយ តាំងនៅមិនយូរ ។

[ ៥០ ] ឥឡូវនេះ ព្រះថេរៈកាលនឹងសម្តែងការកើតឡើងនៃការវិនាសរបស់ពួកជនដែលមិនធ្វើយ៉ាងនេះ ទើបពោលគាថាថា **បស្សាមិ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **បស្សាមិ** បានដល់ ឃើញដោយមំសចក្ខុជាដើម ។ បទថា **លោកេ** បានដល់ ក្នុងអបាយជាដើម ។ បទថា **បរិផន្ទមានំ** បានដល់ ឃ្លេងឃ្លោងទៅខាងនោះ ខាងនេះ ។ បទថា **បជំ ឥមំ** បានដល់ ពួកសត្វនេះ ។ បទថា **តណ្ហាគតំ** បានដល់ ជាអ្នកទៅហើយក្នុងតណ្ហា អធិប្បាយថា ត្រូវតណ្ហាគ្របសង្កត់ឲ្យធ្លាក់ទៅ ។ បទថា **ភវេសុ** បានដល់ ក្នុងកាមភពជាដើម ។ បទថា **ហីនា នរា** បានដល់ នរជនមានការងាររថោកទាប ។ បទថា **មច្ចុមុខេ លបន្តិ** សេចក្តីថា រំខានទ្រូវក្នុងមាត់នៃមរណៈដែលដល់ក្នុងកាលទីបំផុត ។ បទថា **អវីតតណ្ហាសេ** បានដល់ មិនទាន់អស់តណ្ហា ។ បទថា **ភវា** បានដល់ កាមភពជាដើម ។ បទថា **ភវេសុ** បានដល់ ក្នុងភព

ទាំងឡាយមានកាមភពជាដើម ។ ម្យ៉ាងទៀត បទថា **ភវាភវេសុ** បានដល់ក្នុងភពតូចនិងភពធំ លោកអធិប្បាយថា ក្នុងភពទាំងឡាយរឿយៗ ។

[ ៥១ ] បទថា **បស្សាមីតិ មំសចក្ខុនាបិ បស្សាមិ** សេចក្ដីថា មំសចក្ខុ ២ យ៉ាង គឺសសម្ភារចក្ខុ បសាទចក្ខុ ។ ដុំសាច់ដែលតាំងនៅត្រង់ប្រឡង់ភ្នែក ដែលកំណត់ដោយការកោងនៃកែវភ្នែកទាំងពីរ គឺខាងក្រោមដោយឆ្អឹងប្រឡង់ភ្នែក ខាងលើដោយឆ្អឹងចិញ្ចើម ខាងក្រៅដោយរោមភ្នែកទាក់ទងដោយខួរដែលមានសរសៃភ្ជាប់ចេញមក ត្រង់កណ្ដាលប្រឡង់ភ្នែកវិចិត្រដោយវង្វង់ពណ៌ខ្មៅជាភ្នែកសភ្នែកខ្មៅ នេះឈ្មោះថា **សសម្ភារចក្ខុ** ។ បសាទដែលចងត្រង់ដុំសាច់នេះ ជាប់ទាក់ទងក្នុងដុំសាច់នេះ អាស្រ័យមហាភូតរូប ៤ ឈ្មោះថា **បសាទចក្ខុ** ដែលបំណងក្នុងទីនេះ ។

បសាទចក្ខុនោះមានភ្នាសស្រោបចក្ខុ ៧ ជាន់ ឲ្យជ្រាបសើម ដូចសំឡីជ្រលក់ប្រេង ៧ ស្រទាប់ក្នុងវង្វង់មូល ដែលឃើញក្នុងប្រទេស ដែលកើតឡើងនៃសណ្ឋានសរីរៈរបស់បុគ្គលដែលឈរត្រង់មុខ ត្រង់កណ្ដាលកែវភ្នែកពណ៌ខ្មៅដែលព័ទ្ធជុំវិញដោយភ្នែកពណ៌សរបស់សសម្ភារចក្ខុនោះ ឲ្យសម្រេចនូវភាពជាវត្ថុនិងទ្វារ ដែលមានប្រមាណប៉ុនក្បាលចៃ តាមសមគួរដល់ចក្ខុវិញ្ញាណជាដើម ។ បសាទចក្ខុនោះ ឈ្មោះថា ចក្ខុ ព្រោះអត្ថថា ប្រាប់ឲ្យស្គាល់អ្វីៗ ( ថា ) ខ្ញុំឃើញដោយមំសចក្ខុនោះ ។

បទថា **ទិព្វចក្ខុនា** បានដល់ ដោយទិព្វចក្ខុយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយតថាគតបានឃើញ ( ពួកបញ្ចវគ្គិយភិក្ខុនៅក្នុងឥសិបតនមិគទាយវ័នទៀប

ក្រុងពារាណសី ) ដោយទិព្វចក្ខុដ៏បរិសុទ្ធ ដូច្នេះ ។

បទថា **បញ្ញាចក្ខុនា** បានដល់ ដោយបញ្ញាចក្ខុ ដែលមក ( ក្នុងមជ្ឈិម-និកាយមជ្ឈិមបណ្ណាសក ) យ៉ាងនេះថា ធម្មចក្ខុគឺសោតាបត្តិមគ្គដ៏ប្រាសចាកធូលី ប្រាសចាកមន្ទិល ក៏កើតឡើង ដូច្នេះ ។

បទថា **ពុទ្ធចក្ខុនា** បានដល់ ដោយពុទ្ធចក្ខុ ដែលមក ( ក្នុងមជ្ឈិម-និកាយមូលបណ្ណាសក ) យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ កាលតថាគតកំពុងប្រមើលមើលសត្វលោកដោយពុទ្ធចក្ខុ ក៏បានឃើញ ដូច្នេះ ។

បទថា **សមន្តចក្ខុនា** បានដល់ ដោយសមន្តចក្ខុ ដែលមក ( ក្នុងខុទ្ទក-និកាយចូឡនិទ្ទេស ) យ៉ាងនេះថា សព្វញ្ញុតញ្ញាណ លោកហៅថា សមន្ត-ចក្ខុ ដូច្នេះ ។

បទថា **បស្សាមិ** បានដល់ ឃើញរូបដោយមំសចក្ខុ ដូចឃើញផ្លែកន្ទួតព្រៃដែលដាក់លើបាតដៃដោយមំសចក្ខុ ។

បទថា **ឧក្ខាមិ** សេចក្តីថា ឃើញច្បាស់នូវចុតិនិងបដិសន្ធិដោយទិព្វចក្ខុ ។ បទថា **ឳលោកេមិ** សេចក្តីថា ត្រួតមើលអរិយសច្ចៈ ៤ ដោយបញ្ញាចក្ខុ ។ បទថា **និជ្ឈាយាមិ** សេចក្តីថា គិតនូវឥន្ទ្រិយ ៥ មានសទ្ធាជាដើមដោយពុទ្ធចក្ខុ ។

បទថា **ឧបបរិក្ខាមិ** សេចក្តីថា ឃើញដោយប្រពៃ គឺស្វែងរកផ្លូវដែលគួរទូន្មាន ( នេយ្យបថ )[១] ៥ ប្រការដោយសមន្តចក្ខុ ។

---

១-នេយ្យបថ ៥ គឺ សន្ធារ ១ វិការៈ ១ លក្ខណៈ ១ និទាន ១ បញ្ញត្តិ ១ ។

បទថា **តណ្ហាជដ្ឋជាយ ជដ្ឋមានំ** បានដល់ ញាប់ញ័រដោយការញាប់ញ័រព្រោះតណ្ហា ។ បន្ទាប់អំពីនេះការអន្ទះអន្ទែង មានការអន្ទះអន្ទែងព្រោះទិដ្ឋិជាដើម មានការអន្ទះអន្ទែងដោយទុក្ខ ព្រោះការវិនាសគឺទិដ្ឋិជាទីបំផុត ។ បទដ៏សេសងាយយល់ហើយ ព្រោះមានន័យដូចពោលហើយ ។

បទថា **សម្ផន្ទមានំ** បានដល់ អន្ទះអន្ទែងរឿយៗ ។ បទថា **វិប្ផន្ទមានំ** បានដល់ ញាប់ញ័រដោយវិធីផ្សេងៗ ។ បទថា **វេធមានំ** បានដល់ ញ័រ ។ បទថា **បវេធមានំ** បានដល់ ញ័រដោយសេចក្តីព្យាយាម ។ បទថា **សម្បវេធមានំ** បានដល់ ញ័ររឿយៗ ។ម្យ៉ាងទៀត លោកពង្រីកបទដោយឧបសគ្គ ។

[ ៥២ ] បទថា **តណ្ហានុគតំ** បានដល់ ចូលទៅតាមតណ្ហា ។ បទថា **តណ្ហានុសដំ** បានដល់ ផ្សាយទៅតាមតណ្ហា ។ បទថា **តណ្ហាយាបន្នំ** បានដល់ រមែងលិចចុះក្នុងតណ្ហា ។ បទថា **តណ្ហាយ ចាតិតំ** បានដល់ ដែលតណ្ហាបន្សាត់ទៅ ។ បាឋៈថា **បរិចាតិតំ** ក៏មាន ។ បទថា **អភិភូតំ** បានដល់ ដែលតណ្ហាញាំញី គឺលិចលង់ហើយ ។ បទថា **បរិយាទិន្នចិត្តំ** បានដល់ មានចិត្តដែលតណ្ហាប្រកាន់ទុកអស់ហើយ ។ ម្យ៉ាងទៀត នៅក្នុងតណ្ហាដូចទៅតាមជំនន់ទឹក ទៅតាមតណ្ហា ដូចធ្លាក់ទៅតាមបច្ច័យនៃរូបដែលមានវិញ្ញាណគ្រប់គ្រង ផ្សាយទៅតាមតណ្ហា ដូចចកផ្សាយបិទបាំងទឹក លិចចុះក្នុងតណ្ហា ដូចលិចក្នុងរណ្តៅឧច្ចារៈ ធ្លាក់ក្នុងតណ្ហា ដូចធ្លាក់អំពីចុងឈើ ចូលក្នុងជ្រោះ ( ត្រូវតណ្ហា ) គ្របសង្កត់ហើយ ដូចប្រកបទុកក្នុងរូបដែលមានវិញ្ញាណគ្រប់គ្រង មានចិត្ត ( ត្រូវតណ្ហា ) សង្កត់សង្កិនហើយ ដូចមានវិបស្សនា

កើតឡើងដល់បុគ្គលដែលកំណត់ដឹងរូបដែលមានវិញ្ញាណគ្រប់គ្រង ។

ម្យ៉ាងទៀត អាចារ្យពួកមួយពណ៌នាទុកយ៉ាងនេះថា **នៅក្នុងតណ្ហា** ដោយកាមឆន្ទៈ **ទៅតាមតណ្ហា** ដោយការស្រេកក្នុងកាម **ផ្សាយទៅតាមតណ្ហា** ដោយការត្រាំក្នុងកាម **លិចចុះក្នុងតណ្ហា** ដោយការក្តៅក្រហាយ ព្រោះកាម **ធ្លាក់ក្នុងតណ្ហា** ដោយការបញ្ចប់ព្រោះកាម ( **ត្រូវតណ្ហា** ) **គ្របសង្កត់ហើយ** ដោយឱឃៈគឺកាម **មានចិត្ត ( ត្រូវតណ្ហា ) សង្កត់សង្កិនហើយ** ដោយការប្រកាន់មាំក្នុងកាម ។

បទថា **កាមភវេ** បានដល់ កាមាវចរភព ។ បទថា **រូបភវេ** បានដល់ រូបាវចរភព ។ បទថា **អរូបភវេ** បានដល់ អរូបាវចរភព ។ ការផ្សេងគ្នារបស់ភពទាំងនោះ បានប្រកាសហើយខាងដើមនោះឯង ។

[ ៥៤ ] បទថា **ភវាភវេសុ** សេចក្តីថា បទថា **ភវោ** ក្នុងបទថា **ភវា-ភវេ** បានដល់ កាមធាតុ ។ បទថា **អភវោ** បានដល់ រូបធាតុនិងអរូបធាតុ ។

ម្យ៉ាងទៀត បទថា **ភវោ** បានដល់ កាមធាតុ រូបធាតុ ។ បទថា **អភវោ** បានដល់ អរូបធាតុ ។ ក្នុងភពតូចភពធំទាំងនោះ ។ បទថា **កម្មភវេ** បានដល់ កម្មវដ្ដៈ ។ បទថា **បុនព្ភវេ** បានដល់ វិបាកវដ្ដៈ ដែលបង្អោនទៅក្នុងភពថ្មី ។ បទថា **កាមភវេ** បានដល់ កាមធាតុ ។ បទថា **កម្មភវេ** បានដល់ កម្មវដ្ដៈ ។ ក្នុងបទទាំងនោះ កម្មវដ្ដៈ ( កម្មភព ) ឈ្មោះថា ភព ព្រោះអត្ថថា ធ្វើឲ្យកើត ។

បទថា **កាមភវេ បុនព្ភវេ** បានដល់ វិបាកវដ្ដៈដែលជាឧបបត្តិភពក្នុង

*កាមធាតុ ។ វិបាកភព ឈ្មោះថា ភព ព្រោះអត្ថថា កើត ។ សូម្បីក្នុងរូបភពជាដើម ក៏ន័យនេះឯង ។*

*ពាក្យថា **កាមភវេ រូបភវេ អរូបភវេ** ក្នុងទីនេះ លោកពោលសំដៅយកក្នុងឱកាសភព ។*

*ក្នុងភពទាំង ៣ បទថា **កម្មភវេ** បានដល់ កម្មវដ្ដៈ ។ បទថា **បុនព្ភវេ** លោកពោលសំដៅយកឧបបត្តិភពដូចគ្នា ។ បទថា **បុនប្បុនំ ភវេ** បានដល់ ក្នុងកាលកើតឡើងរឿយៗ ។ បទថា **គតិយា** បានដល់ ឯណាទីមួយក្នុងគតិ ៥ ។ បទថា **អត្តភាវាភិនិព្វត្តិយា** បានដល់ គតិក្នុងការកើតឡើងនៃអត្តភាពទាំងឡាយ ។*

*បទថា **អវីតតណ្ហា** ជាបទដើម ។ បទថា **អវិគតតណ្ហា** សេចក្ដីថា ឈ្មោះថា **អវិគតតណ្ហា** ព្រោះអត្ថថា មិនទាន់ប្រាសចាកតណ្ហា ព្រោះមិនមានខណិកបហាន ដូចខណិកសមាធិ ។*

*បទថា **អចត្តតណ្ហា** សេចក្ដីថា ឈ្មោះថា **អចត្តតណ្ហា** ព្រោះអត្ថថា មានតណ្ហាមិនទាន់លះបាន ព្រោះមិនមានតទង្គប្បហាន ។*

*បទថា **អវន្តតណ្ហា** សេចក្ដីថា ឈ្មោះថា **អវន្តតណ្ហា** ព្រោះអត្ថថា មានតណ្ហាមិនទាន់ខ្ជាក់បាន ព្រោះមិនមានវិក្ខម្ភនប្បហាន ។*

*បទថា **អមុត្តតណ្ហា** សេចក្ដីថា ឈ្មោះថា **អមុត្តតណ្ហា** ព្រោះអត្ថថា មានតណ្ហាមិនទាន់ផុតទៅបាន ព្រោះមិនមានសមុច្ឆេទប្បហានបរិបូណ៌ ។*

*បទថា **អប្បហីនតណ្ហា** សេចក្ដីថា ឈ្មោះថា **អប្បហីនតណ្ហា** ព្រោះ*

អត្ថថា មានតណ្ហាមិនទាន់លះបាន ព្រោះមិនមានបដិបស្សទ្ធិប្បហាន ។

បទថា **អប្បដិនិស្សដ្ឋតណ្ហា** សេចក្តីថា ឈ្មោះថា **អប្បដិនិស្សដ្ឋតណ្ហា** ព្រោះមិនទាន់លះសង្កិលេសដែលជាអច្ចន្តៈ ដែលតាំងមាំក្នុងភពហើយតាំងនៅ ព្រោះមិនមាននិស្សរណប្បហាន ។

[ ៥៥ ] ឥឡូវនេះព្រោះបុគ្គលមិនទាន់ប្រាសចាកតណ្ហា រមែងអន្ទះអន្ទែង និងកន្ទក់កន្ទេញដូច្នោះ ព្រះមានព្រះភាគកាលទ្រង់ដឹកនាំក្នុងការកម្ចាត់តណ្ហា ទើបពោលពាក្យថា **មមាយិតេ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **មមាយិតេ** បានដល់ ព្រោះវត្ថុដែលប្រកាន់ជារបស់អញដោយការប្រកាន់ថារបស់អញ ដោយតណ្ហានិងទិដ្ឋិ ។ ព្រះមានព្រះភាគត្រាស់ហៅអ្នកស្តាប់ទាំងឡាយដោយបទថា **បស្សថ** ។

បទថា **ឯតម្បិ** បានដល់ ទោសនោះ បទដ៏សេសប្រាកដជាក់ច្បាស់ហើយនោះឯង ។

[ ៥៦ ] បទថា **ទ្វេ មមត្តា** បានដល់ អាល័យ ២ យ៉ាង ។ បទថា **យាវតា** ជានិបាត ប្រើក្នុងអត្ថថា កំណត់បែងចែក ។ បទថា **តណ្ហាសង្ខាតេន** បានដល់ ដោយចំណែកនៃតណ្ហា ។ បទថា **សង្ខា សង្ខាតំ**[១] សេចក្តីថា ដោយអត្ថក៏ដូចគ្នាតែមួយ ដូចក្នុងប្រយោគ ( ខុទ្ទកនិកាយសុត្តនិបាត ) ថា **សញ្ញានិទានា ហិ បបញ្ចសង្ខា** ព្រោះធម៌ជាចំណែកនៃសេចក្តីយឺតយូរទាំងឡាយ មានសញ្ញាជាហេតុ ដូច្នេះ ។

---

១-បិដកខ្មែរមិនមានបទនេះទេ មានតែក្នុងអដ្ឋកថាប៉ុណ្ណោះ ។

បទថា **សីមកតំ** បានដល់ វៀរចាកទោសព្រោះមិនមានព្រំដែន ដែលធ្វើឲ្យជាព្រំដែន ដូចក្នុងប្រយោគ ( ក្នុងវិនយបិដក មហាវគ្គ ) ថា **តិយោជនបរមំ សីមំ សម្មន្និតុំ** ភិក្ខុសម្មតិសីមាទំហំ ៣ យោជន៍យ៉ាងធំ ដូច្នេះ ។

បទថា **ឱធិកតំ** បានដល់ វៀរចាកទោសដែលកើតព្រោះការកំណត់ពាក្យទុក ដូចដើមឈើដែលនៅក្នុងរវាងដែន ដែលកំណត់ទុក ។

បទថា **បរិយន្តកតំ** បានដល់ ធ្វើការកំណត់ទុក គឺធ្វើព្រំដែនថា ដើមឈើដែលនៅក្នុងរវាងសីមា ( **សីមន្តរិក** ) ជាសាធារណៈទាំងពីរចំណែក ដើមឈើនេះ ត្រូវធ្វើឲ្យដូចជាជួរដើមត្នោត ដែលទាក់ទងជាជួរតែមួយ ។

បទថា **បរិគ្គហិតំ** បានដល់ កាន់យកដោយអាការៈទាំងពួងផុតទីដែលបុគ្គលដទៃកាន់យក សូម្បីក្នុងរយៈកាលមួយ ។

បទថា **មមាយិតំ** បានដល់ ធ្វើនូវសេចក្តីអាល័យ ដូចសេនាសនៈរបស់ភិក្ខុដែលចូលចាំវស្សា ។

បទថា **ឥធំ មមំ** បានដល់ តាំងនៅក្នុងទីជិត ។ បទថា **ឯតំ មមំ** បានដល់ តាំងនៅក្នុងទីឆ្ងាយ ។ បទថា **ឯត្តកំ** បានដល់ កំណត់បរិក្ខារដូចក្នុងសេចក្តីថា **ឯតកម្បិ នប្បដិភាសេយ្យ** សូម្បីត្រឹមប៉ុណ្ណោះ ក៏មិនគប្បីពោលតប ។ បទថា **ឯត្តាវតា** បានដល់ ការកំណត់ដោយនិបាត ក្នុងអត្ថថា កំណត់ដូចក្នុងសេចក្តីថា **ឯត្តាវតា ខោ មហាឆាម** ម្នាលមហានាម ដោយពាក្យមានប្រមាណប៉ុណ្ណោះឯង ។ បទថា **កេវលម្បិ មហាបឋវី** បានដល់ មហាប្រឹថពីសូម្បីទាំងមូល ។ បទថា **អដ្ឋសតតណ្ហាវិចរិតំ** បានដល់ ពង្រីកទៅ

ជាតណ្ហា ១០៨ បើសួរថា ១០៨ ដូចម្ដេច ឆ្លើយថា តណ្ហាដែលប្រព្រឹត្តទៅក្នុងជវនវិថី ក្នុងចក្ខុទ្វារជាដើម យ៉ាងនេះថា រូបតណ្ហា ។បេ។ ធម្មតណ្ហាជាអារម្មណ៍ដូចគ្នានឹងបិតា ដូចបានឈ្មោះមកអំពីបិតា ក្នុងពាក្យជាដើមថា សេដ្ឋីបុត្ត ព្រាហ្មណបុត្ត ដូច្នេះ ។

ក្នុងបទនេះឈ្មោះថា **រូបតណ្ហា** ព្រោះអត្ថថា តណ្ហាមានរូបជាអារម្មណ៍ គឺតណ្ហាក្នុងរូប ។ រូបតណ្ហានោះ មាន ៣ គឺដែលត្រេកអរក្នុងរូប ប្រព្រឹត្តទៅដោយតម្រេកក្នុងកាម ឈ្មោះថា កាមតណ្ហា ដែលត្រេកអរ ប្រព្រឹត្តទៅយ៉ាងនេះថា រូបទៀង ឋិតថេរ មាំទាំដោយតម្រេកដែលសហគតៈដោយសស្សតទិដ្ឋិ ឈ្មោះថា **ភវតណ្ហា** ។ ដែលត្រេកអរប្រព្រឹត្តទៅយ៉ាងនេះថា រូបដាច់សូន្យវិនាស ស្លាប់ហើយនឹងមិនកើត ប្រព្រឹត្តទៅដោយតម្រេកដែលសហគតៈដោយឧច្ឆេទទិដ្ឋិ ឈ្មោះថា **វិភវតណ្ហា** ។ សទ្ទតណ្ហាជាដើម មានន័យដូចរូបតណ្ហានោះឯង ។ តណ្ហាទាំងនោះរួមជាតណ្ហាវិចរិត ១៨ ។ តណ្ហាទាំងនោះក្នុងរូបខាងក្នុងជាដើម ១៨ ក្នុងរូបខាងក្រៅជាដើម ១៨ រួមជា ៣៦ ដែលជាអតីតៈ ៣៦ អនាគត ៣៦ បច្ចុប្បន្ន ៣៦ រួមជា ១០៨ ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត តណ្ហាវិចរិតដែលអាស្រ័យខន្ធបញ្ចកៈខាងក្នុង គឺដែលអាស្រ័យរូបខាងក្នុងជាដើមយ៉ាងនេះថា កាលប្រកាន់ថា ជាអញមាន ក៏រមែងមានសេចក្ដីប្រកាន់ថា អញយ៉ាងនេះ ។បេ។ ដូច្នេះ មាន ១៨ តណ្ហាវិចរិតដែលអាស្រ័យខន្ធបញ្ចកៈខាងក្រៅ គឺដែលអាស្រ័យរូបខាងក្រៅជាដើមថា កាលប្រកាន់ថាជាអញមាន ដោយខន្ធបញ្ចកៈនេះ ក៏រមែងមានការប្រកាន់ថា អញយ៉ាងនេះ

*ដោយខន្ធបញ្ចកៈនេះ ។បេ។ ដូច្នេះ មាន ១៨ រួមជា ៣៦ ។ ដែលជា អតីតៈ ៣៦ អនាគត ៣៦ បច្ចុប្បន្ន ៣៦ រួមជាតណ្ហាវិបរិត ១០៨ យ៉ាង នេះ ដោយប្រការដូច្នេះ ។*

*បទថា* **វីសតិវត្ថុកា សក្កាយទិដ្ឋិ** *សេចក្តីថា ឈ្មោះថា សក្កាយទិដ្ឋិ ព្រោះអត្ថថា ទិដ្ឋិក្នុងកាយនោះ ក្នុងកាលកាយពោលគឺខន្ធបញ្ចកៈមាន ដោយ អត្ថថាកើតឡើង មានដោយធ្វើវត្ថុដែលប្រព្រឹត្តទៅដោយអំណាចការប្រកាន់ ៤ យ៉ាង ដោយន័យជាដើមថា ពិចារណារូបក្នុងរូបនីមួយៗនៃខន្ធ ៥ មានរូប ជាដើមថាជាត្លួន ដូច្នេះ ។*

*បទថា* **ទសវត្ថុកា មិច្ឆាទិដ្ឋិ** *បានដល់ មិច្ឆាទិដ្ឋិដែលប្រព្រឹត្តទៅដោយ ន័យជាដើមថា ទានដែលបុគ្គលឲ្យហើយមិនមានផល យញ្ញដែលបូជាហើយ មិនមានផល ម្យ៉ាងទៀត ទិដ្ឋិដែលមិនពិតប្រាកដជាទិដ្ឋិដែលអាក្រក់ ព្រោះ ប្រកាន់ខុស ឈ្មោះថា មិច្ឆាទិដ្ឋិ ។ ឈ្មោះថា* **មិច្ឆាទិដ្ឋិ** *ព្រោះអត្ថថា ទិដ្ឋិ ដែលបណ្ឌិតទាំងឡាយរង្កៀស ព្រោះមិននាំប្រយោជន៍មកដូច្នេះក៏មាន ។*

*មិច្ឆាទិដ្ឋិនោះ មានការប្រកាន់មាំដោយមិនមែនជាឧបាយជាលក្ខណៈ មាន ការប្រកាន់ជាកិច្ច មានការប្រកាន់ខុសជាបច្ចុប្បដ្ឋាន មានភាពជាអ្នកមិនប្រាថ្នា ឃើញព្រះអរិយៈទាំងឡាយជាបទដ្ឋានគប្បីឃើញថាមានទោសយ៉ាងក្រៃលែង ។*

*បទថា* **ទសវត្ថុកា អន្តគ្គាហិកា ទិដ្ឋិ** *បានដល់ ទិដ្ឋិដែលប្រព្រឹត្តទៅ ដោយន័យជាដើមថា លោកទៀង លោកមិនទៀង លោកមានទីបំផុត ប្រព្រឹត្ត ទៅយ៉ាងនេះដោយអំណាចធ្វើចំណែកនីមួយៗជាទីតាំងប្រកាន់នូវអន្តគ្គាហិក-*

ទិដ្ឋិដែលមានវត្ថុ ១០ ។

បទថា **យា ឯវរូបា ទិដ្ឋិ** បានដល់ ទិដ្ឋិដែលមានជាតិយ៉ាងនេះ ។ បទថា **ទិដ្ឋិគតំ** បានដល់ កាលប្រព្រឹត្តទៅក្នុងទិដ្ឋិទាំងឡាយ ។ ទស្សនៈនេះឈ្មោះថា **ទិដ្ឋិគតំ** ព្រោះអត្ថថា ឈមចុះខាងក្នុងនៃទិដ្ឋិ ៦២ ។

ព្រៃស្ដុកឈានកន្លងបានដោយលំបាក គឺទិដ្ឋិ ឈ្មោះថា **ទិដ្ឋិគហនំ** ដូចព្រៃស្មៅ ព្រៃស្ដុក ព្រៃភ្នំ ។ ឈ្មោះថា **ទិដ្ឋិកន្តារំ** ដោយអត្ថថា មានភ័យចំពោះមុខ គួរវៀស ដូចកន្តារព្រោះចោរនិងកន្តារព្រោះសត្វកាច កន្តារព្រោះមិនមានទឹកនិងកន្តារព្រោះបាយរកបានដោយលំបាក ។

ឈ្មោះថា **ទិដ្ឋិវិសូកាយិកំ** ដោយអត្ថថា ចាក់ដោតនិងដោយអត្ថថា បញ្ច្រាសនូវសម្មាទិដ្ឋិ ព្រោះថា មិច្ឆាទស្សនៈកើតឡើង រមែងចាក់ដោតនិងបញ្ច្រាសនូវសម្មាទស្សនៈ ។

ឈ្មោះថា **ទិដ្ឋិវិប្ផន្ទិតំ** ព្រោះអត្ថថា អន្ទះអន្ទែងរហូតខុសប្រក្រតីដោយទិដ្ឋិ ព្រោះជួនកាលកាន់យកនូវការទៀង ជួនកាលកាន់យកនូវការដាច់សូន្យ ។ បុគ្គលមានទិដ្ឋិរមែងមិនអាចតាំងមាំក្នុងការឃើញ ជួនកាលក៏អណ្ដែតទៅតាមការទៀង ជួនកាលក៏អណ្ដែតទៅតាមការដាច់សូន្យ ។

ឈ្មោះថា **ទិដ្ឋិសញ្ញោជនំ** ព្រោះអត្ថថា ទិដ្ឋិនោះឯងឈ្មោះថាសំយោជនៈដោយអត្ថថា ចងទុក ។

ឈ្មោះថា **គាហោ** ព្រោះអត្ថថា កាន់យកអារម្មណ៍ទុកមាំ ដូចក្រពើជាដើមពាំបុរស ។ ឈ្មោះថា **បតិដ្ឋាហោ** ព្រោះអត្ថថា តាំងមាំ ពិតហើយ

*ទិដ្ឋិនេះតាំងមាំហើយ កាន់យកដោយបវត្តិភាពដែលមានកម្លាំង ។ ឈ្មោះថា* **អភិនិវេសោ** *ព្រោះអត្ថថា ប្រកាន់មាំដោយអំណាចការទៀនជាដើម ។*

*ឈ្មោះថា* **បរាមាសោ** *ព្រោះអត្ថថា ឈានកន្លងសភាវៈនៃធម៌ហើយ ស្ទាបអង្អែលទៅខាងមុខដោយអំណាចការទៀនជាដើម ។ ឈ្មោះថា* **កុម្មគ្គោ** *ព្រោះអត្ថថា ជាផ្លូវដែលបណ្ឌិតវៀរស្បៀស ព្រោះមិននាំប្រយោជន៍មក ឬជាផ្លូវនៃអបាយដែលបណ្ឌិតវៀរស្បៀស ។*

*ឈ្មោះថា* **មិច្ឆាបថោ** *ព្រោះជាផ្លូវមិនពិតប្រាកដ ដូចផ្លូវដែលមនុស្សវង្វេងទិសប្រកាន់ថា នេះជាផ្លូវរបស់ស្រុកឈ្មោះនោះ រមែងមិនធ្វើបុគ្គលនោះឲ្យដល់នូវស្រុកបានយ៉ាងណា ទិដ្ឋិដែលបុគ្គលមានទិដ្ឋិប្រកាន់ថាជាផ្លូវទៅកាន់សុគតិ ក៏មិនបញ្ជូនបុគ្គលនោះឲ្យដល់នូវសុគតិបាន ព្រោះហេតុនោះ ទើបឈ្មោះថា* **មិច្ឆាបថោ** *ព្រោះជាផ្លូវដែលមិនពិត ។*

*ឈ្មោះថា* **មិច្ឆត្តំ** *ព្រោះមានការឃើញខុសជាសភាវៈ ។ ឈ្មោះថា* **តិត្ថាយតនំ** *ព្រោះអត្ថថា ជាទីចូងនៃបុគ្គលពាលទាំងឡាយដោយវិលទៅជុំវិញក្នុងទីនោះឯង កំពង់នោះផង ព្រោះជាប្រភពកើតនៃសេចក្តីវិនាសទាំងឡាយផង ហេតុនោះ ទើបឈ្មោះថា* **តិត្ថាយតនំ** *ប្រែថា លទ្ធិតិរ្ថិយ ។ ម្យ៉ាងទៀត ឈ្មោះថា* **តិត្ថាយតនំ** *ដោយអត្ថថា ជាប្រភពកើតដោយអត្ថថា ជាប្រទេសដែលកើតនិងជាទីនៅអាស្រ័យរបស់ពួកតិរ្ថិយទាំងឡាយ ។ ការប្រកាន់ដែលជាការស្វែងរកខុស ឬការប្រកាន់ដោយភាពស្វែងរកខុស ដូច្នោះទើបឈ្មោះថា* **វិបរិយេសគ្គាហោ** *។ ការប្រកាន់ខុសសភាវៈ ឈ្មោះថា* **វិបរីតគ្គាហោ** *។ ព្រោះ*

ការប្រកាន់ដែលផ្លាស់ប្តូរ ប្រព្រឹត្តទៅដោយន័យជាដើមថា ប្រកាន់ក្នុងវត្ថុដែលមិនទៀងថាទៀង ឈ្មោះថា **វិបល្លាសគ្គាហោ** ។

ការមិនប្រកាន់ដោយឧបាយ ឈ្មោះថា **មិច្ឆាគាហោ** ។ ការប្រកាន់ក្នុងរឿងដែលមិនពិត មិនមែនសភាវៈ ថាពិត ថាមែនជាសភាវៈ ឈ្មោះថា **អយាថាវកស្មឹ យាថាវកន្តិគាហោ** ។

បទថា **យាវតា** បានដល់ មានប្រមាណប៉ុនណា ។ បទថា **ទ្វាសដ្ឋិទិដ្ឋិគតានិ** បានដល់ ទិដ្ឋិ ៦២ ដែលមកក្នុងព្រហ្មជាលសូត្រ ។

បទថា **អច្ចេនសង្ខិនោបិ ជន្តុន្តិ** សេចក្តីថា ជាអ្នកមានការតក់ស្លុតកើតឡើងថា មនុស្សទាំងឡាយនឹងដណ្តើម នឹងគំរាមយកដោយកម្លាំងបាយរមែងញាប់ញ័រ ។

បទថា **អច្ចិជ្ជន្តេបិ** បានដល់ ក្នុងកាលដែលគេកំពុងដណ្តើមដោយន័យដែលពោលហើយខ្លះ ។

បទថា **អច្ចិន្នេបិ** បានដល់ ក្នុងកាលដែលគេដណ្តើមយកហើយ ដោយន័យដែលពោលហើយខ្លះ ។

បទថា **វិបរិណាមសង្ខិនោបិ** បានដល់ ជាអ្នកមានការរង្កៀសដោយការផ្លាស់ប្តូរទៅជាដទៃខ្លះ ។

បទថា **វិបរិណាមន្តេបិ** បានដល់ ក្នុងកាលដែលប្រែប្រួលទៅខ្លះ ។ បទថា **វិបរិណតេបិ** បានដល់ កាលវត្ថុនោះប្រែប្រួលទៅហើយខ្លះ ។ បទថា **ជន្តុន្តិ** បានដល់ រមែងញាប់ញ័រ ។ បទថា **សម្ពន្តន្តិ** បានដល់ រមែងញាប់

ញ័រដោយអាការៈទាំងពួង ។ បទថា **វិប្ផន្ទន្តិ** បានដល់ រមែងញាប់ញ័រដោយអាការៈមានបែបផ្សេងៗ ។ បទថា **វេធន្តិ** បានដល់ ឃើញភ័យហើយញាប់ញ័រ ។ បទថា **បវេធន្តិ** បានដល់ ញាប់ញ័រជាពិសេស ព្រោះភ័យដែលគួរតក់ស្លុត ។

បទថា **សម្បវេធន្តិ** បានដល់ ញាប់ញ័រដោយអាការៈទាំងពួង ព្រោះភ័យដែលធ្វើឲ្យព្រឺរោមព្រឺស្បែក ។

បទថា **ផន្ទមានេ** ជាទុតិយាវិភត្តិពហុវចនៈ ។

[ ៥៧ ] បទថា **អប្បោទកេ** បានដល់ មានទឹកតិច ។ បទថា **បរិត្តោទកេ** បានដល់ មានទឹកបន្តិចបន្តួច ។ បទថា **ឧទកបរិយាទានេ** បានដល់ មានទឹកអស់ទៅ ។ បទថា **ពលាកាហិ វា** បានដល់ ហ្វូងបក្សីដ៏សេសអំពីដែលពោលហើយ ។

បទថា **បរិចាតិយមានា** បានដល់ បៀតបៀនប៉ះខ្ទប់ ។ បទថា **ឧក្ខិបិយមានា** បានដល់ នាំមកអំពីរវាងភក់ ឬលេប ។ បទថា **ខជ្ជមានា** បានដល់ ទំពាស៊ី ។ ត្រីទាំងឡាយរមែងក្តៅក្រហាយព្រោះហ្វូងក្អែក រមែងសោប់សោលព្រោះហ្វូងខ្វែង រមែងស្លុតរន្ធត់ព្រោះហ្វូងកុក រមែងញាប់ញ័រដោយអំណាចនៃការស្លាប់ ក្នុងពេលដែលត្រូវពាំដោយចំពុះ រមែងបម្រះនទៀលក្នុងវេលាត្រូវចឹក រមែងសោប់សោលក្នុងពេលជិតស្លាប់ ។

[ ៥៨ ] បទថា **បស្សិត្វា** បានដល់ ឃើញទោសមិនមែនគុណ ។ បទថា **តុលយិត្វា** បានដល់ ប្រៀបធៀបគុណនិងទោស ។ បទថា **តិរយិត្វា**

បានដល់ គិតដោយពិស្តារនូវគុណនិងទោស ។ បទថា **វិភាវយិត្វា** បានដល់ លែង គឺវៀរវត្ថុដែលជាចំណែកថោកថយ ។ បទថា **វិភូតំ កត្វា** បានដល់ ឲ្យដល់នូវការសម្រេចហើយបែកចេញមកបាន ។

ម្យ៉ាងទៀត ឃើញដោយការដោះនូវទោសដែលជេរជាស ហើយធ្វើនូវការចែកជាច្រើនប្រៀបធៀបដោយការដោះនូវទោសដែលកើតព្រោះមិនមានការកំណត់ហើយធ្វើប្រមាណទុក ។ ពិចារណាដោយការដោះវត្ថុដែលជាទោស ហើយចែកជាចំណែកៗ ត្រួតត្រាដោយការដោះទោស ព្រោះការវង្វេងហើយវាយតម្លៃ ធ្វើឲ្យជាក់ច្បាស់ដោយការដោះនូវទោស ដែលជាដុំហើយចែកជាចំណែកៗតាមប្រក្រតី ។

បទថា **បហាយ** បានដល់ លះបង់ ។ បទថា **បដិនិស្សជ្ជិត្វា** បានដល់ រលាស់ចោល ។ បទថា **អមមាយន្តោ** បានដល់ មិនធ្វើសេចក្តីអាល័យដោយតណ្ហានិងទិដ្ឋិ ។ បទថា **អគ្គណ្ហន្តោ** បានដល់ មិនកាន់យកដោយបញ្ញាក្នុងចំណែកខាងដើមនៃទិដ្ឋិ ។ បទថា **អបរាមសន្តោ** បានដល់ មិនធ្វើនូវការឈមចុះដោយវិតក្កៈ ។ បទថា **អនភិនិវិសន្តោ** បានដល់ មិនចូលទៅដោយអំណាចទិដ្ឋិដែលឈានចុះពិតប្រាកដ ។

[ ៥៩ ] បទថា **អកុព្វមានោ** បានដល់ មិនធ្វើដោយអំណាចតណ្ហាជាគ្រឿងប្រកាន់ ។ បទថា **អជនយមានោ** បានដល់ មិនឲ្យកើតដោយអំណាចតណ្ហាដែលឲ្យកើតក្នុងភពថ្មី ។ បទថា **អសញ្ជនយមានោ** បានដល់ មិនឲ្យកើតព្រមជាពិសេស ។ បទថា **អនិព្វត្តយមានោ** បានដល់ មិនឲ្យកើតឡើង

ដោយអំណាចតណ្ហា គឺការប្រាថ្នា ។ បទថា **អនភិនិព្វត្តយមានោ** បានដល់ មិនឲ្យកើតចំពោះដោយអាការៈទាំងពួង ។ ម្យ៉ាងទៀត បទនេះលោកពង្រីកដោយឧបសគ្គ ។

[ ៦០ ] ព្រះដ៏មានព្រះភាគទ្រង់សម្តែងនូវការត្រេកអរដោយគាថាដំបូង និងទ្រង់សម្តែងទោសដោយគាថា ៤ បន្ទាប់អំពីនោះ ក្នុងរឿងនេះ យ៉ាងនេះហើយ ដើម្បីទ្រង់សម្តែងការលោះចេញព្រមដោយឧបាយនិងអានិសង្សនៃការលោះចេញ ឬកាលទ្រង់សម្តែងទោសនៃភាពអាក្រក់និងការសៅហ្មងរបស់កាមទាំងឡាយដោយគាថាទាំងអស់នេះ ឥឡូវនេះ ដើម្បីសម្តែងអានិសង្សក្នុងនេក្ខម្មៈ ទើបពោលគាថា ២ ថា **ឧភោសុ អន្តេសុ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **ឧភោសុ អន្តេសុ** បានដល់ ក្នុងទីកំណត់ទុកជាគូៗ មានផស្សៈនិងផស្សសមុទយៈជាដើម ។ បទថា **វិនេយ្យ ឆន្ទំ** បានដល់ កម្ចាត់នូវឆន្ទរាគៈ ។ បទថា **ផស្សំ បរិញ្ញាយ** បានដល់ កំណត់ដឹងដោយបរិញ្ញា ៣ នូវនាមរូបទាំងមូលគឺផស្សៈ មានចក្ខុសម្ផស្សជាដើម ឬអរូបធម៌ទាំងមូលដែលសម្បយុត្តដោយផស្សៈនោះ ដោយទំនងនៃផស្សៈនិងរូបធម៌ដោយអំណាចជាវត្ថុ ទ្វារនិងអារម្មណ៍នៃអរូបធម៌ទាំងនោះ ។

បទថា **អននុគិទ្ធោ** បានដល់ មិនជាប់ក្នុងធម៌ទាំងពួងមានរូបជាដើម ។ បទថា **យទត្តគរហី តទកុព្វមានោ** សេចក្តីថា មិនធ្វើកម្មដែលខ្លួនតិះដៀលខ្លួនបាន ។ បទថា **ន លិម្បតី ទិដ្ឋសុតេសុ ធីរោ** សេចក្តីថា ធីរជនបែបនេះដែលដល់ព្រមដោយបញ្ញា រមែងមិនជាប់ដោយការជាប់ សូម្បីតែមួយនៃការ

ជាប់ទាំងពីរក្នុងធម៌ទាំងឡាយ ទាំងដែលឃើញហើយនិងស្តាប់ហើយ គឺមិនជាប់ក្នុងធម៌ណាមួយដូចអាកាស រមែងជាបុគ្គលដល់នូវការផ្លូវផង់បំផុត ។

[ ៦១ ] បទថា **ផស្សោ ឯកោ អន្តោ** បានដល់ ផស្សៈជាកំណត់ ១ ។ ឈ្មោះថា **ផស្សោ** ព្រោះអត្ថថា ពាល់ត្រូវ ផស្សៈនេះមានការពាល់ត្រូវជាលក្ខណៈ មានការប៉ះទង្គិចជាកិច្ច មានការប្រជុំជាបច្ចុប្បដ្ឋាន មានអារម្មណ៍ដែលមកដល់គន្លងជាបទដ្ឋាន ។

ផស្សៈនេះ សូម្បីជាអរូបធម៌ ក៏ប្រព្រឹត្តទៅដោយអាការៈពាល់ត្រូវក្នុងអារម្មណ៍នោះឯង ដូច្នេះទើបឈ្មោះថា មានការពាល់ត្រូវជាលក្ខណៈ សូម្បីមិនជាប់ជាឯកទេស ក៏ប៉ះទង្គិច ដូចរូបប៉ះនឹងចក្ខុ សំឡេងប៉ះត្រចៀក ចិត្តប៉ះអារម្មណ៍ដូច្នោះ ទើបឈ្មោះថា មានការប៉ះទង្គិចជាកិច្ច ។ ម្យ៉ាងទៀត គប្បីជ្រាបថា មានការប៉ះទង្គិចជាកិច្ចដោយរស មានអត្ថថា ដល់ព្រម ព្រោះកើតឡើងអំពីការប៉ះទង្គិចគ្នានៃវត្ថុនិងអារម្មណ៍ សមដូចពាក្យដែលលោកពោលទុកក្នុងអដ្ឋកថាថា ផស្សៈដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ដែលឈ្មោះថា មិនមានការពាល់ត្រូវជាលក្ខណៈនោះរមែងមិនមាន តែផស្សៈ មានការប៉ះទង្គិចជាកិច្ច រមែងប្រព្រឹត្តទៅក្នុងទ្វារ ៥ នោះឯង ដ្បិតថា ពាក្យថា មានការពាល់ត្រូវជាលក្ខណៈក្តី មានការប៉ះទង្គិចជាកិច្ចក្តី ជាឈ្មោះរបស់ផស្សៈដែលប្រព្រឹត្តទៅក្នុងទ្វារ ៥ ។ ពាក្យថា មានការពាល់ត្រូវជាលក្ខណៈ ជាឈ្មោះរបស់ផស្សៈដែលប្រព្រឹត្តទៅតាមមនោទ្វារ ពាក្យថា មានការប៉ះទង្គិចជាកិច្ច មិនមែនឈ្មោះរបស់ផស្សៈដែលប្រព្រឹត្តទៅតាមមនោទ្វារ កាលលោកពោលពាក្យនេះហើយ បាននាំព្រះ

សូត្រនេះមកថា

មហាបពិត្រ ដូចពពែ ២ ជល់គ្នា គប្បីឃើញចក្ខុដូចពពែទី ១ គប្បីឃើញរូបដូចពពែទី ២ គប្បីឃើញផស្សៈដូចការជល់គ្នារបស់ពពែ ២ នោះយ៉ាងណា ផស្សៈមានការពាល់ត្រូវជាលក្ខណៈនិងមានការប៉ះទង្គិចជាកិច្ច ក៏យ៉ាងនោះ មហាបពិត្រ ដូចគន្ទឹះនឹមទង្គល ២ ដែលប៉ះទង្គិចគ្នា គប្បីឮសំឡេងសូម្បីការទះដៃទាំងពីរ ( ក៏ឮសំឡេងដូចគ្នា ) គប្បីឃើញចក្ខុ ដូចបាតដៃទី ១ គប្បីឃើញរូបដូចបាតដៃទី ២ គប្បីឃើញផស្សៈដូចការប៉ះគ្នារបស់បាតដៃទាំងពីរនោះយ៉ាងណា ផស្សៈមានការពាល់ត្រូវជាលក្ខណៈ និងមានការប៉ះទង្គិចជាកិច្ចក៏យ៉ាងនោះ ។ គប្បីជ្រាបសេចក្តីពិស្តារដូចតទៅនេះ ឧបមាដូចចក្ខុវិញ្ញាណជាដើម លោកពោលដោយឈ្មោះថា ចក្ខុ ក្នុងសេចក្តីថា ឃើញរូបដោយចក្ខុជាដើមយ៉ាងណា ចក្ខុជាដើមនោះ ក្នុងទីនេះក៏គប្បីជ្រាបថា លោកពោលដោយឈ្មោះថា ចក្ខុ ជាដើមក៏យ៉ាងនោះ ។

ព្រោះហេតុនោះ ក្នុងសេចក្តីថា គប្បីឃើញចក្ខុដូច ( ពពែ ) ជាដើម គប្បីជ្រាបអត្ថដោយន័យថា គប្បីឃើញចក្ខុវិញ្ញាណដូច... កាលបើយ៉ាងនោះ សូម្បីក្នុងព្រះសូត្រនេះ ក៏រមែងសម្រេចអត្ថថា មានការប៉ះទង្គិចជាកិច្ច ដោយកិច្ចដែលមានកិច្ចជាអត្ថនោះឯង ព្រោះការប៉ះទង្គិចនៃចិត្តនិងអារម្មណ៍ តែមានការប្រជុំគ្នាជាបច្ចុប្បដ្ឋាន ព្រោះប្រកាសការប៉ះទង្គិចគ្នាដោយការប្រជុំគ្នានៃធម៌ទាំង ៣ ដោយអំណាចនៃហេតុរបស់ខ្លួន ព្រោះផស្សៈនេះលោកប្រកាសក្នុងទីនោះដោយអំណាចនៃការប្រកបហេតុយ៉ាងនេះថា ជាការប្រព្រឹត្តទៅរួមគ្នានៃធម៌ ៣

យ៉ាងជាផស្សៈ ហេតុនោះ ទើបសុត្តបទនេះមានអត្ថដូច្នេះថា ឈ្មោះថា ផស្សៈ ព្រោះការប្រព្រឹត្តទៅរួមគ្នានៃធម៌ ៣ យ៉ាង ។ ផស្សៈមិនមែនត្រឹមតែប្រព្រឹត្តទៅរួមគ្នាប៉ុណ្ណោះ តែរមែងប្រាកដដោយអាការៈនោះឯង ព្រោះប្រកាសឲ្យដឹងយ៉ាងនេះ ហេតុនោះ ទើបលោកពោលថា មានការប្រជុំគ្នាជាបច្ចុប្បដ្ឋាន ម្យ៉ាងទៀត ផស្សៈ ឈ្មោះថា មានវេទនាជាគ្រឿងប្រាកដ ដោយការប្រាកដដែលមានផលជាអត្ថ អធិប្បាយថា ដ្បិតថា ផស្សៈនេះញុំាងវេទនាឲ្យប្រាកដ គឺឲ្យកើតឡើង ។ ម្យ៉ាងទៀត គប្បីជ្រាបថា ផស្សៈនេះដែលបច្ច័យឲ្យកើតឡើង សូម្បីមានវត្ថុដទៃពោលគឺវត្ថុនិងអារម្មណ៍ជាបច្ច័យ រមែងធ្វើចិត្តប៉ុណ្ណោះដែលជាទីអាស្រ័យរបស់ខ្លួន ព្រោះខ្លួនអាស្រ័យចិត្តឲ្យកើតវេទនាឡើង មិនមែនធ្វើវេទនាឲ្យកើតក្នុងវត្ថុ ឬក្នុងអារម្មណ៍សូម្បីជាបច្ច័យរបស់ខ្លួន ដូចឧស្មាដែលអាស្រ័យធាតុពោល គឺជុំល័ក្ត សូម្បីមានកម្តៅខាងក្រៅជាបច្ច័យ ក៏រមែងធ្វើនូវការទន់ក្នុងជុំល័ក្តដែលជាទីអាស្រ័យរបស់ខ្លួន មិនមែនធ្វើការទន់ក្នុងកម្តៅពោលគឺរងើកភ្លើងដែលប្រាសចាកអណ្តាតខាងក្រៅ សូម្បីជាបច្ច័យរបស់ខ្លួន ។

ម្យ៉ាងទៀត ផស្សៈនេះលោកពោលថា មានអារម្មណ៍ដែលមកដល់គន្លងជាបទដ្ឋាន ព្រោះកើតឡើងដោយមិនមានការរារាំងក្នុងអារម្មណ៍ដែលត្រូវចោមរោមដោយការប្រមូលមក ដែលសមគួរនិងដោយឥន្ទ្រិយ ផស្សៈតាំងឡើង គឺកើតឡើងអំពីបច្ច័យណា បច្ច័យនោះលោកហៅថា **ផស្សសមុទយោ** ។ សមដូចព្រះតម្រាស់ថា ព្រោះសឡាយតនៈជាបច្ច័យ ទើបផស្សៈកើតឡើង ដូច្នេះ ។

គប្បីជ្រាបថា អតីតទុកៈ លោកពោលដោយអំណាចនៃកាល ។ វេទនា

ទុកៈ លោកពោលដោយអំណាចនៃសុខនិងទុក្ខ ព្រោះធ្វើឧបេក្ខាវេទនាឲ្យជាសុខតែម្យ៉ាង ព្រោះលោកពោលទុកថា ឧបេក្ខាលោកពោលថា សុខនោះឯង ព្រោះស្ងប់ ។ នាមរូបទុកៈ លោកពោលដោយអំណាចនៃរូបធម៌និងអរូបធម៌ ។

អាយតនទុកៈ លោកពោលដោយអំណាចនៃការប្រព្រឹត្តទៅក្នុងសង្សារវដ្តៈ ។ សក្កាយទុកៈ លោកពោលដោយអំណាចនៃបញ្ចក្ខន្ធ ។

បណ្តាបទទាំងនោះ ឈ្មោះថា **សុខា** ព្រោះអត្ថថា ប្រព្រឹត្តទៅសប្បាយ ឈ្មោះថា **វេទនា** ព្រោះអត្ថថា សោយអារម្មណ៍ ឈ្មោះថា **ទុក្ខា** ព្រោះអត្ថថា ប្រព្រឹត្តទៅលំបាក ។ នាមមានការបង្អោនទៅជាលក្ខណៈ រូបមានការបែកធ្លាយជាលក្ខណៈ ។ អាយតនៈខាងក្នុង ៦ មានចក្ខាយតនៈជាដើម អាយតនៈខាងក្រៅ ៦ មានរូបាយតនៈជាដើម បញ្ចក្ខន្ធមានរូបក្ខន្ធជាដើមជាសក្កាយៈដោយអត្ថថា មាន ។ អវិជ្ជា កម្ម តណ្ហា អាហារ ផស្សៈនិងនាមរូបជាសក្កាយសមុទយៈ ។

[ ៦២ ] បទថា **ចក្ខុសម្ផស្សោ** សេចក្តីថា ឈ្មោះថា ចក្ខុ ព្រោះអត្ថថា ប្រាប់ឲ្យស្គាល់របស់ណាមួយ អធិប្បាយថា ត្រេកអរ គឺធ្វើឲ្យជាក់ច្បាស់នូវរូប ។ ផស្សៈដែលប្រព្រឹត្តទៅតាមផ្លូវភ្នែក ឈ្មោះថា **ចក្ខុសម្ផស្សោ** ។

ចក្ខុសម្ផស្សៈនោះ ជាបច្ច័យ ៨ យ៉ាងដល់វេទនាដែលសម្បយុត្តជាមួយខ្លួន គឺសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ អាហារប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ។

ឈ្មោះថា **សោត** ព្រោះអត្ថថា ស្តាប់ ។ សោតៈនោះ ឲ្យសម្រេចភាពជាវត្ថុនិងទ្វារ តាមគួរដល់សោតវិញ្ញាណជាដើម តាំងនៅក្នុងប្រទេសមានសណ្ឋានដូចចោះដោយម្រាមដៃ មានរោមពណ៌ក្រហមស្តើង ដុះគ្របដណ្តប់ខាងក្នុងប្រហោងសសម្ភារសោតៈ ។

សម្ផស្សៈដែលប្រព្រឹត្តទៅតាមសោតៈ ឈ្មោះថា **សោតសម្ផស្សោ** ។ សូម្បីក្នុងឃានសម្ផស្សៈជាដើមក៏ន័យនេះឯង ។

ឈ្មោះថា **ឃាន** ព្រោះអត្ថថា ហិត ឃានៈនោះឲ្យសម្រេចនូវភាពជាវត្ថុនិងទ្វារតាមគួរដល់ឃានវិញ្ញាណជាដើម តាំងនៅក្នុងប្រទេសមានសណ្ឋានដូចជើងពពែខាងក្នុងប្រហោងសសម្ភារឃានៈ ។

ឈ្មោះថា **ជិវ្ហា** ព្រោះអត្ថថា ហៅនូវជីវិត ម្យ៉ាងទៀត ឈ្មោះថា **ជិវ្ហា** ដោយអត្ថថា លិឍក្ខរសេ ។ ជិវ្ហានោះឲ្យសម្រេចភាពជាវត្ថុនិងទ្វារតាមគួរដល់ជិវ្ហាវិញ្ញាណជាដើម តាំងនៅក្នុងប្រទេសមានសណ្ឋានដូចគ្នានឹងត្របកផ្កាឧប្បល ដែលកាត់ត្រង់កណ្តាលផ្នែកខាងលើ វៀរខាងចុងគល់និងចំហៀងនៃសសម្ភារជិវ្ហា ។

ឈ្មោះថា **កាយ** ព្រោះអត្ថថា ជា**ទីកើតឡើង**នៃធម៌ដែលប្រព្រឹត្តទៅដោយអាសវៈជាទីគួររង្កៀសទាំងឡាយ ។

ពាក្យថា **ទីកើតឡើង** សេចក្តីថា ជាប្រទេសដែលកើតឡើង ។ កាយបសាទឲ្យសម្រេចភាពជាវត្ថុនិងទ្វារតាមគួរដល់កាយវិញ្ញាណជាដើម ដោយច្រើនតាំងនៅក្នុងកាយនោះ អស់កាលដែលការប្រព្រឹត្តទៅនៃសង្ខារដែលមាន

*ចិត្តគ្រប់គ្រងមាននៅក្នុងកាយនេះ ។ ឈ្មោះថា* **មនោ** *ព្រោះអត្ថថា ដឹង អធិប្បាយថា ដឹងច្បាស់ ។*

*បទថា* **មនោ** *បានដល់ កវង្គចិត្ត ដែលប្រព្រឹត្តទៅដោយអាវជ្ជនៈ ។ សម្ផស្សៈដែលប្រព្រឹត្តទៅក្នុងមនោ ឈ្មោះថា* **មនោសម្ផស្សោ** *។*

*ដើម្បីសម្តែងថា ផស្សៈទាំង ៦ យ៉ាង រាប់ជាពីរយ៉ាងប៉ុណ្ណោះ ហេតុនោះ ទើបព្រះថេរៈពោលថា* **អធិវចនសម្ផស្សោ បដិឃសម្ផស្សោ** *ដូច្នេះ ។*

*អធិវចនសម្ផស្ស ប្រព្រឹត្តទៅតាមមនោទ្វារ បដិឃសម្ផស្សប្រព្រឹត្តទៅ តាមបញ្ចទ្វារ ព្រោះកើតឡើងដោយការប៉ះខ្ទប់វត្ថុនិងអារម្មណ៍ជាដើម ។*

*សម្ផស្សៈជាអារម្មណ៍នៃសុខវេទនា ឈ្មោះថា* **សុខវេទនីយោ** *។ សម្ផស្សៈ ជាអារម្មណ៍នៃទុក្ខវេទនា ឈ្មោះថា* **ទុក្ខវេទនីយោ** *។ សម្ផស្សៈជាអារម្មណ៍ នៃអទុក្ខមសុខវេទនា ឈ្មោះថា* **អទុក្ខមសុខវេទនីយោ** *។*

*បណ្តាបទទាំងនោះ ឈ្មោះថា* **សុខ** *ព្រោះអត្ថថា ប្រព្រឹត្តទៅសប្បាយ អធិប្បាយថា កើតឡើងដល់បុគ្គលណា ក៏ធ្វើឲ្យបុគ្គលនោះមានសេចក្តីសុខ ។ ម្យ៉ាងទៀត ឈ្មោះថា* **សុខ** *ព្រោះអត្ថថា ជីក ឬទំពាស៊ីនូវសេចក្តីលំបាកកាយ និងលំបាកចិត្តបានដោយល្អ ។*

*ឈ្មោះថា* **ទុក្ខ** *ព្រោះអត្ថថា ប្រព្រឹត្តទៅលំបាក អធិប្បាយថា កើតឡើង ដល់បុគ្គលណា ក៏ធ្វើបុគ្គលនោះឲ្យមានសេចក្តីទុក្ខ ។*

*ឈ្មោះថា* **អទុក្ខមសុខ** *ព្រោះអត្ថថា ទុក្ខក៏មិនមែន សុខក៏មិនមែន* **ម** *អក្ខរៈ លោកពោលដោយអំណាចសន្ធិ ។ បទថា* **កុសលោ** *ជាដើម លោក*

ពោលដោយអំណាចនៃជាតិ ។ បណ្តាបទទាំងនោះ បទថា **កុសលោ** បាន ដល់ ដែលសម្បយុត្តដោយកុសលចិត្ត ២១ ដួង ។

បទថា **អកុសលោ** បានដល់ ដែលសម្បយុត្តដោយអកុសលចិត្ត ១២ ដួង ។ បទថា **អព្យាកតោ** បានដល់ ដែលសម្បយុត្តដោយអព្យាកតចិត្ត ពោលគឺវិបាកចិត្តនិងកិរិយាចិត្តដ៏សេស ។

ព្រះសារីបុត្តត្ថេរ កាលចង់សម្តែងដោយអំណាចនៃប្រភេទរបស់ភពថ្មី ទើបពោលថា **កាមាវចរោ** ជាដើម ។ ផស្សៈដែលសម្បយុត្តដោយកាមាវចរ ចិត្ត ៥៤ ដួង ឈ្មោះថា **កាមាវចរោ** ។ ឈ្មោះថា **រូបាវចរោ** ព្រោះអត្ថថា លះនូវកាមភព អន្ទោលទៅក្នុងរូបភព ។ ផស្សៈនេះសម្បយុត្តដោយរូបាវចរ ចិត្ត ១៥ ដួង ដោយអំណាចនៃកុសលចិត្តនិងអព្យាកតចិត្ត ។

ឈ្មោះថា **អរូបាវចរោ** ព្រោះអត្ថថា លះនូវកាមភពនិងរូបភពហើយ ត្រាច់ទៅក្នុងអរូបភព ។ ផស្សៈនេះសម្បយុត្តដោយអរូបាវចរចិត្ត ១២ ដោយ អំណាចនៃកុសលចិត្តនិងអព្យាកតចិត្ត ។

ឥឡូវនេះ ព្រះថេរៈកាលសម្តែងដោយអំណាចនៃការប្រកាន់មាំ ទើប ពោលថា **សុញ្ញតោ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **សុញ្ញតោ** ជាដើម សេចក្តីថា លោកហៅថា **សុញ្ញតោ** ព្រោះទទេចាករាគៈ ទោសៈ មោហៈ ហៅថា **អនិមិត្តោ** ព្រោះ មិនមានគ្រឿងសម្គាល់នៃរាគៈ ទោសៈ មោហៈ ហៅថា **អប្បណិហិតោ** ព្រោះ មិនមានទីតាំងនៃរាគៈ ទោសៈ មោហៈ ។

*ឥឡូវនេះ ព្រះថេរៈកាលសម្តែងដោយអំណាចផស្សៈដែលទាក់ទងនិង មិនទាក់ទងក្នុងវដ្តៈ ទើបពោលថា* **លោកិយោ** *ជាដើម ។*

*វដ្តៈ លោកហៅថា* **លោក** *ដោយអត្ថថា បែកធ្លាយ វិនាស ផស្សៈឈ្មោះ ថា* **លោកិយ** *ព្រោះអត្ថថា ប្រកប ( សត្វ ) ទុកក្នុងលោកដោយភាវៈដែល ទាក់ទងក្នុងលោកនេះ ឈ្មោះថា* **ឧត្តរ** *ព្រោះអត្ថថា ឆ្លងឡើងហើយ ឈ្មោះ ថា លោកុត្តរៈ ព្រោះអត្ថថា ឆ្លងឡើងចាកលោកដោយភាវៈដែលមិនទាក់ទង ក្នុងលោក ។*

*បទថា* **ផុសនា** *បានដល់ អាការៈដែលពាល់ត្រូវ ។ បទថា* **សម្ផុសនា សម្ផុសិតត្តំ** *លោកពង្រីកដោយឧបសគ្គ ។ បទថា* **ឯវំ ញាតំ កត្វា** *បាន ដល់ ធ្វើឲ្យប្រាកដយ៉ាងនេះ កាលដឹងរមែងពិចារណា គឺរមែងឃើញ រមែង គិតដោយអាការៈដែលគប្បីប្រព្រឹត្តទៅខាងមុខ រមែងពិចារណាដោយភាពជា អនិច្ចំ ព្រោះមានទីបំផុតគឺការមិនទៀង និងព្រោះមានខាងដើមនិងទីបំផុត ។*

*ឈ្មោះថា* **ទុក្ខតោ** *ព្រោះមានការកើតឡើងនិងការវិនាសទៅគ្របសង្កត់ និងព្រោះជាទីតាំងនៃទុក្ខ ។ ឈ្មោះថា* **រោគតោ** *ព្រោះត្រូវឲ្យប្រព្រឹត្តទៅ ដោយបច្ច័យនិងព្រោះជាមូលនៃរោគ ។ ឈ្មោះថា* **គណ្ឌតោ** *ព្រោះប្រកប ដោយការចាក់ដោត ព្រោះជាទុក្ខ ព្រោះមានការហូរចេញនូវរបស់មិនស្អាតគឺ កិលេសនិងព្រោះហើមដោយជុំវិញ បែកធ្លាយទៅដោយការកើតឡើង ការ វិនាសទៅព្រម និងការបែកធ្លាយ ។ ឈ្មោះថា* **សល្លតោ** *ព្រោះឲ្យកើតនូវការ បៀតបៀន ព្រោះចាក់ទម្លុះខាងក្នុងនិងព្រោះគប្បីនាំចេញបានលំបាក ។ ឈ្មោះ*

ថា **អឃតោ** ព្រោះជាការៈដែលគួរតិះដៀល ព្រោះមិននាំមកនូវសេចក្តីចម្រើន និងព្រោះជាទីតាំងនៃសេចក្តីលំបាក ។ ឈ្មោះថា **អាពាធតោ** ព្រោះមិនឲ្យកើតសេរីភាពនិងព្រោះជាបទដ្ឋាននៃអាពាធ ។ ឈ្មោះថា **បរតោ** ព្រោះមិនមានអំណាចនិងព្រោះចាត់ចែងមិនបាន ។ ឈ្មោះថា **បលោកតោ** ព្រោះទ្រុឌទ្រោមដោយព្យាធិ ជរានិងមរណៈ ។ ឈ្មោះថា **ឦតិតោ** ព្រោះនាំមកនូវសេចក្តីវិនាសមិនមែនតិច ។

ឈ្មោះថា **ឧបទ្ទវតោ** ព្រោះនាំមកនូវសេចក្តីវិនាសច្រើនយ៉ាងដែលមិនមានអ្នកណាដឹងបាន និងព្រោះជាទីតាំងនៃអន្តរាយទាំងពួង ។

ឈ្មោះថា **ភយតោ** ព្រោះជាប្រភពកើត ( អណ្តូង ) នៃភ័យទាំងពួង និងព្រោះជាបដិបក្ខចំពោះការធូរស្បើយនៃចិត្តយ៉ាងក្រៃលែង ពោលគឺការស្ងប់ទុក្ខ ។

ឈ្មោះថា **ឧបសគ្គតោ** ព្រោះពាក់ព័ន្ធដោយការវិនាសមិនមែនតិច ព្រោះចូលទៅតាំងទុកនូវទោសនិងព្រោះមិនគួរ ដល់ការអត់ធន់ដូចឧបសគ្គ ។

ឈ្មោះថា **ចលតោ** ព្រោះញាប់ញ័រដោយព្យាធិ ជរានិងមរណៈនិងដោយលោកធម៌មានលាភជាដើម ។

ឈ្មោះថា **បភង្គុតោ** ព្រោះចូលដល់នូវការបែកធ្លាយជាប្រក្រតី ដោយសេចក្តីព្យាយាមតាមសភាវៈ ។

ឈ្មោះថា **អធុវតោ** ព្រោះធ្លាក់ទៅបានមិនកំណត់កាលទាំងពួង និងព្រោះមិនមានការឋិតថេរ ។

ឈ្មោះថា **អតាណាតោ** ព្រោះមិនមានការជ្រកកោននិងព្រោះមិនបាននូវការផុតភ័យ ។

ឈ្មោះថា **អលេណាតោ** ព្រោះជារបស់មិនគួរនៃបនិត្យនិងព្រោះមិនធ្វើកិច្ចពួនសម្ងំ សូម្បីរបស់បុគ្គលដែលនៃបនិត្យ ។

ឈ្មោះថា **អសរណាតោ** ព្រោះមិនមានភាពជាអ្នកធ្វើទីពឹងចាកភ័យដល់អ្នកអាស្រ័យទាំងឡាយ ។

ឈ្មោះថា **រិត្តតោ** ព្រោះទទេចាកអត្តភាពដែលឋិតថេរ ស្អាត ជាសុខតាមដែលកំណត់ទុក ។

ឈ្មោះថា **តុច្ឆតោ** ព្រោះជារបស់ទទេនោះឯង ឬព្រោះជារបស់តិចតួចមែនពិត របស់តិចតួចក្នុងលោក លោកហៅថារបស់ទទេ ។

ឈ្មោះថា **សុញ្ញតោ** ព្រោះវៀរចាកម្ចាស់ដែលនៅអាស្រ័យ អ្នកប្រាជ្ញ អ្នកធ្វើ និងអ្នកអធិដ្ឋាន ។

ឈ្មោះថា **អនត្តតោ** ព្រោះភាពដែលខ្លួនឯងមិនមែនម្ចាស់ជាដើម ។

ឈ្មោះថា **អាទីនវតោ** ព្រោះមានទុក្ខប្រព្រឹត្តទៅនិងព្រោះភាពជាទោសរបស់ទុក្ខ ម្យ៉ាងទៀត ឈ្មោះថា **អាទីនវតោ** ព្រោះអត្ថថា បន្សាត់ទៅ គឺទៅប្រព្រឹត្តទៅកាន់ការបែកបាក់ ពាក្យនេះជាឈ្មោះរបស់បុគ្គលកំព្រា ។ សូម្បីខន្ធទាំងឡាយ ក៏ឈ្មោះថា កំព្រាដូចគ្នាដោយភាពជាទោស ព្រោះដូចគ្នានឹងទោស ។

ឈ្មោះថា **វិបរិណាមធម្មតោ** ព្រោះមានប្រក្រតីប្រែប្រួល ២ យ៉ាង គឺ

ព្រោះជរានិងមរណៈ ។

ឈ្មោះថា **អាសារកតោ** ព្រោះទុព្វលភាពនិងព្រោះកាច់បំបាក់បានងាយដូចក្រមរឈើ ។

ឈ្មោះថា **អឃមូលតោ** ព្រោះជាហេតុនៃសេចក្ដីលំបាក ។

ឈ្មោះថា **វធកតោ** ព្រោះសម្លាប់នូវការស្និទ្ធស្នាល ដូចសត្រូវដែលនៅចំពោះមុខធ្វើជាមិត្ត ។

ឈ្មោះថា **វិភវតោ** ព្រោះប្រាសចាកសេចក្ដីចម្រើននិងព្រោះមានសេចក្ដីវិនាស ។

ឈ្មោះថា **សាសវតោ** ព្រោះមានអាសវៈជាបទដ្ឋាន ។

ឈ្មោះថា **សង្ខតតោ** ព្រោះជារបស់ដែលហេតុបច្ច័យទាំងឡាយតាក់តែងហើយ ។

ឈ្មោះថា **មារាមិសតោ** ព្រោះជានុយនៃមច្ចុមារនិងកិលេសមារ ។

ឈ្មោះថា **ជាតិជរាព្យាធិមរណធម្មតោ** ព្រោះមានជាតិ ជរា ព្យាធិនិងមរណៈជាប្រក្រតី ។

ឈ្មោះថា **សោកបរិទេវឧបាយាសធម្មតោ** ព្រោះជាហេតុនៃសេចក្ដីសោក បរិទេវៈ និងឧបាយាសៈ ។

ឈ្មោះថា **សង្កិលេសធម្មតោ** ព្រោះមានតណ្ហា ទិដ្ឋិ ទុច្ចរិតនិងសង្កិលេសទាំងឡាយជាអារម្មណ៍តាមធម្មតា ។

ឈ្មោះថា **សមុទយតោ** ព្រោះការកើតឡើងដោយអំណាចនៃអវិជ្ជា កម្ម

តណ្ហានិងសឡាយតនៈ ។

ឈ្មោះថា **អត្តង្គមតោ** ព្រោះមិនមានអវិជ្ជាជាដើមនោះ ។

ឈ្មោះថា **អស្សាទតោ** ព្រោះការត្រេកអរ មានការផ្អែមល្ហែមដោយអំណាចធនុរាគៈក្នុងផស្សៈ ។

ឈ្មោះថា **អាទីនវតោ** ព្រោះការប្រែប្រួលនៃផស្សៈ ។

ឈ្មោះថា **និស្សរណតោ** ព្រោះការចេញទៅនៃគុណនិងទោសទាំងពីរ ។ បទថា **តិរេតិ** គប្បីឃើញបាឋៈដ៏សេសក្នុងបទទាំងពួងថា **តិរេតិ** ( ពិចារណា ) ។

បទថា **បជហាតិ** សេចក្តីថា នាំចេញចាករបស់ខ្លួន ។ បទថា **វិនោទេតិ** សេចក្តីថា ធ្វើឲ្យស្រោលស្តើង ។ បទថា **ព្យន្តីករោតិ** សេចក្តីថា ធ្វើឲ្យដល់ទីបំផុត ។ បទថា **អនភាវង្គមេតិ** សេចក្តីថា ឲ្យដល់នូវការមិនមានក្នុងខាងក្រោយ ។

ឈ្មោះថា **ឧច្ឆិន្នមូលា** ព្រោះអត្ថថា ឫសគល់ដែលសម្រេចដោយតណ្ហានិងអវិជ្ជានៃធនុរាគៈទាំងនោះ ត្រូវកាត់ផ្តាច់ហើយដោយសស្ត្រាគឺអរិយមគ្គ ។

ឈ្មោះថា **តាលាវត្ថុកតា** ព្រោះអត្ថថា ធ្វើទីតាំងនៃធនុរាគៈទាំងនោះឲ្យដូចជាត្នោតកំបុតចុង ដូចកាលបុគ្គលដកដើមត្នោតឡើងព្រមទាំងឫសហើយធ្វើប្រទេសនោះឲ្យត្រឹមតែទីដែលតាំងនៅនៃដើមត្នោតនោះ ការកើតឡើងនៃដើមត្នោតនោះ រមែងមិនប្រាកដទៀតយ៉ាងណា កាលព្រះយោគាវចរដកនូវរស មានរូបជាដើមព្រមទាំងឫសដោយសស្ត្រាគឺអរិយមគ្គ ធ្វើចិត្តឲ្យត្រឹមតែជាទីតាំងដែលធនុរាគៈទាំងនោះ ធ្លាប់កើតឡើងហើយក្នុងកាលមុន ធនុរាគៈទាំង

អស់នោះលោកហៅថា ត្រូវធ្វើឲ្យដូចត្នោតកំបុតចុង ដូច្នោះ ។

បទថា **យស្សេសោ** បានដល់ ការជាប់ចិត្តនោះ ដែលបុគ្គលណា ។ បទថា **សមុច្ឆិន្នោ** បានដល់ កាត់ផ្តាច់ហើយដោយប្រពៃ ។ បទថា **វូបសន្តោ** បានដល់ ស្ងប់បានហើយដោយផល ។ បទថា **បដិប្បស្សទ្ធោ** បានដល់ រម្ងាប់បានហើយដោយបដិប្បស្សទ្ធិបហាន ម្យ៉ាងទៀត លោកពង្រីកបទដោយឧបសគ្គ ។ បទថា **អភព្វុប្បត្តិកោ** បានដល់ មិនគួរដើម្បីនឹងកើតឡើងទៀត ។ បទថា **ញាណគ្គិ ឆានឌ្ឍោ** បានដល់ ដុតហើយដោយភ្លើងគឺមគ្គញាណ ។ ម្យ៉ាងទៀត អាចារ្យពួកមួយពណ៌នាយ៉ាងនេះថា លះបានហើយព្រមដោយវត្ថុ ដូចបោះចោលទៅព្រមជាមួយភាជនៈដែលដាក់ថ្នាំពិស ។ កាត់ព្រមទាំងឫសដូចកាត់ឫសវល្លិ៍ដែលមានពិសដូច្នោះទើបឈ្មោះថា **សមុច្ឆិន្នោ វូបសន្តោ** ដូចស្រោចទឹកលត់នូវភ្លើងក្នុងចង្ក្រាន ។ រលាស់ចោលហើយ ដូចតំណក់ទឹកដែលធ្លាក់ចុះ ក្នុងរងើកភ្លើងដែលរលត់ហើយ ធ្វើមិនឲ្យកើតឡើងបាន ដូចពូជដែលត្រូវកាត់ហេតុកើតរបស់ពន្លកហើយ ដុតដោយភ្លើង គឺញាណ ដូចដើមឈើពុលត្រូវរន្ទះបាញ់ដូច្នេះ ។

បទថា **វីតគេធោ** នេះលោកពោលដោយអំណាចនៃការលះភាវៈរបស់ខ្ជិន ។ បទថា **វិគតគេធោ** នេះ លោកពោលដោយអំណាចនៃការលះភាវៈដែលនៅមានអាល័យក្នុងអារម្មណ៍ ។ បទថា **វន្តគេធោ** នេះ ពោលដោយអំណាចសម្តែងភាវៈមិនកាន់យក ។ បទថា **មុត្តគេធោ** នេះ ពោលដោយអំណាចនៃការដោះចាកសន្តតិ ។ បទថា **បហីនគេធោ** នេះ ពោលដោយ

*អំណាចនៃការមិនតាំងមាំក្នុងទីណាមួយរបស់បុគ្គលដែលផុតហើយ ។*

*បទថា* **បដិនិស្សដ្ឋគេធោ** *នេះ ពោលដោយអំណាចសម្ដែងការលះបង់នូវការជាប់ចិត្តដែលធ្លាប់ប្រកាន់ទុក ។ បទថា* **វីតរាគោ វិគតរាគោ ចត្តរាគោ វន្តរាគោ** *គប្បីប្រកបដោយន័យដែលពោលហើយ ។*

*បណ្ដាបទទាំងនោះ ឈ្មោះថា* **គេធោ** *ដោយអំណាចនៃការជាប់ចិត្ត ។ ឈ្មោះថា* **រាគោ** *ដោយអំណាចនៃការត្រេកអរ ។*

*បទថា* **និច្ឆាតោ** *បានដល់ មានតណ្ហាចេញហើយ បាឋៈថា* **និច្ឆរោ** *ក៏មាន សេចក្ដីថា វៀរចាកដំបូល គឺតណ្ហា ។*

*បទថា* **និព្វុតោ** *បានដល់ មានសភាវៈរលត់ហើយ ។ បទថា* **សីតិភូតោ** *បានដល់ មានការត្រជាក់ជាសភាវៈ ។ បទថា* **សុខប្បដិសំវេទី** *បានដល់ មានសភាវៈសោយនូវសុខផ្លូវកាយនិងសុខផ្លូវចិត្ត ។ បទថា* **ព្រហ្មភូតេន** *បានដល់ មានសភាវៈឧត្តម ។*

*[ ៦៣ ] បទថា* **អត្តនា** *បានដល់ មានចិត្ត ។ បទថា* **កតត្តា ច** *បានដល់ ព្រោះធ្វើនូវកម្មអាក្រក់ផង ។ បទថា* **អកតត្តា ច** *បានដល់ ព្រោះមិនធ្វើនូវកម្មល្អផង ។ បទថា* **កតំ មេ កាយទុច្ចរិតំ អកតំ មេ កាយសុចរិតំ** *ជាដើម ពោលដោយអំណាចនៃទ្វារ ដោយអំណាចការមិនវៀរចាកនិងការវៀរចាកនិងដោយអំណាចកម្មបថ ។*

*បទថា* **សីលេសុម្ហិ ន បរិបូរការី** *ជាដើម ពោលដោយអំណាចនៃបារិសុទ្ធិសីល ៤ ។ បទថា* **ជាគរិយមននុយុត្តោ** *ពោលដោយអំណាចធម៌*

ជាគ្រឿងភ្ញាក់រឭក ៥ ។ បទថា **សតិសម្បជញ្ញេន** ពោលដោយអំណាចសាត្ថកសម្បជញ្ញៈជាដើម ។

ពោធិបក្ខិយធម៌ទាំងឡាយមានបទថា **ចត្តារោ សតិប្បដ្ឋានា** ពោលដោយអំណាចលោកិយៈនិងលោកុត្តរ ។

បទទាំង ៤ មានបទថា **ឥទុក្ខំ មេ អបរិញ្ញាតំ** ជាដើម ពោលដោយអំណាចអរិយសច្ចៈ ។ បទទាំងនោះ មានអត្ថប្រាកដហើយ ព្រោះមានន័យដូចពោលហើយក្នុងទីនោះៗ ។

[ ៦៤ ] បទទាំង ៧ ថា **ធីរោ បណ្ឌិតោ** ជាដើម មានអត្ថដូចពោលទុកហើយដូចគ្នា ម្យ៉ាងទៀត ឈ្មោះថា **ធីរោ** ដោយអត្ថថា មិនញាប់ញ័រក្នុងទុក្ខ ។ ឈ្មោះថា **បណ្ឌិតោ** ព្រោះអត្ថថា មិនត្រេកអរក្នុងសុខ ។ ឈ្មោះថា **បញ្ញវា** ដោយអត្ថថា ធ្វើនូវការសន្សំប្រយោជន៍ក្នុងបច្ចុប្បន្ននិងប្រយោជន៍ខាងមុខ ។

ឈ្មោះថា **ពុទ្ធិមា** ដោយអត្ថថា មិនញាប់ញ័រក្នុងប្រយោជន៍ខ្លួននិងប្រយោជន៍អ្នកដទៃ ។ ឈ្មោះថា **ញាណី** ដោយអត្ថថា មិនថយក្រោយក្នុងអត្ថទាំងជ្រៅទាំងរាក់ ។ ឈ្មោះថា **វិភាវី** ព្រោះអត្ថថា ជាក់ច្បាស់ក្នុងអត្ថដែលកំបាំង ។ ឈ្មោះថា **មេធាវី** គឺបុគ្គលដែលដូចជាជញ្ជីងដោយអត្ថថា មាំទាំព្រោះមិនមានការសៅហ្មង ។

បទថា **ន លិម្បតិ** សេចក្តីថា មិនជាប់ក្នុងការកើតរបស់ខ្លួន ដូចគំនូសក្នុងអាកាស ។ បទថា **ន សំលិម្បតិ** សេចក្តីថា មិនជាប់ដោយពិសេស ។

*បទថា* **ន ឧបលិប្បតិ** *សេចក្តីថា សូម្បីប្រកប ក៏មិនជាប់ជំពាក់ ដូចស្នាមគំនូសក្នុងបាតដៃ ។*

*បទថា* **អលិត្តោ** *សេចក្តីថា ប្រកបមិនសៅហ្មង ដូចកែវមណីដែលដាក់លើសំពត់ដែនកាសី ។ បទថា* **អសំលិត្តោ** *សេចក្តីថា មិនសៅហ្មងជាពិសេស ដូចសំពត់ដែនកាសីដែលរុំកែវមណី ។ បទថា* **អនុបលិត្តោ** *សេចក្តីថា សូម្បីចូលទៅក៏មិនជាប់ជំពាក់ ដូចដំណក់ទឹកលើស្លឹកឈូក ។ បទថា* **និក្ខន្តោ** *សេចក្តីថា ចេញទៅខាងក្រៅ ដូចគេចចេញអំពីគុក ។ បទថា* **និស្សដ្ឋោ** *សេចក្តីថា លះដាច់ហើយ ដូចសំពត់សៅហ្មងដែលអមិត្តដណ្តប់ហើយ ។ បទថា* **វិប្បមុត្តោ** *សេចក្តីថា ផុតដោយល្អ ដូចញ៉ាំងនូវការត្រេកអរក្នុងវត្ថុដែលគួរកាន់យកឲ្យវិនាសហើយ មិនមកទៀត ។ បទថា* **វិសញ្ញុត្តោ** *សេចក្តីថា មិនប្រកបដោយកិលេសទាំងឡាយដោយភាពតែមួយ ដូចអ្នកជំងឺប្រាសចាកព្យាធិដូច្នោះ ។ បទថា* **វិមរិយាទិកតេន ចេតសា** *សេចក្តីថា មានចិត្តធ្វើឲ្យប្រាសចាកដែនកិលេស អធិប្បាយថា មានចិត្តផុតហើយចាកកិលេសទាំងពួង ដោយកពទាំងពួង ដោយអារម្មណ៍ទាំងពួង ។*

*[ ៦៥ ] ក្នុងគាថាថា* **សញ្ញំ បរិញ្ញា** *ជាដើម មានសេចក្តីសង្ខេប ដូចតទៅនេះថា មិនមែនផស្សៈតែម្យ៉ាងប៉ុណ្ណោះទេ ម្យ៉ាងទៀត មុនីកំណត់ដឹងសញ្ញាផ្សេងៗដោយកាមសញ្ញាជាដើម ឬកំណត់ដឹងនាមរូបដោយគន្ធនៃសញ្ញាដោយន័យដែលពោលហើយក្នុងកាលមុននោះឯង ដោយបរិញ្ញា ៣ ហើយគប្បីឆ្លងឱឃៈបានទាំង ៤ ដោយបដិបទានេះ បន្ទាប់អំពីនោះ មុនី*

នោះឆ្លងឱឃៈបានហើយ មិនប្រទាក់ក្នុងសេចក្តីហួងហែងទាំងឡាយ ដោយតណ្ហានិងទិដ្ឋិ ព្រោះលះកិលេស គឺតណ្ហានិងទិដ្ឋិបាន ជាមុនីមានអាសវៈអស់ហើយជាអ្នកមានព្រួញដកឡើងហើយ ព្រោះដកនូវសរ គឺកិលេសមានរាគៈជាដើមបានហើយ ជាអ្នកប្រព្រឹត្តមិនប្រហែស ព្រោះដល់នូវការបរិបូណ៌នៃសតិ ឬជាអ្នកមិនប្រមាទ ត្រាច់ទៅក្នុងកាលខាងដើម ជាអ្នកដកនូវព្រួញបានដោយត្រាច់ទៅដោយការមិនប្រមាទនោះ រមែងមិនប្រាថ្នានូវលោកនេះ និងលោកដទៃ មានអត្តភាពរបស់ខ្លួន និងរបស់អ្នកដទៃជាដើម រមែងបរិនិព្វានព្រោះរំលត់ចរិមចិត្តបានដោយពិត ដូចភ្លើងអស់កំញមដូច្នោះ ។ ព្រះមានព្រះភាគទ្រង់ដាក់របៀបធម៌នោះឯង បញ្ចប់ទេសនាដោយកំពូល គឺអរហត្តដោយប្រការដូច្នេះ តែមិនញុំាងមគ្គ និងផលឲ្យកើតឡើងដោយទេសនានេះ ព្រោះទ្រង់សម្តែងដល់ព្រះខីណាស្រព ( បិណ្ឌោលការទ្វាជ ) ដូច្នេះឯង ។

[ ៦៦ ] ឈ្មោះថា **សញ្ញា** ព្រោះអត្ថថា ចាំអារម្មណ៍ មានពណ៌ខៀវជាដើមបាន សញ្ញានោះមានការចាំបានជាលក្ខណៈ មានការដឹងក្រែលែងចំពោះជាកិច្ច មានសញ្ញាដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ដែលឈ្មោះថា មិនមានការចាំបានជាលក្ខណៈ មិនមានសញ្ញាទាំងអស់ មានការចាំបានជាលក្ខណៈ ។ សញ្ញាណារមែងចាំបានដោយការដឹងក្រែលែង ក្នុងទីនេះសញ្ញានោះឈ្មោះថាមានការដឹងក្រែលែងចំពោះជាកិច្ច ។ គប្បីជ្រាបការប្រព្រឹត្តទៅរបស់សញ្ញាដែលមានការដឹងក្រែលែងចំពោះជាកិច្ចនោះ ក្នុងពេលដែលជាងឈើធ្វើនូវគ្រឿងសម្គាល់ទុកត្រង់ឈើ ចាំឈើនោះបានដោយគ្រឿងសម្គាល់នោះទៀត

និងក្នុងពេលដែលកំណត់គ្រឿងសម្គាល់ មានប្រជ្រុយជាដើមរបស់បុរស ចាំបុរសនោះបានថា បុរសនេះ គឺបុគ្គលឈ្មោះនោះ ដោយគ្រឿងសម្គាល់នោះទៀត និងក្នុងពេលដែលភណ្ឌាគារិកៈដែលជាអ្នកមើលថែគ្រឿងប្រដាប់របស់ព្រះរាជា សរសេរឈ្មោះទុកត្រង់គ្រឿងប្រដាប់នោះៗ កាលមានពាក្យបញ្ជាថា ចូរនាំគ្រឿងប្រដាប់ឈ្មោះនោះមក ក៏អុជប្រទីបចូលក្នុងបន្ទប់ដែលរក្សាទ្រព្យសំខាន់ៗ អានអក្សរហើយនាំគ្រឿងប្រដាប់នោះៗមកបាន ។

ម្យ៉ាងទៀត សញ្ញាមានការចាំបានជាលក្ខណៈដោយអំណាចរួបរួមគ្រប់យ៉ាងទុកបាន មានការធ្វើនិមិត្តដែលជាបច្ច័យនៃការចាំបានទៀត ជាកិច្ចដូចជាងចាំងជាដើម ធ្វើគ្រឿងសម្គាល់ទុកត្រង់ឈើជាដើម មានការធ្វើនូវការយកមាំជាបច្ចុប្បដ្ឋាន ដោយអំណាចនិមិត្តតាមដែលសម្គាល់ទុក ដូចបុគ្គលខ្វាក់ភ្នែកស្ទាបដំរី ឬមានការតាំងនៅមិនយូរជាបច្ចុប្បដ្ឋាន ព្រោះមានការប្រព្រឹត្តមិនឈមចុះក្នុងអារម្មណ៍ដូចផ្លេកបន្ទោរ មានអារម្មណ៍តាមដែលចូលទៅតាំងទុកហើយជាបទដ្ឋាន ដូចការសម្គាល់ថាបុរសរបស់កូនម្រឹគតូចៗក្នុងទីងមោងស្មៅ ដូច្នោះ ។

សញ្ញាណាសម្បយុត្តដោយញាណក្នុងទីនេះ សញ្ញានោះរមែងប្រព្រឹត្តទៅតាមញាណនោះឯង ធម៌ដ៏សេសគប្បីជ្រាបថា ដូចបឋវីជាដើម ក្នុងបឋវីដែលប្រព្រឹត្តទៅដោយសម្ភារៈជាដើម ។

សញ្ញាដែលបដិសំយុត្តដោយកាម ឈ្មោះ **កាមសញ្ញា** សញ្ញាដែលបដិសំយុត្តដោយព្យាបាទៈ ឈ្មោះ **ព្យាបាទសញ្ញា** សញ្ញាដែលបដិសំយុត្ត

ដោយវិហិង្សា ឈ្មោះថា **វិហឹសាសញ្ញា** ។

បណ្តាសញ្ញាទាំងនោះ សញ្ញា ២ រមែងកើតឡើងទាំងក្នុងសត្វទាំងក្នុងសង្ខារទាំងឡាយ កាមសញ្ញារមែងកើតឡើងដល់អ្នកត្រិះរិះដល់សត្វ ឬសង្ខារទាំងឡាយដែលជាទីស្រឡាញ់ជាទីពេញចិត្ត ព្យាបាទសញ្ញារមែងកើតឡើងតាំងអំពីពេលក្រោធសម្លឹងមើលសត្វ ឬសង្ខារទាំងឡាយដែលមិនជាទីស្រឡាញ់មិនជាទីពេញចិត្ត រហូតដល់វិនាសទៅ វិហិង្សាសញ្ញារមែងមិនកើតឡើងក្នុងសង្ខារទាំងឡាយ ព្រោះថាសង្ខារដែលឈ្មោះថា ធ្វើឲ្យជាទុក្ខមិនមាន តែកើតឡើងក្នុងសត្វទាំងឡាយ ក្នុងពេលគិតថា សត្វទាំងនេះ ចូរត្រូវសម្លាប់ ចូរដាច់សូន្យ ចូរវិនាស ឬកុំបីមានដូច្នេះ សញ្ញាដែលបដិសំយុត្តដោយនេក្ខម្ម ឈ្មោះថា **នេក្ខម្មសញ្ញា** នេក្ខម្មសញ្ញានោះ ជាកាមាវចរក្នុងកាលជាចំណែកខាងដើមនៃអសុភ ជារូបាវចរៈក្នុងអសុភឈាន ជាលោកុត្តរក្នុងកាលដែលមគ្គផលកើតឡើង ព្រោះធ្វើឈាននោះឲ្យជាបាទ ។

សញ្ញាដែលបដិសំយុត្តដោយអព្យាបាទ ឈ្មោះថា **អព្យាបាទសញ្ញា** អព្យាបាទសញ្ញានោះ ជាកាមាវចរក្នុងកាលជាចំណែកខាងដើមនៃមេត្តា ជារូបាវចរក្នុងមេត្តាឈាន ជាលោកុត្តរក្នុងកាលដែលមគ្គផលកើតឡើង ព្រោះធ្វើឈាននោះឲ្យជាបាទ ។

សញ្ញាដែលបដិសំយុត្តដោយអវិហិង្សាឈ្មោះថា **អវិហឹសាសញ្ញា** អវិហិង្សាសញ្ញានោះ ជាកាមាវចរក្នុងកាលជាចំណែកខាងដើមនៃករុណា ជារូបាវចរក្នុងករុណាឈាន ជាលោកុត្តរក្នុងកាលដែលមគ្គផលកើតឡើង ព្រោះធ្វើឈាន

នោះឲ្យជាបាទ ។

ក្នុងកាលណាអលោភៈជាគោលសំខាន់ ក្នុងកាលនោះ សញ្ញាទាំងពីរនេះ រមែងទៅតាមអលោភៈនោះ ក្នុងកាលណាមេត្តាជាគោលសំខាន់ ក្នុងកាលនោះ សញ្ញាទាំងពីរនេះ រមែងទៅតាមមេត្តានោះ ក្នុងកាលណាករុណាជាគោលសំខាន់ ក្នុងកាលនោះ សញ្ញាទាំងពីរនេះ រមែងទៅតាមករុណានោះឯង ។ សញ្ញាដែលកើតឡើងប្រារព្ធរូបារម្មណ៍ ឈ្មោះថា **រូបសញ្ញា** ក្នុងសទ្ទសញ្ញាជាដើមក៏ន័យនេះឯង ពាក្យនេះជាឈ្មោះរបស់សញ្ញានោះឯង ដោយអារម្មណ៍ សូម្បីវត្ថុដែលកើតអំពីចក្ខុសម្ផស្សជាដើម ឈ្មោះថា លោកពោលហើយនោះឯង ព្រោះបានពោលដល់អារម្មណ៍ទាំងឡាយទុកហើយ ។

បទថា **យា តជ្ជា សញ្ញា** សេចក្ដីថា គប្បីជ្រាបសញ្ញាដទៃៗ យ៉ាងនេះថា សញ្ញាកើតអំពីបដិឃសម្ផស្ស សញ្ញាកើតអំពីអធិវចនសម្ផស្ស ជាដើម ។

បណ្ដាបទទាំងនោះ បទថា សញ្ញាកើតអំពីអធិវចនសម្ផស្ស បានដល់សញ្ញាដែលប្រព្រឹត្តទៅតាមទ្វារ ៦ ដោយបរិយាយនោះឯង ។ អរូបក្ខន្ធ ៣ ដែលមកតាមក្រោយ ( សញ្ញា ) រមែងបានឈ្មោះថា **អធិវចនសម្ផស្សជាសញ្ញា** ព្រោះសហជាតសញ្ញារបស់ខ្លួន ។

តែដោយនិប្បរិយាយ សញ្ញាដែលប្រព្រឹត្តទៅតាមទ្វារ ៥ ឈ្មោះថា **បដិឃសម្ផស្សជា សញ្ញា** ។ សញ្ញាដែលប្រព្រឹត្តទៅតាមមនោទ្វារ ឈ្មោះថា **អធិវចនសម្ផស្សជា សញ្ញា** ។ សញ្ញាទាំងនេះ គប្បីជ្រាបថា លោក

កំណត់ជាអតិរេកសញ្ញា ។

បទថា **សញ្ញា** បានដល់ ឈ្មោះនៃសភាវៈ ។ បទថា **សញ្ញាណនា** បានដល់ អាការៈដែលដឹងព្រម ។ បទថា **សញ្ញាណិតត្តំ** បានដល់ ការកើត គឺការដឹងព្រម ។ បទថា **អវិជ្ជាយំ** មានវិនិច្ឆ័យថា កាយទុច្ចរិតជាដើម ឈ្មោះថា មិនគប្បីជួប ដោយអត្ថថា មិនគួរបំពេញ អធិប្បាយថា មិនគប្បីបាន ។ ឈ្មោះថា **អវិជ្ជា** ព្រោះអត្ថថា ជួបនូវកាយទុច្ចរិតជាដើមនោះ ដែលជារបស់មិនគប្បីជួប ។

កាយសុចរិតជាដើម ឈ្មោះថា គប្បីជួបដោយផ្ទុយគ្នានឹងកាយទុច្ចរិតជាដើមនោះ ។ ឈ្មោះថា **អវិជ្ជា** ព្រោះអត្ថថា មិនជួបសុចរិតជាដើមនោះដែលជារបស់គប្បីជួប ។

ឈ្មោះថា **អវិជ្ជា** ព្រោះអត្ថថា ធ្វើមិនឲ្យដឹងនូវអត្ថថាគំនរនៃខន្ធទាំងឡាយ ។ អត្ថថា ទីតនៃអាយតនៈទាំងឡាយ អត្ថថា សូន្យនៃធាតុទាំងឡាយ អត្ថថា ជាធំនៃឥន្ទ្រិយទាំងឡាយ អត្ថថា ពិតនៃសច្ចៈទាំងឡាយ ។ ឈ្មោះថា **អវិជ្ជា** ព្រោះអត្ថថា ធ្វើមិនឲ្យដឹងអត្ថ ៤ យ៉ាង ដែលពោលហើយដោយអំណាចទុក្ខជាដើម ជាសភាពបៀតបៀនជាដើម ។

ឈ្មោះថា **អវិជ្ជា** ព្រោះអត្ថថា ញុំាងសត្វទាំងឡាយឲ្យស្ទុះទៅក្នុងកំណើត គតិ ភព វិញ្ញាណដ្ឋិតិ និងសត្តាវាសទាំងឡាយ ក្នុងសង្សារដែលមិនមានទីបំផុត ។

ឈ្មោះថា **អវិជ្ជា** ព្រោះអត្ថថា ស្ទុះទៅក្នុងស្ត្រីនិងបុរសជាដើម ដែលមិន

មានដោយបរមត្ថ មិនស៊ុះទៅក្នុងសត្វជាដើមដែលមាន ។ ម្យ៉ាងទៀត ឈ្មោះថា **អវិជ្ជា** ព្រោះបិទបាំងនូវធម៌ទាំងឡាយដែលអាស្រ័យវត្ថុនិងអារម្មណ៍នៃចក្ខុវិញ្ញាណជាដើមកើតឡើងក៏មាន ។ នូវអវិជ្ជាយៈនោះ ។

គប្បីធ្ងន់ឡើង ( ឧត្តរេយ្យ ) ដោយអំណាចនៃការមោយៈ គប្បីធ្ងន់ផុត ( បតរេយ្យ ) ដោយអំណាចករោយៈ គប្បីកន្លង ( សមតិក្កមេយ្យ ) ដោយអំណាចនៃទិដ្ឋោយៈ គប្បីប្រព្រឹត្តកន្លង ( វីតិវត្តេយ្យ ) ដោយអំណាចនៃអវិជ្ជោយៈ ។

ម្យ៉ាងទៀត គប្បីធ្ងន់ឡើងដោយអំណាចលះដោយសោតាបត្តិមគ្គ គប្បីធ្ងន់ផុត ដោយអំណាចលះដោយសកទាគាមិមគ្គ គប្បីកន្លងដោយអំណាចលះដោយអនាគាមិមគ្គ គប្បីប្រព្រឹត្តកន្លងដោយអំណាចលះដោយអរហត្តមគ្គ ។

ម្យ៉ាងទៀត អាចារ្យពួកខ្លះពោលទុកថា ពាក្យ ៥[១] មានពាក្យថា ធ្ងន់ជាដើម គប្បីប្រកបដោយបហានៈ ៥ មានតទង្គប្បហានជាដើម ។

[ ៦៧ ] ព្រះសារីបុត្តត្ថេរ កាលពោលថា **មោឆំ វុច្ចតិ ញាណំ** ដូច្នេះហើយ ដើម្បីសម្តែងញាណនោះដោយប្រភេទ ទើបពោលថា **យា បញ្ញា បជានណា** ជាដើម ។

វៀរន័យដែលពោលហើយនោះឯង គប្បីជ្រាបបទថា **អមោហោ ធម្ម-វិចយោ** ដូចតទៅនេះថា

---

១-ពាក្យ ៥ គឺ វិតរេយ្យ ( ធ្ងន់ ) ១ ឧត្តរេយ្យ ( ធ្ងន់ឡើង ) ១ បតរេយ្យ ( ធ្ងន់ផុត ) ១ សមតិក្កមេយ្យ ( កន្លង ) ១ វីតិវត្តេយ្យ ( ប្រព្រឹត្តកន្លង ) ១ តែពាក្យទាំង ៥ នេះ បិដកខ្មែរឃើញប្រែត្រឹមតែបួន បណ្ឌិតគប្បីពិចារណា ។

អមោហៈ ការមិនវង្វេង ជាបដិបក្ខចំពោះការមិនចម្រើនក្នុងកុសលធម៌ទាំងឡាយ គឺជាហេតុឲ្យចម្រើន ។ បុគ្គលរមែងកាន់យកការមិនវិបរិតដោយការមិនវង្វេងអំពីការកាន់យកការវិបរិតរបស់បុគ្គលវង្វេង ។ បុគ្គលទ្រទ្រង់ចាំពិតតាមសេចក្តីពិត រមែងប្រព្រឹត្តទៅក្នុងសភាវៈដែលពិត ដោយការមិនវង្វេង ។ ឯបុគ្គលវង្វេង រមែងកាន់យកការពិតថាមិនពិត កាន់យកការមិនពិតថាពិត រមែងមានទុក្ខព្រោះមិនបាននូវវត្ថុដែលប្រាថ្នាដោយប្រការនោះ ។

បុគ្គលមិនវង្វេង រមែងមិនមានមរណទុក្ខ ព្រោះកើតការពិចារណាយ៉ាងនេះថា នឹងបានការមិនស្លាប់នោះអំពីណាក្នុងលោកនេះជាដើម ។ ការស្លាប់ដោយការវង្វេងជាទុក្ខ ការស្លាប់ដោយការវង្វេងនោះ មិនមានដល់បុគ្គលមិនវង្វេង ។ បព្វជិតទាំងឡាយ រមែងនៅរួមគ្នាជាសុខ ។ មិនកើតឡើងក្នុងកំណើតតិរច្ឆាន ។ ឯបុគ្គលដែលវង្វេងជានិច្ច រមែងចូលដល់កំណើតតិរច្ឆានដោយការវង្វេង តែការមិនវង្វេងជាបដិបក្ខចំពោះការវង្វេង ។ ការវង្វេងធ្វើឲ្យមិនមានភាពជាកណ្តាលដោយអំណាចការវង្វេង ។ អវិហិង្សាសញ្ញា ធាតុសញ្ញា ការបដិបត្តិមជ្ឈិមបដិទា ការទម្លាយគន្ថៈ ២ ខាងក្រោយ រមែងមានដោយការមិនវង្វេង ។ សតិប្បដ្ឋាន ២ ខាងក្រោយ រមែងសម្រេចដោយអានុភាពនៃការមិនវង្វេងនោះឯង ។

ការមិនវង្វេងជាបច្ច័យឲ្យជាអ្នកមានអាយុវែង ព្រោះថាបុគ្គលមិនវង្វេងដឹងនូវប្រយោជន៍និងមិនមែនប្រយោជន៍ វៀរនូវវត្ថុមិនជាប្រយោជន៍ សេពចំពោះនូវវត្ថុដែលជាប្រយោជន៍ រមែងមានអាយុវែង មិនសាបសូន្យចាកអត្ថ

សម្បត្តិ ។ បុគ្គលមិនវង្វេង កាលធ្វើវត្ថុដែលជាប្រយោជន៍ដល់ខ្លួនទោះឯង រមែងញុំាងខ្លួនឲ្យដល់ព្រម ។ ការមិនវង្វេងរមែងជាបច្ច័យនៃការនៅដ៏ប្រសើរ ។ បុគ្គលមិនវង្វេងជាអ្នករំលត់ក្នុងចំណែកដែលជាកណ្ដាល ។

បុគ្គលមិនវង្វេង រមែងឃើញអនត្តាដោយការមិនវង្វេង ព្រោះមិនមានសេចក្ដីសង្ស័យទាំងពួង ។ បុគ្គលមិនវង្វេង ជាបុគ្គលឈ្លាសកាន់យកតាមសេចក្ដីពិត រមែងដឹងនូវខន្ធបញ្ចកៈដែលមិនមែនអ្នកនាំដោយភាពមិនមែនអ្នកនាំ ដូចឃើញអនត្តា ព្រោះការមិនវង្វេងនោះយ៉ាងណា ការមិនវង្វេងព្រោះឃើញអនត្តាក៏យ៉ាងនោះ បុគ្គលណាដឹងនូវការទទេនៃអត្តាហើយ នឹងគប្បីដល់នូវការវង្វេងទៀតនោះ ។

បទថា **តេន ញាណេន សមន្នាគតោ** សេចក្ដីថា ព្រះសេក្ខៈជាដើម ជាអ្នកមានការព្រមព្រៀងដោយញាណ មានប្រការដូចពោលហើយនោះ ឈ្មោះថា **មុនិ** ។

បទថា **មោនប្បត្តោ** សេចក្ដីថា ដល់ហើយនូវភាពជាមុនីដោយញាណដែលបានចំពោះហើយ ។ បទថា **តីណិ** ជាបទកំណត់ចំនួន ។ បទថា **មោ–នេយ្យានិ** បានដល់ ធម៌គឺបដិបទាដែលធ្វើនូវភាពជាមុនី គឺធ្វើឲ្យជាមុនី ក្នុងបទថា **កាយមោនេយ្យំ** ជាដើម មានវិនិច្ឆ័យដូចតទៅនេះថា ប្រការដែលគប្បីបញ្ញត្តដោយអំណាចនៃកាយវិញ្ញត្តិនិងរូបកាយ ឈ្មោះថាមោនេយ្យធម៌ផ្លូវកាយ ។ ប្រការដែលគប្បីបញ្ញត្តដោយអំណាចនៃវចីវិញ្ញត្តិនិងសទ្ទវាចា ឈ្មោះថា មោនេយ្យធម៌ផ្លូវវាចា ។ ប្រការដែលគប្បីបញ្ញត្តដោយអំណាចនៃចិត្ត

ដែលប្រព្រឹត្តទៅក្នុងមនោទ្វារជាដើម ឈ្មោះថា មោនេយ្យធម៌ផ្លូវចិត្ត ។

បទថា **តិវិធកាយទុច្ចរិតានំ បហានំ** បានដល់ លះនូវការប្រព្រឹត្តអាក្រក់ដែលប្រព្រឹត្តទៅផ្លូវកាយ ៣ យ៉ាង មានបាណាតិបាតជាដើម ។ បទថា **កាយសុចរិតំ** បានដល់ ការប្រព្រឹត្តល្អដែលប្រព្រឹត្តទៅផ្លូវកាយ ។ បទថា **កាយារម្មណេ ញាណំ** បានដល់ ញាណក្នុងធម៌ដែលមានកាយជាអារម្មណ៍ ដែលធ្វើកាយឲ្យជាអារម្មណ៍ប្រព្រឹត្តទៅដោយអំណាចនៃអនិច្ចំជាដើម ។ បទថា **កាយបរិញ្ញា** បានដល់ ញាណដែលប្រព្រឹត្តទៅដោយអំណាចដឹងនូវកាយ ដោយញាតបរិញ្ញា តីរណបរិញ្ញានិងបហានបរិញ្ញា ។ បទថា **បរិញ្ញាសហគតោ មគ្គោ** បានដល់ មគ្គដែលពិចារណាកាយខាងក្នុងហើយឲ្យកើតឡើង ឈ្មោះថា សហគតៈដោយបរិញ្ញា ។

បទថា **កាយេ ឆន្ទរាគស្ស បហានំ** បានដល់ លះនូវឆន្ទរាគៈ គឺតណ្ហាក្នុងកាយ ។ បទថា **កាយសង្ខារនិរោធោ** បានដល់ ការរំលត់ គឺការរម្ងាប់ខ្យល់ដង្ហើមចូលនិងខ្យល់ដង្ហើមចេញ គឺការចូលចតុត្ថជ្ឈានសមាបត្តិ ។ បទថា **វចីសង្ខារនិរោធោ** បានដល់ ការរំលត់ គឺការរម្ងាប់វិតក្ក វិចារៈ គឺការចូលទុតិយជ្ឈានសមាបត្តិ ។ បទថា **ចិត្តសង្ខារនិរោធោ** បានដល់ ការរំលត់ គឺការរារាំងនូវសញ្ញានិងវេទនា គឺដោយការចូលសញ្ញាវេទយិតនិរោធសមាបត្តិ ។

ក្នុងបទថា **កាយមុនិ** ជាដើម ក្នុងគាថាដំបូង មានវិនិច្ឆ័យដូចតទៅនេះថា ឈ្មោះថា **កាយមុនិ** ដោយអំណាចលះកាយទុច្ចរិតបាន ។ ឈ្មោះថា **វាចាមុនិ** ដោយអំណាចលះវចីទុច្ចរិតបាន ឈ្មោះថា **មនោមុនិ** ដោយអំណាច

*លះមនោទុច្ចរិតបាន ឈ្មោះថា* **អនាសវមុនិ** *ដោយអំណាចលះអកុសលទាំងពួងបាន ។*

*បទថា* **មោនេយ្យសម្បន្នំ** *សេចក្តីថា ឈ្មោះថា* **មោនេយ្យសម្បន្នំ** *ព្រោះដឹងវត្ថុដែលគួរដឹង តាំងនៅក្នុងផល ។*

*បទថា* **អាហុ សព្វប្បហាយិនំ** *សេចក្តីថា បណ្ឌិតទាំងឡាយពោលថា ជាអ្នកលះកិលេសទាំងពួង ព្រោះលះកិលេសទាំងពួងតាំងនៅ ។*

*គាថាទី ២ មានវិនិច្ឆ័យដូចតទៅនេះថា ក្នុងបទថា* **និន្ហាតបាបកំ** *គប្បីឃើញអត្ថយ៉ាងនេះថា បណ្ឌិតទាំងឡាយ ពោលថាជាអ្នកមានបាបដែលលាងហើយ ព្រោះជាអ្នកលាង គឺជម្រះបាបទាំងពួងដែលគួរកើតឡើងក្នុងអាយតនៈទាំងពួង ពោលគឺខាងក្នុងនិងខាងក្រៅ ដោយអំណាចអារម្មណ៍ខាងក្នុងនិងខាងក្រៅដោយមគ្គញាណតាំងនៅហើយ ។*

*មុនីដែលនៅគ្រប់គ្រងផ្ទះ ឈ្មោះថា អគារមុនី មុនីដែលបព្វជ្ជាឈ្មោះថា អនាគារមុនី ព្រះសេក្ខៈ ៧ ឈ្មោះថា សេក្ខមុនី ព្រះអរហន្តទាំងឡាយឈ្មោះថា អសេក្ខមុនី ព្រះបច្ចេកពុទ្ធទាំងឡាយឈ្មោះថា បច្ចេកមុនី ព្រះសម្មាសម្ពុទ្ធទាំងឡាយឈ្មោះថា មុនិមុនី ។*

*ព្រះសារីបុត្តត្ថេរពោលថា* **កតមេ អាគារមុនយោ** *ដោយអំណាចនៃការសួរ ដើម្បីប្រាប្ថានឹងឆ្លើយ ។*

*បទថា* **អគារិកា** *បានដល់ ជាអ្នកខ្វល់ខ្វាយក្នុងការងារគ្រប់គ្រងផ្ទះ មានកសិកម្មនិងគោរក្ខកម្មជាដើម ។*

បទថា **ឥដ្ឋបត្តា** បានដល់ ដែលឃើញនិព្វានហើយ ។ បទថា **វិញ្ញាតសាសនា** សេចក្តីថា ឈ្មោះថា មានពាក្យប្រៀនប្រដៅដែលដឹងច្បាស់ហើយ ព្រោះអត្ថថា មានពាក្យប្រៀនប្រដៅ គឺត្រៃសិក្ខាដឹងច្បាស់ហើយ ។

ពាក្យថា មិនមានផ្ទះ សេចក្តីថា បព្វជិតទាំងឡាយលោកហៅថា មិនមានផ្ទះ ព្រោះអត្ថថា លោកទាំងនេះមិនមានការងាររបស់អ្នកគ្រប់គ្រងផ្ទះ មានកសិកម្មនិងគោរក្ខកម្មជាដើម ។

បទថា **សត្ត សេក្ខា** សេចក្តីថា ឈ្មោះថា **សេក្ខា** ព្រោះអត្ថថា ព្រះអរិយបុគ្គល ៧ មានសោតាបន្នៈជាដើម នៅសិក្សាក្នុងត្រៃសិក្ខានៅឡើយ ។

ព្រះអរហន្តទាំងឡាយឈ្មោះថា **អសេក្ខ** ព្រោះអត្ថថា មិនត្រូវសិក្សាព្រះបច្ចេកពុទ្ធទាំងឡាយ ឈ្មោះថា បច្ចេកមុនី ព្រោះអត្ថថា តែមួយអង្គនោះឯងមិនមានគ្រូអាចារ្យអាស្រ័យហេតុនោះៗ ត្រាស់ដឹងអរិយសច្ចៈ ៤ ។

## តថាគត ៨ យ៉ាង

ក្នុងបទថា **មុនិមុនយោ វុច្ចន្តិ តថាគតា** នេះ មានវិនិច្ឆ័យដូចតទៅនេះថា ព្រះដ៏មានព្រះភាគទ្រង់ព្រះនាមថា តថាគត ដោយហេតុ ៨ ប្រការគឺ ព្រោះទ្រង់យាងមកយ៉ាងនោះ ១ ព្រោះទ្រង់យាងទៅយ៉ាងនោះ ១ ព្រោះយាងមកកាន់លក្ខណៈពិត ១ ព្រោះត្រាស់ដឹងធម៌ដែលពិតតាមសេចក្តីពិត ១ ព្រោះទ្រង់ឃើញអារម្មណ៍ដែលពិត ១ ព្រោះមានវាចាពិត ១ ព្រោះទ្រង់ធ្វើយ៉ាងនោះ ១ ព្រោះទ្រង់គ្របសង្កត់ ១ ។

ព្រះដ៏មានព្រះភាគទ្រង់ព្រះនាមថា តថាគត ព្រោះយាងមកយ៉ាងនោះ

ដូចម្តេច ។ ដូចព្រះសម្មាសម្ពុទ្ធអង្គមុនៗ ទ្រង់ខ្វល់ខ្វាយដើម្បីប្រយោជន៍ដល់លោកទាំងពួង យាងមកហើយ លោកអធិប្បាយទុកដូចម្តេច ព្រះដ៏មានព្រះភាគអង្គមុនៗ យាងមកដោយអភិនីហារណា ព្រះមានព្រះភាគនៃយើងទាំងឡាយក៏យាងមកដោយអភិនីហារនោះដូចគ្នា ។ ម្យ៉ាងទៀត ព្រះមានព្រះភាគអង្គមុនៗ ទ្រង់បំពេញបារមី ៣០ គឺបារមី ១០ ឧបបារមី ១០ បរមត្ថបារមី ១០ ពោលគឺទាន សីល នេក្ខម្មៈ បញ្ញា វីរិយៈ ខន្តិ សច្ចៈ អធិដ្ឋាន មេត្តា និងឧបេក្ខា ។ ទ្រង់បរិច្ចាគមហាបរិច្ចាគ ៥ ប្រការ គឺបរិច្ចាគអវយវៈ ១ បរិច្ចាគភ្នែក ១ បរិច្ចាគទ្រព្យ ១ បរិច្ចាគរាជសម្បត្តិ ១ និងបរិច្ចាគបុត្តភរិយា ១ ។ ទ្រង់បំពេញបុព្វប្បយោគ បុព្វចរិយាការសម្តែងធម៌និងញាតត្ថចរិយាជាដើម ។ ទ្រង់ដល់នូវទីបំផុតនៃពុទ្ធចរិយា យាងមកហើយយ៉ាងណា ព្រះដ៏មានព្រះភាគនៃយើងទាំងឡាយ ក៏យាងមកយ៉ាងនោះ ។ ម្យ៉ាងទៀត ព្រះដ៏មានព្រះភាគអង្គមុនៗ ទ្រង់ចម្រើនសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គៈ ៧ អរិយមគ្គមានអង្គ ៨ យាងមកហើយយ៉ាងណា ព្រះដ៏មានព្រះភាគនៃយើងទាំងឡាយក៏យាងមកយ៉ាងនោះ ។ ព្រះដ៏មានព្រះភាគទ្រង់ព្រះនាមថា តថាគត ព្រោះយាងមកយ៉ាងនោះ ដោយប្រការដូច្នេះ ។

> ព្រះមុនីទាំងឡាយ មានព្រះទីបង្ករសម្ពុទ្ធជាដើម យាងមកកាន់
> ភាពជាព្រះសព្វញ្ញូក្នុងលោកនេះយ៉ាងណា សូម្បីព្រះសក្យ
> មុនីអង្គនេះ ក៏យាងមកយ៉ាងនោះ ដោយហេតុនោះ ទើបព្រះ

ដ៏មានចក្ខុទ្រង់ព្រះនាមថា តថាគត ដូច្នេះ ។

ព្រះដ៏មានព្រះភាគព្រះនាមថា តថាគត ព្រោះទ្រង់យាងទៅយ៉ាងនោះដូចម្តេច ។ ព្រះសម្មាសម្ពុទ្ធអង្គមុនៗ ប្រសូតភ្លាមក៏យាងទៅ ។ ព្រះដ៏មានព្រះភាគទាំងនោះយាងទៅដូចម្តេច ។ មែនពិត ព្រះដ៏មានព្រះភាគទាំងនោះប្រសូតភ្លាមនោះឯង ប្រថាប់ឈរលើប្រឹថពីដោយព្រះយុគលបាទដ៏ស្មើ បែរព្រះភក្ត្រទៅកាន់ទិសឧត្តរ យាងទៅដោយព្រះបាទ ៧ ជំហាន ដូចព្រះបាលីដែលត្រាស់ទុក ( ក្នុងមជ្ឈិមនិកាយឧបរិបណ្ណាសក ) ថា

> ម្នាលអានន្ទ ពោធិសត្វប្រសូតមកភ្លាម ទ្រង់ប្រតិស្ឋានលើផែនដីដោយព្រះបាទដ៏ស្មើ បែរព្រះភក្ត្រទៅទិសខាងជើង ទ្រង់ស្តេចដោយព្រះបាទបាន ៧ ជំហាន កាលគេកំពុងបាំងស្វេតច្ឆត្រថ្វាយ ទ្រង់ក្រឡេកមើលគ្រប់ទិសទាំងអស់ ទើបបញ្ចេញអាសភិវាចាថា អាត្មាអញជាកំពូលរបស់លោក អាត្មាអញជាបុគ្គលចម្បងជាងលោក អាត្មាអញ ជាបុគ្គលប្រសើរជាងសត្វលោក ជាតិនេះជាជាតិទីបំផុត ឥឡូវនេះ មិនមានភពថ្មីទៀតឡើយ ដូច្នេះ ។

ការយាងទៅរបស់ព្រះដ៏មានព្រះភាគអង្គនោះជាអាការៈដែលពិត មិនប្រែប្រួលដោយភាពជាបុព្វនិមិត្តនៃការសម្រេចគុណវិសេសច្រើនប្រការ គឺការដែលព្រះអង្គប្រសូតភ្លាមនោះឯង ក៏បានប្រថាប់ឈរ ដោយព្រះយុគលបាទដ៏ស្មើ នេះជាបុព្វនិមិត្តនៃការបានឥទ្ធិបាទ ៤ របស់ព្រះអង្គ ។

ម្យ៉ាងទៀត ភាពដែលព្រះអង្គបែរព្រះភក្ត្រទៅទិសខាងជើង ជាបុព្វនិមិត្ត នៃភាពជាលោកុត្តរធម៌ទាំងពួង ។ ការឈានព្រះបាទ ៧ ជំហាន ជាបុព្វនិមិត្ត នៃការបានទូវរតនៈ គឺពោជ្ឈង្គ ៧ ប្រការ ម្យ៉ាងទៀត ការលើកផ្ចិតចាមរី ឡើង ដែលពោលទុក ( ក្នុងខុទ្ទកនិកាយសុត្តនិបាត ) ថា ចាមរទាំងឡាយ មានដងជាវិការៈនៃមាសសំយុងចុះ ដូច្នេះ ។ ជាបុព្វនិម្មិតនៃការញុំាញតិរ្ថិយ ទាំងពួង ។ ការបាំងស្វេតច្ឆត្រជាបុព្វនិមិត្តនៃការបានស្វេតច្ឆត្រដ៏ប្រសើរបរិសុទ្ធ គឺព្រះអរហត្តវិមុត្តិធម៌ ។ ការទតមើលគ្រប់ទិសជាបុព្វនិមិត្តនៃការបានអនាវរ-ណញ្ញាណ គឺភាពជាព្រះសព្វញ្ញូ ។ ការបន្លឺអាសភិវាចា ជាបុព្វនិមិត្តនៃការ ប្រកាសធម្មចក្កដ៏ប្រសើរ ដែលបុគ្គលណាមួយឲ្យប្រព្រឹត្តទៅមិនបាន សូម្បីព្រះ ដ៏មានព្រះភាគអង្គនេះ ក៏យាងទៅយ៉ាងនោះ ។ ការយាងទៅរបស់ទ្រង់ក៏បាន ជាអាការៈដែលពិត មិនប្រែប្រួលដោយភាពជាបុព្វនិមិត្តនៃការសម្រេចគុណ វិសេសទាំងនោះឯង ដោយហេតុនេះ ទើបបុរាណាចារ្យទាំងឡាយពោលថា

ព្រះគោតមនោះ ប្រសូតហើយក្នុងអម្បាញ់មិញនោះក៏ទ្រង់ប៉ះ
នូវផែនដីដោយព្រះយុគលបាទដ៏ស្មើ ទ្រង់យាងបាន ៧ ជំហាន
ដូចគោមេហ្វូង ទើបតែកើតក៏ដើរបាន ឯពួកទេវតាក៏បាំង
ស្វេតច្ឆត្រ ព្រះគោតមនោះទ្រង់យាងទៅបាន ៧ ជំហាន ទត
ទៅជុំវិញទិស ទ្រង់បន្លឺព្រះសូរសៀងប្រកបដោយអង្គ ៨
ប្រការ ដូចរាជសីហ៍ឈរលើកំពូលបព៌តដូច្នោះ ដូច្នេះ ។

ព្រះដ៏មានព្រះភាគទ្រង់ព្រះនាមថា តថាគត ព្រោះយាងទៅយ៉ាងនោះ

ដោយប្រការដូច្នេះ ។ មា៉ងទៀត ព្រះដ៏មានព្រះភាគអង្គមុនៗ យាងទៅហើយយ៉ាងណា ព្រះមានព្រះភាគអង្គនេះក៏ដូចគ្នា ទ្រង់លះកាមច្ឆន្ទៈដោយនេក្ខម្មៈយាងទៅហើយ ។បេ។ ទ្រង់លះនីវរណៈដោយបឋមជ្ឈាន ទ្រង់លះនិច្ចសញ្ញាដោយអនិច្ចានុបស្សនា ។បេ។ ទ្រង់លះកិលេសទាំងអស់ ដោយអរហត្តមគ្គយាងទៅហើយ ព្រះដ៏មានព្រះភាគទ្រង់ព្រះនាមថាតថាគត ព្រោះយាងទៅយ៉ាងនោះ ដោយប្រការដូច្នេះ ។

ព្រះដ៏មានព្រះភាគទ្រង់នាមថាតថាគត ព្រោះយាងមកកាន់លក្ខណៈពិតដូចម្តេច ។

បឋវីធាតុ មានការរឹង មិនប្រែប្រួលជាលក្ខណៈ អាបោធាតុមានការហូរជាលក្ខណៈ តេជោធាតុមានការក្តៅជាលក្ខណៈ វាយោធាតុមានការឧបការៈជាលក្ខណៈ អាកាសធាតុមានការប៉ះមិនបានជាលក្ខណៈ វិញ្ញាណធាតុមានការដឹងអារម្មណ៍ជាលក្ខណៈ រូបមានការបែកធ្លាយជាលក្ខណៈ ។

វេទនាមានការសោយអារម្មណ៍ជាលក្ខណៈ សញ្ញាមានការចាំនូវអារម្មណ៍ជាលក្ខណៈ សង្ខារមានការតាក់តែងអារម្មណ៍ជាលក្ខណៈ វិញ្ញាណមានការដឹងអារម្មណ៍ជាលក្ខណៈ ។

វិតក្កៈ មានការលើកចិត្តឡើងកាន់អារម្មណ៍ជាលក្ខណៈ វិចារៈមានការតាមបបោសអង្អែលអារម្មណ៍ជាលក្ខណៈ បីតិមានការផ្សាយទៅជាលក្ខណៈសុខៈមានការត្រេកអរជាលក្ខណៈ ឯកគ្គតាចិត្តមានការមិនរាយមាយជាលក្ខណៈ ។ សទ្ធិន្ទ្រិយមានការបង្អោនចិត្តជឿជាលក្ខណៈ វីរិយិន្ទ្រិយមានការផ្គងជា

*លក្ខណៈ សតិន្ទ្រិយមានការរឭកជាលក្ខណៈ សមាធិន្ទ្រិយមានការមិនរវើរវាយជាលក្ខណៈ បញ្ញិន្ទ្រិយមានការដឹងនូវអារម្មណ៍ផ្សេងៗជាលក្ខណៈ ។*

*សទ្ធាពលៈ មានការមិនញាប់ញ័រក្នុងអារម្មណ៍ ជាទីតាំងនៃការមិនជឿជាលក្ខណៈ វីរិយពលៈ មានការមិនញាប់ញ័រក្នុងអារម្មណ៍ដែលជាទីតាំងនៃការខ្ជិលច្រអូសជាលក្ខណៈ សតិពលៈ មានការមិនញាប់ញ័រក្នុងអារម្មណ៍ដែលជាទីតាំងនៃការមិនមានសតិជាលក្ខណៈ សមាធិពលៈ មានការមិនញាប់ញ័រក្នុងអារម្មណ៍ដែលជាទីតាំងនៃការរវើរវាយជាលក្ខណៈ បញ្ញាពលៈ មានការមិនញាប់ញ័រក្នុងអារម្មណ៍ជាទីតាំងនៃអវិជ្ជាជាលក្ខណៈ ។*

*សតិសម្ពោជ្ឈង្គៈ មានការប្រាកដជាលក្ខណៈ ធម្មវិចយសម្ពោជ្ឈង្គៈ មានការជ្រើសរើសជាលក្ខណៈ វីរិយសម្ពោជ្ឈង្គៈ មានការផ្គងជាលក្ខណៈ បីតិ-សម្ពោជ្ឈង្គៈ មានការផ្សាយទៅជាលក្ខណៈ បស្សទ្ធិសម្ពោជ្ឈង្គៈ មានការស្ងប់ជាលក្ខណៈ សមាធិសម្ពោជ្ឈង្គៈ មានការមិនរាយមាយជាលក្ខណៈ ឧបេក្ខា-សម្ពោជ្ឈង្គៈ មានការសម្លឹងចំពោះជាលក្ខណៈ ។*

*សម្មាទិដ្ឋិ មានការឃើញត្រូវជាលក្ខណៈ សម្មាសង្កប្បៈ មានការលើកចិត្តឡើងកាន់អារម្មណ៍ជាលក្ខណៈ សម្មាវាចា មានការកំណត់កាន់យកជាលក្ខណៈ សម្មាកម្មន្តៈ មានការតាំងឡើងជាលក្ខណៈ សម្មាអាជីវៈ មានការផូរផង់ជាលក្ខណៈ សម្មាវាយាមៈ មានការផ្គងជាលក្ខណៈ សម្មាសតិ មានការប្រាកដជាលក្ខណៈ សម្មាសមាធិ មានការមិនរាយមាយជាលក្ខណៈ ។*

*អវិជ្ជា មានការមិនដឹងជាលក្ខណៈ សង្ខារ មានការតាំងចិត្តជាលក្ខណៈ*

វិញ្ញាណ មានការដឹងអារម្មណ៍ជាលក្ខណៈ នាម មានការបង្អោនទៅកាន់អារម្មណ៍ជាលក្ខណៈ រូប មានការបែកធ្លាយជាលក្ខណៈ សឡាយតនៈ មានការបន្តជាលក្ខណៈ ផស្សៈ មានការប៉ះខ្ទប់ជាលក្ខណៈ វេទនា មានការសោយអារម្មណ៍ជាលក្ខណៈ តណ្ហា មានភាពជាហេតុជាលក្ខណៈ ឧបាទាន មានការប្រកាន់មាំជាលក្ខណៈ ភព មានការកពូនជាលក្ខណៈ ជាតិ មានការកើតឡើងជាលក្ខណៈ ជរា មានការទ្រុឌទ្រោមជាលក្ខណៈ មរណៈ មានការឃ្លាតចាកភពដែលប្រាកដជាលក្ខណៈ ធាតុ មានភាពទទេជាលក្ខណៈ អាយតនៈ មានការបន្តជាលក្ខណៈ ។

សតិប្បដ្ឋាន មានការប្រាកដជាលក្ខណៈ សម្មប្បធាន មានការផ្តើមប្រារព្ធជាលក្ខណៈ ឥទ្ធិបាទ មានការសម្រេចជាលក្ខណៈ ឥន្ទ្រិយ មានភាពជាធំជាលក្ខណៈ ពលៈ មានការមិនញាប់ញ័រជាលក្ខណៈ ពោជ្ឈង្គៈ មានការនាំចេញចាកទុក្ខជាលក្ខណៈ មគ្គ មានភាពជាហេតុជាលក្ខណៈ សច្ចៈ មានការពិតជាលក្ខណៈ សមថៈ មានការមិនរាយមាយជាលក្ខណៈ វិបស្សនា មានការតាមពិចារណាឃើញជាលក្ខណៈ សមថៈនិងវិបស្សនា មានរសតែមួយជាលក្ខណៈ យុគនទ្ធៈ ( ធម៌ដែលប្រព្រឹត្តទៅជាគូ ) មានការមិនឈានកន្លងគ្នាជាលក្ខណៈ សីលវិសុទ្ធិ មានការសង្រួមជាលក្ខណៈ ចិត្តវិសុទ្ធិ មានការមិនរាយមាយជាលក្ខណៈ ទិដ្ឋិវិសុទ្ធិ មានការឃើញជាលក្ខណៈ ខយញ្ញាណ មានការកាត់បានជាសមុច្ឆេទជាលក្ខណៈ អនុប្បាទិញ្ញាណ មានការរម្ងាប់ជាលក្ខណៈ ។

ឆន្ទៈ មានមូលជាលក្ខណៈ មនសិការៈ មានការតាំងឡើងជាលក្ខណៈ

ផស្សៈ មានការប្រជុំជាលក្ខណៈ វេទនា មានការផ្សាយទៅក្នុងអារម្មណ៍ជាលក្ខណៈ សមាធិ មានភាពជាប្រធាន ( ប្រមុខ ) ជាលក្ខណៈ សតិ មានភាពជាធំ ( អធិបតី ) ជាលក្ខណៈ បញ្ញា មានភាពជាកំពូលជាងនោះជាលក្ខណៈ វិមុត្តិ មានសារៈជាលក្ខណៈ ព្រះនិព្វាន មានការឈមចុះកាន់អមតៈ មានបរិយោសានជាលក្ខណៈ វត្ថុនីមួយៗជាលក្ខណៈដែលពិតមិនប្រែប្រួល ។ ព្រះមានព្រះភាគយាងមកកាន់លក្ខណៈដែលពិតដោយញាណគតិ គឺទ្រង់សម្រេចទ្រង់ចាក់ធ្លុះដោយលំដាប់ មិនខុសក្លាំងក្លាត់ ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា តថាគត ។ ព្រះដ៏មានព្រះភាគទ្រង់ព្រះនាមថា តថាគត ព្រោះយាងមកកាន់លក្ខណៈដែលពិតយ៉ាងនេះ ដោយប្រការដូច្នេះ ។

ព្រះដ៏មានព្រះភាគទ្រង់ព្រះនាមថា តថាគត ព្រោះត្រាស់ដឹងធម៌ដែលពិត តាមសេចក្ដីពិតដូចម្ដេច ។

អរិយសច្ចៈ ៤ ឈ្មោះថាធម៌ពិត ដូចព្រះតម្រាស់ ( ក្នុងសំយុត្តនិកាយ មហាវារវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ ធម្មជាត ៤ យ៉ាងនេះជារបស់ពិត មិនប្រែប្រួល មិនក្លាយទៅជារបស់ដទៃឡើយ ។ ធម្មជាត ៤ គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា នេះជាទុក្ខ នុ៎ះជាធម្មជាតពិត មិនប្រែប្រួល មិនក្លាយទៅជារបស់ដទៃឡើយ ដូច្នេះ ។ សេចក្ដីពិស្ដារនៅមានត ។ ព្រះដ៏មានព្រះភាគត្រាស់ដឹងអរិយសច្ចៈ ៤ ហេតុនោះទើបទ្រង់ទទួលព្រះនាមថា តថាគត ព្រោះត្រាស់ដឹងធម៌ពិត ឯ **គត** សព្ទក្នុងទីនេះ មានអត្ថថា ត្រាស់ដឹង ។

ម្យ៉ាងទៀត សភាវៈដែលជរានិងមរណៈកើតនិងប្រជុំឡើង ព្រោះមាន

ជាតិជាបច្ច័យជាសភាវៈពិត មិនប្រែប្រួល មិនក្លាយជាបការៈដទៃ ។បេ។ សភាវៈដែលសង្ខារទាំងឡាយកើតនិងប្រជុំឡើង ព្រោះមានអវិជ្ជាជាបច្ច័យជាសភាវៈពិត មិនប្រែប្រួល មិនក្លាយជារបស់ដទៃ សភាវៈដែលអវិជ្ជាជាបច្ច័យដល់សង្ខារទាំងឡាយ ។បេ។ សភាវៈដែលជាតិជាបច្ច័យដល់ជរានិងមរណៈជាសភាវៈដែលពិត មិនប្រែប្រួល មិនក្លាយជាដទៃ ព្រះដ៏មានព្រះភាគត្រាស់ដឹងធម៌ពិតនោះទាំងអស់ ព្រោះហេតុនោះ ទើបបានទទួលព្រះនាមថា តថាគត ព្រោះត្រាស់ដឹងនូវធម៌ពិត ។ ព្រះដ៏មាន ព្រះភាគ ទ្រង់ព្រះនាមថា តថាគត ព្រោះត្រាស់ដឹងនូវធម៌ពិត តាមសេចក្តីពិត ដោយប្រការដូច្នេះ ។

ព្រះដ៏មានព្រះភាគទ្រង់ព្រះនាមថា តថាគត ព្រោះទ្រង់ឃើញអារម្មណ៍ដែលពិតដូចម្តេច ។

ព្រះដ៏មានព្រះភាគទ្រង់ដឹង ទ្រង់ឃើញដោយប្រការទាំងពួងនូវអារម្មណ៍ដែលជារូបារម្មណ៍ ដែលមកប្រាកដតាមចក្ខុទ្វារនៃពួកសត្វ មួយអន្លើដោយទេវតានិងមនុស្សក្នុងលោកនេះនិងទេវលោក ។បេ។ គឺរបស់សត្វទាំងឡាយមិនមានប្រមាណក្នុងលោកធាតុដែលមិនមានប្រមាណ ។ អារម្មណ៍នោះ ទ្រង់ដឹង ទ្រង់ឃើញយ៉ាងនេះ ទ្រង់ចែកដោយអំណាចឥដ្ឋារម្មណ៍និងអនិដ្ឋារម្មណ៍ជាដើម ឬដោយអំណាចបទដែលបានក្នុងអារម្មណ៍ ដែលបានឃើញ បានឮបានជ្រាបនិងបានដឹង ១៣ វារៈខ្វះ ៥២ ន័យខ្វះ ដែលមានឈ្មោះច្រើនដោយន័យ ( ក្នុងអភិធម្ម ធម្មសង្គណិ ) ថា រូបជារូបាយតនៈនោះ តើដូចម្តេច ។ រូបណា គឺពណ៌អាស្រ័យមហាភូតរូបទាំង ៤ ជាវត្ថុដែលអាចឃើញបាន

ប្រកបដោយការប៉ះពាល់ជាពណ៌ខៀវ លឿង ដូច្នេះជាដើម ។ រមែងជាអារម្មណ៍ដែលពិតតែម្យ៉ាងមិនប្រែប្រួល ។ ក្នុងអារម្មណ៍មានសំឡេងជាដើមដែលមកប្រាកដតាមសោតទ្វារជាដើមក៏ន័យនេះ សេចក្តីនេះសមដូចព្រះបាលីដែលព្រះដ៏មានព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ អារម្មណ៍ណាដែលលោកព្រមទាំងទេវលោក មារលោក ព្រហ្មលោក និងពពួកសត្វព្រមទាំងសមណព្រាហ្មណ៍និងមនុស្សជាសម្មតិទេពនិងមនុស្សដ៏សេស បានឃើញ ឮ ពាល់ត្រូវ ដឹងច្បាស់ បានដល់ ស្វែងរក ពិចារណារឿយៗដោយចិត្ត តថាគតដឹងច្បាស់នូវអារម្មណ៍នោះ ឯអារម្មណ៍នោះតថាគតដឹងប្រាកដហើយ អារម្មណ៍នោះមិនឋិតនៅក្នុងតថាគតទេ ដូច្នេះ ។ ព្រះដ៏មានព្រះភាគទ្រង់ព្រះនាមថា តថាគត ព្រោះទ្រង់ឃើញអារម្មណ៍ដែលពិត ដោយប្រការដូច្នេះ ។ ក្នុងព្រះតម្រាស់នេះ គប្បីជ្រាបសេចក្តីសម្រេចនៃពាក្យថា **តថាគត** ក្នុងអត្ថថា ទ្រង់ឃើញអារម្មណ៍ដែលពិត ។

ព្រះដ៏មានព្រះភាគទ្រង់ព្រះនាមថា តថាគត ព្រោះមានវាចាពិតដូចម្តេច ។

រាត្រីណា ដែលព្រះដ៏មានព្រះភាគគង់លើអបរាជិតបល្ល័ង្ក ក្នុងពោធិមណ្ឌលដ្ឋាន ទ្រង់ញាំញីមារទាំង ៤ ហើយត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណអស់រាត្រីណា ដែលទ្រង់បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុក្នុងចន្លោះដើមសាលព្រឹក្សទាំងគូក្នុងរវាងរាត្រីទាំងពីរនេះ គឺក្នុងកាលប្រមាណ ៤៥ វស្សា ព្រះវាចាណា ដែលព្រះដ៏មានព្រះភាគត្រាស់ទុកក្នុងបឋមពោធិកាលក្តី ក្នុងមជ្ឈិមពោធិកាលក្តី ក្នុងបច្ឆិមពោធិកាលក្តី គឺសុត្តៈ គេយ្យៈ ។បេ។

វេទល្ល: វាចាទាំងអស់នោះ បុគ្គលណាមួយតិះដៀលមិនបាន មិនខ្វះ មិនលើស ដោយអត្ថនិងដោយព្យញ្ជនៈបរិបូណ៌ដោយអាការៈទាំងពួង បន្ទាបង់នូវសេចក្តីស្រវឹង គឺរាគៈ ទោសៈ មោហៈក្នុងព្រះវាចានោះ មិនមានការក្រាំងក្រាត់សូម្បីប៉ុនចុងរោមទ្រាយ ព្រះវាចាទាំងអស់រមែងពិតតែម្យ៉ាង មិនប្រែប្រួល មិនក្លាយជាដទៃ ដូចប្រថាប់ទុកដោយត្រាតែមួយ ដូចវាល់ដោយនាឡិតែមួយ ដូចថ្លឹងដោយជញ្ជីងតែមួយ ដោយហេតុនោះទើបទ្រង់ត្រាស់ទុក ( ក្នុងទីឃនិកាយ បាដិកវគ្គ ) ថា ម្នាលចុន្ទ តថាគតត្រាស់ដឹងនូវសម្មាសម្ពោធិដ៏ប្រសើរក្នុងវេលាយប់ណាផង បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុក្នុងវេលាយប់ណាផង រមែងសម្តែងហៅ ចន្លួលបង្ហាញនូវហេតុណាក្នុងចន្លោះនុ៎ះ ហេតុទាំងអស់នោះ សុទ្ធតែពិត មិនមែនត្រឡប់ទៅជាដទៃឡើយ ហេតុដូច្នោះហើយបានជាគេហៅថា ព្រះតថាគត ដូច្នេះ ។ ក្នុងទីនេះ សព្ទថា **គត** មានអត្ថស្មើនឹង **គទ** ប្រែថា វាចាព្រះដ៏មានព្រះភាគទ្រង់ព្រះនាមថា **តថាគត** ព្រោះមានវាចាពិតយ៉ាងនេះដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត គប្បីជ្រាបការសម្រេចបទ ក្នុងអត្ថនោះយ៉ាងនេះថា **អាគទនំ** ជា **អាគទោ** ប្រែថា វាចា មានវិគ្គហៈថា ឈ្មោះថា តថាគត ព្រោះមានវាចាពិត មិនវិបរិត ដោយផ្លាស់ **ទ** ជា **ត** ។

ព្រះដ៏មានព្រះភាគទ្រង់ព្រះនាមថា តថាគត ព្រោះទ្រង់ធ្វើយ៉ាងនោះ តើដូចម្តេច ។

មែនពិត ព្រះដ៏មានព្រះភាគទ្រង់មានព្រះវរកាយត្រូវជាមួយព្រះវាចា ទ្រង់

មានព្រះវាចាត្រូវជាមួយព្រះកាយ ព្រោះហេតុនោះ ទ្រង់មានព្រះវាចាយ៉ាងណា ទ្រង់ក៏ធ្វើយ៉ាងនោះ ទ្រង់ធ្វើយ៉ាងណា ទ្រង់ក៏មានព្រះវាចាយ៉ាងនោះ ទ្រង់ជាបុគ្គលយ៉ាងនេះ ទ្រង់មានព្រះវាចាយ៉ាងណា ព្រះវរកាយក៏ប្រព្រឹត្តទៅ អធិប្បាយថា ទ្រង់ប្រព្រឹត្តយ៉ាងនោះ ព្រះវរកាយយ៉ាងណា ព្រះវាចាក៏ទ្រង់ប្រព្រឹត្តទៅយ៉ាងនោះ ដោយហេតុនោះ ទើបទ្រង់ព្រះនាមថា តថាគត ។ ដោយហេតុនោះ ទើបទ្រង់ត្រាស់ទុក ( ក្នុងអង្គុត្តរនិកាយចតុក្កនិបាត ) ថា ម្នាលភិក្ខុទាំងឡាយ តថាគតថាយ៉ាងណា ធ្វើយ៉ាងនោះ ធ្វើយ៉ាងណា ថាយ៉ាងនោះ ថាយ៉ាងណា ធ្វើយ៉ាងនោះ ធ្វើយ៉ាងណា ថាយ៉ាងនោះ ហេតុនោះទើបបានជាគេហៅថា តថាគត ដូច្នេះ ។ ព្រះដ៏មានព្រះភាគទ្រង់ព្រះនាមថា តថាគត ព្រោះទ្រង់ធ្វើយ៉ាងនោះ ដោយប្រការដូច្នេះ ។

ព្រះដ៏មានព្រះភាគទ្រង់ព្រះនាមថា តថាគត ព្រោះទ្រង់គ្របសង្កត់ដូចម្តេច ។

ព្រះដ៏មានព្រះភាគ ទ្រង់គ្របសង្កត់សព្វសត្វ ខាងលើដល់ភវគ្គព្រហ្ម ខាងក្រោមដល់អវីចិ ខាងទទឹងក្នុងលោកធាតុប្រមាណមិនបាន ដោយសីល ដោយសមាធិ ដោយបញ្ញា ដោយវិមុត្តិនិងដោយវិមុត្តិញ្ញាណទស្សនៈ ការថ្លឹង ឬប្រមាណទ្រង់បានមិនមាន ទ្រង់មិនមានបុគ្គលណាប្រៀបធៀបបាន ដែលបុគ្គលណាមួយប្រមាណមិនបាន ជាអគ្គបុគ្គល ជាព្រះរាជានៃព្រះរាជា ជាទេវតានៃទេវតា ជាសក្កៈនៃសក្កៈ ជាព្រហ្មនៃព្រហ្មទាំងឡាយ ដោយហេតុនោះ ទើបទ្រង់ត្រាស់ទុក ( ក្នុងអង្គុត្តរនិកាយចតុក្កនិបាត ) ថា ម្នាលភិក្ខុទាំងឡាយ

តថាគតជាអ្នកគ្របសង្កត់ អង់អាច ជាអ្នកឃើញពិត មានអំណាចគ្របសង្កត់លោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេសបានហេតុ នោះបានជាគេហៅថាតថាគត ដូច្នេះ ។

សេចក្តីនោះ គប្បីជ្រាបការសម្រេចបទយ៉ាងនេះ **អគទោ** ប្រែថា ឱសថដូច **អគទោ** ដែលប្រែថា វាចា ឱសថនេះគឺអ្វី គឺទេសនាវិលាសនិងការសន្សំបុណ្យ ។ ដ្បិតថា ព្រះដ៏មានព្រះភាគអង្គនេះ ទ្រង់គ្របសង្កត់នូវបុគ្គលដែលមានវាទៈផ្សុយទាំងអស់ក្នុងលោក ព្រមទាំងទេវលោក ដូចគ្រូពេទ្យមានអានុភាពច្រើន គ្របសង្កត់ពស់ទាំងឡាយដោយទិព្វឱសថ ដូច្នោះ ។ បណ្ឌិតគប្បីជ្រាបថា ព្រះដ៏មានព្រះភាគទ្រង់ព្រះនាមថា តថាគត ព្រោះថាទ្រង់មានព្រះឱសថ គឺទេសនាវិលាសនិងសម្រេចមកអំពីបុណ្យដែលពិត មិនវិបរិតក្នុងការគ្របសង្កត់លោកទាំងពួងដូច្នេះ ព្រោះផ្លាស់ **ឧ** អក្ខរៈ ជា **ត** អក្ខរៈ ។ ព្រះដ៏មានព្រះភាគទ្រង់ព្រះនាមថា តថាគត ព្រោះអត្ថថា ទ្រង់គ្របសង្កត់ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត ព្រះដ៏មានព្រះភាគទ្រង់ព្រះនាមថា តថាគត ព្រោះយាងទៅដោយកិរិយាដែលពិតក៏មាន ទ្រង់ព្រះនាមថា តថាគត ព្រោះទ្រង់ដល់នូវកិរិយាដែលពិតក៏មាន ។

បទថា **គតោ** សេចក្តីថា ឈមចុះ ប្រព្រឹត្តទៅកន្លង សម្រេច បដិបត្តិ ។ ក្នុង ៤ យ៉ាងនោះ ព្រះដ៏មានព្រះភាគទ្រង់ព្រះនាមថា តថាគត ព្រោះទ្រង់ទៅ

គឺទ្រង់ឈមចុះនូវលោកទាំងពួង ដោយតីរណប្បរិញ្ញា គឺដោយកិរិយាដែលពិត ។ ទ្រង់ព្រះនាមថា តថាគត ព្រោះទ្រង់ទៅ គឺទ្រង់កន្លងនូវលោកសមុទយៈ ដោយបហានប្បរិញ្ញា គឺដោយកិរិយាដែលពិត ។ ទ្រង់ព្រះនាមថា តថាគត ព្រោះទ្រង់ទៅ គឺទ្រង់សម្រេចលោកនិរោធដោយសច្ឆិកិរិយា គឺដោយកិរិយាដែលពិត ទ្រង់ព្រះនាមថា តថាគត ព្រោះទ្រង់ទៅ គឺទ្រង់បដិបត្តិបដិបទាដែលឲ្យដល់នូវលោកនិរោធ គឺកិរិយាដែលពិត ដោយហេតុនោះ ព្រះតម្រាស់ណាដែលព្រះដ៏មានព្រះភាគត្រាស់ទុក ( ក្នុងអង្គុត្តរនិកាយចតុក្កនិបាត ) ថា ម្នាលភិក្ខុទាំងឡាយ លោក ( គឺទុក្ខសច្ច ) តថាគតបានត្រាស់ដឹងហើយ តថាគតផុតចាកលោក ( គឺទុក្ខសច្ច ) ហើយ ម្នាលភិក្ខុទាំងឡាយ លោកសមុទយៈតថាគតបានត្រាស់ដឹងហើយ លោកសមុទយៈ តថាគតបានលះបង់ហើយ ម្នាលភិក្ខុទាំងឡាយ លោកនិរោធៈ តថាគតបានត្រាស់ដឹងហើយ លោកនិរោធៈ តថាគតបានធ្វើឲ្យជាក់ច្បាស់ហើយ ម្នាលភិក្ខុទាំងឡាយ លោកនិរោធគាមិនីបដិបទា តថាគតបានត្រាស់ដឹងហើយ លោកនិរោធគាមិនីបដិបទា តថាគតបានចម្រើនហើយ ។ ម្នាលភិក្ខុទាំងឡាយ អារម្មណ៍ណាដែលលោកព្រមទាំងទេវលោក ។បេ។ អារម្មណ៍នោះ តថាគតបានដឹងជាក់ស្តែងហើយ ដោយសារចិត្ត ព្រោះហេតុនោះ បានជាគេហៅថា តថាគត ដូច្នេះ ។ គប្បីជ្រាបអត្ថនៃព្រះតម្រាស់នោះ យ៉ាងនេះ ។ មួយវិញទៀត សេចក្តីនេះក៏ត្រឹមតែជាមាតិកាដែលសម្តែងថា ពាក្យថា តថាគត ជាព្រះនាមរបស់ព្រះតថាគតប៉ុណ្ណោះដែលពិត ព្រះតថាគតប៉ុណ្ណោះ ទើបពណ៌នាភាវៈដែលព្រះតថាគត

មានព្រះនាមថា តថាគត ដោយអាការៈទាំងពួងបាន ។ម្យ៉ាងទៀត ព្រោះព្រះពុទ្ធទាំងពួងជាអ្នកមានព្រះគុណ គឺភាពជាតថាគតស្មើដូចគ្នា ព្រោះហេតុនោះ ទើបប្រើពាក្យថា តថាគត បានដូចគ្នានឹងព្រះពុទ្ធគ្រប់អង្គ ។

បទថា **អរហាន្តោ** សេចក្តីថា ព្រះតថាគតឈ្មោះថាជាព្រះអរហន្ត ព្រោះជាអ្នកឆ្ងាយចាកកិលេសទាំងឡាយ ព្រោះទ្រង់ទម្លាយសត្រូវទាំងឡាយ ព្រោះទ្រង់កាច់បំបាក់នូវសង្សារចក្ក ព្រោះទ្រង់គួរដល់បច្ច័យជាដើម និងព្រោះមិនធ្វើបាបក្នុងទីស្ងាត់ ។ មែនពិត ព្រះតថាគតទ្រង់ឆ្ងាយ គឺទ្រង់តាំងនៅក្នុងទីឆ្ងាយចាកកិលេសទាំងឡាយ ព្រោះទ្រង់កម្ចាត់កិលេសទាំងឡាយ មួយអន្លើដោយវាសនាបានដោយមគ្គ ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា **អរហាន្តោ** ព្រោះទ្រង់ឆ្ងាយចាកកិលេស ។

ព្រះលោកនាថអង្គនោះ ទ្រង់ឈ្មោះថាឆ្ងាយចាកកិលេស ព្រោះ
ជាបុគ្គលមិនចូលរួមជាមួយកិលេស ដែលសត្វលោកតែង
ចូលរួម ព្រោះទ្រង់មិនចូលរួមជាមួយទោសទាំងឡាយ ដោយ
ហេតុនោះ ទើបទ្រង់ព្រះនាមថា អរហំ ដូច្នេះ ។

ម្យ៉ាងទៀត សត្រូវគឺកិលេសទាំងនោះ ព្រះតថាគតអង្គនោះទ្រង់កម្ចាត់ហើយដោយមគ្គ ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា អរហន្ត ព្រោះទ្រង់កម្ចាត់សត្រូវទាំងឡាយ ។

ព្រោះសត្រូវទាំងពួង ពោលគឺរាគៈជាដើម ព្រះលោកនាថទ្រង់
កម្ចាត់ហើយដោយសស្ត្រា គឺបញ្ញា ព្រោះហេតុនោះ ទើប

ទ្រង់ព្រះនាមថា អរហំ ដូច្នេះ ។

ម្យ៉ាងទៀត សង្សារចក្កនោះមានដុំសម្រេចដោយអវិជ្ជានិងភវតណ្ហា មានកាំ គឺបុញ្ញាភិសង្ខារជាដើម មានខ្នងកង់ គឺជរានិងមរណៈ ដែលក្ងៀសម្រេចដោយអាសវសមុទយៈ វិតរុំទុកក្នុងរថគឺភព ៣ វិលទៅអស់កាលមិនមានខាងដើមនៃសង្សារចក្កនោះ ព្រះតថាគតនោះ ប្រថាប់ឈរលើផែនដី គឺសីលដោយព្រះយុគលបាទ គឺវិរិយៈត្រង់ពោធិមណ្ឌលដ្ឋាន ទ្រង់កាន់ពូថៅ គឺញាណដែលធ្វើនូវការអស់ទៅនៃកម្មដោយព្រះហស្តគឺសទ្ធា ទ្រង់កាប់ក្របែលហើយ ហេតុនោះ ទើបព្រះនាមថា **អរហន្ត** ។

ព្រោះកាំនៃសង្សារចក្ក ដែលព្រះលោកនាថទ្រង់កាប់ក្របែល
ហើយដោយដាវ គឺបញ្ញា ដោយហេតុនោះ ទើបទ្រង់បាននាម
ថា **អរហំ** ដូច្នេះ ។

ម្យ៉ាងទៀត ព្រះតថាគតគួរដល់បច្ច័យ មានចីវរជាដើម និងការបូជាពិសេស ព្រោះទ្រង់ជាអគ្គទក្ខិណេយ្យបុគ្គល ព្រោះហេតុនោះឯង កាលព្រះតថាគតកើតឡើងហើយ ទេវតានិងមនុស្សដែលមានសក្តិធំទាំងឡាយ ក៏មិនបូជាក្នុងទីដទៃ ។ ពិតយ៉ាងនោះ សហម្បតីព្រហ្ម ទ្រង់បូជាព្រះតថាគតដោយកម្រងរតនៈ ប្រមាណប៉ុនភ្នំសិនេរុ ។ ទេវតានិងមនុស្សដទៃៗ មានព្រះបាទពិម្ពិសារនិងព្រះបាទបសេនទិកោសលជាដើម បូជាតាមកម្លាំង ។ ព្រះបាទអសោកមហារាជទ្រង់ក៏លះព្រះរាជទ្រព្យ ៩៦ កោដិ សាងវិហារ ៨៤០០០ ពេញជម្ពូទ្វីប ឧទ្ទិសព្រះដ៏មានព្រះភាគ ទោះបីទ្រង់បរិនិព្វានហើយ ចាំបាច់ពោលថ្វី

ដល់ការបូជាពិសេសនៃជនដទៃៗ ហេតុនោះទើបទ្រង់ព្រះនាមថា **អរហន្ត** ព្រោះជាអ្នកគួរដល់បច្ច័យជាដើម ។

ព្រោះព្រះលោកនាថអង្គនោះ គួរដល់ការបូជាពិសេសនិង
ដោយបច្ច័យទាំងឡាយ ហេតុនោះ ទើបព្រះជិនស្រីគួរដល់
ព្រះនាមនេះថា អរហំ ក្នុងលោក តាមសមគួរដល់អត្ថ
ដូច្នេះ ។

បុគ្គលពាលដែលសម្គាល់ខ្លួនថាជាបណ្ឌិតពួកខ្លះក្នុងលោក ធ្វើនូវបាបក្នុងទីស្ងាត់ ព្រោះខ្លាចពាក្យតិះដៀលយ៉ាងណា ព្រះតថាគតមិនធ្វើបាបនោះ ក្នុងកាលណាឡើយ ហេតុនោះទើបទ្រង់ព្រះនាមថា **អរហន្ត** ព្រោះមិនធ្វើបាបក្នុងទីស្ងាត់ ។

ព្រោះទីកំបាំងក្នុងការធ្វើបាប មិនមានដល់ព្រះតថាគត ដែល
ជាបុគ្គលនឹងធឹង ដោយហេតុនោះ ទើបព្រះតថាគតប្រាកដ
នាមថា អរហំ ព្រោះមិនមានទីកំបាំង ។

ក្នុងទីទាំងពួង ក៏ពោលទុកយ៉ាងនេះថា

ព្រោះទ្រង់ឆ្ងាយចាកសត្រូវ គឺកិលេសនិងព្រោះទ្រង់ធ្វើការ
កម្ចាត់នូវសត្រូវ គឺកិលេសហើយ ព្រះមុនីនោះទ្រង់កាច់
បំបាក់នូវកម្មនៃសង្សារចក្កបានហើយ ជាអ្នកគួរដល់បច្ច័យ
ជាដើម ទ្រង់មិនធ្វើបាបទាំងឡាយក្នុងទីស្ងាត់ ហេតុនោះ
ទើបទ្រង់ព្រះនាមថា អរហំ ដូច្នេះ ។

ព្រោះព្រះពុទ្ធទាំងពួង ជាអ្នកស្មើគ្នាដោយគុណ គឺភាពជាព្រះអរហន្ត ហេតុនោះ ទើបព្រះសារីបុត្តត្រូវពោលថា **អរហន្តោ** ដោយអំណាចនៃព្រះពុទ្ធទាំងពួង ។ បទថា **សម្មាសម្ពុទ្ធោ** សេចក្តីថា ឈ្មោះថា **សម្មាសម្ពុទ្ធោ** ព្រោះត្រាស់ដឹងធម៌ទាំងពួងដោយប្រពៃនិងដោយព្រះអង្គឯង ។ ពិតយ៉ាងនោះ ព្រះតថាគតនេះ ត្រាស់ដឹងដោយប្រពៃនិងដោយព្រះអង្គឯងនូវធម៌ទាំងពួង គឺនូវធម៌ដែលគួរដឹងក្រៃលែង ដោយភាពជាធម៌ដែលគួរដឹងក្រៃលែងនូវធម៌ដែលកំណត់ដឹង ដោយភាពជាធម៌ដែលគួរកំណត់ដឹងនូវធម៌ដែលគួរលះដោយភាពជាធម៌ដែលគួរលះនូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ដោយភាពជាធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់និងនូវធម៌ដែលគួរចម្រើនដោយភាពជាធម៌ដែលគួរចម្រើន ព្រោះហេតុនោះឯង ទើបទ្រង់ត្រាស់ទុក ( ក្នុងខុទ្ទកនិកាយសុត្តនិបាត ) ថា

វិជ្ជានិងវិមុត្តិដែលគប្បីដឹងច្បាស់ តថាគតដឹងច្បាស់ហើយ
មគ្គសច្ចដែលគប្បីចម្រើន តថាគតបានចម្រើនហើយ សមុ-
ទយសច្ចដែលគប្បីលះ តថាគតលះបង់ហើយ ម្នាលព្រាហ្មណ៍
ព្រោះហេតុនោះ ទើបតថាគតឈ្មោះថា ពុទ្ធៈ ដូច្នេះ ។

ម្យ៉ាងទៀត ព្រះដ៏មានព្រះភាគអង្គនោះ ត្រាស់ដឹងដោយប្រពៃនិងដោយព្រះអង្គឯងនូវធម៌ទាំងឡាយ សូម្បីដោយការលើកឡើងជាបទៗ យ៉ាងនេះថា ចក្ខុឈ្មោះថា ទុក្ខសច្ចៈ តណ្ហាមានមកអំពីខាងដើម ជាសមុដ្ឋានដោយភាពជាហេតុនៃចក្ខុនោះ ឈ្មោះថា **សមុទយសច្ចៈ** ការមិនប្រព្រឹត្តទៅនៃទុក្ខសច្ចៈនិងសមុទយសច្ចៈទាំងពីរ ឈ្មោះថា **និរោធសច្ច** បដិបទាជាគ្រឿងដឹងច្បាស់នូវ

និរោធ ឈ្មោះថា **មគ្គសច្ច** ក្នុងសោតៈ យានៈ ដ្បិត កាយនិងមនោ ក៏ន័យនេះ ។

ម្យ៉ាងទៀត អាយតនៈ ៦ មានរូបាយតនៈជាដើម ពួកនៃវិញ្ញាណ ៦ មានចក្ខុវិញ្ញាណជាដើម ផស្សៈ ៦ មានចក្ខុសម្ផស្សៈជាដើម វេទនា ៦ មានចក្ខុសម្ផស្សជាវេទនាជាដើម សញ្ញា ៦ មានរូបសញ្ញាជាដើម ចេតនា ៦ មានរូបសញ្ចេតនាជាដើម វិតក្ក ៦ មានរូបវិតក្កជាដើម វិចារៈ ៦ មានរូបវិចារៈជាដើម ខន្ធ ៥ មានរូបក្ខន្ធជាដើម កសិណ ១០ អនុស្សតិ ១០ សញ្ញា ១០ មានឧទ្ធុមាតកសញ្ញាជាដើម អាការៈ ៣២ មានសក់ជាដើម អាយតនៈ ១២ ធាតុ ១៨ ភព ៩ មានកាមភពជាដើម ឈាន ៤ មានបឋមជ្ឈានជាដើម អប្បមញ្ញា ៤ មានមេត្តាភាវនាជាដើម អរូបសមាបត្តិ ៤ ។ អង្គនៃបដិច្ចសមុប្បាទដោយបដិលោម មានជរានិងមរណៈជាដើម ដោយអនុលោម មានអវិជ្ជាជាដើម គប្បីប្រកបដោយន័យនេះដូចគ្នា ។

ក្នុងបទទាំងនោះ មានការប្រកបសេចក្ដីដោយចំពោះបទដូចតទៅនេះថា ព្រះដ៏មានព្រះភាគអង្គនោះត្រាស់ដឹងគឺតាមត្រាស់ដឹង បានដល់ ទ្រង់ចាក់ធ្លុះដោយប្រពៃនិងដោយព្រះអង្គឯងនូវធម៌ទាំងពួង ដោយការលើកឡើងជាបទៗយ៉ាងនេះថា ជរានិងមរណៈឈ្មោះថា **ទុក្ខសច្ច** ជាតិ ឈ្មោះថា **សមុទយសច្ច** ការរលាស់ចេញនូវសច្ចៈទាំង ២ ឈ្មោះថា **និរោធសច្ច** បដិបទាជាគ្រឿងដឹងច្បាស់នូវនិរោធ ឈ្មោះថា **មគ្គសច្ច** ឬឈ្មោះថា សម្មាសម្ពុទ្ធដោយអំណាចនៃវិមោក្ខន្តិកញ្ញាណ ព្រោះត្រាស់ដឹងដោយប្រពៃនិងដោយព្រះអង្គឯងនូវបទ

*ដែលគួរទូន្មានណាមួយ ដែលមានទាំងអស់ ឯការចែកបទទាំងនោះ នឹងមានច្បាស់ខាងមុខនោះឯង ព្រោះព្រះពុទ្ធទាំងពួងជាអ្នកស្មើដោយគុណនៃព្រះសម្មាសម្ពុទ្ធ ហេតុនោះទើបព្រះថេរៈពោលថា* **សម្មាសម្ពុទ្ធា** *ដោយអំណាចនៃព្រះពុទ្ធទាំងពួង ។*

*បទថា* **មោនេន** *សេចក្ដីថា មែនពិត បុគ្គលដែលឈ្មោះថាជាមុនី ដោយភាពជាអ្នកស្ងប់ស្ងៀមដោយមគ្គញាណ ពោលគឺមោនេយ្យបដិបទាក៏ពិត តែក្នុងទីនេះ បទថា* **មោនេន** *លោកពោលសំដៅយកតុណ្ហីភាព ។*

*បទថា* **មូឡ្ហរូបោ** *បានដល់ ជាបុគ្គលទទេ ។ បទថា* **អវិទ្ទសុ** *បានដល់ មិនមែនជាអ្នកដឹង ព្រោះថាបុគ្គលសូម្បីជាអ្នកនៅស្ងៀមបែបនេះ ក៏មិនឈ្មោះថាជាមុនី ។ម្យ៉ាងទៀត រមែងមិនឈ្មោះថា មុនី ដោយភាពជាអ្នកស្ងៀម អធិប្បាយថា ភាពជាបុគ្គលទទេនិងភាពជាបុគ្គលមិនដឹង ។*

*បទថា* **យោ ច តុលំវ បគ្គយ្ហ** *សេចក្ដីថា ដូចអ្នកឈរកាន់គ្រឿងថ្លឹង បើធ្ងន់ក៏ដកចេញ បើខ្វះក៏បន្ថែមយ៉ាងណា បុគ្គលនាំទៅ គឺវៀរចាកអំពើអាក្រក់ ដូចបុគ្គលថ្លឹងយកចំណែកដែលលើសចេញ ញ៉ាំងសេចក្ដីល្អឲ្យពេញដូចបុគ្គលថ្លឹងបន្ថែមចំណែកដែលខ្វះខាតឲ្យពេញដូច្នោះ អធិប្បាយថា កាលបុគ្គលកំពុងធ្វើយ៉ាងនេះ កាន់យកធម៌ដ៏ប្រសើរ គឺឧត្តមនោះឯង ពោលគឺសីល សមាធិ បញ្ញា វិមុត្តិ វិមុត្តិញាណទស្សនៈ វៀរនូវបាប គឺអកុសលទាំងឡាយ បុគ្គលនោះឈ្មោះថា មុនី ។*

*បទថា* **តេន សោ មុនិ** *សេចក្ដីថា ប្រសិនបើសួរថា ព្រោះហេតុអ្វី*

បុគ្គលនោះឈ្មោះថាជាមុនី គប្បីតបថា បុគ្គលនោះឈ្មោះថាជាមុនី ព្រោះហេតុដែលពោលហើយខាងដើមនោះ ។

បទថា **យោ មុនាតិ ឧភោ លោកេ** សេចក្តីថា បុគ្គលណារមែងដឹងអត្ថទាំងពីរនេះក្នុងខន្ធលោកជាដើម ដោយន័យជាដើមថា ទាំងនេះជាខន្ធមានខាងក្នុង ទាំងនេះខាងក្រៅដូច្នេះ ដូចមនុស្សលើកជញ្ជីងឡើងហើយថ្លឹងដូច្នោះ ។

បទថា **មុនិ តេន បវុច្ចតិ** សេចក្តីថា ហៅថា មុនី ក៏ដោយហេតុនោះៗឯង ។ បទថា **អសតញ្ច** ជាដើម មានសេចក្តីដូចតទៅនេះថា ធម៌របស់អសប្បុរសនិងរបស់សប្បុរសផ្សេងគ្នាដោយជាអកុសលនិងកុសល បុគ្គលនោះដឹងនូវធម៌អសប្បុរសនិងសប្បុរសនោះ ដោយញាណជាគ្រឿងថ្លឹះបញ្ចាំងក្នុងលោកទាំងពួងនេះថាជាខាងក្នុងនិងខាងក្រៅហើយកន្លងបង់ គឺឈានកន្លងនូវធម៌ជាគ្រឿងជាប់ជំពាក់ ៧ យ៉ាង មានរាគៈជាដើម និងសំណាញ់ ២ យ៉ាង គឺតណ្ហានិងទិដ្ឋិហើយតាំងនៅ ព្រោះដឹងនូវធម៌ប្រសើរនោះឯង ឈ្មោះថាជាមុនី ព្រោះប្រកបដោយញាណជាគ្រឿងថ្លឹះបញ្ចាំងនោះ ពោលគឺមោនៈ ។

បទថា **ទេវមនុស្សេហិ បូជិតោ** នេះ ជាពាក្យសរសើរបុគ្គលនោះ ដ្បិតថា បុគ្គលនោះ ជាអ្នកគួរដល់ការបូជានៃទេវតានិងមនុស្សទាំងឡាយ ព្រោះជាមុនីមានអាសវៈអស់ហើយ ហេតុនោះទើបពោលយ៉ាងនេះ ។

[ ៦៨ ] បទថា **សង្គំ** ជាបទដើម បទថា **សត្ត សង្គានិ** ជាបទកំណត់ចំនួន ។ បទថា **រាគសង្គំ** សេចក្តីថា ឈ្មោះថា **រាគ** ព្រោះអត្ថថាត្រេកអរ ឈ្មោះថា **សង្គំ** ព្រោះអត្ថថា ឲ្យកើតនូវការបៀតបៀន ព្រោះមុត

*ចូលទៅខាងក្នុងនិងព្រោះដកចេញបានដោយលំបាក តម្រេកផង ជាព្រួញផង ព្រោះហេតុនោះ ទើបឈ្មោះថា* **រាគសល្លំ** *ៗ ក្នុង* **ទោសសល្លំ** *ជាដើមក៏មានន័យដូចគ្នា ៗ*

*បទថា* **អព្ពូឡ្ហសល្លោ** *ជាមូលបទ ៗ បទថា* **អព្ពុហិតសល្លោ** *បានដល់ នាំយកព្រួញចេញហើយ ៗ បទថា* **ឧទ្ធដសល្លោ** *បានដល់ ទាញព្រួញឡើង ៗ បទថា* **សមុទ្ធដសល្លោ** *លោកពោលដោយអំណាចឧបសគ្គ ៗ បទថា* **ឧប្បាដិតសល្លោ** *បានដល់ ដកនូវព្រួញឡើង ៗ បទថា* **សមុប្បាដិតសល្លោ** *លោកពោលដោយអំណាចឧបសគ្គ ៗ បទថា* **សក្កច្ចការី** *សេចក្តីថា ជាអ្នកធ្វើដោយគោរព ដោយអំណាចធ្វើដោយគោរពបុគ្គល ឬទេយ្យធម៌ដោយការចម្រើនកុសលធម៌មានទានជាដើម ៗ ជាអ្នកធ្វើរឿយៗ ដោយការធ្វើជាប់តគ្នាទៅ ៗ ជាអ្នកធ្វើមិនឈប់ដោយការធ្វើមិនឈប់បង្អង់ ៗ សត្វបង្កួយរត់ទៅបន្តិច ហើយឈប់បន្តិច មិនជាប់តគ្នា យ៉ាងណា បុគ្គលណាក្នុងមួយថ្ងៃ ឲ្យទានក្តី បូជាក្តី ស្តាប់ធម៌ក្តី ធ្វើសមណធម៌ក្តី មិនធ្វើយូរ មិនញ៉ាំងការធ្វើនោះឲ្យជាប់ត ឧបមេយ្យនេះ ក៏យ៉ាងនោះ ៗ បុគ្គលនោះ ហៅថា ជាអ្នកមិនធ្វើរឿយៗ ធ្វើហើយឈប់ ៗ បុគ្គលនេះមិនធ្វើយ៉ាងនោះ ព្រោះហេតុនោះ ទើបឈ្មោះថា ជាអ្នកធ្វើមិនឈប់ ៗ*

*បទថា* **អនោលីនវុត្តិកោ** *សេចក្តីថា ជាអ្នកមានការប្រព្រឹត្តធូរថយក៏មិនមែន ព្រោះមានការផ្សាយទៅ ពោលគឺការធ្វើមិនមានចន្លោះ ហេតុនោះ ទើបឈ្មោះថា ជាអ្នកមានការប្រព្រឹត្តមិនធូរថយ ៗ*

បទថា **អនិក្ខិត្តច្ឆន្ទោ** សេចក្តីថា ឈ្មោះថា **អនិក្ខិត្តច្ឆន្ទោ** ព្រោះការមិនដាក់ចុះឆន្ទៈក្នុងសេចក្តីព្យាយាមក្នុងការធ្វើកុសល ។

បទថា **អនិក្ខិត្តធុរោ** សេចក្តីថា ឈ្មោះថា **អនិក្ខិត្តធុរោ** ព្រោះមិនដាក់ធុរៈ គឺសេចក្តីព្យាយាម អធិប្បាយថា ជាអ្នកមានចិត្តមិនរួញរា ។

បទថា **យោ តត្ថ ឆន្ទោ ច វាយាមោ ច** សេចក្តីថា ការពេញចិត្តក្នុងធម៌ គឺភាពជាអ្នកប្រាថ្នាដើម្បីធ្វើ ។ សេចក្តីព្យាយាម ពោលគឺប្រកបសេចក្តីឧស្សាហ៍ដោយអំណាចការខ្នះខ្នែង និងភាពជាអ្នកឧស្សាហ៍ដោយអំណាចការខ្នះខ្នែងមានប្រមាណក្រៃលែងក្នុងកុសលធម៌ទាំងនោះ នេះឈ្មោះថា ការព្យាយាម ដោយអត្ថថា ទៅកាន់ត្រើយ នេះឈ្មោះថា ការឧស្សាហ៍ដោយអត្ថថា ទៅមុន នេះឈ្មោះថា ភាពជាបុគ្គលឧស្សាហ៍[១]ដោយអត្ថថា មានប្រមាណក្រៃលែង ។

បទថា **អប្បដិវានី ច** បានដល់ ការមិនថយក្រោយ ។ បទថា **សតិ ច សម្បជញ្ញញ្ច** សេចក្តីថា ឈ្មោះថា **សតិ** ព្រោះអត្ថថា រឭកបាន ឈ្មោះថា **សម្បជញ្ញ** ព្រោះអត្ថថា ដឹងច្បាស់ អធិប្បាយថា ដឹងដោយប្រការទាំងឡាយដោយជុំវិញ គប្បីជ្រាបប្រភេទដោយអំណាចនៃសម្បជញ្ញៈនេះ គឺសាត្ថកសម្បជញ្ញៈ សប្បាយសម្បជញ្ញៈ គោចរសម្បជញ្ញៈ អសម្មោហសម្បជញ្ញៈ ។ បទថា **អាតប្បំ** បានដល់ សេចក្តីព្យាយាមជាគ្រឿងដុតកិលេស ។ បទថា **បធានំ** បានដល់ សេចក្តីព្យាយាមដ៏ឧត្តម ។ បទថា **អធិដ្ឋានំ** បានដល់ ការ

---

១-បិដកខ្មែរថា សេចក្តីប្រឹងប្រែង ។

តាំងមាំក្នុងការធ្វើកុសល ។ បទថា **អនុយោគោ** បានដល់ ការប្រកបរឿយៗ ។ បទថា **អប្បមាទោ** បានដល់ ការមិនស្រវឹង គឺមិននៅប្រាសចាកសតិ ។

[ ៦៩ ] បទថា **ឥមំ លោកំ ឆាសីសតិ** ជាមូលបទ ។ បទថា **សកត្ត-ភាវំ** បានដល់ អត្តភាពរបស់ខ្លួន ។ បទថា **បរត្តភាវំ** បានដល់ អត្តភាពក្នុងបរលោក ។ រូប វេទនាជាដើមរបស់ខ្លួន គឺខន្ធ ៥ របស់ខ្លួន រូបនិងវេទនាជាដើមរបស់អ្នកដទៃ គឺខន្ធ ៥ ក្នុងបរលោក ។ បទថា **កាមធាតុំ** បានដល់ កាមភព ។ បទថា **រូបធាតុំ** បានដល់ រូបភព ។ បទថា **អរូបធាតុំ** បានដល់ អរូបភព ។ ដើម្បីសម្តែងទុក្ខដោយអំណាចនៃរូបនិងអរូបទៀត ព្រះថេរៈក៏ពោលកាមធាតុ រូបធាតុទុកមួយចំណែក ពោលអរូបធាតុទុកមួយចំណែក ។

បទថា **គតិំ វា** សេចក្តីថា គតិ ៥ លោកពោលដោយអំណាចជាទីតាំង ។ បទថា **ឧបបត្តិំ វា** សេចក្តីថា កំណើត ៤ លោកពោលដោយអំណាចការកើតឡើង ។ បទថា **បដិសន្ធិំ វា** សេចក្តីថា បដិសន្ធិលោកពោលដោយអំណាចការបន្តនៃភព ៣ ។ បទថា **ភវំ វា** លោកពោលដោយអំណាចកម្មនិងភព ។ បទថា **សំសារំ វា** លោកពោលដោយអំណាចមិនដាច់ខ្សែនៃខន្ធជាដើម ។ បទថា **វដ្តំ វា** សេចក្តីថា មិនសង្ស័យវដ្តៈ ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដូច្នេះឯង ។

**អដ្ឋកថា គុហដ្ឋកសុត្តនិទ្ទេសទី ២ ចប់**

# ទុដ្ឋដ្ឋកសុត្តនិទ្ទេស ទី ៣

[ ៧០ ] ( ព្រះមានព្រះភាគទ្រង់ត្រាស់ថា ) តិរ្ថិយពួកខ្លះ មានចិត្តខឹង ហើយជេរ ពួកជនឯទៀត មានចិត្តជឿថា មែន រមែងជេរតាម តែព្រះពុទ្ធជាមុនិមិនអើពើនូវវាទៈ ដែលកើតហើយ ព្រោះហេតុនោះ បង្គោល គឺកិលេសរបស់ព្រះពុទ្ធជាមុនិមិនមានក្នុងទីណាទេ ។

[ ៧១ ] ពាក្យថា តិរ្ថិយពួកខ្លះ មានចិត្តខឹងហើយជេរ គឺពួកតិរ្ថិយទាំងនោះ មានចិត្តខឹង មានចិត្តប្រទូស្ត មានចិត្តអាក់អន់ មានចិត្តអាក់អន់តប មានចិត្តបៀតបៀន មានចិត្តបៀតបៀនតប មានចិត្តគុំគួន មានចិត្តគុំគួនតប ហើយជេរប្រទេចនូវព្រះមានព្រះភាគនិងព្រះភិក្ខុសង្ឃ ដោយហេតុមិនពិត ហេតុនោះ ( ទ្រង់ត្រាស់ថា ) តិរ្ថិយពួកខ្លះ មានចិត្តខឹងហើយជេរ ។

[ ៧២ ] ពាក្យថា ពួកជនឯទៀត មានចិត្តជឿថាមែន រមែងជេរតាម គឺពួកជនណា ជឿ ជឿស៊ប់ ចុះចិត្តស៊ប់ តាមពាក្យនៃតិរ្ថិយទាំងនោះ មានចិត្តជឿថាមែន មានសេចក្តីសម្គាល់ថាមែន មានចិត្តជឿប្រាកដ មានសេចក្តីសម្គាល់ថា ប្រាកដ មានចិត្តថាទៀងទាត់ មានសេចក្តីសម្គាល់ថាទៀងទាត់ មានចិត្តថាពិត មានសេចក្តីសម្គាល់ថាពិត មានចិត្តថាមិនប្រែប្រួល មានសេចក្តីសម្គាល់ថា មិនប្រែប្រួល ហើយជេរប្រទេចនូវព្រះមានព្រះភាគនឹងព្រះភិក្ខុសង្ឃដោយហេតុមិនពិត ហេតុនោះ ( ទ្រង់ត្រាស់ថា ) ពួកជនឯទៀត មានចិត្តជឿថាមែន រមែងជឿតាម ។

[ ៧៣ ] ពាក្យថា ព្រះពុទ្ធជាមុនិ រមែងមិនអើពើនូវវាទៈដែលកើតឡើង គឺវាទៈនោះកើត កើតព្រម កើតហើយ កើតចំពោះហើយ កើតប្រាកដហើយ

ជាវាទៈលាន់កងរំពងអំពីសំណាក់បុគ្គលដទៃ ជាពាក្យជេរប្រទេចនូវព្រះមានព្រះភាគនិងព្រះភិក្ខុសង្ឃដោយហេតុមិនពិត ហេតុនោះ ( ទ្រង់ត្រាស់ថា ) នូវវាទៈដែលកើតហើយ ។ ពាក្យថា ព្រះពុទ្ធជាមុនិ រមែងមិនអើពើ សេចក្តីថា ញាណ លោកហៅថា មោនៈ បានដល់ប្រាជ្ញា ការដឹងច្បាស់ ។បេ។ សេចក្តីមិនវង្វេង ការពិចារណាធម៌ សេចក្តីឃើញត្រូវ ព្រះពុទ្ធជាមុនិប្រកបដោយញាណនោះ ឈ្មោះថា ទ្រង់ដល់នូវមោនៈ ។បេ។ ព្រះមានព្រះភាគនោះកន្លងនូវបណ្តាញ គឺសេចក្តីជាប់ ទើបឈ្មោះថា មុនិ ។ បុគ្គលណាអើពើនូវវាទៈ បុគ្គលនោះ រមែងអើពើនូវវាទៈដោយហេតុ ២ យ៉ាង ។ គឺបុគ្គលអ្នកបង្កទោស រមែងអើពើនូវវាទៈ ព្រោះភាពនៃខ្លួនជាអ្នកបង្កទោស ១ ។ មួយទៀត បុគ្គលត្រូវគេស្តី គេតិះដៀល រមែងខឹង គុំគួន តបត ធ្វើសេចក្តីក្រោធផង ទោសៈផង សេចក្តីអាក់អន់ផង ឲ្យប្រាកដថា អញជាអ្នកមិនបង្កទោស ១ ។ បុគ្គលណារមែងអើពើនូវវាទៈ បុគ្គលនោះរមែងអើពើនូវវាទៈដោយហេតុ ២ នេះឯង ។ ព្រះពុទ្ធជាមុនិ រមែងមិនអើពើនូវវាទៈដោយហេតុ ២ យ៉ាង ។ គឺព្រះពុទ្ធជាអ្នកមិនបង្កទោស រមែងមិនអើពើនូវវាទៈ ព្រោះភាពនៃព្រះអង្គជាអ្នកមិនបង្កទោស ១ ។ មួយទៀត ព្រះពុទ្ធកាលគេស្តី គេតិះដៀលរមែងមិនខឹង មិនគុំគួន មិនតបត ទាំងមិនធ្វើសេចក្តីក្រោធផង ទោសៈផង សេចក្តីអាក់អន់ផង ឲ្យប្រាកដថា អញជាអ្នកមិនបង្កទោស ១ ។ ព្រះពុទ្ធជាមុនិរមែងមិនអើពើ មិនរវល់ មិនកាន់យក មិនប៉ះពាល់ មិនប្រកាន់ទុកនូវវាទៈដោយហេតុ ២ នេះឯង ហេតុនោះ ( ទ្រង់ត្រាស់ថា ) ព្រះពុទ្ធជាមុនិ រមែងមិន

អើពើនូវវាទៈដែលកើតហើយ ។

[ ៧៤ ] អធិប្បាយពាក្យថា ព្រោះហេតុនោះ បង្គោលគឺកិលេសរបស់ព្រះពុទ្ធជាមុនិ មិនមានក្នុងទីណាទេ ត្រង់ពាក្យថា ព្រោះហេតុនោះ គឺព្រោះដំណើរនោះ ព្រោះការណ៍នោះ ព្រោះហេតុនោះ ព្រោះបច្ច័យនោះ ព្រោះនិទាននោះ ព្រះពុទ្ធជាមុនិ មិនមានព្រះហឫទ័យត្រូវកិលេសបៀតបៀន ឬបង្គោលគឺកិលេសកើតហើយទេ ។ ចេតោខីលៈ ( បង្គោលគឺកិលេសរបស់ចិត្ត ) ៥ យ៉ាង ក៏មិនមាន ខីលៈ ៣ យ៉ាង គឺរាគខីលៈ ទោសខីលៈ មោហខីលៈ មិនមាន អត្ថិមាន ឥតមាន លែងកើតមាន គឺព្រះពុទ្ធជាមុនិ បានលះបង់ ផ្តាច់ផ្តិល រម្ងាប់ ស្ងប់រម្ងាប់ មិនគួរដល់ការកើតទៀត ដុតដោយភ្លើងគឺញាណហើយ ។ ពាក្យថា ក្នុងទីណាមួយ គឺក្នុងកន្លែងណាមួយ ក្នុងតំបន់ណាមួយ ក្នុងទីខ្លះ ខាងក្នុងក្តី ខាងក្រៅក្តី ទាំងខាងក្នុង ខាងក្រៅក្តី ហេតុដូច្នោះ ( ទ្រង់ត្រាស់ថា ) ហេតុនោះ បង្គោលគឺកិលេសរបស់ព្រះពុទ្ធជាមុនិ មិនមានក្នុងទីណាទេ ។ ហេតុនោះ ព្រះមានព្រះភាគទ្រង់ត្រាស់ថា

តិរ្ថិយពួកខ្លះ មានចិត្តខឹង ហើយជនពួកជនឯទៀត មានចិត្ត
ជឿថា មែន រមែងជេរតាម តែព្រះពុទ្ធជាមុនិ មិនអើពើនូវ
វាទៈដែលកើតហើយ ព្រោះហេតុនោះ បង្គោលគឺកិលេស
របស់ព្រះពុទ្ធជាមុនិ មិនមានក្នុងទីណាទេ ដូច្នេះ ។

[ ៧៥ ] បុគ្គលគប្បីកន្លងនូវទិដ្ឋិរបស់ខ្លួន ដោយប្រការដូចម្តេចបាន បុគ្គលដែលត្រូវសេចក្តីប្រាថ្នាដឹកនាំ ឋិតនៅស៊ប់ក្នុងសេចក្តីពេញចិត្ត រមែងធ្វើ

នូវទិដ្ឋិទាំងឡាយ ឲ្យគ្រប់គ្រាន់ដោយខ្លួនឯង ដឹងយ៉ាងណាក៏ពោលយ៉ាងនោះ ។

[ ៧៦ ] ពាក្យថា បុគ្គលគប្បីកន្លងនូវទិដ្ឋិរបស់ខ្លួនដោយប្រការដូចម្តេចបាន អធិប្បាយថា ពួកតិរ្ថិយណា មានទិដ្ឋិយ៉ាងនេះ មានសេចក្តីគួរយ៉ាងនេះ មានសេចក្តីពេញចិត្តយ៉ាងនេះ មានលទ្ធិយ៉ាងនេះ មានអធ្យាស្រ័យយ៉ាងនេះ មានសេចក្តីប៉ុនប៉ងយ៉ាងនេះថា ពួកយើងនឹងសម្លាប់នាងសុន្ទរី បរិព្វាជិកា ហើយប្រកាសទោសរបស់ពួកសមណសក្យបុត្តិយ៍ កាលបើធ្វើយ៉ាងនេះ ពួកយើងនឹងប្រមូលយកនូវលាភ យស សក្ការៈ និងសេចក្តីរាប់អានទុំះបាន ទើបពួកតិរ្ថិយទាំងនោះ មិនអាចនឹងកន្លងនូវទិដ្ឋិរបស់ខ្លួន សេចក្តីគួររបស់ខ្លួន សេចក្តីពេញចិត្តរបស់ខ្លួន លទ្ធិរបស់ខ្លួន អធ្យាស្រ័យរបស់ខ្លួន សេចក្តីប៉ុនប៉ងរបស់ខ្លួនបានឡើយ ។ តាមពិតការមិនមានយសនោះឯង ក៏ត្រឡប់មកដល់ពួកតិរ្ថិយនោះវិញទេ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលគប្បីកន្លងនូវទិដ្ឋិរបស់ខ្លួនដោយប្រការដូចម្តេចបាន យ៉ាងនេះខ្លះ ។ មួយទៀត បុគ្គលណាមានវាទៈយ៉ាងនេះថា លោក គឺអត្តភាពទៀងទាត់ ការឃើញនេះឯងជាការពិត ការឃើញដទៃជាមោឃៈ បុគ្គលនោះ គប្បីកន្លង ឈានកន្លង កន្លងផុត ប្រព្រឹត្តកន្លងនូវទិដ្ឋិរបស់ខ្លួន សេចក្តីគួររបស់ខ្លួន សេចក្តីពេញចិត្តរបស់ខ្លួន លទ្ធិរបស់ខ្លួនអធ្យាស្រ័យរបស់ខ្លួន សេចក្តីប៉ុនប៉ងរបស់ខ្លួនដោយប្រការដូចម្តេចបាន ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ( ព្រោះថា ) ទិដ្ឋិនោះ ដែលបុគ្គលនោះធ្វើឲ្យពេញលេញ សមាទាន កាន់យក ស្ទាបអង្អែល ឋិតនៅស៊ប់ ជ្រុលជ្រប់ ចុះចិត្តស៊ប់ហើយ ដោយប្រការដូច្នោះ ហេតុនោះ ( ទ្រង់ត្រាស់ថា )

បុគ្គលគប្បីកន្លងនូវទិដ្ឋិរបស់ខ្លួន ដោយប្រការដូចម្ដេចបានយ៉ាងនេះខ្លះ ។ បុគ្គលណាមានវាទៈយ៉ាងនេះថា លោកទៀងទាត់ លោកមិនទៀងទាត់ លោកមានទីបំផុត លោកមិនមានទីបំផុត ជីវិតនោះ សរីរៈនោះ ជីវិតដទៃ សរីរៈដទៃ សត្វស្លាប់ទៅរមែងកើតទៀត សត្វស្លាប់ទៅរមែងមិនកើតទៀត សត្វស្លាប់ទៅកើតទៀតខ្លះ មិនកើតទៀតខ្លះ សត្វស្លាប់ទៅ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ការឃើញនេះឯងជាការពិត ការឃើញដទៃជាមោឃៈ បុគ្គលនោះ គប្បីកន្លង ឈានកន្លង កន្លងផុត ប្រព្រឹត្តកន្លងនូវទិដ្ឋិរបស់ខ្លួន សេចក្ដីគួររបស់ខ្លួន សេចក្ដីពេញចិត្តរបស់ខ្លួន លទ្ធិរបស់ខ្លួន អធ្យាស្រ័យរបស់ខ្លួន សេចក្ដីប៉ុនប៉ងរបស់ខ្លួន ដោយប្រការដូចម្ដេចបាន ។ ដំណើរនោះ តើព្រោះហេតុដូចម្ដេច ។ ( ព្រោះថា ) ទិដ្ឋិនោះ ដែលបុគ្គលនោះធ្វើឲ្យពេញលេញ សមាទាន កាន់យក ស្ទាបអង្អែល ឋិតនៅស៊ប់ ជ្រុលជ្រប់ ចុះចិត្តស៊ប់ហើយ ដូច្នេះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលគប្បីកន្លងនូវទិដ្ឋិរបស់ខ្លួនដោយប្រការដូចម្ដេចបាន យ៉ាងនេះខ្លះ ។

[ ៧៧ ] អធិប្បាយពាក្យថា បុគ្គលដែលត្រូវសេចក្ដីប្រាថ្នាដឹកនាំ ឋិតនៅស៊ប់ក្នុងសេចក្ដីពេញចិត្ត ត្រង់ពាក្យថា បុគ្គលដែលត្រូវសេចក្ដីប្រាថ្នាដឹកនាំ គឺបុគ្គលដែលត្រូវទិដ្ឋិរបស់ខ្លួន សេចក្ដីគួររបស់ខ្លួន សេចក្ដីពេញចិត្តរបស់ខ្លួន លទ្ធិរបស់ខ្លួន នាំទៅ នាំចេញទៅ បន្សាត់ទៅ ប្រមូលទៅ ។ បុគ្គលដែលហត្ថិយាន ឬរថយាន អស្សយាន ឬគោយាន អជយាន ឬមេណ្ឌកយាន ឱដ្ឋយាន ឬឃរយាន ( យានដែលទឹមដោយលា ) នាំទៅ នាំចេញទៅ បំផាយ

ទៅ ប្រមូលទៅ យ៉ាងណាមិញ បុគ្គលដែលត្រូវទិដ្ឋិរបស់ខ្លួន សេចក្ដីគួររបស់ខ្លួន សេចក្ដីពេញចិត្តរបស់ខ្លួន លទ្ធិរបស់ខ្លួន នាំទៅ នាំចេញទៅ បន្សាត់ទៅ ប្រមូលទៅ ក៏យ៉ាងនោះដែរ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលដែលត្រូវសេចក្ដីប្រាថ្នាដឹកនាំ ។ ពាក្យថា ឋិតនៅស៊ប់ក្នុងសេចក្ដីពេញចិត្ត គឺឋិតនៅស៊ប់ តាំងនៅស៊ប់ ជាប់ស្អិត ប្រកាន់ស៊ប់ ជ្រួលជ្រប់ ចុះស៊ប់ក្នុងទិដ្ឋិរបស់ខ្លួន ក្នុងសេចក្ដីគួររបស់ខ្លួន ក្នុងសេចក្ដីពេញចិត្តរបស់ខ្លួន ក្នុងលទ្ធិរបស់ខ្លួន ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលដែលត្រូវសេចក្ដីប្រាថ្នាដឹកនាំ ឋិតនៅស៊ប់ក្នុងសេចក្ដីពេញចិត្ត ។

[ ៧៨ ] ពាក្យថា រមែងធ្វើនូវទិដ្ឋិទាំងឡាយឲ្យគ្រប់គ្រាន់ដោយខ្លួនឯង គឺរមែងធ្វើនូវទិដ្ឋិឲ្យគ្រប់គ្រាន់ ធ្វើឲ្យបរិបូណ៌ ធ្វើមិនឲ្យខ្វះខាត ធ្វើឲ្យខ្ពស់ ឲ្យប្រសើរ ឲ្យវិសេស ឲ្យជាប្រធាន ឲ្យឧត្តម ឲ្យថ្លៃថ្លាដោយខ្លួនឯង បុគ្គលរមែងធ្វើនូវទិដ្ឋិឲ្យគ្រប់គ្រាន់ ធ្វើឲ្យបរិបូណ៌ ធ្វើមិនឲ្យខ្វះខាត ធ្វើឲ្យខ្ពស់ ឲ្យប្រសើរ ឲ្យវិសេស ឲ្យជាប្រធាន ឲ្យឧត្តម ឲ្យថ្លៃថ្លាដោយខ្លួនឯងថា សាស្ដានេះជាសព្វញ្ញូ ធ្វើនូវទិដ្ឋិឲ្យគ្រប់គ្រាន់ ធ្វើឲ្យបរិបូណ៌ ធ្វើមិនឲ្យខ្វះខាត ធ្វើឲ្យខ្ពស់ ឲ្យប្រសើរ ឲ្យវិសេស ឲ្យជាប្រធាន ឲ្យឧត្តម ឲ្យថ្លៃថ្លា រមែងញុំាងទិដ្ឋិឲ្យកើត ឲ្យកើតព្រម ឲ្យកើតឡើង ឲ្យកើតប្រាកដដោយខ្លួនឯងថា នេះជាធម៌ដែលខ្លួនសម្ដែងល្អហើយ នេះជាគណៈប្រតិបត្តិល្អហើយ នេះជាទិដ្ឋិដ៏ប្រសើរ នេះជាបដិបទាដែលបញ្ញត្តល្អហើយ នេះជាមគ្គ ជាឧបាយស្រោចស្រង់សត្វ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលធ្វើនូវទិដ្ឋិទាំងឡាយឲ្យគ្រប់គ្រាន់ដោយខ្លួន

ឯង ។

[ ៧៩ ] ពាក្យថា បុគ្គលដឹងយ៉ាងណា តែងពោលយ៉ាងនោះ គឺបុគ្គលដឹងយ៉ាងណា តែងពោល សម្តែង បរិយាយ បំភ្លឺ និយាយបញ្ចេញយ៉ាងនោះ ។ បុគ្គលដឹងយ៉ាងណាថា លោកទៀងទាត់ ការឃើញនេះឯងជាការពិត ការឃើញដទៃជាមោឃៈ ដូច្នេះ គប្បីពោលសម្តែង និយាយ បំភ្លឺ និយាយ-បញ្ចេញយ៉ាងនោះ ។ បុគ្គលដឹងយ៉ាងណាថា លោកមិនទៀងទាត់ ។បេ។ សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនមែនកើតទៀតក៏មិនមែន ការឃើញនេះឯងជាការពិត ការឃើញដទៃជាមោឃៈ ដូច្នេះ គប្បីពោល សម្តែង និយាយ បំភ្លឺ និយាយបញ្ចេញ យ៉ាងនោះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលដឹងយ៉ាងណា ពោលយ៉ាងនោះ ។ ហេតុនោះ ព្រះមានបុណ្យត្រាស់ថា

បុគ្គលគប្បីកន្លងនូវទិដ្ឋិរបស់ខ្លួន ដោយប្រការដូចម្តេចបាន
បុគ្គលដែលត្រូវសេចក្តីប្រាថ្នាដឹកនាំ ឋិតនៅស៊ប់ក្នុងសេចក្តី
ពេញចិត្ត រមែងធ្វើនូវទិដ្ឋិទាំងឡាយឲ្យគ្រប់គ្រាន់ដោយខ្លួនឯង
ដឹងយ៉ាងណា ក៏ពោលយ៉ាងនោះ ដូច្នេះ ។

[ ៨០ ] ជនណា ដែលគេមិនបានសាកសួរនូវសីលនិងវត្តរបស់ខ្លួនហើយ ពោលអួតប្រាប់ពួកបុគ្គលដទៃ ជនអ្នកឈ្លាសវៃទាំងឡាយ ពោលនូវជនដែលពោលអួតខ្លួនដោយខ្លួនឯងនោះថា ជាអ្នកមិនមានអរិយធម៌ ។

[ ៨១ ] អធិប្បាយពាក្យថា ជនណា ( ដែលគេមិនបានសាកសួរ ) នូវសីលនិងវត្តរបស់ខ្លួន ត្រង់ពាក្យថា ណា គឺជនណា បែបណា ប្រកបដោយ

ប្រការណា តាំងនៅដោយប្រការណា មានប្រការយ៉ាងណា ដល់នូវឋានៈបែបណា ប្រកបដោយធម៌ណា ទោះជាក្សត្រ ឬព្រាហ្មណ៍ វេស្សៈ ឬសូទ្រ គ្រហស្ថ ឬបព្វជិត ទេវតាឬមនុស្ស ។ ពាក្យថា សីលនិងវត្ត គឺសីលផង វត្តផងក៏មាន វត្តមិនមែនសីលក៏មាន ។

សីលនិងវត្ត តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល សង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈនិងគោចារៈ ឃើញភ័យក្នុងទោសទាំងឡាយដែលមានប្រមាណតិច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ការសង្រួម ការរវាំង ការមិនប្រព្រឹត្តកន្លងណា ក្នុងសិក្ខាបទទាំងឡាយនោះ នេះឈ្មោះថា សីល ។ ការកាន់យកដោយប្រពៃណា នោះឈ្មោះថា វត្ត ។ សីលដោយអត្ថថា សង្រួម វត្តដោយអត្ថថា ការកាន់យកដោយប្រពៃ នេះលោកហៅថា សីលផង វត្តផង ។

វត្តមិនមែនសីល តើដូចម្តេច ។ ធុតង្គវត្ត ៨ គឺអរញ្ញិកង្គៈ បិណ្ឌបាតិកង្គៈ បំសុកូលិកង្គៈ តេចីវរិកង្គៈ សបទានចារិកង្គៈ ខលុបច្ឆាភត្តិកង្គៈ នេសជ្ជិកង្គៈ យថាសន្ថតិកង្គៈ នេះលោកហៅថា វត្តមិនមែនសីល ។ សូម្បីការកាន់យកដោយប្រពៃដោយវីរិយៈ លោកហៅថា វត្ត មិនមែនសីលដែរ ។ បុគ្គលផ្គងចិត្ត តម្កល់ចិត្តថា ស្បែក សរសៃ និងឆ្អឹងចូរសល់នៅចុះ ឯសាច់និងឈាមក្នុងសរីរៈ ចង់រីងស្ងួតទៅក៏ដោយចុះ ហេតុណាដែលអញគួរដល់ដោយសេចក្តីសង្វាតនៃបុរស ដោយកម្លាំងនៃបុរស ដោយព្យាយាមនៃបុរស ដោយសេចក្តីប្រឹងប្រែងនៃបុរស បើការមិនសម្រេចនូវហេតុនោះទេ នឹងមិន

បញ្ឈប់នូវព្យាយាមឡើយ ការកាន់យកដោយប្រពៃដោយវីរិយៈ មានសភាព យ៉ាងនេះ ក៏លោកហៅថា វត្តមិនមែនសីល ។ បុគ្គលផ្គូរផ្គងចិត្ត តម្កល់ចិត្ត ថា ចិត្តអាត្មាអញនឹងមិនទាន់រួចចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ ដរាបណា អាត្មាអញមិនដោះក្អែននេះចេញដរាបនោះ ការកាន់យកដោយ ប្រពៃដោយវីរិយៈ មានសភាពយ៉ាងនេះ ក៏លោកហៅថា វត្តមិនមែនសីល ។ បុគ្គលផ្គងចិត្ត តម្កល់ចិត្តថា

កាលបើសរគឺតណ្ហាដែលអាត្មាដកមិនទាន់បានទេ អាត្មានឹង មិនបរិភោគ នឹងមិនផឹក នឹងមិនចេញអំពីលំនៅ នឹងមិន ទម្រេតកាយទេ ដូច្នេះ ។

ការកាន់យកដោយប្រពៃដោយវីរិយៈ មានសភាពយ៉ាងនេះ ក៏លោកហៅ ថា វត្ត មិនមែនសីល ។ បុគ្គលផ្គងចិត្ត តម្កល់ចិត្តថា ចិត្តរបស់អាត្មាអញ មិនទាន់រួចចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំដរាបណា ដរាបនោះ អាត្មាអញនឹងមិនក្រោកអំពីអាសនៈ មិនចុះអំពីទីចង្រ្កម មិនចេញអំពីវិហារ មិនចេញអំពីអឌ្ឍយោគៈ មិនចេញអំពីប្រាសាទ មិនចេញអំពីផ្ទះមានដំបូល មិនចេញអំពីគុហា មិនចេញអំពីលេណដ្ឋាន មិនចេញអំពីកុដិ មិនចេញអំពីផ្ទះ មានកំពូល មិនចេញអំពីជុំរុំ មិនចេញអំពីរោង មិនចេញអំពីលំនៅដ៏ប្លែក មិន ចេញអំពីឧបដ្ឋានសាលា មិនចេញអំពីមណ្ឌប មិនចេញអំពីគល់ឈើនេះទេ ការកាន់យកដោយប្រពៃដោយវីរិយៈមានសភាពយ៉ាងនេះ ក៏លោកហៅថា វត្ត មិនមែនសីល ។ បុគ្គលផ្គងចិត្ត តម្កល់ចិត្តថា អាត្មាអញនឹងនាំមក ប្រមូល

មក សម្រេច ពាល់ត្រូវ ធ្វើឲ្យជាក់ច្បាស់នូវអរិយធម៌ក្នុងបុព្វណ្ហសម័យនេះឯង ការកាន់យកដោយប្រពៃដោយវិរិយៈ មានសភាពយ៉ាងនេះ ក៏លោកហៅថា វត្ត មិនមែនសីល ។ បុគ្គលផ្គងចិត្ត តម្កល់ចិត្តថា អាត្មាអញនឹងនាំមកប្រមូលមក សម្រេច ពាល់ត្រូវ ធ្វើឲ្យជាក់ច្បាស់នូវអរិយធម៌ក្នុងសម័យថ្ងៃត្រង់នេះឯង ក្នុងសម័យថ្ងៃរសៀល ក្នុងវេលាមុនភត្ត ក្នុងវេលាក្រោយភត្ត ក្នុងយាមជាខាងដើម ក្នុងយាមជាកណ្តាល ក្នុងយាមជាទីបំផុត ក្នុងកាលខាងរនោច ក្នុងកាលខាងខ្នើត ក្នុងវស្សានរដូវ ក្នុងហេមន្តរដូវ ក្នុងគិម្ហរដូវ ក្នុងចំណែកនៃវ័យជាខាងដើម ក្នុងចំណែកនៃវ័យជាកណ្តាល ក្នុងចំណែកនៃវ័យជាទីបំផុត ការកាន់យកដោយប្រពៃដោយវិរិយៈមានសភាពយ៉ាងនេះ ក៏លោកហៅថា វត្តមិនមែនសីល ។ ពាក្យថា ជន គឺ សត្វ នរៈ មាណព បុរស បុគ្គល សត្វមានជីវិត សត្វមានជាតិ សត្វមានជរា សត្វទៅដោយឥន្ទ្រិយ សត្វកើតអំពីមនុស្ស ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជនណា ( ដែលគេមិនបានសាកសួរ ) នូវសីលនិងវត្តរបស់ខ្លួន ។

[ ៨២ ] អធិប្បាយពាក្យថា ជនណា ដែលគេមិនបានសាកសួរហើយពោលអួតប្រាប់បុគ្គលដទៃ ត្រង់ពាក្យថា បុគ្គលដទៃ បានដល់ជនដទៃ គឺក្សត្រ ព្រាហ្មណ៍ វេស្សៈ សូទ្រ គ្រហស្ថ បព្វជិត ទេវតា មនុស្សទាំងឡាយ ។ ពាក្យថា ដែលគេមិនបានសាកសួរ គឺដែលគេមិនបានដណ្តឹង មិនបានសួរ មិនបានអារាធនា មិនបានអញ្ជើញ មិនបានឲ្យជ្រះថ្លា ។ ពាក្យថា ពោលអួត គឺ ផ្តើមនិយាយនូវសីល ឬវត្ត ឬក៏សីលនិងវត្តរបស់ខ្លួន ។ បុគ្គលផ្តើមនិយាយ

សម្តែង ពោល បំភ្លឺ បញ្ចេញថា អាត្មាជាអ្នកបរិបូណ៌ដោយសីលក្តី ថាបរិបូណ៌ដោយវត្តក្តី ថាបរិបូណ៌ដោយសីលនិងវត្តក្តី ដោយជាតិក្តី ដោយគោត្តក្តី ដោយភាពនៃខ្លួនជាកូនអ្នកមានត្រកូលក្តី ដោយភាពនៃខ្លួនមានសម្បុរល្អក្តី ដោយទ្រព្យក្តី ដោយការរៀនសូត្រក្តី ដោយការងារក្តី ដោយសិល្បៈក្តី ដោយថ្នាក់នៃវិជ្ជាក្តី ដោយសុតៈក្តី ដោយការវាងវៃក្តី ដោយវត្ថុណាមួយក្តី ថាជាអ្នក ( ចេញ ) អំពីត្រកូលខ្ពស់ ហើយបួសក្តី ថា ( ចេញ ) អំពីត្រកូលដ៏ប្រសើរ ហើយបួសក្តី ថា ( ចេញ ) អំពីត្រកូលមានទ្រព្យច្រើនហើយបួសក្តី ថា ( ចេញ ) អំពីត្រកូលមានទ្រព្យលើសលុបហើយបួសក្តី ថាជាអ្នកមានយស ល្បីល្បាញជាងគ្រហស្ថនិងបព្វជិតទាំងឡាយក្តី ថាអាត្មាអញជាអ្នកមានលាភ ចំពោះចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារក្តី ថាជាអ្នកចេះព្រះសូត្រក្តី ថាជាអ្នកទ្រទ្រង់វិន័យក្តី ថាជាធម្មកថិកក្តី ថាជាអ្នកកាន់អរញ្ញិកធុតង្គក្តី កាន់បិណ្ឌបាតិកធុតង្គក្តី កាន់បំសុកូលិកធុតង្គក្តី កាន់តេចីវរិកធុតង្គក្តី កាន់សបទានចារិកធុតង្គក្តី កាន់ខលុបច្ឆាភត្តិកធុតង្គក្តី កាន់នេសជ្ជិកធុតង្គក្តី កាន់សន្ថតិកធុតង្គក្តី ថាជាអ្នកបានបឋមជ្ឈានក្តី បានទុតិយជ្ឈានក្តី បានតតិយជ្ឈានក្តី បានចតុត្ថជ្ឈានក្តី បានអាកាសានញ្ចាយតនសមាបត្តិក្តី បានវិញ្ញាណញ្ចាយតនសមាបត្តិក្តី បានអាកិញ្ចញ្ញាយតនសមាបត្តិក្តី បាននេវសញ្ញានាសញ្ញាយតនសមាបត្តិក្តី ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជនណាដែលគេមិនទាន់សាកសួរហើយពោលអួតប្រាប់បុគ្គលដទៃ ។

[ ៨៣ ] អធិប្បាយពាក្យថា ជនអ្នកឈ្លាសវៃទាំងឡាយពោលនូវជន

នោះថា ជាអ្នកមិនមានអរិយធម៌ ត្រង់ពាក្យថា ជនអ្នកឈ្លាសវៃ គឺជនទាំងឡាយណា ជាអ្នកឈ្លាសវៃក្នុងខន្ធ ឈ្លាសវៃក្នុងធាតុ ឈ្លាសវៃក្នុងអាយតនៈ ឈ្លាសវៃក្នុងបដិច្ចសមុប្បាទ ឈ្លាសវៃក្នុងសតិប្បដ្ឋាន ឈ្លាសវៃក្នុងសម្មប្បធាន ឈ្លាសវៃក្នុងឥទ្ធិបាទ ឈ្លាសវៃក្នុងឥន្ទ្រិយ ឈ្លាសវៃក្នុងពលៈ ឈ្លាសវៃក្នុងពោជ្ឈង្គ ឈ្លាសវៃក្នុងមគ្គ ឈ្លាសវៃក្នុងផល ឈ្លាសវៃក្នុងព្រះនិព្វាន ពួកអ្នកឈ្លាសវៃនោះ បានពោលយ៉ាងនេះថា នុ៎ះជាធម៌របស់ពួកជនមិនមែនជាអរិយៈ នុ៎ះមិនមែនជាធម៌របស់ពួកអរិយៈ នុ៎ះជាធម៌របស់ពួកពាល នុ៎ះមិនមែនធម៌របស់ពួកបណ្ឌិត នុ៎ះជាធម៌របស់ពួកអសប្បុរស នុ៎ះមិនមែនជាធម៌របស់ពួកសប្បុរស ពួកជនអ្នកឈ្លាសវៃ បានពោលយ៉ាងនេះ ហើយសម្តែងយ៉ាងនេះ និយាយយ៉ាងនេះ បំភ្លឺយ៉ាងនេះ បញ្ចេញយ៉ាងនេះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជនអ្នកឈ្លាសវៃទាំងឡាយបានពោលនូវជននោះថា ជាអ្នកមិនមានអរិយធម៌ ។

[ ៨៤ ] ពាក្យថា ជនណាពោលអួតខ្លួនដោយខ្លួនឯង អធិប្បាយថា អត្តា លោកពោលថា ខ្លួន ។ ពាក្យថា ពោលអួតដោយខ្លួនឯង គឺបុគ្គលពោលអួតខ្លួនដោយខ្លួនឯង គឺថាពោលអួត សម្តែងនិយាយ បំភ្លឺ បញ្ចេញថា អាត្មាអញជាអ្នកបរិបូណ៌ដោយសីលក្តី ថាបរិបូណ៌ដោយវត្តក្តី ថាបរិបូណ៌ដោយសីលនិងវត្តក្តី ដោយជាតិក្តី ដោយគោត្តក្តី ដោយភាពនៃខ្លួនជាកូនអ្នកមានត្រកូលក្តី ដោយភាពនៃខ្លួនមានសម្បុរល្អក្តី ដោយទ្រព្យក្តី ដោយការរៀនសូត្រក្តី ដោយការងារក្តី ដោយសិល្បៈក្តី ដោយថ្នាក់នៃវិជ្ជាក្តី ដោយសុតៈក្តី ដោយ

ការវាងវៃក្តី ដោយវត្ថុណាមួយក្តី ថាជាអ្នក ( ចេញ ) អំពីត្រកូលខ្ពស់ហើយបួសក្តី ថា ( ចេញ ) អំពីត្រកូលដ៏ប្រសើរហើយបួសក្តី ថា ( ចេញ ) អំពីត្រកូលមានទ្រព្យ ច្រើនហើយបួសក្តី ថា ( ចេញ ) អំពីត្រកូលមានទ្រព្យលើសលុបហើយបួសក្តី ថាជាអ្នកមានយសល្បីល្បាញ ជាងគ្រហស្ថនិងបព្វជិតទាំងឡាយក្តី ថាអាត្មាជាអ្នកមានលាភ ចំពោះចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារក្តី ថាជាអ្នកចេះព្រះសូត្រក្តី ថាជាអ្នកទ្រទ្រង់វិន័យក្តី ថាជាធម្មកថិកក្តី ថាជាអ្នកកាន់អារញ្ញិកធុតង្គក្តី កាន់បិណ្ឌបាតិកធុតង្គក្តី កាន់បំសុកូលិកធុតង្គក្តី កាន់តេចីវរិកធុតង្គក្តី កាន់សបទានចារិកធុតង្គក្តី កាន់ខលុបច្ឆាភត្តិកធុតង្គក្តី កាន់នេសជ្ជិកធុតង្គក្តី កាន់យថាសន្ថតិកធុតង្គក្តី ថាជាអ្នកបានបឋមជ្ឈានក្តី បានទុតិយជ្ឈានក្តី បានតតិយជ្ឈានក្តី បានចតុត្ថជ្ឈានក្តី បានអាកាសានញ្ចាយតនសមាបត្តិក្តី បានវិញ្ញាណញ្ចាយតនសមាបត្តិក្តី បានអាកិញ្ចញ្ញាយតនសមាបត្តិក្តី បាននេវសញ្ញានាសញ្ញាយតនសមាបត្តិក្តី ព្រោះហេតុនោះ ( ទ្រង់ត្រាស់ថា ) ជនណា ពោលអួតខ្លួនដោយខ្លួនឯង ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ជនណា ដែលគេមិនបានសាកសួរនូវសីលនិងវត្តរបស់ខ្លួន
ហើយ ពោលអួតប្រាប់ពួកបុគ្គលដទៃ ជនអ្នកឆ្លាសវៃទាំង
ឡាយ ពោលនូវជនដែលពោលអួតខ្លួនដោយខ្លួនឯងនោះថា
ជាអ្នកមិនមានអរិយធម៌ ដូច្នេះ ។

[ ៨៥ ] ភិក្ខុណា ជាអ្នកស្ងប់រម្ងាប់ផង អ្នកមានចិត្តរលត់ផង អ្នកមិន

អួតអាងចំពោះសីលទាំងឡាយថា អាត្មាអញដូច្នេះផង កិលេសដ៏ក្រាស់ណាមួយក្នុងលោកនៃភិក្ខុណា មិនមានផង ជនអ្នកឈ្លាសវៃទាំងឡាយ រមែងពោលនូវភិក្ខុនោះថា ជាអ្នកមានអរិយធម៌ ។

[ ៨៦ ] អធិប្បាយពាក្យថា ភិក្ខុណាជាអ្នកស្ងប់រម្ងាប់ផង អ្នកមានចិត្តរលត់ផង ត្រង់ពាក្យថា អ្នកស្ងប់រម្ងាប់ គឺអ្នកស្ងប់រម្ងាប់ ព្រោះជាអ្នកស្ងប់-រម្ងាប់រាគៈ អ្នកស្ងប់រម្ងាប់ ព្រោះជាអ្នកស្ងប់រម្ងាប់ទោសៈ អ្នកស្ងប់រម្ងាប់ ព្រោះជាអ្នកស្ងប់រម្ងាប់មោហៈ អ្នកស្ងប់រម្ងាប់ ចូលទៅជិតស្ងប់ រលត់រលាស់ចេញព្រោះជាអ្នកស្ងប់រម្ងាប់ ចូលទៅជិតស្ងប់ ផុត រំលត់ ប្រាសចេញ រលាស់ចេញនូវក្រោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋេយ្យៈ ថម្ភៈ សារម្ភៈ មានៈ អតិមានៈ មទៈ បមាទៈ កិលេសទាំងពួង ទុច្ចរិតទាំងពួង សេចក្តីក្រវល់ក្រវាយទាំងពួង សេចក្តីក្រហល់ក្រហាយទាំងពួង សេចក្តីក្តៅក្រហាយទាំងពួង ការតាក់តែងនូវអកុសលទាំងពួង ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកស្ងប់រម្ងាប់ ។ ពាក្យថា ភិក្ខុ គឺឈ្មោះថា ភិក្ខុ ព្រោះទម្លាយចោលនូវធម៌ទាំង ៧ ។ គឺជាអ្នកទម្លាយសក្កាយទិដ្ឋិ ទម្លាយវិចិកិច្ឆា ទម្លាយសីលព្វ-តបរាមាសៈ ទម្លាយរាគៈ ទម្លាយទោសៈ ទម្លាយមោហៈ ទម្លាយមានះ ។ ពួកអកុសលធម៌ដ៏លាមកប្រកបដោយសេចក្តីសៅហ្មង ប្រព្រឹត្តទៅក្នុងភពថ្មីប្រកបដោយការក្រវល់ក្រវាយ មានផលជាទុក្ខ មានជាតិ ជរា មរណៈក្នុងខាងមុខ ភិក្ខុនោះទម្លាយបង់ហើយ ។

( ព្រះមានព្រះភាគទ្រង់សម្តែងថាម្នាលសភិយៈបុគ្គលណា )

ដល់នូវការរលត់ ធ្ងន់សេចក្តីសង្ស័យដោយផ្លូវដែលខ្លួនធ្វើ
ហើយ លះបង់នូវវិភវតណ្ហានិងភវតណ្ហា មានព្រហ្មចរិយធម៌
ប្រព្រឹត្តគ្រប់គ្រាន់ហើយ មានភពថ្មីអស់ហើយ បុគ្គលនោះ
ឈ្មោះថា ភិក្ខុ ដូច្នេះ ។

ហេតុនោះ ( ទ្រង់ត្រាស់ថា ) ភិក្ខុណា ជាអ្នកស្ងប់រម្ងាប់ផង ។ ពាក្យថា អ្នកមានចិត្តរលត់ គឺអ្នកមានចិត្តរលត់ ព្រោះជាអ្នករំលត់នូវរាគៈ ព្រោះជាអ្នករំលត់ទោសៈ ព្រោះជាអ្នករំលត់មោហៈ អ្នកមានចិត្តរលត់ ព្រោះជាអ្នករំលត់នូវក្រោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋេយ្យៈ ថម្ភៈ សារម្ភៈ មានៈ អតិមានៈ មទៈ បមាទៈ កិលេសទាំងពួង ទុច្ចរិតទាំងពួង សេចក្តីក្រវល់ក្រវាយទាំងពួង សេចក្តីក្តៅក្រហាយទាំងពួង សេចក្តីអន្ទះអន្ទែងទាំងពួង ការតាក់តែងអកុសលទាំងពួង ហេតុនោះ ( ទ្រង់ត្រាស់ថា ) ភិក្ខុណា ជាអ្នកស្ងប់រម្ងាប់ផង អ្នកមានចិត្តរលត់ផង ។

[ ៨៧ ] អធិប្បាយពាក្យថា អ្នកមិនអួតអាងចំពោះសីលទាំងឡាយថា អាត្មាអញដូច្នេះ ត្រង់ពាក្យថា ដូច្នេះ គឺជាពាក្យតបទ ជាប់ជាមួយដោយបទ ជាពាក្យបំពេញបទ រួបរួមអក្ខរៈ ជាពាក្យសម្រួលព្យញ្ជនៈ ពាក្យថា ដូច្នេះ នេះ ជាលំដាប់បទ ។ ពាក្យថា មិនអួតអាងចំពោះសីលទាំងឡាយ គឺបុគ្គលខ្លះក្នុងលោកនេះ ជាអ្នកពោលអួតអាង ។ បុគ្គលនោះ រមែងពោលអួតអាងថា អាត្មាអញបរិបូណ៌ដោយសីលក្តី បរិបូណ៌ដោយវត្តក្តី បរិបូណ៌ដោយសីលនិងវត្តក្តី ដោយជាតិក្តី ដោយគោត្តក្តី ដោយភាពនៃខ្លួនជាកូនអ្នកមានត្រកូល

ក្តី ដោយភាពនៃខ្លួនជាអ្នកមានសម្បុរល្អក្តី ។បេ។ ពោលអួតអាងថា អាត្មាអញជាអ្នកបាននូវនេវសញ្ញានាសញ្ញាយតនសមាបត្តិក្តី ។ បុគ្គលរមែងមិនពោល មិនអួតអាងយ៉ាងនេះ គឺជាអ្នកវៀរ ជៀសវាង គេចចេញ រលាស់ចេញ ដោះចេញ ប្រាសចេញឆ្ងាយ ចាកការពោលអួត នៅដោយចិត្តប្រាសចាកសេចក្តីសល់វល់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកមិនអួតអាងចំពោះសីលទាំងឡាយថា អាត្មាអញដូច្នេះ ។

[ ៨៨ ] អធិប្បាយពាក្យថា ជនអ្នកឈ្លាសវៃរមែងពោលនូវបុគ្គលនោះថាជាអ្នកមានអរិយធម៌ ត្រង់ពាក្យថា ជនអ្នកឈ្លាសវៃ គឺជនទាំងឡាយណា ជាអ្នកឈ្លាសវៃក្នុងខន្ធ ឈ្លាសវៃក្នុងធាតុ ឈ្លាសវៃក្នុងអាយតនៈ ឈ្លាសវៃក្នុងបដិច្ចសមុប្បាទ ឈ្លាសវៃក្នុងសតិប្បដ្ឋាន ឈ្លាសវៃក្នុងសម្មប្បធាន ឈ្លាសវៃក្នុងឥទ្ធិបាទ ឈ្លាសវៃក្នុងឥន្ទ្រិយ ឈ្លាសវៃក្នុងពល ឈ្លាសវៃក្នុងពោជ្ឈង្គ ឈ្លាសវៃក្នុងមគ្គ ឈ្លាសវៃក្នុងផល ឈ្លាសវៃក្នុងព្រះនិព្វាន ជនអ្នកឈ្លាសវៃនោះ រមែងពោលយ៉ាងនេះថា នុ៎ះជាធម៌របស់ពួកអរិយៈ នុ៎ះមិនមែនជាធម៌របស់ពួកអ្នកមិនមែនអរិយៈ នុ៎ះជាធម៌របស់ពួកបណ្ឌិត នុ៎ះមិនមែនជាធម៌របស់ពួកពាល នុ៎ះជាធម៌របស់ពួកសប្បុរស នុ៎ះមិនមែនជាធម៌របស់ពួកអសប្បុរស ពួកអ្នកឈ្លាសវៃរមែងពោលយ៉ាងនេះ សម្តែងយ៉ាងនេះ និយាយយ៉ាងនេះ បំភ្លឺយ៉ាងនេះ បញ្ចេញយ៉ាងនេះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជនអ្នកឈ្លាសវៃទាំងឡាយ រមែងពោលនូវបុគ្គលនោះថា ជាអ្នកមានអរិយធម៌ ។

[ ៨៩ ] អធិប្បាយពាក្យថា កិលេសដ៏ក្រាស់ណាមួយ ក្នុងលោកនៃ

ភិក្ខុណា មិនមាន ត្រង់ពាក្យថា នៃភិក្ខុណា គឺនៃព្រះអរហន្តខីណាស្រព ។ ពាក្យថា កិលេសដ៏ក្រាស់ បានដល់ កិលេសដ៏ក្រាស់ ៧ គឺ កិលេសដ៏ក្រាស់គឺរាគៈ កិលេសដ៏ក្រាស់គឺទោសៈ កិលេសដ៏ក្រាស់គឺមោហៈ កិលេសដ៏ក្រាស់គឺមានះ កិលេសដ៏ក្រាស់គឺទិដ្ឋិ កិលេសដ៏ក្រាស់គឺកិលេស កិលេសដ៏ក្រាស់គឺកម្ម ។ កិលេសដ៏ក្រាស់ទាំងនោះ នៃព្រះខីណាស្រពនោះមិនមាន ឥតមាន គ្មានសោះ មិនកើតមាន គឺលោកលះបង់ ផ្តាច់ផ្តិល រម្ងាប់ ស្ងប់រម្ងាប់ ធ្វើមិនឲ្យកើតទៀត ដុតដោយភ្លើងគឺញាណហើយ ។ ពាក្យថា ណាមួយ គឺណាមួយ នីមួយ ណានីមួយ ខាងក្នុងក្តី ខាងក្រៅក្តី ទាំងខាងក្នុងខាងក្រៅក្តី ។ ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក មនុស្សលោក ទេវលោក ខន្ធលោក ធាតុលោក អាយតនលោក ហេតុនោះ ( ទ្រង់ត្រាស់ថា ) កិលេសដ៏ក្រាស់ណាមួយក្នុងលោកនៃភិក្ខុណាមិនមាន ។ ហេតុនោះ ព្រះមានព្រះភាគសម្តែងថា

ភិក្ខុណាជាអ្នកស្ងប់រម្ងាប់ផង អ្នកមានចិត្តរលត់ផង អ្នកមិនអួតអាងចំពោះសីលទាំងឡាយថា អាត្មាអញដូច្នេះផង កិលេសដ៏ក្រាស់ណាមួយក្នុងលោកនៃភិក្ខុណាមិនមានផង ជនអ្នកឈ្លាសវៃទាំងឡាយ រមែងពោលនូវបុគ្គលនោះ ថាជាអ្នកមានអរិយធម៌ ដូច្នេះ ។

[ ៩០ ] ធម៌ទាំងឡាយ ដែលបុគ្គលណាសម្រេចហើយ តាក់តែងហើយ ធ្វើឲ្យតាំងនៅក្នុងខាងមុខហើយ ជាធម៌មិនផូរផង់ បុគ្គលនោះឃើញនូវអានិសង្ស

ណាក្នុងខ្លួន រមែងអាស្រ័យនូវអានិសង្សនោះ និងសេចក្ដីស្ងប់ដែលអាស្រ័យនូវការកម្រើក ។

[ ៩១ ] អធិប្បាយពាក្យថា ធម៌ទាំងឡាយ ដែលបុគ្គលណាសម្រេចហើយ តាក់តែងហើយ ត្រង់ពាក្យថា សម្រេច បានដល់កិរិយាសម្រេច ២ ប្រការ គឺកិរិយាសម្រេចគឺតណ្ហា ១ កិរិយាសម្រេចគឺទិដ្ឋិ ១ ។បេ។ នេះហៅថា កិរិយាសម្រេចគឺតណ្ហា ។បេ។ នេះហៅថា កិរិយាសម្រេចគឺទិដ្ឋិ ។ ពាក្យថា តាក់តែងហើយ គឺធ្វើព្រមហើយ ចាត់ចែងហើយ តាក់តែងប្រាកដហើយ តាំងទុកព្រមហើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) តាក់តែងហើយ ។ ម្យ៉ាងទៀត ធម៌ទាំងឡាយមានសភាពមិនទៀង ដែលបច្ច័យតាក់តែងហើយ អាស្រ័យគ្នាទើបកើតឡើង មានការអស់ទៅជាធម្មតា មានការសូន្យទៅជាធម្មតា មានការព្រាត់ប្រាសជាធម្មតា មានការរលត់ជាធម្មតា ហេតុនោះ ( ទ្រង់ត្រាស់ថា ) តាក់តែងហើយ ។ ពាក្យថា ដែលបុគ្គលណា គឺបុគ្គលដែលលុះក្នុងទិដ្ឋិ ។ ទិដ្ឋិ ៦២ លោកពោលថា ធម៌ទាំងឡាយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ធម៌ទាំងឡាយដែលបុគ្គលណា សម្រេចហើយ តាក់តែងហើយ ។

[ ៩២ ] អធិប្បាយពាក្យថា ធ្វើឲ្យតាំងនូវក្នុងខាងមុខហើយ ជាធម៌មិនផូរផង់ ត្រង់ពាក្យថា ធ្វើឲ្យតាំងនូវក្នុងខាងមុខហើយ បានដល់ការធ្វើឲ្យតាំងនៅក្នុងខាងមុខ ២ គឺការធ្វើតណ្ហាឲ្យតាំងនៅក្នុងខាងមុខ ១ ការធ្វើទិដ្ឋិឲ្យតាំងនៅក្នុងខាងមុខ ១ ។បេ។ នេះឈ្មោះថា ការធ្វើតណ្ហាឲ្យតាំងនៅក្នុងខាងមុខ ។បេ។ នេះឈ្មោះថា ការធ្វើទិដ្ឋិឲ្យតាំងនៅក្នុងខាងមុខ ។ ការធ្វើតណ្ហាឲ្យតាំងនៅក្នុង

ខាងមុខ ដែលបុគ្គលនោះមិនទាន់លះបង់ហើយ ការធ្វើទិដ្ឋិឲ្យតាំងនៅក្នុងខាងមុខ ដែលបុគ្គលនោះមិនទាន់រលាស់ចេញហើយ បុគ្គលនោះធ្វើតណ្ហា ឬទិដ្ឋិឲ្យតាំងនៅអំពីមុខហើយប្រព្រឹត្ត មានតណ្ហាដូចជាទង់ជ័យ មានតណ្ហាដូចជាទង់ មានតណ្ហាជាធំ មានទិដ្ឋិដូចជាទង់ជ័យ មានទិដ្ឋិដូចជាទង់ មានទិដ្ឋិជាធំ ត្រូវតណ្ហាឬទិដ្ឋិរួបរឹតហើយប្រព្រឹត្តទៅ ព្រោះហេតុនៃការធ្វើតណ្ហាឲ្យតាំងនៅក្នុងខាងមុខ ដែលខ្លួនមិនទាន់លះបង់ ព្រោះហេតុនៃការធ្វើទិដ្ឋិឲ្យតាំងនៅក្នុងខាងមុខ ដែលខ្លួនមិនទាន់រលាស់ចេញ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ធ្វើឲ្យតាំងនៅក្នុងខាងមុខហើយ ។ ពាក្យថា រមែងមាន គឺមាន មានគ្រប់គ្រាន់ កើតមាន ។ ពាក្យថា មិនផូរផង់ គឺមិនផូរផង់ មិនថ្លាស្អាត មិនបរិសុទ្ធិ ជាធម៌សៅហ្មង ប្រកបដោយសេចក្តីសៅហ្មង ហេតុនោះ ( ទ្រង់ត្រាស់ថា ) ធ្វើឲ្យតាំងនៅក្នុងខាងមុខហើយជាធម៌មិនផូរផង់ ។

[ ៩៣ ] អធិប្បាយពាក្យថា បុគ្គលនោះ ឃើញនូវអានិសង្សណា ក្នុងខ្លួន ត្រង់ពាក្យថា អានិសង្សណាក្នុងខ្លួន គឺអានិសង្សណាចំពោះខ្លួន ។ ទិដ្ឋិលោកហៅថា ខ្លួន ។ បុគ្គលរមែងឃើញអានិសង្ស ២ យ៉ាងនៃទិដ្ឋិរបស់ខ្លួន គឺអានិសង្សក្នុងបច្ចុប្បន្ន ១ អានិសង្សក្នុងបរលោក ១ ។

អានិសង្សនៃទិដ្ឋិក្នុងបច្ចុប្បន្ន តើដូចម្តេច ។ សាស្តាជាអ្នកមានទិដ្ឋិបែបណា ពួកសាវកក៏រមែងមានទិដ្ឋិបែបនោះ ។ ពួកសាវករមែងធ្វើសក្ការៈ គោរព រាប់អាន បូជា ធ្វើនូវការកោតក្រែងចំពោះសាស្តា មានទិដ្ឋិបែបនោះ ទាំងបាននូវចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ច័យភេសជ្ជបរិក្ខារ ព្រោះការធ្វើ

សក្ការៈជាដើមនោះជាហេតុ នេះឈ្មោះថា អានិសង្សនៃទិដ្ឋិក្នុងបច្ចុប្បន្ន ។

អានិសង្សនៃទិដ្ឋិក្នុងបរលោក តើដូចម្តេច ។ ទិដ្ឋិនេះ គួរដើម្បីភាពជានាគក្តី ភាពជាគ្រុឌក្តី ភាពជាយក្សក្តី ភាពជាអសុរក្តី ភាពជាគន្ធព្វក្តី ភាពជាមហារាជក្តី ភាពជាព្រះឥន្ទក្តី ភាពជាព្រះព្រហ្មក្តី ភាពជាទេវតាក្តី ទិដ្ឋិនេះគួរដើម្បីសេចក្តីហ្មត់ចត់ ស្អាតវិសេស បរិសុទ្ធិ ផុត រួចស្រឡះ រួចចេញ ជនទាំងឡាយ រមែងហ្មត់ចត់ ស្អាតវិសេស បរិសុទ្ធិ ផុត រួចស្រឡះ រួចចេញ ( ចាកទុក្ខ ) ដោយទិដ្ឋិនេះ អាត្មាអញនឹងហ្មត់ចត់ ស្អាតវិសេស បរិសុទ្ធិ ផុត រួចស្រឡះ រួចចេញដោយទិដ្ឋិនេះ បុគ្គលជាអ្នកប៉ុនប៉ងចំពោះផលក្នុងខាងមុខដូច្នេះ នេះឈ្មោះថា អានិសង្សនៃទិដ្ឋិក្នុងបរលោក ។

បុគ្គលឃើញ មើល គន់គិត ពិនិត្យ ពិចារណានូវអានិសង្សនៃទិដ្ឋិរបស់ខ្លួន ២ នេះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលនោះឃើញនូវអានិសង្សណាក្នុងខ្លួន ។

[ ៩៤ ] ពាក្យថា រមែងអាស្រ័យនូវអានិសង្សនោះ និងសេចក្តីស្ងប់ដែលអាស្រ័យនូវការកម្រើក អធិប្បាយថា សេចក្តីស្ងប់ ៣ យ៉ាង គឺអច្ចន្តសន្តិ ( ស្ងប់ដោយដាច់ខាត ) តទង្គសន្តិ ( ស្ងប់ដោយអង្គឈាននោះ ) សម្មតិសន្តិ ( ស្ងប់ដោយសេចក្តីសន្មត ) ។

អច្ចន្តសន្តិ តើដូចម្តេច ។ អមតនិព្វាន លោកហៅថា អច្ចន្តសន្តិ បានខាងការរម្ងាប់សង្ខារទាំងពួង ការលះលែងឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាករាគៈ ការរលត់ និព្វាននេះ ឈ្មោះថា អច្ចន្តសន្តិ ។

តទង្គសន្តិ តើដូចម្តេច ។ នីវរណៈរបស់បុគ្គលចូលបឋមជ្ឈាន រមែងស្ងប់រម្ងាប់ ។ វិតក្កនិងវិចារៈរបស់បុគ្គលចូលទុតិយជ្ឈានរមែងស្ងប់រម្ងាប់ បីតិរបស់បុគ្គលចូលតតិយជ្ឈានរមែងស្ងប់រម្ងាប់ សុខនិងទុក្ខរបស់បុគ្គលចូលចតុត្ថជ្ឈានរមែងស្ងប់រម្ងាប់ ។ រូបសញ្ញា បដិឃសញ្ញា នានត្តសញ្ញារបស់បុគ្គលចូលអាកាសានញ្ចាយតនៈ រមែងស្ងប់រម្ងាប់ ។ អាកាសានញ្ចាយតនសញ្ញារបស់បុគ្គលចូលវិញ្ញាណញ្ចាយតនៈរមែងស្ងប់រម្ងាប់ ។ វិញ្ញាណញ្ចាយតនសញ្ញារបស់បុគ្គលចូលអាកិញ្ចញ្ញាយតនៈរមែងស្ងប់រម្ងាប់ ។ អាកិញ្ចញ្ញាយតនសញ្ញារបស់បុគ្គលចូលនេវសញ្ញានាសញ្ញាយតនៈរមែងស្ងប់រម្ងាប់ ។ នេះឈ្មោះថា តទង្គសន្តិ ។

សម្មុតិសន្តិ តើដូចម្តេច ។ សេចក្តីស្ងប់រម្ងាប់ដោយអំណាចទិដ្ឋិគឺ ទិដ្ឋិ ៦២ លោកហៅថា សម្មុតិសន្តិ ។ មួយទៀត សេចក្តីស្ងប់ដែលលោកអធិប្បាយទុកក្នុងទីនេះ ក៏ឈ្មោះថា សម្មុតិសន្តិ ។

ពាក្យថា រមែងអាស្រ័យនូវអានិសង្សនោះនិងសេចក្តីស្ងប់ អាស្រ័យនូវការកម្រើក បានសេចក្តីថា បុគ្គលអាស្រ័យ ជាប់ជំពាក់ អែបនែប លិចចុះជឿស៊ប់នូវសេចក្តីស្ងប់នៅកម្រើក សេចក្តីស្ងប់នៅកម្រើកខ្លាំង សេចក្តីស្ងប់នៅញាប់ញ័រ សេចក្តីស្ងប់នៅញាប់ញ័រខ្លាំង សេចក្តីស្ងប់នៅរំភើប សេចក្តីស្ងប់នៅបៀតបៀន សេចក្តីស្ងប់ដែលគេចាត់ចែង សេចក្តីស្ងប់ដែលគេចាត់ចែងដោយវិសេស សេចក្តីស្ងប់ជាសភាពមិនទៀង ដែលបច្ច័យតាក់តែងអាស្រ័យគ្នាកើតឡើង មានកិរិយាអស់ទៅជាធម្មតា សូន្យទៅជាធម្មតា ប្រាសទៅជា

ធម្មតា រលត់ជាធម្មតា ហេតុនោះ ( ទ្រង់ត្រាស់ថា ) រមែងអាស្រ័យនូវអានិសង្សនោះនិងសេចក្ដីស្ងប់អាស្រ័យនូវការកម្រើក ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ធម៌ទាំងឡាយដែលបុគ្គលណា សម្រេចហើយ តាក់តែងហើយ
ធ្វើឲ្យតាំងនៅក្នុងខាងមុខហើយ ជាធម៌មិនផូរផង់ បុគ្គលនោះ
រមែងឃើញនូវអានិសង្សណាក្នុងខ្លួន រមែងអាស្រ័យនូវអានិ-
សង្សនោះនិងសេចក្ដីស្ងប់អាស្រ័យនូវការកម្រើក ដូច្នេះ ។

[ ៩៥ ] ការជាប់ចំពាក់គឺទិដ្ឋិ និងការជ្រើសរើសក្នុងធម៌ទាំងឡាយហើយប្រកាន់ បុគ្គលមិនងាយប្រព្រឹត្តកន្លងបានទេ ព្រោះហេតុនោះ ទើបជនរមែងលះបង់ផង ប្រកាន់ផងនូវធម៌ក្នុងការជាប់ជំពាក់ទាំងនោះ ។

[ ៩៦ ] អធិប្បាយពាក្យថា ការជាប់ជំពាក់គឺទិដ្ឋិ បុគ្គលមិនងាយប្រព្រឹត្តកន្លងបានទេ ត្រង់ពាក្យថា ការជាប់ជំពាក់គឺទិដ្ឋិ បានដល់ការចុះចិត្តស៊ប់ ការស្ទាបអង្អែល ការជាប់ជំពាក់គឺទិដ្ឋិថា លោកទៀង ការឃើញនេះឯងជាការពិត ការឃើញដទៃជាមោឃៈ ការចុះចិត្តស៊ប់ ការស្ទាបអង្អែល ការជាប់ជំពាក់គឺទិដ្ឋិថា លោកមិនទៀង លោកមានទីបំផុត លោកមិនមានទីបំផុត ជីវិតនោះសរីរៈនោះ ជីវិតដទៃសរីរៈដទៃ សត្វស្លាប់ទៅកើតទៀតក៏មាន សត្វស្លាប់ទៅមិនកើតទៀតក៏មាន សត្វស្លាប់ទៅកើតទៀតផង មិនកើតទៀតផង សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ការឃើញនេះឯងជាការពិត ការឃើញដទៃជាមោឃៈ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ការជាប់ជំពាក់

គឺទិដ្ឋិ ។ ពាក្យថា បុគ្គលមិនងាយប្រព្រឹត្តកន្លងបានទេ គឺប្រព្រឹត្តកន្លងដោយលំបាក ធ្លងដោយក្រ ធ្លងចេញបានដោយកម្រ ប្រព្រឹត្តកន្លងបានដោយតឹងឈានកន្លងបានដោយលំបាក ហេតុនោះ ( ទ្រង់ត្រាស់ថា ) ការជាប់ជំពាក់គឺទិដ្ឋិ បុគ្គលមិនងាយប្រព្រឹត្តកន្លងបានទេ ។

[ ៩៧ ] ពាក្យថា ការជ្រើសរើសក្នុងធម៌ទាំងឡាយហើយប្រកាន់ ត្រង់ពាក្យថា ក្នុងធម៌ទាំងឡាយ គឺក្នុងទិដ្ឋិ ៦២ ។ ពាក្យថា ជ្រើសរើស គឺការរិះរក វិនិច្ឆ័យ ជ្រើសរើស ពិនិត្យ ថ្លឹងមើល លៃលក ពិចារណា ធ្វើឲ្យច្បាស់ហើយ ប្រកាន់តាមជួរ ប្រកាន់ស្អិត ប្រកាន់មាំ ប្រកាន់ចំណែក ប្រកាន់គំនរ ប្រកាន់ដោយការប្រមូល គឺថាការប្រកាន់ ការស្ទាបអង្អែល ការជាប់ជំពាក់ ការចូលចិត្ត ការចុះចិត្តជឿថា ហេតុនេះពិត ទៀង ទៀងទាត់ ប្រាកដពិតមែន មិនប្រែប្រួល ហេតុនោះ ( ទ្រង់ត្រាស់ថា ) ការជ្រើសរើសក្នុងធម៌ទាំងឡាយហើយប្រកាន់ ។

[ ៩៨ ] ពាក្យថា ព្រោះហេតុនោះ របស់បទថា ព្រោះហេតុនោះ ជន ( រមែងប្រកាន់ ) ក្នុងការជាប់ជំពាក់ទាំងនោះគឺ ព្រោះហេតុដូច្នោះ ព្រោះដំណើរនោះ ព្រោះហេតុនោះ ព្រោះបច្ច័យនោះ ព្រោះនិទាននោះ ។ ពាក្យថា ជន គឺសត្វ នរៈ មាណព បុរស បុគ្គល សត្វមានជីវិត សត្វមានជាតិ សត្វមានជរា សត្វទៅដោយឥន្ទ្រិយ សត្វកើតអំពីមនុស្ស ។ ពាក្យថា ក្នុងការជាប់ជំពាក់ទាំងនោះ គឺក្នុងហេតុជាគ្រឿងជាប់ជំពាក់ គឺទិដ្ឋិទាំងនោះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ព្រោះហេតុនោះ ជន ( រមែងប្រកាន់ ) ក្នុងការ

ជាប់ជំពាក់ទាំងនោះ ។

[ ៩៩ ] អធិប្បាយពាក្យថា រមែងលះបង់ផង ប្រកាន់ផងនូវធម៌ ត្រង់ពាក្យថា រមែងលះបង់ គឺបុគ្គលលះបង់ដោយហេតុ ២ យ៉ាង គឺលះបង់ដោយកិរិយាកាត់ចោលអំពីបុគ្គលដទៃ ឬកាលមិនទាន់ដល់លះបង់ ។

បុគ្គលលះបង់ដោយកិរិយាកាត់ចោលអំពីបុគ្គលដទៃ តើដូចម្តេច ។ បុគ្គលដទៃកាត់ចោលថា សាសនានោះ មិនមែនជាសព្វញ្ញូទេ ធម៌មិនមែនសម្តែងត្រូវទេ គណៈមិនមែនប្រតិបត្តិត្រូវទេ ទិដ្ឋិមិនល្អទេ បដិបទាមិនមែនបញ្ញត្តល្អទេ មគ្គមិនមែនជាឧបាយស្រោចស្រង់ទេ សេចក្តីស្អាត ស្អាតវិសេស សេចក្តីបរិសុទ្ធ ការរួច ការរួចវិសេសនិងការរួចស្រឡះក្នុងធម៌នុ៎ះ ក៏មិនមានពួកជនរមែងស្អាត ស្អាតវិសេស បរិសុទ្ធិ រួច រួចវិសេស រួចស្រឡះព្រោះធម៌នុ៎ះក៏ទេ បុគ្គលនោះជាអ្នកថោកទាប ខ្សត់ខ្សោយ អាប់ឱន លាមក ជ្រោកជ្រាករំកាច់រំកោច ។ បុគ្គលដទៃកាត់ចោលយ៉ាងនេះ ។ បុគ្គលនោះ ដែលត្រូវគេកាត់ចោលយ៉ាងនេះ រមែងលះបង់សាស្តា លះបង់ធម៌ដែលសាស្តាសម្តែងលះបង់គណៈ លះបង់ទិដ្ឋិ លះបង់សេចក្តីប្រតិបត្តិ លះបង់មគ្គ ។ បុគ្គលលះបង់ដោយកិរិយាកាត់ចោលអំពីបុគ្គលដទៃយ៉ាងនេះ ។

បុគ្គលកាលមិនទាន់ដល់លះបង់ តើដូចម្តេច ។ បុគ្គលកាលមិនទាន់ដល់សីល លះបង់សីល មិនទាន់ដល់វត្ត លះបង់វត្ត មិនទាន់ដល់សីលនិងវត្តលះបង់សីលនិងវត្ត ។ បុគ្គលកាលមិនទាន់ដល់លះបង់យ៉ាងនេះ ។

ពាក្យថា ប្រកាន់ផងនូវធម៌ គឺបុគ្គលប្រកាន់សាស្តា ប្រកាន់ធម៌ដែល

សាស្តាសម្តែង ប្រកាន់គណៈ ប្រកាន់ទិដ្ឋិ ប្រកាន់សេចក្តីប្រតិបត្តិ ប្រកាន់ស្នាបអន្លើល ជាប់ជំពាក់នូវមគ្គ ហេតុនោះ ( ទ្រង់ត្រាស់ថា ) លះបង់ផង ប្រកាន់ផងនូវធម៌ ។ ហេតុនោះ ព្រះមានព្រះភាគសម្តែងថា

ការជាប់ជំពាក់ដោយទិដ្ឋិ និងការជ្រើសរើសក្នុងធម៌ទាំងឡាយ ហើយប្រកាន់ បុគ្គលមិនងាយប្រព្រឹត្តកន្លងបានទេ ព្រោះហេតុនោះ ទើបជនរមែងលះបង់ផង ប្រកាន់ផងនូវធម៌ ក្នុងការជាប់ជំពាក់ទាំងនោះ ។

[ ១០០ ] ទិដ្ឋិដែលគេកំណត់ហើយក្នុងភពតូចធំ ក្នុងលោកណាមួយនៃបុគ្គលមានប្រាជ្ញាកម្ចាត់មិនមានទេ បុគ្គលមានប្រាជ្ញាកម្ចាត់នោះ លះបង់មាយាផង មានះផង តើនឹងលុះដោយកិលេសដូចម្តេចកើត ព្រោះលោកមិនមានការអែបអែប ។

[ ១០១ ] អធិប្បាយពាក្យថា ទិដ្ឋិដែលគេកំណត់ហើយក្នុងភពតូចធំ ក្នុងលោកណាមួយនៃបុគ្គលមានប្រាជ្ញាកម្ចាត់មិនមានទេ ត្រង់ពាក្យថា បុគ្គលមានប្រាជ្ញាកម្ចាត់ សេចក្តីថា បញ្ញា លោកហៅថា ប្រាជ្ញាកម្ចាត់ បានខាងប្រាជ្ញា ការដឹង ការពិចារណា ការពិចារណាសព្វ ការពិចារណាធម៌ ការកំណត់ ការចូលទៅកំណត់ ការចូលទៅកំណត់ចំពោះ ភាពជាបណ្ឌិត ភាពជាអ្នកឈ្លាស ភាពជាអ្នកល្អិតល្អន់ ភាពជាអ្នកវាងវៃ ការគិត ការត្រិះរិះ បញ្ញាដូចផែនដី បញ្ញាជាគ្រឿងទម្លាយបង់ ( នូវកិលេស ) បញ្ញាជាគ្រឿងដឹកនាំ ការឃើញច្បាស់ ការដឹងខ្លួន ជន្ទញ គឺ ( បញ្ញា ) ការដឹងច្បាស់ បញ្ញិន្ទ្រិយ កម្លាំងគឺបញ្ញា សស្ត្រាគឺបញ្ញា ប្រាសាទគឺបញ្ញា ពន្លឺគឺបញ្ញា រស្មីគឺបញ្ញា ប្រទីបគឺបញ្ញា

កែវគឺបញ្ញា ការមិនវង្វេង ការពិចារណាធម៌ សម្មាទិដ្ឋិ ។ ព្រោះហេតុអ្វី បញ្ញា លោកហៅថា ប្រាជ្ញាកម្ចាត់ ។ ( ព្រោះថា ) ដោយបញ្ញានោះ កាយទុច្ចរិតបុគ្គលកម្ចាត់បង់ លាង លាងដោយល្អ លាងជម្រះហើយ វចីទុច្ចរិតបុគ្គលកម្ចាត់បង់ លាង លាងដោយល្អ លាងជម្រះហើយ ។ មនោទុច្ចរិតបុគ្គលកម្ចាត់បង់ លាង លាងដោយល្អ លាងជម្រះហើយ ។ រាគៈបុគ្គលកម្ចាត់បង់ លាង លាងដោយល្អ លាងជម្រះហើយ ។ ទោសៈ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ មាយា សាថេយ្យៈ ថម្ភៈ សារម្ភៈ មានៈ អតិមានៈ មទៈ បមាទៈ កិលេសទាំងអស់ ទុច្ចរិតទាំងអស់ សេចក្តីក្រវល់ក្រវាយទាំងអស់ សេចក្តីអន្ទះអន្ទែងទាំងអស់ សេចក្តីក្តៅក្រហាយទាំងអស់ ការតាក់តែងនូវអកុសលទាំងអស់ បុគ្គលកម្ចាត់បង់ លាង លាងដោយល្អ លាងជម្រះហើយ ។ ព្រោះហេតុនោះ បញ្ញា លោកហៅថា ប្រាជ្ញាកម្ចាត់ ។ មួយទៀត មិច្ឆាទិដ្ឋិបុគ្គលកម្ចាត់បង់ លាង លាងដោយល្អ លាងជម្រះហើយដោយសម្មាទិដ្ឋិ ។ មិច្ឆាសង្កប្បៈ បុគ្គលកម្ចាត់បង់ លាង លាងដោយល្អ លាងជម្រះហើយដោយសម្មាសង្កប្បៈ ។ មិច្ឆាវាចាបុគ្គលកម្ចាត់បង់ដោយសម្មាវាចា ។ មិច្ឆាកម្មន្តៈ បុគ្គលកម្ចាត់បង់ដោយសម្មាកម្មន្តៈ ។ មិច្ឆាអាជីវៈ បុគ្គលកម្ចាត់បង់ដោយសម្មាអាជីវៈ ។ មិច្ឆាវាយាមៈ បុគ្គលកម្ចាត់បង់ដោយសម្មាវាយាម ។ មិច្ឆាសតិ បុគ្គលកម្ចាត់បង់ដោយសម្មាសតិ ។ មិច្ឆាសមាធិ បុគ្គលកម្ចាត់បង់ដោយសម្មាសមាធិ ។ មិច្ឆាញាណៈ បុគ្គលកម្ចាត់បង់ដោយសម្មាញាណ ។ មិច្ឆាវិមុត្តិ បុគ្គលកម្ចាត់បង់ លាង លាងដោយល្អ លាងជម្រះហើយដោយ

សម្មាវិមុត្តិ ។ មួយទៀត កិលេសទាំងអស់ ទុច្ចរិតទាំងអស់ សេចក្តីក្រវល់ក្រវាយទាំងអស់ សេចក្តីអន្ទះអន្ទែងទាំងអស់ សេចក្តីក្តៅក្រហាយទាំងអស់ ការតាក់តែងអកុសលទាំងអស់ បុគ្គលកម្ចាត់បង់ លាង លាងដោយល្អ លាងជម្រះហើយដោយអរិយមគ្គមានអង្គ ៨ ។ ព្រះអរហន្ត ផ្តេកផ្តិត មូលមិត្ត ចូលទៅជិត អែបនែប ចូលទៅដល់ កើតឡើងព្រម ប្រកបដោយគុណធម៌ទាំងឡាយជាគ្រឿងកម្ចាត់បង់នេះ ព្រោះហេតុនោះ ព្រះអរហន្ត ឈ្មោះថា អ្នកមានប្រាជ្ញាកម្ចាត់ ។ ព្រះអរហន្តនោះមានរាគៈកម្ចាត់ហើយ មានបាបកម្ចាត់ហើយមានកិលេសកម្ចាត់ហើយ មានសេចក្តីអន្ទះអន្ទែងកម្ចាត់ហើយ ព្រោះហេតុនោះឈ្មោះថា អ្នកមានប្រាជ្ញាកម្ចាត់ ។ ពាក្យថា ណាមួយ គឺទីមួយ ណាទីមួយណាក៏ដោយ ខាងក្នុងក្តី ខាងក្រៅក្តី ទាំងខាងក្នុងខាងក្រៅក្តី ។ ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក ។បេ។ ក្នុងអាយតនលោក ។ ពាក្យថា កិរិយាកំណត់ បានដល់កិរិយាកំណត់ ២ យ៉ាង គឺកិរិយាកំណត់ គឺតណ្ហា ១ កិរិយាកំណត់គឺទិដ្ឋិ ១ ។បេ។ នេះឈ្មោះថា កិរិយាកំណត់គឺតណ្ហា ។បេ។ នេះឈ្មោះថាកិរិយាកំណត់គឺទិដ្ឋិ ។ ពាក្យថា ក្នុងភពតូចភពធំ បានដល់ ក្នុងកម្មភព បុនព្ភពឈ្មោះថា ភពតូចភពធំ គឺក្នុងកាមភពកម្មភព ក្នុងកាមភពបុនព្ភព ក្នុងរូបភពកម្មភព ក្នុងរូបភពបុនព្ភព ក្នុងអរូបភពកម្មភព ក្នុងអរូបភពបុនព្ភពគឺថាក្នុងការកើតរឿយៗ ការប្រព្រឹត្តទៅរឿយៗ ការកើតរឿយៗ បដិសន្ធិរឿយៗ ការញុំាងអត្តភាពឲ្យកើតរឿយៗ ។ ពាក្យថា ទិដ្ឋិដែលគេកំណត់ហើយក្នុងភពតូចភពធំ ក្នុងលោកណាមួយ នៃបុគ្គលមានប្រាជ្ញាកម្ចាត់មិនមានទេ

សេចក្តីថា ទិដ្ឋិដែលតែងតាំង បង្កើត តាក់តែង តម្កល់ទុកក្នុងភពតូចភពធំក្នុងលោកណាមួយនៃបុគ្គលមានប្រាជ្ញាកម្ចាត់មិនមាន ឥតមាន គ្មាន មិនកើត មានគឺលោកលះបង់ ផ្តាច់បង់ រម្ងាប់ ស្ងប់អស់ហើយ ធ្វើមិនគួរឲ្យកើត ដុតដោយភ្លើងគឺញាណហើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ទិដ្ឋិដែលគេកំណត់ក្នុងភពតូចភពធំក្នុងលោកណាមួយនៃបុគ្គលមានប្រាជ្ញាកម្ចាត់មិនមានទេ ។

[ ១០២ ] ពាក្យថា បុគ្គលមានប្រាជ្ញាកម្ចាត់នោះ លះបង់មាយាផង មានៈផង អធិប្បាយថា ការប្រព្រឹត្តបញ្ឆោត លោកហៅថា មាយា ។ បុគ្គលខ្លះក្នុងលោកនេះ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត តាំងទុកនូវសេចក្តីប្រាថ្នាដ៏លាមក ព្រោះហេតុនៃការបិទបាំងនូវទុច្ចរិតនោះ គឺប្រាថ្នាថាសូមកុំឲ្យជនដឹងអញ ត្រិះរិះថាសូមកុំឲ្យជនដឹងអញ ពោលវាចាថា សូមកុំឲ្យជនដឹងអញ ព្យាយាមដោយកាយថាសូមកុំឲ្យជនដឹងអញ មាយា ភាពនៃមាយា ការនិយាយលើស ការបញ្ឆោត ការបោកប្រាស់ ការលាក់កំណួច ការលួចគំនិត ការលាក់ពុត ការលាក់ទោសខ្លួន ការបិទបាំងមារយាទ ការបិទបាំងជិតស្និទ្ធ អំពើមិនរាក់ អំពើមិនប្រាកដ ការបំបាំងទោសដោយស្រួល កិរិយាអាក្រក់ណា មានសភាពយ៉ាងនេះ នេះលោកហៅថាមាយា ។

ពាក្យថា មានៈ អធិប្បាយថា មានៈ ដោយចំណែកមួយ គឺការក្រអឺតក្រអោងនៃចិត្ត ។ មានៈដោយចំណែក ២ គឺសេចក្តីប្រកាន់ដោយការលើកខ្លួន សេចក្តីប្រកាន់ដោយការបន្តុះបង្អាប់អ្នកដទៃ ។ មានៈដោយចំណែក ៣ គឺការប្រកាន់ថា អញជាមនុស្សប្រសើរ ការប្រកាន់ថា អញជាមនុស្សស្មើ ការ

ប្រកាន់ថា អញជាមនុស្សថោកទាប ។ មានះដោយចំណែក ៤ គឺបុគ្គលញុំាង មានះឲ្យកើតព្រោះលាភ ញុំាងមានះឲ្យកើតព្រោះយស ញុំាងមានះឲ្យកើត ព្រោះបសំសា ញុំាងមានះឲ្យកើតព្រោះសុខ ។ មានះដោយចំណែក ៥ គឺ បុគ្គលញុំាងមានះឲ្យកើតថា អញជាអ្នកបានរូបទាំងឡាយជាទីគាប់ចិត្ត ញុំាង ឲ្យមានះឲ្យកើតថា អញជាអ្នកបានសំឡេង ក្លិន រស ផ្សព្វទាំងឡាយជាទីគាប់ ចិត្ត ។ មានះដោយចំណែក ៦ គឺបុគ្គលញុំាងមានះឲ្យកើត ព្រោះការបរិបូណ៌ ដោយចក្ខុ ញុំាងមានះឲ្យកើតព្រោះការបរិបូណ៌ដោយសោតៈ ញុំាងមានះឲ្យ កើតព្រោះការបរិបូណ៌ដោយឃានៈ បរិបូណ៌ដោយជិវ្ហា បរិបូណ៌ដោយកាយ បរិបូណ៌ដោយចិត្ត ។ មានះដោយចំណែក ៧ គឺការប្រកាន់ ( ក្រអឺត ក្រអោង ) ការមើលងាយ ការប្រកាន់ថាអញប្រសើរជាង ការប្រកាន់ថា ថោកទាប ការប្រកាន់ថាមានគុណវិសេសក្នុងខ្លួន ការប្រកាន់ថាអញមាន ( ខន្ធ គ្រប់គ្រាន់ ) ការប្រកាន់ខុស ។ មានះដោយចំណែក ៨ គឺបុគ្គលញុំាងការ ក្រអឺតក្រអោងឲ្យកើតព្រោះលាភ ញុំាងការប្រកាន់ថោកទាបឲ្យកើតព្រោះមិន មានលាភ ញុំាងការក្រអឺតក្រអោងឲ្យកើតព្រោះយស ញុំាងការប្រកាន់ថោក ទាបឲ្យកើតព្រោះមិនមានយស ញុំាងការក្រអឺតក្រអោងឲ្យកើតព្រោះបសំសា ញុំាងការប្រកាន់ថោកទាបឲ្យកើតព្រោះនិន្ទា ញុំាងការក្រអឺតក្រអោងឲ្យកើត ព្រោះសុខ ញុំាងការប្រកាន់ថោកទាបឲ្យកើតព្រោះទុក្ខ ។ មានះដោយចំណែក ៩ គឺបុគ្គលប្រសើរ មានសេចក្តីប្រកាន់ថាអញជាបុគ្គលប្រសើរ បុគ្គលប្រសើរ មានសេចក្តីប្រកាន់ថាអញជាបុគ្គលប្រសើរ បុគ្គលប្រសើរមានសេចក្តីប្រកាន់

ថាអញជាបុគ្គលថោកទាប បុគ្គលស្មើមានសេចក្តីប្រកាន់ថាអញជាបុគ្គលប្រសើរ បុគ្គលស្មើមានសេចក្តីប្រកាន់ថាអញជាបុគ្គលស្មើ បុគ្គលស្មើមានសេចក្តីប្រកាន់ថាអញជាបុគ្គលថោកទាប បុគ្គលថោកទាបមានសេចក្តីប្រកាន់ថាអញជាបុគ្គលប្រសើរ បុគ្គលថោកទាបមានសេចក្តីប្រកាន់ថាអញជាបុគ្គលស្មើ បុគ្គលថោកទាបមានសេចក្តីប្រកាន់ថា អញជាបុគ្គលថោកទាប ។ មានៈដោយចំណែក ១០ គឺបុគ្គលខ្លះក្នុងលោកនេះ ញុំាងមានៈឲ្យកើតព្រោះជាតិ ព្រោះគោត្ត ព្រោះភាពនៃខ្លួនជាកូនមានត្រកូល ព្រោះភាពនៃខ្លួនមានសម្បុរល្អ ព្រោះទ្រព្យ ព្រោះការរៀន ព្រោះការងារ ព្រោះសិល្បសាស្រ្ត ព្រោះហេតុជាទីតាំងនៃវិជ្ជា ព្រោះសុតៈនិងបដិភាណៈ ព្រោះវត្ថុណាមួយ ។ មានៈ ការប្រកាន់ ភាពជាអ្នកប្រកាន់ ការក្រអឺតក្រអោង ការតម្កើង ការប្រកាន់ឫកខ្ពស់ដូចទង់ជ័យ ការផ្គងឡើង ភាពនៃចិត្តប្រាថ្នាដូចជាទង់ណា មានសភាពយ៉ាងនេះ នេះលោកហៅថា មានៈ ។

ពាក្យថា បុគ្គលមានប្រាជ្ញាកម្ចាត់នោះ លះបង់មាយាផង មានៈផង គឺលះបង់ កម្ចាត់បង់ បន្ទោបង់ ធ្វើឲ្យវិនាស មិនឲ្យកើតនូវមាយានិងមានៈ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលមានប្រាជ្ញាកម្ចាត់នោះ លះបង់មាយាផង មានៈផង ។

[ ១០៣ ] អធិប្បាយពាក្យថា បុគ្គលមានប្រាជ្ញាកម្ចាត់នោះ គប្បីលុះដោយកិលេស ដូចម្តេចកើត ព្រោះលោកមិនមានការអែបនែប ត្រង់ពាក្យថា ការអែបនែប បានខាងការអែបនែប ២ គឺការអែបនែបគឺតណ្ហា ១ ការអែប

នៃបគឺទិដ្ឋិ ១ ។បេ។ នេះឈ្មោះថា ការអែបនៃបគឺតណ្ហា ។បេ។ នេះឈ្មោះថា ការអែបនៃបគឺទិដ្ឋិ ។ បុគ្គលនោះ លះបង់ការអែបនៃបគឺតណ្ហា រលាស់ចេញនូវការអែបនៃបគឺទិដ្ឋិ ឈ្មោះថា អ្នកមិនមានការអែបនៃប ព្រោះលះបង់ការអែបនៃបគឺតណ្ហាហើយ ព្រោះរលាស់ចេញនូវការអែបនៃបគឺទិដ្ឋិហើយ ។ បុគ្គលនោះ គប្បីលុះដោយរាគៈដូចម្តេច លុះដោយទោសៈដូចម្តេច លុះដោយមោហៈដូចម្តេច លុះដោយមានះដូចម្តេច លុះដោយទិដ្ឋិដូចម្តេច លុះដោយឧទ្ធច្ចៈដូចម្តេច លុះដោយវិចិកិច្ឆាដូចម្តេច លុះដោយអនុសយក្កិលេសទាំងឡាយដូចម្តេចកើត ថាជាអ្នកត្រេកអរក្តី ថាជាអ្នកខឹងក្តី ថាជាអ្នកវង្វេងក្តី ថាជាអ្នកជាប់ចំពាក់ក្តី ថាជាអ្នកស្ទាបអង្អែលក្តី ថាជាអ្នកដល់នូវការរាយមាយក្តី ថាជាអ្នកដល់នូវការមិនដាច់ស្រេចក្តី ថាជាអ្នកដល់នូវកម្លាំងក្តី ។ អភិសង្ខារទាំងនោះ បុគ្គលមានប្រាជ្ញាកម្ចាត់លះបង់ហើយ បុគ្គលនោះគប្បីទៅកាន់គតិទាំងឡាយ ថាជាបុគ្គលទៅកើតក្នុងនរកក្តី ថាទៅកើតក្នុងកំណើតតិរច្ឆានក្តី ថាទៅកើតក្នុងបិត្តិវិស័យក្តី ថាជាមនុស្សក្តី ថាជាទេវតាក្តី ថាមានរូបក្តី ថាមិនមានរូបក្តី ថាមានសញ្ញាក្តី ថាមិនមានសញ្ញាក្តី ថាមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែនក្តី ដោយហេតុដូចម្តេចកើត ព្រោះអភិសង្ខារទាំងឡាយលោកលះបង់ហើយ ។ បុគ្គលមានប្រាជ្ញាកម្ចាត់គប្បីទៅដោយហេតុណា ហេតុនោះមិនមាន បច្ច័យមិនមាន ការណ៍មិនមានទេ ព្រោះហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលមានប្រាជ្ញាកម្ចាត់នោះ គប្បីលុះដោយកិលេសដូចម្តេចកើត ព្រោះលោកមិនមានការអែបនៃប ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

ទិដ្ឋិដែលគេកំណត់ហើយក្នុងភពតូចភពធំ ក្នុងលោកណាមួយ នៃបុគ្គលមានប្រាជ្ញាកម្ចាត់មិនមានទេ បុគ្គលមានប្រាជ្ញាកម្ចាត់នោះ លះបង់មាយាផង មានះផង តើនឹងលុះដោយកិលេសដូចម្ដេចកើត ព្រោះលោកមិនមានការអែបនែប ដូច្នេះ ។

[ ១០៤ ] បុគ្គលមានកិលេសជាគ្រឿងអែបនែប រមែងអើពើនឹងវាទៈក្នុងធម៌ទាំងឡាយ ជនគប្បីពោលនូវបុគ្គលមិនមានការអែបនែបដោយកិលេសណាដូចម្ដេចបាន ព្រោះអត្តទិដ្ឋិ ( ការឃើញថាមានខ្លួន ) និរត្តទិដ្ឋិ ( ការឃើញការមិនមានខ្លួន ) នៃព្រះអរហន្តនោះមិនមានទេ ព្រះអរហន្តនោះ បានលាងនូវទិដ្ឋិទាំងអស់ក្នុងលោកនេះហើយ ។

[ ១០៥ ] អធិប្បាយពាក្យថា បុគ្គលមានកិលេសជាគ្រឿងអែបនែបរមែងអើពើនឹងវាទៈក្នុងធម៌ទាំងឡាយ ត្រង់ពាក្យថា កិលេសជាគ្រឿងអែបនែប បានខាងការអែបនែប ២ យ៉ាង គឺការអែបនែបគឺតណ្ហា ១ ការអែបនែបគឺទិដ្ឋិ ១ ។បេ។ នេះឈ្មោះថា ការអែបនែបគឺតណ្ហា ។បេ។ នេះឈ្មោះថា ការអែបនែបគឺទិដ្ឋិ ។ បុគ្គលនោះ មិនទាន់លះបង់ការអែបនែបគឺតណ្ហា មិនទាន់រលាស់ចោលការអែបនែបគឺទិដ្ឋិ រមែងអើពើនូវវាទៈ ក្នុងធម៌ទាំងឡាយថា ជាអ្នកត្រេកអរក្តី ថាជាអ្នកខឹងក្តី ថាជាអ្នកវង្វេងក្តី ថាជាអ្នកជាប់ចំពាក់ក្តី ថាជាអ្នកស្ទាបអង្អែលក្តី ថាជាអ្នកដល់នូវការរាយមាយក្តី ថាជាអ្នកដល់នូវការមិនដាច់ស្រេចក្តី ថាជាអ្នកដល់នូវកម្លាំងក្តី ព្រោះការអែបនែបគឺតណ្ហា ខ្លួនមិនទាន់លះបង់ ព្រោះការអែបនែបគឺទិដ្ឋិ ខ្លួនមិនទាន់រលាស់ចេញ ។ អភិសង្ខារទាំងនោះ

បុគ្គលមិនទាន់លះបង់ហើយ បុគ្គលរមែងអើពើនូវវាទៈដោយគតិ ព្រោះអភិ-សង្ខារទាំងឡាយដែលខ្លួនមិនទាន់លះបង់ គឺរមែងដល់ ចូលទៅជិត ប្រកាន់ស្ទាបអង្អែល ជាប់ចំពាក់នូវវាទៈថា ជាអ្នកកើតក្នុងនរកក្តី កើតក្នុងកំណើតតិរច្ឆានក្តី កើតក្នុងបិត្តិវិស័យក្តី ជាមនុស្សក្តី ជាទេវតាក្តី មានរូបក្តី មិនមានរូបក្តី មានសញ្ញាក្តី មិនមានសញ្ញាក្តី មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែនក្តី ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលមានកិលេសជាគ្រឿងអែបនែបរមែងអើពើនូវវាទៈក្នុងធម៌ទាំងឡាយ ។

[ ១០៦ ] អធិប្បាយពាក្យថា ជនគប្បីពោលនូវបុគ្គលមិនមានការអែបនែបដោយកិលេសណា ដូចម្តេចបាន ត្រង់ពាក្យថា ការអែបនែប បានដល់ការអែបនែបពីរគឺ ការអែបនែបគឺតណ្ហា ១ ការអែបនែបគឺទិដ្ឋិ ១ ។បេ។ នេះឈ្មោះថា ការអែបនែបគឺតណ្ហា ។បេ។ នេះឈ្មោះថា ការអែបនែបគឺទិដ្ឋិ ។ បុគ្គលនោះលះបង់ការអែបនែបគឺតណ្ហា រលាស់ចោលការអែបនែបគឺទិដ្ឋិ ព្រោះការអែបនែបគឺតណ្ហា លោកលះបង់ហើយ ព្រោះការអែបនែបគឺទិដ្ឋិ លោករលាស់ចេញហើយ ជនគប្បីពោលនូវបុគ្គលមិនមានកិលេសជាគ្រឿងអែបនែបដោយរាគៈដូចម្តេច គប្បីពោលដោយទោសៈដូចម្តេច គប្បីពោលដោយមោហៈដូចម្តេច គប្បីពោលដោយមានះដូចម្តេច គប្បីពោលដោយទិដ្ឋិដូចម្តេច គប្បីពោលដោយឧទ្ធច្ចៈដូចម្តេច គប្បីពោលដោយវិចិកិច្ឆាដូចម្តេច គប្បីពោលដោយអនុស័យទាំងឡាយដូចម្តេច ថាជាអ្នកត្រេកអរក្តី ថាជាអ្នកទឹងក្តី ថាជាអ្នកវង្វេងក្តី ថាជាអ្នកជាប់ចំពាក់ក្តី ថាជាអ្នកស្ទាបអង្អែលក្តី ថាជាអ្នកដល់នូវ

ការរាយមាយក្តី ថាជាអ្នកដល់នូវការមិនដាច់ស្រេចក្តី ថាជាអ្នកដល់នូវកម្លាំងក្តី ។ អភិសង្ខារទាំងនោះ បុគ្គលនោះលះបង់ហើយ ជនគប្បីពោលនូវគតិទាំងឡាយថា ជាអ្នកកើតក្នុងនរកដូច្នេះក្តី ។បេ។ មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែនដូច្នេះក្តី ដោយហេតុដូចម្តេចបាន ព្រោះអភិសង្ខារទាំងឡាយលោកលះបង់ហើយ ។ ជនគប្បីពោល សម្តែង និយាយ បំភ្លឺ បញ្ចេញដោយហេតុណា ហេតុនោះមិនមាន បច្ច័យមិនមាន ការណ៍មិនមាន ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជនគប្បីពោលនូវបុគ្គលមិនមានការអែបនែបដោយកិលេសណាដូចម្តេចបាន ។

[ ១០៧ ] អធិប្បាយពាក្យថា អត្តទិដ្ឋិនិងនិរត្តទិដ្ឋិនៃបុគ្គលនោះមិនមានទេ ត្រង់ពាក្យថា អត្តទិដ្ឋិ គឺសស្សតទិដ្ឋិមិនមាន ពាក្យថា និរត្តទិដ្ឋិ គឺឧច្ឆេទទិដ្ឋិក៏មិនមាន បានសេចក្តីថា ការប្រកាន់ថាខ្លួនមិនមាន ការគួរដោះថាមិនមែនខ្លួនក៏មិនមាន ។ ការប្រកាន់របស់បុគ្គលណាមាន ការគួរដោះរបស់បុគ្គលនោះក៏មាន ការគួរដោះរបស់បុគ្គលណាមាន ការប្រកាន់របស់បុគ្គលនោះក៏មាន ។ ព្រះអរហន្តកន្លងផុតការប្រកាន់និងការដោះហើយ ប្រព្រឹត្តកន្លងនូវសេចក្តីចម្រើននិងសេចក្តីវិនាស ។ ព្រះអរហន្តនោះ មានព្រហ្មចរិយៈនៅហើយ មានធម៌ជាគ្រឿងប្រព្រឹត្ត ប្រព្រឹត្តហើយ ។បេ។ ព្រះអរហន្តនោះ មិនមានភពថ្មីទៀតទេ ហេតុនោះ ( ទ្រង់ត្រាស់ថា ) អត្តទិដ្ឋិ ( ការឃើញថាមានខ្លួន ) និរត្តទិដ្ឋិ ( ការឃើញថាមិនមានខ្លួន ) នៃបុគ្គលនោះមិនមានទេ ។

[ ១០៨ ] ពាក្យថា បុគ្គលនោះបានលាងនូវទិដ្ឋិទាំងអស់ក្នុងលោកនេះ

ហើយ សេចក្តីថា ទិដ្ឋិទាំង ៦២ បុគ្គលនោះលះបង់ ផ្តាច់ផ្តិល រម្ងាប់ ស្ងប់រម្ងាប់ ធ្វើមិនគួរដល់ការកើតទៀត ដុតដោយភ្លើងគឺញាណហើយ ។ បុគ្គលនោះបាន លាង កម្ចាត់បង់ កម្ចាត់ជាច់ស្រឡះ កម្ចាត់ដោយមិនសល់ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាននូវទិដ្ឋិទាំងអស់ក្នុងលោក ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលនោះ បានលាងនូវទិដ្ឋិទាំងអស់ក្នុងលោកនេះហើយ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

បុគ្គលមានកិលេសជាគ្រឿងអែបនែប រមែងអើពើនូវវាទៈក្នុងធម៌ទាំងឡាយ ជនគប្បីពោលនូវបុគ្គលមិនមានការអែបនែបដោយកិលេសណាដូចម្តេចបាន ព្រោះអត្តទិដ្ឋិ ( ការឃើញថាមានខ្លួន ) និរត្តទិដ្ឋិ ( ការឃើញថាមិនមានខ្លួន ) នៃបុគ្គលនោះមិនមានទេ បុគ្គលនោះបានលាងនូវទិដ្ឋិទាំងអស់ក្នុងលោកនេះហើយ ដូច្នេះ ។

## ចប់ ទុដ្ឋដ្ឋកសុត្តនិទ្ទេស ទី ៣ ។

# អដ្ឋកថា

## ទុដ្ឋដ្ឋកសុត្តនិទ្ទេសទី ៣

[ ៧០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាដំបូង ក្នុងទុដ្ឋដ្ឋកសុត្តនិទ្ទេសមុន ។ បណ្ដាបទទាំងនោះ បទថា **វទន្តិ** សេចក្ដីថា រមែងតិះដៀលក្នុងព្រះដ៏មានព្រះភាគនិងភិក្ខុសង្ឃ ។

បទថា **ទុដ្ឋមនាបិ ឯកេ អញ្ញេបិ វេ សច្ចមនា** សេចក្ដីថា បទថា **ឯកេ** បានដល់ តិរ្ថិយពួកខ្លះមានចិត្តដែលទោសប្រទូស្ត ពួកខ្លះមានសេចក្ដីសម្គាល់បែបនោះ ក៏ជាអ្នកមានចិត្តដែលទោសប្រទូស្តហើយ អធិប្បាយថា ជនពួកណាស្ដាប់តិរ្ថិយទាំងនោះហើយជឿ ជនទាំងនោះយល់ថា ពិត ។

បទថា **វាទញ្ច ជាតំ** សេចក្ដីថា ពាក្យជេរណាមួយដែលកើតឡើង ។ បទថា **មុនិ នោ ឧបេតិ** សេចក្ដីថា មុនី គឺព្រះពុទ្ធរមែងមិនទទួលយក ព្រោះមិនមែនអ្នកធ្វើនិងព្រោះការមិនកម្រើក ។ បទថា **តស្មា មុនី នត្ថិ ខិលោ កុហិញ្ចិ** សេចក្ដីថា ព្រោះហេតុនោះ មុនីនេះគប្បីជ្រាបថា មិនមានកិលេសជាគ្រឿងដោតចិត្តដោយកិលេសជាគ្រឿងដោតចិត្ត មានរាគៈជាដើមក្នុងទីណាមួយ ។

[ ៧១ ] បទថា **ទុដ្ឋមនា** សេចក្ដីថា មានចិត្តដែលទោសទាំងឡាយកើតឡើងប្រទូស្តហើយ ។ បទថា **វិរុទ្ធមនា** សេចក្ដីថា មានចិត្តដែលកិលេសទាំងនោះរារាំងទុក មិនឲ្យឱកាសដល់កុសល ។ បទថា **បដិវិរុទ្ធមនា** លោកពង្រីកដោយអំណាចឧបសគ្គ ។ បទថា **អាហតមនា** សេចក្ដីថា ឈ្មោះថាមានចិត្ត

ដែលទោសៈមកប៉ះខ្ទប់ ព្រោះអត្ថថា តិរ្ថិយទាំងនោះ មានចិត្តដែលបដិឃៈមកប៉ះខ្ទប់ហើយ ។

បទថា **បច្ចាហតមនា** លោកពង្រីកដោយអំណាចនៃឧបសគ្គដូចគ្នា ។ បទថា **អាឃាតិតមនា** សេចក្តីថា ឈ្មោះថាមានចិត្តអាឃាត ព្រោះអត្ថថា តិរ្ថិយទាំងនោះ មានចិត្តអាឃាតដោយអំណាចវិហិង្សា ។

បទថា **បច្ចាឃាតិតមនា** លោកពង្រីកដោយអំណាចឧបសគ្គដូចគ្នា ។ម្យ៉ាងទៀត ឈ្មោះថា **ឧទ្ធមនា** ដោយអំណាចសេចក្តីក្រោធ ឈ្មោះថា **បឧទ្ធមនា** ដោយអំណាចការចងក្រោធទុក ឈ្មោះថា **វិរុទ្ធមនា** ដោយអំណាចការលុបគុណ ឈ្មោះថា **បដិវិរុទ្ធមនា** ដោយអំណាចការវាយឫកស្មើ ឈ្មោះថា **អាហតបច្ចាហតមនា** ដោយអំណាចទោសៈ ឈ្មោះថា **អាឃាតិតបច្ចាឃាតិតមនា** ដោយអំណាចព្យាបាទៈ អាចារ្យពួកខ្លះពណ៌នាដោយន័យជាដើមយ៉ាងនេះថា ឈ្មោះថា **ឧទ្ធមនា** និង **បឧទ្ធមនា** ព្រោះមិនបាននូវបច្ច័យទាំងឡាយ ឈ្មោះថា **វិរុទ្ធមនា** និង **បដិវិរុទ្ធមនា** ព្រោះមិនមានយស ឈ្មោះថា **អាហតបច្ចាហតមនា** ព្រោះការតិះដៀល ឈ្មោះថា **អាឃាតិតបច្ចាឃាតិតមនា** ព្រោះជាបុគ្គលមានការដល់ព្រមដោយទុក្ខវេទនា ។

បទថា **ឧបវទន្តិ** សេចក្តីថា ធ្វើនូវការនិន្ទាឲ្យកើតឡើង ។ បទថា **អភូតេន** សេចក្តីថា ដែលមិនមាន ។

[ ៧២ ] បទថា **សទ្ធហាន្តា** សេចក្តីថា ញ៉ាំងសទ្ធាឲ្យកើតឡើង ដោយអំណាចការជ្រះថ្លា ។ បទថា **ឱកប្បេន្តា** សេចក្តីថា ឈមចុះ កំណត់ដោយ

អំណាចនៃគុណ ។ បទថា **អធិមុច្ចន្តា** សេចក្តីថា ចុះចិត្តស៊ប់នូវការយល់ឃើញដោយអំណាចការជ្រះថ្លា ហើយទទួលយកទុកនូវពាក្យរបស់តិរិយទាំងនោះ ។

បទថា **សច្ចមនា** សេចក្តីថា យល់ថាពិត ។ បទថា **សច្ចសញ្ញិនោ** សេចក្តីថា មានការសម្គាល់ថាពិត ។ បទថា **តថមនា** សេចក្តីថា យល់ថាមិនវិបរិត ។ បទថា **ភូតមនា** បានដល់ យល់ថាមានតាមសេចក្តីពិត ។ បទថា **យាថាវមនា** សេចក្តីថា មានចិត្តមិនញាប់ញ័រ ។ បទថា **អវិបរីតមនា** បានដល់ សម្រេចចិត្ត ។

បណ្តាបទទាំងនោះ បទថា **សច្ចមនា សច្ចសញ្ញិនោ** គប្បីជ្រាបថា លោកពោលគុណរបស់បុគ្គលដែលពោលពិត ។

បទថា **តថមនា តថសញ្ញិនោ** លោកពោលគុណដែលជាប់តតាមសេចក្តីពិត ។ បទថា **ភូតមនា ភូតសញ្ញិនោ** លោកពោលគុណដែលមានក្នុងចិត្ត ។ បទថា **យាថាវមនា យាថាវសញ្ញិនោ** លោកពោលគុណដែលមានហេតុបច្ច័យ ។ បទថា **អវិបរីតមនា អវិបរីតសញ្ញិនោ** លោកពោលគុណ គឺពោលមិនវិបរិត ។

[ ៧៣ ] បទថា **បរតោ ឃោសោ** សេចក្តីថា មានសទ្ទាកើតឡើងអំពីសម្នាក់អ្នកដទៃ ។ បទថា **អក្កោសោ** សេចក្តីថា ពាក្យជេរឯណានីមួយក្នុង ១០ យ៉ាង មានជាតិជាដើម ។ បទថា **យោ វាចំ ឧបេតិ** សេចក្តីថា បុគ្គលណា រមែងទទួលពាក្យស្តីថា ។ បទថា **ការកោ វា** សេចក្តីថា ជាអ្នកមាន

ទោសដែលធ្វើហើយក្តី ។ បទថា **ការកតាយ** សេចក្តីថា ដោយការដែលមានទោសៈដែលធ្វើហើយ ។ បទថា **វុច្ចមានោ** សេចក្តីថា ត្រូវគេពោល ។ បទថា **ឧបវទិយមានោ** សេចក្តីថា ត្រូវគេប្រាថ្នាពោលដល់ទោស ។ បទថា **កុប្បតិ** សេចក្តីថា សម្តែងនូវការក្រោធ ។

[ ៧៤ ] បទថា **ខីលជាតតាបិ ឥត្ថិ** សេចក្តីថា ឈ្មោះថា **ខីលជាត-តាបិ** ព្រោះអត្ថថា មានកិលេសដូចចម្រឹងគឺបដិឃៈ ពោលគឺភាពជាសំរាមនៃចិត្តដោយភាពជាចំណងនៃចិត្តកើតហើយ ។ ការៈនៃបុគ្គលមានកិលេសដូចចម្រឹងដោតចិត្តកើតហើយនោះ ឈ្មោះថា ភាពជាអ្នកមានកិលេសដូចចម្រឹងដោតចិត្តកើតហើយ ។ ភាពជាអ្នកមានកិលេស ដូចចម្រឹងដោតចិត្តនោះរមែងមិនមាន គឺមានក៏មិនមែន ។ បទថា **បញ្ចបិ ចេតោខីលា** សេចក្តីថា ជាអ្នកមិនទាន់ប្រាសចាកតម្រេកក្នុងកាយ ជាអ្នកមិនទាន់ប្រាសចាកតម្រេកក្នុងរូប បរិភោគអាហារពេញផ្ទៃតាមសេចក្តីត្រូវការ ប្រកបសេចក្តីសុខក្នុងការទម្រេតរមែងប្រព្រឹត្តព្រហ្មចរិយៈ ប្រាថ្នាទេវនិកាយណាមួយថា អញនឹងជាទេវតា ឬទេវតាដទៃៗដោយសីល វត្ត តបៈ ឬព្រហ្មចរិយៈនេះ កិលេសដូចចម្រឹងដោតចិត្ត ពោលគឺភាពជាសំរាមដោយការចងភ្ជាក់ចិត្ត ៥ យ៉ាងបែបនេះរមែងមិនមាន ។

[ ៧៥ ] ព្រះមានព្រះភាគកាលត្រាស់គាថានេះហើយ សួរព្រះអានន្ទត្ថេរថា ម្នាលអានន្ទ ភិក្ខុទាំងឡាយត្រូវពោលបរិភាសប្រមាទយ៉ាងនេះហើយ បានពោលអ្វីខ្លះឬ ព្រះអានន្ទត្ថេរក្រាបទូលថា បពិត្រព្រះអង្គ មិនបានពោលអ្វី

ឡើយ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលអានន្ទ ភិក្ខុទាំងឡាយមិនគប្បីជាអ្នកស្ងៀមគ្រប់កាលដោយគិតថា អាត្មាអញ ជាអ្នកមានសីល ដ្បិតថា កាលបណ្ឌិតច្រឡូកច្រឡំជាមួយបុគ្គលពាលហើយមិនពោល មនុស្សទាំងឡាយក្នុងលោកក៏មិនដឹងថាជាបណ្ឌិត ដូច្នេះហើយ ដើម្បីសម្តែងធម៌បានត្រាស់គាថានេះថា ម្នាលអានន្ទ ភិក្ខុទាំងឡាយចូរឆ្លើយតបយ៉ាងនេះជាមួយមនុស្សទាំងនោះ ហើយបានត្រាស់គាថានេះថា អ្នកពោលពាក្យមិនពិត ឬបុគ្គលណាធ្វើ ( អំពើអាក្រក់ ) ហើយនិយាយថា អញមិនធ្វើទេ ( បុគ្គលនោះ ) រមែងទៅកាន់នរក ដូច្នេះ ។ ព្រះថេរៈរៀនព្រះពុទ្ធវចនៈនោះហើយ ពោលនឹងភិក្ខុទាំងឡាយថា លោកទាំងឡាយគប្បីឆ្លើយតបនឹងពួកមនុស្សដោយគាថានេះ ភិក្ខុទាំងឡាយបានធ្វើយ៉ាងនោះ មនុស្សដែលជាបណ្ឌិតបាននាំគ្នាស្ងៀម ចំណែកព្រះរាជាទ្រង់បញ្ជូនពួករាជបុរសទៅក្នុងទីទាំងពួងចាប់ពួកអ្នកលេងដែលពួកតិរ្ថិយជួលឲ្យសម្លាប់នាងសុន្ទរី ទ្រង់សម្លុត ទើបទ្រង់ជ្រាបការប្រព្រឹត្តទៅនោះ បានត្រាស់បរិភាសតិរ្ថិយទាំងឡាយ ចំណែកមនុស្សទាំងឡាយឃើញតិរ្ថិយហើយ ក៏យកដុំដីគ្រវែង យកធូលីបាចពោលថា ជនទាំងនេះធ្វើនូវការវិនាសយសឲ្យកើតដល់ព្រះពុទ្ធ ទើបព្រះអានន្ទត្ថេរក្រាបទូលដល់ព្រះដ៏មានព្រះភាគ ព្រះអង្គបានត្រាស់ព្រះគាថានេះដល់ព្រះថេរៈថា **សកណ្ហិ ធិដ្ឋី ។បេ។ វទេយ្យុំ** ដូច្នេះ ។

គាថានេះមានសេចក្តីថា ជនជាតិរ្ថិយមានទិដ្ឋិយ៉ាងនេះថា ពួកយើងសម្លាប់នាងសុន្ទរីហើយ ប្រកាសទោសរបស់ពួកសមណសក្យបុត្តទាំងឡាយ នឹងត្រេកអរក្នុងសក្ការៈដែលបានមកដោយឧបាយនេះ ជនជាតិរ្ថិយនោះគប្បីឈាន

កន្ទង់ទិដ្ឋិនោះបានដូចម្តេច ដោយពិត ការវិនាសយសនោះរមែងមកដល់ជន ដែលជាតិរ្ថិយនោះឯង ដែលមិនអាចកន្ទង់នូវទិដ្ឋិនោះបាន ឬជាសស្សតវាទី នោះ តាមការពេញចិត្តក្នុងទិដ្ឋិនោះនិងតាំងមាំក្នុងការពេញចិត្តក្នុងទិដ្ឋិនោះ គប្បីកន្ទង់នូវទិដ្ឋិរបស់ខ្លួនបានដូចម្តេច តែកាលធ្វើឲ្យពេញចិត្តខ្លួនឯង គឺកាល ធ្វើទិដ្ឋិទាំងនោះឲ្យបរិបូណ៌ដោយខ្លួននោះឯង គប្បីពោលវត្ថុដែលខ្លួនដឹងនោះ ឯង ។

[ ៧៦ ] បទថា **អវណ្ណំ បកាសយិត្វា** សេចក្តីថា ធ្វើទោស មិនមែន គុណឲ្យប្រាកដ ។ បទថា **សក្ការំ** បានដល់ ការធ្វើនូវសេចក្តីគោរពដោយ បច្ច័យ ៤ ។ បទថា **សម្មានំ** បានដល់ ការរាប់អានច្រើនដោយចិត្ត ។ បទ ថា **បច្ចាហរិស្សាម** សេចក្តីថា នឹងញុំាងលាភជាដើមនោះឲ្យកើត ។ បទថា **ឯវំទិដ្ឋិកា** បានដល់ មានលទ្ធិយ៉ាងនេះ ព្រោះជនជាតិរ្ថិយទាំងនោះ មានលទ្ធិ នេះយ៉ាងនេះថា ពួកយើងនឹងញុំាងលាភជាដើមនោះឲ្យកើត ម្យ៉ាងទៀត ជនជា តិរ្ថិយទាំងនោះ អត់ធ្មត់និងពេញចិត្តថា អញមានធម៌ មានប្រការដូចពោលហើយ ម្យ៉ាងទៀត តិរ្ថិយទាំងនោះ មានចិត្តមានសភាពយ៉ាងនេះថា ការគិតរបស់អញ មាន ហេតុនោះ ព្រះសារីបុត្តត្ថេរកាលនឹងសម្តែងថា ជនជាតិរ្ថិយទាំងនោះ មាន សេចក្តីគួរមួយអន្លើដោយទិដ្ឋិក្តី មានសេចក្តីពេញចិត្តមួយអន្លើដោយទិដ្ឋិនិង សេចក្តីគួរក្តី មានលទ្ធិមួយអន្លើដោយទិដ្ឋិ សេចក្តីគួរនិងការពេញចិត្តក្តី មាន អធ្យាស្រ័យមួយអន្លើដោយទិដ្ឋិ សេចក្តីគួរ សេចក្តីពេញចិត្តនិងលទ្ធិក្តី មាន សេចក្តីប៉ុនប៉ងមួយអន្លើដោយទិដ្ឋិ សេចក្តីគួរ សេចក្តីពេញចិត្ត លទ្ធិនិងអធ្យា

ស្រ័យក្តី ដូច្នេះ ទើបពោលថា **ឃរំទិដ្ឋិកា ។បេ។ ឃរំអធិប្បាយា** ដូច្នេះ ។

បទថា **សកំ ទិដ្ឋឹ** បានដល់ ផ្ទះសម្នាក់របស់ខ្លួន ។ បទថា **សកំ ខន្តឹ** បានដល់ ការអត់សង្កត់របស់ខ្លួន ។ បទថា **សកំ រុចឹ** បានដល់ សេចក្តីពេញចិត្តរបស់ខ្លួន ។ បទថា **សកំ លទ្ធឹ** បានដល់ លទ្ធិរបស់ខ្លួន ។ បទថា **សកំ អជ្ឈាសយំ** បានដល់ អធ្យាស្រ័យរបស់ខ្លួន ។ បទថា **សកំ អធិប្បាយំ** បានដល់ សភាវៈរបស់ខ្លួន ។ បទថា **អតិក្កមិតុំ** បានដល់ ដើម្បីឈានកន្លងព្រម ។ បទថា **អជ្ជេវ ស្វេ អយសោ** សេចក្តីថា ការវិនាសយសនោះឯងដោយចំណែកមួយ ។ បទថា **តេ បច្ចាគតោ** សេចក្តីថា រមែងមកជារបស់តិរិយទាំងនោះ ។ បទថា **តេ** ជាទុតិយាវិភត្តិ ចុះក្នុងអត្ថនៃឆដ្ឋីវិភត្តិ ។

បទថា **អថវា** ជាបទសម្តែងអត្ថមួយទៀត ។ បទថា **សស្សតោ** បានដល់ ទៀង ឋិតថេរ ។ បទថា **លោកោ** បានដល់ អត្តភាព ។ បទថា **ឥទមេវ សច្ចំ មោឃមញ្ញំ** សេចក្តីថា វត្ថុនេះប៉ុណ្ណោះពិត វត្ថុដទៃទទេ ។ បទថា **សមត្តា** បានដល់ ឲ្យបរិបូណ៌ ។ បទថា **សមាធិដ្ឋា** បានដល់ កាន់យកដោយប្រពៃ ។ បទថា **គហិតា** បានដល់ ចូលទៅកាន់យក ។

បទថា **បរាមដ្ឋា** បានដល់ ពាល់ត្រូវ កាន់យកដោយអាការៈទាំងពួង ។ បទថា **អភិនិវិដ្ឋា** បានដល់ បាននូវទីពឹងជាពិសេស ។ បទថា **អសស្សតោ** គប្បីជ្រាបដោយបរិយាយផ្ទុយគ្នាតាមដែលពោលហើយ ។

បទថា **អន្តវា** បានដល់ មានក្នុងទីបំផុត ។ បទថា **អនន្តវា** បានដល់ មិនមានទីបំផុត គឺសេចក្តីចម្រើន ។ បទថា **តំ ជីវំ** បានដល់ ( **សោ ជីវោ** )

ជីវិតក៏ដូច្នោះ លោកធ្វើជាលិង្គវិបល្លាស ។ បទថា **ជីវោ** ក៏បានដល់ អត្តា នោះឯង ។ បទថា **តថាគតោ** បានដល់ សត្វ ។ អាចារ្យពួកខ្លះពោលថា បានដល់ ព្រះអរហន្ត ។ បទថា **បរម្មរណា** បានដល់ បន្ទាប់អំពីស្លាប់ទៅ អធិប្បាយថា បរលោក ។ បទថា **ន ហោតិ តថាគតោ បរម្មរណា** សេចក្តីថា បន្ទាប់អំពីស្លាប់ទៅរមែងមិនកើតទៀត ។ បទថា **ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណា** សេចក្តីថា បន្ទាប់អំពីស្លាប់ទៅកើតទៀតក៏មាន មិនកើតទៀតក៏មាន ។ បទថា **នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណា** សេចក្តីថា កើតទៀតក៏មិនមែន ដោយអំណាចការដាច់សូន្យ មិនកើតទៀតក៏មិនមែន ដោយអំណាចការទៀង ។

[ ៧៧ ] បទថា **សកាយ ទិដ្ឋិយា** ជាដើម ជាតតិយាវិភត្តិ ។ បទថា **អល្លីនោ** បានដល់ ( ជាប់ស្អិត ) តែមួយ ។

[ ៧៨ ] បទថា **សយំ សមត្តំ ករោតិ** សេចក្តីថា ដោះនូវការខ្វះខាតធ្វើខ្លួនឲ្យពេញដោយប្រពៃដោយខ្លួនឯង ។ បទថា **បរិបុណ្ណំ** សេចក្តីថា ដោះទោសដែលប្រព្រឹត្តកន្លងនិងធ្វើឲ្យសម្បូរ ។ បទថា **អនោមំ** សេចក្តីថា ដោះទោសដែលអាក្រក់ ធ្វើឲ្យមិនលាមក ។ បទថា **អគ្គំ** បានដល់ ធ្វើឲ្យនៅក្នុងលំដាប់ដើម ។ បទថា **សេដ្ឋំ** បានដល់ ឲ្យជាប្រធាន គឺប្រាសចាកទោស ។ បទថា **វិសេដ្ឋំ** បានដល់ ឲ្យចម្រើនបំផុត ។ បទថា **ធាមោក្ខំ** បានដល់ ក្រៃលែង ។ បទថា **ឧត្តមំ** បានដល់ វិសេស គឺមិនមានខាងក្រោម ។ បទថា **បវរំ ករោតិ** សេចក្តីថា ធ្វើឲ្យខ្ពង់ខ្ពស់ជាវិសេស ។ ម្យ៉ាងទៀត អាចារ្យ

ពួកមួយពណ៌នាយ៉ាងនេះថា ធ្វើឲ្យលើស ដោយដោះទោសដែលដេកត្រាំ ធ្វើឲ្យប្រសើរដោយដោះទោសដែលជាសង្កិលេស ធ្វើឲ្យវិសេសដោយដោះទោសដែលជាឧបក្កិលេស ធ្វើឲ្យជាប្រធានដោយដោះទោសដែលពេញ ធ្វើឲ្យឧត្តមដោយដោះទោសដែលជាកណ្តាលធ្វើឲ្យបវរដោយដោះទោសឧត្តមនិងកណ្តាល ។

បទថា **អយំ សត្ថា សព្ពញ្ញូ** សេចក្តីថា ព្រះសាស្តារបស់ពួកយើងនេះជាព្រះសព្វញ្ញូដោយទ្រង់ដឹងគ្រប់យ៉ាង ។ បទថា **អយំ ធម្មោ ស្វាក្ខាតោ** សេចក្តីថា ព្រះធម៌របស់ពួកយើងនេះ ព្រះតថាគតត្រាស់ហើយដោយល្អ ។ បទថា **អយំ គណោ សុប្បដិបន្នោ** សេចក្តីថា គណសង្ឃរបស់ពួកយើងនេះបដិបត្តិហើយដោយល្អ ។ បទថា **អយំ ទិដ្ឋិ ភទ្ទិកា** សេចក្តីថា លទ្ធិរបស់ពួកយើងនេះល្អ ។ បទថា **អយំ បដិបទា សុប្បញ្ញត្តា** សេចក្តីថា បដិបទាដែលជាចំណែកខាងដើមរបស់ពួកយើងនេះ ដែលព្រះសាស្តាទ្រង់បញ្ញត្តហើយដោយល្អ ។ បទថា **អយំ មគ្គោ និយ្យានិកោ** សេចក្តីថា មគ្គដែលឲ្យឈានចុះកាន់ភាពជាអរិយៈរបស់ពួកយើងនេះ ជាគ្រឿងនាំចេញចាកទុក្ខ បុគ្គលរមែងធ្វើឲ្យពេញដោយខ្លួនឯង ដោយប្រការដូច្នេះ ។

[ ៧៩ ] បទថា **ការេយ្យ** បានដល់ គប្បីពោលថា លោកទៀង គប្បីសម្តែងថា វត្ថុនេះពិត វត្ថុដទៃទទេ គប្បីក្លែងថា លោកមានទីបំផុត គឺឲ្យកាន់យកដោយវិធីមានបែបផ្សេងៗថា កើតទៀតក៏មាន មិនកើតទៀតក៏មាន ។

លំដាប់នោះ លុះកន្លង ៧ ថ្ងៃ ព្រះរាជាក៏ត្រាស់ឲ្យចោលសាកសពនោះពេលល្ងាចយាងទៅវិហារ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ក្រាបទូលថា បពិត្រ

ព្រះអង្គដ៏ចម្រើន កាលសេចក្តីវិនាសយសកើតឡើងដូច្នេះ គួរប្រាប់ដល់ខ្ញុំព្រះអង្គមិនមែនឬ កាលព្រះរាជាក្រាបទូលយ៉ាងនេះហើយ ព្រះដ៏មានព្រះភាគត្រាស់ថា មហាពិត្រ ការប្រាប់ដល់អ្នកដទៃថា តថាគតជាអ្នកមានសីលសម្បូរដោយគុណដូច្នេះ មិនសមគួរដល់ព្រះអរិយៈទាំងឡាយ ដូច្នេះហើយទ្រង់បានភាសិតគាថាដ៏សេសថា **យោ អត្តនោ សីលវតានិ** ដូច្នេះ ដើម្បីជាហេតុឲ្យកើតរឿងនោះ ។

បណ្តាបទទាំងនោះ បទថា **សីលវតានិ** បានដល់ សីលទាំងឡាយ មានបាតិមោក្ខជាដើមនិងធុតង្គទាំងឡាយ មានអរញ្ញិកធុតង្គជាដើម ។ បទថា **អនានុបុដ្ឋោ** បានដល់ ដែលបុគ្គលណាមួយមិនសួរ ។ បទថា **ចាវា** បានដល់ រមែងពោល ។ បទថា **អនរិយធម្មំ កុសលា តមាហុ យោ អាតុមានំ សយមេវ ចាវា** សេចក្តីថា ជនណា រមែងប្រាប់ខ្លួនថាទៀងនោះឯងយ៉ាងនេះ អ្នកឈ្លាសទាំងឡាយ រមែងពោលវាទៈរបស់ជននោះយ៉ាងនេះថា នុ៎ះមិនមែនធម៌របស់អរិយជន ។

[ ៨១ ] បទថា **អត្ថិ សីលញ្ចេវ វត្តញ្ច** សេចក្តីថា ជាសីលផង ព្រោះអត្ថថា សំវរៈ ជាវត្តផង ព្រោះអត្ថថា សមាទាន ។ បទថា **អត្ថិ វត្តំ ន សីលំ** សេចក្តីថា សេចក្តីនោះជាវត្ត តែមិនជាសីលដោយអត្ថដូចពោលហើយ ។ បទថា **កតមំ** ជាកថេតុកម្យតាបុច្ឆា ។ បទថា **ឥធ ភិក្ខុ សីលវា** ជាដើម មានន័យដូចពោលហើយនោះឯង ។ បទថា **សំវរដ្ឋេន** ដោយអត្ថថា ធ្វើនូវការសង្រួម គឺដោយអត្ថថា បិទនូវទ្វារដែលឈានកន្លង ។

*បទថា **សមាទានវត្តំ** សេចក្ដីថា ដោយអត្ថថា កាន់យកដោយប្រពៃនូវសិក្ខាបទនោះៗ ។ បទថា **អារញ្ញិកង្គំ** សេចក្ដីថា ឈ្មោះថា អារញ្ញិក ព្រោះអត្ថថា មានទីលំនៅអាស្រ័យនៅក្នុងព្រៃ អង្គនៃអ្នកមានទីលំនៅអាស្រ័យនៅក្នុងព្រៃនោះ ឈ្មោះថា អារញ្ញិកង្គធុតង្គ ។ បទថា **បិណ្ឌបាតិកង្គំ** សេចក្ដីថា ការធ្លាក់ចុះនៃដុំអាមិស ពោលគឺភិក្ខា ឈ្មោះថា បិណ្ឌបាត លោកអធិប្បាយថា ការធ្លាក់ចុះក្នុងបាត្រនៃដុំបាយដែលអ្នកដទៃឲ្យ ។ ឈ្មោះថា បិណ្ឌបាតិកៈ ព្រោះអត្ថថា ដុំបាយនោះ គឺចូលទៅកាន់ត្រកូលនោះៗស្វែងរក ។ ម្យ៉ាងទៀត ឈ្មោះថា បិណ្ឌបាតី ព្រោះអត្ថថា មាន**ការប្រព្រឹត្តទៅ**ដើម្បីឲ្យដុំបាយធ្លាក់ចុះ ។ ពាក្យថា **ការប្រព្រឹត្តទៅ** គឺការត្រាច់ទៅ បិណ្ឌបាតីនោះឯងជាបិណ្ឌបាតិកៈ ។ អង្គនៃបិណ្ឌបាតិកៈនោះ ឈ្មោះថា បិណ្ឌបាតិកង្គធុតង្គ ហេតុលោកហៅថាអង្គព្រោះហេតុនោះភិក្ខុនោះជាបុគ្គលត្រាច់ទៅដើម្បីដុំបាយជាវត្តដោយការសមាទានណា ពាក្យនេះ គប្បីជ្រាបថា ជាឈ្មោះនៃការសមាទាននោះ ដោយន័យនេះឯង សំពត់ឈ្មោះថា **បំសុកូល** ព្រោះអត្ថថា ហាក់ដូចជាប្រឡាក់ដោយធូលីក្នុងទីនោះៗ ដោយអត្ថថា ផ្សាយទៅ ព្រោះតាំងនៅលើធូលីទាំងឡាយក្នុងទីកន្លែងណាមួយ មានផ្លូវដើរ ព្រៃស្មសាននិងគំនរសំរាមជាដើម ។ ម្យ៉ាងទៀត ឈ្មោះថា **បំសុកូល** ព្រោះអត្ថថា ដល់នូវភាវៈគួរស្អៀសដូចធូលី លោកអធិប្បាយថា ដល់នូវភាពជារបស់គួរស្អៀស ។ កាលទ្រទ្រង់ទុកនូវសំពត់បំសុកូល មានពាក្យលម្អិតដែលបានពោលហើយយ៉ាងនេះ ឈ្មោះថា **បំសុកូល** ។ ការទ្រទ្រង់ទុកនូវសំពត់បង្សុកូលជាប្រក្រតីរបស់ភិក្ខុនោះ ហេតុនោះ ទើបឈ្មោះថា**បំសុ-***

**ក្ខុលិក** គឺអ្នកទ្រទ្រង់ទុកនូវសំពត់បំសុកូល ។ អង្គនៃភិក្ខុអ្នកទ្រទ្រង់ទុកនូវសំពត់បំសុកូលនោះ ឈ្មោះថា **បំសុក្ខុលិកង្គធុតង្គ** ។ ឈ្មោះថា **តេចីវរិក** ព្រោះអត្ថថា មានត្រៃចីវរ ពោលគឺសង្ឃាដិ ឧត្តរាសង្គនិងអន្តរវាសកៈជាប្រក្រតី ។ អង្គនៃតេចីវរិកៈ ឈ្មោះថា **តេចីវរិកង្គធុតង្គ** ។

បទថា **សបទានចារិកង្គំ** សេចក្តីថា ការកាត់ជាកំណាត់ លោកហៅថា **ទាន** ប្រាសចាកការកាត់ ឈ្មោះថា **អបទាន** អធិប្បាយថា មិនច្នៃ ។ ប្រកបដោយការប្រាសចាកការច្នៃ ឈ្មោះថា **សបទាន** ។ លោកអធិប្បាយថា តាមលំដាប់ផ្ទះ វៀរចាកការច្នៃ ( រំលង ) ។ ឈ្មោះថា **សបទានចារី** ព្រោះអត្ថថា មានការត្រាច់ទៅតាមលំដាប់ផ្ទះជាប្រក្រតី សបទានចារីនោះឯង ជាសបទានចារិកៈ អង្គនៃសបទានចារិកៈ គឺបុគ្គលត្រាច់ទៅតាមលំដាប់ផ្ទះជាប្រក្រតី ឈ្មោះថា **សបទានចារិកង្គធុតង្គ** ។

បទថា **ខលុ** ក្នុងបទថា **ខលុបច្ឆាភត្តិកង្គំ** ជានិបាតចុះក្នុងអត្ថបដិសេធ ។ ភត្តដែលភិក្ខុអ្នកហាមភត្តហើយ បានមកខាងក្រោយ ឈ្មោះថា បច្ឆាភត្ត ។ ការបរិភោគភត្តដែលបានមកខាងក្រោយ ឈ្មោះថា **បច្ឆាភត្តភោជន** ។ ឈ្មោះថា បច្ឆាភត្តិកៈ ព្រោះអត្ថថា ជាអ្នកមានបច្ឆាភត្តជាប្រក្រតី ព្រោះធ្វើសញ្ញាក្នុងបច្ឆាភត្ត ភោជននោះ ឈ្មោះថាភត្ត មិនមែនបច្ឆាភត្តិកៈ ឈ្មោះថា ខលុបច្ឆា-ភត្តិកៈ ពាក្យនេះជាឈ្មោះរបស់ការបរិភោគច្រើន ដែលហាមទុកដោយអំណាចសមាទាន ។ អង្គនៃខលុបច្ឆាភត្តិកៈ គឺបុគ្គលមិនបរិភោគភត្តដែលបានមកខាងក្រោយ ឈ្មោះថា **ខលុបច្ឆាភត្តិកង្គធុតង្គ** ។

បទថា **នេសជ្ជិកង្គំ** សេចក្តីថា ឈ្មោះថា នេសជ្ជិកៈ ព្រោះអត្ថថា មានការហាមនូវការដេក ដោយការអង្គុយជាប្រក្រតី អង្គនៃនេសជ្ជិកៈ ឈ្មោះថា **នេសជ្ជិកង្គធុតង្គ** ។

បទថា **យថាសន្ថតិកង្គំ** សេចក្តីថា សេនាសនៈដែលគេចាត់ទុកណាមួយនោះឯងឈ្មោះថា **យថាសន្ថតិ** ពាក្យនេះជាឈ្មោះសេនាសនៈដែលគេសម្តែងឲ្យជាគ្រាដំបូងយ៉ាងនេះថា សេនាសនៈនេះ រមែងដល់លោក ឈ្មោះថា **យថា-សន្ថតិក** ព្រោះអត្ថថា មានការនៅក្នុងសេនាសនៈតាមដែលចាត់ទុកនោះជាប្រក្រតី ។ អង្គនៃយថាសន្ថតិកៈ ឈ្មោះថា **យថាសន្ថតិកង្គធុតង្គ** ។

អង្គទាំងអស់នេះឯង ឈ្មោះថា **ធុតង្គ** ព្រោះអត្ថថាជាអង្គនៃភិក្ខុអ្នកកម្ចាត់ ព្រោះកម្ចាត់កិលេសដោយការសមាទាននោះៗ ឬព្រោះអត្ថថា មានញាណដែលបានវោហារថា **ធុត** ព្រោះកម្ចាត់កិលេសជាអង្គ ម្យ៉ាងទៀត ឈ្មោះថា **ធុតង្គ** ព្រោះអត្ថថា ធុតៈ ( ញាណ ) ទាំងនោះផង ។ ជាអង្គ ព្រោះកម្ចាត់ធម៌ដែលជាបដិបក្ខដោយការបដិបត្តិផង ។ ក្នុងសេចក្តីនេះ គប្បីជ្រាបវិនិច្ឆ័យដោយអត្ថយ៉ាងនេះមុន ។

ធុតង្គទាំងនេះឯង មានចេតនាជាគ្រឿងសមាទានជាលក្ខណៈ សមដូចលោកពោលទុក ( ក្នុងវិសុទ្ធិមគ្គ ) ថា បុគ្គលដែលតាំងចិត្តស៊ប់ រមែងតាំងចិត្តស៊ប់ដោយធម៌ណា ធម៌ទាំងនោះគឺចិត្តនិងចេតសិក ចេតនាជាគ្រឿងសមា-ទាននោះគឺធុតង្គ បទដែលហាមនោះគឺវត្ថុ ។ ធុតង្គទាំងអស់នោះឯង មានការកម្ចាត់ការចង់បានជាកិច្ច ។ មានការមិនចង់បានជាបច្ចុប្បដ្ឋាន ។ មានអរិយ

ធម៌ មានការប្រាថ្នាតិចជាដើមជាបទដ្ឋាន ។ ក្នុងសេចក្តីនេះ គប្បីជ្រាបវិនិច្ឆ័យដោយលក្ខណៈជាដើម ដោយប្រការដូច្នេះ ។

បទថា **វីរិយសមាធានម្បិ** បានដល់ ការកាន់យកសេចក្តីព្យាយាម ។ បទថា **កាមំ** ជានិបាត ចុះក្នុងអត្ថថា ចំណែកមួយ ។ បទថា **តចោ ច ន្ហារុ ច** បានដល់ ស្បែកនិងសរសៃទាំងឡាយ ។ បទថា **អដ្ឋិ ច** បានដល់ ឆ្អឹងទាំងអស់ ។ បទថា **អវសុស្សតុ** បានដល់ ចូររីងស្ងួតទៅ ។ បទថា **ឧបសុស្សតុ មំសលោហិតំ** បានដល់ សាច់និងឈាមទាំងអស់ ចូររីងស្ងួតទៅ ។ បទថា **តចោ** សេចក្តីថា ជាអង្គចំណែកមួយ[១] ។ បទថា **ន្ហារុ** សេចក្តីថា ជាអង្គចំណែកមួយ ។ បទថា **អដ្ឋិ** សេចក្តីថា ជាអង្គចំណែកមួយ ។ បទថា **ឧបសុស្សតុ មំសលោហិតំ** សេចក្តីថា ជាអង្គចំណែកមួយ ។ បទថា **យន្តំ** ជាបទភ្ជាប់ជាមួយបទដែលគប្បីពោលខាងមុខ ។ បទថា **បុរិសថាមេន** បានដល់ ដោយកម្លាំងកាយរបស់បុរស ។ បទថា **ពលេន** បានដល់ ដោយកម្លាំងញាណ ។ បទថា **វីរិយេន** បានដល់ ដោយតេជះនៃសេចក្តីព្យាយាមនៃញាណផ្លូវចិត្ត ។ បទថា **បរក្កមេន** បានដល់ ដោយការឈានចូលកាន់ឋានៈខាងមុខៗ គឺដោយសេចក្តីព្យាយាមដែលដល់លំដាប់ឧស្សាហៈ ។ បទថា **បត្តព្វំ** បានដល់ ឥដ្ឋផលនោះដែលគប្បីសម្រេច ។ បទថា **ន តំ អប្បាបុណិត្វា** បានដល់ មិនទាន់សម្រេចផល ដែលគប្បីសម្រេចនោះ ។ បទថា **វីរិយស្ស សណ្ឋានំ ភវិស្សតិ** សេចក្តីថា សេចក្តីសង្ខេប គឺការវង្វេងនៃសេចក្តី

១-អង្គមួយក្នុង មហាបធានដែលមានអង្គ ៤ ដែលទ្រង់អធិដ្ឋានទុកក្នុងពេលមុនត្រាស់ដឹង ។

ព្យាយាមដែលមានប្រការដូចពោលហើយនឹងមិនមាន ។ បាឋៈថា **សណ្ឋានំ** ក៏មានសេចក្តីក៏យ៉ាងនោះឯង ។ បទថា **ចិត្តំ បគ្គណ្ហាតិ** សេចក្តីថា ផ្គងចិត្ត គឺឧស្សាហៈ ។ បទថា **បទហតិ** សេចក្តីថា តាំងនៅចំពោះ ។

បទថា **នាសិស្សំ** សេចក្តីថា អញនឹងមិនទំពាស៊ី គឺនឹងមិនបរិភោគ ។ បទថា **ន បិវិស្សាមិ** សេចក្តីថា នឹងមិនហុតបបរនិងទឹកផឹកជាដើម ។ បទថា **វិហារតោ ន និក្ខមេ** សេចក្តីថា មិនគប្បីចេញខាងក្រៅសេនាសនៈ ។ បទថា **នបិ បស្សំ និបាតេស្សំ** សេចក្តីថា នឹងមិនធ្វើឲ្យក្បាលធ្លាក់ គឺតាំងនៅលើគ្រែ តាំង ផែនដី ឬត្រង់កម្រាល គឺកន្ទេលផែង ។ បទថា **តណ្ហាសល្លេ អនូហតេ** សេចក្តីថា កាលព្រួញ ពោលគឺតណ្ហាដែលអាត្មាអញដកមិនបាន អធិប្បាយថា មិនទាន់ប្រាសទៅ ។

បទថា **ឥមំ បល្លង្កំ** សេចក្តីថា ការអង្គុយដែលទាក់ទងដោយជើងពត់ចូលដោយជុំវិញ គឺអង្គុយពត់ភ្នែន ។ បទថា **ន ភិន្ទិស្សាមិ** បានដល់ នឹងមិនលះបង់ ។ បទថា **យាវ មេ ន អនុបាទាយ** បានដល់ មិនប្រកាន់ដោយឧបាទាន ៤ ។ បទថា **អាសវេហិ** បានដល់ ចាកអាសវៈ ៤ មានកាមាសវៈជាដើម ។ បទថា **វិមុច្ចិស្សតិ** បានដល់ នឹងមិនទាន់រួចផុតដោយសមុច្ឆេទវិមុត្តិ ។ បទផ្តើមថា **ន តាវាហំ ឥមម្ហា អាសនា វុដ្ឋហិស្សាមិ** រហូតដល់ បទថា **រុក្ខមូលា និក្ខមិស្សាមិ** លោកពោលដោយអំណាចនៃទីលំនៅ ។ បទថា **ឥមស្មិញ្ចេវ បុព្វណ្ហសមយំ អរិយធម្មំ អាហរិស្សាមិ** រហូតដល់ បទថា **គិម្ហេ** លោកពោលដោយអំណាចនៃកាលវេលា ។

បទថា **បុរិមេ វយោខន្ធេ** ជាដើម លោកពោលដោយអំណាចនៃវ័យ ។

បណ្ដាបទទាំងនោះ បទថា **អាសនា ន វុដ្ឋហិស្សាមិ** សេចក្ដីថា នឹងមិនក្រោកអំពីអាសនៈដែលអង្គុយហើយ ។ បទថា **អឌ្ឍយោគា** បានដល់ ចាកផ្ទះដែលប្រក់តែមួយចំហៀង ។ បទថា **ចាសាទា** បានដល់ ប្រាសាទវែង ។ បទថា **ហម្មិយា** បានដល់ ប្រាសាទត្រងិល ។ បទថា **គុហាយ** បានដល់ គុហាដី ។ បទថា **លេណា** បានដល់ គុហាភ្នំដែលមានព្រំដែននិងមិនមានព្រំដែន[១] ។ បទថា **កុដិយា** បានដល់ កុដិដែលបូកលាបជាដើម ។ បទថា **កូដាគារា** បានដល់ ផ្ទះកំពូលដែលគេលើកឡើង ។ បទថា **អដ្ដា** បានដល់ បន្ទប់ដែលនៅលើខ្លោងទ្វារ ( ប៉ម ) ។ បទថា **មាឡា** បានដល់ អំពីរោងមូល ។ ទីនៅអាស្រ័យពិសេសណាមួយ ឈ្មោះថា **ឧទ្ទណ្ឌា** ។ អាចារ្យខ្លះលោកពោលថា **តិណធនគេហោ** ផ្ទះដែលមានដំបូលដូច្នេះក៏មាន ។ បទថា **ឧបដ្ឋានសាលា** បានដល់ រោងប្រជុំ ឬរោងឆាន់ ។ បទថា **មណ្ឌុធា** ជាដើម ប្រាកដជាក់ច្បាស់ហើយ ។ បទថា **អរិយធម្មំ** បានដល់ ធម៌ដែលប្រាសចាកទោស ឬធម៌របស់ព្រះអរិយៈទាំងឡាយ គឺរបស់ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធនិងព្រះសាវកទាំងឡាយ ។ បទថា **អាហារិស្សាមិ** បានដល់ នឹងនាំមកក្បែរចិត្តរបស់អាត្មាដោយសីល ។ បទថា **សមាហារិស្សាមិ** បានដល់ មិននាំមកជាពិសេសដោយសមាធិ ។ បទថា **អធិគច្ឆិស្សាមិ** បានដល់ នឹងដល់ដោយអំណាចនៃការបានចំពោះដោយធុតង្គ ។ បទថា **ផស្សយិស្សាមិ** បាន

---

១-គុហាទាល់និងគុហាដែលមានរូងរហូត ។

ដល់ នឹងពាល់ត្រូវដោយមគ្គ ៣ ។ បទថា **សច្ឆិករិស្សាមិ** បានដល់ នឹងធ្វើឲ្យប្រចក្សដោយផល ។ ន័យម្យ៉ាងទៀត នឹងនាំមកដោយសោតាបត្តិមគ្គ នឹងនាំមកដោយល្អ ដោយសកទាគាមិមគ្គ នឹងសម្រេចដោយអនាគាមិមគ្គ នឹងពាល់ត្រូវដោយអរហត្តមគ្គ នឹងធ្វើឲ្យជាក់ច្បាស់ដោយបច្ចវេក្ខណៈ ។ បទថា **ផស្សយិស្សាមិ** ក្នុងន័យទាំងពីរ សេចក្តីថា ពាល់ត្រូវនូវព្រះនិព្វានដោយនាមកាយ ។

[ ៨២ ] បទថា **អបុដ្ឋោ** ជាមូលបទ បទនោះមានសេចក្តីថា ដែលបុគ្គលណាមួយមិនសួរ ។ បទថា **អបុច្ឆិតោ** សេចក្តីថា មិនឲ្យដឹងហើយ ។ បទថា **អយាចិតោ** សេចក្តីថា មិនសំណូមពរ ។ បទថា **អនជ្ឈេសិតោ** សេចក្តីថា មិនបង្គាប់ អាចារ្យខ្លះពោលថា មិនប្រាថ្នា ។ បទថា **អប្បសាទិតោ** សេចក្តីថា មិនមានអ្នកណាជ្រះថ្លា ។ បទថា **ចាវេតិ** សេចក្តីថា រមែងពោល ។ បទថា **អហាមស្មិ** បានដល់ ជាអញ អញគឺ ។ បទថា **ជាតិយា វា** សេចក្តីថា ដោយជាតិក្សត្រនិងជាតិព្រាហ្មណ៍ក្តី ។ បទថា **គោត្តេន វា** សេចក្តីថា ដោយគោតមគោត្រក្តី ។ បទថា **កោលបុត្តិយេន វា** សេចក្តីថា ដោយភាពជាកូនរបស់ត្រកូលក្តី ។ បទថា **វណ្ណពោក្ខរតាយ វា** សេចក្តីថា ដោយភាពជាអ្នកមានរូបស្អាតក្តី ។ បទថា **ធនេន វា** សេចក្តីថា ដោយទ្រព្យសម្បត្តិក្តី ។ បទថា **អជ្ឈេនេន វា** សេចក្តីថា ដោយការអញ្ជើញក្តី ។ បទថា **កម្មាយតនេន វា** សេចក្តីថា ការងារនោះឯង ឈ្មោះថា កម្មាយតនៈដោយការងារនោះ មានកសិកម្មនិងគោរក្ខកម្មជាដើមក្តី ។ បទថា **សិប្បាយតនេន**

វា សេចក្ដីថា ដោយសិប្បធ្ងជាដើមក្ដី ។ បទថា **វិជ្ជដ្ឋានេន វា** សេចក្ដីថា ដោយសិល្បសាស្ត្រ ១៨ យ៉ាង ។ បទថា **សុតេន វា** សេចក្ដីថា ដោយគុណ គឺភាពជាពហុស្សូតក្ដី ។ បទថា **បដិភាណេន វា** សេចក្ដីថា ដោយញាណ ពោលគឺបដិភាណក្នុងហេតុនិងមិនមែនហេតុក្ដី ។ បទថា **អញ្ញតរ-ញ្ញតរេន វា វត្ថុនា** បានដល់ ដោយហេតុឯណានីមួយនៃជាតិកំណើតជាដើម ។

បទថា **ឧច្ចាកុលា** សេចក្ដីថា ចាកត្រកូលក្សត្រនិងត្រកូលព្រាហ្មណ៍ដោយបទនេះ រមែងសម្ដែងដោយភាពជាធំដោយជាតិនិងគោត្ត ។ បទថា **មហា-ភោគកុលា** សេចក្ដីថា ចាកត្រកូលគហបតីមហាសាល ។ ដោយបទនេះ រមែងសម្ដែងភាពជាធំដោយការមាំទាំ ។ បទថា **ឧឡារភោគកុលា** សេចក្ដីថា ចាកត្រកូលវេស្សៈដ៏សេសជាដើម ។ ដោយបទនេះ រមែងសម្ដែងដល់មាសនិងប្រាក់ជាដើម សន្ទឹកសន្ធាប់ ព្រោះថាសូម្បីពួកចណ្ឌាលក៏មានភោគសម្បត្តិធំបាន ។ បទថា **ញាតោ** បានដល់ ប្រាកដ ។ បទថា **យសស្សី** សេចក្ដីថា ដល់ព្រមដោយបរិវារ ។ បទថា **សុត្តន្តិកោ** បានដល់ ជាអ្នកខ្វល់ខ្វាយក្នុងព្រះសូត្រ ។ បទថា **វិនយធរោ** បានដល់ ជាអ្នកទ្រទ្រង់ព្រះវិន័យបិដក ។ បទថា **ធម្មកថិកោ** បានដល់ ជាអ្នកជំនាញព្រះអភិធម្ម ។ បទថា **អារញ្ញិកោ** ជាដើម លោកពោលដើម្បីសម្ដែងបដិបទាដែលជាចំណែកខាងដើមនៃធុតង្គ ។ បទថា **បឋមស្ស ឈានស្ស លាភី** ជាដើម លោកពោលសម្ដែងរូបសមាបត្តិនិងអរូបសមាបត្តិ ៨ ដោយអំណាចសម្ដែងដោយ

ការចាក់ដុះ ។ បទថា **ចាវេតិ** ជាមូលបទ ។ បទថា **កាថេតិ** សេចក្តីថា រមែងពោលថា ខ្ញុំជាអាចារ្យទ្រទ្រង់បិដក ។ បទថា **ភណាតិ** សេចក្តីថា ធ្វើឲ្យប្រាកដថា ខ្ញុំជាអ្នកសមាទានធុតង្គ ។ បទថា **ទីបយតិ** សេចក្តីថា បង្អួលបង្ហាញថា ខ្ញុំជាអ្នកបានរូបឈាន ។ បទថា **វោហរតិ** សេចក្តីថា បន្លឺវាចាថា ខ្ញុំជាអ្នកបានអរូបឈាន ។

[ ៨៣ ] បទថា **ខន្ធកុសលា** សេចក្តីថា ឈ្លាសក្នុងលក្ខណៈចំពោះខ្លួននិងសាមញ្ញលក្ខណៈក្នុងខន្ធ ៥ អធិប្បាយថា ជាអ្នកឈ្លាសដោយអំណាចនៃញាតបរិញ្ញា តីរណបរិញ្ញានិងបហានបរិញ្ញា សូម្បីក្នុងធាតុអាយតនៈនិងបដិច្ចសមុប្បាទជាដើមក៏ន័យឯង ។ បទថា **និព្វានកុសលា** សេចក្តីថា ជាអ្នកឈ្លាសក្នុងព្រះនិព្វាន ។ បទថា **អនរិយានំ** បានដល់ មិនមែនរបស់ពួកអរិយជន ។ បទថា **ឯសោ ធម្មោ** បានដល់ សភាវៈនេះ ។ បទថា **ពាលានំ** បានដល់ ពួកជនដែលមិនមែនជាបណ្ឌិត ។ បទថា **អសប្បុរិសានំ** បានដល់ មិនមែនរបស់ពួកសប្បុរស ។

[ ៨៤-៨៥ ] បទថា **អត្តា** បានដល់ នូវខ្លួន ។ បទថា **សន្តោ** សេចក្តីថា ឈ្មោះថា **សន្តោ** ព្រោះចូលទៅស្ងប់កិលេសមានរាគៈជាដើម ឈ្មោះថា **អភិនិព្វុតត្តោ** ក៏ដូចគ្នា ។ បទថា **ឥតិហន្តិ សីលេសុ អកត្ថមានោ** សេចក្តីថា មិនអួតក្នុងសីលទាំងឡាយដោយន័យជាដើមថា ខ្ញុំជាអ្នកដល់ព្រមដោយសីលដោយប្រការដូច្នេះ លោកអធិប្បាយទុកថា មិនពោលវាចាបង្អួនចូលមករកខ្លួននៅនិមិត្តនៃសីល ។ បទថា **តមរិយធម្មំ កុសលា វទន្តិ** សេចក្តី

ថា អ្នកឈ្លាសក្នុងខន្ធជាដើមមានព្រះពុទ្ធជាដើម រមែងពោលការមិនអួតក្នុងសីលរបស់ភិក្ខុនោះថា នេះជាអរិយធម៌ ។ បទថា **យស្សុស្សទា នត្ថិ កុហិ-ញ្ចិ លោកេ** សេចក្តីថា កិលេសដែលផ្សាយឡើង ៧ ប្រការ មានរាគៈជាដើម មិនមានដល់ភិក្ខុណា គឺដល់ព្រះខីណាស្រព ក្នុងទីណាមួយក្នុងលោក ក្ខាប់សេចក្តីថា បណ្ឌិតទាំងឡាយរមែងពោលការមិនអួតនោះ របស់ភិក្ខុនោះ យ៉ាងនេះថា នេះជាអរិយធម៌ ។

[ ៨៦ ] បទថា **សន្តោ** ជាមូលបទ ។ បទថា **រាគស្ស សមិតត្តា** សេចក្តីថា ព្រោះរម្ងាប់រាគៈដែលមានតម្រេកជាលក្ខណៈបាន សូម្បីក្នុងទោសៈជាដើមក៏មានន័យនេះឯង ។ បទថា **វិជ្ឈាតត្តា** សេចក្តីថា ព្រោះដុតនូវកិលេសជាគ្រឿងក្តៅក្រហាយទាំងពួងបាន ។ បទថា **និព្វុតត្តា** សេចក្តីថា ព្រោះរំលត់កិលេសជាគ្រឿងដុតទាំងពួងបាន ។ បទថា **វិគតត្តា** សេចក្តីថា ព្រោះប្រាសចាក គឺឆ្ងាយអំពីអភិសង្ខារដែលជាចំណែកនៃអកុសលធម៌ទាំងពួង ។ បទថា **បដិប្បស្សទ្ធត្តា** សេចក្តីថា ព្រោះការកើតឡើងនៃការស្ងប់រម្ងាប់ដោយអាការៈទាំងពួង ។ បទថា **សត្តន្នំ ធម្មានំ ភិន្នត្តា ភិក្ខុ** សេចក្តីថា ឈ្មោះថា **ភិក្ខុ** ព្រោះទម្លាយនូវធម៌ ៧ ប្រការ ដែលនឹងពោលខាងមុខតាំងនៅ ។ កិលេស ៣ យ៉ាងនេះ គឺសក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសៈទម្លាយបានដោយសោតាបត្តិមគ្គ កិលេសគ្រោតគ្រាត ២ យ៉ាងគឺកាមរាគៈទោសៈកម្ចាត់បានដោយសកទាគាមិមគ្គ ។ កិលេស ២ យ៉ាងនោះឯងដែលជាចំណែកល្អិត កម្ចាត់បានដោយអនាគាមិមគ្គ ។ កិលេស ២ យ៉ាងទាំងនេះ

*គឺមោហៈ មានះទម្លាយដោយអរហត្តមគ្គ ។ មួយាងទៀត ដើម្បីសម្តែងកិលេសទាំងឡាយដ៏សេស ទើបព្រះសារីបុត្តត្ថេរពោលថា* **ភិន្នាស្ស ហោន្តិ ចាបកា អកុសលា ធម្មា** *ដូច្នេះជាដើម ។ បទថា* **សង្កិលេសកា** *បានដល់ ជាបច្ច័យនៃការសៅហ្មង ។ បទថា* **ពោនោព្ភវិកា** *បានដល់ ឲ្យកើតក្នុងភពទៀត ។ បទថា* **សទរា** *មានវិគ្គហថា ឈ្មោះថា* **សទរា** *ព្រោះអត្ថថា ជាទីមានសេចក្តីក្រវល់ក្រវាយគឺកិលេស ។ បាឋៈថា* **សទរា** *ក៏មាន សេចក្តីថា ប្រព្រឹត្តទៅដោយសេចក្តីក្រវល់ក្រវាយ ។ បទថា* **ទុក្ខវិបាកា** *សេចក្តីថា ឲ្យទុក្ខក្នុងវេលាឲ្យផល ។ បទថា* **អាយតឹ ជាតិជរាមរណិយា** *សេចក្តីថា ជាបច្ច័យដល់ជាតិ ជរានិងមរណៈក្នុងអនាគតកាល ។*

*ក្នុងបទថា* **បជ្ជេន កតេន អត្តនា** *ជាដើម មានអត្ថសមោធានដូច្នេះថា បុគ្គលណា គួរដល់ពាក្យសរសើរទាំងនេះយ៉ាងនេះថា ដល់នូវការបរិនិព្វានហើយ ដោយមគ្គដែលខ្លួនចម្រើនហើយ ឆ្លងផុតសេចក្តីសង្ស័យបានហើយ ព្រោះដល់នូវការរំលត់កិលេសទាំងអស់បាន លះហើយនូវសេចក្តីវិនាសនិងសេចក្តីចម្រើន មានប្រភេទ គឺវិបត្តិនិងសម្បត្តិ ការវិនាសនិងការចម្រើន ការដាច់សូន្យនិងការទៀង បាបនិងបុណ្យដែលមានមគ្គនៅចប់ហើយ ជាអ្នកមានភពថ្មីអស់ហើយដូច្នេះ បុគ្គលនោះឈ្មោះថា* **ភិក្ខុ** *។*

*[ ៨៧ ] បាឋៈ ២ ថា* **ឥតិហំ** *និង* **ឥធហំ** *លោកលើកបាឋៈថា* **ឥធហំ** *សំដៅយកការតបទជាដើមថា* **ឥតិ** *។ បណ្តាបទទាំងនោះ បទថា* **ឥតិ** *បានដល់ វត្ថុដែលបានពោលហើយ ។ បទថា* **បទសន្ធិ** *បានដល់ ការតបទ*

ទាំងឡាយ ឈ្មោះថា **បទសន្ធិ** សេចក្តីថា ការភ្ជាប់បទ ។ បទថា **បទសំសគ្គោ** បានដល់ ភាពតែមួយដូចគ្នានៃបទទាំងឡាយ ។ បទថា **បទបារិបូរិ** បានដល់ សេចក្តីបរិបូណ៌នៃបទទាំងឡាយ សេចក្តីតែមួយដូចគ្នានឹងបទទាំងពីរ ។ បទថា **អក្ខរសមវាយោ** សេចក្តីថា ដើម្បីសម្តែងថា បទទាំងឡាយដូចគ្នាក្តី មិនបរិបូណ៌ក្តី នេះរមែងមិនជាទីប្រជុំ គឺមិនជាទីរួមនៃអក្ខរៈទាំងឡាយយ៉ាងនេះ ទើបព្រះសារីបុត្តត្ថេរពោលថា **អក្ខរសមវាយោ** ដូច្នេះ ។ បទថា **ព្យញ្ជនសិលិដ្ឋតា** សេចក្តីថា ការប្រចក្សនៃអត្ថ នៃព្យញ្ជនៈទាំងឡាយ គឺនៃអត្ថនិងព្យញ្ជនៈដែលពោលហើយ ដើម្បីសេចក្តីបរិបូណ៌នៃការរួបរួមព្យញ្ជនៈការពីរោះមិនមែនការមិនរៀបរយនៃបាឋៈ ព្រោះជាការពីរោះនៃហេតុទាំងឡាយ ។ បទថា **បទានុបុព្វតាមេតំ** សេចក្តីថា ភាពជាលំដាប់នៃបទទាំងឡាយ ឈ្មោះថា ការប្រព្រឹត្តទៅតាមលំដាប់បទ អធិប្បាយថា ជាលំដាប់នៃបទ ។ បទថា **មេតំ** បានដល់ ពាក្យនោះ បើសួរថា បទណា គប្បីឆ្លើយថា បទថា **ឥតិ** នេះ ។ ម អក្ខរៈក្នុងបទថា **មេតំ** នេះ លោកពោលដោយជាបទសន្ធិ ។ បទថា **កត្តី ហោតិ** សេចក្តីថា ជាអ្នកមានប្រក្រតីពោលលើកខ្លួនថា ខ្ញុំជាអ្នកដល់ព្រមដោយសីល ។ បទថា **កត្ថតិ** សេចក្តីថា រមែងពោលដោយន័យដែលពោលហើយ ។ បទថា **វិកត្ថតិ** សេចក្តីថា រមែងពោលមានបែបផ្សេងៗ ។ បទថា **កត្ថនា** បានដល់ ដោយការពោល ។ បទថា **អារតោ** បានដល់ នៅក្នុងទីឆ្ងាយ ។ បទថា **វិរតោ** សេចក្តីថា ត្រេកអរដោយការប្រាសចាកដោយអំណាចឈានធ្វើងឋានៈ ។ បទថា **បដិវិរតោ** សេចក្តីថា ជាអ្នក

ចេញចាកឋានៈនោះហើយ មិនប្រកបដោយអាការៈទាំងពួងហើយត្រេកអរ បណ្ដាបទទាំងនោះ បទថា **អារតោ** គឺដូចឃើញបិសាចហើយគេចទៅ **វិរតោ** គឺដូចរត់ទៅដោយជុំវិញកាលដ៏រីជាន់ **បដិវិរតោ** គឺដូចទាហានច្បាំងញាំញី ស្រេចហើយទៅ ។

[ ៨៩ ] បទថា **ខីណាសវស្ស** បានដល់ ជាអ្នកមានអាសវៈ គឺកិលេស អស់ហើយ ។ បទថា **កម្មស្សូនោ** បានដល់ កិលេសជាហេតុខ្ពរឡើងនៃកម្ម ពោលគឺបុញ្ញាភិសង្ខារ អបុញ្ញាភិសង្ខារនិងអនេញ្ជាភិសង្ខារ ព្រោះផ្សាយឡើង ។ បទថា **តស្សិមេ** សេចក្ដីថា កិលេសជាហេតុផ្សាយឡើងទាំងនេះមិនមាន ដល់បុគ្គលនោះ គឺអ្នកមានអាសវៈអស់ហើយ ។

[ ៩០ ] ព្រះមានព្រះភាគកាលទ្រង់សម្ដែងបដិបទារបស់ព្រះខីណាស្រព យ៉ាងនេះហើយ ឥឡូវនេះ កាលនឹងសម្ដែងបដិបទារបស់តិរ្ថិយទាំងឡាយដែល មានទិដ្ឋិ ទើបពោលថា **បកប្បិតា សង្ខតា** ។

បណ្ដាបទទាំងនោះ បទថា **បកប្បិតា** សេចក្ដីថា ដែលបុគ្គលកំណត់ ហើយ ។ បទថា **សង្ខតា** សេចក្ដីថា ដែលបច្ច័យតាក់តែងហើយ ។ បទថា **យស្ស** សេចក្ដីថា ដែលបុគ្គលមានទិដ្ឋិណាមួយ ។ បទថា **ធម្មា** បានដល់ ទិដ្ឋិទាំងឡាយ ។ បទថា **បុរក្ខតា** បានដល់ ធ្វើទុកខាងមុខ ។ បទថា **សន្តិ** បានដល់ មាន ។ បទថា **អវីវទាតា** បានដល់ មិនផូរផង់ ។ បទថា **យទត្តនិ បស្សតិ អានិសំសំ តន្និស្សិតោ កុប្បបដិច្ចសន្តី** សេចក្ដីថា ទិដ្ឋិធម៌ទាំងនេះ របស់បុគ្គលទិដ្ឋិណាជាធម៌ដែលបុគ្គលធ្វើទុកខាងមុខ មិនសស្អាតមាន បុគ្គល

នោះ ជាបុគ្គលយ៉ាងនេះ គឺព្រោះឃើញសក្ការៈជាដើម ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ននិងអានិសង្សមានគតិវិសេសជាដើម ដែលប្រព្រឹត្តទៅក្នុងភពខាងមុខរបស់ទិដ្ឋិនោះក្នុងខ្លួន ព្រោះហេតុនោះ ទើបជាបុគ្គលអាស្រ័យទិដ្ឋិពោល គឺសន្តិ ដែលកម្រើក ដែលអាស្រ័យគ្នាកើតឡើង ព្រោះអាស្រ័យ អានិសង្សនោះនិងការកម្រើកនោះ កើតឡើងនិងព្រោះជាសន្តិសម្មុតិ បុគ្គលនោះគប្បីលើកខ្លួន ឬគប្បីបន្ទាបអ្នកដទៃដោយគុណនិងទោសដែលមិនមានពិត ព្រោះអាស្រ័យទិដ្ឋិនោះ ។

[ ៩១ ] បទថា **សង្ខតា** ជាមូលបទ ។ បទថា **សង្ខតា** សេចក្តីថា ដែលបច្ច័យទាំងឡាយប្រជុំគ្នាធ្វើ លោកពង្រីកបទដោយឧបសគ្គ ។ បទថា **អភិសង្ខតា** សេចក្តីថា ដែលបច្ច័យទាំងឡាយតាក់តែងច្រើនហើយ ។ បទថា **សណ្ឋបិតា** សេចក្តីថា តាំងទុកដោយប្រពៃដោយអំណាចនៃបច្ច័យនោះឯង ។ បទថា **អនិច្ចា** សេចក្តីថា ព្រោះមានហើយប្រែជាមិនមាន ។ បទថា **បដិច្ចសមុប្បន្នា** សេចក្តីថា អាស្រ័យវត្ថុនិងអារម្មណ៍កើតឡើង ។ បទថា **ខយធម្មា** សេចក្តីថា មានការអស់ទៅតាមលំដាប់ជាសភាវៈ ។ បទថា **វយធម្មា** សេចក្តីថា មានការវិនាសជុំវិញដោយអំណាចនៃការប្រព្រឹត្តទៅជាសភាវៈ ។ បទថា **វិរាគធម្មា** សេចក្តីថា មានការទៅប្រាសដោយមិនត្រឡប់ជាសភាវៈ ។ បទថា **និរោធធម្មា** សេចក្តីថា មានការរលត់ជាសភាវៈ អធិប្បាយថា មានការរលត់ដោយមានការមិនកើតឡើងជាធម្មតាជាសភាវៈ ។ បទថា **ទិដ្ឋិគតិកស្ស** សេចក្តីថា ដែលបុគ្គលអ្នកប្រកាន់ទិដ្ឋិ ៦២ តាំងនៅ ។

[ ៩២ ] បទថា **បុរេក្ខារា** សេចក្តីថា ធ្វើទុកខាងមុខ ។ បទថា **តណ្ហាធជោ** សេចក្តីថា ឈ្មោះថា **តណ្ហាធជោ** ដោយអត្ថថា លើកឡើង ឈ្មោះថា **តណ្ហាធជោ** ព្រោះអត្ថថា មានទង់ជ្វាលាគឺតណ្ហា ឈ្មោះថា **តណ្ហាកេតុ** ព្រោះអត្ថថា មានតណ្ហានោះឯងជាកំពូលទង់ ដោយអត្ថថា ត្រាច់ទៅខាងមុខ ។ បទថា **តណ្ហាធិបតេយ្យា** សេចក្តីថា ឈ្មោះថា **តណ្ហាធិបតេយ្យា** ព្រោះអត្ថថា តណ្ហា មកដោយភាពជាធំ ដោយអំណាចភាពជាធំ ដោយការពេញចិត្ត ម្យ៉ាងទៀត ឈ្មោះថា **តណ្ហាធិបតេយ្យា** ព្រោះអត្ថថា មានតណ្ហាជាធំ ក្នុងបទថា **ទិដ្ឋិធជោ** ជាដើម ក៏ន័យនេះដូចគ្នា ។ បទថា **អវោទាតា** សេចក្តីថា មិនបរិសុទ្ធិ ។ បទថា **សង្កិលិដ្ឋា** សេចក្តីថា សៅហ្មងឯង ។ បទថា **សង្កិលេសិកា** សេចក្តីថា ជាអារម្មណ៍ទីតាំងនៃការក្តៅក្រហាយ ។

[ ៩៣ ] បទថា **ទ្វេ អានិសំសេ បស្សតិ** បានដល់ រមែងឃើញគុណ ២ យ៉ាង ។ បទថា **ទិដ្ឋធម្មិកញ្ច អានិសំសំ** សេចក្តីថា អានិសង្សដែលជាធម៌ប្រចក្សក្នុងអត្តភាពនេះផងដែរ ។ បទថា **សម្បរាយិកំ** សេចក្តីថា អានិសង្សដែលគប្បីដល់ក្នុងបរលោក ។ បទថា **យំទិដ្ឋិកោ សត្ថា ហោតិ** បានដល់ សាស្តាជាអ្នកមានលទ្ធិណាមួយ ។ បទថា **តំទិដ្ឋិកា សាវកា ហោន្តិ** សេចក្តីថា សាវកទាំងឡាយ ដែលស្តាប់ពាក្យរបស់សាស្តានោះ ក៏ជាអ្នកមានលទ្ធិយ៉ាងនោះ ។ បទថា **សក្ករោន្តិ** សេចក្តីថា រមែងធ្វើឲ្យដល់សក្ការៈ ។ បទថា **គរុករោន្តិ** សេចក្តីថា រមែងធ្វើឲ្យដល់នូវសេចក្តីគោរព ។ បទថា **មានេន្តិ** សេចក្តីថា រមែងប្រព្រឹត្តស្រឡាញ់ដោយចិត្ត ។ បទថា **បូជេន្តិ** សេចក្តីថា

រមែងបូជាដោយនាំបច្ច័យ ៤ មកបូជា ។ បទថា **អបចិតឹ ករោន្តិ** សេចក្តីថា រមែងធ្វើឲ្យដល់នូវការកោតក្រែង ។ បណ្តាបទទាំងនោះ សាវកទាំងឡាយសក្ការៈ គឺតាក់តែងបច្ច័យ ៤ ធ្វើឲ្យប្រណីតៗថ្វាយដល់សាស្តាណា សាស្តានោះឈ្មោះថា សាវកទាំងឡាយធ្វើសក្ការៈហើយ ។ សាវកទាំងឡាយរមែងផ្តើម ថ្វាយនូវសេចក្តីគោរពក្នុងសាស្តាណា សាស្តានោះឈ្មោះថា ដែលសាវកទាំងឡាយគោរពហើយ សាវកទាំងឡាយរមែងមានចិត្តប្រព្រឹត្តស្រឡាញ់នូវសាស្តាណា សាស្តានោះឈ្មោះថា ដែលសាវកទាំងឡាយរាប់អានហើយ សាវកទាំងឡាយ រមែងធ្វើយ៉ាងនោះដល់សាស្តាណា សាស្តានោះឈ្មោះថា ដែលសាវកទាំងឡាយបូជាហើយ សាវកទាំងឡាយរមែងធ្វើនូវការគោរពក្រៃលែង មានការក្រាបថ្វាយបង្គំ ការក្រោកទទួល ការប្រណម្យអញ្ជលីជាដើម ដល់សាស្តាណា សាស្តានោះឈ្មោះថា ដែលសាវកទាំងឡាយធ្វើនូវការកោតក្រែងហើយ អាចារ្យពួកខ្លះអធិប្បាយថា ធ្វើសក្ការៈដោយកាយ ធ្វើនូវការគោរពដោយវាចា រាប់អានដោយចិត្ត បូជាដោយលាភ ។ បទថា **អលំ នាគត្តាយ វា** សេចក្តីថា ល្មម គឺគួរដើម្បីជាស្តេចនាគ ។ បទថា **សុបណ្ណត្តាយ វា** សេចក្តីថា ដើម្បីជាស្តេចគ្រុឌ ។ បទថា **យក្ខត្តាយ វា** សេចក្តីថា ដើម្បីភាពជាយក្ខសេនាបតី ។ បទថា **អសុរត្តាយ វា** សេចក្តីថា ដើម្បីជាអសុរៈ ។ បទថា **គន្ធព្វត្តាយ វា** សេចក្តីថា ដើម្បីការកើតក្នុងពួកទេវគន្ធព្វ ។ បទថា **មហារាជត្តាយ វា** សេចក្តីថា ដើម្បីភាពជាទេវមហារាជ ៤ អង្គណាមួយ ។ បទថា **ឥន្ទត្តាយ វា** សេចក្តីថា ដើម្បីភាពជាសក្កៈ ។

បទថា **ព្រហ្មត្តាយ វា** សេចក្តីថា ដើម្បីភាពជាព្រហ្មអង្គណាមួយក្នុងពួកព្រហ្មជាដើម ។ បទថា **ទេវត្តាយ វា** សេចក្តីថា ដើម្បីភាពជាសម្មតិទេពជាដើមអង្គណាមួយ ។ បទថា **សុទ្ធិយា** សេចក្តីថា ល្មម គឺគួរដើម្បីភាពជាអ្នកបរិសុទ្ធ ។ បទថា **វិសុទ្ធិយា** សេចក្តីថា ដើម្បីភាពជាអ្នកបរិសុទ្ធបរិបូរវៀរចាកមន្ទិលទាំងពួង ។ បទថា **បរិសុទ្ធិយា** សេចក្តីថា ដើម្បីសេចក្តីបរិសុទ្ធដោយអាការៈទាំងពួង ។

បណ្តាបទទាំងនោះ ដើម្បីភាពជាធំក្នុងកំណើតតិរច្ឆាន ឈ្មោះថា **សុទ្ធិយា** ដើម្បីភាពជាធំក្នុងទេវលោក ឈ្មោះថា **វិសុទ្ធិយា** ដើម្បីភាពជាធំក្នុងព្រហ្មលោក ឈ្មោះថា **បរិសុទ្ធិយា** ដើម្បីឈានកន្លង ៨៤០០០ កប្បហើយរួចផុតទៅ ឈ្មោះថា **មុត្តិយា** ដើម្បីផុតទៅដោយមិនមានអន្តរាយ ឈ្មោះថា **វិមុត្តិយា** ដើម្បីផុតទៅដោយអាការៈទាំងពួង ឈ្មោះថា **បរិមុត្តិយា** ។ បទថា **សុជ្ឈន្តិ** សេចក្តីថា រមែងដល់នូវសេចក្តីបរិសុទ្ធ ដោយភាពជាបព្វជិតក្នុងលទ្ធិដទៃៗនោះ ។ បទថា **វិសុជ្ឈន្តិ** សេចក្តីថា រមែងបរិសុទ្ធិដោយវិធីច្រើនយ៉ាង ដោយភាពជាបុគ្គលដែលកាន់យកបព្វជ្ជា ប្រកបដោយការបដិបត្តិ ។ បទថា **បរិសុជ្ឈន្តិ** សេចក្តីថា ដល់នូវការសម្រេចហើយបរិសុទ្ធិដោយអាការៈទាំងពួង រមែងផុតទៅដោយធម៌ដែលជាលទ្ធិដទៃៗរបស់សាស្តាទាំងនោះ រមែងរួចស្រឡះដោយឱវាទរបស់សាស្តានោះ រមែងរួចចេញដោយអនុសាសន៍របស់សាស្តានោះ ។ បទថា **សុជ្ឈិស្សាមិ** ជាដើម លោកពោលទុកដោយអំណាចនៃអនាគត ។ បទថា **អាយតឹ ផលចាជិកន្ថិ**

សេចក្តីថា សង្ឃឹមផល គឺ វិបាកក្នុងអនាគត ព្រោះថា ទិដ្ឋិដែលពួកមេលទ្ធិប្រព្រឹត្តកន្លងនេះ កាលសម្រេចផល រមែងឲ្យសម្រេចជាសត្វនរកខ្លះ ជាសត្វក្នុងកំណើតតិរច្ឆានខ្លះ ។

[ ៩៤ ] បទថា **អច្ចន្តសន្តិ** សេចក្តីថា សន្តិគឺការចេញទៅដោយបរិបូរ ។ បទថា **តទង្គសន្តិ** សេចក្តីថា ឈាន ឈ្មោះថា **តទង្គសន្តិ** ព្រោះអត្ថថាញុំាងអង្គដែលមិនមែនគុណមាននីវរណៈជាដើមឲ្យស្ងប់ ដោយអង្គដែលជាគុណមានបឋមជ្ឈានជាដើម ។ បទថា **សម្មតិសន្តិ** សេចក្តីថា សន្តិដោយ ទិដ្ឋិដោយអំណាចពោលរួម ។ ដើម្បីសម្តែងសន្តិទាំងនោះជាចំណែកៗទើបព្រះសារីបុត្តត្ថេរពោលថា **កតមា អច្ចន្តសន្តិ** ជាដើម ។

បទថា **អមតំ និព្វានំ** ជាដើម មានអត្ថដូចពោលហើយខាងដើមនោះឯង ។ បទទាំងឡាយថា **បឋមំ ឈានំ សមាបន្នស្ស នីវរណា សន្តា ហោន្តិ** ជាដើម លោកពោលដោយអំណាចការបរិបូណ៌ ខាងក្នុងអប្បនា ។ ម្យ៉ាងទៀត បទថា **សម្មតិសន្តិ** ព្រះមានព្រះភាគ ទ្រង់បំណងយកថា **សន្តិ** ក្នុងគាថានេះ ( **អបិ ច សម្មតិសន្តិ ឥមស្មឹ អត្ថេ អធិប្បេតា សន្តិ** ) ព្រះសារីបុត្តត្ថេរហាមសន្តិ ២ យ៉ាងក្រៅអំពីនេះ សម្តែងសម្មតិសន្តិប៉ុណ្ណោះ ។

បទថា **កុប្បសន្តិ** បានដល់ សន្តិដែលកម្រើក ដោយអំណាចឲ្យកើតវិបាក និងដោយអំណាចការប្រែប្រួល ។ បទថា **បកុប្បសន្តិ** បានដល់សន្តិដែលកម្រើកដោយពិសេស ។ បទថា **ឃដិតសន្តិ** បានដល់ សន្តិដែលញាប់ញ័រ ។ បទថា **សមេរិតសន្តិ** បានដល់ សន្តិ ដែលកម្រើកដោយ

ពិសេស ។ បទថា **ចលិតសន្ធិ** ជាវេវចនៈរបស់បទថា **សមេរិតសន្ធិ** នោះឯង ។ បទថា **យត្ថិតសន្ធិ** បានដល់ សន្ធិដែលបៀតបៀន ។ បទថា **សន្តី និស្សិតោ** បានដល់ អាស្រ័យសន្តិ ពោលគឺទិដ្ឋិ ។ បទថា **អស្សិតោ**[១] បានដល់ ចងហើយគឺអាស្រ័យដោយវិសេស ។ បទថា **អញ្ញីណោ** បានដល់ ដូចគ្នាតែមួយ ។

[ ៩៥ ] កាលបុគ្គលអាស្រ័យហើយយ៉ាងនេះ ជាបឋមការ ជាប់ជំពាក់គឺទិដ្ឋិ និងការជ្រើសរើសក្នុងធម៌ទាំងឡាយ ហើយ ប្រកាន់ បុគ្គលមិនងាយប្រព្រឹត្តកន្លងបានទេ ព្រោះហេតុនោះ ទើបជនរមែងលះបង់ផង ប្រកាន់ផងនូវធម៌ ក្នុងការជាប់ជំពាក់ ទាំងនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ទិដ្ឋីនិវេសា** សេចក្តីថា ការប្រកាន់មាំដោយទិដ្ឋិ ពោលគឺការប្រកាន់មាំថា វត្ថុនេះពិត ។ បទថា **ន ហិ ស្វាតិវត្តា** សេចក្តីថា រមែងមិនជាវត្ថុដែលគប្បីឈានកន្លងបានដោយងាយ ។ បទថា **ធម្មេសុ និច្ឆេយ្យ សមុគ្គហីតំ** មានអធិប្បាយថា ការប្រកាន់មាំដាច់ខាតដោយទិដ្ឋិ ដែលជាទីប្រកាន់មាំដែលត្រូវបុគ្គលប្រកាន់មាំនោះៗ ក្នុងធម៌គឺទិដ្ឋិ ៦២ ឲ្យប្រព្រឹត្តទៅ ក៏មិនជាវត្ថុដែលឈានកន្លងបានដោយងាយ ។ បទថា **តស្មា នរោ តេសុ និវេសនេសុ និរស្សតី អាទិយតី ច ធម្មំ** អធិប្បាយថា ព្រោះមិនជាវត្ថុដែលឈានកន្លងបានដោយងាយដូច្នោះក្នុងការប្រកាន់មាំដោយទិដ្ឋិទាំង

---

១-បិដកខ្មែរមិនមានបទនេះ ។

នោះឯង នរជនរមែងលះបង់ខ្លះ រមែងប្រកាន់ខ្លះ រមែងលះបោលខ្លះ រមែងចាប់ទុកខ្លះនូវសាស្តាដែលពោលនូវធម៌ មានសីលពត សីលគោ សីលវត្ត ការធ្វើរដោយក្តក់ ៥ ការលោតចូលជ្រោះដែលទេវតាសណ្ឋិត ការធ្វើសេចក្តីព្យាយាមដោយការអត្តកិលមថានុយោគ ប្រហោងទិងដេកលើបន្លាជាដើម និងនូវធម៌នោះៗ ប្រភេទជាពួកជាដើម ដូចស្វាព្រៃលះបង់មែកឈើខ្លះ កាន់យកមែកឈើខ្លះនោះៗ កាលលះខ្លះ កាន់យកខ្លះ យ៉ាងនេះ គប្បីញ៉ាំងយសនិងការវិនាសយស ឲ្យកើតឡើងដល់ខ្លួនឯងខ្លះ ដល់អ្នកដទៃខ្លះ ដោយគុណនិងទោសទាំងឡាយសូម្បីមិនមាន ព្រោះភាពជាអ្នកមានចិត្តមិនតាំងមាំ ។

[ ៩៦ ] បទថា **ទុរតិវត្តា** សេចក្តីថា លំបាកនឹងឈានកន្លង ។ បទថា **ទុត្តរា** សេចក្តីថា ឆ្លងឡើងបានលំបាក ។ បទថា **ទុប្បតរា ទុស្សមតិក្កមា ទុវីតិវត្តា** លោកពង្រីកដោយឧបសគ្គ ។

[ ៩៧ ] បទថា **ធិច្ឆនិត្វា** សេចក្តីថា ធ្វើនូវការសម្រេចដោយអំណាចនៃការទៀង ។ បទថា **វិនិច្ឆនិត្វា** សេចក្តីថា វិនិច្ឆ័យដោយវិធីផ្សេងៗដោយអំណាចអត្តា ។ បទថា **វិចិនិត្វា** សេចក្តីថា ស្វែងរក ។ បទថា **បវិចិនិត្វា** សេចក្តីថា ស្វែងរកដោយអាការៈទាំងពួងដោយការប្រកាន់មាំថាអត្តា បាឋៈថា **ធិចិនិត្វា វិច្ឆិនិត្វា** ក៏មាន ។ បទថា **ឱធិស្សគ្គាហោ** សេចក្តីថា កាន់យកដោយមិនពិសេស ។ បទថា **វិលគ្គាហោ** សេចក្តីថា កាន់យកដោយអំណាចចំណែកបែងចែក ដូចប្រយោគថា **វិលសោ បដិវិភជិត្វា** ប្រែថា វិលែកជាចំណែកជាដើម ។ បទថា **វរគ្គាហោ** សេចក្តីថា កាន់យកដ៏ឧត្តម ។

បទថា **កោដ្ឋាសគ្គាហោ** សេចក្តីថា កាន់យកដោយអំណាចអវយវៈ ។ បទថា **ឧច្ចយគ្គាហោ** សេចក្តីថា កាន់យកដោយអំណាចជាគំនរ ។ បទថា **សមុច្ចយគ្គាហោ** សេចក្តីថា កាន់យកដោយអំណាចជាចំណែកៗ និងដោយអំណាចជាគំនរ ។ បទថា **ឥទំ សច្ចំ** សេចក្តីថា នេះឯងជាសភាវៈ ( ពិត ) ។ បទថា **តច្ឆំ** បានដល់ ជាសភាវៈពិត គឺមិនមែនភាវៈប្រែប្រួល ។ បទថា **តថំ** បានដល់ វៀរចាកការប្រែប្រួល ។ បទថា **ភូតំ** បានដល់ មានពិត ។ បទថា **យាថាវំ** បានដល់ ជាសភាវៈយ៉ាងនោះឯង ។ បទថា **អវិបរីតំ** បានដល់ មិនប្រែប្រួល ។

[ ៩៩-១០០ ] បទថា **និរស្សតិ** សេចក្តីថា រមែងលះបង់ គឺរមែងបោះបង់ ។ បទថា **បរិច្ឆិន្ទនាយ វា** សេចក្តីថា ដោយការចង្អុលបង្ហាញដោយមនុស្សដទៃ ។ បទថា **អនភិសម្ភុណន្តោ វា** បានដល់ មិនសម្រេចបំណងឬមិនអាច ទើបលះបង់ ។ បទថា **បរោ វិច្ឆិន្ទតិ** សេចក្តីថា បុគ្គលដទៃធ្វើនូវការបែក ។ បទថា **នេត្ថ** សេចក្តីថា មិនមានក្នុងលទ្ធិនេះ ។ បទថា **សីលំ អនភិសម្ភុណន្តោ** សេចក្តីថា មិនញ៉ាំងសីលឲ្យដល់ព្រម ។ បទថា **សីលំ និរស្សតិ** សេចក្តីថា រមែងលះបង់នូវសីល ក្នុងបទដទៃៗបន្ទាប់អំពីនេះក៏មានន័យដូច្នេះឯង ។

បុគ្គលណា ឈ្មោះថា អ្នកមានបញ្ញា ព្រោះប្រកបដោយបញ្ញាគ្រឿងកម្ចាត់ទោសមានមិច្ឆាទិដ្ឋិទាំងពួងជាដើម ទិដ្ឋិដែលកំណត់ហើយក្នុងភពតូចនិងភពធំរមែងមិនមានដល់បុគ្គលអ្នកមានបញ្ញានោះក្នុងទីណាមួយឡើយ ក្នុងលោក

ព្រោះបុគ្គលអ្នកមានបញ្ញាលះនូវមាយានិងមានះបានហើយ ជាអ្នកមិនមានកិលេសជាគ្រឿងចូលដល់ គប្បីទៅដោយកិលេសណាមួយ លោកអធិប្បាយទុកដូចម្តេច លោកអធិប្បាយថា ទិដ្ឋិជាគ្រឿងកំណត់ក្នុងភពនោះៗ រមែងមិនមានដល់បុគ្គលដែលឈ្មោះថាមានបញ្ញា ព្រោះប្រកបដោយធម៌ជាគ្រឿងកម្ចាត់ គឺដល់ព្រះអរហន្តដែលមានបាបទាំងពួងកម្ចាត់ហើយ ក្នុងទីណាមួយក្នុងលោក បុគ្គលនោះឈ្មោះថាជាអ្នកមានបញ្ញា ព្រោះមិនមានទិដ្ឋិនោះនិងព្រោះលះមាយានិងមានះនោះដែលពួកតិរ្ថិយទាំងឡាយប្រើបិទបាំងកម្មអាក្រក់ ដែលខ្លួនធ្វើហើយដល់នូវអគតិយ៉ាងនេះ គប្បីទៅដោយទោសទាំងឡាយ មានរាគៈជាដើមណាមួយ បុគ្គលនោះជាអ្នកមិនមានកិលេសជាគ្រឿងចូលដល់ គប្បីទៅកាន់បញ្ញត្តិ ក្នុងទិដ្ឋិធម៌ឬក្នុងគតិវិសេស មាននរកជាដើម ក្នុងសម្បរាយភពដោយកិលេសណាមួយ ព្រោះថាបុគ្គលនោះឈ្មោះថាជាអ្នកមិនមានកិលេសជាគ្រឿងចូលដល់ ព្រោះមិនមានកិលេសជាគ្រឿងចូលដល់គឺតណ្ហានិងទិដ្ឋិទាំងពីរយ៉ាង ។

[ ១០១ ] បទថា **កឹការណា** បានដល់ ព្រោះហេតុអ្វី ។ បទថា **ធោនា វុច្ចតិ បញ្ញា** សេចក្តីថា បញ្ញា លោកហៅថា **ធោនា** ព្រោះហេតុអ្វី ។ បទថា **តាយ បញ្ញាយ កាយទុច្ចរិតំ** សេចក្តីថា ដោយបញ្ញានោះ ដែលមានប្រការដូចពោលហើយ ( រមែងកម្ចាត់ ) នូវកាយទុច្ចរិត ព្រោះអត្ថថា ប្រព្រឹត្តអាក្រក់ ឬព្រោះប្រព្រឹត្តវិនាសដោយអំណាចកិលេសដែលប្រព្រឹត្តទៅផ្លូវកាយ ។ បទថា **ធុតញ្ច ធោតញ្ច** បានដល់ ឲ្យញាប់ញ័រហើយនិងជម្រះហើយ ។

*បទថា* **សច្ឆេកតញ្ញុ** *បានដល់ ជម្រះហើយដោយប្រពៃ ។ បទថា* **និច្ឆេកតញ្ញុ** *សេចក្តីថា បោក គក់ហើយដោយល្អ ដោយពិសេស ។ បទថា* **រាគោ ធុតោ** *៥ ជាដើម គប្បីប្រកបដោយអំណាចនៃមគ្គ ៤ ។*

*បទថា* **សម្មាទិដ្ឋិយា មិច្ឆាទិដ្ឋិ ធុតា ៥** *សេចក្តីថា មិច្ឆាទិដ្ឋិត្រូវធ្វើឲ្យញាប់ញ័រ ត្រូវធ្វើឲ្យកម្រើក ជម្រះបានដោយសម្មាទិដ្ឋិដែលសម្បយុត្តដោយមគ្គ សូម្បីក្នុងសម្មាសង្កប្បៈជាដើមក៏ន័យនេះឯង សមដូចព្រះតម្រាស់ដែលត្រាស់ទុក ( ក្នុងទីឃនិកាយបាដិកវគ្គ ) ថា បុគ្គលមានគំនិតយល់ត្រូវហើយការយល់ខុសក៏សាបសូន្យអស់ ដូច្នេះ គប្បីឲ្យព្រះសូត្រពិស្តារ ។ បទថា* **សម្មាញាណេន** *បានដល់ ញាណដែលសម្បយុត្តដោយមគ្គ ឬបច្ចវេក្ខណញ្ញាណ ។ បទថា* **មិច្ឆាញាណំ** *បានដល់ ញាណដែលវិបរិត គឺញាណដែលមិនពិត និងមោហៈដែលកើតឡើងដោយអាការៈធ្វើបាប ដោយអំណាចការគិតដែលសុខុមក្នុងការធ្វើបាបទាំងឡាយ ហើយពិចារណាថា អញធ្វើល្អហើយ ។ បទថា* **សម្មាវិមុត្តិយា មិច្ឆាវិមុត្តិ** *សេចក្តីថា សមុច្ឆេទវិមុត្តិជាគ្រឿងកម្ចាត់នូវវិមុត្តិដែលវិបរិត គឺវិមុត្តិដែលមិនពិតនោះឯង ដែលខ្ជួនសម្គាល់ថា ចេតោវិមុត្តិ ។*

*បទថា* **អរហា ឥមេហិ ធោនិយេហិ ធម្មេហិ** *សេចក្តីថា ព្រះអរហន្តតាំងនៅឆ្ងាយចាកកិលេស មានរាគៈជាដើម រមែងជាអ្នកចូលដល់ដោយធម៌ជាគ្រឿងកម្ចាត់កិលេសដែលមានប្រការដូចពោលហើយទាំងនេះ ។ បទថា* **ធោនោ** *បានដល់ បុគ្គលអ្នកមានបញ្ញា ព្រោះហេតុនោះ ទើបព្រះសារីបុត្តត្រេរពោល*

ថា **សោ ធុតរាគោ** ជាដើម ។

[ ១០២ ] បទថា **មាយា វុច្ចតិ វញ្ចនិកា ចរិយា** សេចក្តីថា ឈ្មោះថា **វញ្ចនិកា ចរិយា** ព្រោះអត្ថថា មានកិរិយាបោកបញ្ឆោតគឺធ្វើនូវការបោកបញ្ឆោត ។ បទថា **តស្ស បដិច្ឆាទនហេតុ** សេចក្តីថា ព្រោះហេតុដែលមិនប្រកាសទុច្ចរិតទាំងនោះ ។ បទថា **បាបិកំ ឥច្ឆំ បណិទហតិ** សេចក្តីថា រមែងញុំាងសេចក្តីប្រាថ្នាលាមកឲ្យតាំងឡើង ។ បទថា **មា មំ ជញ្ញាតិ ឥច្ឆតិ** សេចក្តីថា រមែងប្រាថ្នាថា អ្នកដទៃកុំបីដឹងអញថា អញធ្វើបាប ។ បទថា **សង្កប្បេតិ** សេចក្តីថា ញុំាងវិតក្កឲ្យកើតឡើង ។ បទថា **វាចំ ភាសតិ** សេចក្តីថា ភិក្ខុទាំងដែលដឹងឈានកន្ទងបញ្ញត្តិ ធ្វើនូវកម្មធ្ងន់ ធ្វើជាអ្នកស្ងប់ពោលថា ឈ្មោះថា ការធ្វើខុសព្រះវិន័យរបស់ពួកយើងមិនមាន ។ បទថា **កាយេន បរក្កមតិ** សេចក្តីថា ប្រព្រឹត្តវត្តដោយកាយ ព្រោះបិទបាំងទោសដែលមានថា អញធ្វើកម្មអាក្រក់នេះហើយ បុគ្គលណាមួយកុំបីដឹងឡើយ ។ ឈ្មោះថា មានមាយា ព្រោះអត្ថថា មានមាយាបោកបញ្ឆោត ។ ភាវៈនៃបុគ្គលមានមាយា ឈ្មោះថា **មាយាវិតា** ។ ឈ្មោះថា **អច្ចសរា** ព្រោះអត្ថថា ជាគ្រឿងមិនទឹកដល់យ៉ាងក្រៃលែង ព្រោះធ្វើហើយនិងបិទបាំងអំពើអាក្រក់ទៀតរបស់សត្វ ។ ឈ្មោះថា **វញ្ចនា** ព្រោះអត្ថថា បិទបាំងដោយសម្តែងរូបភាពដទៃ ដោយកិរិយាផ្លូវកាយនិងផ្លូវវាចា ។ ឈ្មោះថា **និកតិ** ព្រោះអត្ថថា ជាគ្រឿងបន្ទំរបស់សត្វទាំងឡាយ អធិប្បាយថា ធ្វើឲ្យខុស ។ ឈ្មោះថា **និកិរណា** ព្រោះបោះអំពើអាក្រក់ទាំងឡាយចេញទៅថា ខ្ញុំមិនបានធ្វើយ៉ាងនេះទេ ។ ឈ្មោះថា **បរិហរណា** ព្រោះ

បន្លែរទៅថា ខ្ញុំមិនបានធ្វើយ៉ាងនេះទេ ។ ឈ្មោះថា **គូហនា** ព្រោះបិទបាំងដោយកាយជាដើម ។ ឈ្មោះថា **បរិគូហនា** ព្រោះលាក់ដោយការៈជុំវិញ ។ ឈ្មោះថា **ឆាទនា** ព្រោះអត្ថថា បិទបាំងទុកដោយកាយកម្មនិងវចីកម្មដូចបិទលាមកទុកដោយស្មៅនិងស្លឹកឈើដូច្នោះ ។ ឈ្មោះថា **បរិច្ឆាទនា** ព្រោះការបិទតាមចំណែកដោយប្រការទាំងពួង ។ ឈ្មោះថា **អនុត្តានិកម្មំ** ព្រោះអត្ថថា មិនធ្វើឲ្យរាក់ហើយសម្តែង ។ ឈ្មោះថា **អនាវិកម្មំ** ព្រោះអត្ថថា មិនធ្វើឲ្យប្រាកដហើយសម្តែង ។ ឈ្មោះថា **វោច្ឆាទនា** ព្រោះបិទទុកយ៉ាងល្អ ។ ឈ្មោះថា **ចាបកិរិយា** ព្រោះធ្វើអាក្រក់ដដែលទៀតដោយការបិទបាំងអំពើអាក្រក់ដែលធ្វើហើយ ។ បទថា **អយំ វុច្ចតិ** សេចក្តីថា បុគ្គលប្រកបដោយធម្មជាតិណា រមែងដូចជារណ្តើកភ្លើងដែលផេះបិទទុក ដូចដង្គត់ដែលទឹកបិទទុក និងដូចសស្ត្រាដែលសំពត់ចាស់រុំទុក ធម្មជាតិនេះ ឈ្មោះថា **មាយា** ព្រោះមានលក្ខណៈបិទបាំងអំពើអាក្រក់ដែលធ្វើហើយ ។

បទថា **ឯកវិធេន មានោ** សេចក្តីថា ការប្រកាន់ខ្លួនដោយកំណត់តែម្យ៉ាង គឺដោយចំណែកមួយ ។ បទថា **យា ចិត្តស្ស ឧណ្ណតិ** សេចក្តីថា រមែងលើកចិត្តឡើង ឈ្មោះថា ការប្រកាន់ខ្លួន ។ ក្នុងបទនេះ លោកពោលដល់ការប្រកាន់ខ្លួនដែលឲ្យកើតឡើងដោយមិនពាល់ត្រូវបុគ្គល ។

បទថា **អត្តុក្កំសនមានោ** សេចក្តីថា ការប្រកាន់ខ្លួនដោយការតាំងខ្លួនទុកខាងលើអ្នកដទៃ ។ បទថា **បរវម្ភនមានោ** សេចក្តីថា ការប្រកាន់ខ្លួនដោយការធ្វើអ្នកដទៃ ឲ្យថោកថយជាងខ្លួន ។ ការប្រកាន់ខ្លួនពីរយ៉ាងនេះ

លោកពោលដោយអំណាចអាការៈដែលប្រព្រឹត្តទៅយ៉ាងនោះដោយច្រើន ។

បទថា **សេយ្យោហមស្មីតិ មានោ** សេចក្តីថា ការប្រកាន់ខ្លួនដែលកើតឡើងថា អញល្អជាងគេ ព្រោះអាស្រ័យជាតិជាដើម ឈ្មោះថា ការប្រកាន់ខ្លួនថា មិនមានអ្នកណាស្មើ ក្នុងការប្រកាន់ខ្លួនថាស្មើគេជាដើមក៏ន័យនេះឯង ។ ការប្រកាន់ខ្លួន ៣ យ៉ាងនេះ លោកក៏ពោលដោយអំណាចតាមអាការៈដែលប្រព្រឹត្តទៅដោយមិនអាស្រ័យការផ្សេងគ្នា របស់បុគ្គលដោយប្រការដូច្នេះ ។ បណ្តាការប្រកាន់ខ្លួនទាំងនោះ ការប្រកាន់ខ្លួននីមួយៗ រមែងកើតឡើងដល់បុគ្គលល្អជាង បុគ្គលស្មើគ្នានិងបុគ្គលអន់ជាងទាំង ៣ ប្រភេទ ។ បណ្តាបុគ្គល ៣ ពួកនោះ ការប្រកាន់ខ្លួនថា អញល្អជាងគេ ជាការប្រកាន់ខ្លួនតាមសេចក្តីពិត របស់បុគ្គលដែលល្អជាងគេនោះឯង មិនមែនការប្រកាន់ខ្លួនតាមពិត របស់បុគ្គលដ៏សេស ។ ការប្រកាន់ខ្លួនថា អញស្មើគេ ជាការប្រកាន់ខ្លួនតាមសេចក្តីពិតរបស់បុគ្គលដែលស្មើគ្នានោះឯង មិនមែនការប្រកាន់ខ្លួនតាមសេចក្តីពិតរបស់បុគ្គលដ៏សេស ។ ការប្រកាន់ខ្លួនថា អញអាក្រក់ជាងគេ ជាការប្រកាន់ខ្លួនតាមសេចក្តីពិត របស់បុគ្គលដែលអាក្រក់ជាងគេនោះឯង មិនមែនការប្រកាន់ខ្លួនតាមសេចក្តីពិតរបស់បុគ្គលដ៏សេស ។ ការប្រកាន់ខ្លួន ៤ យ៉ាង លោកពោលដោយអំណាចលោកធម៌ ការប្រកាន់ខ្លួន ៥ យ៉ាង លោកពោលដោយអំណាចកាមគុណ ៥ ការប្រកាន់ខ្លួន ៦ យ៉ាង លោកពោលដោយអំណាចការដល់ព្រមនៃចក្ខុជាដើម ។ បណ្តាបទនោះ បទថា **មានំ ជនេតិ** សេចក្តីថា ញ៉ាំងនូវការប្រកាន់ខ្លួនឲ្យកើតឡើង ។

ក្នុងនិទ្ទេស គឺការប្រកាន់ខ្លួន ៧ យ៉ាង មានវិនិច្ឆ័យដូចតទៅនេះថា បទថា **មានោ** បានដល់ ការប៉ោងឡើង ។ បទថា **អតិមានោ** បានដល់ ការប្រកាន់ខ្លួនដែលកើតឡើង ដោយអំណាចពោលលើកខ្លួនថា អ្នកដែលស្មើជាមួយអញដោយជាតិជាដើមមិនមាន ។

បទថា **មានាតិមានោ** បានដល់ ការប្រកាន់ខ្លួនដែលកើតឡើងថា កាលមុនបុគ្គលនេះឯងស្មើអញ ឥឡូវនេះ អញប្រសើរ បុគ្គលនេះជាអ្នកថោកថយជាង ការប្រកាន់ខ្លួននេះដូចភារៈត្រួតលើភារៈ ។ ព្រះសារីបុត្តត្រូវពោលថា **មានាតិមានោ** ដើម្បីសម្តែងថា ឈ្មោះថា ការប្រកាន់ខ្លួនក្រៃលែងជាងមុនអាស្រ័យការប្រកាន់ខ្លួនថា ស្មើគេដែលមានក្នុងកាលមុន ។

បទថា **ឱមានោ** បានដល់ ការប្រកាន់ខ្លួនថា អាក្រក់ជាង ។ ការប្រកាន់ខ្លួនដែលលោកពោលថា អញជាមនុស្សអាក្រក់ ដូច្នេះឈ្មោះថា ការប្រកាន់ខ្លួនថាអាក្រក់ ។ ម្យ៉ាងទៀត គប្បីជ្រាបការប្រកាន់ខ្លួននេះថា ការប្រកាន់ខ្លួនថាអាក្រក់ ក្នុងបទនេះដោយអំណាចធ្វើខ្លួនទុកខាងក្រោម ប្រព្រឹត្តទៅយ៉ាងនេះថា ឯងជាអ្នកមានជាតិ ជាតិរបស់ឯងដូចជាតិក្អែក ឯងជាអ្នកមានគោត្ត គោត្តរបស់ឯងដូចជាគោត្តចណ្ឌាល ឯងមានសំឡេង សំឡេងរបស់ឯងដូចសំឡេងក្អែក ។

បទថា **អធិមានោ** សេចក្តីថា ការប្រកាន់ខ្លួនថាសម្រេចហើយ ដែលកើតឡើងដល់បុគ្គលដែលមិនទាន់សម្រេចសច្ចៈ ៤ តែមានការសម្គាល់ថាសម្រេចហើយ ជាអ្នកមានការសម្គាល់ក្នុងកិច្ចដែលគប្បីធ្វើដោយមគ្គ ៤ ដែល

ខ្លួនមិនទាន់បានធ្វើ ថាធ្វើហើយ ជាអ្នកមានការសម្គាល់ក្នុងធម៌ គឺសច្ចៈ ៤ ដែលខ្លួនមិនទាន់សម្រេច ថាសម្រេចហើយ ជាអ្នកមានសេចក្តីសម្គាល់ក្នុងព្រះអរហត្តដែលខ្លួនមិនទាន់ធ្វើឲ្យជាក់ច្បាស់ថា ធ្វើឲ្យជាក់ច្បាស់ហើយ ឈ្មោះថា ការសម្គាល់ខ្លួនខុស ការសម្គាល់ខ្លួនខុសនេះ រមែងកើតឡើងដល់បុគ្គលណា រមែងមិនកើតឡើងដល់បុគ្គលណា ឆ្លើយថា រមែងមិនកើតឡើងដល់ព្រះអរិយសាវកឡើយ ព្រោះព្រះអរិយសាវកនោះកើតសោមនស្សក្នុងការពិចារណាមគ្គ ផល និព្វាន និងកិលេសដែលលះបានហើយនិងកិលេសដែលនៅសេសសល់ មិនមានការសង្ស័យក្នុងការចាក់ធ្លុះអរិយគុណ ហេតុនោះ ការប្រកាន់ខ្លួនថា អញជាព្រះសកទាគាមីជាដើម ទើបមិនកើតឡើងដល់ព្រះសោតាបន្នជាដើម ។ ការប្រកាន់ខ្លួននេះ រមែងមិនកើតឡើងដល់អ្នកទ្រុស្តសីល ព្រោះអ្នកទ្រុស្តសីលនោះជាអ្នកអស់សង្ឃឹម ក្នុងការសម្រេចអរិយគុណនោះឯង រមែងមិនកើតឡើងដល់អ្នកមានសីលដែលលះកម្មដ្ឋាន គិតតែពីដេកលក់រឿយៗ ។ តែរមែងកើតឡើងដល់បុគ្គលមានសីលបរិសុទ្ធ ជាអ្នកមិនប្រមាទក្នុងកម្មដ្ឋាន កំណត់នាមរូប ឆ្លងសេចក្តីសង្ស័យបានដោយបច្ចយបរិគ្គហញ្ញាណ លើកឡើងកាន់ត្រៃលក្ខណ៍ ពិចារណាសង្ខារធម៌ ផ្តើមវិបស្សនា ។ កាលកើតឡើង រមែងជាអ្នកបានសមថៈសុទ្ធៗ ខ្លះជាអ្នកបានវិបស្សនាសុទ្ធៗ ខ្លះរមែង ( សម្គាល់ថា ) តាំងនៅក្នុងរវាង ( សោតាបន្ននិងអនាគាមី ) ។ បុគ្គលនោះ កាលមិនឃើញកិលេសកម្រើក ១០ ឆ្នាំខ្លះ ២០ ឆ្នាំខ្លះ ៣០ ឆ្នាំខ្លះ រមែងសម្គាល់ថា អញជាសោតាបន្នក៏មាន ជាសកទាគាមីក៏មាន ជាព្រះ

អនាគាមីក៏មាន តែបុគ្គលណាបានសមថៈនិងវិបស្សនារមែង ( សម្គាល់ថា ) តាំងនៅក្នុងអរហត្តប៉ុណ្ណោះ ។ ដ្បិតថា លោកសង្កត់កិលេសទាំងឡាយបានដោយកម្លាំងសមាធិ កំណត់សង្ខារទាំងឡាយបានដោយកម្លាំងវិបស្សនា ហេតុនោះទើបកិលេសទាំងឡាយមិនកម្រើក អស់ ៦០ ឆ្នាំខ្លះ ៨០ ឆ្នាំខ្លះ ១០០ ឆ្នាំខ្លះ ។ ការត្រាច់ទៅនៃចិត្តរមែងដូចព្រះខីណាស្រព ។ លោកទាំងនោះ កាលមិនឃើញកិលេសកម្រើក អស់កាលយូរយ៉ាងនេះ ទើបមិន ( សម្គាល់ថា ) តាំងនៅក្នុងរវាង រមែងសម្គាល់ថា អញជាព្រះអរហន្ត ។

បទថា **អស្មិមានោ** សេចក្តីថា ការប្រកាន់ខ្លួនដែលកើតឡើងក្នុងបញ្ចក្ខន្ធថា រូបជាដើម គឺអញ ដោយន័យជាដើមថា អញមានក្នុងរូប ។ បទថា **មិច្ឆា-មានោ** សេចក្តីថា ការប្រកាន់ខ្លួនដែលកើតឡើងដោយព្រំដែនការងារ ព្រំដែនសិប្បៈ វិជ្ជដ្ឋាន សុតៈ បដិភាណនិងសីលវត្តដ៏លាមកនិងដោយទិដ្ឋិដ៏លាមក ។

បណ្តាបទទាំងនោះ ការងាររបស់អ្នកប្រមង់ អ្នកចាប់ត្រីនិងពួកព្រានឈ្មោះថា ការងារដែលអាក្រក់ ។ ភាពជាអ្នកឈ្លាសក្នុងការបង់សំណាញ់ ចាប់ត្រីនិងធ្វើលបដាក់ត្រីនិងក្នុងការដាក់អន្ទាក់សត្វ ការបោះចម្រូងជាដើម ឈ្មោះថា សិប្បដែលអាក្រក់ ។ វិជ្ជាដែលប្រទូស្តអ្នកដទៃណាមួយ ឈ្មោះថា វិជ្ជាដែលអាក្រក់ ។ សុតៈ ដែលប្រកបដោយរឿងការតយុទ្ធនិងរឿងដណ្តើមនាងសិតាជាដើម ឈ្មោះថា សុតៈដែលអាក្រក់ ។ បដិភាណក្នុងការតែងកំណាព្យ ការរាំនិងច្រៀងជាដើមដែលប្រកបដោយពាក្យជាទុព្ភាសិតឈ្មោះថាបដិភាណដែលអាក្រក់ ។ សីលពពែ សីលគោ ឈ្មោះថា សីលដែលអាក្រក់ ។ វត្ត

ដែលជាវត្តពពែនិងវត្តគោក៏ដូចគ្នា ។ ទិដ្ឋិណាមួយបណ្តាទិដ្ឋិ ៦២ ឈ្មោះថា ទិដ្ឋិលាមក ។ ការប្រកាន់ខ្លួន ៨ យ៉ាង មានអត្ថាធិប្បាយហើយ ។

ក្នុងនិទ្ទេសនៃការប្រកាន់ខ្លួន ៩ យ៉ាងមានវិនិច្ឆ័យដូចតទៅនេះថា

ការប្រកាន់ខ្លួន ៩ យ៉ាង មានការប្រកាន់ខ្លួនថា អញជាបុគ្គលប្រសើរជាងគេជាដើម លោកពោលអាស្រ័យបុគ្គល ។

ក្នុងបទនេះ ការប្រកាន់ខ្លួនរបស់បុគ្គលដែលប្រសើរជាងគេថា អញប្រសើរជាងគេ រមែងកើតឡើងដល់ពួកព្រះរាជានិងពួកបព្វជិត ។ ដ្បិតថា ព្រះរាជារមែងធ្វើនូវការប្រកាន់ខ្លួននេះថា មានអ្នកណាដែលស្មើអញដោយដែន ឬដោយទ្រព្យនិងពាហនៈទាំងឡាយ ។ បព្វជិតក៏ធ្វើការប្រកាន់ខ្លួននេះថា មានអ្នកណាដែលស្មើអញដោយគុណមានសីលនិងធុតង្គជាដើម ។ សូម្បីការប្រកាន់ខ្លួនរបស់បុគ្គលដែលប្រសើរជាងគេថា អញស្មើគេ ក៏កើតឡើងដល់ពួកព្រះរាជានិងពួកបព្វជិតទាំងនោះដូចគ្នា ។ ដ្បិតថាព្រះរាជារមែងធ្វើនូវការប្រកាន់ខ្លួនថា អាត្មាអញ មានការផ្សេងអ្វីដោយឡែកជាមួយព្រះរាជាដទៃដោយដែន ឬដោយទ្រព្យនិងពាហនៈទាំងឡាយ ។ បព្វជិតក៏ធ្វើនូវការប្រកាន់ខ្លួនយ៉ាងនេះថា អាត្មាអញ មានការប្លែកអ្វីជាមួយភិក្ខុដទៃដោយគុណមានសីលនិងធុតង្គជាដើម ។ ការប្រកាន់ខ្លួនរបស់បុគ្គលដែលប្រសើរជាងគេថា អញអាក្រក់ជាងគេ ក៏កើតឡើងដល់ពួកព្រះរាជានិងពួកបព្វជិតទាំងនោះដូចគ្នា ដ្បិតថា ដែនឬទ្រព្យនិងពាហនៈជាដើមរបស់ព្រះរាជាអង្គណា មិនឧត្តម សម្បូរព្រះរាជាអង្គនោះ រមែងធ្វើនូវការប្រកាន់ខ្លួនថា អាត្មាអញជាព្រះរាជាបានដូចម្តេច ត្រឹមតែ

ហៅអញយ៉ាងឆាយថា ព្រះរាជាប៉ុណ្ណោះ ។ សូម្បីបព្វជិតដែលមានលាភសក្ការៈ តិច ក៏ធ្វើការប្រកាន់ខ្លួននេះថា អញជាបុគ្គលមានលាភសក្ការៈ ឈ្មោះថា ធម្មកថិកអ្វី ឈ្មោះថាពហុស្សុតអ្វី ឈ្មោះថាមហាថេរអ្វី ត្រឹមតែពោលថា អាត្មាអញជាធម្មកថិក ជាពហុស្សុត ជាមហាថេរប៉ុណ្ណោះ ។

ការប្រកាន់ខ្លួនរបស់បុគ្គលដែលស្មើគេថា អញប្រសើរជាងគេជាដើម រមែងកើតឡើងដល់ឥស្សរជន មានអាមាត្យជាដើម ព្រោះថា អាមាត្យរមែងធ្វើនូវការប្រកាន់ខ្លួនទាំងឡាយទាំងនេះថា រាជបុរសដទៃ មានបុគ្គលណាដែលស្មើអញដោយសម្បត្តិក្នុងដែន ឬភោគៈ យាន ពាហនៈជាដើមដូច្នេះខ្លះ អញមានការធ្វើអ្វីជាមួយរាជបុរសដទៃៗដូច្នេះខ្លះ ថាអាត្មាអញមានឈ្មោះថា អាមាត្យប៉ុណ្ណោះ តែមិនមានត្រឹមតែអាហារនិងគ្រឿងស្លៀកដណ្តប់ អាត្មាអញឈ្មោះថា អាមាត្យអ្វី ដូច្នេះខ្លះ ។

ការប្រកាន់ខ្លួនរបស់បុគ្គលអាក្រក់ជាងគេថា អាត្មាអញប្រសើរជាងគេជាដើម រមែងកើតឡើងដល់ពួកទាសៈជាដើម ដ្បិតថា ទាសៈរមែងធ្វើនូវការប្រកាន់ខ្លួនទាំងឡាយនេះថា ឈ្មោះថា ទាសៈដទៃ មានអ្នកណាខ្លះស្មើអញ ខាងចំណែកមាតាក្តី ចំណែកបិតាក្តី ទាសៈដទៃៗមិនអាចរស់នៅ កើតជាទាសៈព្រោះមាត់និងផ្ទៃ តែអាត្មាអញល្អជាង ព្រោះមកតាមខ្សែស្រឡាយដូច្នេះខ្លះ ថាអញមានការធ្វើអ្វីផ្សេងជាមួយទាសៈឈ្មោះនោះ ដោយភាពជាទាសៈបរិសុទ្ធទាំងពីរចំណែក ព្រោះមកតាមខ្សែស្រឡាយ ( ពូជ ) ដូច្នេះខ្លះ ថាអញចូលដល់ភាពជាទាសៈ ព្រោះមាត់និងផ្ទៃ តែមិនមានឋានៈទាសៈ ដោយហោចនៃ

មាតាបិតា អញឈ្មោះថាទាសៈបានដូចម្តេច ដូច្នេះខ្លះ ។

សូម្បីពួកអ្នកចាក់សំរាមនិងពួកចណ្ឌាលជាដើម ក៏ធ្វើនូវការប្រកាន់ខ្លួនទាំងនេះ ដូចទាសៈនោះឯង ។ ក្នុងសេចក្តីនេះ ការប្រកាន់ខ្លួនរបស់បុគ្គលដែលប្រសើរជាងគេ ដែលកើតឡើងថា អញប្រសើរជាងគេ ជាការប្រកាន់ខ្លួនតាមសេចក្តីពិត ការប្រកាន់ខ្លួនពីរយ៉ាងក្រៅអំពីនេះ មិនមែនការប្រកាន់ខ្លួនតាមសេចក្តីពិត ។ ការប្រកាន់ខ្លួនរបស់បុគ្គលដែលស្មើគេ ដែលកើតឡើងថា អញស្មើគេរបស់បុគ្គលដែលអន់ជាងគេ ដែលកើតឡើងថា អញអាក្រក់ជាងគេ ជាការប្រកាន់ខ្លួនតាមសេចក្តីពិត ។ ការប្រកាន់ខ្លួនពីរយ៉ាងក្រៅអំពីនេះ មិនមែនការប្រកាន់ខ្លួនតាមសេចក្តីពិតទេ ។

បណ្តាការប្រកាន់ខ្លួនទាំងនោះ ការប្រកាន់ខ្លួនតាមសេចក្តីពិត សម្លាប់ដោយអរហត្តមគ្គ ។ ការប្រកាន់ខ្លួនមិនតាមសេចក្តីពិត សម្លាប់ដោយសោតាបត្តិមគ្គ ។

ក្នុងទីនេះ ការប្រកាន់ខ្លួនរបស់បុគ្គលដែលប្រសើរជាងគេថាអញប្រសើរជាងគេ ជាការប្រកាន់ខ្លួនដែលកើតឡើងយ៉ាងនេះថា អញជាបុគ្គលប្រសើរដោយអត្ថថា ខ្ពង់ខ្ពស់ជាងបុគ្គលដែលខ្ពង់ខ្ពស់ ។ ការប្រកាន់របស់បុគ្គលដែលប្រសើរជាងគេថា អញស្មើនឹងគេ ជាការប្រកាន់ខ្លួនដែលកើតឡើងយ៉ាងនេះថា អញជាបុគ្គលស្មើ ដោយអត្ថថា ស្មើជាមួយបុគ្គលខ្ពង់ខ្ពស់ ។ ការប្រកាន់របស់បុគ្គលដែលប្រសើរជាងគេថា អាត្មាអញជាបុគ្គលអាក្រក់ជាងគេ ជាការប្រកាន់ខ្លួនដែលកើតឡើងយ៉ាងនេះថា អាត្មាអញជាបុគ្គលអាក្រក់ ដោយអត្ថ

*ថា អាក្រក់ជាងបុគ្គលខ្ពង់ខ្ពស់ ។*

*ការប្រកាន់ខ្លួន ៣ យ៉ាងនេះថា ការប្រកាន់ខ្លួនថាល្អជាងគេ ការប្រកាន់ខ្លួនថាស្មើគេ ការប្រកាន់ខ្លួនថាអាក្រក់ជាងគេ រមែងកើតឡើងដល់បុគ្គលប្រសើរជាងគេ ដោយប្រការដូច្នេះ ។*

*ការប្រកាន់ខ្លួន ៣ យ៉ាងថា អញជាបុគ្គលប្រសើរជាងគេ ស្មើគេ អន់ជាងគេ រមែងកើតឡើងដល់បុគ្គលដែលស្មើគេ ។ ការប្រកាន់ខ្លួន ៣ យ៉ាងថា អញជាបុគ្គលអន់ជាងគេ ស្មើគេ ប្រសើរជាងគេ រមែងកើតឡើងដល់បុគ្គលដែលអន់ជាងគេ ។*

*ក្នុងនិទ្ទេសនៃការប្រកាន់ខ្លួន ១០ យ៉ាង មានវិនិច្ឆ័យដូចតទៅនេះថា បទថា* **ឯកេច្ចោ មានំ ជនេតិ** *សេចក្តីថា បុគ្គលពួកខ្លះ រមែងញ៉ាំងការប្រកាន់ខ្លួនឲ្យកើត ។ បទថា* **ជាតិយា វា** *បានដល់ ព្រោះការដល់ព្រមដោយជាតិមានភាពជាក្សត្រជាដើម ។ បទថា* **គោត្តេន វា** *បានដល់ ព្រោះគោត្តប្រសើរមានគោតមគោត្តជាដើម ។ បទថា* **កោលបុត្តិយេន វា** *បានដល់ ព្រោះភាពជាបុត្តត្រកូលធំ ។ បទថា* **វណ្ណបោក្ខរតាយ វា** *បានដល់ ព្រោះភាពជាអ្នកមានសរីរៈសម្បូរដោយវណ្ណៈ សរីរៈលោកហៅថា បោក្ខរៈ សេចក្តីថា ព្រោះភាពដែលបុគ្គលនោះ ជាអ្នកមានរូបស្អាត ព្រោះដល់ព្រមដោយវណ្ណៈ ។ បទថា* **ធនេន វា** *បានដល់ ព្រោះភាពជាអ្នកដល់ព្រមដោយទ្រព្យ សេចក្តីថា ទ្រព្យរបស់អាត្មាអញដែលកប់ទុកប្រមាណមិនបាន ។ បទថា* **អជ្ឈេនេន វា** *បានដល់ ព្រោះស្វាធ្យាយមន្ត ។*

បទថា **កម្មាយតនេន វា** បានដល់ ព្រោះកិច្ចការងារដែលប្រព្រឹត្តទៅដោយន័យជាដើមថា ពួកសត្វដ៏សេស ដូចជាក្អែកបាក់ស្លាប តែអាត្មាអញជាអ្នកមានឫទ្ធិច្រើន មានអានុភាពច្រើន ឬថាអញធ្វើនូវកម្មណា កម្មនោះរមែងសម្រេច ។ បទថា **សិប្បាយតនេន វា** បានដល់ ព្រោះព្រំដែនសិប្បៈ ដែលប្រព្រឹត្តទៅដោយន័យជាដើមថា ពួកសត្វដ៏សេសជាអ្នកមិនមានសិប្បៈ អាត្មាអញជាអ្នកមានសិប្បៈ ។

បទថា **វិជ្ជាដ្ឋានេន វា** នេះ មានន័យដូចពោលហើយខាងដើមនោះឯង ។ បទថា **សុតេន វា** បានដល់ ព្រោះសុតៈ មានជាដើមយ៉ាងនេះថា ពួកសត្វដ៏សេសជាបុគ្គលមានសុតៈតិច តែអញជាពហុស្សូត ។

បទថា **បដិភាណេន វា** បានដល់ ព្រោះបដិភាណ មានជាដើមថា ពួកសត្វដ៏សេសជាបុគ្គលមិនមានបដិភាណ តែអញមានបដិភាណមិនមានប្រមាណ ។ បទថា **អញ្ញតរញ្ញតរេន វា វត្ថុនា** បានដល់ ព្រោះវត្ថុដទៃដែលមិនបានពោលដល់ ។ បទថា **យោ ឯវរូបោ មានោ** បានដល់ ឈ្មោះថា មានះដោយអំណាចធ្វើនូវការប្រកាន់ខ្លួន ។

បទថា **មញ្ញនា មញ្ញិតត្តំ** សេចក្តីថា សម្តែងដោយភាពជាអាការៈ ។ ឈ្មោះថា **ឧណ្ណតិ** ព្រោះអត្ថថា លើកឡើង គឺលើកឡើងតម្កល់ទុកនូវបុគ្គលដែលមានការប្រកាន់ខ្លួនកើតឡើង ។ ឈ្មោះថា **ឧណ្ណាមោ** ព្រោះអត្ថថា ប៉ោងឡើង គឺលើកឡើងតាំងទុកនូវបុគ្គលដែលមានការប៉ោងឡើងកើតឡើង ។ ឈ្មោះថា **ធជោ** ដោយអត្ថថា លើកឡើងព្រម ឈ្មោះថា **សម្បគ្គាហោ** ព្រោះអត្ថ

ថា ផ្គងចិត្តទុក ដោយអត្ថថា លើកឡើង ។ ទង់ដែលខ្ពស់បំផុត បណ្ដាទង់ជាច្រើន លោកហៅថា **កេតុ** ការប្រកាន់ខ្លួន កាលកើតឡើងរឿយៗ ក៏ឈ្មោះថា **កេតុ** ព្រោះអត្ថថា ដូចទង់ ដោយអត្ថថា លើកឡើងខ្ពស់ ដោយប្រៀបធៀបនឹងទង់ដទៃៗ ។ ឈ្មោះថា **កេតុកម្យំ** ព្រោះអត្ថថា ប្រាថ្នាខ្ពស់ដូចទង់នោះ ភាវៈនៃភាពប្រាថ្នាខ្ពស់ដូចទង់នោះ ឈ្មោះថា **កេតុកម្យតា** ។ ការប្រាថ្នាខ្ពស់ដូចទង់នោះ ជារបស់ចិត្ត មិនមែនរបស់ខ្លួន ព្រោះហេតុនោះ ទើបលោកពោលថា **កេតុកម្យតា ចិត្តស្ស** ។ ចិត្តដែលសម្បយុត្តដោយការប្រកាន់ខ្លួនរមែងប្រាថ្នាខ្ពស់ដូចទង់ ភាវៈនៃចិត្តនោះ ឈ្មោះថា ការប្រកាន់ខ្លួនពោលគឺទង់ដូច្នេះ ។

បុគ្គលអ្នកមានបញ្ញា វៀរមាយានិងមានៈ គឺបុគ្គលអ្នកមានបញ្ញានោះ ឯណា គឺព្រះអរហន្តវៀរកិលេសទាំងឡាយបានដោយអំណាចបន្ទោបង់និងធ្វើឲ្យសូន្យទៅជាដើម ដោយន័យដែលពោលហើយខាងដើមតាំងនៅ បុគ្គលមានបញ្ញានោះ គប្បីទៅដោយកិលេសមានរាគៈជាដើមដូចម្ដេចកើត ។

[ ១០៣ ] បទថា **នេរយិកោតិ វា** បានដល់ ជាសត្វដែលកើតឡើងក្នុងនរក សូម្បីក្នុងសត្វដែលកើតក្នុងកំណើតតិរច្ឆានជាដើម ក៏ន័យនេះដូចគ្នា ។ បទថា **សោ ហោតុ នត្ថិ** សេចក្ដីថា បុគ្គលអ្នកមានបញ្ញា គប្បីកើតក្នុងគតិជាដើម ដោយហេតុឲ្យកើតណា ហេតុនោះមិនមាន ។ បទថា **បច្ចយោ** ជាវេវចនៈរបស់បទថា **ហេតុ** នោះឯង ។ បទថា **ការណំ** បានដល់ ឋានៈ ។ ឯ **ការណា** លោកពោលថា ជាឋានៈនៃផលរបស់ខ្លួន ព្រោះមានការប្រព្រឹត្តទៅទាក់ទង

ដោយសេចក្តីខ្វល់ខ្វាយនោះ ។ ព្រោះហេតុនោះ បុគ្គលមានបញ្ញា គប្បីកើតក្នុងគតិជាដើម ដោយហេតុណា ដោយបច្ច័យណា ហេតុនោះ បច្ច័យនោះដែលជាការណៈមិនមាន ។

[ ១០៤ ] បុគ្គលណាជាអ្នកមានកិលេសជាគ្រឿងចូលដល់ ព្រោះមានកិលេសជាគ្រឿងចូលដល់ពីរយ៉ាងនោះ បុគ្គលនោះ ព្រះដ៏មានព្រះភាគត្រាស់ថា

បុគ្គលមានកិលេសជាគ្រឿងអែបនែបរមែងអើពើនឹងវាទៈក្នុងធម៌ទាំងឡាយ ជនគប្បីពោលនូវបុគ្គលមិនមានការអែបនែបដោយកិលេសណា ដូចម្តេចបាន ព្រោះអត្តទិដ្ឋិ ( ការឃើញថា មានខ្លួន ) និរត្តទិដ្ឋិ ( ការឃើញថាមិនមានខ្លួន ) នៃព្រះអរហន្តនោះមិនមានទេ ព្រះអរហន្តនោះ បានលាងនូវទិដ្ឋិទាំងអស់ក្នុងលោកនេះហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧបយោ** បានដល់ ជាអ្នកអាស្រ័យតណ្ហានិងទិដ្ឋិ ។ បទថា **ធម្មេសុ ឧបេតិ វាទំ** សេចក្តីថា រមែងចូលដល់វាទៈ តិះដៀលនូវធម៌ទាំងឡាយនោះៗយ៉ាងនេះថា ជាបុគ្គលតម្រេកខ្លះ ជាអ្នកប្រទូស្តខ្លះ ។ បទថា **អនូបយំ កេន កថំ វទេយ្យ** សេចក្តីថា បុគ្គលណាមួយ គប្បីតិះដៀលព្រះខីណាស្រពដែលឈ្មោះថា មិនមានកិលេសជាគ្រឿងចូលដល់ ព្រោះលះនូវតណ្ហានិងទិដ្ឋិបានថា ជាបុគ្គលតម្រេកខ្លះ ជាអ្នកប្រទូស្តខ្លះ ដោយរាគៈឬទោសៈណាមួយ ដូចម្តេចកើត ព្រះខីណាស្រពជាអ្នកប្រាថ្នា មិនគួរ

ពោលតិះដៀលយ៉ាងនេះឡើយ អធិប្បាយថា ព្រះខីណាស្រពនោះ នឹងជាអ្នកបិទបាំងវត្តុដែលធ្វើហើយ ដូចពួកតិរ្ថិយឬ ។

បទថា **អត្តំ និរត្តំ ន ហិ តស្ស អត្ថិ** សេចក្ដីថា ព្រោះទិដ្ឋិថា មានខ្លួនឬទិដ្ឋិថា ដាច់សូន្យរមែងមិនមានដល់បុគ្គលមិនមានកិលេសជាគ្រឿងចូលដល់នោះ ។ ម្យ៉ាងទៀត សូម្បីការប្រកាន់និងការលែង ដែលហៅថា **អត្តទិដ្ឋិ** និង **និរត្តទិដ្ឋិ** ក៏មិនមាន ។ បើសួរថា ហេតុអ្វីទើបមិនមាន ឆ្លើយថា ព្រោះព្រះអរហន្តនោះ បានលាងនូវទិដ្ឋិទាំងអស់ក្នុងលោកនេះហើយ អធិប្បាយថា ព្រោះបុគ្គលដែលមិនមានកិលេសជាគ្រឿងចូលដល់នោះ រលាស់ចោលហើយ លះហើយ បន្ទោបង់ហើយនូវទិដ្ឋិទាំងពួងដោយទឹក គឺញាណក្នុងអត្តភាពក្នុងលោកនេះឯង ។ ព្រះដ៏មានព្រះភាគទ្រង់បញ្ចប់ព្រះធម្មទេសនាដោយកំពូល គឺអរហត្តដោយប្រការដូច្នេះ ។ ព្រះរាជាទ្រង់ស្ដាប់ព្រះធម្មទេសនានោះហើយ ទ្រង់ត្រេក-អរថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយយាងចៀសចេញទៅ ។

[ ១០៥ ] បទថា **រត្តោតិ វា** បានដល់ ជាអ្នកត្រេកអរដោយរាគៈ ។ ក្នុងបទថា **ទុដ្ឋោតិ វា** ជាដើម ក៏ន័យនេះដូចគ្នា ។ បទថា **តេ អភិសង្ខារា អប្បហីនា** សេចក្ដីថា បុញ្ញាភិសង្ខារ អបុញ្ញាភិសង្ខារនិងអនេញ្ជាភិសង្ខារទាំងនោះ ដែលបុគ្គលនោះមិនលះហើយ ។

បទថា **អភិសង្ខារានំ អប្បហីនត្តា** សេចក្ដីថា ព្រោះភាពដែលសភាវៈជាគ្រឿងតាក់តែងគឺកម្ម មានប្រការដូចពោលហើយទាំងនោះ ដែលបុគ្គលនោះមិនលះបង់ហើយ ។ បទថា **គតិយា វាធំ ឧបេតិ** សេចក្ដីថា រមែងចូលដល់

ការពោលដោយគតិ ៥ ណាមួយ ព្រោះហេតុនោះ ទើបព្រះសារីបុត្តត្ថេរពោលថា **នេរយិកោតិ វា ។បេ។ វាធំ ឧបេតិ ឧបគច្ឆតិ** ដូច្នេះ ។

[ ១០៦-១០៨ ] បទថា **វេទយ្យ** បានដល់ គប្បីពោល ។ បទថា **គហិតំ នត្ថិ** សេចក្តីថា វត្ថុដែលគប្បីកាន់យករមែងមិនមាន ។ បទថា **មុញ្ចិតព្វំ នត្ថិ** សេចក្តីថា វត្ថុដែលគប្បីលែងរមែងមិនមាន ព្រោះភាពជាអ្នកលែងហើយតាំងនៅ ។

បទថា **យស្សត្ថិ គហិតំ** សេចក្តីថា បុគ្គលណាមានវត្ថុដែលប្រកាន់ថាអញរបស់អញ ។ បទថា **តស្សត្ថិ មុញ្ចិតព្វំ** សេចក្តីថា បុគ្គលនោះ រមែងមានវត្ថុដែលគប្បីលែង បទទាំងឡាយខាងមុខ គប្បីត្រឡប់គ្នាប្រកប ។

បទថា **គហណមុញ្ចនា សមតិក្កន្តោ** សេចក្តីថា ព្រះអរហន្តឈានកន្លងចាកការកាន់យកនិងការលែង ។ បទថា **វុឌ្ឍិបរិហានិវីតិវត្តោ** សេចក្តីថា ឈានកន្លងនូវការចម្រើននិងការវិនាសប្រព្រឹត្តទៅ ។

បទផ្តើមថា **សោ វុដ្ឋវាសោ** រហូតដល់បទចុងក្រោយគឺ **ញាណគ្គិនា ទឌ្ឍានិ** មានន័យដូចពោលហើយខាងដើមនោះឯង ។

បទថា **អធោសិ** សេចក្តីថា កាត់ហើយ ។ បទថា **ធុនិ សន្ធុនិ និទ្ធុនិ** លោកពង្រីកដោយឧបសគ្គដូច្នេះ ។

**អដ្ឋកថា ទុដ្ឋដ្ឋកសុត្តនិទ្ទេសទី ៣ ចប់**

# សុទ្ធដ្ឋកសុត្តនិទ្ទេសទី ៤

[ ១០៩ ] ( ព្រះមានព្រះភាគត្រាស់ថា ) អាត្មាអញឃើញ ( នូវរូប ) ដ៏បរិសុទ្ធ ឧត្តម មិនមានរោគ សេចក្ដីបរិសុទ្ធដ៏ប្រពៃរបស់នរជន រមែងកើតមានដោយសាររូបដែលខ្លួនឃើញ បុគ្គលពាល អ្នកឃើញរឿយៗនូវការបរិសុទ្ធ កាលដឹងច្បាស់យ៉ាងនេះ រមែងយល់ថា ( ការឃើញនេះ ) ឧត្តម ហើយជឿនូវការឃើញនោះ ថាជាញាណ ។

[ ១១០ ] អធិប្បាយពាក្យថា អាត្មាអញឃើញ ( នូវរូប ) ដ៏បរិសុទ្ធ ឧត្តម មិនមានរោគ ត្រង់ពាក្យថា អាត្មាអញឃើញ ( នូវរូប ) ដ៏បរិសុទ្ធ គឺ អាត្មាអញឃើញ ( រូប ) បរិសុទ្ធ មើល ( រូប ) បរិសុទ្ធ ក្រឡេកមើល ( រូប ) បរិសុទ្ធ សម្លឹងមើល ( រូប ) បរិសុទ្ធ សង្កេតមើល ( រូប ) បរិសុទ្ធ ។ ពាក្យថា ឧត្តម មិនមានរោគ គឺឧត្តម ដល់នូវភាពមិនមានរោគ ដល់នូវសេចក្ដីក្សេម ដល់នូវទីជ្រក ដល់នូវទីពឹងពំនាក់ ដល់នូវទីរឭក ដល់នូវការប្រព្រឹត្តទៅខាងមុខ ដល់នូវការមិនមានភ័យ ដល់នូវភាពទៀងទាត់ ដល់នូវអមតៈ ដល់នូវភាពប្រាសចាកតណ្ហា ហេតុនោះ ( ទ្រង់ត្រាស់ថា ) អាត្មាអញឃើញ ( នូវរូប ) បរិសុទ្ធ ឧត្តម មិនមានរោគ ។

[ ១១១ ] ពាក្យថា សេចក្ដីបរិសុទ្ធដ៏ប្រពៃរបស់នរជន រមែងកើតមានដោយសាររូបដែលខ្លួនឃើញ សេចក្ដីថា សេចក្ដីស្អាត សេចក្ដីស្អាតវិសេស សេចក្ដីបរិសុទ្ធ ការផុត ការផុតស្រឡះ ការផុតដោយជុំវិញ របស់នរជនរមែងកើតមាន ឬនរជន ស្អាត ស្អាតវិសេស បរិសុទ្ធិផុត ផុតស្រឡះ ផុតដោយជុំវិញ ដោយសារការឃើញរូប ដោយចក្ខុវិញ្ញាណ ហេតុនោះ ( ទ្រង់ត្រាស់

ថា ) សេចក្តីបរិសុទ្ធដ៏ប្រពៃ របស់នរជនរមែងកើតមានដោយសាររូបដែលខ្លួនឃើញ ។

[ ១១២ ] ពាក្យថា បុគ្គលពាលកាលដឹងច្បាស់យ៉ាងនេះ រមែងយល់ថា ( ការឃើញនេះ ) ឧត្តម គឺកាលដឹងចំពោះ ដឹងទូទៅ ដឹងវិសេស ដឹងច្បាស់ ចាក់ធ្លុះចំពោះយ៉ាងនេះ រមែងយល់ ដឹង ថ្លឹងមើល ពិចារណាឃើញ យល់ច្បាស់ ធ្វើឲ្យប្រាកដថា ការឃើញនេះ ថ្លៃថ្លា លើសលុប ប្រសើរ ប្រសើរវិសេស ចម្បង ឧត្តម ក្រៃលែង ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលពាលកាលដឹងច្បាស់យ៉ាងនេះ រមែងយល់ថា ( ការឃើញនេះ ) ឧត្តម ។

[ ១១៣ ] ពាក្យថា អ្នកឃើញរឿយៗនូវការបរិសុទ្ធ រមែងជឿ ( នូវការឃើញនោះ ) ថាជាញាណ សេចក្តីថា បុគ្គលណា ឃើញនូវសេចក្តីបរិសុទ្ធ បុគ្គលនោះឈ្មោះថា អ្នកឃើញរឿយៗនូវសេចក្តីបរិសុទ្ធ ។ ពាក្យថា ជឿ ( នូវការឃើញនោះ ) ថាជាញាណ គឺជឿនូវការឃើញរូបដោយចក្ខុវិញ្ញាណ ថាជាញាណជឿថាជាមគ្គ ជឿថាជាផ្លូវ ជឿថាជាគ្រឿងដឹកនាំ ព្រោះហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកឃើញរឿយៗនូវសេចក្តីបរិសុទ្ធ ជឿ ( នូវការឃើញនោះ ) ថាជាញាណ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

អាត្មាអញឃើញ ( នូវរូប ) ដ៏បរិសុទ្ធ ឧត្តម មិនមានរោគ
សេចក្តីបរិសុទ្ធដ៏ប្រពៃរបស់នរជនរមែងមានដោយសារ ( រូប )
ដែលខ្លួនឃើញ បុគ្គលពាលអ្នកឃើញរឿយៗនូវការបរិសុទ្ធ
កាលដឹងច្បាស់យ៉ាងនេះ រមែងយល់ថា ( ការឃើញនេះ )

ឧត្តម ហើយជឿ ( នូវការឃើញនោះ ) ថាជាញាណ ដូច្នេះ ។

[ ១១៤ ] បើសេចក្ដីបរិសុទ្ធរបស់នរជន កើតមានដោយសាររូប ដែលខ្លួនឃើញ ឬនរជននោះលះបង់ទុក្ខ គឺរួចចាកទុក្ខដោយសារញាណបាន នរជនអ្នកមានឧបធិក្កិលេសនោះ ឈ្មោះថា បរិសុទ្ធិដោយផ្លូវដទៃ ព្រោះថា ទិដ្ឋិរមែងប្រាប់នូវបុគ្គលអ្នកពោលដូច្នោះនោះ ។

[ ១១៥ ] ពាក្យថា បើសេចក្ដីបរិសុទ្ធរបស់នរជនកើតមាន ដោយសាររូប ដែលខ្លួនឃើញ គឺសេចក្ដីស្អាត ស្អាតវិសេស បរិសុទ្ធិ ការផុត ផុតស្រឡះ ផុតដោយជុំវិញរបស់នរជនកើតមាន ឬនរជនស្អាត ស្អាតពិសេស បរិសុទ្ធិ ផុត ផុតស្រឡះ ផុតដោយជុំវិញ ដោយសារការឃើញរូប ដោយចក្ខុវិញ្ញាណ ព្រោះហេតុនោះ ( ទ្រង់ត្រាស់ថា ) បើសេចក្ដីបរិសុទ្ធរបស់នរជនកើតមាន ដោយសាររូបដែលខ្លួនឃើញ ។

[ ១១៦ ] ពាក្យថា ឬនរជននោះ លះបង់ទុក្ខដោយសារញាណបាន គឺបើនរជន លះបង់ជាតិទុក្ខ លះបង់ជរាទុក្ខ លះបង់ព្យាធិទុក្ខ លះបង់មរណទុក្ខ លះបង់សោកទុក្ខ បរិទេវទុក្ខ ទុក្ខទុក្ខ ទោមនស្សទុក្ខ ឧបាយាសទុក្ខដោយសារការឃើញរូបដោយចក្ខុវិញ្ញាណ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ឬនរជននោះ លះបង់ទុក្ខ គឺរួចចាកទុក្ខដោយសារញាណបាន ។

[ ១១៧ ] ពាក្យថា នរជនអ្នកមានឧបធិក្កិលេសនោះ ឈ្មោះថាបរិសុទ្ធិដោយផ្លូវដទៃ សេចក្ដីថា នរជនរមែងស្អាត ស្អាតវិសេស បរិសុទ្ធិ ផុត ផុត

ស្រឡះ ផុតដោយជុំវិញ ដោយផ្លូវមិនបរិសុទ្ធដទៃ ដោយបដិបទាខុស ដោយគន្លងមិនមែនជាទីដឹកនាំ ក្រៅអំពីសតិប្បដ្ឋាន ក្រៅអំពីសម្មប្បធាន ក្រៅអំពីឥទ្ធិបាទ ក្រៅអំពីឥន្ទ្រិយ ក្រៅអំពីពលៈ ក្រៅអំពីពោជ្ឈង្គ ក្រៅអំពីអដ្ឋង្គិកមគ្គដ៏ប្រសើរ ។ ពាក្យថា មានឧបធិក្កិលេស គឺប្រកបដោយរាគៈ ប្រកបដោយទោសៈ ប្រកបដោយមោហៈ ប្រកបដោយមានះ ប្រកបដោយតណ្ហា ប្រកបដោយទិដ្ឋិ ប្រកបដោយកិលេស ប្រកបដោយឧបាទាន ហេតុនោះ ( ទ្រង់ត្រាស់ថា ) នរជន អ្នកមានឧបធិក្កិលេសនោះ ឈ្មោះថា បរិសុទ្ធិដោយផ្លូវដទៃ ។

[ ១១៨ ] ពាក្យថា ព្រោះថាទិដ្ឋិរមែងប្រាប់នូវបុគ្គលអ្នកពោលដូច្នោះនោះ សេចក្តីថា ទិដ្ឋិនោះឯង រមែងប្រាប់បុគ្គលនោះដូច្នេះថា បុគ្គលនេះជាមិច្ឆាទិដ្ឋិ មានសេចក្តីយល់ផ្ទុយ ។ ពាក្យថា ពោលដូច្នោះ គឺពោលថ្លែង ពណ៌នា ពន្យល់ ពោលប្រកាន់ដោយប្រការដូច្នោះ គឺពោលថ្លែង ពណ៌នា ពន្យល់ ពោល ប្រកាន់ដោយប្រការដូច្នោះថា លោកទៀង ពាក្យនេះជាពាក្យពិត ពាក្យដទៃជាមោឃៈ ពោលថ្លែង ពណ៌នា ពន្យល់ ពោលប្រកាន់ដោយប្រការដូច្នោះថា លោកមិនទៀង លោកមានទីបំផុត លោកមិនមានទីបំផុត ជីវៈនោះ សរីរៈនោះ ជីវៈដទៃ សរីរៈដទៃ សត្វស្លាប់ហើយកើតទៀត សត្វស្លាប់ហើយមិនកើតទៀត សត្វស្លាប់ហើយកើតទៀតក៏មាន មិនកើតទៀតក៏មាន សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ពាក្យនេះជាពាក្យពិត ពាក្យដទៃជាមោឃៈ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ព្រោះថា ទិដ្ឋិរមែងប្រាប់នូវបុគ្គលអ្នកពោល

ដូច្នោះនោះ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

បើសេចក្តីបរិសុទ្ធរបស់នរជនកើតមាន ដោយសាររូបដែល ខ្លួនឃើញ ឬនរជននោះ លះបង់ទុក្ខដោយញាណបាន នរជន អ្នកមានឧបធិក្កិលេសនោះ រមែងបរិសុទ្ធិដោយផ្លូវដទៃ ព្រោះ ថា ទិដ្ឋិរមែងប្រាប់នូវបុគ្គលអ្នកពោលដូច្នោះនោះ ដូច្នេះ ។

[ ១១៩ ] ព្រាហ្មណ៍ មិនពោលនូវសេចក្តីបរិសុទ្ធ ព្រោះផ្លូវដទៃ ព្រោះ អារម្មណ៍ដែលឃើញ ឬឮ ព្រោះសីលនិងវត្ត ឬព្រោះអារម្មណ៍ដែលប៉ះពាល់ ឡើយ ទាំងជាអ្នកមិនជាប់នៅក្នុងបុណ្យនិងបាប ជាអ្នកលះបង់នូវអត្តា ជាអ្នក លែងធ្វើក្នុងលោកនេះ ។

[ ១២០ ] អធិប្បាយពាក្យថា ព្រាហ្មណ៍មិនពោលនូវសេចក្តីបរិសុទ្ធ ព្រោះ ផ្លូវដទៃ ព្រោះអារម្មណ៍ដែលខ្លួនឃើញ ឬឮ ព្រោះសីលនិងវត្ត ឬព្រោះអារម្មណ៍ ដែលប៉ះពាល់ឡើយ ត្រង់ពាក្យថា មិន គឺជាពាក្យបដិសេធ ។ ពាក្យថា ព្រាហ្មណ៍ គឺបុគ្គលដែលឈ្មោះថាព្រាហ្មណ៍ព្រោះបន្សាត់បង់នូវធម៌ ៧ គឺជាអ្នកបន្សាត់ បង់សក្កាយទិដ្ឋិ បន្សាត់បង់វិចិកិច្ឆា បន្សាត់បង់សីលព្វតបរាមាស បន្សាត់បង់ រាគៈ បន្សាត់បង់ទោសៈ បន្សាត់បង់មោហៈ បន្សាត់បង់មានះ ។ លោកបន្សាត់ បង់អកុសលធម៌ទាំងឡាយដ៏លាមក ជាធម៌ប្រកបដោយសេចក្តីសៅហ្មងព្រម មានកិរិយានាំសត្វឲ្យកើតទៀត ប្រកបដោយសេចក្តីក្រវល់ក្រវាយ មានផល ជាទុក្ខ ជាបច្ច័យរបស់ជាតិ ជរានិងមរណៈ តទៅទៀត ។

( ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលសភិយៈ ) បុគ្គល

ណា ដែលបន្សាត់ចោលនូវធម៌ដ៏លាមកទាំងពួង ជាអ្នកមាន មន្ទិលទៅប្រាសហើយ មានចិត្តតម្កល់មាំដោយប្រពៃ មានចិត្ត នឹងធឹង កន្លងហើយនូវសង្សារ បុគ្គលនោះ ឈ្មោះថា ជាអ្នក មានកិច្ចសម្រេចអស់ហើយ ជាអ្នកមិនអាស្រ័យ ( ដោយ តណ្ហានិងទិដ្ឋិ ) ជាតាទិបុគ្គល បុគ្គលនោះ លោកហៅថា ព្រាហ្មណ៍ ដូច្នេះ ។

ពាក្យថា ព្រាហ្មណ៍មិនពោលនូវសេចក្តីបរិសុទ្ធ ព្រោះផ្លូវដទៃ គឺព្រាហ្មណ៍ មិនពោល មិនថ្លែង មិនពណ៌នា មិនពន្យល់ មិនពោលប្រកាន់នូវសេចក្តីស្អាត ស្អាតវិសេស សេចក្តីបរិសុទ្ធ ការផុត ផុតស្រឡះ ផុតដោយជុំវិញ ដោយផ្លូវ មិនបរិសុទ្ធដទៃ ដោយមិច្ឆាបដិបទា ដោយគន្លងមិនជាទីដឹកនាំ ក្រៅចាកសតិ- ប្បដ្ឋាន ក្រៅចាកសម្មប្បធាន ក្រៅចាកឥទ្ធិបាទ ក្រៅចាកឥន្ទ្រិយ ក្រៅចាកពលៈ ក្រៅចាកពោជ្ឈង្គ ក្រៅចាកអដ្ឋង្គិកមគ្គដ៏ប្រសើរ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ព្រាហ្មណ៍ មិនពោលនូវសេចក្តីបរិសុទ្ធ ព្រោះផ្លូវដទៃ ។ ពាក្យថា ព្រោះ អារម្មណ៍ដែលខ្លួនឃើញ ឬឮ ព្រោះសីលនិងវត្ត ឬព្រោះអារម្មណ៍ដែលប៉ះ ពាល់ឡើយ សេចក្តីថា មានសមណព្រាហ្មណ៍ពួកខ្លះ ប្រកាន់សេចក្តីបរិសុទ្ធ ដោយសាររូបដែលឃើញ សមណព្រាហ្មណ៍ទាំងនោះ ជឿនូវការឃើញរូប ទាំងឡាយខ្លះ ថាជាមង្គល ជឿនូវការឃើញរូបទាំងឡាយខ្លះ ថាមិនមែនជា មង្គល ។

សមណព្រាហ្មណ៍ទាំងឡាយពួកខ្លះ ជឿនូវការឃើញរូបទាំងឡាយដូច

ម្តេច ថាជាមង្គល ។ សមណព្រាហ្មណ៍ទាំងនោះ ក្រោកឡើងអំពីព្រលឹម ឃើញនូវរូបទាំងឡាយ ដែលសន្មតថាជាមង្គលដ៏ក្រៃលែង គឺឃើញសត្វត្រចៀកកាំ ឃើញដើមញ្ចៅដែលដុះដោយបុស្សនក្ខត្តឫក្ស ឃើញស្ត្រីមានគភ៌ ឃើញបុគ្គលកំពុងបញ្ចិះនាងកុមារិកាលើកដើរទៅ ឃើញក្អមមានទឹកពេញ ឃើញត្រីឆ្អិន ឃើញសេះអាជានេយ្យ ឃើញរថដែលទឹមដោយសេះអាជានេយ្យ ឃើញគោឧសភៈ ឃើញមេគោក្រហម ក៏ប្រកាន់ជឿនូវការឃើញរូបទាំងឡាយមានសភាពយ៉ាងនេះ ថាជាមង្គល ។

សមណព្រាហ្មណ៍ទាំងឡាយពួកខ្លះ ជឿនូវការឃើញរូបទាំងឡាយ ដូចម្តេច ថាមិនមែនជាមង្គល ។ សមណព្រាហ្មណ៍ទាំងនោះ ឃើញគំនរចំបើង ឃើញឆ្នាំងខ្ទាញ់ ឃើញឆ្នាំងទទេ ឃើញស្ត្រីបុំ ឃើញស្រមណ៍អាក្រាត ឃើញលា ឃើញយានដែលទឹមដោយលា ឃើញយានដែលទឹមដោយសត្វពាហនៈម្នាង ឃើញមនុស្សខ្វាក់ ឃើញមនុស្សក្ញែង ឃើញមនុស្សខ្វក ឃើញមនុស្សខ្វិន ឃើញមនុស្សជរា ឃើញមនុស្សឈឺ ឃើញមនុស្សស្លាប់ ក៏ប្រកាន់ជឿនូវការឃើញរូបទាំងឡាយមានសភាពយ៉ាងនេះថាមិនមែនជាមង្គល ។ សមណព្រាហ្មណ៍ទាំងឡាយនេះ ប្រកាន់សេចក្តីបរិសុទ្ធដោយសាររូបដែលឃើញ សមណព្រាហ្មណ៍ទាំងនោះ តែងជឿថា សេចក្តីស្អាត ស្អាតវិសេស សេចក្តីបរិសុទ្ធ ការផុត ផុតស្រឡះ ផុតដោយជុំវិញ ដោយសាររូបដែលឃើញ ។

មានសមណព្រាហ្មណ៍ពួកខ្លះ ប្រកាន់សេចក្តីបរិសុទ្ធដោយសំឡេងដែលឮ សមណព្រាហ្មណ៍ទាំងនោះ ជឿនូវការឮសំឡេងទាំងឡាយខ្លះ ថាជាមង្គល

ជឿនូវការឮសំឡេងទាំងឡាយខ្លះ ថាមិនមែនជាមង្គល ។

សមណព្រាហ្មណ៍ទាំងឡាយពួកខ្លះ រមែងជឿនូវការឮសំឡេងទាំងឡាយដូចម្តេច ថាជាមង្គល ។ សមណព្រាហ្មណ៍ទាំងឡាយនោះ ក្រោកឡើងអំពីព្រលឹម ឮសំឡេងទាំងឡាយដែលសន្មតថាជាមង្គលដ៏ក្រៃលែង ដូចឮថា ចម្រើនក្តី កំពុងចម្រើនក្តី ពេញក្តី សក្តី មិនមានសោកក្តី មានចិត្តល្អក្តី នក្ខត្តឫក្សល្អក្តី មង្គលល្អក្តី សិរីក្តី ចម្រើនដោយសិរីក្តី ក៏ប្រកាន់ជឿនូវការឮសំឡេងទាំងឡាយមានសភាពយ៉ាងនេះ ថាជាមង្គល ។

សមណព្រាហ្មណ៍ទាំងឡាយពួកខ្លះ ជឿនូវការឮសំឡេងទាំងឡាយ ដូចម្តេច ថាមិនមែនជាមង្គល ។

សមណព្រាហ្មណ៍ទាំងនោះ ឮពាក្យថា មនុស្សខ្វាក់ក្តី ក្ងែងក្តី ខ្វកក្តី ខ្វិនក្តី ជរាក្តី ឈឺក្តី ស្លាប់ក្តី ដាច់ក្តី បែកក្តី ឆេះក្តី វិនាសក្តី មិនមានក្តី ក៏ប្រកាន់ជឿនូវការឮសំឡេង មានសភាពយ៉ាងនេះ ថាមិនមែនជាមង្គល ។ សមណព្រាហ្មណ៍ទាំងនេះ អ្នកប្រកាន់សេចក្តីបរិសុទ្ធដោយសំឡេងដែលឮ គឺសមណព្រាហ្មណ៍ទាំងនោះ ជឿនូវសេចក្តីស្អាត ស្អាតវិសេស ស្អាតជុំវិញ ការផុត ផុតស្រឡះ ផុតដោយជុំវិញ ព្រោះសំឡេងដែលឮ ។

មានសមណព្រាហ្មណ៍ពួកខ្លះ ប្រកាន់សេចក្តីបរិសុទ្ធដោយសីល សមណព្រាហ្មណ៍ទាំងនោះ តែងជឿថាសេចក្តីស្អាត ស្អាតវិសេស ស្អាតជុំវិញ ការផុត ផុតស្រឡះ ផុតដោយជុំវិញ ដោយហេតុត្រឹមតែសីល ត្រឹមតែការសង្រួម ត្រឹមតែការរវាំង ត្រឹមតែការមិនប្រព្រឹត្តកន្លង ។ សមណមុណ្ឌិកាបុត្ត បានពោល

យ៉ាងនេះថា ម្នាលជាងឈើ ខ្ញុំតែងបញ្ញត្តនូវបុរសបុគ្គលដែលប្រកបដោយធម៌ទាំងឡាយ ៤ យ៉ាង ថាជាបុគ្គលមានកុសលបរិបូណ៌ មានកុសលដ៏ឧត្តម ជាបុគ្គលដល់ហើយនូវធម៌ដែលគេគប្បីដល់ដ៏ឧត្តម ជាសមណៈមិនមានបរាជ័យ ។ ធម៌ ៤ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលជាងឈើ បុរសបុគ្គលក្នុងលោកនេះ មិនធ្វើនូវអំពើលាមកដោយកាយ ១ មិនពោលនូវវាចាដ៏លាមក ១ មិនត្រិះរិះនូវសេចក្តីត្រិះរិះដ៏លាមក ១ មិនចិញ្ចឹមជីវិតដោយការចិញ្ចឹមជីវិតដ៏លាមក ១ ម្នាលជាងឈើ ខ្ញុំតែងបញ្ញត្តនូវបុរសបុគ្គល ដែលប្រកបដោយធម៌ ៤ នេះឯង ថាជាបុគ្គលមានកុសលដ៏បរិបូណ៌ មានកុសលដ៏ឧត្តម ជាបុគ្គលដល់ហើយនូវធម៌ ដែលបុគ្គលគប្បីដល់ដ៏ឧត្តម ជាសមណៈមិនមានបរាជ័យ ។ មានសមណព្រាហ្មណ៍ពួកខ្លះ ជាអ្នកប្រកាន់នូវសេចក្តីបរិសុទ្ធដោយសីល សមណព្រាហ្មណ៍ទាំងនោះ រមែងជឿសេចក្តីស្អាត ស្អាតវិសេស ស្អាតជុំវិញ ការផុត ផុតស្រឡះ ផុតដោយជុំវិញ ដោយហេតុត្រឹមតែសីលត្រឹមតែការសង្រួម ត្រឹមតែការរវាំង ត្រឹមតែការមិនប្រព្រឹត្តកន្លងយ៉ាងនេះឯង ។

មានសមណព្រាហ្មណ៍ពួកខ្លះ ជាអ្នកប្រកាន់នូវសេចក្តីបរិសុទ្ធដោយវត្ត សមណព្រាហ្មណ៍ទាំងនោះ ជាអ្នកប្រព្រឹត្តវត្តដំរីក៏មាន ប្រព្រឹត្តវត្តសេះក៏មាន ប្រព្រឹត្តវត្តគោក៏មាន ប្រព្រឹត្តវត្តឆ្កែក៏មាន ប្រព្រឹត្តវត្តក្អែកក៏មាន ប្រព្រឹត្តវត្តរបស់វាសុទេពក៏មាន ប្រព្រឹត្តវត្តរបស់ពលទេពក៏មាន ប្រព្រឹត្តវត្តរបស់បុណ្ណ-ភទ្ទក៏មាន ប្រព្រឹត្តវត្តរបស់មណិភទ្ទក៏មាន ប្រព្រឹត្តវត្តភ្លើងក៏មាន ប្រព្រឹត្តវត្តនាគក៏មាន ប្រព្រឹត្តវត្តគ្រុឌក៏មាន ប្រព្រឹត្តវត្តយក្សក៏មាន ប្រព្រឹត្តវត្តអសុរក៏

មាន ប្រព្រឹត្តវត្តគន្ធព្វក៏មាន ប្រព្រឹត្តវត្តមហារាជក៏មាន ប្រព្រឹត្តវត្តព្រះចន្ទក៏មាន ប្រព្រឹត្តវត្តព្រះអាទិត្យក៏មាន ប្រព្រឹត្តវត្តព្រះឥន្ទក៏មាន ប្រព្រឹត្តវត្តព្រះព្រហ្មក៏មាន ប្រព្រឹត្តវត្តទេវតាក៏មាន ប្រព្រឹត្តវត្តសំពះទិសក៏មាន ។ សមណព្រាហ្មណ៍ទាំងឡាយនេះ ជាអ្នកប្រកាន់សេចក្តីបរិសុទ្ធដោយវត្ត សមណព្រាហ្មណ៍ទាំងនោះ រមែងជឿសេចក្តីស្អាត ស្អាតវិសេស ស្អាតជុំវិញ ការផុត ផុតស្រឡះ ផុតដោយជុំវិញ ព្រោះវត្ត ។

មានសមណព្រាហ្មណ៍ពួកខ្លះ អ្នកប្រកាន់សេចក្តីបរិសុទ្ធដោយអារម្មណ៍ដែលប៉ះពាល់ ។ សមណព្រាហ្មណ៍ទាំងនោះ ក្រោកឡើងអំពីព្រលឹមស្ទាបប្រឹថពី ស្ទាបស្មៅស្រស់ ស្ទាបអាចម៍គោ ស្ទាបអណ្តើក ជាន់នូវបណ្តាញ ( ដែក ) ស្ទាបរទេះដែលពេញដោយល្ង ស៊ីល្ងដែលជាមង្គល លាបប្រេងមង្គល ស៊ីឈើស្ទន់មង្គល ងូតដោយដីស្អិតមង្គល ស្លៀកសំពត់មង្គល ជូតឈ្នួតមង្គល ។ សមណព្រាហ្មណ៍ទាំងនេះ ជាអ្នកប្រកាន់សេចក្តីបរិសុទ្ធដោយអារម្មណ៍ដែលប៉ះពាល់ សមណព្រាហ្មណ៍ទាំងនោះ រមែងជឿសេចក្តីស្អាត ស្អាតវិសេស ស្អាតជុំវិញ ការផុត ផុតស្រឡះ ផុតដោយជុំវិញដោយអារម្មណ៍ដែលប៉ះពាល់ ។

ពាក្យថា ព្រាហ្មណ៍មិនពោលនូវសេចក្តីបរិសុទ្ធព្រោះផ្លូវដទៃ ព្រោះអារម្មណ៍ដែលឃើញក្តី ដែលឮក្តី ព្រោះសីលនិងវត្តក្តី ព្រោះអារម្មណ៍ដែលប៉ះពាល់ក្តី បានសេចក្តីថា ព្រាហ្មណ៍មិនពោលនូវសេចក្តីបរិសុទ្ធដោយសេចក្តីបរិសុទ្ធព្រោះអារម្មណ៍ដែលឃើញផង មិនពោលនូវសេចក្តីបរិសុទ្ធដោយសេចក្តី

បរិសុទ្ធ ព្រោះអារម្មណ៍ដែលឮផង មិនពោលនូវសេចក្ដីបរិសុទ្ធដោយសេចក្ដីបរិសុទ្ធ ព្រោះសីលផង មិនពោលនូវសេចក្ដីបរិសុទ្ធដោយសេចក្ដីបរិសុទ្ធ ព្រោះវត្តផង មិនពោល មិនថ្លែង មិនពណ៌នា មិនពន្យល់ មិននិយាយនូវសេចក្ដីបរិសុទ្ធដោយសេចក្ដីបរិសុទ្ធ ព្រោះអារម្មណ៍ដែលប៉ះពាល់ផង ព្រោះហេតុនោះ ( ទ្រង់ត្រាស់ថា ) ព្រាហ្មណ៍មិនពោលនូវសេចក្ដីបរិសុទ្ធដោយផ្លូវដទៃ ព្រោះអារម្មណ៍ដែលឃើញក្ដី ដែលឮក្ដី ព្រោះសីលនិងវត្តក្ដី ព្រោះអារម្មណ៍ដែលប៉ះពាល់ក្ដី ។

[ ១២១ ] ពាក្យថា មិនជាប់នៅក្នុងបុណ្យនិងបាប មានសេចក្ដីថា កុសលាភិសង្ខារណាមួយ ដែលឲ្យបដិសន្ធិក្នុងត្រៃជាតិ លោកហៅថាបុណ្យ ។ អកុសលទាំងអស់ លោកហៅថា បាប ។ កាលណាបុញ្ញាភិសង្ខារ អបុញ្ញាភិសង្ខារនិងអានេញ្ជាភិសង្ខារ ដែលព្រាហ្មណ៍លះបង់ហើយ ផ្ដាច់ឫសចោលហើយ ធ្វើមិនឲ្យមានទីកើតដូចជាដើមត្នោត ដល់នូវភាពតាំងនៅមិនបាន មានសភាពមិនកើតតទៅទៀត ក្នុងកាលណា ព្រាហ្មណ៍ឈ្មោះថា មិនជាប់ មិនជាប់ព្រម មិនជាប់មាំ ជាអ្នកមិនប្រឡាក់ មិនប្រឡាក់ព្រម មិនចូលទៅប្រឡាក់ ស្ទុះចេញ លះបង់ រួចស្រឡះ ប្រាសចេញ មានចិត្តប្រាសចាកកិលេសដូចជាទំនប់ជាដើម ក្នុងបុណ្យនិងបាប ព្រោះហេតុប៉ុណ្ណេះ ក្នុងកាលនោះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនជាប់នៅក្នុងបុណ្យនិងបាប ។

[១២២] ពាក្យថា ជាអ្នកលះបង់នូវអត្តា លែងធ្វើក្នុងលោកនេះ អធិប្បាយថា អ្នកលះបង់នូវអត្តទិដ្ឋិ ឈ្មោះថា អ្នកលះបង់នូវអត្តា ។ អ្នកលះបង់នូវ

សេចក្តីប្រកាន់ ឈ្មោះថា អ្នកលះបង់នូវអត្តា ។ វត្ថុណា ដែលគេប្រកាន់ ប្រួសអង្អែល ត្រេកអរចំពោះ ចុះចិត្ត ចុះចិត្តស៊ប់ហើយ ដោយអំណាចតណ្ហា ដោយអំណាចទិដ្ឋិ វត្ថុទាំងអស់នោះ ព្រាហ្មណ៍បានកម្ចាត់ ខ្ជាក់ចោល ផុត លះបង់ រលាស់ចោលហើយ ឈ្មោះថា អ្នកលះបង់នូវអត្តា ។ ពាក្យថា លែង ធ្វើក្នុងលោកនេះ គឺមិនធ្វើ មិនឲ្យកើត មិនឲ្យកើតព្រម មិនបង្កើត មិនបង្កើត ចំពោះនូវបុញ្ញាភិសង្ខារក្តី នូវអបុញ្ញាភិសង្ខារក្តី នូវអានេញ្ជាភិសង្ខារក្តី ហេតុ នោះ ( ទ្រង់ត្រាស់ថា ) ជាអ្នកលះបង់នូវអត្តា លែងធ្វើក្នុងលោកនេះ ។ ហេតុ នោះ ព្រះមានព្រះភាគទ្រង់ត្រាស់ថា

ព្រាហ្មណ៍មិនពោលនូវសេចក្តីបរិសុទ្ធដោយផ្លូវដទៃ ព្រោះ
អារម្មណ៍ដែលឃើញក្តីដែលឮក្តី ព្រោះសីលនិងវត្តក្តី ព្រោះ
អារម្មណ៍ដែលប៉ះពាល់ក្តី ទាំងមិនជាប់នៅក្នុងបុណ្យនិងបាប
ជាអ្នកលះបង់នូវអត្តា លែងធ្វើក្នុងលោកនេះ ដូច្នេះ ។

[ ១២៣ ] ជនណា ជាអ្នកលង់តាមការញាប់ញ័រ លះបង់វត្ថុមុន អាស្រ័យ វត្ថុក្រោយ ជននោះនឹងឆ្លងនូវការជាប់ចំពាក់មិនបានទេ ជននោះតែងប្រកាន់ តែងលះបង់ ដូចជាស្វាតោងមែកឈើចំពោះមុខ ។

[ ១២៤ ] ពាក្យថា លះបង់វត្ថុមុនហើយអាស្រ័យវត្ថុក្រោយ គឺលះបង់ សាស្តាមុន មកពឹងផ្អែកនឹងសាស្តាក្រោយ លះបង់ធម៌ដែលសាស្តាប្រាប់មុន មកអាស្រ័យធម៌ដែលសាស្តាប្រាប់ក្រោយ លះបង់ពួកមុន មកអាស្រ័យពួក ក្រោយ លះបង់ទិដ្ឋិមុន មកអាស្រ័យទិដ្ឋិក្រោយ លះបង់បដិបទាមុន មក

អាស្រ័យបដិបទាក្រោយ លះបង់មគ្គមុន ហើយអាស្រ័យ អាស្រ័យព្រម ជាប់នៅ ជក់នៅ ចុះចិត្ត ចុះចិត្តស៊ប់នូវមគ្គក្រោយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) តែងលះបង់វត្ថុមុន អាស្រ័យវត្ថុក្រោយ ។

[ ១២៥ ] ពាក្យថា ជនណាជាអ្នកលង់តាមការញាប់ញ័រ... ជននោះនឹងធ្លងនូវការជាប់ចំពាក់មិនបានទេ អធិប្បាយថា តណ្ហាហៅថា ការញាប់ញ័របាន ខាងតម្រេក តម្រេកខ្លាំង ។បេ។ អភិជ្ឈា លោភៈ អកុសលមូល ។ ពាក្យថា ជាអ្នកលង់តាមការញាប់ញ័រ គឺជាអ្នកប្រព្រឹត្តតាមការញាប់ញ័រទៅ តាមការញាប់ញ័រ ផ្សាយទៅតាមការញាប់ញ័រ ដល់នូវការញាប់ញ័រ ធ្លាក់ចុះ គ្របសង្កត់ មានចិត្តរួបរឹតដោយការញាប់ញ័រ ។ ពាក្យថា នឹងធ្លងនូវការជាប់ចំពាក់មិនបានទេ គឺនឹងធ្លងមិនបាន ធ្លងឡើងមិនបាន ធ្លងមិនផុត មិនកន្លងព្រម មិនប្រព្រឹត្តកន្លងនូវការចំពាក់គឺរាគៈ ការចំពាក់គឺទោសៈ ការចំពាក់គឺមោហៈ ការចំពាក់គឺមានះ ការចំពាក់គឺទិដ្ឋិ ការចំពាក់គឺកិលេស ការចំពាក់គឺទុច្ចរិត ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជនណា ជាអ្នកលង់តាមការញាប់ញ័រ ជននោះ នឹងធ្លងនូវការជាប់ចំពាក់មិនបានទេ ។

[ ១២៦ ] ពាក្យថា ជនទាំងនោះ តែងប្រកាន់ តែងលះបង់ សេចក្តីថា ប្រកាន់យកនូវសាស្តា លះបង់នូវសាស្តានោះ ហើយប្រកាន់សាស្តាដទៃវិញ ប្រកាន់ធម៌ដែលសាស្តាប្រាប់ លះបង់ធម៌ដែលសាស្តាប្រាប់នោះ ហើយប្រកាន់ធម៌ដទៃដែលសាស្តាប្រាប់វិញ ប្រកាន់ពួក លះបង់ពួកនោះហើយប្រកាន់ពួកដទៃវិញ ប្រកាន់ទិដ្ឋិ លះបង់ទិដ្ឋិនោះ ហើយប្រកាន់ទិដ្ឋិដទៃវិញ ប្រកាន់

បដិបទា លះបង់បដិបទានោះហើយប្រកាន់បដិបទាដទៃវិញ ប្រកាន់មគ្គ លះបង់មគ្គនោះហើយប្រកាន់មគ្គដទៃវិញ ប្រកាន់ផល លះបង់ផល ប្រកាន់យកផល លែងចោលផល ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជនទាំងនោះ តែងប្រកាន់តែងលះបង់ ។

[ ១២៧ ] ពាក្យថា ដូចជាស្វាតោងមែកឈើចំពោះមុខ សេចក្តីថា ស្វាកាលត្រាច់ទៅក្នុងព្រៃតូចព្រៃធំ តែងតោងមែកឈើ លែងនូវមែកឈើនោះចោល ហើយតោងមែកឈើដទៃ លែងមែកឈើនោះចោល ហើយតោងមែកឈើដទៃវិញ យ៉ាងណា ពួកសមណព្រាហ្មណ៍ផ្តេសផ្តាស តែងប្រកាន់ផល លះបង់ផល កាន់យកផល លែងចោលផល នូវទិដ្ឋិផ្តេសផ្តាស ក៏យ៉ាងនោះដែរ ព្រោះហេតុនោះ ( ទ្រង់ត្រាស់ថា ) ដូចជាស្វាតោងមែកឈើចំពោះមុខ ព្រោះហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ជនណា ជាអ្នកលង់តាមការញាប់ញ័រ លះបង់វត្ថុមុន អាស្រ័យ
វត្ថុក្រោយ ជននោះ នឹងឆ្លងនូវការជាប់ចំពាក់មិនបាន ជននោះ
តែងប្រកាន់ តែងលះបង់ ដូចជាស្វាតោងមែកឈើចំពោះមុខ
ដូច្នេះ ។

[ ១២៨ ] ជនសមាទាននូវវត្តទាំងឡាយដោយខ្លួនឯង ជាអ្នកជាប់ក្នុងសញ្ញា តែងទៅរកវត្ថុខ្ពស់ទាប ឯអ្នកប្រាជ្ញ មានបញ្ញាដូចផែនដី ត្រាស់ដឹងនូវធម៌ដោយវេទទាំងឡាយ មិនទៅរកវត្ថុខ្ពស់ទាបទេ ។

[ ១២៩ ] អធិប្បាយពាក្យថា ជនសមាទាននូវវត្តទាំងឡាយដោយខ្លួនឯង

ត្រង់ពាក្យថា សមាទានដោយខ្លួនឯង គឺកាន់យកព្រមដោយខ្លួនឯង ។ ពាក្យថា វត្តទាំងឡាយ សេចក្តីថា កាន់យក កាន់យកព្រម ប្រកាន់ ប្រកាន់ព្រម ក្ដួចកាន់យក បបោសអង្អែល ជាប់ចិត្ត នូវវត្តដំរីក្តី វត្តសេះក្តី វត្តគោក្តី វត្តឆ្កែក្តី វត្តក្អែកក្តី វត្តវាសុទេពក្តី វត្តពលទេពក្តី វត្តបុណ្ណភទ្រក្តី វត្តមណិភទ្រក្តី វត្តភ្លើងក្តី វត្តនាគក្តី វត្តគ្រុឌក្តី វត្តយក្ខក្តី វត្តអសុរក្តី ។បេ។ វត្តទិសក្តី ។ ពាក្យថា ជន គឺសត្វ នរៈ ។បេ។ សត្វមានជាតិជាមនុស្ស ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជនសមាទាននូវវត្តទាំងឡាយដោយខ្លួនឯង ។

[ ១៣០ ] ពាក្យថា ជាអ្នកជាប់ក្នុងសញ្ញា រមែងទៅរកវត្ថុខ្ពស់ទាប សេចក្តីថា ចេញអំពីសាស្តា ទៅរកសាស្តា ចេញអំពីធម៌ដែលសាស្តាប្រាប់ ទៅរកធម៌ដែលសាស្តាប្រាប់ អំពីពួក ទៅរកពួក អំពីទិដ្ឋិ ទៅរកទិដ្ឋិ អំពីបដិបទា ទៅរកបដិបទា អំពីមគ្គ ទៅរកមគ្គ ។ ពាក្យថា ជាអ្នកជាប់នៅក្នុងសញ្ញា គឺចំពាក់ ចំពាក់ធ្វាក់ ចំពាក់ចាក់ស្រេះ ជ្ពក់ ទាក់ជាប់មាំហើយក្នុងកាមសញ្ញា ព្យាបាទសញ្ញា វិហឹសាសញ្ញា ទិដ្ឋិសញ្ញា ។ កណ្តៀៈដែលចំពាក់ ចំពាក់ធ្វាក់ ចំពាក់ចាក់ស្រេះ ជ្ពក់ ទាក់ជាប់មាំហើយ ឰដ៏ចម្រឹងជញ្ជាំង ឬដៃកែវ យ៉ាងណាមិញ បុគ្គលអ្នកចំពាក់ ចំពាក់ធ្វាក់ ចំពាក់ចាក់ស្រេះ ជ្ពក់ ទាក់ជាប់មាំហើយ ក្នុងកាមសញ្ញា ព្យាបាទសញ្ញា វិហឹសាសញ្ញា ទិដ្ឋិសញ្ញា ក៏យ៉ាងនោះដែរ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជនអ្នកជាប់នៅក្នុងសញ្ញាតែងទៅរកវត្ថុខ្ពស់ទាប ។

[ ១៣១ ] អធិប្បាយពាក្យថា អ្នកប្រាជ្ញ ត្រាស់ដឹងនូវធម៌ដោយវេទទាំងឡាយ ត្រង់ពាក្យថា អ្នកប្រាជ្ញ គឺអ្នកដឹង អ្នកប្រកបដោយវិជ្ជា អ្នកមានញាណ

អ្នកមានប្រាជ្ញា មានបញ្ញាជាគ្រឿងចុះយល់ មានបញ្ញាជាគ្រឿងថ្លឹង ។ ញាណ បញ្ញា បញ្ញិន្ទ្រិយ បញ្ញាពល ធម្មវិចយសម្ពោជ្ឈង្គៈ វិមំសា វិបស្សនា សម្មាទិដ្ឋិ ក្នុងមគ្គទាំងឡាយ ៤ លោកហៅថា វេទ ក្នុងបទថា ដោយវេទទាំងឡាយ ។ បុគ្គលដល់នូវទីបំផុត សម្រេចនូវទីបំផុត ដល់នូវចុង សម្រេចនូវចុង ដល់នូវទីបំផុតដោយជុំវិញ សម្រេចនូវទីបំផុតដោយជុំវិញ ដល់នូវទីអវសាន សម្រេចនូវទីអវសាននៃជាតិ ជរានិងមរណៈ ដល់ហើយនូវទីជ្រកកោន សម្រេចនូវទីជ្រកកោន ដល់នូវទីពួន សម្រេចនូវទីពួន ដល់នូវទីពឹង ទីរឭក សម្រេចនូវទីពឹងទីរឭក ដល់នូវទីមិនមានភ័យ សម្រេចនូវទីមិនមានភ័យ ដល់នូវទីមិនច្យុត សម្រេចនូវទីមិនច្យុត ដល់នូវអមតៈ សម្រេចនូវអមតៈ ដល់នូវព្រះនិព្វាន សម្រេចនូវព្រះនិព្វានដោយវេទទាំងនោះ ។ មួយទៀត បុគ្គលដល់នូវទីបំផុតនៃវេទទាំងឡាយ ឈ្មោះថា វេទគូបុគ្គល ។ បុគ្គលដល់នូវទីបំផុតដោយវេទទាំងឡាយ ឈ្មោះថា វេទគូបុគ្គល ។ បុគ្គលដែលឈ្មោះថា វេទគូ ព្រោះដឹងច្បាស់នូវធម៌ទាំងឡាយ ៧ ប្រការ គឺជាអ្នកដឹងច្បាស់សក្កាយទិដ្ឋិ ១ ដឹងច្បាស់វិចិកិច្ឆា ១ ដឹងច្បាស់សីលព្វតបរាមាស ១ ដឹងច្បាស់រាគៈ ១ ដឹងច្បាស់ទោសៈ ១ ដឹងច្បាស់មោហៈ ១ ដឹងច្បាស់មានះ ១ អកុសលធម៌ទាំងឡាយដ៏លាមក ប្រកបដោយសេចក្តីសៅហ្មងព្រម ជាធម៌ញុំាងសត្វឲ្យកើតក្នុងភពថ្មីទៀត ប្រកបដោយសេចក្តីក្រវល់ក្រវាយ ជាធម៌មានសេចក្តីទុក្ខជាផល ជាបច្ច័យរបស់ជាតិ ជរានិងមរណៈ តទៅទៀត វេទគូបុគ្គលដឹងច្បាស់ហើយ ។

*( ព្រះមានព្រះភាគត្រាស់ថា ម្នាលសភិយៈ ) បុគ្គលណា ពិចារណាហើយនូវវេទទាំងអស់របស់ពួកសមណព្រាហ្មណ៍ ជាអ្នកប្រាសចាកតម្រេកក្នុងវេទទាំងពួង កន្លងនូវវេទទាំងពួង បុគ្គលនោះ ឈ្មោះថា វេទគូបុគ្គល ដូច្នេះ ។*

*ពាក្យថា ត្រាស់ដឹងនូវធម៌ គឺត្រាស់ដឹង ត្រាស់ដឹងចំពោះនូវធម៌ ។ ត្រាស់ដឹង ត្រាស់ដឹងចំពោះនូវធម៌ថា សង្ខារទាំងពួងមិនទៀង ។ ត្រាស់ដឹង ត្រាស់ដឹងចំពោះនូវធម៌ថា សង្ខារទាំងពួងជាទុក្ខ ។ ត្រាស់ដឹង ត្រាស់ដឹងចំពោះនូវធម៌ថា ធម៌ទាំងពួងជាអនត្តា ។ ត្រាស់ដឹង ត្រាស់ដឹងចំពោះនូវធម៌ថា សង្ខារទាំងឡាយ ( កើត ) ព្រោះអវិជ្ជា ជាបច្ច័យ ។ ត្រាស់ដឹង ត្រាស់ដឹងចំពោះនូវធម៌ថា វិញ្ញាណ ( កើត ) ព្រោះសង្ខារជាបច្ច័យ ។ នាមនិងរូប ( កើត ) ព្រោះវិញ្ញាណជាបច្ច័យ ។ អាយតនៈ ៦ ( កើត ) ព្រោះនាមរូបជាបច្ច័យ ។ ផស្សៈ ( កើត ) ព្រោះអាយតនៈ ៦ ជាបច្ច័យ ។ វេទនា ( កើត ) ព្រោះផស្សៈជាបច្ច័យ ។ តណ្ហា ( កើត ) ព្រោះវេទនាជាបច្ច័យ ។ ឧបាទាន ( កើត ) ព្រោះតណ្ហាជាបច្ច័យ ។ ភព ( កើត ) ព្រោះឧបាទានជាបច្ច័យ ។ ជាតិ ( កើត ) ព្រោះភពជាបច្ច័យ ។ ត្រាស់ដឹង ត្រាស់ដឹងចំពោះនូវធម៌ថា ជរានិងមរណៈ ( កើត ) ព្រោះជាតិជាបច្ច័យ ។ ត្រាស់ដឹង ត្រាស់ដឹងចំពោះនូវធម៌ថា កិរិយារលត់សង្ខារ ព្រោះការរលត់អវិជ្ជា ។ ត្រាស់ដឹង ត្រាស់ដឹងចំពោះនូវធម៌ថា កិរិយារលត់វិញ្ញាណ ព្រោះការរលត់សង្ខារ ។ កិរិយារលត់នាមនិងរូប ព្រោះការរលត់វិញ្ញាណ ។ កិរិយារលត់អាយតនៈ ៦ ព្រោះការ*

រលត់នាមរូប ។ កិរិយារលត់ផស្សៈ ព្រោះការរលត់អាយតនៈ ៦ ។ កិរិយារលត់វេទនា ព្រោះការរលត់ផស្សៈ ។ កិរិយារលត់តណ្ហា ព្រោះការរលត់វេទនា ។ កិរិយារលត់ឧបាទាន ព្រោះកិរិយារលត់តណ្ហា ។ កិរិយារលត់ភព ព្រោះការរលត់ឧបាទាន ។ កិរិយារលត់ជាតិ ព្រោះការរលត់ភព ។ ត្រាស់ដឹង ត្រាស់ដឹងចំពោះនូវធម៌ថា កិរិយារលត់ជរានិងមរណៈ ព្រោះការរលត់ជាតិ ។ ត្រាស់ដឹង ត្រាស់ដឹងចំពោះនូវធម៌ថា នេះទុក្ខ ។ នេះជាហេតុនាំឲ្យកើតទុក្ខ ។ នេះជាការរលត់ទុក្ខ ។ ត្រាស់ដឹង ត្រាស់ដឹងចំពោះនូវធម៌ថា នេះជាបដិបទាទៅកាន់ការរលត់ទុក្ខ ។ ត្រាស់ដឹង ត្រាស់ដឹងចំពោះនូវធម៌ថា នេះពួកអាសវៈ ។ នេះជាហេតុនាំឲ្យកើតអាសវៈ ។ នេះជាការរំលត់អាសវៈ ។ ត្រាស់ដឹង ត្រាស់ដឹងចំពោះនូវធម៌ថា នេះបដិបទាទៅកាន់ការរលត់អាសវៈ ។ នេះពួកធម៌គួរត្រាស់ដឹង ។ នេះពួកធម៌គួរកំណត់ដឹង ។ នេះពួកធម៌គួរលះបង់ ។ នេះពួកធម៌គួរចម្រើន ។ ត្រាស់ដឹង ត្រាស់ដឹងចំពោះនូវធម៌ថា នេះពួកធម៌គួរធ្វើឲ្យជាក់ច្បាស់ ។ ត្រាស់ដឹង ត្រាស់ដឹងចំពោះនូវធម៌ គឺហេតុឲ្យកើតផង ឲ្យរលត់ផង សេចក្តីរីករាយផង ទោសផង រលាស់ចេញផងនៃផស្សាយតនៈ ៦ ។ ត្រាស់ដឹង ត្រាស់ដឹងចំពោះនូវធម៌ គឺហេតុឲ្យកើតផង ឲ្យរលត់ផង សេចក្តីរីករាយផង ទោសផង រលាស់ចេញផង នៃឧបាទានក្ខន្ធ ៥ ។ ត្រាស់ដឹង ត្រាស់ដឹងចំពោះនូវធម៌ គឺហេតុឲ្យកើតផង ឲ្យរលត់ផង សេចក្តីរីករាយផង ទោសផង រលាស់ចេញផង នៃមហាភូត ៤ ។ ត្រាស់ដឹង ត្រាស់ដឹងចំពោះនូវធម៌ថា វត្ថុណាមួយ មានកិរិយាកើតឡើងជាធម្មតា វត្ថុទាំងពួងនោះ មាន

កិរិយារលត់ទៅវិញជាធម្មតា ហេតុនោះ ( ទ្រង់ត្រាស់ថា ) ឯអ្នកប្រាជ្ញត្រាស់ដឹងនូវធម៌ដោយវេទទាំងឡាយ ។

[ ១៣២ ] ពាក្យថា មានបញ្ញាដូចផែនដី មិនទៅរកវត្ថុ ខ្ពស់និងទាប គឺ មិនចេញអំពីសាស្តាទៅរកសាស្តា មិនចេញអំពីធម៌ដែលសាស្តាប្រាប់ទៅរកធម៌ដែលសាស្តាប្រាប់ មិនចេញអំពីពួកទៅរកពួក មិនចេញអំពីទិដ្ឋិទៅរកទិដ្ឋិ មិនចេញអំពីបដិបទាទៅរកបដិបទា មិនចេញអំពីមគ្គទៅរកមគ្គ ។ ពាក្យថា មានបញ្ញាដូចជាផែនដី គឺមានបញ្ញាច្រើន មានបញ្ញាក្រាស់ មានបញ្ញាស្រស់ មានបញ្ញារហ័ស មានបញ្ញាមុត មានបញ្ញាជាគ្រឿងទម្លាយបង់នូវកិលេស ។ ប្រឹថពី ហៅថា ផែនដី ។ អ្នកប្រាជ្ញប្រកបព្រមហើយ ដោយបញ្ញាដ៏ទូលាយ លាតផ្សាយស្មើដោយប្រឹថពីនោះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មានបញ្ញាដូចផែនដី មិនទៅរកវត្ថុខ្ពស់ទាប ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ជនសមាទាននូវវត្តទាំងឡាយដោយខ្លួនឯង ជាអ្នកជាប់នៅ
ក្នុងសញ្ញា តែងទៅរកវត្ថុខ្ពស់ទាប ឯអ្នកប្រាជ្ញមានបញ្ញា ដូច
ផែនដី ត្រាស់ដឹងនូវធម៌ដោយវេទទាំងឡាយ មិនទៅរកវត្ថុ
ខ្ពស់និងទាបទេ ដូច្នេះ ។

[ ១៣៣ ] អ្នកប្រាជ្ញនោះ ជាអ្នកមានសេនាទៅប្រាសហើយក្នុងធម៌ទាំងពួងទាំងឡាយ គឺអារម្មណ៍ណាមួយ ដែលលោកឃើញហើយក្តី ឮហើយក្តី ប៉ះពាល់ហើយក្តី ជនគប្បីកំណត់នូវអ្នកប្រាជ្ញ ជាអ្នកឃើញ អ្នកមានដំបូលបើកហើយ កំពុងប្រព្រឹត្តនោះឯង ដោយកិលេសដូចម្តេច ក្នុងលោកនេះបាន ។

[ ១៣៤ ] ពាក្យថា អ្នកប្រាជ្ញនោះ ជាអ្នកមានសេនាទៅប្រាសហើយក្នុងធម៌ទាំងពួងទាំងឡាយ គឺអារម្មណ៍ណាមួយ ដែលលោកឃើញហើយក្តី ឮហើយក្តី ប៉ះពាល់ហើយក្តី អធិប្បាយថា សេនារបស់មារ លោកហៅថា សេនា ។ កាយទុច្ចរិតជាមារសេនា វចីទុច្ចរិតជាមារសេនា មនោទុច្ចរិតជាមារសេនា រាគៈជាមារសេនា ទោសៈជាមារសេនា មោហៈជាមារសេនា កោធៈ ឧបនាហៈ ។បេ។ អកុសលាភិសង្ខារទាំងអស់ជាមារសេនា ។ ដូចពាក្យដែលព្រះមានព្រះភាគត្រាស់ដូច្នេះថា

កាមជាសេនាទី ១ របស់អ្នក សេចក្តីមិនត្រេកអរ ( ក្នុងធម៌ជាកុសល ) លោកហៅថា សេនាទី ២ សេចក្តីស្រេកឃ្លានជាសេនាទី ៣ របស់អ្នក តណ្ហាលោកហៅថា សេនាទី ៤ ថីនមិទ្ធៈជាសេនទី ៥ របស់អ្នក សេចក្តីខ្លាច លោកហៅថា សេនាទី ៦ វិចិកិច្ឆាជាសេនាទី ៧ របស់អ្នក ការលុបគុណនិងសេចក្តីរឹងត្អឹងជាសេនាទី ៨ របស់អ្នក លាភ សេចក្តីសរសើរនិងសក្ការៈ ( ជាសេនាទី ៩ ) យសដែលបុគ្គលបានមកដោយការខុស បុគ្គលដែលលើកតម្កើងខ្លួនឯងទាំងមើលងាយអ្នកដទៃ ( នេះជា ) សេនាទី ១០ ម្នាលមារ នេះជាសេនារបស់អ្នកឯងដែលមានធម៌ខ្មៅ ជាសេនាតែងបៀតបៀន ( នូវពួកសមណព្រាហ្មណ៍ ) បុគ្គលមិនក្លៀវក្លា មិនអាចឈ្នះនូវសេនានោះទេ ( លុះតែបុគ្គលក្លៀវក្លា ) ទើប

ឈ្នះហើយបានសុខ ដូច្នេះ ។

កាលណា មារសេនាទាំងពួងនិងកិលេសជាសត្រូវទាំងពួង ដែលបុគ្គលណា ឈ្នះ ផ្ចាញ់ បំបាក់ កម្ទេច ធ្វើឲ្យមានមុខងាកចេញដោយអរិយមគ្គទាំង ៤ បានហើយ បុគ្គលនោះ លោកហៅថា អ្នកមានសេនាទៅប្រាសហើយ ។ បុគ្គលនោះមានសេនាទៅប្រាសក្នុងអារម្មណ៍ដែលឃើញ មានសេនាទៅប្រាសក្នុងអារម្មណ៍ដែលឮ មានសេនាទៅប្រាសក្នុងអារម្មណ៍ដែលប៉ះពាល់ មានសេនាទៅប្រាសក្នុងអារម្មណ៍ដែលដឹង ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកប្រាជ្ញនោះ មានសេនាទៅប្រាសហើយក្នុងធម៌ទាំងពួងទាំងឡាយ គឺអារម្មណ៍ណាមួយដែលលោកឃើញហើយក្តី ឮហើយក្តី ប៉ះពាល់ហើយក្តី ។

[ ១៣៥ ] ពាក្យថា អ្នកឃើញ អ្នកមានដំបូលបើកហើយ កំពុងប្រព្រឹត្តនោះឯង គឺអ្នកឃើញការស្អាត អ្នកឃើញការស្អាតវិសេស អ្នកឃើញការបរិសុទ្ធ អ្នកឃើញការហ្មត់ចត់ អ្នកឃើញការផូរផង់ ។ ឬថា អ្នកមានសេចក្តីយល់ស្អាត អ្នកមានសេចក្តីយល់ស្អាតវិសេស អ្នកមានសេចក្តីយល់បរិសុទ្ធិ អ្នកមានសេចក្តីយល់ហ្មត់ចត់ ។ អ្នកមានសេចក្តីយល់ផូរផង់ ។ ពាក្យថា អ្នកមានដំបូលបើកហើយ សេចក្តីថា ដំបូលគឺតណ្ហា ដំបូលគឺកិលេស ដំបូលគឺអវិជ្ជា ។ គ្រឿងប្រក់ទាំងនោះ លោកបើក កំចាត់បង់ បំផ្លាញចោល ដករំលើងចោល លះបង់ ផ្តាច់បង់ ស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើត ដុតដោយភ្លើង គឺញាណហើយ ។ ពាក្យថា កំពុងប្រព្រឹត្ត គឺកំពុងត្រាច់ទៅ កំពុងត្រាច់ទៅផ្សេងៗ កំពុងសម្រេចឥរិយាបថ កំពុងប្រព្រឹត្ត កំពុងរក្សា កំពុងរស់នៅ កំពុងញ៉ាំង

អត្តភាពឲ្យប្រព្រឹត្តទៅ ព្រោះហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកឃើញ អ្នកមានជំបូលបើកហើយ កំពុងប្រព្រឹត្តនោះឯង ។

[ ១៣៦ ] អធិប្បាយពាក្យថា គប្បីកំណត់ដោយកិលេសដូចម្តេច ក្នុងលោកនេះ ត្រង់ពាក្យថា កំណត់ បានដល់ការកំណត់មាន ២ គឺការកំណត់គឺតណ្ហា ១ ការកំណត់គឺទិដ្ឋិ ១ ។បេ។ នេះការកំណត់គឺតណ្ហា ។បេ។ នេះការកំណត់គឺទិដ្ឋិ ។ ការកំណត់គឺតណ្ហា អ្នកប្រាជ្ញនោះ បានលះបង់ហើយ ការកំណត់គឺទិដ្ឋិ អ្នកប្រាជ្ញនោះ បានរលាស់ចោលហើយ ព្រោះលោកលះបង់នូវការកំណត់គឺតណ្ហា ព្រោះលោករលាស់ចោលនូវការកំណត់គឺទិដ្ឋិ ជនគប្បីកំណត់ដោយរាគៈដូចម្តេច គប្បីកំណត់ដោយទោសៈដូចម្តេច គប្បីកំណត់ដោយមោហៈដូចម្តេច គប្បីកំណត់ដោយមានះដូចម្តេច គប្បីកំណត់ដោយទិដ្ឋិដូចម្តេច គប្បីកំណត់ដោយឧទ្ធច្ចៈដូចម្តេច គប្បីកំណត់ដោយវិចិកិច្ឆាដូចម្តេច គប្បីកំណត់ដោយអនុស័យទាំងឡាយដូចម្តេចបានថា លោកនៅត្រេកត្រអាលក្តី នៅប្រទូស្តក្តី នៅវង្វេងក្តី នៅជាប់ចំពាក់ក្តី នៅបបោសអង្អែលក្តី ដល់នូវការរាយមាយក្តី ដល់នូវការមិនដាច់ស្រេចក្តី ដល់នូវកម្លាំងក្តី ។ អភិសង្ខារទាំងនោះ អ្នកប្រាជ្ញនោះ លះបង់ហើយ ព្រោះលោកលះអភិសង្ខារហើយ ជនគប្បីកំណត់នូវគតិទាំងឡាយថា លោកទៅកើតក្នុងនរកក្តី កើតក្នុងកំណើតតិរច្ឆានក្តី កើតក្នុងប្រេតវិស័យក្តី ជាមនុស្សក្តី ជាទេវតាក្តី ព្រហ្មមានរូបក្តី ព្រហ្មឥតរូបក្តី ព្រហ្មមានសញ្ញាក្តី ព្រហ្មឥតសញ្ញាក្តី ព្រហ្មមានសញ្ញា ក៏មិនមែន មិនមានសញ្ញាក៏មិនមែនក្តី ដោយប្រការដូចម្តេចបាន ។ មិនមានហេតុ

មិនមានបច្ច័យ មិនមានទំនងជាហេតុល្មមឲ្យជន គប្បីកំណត់ គប្បីកំណត់ទុក គប្បីដល់នូវការកំណត់ទុកបានឡើយ ។ ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក មនុស្សលោក ទេវលោក ខន្ធលោក ធាតុលោក អាយតនលោក ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជនគប្បីកំណត់ដោយកិលេសដូចម្តេចក្នុងលោកនេះបាន ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

អ្នកប្រាជ្ញនោះ មានសេនាទៅប្រាសហើយក្នុងធម៌ទាំងពួងទាំងឡាយ គឺអារម្មណ៍ណាមួយដែលលោកឃើញហើយក្តី ឮហើយក្តី ប៉ះពាល់ហើយក្តី ជនគប្បីកំណត់នូវអ្នកប្រាជ្ញ ជាអ្នកឃើញមានជំបូលបើកហើយ កំពុងប្រព្រឹត្តនោះឯង ដោយកិលេសដូចម្តេចក្នុងលោកនេះបាន ដូច្នេះ ។

[ ១៣៧ ] ព្រះខីណាស្រពទាំងឡាយនោះ មិនកំណត់ មិនធ្វើឲ្យជាប្រធាន មិនពោលថា ( ទិដ្ឋិ ) មានសេចក្តីបរិសុទ្ធជាទីបំផុត កាត់គ្រឿងចងស្រែះគឺសេចក្តីប្រកាន់ដែលចងស្រែះហើយ មិនធ្វើនូវបំណងក្នុងលោកណាមួយ ។

[ ១៣៨ ] អធិប្បាយពាក្យថា មិនកំណត់ មិនធ្វើឲ្យជាប្រធាន ត្រង់ពាក្យថា កំណត់ បានដល់ការកំណត់ ២ គឺការកំណត់គឺតណ្ហា ១ ការកំណត់គឺទិដ្ឋិ ១ ។បេ។ នេះការកំណត់គឺតណ្ហា ។បេ។ នេះការកំណត់គឺទិដ្ឋិ ។ ការកំណត់គឺតណ្ហា ព្រះខីណាស្រពទាំងនោះបានលះបង់ហើយ ការកំណត់គឺទិដ្ឋិលោករលាស់ចោលហើយ ព្រះខីណាស្រពទាំងឡាយមិនកំណត់ មិនបណ្តុះ មិនឲ្យលូតលាស់ មិនបង្កើត មិនបង្កើតចំពោះនូវការកំណត់គឺតណ្ហា ឬការ

កំណាត់គឺទិដ្ឋិ ព្រោះការកំណាត់គឺតណ្ហា លោកលះបង់ហើយ ព្រោះការកំណាត់គឺទិដ្ឋិ លោករលាស់ចោលហើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនកំណាត់ ។ ពាក្យថា មិនធ្វើឲ្យជាប្រធាន បានខាងការធ្វើឲ្យជាប្រធាន ២ គឺការធ្វើឲ្យជាប្រធានគឺតណ្ហា ១ ការធ្វើឲ្យជាប្រធានគឺទិដ្ឋិ ១ ។បេ។ នេះការធ្វើឲ្យជាប្រធានគឺតណ្ហា ។បេ។ នេះការធ្វើឲ្យជាប្រធានគឺទិដ្ឋិ ។ ការធ្វើឲ្យជាប្រធានគឺតណ្ហា ព្រះខីណាស្រពទាំងនោះលះបង់ហើយ ការធ្វើឲ្យជាប្រធានគឺទិដ្ឋិ លោករលាស់ចោលហើយ ព្រះខីណាស្រពទាំងឡាយ រមែងមិនធ្វើនូវតណ្ហានិងទិដ្ឋិឲ្យជាប្រធាន មិនមានតណ្ហាជាទង់ជ័យ មិនមានតណ្ហាជាទង់សំគាល់ មិនមានតណ្ហាជាអធិបតី មិនមានទិដ្ឋិជាទង់ជ័យ មិនមានទិដ្ឋិជាទង់សំគាល់ មិនមានទិដ្ឋិជាអធិបតី មិនមានតណ្ហានិងទិដ្ឋិចោមរោម ព្រោះការធ្វើឲ្យជាប្រធានគឺតណ្ហា លោកលះបង់ហើយ ព្រោះការធ្វើឲ្យជាប្រធានគឺទិដ្ឋិ លោករលាស់ចោលហើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនកំណាត់ មិនធ្វើឲ្យជាប្រធាន ។

[ ១៣៩ ] ពាក្យថា មានសេចក្តីបរិសុទ្ធជាទីបំផុត ក្នុងបទថា ព្រះខីណាស្រពទាំងនោះ មិនពោលថា ទិដ្ឋិមានសេចក្តីបរិសុទ្ធជាទីបំផុត គឺព្រះខីណាស្រពទាំងឡាយ មិនពោល មិនថ្លែង មិនពណ៌នា មិនសម្តែង មិននិយាយនូវអកិរិយទិដ្ឋិ នូវសស្សតវាទថា មានសេចក្តីបរិសុទ្ធជាទីបំផុត មានសេចក្តីបរិសុទ្ធព្រោះសំសារ ព្រោះហេតុនោះ ( ទ្រង់ត្រាស់ថា ) ព្រះខីណាស្រពទាំងនោះ មិនពោលថា ( ទិដ្ឋិ ) មានសេចក្តីបរិសុទ្ធជាទីបំផុត ។

[ ១៤០ ] អធិប្បាយពាក្យថា កាត់គ្រឿងចងស្រែះ គឺសេចក្តីប្រកាន់ដែល

ចង់ស្រេះហើយ ត្រង់ពាក្យថា គ្រឿងចង់ស្រេះ បានដល់ គ្រឿងចង់ស្រេះ ៤ គឺអភិជ្ឈាកាយគន្ថៈ ១ ព្យាបាទកាយគន្ថៈ ១ សីលព្វតបរាមាសកាយគន្ថៈ ១ ឥទំសច្ចាភិនិវេសកាយគន្ថៈ ១ ។ តម្រេកក្នុងទិដ្ឋិរបស់ខ្លួន ឈ្មោះថា អភិជ្ឈាកាយគន្ថៈ ។ ការគំនុំ ការមិនពេញចិត្តក្នុងវាទៈរបស់បុគ្គលដទៃ ឈ្មោះថា ព្យាបាទកាយគន្ថៈ ។ បុគ្គលបបោសអង្អែលនូវសីលក្តី វត្តក្តី សីលនិងវត្តក្តី របស់ខ្លួន ឈ្មោះថា សីលព្វតបរាមាសកាយគន្ថៈ ។ ទិដ្ឋិរបស់ខ្លួន ឈ្មោះថា ឥទំសច្ចាភិនិវេសកាយគន្ថៈ ។ ព្រោះហេតុអ្វី ( គន្ថៈទាំងឡាយ ) លោកហៅថា គ្រឿងចង់ស្រេះគឺសេចក្តីប្រកាន់ ។ ពួកបុគ្គលកាន់យក ប្រកាន់ ក្ដួចកាន់ បបោសអង្អែល ចូលចិត្តរូប កាន់យក ប្រកាន់ ក្ដួចកាន់ បបោសអង្អែល ចូលចិត្ត វេទនា សញ្ញា សង្ខារ វិញ្ញាណ គតិ ឧប្បត្តិ បដិសន្ធិ ភព សង្សារ វដ្ដៈ ដោយគន្ថៈទាំងនោះ ព្រោះហេតុនោះ គន្ថៈទាំងនោះ លោកហៅថា គ្រឿងចង់ស្រេះគឺសេចក្តីប្រកាន់ ។ ពាក្យថា កាត់ គឺលះបង់ ឬកំចាត់បង់នូវគ្រឿងចង់ស្រេះទាំងឡាយ ។ មួយទៀតថា ស្រាយ ឬថាលះបង់នូវចំណង គ្រឿងចងដែលចង់ស្រេះហើយ ចំណងដែលចងហើយ ចងវិសេសហើយ ចងដោយប្រការដ៏ច្រើន ជាប់នៅ ចំពាក់នៅ ទាក់នៅ ។ បុគ្គលទាំងឡាយរុះរើ ធ្វើឲ្យខ្ទេចខ្ទីនូវវត្ថុ្ក៏ រថក្តី រទេះក្តី រថទ្រង់គ្រឿងក្តី យ៉ាងណាមិញ មុនីបោះបង់ ឬលះបោលនូវគន្ថៈទាំងឡាយ ឬថាស្រាយ ឬលះបោលនូវគន្ថៈទាំងឡាយដែលចាក់ស្រេះ ក្រង ចងធ្លាក់ ពាក់ព័ន្ធ ព័ទ្ធមាំ ជាប់ ចំពាក់ ចងមាំ ចងជាប់ ក៏យ៉ាងនោះដែរ ព្រោះហេតុនោះ ( ទ្រង់ត្រាស់ថា ) លះបង់នូវគ្រឿងចង់ស្រេះ

គឺសេចក្ដីប្រកាន់ដែលចងស្រែះហើយ ។

[ ១៤១ ] ពាក្យថា មិនធ្វើនូវបំណាងក្នុងលោកណាមួយ សេចក្ដីថា តណ្ហា លោកហៅថា បំណាង បានដល់តម្រេក តម្រេកខ្លាំង ។បេ។ អភិជ្ឈា លោភៈ អកុសលមូល ។ ពាក្យថា មិនធ្វើនូវបំណាង គឺមិនធ្វើ មិនបង្កើត មិនឲ្យកើត ព្រម មិនឲ្យកើត មិនឲ្យកើតចំពោះនូវបំណាង ។ ពាក្យថា ណាមួយ គឺណា មួយ ឯណាមួយ ឯណានីមួយ ខាងក្នុងក្ដី ខាងក្រៅក្ដី ទាំងខាងក្នុងខាងក្រៅក្ដី ។ ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក ។បេ។ អាយតនលោក ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនធ្វើនូវបំណាងក្នុងលោកណាមួយ ហេតុនោះ ព្រះមាន ព្រះភាគត្រាស់ថា

ព្រះខីណាស្រពទាំងឡាយនោះ មិនកំណត់ មិនធ្វើឲ្យជាប្រធាន
មិនពោលថា ទិដ្ឋិមានសេចក្ដីបរិសុទ្ធជាទីបំផុត កាត់គ្រឿងចង
ស្រែះ គឺសេចក្ដីប្រកាន់ដែលចងស្រែះហើយ មិនធ្វើនូវបំណាង
ក្នុងលោកណាមួយ ដូច្នេះ ។

[ ១៤២ ] ព្រាហ្មណ៍ណា កន្លងហួសដែនហើយ ព្រាហ្មណ៍នោះ មិនមាន ការប្រកាន់មាំ ព្រោះដឹងព្រោះឃើញទេ ព្រាហ្មណ៍នោះ មិនមានសេចក្ដីត្រេកអរ ក្នុងកាមរាគ មិនត្រេកអរក្នុងរូបរាគនិងអរូបរាគ ព្រាហ្មណ៍នោះ មិនមានការ ប្រកាន់ថា នេះប្រសើរ ដូច្នេះឡើយ ។

[ ១៤៣ ] អធិប្បាយពាក្យថា ព្រាហ្មណ៍ណា កន្លងហួសដែនហើយ ព្រាហ្មណ៍នោះ មិនមានការប្រកាន់មាំ ព្រោះដឹង ព្រោះឃើញទេ ត្រង់ពាក្យ

ថា ដែន បានដល់ ដែន ៤ ។ សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសៈ ទិដ្ឋានុស័យ វិចិកិច្ឆានុស័យ ព្រមទាំងកិលេសដែលតាំងនៅជាមួយគ្នានោះ នេះដែនទី ១ ។ កាមរាគសញ្ញោជនៈ បដិឃសញ្ញោជនៈដ៏គ្រោតគ្រាត កាមរាគានុស័យ បដិឃានុស័យដ៏គ្រោតគ្រាត ព្រមទាំងពួកកិលេសដែលតាំងនៅជាមួយគ្នានោះ នេះដែនទី ២ ។ កាមរាគសញ្ញោជនៈ បដិឃសញ្ញោជនៈដ៏ល្អិត កាមរាគានុស័យ បដិឃានុស័យដ៏ល្អិត ព្រមទាំងពួកកិលេស ដែលតាំងនៅជាមួយគ្នានោះ នេះដែនទី ៣ ។ រូបរាគៈ អរូបរាគៈ មានៈ ឧទ្ធច្ចៈ អវិជ្ជា មានានុសយៈ ភវរាគានុសយៈ អវិជ្ជានុសយៈ ព្រមទាំងពួកកិលេសដែលតាំងនៅជាមួយគ្នានោះ នេះដែនទី ៤ ។ កាលណា បុគ្គលកន្លង កន្លងព្រម ប្រព្រឹត្តកន្លងដែនទាំង ៤ នេះ ដោយអរិយមគ្គទាំង ៤ ហើយ បុគ្គលនោះលោកហៅថា អ្នកកន្លងហួសដែន ។ ពាក្យថា ព្រាហ្មណ៍ សេចក្តីថា បុគ្គលឈ្មោះថាព្រាហ្មណ៍ ព្រោះបន្សាត់បង់ធម៌ ៧ ។បេ។ មិនអាស្រ័យ ( ដោយតណ្ហានិងទិដ្ឋិ ) ជាតាទិបុគ្គល បុគ្គលនោះ លោកហៅថា ព្រាហ្មណ៍ ។ ពាក្យថា ព្រាហ្មណ៍នោះ គឺព្រះអរហន្តខីណាស្រព ។ ពាក្យថា ព្រោះដឹង គឺព្រោះដឹងដោយបរចិត្តញ្ញាណក្តី ព្រោះដឹងដោយបុព្វេនិវាសានុស្សតិញ្ញាណក្តី ។ ពាក្យថា ព្រោះឃើញ គឺព្រោះឃើញដោយមំសចក្ខុក្តី ដោយទិព្វចក្ខុក្តី ហេតុនោះ ទ្រង់ត្រាស់ថា ព្រាហ្មណ៍ណា កន្លងហួសដែនហើយ ព្រាហ្មណ៍នោះ មិនមានការប្រកាន់ ព្រោះដឹង ព្រោះឃើញទេ ។ ពាក្យថា ការប្រកាន់មាំ គឺការប្រកាន់ ការបបោស អង្អែល ការចូលចិត្ត ការជាប់ចិត្ត ការចុះចិត្តស៊ប់ នៃព្រាហ្មណ៍នោះថា នេះ

ថ្លៃថ្លា ខ្ពង់ខ្ពស់ ប្រសើរវិសេស ចម្បង ឧត្តម បវរ ។ ពាក្យថា មិនមាន គឺមិនមាន មិនមានព្រម មិនបាន ។ គឺលោកលះបង់ ផ្តាច់បង់ រម្ងាប់ ស្ងប់ រម្ងាប់ ធ្វើមិនគួរឲ្យកើត ដុតដោយភ្លើងគឺញាណហើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ព្រាហ្មណ៍ណា កន្លងហួសដែនហើយ ព្រាហ្មណ៍នោះ មិនមានការប្រកាន់មាំ ព្រោះដឹង ព្រោះឃើញទេ ។

[ ១៤៤ ] ពាក្យថា មិនមានសេចក្តីត្រេកអរក្នុងកាមរាគ មិនត្រេកអរក្នុងរូបរាគនិងអរូបរាគ សេចក្តីថា បុគ្គលទាំងឡាយណា ត្រេកអររីករាយ ជាប់ជ្រប់ ងប់ ទាក់ ជ្តក់ ចំពាក់ក្នុងកាមគុណទាំង ៥ បុគ្គលទាំងនោះ លោកហៅថា អ្នកត្រេកអរក្នុងកាមរាគ ។ បុគ្គលទាំងឡាយណា ត្រេកអររីករាយ ជាប់ជ្រប់ ងប់ ទាក់ ជ្តក់ ចំពាក់ក្នុងរូបាវចរសមាបត្តិនិងអរូបាវចរសមាបត្តិទាំងឡាយ បុគ្គលទាំងនោះ លោកហៅថា អ្នកត្រេកអរក្នុងរូបរាគនិងអរូបរាគ ។ ពាក្យថា មិនមានសេចក្តីត្រេកអរក្នុងកាមរាគ មិនត្រេកអរក្នុងរូបរាគនិងអរូបរាគ បានសេចក្តីថា ក្នុងកាលណា កាមរាគ រូបរាគនិងអរូបរាគ ព្រះខីណាស្រពលះបង់ ផ្តាច់ឫសចោល ធ្វើមិនឲ្យមានទីកើត ដូចជាដើមត្នោត ដល់នូវភាពមិនមាន មានសភាពមិនកើតឡើងតទៅទៀត ព្រះខីណាស្រព មិនមានសេចក្តីត្រេកអរក្នុងកាមរាគ មិនត្រេកអរក្នុងរូបរាគនិងអរូបរាគក្នុងកាលនោះ ដោយកាលមានប្រមាណប៉ុណ្ណេះឯង ។

[ ១៤៥ ] អធិប្បាយពាក្យថា ព្រាហ្មណ៍នោះ មិនមានការប្រកាន់ថា នេះប្រសើរដូច្នេះឡើយ ត្រង់ពាក្យថា ព្រាហ្មណ៍នោះ គឺព្រះអរហន្តខីណាស្រព ។

ការប្រកាន់ ការបបោសអង្អែល ការចូលចិត្ត ការជាប់ចិត្ត ការចុះចិត្តស៊ប់របស់លោកថា នេះថ្លៃថ្លា ខ្ពង់ខ្ពស់ ប្រសើរ វិសេស ចម្បង ឧត្តម បវរ ។ ពាក្យថា មិនមាន គឺមិនមាន មិនមានព្រម មិនបាន ។ គឺលោកលះបង់ ផ្ដាច់បង់ រម្ងាប់បង់ កម្ចាត់ កម្ចាត់បង់ហើយ ធ្វើមិនគួរឲ្យកើត ដុតដោយភ្លើងគឺញាណហើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ព្រាហ្មណ៍នោះ មិនមានការប្រកាន់ថា នេះប្រសើរដូច្នេះឡើយ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ព្រាហ្មណ៍ណា កន្លងហួសដែនហើយ ព្រាហ្មណ៍នោះ មិន
មានការប្រកាន់មាំ ព្រោះដឹង ព្រោះឃើញទេ ព្រាហ្មណ៍នោះ
មិនមានសេចក្ដីត្រេកអរក្នុងកាមរាគ មិនត្រេកអរក្នុងរូបរាគ
និងអរូបរាគ ព្រាហ្មណ៍នោះ មិនមានការប្រកាន់ថា នេះ
ប្រសើរ ដូច្នេះឡើយ ។

**ចប់ សុទ្ធដ្ឋកសុត្តនិទ្ទេស ទី ៤ ។**

## អដ្ឋកថា

## សុទ្ធដ្ឋកសុត្តនិទ្ទេសទី ៤

[ ១០៩ ] ក្នុងសុទ្ធដ្ឋកសុត្តនិទ្ទេសទី ៤ គប្បីជ្រាបអត្ថក្នុងគាថាដំបូងមុន ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយការបរិសុទ្ធរមែងមាន ព្រោះការឃើញបែបនេះក៏មិនមែន ម្យ៉ាងទៀត បុគ្គលពាល ដែលមានទិដ្ឋិឃើញព្រាហ្មណ៍ចន្ទាភៈ ឬបុគ្គលបែបនេះដទៃជាអ្នកមិនបរិសុទ្ធ ព្រោះល្អក់ដោយកិលេស ជាអ្នកមានរោគ ព្រោះត្រូវរោគ គឺកិលេសលិចលង់ រមែងយល់ថា អាត្មាអញ រមែងឃើញបុគ្គលបរិសុទ្ធ ជាអ្នកមិនមានរោគយ៉ាងក្រៃលែង ការបរិសុទ្ធរមែងមានដល់នរជន ព្រោះការឃើញពោលគឺទិដ្ឋិនោះ ។ បុគ្គលពាលនោះយល់យ៉ាងនេះហើយថា ការឃើញនោះជាការឃើញដ៏កំពូល ជាអ្នកពិចារណាឃើញនូវការបរិសុទ្ធ ក្នុងការឃើញនោះ រមែងជឿថា ការឃើញនោះជាមគ្គញ្ញាណ តែការឃើញនោះ មិនបានជាមគ្គញ្ញាណឡើយ ។

[ ១១០ ] បទថា **បរមំ អារោគ្យប្បត្តំ** សេចក្តីថា ដល់នូវការមិនមានព្យាធិដ៏ឧត្តមតាំងនៅ ។ បទថា **តាណប្បត្តំ** សេចក្តីថា ដល់នូវធម៌ជាគ្រឿងគ្រប់គ្រងយ៉ាងនោះ ។ បទថា **លេណប្បត្តំ** សេចក្តីថា ដល់នូវធម៌ជាទីពួន ។ បទថា **សរណប្បត្តំ** សេចក្តីថា ដល់នូវធម៌ជាទីពឹង ឬដល់នូវធម៌ជាគ្រឿងញ៉ាំងទុក្ខឲ្យវិនាស ។ បទថា **អភយប្បត្តំ** សេចក្តីថា ដល់នូវការផុតភ័យ ។ បទថា **អច្ចុតប្បត្តំ** សេចក្តីថា ដល់នូវការៈទៀង ។ បទថា **អមតប្បត្តំ** សេចក្តីថា ដល់នូវធម៌មិនស្លាប់ គឺមហានិព្វាន ។ បទថា **និព្វានប្បត្តំ** សេចក្តី

ថា ដល់នូវធម៌ដែលវៀរចាកតណ្ហាជាគ្រឿងរួបរឹត ។

[ ១១២ ] បទថា **អភិជានន្តោ** សេចក្ដីថា ដឹងដោយវិសេស ។ បទថា **អាជានន្តោ** សេចក្ដីថា ដឹងទូទៅដល់អត្ថ ។ បទថា **វិជានន្តោ** សេចក្ដីថា ដឹងច្រើនយ៉ាង ។ បទថា **បដិវិជានន្តោ** សេចក្ដីថា ដឹងច្បាស់ ព្រោះអាស្រ័យការឃើញនោះៗ ។ បទថា **បដិវិជ្ឈន្តោ** សេចក្ដីថា ធ្វើទុកក្នុងហឫទយៈ ។

[ ១១៣ ] បទថា **ចក្ខុវិញ្ញាណេន រូបទស្សនំ** សេចក្ដីថា ការឃើញរូបដោយចក្ខុវិញ្ញាណ ។ បទថា **ញាណន្តិ បច្ចេតិ** សេចក្ដីថា រមែងជឿថា ជាបញ្ញា ។ បទថា **មគ្គោតិ បច្ចេតិ** សេចក្ដីថា រមែងជឿថាជាឧបាយ ។ បទថា **បថោ** សេចក្ដីថា ជាទីសញ្ចរ ។ បទថា **នីយានំ** សេចក្ដីថា ជាគ្រឿងកាន់យកទៅ បាឋៈថា **និយ្យានំ** ក៏មាន ។

[ ១១៤ ] គាថាទី ២ ថា **ទិដ្ឋេន ចេ សុទ្ធិ** ជាដើម អត្ថរបស់គាថានោះថា បើការបរិសុទ្ធចាកកិលេសមានដល់នរជនបានព្រោះវត្ថុដែលឃើញ ពោលគឺការឃើញរូបនោះ ឬថាបើនរជននោះ រមែងលះទុក្ខមានជាតិជាដើមបានដោយញាណនោះសោត កាលបើយ៉ាងនោះ នរជននោះរមែងបរិសុទ្ធដោយមគ្គដែលមិនបរិសុទ្ធដទៃចាកអរិយមគ្គនោះឯង គឺរមែងដល់នូវភាពជាបុគ្គលដែលគប្បីពោលថា ជាអ្នកមានឧបធិដោយឧបធិ មានរាគៈជាដើមនោះឯងរមែងបរិសុទ្ធបាន តែបុគ្គលបែបនេះ រមែងមិនបរិសុទ្ធព្រោះទិដ្ឋិ រមែងប្រាប់នរជននោះថា ជាអ្នកពោលយ៉ាងនោះ គឺទិដ្ឋិនោះឯង រមែងប្រាប់ថា បុគ្គលនេះជាមិច្ឆាទិដ្ឋិបុគ្គលនោះរមែងពោលយ៉ាងនោះៗដោយន័យថា លោកទៀងជាដើម

តាមសមគួរដល់ទិដ្ឋិ ។

[ ១១៧ ] ឈ្មោះថា **សរាគោ** ព្រោះអត្ថថា ប្រព្រឹត្តទៅដោយរាគៈ អធិប្បាយថា មានរាគៈ ក្នុងបទថា **សទោសោ** ជាដើមក៏ន័យនេះឯង ។

[ ១១៨ ] គាថាទី ៣ ថា **ន ព្រាហ្មណោ** ជាដើម អត្ថនៃគាថានោះថា បុគ្គលណា ឈ្មោះថាជាព្រាហ្មណ៍ព្រោះបណ្តេត គឺបន្សាត់បាបហើយ បុគ្គលនោះដល់នូវការអស់អាសវៈ ជាព្រាហ្មណ៍ខីណាសវៈដោយមគ្គ មិនពោលនូវការបរិសុទ្ធដោយមិច្ឆាញាណ ដែលកើតឡើងក្នុងអារម្មណ៍ដែលឃើញ ពោលគឺរូបដែលសន្មតថា ជាមង្គលក្រៅលែងក្នុងអារម្មណ៍ដែលបានឮ ពោលគឺសំឡេងយ៉ាងនោះក្នុងសីល ពោលគឺការមិនឈានកន្លងក្នុងវត្ត ពោលមានហត្ថីវត្តជាដើមនិងក្នុងអារម្មណ៍ដែលជ្រាបដោយបឋវីជាដើម ដែលដទៃអំពីអរិយមគ្គញ្ញាណ ។ ពាក្យនេះលោកពោលដោយការពោលសរសើរព្រាហ្មណ៍ខីណាសវៈ ។ ព្រាហ្មណ៍នោះ ជាអ្នកមិនចូលទៅជាប់ក្នុងបុណ្យដែលប្រព្រឹត្តទៅក្នុងធាតុ ៣ ( កាមធាតុ រូបធាតុ អរូបធាតុ ) និងក្នុងបាបទាំងពួង ព្រោះហេតុអ្វី ព្រោះបុណ្យនិងបាប ព្រាហ្មណ៍នោះលះបានហើយ ទើបឈ្មោះថាជាអ្នកលះបង់នូវអត្តា ព្រោះព្រាហ្មណ៍នោះ លះការយល់ឃើញថាខ្លួនឬការប្រកាន់យ៉ាងណាមួយបាន ទើបលោកពោលថា ជាអ្នកលែងធ្វើក្នុងលោកនេះ ព្រោះមិនធ្វើបុញ្ញាភិសង្ខារជាដើម ។ ព្រោះហេតុនោះទើបព្រះមានព្រះភាគត្រាស់សរសើរបុគ្គលនោះយ៉ាងនេះ ។ម្យ៉ាងទៀត គប្បីជ្រាបការភ្ជាប់បទនេះទាំងអស់នោះឯងដោយបទដំបូងថា

**បុញ្ញេ ច បាបេ ច អនូបលិត្តោ**

**អត្តញ្ជហោ នយិធ បកុព្វមានោ**

**ន ព្រាហ្មណោ អញ្ញតោ សុទ្ធិមាហ**[១]

*ទាំងជាអ្នកមិនជាប់នៅក្នុងបុណ្យនិងបាប ជាអ្នកលះបង់នូវអត្តា ជាអ្នកលែងធ្វើក្នុងលោកនេះ ព្រាហ្មណ៍មិនពោលនូវសេចក្តីបរិសុទ្ធព្រោះផ្លូវដទៃ ដូច្នេះ ។*

[១២០] *បទថា* **នាតិ បដិក្ខេបោ** *សេចក្តីថា* **ន** *សព្ទ ជាសព្ទបដិសេធ ។ គាថាថា* **ពាហេត្វា សព្វបាបកានិ** *ជាដើម សេចក្តីថា បុគ្គលណាបន្សាត់នូវបាបទាំងពួងហើយដោយមគ្គទី ៤ ឈ្មោះថា មានចិត្តនឹងធឹង ព្រោះទិដ្ឋិតាំងនៅមិនបាន ឈ្មោះថា ជាអ្នកមានមន្ទិលទៅប្រាសហើយ ព្រោះបន្សាត់បាបចេញហើយនោះឯង គឺដល់នូវភាពជាអ្នកប្រាសចាកមន្ទិល គឺភាពជាព្រហ្មភាពជាអ្នកប្រសើរ ឈ្មោះថា មានចិត្តតម្កល់មាំដោយប្រពៃដោយមគ្គសមាធិនិងផលសមាធិដែលលះមន្ទិលគឺកិលេសដែលធ្វើនូវការរាយមាយដល់សមាធិ ។ ទើបទ្រង់ត្រាស់ថា ជាអ្នកមានកិច្ចសម្រេចអស់ហើយ ព្រោះភាពជាអ្នកមានកិច្ចសម្រេចហើយ ព្រោះកន្លងនូវសង្សារបានហើយ ព្រោះឈានកន្លងហេតុនៃសង្សារ ឈ្មោះថា ជាអ្នកមិនអាស្រ័យដោយតណ្ហានិងទិដ្ឋិ ព្រោះជាបុគ្គលដែលតណ្ហានិងទិដ្ឋិមិនអាស្រ័យហើយ នឹងឈ្មោះថា ជាតាទិបុគ្គល ព្រោះមិន*

---

*១-បាទទី ៣ នេះ ក្នុងបិដកខ្មែរជាបាទទី ១ តែក្នុងទីនេះ ព្រះអដ្ឋកថាចារ្យលោកលើកបាទទី ១ នេះ មកធ្វើជាបាទទី ៣ ទើបយើងរក្សាទុក បណ្ឌិតគប្បីជ្រាប ។*

មានការធ្វើឲ្យខុសប្លែកដោយលោកធម៌ បុគ្គលនោះគួរសរសើរយ៉ាងនេះ ទើបហៅថា ជាព្រហ្ម គឺជាព្រាហ្មណ៍ ។

បទថា **អញ្ញត្រ សតិប្បដ្ឋានេហិ** សេចក្តីថា ផុតសតិប្បដ្ឋាន ៤ ក្នុងសម្មប្បធានជាដើម ក៏ន័យនេះឯង ។

បទថា **សន្តេកេ សមណព្រាហ្មណា** សេចក្តីថា សមណព្រាហ្មណ៍ពួកខ្លះ បាននូវវោហារថា សមណព្រាហ្មណ៍ តាមការកំណត់របស់លោកមាន ។ បទថា **ទិដ្ឋសុទ្ធិកា** សេចក្តីថា ប្រាថ្នានូវការបរិសុទ្ធដោយរូបដែលឃើញ ។ បទថា **តេ ឯកច្ចានំ រូបានំ ទស្សនំ** សេចក្តីថា សមណព្រាហ្មណ៍ទាំងនោះប្រាថ្នានូវសេចក្តីបរិសុទ្ធដោយការឃើញរូប រមែងជឿនូវការសម្លឹងមើលនូវរូបារម្មណ៍ទាំងនោះ ។ បទថា **មង្គលំ បច្ចេន្តិ** សេចក្តីថា រមែងតាំងទុកនូវហេតុនៃការសម្រេចហេតុនៃការចម្រើន ហេតុនៃសម្បត្តិទាំងពួង ។ បទថា **អវមង្គលំ បច្ចេន្តិ** សេចក្តីថា រមែងឲ្យតាំងទុកនូវហេតុនៃសេចក្តីសម្រេច ក៏មិនជាហេតុនៃសេចក្តីចម្រើនក៏មិនមែន នូវហេតុនៃសម្បត្តិទាំងពួងក៏មិនមែន ។

បទថា **តេ កាលតោ វុដ្ឋហិត្វា** សេចក្តីថា សមណព្រាហ្មណ៍ទាំងនោះគឺពួកប្រកាន់វត្ថុជាដើមថាជាមង្គល ក្រោកឡើងមុនអរុណនោះឯង ។ បទថា **អភិមង្គលគតានិ** សេចក្តីថា ដល់នូវហេតុនៃសេចក្តីចម្រើនដោយពិសេស ។ បទថា **រូបានិ បស្សន្តិ** សេចក្តីថា រមែងឃើញរូបារម្មណ៍មានបែបផ្សេងៗ ។ បទថា **វាតសកុណំ** សេចក្តីថា បក្សីមានឈ្មោះយ៉ាងនោះ ។

បទថា **បុស្សវេឡុវលដ្ឋឹ** បានដល់ ផ្លៃឫស្សីដំបូងដែលកើតឡើងដោយបុស្ស

ឫក្ស ។ បទថា **គត្តិនិត្ថី** បានដល់ ស្រីមានគភ៌ ។ បទថា **កុមារកំ ១ឆេ្ន អាភោបេត្វា គច្ឆន្តី** បានដល់ បុគ្គលដែលលើកក្មេងតូចៗដាក់លើស្មាដើរទៅ ។ បទថា **បុណ្ណឃដំ** បានដល់ ក្អមពេញដោយទឹក ។ បទថា **រោហិតមច្ឆំ** បានដល់ ត្រីឆ្ពិនក្រហម ។ បទថា **អាជញ្ញរថំ** បានដល់ រថទឹមដោយសេះសិន្ធព ។ បទថា **ឧសភំ** បានដល់ គោដែលជាមង្គល ។ បទថា **គោកបិលំ** បានដល់ មេគោក្រហម ។

បទថា **បលាលបុញ្ជំ** បានដល់ ពំនូកចំបើង ។ បទថា **តក្កឃដំ** បានដល់ ឆ្នាំងពេញទៅដោយតក្កៈជាដើម ។ បទថា **រិត្តឃដំ** បានដល់ ឆ្នាំងទទេ ។ បទថា **នដំ** បានដល់ ការប្រៀនរំរបស់អ្នករបាំជាដើម ។ អាចារ្យពួកខ្លះពោលថា កិរិយារបស់អ្នកលេង ។ បទថា **ឆគ្គសមណកំ** បានដល់ សមណៈមិនស្លៀកសំពត់ ។ បទថា **១រំ** បានដល់ លា ។ បទថា **១រយានំ** សេចក្ដីថា យានជាដើមដែលទឹមដោយលា ។ បទថា **ឯកយុត្តយានំ** បានដល់ យានដែលទឹមដោយសត្វពាហនៈ ១ ។ បទថា **កាណំ** បានដល់ មនុស្សខ្វាក់ភ្នែកម្ខាងនិងសងខាង ។ បទថា **កុណឹ** បានដល់ មនុស្សក្ញែង ។ បទថា **១ញ្ជំ** បានដល់ មនុស្សជើងខ្ចក គឺមនុស្សមានជើងទៅទទឹង ។ បទថា **បក្ខហតំ** បានដល់ មនុស្សខ្វិន ។ បទថា **ជិណ្ណកំ** បានដល់ បុគ្គលចាស់គ្រោះជរា ។ បទថា **ព្យាធិកំ** បានដល់ មនុស្សត្រូវព្យាធិបៀតបៀន ។ បទថា **មតំ** បានដល់ អ្នកស្លាប់ ។

បទថា **សុតសុទ្ធិកា** បានដល់ ប្រាថ្នានូវការបរិសុទ្ធដោយសំឡេងដែល

បានឮដោយសោតវិញ្ញាណ ។ បទថា **សុតានំ សវនំ** បានដល់ ការបានឮសទ្ទារម្មណ៍ ។ បទថា **វឌ្ឍាតិ វា** ជាដើម លោកពោលកាន់យកត្រឹមតែសំឡេងដែលប្រព្រឹត្តទៅក្នុងលោកតែសំឡេងដែលពោលដោយឈ្មោះនោះៗថា **ការណោ** ជាដើមនោះឯង មិនជាមង្គល ។ បទថា **ជិន្ទន្តិ វា** បានដល់ សំឡេងថា ត្រូវកាត់ដៃនិងកាត់ជើងជាដើម ។ បទថា **ភិន្ទន្តិ វា** បានដល់ សំឡេងថា ត្រូវវាយក្បាលជាដើម ។ បទថា **ឌយ្ហន្តិ វា** បានដល់ សំឡេងថា ត្រូវភ្លើងឆេះ ។ បទថា **នដ្ឋន្តិ វា** បានដល់ សំឡេងថា វិនាស ព្រោះពួកចោរជាដើម ។ បទថា **នត្ថីតិ វា** សេចក្តីថា ឬសំឡេងថា របស់មិនមាន ។

បទថា **សីលសុទ្ធិកា** បានដល់ បុគ្គលប្រាថ្នាសេចក្តីបរិសុទ្ធវិសេសដោយសីល ។ បទថា **សីលមត្តេន** បានដល់ ដោយហេតុគឺសំវរៈ ។ បទថា **សញ្ញមមត្តេន** បានដល់ ដោយហេតុត្រឹមតែការវៀរ ។ បទថា **សំវរមត្តេន** សេចក្តីថា ដោយហេតុត្រឹមតែរាំងខ្ទារ ។ បទថា **អវីតិក្កមមត្តេន** សេចក្តីថា ដោយហេតុត្រឹមតែមិនឈានកន្លងនូវសីល ។ បទថា **សមណាមុណ្ឌិកាបុត្តោ** ជាឈ្មោះដែលបានមកអំពីចំណែកមាតា ។ បទថា **សម្បន្នកុសលំ** សេចក្តីថា មានកុសលបរិបូណ៌ ។ បទថា **បរមកុសលំ** សេចក្តីថា មានត្រកូលខ្ពស់ ។ បទថា **ឧត្តមបត្តិប្បត្តំ** សេចក្តីថា ដែលដល់អរហត្តដ៏ឧត្តម ដែលគួរដល់ហើយរស់នៅ ។ បទថា **អយោជ្ឈំ** សេចក្តីថា សមណៈដែលបុគ្គលណាមួយមិនអាចឲ្យចាញ់ ។

បទថា **វត្តសុទ្ធិកា** សេចក្តីថា ជាអ្នកប្រាថ្នានូវការបរិសុទ្ធដោយវត្ត គឺ

ការសមាទាន ។ បទថា **ហត្ថិវត្តិកា វា** សេចក្តីថា ឈ្មោះថា អ្នកប្រព្រឹត្តហត្ថីវត្ត ព្រោះអត្ថថា មានហត្ថីវត្តដែលសមាទានទុក អធិប្បាយថា ធ្វើនូវកិរិយាត្រាប់ដំរីគ្រប់យ៉ាង ធ្វើដូចម្តេច សមណព្រាហ្មណ៍ទាំងនោះ កើតនូវការគិតយ៉ាងនេះថា ចាប់តាំងពីថ្ងៃនេះទៅ អញនឹងធ្វើវត្តដែលដំរីទាំងឡាយគប្បីធ្វើ ទើបធ្វើអាការៈដើរ ឈរ អង្គុយ ដេក បន្ទោបង់ឧច្ចារៈ បស្សាវៈ ដូចដំរីទាំងឡាយនិងអាការៈដែលឃើញដំរីដទៃៗ ហើយលើកប្រមោយដើរទៅគ្រប់យ៉ាង ដូច្នោះ ទើបឈ្មោះថា ជាអ្នកប្រព្រឹត្តហត្ថីវត្ត ។ ក្នុងបទថា ជាអ្នកប្រព្រឹត្តអស្សវត្តជាដើម ក៏គប្បីប្រកបបទតាមដែលគួរប្រកបដោយអំណាចបទដែលបានមក ។

បណ្តាបទទាំងនោះ ក្នុងបទថា **ទិសាវតិកា វា** ដែលជាបទចុងក្រោយ សេចក្តីថា ជាអ្នកប្រព្រឹត្តវត្តដែលសមាទាន ដោយអំណាចនមស្ការទិស មានទិសខាងកើតជាដើម ។ ការសមាទានវត្តរបស់សមណព្រាហ្មណ៍ មានប្រការដូចពោលហើយទាំងនោះ កាលសម្រេចរមែងនាំចូលទៅដល់ភាពជាសម្លាញ់ជាមួយដំរី ( កើតជាដំរី ) ជាដើម តែបើមិច្ឆាទិដ្ឋិមានដល់បុគ្គលដែលគិតថា អញរមែងជាទេវតា ឬទេវតាអង្គណាមួយដោយការសមាទានសីលនិងវត្តនិងការប្រព្រឹត្តដ៏ប្រសើរនេះ គប្បីជ្រាបថា នរកនិងកំណើតតិរច្ឆានណាមួយរមែងមាន ។ សមដូចព្រះដ៏មានព្រះភាគត្រាស់ទុក ( ក្នុងមជ្ឈិមនិកាយ កុក្កុរោវាទសូត្រ ) ថា

ម្នាលបុណ្ណៈ បុគ្គលពួកមួយក្នុងលោកនេះ ចម្រើនកុក្កុរវត្តឲ្យ

បរិបូណ៌ ឥតមានចន្លោះ ចម្រើនកុក្កុរសីលឲ្យបរិបូណ៌ ឥតមាន ចន្លោះ ចម្រើនកុក្កុរចិត្តឲ្យបរិបូណ៌ ឥតមានចន្លោះ ចម្រើន កុក្កុរាកប្បៈឲ្យបរិបូណ៌ ឥតមានចន្លោះ បុគ្គលនោះ លុះបាន ចម្រើនកុក្កុរវត្តឲ្យបរិបូណ៌ ឥតមានចន្លោះ ចម្រើនកុក្កុរសីលឲ្យ បរិបូណ៌ ឥតមានចន្លោះ ចម្រើនកុក្កុរចិត្តឲ្យបរិបូណ៌ ឥតមាន ចន្លោះ ចម្រើនកុក្កុរាកប្បៈឲ្យបរិបូណ៌ ឥតមានចន្លោះហើយ ដល់ទម្លាយរាងកាយបន្ទាប់អំពីមរណៈ ក៏បានទៅកើតជា មួយនឹងសុនខទាំងឡាយ ប្រសិនបើសេនិយអចេលនោះ មាន ទិដ្ឋិយ៉ាងនេះថា អាត្មាអញគង់បានជាទេវតាធំ ឬជាទេវតាណា មួយដោយសីលនេះផង ដោយវត្តនេះផង ដោយតបៈនេះផង ដោយព្រហ្មចរិយៈនេះផងពុំខាន ទិដ្ឋិរបស់សេនិយអចេល នោះ ឈ្មោះថា មិច្ឆាទិដ្ឋិ នៃបុណ្ណៈ តថាគតពោលថា បណ្ដា គតិទាំងឡាយពីរ គតិណាមួយ គឺនរក ឬកំណើតនៃតិរច្ឆាន ជារបស់បុគ្គលដែលមានចិត្តតាំងនៅក្នុងមិច្ឆាទិដ្ឋិពិត នៃបុណ្ណៈ កុក្កុរវត្តដែលបុគ្គលបានធ្វើឲ្យពេញ បើមិនកើតក្នុងនរក ក៏គង់ ទៅកើតជាមួយនឹងសុនខទាំងឡាយពុំលែងឡើយ ដូច្នេះ ។

បទថា **មុត្តសុទ្ធិកា** សេចក្តីថា ជាអ្នកប្រាថ្នាការបរិសុទ្ធដោយអារម្មណ៍ ដែលពាល់ត្រូវ ។ បទថា **បឋវី អាមសន្តិ** សេចក្តីថា រមែងពាល់ត្រូវផែនដី ធំដែលមានសម្ភារៈដោយកាយ ។ បទថា **ហរិតំ** បានដល់ ស្មៅចិញ្ចៀនពណ៌

ខៀវស្រស់ ។ បទថា **គោមយំ** បានដល់ អាចម៍គោជាដើម ។ បទថា **កច្ឆបំ** បានដល់ អណ្ដើកច្រើនប្រភេទ មានអណ្ដើកសង្កល់ជាដើម ។ បទថា **ជាលំ អក្កមន្តិ** បានដល់ ជាន់សំណាញ់ដែក ។ បទថា **តិលវាហំ** បានដល់ រទេះផ្ទុកល្ង ឬគំនរល្ង ។ បទថា **បុស្សតិលំ ខាទន្តិ** បានដល់ ទំពាស៊ីល្ងដែលប្រកបដោយមង្គល ។ បទថា **បុស្សតេលំ មក្ខេន្តិ** បានដល់ ធ្វើប្រេងល្ងយ៉ាងនោះ ជាគ្រឿងប្រោះព្រំសរីរៈ ។ បទថា **ទន្តកដ្ឋំ** បានដល់ ឈើស្ទន់ ( ឈើជម្រះធ្មេញ ) ។ បទថា **មត្តិកាយ នហាយន្តិ** បានដល់ ជូតសរីរៈដោយដីទន់ មានលម្អិតដីជាដើមហើយងូត ។ បទថា **សាដកំ និវាសេន្តិ** បានដល់ ដណ្ដប់សំពត់ដែលប្រកបដោយមង្គល ។ បទថា **វេដ្ឋនំ វេដ្ឋន្តិ** បានដល់ ដាក់ គឺជូតឈ្នួតក្បាល ដែលជាសំពត់អំពីដែនបត្តុណ្ណៈជាដើមលើក្បាល ។

[ ១២១ ] បទថា **តេធាតុកំ កុសលាភិសង្ខារំ** សេចក្ដីថា បច្ចយាភិសង្ខារដែលកើតអំពីការឈ្លាសឲ្យបដិសន្ធិក្នុងកាមធាតុ រូបធាតុនិងអរូបធាតុ ។ បទថា **សព្វំ អកុសលំ** សេចក្ដីថា អកុសលដែលកើតអំពីការមិនឈ្លាស ១២ ។ បទថា **យតោ** បានដល់ ក្នុងកាលណា បុញ្ញាភិសង្ខារ ១៣ អបុញ្ញាភិសង្ខារ ១២ និងអនេញ្ជាភិសង្ខារ ៤ ឈ្មោះថា ព្រាហ្មណ៍លះបានហើយដោយសមុច្ឆេទប្បហានតាមសមគួរ ។

[ ១២២ ] បទថា **អត្តនិដ្ឋិជហោ** សេចក្ដីថា លះនូវទិដ្ឋិដែលប្រកាន់ថា នោះជាតួខ្លួនរបស់អញ ។ បទថា **គាហាញ្ជហោ** សេចក្ដីថា លះនូវការប្រកាន់ដែលសម្បយុត្តដោយមានះថា នុ៎ះជាអញ ។ បទថា **អត្តញ្ជហោ** មួយពាក្យ

ទៀត បានដល់ ការស្ទាបអង្អែលដោយអំណាចការប្រកាន់ដោយតណ្ហានិង ដោយអំណាចការប្រកាន់ដោយទិដ្ឋិថា នុ៎ះរបស់អញ បន្ទាប់មកបានដល់ ការប្រកាន់ ការប្រកាន់មាំក្នុងតណ្ហានិងទិដ្ឋិនោះ ការលេបនិងការជាប់ចិត្តដោយអំណាចតណ្ហាដែលមានកម្លាំងនិងការងប់ជ្រប់ដ៏ខ្លាំងក្លា ។ បទថា **សត្តំ តំ ចត្តំ ហោតិ** ជាដើម មានន័យដូចពោលហើយនោះឯង ។

[ ១២៣ ] កាលត្រាស់ថា **ន ព្រាហ្មណោ អញ្ញតោ សុទ្ធិមាហ** យ៉ាងនេះហើយ ឥឡូវនេះ ព្រះមានព្រះភាគកាលសម្តែងនូវទិដ្ឋិនោះ របស់ពួកអ្នកមានទិដ្ឋិដែលពោលនូវការបរិសុទ្ធដោយមគ្គដទៃ ជាទិដ្ឋិនាំទុក្ខចេញមិនបាន ទើបត្រាស់ថា **បុរិមំ បហាយ** ដូច្នេះជាដើម ។ គាថានោះមានសេចក្តីថា សមណព្រាហ្មណ៍ទាំងនោះ ជាអ្នកពោលនូវការបរិសុទ្ធដោយមគ្គដទៃ លះនូវសាស្តាដើមជាដើម អាស្រ័យសាស្តាក្រោយ ព្រោះត្រូវការប្រកាន់និងការមិនប្រកាន់គ្របសង្កត់ ព្រោះលះនូវទិដ្ឋិនោះមិនបាន ទៅតាមតណ្ហាពោលគឺសេចក្តីស្វែងរក គឺត្រូវតណ្ហាគ្របសង្កត់ រមែងមិនឆ្លងកិលេសជាគ្រឿងជាប់ជំពាក់មានរាគៈជាដើម កាលមិនឆ្លងនូវកិលេសជាគ្រឿងជាប់ជំពាក់រមែងរៀនផង រមែងលះផងនូវធម៌នោះៗ ដូចស្វាចាប់និងលែងមែកឈើ ។

[ ១២៤ ] បទថា **បុរិមំ សត្ថារំ បហាយ** សេចក្តីថា វៀរនូវបញ្ញាក្នុងសាស្តាដែលប្រកាន់ហើយក្នុងកាលមុន ។ បទថា **អបរំ សត្ថារំ និស្សិតា** សេចក្តីថា អាស្រ័យគឺជាប់ស្អិតក្នុងបញ្ញារបស់សាស្តាដទៃ ។ ក្នុងបទថា **បុរិមំ ធម្មក្ខានំ បហាយ** ជាដើម ក៏ន័យនេះឯង ។

[ ១២៥ ] បទថា **ឃជានុគា** សេចក្ដីថា ទៅតាមតណ្ហា ។ បទថា **ឃជា-នុគតា** សេចក្ដីថា ទៅតាមតណ្ហាហើយ ។ បទថា **ឃជានុសដា** សេចក្ដីថា ផ្សាយទៅតាម ឬស្ទុះទៅតាមតណ្ហា ។ បទថា **ឃជាយ បន្នា បតិតា** សេចក្ដីថា លិចចុះក្នុងតណ្ហានិងដែលតណ្ហាគ្របសង្កត់ហើយ ។

[ ១២៧ ] បទថា **មក្កដោ** បានដល់ ស្វា ។ បទថា **អរញ្ញេ** សេចក្ដីថា ក្នុងព្រៃតូច ។ បទថា **បវនេ** សេចក្ដីថា ក្នុងព្រៃធំ ។ បទថា **ចរមានោ** សេចក្ដីថា ទៅ ។ បទថា **ឃវមេវ** ជាបទឧបមេយ្យ គ្រឿងញ៉ាំងបទឧបមាឲ្យដល់ព្រម ។ បទថា **បុថូ** សេចក្ដីថា ផ្សេងៗ ។ បទថា **បុថុទិដ្ឋិគតានិ** សេចក្ដីថា ទិដ្ឋិមានបែបផ្សេងៗ ។ បទថា **គណ្ហន្តិ ច មុញ្ចន្តិ ច** សេចក្ដីថា រមែងចាប់ដោយអំណាចនៃការកាន់យកនិងរមែងលែងដោយអំណាចនៃការលះ ។ បទថា **អាទិយន្តិ ច និរស្សជន្តិ ច** សេចក្ដីថា រមែងធ្វើនូវកន្សល់ រមែងលះបង់និងរមែងបន្សាត់ទៅនូវកន្សល់ ។

[ ១២៨ ] ការភ្ជាប់សេចក្ដីក្នុងគាថាទី ៥ មានដូចតទៅនេះថា នរជនណាដែលត្រាស់ទុកថា **ទិដ្ឋី ហិ នំ ចាវ តថា វទានំ** ព្រោះថា ទិដ្ឋិរមែងប្រាប់នូវបុគ្គលអ្នកពោលដូច្នោះនោះ[១] នរជននោះសមាទានវត្តទាំងឡាយដោយខ្លួនឯងជាដើម ។

បណ្ដាបទទាំងនោះ បទថា **សយំ** ប្រែថា ឯង ។ បទថា **សមាទាយ** សេចក្ដីថា កាន់យក ។ បទថា **វតានិ** បានដល់ វត្តទាំងឡាយ មានហត្ថីវត្ត

---

១-គាថានេះមានត្រង់ឃ្នាប ១១៤ ។

ជាដើម ។ បទថា **ឧច្ចាវចំ** សេចក្តីថា ត្រឡប់ទៅត្រឡប់មក ឬអាក្រក់និង ប្រណីត គឺចាកសាស្តាចូលកាន់សាស្តាជាដើម ។ បទថា **សញ្ញសត្តោ** សេចក្តី ថា ជាអ្នកជាប់ជំពាក់ក្នុងកាមសញ្ញាជាដើម ។ បទថា **វិទ្វា ច វេទេហិ សមេច្ច ធម្មំ** សេចក្តីថា ចំណែកបុគ្គលដែលមាននូវការដឹង គឺព្រះអរហន្តត្រាស់ដឹងនូវ សច្ចធម៌ ៤ ដែលជាបរមត្ថ ដោយការដឹង គឺមគ្គញាណ ៤ ។ បទដ៏សេស ជាក់ច្បាស់ហើយនោះឯង ។

[ ១២៩ ] បទថា **សយំ សមាទាយ** សេចក្តីថា កាន់យកឯងនោះឯង ។ បទថា **អាទាយ** សេចក្តីថា កាន់យកហើយ គឺទទួលយកហើយ ។ បទថា **សមាទាយ** សេចក្តីថា កាន់យកហើយដោយប្រពៃ ។ បទថា **អាទិយិត្វា** សេចក្តីថា ធ្វើនូវការប្រកាន់ ។ បទថា **សមាទិយិត្វា** សេចក្តីថា ធ្វើនូវការ ប្រកាន់ដោយប្រពៃ ។ បទថា **គណ្ហិត្វា** សេចក្តីថា មិនលះបង់ ។ បទថា **បរាមសិត្វា** សេចក្តីថា សម្តែងហើយ ។ បទថា **អភិនិវិសិត្វា** សេចក្តីថា តាំងមាំហើយ ។ បទថា **កាមសញ្ញាទយោ** ជាដើម មានន័យដូចពោលហើយ នោះឯង ។

[ ១៣១ ] បទថា **វិទ្វា** បានដល់ អ្នកមានបញ្ញា ។ បទថា **វិជ្ជាគតោ** សេចក្តីថា ដែលដល់នូវការដឹងច្បាស់ ។ បទថា **ញាណី** សេចក្តីថា ដល់ ព្រមដោយបញ្ញា ។ បទថា **វិភាវី** សេចក្តីថា ពិចារណាដោយញាណ ។ បទ ថា **មេធាវី** សេចក្តីថា ជាអ្នកមានញាណត្រិះរិះដោយអនិច្ចលក្ខណៈជាដើម ។ បទថា **បញ្ញា** ជាដើម មានន័យដូចពោលហើយខាងដើមនោះឯង ។

ឈ្មោះថា **ធម្មវិចយសម្ពោជ្ឈង្គោ** ព្រោះអត្ថថា ពិចារណានូវសច្ចធម៌ ៤ ។ អត្ថរបស់ពោជ្ឈង្គបានពោលទុកហើយខាងដើមនោះឯង ។ បទថា **វីមំសា** សេចក្តីថា បញ្ញាជាគ្រឿងពិចារណាសច្ចធម៌នោះឯង ។ លោកអធិប្បាយថា វីមំសា គឺការគិតនូវធម៌ ។ បទថា **វិបស្សនា** សេចក្តីថា បញ្ញាជាគ្រឿងឃើញដោយអាការៈផ្សេងៗ ដែលសម្បយុត្តដោយមគ្គនោះឯង ។ បទថា **សម្មាទិដ្ឋិ** សេចក្តីថា សម្មាទិដ្ឋិដែលល្អ ដែលបណ្ឌិតសរសើរ ដែលប្រពៃ ដែលសម្បយុត្តដោយមគ្គ ។ បទថា **តេហិ វេទេហិ** សេចក្តីថា ដោយមគ្គញាណ ៤ នោះឯង ។ បទថា **អន្តគតោ** សេចក្តីថា ដល់នូវទីបំផុតនៃជាតិ ជរានិងមរណៈ ។ បទថា **កោដិគតោ** ជាដើម មានន័យដូចពោលហើយខាងដើមនោះឯង ។ បទថា **វេទានំ វា អន្តគតោ** សេចក្តីថា ដល់នូវទីបំផុតនៃវត្ថុដែលគប្បីដឹង ។ បទថា **វេទេហិ វា អន្តគតោ** សេចក្តីថា ដល់នូវព្រះនិព្វាន ពោលគឺទីបំផុតដោយទីបំផុតជុំវិញនៃទុក្ខក្នុងវដ្តៈដោយបញ្ញា គឺមគ្គញាណ ៤ ។ បទថា **វិទិ-តត្តា** សេចក្តីថា ព្រោះភាពជាអ្នកដឹងច្បាស់ គឺព្រោះភាពជាអ្នកដឹង ។

គាថាថា **វេទានិ វិចេយ្យ កេវលានិ** ជាដើម សេចក្តីថា បុគ្គលណាធ្វើនូវការអស់កិលេសដោយវេទ គឺមគ្គញាណ ៤ ដល់ហើយ បុគ្គលនោះ ឈ្មោះថា ដល់នូវវេទដោយបរមត្ថ ។ មយ៉ាងទៀត បុគ្គលណាជ្រើសរើសនូវវេទទាំងឡាយដែលហៅថា សាស្ត្ររបស់សមណព្រាហ្មណ៍ទាំងពួង ដោយអំណាចអនិច្ចលក្ខណៈជាដើមដោយកិច្ចដោយមគ្គភាវនានោះឯង ។ ឈានកន្លងនូវវេទទាំងពួងនោះឯង ដោយការលះឆន្ទរាគៈក្នុងវេទនោះ ជាអ្នកប្រាសចាករាគៈក្នុង

វេទនាទាំងពួងដែលកើតព្រោះវេទជាបច្ច័យ ឬដែលកើតឡើងដោយប្រការដទៃព្រោះហេតុនោះ កាលទ្រង់សម្តែងអត្ថនោះ ត្រូវទូលសួរថា បុគ្គលដល់នូវវេទពោលគឺដល់នូវការសម្រេចអ្វី មិនបានត្រាស់តបថា នូវការសម្រេចនេះ ត្រាស់ថា បុគ្គលណាពិចារណាហើយនូវវេទទាំងអស់ ។បេ។ ឈ្មោះថា វេទគូបុគ្គលដូច្នេះ ។ ម្យ៉ាងទៀត ព្រោះបុគ្គលណា ជ្រើសរើសនូវវេទទាំងឡាយដោយបញ្ញាជាគ្រឿងជ្រើសរើស រមែងប្រព្រឹត្តទៅ កន្លងនូវវេទទាំងឡាយដោយការលះឆន្ទរាគៈក្នុងវេទនោះ បុគ្គលនោះដល់គឺដឹង គឺឈានកន្លងនូវវេទទាំងឡាយដែលហៅថាសាស្រ្ត បុគ្គលណា ប្រាសចាករាគៈក្នុងវេទនាទាំងឡាយ បុគ្គលនោះក៏ដល់ គឺឈានកន្លងនូវវេទទាំងឡាយ ដែលហៅថាវេទនា គឺដល់នូវវេទនាក្រៃលែង សូម្បីដូច្នោះ ក៏ឈ្មោះថា វេទគូ ព្រោះហេតុនោះ កាលទ្រង់សម្តែងសេចក្តីនោះ ក៏មិនបានត្រាស់ថា នូវការសម្រេចនេះ តែត្រាស់ថា បុគ្គលណាពិចារណាហើយនូវវេទទាំងអស់ ។បេ។ ឈ្មោះថាវេទគូបុគ្គល ដូច្នេះ ។

បទថា **សមេច្ច** សេចក្តីថា មកព្រមដោយញាណ ។ បទថា **អភិសមេច្ច** សេចក្តីថា ចាក់ធ្លុះដោយញាណ ។ បទថា **ធម្មំ** បានដល់ សច្ចធម៌ ៤ ។ បទថា **សព្វេ សង្ខារា** បានដល់ ធម៌មួយអន្លើដោយបច្ច័យទាំងពួង ។ ពិតហើយធម៌ទាំងនោះ ឈ្មោះថា សង្ខារដែលបច្ច័យតាក់តែងរមែងរួមធ្វើដោយបច្ច័យទាំងឡាយ ព្រោះហេតុនោះ ទើបឈ្មោះថា សង្ខារ ។ សង្ខារទាំងនោះលោកពោលដោយវិសេសថា **សង្ខត** ព្រោះរួមធ្វើដោយបច្ច័យទាំងឡាយ ដោយប្រការដូច្នេះ ។ ក្នុងអដ្ឋកថាទាំងឡាយពោលថា ធម៌មានរូបដែលប្រព្រឹត្តទៅ

ក្នុងភូមិ ៣ ជាដើមដែលកើតព្រោះកម្ម ឈ្មោះថា អភិសង្ខតសង្ខារ ។ អភិសង្ខតសង្ខារទាំងនោះ រមែងសង្គ្រោះចូលក្នុងសង្ខតសង្ខារទាំងឡាយ ដូចក្នុងប្រយោគថា **អនិច្ចា វត សង្ខារា** សង្ខារទាំងឡាយមិនទៀងហ្ន៎ ជាដើម សង្ខារមានអវិជ្ជាជាបច្ច័យនោះឯង មកក្នុងប្រយោគថា ម្នាលភិក្ខុទាំងឡាយ បើបុរសបុគ្គលលុះក្នុងអំណាចអវិជ្ជាហើយ រមែងតាក់តែងសង្ខារជាបុណ្យជាដើម ។ កុសលចេតនានិងអកុសលចេតនា ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា អភិសង្ខរណសង្ខារ ។ សេចក្តីព្យាយាមផ្លូវកាយនិងសេចក្តីព្យាយាមផ្លូវចិត្ត ដែលមកក្នុងប្រយោគថា ចក្រនោះដែលអ្នកបង្វិលទៅ ក៏ទៅកាន់ទីអស់កំណត់ត្រឹមតែមួយវិលប៉ុណ្ណោះ ហើយក៏តាំងនៅនឹងថ្កល់ជាដើម ឈ្មោះថា បយោគាភិសង្ខារ ( សង្ខារគឺសេចក្តីព្យាយាម ) ។ វិតក្កៈវិចារៈដែលមកក្នុងប្រយោគថា ម្នាលអាវុសោវិសាខៈ ភិក្ខុដែលចូលសញ្ញាវេទយិតនិរោធនោះ វចីសង្ខាររលត់មុន តមកទើបកាយសង្ខារ ( រលត់ ) តពីនោះមកទៀត ទើបចិត្តសង្ខារ ( រលត់ ) ជាដើម ឈ្មោះថា វចីសង្ខារ ព្រោះអត្ថថា តាក់តែងវាចា ។ ខ្យល់អស្សាសៈបស្សាសៈ ឈ្មោះថា កាយសង្ខារ ព្រោះអត្ថថា តាក់តែងកាយ ។ សញ្ញានិងវេទនា ឈ្មោះថា ចិត្តសង្ខារ ព្រោះអត្ថថា តាក់តែងចិត្ត ក្នុងទីនេះ លោកបំណងយកសង្ខតសង្ខារ ។

បទថា **អនិច្ចា** សេចក្តីថា ព្រោះអត្ថថា មានហើយត្រឡប់ជាមិនមាន ។ បទថា **ទុក្ខា** សេចក្តីថា ព្រោះអត្ថថា បៀតបៀន ។ បទថា **សព្វេ ធម្មា** សេចក្តីថា លោកពោលរួមព្រះនិព្វានទុកខាងក្នុងផងដែរ ។ បទថា **អនត្តា**

សេចក្តីថា ព្រោះអត្ថថា មិនប្រព្រឹត្តទៅក្នុងអំណាច ។ ក្នុងបទថា **អវិជ្ជា-បច្ចយា សង្ខារា** នេះ ផលអា**ស្រ័យ**ធម៌ណា **រមែងមកដល់**ធម៌នោះឈ្មោះថា ជាបច្ច័យ ។ ពាក្យថា **អាស្រ័យ** សេចក្តីថា វៀរមិនបាន អធិប្បាយថា មិនហាម ។ ពាក្យថា **រមែងមកដល់** សេចក្តីថា កើតឡើងនិងប្រព្រឹត្តទៅ ។ ម្យ៉ាងទៀត ឈ្មោះថា មានឧបការៈជាអត្ថ មានបច្ច័យជាអត្ថ ។ អវិជ្ជានោះផង ជាបច្ច័យផង ឈ្មោះថា អវិជ្ជាបច្ចយា ព្រោះហេតុនោះ ព្រោះអវិជ្ជាជាបច្ច័យ ទើបសង្ខារទាំងឡាយ**កើតឡើង** ។ ពាក្យថា **កើតឡើង** បានដល់រមែងកើតឡើងចំពោះ ។ គប្បីប្រកបសព្ទថា **កើតឡើង** ( **សម្ភវន្តិ** ) ជាមួយបទដ៏សេសទាំងឡាយ ដោយប្រការដូច្នេះ ។

បណ្តាបទទាំងនោះ អវិជ្ជាដូចម្តេច ការមិនដឹងក្នុងទុក្ខ ១ ការមិនដឹងក្នុងទុក្ខសមុទយៈ ១ ការមិនដឹងក្នុងទុក្ខនិរោធ ១ ការមិនដឹងក្នុងទុក្ខនិរោធគាមិនីបដិបទា ១ ការមិនដឹងក្នុងចំណែកខាងដើម ១ រមែងមិនដឹងក្នុងចំណែកខាងចុង ១ ការមិនដឹងក្នុងចំណែកខាងដើមនិងចំណែកខាងចុង ១ ការមិនដឹងឥទប្បច្ចយតានិងបដិច្ចសមុប្បាទ ១ ។

សង្ខារដូចម្តេច បុញ្ញាភិសង្ខារ អបុញ្ញាភិសង្ខារ អានេញ្ជាភិសង្ខារ កាយ-សង្ខារ វចីសង្ខារ ចិត្តសង្ខារ ។ កាមាវចរកុសលចេតនា ៨ រូបាវចរកុសលចេតនា ៥ ជាបុញ្ញាភិសង្ខារ ។ អកុសលចេតនា ១២ ជាអបុញ្ញាភិសង្ខារ អរូបាវចរកុសលចេតនា ៤ ជាអានេញ្ជាភិសង្ខារ ។ កាយសញ្ចេតនាជាកាយ-សង្ខារ ។ វចីសញ្ចេតនាជាវចីសង្ខារ ។ មនោសញ្ចេតនាជាចិត្តសង្ខារ ។ គប្បី

មានពាក្យសួរក្នុងបទនោះថា ឈ្មោះថា សង្ខារទាំងនេះមានអវិជ្ជាជាបច្ច័យនោះ គប្បីដឹងបានដូចម្ដេច គឺគប្បីដឹងបានដោយភាវៈក្នុងភាពជាអវិជ្ជា ។

ការមិនដឹង ពោលគឺអវិជ្ជាក្នុងធម៌ ៨ ប្រការ មានទុក្ខជាដើម ដែលបុគ្គលណាមិនទាន់លះបាន បុគ្គលនោះកាន់យកទុក្ខក្នុងសង្សារវដ្ដ ដោយសម្គាល់ថាជាសុខ ប្រារព្ធយកសង្ខារទាំង ៣ ដែលជាហេតុនៃទុក្ខនោះឯង ព្រោះការមិនដឹងក្នុងទុក្ខនិងចំណែកខាងដើមជាដើមមុន ។ បុគ្គលប្រារព្ធសង្ខារទាំងឡាយដែលជាបរិក្ខារនៃតណ្ហា ដែលជាហេតុនៃទុក្ខ សម្គាល់ថាជាហេតុនៃសុខ ព្រោះការមិនដឹងក្នុងសមុទយៈ ។

បុគ្គលជាអ្នកមានការសម្គាល់ក្នុងគតិវិសេស មិនមែនការរំលត់ទុក្ខថាជាការរំលត់ទុក្ខ ជាអ្នកមានសេចក្ដីសម្គាល់ក្នុងការបួងសួងនិងការបំពេញវត្ត ដើម្បីការមិនស្លាប់ជាដើម មិនមែនផ្លូវនៃការរំលត់ទុក្ខឡើយ ថាជាផ្លូវនៃការរំលត់ទុក្ខ កាលប្រាថ្នានូវការរំលត់ទុក្ខ រមែងប្រារព្ធសង្ខារទាំង ៣ ដោយការបួងសួងនិងការបំពេញវត្តដើម្បីការមិនស្លាប់ជាដើម ព្រោះការមិនដឹងក្នុងនិរោធនិងក្នុងមគ្គ ។

ម្យ៉ាងទៀត បុគ្គលនោះមិនដឹងទុក្ខ ពោលគឺផលបុណ្យ សូម្បីពេញទៅដោយទោសមិនមែនតិច មានជាតិ ជរានិងមរណៈជាដើមដោយវិសេសថាជាទុក្ខ ព្រោះភាពដែលមិនទាន់លះអវិជ្ជាក្នុងសច្ចៈ ៤ បាននោះ ។ រមែងប្រារព្ធបុញ្ញាភិសង្ខារប្រភេទកាយសង្ខារ វចីសង្ខារ ចិត្តសង្ខារ ដើម្បីសម្រេចផលបុណ្យនោះ ដូចបុគ្គលប្រាថ្នាជាទេវតានិងទេពអប្សរធ្វើនូវការលោតចូល

ជ្រោះដែលទេវតាអាស្រ័យនៅដូច្នោះ ។

ម្យ៉ាងទៀត បុគ្គលមិនឃើញភាពជាវិបរិណាមទុក្ខ ដែលឲ្យកើតនូវការក្តៅក្រហាយធំ ក្នុងទីបំផុតនៃផលបុណ្យនោះ ដែលសន្មតថាជាសុខ និងការមិនពេញចិត្ត រមែងប្រារព្ធបុញ្ញាភិសង្ខារដែលមានប្រការដូចពោលហើយនោះឯង ដែលជាបច្ច័យនៃទុក្ខនោះ ដូចមមាចហើរចូលអណ្តាតភ្លើងនិងដូចបុគ្គលចង់បានទឹកឃ្មុំ លិឍនូវមុខសស្ត្រាដែលលាបដោយទឹកឃ្មុំដូច្នោះ ។ ម្យ៉ាងទៀត បុគ្គលមិនឃើញទោសក្នុងការចូលទៅសេពកាមជាដើម ដែលមានវិបាករមែងប្រារព្ធបុញ្ញាភិសង្ខារដែលប្រព្រឹត្តទៅក្នុងទ្វារ ៣ ព្រោះសម្គាល់ថា ជាសុខនិងព្រោះត្រូវកិលេសគ្របសង្កត់ ដូចកូនក្មេងលេងលាមកនិងដូចមនុស្សចង់ស្លាប់បរិភោគនូវថ្នាំពុលដូច្នោះ ។ ម្យ៉ាងទៀត បុគ្គលមិនដឹងច្បាស់នូវភាពជាវិបរិណាមទុក្ខនៃសង្ខារក្នុងអរូបវិបាក រមែងប្រារព្ធអានេញ្ជាភិសង្ខារដែលជាចិត្តសង្ខារដោយវិបល្លាសថាទៀងជាដើម ដូចអ្នកវង្វេងទិសកាន់យកផ្លូវដើរឆ្ពោះទៅនគរបិសាចដូច្នោះ ។

ព្រោះមានអវិជ្ជានោះឯង ទើបមានសង្ខារ មិនមែនព្រោះមិនមាន ព្រោះហេតុនោះ គប្បីជ្រាបសេចក្តីនេះថា សង្ខារទាំងនេះរមែងមាន ព្រោះអវិជ្ជាជាបច្ច័យ ដោយប្រការដូច្នេះ ។

ក្នុងសេចក្តីនេះលោកពោលថា ពួកយើងកាន់យកអត្ថនេះមុនថា អវិជ្ជាជាបច្ច័យដល់សង្ខារទាំងឡាយ អវិជ្ជានេះតែម្យ៉ាងប៉ុណ្ណោះ ជាបច្ច័យដល់សង្ខារទាំងឡាយឬ ឬថាមានបច្ច័យដទៃៗទៀត ក្នុងរឿងនេះដូចម្តេច បើអវិជ្ជាតែ

ម្យ៉ាងជាបច្ច័យ ការពោលដល់ហេតុតែម្យ៉ាងប៉ុណ្ណោះ រមែងត្រឹមត្រូវ កាលបើដូច្នោះ សូម្បីបច្ច័យដទៃទៀតមាន ការចង្អុលបង្ហាញហេតុតែម្យ៉ាងថា សង្ខារទាំងឡាយមានអវិជ្ជាជាបច្ច័យ រមែងមិនកើតឡើងឬ មិនកើតឡើងក៏មិនមែន ព្រោះហេតុអ្វី ព្រោះថា

ក្នុងលោកនេះផលណាមួយ រមែងមានអំពីហេតុតែម្យ៉ាងក៏មិន
មែន ផលច្រើនយ៉ាងរមែងមានអំពីហេតុតែមួយក៏មិនមែន ផល
តែមួយរមែងមានអំពីហេតុច្រើនយ៉ាងក៏មិនមែន តែប្រយោជន៍
ក្នុងការសម្តែងហេតុតែម្យ៉ាងនិងផលតែម្យ៉ាងមាន ដូច្នេះ ។

ពិតហើយ ព្រះមានព្រះភាគទ្រង់សម្តែងហេតុក្តី ផលក្តី តែម្យ៉ាងប៉ុណ្ណោះ ដោយសមគួរដល់លម្អនៃទេសនានិងដល់ពួកវេនេយ្យសត្វ ព្រោះជាប្រធានក្នុងទីខ្លះ ព្រោះប្រាកដច្បាស់ក្នុងទីខ្លះ ជាអសាធារណៈក្នុងទីខ្លះ ដូច្នោះក្នុងសេចក្តីនេះ កាលហេតុនៃសង្ខារទាំងឡាយ មានវត្ថុអារម្មណ៍និងសហជាតធម៌ជាដើមដទៃ ៗ មាន អវិជ្ជានេះគប្បីជ្រាបថា ទ្រង់សម្តែងដោយភាពជាហេតុនៃសង្ខារទាំងឡាយ ព្រោះជាប្រធាន គឺជាហេតុនៃហេតុរបស់សង្ខារទាំងឡាយមានតណ្ហាជាដើមដទៃៗ តាមព្រះបាលី ( ក្នុងសំយុត្តនិកាយនិទានវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុពិចារណាឃើញនូវសេចក្តីត្រេកអរក្នុងឧបាទានិយធម៌ទាំងឡាយ ( ធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ជាបច្ច័យនៃឧបាទានទាំង ៤ ) តណ្ហារមែងចម្រើនឡើង ដូច្នេះ ។ និងព្រះតម្រាស់មួយកន្លែងទៀត ( មជ្ឈិមនិកាយមូលបណ្ណាសក ) ថា សេចក្តីកើតឡើងនៃអាសវៈ ព្រោះ

សេចក្តីកើតឡើងនៃអវិជ្ជា ដូច្នេះ ។ និងប្រាកដច្បាស់តាមព្រះបាលីថា ម្នាល ភិក្ខុទាំងឡាយ បុគ្គលអ្នកមិនមានបញ្ញា ត្រូវអវិជ្ជាគ្របសង្កត់ រមែងតាក់តែង បុញ្ញាភិសង្ខារនិងព្រោះមិនជាសាធារណៈ ។ ម្យ៉ាងទៀត គប្បីជ្រាបប្រយោជន៍ ក្នុងការសម្តែងហេតុនិងផលទីមួយៗ ក្នុងទីទាំងពួង ដោយពាក្យអធិប្បាយក្នុង ទីសម្តែងដល់ហេតុនិងផលទីមួយៗនោះឯង ។ ក្នុងសេចក្តីនេះ លោកពោល ថា កាលបើយ៉ាងនោះ ភាពដែលអវិជ្ជាមានទោស មានផលមិនគួរប្រាថ្នាដោយ ចំណែកមួយ ជាបច្ច័យនៃបុញ្ញាភិសង្ខារនិងអានេញ្ជាភិសង្ខារ នឹងត្រូវបានដូច ម្តេច ព្រោះអំពៅកើតអំពីពូជនៃស្តៅក៏មិនមែន នឹងមិនត្រូវបានដូចម្តេច ព្រោះ ក្នុងលោក

បច្ច័យនៃសភាវធម៌ទាំងឡាយដែលខុសគ្នា ( ជាមួយផល )
ក្តី មិនខុសគ្នាក្តី ដែលដូចគ្នានិងមិនដូចគ្នា ( ជាមួយផល )
ក៏ដូចគ្នា រមែងជាហេតុសម្រេច ( គឺឲ្យកើតផល ) បាន តែ
ធម៌ទាំងនោះ មិនបានជាវិបាកឡើយ ដូច្នេះ ។

ដោយប្រការដូច្នេះ អវិជ្ជានេះ មានផលមិនគួរប្រាថ្នាដោយចំណែកមួយ ដោយអំណាចនៃវិបាកនិងមានទោស ដោយអំណាចនៃសភាវៈ ក៏គប្បីជ្រាបថា ជាបច្ច័យនៃបុញ្ញាភិសង្ខារជាដើមទាំងអស់ ដោយអំណាចជាបច្ច័យដែលខុស គ្នានិងមិនខុសគ្នាដោយឋានៈ កិច្ច សភាវៈនិងដោយអំណាចជាបច្ច័យដែលដូច គ្នានិងមិនដូចគ្នាតាមសមគួរ ម្យ៉ាងទៀត នៅមានបរិយាយដទៃទៀតថា

បុគ្គលណាវង្វេងក្នុងចុតិនិងបដិសន្ធិក្នុងសង្សារវដ្ត និងក្នុង

*លក្ខណៈនៃសង្ខារទាំងឡាយនិងក្នុងធម៌ដែលអាស្រ័យគ្នានឹងគ្នាកើតឡើង បុគ្គលនោះរមែងតាក់តែងសង្ខារ ៣ យ៉ាងនោះ ព្រោះអវិជ្ជាជាបច្ច័យនៃសង្ខារទាំង ៣ នោះ ។*

*ដូចនរជនខ្វាក់អំពីកំណើត មិនមានអ្នកនាំទៅ ជួនកាលក៏ដើរត្រូវផ្លូវ ជួនកាលក៏ដើរខុសផ្លូវយ៉ាងណា បុគ្គលពាលត្រាច់ទៅក្នុងសង្សារវដ្ដ មិនមានអ្នកដឹកនាំក៏យ៉ាងនោះ ជួនកាលធ្វើបុណ្យជួនកាលក៏ធ្វើបាប ។*

*បុគ្គលនោះដឹងនូវធម៌ ហើយសម្រេចនូវសច្ចៈទាំងឡាយក្នុងកាលណា នឹងជាអ្នកចូលទៅស្ងប់ព្រោះអវិជ្ជាស្ងប់ ត្រាច់ទៅក្នុងកាលនោះ ដូច្នេះ ។*

*បទថា* **សង្ខារប្បច្ចយា វិញ្ញាណំ** *សេចក្ដីថា ពួកនៃវិញ្ញាណ ៦ គឺចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ មនោវិញ្ញាណ ។ បណ្ដាវិញ្ញាណទាំងនោះ ចក្ខុវិញ្ញាណមាន ២ យ៉ាង គឺជាកុសលវិបាក ១ ជាអកុសលវិបាក ១ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណនិងកាយវិញ្ញាណក៏ដូចគ្នា ។ ចំណែកមនោវិញ្ញាណមាន ២២ យ៉ាង គឺវិបាកមនោធាតុ ២ អហេតុកវិបាកមនោវិញ្ញាណធាតុ ៣ អហេតុកវិបាកចិត្ត ៨ រូបាវចរវិបាកចិត្ត ៥ អរូបាវចរវិបាកចិត្ត ៤ វិបាកវិញ្ញាណខាងលោកិយទាំងអស់ ៣២ ដោយប្រការដូច្នេះ ។*

*ក្នុងសេចក្ដីនោះ គប្បីមានពាក្យសួរថា ក្នុងសេចក្ដីនេះថា វិញ្ញាណដែល*

មានប្រការដូចពោលហើយនេះ មានព្រោះសង្ខារជាបច្ច័យ គប្បីដឹងបាន ដូចម្តេច គប្បីដឹងបាន ព្រោះកាលមិនមានកម្មសន្សំទុក វិបាកក៏មិនមាន ។

វិញ្ញាណនោះជាវិបាក ហើយវិបាកនិងមិនកើតឡើង កាលមិនមានកម្ម ដែលសន្សំទុក បើគប្បីកើតឡើង វិបាកទាំងពួងរបស់កម្មគ្រប់យ៉ាងគប្បីកើត ឡើងដល់សត្វគ្រប់ពួក តែវិបាកទាំងអស់រមែងមិនកើតឡើង គប្បីជ្រាបសេចក្តី នេះថា វិញ្ញាណនេះរមែងមានព្រោះសង្ខារជាបច្ច័យ ។

វិញ្ញាណទាំងអស់នោះឯង រមែងប្រព្រឹត្តទៅដោយប្រការ ២ គឺបវត្តិនិង បដិសន្ធិ ។ ក្នុង ២ ប្រការនោះ ទ្វិបញ្ចវិញ្ញាណ ១០ មនោធាតុ ២ អហេតុ-កមនោវិញ្ញាណធាតុដែលសហគតៈដោយសោមនស្ស ១ រួមជាវិញ្ញាណ ១៣ រមែងប្រព្រឹត្តទៅក្នុងបវត្តិប៉ុណ្ណោះ ក្នុងបញ្ចវោការភព វិញ្ញាណ ១៩ ដ៏សេស រមែងប្រព្រឹត្តទៅទាំងក្នុងបវត្តិទាំងក្នុងបដិសន្ធិ ក្នុងភព ៣ តាមសមគួរ ។

វិញ្ញាណនេះត្រឹមតែជាធម៌ បានបច្ច័យហើយរមែងចូលដល់
ភពដទៃ ដោយប្រការដូច្នេះ វិញ្ញាណនោះមិនមានការឃ្លាត
មកអំពីភពនោះ តែវៀរហេតុចាកភពនោះហើយរមែងមានមិន
បាន ដូច្នេះ ។

វិញ្ញាណដែលបានបច្ច័យដោយប្រការដូច្នេះហើយ នេះត្រឹមតែជារូបធម៌ និងអរូបធម៌ កាលកើតឡើង ហៅថា ចូលដល់ភពដទៃ ។ មិនមែនសត្វ មិនមែនជីវៈ ។ ម្យ៉ាងទៀត វិញ្ញាណនោះ រមែងមិនមានការឃ្លាតចាកអតីត ភពមកក្នុងលោកនេះ ទាំងវៀរហេតុចាកអតីតភពនោះចេញហើយ រមែងមិន

ប្រាកដក្នុងលោកនេះ ។

ក្នុងវិញ្ញាណនេះលោកហៅវិញ្ញាណដួងដំបូងថា ចុតិវិញ្ញាណ ព្រោះឃ្លាតទៅ ហៅវិញ្ញាណដួងក្រោយថា បដិសន្ធិវិញ្ញាណ ព្រោះបន្តខាងដើមនៃភពថ្មី ។

ក្នុងសេចក្តីនេះ មានអ្នកសួរថា កាលមានការប្រាកដដោយមិនបាន ឃ្លាតមកយ៉ាងនេះ ព្រោះខន្ធទាំងឡាយក្នុងអត្តភាពមនុស្សនេះរលត់ទៅនិង ព្រោះកម្មដែលជាបច្ច័យនៃផល មិនទៅក្នុងទីដែលកើតឡើងនៃផលនោះ ផល នោះក៏គប្បីមានដល់បុគ្គលដទៃនិងអំពីកម្មដទៃមិនមែនឬ កាលមិនមានអ្នក សោយផល ផលនោះគប្បីមានដល់បុគ្គលណាវិញ ព្រោះហេតុនោះ សេចក្តី នេះមិនត្រឹមត្រូវ ក្នុងសេចក្តីនោះខ្ញុំនឹងឆ្លើយដូចតទៅនេះថា

ផលក្នុងសន្តានមិនមែនមានដល់បុគ្គលដទៃ និងមិនមានអំពី
កម្មដទៃ ការតាក់តែងពូជទាំងឡាយជាសាធកៈក្នុងសេចក្តីនេះ
បាន ការសន្មតថា មានអ្នកសោយសម្រេចបាន ដោយ
ការកើតឡើងនៃផលនោះឯង ដូចដើមឈើដែលសន្មតគ្នាថា
ចេញផ្លែ សម្រេចបានដោយការកើតឡើងនៃផ្លែដូច្នោះ ដូច្នេះ ។

បុគ្គលណាគប្បីពោលថា កាលបើយ៉ាងនោះ សង្ខារទាំងនោះ កាលមាន គប្បីជាបច្ច័យដល់ផលឬ ឬថាមិនមាន ក៏ជាបច្ច័យដល់ផលបាន ។ បើមាន ទើបជាបច្ច័យបានសោតវិបាកនៃសង្ខារទាំងនោះគប្បីមានក្នុងបវត្តិខណៈនោះឯង បើមិនមានសង្ខារទាំងនោះ គប្បីនាំផលមកឲ្យបានជានិច្ច ទាំងមុននិងក្រោយ បវត្តិខណៈ ។ គប្បីឆ្លើយនឹងបុគ្គលនោះយ៉ាងនេះថា

សង្ខារទាំងនោះជាបច្ច័យដល់ផល ព្រោះធ្វើផលឲ្យកើតឡើង តែនឹងនាំផលមកឲ្យជានិច្ចក៏ទេ គប្បីជ្រាបកិរិយាមានការផានា ជាដើម ថាជានិទស្សនៈក្នុងសេចក្ដីនោះបាន ដូច្នេះ ។

បទថា **វិញ្ញាណប្បច្ចយា នាមរូបំ** នេះ វេទនាខន្ធ សញ្ញាខន្ធនិងសង្ខារក្ខន្ធជានាម មហាភូតរូប ៤ និងឧបាទាយរូបរបស់មហាភូតរូប ៤ ជារូប ។

ក្នុងបដិសន្ធិខណៈរបស់គព្ភសេយ្យកសត្វដែលមិនមានការរូបនិងរបស់ពួកសត្វដែលកើតក្នុងស៊ុត វត្ថុទសកៈនិងកាយទសកៈ រួមជារូប ២០ និងនាមខន្ធ ៣ រួមធម៌ទាំងនេះជា ២៣ គប្បីជ្រាបថា ឈ្មោះថា នាមរូប ដែលមានព្រោះវិញ្ញាណជាបច្ច័យ ។ បន្ថែមភាវទសកៈរបស់ពួកសត្វ ដែលមានភាវរូប ទើបរួមជាធម៌ ៣៣ ។

ក្នុងបដិសន្ធិខណៈ របស់សត្វជាន់ព្រហ្មកាយិកាទាំងឡាយ បណ្ដាពួកឱបបាតិកសត្វទាំងឡាយ ចក្ខុទសកៈ សោតទសកៈ វត្ថុទសកៈនិងជីវិតិន្ទ្រិយនវកៈ រួមជា ៣៩ រូប និងនាមខន្ធ ៣ ទៀត រួមធម៌ទាំងនេះជា ៤២ គប្បីជ្រាបថា ឈ្មោះថា នាមរូប ដែលមានព្រោះវិញ្ញាណជាបច្ច័យ ។

ចំណែកក្នុងកាមភពក្នុងបដិសន្ធិខណៈ របស់ពួកឱបបាតិកសត្វដ៏សេស ឬសំសេទជៈដែលមានភាវៈមានអាយតនៈបរិបូណ៌ ចក្ខុទសកៈ សោតទសកៈ ឃានទសកៈ ជិវ្ហាទសកៈ កាយទសកៈ វត្ថុទសកៈ ភាវទសកៈ នីមួយៗ ១០ រួមជា ៧០ និងនាមខន្ធ ៣ រួមធម៌ទាំងនេះជា ៧៣ គប្បីជ្រាបថា ឈ្មោះថា នាមរូបដែលមានព្រោះវិញ្ញាណជាបច្ច័យ នេះជាកំណត់យ៉ាងឧក្រិដ្ឋ តែកំណត់

យ៉ាងទាប គប្បីជ្រាបការតាក់តែងនាមរូបព្រោះវិញ្ញាណជាបច្ច័យ ក្នុងបដិសន្ធិដោយបន្ទួយចំនួន ដោយអំណាចនៃទសកៈដែលខ្វះនោះៗនៃនាមរូបនោះៗ ។

ចំណែកបដិសន្ធិរបស់ពួកអរូបព្រហ្មមានចំពោះនាមខន្ធ ៣ ប៉ុណ្ណោះ ក្នុងបដិសន្ធិរបស់ពួកអសញ្ញីសត្វ មានចំពោះជីវិតិន្ទ្រិយនវកៈដោយរូបប៉ុណ្ណោះឯង ។ គប្បីជ្រាបន័យក្នុងបដិសន្ធិប៉ុណ្ណោះសិន ។

ចំណែកក្នុងបវត្តិកាលសុទ្ធដ្ឋករូប ( ក្រុមរូប ៨ សុទ្ធ គឺអវិនិព្ភោគរូប ) ដែលមានឧតុជាសមុដ្ឋាន ដោយឧតុដែលប្រព្រឹត្តទៅព្រមជាមួយបដិសន្ធិចិត្ត រមែងប្រាកដឡើងក្នុងឋិតិខណៈនៃបដិសន្ធិចិត្តក្នុងទីគ្រប់អន្ទី ដែលប្រព្រឹត្តទៅនៃរូប ចាប់តាំងអំពីភវង្គចិត្តជួងទី ១ សុទ្ធដ្ឋករូបដែលមានចិត្តជាសមុដ្ឋានរមែងប្រាកដ ។ រូប ២៦ ដោយអំណាចនៃសុទ្ធដ្ឋកៈរូបដែលមានអាហារជាសមុដ្ឋាន និងដោយអំណាចនៃនវកៈទាំងពីរ ដែលមានឧតុនិងចិត្តជាសមុដ្ឋានយ៉ាងនេះ គឺសទ្ទនវកៈដែលតាំងឡើងអំពីឧតុនិងអំពីចិត្តក្នុងវេលាដែលសំឡេងប្រាកដ និងសុទ្ធដ្ឋករូបដែលមានអាហារជាសមុដ្ឋានរបស់ពួកសត្វដែលអាស្រ័យកវឡិង្កា-រាហាររស់នៅនិងរូប ៧០ ដែលមានកម្មដូចពោលហើយជាសមុដ្ឋានដែលកើតឡើង ៣ ដងក្នុងចិត្តមួយជួងៗ ទើបរួមជារូប ៩៦ និងនាមខន្ធ ៣ រួមជាធម៌ ៩៩ គប្បីជ្រាបថា ឈ្មោះថា នាមរូប ដែលមានព្រោះវិញ្ញាណជាបច្ច័យតាមសមគួរដែលនឹងកើតបាន ។ គប្បីមានពាក្យសួរក្នុងកាលដែលវិញ្ញាណជាបច្ច័យដល់នាមរូបនោះថា ពាក្យថា នាមរូប ក្នុងបដិសន្ធិរមែងមានព្រោះវិញ្ញាណជាបច្ច័យ នុ៎ះនឹងដឹងបានដូចម្តេច គប្បីឆ្លើយថា ដឹងបានដោយសូត្រនិងដោយ

យុត្តិ ។

ក្នុងសូត្រ គឺភាពដែលវេទនាជាដើម មានវិញ្ញាណជាបច្ច័យដោយចំណែកច្រើន ជាការសម្រេចបានដោយន័យជាដើមថា ពួកធម៌ប្រព្រឹត្តទៅតាមចិត្ត តែដោយយុត្តិ គឺ

ពាក្យថា វិញ្ញាណជាបច្ច័យដល់រូបដែលឃើញមិនបាន រមែងសម្រេចបានដោយរូបដែលកើតអំពីចិត្តដែលឃើញបានក្នុងលោកនេះ ដោយប្រការដូច្នេះឯង ដូច្នេះ ។

បទថា **នាមរូបប្បច្ចយា សឡាយតនំ** បានពោលទុកហើយនោះឯងក្នុងទីនេះ រូបមាន ១១ យ៉ាង គឺមហាភូតរូប ៤ វត្ថុរូប ៦ និងជីវិតិន្ទ្រិយរូប ១ ដោយពិតប្រាកដ ចំណែកអាយតនៈមាន ៦ គឺចក្ខាយតនៈ សោតាយតនៈ ឃានាយតនៈ ជីវ្ហាយតនៈ កាយាយតនៈនិងមនាយតនៈ ។ គប្បីមានពាក្យសួរក្នុងសេចក្តីនោះថាបទថា នាមរូបជាបច្ច័យដល់សឡាយតនៈនោះ នឹងដឹងបានដូចម្តេច ឆ្លើយថា ដឹងបានដោយកាលនាមរូបមាន សឡាយតនៈក៏មាន ពិតហើយអាយតនៈនោះៗ រមែងមានព្រោះនាមនិងរូបនោះៗ មាន មិនមែនដោយប្រការដទៃឡើយ ។

បទថា **សឡាយតនប្បច្ចយា ផស្សោ** សេចក្តីថា

ផស្សៈដោយសង្ខេបមាន ៦ ប៉ុណ្ណោះ មានចក្ខុសម្ផស្សជាដើម ផស្សៈទាំងនោះដោយពិស្តារមាន ៣២ ដូចវិញ្ញាណដូច្នេះ ។

*បទថា* **ផស្សប្បច្ចយា វេទនា** *សេចក្ដីថា*

*វេទនាពោលដោយទ្វារមាន ៦ ប៉ុណ្ណោះ មានចក្ខុសម្ផស្ស ជាវេទនាជាដើម វេទនាទាំងនោះ ពោលដោយប្រភេទក្នុងទីនេះ មាន ៣២ ដូច្នេះ ។*

*បទថា* **វេទនាបច្ចយា តណ្ហា** *សេចក្ដីថា*

*តណ្ហាលោកដែលសម្ដែងក្នុងទីនេះមាន ៦ ដោយប្រភេទមាន រូបតណ្ហាជាដើម ក្នុងតណ្ហាទាំងនោះ តណ្ហានីមួយៗ មាន ៣ យ៉ាង ដោយអាការៈដែលប្រព្រឹត្តទៅ ។*

*បុគ្គលមានទុក្ខរមែងប្រាថ្នាសុខ បុគ្គលមានសុខរមែងប្រាថ្នាសុខក្រៃលែង ចំណែកឧបេក្ខា លោកពោលថា ជាសុខពិត ព្រោះស្ងប់ ព្រោះហេតុនោះ ទើបវេទនាទាំង ៣ ជាបច្ច័យដល់តណ្ហា ទើបព្រះមហេសីត្រាស់ថា ព្រោះវេទនាជាបច្ច័យ ទើប មានតណ្ហា ដូច្នេះ ។*

*បទថា* **តណ្ហាបច្ចយា ឧបាទានំ** *សេចក្ដីថា ឧបាទាន ៤ គឺកាមុបាទាន ១ ទិដ្ឋុបាទាន ១ សីលព្វតុបាទាន ១ អត្តវាទុបាទាន ១ ។ ក្នុងបទថា* **ឧបាទានបច្ចយា ភវោ** *នេះ បំណងយកកម្មភព តែឧបបត្តិភព លោកពោល ដោយអំណាចនៃការលើកបទឡើងសម្ដែង ។*

*បទថា* **ភវប្បច្ចយា ជាតិ** *សេចក្ដីថា ព្រោះកម្មភពជាបច្ច័យ ទើបប្រាកដបដិសន្ធិខន្ធទាំងឡាយ ។ បើមានពាក្យសួរក្នុងសេចក្ដីនេះថា ភពជាបច្ច័យដល់*

ជាតិនោះនឹងដឹងបានដូចម្ដេច ឆ្លើយថា ដឹងបានដោយការប្រាកដផ្សេងគ្នា មានថោកទាបនិងប្រណីតជាដើម សូម្បីមានការស្មើគ្នា ដោយបច្ច័យខាងក្រៅ ។ មែនពិតការផ្សេងគ្នាមានថោកទាប និងប្រណីតជាដើម របស់ពួកសត្វដែលជាកូនភ្លោះរមែងប្រាកដ សូម្បីមានការស្មើគ្នាដោយបច្ច័យខាងក្រៅមានទឹកសុក្កៈរបស់បិតានិងឈាមរបស់មាតានិងអាហារជាដើម ឯការផ្សេងគ្នានោះ មិនមានហេតុក៏មិនមែន ព្រោះមិនមានក្នុងកាលទាំងពួងនិងដល់សត្វទាំងពួងឡើយ ។ មានហេតុដទៃចាកកម្មភពក៏មិនមែន ព្រោះមិនមានហេតុដទៃក្នុងខាងក្នុងរបស់ពួកសត្វដែលកើតក្នុងភពនោះ ហេតុនោះ ទើបឈ្មោះថា មានកម្មភពជាហេតុពិត ។ ពិតហើយ កម្មជាហេតុនៃការផ្សេងគ្នា មានថោកទាបនិងប្រណីតជាដើម របស់សត្វទាំងឡាយ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ទុក ( ក្នុងមជ្ឈិមនិកាយ ឧបរិបណ្ណាសក ) ថា កម្មតែងចែកសត្វទាំងឡាយ ដើម្បីឲ្យថោកទាបនិងខ្ពង់ខ្ពស់ ដូច្នេះ ។ ព្រោះហេតុនោះ គប្បីជ្រាបសេចក្ដីនេះថា ភពជាបច្ច័យដល់ជាតិ ដូច្នេះ ។

ក្នុងបទថា **ជាតិប្បច្ចយា ជរាមរណំ** ជាដើម មានវិនិច្ឆ័យថា ព្រោះកាលជាតិមិនមាន ជរាមរណៈនិងធម៌មានសោកៈជាដើម រមែងមិនមាន ។ តែកាលជាតិមាន ជរាមរណៈនិងធម៌មានសោកៈជាដើម ដែលទាក់ទងដោយជរាមរណៈជាដើមរបស់ជនពាល ដែលទុក្ខធម៌ពោលគឺជរាមរណៈពាល់ត្រូវហើយក្ដី ឬដែលមិនជាប់ទាក់ទងក្នុងជនពាល ដែលទុក្ខធម៌ទាំងនោះពាល់ត្រូវហើយក្ដី រមែងមាន ។ ព្រោះហេតុនោះ ព្រោះជាតិជាបច្ច័យ ទើបមានជរា-

មរណៈ ។

បទថា **សមេច្ច អភិសមេច្ច ធម្មំ** សេចក្តីថា ប្រកបដោយញាណ ចាក់ធ្លុះនូវសច្ចធម៌ ៤ ។

កាលសម្តែងការប្រព្រឹត្តទៅនៃបច្ចយាការៈ ១២ បទ យ៉ាងនេះហើយ ឥឡូវនេះដើម្បីសម្តែងការរលត់អវិជ្ជាជាដើម ដោយអំណាចនៃវិវដ្តៈ ទើបព្រះសារីបុត្តត្ថេរ ពោលពាក្យជាដើមថា **អវិជ្ជានិរោធា សង្ខារនិរោធោតិ សមេច្ច អភិសមេច្ច ធម្មំ** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អវិជ្ជានិរោធា** សេចក្តីថា ព្រោះរលត់ដូចមិនកើតឡើង គឺព្រោះរលត់ដូចប្រព្រឹត្តទៅមិនបានទៀតនៃអវិជ្ជា ។ បទថា **សង្ខារនិរោធោ** សេចក្តីថា រមែងមានការរលត់មិនកើតឡើងនៃសង្ខារទាំងឡាយ ក្នុងបទដ៏សេសទាំងឡាយក៏យ៉ាងនេះ ។

បទថា **ឥទំ ទុក្ខំ** ជាដើម ក៏មានន័យដូចពោលហើយក្នុងកាលមុននោះឯង ។ បទថា **ឥមេ ធម្មា អភិញ្ញេយ្យា** សេចក្តីថា ធម៌ដែលប្រព្រឹត្តទៅក្នុងភូមិទាំង ៣ គប្បីជ្រាបដោយអាការៈដ៏ស្អាត ដោយអំណាចឈមចុះកាន់សភាវនិងលក្ខណៈ ឬដោយសភាវៈដោយញាណដ៏ក្រៃលែង ។

បទថា **បរិញ្ញេយ្យា** សេចក្តីថា គប្បីកំណត់ដឹងទូទៅដោយអំណាចឈមចុះកាន់សាមញ្ញលក្ខណៈនិងដោយអំណាចសម្រេចកិច្ច ។

បទថា **ឥមេ ធម្មា បហាតព្វា** សេចក្តីថា ធម៌ដែលប្រព្រឹត្តទៅក្នុងចំណែកសមុទយៈទាំងនោះគប្បីលះដោយអង្គគុណនោះៗ ។ បទថា **ភាវេតព្វា** សេចក្តី

ថា គប្បីឲ្យចម្រើន ។ បទថា **សច្ឆិកាតព្វា** សេចក្តីថា គប្បីធ្វើឲ្យប្រចក្ស ។ ការធ្វើឲ្យជាក់ច្បាស់មាន ២ យ៉ាង គឺការធ្វើឲ្យជាក់ច្បាស់ដោយការបាននូវចំពោះ និងការធ្វើឲ្យជាក់ច្បាស់ដោយអារម្មណ៍ ។ បទថា **ឆន្នំ ផស្សាយតនានំ** សេចក្តីថា នៃអាយតនៈ ៦ មានចក្ខុជាដើម ។ បទថា **សមុទយញ្ច អត្ថង្គមញ្ច** សេចក្តីថា ការកើតនិងការរលត់ ។

[ ១៣២ ] បទថា **ភូរិបញ្ញោ** សេចក្តីថា បញ្ញា ឈ្មោះថា ភូរិ ព្រោះអត្ថថា ដូចផែនដី បុគ្គលប្រកបដោយបញ្ញាដូចផែនដីនោះ ឈ្មោះថា មានបញ្ញាទូលាយដូចផែនដី ។ ក្នុងបទថា **មហាបញ្ញោ** ជាដើម សេចក្តីថា ប្រកបដោយបញ្ញាធំជាដើម សេចក្តីផ្សេងគ្នានៃបុគ្គលមានបញ្ញាធំជាដើម ក្នុងបទទាំងនោះ មានន័យដូចតទៅនេះថា

បញ្ញាធំដូចម្តេច ឈ្មោះថា មហាបញ្ញា ព្រោះអត្ថថា កំណត់អត្ថធំ ។ ឈ្មោះថា បញ្ញាធំ ព្រោះអត្ថថា កំណត់នូវធម៌ធំ និរុត្តិធំ បដិភាណធំ ឈ្មោះថា បញ្ញាធំ ព្រោះអត្ថថា កំណត់សីលក្ខន្ធធំ ។ ឈ្មោះថា បញ្ញាធំ ព្រោះអត្ថថា កំណត់សមាធិក្ខន្ធ បញ្ញាខន្ធ វិមុត្តិក្ខន្ធ វិមុត្តិញាណទស្សនក្ខន្ធធំ ។ ឈ្មោះថា បញ្ញាធំ ព្រោះអត្ថថា កំណត់ឋានាឋានញ្ញាណធំ វិហារសមាបត្តិធំ អរិយសច្ចៈធំ សតិប្បដ្ឋានធំ សម្មប្បធានធំ ឥទ្ធិបាទធំ ឥន្ទ្រិយធំ ពលៈធំ ពោជ្ឈង្គធំ អរិយមគ្គធំ សាមញ្ញផលធំ អភិញ្ញាធំ និងនិព្វានដែលជាបរមត្ថធំ ។

បញ្ញាច្រើនដូចម្តេច ឈ្មោះថា បញ្ញាច្រើន ព្រោះអត្ថថា ញាណប្រព្រឹត្តទៅក្នុងខន្ធផ្សេងៗច្រើន ។ ឈ្មោះថា បញ្ញាច្រើន ព្រោះអត្ថថា ញាណប្រព្រឹត្ត

*ទៅក្នុងជាតុផ្សេងៗច្រើន ក្នុងអាយតនៈផ្សេងៗច្រើន ក្នុងបដិច្ចសមុប្បាទផ្សេងៗ ច្រើន ក្នុងការបានសុញ្ញតាផ្សេងៗច្រើន ក្នុងអត្ថផ្សេងៗច្រើន ក្នុងធម៌ ក្នុងនិរុត្តិ ក្នុងបដិភាណផ្សេងៗច្រើន ក្នុងសីលក្ខន្ធផ្សេងៗច្រើន ក្នុងសមាធិ បញ្ញា វិមុត្តិ វិមុត្តិញ្ញាណទស្សនក្ខន្ធផ្សេងៗច្រើន ក្នុងឋានាឋានញ្ញាណផ្សេងៗច្រើន ក្នុងវិហារ សមាបត្តិផ្សេងៗច្រើន ក្នុងអរិយសច្ចៈផ្សេងៗច្រើន ក្នុងសតិប្បដ្ឋានផ្សេងៗ ច្រើន ក្នុងសម្មប្បធាន ក្នុងឥទ្ធិបាទ ក្នុងឥន្ទ្រិយ ក្នុងពលៈ ក្នុងពោជ្ឈង្គៈ ក្នុង អរិយមគ្គផ្សេងៗច្រើន ក្នុងសាមញ្ញផល ក្នុងអភិញ្ញា ក្នុងនិព្វានដែលជាបរមត្ថ កន្លងនូវធម៌ដែលជាសាធារណៈដល់ជនផ្សេងៗច្រើន ។*

**ហាសប្បញ្ញា** *តើដូចម្តេច ឈ្មោះថា បញ្ញាជាគ្រឿងរីករាយ ព្រោះអត្ថថា បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកច្រើនដោយការរីករាយ ច្រើនដោយវេទ ច្រើនដោយការត្រេកអរ ច្រើនដោយបាមោជ្ជៈ ញ៉ាំងសីលឲ្យបរិបូណ៌ ញ៉ាំង ឥន្ទ្រិយសំវរៈឲ្យបរិបូណ៌ ញ៉ាំងភោជនេមត្តញ្ញុតាឲ្យបរិបូណ៌ ញ៉ាំងជាគរិយានុ- យោគ ញ៉ាំងសីលក្ខន្ធ ញ៉ាំងសមាធិក្ខន្ធ ញ៉ាំងបញ្ញាខន្ធ ញ៉ាំងវិមុត្តិក្ខន្ធ ញ៉ាំង វិមុត្តិញ្ញាណទស្សនក្ខន្ធឲ្យបរិបូណ៌ ឈ្មោះថា* **ហាសប្បញ្ញា** *ព្រោះអត្ថថា បុគ្គល ច្រើនដោយការត្រេកអរ ច្រើនដោយបាមោជ្ជៈ ចាក់ធ្លុះឋានាឋានញ្ញាណ ។ ឈ្មោះថា* **ហាសប្បញ្ញា** *ព្រោះអត្ថថា ច្រើនដោយការត្រេកអរ រមែងញ៉ាំង វិហារសមាបត្តិឲ្យបរិបូណ៌ ។ ឈ្មោះថា* **ហាសប្បញ្ញា** *ព្រោះអត្ថថា ច្រើន ដោយការត្រេកអរ ចាក់ធ្លុះនូវអរិយសច្ចៈ ព្រោះអត្ថថា ចម្រើនសតិប្បដ្ឋាន ព្រោះអត្ថថា ចម្រើនសម្មប្បធាន ឥទ្ធិបាទ ឥន្ទ្រិយ ពលៈ ពោជ្ឈង្គៈនិងអរិយ*

មគ្គ ។

ឈ្មោះថា **ហាសបញ្ញា** ព្រោះអត្ថថា ជាអ្នកច្រើនដោយការរីករាយ រមែងធ្វើឲ្យជាក់ច្បាស់នូវសាមញ្ញផល ។ ឈ្មោះថា **ហាសបញ្ញា** ព្រោះអត្ថថា ចាក់ធ្លុះនូវអភិញ្ញា ។ ឈ្មោះថា **ហាសបញ្ញា** ព្រោះអត្ថថា ជាអ្នកច្រើនដោយការរីករាយ ច្រើនដោយវេទ ការត្រេកអរ បាមោជ្ជៈ ធ្វើឲ្យជាក់ច្បាស់នូវនិព្វានដែលជាបរមត្ថ ។

**ជវនបញ្ញា** ដូចម្តេច ឈ្មោះថា បញ្ញារហ័ស ព្រោះអត្ថថា ស្ទុះទៅកាន់រូបណាមួយដែលជាអតីតៈ អនាគត បច្ចុប្បន្ន ខាងក្នុងក្តី ខាងក្រៅក្តី ឱឡារិកក្តី សុខុមក្តី ថោកទាបក្តី ប្រណីតក្តី ឆ្ងាយក្តី ជិតក្តី ទាំងអស់ដោយភាពជាអនិច្ចំ បានរហ័ស ។ ឈ្មោះថា បញ្ញារហ័ស ព្រោះអត្ថថា ស្ទុះទៅជាទុក្ខំ ជាអនត្តា បានរហ័ស ។ ឈ្មោះថា បញ្ញារហ័ស ព្រោះអត្ថថា ស្ទុះទៅកាន់វេទនា សញ្ញា សង្ខារ វិញ្ញាណណាមួយដែលជាអតីតៈ អនាគត បច្ចុប្បន្ន ។បេ។ ឆ្ងាយក្តី ជិតក្តីទាំងអស់ដោយភាពជាអនិច្ចំ ទុក្ខំ អនត្តា បានរហ័ស ។ ឈ្មោះថា បញ្ញារហ័ស ព្រោះអត្ថថា ស្ទុះទៅកាន់ចក្ខុ ។បេ។ ជរា មរណៈ ដែលជាអតីតៈ អនាគតនិងបច្ចុប្បន្នដោយជាអនិច្ចំ ទុក្ខំ អនត្តា បានរហ័ស ។

ឈ្មោះថា បញ្ញារហ័ស ព្រោះអត្ថថា ត្រិះរិះ ពិចារណា រិះគិត គឺធ្វើឲ្យជាក់ច្បាស់នូវរូបដែលជាអតីតៈ អនាគតនិងបច្ចុប្បន្ន ថាជាអនិច្ចំ ព្រោះអត្ថថា អស់ទៅ ថាជាទុក្ខំ ព្រោះអត្ថថា គួរខ្លាច ថាជាអនត្តា ព្រោះអត្ថថា មិនមានសារៈ ស្ទុះទៅក្នុងនិព្វាន ដែលជាទីរំលត់រូបបានរហ័ស ។ ឈ្មោះថា បញ្ញារហ័ស

ព្រោះអត្ថថា ត្រិះរិះ ពិចារណា រិះគិត គឺធ្វើឲ្យជាក់ច្បាស់នូវវេទនា សញ្ញា សង្ខារ វិញ្ញាណ ចក្ខុ ។បេ។ ជរានិងមរណៈដែលជាអតីតៈ អនាគតនិងបច្ចុប្បន្នថាជាអនិច្ចំ ព្រោះអត្ថថា អស់ទៅ ថាជាទុក្ខំ ព្រោះអត្ថថា គួរខ្លាច ថាជាអនត្តា ព្រោះអត្ថថា មិនមានសារៈ ហើយស្ទុះទៅក្នុងនិព្វានដែលជាទីរំលត់ជរានិងមរណៈបានរហ័ស ។

ឈ្មោះថា បញ្ញារហ័ស ព្រោះអត្ថថា ត្រិះរិះ ពិចារណា រិះគិត គឺធ្វើឲ្យជាក់ច្បាស់នូវរូបដែលជាអតីតៈ អនាគតនិងបច្ចុប្បន្ន ថាជាអនិច្ចំ ដែលបច្ច័យប្រជុំតាក់តែង អាស្រ័យគ្នានឹងគ្នាកើតឡើង មានការអស់ទៅជាធម្មតា មានការវិនាសទៅជាធម្មតា មានការប្រាសចាកតម្រេកជាធម្មតា មានការរំលត់ជាធម្មតា ហើយស្ទុះទៅក្នុងនិព្វានដែលជាទីរំលត់នូវរូបបានរហ័ស ។ ឈ្មោះថា បញ្ញារហ័ស ព្រោះអត្ថថា ត្រិះរិះ ពិចារណា រិះគិត គឺធ្វើឲ្យជាក់ច្បាស់នូវវេទនា សញ្ញា សង្ខារ វិញ្ញាណ ចក្ខុ ។បេ។ ជរានិងមរណៈដែលជាអតីតៈ អនាគតនិងបច្ចុប្បន្ន ថាជាអនិច្ចំ ។បេ។ មានការរលត់ជាធម្មតា ហើយស្ទុះទៅក្នុងនិព្វានដែលជាទីរំលត់ជរានិងមរណៈបានរហ័ស ។

**តិក្ខប្បញ្ញា** តើដូចម្ដេច ឈ្មោះថា បញ្ញាមុត ព្រោះអត្ថថា កាត់កិលេសទាំងឡាយបានរហ័ស ។ ឈ្មោះថា បញ្ញាមុត ព្រោះអត្ថថា ញុំាងកាមវិតក្កដែលកើតឡើង ព្យាបាទវិតក្កដែលកើតឡើង វិហិង្សាវិតក្កដែលកើតឡើង បាបអកុសលធម៌ទាំងឡាយដែលកើតឡើង រាគៈដែលកើតឡើង ទោសៈ មោហៈ សេចក្ដីក្រោធ ការចងក្រោធ ការលុបគុណ ការវាយឫកស្មើ ការច្រណែន ការ

កំណាញ់ មាយា អួតអាង មុខរឹង ប្រណាំងវាសនា ប្រកាន់ខ្លួន មើលងាយអ្នកដទៃ ការស្រវឹង សេចក្តីប្រមាទដែលកើតឡើង កិលេសទាំងពួង ទុច្ចរិតទាំងពួង អភិសង្ខារទាំងពួង កម្មជាគ្រឿងទៅកាន់ភពទាំងពួង គឺលះ បន្ទោបង់ធ្វើឲ្យសាបសូន្យ ឲ្យដល់នូវការមិនមានក្នុងកាលជាខាងក្រោយ ។ ឈ្មោះថាបញ្ញាមុត ព្រោះអត្ថថា ជាបញ្ញាគ្រឿងចាក់ធ្លុះ គឺធ្វើឲ្យជាក់ច្បាស់ ពាល់ត្រូវនូវអរិយមគ្គ ៤ សាមញ្ញផល ៤ បដិសម្ភិទា ៤ និងអភិញ្ញា ៦ បានក្នុងអាសនៈ ១ ។

**និព្វេធិកបញ្ញា** តើដូចម្តេច ឈ្មោះថា បញ្ញាជាគ្រឿងទម្លាយបង់ ព្រោះអត្ថថា បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកច្រើនដោយការភ្ញាក់ផ្អើល ច្រើនដោយការតក់ស្លុត ច្រើនដោយការអផ្សុក ច្រើនដោយការមិនត្រេកអរ ច្រើនដោយការមិនត្រេកអរក្រៃលែង បែរមុខមិនត្រេកអរក្នុងសង្ខារទាំងពួង រមែងចាក់ធ្លុះ រមែងទម្លាយនូវគំនរលោភៈដែលមិនធ្លាប់ចាក់ធ្លុះ មិនធ្លាប់ទម្លាយក្នុងសង្ខារទាំងពួង ។ ឈ្មោះថា បញ្ញាជាគ្រឿងទម្លាយបង់ ព្រោះអត្ថថា ជាគ្រឿងចាក់ធ្លុះ ជាគ្រឿងទម្លាយនូវគំនរទោសៈ គំនរមោហៈ សេចក្តីក្រោធ ការចងក្រោធ ។បេ។ កម្មជាគ្រឿងទៅកាន់ភពទាំងពួង ដែលមិនធ្លាប់ចាក់ធ្លុះ មិនធ្លាប់ទម្លាយ ។

[ ១៣៣ ] បទថា **ស សព្វធម្មេហិ វិសេនិភូតោ យង្កិញ្ចិ ទិដ្ឋំវ សុតំ មុតំ វា** សេចក្តីថា អ្នកមានបញ្ញាទូលាយដូចផែនដីនោះ គឺព្រះខីណាស្រព ឈ្មោះថា ជាអ្នកកម្ចាត់សេនា ព្រោះជាអ្នកញុំាងសេនាមារក្នុងធម៌ទាំងពួងនោះ ដែល

ជារូបដែលឃើញ សំឡេងដែលបានឮ ឬអារម្មណ៍ដែលជ្រាបណាមួយឲ្យវិនាសហើយតាំងនៅ ។ បទថា **តមេវ ទស្សឹ** សេចក្តីថា នូវបុគ្គលនោះឯងដែលឃើញនូវការបរិសុទ្ធ ។ បទថា **វិវដំ ចរន្តំ** សេចក្តីថា ប្រព្រឹត្ត បើកផ្ទារព្រោះប្រាសចាកគ្រឿងបិទបាំង គឺតណ្ហាជាដើម ។ បទថា **កេនីធ លោកស្មិំ វិកប្បយេយ្យ** សេចក្តីថា បុគ្គលណាមួយក្នុងលោក នេះគប្បីកំណត់ដោយកិលេសណាមួយ គឺដោយការកំណត់ដោយតណ្ហា ឬដោយការកំណត់ដោយទិដ្ឋិ ឬដោយកិលេសដែលពោលហើយក្នុងកាលមុន មានរាគៈជាដើម ព្រោះលះកិលេសទាំងនោះបានហើយ ។

[ ១៣៤ ] ក្នុងគាថា ៤ ថា **កាមា តេ បឋមា សេនា** ជាដើម មានអត្ថដូចតទៅនេះថា ព្រោះកិលេសកាមទាំងឡាយ ធ្វើពួកសត្វដែលគ្រប់គ្រងផ្ទះឲ្យវង្វេងក្នុងវត្ថុកាមទាំងឡាយ តាំងអំពីខាងដើម កាលសត្វទាំងនោះគ្របសង្កត់កិលេសកាមបានហើយ ចូលដល់ភាពជាបព្វជិត ការមិនត្រេកអរក្នុងសេនាសនៈដែលស្ងាត់ឬក្នុងធម៌ ដែលជាអធិកុសលដទៃៗ រមែងកើតឡើងសមដូចព្រះសារីបុត្តត្ថេរពោលទុក ( ក្នុងសំយុត្តនិកាយសឡាយតនវគ្គ ) ថាម្នាលអាវុសោ សេចក្តីត្រេកអរ ( មិនអផ្សុកក្នុងបព្វជ្ជានេះឯង ) ដែលបព្វជិតធ្វើបានដោយកម្រ ដូច្នេះ ។ បន្ទាប់អំពីនោះ ការឃ្លាននិងការស្រេក រមែងបៀតបៀនបព្វជិតទាំងនោះ ព្រោះមានជីវិតទាក់ទងដោយអ្នកដទៃ កាលត្រូវការឃ្លាននិងការស្រេកបៀតបៀន តណ្ហាក្នុងការស្វែងរករមែងធ្វើចិត្តឲ្យលំបាក ។ លំដាប់នោះ ការរួញរានិងការងោកងុយ រមែងបៀតបៀនបុគ្គលអ្នកមានចិត្ត

លំបាកទាំងនោះ ។ បន្ទាប់អំពីនោះ ការខ្វាចដែលហៅថា ការតក់ស្លុត រមែង កើតដល់បុគ្គលដែលមិនទាន់សម្រេចគុណវិសេស ដែលនៅក្នុងសេនាសនៈព្រៃ ដែលសង្កត់ចិត្តបានលំបាក ។ កាលបុគ្គលទាំងនោះមិនទុកចិត្តមានចិត្តវង្វេង ធ្វើចិត្តឲ្យត្រេកអរក្នុងសេនៃវិវេកមិនបានអស់កាលយូរ រមែងកើតសេចក្ដីសង្ស័យក្នុងបរិយត្តិថា នេះគប្បីជាមគ្គឬហ្ន៎ កាលបន្ទោបង់សេចក្ដីសង្ស័យនោះបាន ការប្រកាន់ខ្លួន ការលុបគុណ ការមុខរឹងរមែងកើត ព្រោះសម្រេចគុណវិសេស មានប្រមាណតិច កាលបន្ទោបង់នូវការប្រកាន់ខ្លួន ការលុបគុណនិងមុខរឹងទាំងនោះបានហើយតាំងនៅ លាភសក្ការៈនិងការសរសើររមែងកើតឡើង ព្រោះអាស្រ័យការសម្រេចគុណវិសេស ដែលក្រៃលែងជាងនោះ បុគ្គលដែលលិចលង់ក្នុងលាភជាដើម ប្រកាសនូវធម្មបដិរូប បានទទួលយសដែលបានដោយផ្លូវខុស ហើយតាំងនៅក្នុងយសនោះ រមែងលើកខ្លួនសង្កត់សង្កិនអ្នកដទៃដោយជាតិជាដើម ដូច្នោះ គប្បីជ្រាបភាពដែលកិលេសទាំងឡាយមានកាមជាដើម ជាសេនាទី ១ ជាដើម ( ដោយប្រការដូច្នេះ ) ។

ព្រះមានព្រះភាគ កាលទ្រង់សម្ដែងសេនា ១០ យ៉ាងនេះ យ៉ាងនេះហើយ កាលទ្រង់ចង្អុលបង្ហាញថា សេនារបស់អ្នកព្រោះភាពជាអ្នកប្រកបដោយធម៌ខ្មៅនោះ រមែងប្រព្រឹត្តទៅដើម្បីឧបការៈដល់នមុចិមារដែលមានធម៌ខ្មៅទើបត្រាស់ថា **ឯសា នមុចិ តេ សេនា កណ្ហស្សាភិប្បហារិណី** ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អភិប្បហារិណី** សេចក្ដីថា ជាអ្នកសម្លាប់ គឺញាំញី ធ្វើអន្តរាយដល់សមណព្រាហ្មណ៍ទាំងឡាយ ។ បទថា **ន នំ អសូរោ**

**ជិនាតិ ជេត្វា ច លភតេ សុខំ** សេចក្តីថា បុគ្គលជាអ្នកខ្លាច គឺបុគ្គលដែលឃើញតែកាយនិងជីវិត រមែងឈ្នះសេនាមារយ៉ាងនេះមិនបាន តែបុគ្គលអ្នកក្លាហាន រមែងឈ្នះបាន កាលឈ្នះហើយ រមែងបានសុខ កើតអំពីមគ្គនិងសុខកើតអំពីផល ។

បទថា **យតោ ចតូហិ អរិយមគ្គេហិ** សេចក្តីថា ដោយមគ្គ ៤ ពោលគឺគ្រឿងដល់នូវព្រះនិព្វាន ដែលមិនមានទោសក្នុងកាលណា ។ បទថា **មារសេនា** សេចក្តីថា កងទ័ពរបស់មារដែលធ្វើតាមបញ្ជា បានដល់ កិលេស ។

បទថា **បដិសេនិករា** សេចក្តីថា ធ្វើនូវភាពជាបដិបក្ខ ។ បទថា **ជិតា ច** សេចក្តីថា ឲ្យដល់នូវបរាជ័យ ។ បទថា **បរាជិតា ច** សេចក្តីថា សង្កត់សង្កិនបានហើយ ។ បទថា **ភគ្គា** បានដល់ បំផ្លាញ ។ បទថា **វិប្បលុត្តា** សេចក្តីថា ធ្វើឲ្យបែកល្អិត ។ បទថា **បរម្មុខា** សេចក្តីថា ឲ្យដល់នូវការគេចមុខ ។ បទថា **វិសេនិភូតោ** សេចក្តីថា ជាអ្នកនៅប្រាសចាកកិលេសតាំងនៅ ។

[ ១៣៥ ] បទថា **វោទានទស្សី** បានដល់ ដែលឃើញនូវវោទានធម៌ គឺធម៌ដែលផូរផង់ក្រៃលែង ។ បទថា **តានិ ឆទនានិ** សេចក្តីថា គ្រឿង បិទបាំង គឺកិលេសមានតណ្ហាជាដើមនេះ ។ បទថា **វិវដានិ** សេចក្តីថា ធ្វើឲ្យប្រាកដ ។ បទថា **វិទ្ធំសិតានិ** សេចក្តីថា នាំចេញទៅចាកឋានដែលតាំងនៅ ។ បទថា **ឧគ្ឃាដិតានិ** បានដល់ កើចកន្ទ្រាក់ ។ បទថា **សមុគ្ឃាដិតានិ** សេចក្តីថា កើចកន្ទ្រាក់ដកឡើងជាពិសេស ។

[ ១៣៧ ] គាថាថា **ន កប្បយន្តិ** ជាដើម មានការភ្ជាប់សេចក្តីនិងអត្ថដូចតទៅនេះថា នឹងពោលដោយក្រៃលែង សប្បុរសទាំងនោះ គឺបែបនោះរមែងមិនកំណត់ដោយការកំណត់ ២ យ៉ាងណាមួយ និងរមែងមិនធ្វើតណ្ហានិងទិដ្ឋិទុកខាងមុខដោយការធ្វើទុកខាងមុខ ២ យ៉ាង ណាមួយ សប្បុរសទាំងនោះ រមែងមិនពោលអកិរិយទិដ្ឋិនិងសស្សតទិដ្ឋិ ដែលមិនមែនការបរិសុទ្ធដល់ទីបំផុតឡើយ ថាជាការបរិសុទ្ធដល់ទីបំផុត ព្រោះជាបុគ្គលសម្រេចនូវការបរិសុទ្ធដល់ទីបំផុតដែលជាបរមត្ថ ។

បទថា **អាទានគន្ថំ គថិតំ វិសជ្ជ** សេចក្តីថា លះគឺកាត់នូវគន្ថៈជាគ្រឿងចង ៤ យ៉ាង ព្រោះជាអ្នកប្រកាន់មាំនូវធម៌ មានរូបជាដើម គឺដែលជាប់ជំពាក់ក្នុងចិត្តរបស់ខ្លួនដោយសស្ត្រាគឺអរិយមគ្គ ។ បទដ៏សេសប្រាកដជាក់ច្បាស់ហើយនោះឯង ។

[ ១៣៨ ] បទថា **អច្ចន្តសុទ្ធី** បានដល់ ការបរិសុទ្ធដល់ទីបំផុត គឺយ៉ាងក្រៃលែង ។ បទថា **សំសារសុទ្ធី** សេចក្តីថា ការបរិសុទ្ធឯងដោយការអន្ទោលទៅក្នុងសង្សារវដ្ត ។ បទថា **អកិរិយទិដ្ឋី** សេចក្តីថា ឈ្មោះថា **អកិរិយទិដ្ឋី** ព្រោះអត្ថថា យល់ឃើញថា កាលបុគ្គលធ្វើបាប ឈ្មោះថា មិនជាការធ្វើ ។ បទថា **សស្សតវាទំ** សេចក្តីថា មិនពោល គឺមិនពោលថាទៀង ឋិតថេរបន្តរឿយៗទៅ ។

[ ១៤០ ] បទថា **គន្តា** សេចក្តីថា ឈ្មោះថា **គន្តា** ព្រោះអត្ថថា ចងនាមកាយ គឺបន្តក្នុងវដ្តៈ ដោយអំណាចចុតិនិងបដិសន្ធិ ។ អភិជ្ឈានោះផង ជា

*គ្រឿងចងផង ដោយអំណាចនៃការបន្តនាមកាយផង ព្រោះហេតុនោះ ទើបឈ្មោះថា អភិជ្ឈាកាយគន្ថ ។ ឈ្មោះថា* **ព្យាបាទោ** *ព្រោះអត្ថថា ញុំាងប្រយោជន៍និងសេចក្ដីសុខឲ្យដល់នូវសេចក្ដីវិនាស ។ ព្យាបាទៈនោះផង ជាគ្រឿងចងដោយន័យដែលពោលហើយនោះផង ព្រោះហេតុនោះ ទើបឈ្មោះថា ព្យាបាទកាយគន្ថ ។ បទថា* **សីលព្វតបរាមាសោ** *សេចក្ដីថា ការស្ទាបអង្អែលដោយប្រការដទៃ គឺការបរិសុទ្ធដោយសីល ការបរិសុទ្ធដោយវត្តរបស់សមណព្រាហ្មណ៍ក្រៅសាសនានេះ ។ បទថា* **ឥទំសច្ចាភិនិវេសោ** *សេចក្ដីថា ការហាមសព្វញ្ញុតញ្ញាណ... ការហាមសូម្បីភាសិតរបស់ព្រះសព្វញ្ញូចេញហើយ ប្រកាន់ដោយអាការៈយ៉ាងនេះថា លោកទៀង វត្ថុនេះប៉ុណ្ណោះពិត វត្ថុដទៃមិនពិត ឈ្មោះថា ឥទំ-សច្ចាភិនិវេស ។ បទថា* **អត្តនោ ទិដ្ឋិយា រាគោ** *សេចក្ដីថា ឆន្ទរាគៈដោយទិដ្ឋិដែលខ្លួនប្រកាន់មាំ កាន់យក ។ បទថា* **បរវាទេសុ អាឃាតោ** *សេចក្ដីថា សេចក្ដីក្រោធ ព្រោះពាក្យរបស់អ្នកដទៃ ។ បទថា* **អប្បច្ចយោ** *បានដល់ អាការៈដែលមិនត្រេកអរ ។ បទថា* **អត្តនោ សីលំ វា** *សេចក្ដីថា សីល មានគោសីលជាដើម ដែលខ្លួនសមាទានហើយក្ដី ។ បទថា* **អត្តនោ ទិដ្ឋិ** *សេចក្ដីថា ទិដ្ឋិដែលខ្លួនប្រកាន់គឺស្ទាបអង្អែល ។ បទថា* **តេហិ គន្ថេហិ** *សេចក្ដីថា ដោយកិលេសជាគ្រឿងបន្តនាមកាយដែលពោលហើយទាំងនេះ ។ បទថា* **រូបំ អាទិយន្តិ** *សេចក្ដីថា រមែងប្រកាន់ គឺចាប់នូវរូបារម្មណ៍ដែលមានសមុដ្ឋាន ៤ ។ បទថា* **ឧបាទិយន្តិ** *សេចក្ដីថា ចូលទៅចាប់ ។ ចាប់ដោយតណ្ហា ប្រកាន់ដោយទិដ្ឋិ ប្រកាន់មាំដោយមានៈ ។ បទថា* **វដ្ដំ** *សេចក្ដីថា វដ្ដៈ*

ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។ បទថា **គន្ថេ** សេចក្តីថា កិលេសជាគ្រឿងចង ។

បទថា **ពោសជ្ជិត្វា** សេចក្តីថា លះដោយប្រពៃ ។ បទថា **គថិតេ** សេចក្តីថា កិលេសជាគ្រឿងចង ។ បទថា **គន្ថិតេ** សេចក្តីថា ដែលចងដោយកិលេសដែលជាគ្រឿងចង ។ បទថា **វិពន្ធេ** សេចក្តីថា ដែលចងជាពិសេស ។ បទថា **អាពន្ធេ** សេចក្តីថា ដែលចងច្រើនយ៉ាង ។ បទថា **បលិពុទ្ធេ** សេចក្តីថា កិលេសជាគ្រឿងចងដែលផុតមិនបាន ។ បទថា **ផោដយិត្វា** សេចក្តីថា ទម្លាយនូវចំណង គឺតណ្ហា មានះនិងទិដ្ឋិ ។ បទថា **វិសជ្ជ** បានដល់ លះបង់ ។

ការនាំកិលេសជាគ្រឿងចង ៤ យ៉ាងនេះ មកតាមលំដាប់កិលេសក្តី តាមលំដាប់មគ្គក្តី រមែងគួរ ។ ពោលតាមលំដាប់កិលេស **អភិជ្ឈាកាយគន្ថ** លះបានដោយអរហត្តមគ្គ **ព្យាបាទកាយគន្ថ** លះបានដោយអនាគាមិមគ្គ **សីល-ព្វតបរាមាសកាយគន្ថ** និង **ឥទំសច្ចាភិនិវេសកាយគន្ថ** លះបានដោយសោតាបត្តិមគ្គ ។ ពោលតាមលំដាប់មគ្គ **សីលព្វតបរាមាសកាយគន្ថ** និង **ឥទំសច្ចាភិនិវេសកាយគន្ថ** លះបានដោយសោតាបត្តិមគ្គ ។ **ព្យាបាទកា-យគន្ថ** លះបានដោយអនាគាមិមគ្គ **អភិជ្ឈាកាយគន្ថ** លះបានដោយអរហត្តមគ្គដូច្នេះ ។ គន្ថៈ ៤ យ៉ាងនេះ មានដល់បុគ្គលណា រមែងចង គឺបន្តបុគ្គលនោះទុកក្នុងវដ្តៈ ដោយអំណាចចុតិនិងបដិសន្ធិ ហេតុនោះ ទើបឈ្មោះថា កិលេសជាគ្រឿងចង ។ កិលេសជាគ្រឿងចងទាំងនោះមាន ៤ ប្រភេទ សត្វទាំងឡាយរមែងសម្ងំដោយអភិជ្ឈានោះ គឺដោយអភិជ្ឈាឯង សម្ងំក្តី អភិជ្ឈានេះត្រឹម

*តែជាការសម្ងឹងប៉ុណ្ណោះក្តី ហេតុនោះ ទើបឈ្មោះថា អភិជ្ឈា គឺលោភៈនោះឯង ។ ឈ្មោះថា* **កាយគន្ថ** *ព្រោះអត្ថថា ចងនាមកាយ គឺបន្តទុកក្នុងវដ្តៈ ដោយអំណាចចុតិនិងបដិសន្ធិ ។*

*ឈ្មោះថា* **ព្យាបាទ** *ព្រោះអត្ថថា ជាគ្រឿងដែលចិត្ត ដល់នូវការវិនាស គឺដល់នូវភាពជាចិត្តខូច ឬធ្វើអាចារៈ គឺវិន័យ រូបសម្បត្តិ ប្រយោជន៍និងសេចក្តីសុខជាដើម ឲ្យដល់នូវសេចក្តីវិនាស ។*

*ការស្ទាបអង្អែល គឺការបរិសុទ្ធដោយសីល ការបរិសុទ្ធដោយវត្តរបស់ពួកសមណព្រាហ្មណ៍ក្រៅសាសនានេះ ឈ្មោះថា សីលព្វតបរាមាសៈ ។ ឈ្មោះថា* **ឥទំសច្ចាភិនិវេស** *ព្រោះអត្ថថា ហាមសូម្បីភាសិតរបស់ព្រះសព្វញ្ញូចេញហើយប្រកាន់មាំដោយអាការៈជាដើមថា លោកទៀង វត្ថុនេះប៉ុណ្ណោះពិត វត្ថុដទៃមិនពិត ។*

*ព្រះសារីបុត្តត្ថេរ កាលនឹងសម្តែងវត្ថុដែលតាក់តែង មានវីជាដើម ជាគ្រឿងប្រៀបធៀប ក្នុងការញែកកិលេសដែលជាគ្រឿងចងទាំងឡាយ ទើបពោលពាក្យជាដើមថា* **យថា វីយ្ហំ វា** *ដូច្នេះ ។*

[ ១៤១ ] *បទថា* **ន ជនេន្តិ** *សេចក្តីថា មិនឲ្យកើតឡើង ។ បទថា* **ន សញ្ជនេន្តិ** *សេចក្តីថា មិនឲ្យកើតព្រម ។ លោកពង្រីកបទថា* **នាភិនិព្វត្តេន្តិ** *ដោយឧបសគ្គ ។ បទថា* **ន សញ្ជនេន្តិ** *លោកពោលសំដៅដល់លក្ខណៈដែលកើតឡើង គឺមិនធ្វើឲ្យកើតឡើង ។ បទថា* **នាភិនិព្វត្តេន្តិ** *លោកពោលសំដៅដល់លក្ខណៈដែលប្រព្រឹត្តទៅ ។*

[ ១៨២ ] ព្រះអរហន្ត ឈ្មោះថា **សីមាតិគោ** ព្រោះកន្លងនូវដែន គឺកិលេស ៤ និងឈ្មោះថា **ព្រាហ្មណោ** ព្រោះបន្សាត់បាបហើយ ម្យ៉ាងទៀត ព្រះអរហន្តនោះជាបុគ្គលយ៉ាងនេះ ដឹងដោយបរចិត្តញ្ញាណនិងបុព្វេនិវាសញ្ញាណ ឬឃើញដោយមំសចក្ខុនិងទិព្វចក្ខុ ទើបមិនមាននូវការប្រកាន់ណាមួយ លោកអធិប្បាយថា តាំងមាំ ។ ម្យ៉ាងទៀត ព្រះអរហន្តនោះឈ្មោះថា **ន រាគរាគី** ព្រោះមិនមានកាមរាគៈ ។ ឈ្មោះថា **ន វិរាគរត្តោ** ព្រោះមិនមានរូបរាគៈនិងអរូបរាគៈ ។ ព្រោះព្រះអរហន្តនោះយ៉ាងនេះ ទើបមិនមានការប្រកាន់ណាមួយក្នុងលោកនេះថា វត្ថុនេះជាកំពូល ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគទ្រង់បញ្ចប់ទេសនាដោយកំពូល គឺអរហត្ត ។

[ ១៨៣ ] បទថា **ចតស្សោ សីមាយោ** សេចក្តីថា ដែនកំណត់ ៤ យ៉ាង ។ បទថា **ទិដ្ឋានុសយោ** សេចក្តីថា ទិដ្ឋិនោះផង ជាអនុស័យផង ព្រោះអត្ថថាមិនទាន់លះបានផង ព្រោះហេតុនោះ ទើបឈ្មោះថា **ទិដ្ឋានុសយោ** ។ ក្នុងបទថា **វិចិកិច្ឆានុសយោ** ជាដើមក៏មានន័យនេះឯង ។ ឈ្មោះថា អនុស័យ ព្រោះអត្ថដូចម្តេច ឆ្លើយថា ព្រោះអត្ថថា ដេកត្រាំ ។ សួរថា ឈ្មោះថា មានអត្ថថាដេកត្រាំនេះដូចម្តេច ឆ្លើយថា មានអត្ថថា លះមិនទាន់បាន ព្រោះកិលេសទាំងនេះ ឈ្មោះថា ដេកត្រាំរឿយៗក្នុងរបស់សត្វនោះៗ ព្រោះអត្ថថា មិនទាន់លះបាន ព្រោះហេតុនោះ ទើបហៅថា អនុស័យ ។

ពាក្យថា រមែងដេកត្រាំ សេចក្តីថា បាននូវហេតុដែលសមគួរ រមែងកើតឡើង បើមានពាក្យសួរថា អាការៈដែលមិនទាន់លះបាន ឈ្មោះថា មានអត្ត

ថា ដេកត្រាំ ក៏មិនគួរពោលអាការៈដែលលះមិនទាន់បានថា រមែងកើតឡើង ព្រោះហេតុនោះ ទើបអនុស័យទាំងឡាយមិនកើតឡើង ក្នុងសេចក្ដីនោះ មានពាក្យឆ្លើយដូច្នេះថា អាការៈដែលមិនទាន់លះបាន មិនមែនអនុស័យ តែកិលេសដែលមានកម្លាំង លោកហៅថា អនុស័យ ព្រោះអត្ថថា មិនទាន់លះបាន អនុស័យដែលសម្បយុត្តជាមួយចិត្ត ប្រព្រឹត្តទៅដោយអារម្មណ៍ជាធម៌មានហេតុ ដោយអត្ថថា ទៅជាមួយបច្ច័យ ជាអកុសលដោយចំណែកមួយ ជាអតីតៈខ្លះ ជាអនាគតខ្លះ ជាបច្ចុប្បន្នខ្លះ ព្រោះហេតុនោះ ទើបគួរពោលថា កើតឡើងនេះជាប្រមាណ ក្នុងសេចក្ដីនេះ ។

ក្នុងអភិសមយកថា គម្ពីរបដិសម្ភិទាមគ្គ លោកសួរថា បុគ្គលរមែងលះកិលេសដែលកើតឡើងចំពោះមុខបានដូចម្ដេច ដូច្នេះហើយពោលថា បុគ្គលមានកម្លាំង រមែងលះអនុស័យបាន ព្រោះអនុស័យទាំងឡាយ មានភាពជាបច្ចុប្បន្ន ។ ក្នុងការចែកបទនៃមោហៈ គម្ពីរធម្មសង្គណី លោកពោលភាពដែលមោហៈកើតឡើងជាមួយអកុសលចិត្តថា អនុស័យ គឺអវិជ្ជា សេចក្ដីគ្របសង្កត់ គឺអវិជ្ជា គន្លឹះគឺអវិជ្ជា គឺមោហៈ ជាអកុសលមូលណា ក្នុងសម័យនោះ នេះមោហៈកើតមានក្នុងសម័យនោះ ដូច្នេះ ។

ក្នុងគម្ពីរកថាវត្ថុ លោកបដិសេធវាទៈទាំងអស់ថា **អនុសយា អព្យាកតា អនុសយា អហេតុកា អនុសយា ចិត្តវិប្បយុត្តា** អនុស័យជាអព្យាក្រឹត អនុស័យមិនមានហេតុ អនុស័យប្រាសចាកចិត្ត ដូច្នេះ ។ ក្នុងឧប្បជ្ជនវារៈ កន្លែងខ្លះនៃមហាវារៈ ៧ ក្នុងអនុសយយមកៈ លោកពោលពាក្យជាដើមថា

**យស្ស កាមរាគានុសយោ ឧប្បជ្ជតិ តស្ស បដិឃានុសយោ ឧប្បជ្ជតិ** *កាមរាគានុស័យរបស់បុគ្គលណាកើតឡើង បដិឃានុស័យរបស់បុគ្គលនោះកើតឡើង ដូច្នេះ ។ ព្រោះហេតុនោះ ពាក្យដែលលោកពោលថា ពាក្យថា រមែងដេកត្រាំ សេចក្តីថា បាននូវហេតុដែលសមគួរ រមែងកើតឡើងនោះ គប្បីជ្រាបថា លោកពោលល្អហើយដោយប្រមាណដែលជាបែបផែននេះ ។*

*ពាក្យដែលលោកពោលហើយថា សម្បយុត្តជាមួយចិត្តប្រព្រឹត្តទៅជាមួយអារម្មណ៍ជាដើម នុ៎ះជាការដែលលោកពោលល្អហើយនោះឯង ។ ក្នុងសេចក្តីនេះ គប្បីសម្រេចចិត្តថា ឈ្មោះថា អនុស័យនេះសម្រេចគ្រប់គ្រាន់ហើយ ជាអកុសលធម៌ដែលសម្បយុត្តជាមួយចិត្ត ។*

*បណ្តាអនុស័យទាំងនោះ ទិដ្ឋានុស័យ លោកពោលទុកក្នុងចិត្តដែលសម្បយុត្តដោយទិដ្ឋិ ៤ ។*

*វិចិកិច្ឆានុស័យ ពោលទុកក្នុងចិត្តដែលសហគតៈដោយវិចិកិច្ឆា ។ អវិជ្ជានុស័យ ពោលទុកក្នុងអកុសលចិត្ត ១២ ដោយអំណាចនៃសហជាតធម៌និងដោយអំណាចនៃអារម្មណ៍ ។*

*ទិដ្ឋិ វិចិកិច្ឆានិងមោហៈទាំង ៣ ពោលទុកក្នុងធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដ៏សេសដោយអំណាចនៃអារម្មណ៍ ។*

*ក្នុងទីនេះ កាមរាគានុស័យ លោកពោលទុកក្នុងចិត្តដែលសហគតៈដោយលោភៈទាំងឡាយដោយអំណាចនៃសហជាតធម៌ និងដោយអំណាចនៃអារម្មណ៍ ។ លោភៈដែលកើតឡើង ពោលទុកក្នុងធម៌ដែលជាកាមាវចរៈដ៏សេសដែល*

*ជាទីពេញចិត្តដោយអំណាចនៃអារម្មណ៍នោះឯង ។ បដិឃានុស័យ ពោលទុកក្នុងចិត្តដែលសហគតៈដោយទោមនស្ស ដោយអំណាចនៃសហជាតធម៌និងដោយអំណាចនៃអារម្មណ៍ ។*

*ទោសៈដែលកើតឡើង ពោលទុកក្នុងធម៌ដែលជាកាមាវចរៈដ៏សេស ដែលមិនជាទីគាប់ចិត្តដោយអំណាចនៃអារម្មណ៍នោះឯង ។ មានុស័យពោលទុកក្នុងចិត្តដែលសហគតៈដោយលោភៈប្រាសចាកទិដ្ឋិ ដោយអំណាចនៃសហជាតធម៌និងដោយអំណាចនៃអារម្មណ៍ ។*

*មានៈដែលកើតឡើង ពោលទុកក្នុងធម៌ដែលជាកាមាវចរៈដ៏សេសនិងក្នុងធម៌ជារូបាវចរៈនិងអរូបាវចរៈ ដែលវៀរចាកទុក្ខវេទនា ដោយអំណាចនៃអារម្មណ៍នោះឯង ។ ភវរាគានុស័យកាលកើតឡើង ក៏ពោលទុកក្នុងចិត្តដែលវិប្បយុត្តដោយទិដ្ឋិ ៤ ដោយអំណាចនៃសហជាតធម៌ តែលោភៈដែលកើតឡើង ពោលទុកក្នុងធម៌ជារូបាវចរៈនិងអរូបាវចរ ដោយអំណាចនៃអារម្មណ៍នោះឯង ។*

*បណ្ដាបទទាំងនោះ បទថា* **ទិដ្ឋានុសយោ** *បានដល់ ទិដ្ឋិ ៦២ ។ បទថា* **វិចិកិច្ឆានុសយោ** *បានដល់ វិចិកិច្ឆាមានវត្ថុ ៨ ។ បទថា* **ឯកេកដ្ឋា ច កិលេសា** *សេចក្ដីថា តាំងនៅដោយភាពតែមួយ ដោយអំណាចកើតរួមគ្នានិងតាំងនៅជាមួយគ្នានឹងទិដ្ឋិនិងវិចិកិច្ឆាដោយអំណាចកើតរួមគ្នា តាំងនៅកន្លែងជាមួយគ្នា ។*

*បទថា* **មានានុសយោ** *បានដល់ មានៈ ៩ ។ បទថា* **បរចិត្ត-**

**ញ្ញាណេន វា ញត្វា** សេចក្តីថា ដឹងដោយបញ្ញា ជាគ្រឿងដឹងវារៈចិត្តរបស់អ្នកដទៃ លោកអធិប្បាយថា ដឹងដោយចេតោបរិយញ្ញាណ ។ បទថា **បុព្វេនិវាសានុស្សតិញ្ញាណេន វា** សេចក្តីថា ដឹងដោយញាណជាគ្រឿងរឭកដល់ខន្ធ ដែលធ្លាប់នៅអាស្រ័យក្នុងអតីតៈ ។ បទថា **មំសចក្ខុនា វា** បានដល់ ដោយចក្ខុប្រក្រតី ។ បទថា **ទិព្វចក្ខុនា វា** សេចក្តីថា ឃើញដោយទិព្វចក្ខុដែលដូចគ្នានឹងទិព្វ ឬអាស្រ័យទិព្វវិហារ ។

[ ១៨៤ ] បទថា **រាគរត្តា** សេចក្តីថា ត្រេកអរដោយរាគៈ ។ បទថា **យេ បញ្ចសុ កាមគុណេសុ** សេចក្តីថា ជនណាតម្រេកក្នុងចំណែក គឺវត្ថុកាមមានរូបជាដើម ៥ យ៉ាង ។ បទថា **វិរាគរត្តា** សេចក្តីថា តម្រេកក្រៃលែង គឺចុះស៊ប់ក្នុងរូបសមាបត្តិនិងអរូបសមាបត្តិ ពោលគឺវិរាគៈ ។ បទថា **យតោ កាមរាគោ ច** សេចក្តីថា ក្នុងកាលណាកាមរាគៈ ។ សូម្បីក្នុងរូបរាគនិងអរូបរាគ ក៏ន័យនេះឯង ។

## អដ្ឋកថា សុទ្ធដ្ឋកសុត្តនិទ្ទេសទី ៤ ចប់

# បរមដ្ឋកសុត្តនិទ្ទេស ទី ៥

[ ១៤៦ ] ( ព្រះមានព្រះភាគត្រាស់ថា ) សត្វក្នុងលោក កាលត្រាំក្នុងទិដ្ឋិទាំងឡាយ ( របស់ខ្លួន ) ថាក្រៃលែង រមែងធ្វើនូវរបស់ណាឲ្យលើសលុប ក៏ពោលនូវរបស់ទាំងអស់ ដទៃ ( អំពីរបស់ខ្លួន ) នោះថា ថោកទាប ព្រោះហេតុនោះ សត្វមិនកន្លងវិវាទទាំងឡាយបានទេ ។

[ ១៤៧ ] ពាក្យថា កាលត្រាំក្នុងទិដ្ឋិទាំងឡាយ ( របស់ខ្លួន ) ថា ក្រៃ-លែង អធិប្បាយថា សមណព្រាហ្មណ៍ពួកខ្លះ ប្រកបដោយទិដ្ឋិ សមណព្រាហ្មណ៍ទាំងនោះ ប្រកាន់ រៀនយក ក្ដួចកាន់ ស្ទាបអង្អែល ប្រកាន់ស្អិត បណ្ដាទិដ្ឋិទាំង ៦២ នូវទិដ្ឋិណាមួយថា នេះក្រៃលែង ជាកំពូល ប្រសើរ ប្រសើរវិសេស ជាប្រធាន ឧត្តម ប្រសើរក្រៃលែង ហើយនៅ នៅរួម នៅគ្រប់គ្រង នៅត្រាំក្នុងទិដ្ឋិរបស់ខ្លួនៗ ។ ពួកអ្នកម្ចាស់ផ្ទះ តែងនៅក្នុងផ្ទះ ពួកអ្នកត្រូវអាបត្តិ តែងនៅក្នុងអាបត្តិទាំងឡាយ ឬពួកអ្នកមានកិលេស នៅក្នុងកិលេសទាំងឡាយ យ៉ាងណា មានសមណព្រាហ្មណ៍ពួកខ្លះ ជាអ្នកប្រកបក្នុងទិដ្ឋិ សមណព្រាហ្មណ៍ទាំងនោះ ប្រកាន់ រៀនយក ក្ដួចកាន់ ស្ទាបអង្អែល ប្រកាន់ស្អិត បណ្ដាទិដ្ឋិទាំង ៦២ នូវទិដ្ឋិណាមួយថា នេះក្រៃលែង ជាកំពូល ប្រសើរ ប្រសើរវិសេស ជាប្រធាន ឧត្តម ប្រសើរក្រៃលែង ហើយនៅ នៅរួម នៅគ្រប់គ្រង នៅត្រាំក្នុងទិដ្ឋិរបស់ខ្លួនៗ ក៏យ៉ាងនោះដែរ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ត្រាំក្នុងទិដ្ឋិទាំងឡាយ ( របស់ខ្លួន ) ថា ក្រៃលែង ។

[ ១៤៨ ] អធិប្បាយពាក្យថា សត្វក្នុងលោករមែងធ្វើនូវរបស់ណាឲ្យលើសលុប ត្រង់ពាក្យថា របស់ណា គឺរបស់ណាមួយ ។ ពាក្យថា ធ្វើឲ្យ

លើសលុប គឺធ្វើឲ្យក្រៃលែង ធ្វើឲ្យជាកំពូល ឲ្យប្រសើរ ឲ្យប្រសើរវិសេស ឲ្យជាប្រធាន ឲ្យឧត្តម ឲ្យប្រសើរក្រៃលែង ។ ធ្វើឲ្យលើសលុប ធ្វើឲ្យជាកំពូល ឲ្យប្រសើរ ឲ្យប្រសើរវិសេស ឲ្យជាប្រធាន ឲ្យឧត្តម ឲ្យប្រសើរក្រៃលែងថា សាស្តានេះជាសព្វញ្ញូ ធ្វើឲ្យលើសលុប ធ្វើឲ្យជាកំពូល ឲ្យប្រសើរ ឲ្យប្រសើរវិសេស ឲ្យជាប្រធាន ឲ្យឧត្តម ឲ្យប្រសើរក្រៃលែង ឲ្យកើត ឲ្យកើតចំពោះថា ធម៌នេះ លោកសម្តែងល្អហើយ ពួកនេះប្រតិបត្តិល្អហើយ ទិដ្ឋិនេះល្អ បដិបទានេះលោកបញ្ញត្តល្អហើយ អ្នកនេះជាទីស្រោចស្រង់សត្វ ។ ពាក្យថា សត្វ គឺសត្វ នរជន ។បេ។ សត្វកើតអំពីមនុស្ស ។ ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក ។បេ។ ក្នុងអាយតនលោក ហេតុនោះ ( ទ្រង់ត្រាស់ថា ) សត្វក្នុងលោក រមែងធ្វើនូវរបស់ណាឲ្យលើសលុប ។

[ ១៤៩ ] ពាក្យថា ពោលនូវរបស់ទាំងអស់ ដទៃ ( អំពីរបស់ខ្លួន ) នោះថា ថោកទាប សេចក្តីថា បុគ្គលលើកតម្កើងសាស្តា ធម៌ដែលសាស្តាសម្តែង គណៈ ទិដ្ឋិ បដិបទា មគ្គរបស់ខ្លួន ហើយបោះ លើកបោះ បោះបោលនូវវាទៈដទៃទាំងអស់ គឺពោលយ៉ាងនេះ សម្តែងយ៉ាងនេះ ពណ៌នាយ៉ាងនេះ បំភ្លឺយ៉ាងនេះ ថ្លែងយ៉ាងនេះថា សាស្តានោះ មិនមែនជាសព្វញ្ញូទេ ធម៌មិនមែនសម្តែងដោយប្រពៃទេ គណៈប្រតិបត្តិមិនប្រពៃទេ ទិដ្ឋិមិនល្អទេ បដិបទាមិនមែនបញ្ញត្តល្អទេ មគ្គមិនមែនស្រោចស្រង់សត្វទេ សេចក្តីស្អាត ឬសេចក្តីស្អាតវិសេស សេចក្តីបរិសុទ្ធ ការរួច រួចវិសេស ឬរួចស្រឡះ មិនមានក្នុងធម៌នុ៎ះទេ ពួកជនមិនមែនស្អាត ស្អាតវិសេស បរិសុទ្ធិ រួច រួចវិសេស ឬរួច

ស្រឡះ ព្រោះធម៌នោះទេ បុគ្គលនោះជាអ្នកថោកទាប ថោកទាបពេក ទន់ទាប លាមកអាក្រក់ ជាមនុស្សកម្សត់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ពោលនូវរបស់ទាំងអស់ដទៃ ( អំពីរបស់ខ្លួន ) នោះថា ថោកទាប ។

[ ១៥០ ] ពាក្យថា ព្រោះហេតុនោះ សត្វមិនកន្លងវិវាទទាំងឡាយបានទេ គឺព្រោះដំណើរនោះ ការណ៍នោះ ហេតុនោះ បច្ច័យនោះ និទាននោះ សត្វមិនកន្លង មិនកន្លងផុត មិនកន្លងហួសនូវការឈ្លោះ ព្រោះទិដ្ឋិទាំងឡាយ ការជជែក ព្រោះទិដ្ឋិទាំងឡាយ សេចក្តីប្រកួតប្រកាន់ ព្រោះទិដ្ឋិទាំងឡាយ ការទាស់ទែង ព្រោះទិដ្ឋិទាំងឡាយ ការបៀតបៀនព្រោះទិដ្ឋិទាំងឡាយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ព្រោះហេតុនោះ សត្វមិនកន្លងវិវាទទាំងឡាយបានទេ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

សត្វក្នុងលោកត្រាំក្នុងទិដ្ឋិទាំងឡាយ ( របស់ខ្លួន ) ថា ក្រៃលែង រមែងធ្វើនូវរបស់ណាឲ្យលើសលុប ក៏ពោលនូវរបស់ទាំងអស់ ដទៃ ( អំពីរបស់ខ្លួន ) នោះថា ថោកទាប ព្រោះហេតុនោះ សត្វមិនកន្លងវិវាទទាំងឡាយបានទេ ។

[ ១៥១ ] បុគ្គលឃើញអានិសង្សណា ចំពោះខ្លួនក្នុងអារម្មណ៍ ដែលឃើញ ដែលឮ ដែលប៉ះពាល់ហើយ ឬក្នុងសីលនិងវត្ត បុគ្គលនោះ ក៏ប្រកាន់អានិសង្សនោះក្នុងទិដ្ឋិនោះ រមែងយល់ឃើញសភាពដទៃទាំងអស់ថា ថោកទាប ដូច្នេះ ។

[ ១៥២ ] អធិប្បាយពាក្យថា បុគ្គលឃើញអានិសង្សណាចំពោះខ្លួនក្នុង

អារម្មណ៍ដែលឃើញ ដែលឮ ដែលប៉ះពាល់ហើយ ឬក្នុងសីលនិងវត្ត ត្រង់ពាក្យថា អានិសង្សណាចំពោះខ្លួន គឺអានិសង្សណាមួយចំពោះខ្លួន ។ ទិដ្ឋិលោកហៅថា ខ្លួន ។ បុគ្គលឃើញអានិសង្សនៃទិដ្ឋិរបស់ខ្លួន ២ យ៉ាង គឺ ទិដ្ឋធម្មិកានិសង្ស ១ សម្បរាយិកានិសង្ស ១ ។

ទិដ្ឋធម្មិកានិសង្សនៃទិដ្ឋិ តើដូចម្តេច ។ គ្រូជាអ្នកប្រកបដោយទិដ្ឋិណា ពួកសាវកក៏ជាអ្នកប្រកបដោយទិដ្ឋិនោះ ពួកសាវកធ្វើសក្ការៈ គោរព រាប់អាន បូជា ធ្វើការកោតក្រែងនូវគ្រូដែលប្រកបដោយទិដ្ឋិនោះ ហើយបាននូវចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ ព្រោះហេតុតែគ្រូនោះ នេះឈ្មោះថា ទិដ្ឋធម្មិកានិសង្សនៃទិដ្ឋិ ។

សម្បរាយិកានិសង្សនៃទិដ្ឋិ តើដូចម្តេច ។ បុគ្គលជាអ្នកប្រាថ្នាផល ក្នុងអនាគតថា ទិដ្ឋិនេះ គួរដើម្បីបានជានាគ ជាគ្រុឌ ជាយក្ខ ជាអសុរ ជាគន្ធព្វ ជាមហារាជ ជាឥន្ទ្រ ជាព្រហ្ម ឬជាទេវតា ទិដ្ឋិនេះ គួរដើម្បីការស្អាត ស្អាតវិសេស បរិសុទ្ធិ រួច រួចវិសេស រួចស្រឡះ ពួកសត្វរមែងស្អាត ស្អាតវិសេស បរិសុទ្ធិ រួច រួចវិសេស រួចស្រឡះដោយទិដ្ឋិនេះ អាត្មាអញនឹងស្អាត ស្អាតវិសេស បរិសុទ្ធិ រួច រួចវិសេស រួចស្រឡះដោយទិដ្ឋិនេះ ។ នេះសម្បរាយិកានិសង្សនៃទិដ្ឋិ ។ បុគ្គលឃើញអានិសង្ស ២ យ៉ាងនេះឯង នៃទិដ្ឋិរបស់ខ្លួន ។

បុគ្គលឃើញអានិសង្ស ២ យ៉ាង នៃទិដ្ឋិសុទ្ធិផង ឃើញអានិសង្ស ២ យ៉ាង នៃសុតសុទ្ធិផង ឃើញអានិសង្ស ២ យ៉ាង នៃសីលសុទ្ធិផង ឃើញ

អានិសង្ស ២ យ៉ាង នៃវត្តសុទ្ធិផង ឃើញអានិសង្ស ២ យ៉ាង នៃមុតសុទ្ធិផង ដែលជាទិដ្ឋធម្មិកានិសង្សនិងសម្បរាយិកានិសង្ស ។

ទិដ្ឋធម្មិកានិសង្ស នៃមុតសុទ្ធិ តើដូចម្ដេច ។ គ្រូប្រកបក្នុងទិដ្ឋិណា ពួកសាវកក៏ប្រកបក្នុងទិដ្ឋិនោះ ។បេ។ នេះទិដ្ឋធម្មិកានិសង្សនៃមុតសុទ្ធិ ។

សម្បរាយិកានិសង្សនៃមុតសុទ្ធិ តើដូចម្ដេច ។ ទិដ្ឋិនេះ គួរដើម្បីបានជានាគ ។បេ។ នេះសម្បរាយិកានិសង្សនៃមុតសុទ្ធិ ។ បុគ្គលឃើញ មើលរមិលមើល សម្ពឹងមើល ពិចារណាឃើញនូវអានិសង្ស ២ យ៉ាងនេះឯង នៃមុតសុទ្ធិ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ឃើញអានិសង្សណាចំពោះខ្លួន ក្នុងអារម្មណ៍ដែលឃើញ ដែលឮ ដែលប៉ះពាល់ហើយ ឬក្នុងសីលនិងវត្ត ។

[ ១៥៣ ] ពាក្យថា បុគ្គលនោះក៏ប្រកាន់អានិសង្សនោះ ក្នុងទិដ្ឋិនោះ គឺត្រង់ពាក្យថា នោះ គឺទិដ្ឋិនោះ ។ ពាក្យថា ក្នុងទិដ្ឋិនោះ គឺក្នុងទិដ្ឋិរបស់ខ្លួន ក្នុងការគួររបស់ខ្លួន ក្នុងសេចក្ដីពេញចិត្តរបស់ខ្លួន ក្នុងលទ្ធិរបស់ខ្លួន ។ ពាក្យថាប្រកាន់ គឺប្រកាន់ តម្កើង កួចកាន់ ស្ទាបអង្អែល ប្រកាន់ស្អិតថា នេះក្រៃលែងជាកំពូល ប្រសើរ ប្រសើរវិសេស ជាប្រធាន ឧត្តម ប្រសើរ ក្រៃលែង ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលនោះ ក៏ប្រកាន់អានិសង្សនោះ ក្នុងទិដ្ឋិនោះ ។

[ ១៥៤ ] ពាក្យថា រមែងយល់ឃើញសភាពដទៃទាំងអស់ថា ថោកទាប គឺឃើញ មើល រមិលមើល សម្ពឹងមើល ពិចារណាមើលនូវគ្រូដទៃ ធម៌ដែលគ្រូនោះសម្ដែងហើយ គណៈ ទិដ្ឋិ បដិបទា មគ្គ ថាថោកទាប ថោកទាបពេក

ទន់ទាប លាមក អាក្រក់ តិចតួច ហេតុនោះ ( ទ្រង់ត្រាស់ថា ) រមែង យល់ឃើញសភាពដទៃទាំងអស់ថា ថោកទាប ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

បុគ្គលឃើញអានិសង្សណាចំពោះខ្លួន ក្នុងអារម្មណ៍ដែល
ឃើញ ដែលឮ ដែលប៉ះពាល់ហើយ ឬក្នុងសីលនិងវត្ត បុគ្គល
នោះ ក៏ប្រកាន់អានិសង្សនោះ ក្នុងទិដ្ឋិនោះ រមែងយល់ឃើញ
សភាពដទៃទាំងអស់ថា ថោកទាប ។

[ ១៥៥ ] បុគ្គលអាស្រ័យសភាពណាហើយ តែងឃើញ
សភាពដទៃថា ថោកទាប ពួកជនអ្នកឆ្លាសតែងពោលការ
ឃើញនោះ ថាជាគ្រឿងជាប់ចំពាក់ ព្រោះហេតុនោះ ភិក្ខុមិន
ត្រូវអាស្រ័យអារម្មណ៍ដែលឃើញ ដែលឮ ដែលប៉ះពាល់
ហើយ ឬសីលនិងវត្តឡើយ ដូច្នេះ ។

[ ១៥៦ ] អធិប្បាយពាក្យថា ពួកជនអ្នកឈ្លាស តែងពោលការឃើញ នោះ ថាជាគ្រឿងជាប់ចំពាក់ ត្រង់ពាក្យថា ពួកជនអ្នកឈ្លាស បានដល់ពួក ជនអ្នកឈ្លាសក្នុងខន្ធ អ្នកឈ្លាសក្នុងធាតុ អ្នកឈ្លាសក្នុងអាយតនៈ អ្នក ឈ្លាសក្នុងបដិច្ចសមុប្បាទ អ្នកឈ្លាសក្នុងសតិប្បដ្ឋាន អ្នកឈ្លាសក្នុងសម្មប្ប- ធាន អ្នកឈ្លាសក្នុងឥទ្ធិបាទ អ្នកឈ្លាសក្នុងឥន្ទ្រិយ អ្នកឈ្លាសក្នុងពល អ្នក ឈ្លាសក្នុងពោជ្ឈង្គ អ្នកឈ្លាសក្នុងមគ្គ អ្នកឈ្លាសក្នុងផល អ្នកឈ្លាសក្នុង ព្រះនិព្វាន ពួកជនអ្នកឈ្លាសទាំងនោះ តែងពោលយ៉ាងនេះ គឺតែងពោល

យ៉ាងនេះ និយាយយ៉ាងនេះ ពណ៌នាយ៉ាងនេះ បំភ្លឺយ៉ាងនេះ ថ្លែងយ៉ាងនេះថា នុ៎ះជាគ្រឿងជាប់ចំពាក់ នុ៎ះជាគ្រឿងជាប់ស្អិត នុ៎ះជាគ្រឿងចង នុ៎ះជាគ្រឿងកង្វល់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ពួកជនអ្នកឈ្លាស តែងពោលការឃើញនោះ ថាជាគ្រឿងជាប់ចំពាក់ ។

[ ១៥៧ ] អធិប្បាយពាក្យថា បុគ្គលអាស្រ័យសភាពណាហើយ តែងឃើញសភាពដទៃថា ថោកទាប ត្រង់ពាក្យថា បុគ្គលអាស្រ័យសភាពណាហើយ គឺអាស្រ័យ អាស្រ័យព្រម ជាប់ស្អិត ចូលទៅរក ជឿស៊ប់ ជឿជាក់នូវគ្រូណា ធម៌ដែលគ្រូនោះសម្តែងហើយ គណៈ ទិដ្ឋិ បដិបទា មគ្គ ។ ពាក្យថា តែងឃើញសភាពដទៃ ថាថោកទាប គឺឃើញ មើល រមិលមើល សម្លឹងមើល ពិចារណាមើលនូវគ្រូដទៃ ធម៌ដែលគ្រូនោះសម្តែងហើយ គណៈ ទិដ្ឋិ បដិបទា មគ្គ ថាថោកទាប ថោកទាបពេក ទន់ទាប លាមក អាក្រក់ តិចតួច ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលអាស្រ័យសភាពណា ហើយតែងឃើញសភាពដទៃ ថាថោកទាប ។

[ ១៥៨ ] ពាក្យថា ព្រោះហេតុនោះ ភិក្ខុមិនត្រូវអាស្រ័យអារម្មណ៍ដែលឃើញ ដែលឮ ដែលប៉ះពាល់ហើយ ឬសីលនិងវត្តឡើយ គឺព្រោះដំណើរនោះ ព្រោះការណ៍នោះ ព្រោះហេតុនោះ ព្រោះបច្ច័យនោះ ព្រោះនិទាននោះ ភិក្ខុមិនត្រូវអាស្រ័យ មិនត្រូវប្រកាន់ មិនត្រូវស្ទាបអង្អែល មិនត្រូវចុះចិត្តស៊ប់នូវទិដ្ឋៈ ឬទិដ្ឋសុទ្ធិ សុតៈ ឬសុតសុទ្ធិ មុតៈ ឬមុតសុទ្ធិ សីល ឬសីលសុទ្ធិ វត្ត ឬវត្តសុទ្ធិទេ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ព្រោះហេតុនោះ ភិក្ខុ

មិនត្រូវអាស្រ័យអារម្មណ៍ដែលឃើញ ដែលឮ ដែលប៉ះពាល់ហើយ ឬសីល និងវត្តឡើយ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

បុគ្គលអាស្រ័យសភាពណាហើយ តែងឃើញសភាពដទៃថា ថោកទាប ពួកជនអ្នកឈ្លាស តែងពោលការឃើញនោះ ថា ជាគ្រឿងជាប់ចំពាក់ ព្រោះហេតុនោះ ភិក្ខុមិនត្រូវអាស្រ័យ អារម្មណ៍ដែលឃើញ ដែលឮ ដែលប៉ះពាល់ហើយ ឬសីល និងវត្តឡើយ ។

[ ១៥៩ ] បុគ្គលមិនគប្បីតែងតាំងទិដ្ឋិក្នុងលោកដោយ ញាណ ឬដោយសីលវត្ត មិនគប្បីប្រៀបផ្ទឹមខ្លួនថា ស្មើ ( នឹង បុគ្គលដទៃ ) មិនគប្បីសំគាល់ថា ថោកទាប ឬថាវិសេស ឡើយ ដូច្នេះ ។

[ ១៦០ ] ពាក្យថា បុគ្គលមិនគប្បីតែងតាំងទិដ្ឋិក្នុងលោកដោយញាណ ឬដោយសីលវត្ត គឺមិនគប្បីតែងតាំង មិនគប្បីបង្កើត មិនគប្បីបង្កើតព្រម មិនគប្បីឲ្យកើត មិនគប្បីឲ្យកើតចំពោះនូវទិដ្ឋិ ដោយអដ្ឋសមាបត្តិញ្ញាណ ដោយបញ្ចាភិញ្ញាញាណ ដោយមិច្ឆាញាណ ដោយសីល ដោយវត្ត ឬដោយសីលវត្ត ។ ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក មនុស្សលោក ទេវលោក ខន្ធលោក ធាតុលោក អាយតនលោក ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនគប្បីតែងតាំងទិដ្ឋិក្នុងលោក ដោយញាណ ឬដោយសីលវត្ត ។

[ ១៦១ ] ពាក្យថា មិនគប្បីប្រៀបផ្ទឹមខ្លួនថា ស្មើ គឺមិនគប្បីប្រៀបផ្ទឹម

ខ្លួនថា អាត្មាអញជាអ្នកស្មើនឹងគេ ដោយជាតិ ដោយគោត្ត ដោយភាពនៃខ្លួនជាកូនអ្នកមានត្រកូល ដោយភាពនៃខ្លួនជាអ្នកមានសម្បុរល្អ ដោយទ្រព្យ ដោយការរៀនមន្ត ដោយកន្លែងធ្វើទូវការងារ ដោយកន្លែងរៀនសិប្បៈ ដោយកន្លែងនៃវិជ្ជា ដោយពហុស្សូត ដោយបដិភាណ ឬដោយវត្ថុណាមួយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនគប្បីប្រៀបផ្ទឹមខ្លួនថាស្មើ ។

[ ១៦២ ] ពាក្យថា មិនគប្បីសំគាល់ថា ថោកទាប ឬវិសេស គឺមិនគប្បីប្រៀបផ្ទឹមខ្លួនថា អាត្មាអញជាអ្នកថោកទាបដោយជាតិ ដោយគោត្ត ។បេ។ ឬដោយវត្ថុណាមួយ មិនគប្បីប្រៀបផ្ទឹមខ្លួនថា អាត្មាអញជាអ្នកប្រសើរដោយជាតិ ដោយគោត្ត ។បេ។ ឬដោយវត្ថុណាមួយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនគប្បីសំគាល់ថា ថោកទាប ឬវិសេស ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

បុគ្គលមិនគប្បីតែងតាំងទិដ្ឋិក្នុងលោកដោយញាណ ឬដោយ
សីលវត្ត មិនគប្បីប្រៀបផ្ទឹមខ្លួនថា ស្មើ ( នឹងបុគ្គលដទៃ )
មិនគប្បីសំគាល់ថា ថោកទាប ឬវិសេសឡើយ ។

[ ១៦៣ ] បុគ្គលនោះ លះបង់អត្តា មិនប្រកាន់ មិនធ្វើ
និស្ស័យ សូម្បីក្នុងញាណទេ កាលសត្វយល់បែកគ្នាផ្សេងៗ
បុគ្គលនោះឯង ជាអ្នកមិនលុះតាមពួកបុគ្គលនោះ មិនត្រឡប់
មកកាន់ ទិដ្ឋិណាមួយឡើយ ដូច្នេះ ។

[ ១៦៤ ] អធិប្បាយពាក្យថា លះបង់អត្តា មិនប្រកាន់ ត្រង់ពាក្យថា លះ

បង់អត្តា គឺលះបង់អត្តទិដ្ឋិ ។ ពាក្យថា លះបង់អត្តា គឺលះបង់សេចក្តីប្រកាន់ ។ ពាក្យថា លះបង់អត្តា គឺលះបង់ បន្សាត់បង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាននូវសេចក្តីប្រកាន់ ការស្ទាបអង្អែល សេចក្តីប្រកាន់ស្អិត ការជ្រុលជ្រប់ ការឱនទៅដោយអំណាចតណ្ហា ដោយអំណាចទិដ្ឋិ ។ ពាក្យថា លះបង់អត្តា មិនប្រកាន់ គឺមិនប្រកាន់ មិនកាន់យក មិនស្ទាបអង្អែល មិនប្រកាន់ស្អិតដោយឧបាទាន ៤ ហេតុនោះ ( ទ្រង់ត្រាស់ថា ) លះបង់អត្តា មិនប្រកាន់ ។

[ ១៦៥ ] ពាក្យថា បុគ្គលនោះ មិនធ្វើនិស្ស័យសូម្បីក្នុងញាណទេ គឺមិនធ្វើ មិនបង្កើត មិនបង្កើតព្រម មិនឲ្យកើត មិនឲ្យកើតចំពោះនូវតណ្ហានិស្ស័យ ឬទិដ្ឋិនិស្ស័យក្នុងអដ្ឋសមាបត្តិញាណ ក្នុងបញ្ចាភិញ្ញាញាណ ឬក្នុងមិច្ឆាញាណ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលនោះ មិនធ្វើនិស្ស័យក្នុងញាណ ។

[ ១៦៦ ] ពាក្យថា កាលសត្វយល់បែកគ្នាផ្សេងៗ បុគ្គលនោះឯងជាអ្នកមិនលុះតាមពួក ឬកាលពួកសត្វ អ្នកកំណត់ហើយ បែកគ្នាហើយ បែកចិត្តជា ២ កើតទៅជា ២ ពួក ប្រកបដោយទិដ្ឋិផ្សេងៗ ប្រកបដោយការគួរផ្សេងៗ ប្រកបដោយសេចក្តីពេញចិត្តផ្សេងៗ ប្រកបដោយលទ្ធិផ្សេងៗ អាស្រ័យទិដ្ឋិ-និស្ស័យផ្សេងៗ កាលលុះនូវឆន្ទាគតិ លុះនូវទោសាគតិ លុះនូវមោហាគតិ លុះនូវភយាគតិ បុគ្គលនោះ មិនលុះនូវឆន្ទាគតិ មិនលុះនូវទោសាគតិ មិនលុះនូវមោហាគតិ មិនលុះនូវភយាគតិ មិនលុះដោយអំណាចរាគ មិនលុះដោយអំណាចទោសៈ មិនលុះដោយអំណាចមោហៈ មិនលុះដោយអំណាចមានះ មិន

លុះដោយអំណាចទិដ្ឋិ មិនលុះដោយអំណាចឧទ្ធច្ចៈ មិនលុះដោយអំណាចវិចិកិច្ឆា មិនលុះដោយអំណាចអនុស័យ គឺធម៌ជាពួកទាំងឡាយនាំទៅ នាំយកទៅ បន្សាត់ទៅ ដឹកនាំទៅមិនបាន ហេតុនោះ ( ទ្រង់ត្រាស់ថា ) កាលសត្វយល់បែកគ្នាផ្សេងៗ បុគ្គលនោះឯង មិនលុះតាមពួក ។

[ ១៦៧ ] ពាក្យថា បុគ្គលនោះ មិនត្រឡប់មកកាន់ទិដ្ឋិណាមួយឡើយ គឺទិដ្ឋិ ៦២ បុគ្គលនោះលះបង់ហើយ ផ្តាច់បង់ហើយ រម្ងាប់ហើយ ស្ងប់ស្ងាត់ហើយ ធ្វើមិនគួរឲ្យកើត ដុតបំផ្លាញដោយភ្លើងគឺញាណហើយ បុគ្គលនោះ មិនត្រឡប់មក មិនងាកមកកាន់ទិដ្ឋិណាមួយទេ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលនោះ មិនត្រឡប់មកកាន់ទិដ្ឋិណាមួយឡើយ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

> បុគ្គលនោះ លះបង់អត្តា មិនប្រកាន់ មិនធ្វើនិស្ស័យ សូម្បីក្នុងញាណ កាលសត្វយល់បែកគ្នាផ្សេងៗ បុគ្គលនោះឯង មិនលុះតាមពួក បុគ្គលនោះ មិនត្រឡប់មកកាន់ទិដ្ឋិណាមួយឡើយ ។
>
> [ ១៦៨ ] ការតាំងទុកអន្តៈទាំង ២ ក្នុងលោកនេះ និងលោកដទៃ ដើម្បីកពតូចកពធំនេះ នៃបុគ្គលណាមិនមានទេ ជម្រកទាំងឡាយណាមួយនិងការពិនិត្យ ហើយប្រកាន់ក្នុងធម៌ទាំងឡាយនៃបុគ្គលនោះ មិនមានឡើយ ដូច្នេះ ។

[ ១៦៩ ] អធិប្បាយពាក្យថា ការតាំងទុកអន្តៈទាំងពីរក្នុងលោកនេះនិង

លោកដទៃ ដើម្បីភពតូចភពធំនេះនៃបុគ្គលណាមិនមានទេ ត្រង់ពាក្យថា នៃបុគ្គលណា គឺនៃព្រះអរហន្តខីណាស្រព ។ ពាក្យថា អន្តៈ គឺផស្សៈ ជាអន្តៈមួយ ការកើតឡើងនៃផស្ស ជាអន្តៈទី ២ ។ អតីតៈ ជាអន្តៈមួយ អនាគតជាអន្តៈទីពីរ ។ សុខវេទនា ជាអន្តៈមួយ ទុក្ខវេទនាជាអន្តៈទីពីរ ។ នាមជាអន្តៈមួយ រូបជាអន្តៈទីពីរ ។ អាយតនខាងក្នុង ៦ ជាអន្តៈមួយ អាយតនខាងក្រៅ ៦ ជាអន្តៈទីពីរ ។ សក្កាយៈជាអន្តៈមួយ ការកើតឡើងនៃសក្កាយៈជាអន្តៈទីពីរ តណ្ហាលោកហៅថា ការតម្កល់ទុក បានដល់សេចក្តីត្រេកអរសេចក្តីត្រេកអរដ៏មានកម្លាំង ។បេ។ អភិជ្ឈា លោភៈ អកុសលមូល ។ ពាក្យថាដើម្បីភពតូចនិងភពធំ គឺដើម្បីកម្មភព បុនព្ភព ឈ្មោះថា ភពតូចនិងភពធំ គឺថាដើម្បីកាមភព កម្មភព កាមភព បុនព្ភព រូបភព កម្មភព រូបភព បុនព្ភពអរូបភព កម្មភព អរូបភព បុនព្ភព គឺថាដើម្បីការកើតរឿយៗ ការទៅរឿយៗឧបបត្តិរឿយៗ បដិសន្ធិរឿយៗ ការញុំាងអត្តភាពឲ្យកើតរឿយៗ ។ ពាក្យថាលោកនេះ គឺអត្តភាពរបស់ខ្លួន ។ ពាក្យថា លោកដទៃ គឺអត្តភាពរបស់បុគ្គលដទៃ ។ ពាក្យថា លោកនេះ គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណរបស់ខ្លួន ។ពាក្យថា លោកដទៃ គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណរបស់បុគ្គលដទៃ ។ពាក្យថា លោកនេះ គឺអាយតនខាងក្នុង ៦ ។ ពាក្យថា លោកដទៃ គឺអាយតនខាងក្រៅ ៦ ។ ពាក្យថា លោកនេះ គឺមនុស្សលោក ។ ពាក្យថាលោកដទៃ គឺទេវលោក ។ ពាក្យថា លោកនេះ គឺកាមធាតុ ។ ពាក្យថាលោកដទៃ គឺរូបធាតុ អរូបធាតុ ។ ពាក្យថា លោកនេះ គឺកាមធាតុ រូបធាតុ ។

ពាក្យថា លោកដទៃ គឺអរូបធាតុ ។

ពាក្យថា ការតាំងទុកអន្ទះទាំងពីរក្នុងលោកនេះនិងលោកដទៃ ដើម្បីភពតូចនិងភពធំនេះ នៃបុគ្គលណាមិនមានទេ បានសេចក្ដីថា ការតាំងទុកអន្ទះទាំងពីរ ក្នុងលោកនេះនិងលោកដទៃ ដើម្បីភពតូចភពធំនេះ នៃបុគ្គលណាមិនមាន មិនមានព្រម មិនកើតមាន គឺបុគ្គលណាលះបង់ហើយ ផ្ដាច់ផ្ដិលហើយ រម្ងាប់ហើយ ស្ងប់ហើយ ធ្វើមិនគួរឲ្យកើត ដុតបំផ្លាញដោយភ្លើង គឺញាណហើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ការតាំងទុកអន្ទះទាំងពីរក្នុងលោកនេះនិងលោកដទៃ ដើម្បីភពតូចភពធំនេះនៃបុគ្គលណាមិនមានទេ ។

[ ១៧០ ] អធិប្បាយពាក្យថា ជម្រកទាំងឡាយណាមួយ នៃបុគ្គលនោះមិនមាន ត្រង់ពាក្យថា ជម្រកទាំងឡាយ បានដល់ ជម្រកពីរយ៉ាង គឺជម្រកគឺតណ្ហា ១ ជម្រកគឺទិដ្ឋិ ១ ។បេ។ នេះជម្រកគឺតណ្ហា ។បេ។ នេះជម្រកគឺទិដ្ឋិ ។ ពាក្យថា នៃបុគ្គលនោះ គឺនៃព្រះអរហន្តខីណាស្រព ។ ពាក្យថា មិនមាន គឺមិនមាន មិនមានព្រម មិនកើតមាន គឺបុគ្គលលះបង់ហើយ ផ្ដាច់ផ្ដិលហើយ រម្ងាប់ហើយ គ្របសង្កត់ហើយ ធ្វើមិនគួរឲ្យកើត ដុតបំផ្លាញដោយភ្លើង គឺញាណហើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជម្រកទាំងឡាយណាមួយនៃបុគ្គលនោះមិនមានឡើយ ។

[ ១៧១ ] អធិប្បាយពាក្យថា ការពិនិត្យហើយប្រកាន់ក្នុងធម៌ទាំងឡាយ ត្រង់ពាក្យថា ក្នុងធម៌ទាំងឡាយ គឺក្នុងទិដ្ឋិ ៦២ ។ ពាក្យថា ពិនិត្យ គឺការពិនិត្យ ពិចារណា សន្សំ ជ្រើសរើស ថ្លឹង ត្រិះរិះ សម្ដែងឲ្យជាក់ច្បាស់ ធ្វើ

ឲ្យប្រាកដ ហើយកាន់តាមជួរ កាន់យកតាមចំណែក កាន់យកមាំ កាន់យកតាមសង្កាត់ កាន់យកជាគំនរ កាន់យកដោយការសន្សំព្រម គឺសេចក្តីប្រកាន់ ការស្ទាបអង្អែល ការប្រកាន់ស្អិត ការប្រកាន់ស៊ប់ ការចុះចិត្តជឿថា នេះទៀងពិត មិនឃ្លៀងឃ្លាត ប្រាកដ គួរតាមសភាពពិត មិនប្រែប្រួល រមែងមិនមាន មិនមានព្រម មិនកើតមាន គឺបុគ្គលបានលះបង់ហើយ ផ្តាច់ផ្តិលហើយ រម្ងាប់ហើយ ស្ងប់ហើយ ធ្វើមិនគួរឲ្យកើត ដុតបំផ្លាញដោយភ្លើង គឺញាណហើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ការពិនិត្យហើយ ប្រកាន់ក្នុងធម៌ទាំងឡាយ ។ ហេតុនោះ ព្រះមានព្រះភាគសម្តែងថា

ការតាំងទុកអន្ទះទាំងពីរ ក្នុងលោកនេះនិងលោកដទៃ ដើម្បីកពតូចកពធំនេះ នៃបុគ្គលណាមិនមានទេ ជម្រកទាំងឡាយណាមួយ ( និង ) ការពិនិត្យហើយប្រកាន់ក្នុងធម៌ទាំងឡាយនៃបុគ្គលនោះមិនមានឡើយ ។

[ ១៧២ ] សេចក្តីសម្គាល់ សូម្បីតូចមួយដែលកំណត់ហើយក្នុងអារម្មណ៍ដែលឃើញ ដែលឮ ឬដែលប៉ះពាល់ហើយនេះនៃបុគ្គលនោះមិនមានទេ អ្នកផងគប្បីកំណត់បុគ្គលដែលជាព្រាហ្មណ៍មិនប្រកាន់ទិដ្ឋិនោះ ក្នុងលោកនេះ ដោយកិលេសដូចម្តេចបាន ដូច្នេះ ។

[ ១៧៣ ] ពាក្យថា សេចក្តីសម្គាល់សូម្បីតូចមួយ ដែលកំណត់ហើយក្នុងអារម្មណ៍ដែលឃើញ ដែលឮ ឬដែលប៉ះពាល់ហើយនេះ នៃបុគ្គលនោះ

មិនមានទេ សេចក្តីថា សេចក្តីសម្គាល់ ភាពជាប្រធាន ភាពជាធំក្នុងទិដ្ឋៈ ឬក្នុងទិដ្ឋសុទ្ធិ ក្នុងសុតៈ ឬក្នុងសុតសុទ្ធិ ក្នុងមុតៈ ឬក្នុងមុតសុទ្ធិ ដែលគេតាំងឡើង កំណត់តាក់តែងតាំងនៅព្រមដោយសញ្ញា ព្រោះសេចក្តីប្រកាន់ខុសដោយសញ្ញានៃព្រះអរហន្តខីណាស្រពនោះមិនមាន មិនមានព្រម មិនកើតមាន គឺលោកលះបង់ ផ្តាច់ផ្តិល រម្ងាប់ ស្ងប់ ធ្វើមិនគួរឲ្យកើត ដុតបំផ្លាញដោយភ្លើងគឺញាណហើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) សេចក្តីសម្គាល់សូម្បីតូចមួយ ដែលកំណត់ហើយក្នុងអារម្មណ៍ដែលឃើញ ដែលឮ ឬដែលប៉ះពាល់ហើយនេះ នៃបុគ្គលនោះមិនមានទេ ។

[ ១៧៤ ] អធិប្បាយពាក្យថា បុគ្គលដែលជាព្រាហ្មណ៍ មិនប្រកាន់ទិដ្ឋិនោះ ត្រង់ពាក្យថា ព្រាហ្មណ៍ គឺបុគ្គលឈ្មោះថា ព្រាហ្មណ៍ ព្រោះជាអ្នកបន្សាត់បង់នូវធម៌ទាំង ៧ ។បេ។ ជាអ្នកមិនអាស្រ័យ ( នូវទិដ្ឋិ ) ជាអ្នកនឹងធឹង បុគ្គលនោះ លោកហៅថា ព្រាហ្មណ៍ ។ ពាក្យថា បុគ្គលដែលជាព្រាហ្មណ៍មិនប្រកាន់ទិដ្ឋិនោះ បានសេចក្តីថា បុគ្គលជាព្រាហ្មណ៍នោះ មិនប្រកាន់ មិនកាន់យក មិនស្ទាបអង្អែល មិនប្រកាន់ស្អិតនូវទិដ្ឋិ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលដែលជាព្រាហ្មណ៍មិនប្រកាន់ទិដ្ឋិនោះ ។

[ ១៧៥ ] អធិប្បាយពាក្យថា គប្បីកំណត់ក្នុងលោកនេះ ដោយកិលេសដូចម្តេចបាន ត្រង់ពាក្យថា កំណត់ បានដល់ការកំណត់ពីរ គឺការកំណត់គឺតណ្ហា ១ ការកំណត់គឺទិដ្ឋិ ១ ។បេ។ នេះការកំណត់គឺតណ្ហា ។បេ។ នេះការកំណត់គឺទិដ្ឋិ ។ ការកំណត់គឺតណ្ហា ព្រាហ្មណ៍នោះ លះបង់ហើយ ការ

កំណាត់គឺទិដ្ឋិ ព្រាហ្មណ៍នោះ រលាស់ចោលហើយ ព្រោះលោកបានលះបង់នូវការកំណាត់គឺតណ្ហា បានរលាស់ចោលនូវការកំណាត់គឺទិដ្ឋិ អ្នកផងគប្បីកំណាត់ដោយរាគៈដូចម្តេច កំណាត់ដោយទោសៈដូចម្តេច កំណាត់ដោយមោហៈដូចម្តេច កំណាត់ដោយមានះដូចម្តេច កំណាត់ដោយទិដ្ឋិដូចម្តេច កំណាត់ដោយឧទ្ធច្ចៈដូចម្តេច កំណាត់ដោយវិចិកិច្ឆាដូចម្តេច កំណាត់ដោយអនុស័យទាំងឡាយដូចម្តេចថា លោកជាអ្នកត្រេកអរ ថាជាអ្នកប្រទូស្ត ថាជាអ្នកវង្វេង ថាជាអ្នកជាប់ចំពាក់ ថាជាអ្នកស្ទាបអង្អែល ថាជាអ្នកដល់នូវសេចក្តីរាយមាយ ថាជាអ្នកដល់នូវការមិនដាច់ស្រេច ឬថាជាអ្នកដល់នូវកម្លាំង ។ អភិសង្ខារទាំងនោះលោកលះបង់ហើយ ព្រោះលោកលះបង់អភិសង្ខារទាំងឡាយហើយ អ្នកផងគប្បីកំណាត់គតិទាំងឡាយ ថាលោកទៅកើតក្នុងនរក ថាកើតក្នុងកំណើតតិរច្ឆាន ថាកើតក្នុងបិត្តិវិស័យ ថាជាមនុស្ស ថាជាទេវតា ថាជាព្រហ្មមានរូប ថាជាព្រហ្មមិនមានរូប ថាជាសញ្ញីព្រហ្ម ថាជាអសញ្ញីព្រហ្ម ឬថាជានេវសញ្ញីនាសញ្ញីព្រហ្មដោយកិលេសដូចម្តេច ។ អ្នកផងគប្បីកំណាត់ គប្បីសម្គាល់ គប្បីដល់នូវការកំណាត់ដោយហេតុណា ហេតុនោះ មិនមានបច្ច័យ មិនមានការណ៍មិនមានទេ ។ ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក មនុស្សលោក ទេវលោក ខន្ធលោក ធាតុលោក អាយតនលោក ហេតុនោះ ( ទ្រង់ត្រាស់ថា ) គប្បីកំណាត់ក្នុងលោកនេះដោយកិលេសដូចម្តេចបាន ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

សេចក្តីសម្គាល់សូម្បីតូចមួយ ដែលកំណាត់ហើយក្នុងអារម្មណ៍

ដែលឃើញ ដែលឮ ឬដែលប៉ះពាល់ហើយនេះ នៃបុគ្គល
នោះមិនមានទេ អ្នកផងគប្បីកំណត់បុគ្គលដែលជាព្រាហ្មណ៍
មិនប្រកាន់ទិដ្ឋិនោះ ក្នុងលោកនេះ ដោយកិលេសដូចម្ដេច
បាន ។

[ ១៧៦ ] ព្រះអរហន្តទាំងឡាយ មិនតែងតាំង មិនធ្វើឲ្យជា
ប្រធាន ដ្បិតធម៌ទាំងឡាយ លោកមិនទទួលយកទេ ព្រាហ្មណ៍
មិនមែនសីលវត្តដឹកនាំបានទេ លោកដល់ត្រើយហើយ ជាអ្នក
នឹងធឹង មិនត្រឡប់មកវិញឡើយ ដូច្នេះ ។

[ ១៧៧ ] អធិប្បាយពាក្យថា មិនតែងតាំង មិនធ្វើឲ្យជាប្រធាន ត្រង់ពាក្យថា តែងតាំង បានដល់ ការតែងតាំង ២ គឺការតែងតាំងគឺតណ្ហា ១ ការតែងតាំងគឺទិដ្ឋិ ១ ។

ការតែងតាំងគឺតណ្ហា តើដូចម្ដេច ។ ការកំណត់ដែន កំណត់ទី កំណត់ជួរ កំណត់ដោយជុំវិញ ហួងហែង អាល័យ ដោយចំណែកតណ្ហាទាំងប៉ុន្មានថា នេះរបស់អញ នុ៎ះរបស់អញ ប៉ុណ្ណេះរបស់អញ ទាំងប៉ុណ្ណោះរបស់អញ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈរបស់អញ គ្រឿងកម្រាល គ្រឿងស្លៀកពាក់ ខ្ញុំស្រី ខ្ញុំប្រុស ពពែ ចៀម មាន់ ជ្រូក ដំរី គោ សេះ លា ស្រែ ចម្ការ ប្រាក់ មាស ស្រុក និគម រាជធានី ដែន ជនបទ បន្ទាយ ឃ្លាំងរបស់អញ បុគ្គលប្រកាន់ផែនដីទាំងអស់ដោយអំណាចតណ្ហា តណ្ហា វិបរីត ១០៨ ទាំងប៉ុន្មាន នេះការតែងតាំងគឺតណ្ហា ។

ការតែងតាំងគឺទិដ្ឋិ តើដូចម្តេច ។ សក្កាយទិដ្ឋិ មានវត្ថុ ២០ មិច្ឆាទិដ្ឋិ មានវត្ថុ ១០ អន្តគ្គាហិកទិដ្ឋិ មានវត្ថុ ១០ ទិដ្ឋិ ដំណើរគឺទិដ្ឋិ ការសាំញ៉ាំគឺទិដ្ឋិ ផ្លូវលំបាកគឺទិដ្ឋិ ចម្រូងគឺទិដ្ឋិ សេចក្តីអន្ទះអន្ទែងគឺទិដ្ឋិ ការប្រកបព្រមគឺទិដ្ឋិ ការកាន់ ការទទួល ការប្រកាន់ ការស្ទាបអង្អែល ផ្លូវអាក្រក់ ផ្លូវខុស ភាពខុស កំពង់និងអណ្តូង ការកាន់យកដោយការស្វែងរកខុស ការកាន់យកវិបរីត ការកាន់យកវិបល្លាស ការកាន់យកខុស ការកាន់យកក្នុងវត្ថុមិនពិតថាជាសភាពពិត ទិដ្ឋិ ៦២ ទាំងប៉ុន្មានណា មានសភាពយ៉ាងនេះ នេះការតែងតាំងគឺទិដ្ឋិ ។

ការតែងតាំងគឺតណ្ហា ព្រះអរហន្តទាំងនោះ លះបង់ហើយ ការតែងតាំងគឺទិដ្ឋិ លោករលាស់ចោលហើយ ព្រះអរហន្តទាំងឡាយ មិនតែងតាំង មិនឲ្យកើត មិនឲ្យកើតព្រម មិនបង្កើត មិនបង្កើតចំពោះនូវការតែងតាំង គឺតណ្ហា ឬនូវការតែងតាំងគឺទិដ្ឋិ ព្រោះលោកលះបង់ការតែងតាំងគឺតណ្ហា រលាស់ចោលការតែងតាំងគឺទិដ្ឋិហើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនតែងតាំង ។

ពាក្យថា ការធ្វើឲ្យជាប្រធាន ក្នុងបទថា មិនធ្វើឲ្យជាប្រធាន បានដល់ ការធ្វើឲ្យជាប្រធាន ២ គឺការធ្វើឲ្យជាប្រធានគឺតណ្ហា ១ ការធ្វើឲ្យជាប្រធានគឺទិដ្ឋិ ១ ។បេ។ នេះការធ្វើឲ្យជាប្រធានគឺតណ្ហា ។បេ។ នេះការធ្វើឲ្យជាប្រធានគឺទិដ្ឋិ ។ ការធ្វើឲ្យជាប្រធានគឺតណ្ហា ព្រះអរហន្តទាំងនោះលះបង់ហើយ ការធ្វើឲ្យជាប្រធានគឺទិដ្ឋិ លោករលាស់ចោលហើយ ព្រះអរហន្តទាំងនោះ មិនធ្វើតណ្ហានិងទិដ្ឋិ ឲ្យជាប្រធានហើយប្រព្រឹត្ត ព្រោះលោកលះបង់ ការធ្វើឲ្យជា

ប្រធានគឺតណ្ហា រលោស់បោលការធ្វើឲ្យជាប្រធានគឺទិដ្ឋិ ព្រះអរហន្តទាំងឡាយ មិនមានតណ្ហាដូចជាទង់ជ័យ មិនមានតណ្ហាដូចជាទង់ មិនមានតណ្ហាជាអធិបតី មិនមានទិដ្ឋិដូចជាទង់ជ័យ មិនមានទិដ្ឋិដូចជាទង់ មិនមានទិដ្ឋិជាអធិបតី គឺតណ្ហា និងទិដ្ឋិ មិនប្រព្រឹត្តហោមរោមហើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនតែង តាំង មិនធ្វើឲ្យជាប្រធាន ។

[ ១៧៨ ] ទិដ្ឋិ ៦២ លោកហៅថា ធម៌ ក្នុងបទថា ដ្បិតធម៌ទាំងឡាយ លោកមិនទទួលយកទេ ។ ពាក្យថា លោក គឺព្រះអរហន្តខីណាស្រពទាំង នោះ ។ ពាក្យថា មិនទទួលយកទេ គឺមិនទទួលថា លោកទៀង ពាក្យនេះ ពិត ពាក្យដទៃជាមោឃៈ មិនទទួលថា លោកមិនទៀង ។បេ។ សត្វខាងមុខ អំពីសេចក្តីស្លាប់កើតទៀតក៏ទេ មិនកើតទៀតក៏ទេ ពាក្យនេះជាពាក្យពិត ពាក្យ ឯទៀតជាមោឃៈ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ដ្បិតធម៌ទាំងឡាយ លោក មិនទទួលយកទេ ។

[ ១៧៩ ] ពាក្យថា មិនមែន ក្នុងបទថា ព្រាហ្មណ៍មិនមែនសីលវត្តដឹក នាំបានទេ ជាពាក្យហាមឃាត់ ។ ពាក្យថា ព្រាហ្មណ៍ គឺបុគ្គល ឈ្មោះថា ព្រាហ្មណ៍ ព្រោះលោកបន្សាត់បង់នូវធម៌ទាំង ៧ ។បេ។ ជាអ្នកមិនអាស្រ័យ ( នូវទិដ្ឋិ ) ជាតាទិបុគ្គល បុគ្គលនោះ លោកហៅថា ព្រាហ្មណ៍ ។ ពាក្យថា ព្រាហ្មណ៍ មិនមែនសីលវត្តដឹកនាំបានទេ បានសេចក្តីថា ព្រាហ្មណ៍គឺសីល ឬ វត្ត ឬសីលវត្តដឹកនាំមិនបាន នាំទៅមិនបាន បន្សាត់ទៅមិនបាន ទង់ទាញទៅ មិន បាន ហេតុនោះ ( ទ្រង់ត្រាស់ថា ) ព្រាហ្មណ៍មិនមែនសីលវត្តដឹកនាំបានទេ ។

[ ១៨០ ] ពាក្យថា លោកដល់ត្រើយហើយ ជាអ្នកនឹងធឹង មិនត្រឡប់មកវិញទេ អធិប្បាយថា អមតនិព្វាន លោកហៅថា ត្រើយ បានខាងការរម្ងាប់សង្ខារទាំងអស់ ការលះបង់ឧបធិទាំងអស់ ការអស់តណ្ហា ការប្រាសចាករាគៈ ការរលត់ និព្វាន ។ បុគ្គលណា ទៅកាន់ត្រើយ ដល់ត្រើយ ទៅកាន់ទីបំផុត ដល់ទីបំផុត ទៅកាន់ខាងចុង ដល់ខាងចុង ។បេ។ ភពថ្មីទៀត នៃបុគ្គលនោះ មិនមានទេ ហេតុនោះ ( ទ្រង់ត្រាស់ថា ) លោកដល់ត្រើយហើយ ។ ពាក្យថា មិនត្រឡប់មកវិញ គឺកិលេសទាំងឡាយណា ដែលលោកលះបង់ហើយ ដោយសោតាបត្តិមគ្គ លោកមិនត្រឡប់ មិនមក មិនត្រឡប់មករកកិលេសទាំងនោះវិញទេ កិលេសទាំងឡាយណា ដែលលោកលះបង់ហើយដោយសកទាគាមិមគ្គ លោកមិនត្រឡប់ មិនមក មិនត្រឡប់មករកកិលេសទាំងនោះវិញទេ កិលេសទាំងឡាយណា ដែលលោកលះបង់ហើយដោយអនាគាមិមគ្គ លោកមិនត្រឡប់ មិនមក មិនត្រឡប់មករកកិលេសទាំងនោះវិញទេ កិលេសទាំងឡាយណា ដែលលោកលះបង់ហើយដោយអរហត្តមគ្គ លោកមិនត្រឡប់ មិនមក មិនត្រឡប់មក រកកិលេសទាំងនោះវិញទេ ហេតុនោះ ( ទ្រង់ត្រាស់ថា ) លោកដល់ត្រើយ ហើយមិនត្រឡប់មកវិញទេ ។ ពាក្យថា ជាអ្នកនឹងធឹង បានដល់ ព្រះអរហន្ត លោកនឹងធឹងដោយអាការៈ ៥ យ៉ាង គឺលោកនឹងធឹងក្នុងឥដ្ឋារម្មណ៍និងអនិដ្ឋារម្មណ៍ ១ លោកនឹងធឹងព្រោះជាអ្នកលះបង់ហើយ ១ លោកនឹងធឹងព្រោះជាអ្នកឆ្លងហើយ ១ លោកនឹងធឹងព្រោះជាអ្នករួចហើយ ១ លោកនឹងធឹងព្រោះការសម្តែងចេញនូវហេតុនោះ ១ ។

លោកនឹងធឹងក្នុងឥដ្ឋារម្មណ៍និងអនិដ្ឋារម្មណ៍ តើដូចម្ដេច ។ ព្រះអរហន្ត លោកនឹងធឹងក្នុងលាភ នឹងធឹងក្នុងអលាភ នឹងធឹងក្នុងយស នឹងធឹងក្នុងអយស នឹងធឹងក្នុងសេចក្ដីសរសើរ នឹងធឹងក្នុងនិន្ទា នឹងធឹងក្នុងសុខនឹងធឹងក្នុងទុក្ខ ។ បើពួកជនលាបដៃម្ខាងដោយគ្រឿងក្រអូប បើពួកជនប្រាសដៃម្ខាងដោយកាំបិត តម្រេកក្នុងការលាបឯណោះក៏មិនមាន សេចក្ដីថ្នាំងថ្នាក់ ក្នុងការប្រាសឯណោះក៏មិនមាន ព្រះអរហន្តលះបង់ស្រឡះនូវសេចក្ដីត្រេកអរនិងសេចក្ដីថ្នាំងថ្នាក់ ប្រព្រឹត្តកន្លងនូវសេចក្ដីលើកតម្កើងនិងសេចក្ដីផ្ចញ់ផ្ចាល់ កន្លងផុតនូវសេចក្ដីស្រឡាញ់និងសេចក្ដីស្អប់ហើយ ព្រះអរហន្តលោកនឹងធឹងក្នុងឥដ្ឋារម្មណ៍និងអនិដ្ឋារម្មណ៍យ៉ាងនេះ ។

ព្រះអរហន្តលោកនឹងធឹង ព្រោះជាអ្នកលះបង់ហើយ តើដូចម្ដេច ។ ព្រះអរហន្តលះបង់ ខ្ជាក់ចោល រួចស្រឡះ លះចោល រលាស់ចោលហើយនូវរាគៈ ។ ព្រះអរហន្តលះបង់ ខ្ជាក់ចោល រួចស្រឡះ លះចោល រលាស់ចោលហើយនូវទោសៈ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ មាយា សាថេយ្យៈ ថម្ភៈ សារម្ភៈ មានៈ អតិមានៈ មទៈ បមាទ កិលេសទាំងអស់ ទុច្ចរិតទាំងអស់ សេចក្ដីក្រវល់ក្រវាយទាំងអស់ សេចក្ដីក្ដៅក្រហាយទាំងអស់ សេចក្ដីអន្ទះអន្ទែងទាំងអស់ អកុសលាភិសង្ខារទាំងអស់ ព្រះអរហន្តលោកនឹងធឹង ព្រោះជាអ្នកលះបង់ហើយយ៉ាងនេះ ។

ព្រះអរហន្តលោកនឹងធឹង ព្រោះជាអ្នកឆ្លងហើយ តើដូចម្ដេច ។ ព្រះអរហន្ត ឆ្លងកាមោឃៈ ឆ្លងភវោឃៈ ឆ្លងទិដ្ឋោឃៈ ឆ្លងអវិជ្ជោឃៈ ឆ្លង ឆ្លង

ផុត ឆ្ងងស្រឡះ កន្លង កន្លងផុត កន្លងហួសនូវផ្លូវគឺសង្សារទាំងអស់ ព្រះអរហន្តនោះ លោកមានកិរិយានៅ នៅស្រេចហើយ មានការប្រព្រឹត្ត ប្រព្រឹត្តហើយ ។បេ។ កពថ្មីទៀតនៃព្រះអរហន្តនោះមិនមានទេ ហេតុនោះ ព្រះអរហន្ត លោកនឹងធឹង ព្រោះជាអ្នកឆ្លងហើយយ៉ាងនេះ ។

ព្រះអរហន្តលោកនឹងធឹង ព្រោះជាអ្នករួចហើយ តើដូចម្តេច ។ ចិត្តរបស់ព្រះអរហន្ត រួច រួចស្រឡះ រួចផុតស្រឡះ ចាករាគៈ ។ ចិត្តលោករួច រួចស្រឡះ រួចផុតស្រឡះចាកទោសៈ ចិត្តលោករួច រួចស្រឡះ រួចផុតស្រឡះចាកមោហៈ ។ ចិត្តលោក រួច រួចស្រឡះ រួចផុតស្រឡះចាកកោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ មាយា សាថេយ្យ ថម្ភៈ សារម្ភៈ មានះ អតិមានះ មទៈ បមាទៈ កិលេសទាំងអស់ ទុច្ចរិតទាំងអស់ សេចក្តីក្រវល់ក្រវាយទាំងអស់ សេចក្តីក្តៅក្រហាយទាំងអស់ សេចក្តីអន្ទះអន្ទែងទាំងអស់ អកុសលាភិសង្ខារទាំងអស់ ព្រះអរហន្តលោកនឹងធឹង ព្រោះជាអ្នករួចហើយយ៉ាងនេះ ។

ព្រះអរហន្តលោកនឹងធឹង ព្រោះការសម្តែងចេញនូវហេតុនោះ តើដូចម្តេច ។ ព្រះអរហន្តលោកនឹងធឹង ព្រោះការសម្តែងចេញនូវហេតុនោះថា កាលបើសីលមាន លោកជាអ្នកមានសីល ។ លោកនឹងធឹង ព្រោះការសម្តែងចេញនូវហេតុនោះថា កាលបើសទ្ធាមាន លោកជាអ្នកមានសទ្ធា ។ លោកនឹងធឹង ព្រោះការសម្តែងចេញនូវហេតុនោះថា កាលបើវិរិយៈមាន លោកជាអ្នកមានវិរិយៈ ។ លោកនឹងធឹង ព្រោះការសម្តែងចេញនូវហេតុនោះថា កាលបើសតិមាន លោកជាអ្នកមានសតិ ។ លោកនឹងធឹង ព្រោះការសម្តែងចេញនូវហេតុនោះថា កាល

បើសមាធិមាន លោកជាអ្នកមានសមាធិ ។ លោកនឹងធឹង ព្រោះការសម្តែងចេញនូវហេតុនោះថា កាលបើបញ្ញាមាន លោកជាអ្នកមានបញ្ញា ។ លោកនឹងធឹង ព្រោះការសម្តែងចេញនូវហេតុនោះថា កាលបើវិជ្ជាមាន លោកជាអ្នកមានវិជ្ជា ៣ ប្រការ ។ លោកនឹងធឹង ព្រោះការសម្តែងចេញនូវហេតុនោះថា កាលបើអភិញ្ញាមាន លោកជាអ្នកមានអភិញ្ញា ៦ ព្រះអរហន្តលោកនឹងធឹង ព្រោះការសម្តែងចេញនូវហេតុនោះ យ៉ាងនេះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) លោកដល់ត្រើយហើយជាអ្នកនឹងធឹង មិនត្រឡប់មកវិញទេ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ព្រះអរហន្តទាំងឡាយ មិនតែងតាំង មិនធ្វើឲ្យជាប្រធាន ដ្បិត
ធម៌ទាំងឡាយ លោកមិនទទួលយកទេ ព្រាហ្មណ៍មិនមែន
សីលវត្តដឹកនាំបានទេ លោកដល់ត្រើយហើយ ជាអ្នកនឹងធឹង
មិនត្រឡប់មកវិញឡើយ ដូច្នេះ ។

## ចប់ បរមដ្ឋកសុត្តនិទ្ទេស ទី ៥

# អដ្ឋកថា

## បរមដ្ឋកសុត្តនិទ្ទេសទី ៥

ក្នុងបរមដ្ឋកសុត្តនិទ្ទេសទី ៥ មានវិនិច្ឆ័យដូចតទៅនេះថា

[ ១៤៦ ] បទថា **បរមន្តិ ទិដ្ឋីសុ បរិព្វសានោ** សេចក្តីថា ប្រកាន់ថា វត្ថុនេះប្រសើរ ហើយនៅក្នុងទិដ្ឋិរៀងៗខ្លួន ។ បទថា **យទុត្តរឹ កុរុតេ** សេចក្តីថា រមែងធ្វើវត្ថុណា មានសាស្តារបស់ខ្លួនជាដើមឲ្យប្រសើរបំផុត ។ បទថា **ហីនាតិ អញ្ញេ តតោ សព្វមាហា** សេចក្តីថា ជននោះ ពោលដល់វត្ថុទាំងពួងដទៃចាកវត្ថុនោះ គឺវៀរសាស្តារបស់ខ្លួនជាដើមនោះថា វត្ថុទាំងនេះអាក្រក់ ។ បទថា **តស្មា វិវាទានិ អវីតិវត្តោ** សេចក្តីថា ព្រោះហេតុនោះ ជននោះរមែងជាបុគ្គលមិនឈានកន្លងនូវជម្លោះ ព្រោះទិដ្ឋិទាំងនោះបានឡើយ ។

[ ១៤៧ ] បទថា **វសន្តិ** សេចក្តីថា នៅដោយអំណាចទិដ្ឋិដែលកើតឡើងលើកដំបូង ។ បទថា **សំវសន្តិ** សេចក្តីថា ចូលទៅ ។ បទថា **អាវសន្តិ** សេចក្តីថា នៅដោយវិសេស ។ បទថា **បរិវសន្តិ** សេចក្តីថា នៅដោយការៈគ្រប់យ៉ាង ។

ព្រះសារីបុត្តត្ថេរ កាលញ៉ាំងអត្ថនោះឲ្យសម្រេចដោយឧបមា ទើបពោលពាក្យជាដើមថា **យថា អាគារិកា វា** ដូច្នេះ ។ បទថា **អាគារិកា វា** បានដល់ ពួកម្ចាស់ផ្ទះ ។ បទថា **ឃរេសុ វសន្តិ** សេចក្តីថា ជាអ្នកប្រាសចាកការតក់ស្លុតនៅអាស្រ័យក្នុងផ្ទះរបស់ខ្លួន ។ បទថា **សាបត្តិកា វា** បានដល់ ជាអ្នកច្រើនដោយអាបត្តិ ។ បទថា **សក្កិលេសា** បានដល់ ច្រើនដោយកិលេស

មានរាគៈជាដើម ។

[ ១៤៨ ] បទថា **ឧត្តរឹ ករោតិ** សេចក្តីថា ធ្វើឲ្យក្រៃលែង ។ បទថា **អយំ សត្ថា សព្វញ្ញូ** សេចក្តីថា ព្រះសាស្តារបស់ពួកយើងនេះ ដឹងនូវធម៌ទាំងពួង ។

[ ១៤៩-១៥១ ] បទថា **សព្វេ បវាទ្យានេ ចិបតិ** សេចក្តីថា ចោលនូវលទ្ធិដទៃទាំងអស់ ។ បទថា **ឧក្ខិបតិ** សេចក្តីថា នាំចេញ ។ បទថា **បរិក្ខិបតិ** សេចក្តីថា ធ្វើក្នុងផ្លូវដែលផ្សុយគ្នា ។ បទថា **ទិដ្ឋិមេធគានិ** បានដល់ បៀតបៀនគ្នាព្រោះទិដ្ឋិ ។

គាថាទី ២ មានសេចក្តីដូចតទៅនេះថា បុគ្គលមិនកន្លងទៅបានយ៉ាងនេះ ឃើញនូវអានិសង្សណា គឺមានប្រការដូចពោលហើយក្នុងកាលមុន ក្នុងខ្លួន ពោលគឺទិដ្ឋិដែលកើតឡើងក្នុងហេតុ ៤ គឺក្នុងរូបដែលឃើញ ក្នុងសំឡេងដែលបានឮ ក្នុងសីលនិងវត្ត ក្នុងអារម្មណ៍ដែលជ្រាប បុគ្គលមិនកន្លងបាននោះ ប្រកាន់មាំនូវអានិសង្សក្នុងលទ្ធិរបស់ខ្លួននោះ គឺក្នុងទិដ្ឋិរបស់ខ្លួននោះថា វត្ថុនេះប្រសើរបំផុត រមែងឃើញវត្ថុដទៃទាំងពួង មានសាស្តាដទៃជាដើម ដោយភាពជារបស់អាក្រក់ ។

[ ១៥២ ] បទថា **ទ្វេ អានិសំសេ បស្សតិ** សេចក្តីថា ឃើញនូវគុណ ២ ប្រការ ។ បទថា **ទិដ្ឋធម្មិកញ្ច** បានដល់ គុណដែលឲ្យផលក្នុងបច្ចុប្បន្ន គឺក្នុងអត្តភាពដែលប្រចក្ស ។ បទថា **សម្បរាយិកញ្ច** បានដល់ គុណដែលគប្បីបានចំពោះក្នុងលោកខាងមុខ ។ បទថា **យំទិដ្ឋិកោ សត្ថា** សេចក្តីថា ជាអ្នក

មានលទ្ធិយ៉ាងណា គឺជាមេលទ្ធិតិរ្ថិយ ។ បទថា **អលំ ឆាគត្តាយ វា** សេចក្តីថា សមគួរដើម្បីភាពជានាគ ក្នុងភាពជាគ្រុឌជាដើម ក៏ន័យនេះឯង ។

បទថា **ទេវត្តាយ វា** បានដល់ ដើម្បីភាពជាសម្មតិទេពជាដើម ។ បទថា **អាយតឹ ផលចាដិកង្ខី ហោតិ** សេចក្តីថា រមែងប្រាថ្នាផលដែលជាវិបាកក្នុងអនាគត ។ បទថា **ទិដ្ឋសុទ្ធិយាបិ ទេ្វ អានិសំសេ បស្សតិ** សេចក្តីថា ឃើញនូវគុណ ២ ប្រការ ដោយការប្រកាន់វត្ថុដែលខ្លួនប្រកាន់ ព្រោះភាពជាហេតុនៃសេចក្តីបរិសុទ្ធដោយអំណាចនៃរូបាយតនៈ ដែលឃើញដោយចក្ខុវិញ្ញាណក្នុងសេចក្តីបរិសុទ្ធ ដោយសំឡេងដែលបានឮជាដើម ក៏ន័យនេះឯង ។

[ ១៥៥ ] គាថាទី ៣ មានសេចក្តីដូចតទៅនេះថា

ជនកាលឃើញយ៉ាងនេះ អាស្រ័យសភាពណា មានសាស្តារបស់ខ្លួនជាដើម តែងឃើញសភាពដទៃ មានសាស្តាដទៃជាដើមថា ថោកទាប តែពួកជនអ្នកឈ្លាសតែងពោលការឃើញនោះ គឺទស្សនៈនោះថា ជាគ្រឿងជាប់ចំពាក់នោះឯង ។ មានអធិប្បាយថា ជាគ្រឿងចងព្រោះសេចក្តីនោះឯង ព្រោះហេតុនោះ ភិក្ខុមិនត្រូវអាស្រ័យអារម្មណ៍ដែលឃើញ ដែលឮ ដែលប៉ះពាល់ហើយ ឬសីលនិងវត្តឡើយ ។ មានអធិប្បាយថា គប្បីមិនប្រកាន់មាំ ។

[ ១៥៦ ] បទថា **កុសលា** បានដល់ ជាអ្នកឈ្លាសក្នុងការដឹងធម៌ មានខន្ធជាដើម ។ បទថា **ខន្ធកុសលា** បានដល់ ឈ្លាសក្នុងខន្ធ ៥ មានរូបក្ខន្ធជាដើម ក្នុងធាតុ អាយតនៈ បដិច្ចសមុប្បាទ សតិប្បដ្ឋាន សម្មប្បធាន ឥទ្ធិបាទ ឥន្ទ្រិយ ពលៈ ពោជ្ឈង្គៈ មគ្គផលនិងនិព្វាន ក៏ន័យនេះឯង ។

*បណ្ដាបទទាំងនោះ បទថា* **មគ្គកុសលា** *បានដល់ ឈ្លាសក្នុងមគ្គ ៤ ។ បទថា* **ផលកុសលា** *បានដល់ ឈ្លាសក្នុងផល ៤ ។ បទថា* **និព្វានកុសលា** *បានដល់ ឈ្លាសក្នុងនិព្វាន ២ យ៉ាង ។ បទថា* **តេ កុសលា** *បានដល់ អ្នកឈ្លាសទាំងនោះ ជាអ្នកឈ្លាសក្នុងប្រការដែលពោលហើយទាំងនេះ ។*

*បទថា* **ឯវំ វទន្តិ** *បានដល់ រមែងពោលយ៉ាងនេះ ។ បទថា* **គន្ថោ ឯសោ** *សេចក្ដីថា បុគ្គលឈ្លាសរមែងពោលដល់ជន ដែលអាស្រ័យសាស្ដាជាដើមរបស់ខ្លួនដែលឃើញ ( យ៉ាងនោះ ) និងទស្សនៈដទៃ មានសាស្ដាដទៃជាដើមដោយភាពជារបស់ថោកទាបថា នេះជាកិលេសគ្រឿងរួបរឹត គឺកិលេសគ្រឿងចង ។ បទថា* **លគ្គនំ ឯតំ** *សេចក្ដីថា ទស្សនៈ មានប្រការដូចពោលហើយនោះ ជាកិលេសគ្រឿងប្រកាន់ស្អិត ដូចដៃកែវដែលបោះភ្ជាប់និងជញ្ជាំងដូច្នោះ ។ បទថា* **ពន្ធនំ ឯតំ** *សេចក្ដីថា ឈ្មោះថា ជាកិលេសជាគ្រឿងចងដូចគ្រឿងចងមានច្រវ៉ាក់ជាដើម ព្រោះអត្ថថា លំបាកនឹងកាត់ផ្ដាច់ ។ បទថា* **បលិពោធោ ឯសោ** *សេចក្ដីថា វត្ថុនោះ ឈ្មោះថាជាកិលេសជាគ្រឿងចងព្រោះអត្ថថា មិនព្រមឲ្យចេញអំពីសង្សារ ។*

*[ ១៥៩ ] គាថាទី ៤ មានអត្ថដូចតទៅនេះថា ភិក្ខុមិនត្រឹមតែមិនអាស្រ័យរូបដែលឃើញនិងសំឡេងដែលបានឮជាដើមតែម្យ៉ាងឡើយ ។ ម្យ៉ាងទៀត មិនគប្បីកំណត់ទិដ្ឋិខាងលើ ដែលមិនបានកើតក្នុងលោក មានអធិប្បាយថា មិនគប្បីឲ្យកើត សេចក្ដីនេះដូចម្ដេច ឆ្លើយថា មិនគប្បីកំណត់ទិដ្ឋិដែលខ្លួនកំណត់ដោយញាណ ឬដោយសីលនិងវត្ត គឺដោយញាណ មានញាណក្នុង*

សមាបត្តិជាដើម ឬដោយសីលនិងវត្ត ។ ភិក្ខុមិនត្រឹមតែមិនកំណត់ទិដ្ឋិតែម្យ៉ាង ម្យ៉ាងទៀត មិនគប្បីប្រៀបផ្ទឹមខ្លួនថាស្មើ ( នឹងបុគ្គលដទៃ ) ឬមិនគប្បីសម្គាល់ថា ថោកទាប ឬថាវិសេសជាងគេ ដោយហេតុមានជាតិជាដើម ព្រោះមានះ ។

[ ១៦០ ] បទថា **អដ្ឋសមាបត្តិញ្ញាណេន វា** សេចក្តីថា ដោយបញ្ញាដែលសម្បយុត្តដោយសមាបត្តិ ៨ មានបឋមជ្ឈានជាដើម ។ បទថា **បញ្ចា-ភិញ្ញាណេន វា** សេចក្តីថា ដោយបញ្ញាដែលសម្បយុត្តដោយអភិញ្ញា ៥ ដែលជាលោកិយ ។ បទថា **មិច្ឆាញាណេន វា** សេចក្តីថា ដោយបញ្ញាដែលប្រព្រឹត្តទៅដោយសភាវៈវិបរិត ឬដោយមិច្ឆាញាណដែលកើតឡើងយ៉ាងនេះក្នុងវត្ថុដែលមិនទាន់រួចផុតថា ពួកយើងរួចផុតហើយ ។

[ ១៦៣ ] គាថាទី ៥ មានអត្ថដូចតទៅនេះថា បុគ្គលនោះ មិនកំណត់និងមិនសម្គាល់នូវទិដ្ឋិយ៉ាងនេះ លះបង់អត្តា មិនប្រកាន់ គឺលះនូវខ្លួនដែលធ្លាប់ប្រកាន់ហើយក្នុងកាលមុន មិនប្រកាន់ខ្លួនដទៃទៀត រមែងមិនធ្វើនិស្ស័យ ២ យ៉ាង ក្នុងញាណដែលមានប្រការដូចពោលហើយនោះ កាលមិនធ្វើ បុគ្គលនោះឯង កាលសត្វយល់បែកគ្នាផ្សេងៗ គឺកាលសត្វទាំងឡាយបែកគ្នាដោយអំណាចនៃទិដ្ឋិផ្សេងៗ ជាអ្នកមិនលុះតាមពួក គឺជាអ្នកដែលមិនទៅជាពួកដោយអំណាចការពេញចិត្តជាដើម រមែងមិនត្រឡប់មកកាន់ទិដ្ឋិណាមួយឡើយក្នុងទិដ្ឋិ ៦២ អធិប្បាយថា រមែងមិនត្រឡប់មក ។

[ ១៦៤ ] បទថា **ចត្តហិ ឧចានាណេហិ** សេចក្តីថា ដោយការប្រកាន់មាំ

៤ យ៉ាង មានកាមុបាទានជាដើម ។

[ ១៦៦ ] បទថា **ស វេ វិវត្តិតេសុ** សេចក្តីថា បុគ្គលនោះ កាលមនុស្ស ទាំងឡាយមិនប្រាថ្នាគ្នានឹងគ្នា ។ បទថា **ភិន្នេសុ** សេចក្តីថា បែកគ្នាជាពីរពួក ។

[ ១៦៨ ] ឥឡូវនេះ ព្រះមានព្រះភាគកាលពោលសរសើរព្រះខីណាស្រពដែលពោលទុកក្នុងគាថានេះ ទើបពោលគាថា ៣ ថា **យស្សូភយន្តេ** ជាដើម ។ បណ្តាគាថា ៣ នោះ គាថាដំបូងមានអត្ថដូចតទៅនេះថា បទថា **យស្សូភយន្តេ** សេចក្តីថា ក្នុងការផ្សេងគ្នា មានផស្សៈជាដើម ដែលពោលហើយក្នុងកាលមុន ។

បទថា **បណិធិ** បានដល់ តណ្ហា ។ បទថា **ភវាភវាយ** បានដល់ ដើម្បីកើតរឿយៗ ។ បទថា **ឥធ វា ហុរំ វា** បានដល់ ក្នុងលោកនេះ មានអត្តភាពរបស់ខ្លួនជាដើម ឬក្នុងលោកខាងមុខ មានអត្តភាពរបស់អ្នកដទៃជាដើម ។

[ ១៦៩ ] បទថា **ផស្សោ ឯកោ អន្តោ** សេចក្តីថា ចក្ខុសម្ផស្សជាដើមជាចំណែកទីមួយ ។ បទថា **ផស្សសមុទយោ** សេចក្តីថា អារម្មណ៍ គឺវត្ថុព្រោះតាំងឡើង គឺកើតឡើង ទើបផស្សៈនោះឈ្មោះថា សមុទយៈ ។ បទថា **ទុតិយោ អន្តោ** សេចក្តីថា ជាចំណែកទីពីរ ។ បទថា **អតីតំ** សេចក្តីថា ប្រព្រឹត្តទៅកន្លងហើយ ឈ្មោះថា អតីតៈ អធិប្បាយថា ឈានកន្លង ។ បទថា **អនាគតំ** សេចក្តីថា មិនទាន់មកដល់ ឈ្មោះថា អនាគត មានអធិប្បាយថា មិនទាន់កើតឡើង ។ សុខវេទនាជាដើម គប្បីជ្រាបថា លោកពោលដោយ

អំណាចជាវិសភាគៈគ្នា ។ ពួក ២ នៃនាមរូប លោកពោលដោយអំណាចនៃការបង្អោនទៅ និងការបែកធ្លាយ ។ បទថា **អជ្ឈត្តិកា** ជាដើម លោកពោលដោយអំណាចនៃអាយតនៈខាងក្នុង និងអាយតនៈខាងក្រៅ ។ បទថា **សក្កាយ** ជាដើម លោកពោលដោយអំណាចនៃការប្រព្រឹត្តទៅ និងហេតុកើតឡើងនៃខន្ធបញ្ចកៈទាំងឡាយ ។ បទថា **សកត្តភាវោ** គឺជា **អត្តនោ អត្តភាវោ** ។ បទ ថា **បរត្តភាវោ** គឺជា **បរស្ស អត្តភាវោ** ។

[ ១៧២-១៧៥ ] គាថាទី ២ មានអត្ថដូចតទៅនេះថា បទថា **ឆិដ្ឋេ** បានដល់ ក្នុងការបរិសុទ្ធព្រោះរូបដែលឃើញខ្លះ ក្នុងសំឡេងដែលបានឮជាដើមក៏ន័យនេះ ។ បទថា **សញ្ញា** បានដល់ ទិដ្ឋិដែលសញ្ញាឲ្យកើតឡើង ។ បទថា **អបរាមសន្តំ** សេចក្ដីថា មិនប្រកាន់មាំដោយតណ្ហា មានះ និងទិដ្ឋិ ។ បទថា **អនភិនិវិសន្តំ** សេចក្ដីថា មិនប្រកាន់មាំដោយតណ្ហា មានះនិងទិដ្ឋិទាំងនោះ ។

បទថា **វិនិពន្ធោតិ វា** សេចក្ដីថា ឬចងដោយមានះ ។ បទថា **បរាម-ដ្ឋោតិ វា** សេចក្ដីថា ឬប្រកាន់មាំដោយប្រការដទៃដោយការទៀង សេចក្ដីសុខនិងការស្អាតជាដើម ។ បទថា **វិក្ខេបគតោ** លោកពោលដោយអំណាចឧទ្ធច្ចៈ ។ បទថា **អនិដ្ឋង្គតោ** លោកពោលដោយអំណាចវិចិកិច្ឆា ។ បទថា **ថាមគតោ** លោកពោលដោយអំណាចអនុស័យ ។ បទថា **គតិយា** លោកពោលដោយអំណាចគតដែលគប្បីទៅ ។

[ ១៧៦ ] គាថាទី ៣ មានអត្ថដូចតទៅនេះថា បទថា **ធម្មាបិ តេសំ ន**

**បដិច្ឆិតាសេ** សេចក្តីថា សូម្បីធម៌ គឺទិដ្ឋិ ៦២ ដែលបុគ្គលទាំងនោះ មិនប្រាថ្នាចំពោះយ៉ាងនេះថា វត្ថុនេះប៉ុណ្ណោះពិត វត្ថុដទៃជាមោឃៈ ។ បទថា **ចារង្គតោ ន បច្ចេតិ តាទិ** សេចក្តីថា បុគ្គលដែលដល់នូវត្រើយ គឺនិព្វាន រមែងមិនមកកាន់កិលេសទាំងឡាយដែលលះបានហើយដោយមគ្គនោះៗ ទៀត និងជាតាទិបុគ្គលដោយអាការៈ ៥ ។ បទដ៏សេសប្រាកដហើយទាំងអស់ ។

[ ១៧៧ ] បទថា **វីសតិវត្ថុកា សក្កាយទិដ្ឋិ** បានដល់ ទិដ្ឋិក្នុងវិជ្ជមានកាយដែលធ្វើនូវខន្ធ ៥ ឲ្យជាទីតាំងប្រព្រឹត្តទៅដោយអាការៈនីមួយៗ ៤ ក្នុងខន្ធនីមួយៗ ដោយន័យជាដើមថា ពិចារណាឃើញរូបដោយភាពជាខ្លួន ។ បទថា **ទសវត្ថុកា មិច្ឆាទិដ្ឋិ** បានដល់ ទិដ្ឋិដែលប្រព្រឹត្តទៅដោយន័យជាដើមថា ទានដែលឲ្យហើយមិនមានផល ។ បទថា **អន្តគ្គាហិកា ទិដ្ឋិ** បានដល់ ទិដ្ឋិដែលប្រព្រឹត្តទៅដោយន័យជាដើមថា លោកទៀង វត្ថុនេះប៉ុណ្ណោះពិត វត្ថុដទៃមិនពិត គឺដែលប្រកាន់ថា ទីបំផុតនីមួយៗ មាន ។ បទថា **យា ឯវរូបា ទិដ្ឋិ** ជាមូលបទដែលទូទៅ ដល់បទទាំង ១៩ ដែលពោលក្នុងឥឡូវនេះ ។ គប្បីភ្ជាប់សេចក្តីទាំងអស់ថា ទិដ្ឋិឯណា ការដល់ទិដ្ឋិនោះឯង ទិដ្ឋិឯណា ព្រៃស្តុកគឺទិដ្ឋិនោះឯង ឯណា ឈ្មោះថា ទិដ្ឋិ ដោយអត្ថថា ឃើញដោយមិនពិតនោះឯង ជាការឃើញដែលទៅក្នុងទិដ្ឋិទាំងឡាយ ព្រោះឈមចុះក្នុងទិដ្ឋិ ៦២ ព្រោះហេតុនោះ ទើបឈ្មោះថា **ទិដ្ឋិគតំ** ។ អត្ថនៃពាក្យនោះ បានពោលទុកហើយខាងដើមនោះឯង ។ ឈ្មោះថា **ទិដ្ឋិគតំ** ព្រោះទៅហើយដោយចំណែកមួយនៃអន្តធម៌ទាំង ២ ។

[ ១៧៨ ] បណ្ដាបទទាំងនោះ បទថា **សស្សតោ** បានដល់ ទៀង ។ បទថា **លោកោ** បានដល់ ខ្លួន ។ មិច្ឆាទិដ្ឋិបុគ្គលរមែងយល់ថា សរីរៈក្នុងលោកនេះប៉ុណ្ណោះវិនាសទៅ តែខ្លួននៅជាខ្លួននោះឯង ទាំងលោកនេះនិងលោកខាងមុខ ។

ពិតហើយ អត្តានោះ សន្មតថាលោក ព្រោះឃើញទូទៅដោយខ្លួនឯងនោះឯង ។ បទថា **អសស្សតោ** បានដល់ មិនទៀង ។ មិច្ឆាទិដ្ឋិបុគ្គលរមែងយល់ថា អត្តារមែងវិនាសទៅជាមួយនឹងសរីរៈនោះឯង ។ បទថា **អន្តវា** សេចក្ដីថាមិច្ឆាទិដ្ឋិបុគ្គលធ្វើឈានឲ្យកើតឡើងក្នុងកសិណតូចតាចហើយយល់ចេតនាដែលមានកសិណតិចតួចជាអារម្មណ៍នោះថា អត្តាមានទីបំផុតដោយជុំវិញ ។ បទថា **អនន្តវា** សេចក្ដីថា មានទីបំផុត ក៏មិនមែន គឺមិច្ឆាទិដ្ឋិបុគ្គល ធ្វើឈានឲ្យកើតឡើងក្នុងអប្បមាណកសិណហើយយល់ ចេតនាដែលមានអប្បមាណកសិណជាអារម្មណ៍នោះថា អត្តាមានទីបំផុតដោយជុំវិញក៏មិនមែន ។ បទថា **តំ ជីវំ តំ សរីរំ** សេចក្ដីថា ជីវៈក្ដី សរីរៈក្ដី តែមួយនោះឯង ។ បទថា **ជីវោ** បានដល់ ខ្លួន លោកពោលជានបុំសកលិង្គ ដោយលិង្គវិបល្លាស ។ បទថា **សរីរំ** សេចក្ដីថា ឈ្មោះថាខន្ធបញ្ចកៈ ដោយអត្ថថា សភាពជាគំនរ ។ បទថា **អញ្ញំ ជីវំ អញ្ញំ សរីរំ** សេចក្ដីថា ជីវិតផ្សេង ខន្ធបញ្ចកៈផ្សេង ។

បទថា **ហោតិ តថាគតោ បរម្មរណា** សេចក្ដីថា ខន្ធទាំងឡាយរមែងវិនាសទៅក្នុងលោកនេះប៉ុណ្ណោះ សត្វខាងមុខបន្ទាប់អំពីស្លាប់រមែងមាន គឺមានមិនវិនាសទៅ ។ បទថា **តថាគតោ** នេះ ប្រើហៅសត្វក៏មាន តែអាចារ្យ

ពួកខ្លះពោលថា បទថា **តថាគតោ** បានដល់ ព្រះអរហន្ត ។ មិច្ឆាទិដ្ឋិបុគ្គលទាំងនេះ ឃើញទោសក្នុងចំណែកថា រមែងមិនកើតទៀត ទើបកាន់យកយ៉ាងនេះ ។ បទថា **ន ហោតិ តថាគតោ បរម្មរណា** សេចក្តីថា ខន្ធទាំងឡាយរមែងវិនាសទៅក្នុងលោកនេះប៉ុណ្ណោះ សត្វខាងមុខអំពីមរណៈ រមែងមិនកើតទៀត គឺដាច់សូន្យ ។ មិច្ឆាទិដ្ឋិបុគ្គលទាំងនេះ ឃើញទោសក្នុងចំណែកថា រមែងកើតទៀត ទើបកាន់យកយ៉ាងនេះ ។ បទថា **ហោតិ ច ន ច ហោតិ** សេចក្តីថា មិច្ឆាទិដ្ឋិបុគ្គលទាំងនេះ ឃើញទោសក្នុងការប្រកាន់ម្ខាងៗ ហើយកាន់យកទាំងសងខាង ។ បទថា **នេវ ហោតិ ន ន ហោតិ** សេចក្តីថា មិច្ឆាទិដ្ឋិបុគ្គលទាំងនេះ ឃើញទោស ២ យ៉ាង ដែលកើតក្នុងការប្រកាន់ទាំងពីរចំណែក ទើបកាន់យកចំណែកដែលរើបាន គឺមិនស្តាប់ខ្លួនថា កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ។

ក្នុងនិទ្ទេសនេះ មានន័យរបស់អដ្ឋកថា ដូចតទៅនេះថា លោកពោលប្រភេទនៃទិដ្ឋិដោយអាការៈ ១០ យ៉ាងថា **សស្សតោ លោកោ** ជាដើម ។ បណ្តាបទទាំងនោះ បទថា **សស្សតោ លោកោ** សេចក្តីថា ទិដ្ឋិដែលប្រព្រឹត្តទៅដោយការប្រកាន់ថា ទៀង របស់បុគ្គលដែលប្រកាន់ថា ខន្ធបញ្ចកៈជាលោក ហើយប្រកាន់ថា លោកទៀង ឋិតថេរ ប្រព្រឹត្តទៅសព្វកាល ។ បទថា **អសស្សតោ** សេចក្តីថា ទិដ្ឋិដែលប្រព្រឹត្តទៅដោយអាការៈប្រកាន់ថា ដាច់សូន្យរបស់បុគ្គលដែលប្រកាន់លោកនោះឯងថាដាច់សូន្យ គឺវិនាស ។ បទថា **អន្តវា** សេចក្តីថា ទិដ្ឋិដែលប្រព្រឹត្តទៅដោយអាការៈប្រកាន់ថា លោកមានទីបំផុត

របស់អ្នកបានបរិត្តកសិណ ចូលកសិណប៉ុនចង្អេរ ឬប៉ុនផ្តិលហើយប្រកាន់រូបធម៌និងអរូបធម៌ ដែលប្រព្រឹត្តទៅក្នុងសមាបត្តិថា ជាលោកផង ថាមានទីបំផុតដោយកំណត់យកកសិណដែលជាទីបំផុតផង ។ ទិដ្ឋិនោះ ជាសស្សតទិដ្ឋិខ្លះ ជាឧច្ឆេទទិដ្ឋិខ្លះ ។ ទិដ្ឋិដែលប្រព្រឹត្តទៅដោយអាការៈកាន់ថា លោកមិនមានទីបំផុតរបស់បុគ្គលដែលបានកសិណបរិបូណ៌ បុគ្គលចូលកសិណនោះហើយកាន់យករូបធម៌និងអរូបធម៌ ដែលប្រព្រឹត្តទៅខាងក្នុងសមាបត្តិថា ជាលោកផង ថាមិនមានទីបំផុតដោយកំណត់យកកសិណជាទីបំផុតផង ។ ទិដ្ឋិនោះ ជាសស្សតទិដ្ឋិខ្លះ ជាឧច្ឆេទទិដ្ឋិខ្លះ ។ បទថា **តំ ជីវំ តំ សរីរំ** សេចក្តីថា ទិដ្ឋិដែលប្រព្រឹត្តទៅដោយអាការៈប្រកាន់ថា ដាច់សូន្យថា កាលសរីរៈដាច់សូន្យ សូម្បីជីវៈក៏ដាច់សូន្យ ព្រោះប្រកាន់សរីរៈ ដែលមានការបែកធ្លាយជាធម្មតានោះឯងថា ជាជីវៈដោយបទទី ២ លោកពោលទិដ្ឋិដែលប្រព្រឹត្តទៅដោយអាការៈប្រកាន់ថា ទៀង ថាកាលសរីរៈដាច់សូន្យ ជីវៈក៏មិនដាច់សូន្យ ព្រោះប្រកាន់ថា ជីវៈដទៃអំពីសរីរៈ ។ ក្នុងបទថា **ហោតិ តថាគតោ** ជាដើម មានសេចក្តីថា សត្វ ឈ្មោះថា តថាគត ទិដ្ឋិទី ១ របស់បុគ្គលដែលប្រកាន់ថា សត្វនោះ ខាងមុខអំពីស្លាប់រមែងកើតទៀត ឈ្មោះថា សស្សតទិដ្ឋិ ។ ទិដ្ឋិទី ២ របស់បុគ្គលដែលប្រកាន់ថា រមែងមិនកើតទៀត ឈ្មោះថា ឧច្ឆេទទិដ្ឋិ ។ ទិដ្ឋិទី ៣ របស់បុគ្គលដែលប្រកាន់ថា រមែងកើតទៀតក៏មាន រមែងមិនកើតទៀតក៏មាន ឈ្មោះថា ឯកច្ចសស្សតទិដ្ឋិ ( យល់ឃើញថាទៀងដោយចំណែកខ្លះ ) ។ ទិដ្ឋិទី ៤ របស់បុគ្គលដែលប្រកាន់ថា រមែងកើតទៀតក៏មិនមែន មិនកើតទៀត

ក៏មិនមែន ឈ្មោះថា អមរាវិក្ខេបទិដ្ឋិ ( ទិដ្ឋិដែលបោះពាក្យសម្ដីមិនឲ្យស្ងាប់ខ្ជួន ) ។ ទិដ្ឋិ ១០ យ៉ាង មានប្រការដូចពោលហើយ ដោយប្រការដូច្នេះ ទិដ្ឋិមាន ២ យ៉ាង តាមដែលប្រកបបាន គឺភវទិដ្ឋិ ១ វិភវទិដ្ឋិ ១ ក្នុងទិដ្ឋិ ២ យ៉ាងនោះ ទិដ្ឋិសូម្បីត្រឹមតែមួយ ព្រះខីណាស្រពនោះក៏មិនប្រាថ្នា ។

[ ១៨០ ] បទថា **យេ កិលេសា** សេចក្ដីថា កិលេសពួកណា ដែលព្រះអរិយបុគ្គលលះហើយដោយសោតាបត្តិមគ្គ អរិយបុគ្គលនោះរមែងមិនត្រឡប់មកកាន់កិលេសទាំងនោះទៀត គឺមិនញុំាងកិលេសទាំងនោះឲ្យត្រឡប់មកកើតទៀត ។

បទថា **ន បច្ចាគច្ឆតិ** សេចក្ដីថា មិនមកខាងក្រោយ ។ បទថា **បញ្ចហាការេហិ តាទិ** សេចក្ដីថា ជាបុគ្គលដូចគ្នាដោយហេតុ ឬចំណែក ៥ យ៉ាង ។ បទថា **ឥដ្ឋានិដ្ឋេ តាទិ** សេចក្ដីថា ជាបុគ្គលដូចគ្នាក្នុងហេតុ ២ យ៉ាង គឺ ឥដ្ឋារម្មណ៍និងអនិដ្ឋារម្មណ៍ ព្រោះដោះនូវការត្រេកអរនិងការមិនត្រេកអរបានហើយតាំងនៅ ។ បទថា **ចត្តាវី** បានដល់ ជាអ្នកលះកិលេសទាំងឡាយ ។ បទថា **តិណ្ណាវី** បានដល់ ឈានកន្លងសង្សារ ។ បទថា **មុត្តាវី** បានដល់ ផុតចាករាគៈជាដើម ។ បទថា **តំនិទ្ទេសា តាទិ** សេចក្ដីថា ឈ្មោះថា ជាបុគ្គលដូចគ្នា ព្រោះគប្បីពោលសម្ដែងចេញហើយដោយគុណ មានសីលនិងសទ្ធាជាដើមនោះៗ ។

ព្រះសារីបុត្តត្ថេរ បំណងនឹងពោលអាការៈ ៥ យ៉ាងឲ្យពិស្ដារ ទើបពោលថា **កថំ អរហា ឥដ្ឋានិដ្ឋេ តាទិ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **លាភេបិ** សេចក្តីថា ក្នុងការបានបច្ច័យ ៤ ។ បទថា **អលាភេបិ** បានដល់ ក្នុងការមិនបានបច្ច័យ ៤ ទាំងនោះ ។ បទថា **យសេបិ** បានដល់ ក្នុងបរិវារ ។ បទថា **អយសេបិ** បានដល់ ក្នុងកាលវិបត្តិចាកបរិវារ ។ បទថា **បសំសាយបិ** បានដល់ ក្នុងការពោលសរសើរ ។ បទថា **និន្ទាយបិ** បានដល់ ក្នុងការតិះដៀល ។ បទថា **សុខេបិ** បានដល់ ក្នុងសុខផ្លូវកាយ ។ បទថា **ទុក្ខេបិ** បានដល់ ក្នុងសេចក្តីទុក្ខផ្លូវកាយ ។ បទថា **ឯកតោ ពាហំ គន្ធេន លិម្បេយ្យុំ** សេចក្តីថា បើជនទាំងឡាយគប្បីឲ្យនូវការលាបដ៏ក្រៃលែងដោយគ្រឿងក្រអូបដែលផ្សំដោយគន្ធជាតិ ៤ យ៉ាង ត្រង់ដៃម្ខាង ។

បទថា **វាសិយា តច្ឆេយ្យុំ** សេចក្តីថា បើនាយជាងយកកាំបិតពន្លះដៃម្ខាងធ្វើឲ្យតូចចុះមក ។ បទថា **អមុស្មិំ នត្ថិ រាគោ** សេចក្តីថា សេចក្តីស្នេហាក្នុងការលាបដោយរបស់ក្រអូបនោះមិនមាន គឺមិនមានឡើយ ។ បទថា **អនុស្មិំ នត្ថិ បដិឃំ** សេចក្តីថា ការមិនត្រេកអរ ពោលគឺការខ្ញាំងខ្ញប់ បានដល់សេចក្តីក្រោធក្នុងការពន្លះដោយកាំបិតនោះមិនមាន គឺមិនមានឡើយ ។ បទថា **អនុនយប្បដិឃវិប្បហីនោ** សេចក្តីថា លះនូវសេចក្តីស្នេហានិងសេចក្តីក្រោធតាំងនៅ ។ បទថា **ឧគ្ឃាតិនិគ្ឃាតិវីតិវត្តោ** សេចក្តីថា ឈានកន្លងនូវការតាមកាន់យកដោយអំណាចនៃការត្រេកអរ និងឈានកន្លងការសង្កត់សង្កិនដោយអំណាចនៃការត្រេកអរហើយតាំងនៅ ។ បទថា **អនុរោធវិរោធសមតិក្កន្តោ** សេចក្តីថា ឈានកន្លងដោយប្រពៃនូវសេចក្តីត្រេកអរនិងការមិន

ត្រេកអរ ។

បទថា **សីលេ សតិ** សេចក្ដីថា ក្នុងកាលសីលមាន ។ បទថា **សីលវា** សេចក្ដីថា ដល់ព្រមដោយសីល ។ ព្រះអរហន្តរមែងបាននូវការសម្ដែងចេញ គឺការពោលដោយសីលនោះ ព្រោះហេតុនោះ ទើបឈ្មោះថា **ឥាធិ** ។ ក្នុងបទយ៉ាងនេះថា **សទ្ធាយ សតិ សទ្ធោ** ជាដើម ក៏ន័យនេះឯង ។

## អដ្ឋកថា បរមដ្ឋកសុត្តនិទ្ទេសទី ៥ ចប់

# ជរាសុត្តនិទ្ទេស ទី ៦

[ ១៨១ ] ( ព្រះមានព្រះភាគត្រាស់ថា ) ជីវិតនេះតិចណាស់ រមែងស្លាប់ខាងអាយអំពី ១០០ ឆ្នាំ បើបុគ្គលណា រស់នៅកន្លងហួស ( ពី ១០០ ឆ្នាំ ) ទៅ បុគ្គលនោះ គង់ស្លាប់ព្រោះជរាពុំខាន ។

[ ១៨២ ] អធិប្បាយពាក្យថា ជីវិតនេះតិចណាស់ ត្រង់ពាក្យថា ជីវិត គឺ អាយុ ការតាំងនៅ ការរស់នៅ ការញុំាងអត្តភាពឲ្យរស់នៅ ការដើរទៅ ការប្រព្រឹត្តទៅ ការរក្សាជីវិត ជីវិតិន្ទ្រិយ ។ មួយទៀត ជីវិតតិច ជីវិតស្តួចស្តើង ដោយហេតុ ២ គឺជីវិតតិច ព្រោះជាធម្មជាតិតាំងនៅតិច ១ ជីវិតតិច ព្រោះកិច្ចរបស់ខ្លួនតិច ១ ។

ជីវិតតិច ព្រោះធម្មជាតិតាំងនៅតិច តើដូចម្តេច ។ សត្វដែលរស់នៅហើយក្នុងខណៈចិត្តជាអតីតៈ មិនកំពុងរស់នៅក្នុងបច្ចុប្បន្ន នឹងមិនរស់នៅក្នុងអនាគតទេ ។ សត្វនឹងរស់នៅក្នុងខណៈចិត្តជាអនាគត មិនកំពុងរស់នៅក្នុងបច្ចុប្បន្ន មិនរស់នៅហើយក្នុងអតីតទេ ។ សត្វកំពុងរស់នៅក្នុងខណៈចិត្តជាបច្ចុប្បន្ន មិនបានរស់នៅហើយក្នុងអតីតៈ នឹងមិនរស់នៅក្នុងអនាគតទេ ។

ជីវិត អត្តភាព សុខ និងទុក្ខទាំងអស់ ប្រកបដោយខណៈចិត្ត
តែមួយ ព្រោះខណៈប្រព្រឹត្តទៅរហ័ស ពួកទេវតាណា ឋិតនៅ
អស់ ៨៤ ពាន់កប្ប ទេវតាទាំងនោះ មិនមែនប្រកបដោយ
ចិត្ត ២ ហើយរស់នៅទេ ខន្ធទាំងឡាយណា របស់បុគ្គល
ដែលស្លាប់ទៅក្តី រស់នៅក្តី រលត់ហើយក្នុងលោកនេះ ខន្ធទាំង
អស់នោះក៏ដូចគ្នា ទៅបដិសន្ធិទៀតមិនបាន ខន្ធទាំងឡាយណា

ដែលកន្លងទៅជាលំដាប់ បែកធ្លាយហើយផង ខន្ធទាំងឡាយណា ជាអនាគតនឹងបែកធ្លាយផង សេចក្ដីផ្សេងគ្នានៃខន្ធទាំងឡាយជាបច្ចុប្បន្នដែលរលត់ហើយ ក្នុងចន្លោះនៃខន្ធទាំងពីរនោះ រមែងមិនមានក្នុងលក្ខណៈ សត្វលោកដែលកើតហើយដោយអនាគតក្ខន្ធ ដែលមិនទាន់កើត មិនឈ្មោះថា រស់នៅហើយ ទាំងមិនឈ្មោះថា កំពុងរស់នៅក្នុងខន្ធជាបច្ចុប្បន្នទេ សត្វលោកស្លាប់ដោយការបែកធ្លាយនៃចិត្ត ( នេះជា ) បញ្ញត្តនៃបរមត្ថ ការប្រែប្រួលទៅដោយធម្មៈ ដូចជាទីទាប រមែងប្រព្រឹត្តទៅដូច្នោះ វេទនាទាំងឡាយ មានសឡាយតនៈជាបច្ច័យ មានភារៈមិនដាច់ តែងប្រព្រឹត្តទៅ ខន្ធទាំងឡាយបែកធ្លាយហើយ ក៏មិនដល់នូវការតម្កល់ទុកគំនរនៃខន្ធក្នុងអនាគតក៏មិនមាន ខន្ធទាំងឡាយដែលកើតឡើងហើយ រមែងឋិតនៅដូចគ្រាប់ស្ពៃ ដែលឋិតនៅលើចុងដែកស្រួច កាលបើខន្ធទាំងឡាយកើតឡើងហើយ ការបែកធ្លាយនៃខន្ធទាំងនោះ ក៏ឋិតនៅក្នុងខាងមុខ សភាវៈដែលត្រូវវិនាសទាំងឡាយ ( ខន្ធ ) កំពុងឋិតនៅ មិនច្របូកច្របល់ដោយខន្ធចាស់ទេ រមែងមកអំពីទីមើលមិនឃើញ លុះបែកធ្លាយហើយ តែងទៅកាន់ទីមើលមិនឃើញវិញ រមែងកើតឡើងផង រមែងវិនាសទៅផង ដូចជាផ្លេកបន្ទោរឮដ៏អាកាស ។ ជីវិតតិច ព្រោះការឋិតនៅតិច

យ៉ាងនេះ ដូច្នេះ ។

ជីវិតតិច ព្រោះកិច្ចរបស់ខ្លួនតិច តើដូចម្តេច ។ ជីវិតជាប់ទាក់ទងដោយដង្ហើមចូល ជីវិតជាប់ទាក់ទងដោយដង្ហើមចេញ ជីវិតជាប់ទាក់ទងដោយដង្ហើមចូលនិងបង្ហើមចេញ ជីវិតជាប់ទាក់ទងដោយមហាភូតរូប ជីវិតជាប់ទាក់ទងដោយភ្លើងធាតុ ជីវិតជាប់ទាក់ទងដោយអាហារជាពំនូត ជីវិតជាប់ទាក់ទងដោយវិញ្ញាណ ។ ឫសគល់របស់ធម៌ទាំងនេះ មានកម្លាំងថយ ។ បុព្វហេតុទាំងឡាយរបស់ធម៌ទាំងនេះ ក៏មានកម្លាំងថយ ។ សូម្បីពួកធម៌ណាជាបច្ច័យធម៌ទាំងនោះ ក៏មានកម្លាំងថយ ។ សូម្បីពួកធម៌ណាជាប្រភព ធម៌ទាំងនោះក៏មានកម្លាំងថយ ។ ពួកធម៌ដែលកើតជាមួយនឹងធម៌ទាំងនេះ ក៏មានកម្លាំងថយ ។ ពួកធម៌ប្រកបជាមួយគ្នានឹងធម៌ទាំងនេះ ក៏មានកម្លាំងថយ ។ ធម៌ដែលកើតឡើងជាមួយគ្នានឹងធម៌ទាំងនេះ ក៏មានកម្លាំងថយ ។ ធម្មជាតិណា ជាគ្រឿងប្រកបធម្មជាតិនោះ ក៏មានកម្លាំងថយ ។ ធម៌ទាំងនោះ មានកម្លាំងថយជានិច្ចដល់គ្នានឹងគ្នា ។ ធម៌ទាំងនេះ មិនឱនរកគ្នានឹងគ្នា ។ ធម៌ទាំងនេះញ៉ាំងគ្នានឹងគ្នាឲ្យធ្លាក់ចុះ ។ ព្រោះមិនបានជាទីពឹងដល់គ្នានឹងគ្នា ។ មួយទៀតធម៌ទាំងនេះ មិនតម្កល់ទុកនូវគ្នានឹងគ្នា ។ សូម្បីធម៌ណា ជាអ្នកបង្កើតធម៌នោះក៏មិនមាន ។ ធម៌ណាមួយមិនមែនវិនាសដោយធម៌ណាមួយទេ ។ ព្រោះថាធម៌ទាំងនេះ បែកធ្លាយទៅដោយប្រការទាំងពួង ។ ធម៌ទាំងនេះកើតហើយព្រោះហេតុនឹងបច្ច័យអំពីមុន ។ ហេតុនិងបច្ច័យទាំងឡាយណា ដែលឲ្យកើតមុន ហេតុនិងបច្ច័យទាំងនោះ ក៏ស្លាប់មុនទៅហើយ ។ ធម៌ទាំងឡាយខាង

ដើមនិងខាងចុង មិនបានឃើញគ្នានឹងគ្នា ក្នុងកាលណាមួយឡើយ ។ ជីវិតតិច ព្រោះកិច្ចរបស់ខ្លួនតិចយ៉ាងនេះ ។

មួយទៀត ពួកមនុស្ស មានជីវិតតិច ជីវិតស្តួចស្តើង ជីវិតខ្លី ជីវិតមានក្នុងមួយខណៈ ជីវិតរហ័ស ជីវិតដាច់ ជីវិតមិនមាំមួន ជីវិតមិនឋិតនៅយូរ បើប្រៀបផ្ទឹមនឹងជីវិតរបស់ពួកទេវតាជាន់ចាតុម្មហារាជិកា ។ របស់ពួកទេវតាជាន់តាវត្តិង្ស ។ របស់ទេវតាជាន់យាមៈ ។ របស់ទេវតាជាន់តុសិត ។ របស់ទេវតាជាន់និម្មានរតី ។ របស់ទេវតាជាន់បរនិម្មិតវសវត្តី ។ ពួកមនុស្សមានជីវិតតិច ជីវិតស្តួចស្តើង ជីវិតថោកថយ ជីវិតមានក្នុងមួយខណៈ ជីវិតរហ័ស ជីវិតដាច់ ជីវិតមិនមាំមួន ជីវិតមិនឋិតនៅយូរ បើប្រៀបផ្ទឹមនឹងជីវិតរបស់ទេវតាព្រហ្មកាយិកៈ ។ សមដូចពាក្យនេះ ដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អាយុរបស់ពួកមនុស្សនេះតិច បរលោកពួកសត្វត្រូវទៅដោយពិត បុគ្គលគប្បីប៉ះពាល់ដោយបញ្ញា គប្បីធ្វើកុសល គប្បីប្រព្រឹត្តព្រហ្មចរិយៈ ( ព្រោះថា ) សត្វដែលកើតហើយ មិនមែនជាមិនស្លាប់ទេ ម្នាលភិក្ខុទាំងឡាយ បុគ្គលណារស់នៅអស់កាលយូរ បុគ្គលនោះគប្បីរស់នៅ ១០០ ឆ្នាំ តិចពី ១០០ ឆ្នាំ ឬច្រើនជាង ១០០ ឆ្នាំ ។

អាយុរបស់ពួកមនុស្សតិច បុរសល្អគប្បីនឿយណាយនឹង
អាយុនោះ គប្បីប្រព្រឹត្តដូចជាបុគ្គលដែលភ្លើងឆេះក្បាល
ដំណើរមិនមកនៃមច្ចុមិនមានទេ ថ្ងៃនិងយប់តែងកន្លងទៅ
ជីវិតក៏ស្រកស្រុតទៅដែរ អាយុរបស់ពួកសត្វរមែងអស់ទៅ

ដូចជាទឹកនៃស្មើងតូចទាំងឡាយ ។ ហេតុនេះ ( ទ្រង់ត្រាស់ថា ) ជីវិតនេះតិចណាស់ ។

[ ១៨៣ ] ពាក្យថា សត្វរមែងស្លាប់ខាងអាយអំពី ១០០ ឆ្នាំ អធិប្បាយថា សត្វរមែងច្យុត ស្លាប់ បាត់បង់ វិនាស ក្នុងកាលជាកលលៈក៏មាន ។ សត្វរមែងច្យុត ស្លាប់ បាត់បង់ វិនាស ក្នុងកាលជាអព្ពុទៈក៏មាន សត្វរមែងច្យុត ស្លាប់ បាត់បង់ វិនាស ក្នុងកាលជាបេសិក៏មាន ។ សត្វរមែងច្យុត ស្លាប់ បាត់បង់ វិនាស ក្នុងកាលជាឃនៈក៏មាន ។ សត្វរមែងច្យុត ស្លាប់ បាត់បង់ វិនាស ក្នុងកាលជាបញ្ចសាខាក៏មាន ។ សត្វគ្រាន់តែមាន កំណើត ច្យុត ស្លាប់ បាត់បង់ វិនាសទៅវិញក៏មាន ។ សត្វរមែងច្យុត ស្លាប់ បាត់បង់ វិនាស ក្នុងផ្ទះជាទីប្រសូតិក៏មាន ។ សត្វកើតបានកន្លះខែ ច្យុត ស្លាប់ បាត់បង់ វិនាសទៅវិញក៏មាន ។ សត្វកើតបានមួយខែ ច្យុត ស្លាប់ បាត់បង់ វិនាសទៅវិញក៏មាន ។ សត្វកើតបាន ២ ខែខ្លះ បាន ៣ ខែខ្លះ បាន ៤ ខែខ្លះ បាន ៥ ខែខ្លះ ច្យុត ស្លាប់ បាត់បង់ វិនាសទៅវិញក៏មាន ។ សត្វកើតបាន ៦ ខែខ្លះ ៧ ខែខ្លះ ៨ ខែខ្លះ ៩ ខែខ្លះ ១០ ខែខ្លះ ១ ឆ្នាំខ្លះ ច្យុត ស្លាប់ បាត់បង់ វិនាសទៅវិញក៏មាន ។ សត្វកើតបាន ២ ឆ្នាំខ្លះ ៣ ឆ្នាំខ្លះ ៤ ឆ្នាំខ្លះ ៥ ឆ្នាំខ្លះ ៦ ឆ្នាំខ្លះ ៧ ឆ្នាំខ្លះ ៨ ឆ្នាំខ្លះ ៩ ឆ្នាំខ្លះ ១០ ឆ្នាំខ្លះ ២០ ឆ្នាំខ្លះ ៣០ ឆ្នាំខ្លះ ៤០ ឆ្នាំខ្លះ ៥០ ឆ្នាំខ្លះ ៦០ ឆ្នាំខ្លះ ៧០ ឆ្នាំខ្លះ ៨០ ឆ្នាំខ្លះ ៩០ ឆ្នាំខ្លះ ច្យុត ស្លាប់ បាត់បង់ វិនាសទៅវិញក៏មាន ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលរមែងស្លាប់ខាងអាយអំពីមួយរយឆ្នាំ ។

[ ១៨៤ ] ពាក្យថា បើបុគ្គលណា រស់នៅកន្លងហួសទៅ គឺបុគ្គលណា រស់នៅកន្លងមួយរយឆ្នាំ បុគ្គលនោះ រស់នៅអស់ ១ ឆ្នាំក្តី រស់នៅអស់ ២ ឆ្នាំក្តី រស់នៅអស់ ៣ ឆ្នាំក្តី រស់នៅអស់ ៤ ឆ្នាំក្តី រស់នៅអស់ ៥ ឆ្នាំក្តី រស់នៅអស់ ១០ ឆ្នាំក្តី រស់នៅអស់ ២០ ឆ្នាំក្តី រស់នៅអស់ ៣០ ឆ្នាំក្តី រស់នៅអស់ ៤០ ឆ្នាំក្តី ហេតុនោះ ( ទ្រង់ត្រាស់ថា ) បើបុគ្គលណា រស់នៅកន្លងហួសទៅ ។

[ ១៨៥ ] ពាក្យថា បុគ្គលនោះ គង់ស្លាប់ ព្រោះជរាពុំខាន អធិប្បាយថា កាលណា បុគ្គលចាស់ ចម្រើនដោយវ័យ មានអាយុច្រើន កន្លងកាលជ្រុលចូលក្នុងបច្ឆិមវ័យ មានធ្មេញបាក់ សក់ស្កូវ ក្បាលធក ក្បាលថ្លែក ស្បែកជ្រួញជ្រីវ មានខ្លួនរទុះដោយប្រជ្រុយ ខ្នងកោងក្ងក់ កាន់ឈើច្រត់ បុគ្គលនោះ គង់ច្យុត ស្លាប់ បាត់បង់ វិនាស ព្រោះជរា ។

ការរួចចាកមរណៈមិនមានទេ សត្វទាំងឡាយដែលកើតហើយ តែងមានភ័យអំពីមរណៈជានិច្ច ដូចជាផ្លែឈើទុំទាំងឡាយ តែងមានភ័យអំពីការជ្រុះចុះ ក្នុងវេលាព្រឹក ភាជន៍ដីដែលកុម្ភការធ្វើហើយទាំងអស់ មានការបែកធ្លាយជាទីបំផុត យ៉ាងណា ជីវិតរបស់សត្វទាំងឡាយ ក៏យ៉ាងនោះដែរ ពួកជនណា ទាំងក្មេង ទាំងចាស់ ទាំងពាល ទាំងបណ្ឌិត ពួកជនទាំងអស់នោះ រមែងលុះអំណាចនៃមច្ចុ ពួកជនទាំងអស់ មានមច្ចុប្រព្រឹត្តទៅខាងមុខ កាលពួកជនទាំងនោះ ដែលមច្ចុគ្របសង្កត់ទៅ

កាន់បរលោក បិតាពឹងបុត្តមិនបាន ឬថាពួកញាតិពឹងពួកញាតិ
ក៏មិនបាន អ្នកចូរមើលចុះ កាលពួកញាតិកំពុងសម្លឹងមើល
កំពុងយំរៀបរាប់ច្រើន សត្វលោកដែលត្រូវមច្ចុនិងជរាបំផ្លាញ
ហើយ ដូចជាបណ្តាសត្វទាំងឡាយ គោមួយៗ ដែលគេត្រូវ
នាំទៅសម្លាប់ ។

ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលនោះគង់ស្លាប់ ព្រោះជរាពុំខាន ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ជីវិតនេះតិចណាស់ រមែងស្លាប់ខាងអាយ អំពីមួយរយឆ្នាំ បើ
បុគ្គលណា រស់នៅកន្លងហួស ( ពីមួយរយឆ្នាំ ) ទៅ
បុគ្គលនោះ គង់ស្លាប់ ព្រោះជរាពុំខាន ។

[ ១៨៦ ] ពួកជន រមែងសោកស្តាយចំពោះវត្ថុដែលហួងហែង ការហួងហែងទាំងឡាយ ពុំមែនជាការទៀងទាត់ទេ វត្ថុនេះ មានសភាពព្រាត់ប្រាសដោយពិត បុគ្គលកាលឃើញដូច្នេះហើយ មិនគួរនៅគ្រប់គ្រងផ្ទះឡើយ ។

[ ១៨៧ ] អធិប្បាយពាក្យថា ពួកជន រមែងសោកស្តាយចំពោះវត្ថុដែលហួងហែង ត្រង់ពាក្យថា ពួកជន បានដល់ ពួកក្សត្រ ព្រាហ្មណ៍ វេស្ស សុទ្ទៈ គ្រហស្ថ បព្វជិត ទេវតា មនុស្ស ។ ពាក្យថា ការហួងហែង បានដល់ការហួងហែង ២ គឺការហួងហែងគឺតណ្ហា ១ ការហួងហែងគឺទិដ្ឋិ ១ ។បេ។ នេះការហួងហែងគឺតណ្ហា ។បេ។ នេះការហួងហែងគឺទិដ្ឋិ ។ ពួកជនជាអ្នកមានសេចក្តីរង្កៀសដោយការដណ្តើមយកវត្ថុដោយហួងហែង រមែងសោកស្តាយក៏

មាន សោកស្តាយចំពោះវត្ថុដែលគេកំពុងដណ្តើមយកក៏មាន សោកស្តាយចំពោះវត្ថុដែលគេដណ្តើមយកហើយក៏មាន ពួកជនមានសេចក្តីរង្កៀសដោយការប្រែប្រួលចាកវត្ថុដែលហួងហែង រមែងសោកស្តាយក៏មាន សោកស្តាយចំពោះវត្ថុដែលកំពុងប្រែប្រួលក៏មាន សោកស្តាយចំពោះវត្ថុដែលប្រែប្រួលហើយក៏មាន រមែងលំបាក ខ្សឹកខ្សួល គក់ទ្រូង ដល់នូវការវង្វេង ហេតុនោះ ( ទ្រង់ត្រាស់ថា ) ពួកជន រមែងសោកស្តាយចំពោះវត្ថុដែលហួងហែង ។

[ ១៨៨ ] អធិប្បាយពាក្យថា ការហួងហែងទាំងឡាយ ពុំមែនជាការទៀងទាត់ទេ ត្រង់ពាក្យថា ការហួងហែង បានដល់ការហួងហែង ២ យ៉ាង គឺការហួងហែងគឺតណ្ហា ១ ការហួងហែងគឺទិដ្ឋិ ១ ។បេ។ នេះការហួងហែងគឺតណ្ហា ។បេ។ នេះការហួងហែងគឺទិដ្ឋិ ។ ការហួងហែងគឺតណ្ហា ជាសភាពមិនទៀង ដែលបច្ច័យតាក់តែងកើតឡើង ព្រោះអាស្រ័យ ( បច្ច័យ ) មានការអស់ទៅជាធម្មតា វិនាសទៅជាធម្មតា ប្រាសទៅជាធម្មតា រលត់ទៅជាធម្មតា ប្រែប្រួលទៅជាធម្មតា ។ ការហួងហែងគឺទិដ្ឋិ ជាសភាពមិនទៀង ដែលបច្ច័យតាក់តែងកើតឡើង ព្រោះអាស្រ័យ ( បច្ច័យ ) មានការអស់ទៅជាធម្មតា វិនាសទៅជាធម្មតា ប្រាសទៅជាធម្មតា រលត់ទៅជាធម្មតា ប្រែប្រួលទៅជាធម្មតា ។ សមដូចពាក្យនេះ ដែលព្រះមានព្រះភាគត្រាស់ហើយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយធ្លាប់ឃើញការហួងហែង ដែលជាសភាពទៀង មាំមួន ឋិតថេរ មិនប្រែប្រួលជាធម្មតា ឋិតនៅស្មើដោយសស្សតិវត្ថុ ដូច្នោះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ដំណើរនុ៎ះយើងខ្ញុំមិនធ្លាប់ឃើញទេ ។ ព្រះអង្គត្រាស់ថាម្នាល

ភិក្ខុទាំងឡាយ ប្រាប់ហើយ ម្នាលភិក្ខុទាំងឡាយ តថាគត ក៏ពិចារណាមិនឃើញនូវការហួងហែងនុ៎ះ ដែលជាសភាពទៀង មាំមួន ឋិតថេរ មិនប្រែប្រួលជាធម្មតា ឋិតនៅស្មើដោយសស្សតិវត្ថុ ដូច្នោះដែរ ។ ការហួងហែងទាំងឡាយជាសភាពទៀង មាំមួន ឋិតថេរ មិនប្រែប្រួលជាធម្មតាឥតមាន មិនដែលមាន មិនមានប្រាកដ មិនកើតមានទេ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ការហួងហែងទាំងឡាយពុំមែនជាការទៀងទាត់ទេ ។

[ ១៨៩ ] ពាក្យថា វត្ថុនេះ មានសភាពព្រាត់ប្រាសដោយពិត គឺភាវៈផ្សេងៗ ភាវៈព្រាត់ប្រាស ភាវៈទៅជាយ៉ាងដទៃ កាលមាន កាលកាន់ព្រម កាលកើតមាន ។ សមដូចពាក្យនេះ ដែលព្រះមានបុណ្យត្រាស់ហើយថា ម្នាលអានន្ទ មិនគួរទេ អ្នកកុំសោក កុំខ្សឹកខ្សួលឡើយ ម្នាលអានន្ទ ក្រែងតថាគតបានពោលហើយ ក្នុងកាលមុន នូវពាក្យនេះថា ភាវៈផ្សេងៗ ភាវៈព្រាត់ប្រាស ភាវៈជាយ៉ាងដទៃ ចាកសត្វនិងសង្ខារទាំងពួង ជាទីស្រឡាញ់ពេញចិត្តដូច្នេះឬ ម្នាលអានន្ទ បុគ្គលគប្បីបាននូវហេតុនោះក្នុងសត្វនិងសង្ខារទាំងនោះ អំពីទីណាថា វត្ថុណាកើតហើយ ប្រាកដហើយ តាក់តែងហើយ មានកិរិយាវិនាសជាធម្មតា ឱ្យវត្ថុនោះ កុំវិនាសឡើយ ដំណើរនោះមិនសមហេតុទេ ។ ព្រោះសេចក្តីប្រែប្រួលជាយ៉ាងដទៃរបស់ខន្ធ ធាតុ អាយតនៈ ដែលមានក្នុងកាលមុនៗ ខន្ធ ធាតុ អាយតនៈដែលមានក្នុងកាលខាងក្រោយៗ ក៏រមែងប្រព្រឹត្តទៅ ( ដូចគ្នា ) ហេតុនោះ ( ទ្រង់ត្រាស់ថា ) វត្ថុនេះ មានសភាពព្រាត់ប្រាសដោយពិត ។

[ ១៩០ ] អធិប្បាយពាក្យថា បុគ្គលឃើញដូច្នេះហើយ មិនគួរនៅគ្រប់គ្រងផ្ទះឡើយ ត្រង់ពាក្យថា ដូច្នេះ គឺជាពាក្យភ្ជាប់បទ ជាពាក្យជាប់ទាក់ទងដោយបទ ជាពាក្យញុំាងបទឲ្យពេញ ជាពាក្យប្រជុំដោយអក្ខរៈ ជាបទសម្រួលព្យញ្ជនៈ ពាក្យថា ដូច្នេះ នេះជាលំដាប់នៃបទ ។ បុគ្គលឃើញ យល់ ថ្លឹង ពិចារណា យល់ច្បាស់ ធ្វើឲ្យប្រាកដក្នុងវត្ថុដែលហួងហែង ដូច្នេះហើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលឃើញដូច្នេះហើយ ។ ពាក្យថា មិនគួរនៅគ្រប់គ្រងផ្ទះ គឺគប្បីកាត់បលិពោធក្នុងឃរាវាសគ្រប់យ៉ាង កាត់បលិពោធក្នុងបុត្តភរិយា កាត់បលិពោធក្នុងពួកញាតិ កាត់បលិពោធក្នុងមិត្តនិងអាមាត្យ កាត់បលិពោធក្នុងការសន្សំ ហើយកោរសក់និងពុកមាត់ ស្លៀកដណ្តប់សំពត់កាសាយៈ ( ចេញ ) ចាកផ្ទះ ហើយបួស ដោយភេទជាបុគ្គលមិនមានផ្ទះ ដល់នូវភាពមិនមានកង្វល់ ត្រាច់ទៅ នែបនៅ សម្រេចសម្រាន្ត ប្រព្រឹត្ត រក្សា សម្រួល រស់នៅតែម្នាក់ឯង ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលឃើញដូច្នេះហើយ មិនគួរនៅគ្រប់គ្រងផ្ទះឡើយ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

> ពួកជន រមែងសោកស្តាយចំពោះវត្ថុដែលហួងហែង ការហួង
> ហែងទាំងឡាយ ពុំមែនជាការទៀងទាត់ទេ វត្ថុនេះមានសភាព
> ព្រាត់ប្រាសដោយពិត បុគ្គលឃើញដូច្នេះហើយ មិនគួរនៅ
> គ្រប់គ្រងផ្ទះឡើយ ។

[ ១៩១ ] បុរសសម្គាល់នូវខន្ធបញ្ចកណាថា នេះរបស់អញ

ខន្ធបញ្ចកៈនោះ រមែងសាបសូន្យដោយមរណៈ បណ្ឌិតជាអ្នករាប់អាន ដឹងច្បាស់ដំណើរនុ៎ះហើយ មិនគប្បីបង្អោនទៅក្នុងសេចក្តីហួងហែងឡើយ ។

[ ១៩២ ] អធិប្បាយពាក្យថា ខន្ធបញ្ចកៈនោះ រមែងសាបសូន្យដោយមរណៈ ត្រង់ពាក្យថា មរណៈ បានដល់ការច្យុតិ ការឃ្លាត ការបែកធ្លាយ ការបាត់បង់ មច្ចុ មរណៈ កាលកិរិយា ការបែកធ្លាយខន្ធ ការដាក់ចោលសាកសព ការផ្តាច់បង់ជីវិតិន្ទ្រិយចាកសត្តនិកាយនោះៗ របស់សត្វទាំងឡាយនោះៗ ។ ពាក្យថា ខន្ធបញ្ចកៈនោះ គឺ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ។ ពាក្យថា សាបសូន្យ គឺសាបសូន្យ លះបង់ បោះបង់ បាត់ទៅ វិនាសទៅ ។ សមដូចភាសិតនេះថា

ភោគៈទាំងឡាយ រមែងលះបង់នូវសត្វក្នុងកាលមុនក៏មាន សត្វលះបង់ភោគៈទាំងនោះ មុនជាងទៅទៀតក៏មាន នែអ្នកប្រាថ្នាកាម ពួកជនអ្នកមានភោគៈមិនទៀងទេ ព្រោះហេតុនោះ ទើបខ្ញុំមិនសោកស្តាយ ក្នុងកាលដែលគួរសោកស្តាយ ព្រះចន្ទរះឡើងពេញវង់លិចទៅ ព្រះអាទិត្យរះឡើងហើយអស្តង្គតទៅ នែអ្នកជាសត្រូវ លោកធម៌ទាំងឡាយ ខ្ញុំដឹងច្បាស់ហើយ ព្រោះហេតុនោះ ខ្ញុំទើបមិនសោកស្តាយ ក្នុងកាលដែលគួរសោកស្តាយ ។

ហេតុនោះ ( ទ្រង់ត្រាស់ថា ) ខន្ធបញ្ចកៈរមែងសាបសូន្យដោយមរណៈ ។

[ ១៩៣ ] អធិប្បាយពាក្យថា បុរសសម្គាល់នូវខន្ធបញ្ចកៈណាថា នេះរបស់អញ ត្រង់ពាក្យថា ខន្ធបញ្ចកៈណា គឺ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ។ ពាក្យថា បុរស គឺការរាប់ ឈ្មោះ បញ្ញត្តិ លោកវោហារ នាម អំពើរបស់នាម ពាក្យទ្រទ្រង់ទុកនូវនាម ភាសា ព្យញ្ជនៈ ការហៅរក ។ ពាក្យថា សម្គាល់ថា នេះរបស់អញ គឺសម្គាល់ក្នុងការសម្គាល់ដោយតណ្ហា សម្គាល់ក្នុងការសម្គាល់ដោយទិដ្ឋិ សម្គាល់ក្នុងការសម្គាល់ដោយមានះ សម្គាល់ក្នុងការសម្គាល់ដោយកិលេស សម្គាល់ក្នុងការសម្គាល់ដោយទុច្ចរិត សម្គាល់ក្នុងការសម្គាល់ដោយបយោគៈ សម្គាល់ក្នុងការសម្គាល់ដោយវិបាក ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុរសសម្គាល់ខន្ធបញ្ចកៈណាថា នេះរបស់អញ ។

[ ១៩៤ ] ពាក្យថា បណ្ឌិតដឹងច្បាស់ដំណើរនុ៎ះ គឺ ដឹង ស្គាល់ ថ្លឹង ត្រិះរិះ ពិចារណា ឈ្វេងយល់ ធ្វើឲ្យប្រាកដនូវទោសនុ៎ះ ក្នុងវត្ថុដែលហួងហែងទាំងឡាយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ដឹងច្បាស់ដំណើរនុ៎ះ ។ ពាក្យថា បណ្ឌិត គឺអ្នកមានប្រាជ្ញា មានញាណ មានបញ្ញាភ្លឺច្បាស់ មានបញ្ញាធ្លុះធ្លាយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បណ្ឌិតដឹងច្បាស់ដំណើរនុ៎ះ ។

[ ១៩៥ ] អធិប្បាយពាក្យថា ជាអ្នករាប់អាន មិនគប្បីបង្អោនទៅក្នុងសេចក្តីហួងហែងឡើយ ត្រង់ពាក្យថា សេចក្តីហួងហែង បានដល់សេចក្តីហួងហែង ២ គឺសេចក្តីហួងហែងគឺតណ្ហា ១ សេចក្តីហួងហែងគឺទិដ្ឋិ ១ ។បេ។ នេះសេចក្តីហួងហែងគឺតណ្ហា ។បេ។ នេះសេចក្តីហួងហែងគឺទិដ្ឋិ ។ ពាក្យថា អ្នករាប់អាន គឺអ្នករាប់អានព្រះពុទ្ធ អ្នករាប់អានព្រះធម៌ អ្នករាប់អានព្រះសង្ឃ

បុគ្គលនោះ តែងរាប់អានព្រះមានព្រះភាគ ព្រះមានព្រះភាគក៏ទ្រង់រាប់អានបុគ្គលនោះ ។ សមដូចពាក្យនេះ ដែលព្រះមានព្រះភាគត្រាស់ហើយថា ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុណា ជាអ្នកកុហក មានចិត្តរឹងត្អឹង ចរចាហួសហេតុ មានការជាប់ចំពាក់ ជាអ្នកឆ្មើងឆ្មៃ មានចិត្តមិនតាំងមាំ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុទាំងនោះ មិនមែនរាប់អានតថាគតទេ មួយទៀត ភិក្ខុទាំងនោះ ប្រាសចាកធម៌វិន័យនេះហើយ ភិក្ខុទាំងនោះមិនដល់នូវការចម្រើន លូតលាស់ ធំទូលាយ ក្នុងធម៌វិន័យនេះទេ ម្នាលភិក្ខុទាំងឡាយ លុះតែពួកភិក្ខុណា មិនកុហក មិនចរចាហួសហេតុ មានប្រាជ្ញាខ្ជាប់ខ្ជួន មិនរឹងត្អឹង មានចិត្តតាំងមាំល្អ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះឯង ឈ្មោះថា អ្នករាប់អានតថាគត មួយទៀត ភិក្ខុទាំងនោះ មិនប្រាសចាកធម៌វិន័យនេះទេ ភិក្ខុទាំងនោះ ដល់នូវសេចក្តីចម្រើន លូតលាស់ ធំទូលាយក្នុងធម៌វិន័យនេះ ។

> ពួកភិក្ខុណា ជាអ្នកកុហក រឹងត្អឹង ចរចារហួសហេតុ មានការ
> ជាប់ចំពាក់ ឆ្មើងឆ្មៃ មានចិត្តមិនតាំងមាំ ភិក្ខុទាំងនោះ មិន
> លូតលាស់ក្នុងធម៌ដែលព្រះសម្មាសម្ពុទ្ធសម្តែងទេ ពួកភិក្ខុ
> ណា ជាអ្នកមិនកុហក មិនចរចាហួសហេតុ មានប្រាជ្ញាខ្ជាប់
> ខ្ជួន មិនរឹងត្អឹង មានចិត្តតាំងមាំល្អ ភិក្ខុទាំងនោះ ទើបលូត
> លាស់ក្នុងធម៌ដែលព្រះសម្មាសម្ពុទ្ធសម្តែងហើយ ។

ពាក្យថា បណ្ឌិតជាអ្នករាប់អាន មិនគប្បីបង្អោនទៅ ក្នុងសេចក្តីហួងហែង បានសេចក្តីថា បុគ្គលអ្នករាប់អាន ( ព្រះរតនត្រៃ ) គប្បីលះបង់សេចក្តីហួង

*ហែងគឺតណ្ហា រលាស់ចោលសេចក្តីហួងហែងគឺទិដ្ឋិ ហើយមិនបង្អោនទៅ មិនបន្ទន់ទៅក្នុងសេចក្តីហួងហែង ជាអ្នកមិនឱនទៅរកសេចក្តីហួងហែងនោះ មិនងាកទៅរកសេចក្តីហួងហែងនោះ មិនឈមទៅរកសេចក្តីហួងហែងនោះ មិនចុះចិត្តស៊ប់ទៅរកសេចក្តីហួងហែងនោះ មិនយកសេចក្តីហួងហែងនោះជាធំ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បណ្ឌិតជាអ្នករាប់អាន មិនគប្បីបង្អោនទៅក្នុងសេចក្តីហួងហែង ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា*

> *បុរសសម្គាល់ខន្ធបញ្ចកៈណាថា នេះរបស់អញ ខន្ធបញ្ចកៈនោះ រមែងសាបសូន្យដោយមរណៈ បណ្ឌិតជាអ្នករាប់អាន ដឹងច្បាស់ដំណើរនុ៎ះហើយ មិនគប្បីបង្អោនទៅក្នុងសេចក្តីហួងហែងឡើយ ។*

*[ ១៩៦ ] បុរសភ្ញាក់ឡើងហើយ មិនឃើញអារម្មណ៍ដែលជួបប្រទះដោយការយល់សប្តិ យ៉ាងណា បុគ្គលមិនឃើញជនជាទីស្រឡាញ់ ដែលធ្វើមរណៈកាលទៅកាន់បរលោកហើយ ក៏យ៉ាងនោះដែរ ។*

*[ ១៩៧ ] ពាក្យថា អារម្មណ៍ដែលជួបប្រទះដោយការយល់សប្តិ យ៉ាងណា គឺជួបប្រទះ កប់ប្រសប់ រួមគ្នា ជួបជុំគ្នា ហេតុនោះ ( ទ្រង់ត្រាស់ថា ) អារម្មណ៍ដែលជួបប្រទះ ដោយការយល់សប្តិ យ៉ាងណា ។*

*[ ១៩៨ ] ពាក្យថា បុរសភ្ញាក់ឡើងហើយមិនឃើញ សេចក្តីថា បុរសអ្នកយល់សប្តិឃើញព្រះចន្ទ ឃើញព្រះអាទិត្យ ឃើញមហាសមុទ្រ ឃើញស្តេចភ្នំសិនេរុ ឃើញដំរី ឃើញសេះ ឃើញរថ ឃើញពលថ្មើរជើង ឃើញ*

សេនាព្យូហៈ ឃើញសួនច្បារជាទីត្រេកអរ ឃើញព្រៃជាទីត្រេកអរ ឃើញផែនដីជាទីត្រេកអរ ឃើញស្រះបោក្ខរណីជាទីត្រេកអរ ភ្ញាក់ឡើងហើយ ក៏មិនឃើញអ្វីសោះ យ៉ាងណា ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុរសភ្ញាក់ឡើងហើយមិនឃើញ ។

[ ១៩៩ ] ពាក្យថា ក៏យ៉ាងនោះដែរ របស់បទថា ជនជាទីស្រឡាញ់ ក៏យ៉ាងនោះដែរ គឺជាវាចាផ្ដល់ដោយសេចក្ដីឧបមា ។ ពាក្យថា ជនជាទីស្រឡាញ់ គឺជនដែលស្រឡាញ់ ដែលរាប់អាន ទោះជាមាតាក្ដី បិតាក្ដី បងប្អូនប្រុសក្ដី បងប្អូនស្រីក្ដី បុត្តក្ដី ធីតាក្ដី មិត្តក្ដី អាមាត្យ ញាតិសាលោហិតក្ដី ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជនជាទីស្រឡាញ់ ក៏យ៉ាងនោះដែរ ។

[ ២០០ ] ពាក្យថា បុគ្គលមិនឃើញជន ដែលធ្វើមរណកាលទៅកាន់បរលោកហើយ សេចក្ដីថា ពួកជនស្លាប់ ធ្វើមរណកាលហើយ លោកហៅថា អ្នកទៅកាន់បរលោក ។ បុគ្គលមិនឃើញ មិនជួប មិនប្រទះ មិនបាន ឥតបាន ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនឃើញជន ដែលធ្វើមរណកាលទៅកាន់បរលោកហើយ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

បុរសភ្ញាក់ឡើងហើយ មិនឃើញអារម្មណ៍ដែលជួបប្រទះ
ដោយការយល់សប្តិ យ៉ាងណា បុគ្គលមិនឃើញជនជាទី
ស្រឡាញ់ ដែលធ្វើមរណកាលទៅកាន់បរលោកហើយ ក៏
យ៉ាងនោះដែរ ។

[ ២០១ ] នាមនេះរបស់ពួកជនណា ដែលគេតែងពោល

ពួកជននោះ គេឃើញខ្លះ ឮខ្លះ នាមហ្នឹងឯងរបស់សត្វទៅកាន់បរលោកដែលគេគួរហៅបាន រមែងសល់នៅ ។

[ ២០២ ] អធិប្បាយពាក្យថា ពួកជននោះ គេឃើញខ្លះ ឮខ្លះ ត្រង់ពាក្យថា គេឃើញ គឺពួកជនណា ដែលជួបប្រទះដោយចក្ខុវិញ្ញាណ ។ ពាក្យថា ឮ គឺពួកជនណា ដែលជួបប្រទះដោយសោតវិញ្ញាណ ។ ពាក្យថា ពួកជននោះ គឺក្សត្រ ព្រាហ្មណ៍ វេស្សៈ សុទ្ទៈ គ្រហស្ថ បព្វជិត ទេវតានិងមនុស្ស ហេតុនោះ ( ទ្រង់ត្រាស់ថា ) ពួកជននោះ គេឃើញខ្លះ ឮខ្លះ ។

[ ២០៣ ] អធិប្បាយពាក្យថា នាមនេះ របស់ពួកជនណា ដែលគេតែងពោល ត្រង់ពាក្យថា របស់ពួកជនណា គឺរបស់ពួកក្សត្រ ព្រាហ្មណ៍ វេស្សៈ សុទ្ទៈ គ្រហស្ថ បព្វជិត ទេវតា មនុស្សណា ។ ពាក្យថា នាម គឺការរាប់ឈ្មោះ បញ្ញត្ត លោកវោហារ នាម អំពើរបស់នាម ពាក្យទ្រទ្រង់នូវនាម ភាសា ព្យញ្ជនៈ ការហៅរក ។ ពាក្យថា គេតែងពោល គឺគេតែងសម្ដែង តែងនិយាយ តែងបំភ្លឺ តែងបញ្ចេញ ហេតុនោះ ( ទ្រង់ត្រាស់ថា ) នាមនេះ របស់ពួកជនណា ដែលគេតែងពោល ។

[ ២០៤ ] ពាក្យថា នាមហ្នឹងឯងដែលគួរហៅបាន រមែងសល់នៅ សេចក្ដីថា រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ដែលឃ្លាតចេញ លះចេញស្រឡះ បាត់បង់ វិនាស តែនាមរមែងសល់នៅ ។ ពាក្យថា គួរហៅបាន គឺគួរពោល សម្ដែង បំភ្លឺ បញ្ចេញបាន ហេតុនោះ ( ទ្រង់ត្រាស់ថា ) នាមហ្នឹងឯង ដែលគួរហៅបាន រមែងសល់នៅ ។ ពាក្យថា ទៅកាន់បរលោករបស់បទថា របស់

សត្វទៅកាន់បរលោក គឺសត្វស្លាប់ ធ្វើមរណកាលហើយ ។ ពាក្យថា របស់សត្វ គឺរបស់សត្វ នរៈ មាណព បុរស បុគ្គល សត្វមានជីវៈ សត្វមានជាតិ សត្វមានជរា សត្វទៅដោយឥន្ទ្រិយ សត្វមានជាតិអំពីមនុស្ស ហេតុនោះ ( ទ្រង់ត្រាស់ថា ) របស់សត្វទៅកាន់បរលោក ដែលគួរហៅបាន ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

នាមនេះ របស់ពួកជនណា ដែលគេតែងពោល ពួកជននោះ
គេឃើញខ្លះ ឮខ្លះ នាមហ្នឹងឯងរបស់សត្វទៅកាន់បរលោក
ដែលគេគួរហៅបាន រមែងសល់នៅ ។

[ ២០៥ ] ពួកជនអ្នកប្រាថ្នា រមែងមិនលះបង់នូវសេចក្តីសោក សេចក្តីខ្សឹកខ្សួលនិងសេចក្តីកំណាញ់ ក្នុងវត្ថុដែលហួងហែង ព្រោះហេតុនោះ មុនិទាំងឡាយជាអ្នកឃើញសេចក្តីក្សេម បានប្រព្រឹត្តលះបង់សេចក្តីហួងហែងចេញ ។

[ ២០៦ ] អធិប្បាយពាក្យថា ពួកជនអ្នកប្រាថ្នា រមែងមិនលះបង់សេចក្តីសោក សេចក្តីខ្សឹកខ្សួលនិងសេចក្តីកំណាញ់ក្នុងវត្ថុដែលហួងហែង ត្រង់ពាក្យថា សេចក្តីសោក គឺការសោក ការសោកស្តាយ ភាពនៃចិត្តសោកស្តាយ សោកខាងក្នុង ស្តាយស្រណោះខាងក្នុង ក្តៅក្រហាយខាងក្នុង ក្តៅរោលរាលខាងក្នុង ជ្រប់ ស្រពោនចិត្ត ទោមនស្ស សរ គឺសោករបស់សត្វដែលត្រូវសេចក្តីវិនាសញាតិប៉ះពាល់ក្តី សេចក្តីវិនាសភោគៈប៉ះពាល់ក្តី សេចក្តីវិនាសគឺរោគប៉ះពាល់ក្តី សេចក្តីវិនាសសីលប៉ះពាល់ក្តី សេចក្តីវិនាសទិដ្ឋិប៉ះពាល់ក្តី ប្រកបដោយសេចក្តីវិនាសណាមួយក្តី ទុក្ខធម៌ណាមួយប៉ះពាល់ក្តី ។ ពាក្យថា

*សេចក្តីខ្សឹកខ្សួលគឺការយំ ការយំរៀបរាប់ អាការយំ អាការយំរៀបរាប់ ភាពនៃការយំ ភាពនៃការយំរៀបរាប់ ការនិយាយ ការពោលឥតប្រយោជន៍ ការពោលរវើរវាយ ការពោលរឿយៗ អាការជាទីពោលរឿយៗ ភាពនៃការពោលរឿយៗ របស់សត្វដែលត្រូវសេចក្តីវិនាសញាតិប៉ះពាល់ក្តី ។បេ។ សេចក្តីវិនាសទិដ្ឋិប៉ះពាល់ក្តី ប្រកបដោយសេចក្តីវិនាសណាមួយក្តី ទុក្ខធម៌ណាមួយប៉ះពាល់ក្តី ។ ពាក្យថា សេចក្តីកំណាញ់ បានដល់សេចក្តីកំណាញ់ ៥ យ៉ាង គឺសេចក្តីកំណាញ់អាវាស ១ សេចក្តីកំណាញ់ត្រកូល ១ សេចក្តីកំណាញ់លាភ ១ សេចក្តីកំណាញ់វណ្ណៈ ១ សេចក្តីកំណាញ់ធម៌ ១ សេចក្តីកំណាញ់ អាការកំណាញ់ ភាពនៃការកំណាញ់ សេចក្តីប្រាថ្នាផ្សេងៗ ស្ទួកទ្រឹះ ភាពនៃចិត្តរួញ ភាពនៃការមិនយកចិត្តគេណា មានសភាពយ៉ាងនេះ នេះហៅថា សេចក្តីកំណាញ់ ។ មួយទៀត សេចក្តីកំណាញ់ខន្ធ ក៏ឈ្មោះថាសេចក្តីកំណាញ់ សេចក្តីកំណាញ់ធាតុ ក៏ឈ្មោះថាសេចក្តីកំណាញ់ សេចក្តីកំណាញ់អាយតនៈ ក៏ឈ្មោះថាសេចក្តីកំណាញ់ ការគិតតែកាន់យក នេះលោកហៅថា សេចក្តីកំណាញ់ ។ តណ្ហា លោកហៅថា ការចង់បាន បានដល់តម្រេក តម្រេកខ្លាំង ។បេ។ ការសំឡឹងរំពៃ លោភ អកុសលមូល ។ ពាក្យថា ការហួងហែង បានដល់ការហួងហែងពីរគឺ ការហួងហែងគឺតណ្ហា ១ ការហួងហែងគឺទិដ្ឋិ ១ ។បេ។ នេះការហួងហែងគឺតណ្ហា ។បេ។ នេះការហួងហែងគឺទិដ្ឋិ ។ ពួកជនមានសេចក្តីរង្កៀសដោយការដណ្តើមយកវត្ថុដែលហួងហែង សោកស្តាយក៏មាន សោកស្តាយវត្ថុដែលគេកំពុងដណ្តើមយកក៏មាន សោកស្តាយវត្ថុដែល*

គេដណ្តើមយកហើយក៏មាន ពួកជនមានសេចក្តីរង្កៀសដោយការប្រែប្រួលនៃវត្ថុដែលហួងហែង រមែងសោកស្តាយក៏មាន សោកស្តាយវត្ថុដែលកំពុងប្រែប្រួលក៏មាន សោកស្តាយវត្ថុដែលប្រែប្រួលហើយក៏មាន ។ អ្នកមានសេចក្តីរង្កៀសដោយការដណ្តើមយកវត្ថុដែលហួងហែងខ្សឹកខ្សួលក៏មាន ខ្សឹកខ្សួលនឹងវត្ថុដែលគេកំពុងដណ្តើមយកក៏មាន ខ្សឹកខ្សួលនឹងវត្ថុដែលគេដណ្តើមយកហើយក៏មាន អ្នកមានសេចក្តីរង្កៀសដោយការប្រែប្រួលនៃវត្ថុដែលហួងហែងខ្សឹកខ្សួលក៏មាន ខ្សឹកខ្សួលនឹងវត្ថុដែលកំពុងប្រែប្រួលក៏មាន ខ្សឹកខ្សួលនឹងវត្ថុដែលប្រែប្រួលហើយក៏មាន ។ ពួកជនរមែងរក្សា គ្រប់គ្រង ក្តួចកាន់ ហួងហែងកំណាញ់វត្ថុដែលហួងហែង ។ ពួកជនរមែងសោកស្តាយវត្ថុដែលហួងហែងមិនលះបង់សេចក្តីសោក មិនលះបង់សេចក្តីខ្សឹកខ្សួល មិនលះបង់សេចក្តីកំណាញ់ មិនលះបង់ មិនលះបោល មិនបន្ទោបង់ មិនធ្វើឲ្យវិនាស មិនធ្វើឲ្យដល់នូវការមិនកើតមានសេចក្តីប្រាថ្នា ហេតុនោះ ( ទ្រង់ត្រាសថា ) ពួកជនអ្នកប្រាថ្នា រមែងមិនលះបង់នូវសេចក្តីសោក សេចក្តីខ្សឹកខ្សួលនិងសេចក្តីកំណាញ់ក្នុងវត្ថុដែលហួងហែង ។

[ ២០៧ ] អធិប្បាយពាក្យថា ព្រោះហេតុនោះ មុនិទាំងឡាយជាអ្នកឃើញសេចក្តីក្សេម បានប្រព្រឹត្តលះបង់សេចក្តីហួងហែងចេញ ត្រង់ពាក្យថា ព្រោះហេតុនោះ គឺព្រោះដូច្នោះ ព្រោះដំណើរនោះ ព្រោះហេតុនោះ ព្រោះបច្ច័យនោះ ព្រោះនិទាននោះ មុនិកាលឃើញច្បាស់នូវទោសទុំះ ក្នុងវត្ថុដែលហួងហែងទាំងឡាយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ព្រោះហេតុនោះ ។ ពាក្យ

ថា មុនិទាំងឡាយ សេចក្តីថា ញាណ ហៅថា មោនៈ បានខាងប្រាជ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ សេចក្តីយល់ឃើញត្រូវ មុនិទាំងឡាយ ប្រកបដោយញាណនោះ ដល់ហើយនូវការដឹង ។ មោនេយ្យៈ មាន ៣ គឺកាយមោនេយ្យៈ វចីមោនេយ្យៈ មនោមោនេយ្យៈ ។បេ។ បុគ្គលណាកន្លងបង់បណ្តាញគឺគ្រឿងជាប់ចំពាក់ បុគ្គលនោះហៅថា មុនិ ។ ពាក្យថា សេចក្តីប្រកាន់ បានដល់ សេចក្តីប្រកាន់ ២ គឺសេចក្តីប្រកាន់គឺតណ្ហា ១ សេចក្តីប្រកាន់គឺទិដ្ឋិ ១ ។បេ។ នេះសេចក្តីប្រកាន់គឺតណ្ហា ។បេ។ នេះសេចក្តីប្រកាន់គឺទិដ្ឋិ ។ មុនិទាំងឡាយ លះបង់សេចក្តីប្រកាន់គឺតណ្ហា វលាស់ចោលសេចក្តីប្រកាន់គឺទិដ្ឋិ បានវង្កាត់ទៅ គ្រាច់ទៅ ដើរទៅ សម្រេច ប្រព្រឹត្ត រក្សា ចិញ្ចឹម ទំនុកបម្រុង ។ ពាក្យថា អ្នកឃើញសេចក្តីក្សេម សេចក្តីថា អមតនិព្វាន លោកហៅថា សេចក្តីក្សេម បានខាងការរម្ងាប់សង្ខារទាំងពួង ការរលាស់ចេញនូវឧបធិទាំងពួង ការអស់ទៅនៃតណ្ហា សេចក្តីនឿយណាយ សេចក្តីរលត់ ព្រះនិព្វាន ។ ពាក្យថា អ្នកឃើញសេចក្តីក្សេម បានសេចក្តីថា អ្នកឃើញសេចក្តីក្សេម អ្នកឃើញទីជ្រកកោន អ្នកឃើញទីពឹងពួន អ្នកឃើញទីពឹង អ្នកឃើញទីមិនមានភ័យ អ្នកឃើញទីមិនច្យុត អ្នកឃើញអមតៈ អ្នកឃើញព្រះនិព្វាន ហេតុនោះ ( ទ្រង់ត្រាស់ថា ) ព្រោះហេតុនោះ មុនិទាំងឡាយជាអ្នកឃើញសេចក្តីក្សេម បានប្រព្រឹត្តលះបង់សេចក្តីប្រកាន់ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ពួកអ្នកប្រាជ្ញា រមែងមិនលះបង់នូវសេចក្តីសោក សេចក្តីខ្សឹក

ខ្យល់និងសេចក្ដីកំណាញ់ ក្នុងវត្ថុដែលហួងហែង ព្រោះហេតុនោះ មុនិទាំងឡាយ ជាអ្នកឃើញសេចក្ដីក្សេម បានប្រព្រឹត្តលះបង់សេចក្ដីហួងហែងចេញ ។

[ ២០៨ ] អ្នកប្រាជ្ញទាំងឡាយ ពោលអំពើនោះ ថាជាសាមគ្គីរបស់ភិក្ខុអ្នកប្រព្រឹត្តរួញថយ គប់រកអាសនៈស្ងាត់ដែលមិនបង្ហាញខ្លួនក្នុងទីកើត ។

[ ២០៩ ] ពាក្យថា របស់ភិក្ខុអ្នកប្រព្រឹត្តរួញថយ អធិប្បាយថា សេក្ខបុគ្គល ៧ លោកហៅថាអ្នកប្រព្រឹត្តរួញថយ ឯព្រះអរហន្ត ជាអ្នកប្រព្រឹត្តរួញថយហើយ ។ សេក្ខបុគ្គល ៧ ពួក លោកហៅថា អ្នកប្រព្រឹត្តរួញថយព្រោះហេតុអ្វី ។ សេក្ខបុគ្គល ៧ ពួកនោះ ញុំាងចិត្តឲ្យរួញថយ ឲ្យខ្វារ ឲ្យវិលវិញ អំពីអារម្មណ៍នោះៗ ខ្ទប់ សង្កត់សង្កិន រារាំង រក្សា គ្រប់គ្រង ត្រាច់ទៅ សម្រេចឥរិយាបថ សម្រាន្តចិត្ត ប្រព្រឹត្តទៅ រក្សា ចិញ្ចឹម ទំនុកបម្រុង ។ សេក្ខបុគ្គលទាំងនោះ ញុំាងចិត្តក្នុងចក្ខុទ្វារឲ្យរួញថយ ឲ្យខ្វារ ឲ្យវិលវិញ ខ្ទប់ សង្កត់សង្កិន រារាំង រក្សា គ្រប់គ្រង ត្រាច់ទៅ សម្រេចឥរិយាបថ សម្រាន្តចិត្ត ប្រព្រឹត្តទៅ រក្សា ចិញ្ចឹម ទំនុកបម្រុង ។ ញុំាងចិត្តក្នុងសោតទ្វារ ញុំាងចិត្តក្នុងឃានទ្វារ ញុំាងចិត្តក្នុងជិវ្ហាទ្វារ ញុំាងចិត្តក្នុងកាយទ្វារ ញុំាងចិត្តក្នុងមនោទ្វារ ឲ្យរួញថយ ឲ្យខ្វារ ឲ្យវិលវិញ ខ្ទប់ សង្កត់សង្កិន រារាំង រក្សា គ្រប់គ្រង ត្រាច់ទៅ សម្រេចឥរិយាបថ សម្រាន្តចិត្ត ប្រព្រឹត្តទៅ រក្សា ចិញ្ចឹម ទំនុកបម្រុង ។ ស្លាបមាន់ ឬទងសរសៃដែលគេដាក់ក្នុងភ្លើង រមែងរួញខ្វារ

វិលវិញ មិនលា យ៉ាងណាមិញ សេក្ខបុគ្គលទាំងនោះ ញុំាងចិត្តឲ្យរួញថយ ឲ្យខ្ទួរ ឲ្យវិលវិញ អំពីអារម្មណ៍នោះៗ ខ្ទប់ សង្កត់សង្កិន រារាំង រក្សា គ្រប់គ្រង ត្រាច់ទៅ សម្រេចឥរិយាបថ សម្រាន្ត ចិត្តប្រព្រឹត្តទៅ រក្សា ចិញ្ចឹម ទំនុកបម្រុង ក៏យ៉ាងនោះដែរ ញុំាងចិត្តក្នុងចក្ខុទ្វារ ញុំាងចិត្តក្នុងសោតទ្វារ ញុំាងចិត្តក្នុងឃានទ្វារ ញុំាងចិត្តក្នុងជិវ្ហាទ្វារ ញុំាងចិត្តក្នុងកាយទ្វារ ញុំាងចិត្តក្នុងមនោទ្វារ ឲ្យរួញថយ ឲ្យខ្ទួរ ឲ្យវិលវិញ ខ្ទប់ សង្កត់សង្កិន រារាំង រក្សា គ្រប់គ្រង ត្រាច់ទៅ សម្រេចឥរិយាបថ សម្រាន្តចិត្ត ប្រព្រឹត្ត រក្សា ចិញ្ចឹម ទំនុកបម្រុង ។ ព្រោះហេតុនោះ សេក្ខបុគ្គល ៧ ពួក លោកហៅថា អ្នកប្រព្រឹត្តរួញថយ ។ ពាក្យថា របស់ភិក្ខុ គឺរបស់ភិក្ខុជាកល្យាណបុថុជ្ជនក្តី ភិក្ខុជាសេក្ខៈក្តី ហេតុនោះ ( ទ្រង់ត្រាស់ថា ) របស់ភិក្ខុអ្នកប្រព្រឹត្តរួញថយ ។

[ ២១០ ] ពាក្យថា គប់រកអាសនៈស្ងាត់ សេចក្តីថា ភិក្ខុអង្គុយក្នុងទីណា ទីនោះលោកហៅថាអាសនៈ គឺគ្រែ តាំង ពូក កន្ទេល ចម្ការណ្ឌ កម្រាលស្មៅ កម្រាលស្លឹកឈើ កម្រាលចំបើង ។ អាសនៈនោះ ជាទីស្ងាត់ ស្ងាត់ច្រៀប ស្ងាត់ឈឹង ចាកការឃើញរូបមិនជាទីសប្បាយ ស្ងាត់ ស្ងាត់ច្រៀប ស្ងាត់ឈឹង ចាកការឮសំឡេងមិនជាទីសប្បាយ ស្ងាត់ ស្ងាត់ច្រៀប ស្ងាត់ឈឹង ចាកការធុំក្លិនមិនជាទីសប្បាយ ចាកការលិទ្ធភក្សរសមិនជាទីសប្បាយ ចាកការពាល់ត្រូវផ្សព្វមិនជាទីសប្បាយ ចាកកាមគុណទាំង ៥ មិនជាទីសប្បាយ ។ កាលគប់រក គប់ប្រសប់ សេពគប់ អាស្រ័យ ចូលចិត្ត ផ្តេកផ្តិត ចំពោះអាសនៈនោះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) គប់រកអាសនៈស្ងាត់ ។

[ ២១១ ] អធិប្បាយពាក្យថា អ្នកប្រាជ្ញទាំងឡាយពោលអំពើនោះថា ជាសាមគ្គីរបស់ភិក្ខុ ដែលមិនបង្ហាញខ្លួនក្នុងទីកើត ត្រង់ពាក្យថា សាមគ្គី បានដល់សាមគ្គី ៣ យ៉ាង គឺគណសាមគ្គី ធម្មសាមគ្គី អនភិនិព្វត្តិសាមគ្គី ។

គណសាមគ្គី តើដូចម្តេច ។ បើភិក្ខុទាំងឡាយច្រើនរូបព្រមព្រៀងគ្នា មានសេចក្តីស្មោះសរនឹងគ្នា មិនទាស់ទែងគ្នា មានសភាពហាក់ដូចទឹកដែលលាយដោយទឹកដោះស្រស់ សម្លឹងមើលគ្នានឹងគ្នា ដោយចក្ខុជាទីស្រឡាញ់ នេះឈ្មោះថា គណសាមគ្គី ។

ធម្មសាមគ្គី តើដូចម្តេច ។ សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពល ៥ ពោជ្ឈង្គ ៧ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ធម៌ទាំងនោះ រមែងលឿនទៅ ថ្លាស្អាត តាំងនៅល្អ រួចស្រឡះក្នុងទីជាមួយគ្នា ការជជែក ការទាស់ទែងនៃធម៌ទាំងនោះរមែងមិនមាន នេះឈ្មោះថា ធម្មសាមគ្គី ។

អនភិនិព្វត្តិសាមគ្គី តើដូចម្តេច ។ បើភិក្ខុទាំងឡាយច្រើនរូប បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ការខ្វះខាត ឬការពេញក្នុងនិព្វានធាតុនៃភិក្ខុទាំងនោះក៏មិនប្រាកដ នេះឈ្មោះថា អនភិនិព្វត្តិសាមគ្គី ។

ពាក្យថា ក្នុងទីកើត គឺនរកជាទីកើតរបស់ពួកសត្វនរក កំណើតតិរច្ឆានជាទីកើតរបស់ពួកសត្វក្នុងកំណើតតិរច្ឆាន បិត្តិវិស័យជាទីកើតរបស់ពួកសត្វក្នុងបិត្តិវិស័យ មនុស្សលោកជាទីកើតរបស់ពួកមនុស្ស ទេវលោកជាទីកើតរបស់ពួកទេវតា ។ ពាក្យថា អ្នកប្រាជ្ញទាំងឡាយពោលអំពើនោះថាជា សាមគ្គីរបស់ភិក្ខុដែលមិនបង្ហាញខ្លួនក្នុងទីកើត បានសេចក្តីថា ភិក្ខុណា ប្រតិបត្តិយ៉ាងនេះ

ឈ្មោះថា មិនគប្បីបង្អាញខ្លួនក្នុងនរក មិនបង្អាញខ្លួនក្នុងកំណើតតិរច្ឆាន មិនបង្អាញខ្លួនក្នុងបិត្តិវិស័យ មិនបង្អាញខ្លួនក្នុងមនុស្សលោក មិនបង្អាញខ្លួនក្នុងទេវលោក អំពើនុ៎ះឈ្មោះថា សេចក្តីព្រមព្រៀង នុ៎ះឈ្មោះថា ជាទីបិទបាំង នុ៎ះឈ្មោះថា ជាទីសមរម្យ នុ៎ះឈ្មោះថា ជាទីសមគួរ នុ៎ះឈ្មោះថាជាទីសមសួនរបស់ភិក្ខុនោះ អ្នកប្រាជ្ញទាំងឡាយពោលហើយយ៉ាងនេះ បានពោលហើយយ៉ាងនេះ រមែងសម្តែងយ៉ាងនេះ និយាយយ៉ាងនេះ បំភ្លឺយ៉ាងនេះ បញ្ចេញយ៉ាងនេះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកប្រាជ្ញទាំងឡាយពោលអំពើនោះថា ជាសាមគ្គីរបស់ភិក្ខុដែលមិនបង្អាញខ្លួនក្នុងទីកើត ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

អ្នកប្រាជ្ញទាំងឡាយពោលអំពើនោះថា ជាសាមគ្គីរបស់ភិក្ខុ
អ្នកប្រព្រឹត្តរួញថយ គប់រកអាសនៈស្ងាត់ ដែលមិនបង្អាញ
ខ្លួនក្នុងទីកើត ។

[ ២១២ ] មុនិមិនអាស្រ័យនៅក្នុងវត្ថុទាំងពួង មិនធ្វើសេចក្តី
ស្រឡាញ់ ទាំងមិនធ្វើសេចក្តីស្អប់ ( ចំពោះសត្វនិងសង្ខារ )
សេចក្តីខ្សឹកខ្សួល និងសេចក្តីកំណាញ់ មិនជាប់នៅក្នុងមុនិនោះ
ដូចជាវារិមិនជាប់នៅលើស្លឹក ( ឈូក ) ។

[ ២១៣ ] ពាក្យថា មុនិ មិនអាស្រ័យនៅក្នុងវត្ថុទាំងពួង អធិប្បាយថា វត្ថុទាំងពួង លោកពោលសំដៅយកអាយតនៈ ១២ គឺភ្នែក ១ រូប ១ ត្រចៀក ១ សំឡេង ១ ច្រមុះ ១ ក្លិន ១ អណ្តាត ១ រស ១ កាយ ១ ផ្សព្វ ១

ចិត្ត ១ ធម៌ ១ ។ ពាក្យថា មុនិ សេចក្ដីថា ញាណ ហៅថា មោនៈ គឺប្រាជ្ញា ការដឹងច្បាស់ ។បេ។ បុគ្គលណា កន្លងបង់នូវបណ្ដាញ គឺគ្រឿងជាប់ចំពាក់ បុគ្គលនោះ ឈ្មោះថា មុនិ ។ ពាក្យថា មិនអាស្រ័យនៅ បានដល់ និស្ស័យ ២ យ៉ាង គឺតណ្ហានិស្ស័យ ១ ទិដ្ឋិនិស្ស័យ ១ ។បេ។ នេះតណ្ហានិស្ស័យ ។បេ។ នេះទិដ្ឋិនិស្ស័យ ។ មុនិលះបង់តណ្ហានិស្ស័យ រលាស់ចោលទិដ្ឋិនិស្ស័យ មិនអាស្រ័យចក្ខុ មិនអាស្រ័យសោតៈ មិនអាស្រ័យឃានៈ មិនអាស្រ័យជិវ្ហា មិនអាស្រ័យកាយ មិនអាស្រ័យចិត្ត មិនអាស្រ័យរូប សំឡេង ក្លិន រស ផ្សព្វ ធម្មារម្មណ៍ ត្រកូល គណៈ អាវាស លាភ យស សេចក្ដីសរសើរ សុខ ចីវរប្បច្ច័យ បិណ្ឌបាតប្បច្ច័យ សេនាសនប្បច្ច័យ គិលានប្បច្ច័យភេសជ្ជបរិក្ខារ កាមធាតុ រូបធាតុ អរូបធាតុ កាមភព រូបភព អរូបភព សញ្ញាភព អសញ្ញាភព នេវសញ្ញានាសញ្ញាភព ឯកវោការភព ចតុវោការភព បញ្ចវោការភព អារម្មណ៍ជាអតីត អនាគត បច្ចុប្បន្ន អារម្មណ៍ដែលឃើញ ឮ ប៉ះពាល់ ឬគប្បីដឹង គឺមិនអាស្រ័យនៅព្រម មិនពួនសម្ងំ មិនចូលទៅជិត មិនជ្រុលជ្រប់ មិនចុះចិត្តស៊ប់ ជាអ្នកចេញទៅ រលាស់ចេញ រួចស្រឡះ ប្រាសចេញ មានចិត្តប្រាសចាកសេចក្ដីសល់វល់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មុនិមិនអាស្រ័យនៅក្នុងវត្ថុទាំងពួង ។

[ ២១៤ ] អធិប្បាយពាក្យថា មិនធ្វើសេចក្ដីស្រឡាញ់ ទាំងមិនធ្វើសេចក្ដីស្អប់ ត្រង់ពាក្យថា សេចក្ដីស្រឡាញ់ បានដល់ សេចក្ដីស្រឡាញ់ ២ គឺពួកសត្វ ១ សង្ខារ ១ ។

ពួកសត្វជាទីស្រឡាញ់ តើដូចម្ដេច ។ ពួកជនណាក្នុងលោកនេះជាអ្នកប្រាថ្នាសេចក្ដីចម្រើន ប្រាថ្នាប្រយោជន៍ ប្រាថ្នាសប្បាយ ប្រាថ្នាសេចក្ដីក្សេមចាកយោគៈដល់មុនិនោះ ទោះជាមាតាក្ដី បិតាក្ដី បងប្អូនប្រុសក្ដី បងប្អូនស្រីក្ដី បុត្តក្ដី ធីតាក្ដី មិត្តក្ដី អាមាត្យក្ដី ញាតិក្ដី សាលោហិតក្ដី នេះពួកសត្វជាទីស្រឡាញ់ ។

ពួកសង្ខារជាទីស្រឡាញ់ តើដូចម្ដេច ។ រូបជាទីពេញចិត្ត សំឡេងជាទីពេញចិត្ត ក្លិនជាទីពេញចិត្ត រសជាទីពេញចិត្ត ផស្សជាទីពេញចិត្ត នេះពួកសង្ខារជាទីស្រឡាញ់ ។ ពាក្យថា ស្អប់ បានដល់សេចក្ដីស្អប់ ២ គឺពួកសត្វ ១ សង្ខារ ១ ។

ពួកសត្វជាទីស្អប់ តើដូចម្ដេច ។ ពួកជនណា ក្នុងលោកនេះ ជាអ្នកមិនប្រាថ្នាសេចក្ដីចម្រើន មិនប្រាថ្នាប្រយោជន៍ មិនប្រាថ្នាសប្បាយ មិនប្រាថ្នាសេចក្ដីក្សេមចាកយោគៈ ជាអ្នកប្រាថ្នា ដើម្បីឲ្យវិនាសចាកជីវិតដល់មុនិនោះ នេះពួកសត្វជាទីស្អប់ ។

ពួកសង្ខារជាទីស្អប់ តើដូចម្ដេច ។ រូបមិនជាទីពេញចិត្ត សំឡេងមិនជាទីពេញចិត្ត ក្លិនមិនជាទីពេញចិត្ត រសមិនជាទីពេញចិត្ត ផស្សមិនជាទីពេញចិត្ត នេះពួកសង្ខាជាទីស្អប់ ។

ពាក្យថា មិនធ្វើសេចក្ដីស្រឡាញ់ ទាំងមិនធ្វើសេចក្ដីស្អប់ បានសេចក្ដីថា បុគ្គលមិនធ្វើសេចក្ដីស្រឡាញ់ដោយអំណាចរាគៈថា សត្វនេះ ជាទីស្រឡាញ់របស់អញ សង្ខារទាំងនេះ ជាទីពេញចិត្តរបស់អញ បុគ្គលមិនធ្វើ មិនបង្កើត

មិនឲ្យកើត មិនឲ្យកើតព្រម មិនឲ្យកើតឡើង មិនឲ្យកើតចំពោះនូវសេចក្ដីស្អប់ ដោយអំណាចបដិឃៈថា សត្វនេះជាទីស្អប់របស់អញ សង្ខារទាំងនេះ ជាទីស្អប់របស់អញ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនធ្វើសេចក្ដីស្រឡាញ់ទាំងមិនធ្វើសេចក្ដីស្អប់ ។

[ ២១៥ ] អធិប្បាយពាក្យថា សេចក្ដីខ្សឹកខ្សួលនិងសេចក្ដីកំណាញ់ មិនជាប់នៅក្នុងមុនិនោះ ដូចជាវារិមិនជាប់នៅលើស្លឹក ( ឈូក ) ត្រង់ពាក្យថា ក្នុងមុនិនោះ គឺក្នុងបុគ្គលជាព្រះអរហន្តខីណាស្រព ។ ពាក្យថា សេចក្ដីខ្សឹកខ្សួល គឺការយំ ការយំរៀបរាប់ អាការយំ អាការយំអណ្ដឺតអណ្ដក ភាពនៃការយំ ភាពនៃការយំរៀបរាប់ ការនិយាយ ការពោលប៉ប៉ាច់ប៉ប៉ោច ការពោលរវើរវាយ ការពោលរឿយៗ អាការជាទីពោលរឿយៗ ភាពនៃការពោលរឿយៗ របស់សត្វដែលត្រូវសេចក្ដីវិនាសញាតិប៉ះពាល់ក្ដី ត្រូវសេចក្ដីវិនាសភោគៈប៉ះពាល់ក្ដី ត្រូវសេចក្ដីវិនាសគឺរោគប៉ះពាល់ក្ដី ត្រូវសេចក្ដីវិនាសសីលប៉ះពាល់ក្ដី ត្រូវសេចក្ដីវិនាសទិដ្ឋិប៉ះពាល់ក្ដី ប្រកបព្រមដោយសេចក្ដីវិនាសណាមួយ ឬត្រូវទុក្ខធម៌ណាមួយប៉ះពាល់ក្ដី ។ ពាក្យថា សេចក្ដីកំណាញ់ បានដល់សេចក្ដីកំណាញ់ ៥ យ៉ាង គឺសេចក្ដីកំណាញ់អាវាស ១ សេចក្ដីកំណាញ់ត្រកូល ១ សេចក្ដីកំណាញ់លាភ ១ សេចក្ដីកំណាញ់វណ្ណៈ ១ សេចក្ដីកំណាញ់ធម៌ ១ សេចក្ដីកំណាញ់ អាការកំណាញ់ ភាពនៃចិត្តកំណាញ់ សេចក្ដីចង់មានហួសហេតុ ស្វួរកន្ទ្រើះ ភាពនៃចិត្តរួញ ភាពនៃការមិនយកចិត្តគេណាមានសភាពយ៉ាងនេះ នេះហៅថា សេចក្ដីកំណាញ់ មួយទៀត សូម្បីសេចក្ដី

*កំណាញ់ខន្ធ ក៏ឈ្មោះថា កំណាញ់ សូម្បីសេចក្ដីកំណាញ់ធាតុ ក៏ឈ្មោះថា កំណាញ់ សូម្បីសេចក្ដីកំណាញ់អាយតនៈ ក៏ឈ្មោះថា កំណាញ់ ការគិតតែកាន់យក នេះលោកហៅថា សេចក្ដីកំណាញ់ ។ ពាក្យថា មិនជាប់នៅ ដូចជាវារិមិនជាប់លើស្លឹក ( ឈូក ) សេចក្ដីថា ស្លឹកឈូក លោកហៅថា ស្លឹក ។ ទឹកលោកហៅថា វារិ ។ វារិមិនជាប់ មិនជ្រួតជ្រាប មិនប្រឡាក់ គឺមិនជាប់ មិនជ្រួតជ្រាប មិនប្រឡាក់ហើយនឹងស្លឹកឈូក យ៉ាងណាមិញ សេចក្ដីខ្សឹកខ្សួល និងសេចក្ដីកំណាញ់ មិនជាប់ មិនជ្រួតជ្រាប មិនប្រឡាក់ គឺមិនជាប់ មិនជ្រួតជ្រាប មិនប្រឡាក់ហើយក្នុងបុគ្គលនោះ គឺក្នុងព្រះអរហន្តខីណាស្រព ក៏យ៉ាងនោះដែរ ទាំងបុគ្គលនោះ មិនជាប់ មិនជ្រួតជ្រាប មិនប្រឡាក់ គឺមិនជាប់ មិនជ្រួតជ្រាប មិនប្រឡាក់ ចេញរួចហើយ រលាស់ចេញហើយ រួចស្រឡះហើយ ប្រាសចេញហើយ ចាកកិលេសទាំងនោះ ជាអ្នកមានចិត្តប្រាសចាកសេចក្ដីសល់វល់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) សេចក្ដីខ្សឹកខ្សួលនិងសេចក្ដីកំណាញ់ មិនជាប់ក្នុងបុគ្គលនោះ ដូចជាវារិមិនជាប់លើស្លឹក ( ឈូក ) ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា*

*មុនិ មិនអាស្រ័យនៅក្នុងវត្ថុទាំងពួង មិនធ្វើសេចក្ដីស្រឡាញ់*
*ទាំងមិនធ្វើសេចក្ដីស្អប់ ( ចំពោះសត្វនិងសង្ខារ ) សេចក្ដី*
*ខ្សឹកខ្សួលនិងសេចក្ដីកំណាញ់ មិនជាប់នៅក្នុងមុនិនោះ ដូចជា*
*វារិមិនជាប់នៅលើស្លឹក ( ឈូក ) ។*

*[ ២១៦ ] តំណក់ទឹក មិនជាប់នៅលើស្លឹកឈូក យ៉ាង*

ណា វារិមិនជាប់នៅលើផ្កាឈូក យ៉ាងណា មុនិ មិនជាប់ក្នុងអារម្មណ៍ដែលខ្លួនឃើញ ឮ ឬប៉ះពាល់ ក៏យ៉ាងនោះដែរ ។

[ ២១៧ ] ពាក្យថា តំណក់ទឹកមិនជាប់លើស្លឹកឈូក យ៉ាងណា សេចក្ដីថា គ្រាប់ទឹក លោកហៅថា តំណក់ទឹក ។ ស្លឹកឈូក លោកហៅថា ឈូក ។ តំណក់ទឹកមិនជាប់នៅ មិនជ្រួតជ្រាប មិនប្រឡាក់ គឺមិនជាប់ មិនជ្រួតជ្រាប មិនប្រឡាក់ហើយ លើស្លឹកឈូកយ៉ាងណា ហេតុនោះ ( ទ្រង់ត្រាស់ថា ) តំណក់ទឹកមិនជាប់លើស្លឹកឈូក យ៉ាងណា ។

[ ២១៨ ] ពាក្យថា វារិ មិនជាប់នៅលើផ្កាឈូក យ៉ាងណា សេចក្ដីថា ផ្កាឈូក លោកហៅថា ឈូក ។ ទឹក លោកហៅថា វារិ ។ វារិ មិនជាប់នៅ មិនជ្រួតជ្រាប មិនប្រឡាក់ គឺមិនជាប់នៅ មិនជ្រួតជ្រាប មិនប្រឡាក់ហើយ លើផ្កាឈូក យ៉ាងណា ហេតុនោះ ( ទ្រង់ត្រាស់ថា ) វារិមិនជាប់នៅលើផ្កាឈូក យ៉ាងណា ។

[ ២១៩ ] អធិប្បាយពាក្យថា មុនិមិនជាប់នៅក្នុងអារម្មណ៍ ដែលខ្លួនឃើញ ឮ ឬប៉ះពាល់ ក៏យ៉ាងនោះ ត្រង់ពាក្យថា យ៉ាងនោះ គឺជាពាក្យផ្ដល់សេចក្ដីឧបមា ។ ពាក្យថា មុនិ សេចក្ដីថា ញាណ លោកហៅថាមោនៈ បានខាងប្រាជ្ញា ការដឹងច្បាស់ ។បេ។ បុគ្គលណា កន្លងបណ្ដាញគឺគ្រឿងជាប់ចំពាក់ បុគ្គលនោះ ឈ្មោះថា មុនិ ។ ពាក្យថា ជាប់ បានដល់ការជាប់ពីរ គឺការជាប់គឺតណ្ហា ១ ការជាប់គឺទិដ្ឋិ ១ ។បេ។ នេះការជាប់គឺតណ្ហា ។បេ។ នេះការជាប់

គឺទិដ្ឋិ ។ មុនិ លះបង់ការជាប់គឺតណ្ហា រលាស់ចោលការជាប់គឺទិដ្ឋិ មិនជាប់ក្នុងរូបដែលឃើញ មិនជាប់ក្នុងសំឡេងដែលឮ មិនជាប់ក្នុងផស្សៈដែលប៉ះពាល់ មិនជាប់ មិនជ្រួតជ្រាប មិនប្រឡាក់ គឺមិនជាប់ មិនជ្រួតជ្រាប មិនប្រឡាក់ ចេញទៅ រលាស់ចេញ រួចស្រឡះ ប្រាសចេញហើយ ក្នុងអារម្មណ៍ដែលដឹង ជាអ្នកមានចិត្តប្រាសចាកសេចក្តីសល់វល់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មុនិមិនជាប់ក្នុងអារម្មណ៍ដែលខ្លួនឃើញ ឮ ឬប៉ះពាល់ យ៉ាងនោះ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

តំណក់ទឹក មិនជាប់នៅលើស្លឹកឈូក យ៉ាងណា វារិ មិនជាប់នៅលើផ្កាឈូក យ៉ាងណា មុនិ មិនជាប់ក្នុងអារម្មណ៍ដែលខ្លួនឃើញ ឮ ឬប៉ះពាល់ ក៏យ៉ាងនោះ ។

[ ២២០ ] បុគ្គលមានប្រាជ្ញាកម្ចាត់ មិនសម្គាល់នូវអារម្មណ៍ដែលខ្លួនឃើញ ឮ ឬប៉ះពាល់ដោយវត្ថុនោះ មិនប្រាថ្នាសេចក្តីបរិសុទ្ធដោយហេតុដទៃ បុគ្គលមានប្រាជ្ញាកម្ចាត់នោះ រមែងមិនត្រេកមិនទ្រាន់ ។

[ ២២១ ] អធិប្បាយពាក្យថា បុគ្គលមានប្រាជ្ញាកម្ចាត់ មិនសម្គាល់ចំពោះអារម្មណ៍ដែលខ្លួនឃើញ ឮ ឬប៉ះពាល់ដោយវត្ថុនោះ ត្រង់ពាក្យថា បុគ្គលមានប្រាជ្ញាកម្ចាត់ សេចក្តីថា បញ្ញា លោកហៅថា ប្រាជ្ញាកម្ចាត់ បានខាងប្រាជ្ញា សេចក្តីដឹងច្បាស់ ។បេ។ សេចក្តីមិនវង្វេង ការពិចារណាធម៌ សេចក្តីយល់ត្រូវ ។ បញ្ញាលោកហៅថា ប្រាជ្ញាកម្ចាត់ តើព្រោះហេតុដូចម្តេច ។ កាយទុច្ចរិត

លោកកម្ចាត់បង់ហើយ លាងហើយ សម្អាតហើយ ជម្រះឲ្យស្អាតហើយដោយបញ្ញានោះ ។ វចីទុច្ចរិត លោកកម្ចាត់បង់ហើយ លាងហើយ សម្អាតហើយ ជម្រះឲ្យស្អាតហើយ ។ មនោទុច្ចរិត លោកកម្ចាត់បង់ហើយ លាងហើយ សម្អាតហើយ ជម្រះឲ្យស្អាតហើយ ។ រាគៈលោកកម្ចាត់បង់ហើយ លាងហើយ សម្អាតហើយ ជម្រះឲ្យស្អាតហើយ ។ ទោសៈ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ មាយា សាថេយ្យៈ ថម្ភៈ សារម្ភៈ មានះ អតិមានះ មទៈ បមាទៈ កិលេសទាំងអស់ ទុច្ចរិតទាំងអស់ សេចក្តីក្រវល់ក្រវាយទាំងអស់ សេចក្តីអន្ទះអន្ទែងទាំងអស់ សេចក្តីក្តៅក្រហាយទាំងអស់ ការតាក់តែង អកុសលទាំងអស់ លោកកម្ចាត់បង់ហើយ លាងហើយ សម្អាតហើយ ជម្រះឲ្យស្អាតហើយ ។ ហេតុនោះ បញ្ញា លោកហៅថា ប្រាជ្ញាកម្ចាត់ មួយទៀត មិច្ឆាទិដ្ឋិ លោកកម្ចាត់បង់ហើយ លាងហើយ សម្អាតហើយ ជម្រះឲ្យស្អាតហើយដោយសម្មាទិដ្ឋិ ។ មិច្ឆាសង្កប្បៈ លោកកម្ចាត់បង់ហើយ លាងហើយ សម្អាតហើយ ជម្រះឲ្យស្អាតហើយ ដោយសម្មាសង្កប្បៈ ។ មិច្ឆាវាចា លោកកម្ចាត់បង់ហើយដោយសម្មាវាចា ។ មិច្ឆាកម្មន្តៈលោកកម្ចាត់បង់ហើយដោយសម្មាកម្មន្តៈ ។ មិច្ឆាអាជីវៈ លោកកម្ចាត់បង់ហើយដោយសម្មាអាជីវៈ ។ មិច្ឆាវាយាមៈ លោកកម្ចាត់បង់ហើយ ដោយសម្មាវាយាមៈ មិច្ឆាសតិ លោកកម្ចាត់បង់ហើយដោយសម្មាសតិ ។ មិច្ឆាសមាធិ លោកកម្ចាត់បង់ហើយដោយសម្មាសមាធិ ។ មិច្ឆាញាណ លោកកម្ចាត់បង់ហើយដោយសម្មាញាណ ។ មិច្ឆាវិមុត្តិ លោកកម្ចាត់បង់ហើយ លាងហើយ សម្អាត

ហើយ ជម្រះឲ្យស្អាតហើយដោយសម្មាវិមុត្តិ ។ មួយទៀត កិលេសទាំងអស់ ទុច្ចរិតទាំងអស់ សេចក្តីក្រវល់ក្រវាយទាំងអស់ សេចក្តីអន្ទះអន្ទែងទាំងអស់ សេចក្តីក្តៅក្រហាយទាំងអស់ ការតាក់តែងអកុសលទាំងអស់ លោកកម្ចាត់បង់ហើយ លាងហើយ សម្អាតហើយ ជម្រះឲ្យស្អាតហើយ ដោយអរិយមគ្គមានអង្គ ៨ ប្រការ ។ ព្រះអរហន្តចូលទៅ ចូលទៅព្រម ចូលទៅជិត ផ្តេកផ្តិត កើតកើតឡើងជាមួយ ប្រកបដោយជោនេយ្យធម៌ទាំងនេះ ព្រោះហេតុនោះ ព្រះអរហន្តឈ្មោះថា អ្នកមានប្រាជ្ញាកម្ចាត់ ។ ព្រះអរហន្តនោះ កម្ចាត់បង់រាគៈ កម្ចាត់បង់បាប កម្ចាត់បង់កិលេស កម្ចាត់បង់សេចក្តីអន្ទះអន្ទែង ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកមានប្រាជ្ញាកម្ចាត់ ។

ពាក្យថា បុគ្គលមានប្រាជ្ញាកម្ចាត់ មិនសម្គាល់នូវអារម្មណ៍ដែលខ្លួនឃើញ ឮ ឬប៉ះពាល់ដោយវត្ថុនោះ បានសេចក្តីថា បុគ្គលមានប្រាជ្ញាកម្ចាត់ មិនសម្គាល់រូបដែលឃើញ មិនសម្គាល់ក្នុងរូបដែលឃើញ មិនសម្គាល់ដោយរូបដែលឃើញ មិនសម្គាល់ថារូបដែលអញឃើញហើយ ។ មិនសម្គាល់សំឡេងដែលឮ មិនសម្គាល់ក្នុងសំឡេងដែលឮ មិនសម្គាល់ដោយសំឡេងដែលឮ មិនសម្គាល់ថា សំឡេងដែលអញឮហើយ ។ មិនសម្គាល់អារម្មណ៍ដែលប៉ះពាល់ មិនសម្គាល់ក្នុងអារម្មណ៍ដែលប៉ះពាល់ មិនសម្គាល់ដោយអារម្មណ៍ដែលប៉ះពាល់ មិនសម្គាល់ថា អារម្មណ៍ដែលអញប៉ះពាល់ហើយ ។ មិនសម្គាល់ហេតុដែលដឹង មិនសម្គាល់ក្នុងហេតុដែលដឹង មិនសម្គាល់ដោយហេតុដែលដឹង មិនសម្គាល់ថាហេតុដែលអញដឹងហើយ ។ សមដូចពាក្យទុំះ ដែល

ព្រះមានព្រះភាគត្រាស់ហើយថា ម្នាលភិក្ខុទាំងឡាយ អ្នកសម្គាល់ហេតុនុ៎ះថា អាត្មាអញកំពុងមាន អ្នកសម្គាល់ហេតុនុ៎ះថា អាត្មាអញកំពុងមិនមានអ្នកសម្គាល់ហេតុនុ៎ះថា អាត្មាអញនឹងមាន អ្នកសម្គាល់ហេតុនុ៎ះថា អាត្មាអញនឹងមិនមាន អ្នកសម្គាល់ហេតុនុ៎ះថា អាត្មាអញនឹងមានរូប អ្នកសម្គាល់ហេតុនុ៎ះថា អាត្មាអញនឹងមិនមានរូប អ្នកសម្គាល់ហេតុនុ៎ះថា អាត្មាអញនឹងមានសញ្ញា អ្នកសម្គាល់ហេតុនុ៎ះថា អាត្មាអញនឹងមិនមានសញ្ញា អ្នកសម្គាល់ហេតុនុ៎ះថា អាត្មាអញនឹងមានសញ្ញាក៏ទេ មិនមានសញ្ញាក៏ទេ ម្នាលភិក្ខុទាំងឡាយ អ្នកសម្គាល់ថាជារោគ អ្នកសម្គាល់ថាជាបូស អ្នកសម្គាល់ថាជាសរ អ្នកសម្គាល់ថា ជាឧបទ្រព ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ អ្នកទាំងឡាយ ( ចូរសិក្សា ) ថា យើងទាំងឡាយ គប្បីនៅដោយចិត្តមិនបានសម្គាល់ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងហ្នឹងឯង ។ បុគ្គលមានប្រាជ្ញាកម្ចាត់មិនសម្គាល់អារម្មណ៍ ដែលខ្លួនឃើញ ឮ ឬប៉ះពាល់ដោយវត្ថុនោះ ។

[ ២២២ ] ពាក្យថា មិនប្រាថ្នាសេចក្តីបរិសុទ្ធ ដោយហេតុដទៃ គឺបុគ្គលមានប្រាជ្ញាកម្ចាត់ រមែងមិនចង់បាន មិនត្រេកអរ មិនប្រាថ្នា មិនស្រឡាញ់ មិនជាប់ចំពោះនូវសេចក្តីស្អាត ការហ្មត់ចត់ ការបរិសុទ្ធ ការរួច ការរួចស្រឡះ ការផុតស្រឡះ ដោយមគ្គមិនបរិសុទ្ធិ ដោយសេចក្តីប្រតិបត្តិខុសដោយគន្លងមិនមែនជានិយ្យានិកធម៌ដទៃ វៀរចាកសតិប្បដ្ឋាន វៀរចាកសម្មប្បធាន វៀរចាកឥទ្ធិបាទ វៀរចាកឥន្ទ្រិយ វៀរចាកពលៈ វៀរចាកពោជ្ឈង្គ វៀរចាកអរិយមគ្គមានអង្គ ៨ ឡើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនប្រាថ្នា

សេចក្តីបរិសុទ្ធិដោយហេតុដទៃ ។

[ ២២៣ ] ពាក្យថា បុគ្គលមានប្រាជ្ញាកម្ចាត់នោះ រមែងមិនត្រេក មិនទ្រាន់ សេចក្តីថា ពាលបុថុជ្ជនទាំងអស់ រមែងត្រេក សេក្ខបុគ្គល ៧ ពួក រាប់ទាំងកល្យាណបុថុជ្ជនផង រមែងទ្រាន់ ព្រះអរហន្តរមែងមិនត្រេក មិនទ្រាន់ ។ ព្រះអរហន្តនោះ ប្រាសចាកតម្រេក ព្រោះអស់រាគៈ ព្រោះប្រាសចាករាគៈ ព្រោះអស់ទោសៈ ព្រោះប្រាសចាកទោសៈ ព្រោះអស់មោហៈ ព្រោះប្រាសចាកមោហៈហើយ ។ ព្រះអរហន្តនោះ មានការអប់រំព្រហ្មចរិយធម៌ស្រេចហើយ មានការប្រព្រឹត្តិ ប្រព្រឹត្តរួចហើយ ។បេ។ ភពថ្មីរបស់ព្រះអរហន្តនោះ មិនមានទេ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលមានប្រាជ្ញាកម្ចាត់នោះ រមែងមិនត្រេក មិនទ្រាន់ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

បុគ្គលមានប្រាជ្ញាកម្ចាត់ មិនសម្គាល់នូវអារម្មណ៍ ដែលខ្លួន
ឃើញ ឮ ឬប៉ះពាល់ដោយវត្ថុនោះ មិនប្រាថ្នាសេចក្តីបរិសុទ្ធ
ដោយហេតុដទៃ បុគ្គលមានប្រាជ្ញាកម្ចាត់នោះ រមែងមិនត្រេក
មិនទ្រាន់ ។

## ចប់ ជរាសុត្តនិទ្ទេស ទី ៦ ។

# អដ្ឋកថា

## ជរាសុត្តនិទ្ទេសទី ៦

ក្នុងជរាសុត្តនិទ្ទេសទី ៦ មានវិនិច្ឆ័យដូចតទៅនេះថា

[ ១៨១-១៨២ ] បទថា **អប្បំ វត ជីវិតំ ឥទំ** សេចក្ដីថា ជីវិតរបស់មនុស្សទាំងឡាយនេះតិចតួច គឺបន្តិចបន្តួច ។ ពាក្យថា ធម្មជាតតាំងនៅតិចនិងពាក្យថាកិច្ចរបស់ខ្លួនតិច មានន័យដូចពោលហើយក្នុងគុហដ្ឋកសូត្រ ។ បទថា **ឱរំ វស្សសតាបិ មិយ្យតិ** សេចក្ដីថា រមែងស្លាប់ខាងក្នុង ១០០ ឆ្នាំ ក្នុងកាលជាកលលៈជាដើមក៏មាន ។

បទថា **អតិច្ច** សេចក្ដីថា ច្រើនជាង ១០០ ឆ្នាំ ។ បទថា **ជរសាបិ មិយ្យតិ** សេចក្ដីថា រមែងស្លាប់ព្រោះជរា សេចក្ដីបន្តអំពីនេះ គប្បីកាន់យកដោយន័យដែលពោលហើយ ក្នុងអដ្ឋកថាគុហដ្ឋកសូត្រនោះឯង ។ បទថា **អប្បំ** បានដល់តិចតួច ។ បទថា **គមនីយោ សម្បរាយោ** សេចក្ដីថា ត្រូវទៅបរលោក ។

[ ១៨៣ ] ឈ្មោះថា **កលល** ក្នុងបទថា **កលលកាលេបិ** នេះ សេចក្ដីថា ក្នុងខណៈបដិសន្ធិជាកលលៈថ្លា ប្រមាណប៉ុនតំណក់ប្រេងដែលជាប់ត្រង់ចុងសរសៃអំបោះដែលធ្វើអំពីរោមសត្វ ៣ សរសៃដែលលោកពោលទុកថា

> តំណក់ប្រេងល្ង មានពណ៌ថ្លា មិនល្អក់យ៉ាងណា រូបដែល
> មានពណ៌ដូចគ្នានោះ លោកហៅថា **កលល** ។ ក្នុងកាល
> ដែលជាកលលៈនោះខ្លះ ដូច្នេះ ។

បទថា **ចវតិ** សេចក្ដីថា ឃ្លាតចាកជីវិត ។ បទថា **មរតិ** សេចក្ដីថា

ដល់នូវការប្រាសចាកជីវិត ។ បទថា **អន្តរធាយតិ** សេចក្តីថា ដល់នូវការឃើញមិនបាន ។ បទថា **វិប្បលុជ្ជតិ** សេចក្តីថា ដាច់ អាចារ្យពួកខ្លះអធិប្បាយយ៉ាងនេះថា ច្យុតទៅអំពីកំណើតអណ្ឌជៈ ស្លាប់អំពីកំណើតជលាពុជៈ បាត់បង់ក្នុងកំណើតសំសេទជៈ វិនាសក្នុងកំណើតឱបបាតិកៈ ។ បទថា **អព្ពុទកាលេបិ** សេចក្តីថា ឈ្មោះថា អព្ពុទៈ រមែងមានពណ៌ដូចទឹកលាងសាច់ កាលនៅជាកលលៈបាន ៧ ថ្ងៃ ។ ឈ្មោះថាកលលៈក៏បាត់ទៅ សមដូចលោកពោលទុកថា

ជាកលលៈបាន ៧ ថ្ងៃ ចាស់ ផុតសភាវៈ ប្រែភាវៈពីកលលៈ
នោះ កើតជាសភាពអព្ពុទៈ ដូច្នេះ ។

ក្នុងកាលជាអព្ពុទៈនោះខ្លះ ។ បទថា **បេសិកាលេបិ** សេចក្តីថា កាលនៅជាអព្ពុទៈនោះបាន ៧ ថ្ងៃ រមែងកើតជាសភាវៈ ឈ្មោះថា បេសិ ដូចគ្នានឹងសំណរលាយ បេសិនោះ គប្បីសម្តែងដោយម្រេចនិងទឹកអំពៅ ឯពួកក្មេងអ្នកស្រុក បេះម្រេចដែលទុំល្អ ខ្ចប់ត្រង់ជាយសំពត់ហើយច្របាច់យកកំពូលនៃរសដាក់ក្នុងអំបែងហាលថ្ងៃ កំពូលនៃរសនោះក៏ក្រៀមទៅៗ ផុតចាកចំណែកទាំងពួង បេសិ រមែងមានលក្ខណៈយ៉ាងនោះ ឈ្មោះថា អព្ពុទៈរមែងបាត់ទៅសមដូចលោកពោលទុកថា

ជាអព្ពុទៈបាន ៧ ថ្ងៃ ក៏ចាស់ផុតសភាវៈ ផ្លាស់សភាវៈដែល
ជាអព្ពុទៈ នោះ កើតជាសភាវៈឈ្មោះថា បេសិ ដូច្នេះ ។

ក្នុងកាលដែលជាបេសិនោះខ្លះ ។ បទថា **ឃនកាលេបិ** សេចក្តីថា កាល

បេសិនោះ នៅបាន ៧ ថ្ងៃ រមែងកើតជាដុំសាច់ ឈ្មោះថា ឃនៈ មានសណ្ឋានដូចពងមាន់ ។ ឈ្មោះថា បេសិ រមែងបាត់ទៅ ។ សមដូចលោកពោលទុកថា

ជាបេសិបាន ៧ ថ្ងៃក៏ចាស់ កន្ទងសភាវៈ ប្រែភាវៈដែលជា
បេសិនោះ កើតជាសភាពឈ្មោះថា **ឃន** ដូចស៊ុតរបស់មេ
មាន់ ជារង្វង់មូលយ៉ាងណា សណ្ឋានរបស់ឃនៈក៏យ៉ាងនោះ
កើតព្រោះកម្មជាបច្ច័យ ដូច្នេះ ។

ក្នុងកាលជាឃនៈនោះខ្លះ ។ បទថា **បញ្ចសាខកាលេបិ** សេចក្តីថា ក្នុងសប្តាហ៍ទី ៥ ក៏កើតនូវពក ៥ ជាដៃ ២ ជើង ២ ក្បាល ១ ដែលព្រះមានព្រះភាគទ្រង់សំដៅដល់ត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ ពក ៥ រមែងតាំងឡើងអំពីកម្ម ក្នុងសប្តាហ៍ទី ៥ ដូច្នេះ ។ ក្នុងកាលដែលជាសាខានោះខ្លះ ។ បន្ទាប់អំពីនោះ ជាការសម្តែងដោយសង្ខេប ឆ្លងនូវសប្តាហ៍ទី ៦ ទី ៧ ជាដើមទៅ រហូតដល់ ៤២ សប្តាហ៍ ជាកាលកើតឡើងនៃសក់ រោមនិងក្រចកជាដើម មួយអន្លើដោយទងសុកដែលតាំងឡើង អំពីផ្ចិតរបស់ទារកនោះ ជាប់នឹងផ្ទៃខាងរបស់មាតា ទងសុកនោះមានប្រហោងដូចគ្នានឹងដើមឈូក រសអាហារជ្រាបតាមទងសុកនោះ ញ៉ាំងរូបដែលមានអាហារជាសមុដ្ឋានឲ្យតាំងឡើង ទារកនោះ ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅអស់កាល ១០ ខែ ដោយអាការៈយ៉ាងនេះ ព្រះថេរៈមិនបានពោលរឿងទាំងពួងនោះ ពោលត្រឹមតែថា **សូតិ-ឃរេ** ដែលលោកសំដៅដល់ពោលថា សក់ រោមនិងក្រចក ។

*ឯមាតារបស់សត្វនោះ បរិភោគភោជនណា ទោះបាយក្តី ទឹកក្តី សត្វនោះ ដែលឋិតនៅក្នុងផ្ទៃនៃមាតានោះ ក៏ញុំាងអត្ត-ភាពឲ្យប្រព្រឹត្តទៅដោយភោជនទោះ ដូច្នេះ[១] ។*

*បណ្តាបទទាំងនោះ បទថា* **សូតិឃរេ** *សេចក្តីថា ក្នុងផ្ទះប្រសូតិ គឺក្នុងផ្ទះដែលជាទីប្រសូតិ បាឋៈថា* **សូតិកាឃរេ** *ក៏មាន កាត់បទដល់ត្រឹមតែ* **សូតិ-កាយ** *។ បទថា* **អឌ្ឍមាសិកោបិ** *សេចក្តីថា ឈ្មោះថា អឌ្ឍមាសកៈ ព្រោះអត្ថថា មានជីវិតនៅកន្លះខែ តាំងអំពីថ្ងៃប្រសូត ក្នុងបទថា មានជីវិត ២ ខែ ជាដើមក៏ន័យនេះឯង ។ បទថា* **សំវច្ឆរិកោ** *ព្រោះអត្ថថា មានជីវិត ១ ឆ្នាំ តាំងអំពីថ្ងៃកើត សូម្បីក្នុងបទថា* **ទ្វេវស្សិកោ** *ជាដើម ក៏ន័យនេះឯង ។*

*[ ១៨៥ ] បទថា* **យទា ជិណ្ណោ ហោតិ** *សេចក្តីថា ក្នុងកាលណា មនុស្សជាបុគ្គលគ្រាំគ្រាព្រោះជរា ជាអ្នករីងស្ងួត ។ បទថា* **វុឌ្ឍោ** *សេចក្តីថា ច្រើនដោយការវិនាស ។ បទថា* **មហល្លកោ** *សេចក្តីថា ជាធំដោយកំណើត ។ បទថា* **អទ្ធគតោ** *សេចក្តីថា កន្លងនូវកាលទាំង ៣ ។ បទថា* **វយោ-អនុប្បត្តោ** *សេចក្តីថា ដល់នូវវ័យទី ៣ តាមលំដាប់ ។ បទថា* **ខណ្ឌទន្តោ** *សេចក្តីថា ឈ្មោះថា មានធ្មេញបាក់ ព្រោះអត្ថថា មានធ្មេញរង្គោះរង្គើចន្លោះពីគ្នានិងបាក់ ដោយអានុភាពរបស់ជរា ។ បទថា* **បលិតកេសោ** *សេចក្តីថា មានសក់ពណ៌ស ។ បទថា* **វិលូនំ** *សេចក្តីថា ធក ដូចសរសៃសក់ត្រូវចាប់ដក ។ បទថា* **ខលិតសិរោ** *សេចក្តីថា មានក្បាលថ្ពែកច្រើន ។ បទថា* **វលីនំ**

---

*១-សំយុត្តនិកាយ សគាថវគ្គ ។*

សេចក្តីថា ស្នាមជ្រួញដែលកើតឯង ។ បទថា **តិលកាហតគត្តោ** សេចក្តីថា មានសរីរៈដេរដាសដោយទុះពណ៌សនិងអាចម៍រុយពណ៌ខ្មៅ ។ បទថា **ភោគ្គោ** បានដល់ បាក់ហើយ ព្រះថេរៈសម្តែងនូវការវៀចរបស់សរីរៈនោះដោយបទនេះ ។ បទថា **ទណ្ឌបរាយនោ** សេចក្តីថា មានឈើច្រត់ជាទីពឹងអាស្រ័យ គឺមានឈើច្រត់ជាសម្មាញ់ ។ បទថា **សោ ជរាយបិ** សេចក្តីថា បុគ្គលនោះសូម្បីត្រូវជរាគ្របសង្កត់ហើយរមែងស្លាប់ ។ បទថា **នត្ថិ មរណម្ហា មោក្ខោ** សេចក្តីថា ឧបាយជាគ្រឿងផុតចាកសេចក្តីស្លាប់មិនមាន គឺមិនចូលទៅបាន ។

បទថា **ផលានមិវ បក្កានំ បាតោ បតនតោ ភយំ** សេចក្តីថា ដូចពួកម្ចាស់របស់ផ្លែឈើ ខ្លាចក្រែងថា ផ្លែឈើទុំមានផ្លែខ្ទរជាដើមដែលទុំមានទងជិតរលួះនឹងជ្រុះក្នុងពេលព្រឹក ។ បទថា **ឯវំ ជាតានមច្ចានំ និច្ចំ មរណតោ ភយំ** សេចក្តីថា ពួកសត្វដែលកើតឡើងហើយ មានភ័យអំពីការស្លាប់ ពោលគឺមច្ចុសព្វកាល គឺអស់កាលជានិច្ច ដូច្នោះដូចគ្នា ។

បទថា **យថាបិ កុម្ភការស្ស** សេចក្តីថា បុគ្គលធ្វើនូវភាជនៈដីយ៉ាងណា ។ បទថា **កតំ មត្តិកភាជនំ** សេចក្តីថា ភាជនៈដែលនាយជាងនោះធ្វើសម្រេចហើយ ។ បទថា **សព្វេ ភេទបរិយន្តា** សេចក្តីថា ភាជនៈដីដែលឆ្អិននិងឆៅទាំងអស់ ឈ្មោះថា មានការបែកធ្លាយក្នុងទីបំផុត ព្រោះអត្ថថា មានការបែកធ្លាយ គឺទម្លាយជាទីបំផុត គឺបញ្ចប់ ។ បទថា **ឯវំ មច្ចានជីវិតំ** សេចក្តីថា អាយុសង្ខាររបស់សត្វទាំងឡាយ ក៏ដូច្នោះដូចគ្នា ។

បទថា **ទហរា ច មហន្តា ច** សេចក្តីថា ទាំងក្មេង ទាំងចាស់ ។ បទថា

**យេ ពាលា យេ ច បណ្ឌិតា** *សេចក្តីថា ទាំងអ្នកល្ងង់ដែលមានជីវិតទាក់ទង ដោយខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញ ទាំងអ្នកឈ្លាស មានព្រះពុទ្ធជាដើម ដែលប្រកបដោយភាពជាបណ្ឌិត ។ បទថា* **សព្វេ មច្ចុវសំ យន្តិ** *សេចក្តីថា បុគ្គលក្មេងជាដើម ដែលមានប្រការដូចពោលហើយទាំងនោះ រមែងចូលដល់នូវអំណាចនៃមច្ចុ ។*

*បទថា* **តេសំ មច្ចុបរេតានំ** *សេចក្តីថា កាលមនុស្សទាំងនោះ ដែលសេចក្តីស្លាប់ចោមរោមហើយ ។ បទថា* **គច្ឆតំ បរលោកតោ** *សេចក្តីថា ទៅអំពីមនុស្សលោកនេះទៅកាន់បរលោក ។ បទថា* **ន បិតា តាយតេ បុត្តំ** *សេចក្តីថា បិតារមែងរក្សាបុត្តទុកមិនបាន ។ បទថា* **ញាតី វា បន ញាតកេ** *សេចក្តីថា ពួកញាតិខាងមាតាបិតាក្តី ក៏មិនអាចរក្សាញាតិទាំងនោះទុកបាន ។*

*បទថា* **បេក្ខតញ្ញេវ ញាតីនំ** *សេចក្តីថា កាលពួកញាតិដូចពោលហើយនោះឯងកំពុងសម្លឹងមើល គឺសម្លឹងមើលនូវគ្នានឹងគ្នានោះឯង ។ បទថា* **បស្ស លាលប្បតំ បុថុ** *សេចក្តីថា ពាក្យថា បស្សៈ ជាអាលបនៈ គឺជាពាក្យហៅ ។ កាលពួកញាតិកំពុងកន្ទក់កន្ទេញ គឺកំពុងរវើរវាយជាច្រើន គឺមានប្រការផ្សេងៗ ។ បទថា* **ឯកមេកោវ មច្ចានំ គោវជ្ឈោ វិយ និយ្យតិ** *សេចក្តីថា បណ្តាសត្វទាំងនោះ ពួកសត្វតែម្នាក់ ដែលមរណៈនាំទៅ គឺឲ្យដល់នូវការស្លាប់ ដូចគោត្រូវនាំទៅសម្លាប់ ។ បទថា* **ឯវំ អព្ភាហតោ លោកោ** *សេចក្តីថា សត្វលោកត្រូវនាំមកដ៏ផ្សាក្តៅយ៉ាងនេះប៉ុណ្ណោះ ។ បទថា* **មច្ចុនា ច ជរាយ ច** *សេចក្តីថា ត្រូវការស្លាប់និងការចាស់គ្របសង្កត់ ។*

[ ១៨៦ ] បទថា **មមាយិតេ** សេចក្តីថា ព្រោះហេតុនៃវត្ថុដែលប្រកាន់ថារបស់អញ ។ បទថា **វិនាភាវសន្តមេវិទំ** សេចក្តីថា វត្ថុដែលប្រកាន់នេះមានការព្រាត់ប្រាស គឺការព្រាត់ប្រាសមាននោះឯង អធិប្បាយថា មិនអាចមិនព្រាត់ប្រាស ។

[ ១៨៧ ] បទថា **សោចន្តិ** សេចក្តីថា ធ្វើនូវសេចក្តីសោយសោកផ្លូវចិត្ត ។ បទថា **កិលមន្តិ** សេចក្តីថា ដល់នូវសេចក្តីលំបាកផ្លូវកាយ ។ បទថា **បរិទេវន្តិ** សេចក្តីថា ដល់នូវការរវើរវាយដោយវាចា មានប្រការផ្សេងៗ ។ បទថា **ឧរត្តាឡឹ កន្ទន្តិ** សេចក្តីថា គក់ទ្រូង គក់ខ្លួន កន្ទក់កន្ទេញ ។ បទថា **សម្មោហំ អាបជ្ជន្តិ** សេចក្តីថា ដល់នូវការវង្វេង ។

[ ១៨៨ ] បទថា **អនិច្ចោ** សេចក្តីថា ដោយអត្ថថា មានហើយ ប្រែជាមិនមាន ។ បទថា **សង្ខតោ** សេចក្តីថា ដែលបច្ច័យទាំងឡាយប្រជុំគ្នាធ្វើ ។ បទថា **បដិច្ចសមុប្បន្នោ** សេចក្តីថា អាស្រ័យការព្រមព្រៀងគ្នានៃបច្ច័យនិងកើតឡើងរួមគ្នានិងត្រឹមត្រូវដោយបដិសេធមិនបាន ។ បទថា **ខយធម្មោ** សេចក្តីថា មានការអស់ទៅជាសភាវៈ ។ បទថា **វយធម្មោ** សេចក្តីថា មានការដល់នូវសេចក្តីវិនាសជាសភាវៈ អធិប្បាយថា មានការដល់នូវការបែកធ្លាយជាសភាវៈ ។ បទថា **វិរាគធម្មោ** សេចក្តីថា មានការប្រាសចាកតម្រេកជាសភាវៈ ។ បទថា **និរោធធម្មោ** សេចក្តីថា មានការរលត់ជាសភាវៈ ។ បទថា **យ្វាយំ បរិគ្គហោ** សេចក្តីថា ការប្រកាន់នេះឯណា ។ បាឋៈថា **យោយំ បរិគ្គហោ** ក៏មាន កាត់បទក៏យ៉ាងនេះឯង ។ បទថា **និច្ចោ** សេចក្តីថា ប្រព្រឹត្ត

ទៅអស់កាលជាប់ត ។ បទថា **ធុវោ** សេចក្តីថា មាំ ។ បទថា **សស្សតោ** សេចក្តីថា មិនឃ្លាត ។ បទថា **អវិបរិណាមធម្មោ** សេចក្តីថា មានការមិនលះប្រក្រតីជាសភាវៈ ។ បទថា **សស្សតិសមំ តថេវ ឋស្សតិ** សេចក្តីថា គប្បីតាំងនៅដូចព្រះចន្ទ ព្រះអាទិត្យ ភ្នំសិនេរុ មហាសមុទ្ទ ផែនដីនិងភ្នំជាដើម ។

[ ១៨៩ ] បទថា **នានាភាវោ** សេចក្តីថា សភាវៈផ្សេងៗដោយកំណើត ។ បទថា **វិនាភាវោ** សេចក្តីថា ការព្រាត់ប្រាសព្រោះសេចក្តីស្លាប់ ។ បទថា **អញ្ញថាភាវោ** សេចក្តីថា សេចក្តីដទៃដោយសភាវៈ ។ បទថា **បុរិមានំ បុរិមានំ ខន្ធានំ** សេចក្តីថា ខន្ធដែលកើតឡើងក្នុងកាលមុនជាប់ៗគ្នា ។ បទថា **វិបរិណាមញ្ញថាភាវា** ភ្ជាប់សេចក្តីថា ខន្ធជាដើមក្រោយៗ លះភាវៈប្រក្រតីហើយប្រព្រឹត្តទៅ គឺកើតឡើងដោយភាវៈដទៃ ។

[ ១៩០ ] បទថា **សត្តំ ឃរាវាសបលិពោធំ** សេចក្តីថា ព្រៃស្តុកក្នុងភាពជាគ្រហស្ថទាំងមូល ។ បទថា **ញាតិមិត្តាមច្ចបលិពោធំ** សេចក្តីថា ញាតិខាងមាតាបិតា មិត្ត សម្លាញ់ អាមាត្យនិងបក្ខពួក ។ បទថា **សន្និធិបលិពោធំ** សេចក្តីថា បោលនូវព្រៃស្តុកក្នុងសម្បត្តិដែលកប់ទុក ។ បទថា **កេសមស្សុំ ឱហារេត្វា** សេចក្តីថា កោរសក់ ពុកមាត់និងពុកចង្កា ។ បទថា **កាសាយានិ វត្ថានិ** សេចក្តីថា សំពត់ដែលជ្រលក់ដោយទឹកចត់ ។

[ ១៩១-១៩២ ] បទថា **មាមកោ** សេចក្តីថា ដល់នូវការរាប់ថា ឧបាសក ឬភិក្ខុរបស់អញ ឬរាប់អានហេតុ មានព្រះពុទ្ធជាដើម ថារបស់អញ ។

បទថា **តេសំ តេសំ សត្តានំ** សេចក្ដីថា ជាពាក្យប្រាប់ថា ទូទៅដល់ពួកសត្វច្រើន ព្រោះកាលពោលអស់មួយថ្ងៃយ៉ាងនេះថា យញ្ញទត្តស្លាប់ សោមទត្តស្លាប់ សត្វទាំងឡាយរមែងមិនដល់នៅការអស់ទៅ មិនសម្ដែងអត្ថដទៃ ព្រោះសត្វណាមួយដែលមិនត្រូវកាន់យកដោយពាក្យទាំងពីរនេះមិនមាននិងមិនមានការសម្ដែងអត្ថដទៃ ។ បទថា **តម្ហា តម្ហា** នេះជាបទសម្ដែងទូទៅដល់ពួកសត្វមិនមែនតិចដោយអំណាចនៃគតិ ។ បទថា **សត្តនិកាយា** សេចក្ដីថា ចាកពួកនៃសត្វទាំងឡាយ អធិប្បាយថា ចាកក្រុមនៃសត្វចាបប្រជុំនៃសត្វ ។ បទថា **ចុតិ** លោកពោលដោយអំណាចនៃការឃ្លាត បទនេះជាពាក្យសាមញ្ញរបស់ចុតិ ដែលមានខន្ធ ១ ខន្ធ ៤ និងខន្ធ ៥ ។ បទថា **ចវនតា** សម្ដែងដល់លក្ខណៈដោយពាក្យសម្ដែងភាវៈ ។ បទថា **ភេទោ** សម្ដែងដល់ការកើតឡើងនៃការបែកធ្លាយរបស់ខន្ធដែលចុតិ ។ បទថា **អន្តរធានំ** សម្ដែងដល់ការប៉ះខ្ទប់មិនបាន ដោយបរិយាយណាមួយរបស់ខន្ធដែលបែកហើយ ដូចឆ្នាំងបែក ។ បទថា **មច្ចុមរណំ** សេចក្ដីថា ការស្លាប់ ពោលគឺមច្ចុ មិនមែនស្លាប់មួយជួរខណៈ ។ អ្នកធ្វើទីបំផុត ឈ្មោះថាកាលៈ ឈ្មោះថា កាលកិរិយា ព្រោះអត្ថថា ជាការធ្វើរបស់អ្នកធ្វើទីបំផុតនោះ ។ ការស្លាប់ដោយសម្មតិលោកសម្ដែងដោយពាក្យមានប្រមាណប៉ុណ្ណោះ ។

ឥឡូវនេះ ដើម្បីនឹងសម្ដែងដោយបរមត្ថ ទើបព្រះសារីបុត្តពោលពាក្យថា **ខន្ធានំ ភេទោ** ជាដើម ។ ដោយបរមត្ថ ខន្ធប៉ុណ្ណោះបែក ឈ្មោះថា សត្វណាមួយស្លាប់មិនមាន តែកាលខន្ធបែក សត្វរមែងស្លាប់ ទើបមានវោហារថា

កាលខន្ធទាំងឡាយបែកហើយ សត្វឈ្មោះថា ស្លាប់ហើយ ។ ក្នុងទីនេះ ការបែកនៃខន្ធទាំងឡាយ រមែងមានដោយអំណាចនៃចតុវោការៈនិងបញ្ចវោការៈ ការដាក់ចុះនូវរាងកាយ រមែងមានដោយអំណាចនៃឯកវោការៈ ម្យ៉ាងទៀត ការបែកនៃខន្ធទាំងឡាយ រមែងមានដោយអំណាចនៃចតុវោការៈប៉ុណ្ណោះ គប្បីជ្រាបការដាក់ចុះនូវរាងកាយ ដោយអំណាចនៃវោការៈទាំងពីរដ៏សេស ព្រោះហេតុអ្វី ព្រោះកើតរាងកាយ ពោលគឺរូបកាយក្នុងកម្មភពទាំងពីរ ។ ម្យ៉ាងទៀត ព្រោះខន្ធទាំងឡាយក្នុងចាតុម្មហារាជិកាជាដើម រមែងបែកទៅប៉ុណ្ណោះ មិនបោះបង់អ្វីមួយទុក ហេតុនោះទើបការបែកនៃខន្ធទាំងឡាយមានដោយអំណាចនៃខន្ធទាំងនោះ ។ មនុស្សជាដើម មានការដាក់ចុះនូវរាងកាយ ក្នុងទីនេះលោកពោលមរណៈថា ការដាក់ចុះនូវរាងកាយ ព្រោះហេតុនៃការដាក់ចុះនូវរាងកាយ ។ ដោយបទថា **ជីវិតិន្ទ្រិយស្សុបច្ឆេទោ** នេះ លោកសម្តែងថា ឈ្មោះថា មរណៈរមែងមានដល់វត្ថុដែលមិនទាក់ទងដោយឥន្ទ្រិយប៉ុណ្ណោះ វត្ថុដែលមិនទាក់ទងដោយឥន្ទ្រិយ រមែងមិនមានមរណៈ ។

ចំណែកពាក្យថា សម្ទូងស្លាប់ ដើមឈើស្លាប់ ត្រឹមតែជាវោហារប៉ុណ្ណោះ តែដោយអត្ថ ពាក្យទាំងឡាយបែបនេះ រមែងសម្តែងដល់ការអស់ទៅដោយការសូន្យទៅរបស់សម្ទូងជាដើមនោះឯង ។

បទថា **រូបគតំ** សេចក្តីថា រូបគតៈ គឺរូបនោះឯង ។ ក្នុងបទថា **វេទនាគតំ** ជាដើម ក៏ន័យនេះដូចគ្នា ។

បណ្តាបទទាំងនោះ បទថា **បុព្វេវ មច្ចំ** សេចក្តីថា ភោគសម្បត្តិទាំង

ឡាយ រមែងលះបង់សត្វទៅមុនខ្លះ សត្វលះបង់ភោគសម្បត្តិទាំងឡាយទៅមុនខ្លះ ព្រះថេរៈហៅព្រះរាជាដែលមកបូន់រាជសម្បត្តិថា **កាមកាមិ** អធិប្បាយថា នៃអ្នកមានកាមដ៏ចម្រើន ឈ្មោះថា ពួកជនមានកាមភោគៈដែលខ្លួនប្រាថ្នាទាំងឡាយមិនទៀងក្នុងលោក កាលភោគៈទាំងឡាយវិនាសទៅ នៅរស់នោះឯង ក៏មិនមានភោគៈខ្លះ វិនាសឯងលះភោគៈទាំងឡាយខ្លះ ព្រោះហេតុនោះក្នុងពេលដែលមហាជនសោយសោក ទើបខ្ញុំមិនសោយសោក ។ ក្នុងបទថា **វិទិតា មយា សត្តុក លោកធម្មា** ព្រះបាទពារាណសីទ្រង់ហៅព្រះរាជាដែលមកបូន់រាជសម្បត្តិ ( ថាសត្រូវ ) អធិប្បាយថា នៃសត្រូវដ៏ចម្រើន លោកធម៌ មានលាភ មិនមានលាភ យស មិនមានយសជាដើម ដែលខ្ញុំដឹងហើយ ។ ឧបមាដូចព្រះចន្ទ រមែងរះឡើង រមែងពេញវង់និងរមែងរលត់ទៅនិងដូចមណ្ឌលព្រះអាទិត្យបញ្ចេញពន្លឺទៅសព្វទ្វីបលោក កម្ចាត់នូវងងឹតពេលល្ងាចក៏គេចទៅ គឺអស្តង្គត មិនប្រាកដទៀតយ៉ាងណា ភោគសម្បត្តិទាំងឡាយរមែងកើតឡើងផង រមែងវិនាសទៅផង ក៏យ៉ាងនោះដូចគ្នា សោយសោកក្នុងភោគសម្បត្តិនោះបានប្រយោជន៍អ្វី ព្រោះដូច្នោះ ទើបខ្ញុំមិនសោយសោក ។

[ ១៩៣ ] បទថា **តណ្ហាមញ្ញនាយ មញ្ញតិ** សេចក្តីថា រមែងសម្គាល់ គឺធ្វើនូវការរាប់អាន ដោយការសម្គាល់ដោយមានះ ដែលតណ្ហាឲ្យកើតហើយ ។ បទថា **ទិដ្ឋិមញ្ញនាយ** សេចក្តីថា ដោយការសម្គាល់កើតឡើង ដោយធ្វើទិដ្ឋិឲ្យជាឧបនិស្ស័យ ។ បទថា **មានមញ្ញនាយ** សេចក្តីថា ដោយការសម្គាល់ដោយមានះដែលកើតរួមគ្នា ។ បទថា **កិលេសមញ្ញនាយ** សេចក្តីថា រមែង

សម្គាល់ដោយការសម្គាល់ដោយកិលេស ដោយអត្ថថា ចូលទៅធ្វើឲ្យក្តៅក្រហាយដែលមានប្រការដូចពោលហើយ ។

[ ១៩៥ ] បទថា **កុហា** សេចក្តីថា ជាអ្នកបោកបញ្ឆោត ។ បទថា **ថទ្ធា** សេចក្តីថា រឹងដូចដង្គត់ឈើ ។ បទថា **លបា** សេចក្តីថា និយាយចាក់បណ្តោយដោយមាននិមិត្តជាបច្ច័យ ។

[ ១៩៦ ] បទថា **សង្គតំ** សេចក្តីថា វត្ថុដែលមកជួប គឺវត្ថុដែលឃើញហើយ ឬដែលពាល់ត្រូវហើយ ។ បទថា **បិយាយិតំ** បានដល់ បុគ្គលដែលខ្ញុំស្រឡាញ់ ។

[ ១៩៧ ] បទថា **សង្គតំ** សេចក្តីថា វត្ថុដែលនៅក្នុងទីចំពោះមុខ ។ បទថា **សមាគតំ** សេចក្តីថា មកជិត ។ បទថា **សមាហិតំ** សេចក្តីថា ដូចគ្នាតែមួយ ។ បទថា **សន្និបតិតំ** សេចក្តីថា ប្រមូលទុក ។

[ ១៩៨ ] បទថា **សុបិនគតោ** សេចក្តីថា ចូលទៅហើយកាន់ភាពយល់សប្តិ ។ បទថា **សេនាវិយូហំ បស្សតិ** សេចក្តីថា ឃើញការបោះជំរំរបស់សេនា ។ បទថា **អារាមរាមណេយ្យកំ** សេចក្តីថា ភាពគួរត្រេកអរនៃសួនច្បារជាដើម ។ ក្នុងបទថា **វនរាមណេយ្យកំ** ជាដើម ក៏ន័យនេះដូចគ្នា ។

[ ២០០ ] បទថា **បេតំ** សេចក្តីថា ចាកលោកនេះទៅកាន់បរលោក ។ បទថា **កាលកតំ** សេចក្តីថា ស្លាប់ហើយ ។

[ ២០១ ] បទថា **នាមមេវាវសិស្សតិ អក្ខេយ្យំ** សេចក្តីថា ធម្មជាតមានរូបជាដើមដែលបុគ្គលលះទៅ សល់ត្រឹមតែឈ្មោះប៉ុណ្ណោះ ដើម្បីនឹងរាប់

គឺហៅយ៉ាងនេះថា ពុទ្ធរក្ខិត ធម្មរក្ខិត ជាដើម ។

[ ២០៤ ] បទថា **យេ ចក្ខុវិញ្ញាណាភិសម្ភូតា** សេចក្តីថា ជនពួកណា មានរូបដែលមានសមុដ្ឋាន ៤ ដែលឃើញមកហើយ ដែលបច្ច័យធ្វើឲ្យជាគំនរ ដែលជ្រាបបានដោយចក្ខុវិញ្ញាណ ។ បទថា **សោតវិញ្ញាណាភិសម្ភូតា** សេចក្តីថា មានសំឡេងដែលមានសមុដ្ឋាន ២ ដែលបានឮមកហើយ ដែលបច្ច័យធ្វើឲ្យជាគំនរដោយសោតវិញ្ញាណ ដោយសំឡេងដែលរំពងមកអំពីទីដទៃ ។

[ ២០៥ ] បទថា **មុនយោ** បានដល់ មុនីដែលជាខីណាស្រព ។ បទថា **ខេមទស្សិនោ** សេចក្តីថា ឃើញនូវព្រះនិព្វាន ។

[ ២០៦ ] ក្នុងសោកនិទ្ទេស បទថា **សោកោ** មានវិនិច្ឆ័យដូចតទៅនេះថា ឈ្មោះថា **ព្យសន** ព្រោះអត្ថថា វិនាស អធិប្បាយថា បន្សាត់ទៅ គឺកម្ចាត់ប្រយោជន៍និងសេចក្តីសុខ ។ ការវិនាសនៃញាតិ ឈ្មោះថា **ញាតិព្យសន** អធិប្បាយថា ការអស់ញាតិ ការវិនាសញាតិដោយចោរ រោគ ភ័យជាដើម ។ ត្រូវការវិនាសនៃញាតិនោះ ។ បទថា **ផុដ្ឋស្ស** សេចក្តីថា លិចលង់ គឺគ្របសង្កត់ ជួប ក្នុងបទដ៏សេសទាំងឡាយក៏ន័យនេះដូចគ្នា ។ តែសេចក្តីប្លែកគ្នាមានដូច្នេះថា ការវិនាសនៃភោគៈទាំងឡាយ ឈ្មោះថា **ភោគព្យសន** អធិប្បាយថា ការអស់ភោគៈ ការវិនាសភោគៈ ដោយអំណាចរាជភ័យនិងចោរភ័យជាដើម ។ ការវិនាសគឺរោគឈ្មោះថា **រោគព្យសន** ។ ដ្បិតថា រោគធ្វើការមិនមានរោគឲ្យវិនាសទៅ ឲ្យអន្តរធានទៅ ព្រោះហេតុនោះ ទើបឈ្មោះថា **ព្យសន** ។ ការវិនាសនៃសីល ឈ្មោះថា **សីលព្យសន** បទនេះជាឈ្មោះរបស់ការ

ទ្រុស្តសីល ។ ការវិនាស គឺទិដ្ឋិដែលកើតឡើង ធ្វើនូវសម្មាទិដ្ឋិឲ្យវិនាសទៅ ឈ្មោះថា **ទិដ្ឋិព្យសនៈ** ។ ក្នុងទីនេះ ការវិនាស ២ យ៉ាងដំបូង មិនពិត ការវិនាស ៣ ខាងក្រោយពិត ត្រូវប៉ះខូចដោយលក្ខណៈ ៣ ការវិនាស ៣ ខាងដើម ជាកុសលក៏មិនមែន ជាអកុសលក៏មិនមែន ការវិនាសសីលនិងទិដ្ឋិ ទាំងពីរជាអកុសល ។

បទថា **អញ្ញតរញ្ញតរេន** សេចក្ដីថា ត្រូវការវិនាសឯណានីមួយរួមទុកហើយក្ដី ត្រូវការវិនាសណាមួយ ក្នុងការវិនាសនៃមិត្តនិងអាមាត្យជាដើមដែលមិនទាន់បានរួមទុកក្ដី ។ បទថា **សមន្នាគតស្ស** សេចក្ដីថា តាមចង គឺមិនផុតទៅ ។ បទថា **អញ្ញតរញ្ញតរេន ទុក្ខធម្មេន** សេចក្ដីថា ត្រូវហេតុដើម្បីការកើតឡើងនៃទុក្ខ គឺសេចក្ដីសោកណាមួយ ។ បទថា **សោកោ** សេចក្ដីថា ឈ្មោះថា **សោកោ** ដោយអំណាចនៃសេចក្ដីសោក បទនេះជាសភាវៈចំពោះខ្លួននៃសេចក្ដីសោកដែលកើតឡើង ដោយហេតុទាំងនេះ ។ បទថា **សោចនា** បានដល់ អាការៈដែលសោក ។ បទថា **សោចិតត្តំ** បានដល់ ភាពជាអ្នកសោយសោក ។ បទថា **អន្តោសោកោ** បានដល់ សេចក្ដីសោកក្នុងខាងក្នុង ។ លោកពង្រីកបទទី ២ ( អន្តោបរិសោកោ ) ដោយឧបសគ្គ ដ្បិតថា សេចក្ដីសោកនោះកើតឡើង ធ្វើខាងក្នុងឲ្យរីងស្ងួត ឲ្យហួតហែងដោយជុំវិញ ហេតុនោះទើបហៅថា សេចក្ដីសោកក្នុងខាងក្នុង សេចក្ដីសោកសៅដោយជុំវិញក្នុងខាងក្នុង ។ បទថា **អន្តោឌាហោ** បានដល់ ការក្ដៅក្រហាយក្នុងខាងក្នុងលោកពង្រីកបទ ២ ដោយឧបសគ្គ ។ បទថា **ចេតសោ បរិជ្ឈាយនា** បានដល់

អាការៈ គឺការក្រៀមក្រំនៃចិត្ត ដ្បិតថា សេចក្ដីសោកកាលកើតឡើង រមែងញ៉ាំងចិត្តឲ្យឆេះ គឺដុតចិត្តដូចភ្លើង ធ្វើឲ្យនិយាយថា ចិត្តរបស់ខ្ញុំត្រូវដុត អ្វីមួយ មិនជាក់ច្បាស់ដល់ខ្ញុំ ចិត្តដល់នូវសេចក្ដីទុក្ខ ឈ្មោះថាទុក្ខចិត្ត ភាវៈនៃទុក្ខចិត្ត ឈ្មោះថា **ទោមនស្សំ** ។ សរគឺសេចក្ដីសោក ដោយអត្ថថា ចូលទៅដោយលំដាប់ ព្រោះហេតុនោះ ទើបឈ្មោះថា **សោកសល្លំ** ។

ក្នុងបរិទេវនិទ្ទេស មានវិនិច្ឆ័យដូចតទៅនេះថា ឈ្មោះថា **អាទេវោ** ព្រោះអត្ថថា ជាហេតុរវើរវាយ គឺយំយ៉ាងនេះថា កូនស្រីរបស់ខ្ញុំ កូនប្រុសរបស់ខ្ញុំ ឈ្មោះថា **បរិទេវៈ** ព្រោះអត្ថថា ជាហេតុរវើរវាយ សរសើរគុណនោះៗ ។ បទ ២ គូខាងក្រោយបន្ទាប់អំពីនោះ លោកពោលដោយអំណាចសម្ដែងអាការៈនិងភាវៈរបស់បទ ២ ខាងដើមនោះឯង ។ បទថា **វាចា** បានដល់ពាក្យពោល ។ បទថា **បលាបោ** បានដល់ ពាក្យពោលដែលទទេ គឺឥតប្រយោជន៍ ។ ឈ្មោះថា **វិប្បលាបោ** ព្រោះអត្ថថា ការរវើរវាយប្លែកៗដោយអំណាចពោលក្រៅរឿងនិងពោលរឿងដទៃៗ ។ បទថា **លាលប្បោ** បានដល់រវើរវាយរឿយៗ ។ អាការៈរវើរវាយ ឈ្មោះថា **លាលប្បនា** ។ ភាពនៃបុគ្គលរវើរវាយ ឈ្មោះថា **លាលប្បិតត្តំ** ។ ភាពជាអ្នកកំណាញ់ជាដើម មានអត្ថដូចបានពោលទុកហើយនោះឯង ។

[ ២០៨ ] គាថាទី ៧ ព្រះមានព្រះភាគត្រាស់ដើម្បីសម្ដែងបដិបទាដែលសមគួរក្នុងលោក ដែលត្រូវមរណៈកម្ចាត់យ៉ាងនេះ ។

បណ្ដាបទទាំងនោះ បទថា **បដិលីនចរស្ស** សេចក្ដីថា ជាអ្នកប្រព្រឹត្តធ្វើ

*ចិត្តឲ្យពួនសម្ងំចាកអារម្មណ៍នោះៗ ។ បទថា* **ភិក្ខុនោ** *បានដល់ កល្យាណ បុថុជ្ជនខ្លះ សេក្ខបុគ្គលខ្លះ ។ បទថា* **សាមគ្គិយមាហុ តស្ស តំ យោ អត្តានំ ភវនេ ន ទស្សយេ** *សេចក្ដីថា ភិក្ខុណាបដិបត្តិយ៉ាងនេះ មិនគប្បីសម្ដែងខ្លួន ក្នុងភពមាននរកជាដើម បណ្ឌិតទាំងឡាយពោលការមិនសម្ដែងខ្លួននោះ របស់ ភិក្ខុនោះថាសមគួរ អធិប្បាយថា ភិក្ខុនោះគប្បីផុតចាកមរណៈនេះ ដោយ អាការៈយ៉ាងនេះ ។*

*[ ២០៩ ] បទថា* **បដិលីនចរា វុច្ចន្តិ** *សេចក្ដីថា ព្រះមានព្រះភាគត្រាស់ ថា អ្នកប្រព្រឹត្តដោយអើពើនូវចិត្តខ្វាសអំពីអារម្មណ៍នោះៗ ។ បទថា* **សត្ត សេក្ខា** *សេចក្ដីថា ឈ្មោះថា សេក្ខបុគ្គល ៧ ពួក តាំងអំពីបុគ្គលតាំងនៅក្នុង សោតាបត្តិមគ្គ រហូតដល់បុគ្គលតាំងនៅក្នុងអរហត្តមគ្គ ព្រោះអត្ថថា សិក្សា ក្នុងសិក្ខា ៣ មានអធិសីលសិក្ខាជាដើម ។ បទថា* **អរហា** *បានដល់ ដែល តាំងនៅក្នុងអរហត្តផល បុគ្គលតាំងនៅក្នុងអរហត្តផលនោះ ឈ្មោះថា* **បដិ-លីនោ** *ព្រោះមានកិច្ចនៅចប់ហើយ ។*

*ព្រះសារីបុត្តត្ថេរ កាលនឹងសម្ដែងហេតុ ក្នុងការប្រព្រឹត្តពួនសម្ងំរបស់ ព្រះសេក្ខៈទាំងឡាយ ទើបពោលថា* **កឹការណា** *ជាដើម ។ បទថា* **តេ តតោ តតោ** *សេចក្ដីថា ព្រះសេក្ខៈ ៧ ពួកនោះ ញុំាងចិត្តឲ្យពួនសម្ងំចាកអារម្មណ៍ នោះៗ ។ បទថា* **ចិត្តំ បដិលីនេន្តា** *សេចក្ដីថា ញុំាងចិត្តរបស់ខ្លួនឲ្យពួនសម្ងំ ។ បទថា* **បដិកុដ្ដេន្តា** *សេចក្ដីថា ឲ្យរួញត្រឡប់ ។ បទថា* **បដិវដ្ដេន្តា** *សេចក្ដីថា រមូរដូចកន្ទេលផែង ។ បទថា* **សន្និរុទ្ធន្តា** *សេចក្ដីថា រារាំង ។*

បទថា **សន្និគ្គណ្ហាន្តា** សេចក្តីថា ធ្វើនូវការសង្កត់ ។ បទថា **សន្និវារេន្តា** សេចក្តីថា ហាមឃាត់ ។ បទថា **រក្ខន្តា** សេចក្តីថា ធ្វើនូវការរក្សា ។ បទថា **គោបេន្តា** សេចក្តីថា ឃុំគ្រងទុកក្នុងប្រអប់គឺចិត្ត ។ ឥឡូវនេះ កាលនឹងសម្តែងដោយអំណាចនៃទ្វារ ទើបព្រះសារីបុត្តត្ថេរពោលថា **ចក្ខុទ្វារេ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **ចក្ខុទ្វារេ** បានដល់ ក្នុងទ្វារគឺចក្ខុវិញ្ញាណ សូម្បីក្នុងសោតទ្វារជាដើមក៏ន័យនេះដូចគ្នា ។ បទថា **ភិក្ខុនោ** បានដល់ របស់ភិក្ខុដែលជាកល្យាណបុថុជ្ជនខ្លះ ភិក្ខុដែលជាសេក្ខបុគ្គលខ្លះ ហេតុនោះ ទើបព្រះថេរៈមិនពោលអត្ថនៃពាក្យរបស់សព្វថាភិក្ខុ សម្តែងតែភិក្ខុដែលបំណងយកក្នុងទីនេះប៉ុណ្ណោះ ។

បណ្តាភិក្ខុទាំងនោះ ភិក្ខុនោះឈ្មោះថា បុថុជ្ជន ព្រោះដកនូវកិលេសទាំងឡាយមិនទាន់បាន និងឈ្មោះថាកល្យាណ ព្រោះប្រកបដោយបដិបទា មានសីលជាដើម ហេតុនោះ ទើបឈ្មោះថា កល្យាណបុថុជ្ជន កល្យាណបុថុជ្ជននោះឯងឈ្មោះថា ជាកល្យាណបុថុជ្ជន ។ នៃភិក្ខុដែលជាកល្យាណបុថុជ្ជននោះ ។ ឈ្មោះថា **សេក្ខ** ព្រោះអត្ថថា សិក្សាអធិសីលជាដើមនៃភិក្ខុនោះ ដែលជាសេក្ខៈខ្លះ គឺជាព្រះសោតាបន្នខ្លះ ព្រះសកទាគាមីខ្លះ ព្រះអនាគាមីខ្លះ ។

[ ២១០ ] ឈ្មោះថា **អាសនំ** ព្រោះអត្ថថា ជាទីអង្គុយ គឺលិចចុះ ។ បទថា **យត្ថ** បានដល់ ក្នុងអាសនៈទាំងឡាយណា មានគ្រែនិងតាំងជាដើម ។ បទថា **មញ្ចោ** ជាដើម ជាពាក្យសម្តែងប្រភេទនៃអាសនៈ ។ ពិតហើយ

*សូម្បីគ្រែលោកក៏ពោលទុកក្នុងអាសនៈទាំងឡាយក្នុងទីនេះ ព្រោះជាឱកាសសម្រាប់អង្គុយ គ្រែនោះ គឺគ្រែដែលគេបញ្ចូលមេទៅក្នុងជំណាប់ជើង ១ គ្រែដែលមានមេជាប់នឹងជើង ១ គ្រែដែលមានជើងដូចជាជើងក្តាម ១ គ្រែដែលមានជើងចុចឬគ្រែដែលគេបញ្ចូលជើងទៅក្នុងជំណាប់មេ ១ ឯណានីមួយ ។ សូម្បីតាំងជាដើមក៏បែបនោះ ឯណានីមួយនោះឯង ។*

*បទថា* **ភិសិ** *បានដល់ ពូកធ្វើអំពីរោមសត្វ ពូកសំពត់ ពូកសម្បកឈើ ពូកស្មៅនិងពូកស្លឹកឈើណាមួយ ។ បទថា* **តដ្ដិកា** *បានដល់ កន្ទេលដែលត្បាញដោយស្លឹកត្នោតជាដើម ។ បទថា* **ចម្មខណ្ឌោ** *បានដល់ កំណាត់ស្បែកណាមួយ ដែលគួរដល់ការអង្គុយ គ្រឿងកម្រាលធ្វើដោយស្មៅជាដើម បានដល់ កម្រាលដែលញាត់ដោយស្មៅជាដើម ។*

*បទថា* **អសប្បាយរូបទស្សនេន** *សេចក្តីថា ចាកការសម្លឹងមើលរូបដែលគួរពេញចិត្ត ដែលមិនជាទីសប្បាយ ។ បទថា* **វិត្តំ** *សេចក្តីថា ស្ងាត់ខាងក្នុង ។ បទថា* **វិវិត្តំ** *សេចក្តីថា ស្ងាត់អំពីការចូលទៅអំពីខាងក្រៅ ។ បទថា* **បវិវិត្តំ** *សេចក្តីថា ស្ងាត់ក្រៃលែងថា មិនមានគ្រហស្ថណាមួយក្នុងទីនោះ ក្នុងការបានឮសំឡេងមិនជាទីសប្បាយ ក៏ន័យនេះដូចគ្នា ។*

*បទថា* **បញ្ចហិ កាមគុណេហិ** *សេចក្តីថា ចាកចំណែកនៃកាម ៥ គឺ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈរបស់ស្រី សមដូចព្រះតម្រាស់ ( ក្នុងអង្គុត្តរនិកាយបញ្ចកនិបាត ) ថា*

*កាមគុណទាំង ៥ នុ៎ះ គឺរូប សំឡេង ក្លិន រស ផ្សព្វ ដែល*

ជាតម្រេកនៃចិត្ត រមែងប្រាកដក្នុងរូបនៃស្ត្រី ដូច្នេះ ។

បទថា **ភជតោ** សេចក្តីថា ធ្វើនូវការសេពដោយចិត្ត ។ បទថា **សម្ភជតោ** សេចក្តីថា សេពដោយប្រពៃ ។ បទថា **សេវតោ** សេចក្តីថា ចូលទៅរក ។ បទថា **និសេវតោ** សេចក្តីថា សេពជាវិស័យ ។ បទថា **សំសេវតោ** សេចក្តីថា សេពដោយល្អ ។ បទថា **បដិសេវតោ** សេចក្តីថា ចូលទៅរករឿយៗ ។

[ ២១១ ] បទថា **គណសាមគ្គី** បានដល់ ភាពដូចគ្នាតែមួយ គឺការព្រមព្រៀងគ្នានៃសមណៈទាំងឡាយ ។ បទថា **ធម្មសាមគ្គី** បានដល់ ការប្រជុំនៃពោធិបក្ខិយធម៌ ៣៧ ប្រការ ។ បទថា **អនភិនិព្វត្តិសាមគ្គី** សេចក្តីថា ប្រជុំនៃព្រះអរហន្តទាំងឡាយដែលមិនទាន់កើតឡើង គឺមិនកើតឡើង ដែលបរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ។ បទថា **សមគ្គា** សេចក្តីថា មិនបែកគ្នាផ្លូវកាយ ។ បទថា **សម្មោទមានា** សេចក្តីថា មានចិត្តត្រេកអរ គឺត្រេកអរដោយល្អ ។ បទថា **អវិវទមានា** សេចក្តីថា មិនធ្វើនូវវិវាទដល់គ្នានឹងគ្នាដោយវាចា ។ បទថា **ខីរោទកីភូតា** សេចក្តីថា ដូចគ្នានឹងទឹកលាយជាមួយទឹកដោះ ។

បទថា **តេ ឯកតោ បក្ខន្ទន្តិ** សេចក្តីថា ពោធិបក្ខិយធម៌ទាំងនោះ រមែងចូលទៅកាន់អារម្មណ៍តែមួយ ។ បទថា **បសីទន្តិ** សេចក្តីថា រមែងចូលដល់នូវការផូរផង់ក្នុងអារម្មណ៍នោះឯង ។ បទថា **អនុបាទិសេសាយ** សេចក្តីថា វៀរចាកឧបាទាន ។

បទថា **និព្វានធាតុយា** សេចក្តីថា ដោយអមតមហានិព្វានធាតុ ។ ក្នុង

បទថា **ឱនត្តំ វា** នេះ ការខ្វះខាត ឈ្មោះថា ឱនត្តៈ អធិប្បាយថា ការមិនបរិបូណ៌ ។ បទថា **បុណ្ណត្តំ វា** សេចក្តីថា ការបរិបូណ៌ ឈ្មោះថា បុណ្ណត្តៈ អធិប្បាយថា ឬការពេញ រមែងមិនប្រាកដ គឺមិនមាន ។

បទថា **នេរយិកានំ** សេចក្តីថា ឈ្មោះថានេរយិកា ព្រោះអត្ថថា គួរដល់នរក ព្រោះបាបដែលមានកម្មឲ្យកើតក្នុងនរក ។ របស់ពួកសត្វដែលកើតក្នុងនរកនោះ ។ បទថា **និរយោ ភវនំ** សេចក្តីថា នរកនោះឯងជាលំនៅ គឺជាផ្ទះរបស់សត្វនរកទាំងនោះ ។ ក្នុងបទថា **តិរច្ឆានយោនិកានំ** ជាដើមក៏ដូច្នោះដូចគ្នា ។

បទថា **តស្សេវសា សាមគ្គី** សេចក្តីថា ការមិនសម្តែងខ្វួននោះ របស់ព្រះទីណាស្រេពនោះ នេះជានិព្វានសាមគ្គី ។ បទថា **ឯតំ ជន្នំ** សេចក្តីថា សេចក្តីនោះជាការសមគួរ ។ បទថា **បដិរូបំ** សេចក្តីថា ដូចគ្នា មានចំណែកប្រៀបធៀបគ្នាបាន គឺមិនមែនមិនដូចគ្នា មិនមានចំណែកប្រៀបគ្នា ។ បទថា **អនុច្ឆវិកំ** សេចក្តីថា សេចក្តីនោះសមគួរដល់ធម៌ដែលធ្វើឲ្យជាសមណៈខ្វះ ដល់ធម៌ដែលជាពាក្យប្រៀនប្រដៅទាក់ទងដោយមគ្គផលនិព្វានខ្វះ រមែងអនុលោមតាមទៅតាមសេចក្តីល្អ ព្រោះការសមគួរដល់ធម៌ទាំងនោះ ។ ដោយពិត ការសាមគ្គីរមែងមានក្នុងទីជិតនោះឯងដោយធម៌ទាំងនោះ ។ ម្យ៉ាងទៀត សេចក្តីនោះជាអនុលោម ព្រោះសមគួរនោះឯង និងរមែងអនុលោមដល់ធម៌ទាំងនោះ ។ ដោយពិត មិនបានតាំងនៅក្នុងភាពជាសត្រូវដែលជំទាស់ឡើយ ។

ឥឡូវនេះ ព្រះមានព្រះភាគត្រាស់គាថា ៣ បន្ទាប់អំពីនេះ ដើម្បីសរសើរ

ព្រះខីណាស្រពដែលទ្រង់សរសើរទុកយ៉ាងនេះថា **យោ អត្តានំ ភវេន ន ឧបស្សយេ** ដូច្នេះ ។

[ ២១២-២១៣ ] បណ្តាគាថា ៣ គាថានោះ គាថាដំបូង មានវិនិច្ឆ័យដូចតទៅនេះថា

បទថា **សព្វត្ថ** បានដល់ ក្នុងអាយតនៈ ១២ ។ ក្នុងនិទ្ទេសថា **ន បិយំ កុព្វតិ នោបិ អប្បិយំ** សេចក្តីថា បទថា **បិយា** បានដល់ ដែលធ្វើបីតិក្នុងចិត្ត ។

[ ២១៤ ] ព្រះសារីបុត្តត្ថេរ កាលនឹងសម្តែងសត្វនិងសង្ខារទាំងនោះ ជាចំណែកៗ ទើបពោលថា **កតមេ សត្តា បិយា ឥធ យស្ស តេ ហោន្តិ** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យស្ស តេ** កាត់បទជា **យេ អស្ស តេ** សេចក្តីថា សត្វទាំងនោះ ។ បទថា **ហោន្តិ** បានដល់ រមែងជា ។ បទថា **អត្ថកាមា** សេចក្តីថា ជាអ្នកប្រាថ្នាសេចក្តីចម្រើន ។ បទថា **ហិតកាមា** សេចក្តីថា ជាអ្នកប្រាថ្នាសេចក្តីសុខ ។ បទថា **ផាសុកាមា** សេចក្តីថា ជាអ្នកប្រាថ្នានៅជាសុខ ។ បទថា **យោគក្ខេមកាមា** សេចក្តីថា ជាអ្នកប្រាថ្នានូវការក្សេម គឺផុតភ័យចាកយោគៈ ៤ ។ ឈ្មោះថា **មាតា** ព្រោះអត្ថថា ថ្នមស្រឡាញ់ ។ ឈ្មោះថា **បិតា** ព្រោះអត្ថថា ប្រព្រឹត្តស្រឡាញ់ ។ ឈ្មោះថា **ភាតា** ព្រោះអត្ថថា ស្និទ្ធស្នាល ។ ក្នុងបទថា **ភគិនី** ក៏មានន័យដូចគ្នា ។ ឈ្មោះថា **បុត្តា** ព្រោះអត្ថថា ជាអ្នកការពារនូវកំណាប់ទ្រព្យដែលឈ្មោះថា បុំ គឺរក្សាវង្សត្រកូល ។ ឈ្មោះថា **ធីតា** ព្រោះអត្ថថា តាំងវង្សត្រកូលទុក ។ បទថា

**មិត្តា** បានដល់ សម្លាញ់ ។ បទថា **អមច្ចា** បានដល់ អ្នកចិញ្ចឹម ។ បទថា **ញាតី** បានដល់ ញាតិខាងបិតា ។ **សាលោហិតា** បានដល់ ញាតិខាងមាតា ។ បទថា **ឥមេ សត្តា បិយា** សេចក្តីថា សត្វទាំងនេះ ញុំាងបីតិឲ្យកើត សត្វដែលជាទីស្អប់ គប្បីជ្រាបដោយបរិយាយផ្ទុយគ្នាតាមដែលពោលមកហើយ ។

[ ២១៦ ] ក្នុងបទថា **យមិទំ ទិដ្ឋសុតំ មុតេសុ វា** នេះគប្បីជ្រាបការភ្ជាប់សេចក្តីយ៉ាងនេះថា មុនីរមែងមិនចូលទៅជាប់ក្នុងរូបដែលឃើញ សំឡេងដែលបានឮ ឬធម្មារម្មណ៍ដែលជ្រាបដូច្នោះ ។

[ ២១៧ ] បទថា **ឧទកថេវោ** បានដល់ ដំណក់នៃទឹក ។ បាឋៈថា **ឧទក–ត្ថេវកោ** ដូច្នេះក៏មាន ។ បទថា **បទុមបត្តេ** បានដល់ លើស្លឹកឈូក ។

[ ២២០ ] ក្នុងបទថា **ធោនោ ន ហិ តេន មញ្ញតិ យមិទំ ទិដ្ឋសុតំ មុតេសុ វា** នេះ គប្បីជ្រាបការភ្ជាប់បទយ៉ាងនេះដូចគ្នាថា ព្រះអរហន្តអ្នកមានបញ្ញាជាគ្រឿងកម្ចាត់ រមែងមិនសម្គាល់ដោយវត្ថុដែលឃើញ ឬដែលបានឮនោះ ឬរមែងមិនសម្គាល់ក្នុងធម្មារម្មណ៍ទាំងឡាយដែលជ្រាប ។ បទថា **ន ហិ សោ រជ្ជតិ នោ វិរជ្ជតិ** សេចក្តីថា រមែងមិនត្រេកត្រអាលដូចពាលបុថុជ្ជន រមែងមិនប្រាសចាកតម្រេក ដូចកល្យាណបុថុជ្ជននិងសេក្ខបុគ្គល តែ ( ព្រះអរហន្ត ) រមែងដល់នូវការរាប់ថា ជាអ្នកប្រាសចាកតម្រេកហើយ ព្រោះមានរាគៈអស់ហើយ ។ បទដ៏សេសប្រាកដច្បាស់ហើយនោះឯង ។

[ ២២១ ] បទថា **តាយ បញ្ញាយ កាយទុច្ចរិតំ** សេចក្តីថា ព្រះយោគីកំណត់វត្ថុដែលគួរកំណត់ដោយបញ្ញាដែលសម្បយុត្តនោះ ឬដោយបញ្ញាដែល

ជាចំណែកខាងដើមនោះឯង រមែងកម្ចាត់នូវកាយទុច្ចរិត ៣ ដោយអំណាចនៃការកាត់ផ្តាច់ ។ បុគ្គលនេះកាលកម្ចាត់វិបន្នធម៌ ក្នុងទេសនាធម៌ទាំងឡាយជាបុគ្គលអ្នកមានការដល់ព្រមដោយធុតធម៌ ទើបឈ្មោះថា រមែងកម្ចាត់បុគ្គលប្រើបញ្ញាជាគ្រឿងកម្ចាត់ធម៌ទាំងនោះ ផ្តើមកម្ចាត់ក្នុងខណៈដែលជាបច្ចុប្បន្នរបស់ខ្លួន លោកហៅថា អ្នកកម្ចាត់ ដូចបុគ្គលដែលផ្តើមបរិភោគ គេហៅថា អ្នកបរិភោគ ម្យ៉ាងទៀត គប្បីជ្រាបលក្ខណៈដោយសព្ទសាស្ត្រក្នុងទីនេះ ។

បទថា **ធុតំ** ជាកត្តុសាធនៈ កម្ចាត់ដោយសោតាបត្តិមគ្គ លាងដោយសកទាគាមិមគ្គ ជម្រះដោយអនាគមិមគ្គ បោកគក់ដោយអរហត្តមគ្គ ។

បទថា **នោនោ ទិដ្ឋំ ន មញ្ញតិ** សេចក្តីថា ព្រះអរហន្តរមែងមិនសម្គាល់នូវរូបាយតនៈដែលឃើញដោយមំសចក្ខុ ដែលឃើញដោយទិព្វចក្ខុ ដោយការសម្គាល់ ៣ យ៉ាង សេចក្តីនេះដូចម្តេច ព្រះអរហន្តមិនឃើញរូបាយតនៈដោយសុភសញ្ញានិងសុខសញ្ញា រមែងមិនញុំាងឆន្ទរាគៈឲ្យកើតក្នុងរូបាយតនៈនោះ មិនត្រេកអរ មិនត្រេកត្រអាលក្នុងរូបាយតនៈនោះ ។ ព្រះអរហន្តរមែងមិនសម្គាល់រូបដែលឃើញដោយការសម្គាល់ដោយតណ្ហាដោយប្រការដូច្នេះ ។ ឬថាព្រះអរហន្ត មិនសង្ឃឹមនូវការត្រេកអរក្នុងរូបាយតនៈយ៉ាងនេះថា រូបរបស់អញក្នុងអនាគតកាលគប្បីដូច្នេះ ឬគប្បីសង្ឃឹមក្នុងរូបសម្បត្តិ មិនឲ្យទាន មិនសមាទានសីល មិនធ្វើឧបោសថកម្ម ព្រះអរហន្តរមែងមិនសម្គាល់រូបដែលឃើញដោយការសម្គាល់ ដោយតណ្ហាយ៉ាងនេះក៏មាន ព្រះអរហន្តមិនបានអាស្រ័យសម្បត្តិនិងវិបត្តិនៃរូបទាំងរបស់ខ្លួននិងរបស់អ្នកដទៃ ញុំាងមានះឲ្យ

កើតថា អញប្រសើរជាងបុគ្គលនេះខ្លះ អញស្មើបុគ្គលនេះខ្លះ អញអាក្រក់ជាងបុគ្គលនេះខ្លះ ។ ព្រះអរហន្តមិនសម្គាល់រូបដែលឃើញដោយការសម្គាល់ដោយមានះយ៉ាងនេះ ។ ព្រះអរហន្តមិនសម្គាល់រូបាយតនៈថាទៀង ថាឋិតថេរបន្តទៅរឿយៗ មិនសម្គាល់ខ្លួនថា វត្ថុដែលទាក់ទងដោយខ្លួន មិនសម្គាល់វត្ថុមិនជាមង្គល ថាជាមង្គល ។ ព្រះអរហន្តមិនសម្គាល់រូបដែលឃើញដោយការសម្គាល់ដោយទិដ្ឋិយ៉ាងនេះ ។

បទថា **ទិដ្ឋស្មឹ ន មញ្ញតិ** សេចក្តីថា កាលមិនសម្គាល់ខ្លួនក្នុងរូបដោយន័យនៃការពិចារណាឃើញ រមែងមិនសម្គាល់ក្នុងរូបដែលឃើញ ។ ព្រះអរហន្តកាលមិនសម្គាល់ថា កិលេសមានរាគៈជាដើមក្នុងរូប ដូចមិនសម្គាល់ទឹកដោះក្នុងកន្សោមដោះ ឈ្មោះថា រមែងមិនសម្គាល់ក្នុងរូបដែលឃើញ ។

ការសម្គាល់ដោយតណ្ហានិងមានះគប្បីជ្រាបថា មិនមានដល់ព្រះអរហន្តនោះដែលមិនញុំាងស្នេហានិងមានះឲ្យកើតឡើងក្នុងវត្ថុដែលខ្លួនមិនសម្គាល់ ដោយការសម្គាល់ដោយទិដ្ឋិនោះឯង ព្រះអរហន្តរមែងមិនសម្គាល់ក្នុងរូបដែលឃើញយ៉ាងនេះ ។

បទថា **ទិដ្ឋតោ** ក្នុងបទទាំងឡាយថា **ទិដ្ឋតោ ន មញ្ញតិ** នេះជាបញ្ចមីវិភត្តិ ព្រោះហេតុនោះ ព្រះអរហន្តកាលមិនសម្គាល់ថា ឧបត្តិ ឬអស់ទៅចាករូបដែលឃើញ មានប្រភេទតាមដែលពោលហើយរបស់ខ្លួនក្តី របស់អ្នកដទៃក្តីក៏តាមព្រមទាំងឧបករណ៍ ឬអត្តាដទៃចាករូបដែលឃើញ គប្បីជ្រាបថារមែងមិនសម្គាល់ចាករូបដែលឃើញ ព្រះអរហន្តនោះ មិនមានការសម្គាល់ដោយ

ទិដ្ឋិនេះ សូម្បីការសម្គាល់ដោយតណ្ហានិងមានះ ក៏គប្បីជ្រាបថា មិនមានដល់ព្រះអរហន្តនោះ ដែលមិនញុំាងស្នេហានិងមានះឲ្យកើតឡើងក្នុងវត្ថុដែលខ្លួនមិនសម្គាល់ដោយការសម្គាល់ដោយទិដ្ឋិនោះឯង ។

ក្នុងបទថា **ទិដ្ឋំ មេតិ ន មញ្ញតិ** នេះ សេចក្តីថា ព្រះអរហន្តមិនប្រកាន់ថាជារបស់អញ ដោយអំណាចនៃតណ្ហាថា នុ៎ះជារបស់អញ រមែងមិនសម្គាល់រូបដែលឃើញ ដោយការសម្គាល់ដោយតណ្ហា ។ បទថា **សុតំ** សេចក្តីថា បានឮដោយមំសសោតៈក្តី បានឮដោយទិព្វសោតៈក្តី បទនេះជាឈ្មោះនៃសទ្ទាយតនៈ ។ បទថា **មុតំ** សេចក្តីថា ចូលទៅទល់អារម្មណ៍ដែលជ្រាបនិងរាប់ហើយកាន់យក លោកអធិប្បាយទុកថា ដែលកើតឡើងដោយសន្និ-លេសអាស្រ័យនូវគ្នានឹងគ្នានៃអារម្មណ៍ទាំងឡាយនិងនៃឥន្ទ្រិយទាំងឡាយ ។ ពាក្យនេះ ជាឈ្មោះនៃគន្ធាយតនៈ រសាយតនៈនិងផោដ្ឋព្វាយតនៈ ។ បទថា **វិញ្ញាតំ** សេចក្តីថា ដឹងច្បាស់ដោយចិត្ត បទនេះជាឈ្មោះនៃអាយតនៈ ៧ ដ៏សេសក្នុងទីនេះ រមែងបានអារម្មណ៍ដែលទាក់ទងដោយសក្កាយទិដ្ឋិនៃធម្មា-រម្មណ៍នោះឯង ។ ចំណែកសេចក្តីពិស្តារក្នុងសេចក្តីនេះ គប្បីជ្រាបដោយន័យដែលពោលហើយក្នុងទិដ្ឋវារៈ ។

ឥឡូវនេះ ព្រះសារីបុត្តត្ថេរកាលនឹងសម្តែងដោយអំណាចនៃសូត្រ ដែលព្រះដ៏មានព្រះភាគត្រាស់ទុក ទើបពោលពាក្យថា **អស្មីតិ ភិក្ខវេ** ជាដើម ។ បណ្តាបទទាំងនោះ បទថា **អស្មិ** សេចក្តីថា មាន បទនេះជាឈ្មោះនៃការទៀង ។ បទថា **មញ្ញិតមេតំ** សេចក្តីថា សេចក្តីនោះជាគ្រឿងកំណត់ដោយ

ទិដ្ឋិ ។ បទថា **អយមហមស្មិ** សេចក្តីថា អញមាន គឺរស់នៅដល់អញ ។

[ ២២២-២២៣ ] បទថា **អញ្ញត្រ សតិប្បដ្ឋានេហិ** សេចក្តីថា វៀរចាក សតិប្បដ្ឋាន ៤ ។

បទថា **សព្វេ ពាលបុថុជ្ជនា វជ្ជន្តិ** សេចក្តីថា ជនផ្សេងៗដែលជាអន្ធពាលទាំងអស់ រមែងជាប់ ។ បទថា **សត្ត សេក្ខា វិវជ្ជន្តិ** សេចក្តីថា អរិយជន ៧ ពួក មានព្រះសោតាបន្នជាដើម រមែងដល់នូវការប្រាសចាកតម្រេក ។ បទថា **អរហា នេវ វជ្ជតិ នោ វិវជ្ជតិ** សេចក្តីថា ព្រោះថាព្រះអរហន្តរមែងមិនធ្វើទាំងពីរយ៉ាង ព្រោះកិលេសទាំងឡាយឲ្យរលត់ឥតសេសសល់ហើយ ។ បទទាំង ៣ ថា **១យា ភាគស្ស** ជាដើម គឺព្រះនិព្វាននោះឯង ។

## អដ្ឋកថា ជរាសុត្តនិទ្ទេសទី ៦ ចប់

# តិស្សមេត្តេយ្យសុត្តនិទ្ទេស ទី ៧

[ ២២៤ ] ( ព្រះតិស្សមេត្តេយ្យៈ មានអាយុក្រាបទូលយ៉ាងនេះថា ) បពិត្រព្រះអង្គទ្រង់និរទុក្ខ សូមព្រះអង្គពោលសេចក្ដីចង្អៀតចង្អល់របស់បុគ្គលដែលប្រកបរឿយៗក្នុងមេថុន យើងខ្ញុំស្ដាប់ពាក្យប្រដៅរបស់ព្រះអង្គហើយនឹងសិក្សាក្នុងវិវេក ។

[ ២២៥ ] ពាក្យថា បុគ្គលប្រកបរឿយៗក្នុងមេថុន អធិប្បាយថា ឈ្មោះថាមេថុនធម្ម បានដល់ ធម៌របស់អសប្បុរស ធម៌របស់អ្នកស្រុក ធម៌របស់ជនថោកទាប ធម៌អាក្រក់ មានទឹកជាទីបំផុត ធម៌កើតក្នុងទីកំបាំង ការជួបជុំរបស់បុគ្គលពីរៗនាក់ ។ ដែលលោកហៅថា មេថុនធម្ម តើព្រោះហេតុអ្វី ។ ធម៌របស់បុគ្គលពីរនាក់ដែលត្រេកអរ ត្រេកអរខ្លាំង ជោក ( ដោយរាគៈ ) រួបរឹត ( ដោយរាគៈ ) មានចិត្តត្រូវកិលេសគ្របសង្កត់ស្មើគ្នាទាំងពីរនាក់ ព្រោះហេតុនោះ ទើបលោកហៅថា មេថុនធម្ម ។ ជនពីរនាក់ ធ្វើជម្លោះ លោកហៅថា គូជម្លោះ ជនពីរនាក់ ធ្វើសេចក្ដីប្រកួតប្រកាន់ លោកហៅថា គូប្រកួតប្រកាន់ជនពីរនាក់ធ្វើការនិយាយគ្នា លោកហៅថា គូនិយាយគ្នា ជនពីរនាក់ធ្វើការជជែកគ្នា លោកហៅថា គូជជែកគ្នា ជនពីរនាក់ ធ្វើអធិករណ៍ លោកហៅថា គូអធិករណ៍ ជនពីរនាក់ ចរចាគ្នាជាប្រក្រតី លោកហៅថា គូចរចា ជនពីរនាក់ និយាយឆ្លើយឆ្លងគ្នាលោកហៅថា គូឆ្លើយឆ្លង យ៉ាងណា ធម៌របស់ជនពីរនាក់ដែលត្រេកអរ ត្រេកអរខ្លាំង ជោក ( ដោយរាគៈ ) រួបរឹត ( ដោយរាគៈ ) មានចិត្តត្រូវកិលេសគ្របសង្កត់ស្មើគ្នាទាំងពីរនាក់ ព្រោះហេតុនោះ ទើបលោកហៅថា មេថុនធម្ម យ៉ាងនោះដែរ ។ ពាក្យថា ប្រកប

រឿយៗក្នុងមេថុន បានសេចក្តីថា ប្រកបតាក់តែង ប្រជុំប្រជា ប្រកបព្រមក្នុងមេថុនធម្ម ប្រព្រឹត្តមេថុនធម្មនោះ ក្រាស់ដោយមេថុនធម្មនោះ គោរពមេថុនធម្មនោះ ឱនទៅក្នុងមេថុនធម្មនោះ ទោរទៅក្នុងមេថុនធម្មនោះ ឈមមុខទៅក្នុងមេថុនធម្មនោះ ចុះចិត្តស៊ប់ទៅក្នុងមេថុនធម្មនោះ ធ្វើមេថុនធម្មនោះឲ្យជាធំ ហេតុនោះ ( លោកពោលថា ) ប្រកបរឿយៗក្នុងមេថុន ។

[ ២២៦ ] អធិប្បាយពាក្យថា ព្រះតិស្សមេត្តេយ្យៈមានអាយុក្រាបទូលយ៉ាងនេះ ត្រង់ពាក្យថា យ៉ាងនេះ គឺជាពាក្យភ្ជាប់បទ ជាប់ដោយបទ បំពេញបទ ប្រជុំនៃអក្ខរៈ សម្រួលព្យញ្ជនៈ ពាក្យថា យ៉ាងនេះ នុ៎ះជាលំដាប់នៃបទ ។ ពាក្យថា មានអាយុ គឺពាក្យជាទីស្រឡាញ់ ពាក្យជាទីគោរព ពាក្យប្រកបដោយសេចក្តីគោរព ពាក្យថា មានអាយុនុ៎ះ ជាពាក្យប្រកបដោយសេចក្តីកោតក្រែង ។ ពាក្យថា តិស្សៈ គឺជានាម ការរាប់ ឈ្មោះ បញ្ញត្តិ វោហារ ជានាម អំពើរបស់នាម ពាក្យទ្រទ្រង់ទុកនូវនាម ភាសា ព្យញ្ជនៈ ការហៅរកនៃព្រះថេរនោះ ។ ពាក្យថា មេត្តេយ្យៈ គឺជាគោត្ត ការរាប់ ឈ្មោះ បញ្ញត្តិ វោហាររបស់ព្រះថេរនោះ ហេតុនោះ ( លោកពោល ) ថា ព្រះតិស្សមេត្តេយ្យៈមានអាយុក្រាបទូលយ៉ាងនេះ ។

[ ២២៧ ] ពាក្យថា បពិត្រព្រះអង្គទ្រង់និរទុក្ខ សូមព្រះអង្គពោលសេចក្តីចង្អៀតចង្អល់ សេចក្តីថា សូមព្រះអង្គពោល ប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក ចែករំលែក ធ្វើឲ្យរាក់ ប្រកាសនូវសេចក្តីចង្អៀតចង្អល់ សេចក្តីតានតឹង សេចក្តីបៀតបៀន សេចក្តីលំបាក សេចក្តីឧបទ្រព សេចក្តីខ្វាំងខ្វាស់ឲ្យទាន ។

*ពាក្យថា បពិត្រព្រះអង្គទ្រង់និរទុក្ខទុំៈ គឺពាក្យជាទីស្រឡាញ់ ពាក្យជាទីគោរព ពាក្យប្រកបដោយសេចក្ដីគោរព ពាក្យថា ព្រះអង្គទ្រង់និរទុក្ខទុំៈ ជាពាក្យប្រកបដោយសេចក្ដីកោតក្រែង ហេតុនោះ ( លោកពោលថា ) បពិត្រព្រះអង្គទ្រង់និរទុក្ខ សូមព្រះអង្គពោលសេចក្ដីចង្អៀតចង្អល់ ។*

*[ ២២៨ ] ពាក្យថា ខ្ញុំស្ដាប់ពាក្យប្រដៅរបស់ព្រះអង្គ គឺខ្ញុំស្ដាប់ត្រងត្រាប់ រៀន ចំណាំ កំណត់នូវពាក្យ គន្លងនៃពាក្យទេសនា ការប្រៀនប្រដៅរបស់ព្រះអង្គ ហេតុនោះ ( លោកពោលថា ) ខ្ញុំស្ដាប់ពាក្យប្រៀនប្រដៅរបស់ព្រះអង្គ ។*

*[ ២២៩ ] អធិប្បាយពាក្យថា សិក្សាក្នុងវិវេក ត្រង់ពាក្យថា វិវេក បានដល់ វិវេក ៣ គឺកាយវិវេក ចិត្តវិវេក ឧបធិវិវេក ។*

*កាយវិវេក តើដូចម្ដេច ។ ភិក្ខុក្នុងសាសនានេះ គប់រកសេនាសនស្ងាត់ គឺព្រៃ គល់ឈើ ភ្នំ ជ្រោះ គុហាក្នុងភ្នំ ព្រៃស្មសាន ព្រៃធំ ទីវាល គំនរចំបើង ជាអ្នកស្ងាត់ដោយកាយ ភិក្ខុនោះដើរម្នាក់ឯង ឈរម្នាក់ឯង អង្គុយម្នាក់ឯង សម្រេចកិរិយាដេកម្នាក់ឯង ចូលទៅកាន់ស្រុកបិណ្ឌបាតម្នាក់ឯង ត្រឡប់មកវិញម្នាក់ឯង អង្គុយក្នុងទីស្ងាត់ម្នាក់ឯង អធិដ្ឋានចង្ក្រមម្នាក់ឯង ត្រាច់ទៅ នៅ សម្រេចឥរិយាបថ ប្រព្រឹត្តទៅ រក្សា រស់នៅ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅតែម្នាក់ឯង នេះកាយវិវេក ។*

*ចិត្តវិវេក តើដូចម្ដេច ។ ចិត្តរបស់ភិក្ខុអ្នកចូលបឋមជ្ឈាន ជាចិត្តស្ងាត់ចាកនីវរណៈចិត្តរបស់ភិក្ខុអ្នកចូលទុតិយជ្ឈានជាចិត្តស្ងាត់ចាកវិតក្កៈនិងវិចារៈ*

ចិត្តរបស់ភិក្ខុអ្នកចូលតតិយជ្ឈាន ជាចិត្តស្ងាត់ចាកបីតិ ចិត្តរបស់ភិក្ខុអ្នកចូលចតុត្ថជ្ឈាន ជាចិត្តស្ងាត់ចាកសុខនិងទុក្ខ ចិត្តរបស់ភិក្ខុអ្នកចូលអាកាសានញ្ចាយតនៈ ជាចិត្តស្ងាត់ចាករូបសញ្ញា ចាកបដិឃសញ្ញា ចាកនានត្តសញ្ញា ចិត្តរបស់ភិក្ខុអ្នកចូលវិញ្ញាណញ្ចាយតនៈ ជាចិត្តស្ងាត់ចាកអាកាសានញ្ចាយតនសញ្ញា ចិត្តរបស់ភិក្ខុអ្នកចូលអាកិញ្ចញ្ញាយតនៈ ជាចិត្តស្ងាត់ចាកវិញ្ញាណញ្ចាយតនសញ្ញា ចិត្តរបស់ភិក្ខុអ្នកចូលនេវសញ្ញានាសញ្ញាយតនៈ ជាចិត្តស្ងាត់ចាកអាកិញ្ចញ្ញាយតនសញ្ញា ចិត្តរបស់ភិក្ខុអ្នកដល់សោតៈ ជាចិត្តស្ងាត់ចាកសក្កាយទិដ្ឋិ ចាកវិចិកិច្ឆា ចាកសីលព្វតបរាមាសៈ ចាកទិដ្ឋានុស័យ ចាកវិចិកិច្ឆានុស័យ ចាកកិលេសទាំងឡាយ ដែលតាំងនៅជាមួយគ្នានឹងសញ្ញោជនៈទាំងនោះ ចិត្តរបស់ភិក្ខុ ជាសកទាគាមិ ជាចិត្តស្ងាត់ចាកកាមរាគសញ្ញោជនៈ ចាកបដិឃសញ្ញោជនៈដ៏គ្រោតគ្រាត ចាកកាមរាគានុស័យ ចាកបដិឃានុស័យដ៏គ្រោតគ្រាត ចាកកិលេសដែលតាំងនៅជាមួយនឹងសញ្ញោជនៈទាំងនោះ ចិត្តរបស់ភិក្ខុជាអនាគាមិ ជាចិត្តស្ងាត់ចាកកាមរាគសញ្ញោជនៈនិងបដិឃសញ្ញោជនៈ ដែលលាយឡំនៅ ដ៏ល្អិតចាកកាមរាគានុស័យ ចាកបដិឃានុស័យ ដែលលាយឡំនៅ ដ៏ល្អិតចាកកិលេសដែលតាំងនៅជាមួយនឹងសញ្ញោជនៈទាំងនោះ ចិត្តរបស់ភិក្ខុជាព្រះអរហន្ត ជាចិត្តស្ងាត់ចាករូបរាគៈ អរូបរាគៈ មានៈ ឧទ្ធច្ចៈ អវិជ្ជា មានានុស័យ ភវរាគានុស័យ អវិជ្ជានុស័យ ចាកកិលេសដែលតាំងនៅជាមួយនឹងសញ្ញោជនៈទាំងនោះ ចាកនិមិត្តទាំងពួងជាខាងក្រៅ នេះចិត្តវិវេក ។

ឧបធិវិវេក តើដូចម្តេច ។ កិលេស ខន្ធនិងអភិសង្ខារទាំងឡាយ លោក

ហៅថា ឧបធិ ។ អមតនិព្វាន លោកហៅថា ឧបធិវិវេក បានខាងការរម្ងាប់សង្ខារទាំងពួង ការរលាស់ចេញនូវឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាកតម្រេក ការរលត់ និព្វាន នេះឧបធិវិវេក ។

កាយវិវេក សម្រាប់អ្នកមានកាយគេចចេញ ( ចាកពួក ) អ្នកត្រេកអរចំពោះនេក្ខម្មៈ ចិត្តវិវេក សម្រាប់អ្នកមានចិត្តបរិសុទ្ធ អ្នកដល់សេចក្តីផូរផង់ដ៏ក្រៃលែង ឯឧបធិវិវេក សម្រាប់បុគ្គលមិនមានឧបធិ អ្នកដល់នូវវិសង្ខារ គឺព្រះនិព្វាន ។

ពាក្យថា សិក្សាក្នុងវិវេក គឺព្រះថេរនោះ មានសិក្ខាសិក្សាហើយដោយប្រក្រតី តែលោកសូមធម្មទេសនាបានពោលយ៉ាងនេះថា នឹងសិក្សាក្នុងវិវេក ។ ហេតុនោះ ព្រះថេរឈ្មោះតិស្សមេត្តេយ្យៈ ពោលថា

( ព្រះតិស្សមេត្តេយ្យៈមានអាយុក្រាបទូលយ៉ាងនេះថា )
បពិត្រព្រះអង្គទ្រង់និទ្ទុក្ខ សូមព្រះអង្គពោលសេចក្តីចង្អៀត
ចង្អល់របស់បុគ្គលដែលប្រកបរឿយៗក្នុងមេថុន យើងខ្ញុំស្តាប់
ពាក្យប្រដៅរបស់ព្រះអង្គហើយនឹងសិក្សាក្នុងវិវេក ដូច្នេះ ។

[ ២៣០ ] ( ព្រះមានព្រះភាគត្រាស់ថា ម្នាលមេត្តេយ្យៈ ) សាសនារបស់បុគ្គលអ្នកប្រកបរឿយៗក្នុងមេថុនធម្មរមែងវិនាសដោយពិត ទាំងបុគ្គលនោះ ក៏រមែងប្រតិបត្តិខុស អំពើនុ៎ះមិនមែនជាអំពើប្រសើរចំពោះបុគ្គលនោះទេ ។

[ ២៣១ ] ពាក្យថា បុគ្គលអ្នកប្រកបរឿយៗក្នុងមេថុនធម្ម អធិប្បាយថា ឈ្មោះថា មេថុនធម្ម បានខាងធម៌របស់អសប្បុរស ធម៌របស់អ្នកស្រុក ធម៌

របស់ជនថោកទាប ធម៌អាក្រក់ មានទឹកជាទីបំផុត ធម៌កើតក្នុងទីកំបាំង ការជួបជុំរបស់បុគ្គលពីរៗនាក់ ។ ដែលលោកហៅថា មេថុនធម្ម តើព្រោះហេតុអ្វី ។ ធម៌របស់បុគ្គលពីរនាក់ ដែលត្រេកអរ ត្រេកអរខ្លាំង ជោក ( ដោយរាគៈ ) ឫបរឹត ( ដោយរាគៈ ) មានចិត្តត្រូវកិលេសគ្របសង្កត់ស្មើគ្នាទាំងពីរនាក់ ព្រោះហេតុនោះ ទើបលោកហៅថា មេថុនធម្ម ដូច្នេះ ។ ជនពីរនាក់ធ្វើជម្លោះ លោកហៅថា គូជម្លោះ ជនពីរនាក់ធ្វើសេចក្ដីប្រកួតប្រកាន់ លោកហៅថា គូប្រកួតប្រកាន់ ជនពីរនាក់ធ្វើការនិយាយគ្នា លោកហៅថា គូនិយាយគ្នា ជនពីរនាក់ធ្វើការជជែកគ្នា លោកហៅថា គូជជែកគ្នា ជនពីរនាក់ធ្វើអធិករណ៍ លោកហៅថា គូអធិករណ៍ ជនពីរនាក់ចរចាជាប្រក្រតី លោកហៅថា គូចរចា ជនពីរនាក់និយាយឆ្លើយឆ្លងគ្នា លោកហៅថា គូឆ្លើយឆ្លងយ៉ាងណា ធម៌របស់បុគ្គលពីរនាក់ ដែលត្រេកអរ ត្រេកអរខ្លាំង ជោក ( ដោយរាគៈ ) ឫបរឹត ( ដោយរាគៈ ) មានចិត្តត្រូវកិលេសគ្របសង្កត់ស្មើគ្នាទាំងពីរនាក់ ព្រោះហេតុនោះ ទើបលោកហៅថា មេថុនធម្ម យ៉ាងនោះដែរ ។ ពាក្យថា ប្រកបរឿយៗក្នុងមេថុន គឺប្រកប តាក់តែង ប្រដុងប្រជា ប្រកបព្រមក្នុងមេថុនធម្ម ប្រព្រឹត្តមេថុនធម្មនោះ ក្រាស់ដោយមេថុនធម្មនោះ គោរពមេថុនធម្មនោះ ឱនទៅក្នុងមេថុនធម្មនោះ ទោរទៅក្នុងមេថុនធម្មនោះ ឈមមុខទៅក្នុងមេថុនធម្មនោះ ចុះចិត្តស៊ប់ក្នុងមេថុនធម្មនោះ ធ្វើមេថុនធម្មនោះឲ្យជាធំហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលអ្នកប្រកបរឿយៗក្នុងមេថុនធម្ម ។ ព្រះមានព្រះភាគត្រាស់ហៅព្រះថេរៈនោះតាមគោត្តថា ម្នាលមេត្តេយ្យៈ ។ ពាក្យថា

ព្រះមានព្រះភាគ ជាពាក្យពោលដោយគោរព ។ មួយទៀត ព្រះពុទ្ធមានរាគៈបំបាក់បង់ហើយ ហេតុនោះ ឈ្មោះថា ព្រះមានព្រះភាគ ។ មានទោសៈបំបាក់បង់ហើយ ហេតុនោះ ឈ្មោះថា ព្រះមានព្រះភាគ ។ មានមោហៈបំបាក់បង់ហើយ ហេតុនោះ ឈ្មោះថា ព្រះមានព្រះភាគ ។ មានមានះបំបាក់បង់ហើយ ហេតុនោះ ឈ្មោះថា ព្រះមានព្រះភាគ ។ មានទិដ្ឋិបំបាក់បង់ហើយ ហេតុនោះ ឈ្មោះថា ព្រះមានព្រះភាគ ។ មានបន្ទាគឺកិលេសបំបាក់បង់ហើយ ហេតុនោះ ឈ្មោះថា ព្រះមានព្រះភាគ ។ មានកិលេសបំបាក់បង់ហើយ ហេតុនោះ ឈ្មោះថា ព្រះមានព្រះភាគ ។ ទ្រង់បែកចែករំលែកធម្មរតនៈ ហេតុនោះ ឈ្មោះថា ព្រះមានព្រះភាគ ។ ជាអ្នកធ្វើនូវទីបំផុតនៃភព ហេតុនោះ ឈ្មោះថា ព្រះមានព្រះភាគ ។ មានព្រះកាយចម្រើនហើយ ហេតុនោះ ឈ្មោះថា ព្រះមានព្រះភាគ ។ មានសីលចម្រើនហើយ មានចិត្តចម្រើនហើយ មានប្រាជ្ញាចម្រើនហើយ ហេតុនោះ ឈ្មោះថា ព្រះមានព្រះភាគ ។ មួយទៀត ព្រះមានបុណ្យទ្រង់គប់រកសេនាសនៈស្ងាត់ គឺព្រៃតូចនិងព្រៃធំ មិនមានសំឡេង មិនមានការគឹកកង ជាទីប្រាសចាកខ្យល់ដែលកើតអំពីកាយនៃជន ជាទីស្ងាត់កំបាំងរបស់មនុស្ស ជាទីសមគួរដល់ការពួនសម្ងំ ហេតុនោះ ឈ្មោះថា ព្រះមានព្រះភាគ ។ មួយទៀត ព្រះមានបុណ្យ ព្រះអង្គមានចំណែកចីវរ បិណ្ឌបាត សេនាសនៈនិងគិលានប្បច្ចយភេសជ្ជបរិក្ខារ ហេតុនោះ ឈ្មោះថា ព្រះមានព្រះភាគ ។ មួយទៀត ព្រះមានបុណ្យ ព្រះអង្គមានចំណែកអត្ថរស ធម្មរស វិមុត្តិរស អធិសីល អធិចិត្តនិងអធិប្បញ្ញា ហេតុនោះ ឈ្មោះថា

ព្រះមានព្រះភាគ ។ មួយទៀត ព្រះមានបុណ្យ ព្រះអង្គមានចំណែកឈាន ៤ អប្បមញ្ញា ៤ អរូបសមាបត្តិ ៤ ហេតុនោះ ឈ្មោះថា ព្រះមានព្រះភាគ ។ មួយទៀត ព្រះមានបុណ្យ ព្រះអង្គមានចំណែកវិមោក្ខ ៨ អភិភាយតនៈ ៨ អនុបុព្វវិហារសមាបត្តិ ៩ ហេតុនោះ ឈ្មោះថា ព្រះមានព្រះភាគ ។ មួយទៀត ព្រះមានបុណ្យ ព្រះអង្គមានចំណែកសញ្ញាភាវនា ១០ កសិណសមាបត្តិ ១០ អានាបានស្សតិសមាធិនិងអសុភសមាបត្តិហេតុនោះឈ្មោះថាព្រះមានព្រះភាគ។ មួយទៀត ព្រះមានបុណ្យ ព្រះអង្គមានចំណែកសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ អរិយមគ្គប្រកបដោយអង្គ ៨ ហេតុនោះ ឈ្មោះថា ព្រះមានព្រះភាគ ។ មួយទៀត ព្រះមានបុណ្យ ព្រះអង្គមានចំណែកតថាគតពល ១០ វេសារជ្ជៈ ៤ បដិសម្ភិទា ៤ អភិញ្ញា ៦ ធម៌របស់ព្រះពុទ្ធ ៦ យ៉ាង ហេតុនោះ ឈ្មោះថា ព្រះមានព្រះភាគ ។ ព្រះនាមថា មានព្រះភាគនុ៎ះ មិនមែនព្រះមាតាធ្វើ មិនមែនព្រះបិតាធ្វើ មិនមែនបងប្អូនប្រុសធ្វើ មិនមែនបងប្អូនស្រីធ្វើ មិនមែនមិត្តនិងអាមាត្យធ្វើ មិនមែនញាតិសាលោហិតធ្វើ មិនមែនសមណៈនិងព្រាហ្មណ៍ធ្វើ មិនមែនទេវតាធ្វើទេ ( ព្រះនាមថា មានព្រះភាគ ) នុ៎ះ របស់ព្រះពុទ្ធទាំងឡាយមានព្រះភាគ ជាព្រះនាមកើតក្នុងទីបំផុតវិមោក្ខ គឺសេចក្តីបញ្ញត្តថា មានព្រះភាគនេះ ( កើត ) អំពីការបានត្រាស់ដំណាលគ្នានឹងការបានចំពោះសព្វញ្ញុតញ្ញាណ ទៀបគល់ពោធិព្រឹក្ស ហេតុនោះ ( លោកពោលថា ) ព្រះមានព្រះភាគត្រាស់ថា ម្នាលមេត្តេយ្យៈ ។

[ ២៣២ ] ពាក្យថា សាសនាវិនាស បានដល់សាសនាវិនាសដោយហេតុ

២ គឺបរិយត្តិសាសនាក៏វិនាស បដិបត្តិសាសនាក៏វិនាស ។

បរិយត្តិសាសនា តើដូចម្តេច ។ ពុទ្ធវចនៈណា គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតក អព្ភូតធម្មៈ វេទល្លៈ ដែលបុគ្គលនោះរៀនហើយ នេះបរិយត្តិសាសនា ។ បរិយត្តិសាសនា វិនាសបាត់បង់ទៅ ( បុគ្គលនោះ ) ទៅជាបុគ្គលខាងក្រៅ ហេតុនោះ ( ទ្រង់ត្រាស់ថា ) សាសនាវិនាស យ៉ាងនេះខ្លះ ។

បដិបត្តិសាសនា តើដូចម្តេច ។ សេចក្តីប្រតិបត្តិដោយប្រពៃ សេចក្តីប្រតិបត្តិដ៏សមគួរ សេចក្តីប្រតិបត្តិមិនជាសឹកសត្រូវ សេចក្តីប្រតិបត្តិចំពោះប្រយោជន៍តាមលំដាប់ សេចក្តីប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌ ភាពបុគ្គលអ្នកធ្វើឲ្យបរិបូណ៌ក្នុងសីលទាំងឡាយ ភាពបុគ្គលមានទ្វារគ្រប់គ្រងក្នុងឥន្ទ្រិយទាំងឡាយ ភាពបុគ្គលអ្នកដឹងប្រមាណក្នុងភោជន សេចក្តីប្រកបរឿយៗ ក្នុងការភ្ញាក់រឭក សតិនិងសម្បជញ្ញៈ សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ អរិយមគ្គប្រកបដោយអង្គ ៨ នេះបដិបត្តិសាសនា ។ បដិបត្តិសាសនានោះ រមែងវិនាសបាត់បង់ទៅ ( បុគ្គលនោះ ) ទៅជាបុគ្គលខាងក្រៅ ហេតុនោះ ( ទ្រង់ត្រាស់ថា ) សាសនាវិនាសយ៉ាងនេះខ្លះ ។

[ ២៣៣ ] ពាក្យថា រមែងប្រតិបត្តិខុស គឺបុគ្គលសម្លាប់សត្វខ្លះ កាន់យកទ្រព្យដែលគេមិនបានឲ្យខ្លះ កាត់ទីតខ្លះ វាយប្រហារទាំងប្លន់ជំខ្លះ ធ្វើការបៀតបៀនទ្រព្យក្នុងផ្ទះមួយខ្លះ ចាំនៅក្បែរផ្លូវរឹបជាន់ខ្លះ គប់រកប្រពន្ធបុគ្គល

ដទៃខ្លះ ពោលកុហកខ្លះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) រមែងប្រតិបត្តិខុស ។

[ ២៣៤ ] ពាក្យថា អំពើនុ៎ះ មិនមែនជាអំពើប្រសើរចំពោះបុគ្គលនោះទេ គឺអំពើនុ៎ះ ជាធម៌មិនប្រសើរ ជាធម៌របស់បុគ្គលពាល ជាធម៌របស់បុគ្គលល្ងង់ខ្លៅ ជាធម៌របស់បុគ្គលមិនមានបញ្ញា ជាធម៌របស់បុគ្គលបោះទៅនូវពាក្យមិនឲ្យស្ដាប់សំដី គឺជាសេចក្ដីប្រតិបត្តិខុស ចំពោះបុគ្គលនោះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) អំពើនុ៎ះ មិនមែនជាអំពើប្រសើរក្នុងបុគ្គលនោះទេ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

( ព្រះមានព្រះភាគត្រាស់ថា ម្នាលមេត្តេយ្យៈ ) សាសនា
របស់បុគ្គលអ្នកប្រកបរឿយៗក្នុងមេថុនធម្ម រមែងវិនាសទៅ
ដោយពិត ទាំងបុគ្គលនោះ ក៏រមែងប្រតិបត្តិខុស អំពើនុ៎ះ មិន
មែនជាអំពើប្រសើរចំពោះបុគ្គលនោះទេ ដូច្នេះ ។

[ ២៣៥ ] បុគ្គលណា ប្រព្រឹត្តម្នាក់ឯងក្នុងកាលមុន ហើយសេពមេថុនធម្ម អ្នកប្រាជ្ញទាំងឡាយ ហៅបុគ្គលនោះថា ជាបុថុជ្ជនថោកទាបក្នុងលោក ដូចជាយានដែលក្លូកហើយ ។

[ ២៣៦ ] ពាក្យថា ប្រព្រឹត្តម្នាក់ឯងក្នុងកាលមុន អធិប្បាយថា បុគ្គលប្រព្រឹត្តម្នាក់ឯងក្នុងកាលមុន ដោយហេតុ ២ គឺដោយចំណែកបព្វជ្ជា ឬដោយការលះបង់ពួក ។

បុគ្គលប្រព្រឹត្តម្នាក់ឯង ក្នុងកាលមុន ដោយចំណែកបព្វជ្ជា តើដូចម្ដេច ។ បុគ្គលកាត់បង់កង្វល់គឺឃរាវាសទាំងអស់ កាត់បង់កង្វល់គឺបុត្តភរិយា កាត់

បង់កង្វល់គឺញាតិ កាត់បង់កង្វល់គឺមិត្តនិងអាមាត្យ កាត់បង់កង្វល់គឺការសន្សំ កោរសក់និងពុកមាត់ ស្លៀកដណ្តប់សំពត់ដែលជ្រលក់ដោយទឹកចត់ ចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ដល់នូវភាពជាអ្នកមិនមានសេចក្តីខ្វល់ខ្វាយត្រាច់ទៅ សម្រាក សម្រាន្ត សម្រេចឥរិយាបថ ប្រព្រឹត្តទៅ រក្សា រស់នៅ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅតែម្នាក់ឯង បុគ្គលប្រព្រឹត្តម្នាក់ឯងក្នុងកាលមុន ដោយចំណែកបព្វជ្ជា យ៉ាងនេះ ។

បុគ្គលប្រព្រឹត្តម្នាក់ឯង ក្នុងកាលមុន ដោយការលះបង់ពួក តើដូចម្តេច ។ បុគ្គលនោះ លុះបួសយ៉ាងនេះហើយ ជាបុគ្គលម្នាក់ឯង តែងគប់រកសេនាសនៈស្ងាត់ គឺព្រៃតូចនិងព្រៃធំ មិនមានសំឡេង មិនមានការគឹកកង ជាទីប្រាសចាកខ្យល់ដែលកើតអំពីកាយនៃជន ជាទីស្ងាត់កំបាំងរបស់មនុស្ស សមគួរដល់ការពួនសម្ងំ ។ បុគ្គលនោះ ដើរតែម្នាក់ឯង ឈរតែម្នាក់ឯង អង្គុយតែម្នាក់ឯង សម្រេចការដេកតែម្នាក់ឯង ចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត តែម្នាក់ឯងត្រឡប់មកវិញតែម្នាក់ឯង អង្គុយក្នុងទីស្ងាត់តែម្នាក់ឯង អធិដ្ឋានចង្ក្រមតែម្នាក់ឯង ត្រាច់ទៅ សម្រាក សម្រាន្ត សម្រេចឥរិយាបថ ប្រព្រឹត្តទៅ រក្សា រស់នៅ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅតែម្នាក់ឯង បុគ្គលប្រព្រឹត្តតែម្នាក់ឯង ក្នុងកាលមុនដោយការលះបង់ពួក យ៉ាងនេះ ។

[ ២៣៧ ] អធិប្បាយពាក្យថា បុគ្គលណា សេពមេថុនធម្ម ឈ្មោះថា មេថុនធម្ម បានខាងធម៌របស់អសប្បុរស ។បេ។ ព្រោះហេតុនោះ ទើបលោកហៅថា មេថុនធម្ម ។ ពាក្យថា បុគ្គលណា សេពមេថុនធម្ម បានសេចក្តីថា

បុគ្គលនោះ ពោលលាព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃនិងសិក្ខា ត្រឡប់ដើម្បីភាពជាបុគ្គលថោកទាប ហើយគប់រក សេពគប់ សេពសម្គព សេពចំពោះមេថុនធម្មក្នុងសម័យដទៃ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលណា សេពមេថុនធម្ម ។

[ ២៣៨ ] អធិប្បាយពាក្យថា ដូចជាយានដែលក្ហូកហើយ ក្នុងលោកត្រង់ពាក្យថា យាន គឺយានទឹមដោយដំរី យានទឹមដោយសេះ យានទឹមដោយគោ យានទឹមដោយពពែ យានទឹមដោយចៀម យានទឹមដោយឱដ្ឋ យានទឹមដោយលា ជាយានក្ហូកហើយ ដែលគេមិនបានទូន្មាន មិនបានធ្វើ មិនបានបង្ហាត់ រមែងកាន់យកផ្លូវខុស ឡើងកាន់ទីមានដង្គត់និងថ្មរដិបរដុបខ្លះ កិនជនអ្នកបរខ្លះ ក្ហូកធ្លាក់ទៅក្នុងជ្រោះខ្លះ ។ យានក្ហូកហើយ ដែលគេមិនបានទូន្មាន មិនបានធ្វើ មិនបានបង្ហាត់នោះ រមែងកាន់យកផ្លូវខុស យ៉ាងណា បុគ្គលជាអ្នកក្ហាត់នោះ ( សឹក ) ប្រៀបដោយយានក្ហូកហើយ រមែងកាន់យកផ្លូវខុស គឺកាន់យកទិដ្ឋិខុស ។បេ។ កាន់យកសមាធិខុស យ៉ាងនោះដែរ ។ យានក្ហូកហើយ ដែលគេមិនបានទូន្មាន មិនបានធ្វើ មិនបានបង្ហាត់នោះ រមែងឡើងកាន់ទីមានដង្គត់និងថ្មរដិបរដុប យ៉ាងណា បុគ្គលអ្នកក្ហាត់នោះ ប្រៀបដោយយានក្ហូកហើយ រមែងឡើងកាន់កាយកម្មមិនស្មើ ឡើងកាន់វចីកម្មមិនស្មើ ឡើងកាន់មនោកម្មមិនស្មើឡើងកាន់បាណាតិបាតមិនស្មើ ឡើងកាន់អទិន្នាទានមិនស្មើ ឡើងកាន់កាមេសុមិច្ឆាចារៈមិនស្មើ ឡើងកាន់មុសាវាទមិនស្មើ ឡើងកាន់បិសុណាវាចាមិនស្មើ ឡើងកាន់ផរុសវាចាមិនស្មើ ឡើងកាន់សម្ផប្បលាបៈមិនស្មើ ឡើង

កាន់អភិជ្ឈាមិនស្មើ ឡើងកាន់ព្យាបាទមិនស្មើ ឡើងកាន់មិច្ឆាទិដ្ឋិមិនស្មើ ឡើងកាន់សង្ខារទាំងឡាយមិនស្មើ ឡើងកាន់កាមគុណ ៥ មិនស្មើ ឡើងកាន់នីវរណៈទាំងឡាយមិនស្មើ យ៉ាងនោះដែរ ។ យានក្អកហើយ ដែលគេមិនបានទូន្មាន មិនបានធ្វើ មិនបានបង្ហាត់នោះ រមែងកិនជនអ្នកបរ យ៉ាងណា បុគ្គលអ្នកភ្ជាត់នោះ ប្រៀបដោយយានក្អកហើយ រមែងកិនខ្លួនក្នុងនរក កិនខ្លួនក្នុងកំណើតតិរច្ឆាន កិនខ្លួនក្នុងបិត្តិវិស័យ កិនខ្លួនក្នុងមនុស្សលោក កិនខ្លួនក្នុងទេវលោក យ៉ាងនោះដែរ ។ យានក្អកហើយ ដែលគេមិនបានទូន្មាន មិនបានធ្វើ មិនបានបង្ហាត់នោះ រមែងក្អកធ្លាក់ទៅក្នុងជ្រោះ យ៉ាងណា បុគ្គលអ្នកភ្ជាត់នោះ ប្រៀបដោយយានក្អកហើយ រមែងធ្លាក់ចុះក្នុងជ្រោះ គឺជាតិខ្ទះ ធ្លាក់ចុះក្នុងជ្រោះ គឺជរាខ្ទះ ធ្លាក់ចុះក្នុងជ្រោះគឺព្យាធិខ្ទះ ធ្លាក់ចុះក្នុងជ្រោះគឺមរណៈខ្ទះ ធ្លាក់ចុះក្នុងជ្រោះ គឺសេចក្តីសោក សេចក្តីខ្សឹកខ្សួល ទុក្ខ ទោមនស្សនិងសេចក្តីចង្អៀតចង្អល់ខ្ទះ យ៉ាងនោះដែរ ។ ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក ។បេ។ ក្នុងមនុស្សលោក ហេតុនោះ ( ទ្រង់ត្រាស់ថា ) ដូចជាយានដែលក្អកហើយក្នុងលោក ។

[ ២៣៩ ] អធិប្បាយពាក្យថា អ្នកប្រាជ្ញទាំងឡាយ ហៅបុគ្គលនោះថា ជាបុថុជ្ជន ថោកទាប ត្រង់ពាក្យថា បុថុជ្ជន គឺឈ្មោះថា បុថុជ្ជនដោយសេចក្តីដូចម្តេច ។ ឈ្មោះថា បុថុជ្ជន ព្រោះញុំាងកិលេសក្រាស់ឲ្យកើត ។ ឈ្មោះថា បុថុជ្ជន ព្រោះជាអ្នកមានសក្កាយទិដ្ឋិដ៏ក្រាស់មិនទាន់លះបង់ ។ ឈ្មោះថា បុថុជ្ជន ព្រោះជាអ្នកពោលប្តេជ្ញាចំពោះមុខសាស្តាទាំងឡាយច្រើន ។ ឈ្មោះ

ថា បុថុជ្ជន ព្រោះជាអ្នកត្រូវគតិទាំងពួងដ៏ក្រាស់ចាក់ស្រេះ ។ ឈ្មោះថា បុថុជ្ជន ព្រោះតាក់តែងដោយអភិសង្ខារផ្សេងៗដ៏ក្រាស់ ។ ឈ្មោះថា បុថុជ្ជន ព្រោះត្រូវឱឃៈផ្សេងៗដ៏ក្រាស់បន្សាត់ទៅ ។ ឈ្មោះថា បុថុជ្ជន ព្រោះក្តៅក្រហាយដោយកម្តៅផ្សេងៗដ៏ក្រាស់ ។ ឈ្មោះថា បុថុជ្ជន ព្រោះរោលរាលដោយកម្តៅរោលរាលផ្សេងៗដ៏ក្រាស់ ។ ឈ្មោះថា បុថុជ្ជន ព្រោះត្រេកអរ ញ៉ាម ជាប់ចិត្ត ជ្រប់ ងល់ងប់ ជាប់ចំពាក់ ចាក់ស្រេះ រួបរឹតក្នុងកាមគុណ ៥ ដ៏ក្រាស់ ។ ឈ្មោះថា បុថុជ្ជន ព្រោះត្រូវនីវរណៈ ៥ ដ៏ក្រាស់ ចាក់ស្រេះ រួបរឹតគ្របសង្កត់ សន្ធប់ បិទបាំង សណ្តំជាប់ ។ ពាក្យថា អ្នកប្រាជ្ញទាំងឡាយហៅបុគ្គលនោះថាជាបុថុជ្ជនថោកទាប គឺអ្នកប្រាជ្ញទាំងឡាយពោលយ៉ាងនេះ បានពោលហើយយ៉ាងនេះ សម្តែងយ៉ាងនេះ និយាយយ៉ាងនេះ បំភ្លឺយ៉ាងនេះ បញ្ចេញយ៉ាងនេះ នូវបុគ្គលនោះ ថាជាមនុស្សបុថុជ្ជន ថោកទាប ទន់ថយ ជ្រោកជ្រាក លាមក អាក្រក់ រំកាច់រំកោច ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកប្រាជ្ញទាំងឡាយពោលនូវបុគ្គលនោះថាជាបុថុជ្ជនថោកទាប ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

បុគ្គលណា ប្រព្រឹត្តតែម្នាក់ឯងក្នុងកាលមុន ហើយសេព
មេថុនធម្ម អ្នកប្រាជ្ញទាំងឡាយ ហៅបុគ្គលនោះ ថាជាបុថុជ្ជន
ថោកទាបក្នុងលោក ដូចជាយានដែលភ្លូកហើយ ដូច្នេះ ។

[ ២៤០ ] យសនិងកេរ្តិ៍ឈ្មោះណា ( ធ្លាប់មាន ) ក្នុងកាលមុន យស និងកេរ្តិ៍ឈ្មោះនោះ របស់បុគ្គលនោះ ក៏សាបសូន្យទៅ បព្វជិតឃើញនូវ

ដំណើរទុំះហើយ គប្បីសិក្សាដើម្បីលះ បង់មេថុនធម្ម ។

[ ២៤១ ] ពាក្យថា យសនិងកេត្តិ៍ឈ្មោះណា ធ្លាប់មានក្នុងកាលមុន យស និងកេត្តិ៍ឈ្មោះនោះ របស់បុគ្គលនោះ រមែងសាបសូន្យទៅ មានសេចក្តី អធិប្បាយដូចតទៅនេះ ចុះយសតើដូចម្តេច ។ បុគ្គលពួកខ្លះក្នុងលោកនេះ ជា អ្នកដែលគេធ្វើសក្ការៈ គោរព រាប់អាន បូជា កោតក្រែង ជាអ្នកបានចីវរ បិណ្ឌបាត សេនាសនៈនិងគិលានប្បច្ច័យភេសជ្ជបរិក្ខារ ក្នុងភាពជាសមណៈ ក្នុងកាលមុន នេះឈ្មោះថា យស ។ ចុះកេត្តិ៍ឈ្មោះ តើដូចម្តេច ។ បុគ្គល ពួកខ្លះក្នុងលោកនេះ កាលនៅក្នុងភាពជាសមណៈ ក្នុងកាលមុន ជាអ្នកពេញ ដោយកេត្តិ៍ឈ្មោះនិងសេចក្តីសរសើរ ជាបណ្ឌិត វាងវៃ មានប្រាជ្ញា ជាពហុស្សូត មានពាក្យដ៏វិចិត្រ មានប្រាជ្ញាល្អ ជាអ្នកទ្រទ្រង់ព្រះសូត្រក្តី ជាអ្នកទ្រទ្រង់វិន័យ ក្តី ជាធម្មកថិកក្តី ជាអ្នកកាន់អរញ្ញិកធុតង្គក្តី ជាអ្នកកាន់បិណ្ឌបាតិកធុតង្គក្តី ជា អ្នកកាន់បង្សុកូលិកធុតង្គក្តី ជាអ្នកកាន់តេចីវរិកធុតង្គក្តី ជាអ្នកកាន់សបទាន ចារិកធុតង្គក្តី ជាអ្នកកាន់ខលុបច្ឆាភត្តិកធុតង្គក្តី ជាអ្នកកាន់នេសជ្ជិកធុតង្គក្តី ជា អ្នកកាន់យថាសន្ថតិកធុតង្គក្តី ជាអ្នកបានបឋមជ្ឈានក្តី ជាអ្នកបានទុតិយជ្ឈាន ក្តី ជាអ្នកបានតតិយជ្ឈានក្តី ជាអ្នកបានចតុត្ថជ្ឈានក្តី ជាអ្នកបានអាកាសាន- ញ្ចាយតនសមាបត្តិក្តី ជាអ្នកបានវិញ្ញាណញ្ចាយតនសមាបត្តិក្តី ជាអ្នកបាន អាកិញ្ចញ្ញាយតនសមាបត្តិក្តី ជាអ្នកបាននេវសញ្ញានាសញ្ញាយតនសមាបត្តិក្តី នេះឈ្មោះថា កេត្តិ៍ឈ្មោះ ។ ពាក្យថា យសនិងកេត្តិ៍ឈ្មោះណា ធ្លាប់មាន ក្នុងកាលមុន យសនិងកេត្តិ៍ឈ្មោះនោះ របស់បុគ្គលនោះ រមែងសាបសូន្យទៅ

បានសេចក្តីថា កាលបព្វជិតនោះ ពោលលាព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃនិង សិក្ខាក្នុងសម័យដទៃ ហើយត្រឡប់ដើម្បីភេទថោកទាប យសនិងកេរ្តិ៍ឈ្មោះ នោះ រមែងសូន្យសាបរលាប ខ្ចាត់ចេញ ជ្រុះចេញ បាត់បង់ វិនាស ហេតុនោះ ( ទ្រង់ត្រាស់ថា ) យសនិងកេរ្តិ៍ឈ្មោះណា ធ្លាប់មានក្នុងកាលមុន យសនិង កេរ្តិ៍ឈ្មោះនោះ របស់បុគ្គលនោះ រមែងសាបសូន្យទៅ ។

[ ២៤២ ] អធិប្បាយពាក្យថា បព្វជិតឃើញនូវដំណើរនុ៎ះហើយ គប្បី សិក្សាដើម្បីលះបង់មេថុនធម្ម ត្រង់ពាក្យថា នូវដំណើរនុ៎ះ សេចក្តីថា យស និងកេរ្តិ៍ឈ្មោះ ក្នុងភាពជាសមណៈ ក្នុងកាលមុន កាលមិនមានយសនិងការ មិនមានកេរ្តិ៍ឈ្មោះរបស់បព្វជិតដែលពោលលានូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ និងសិក្ខាហើយត្រឡប់ដើម្បីភេទថោកទាប ក្នុងកាលជាចំណែកខាងក្រោយ បព្វជិតឃើញ ជួប ប្រទះ ថ្លឹង ពិចារណា ឈ្វេងយល់ ធ្វើឲ្យជាក់ច្បាស់នូវ សម្បត្តិនិងវិបត្តិនុ៎ះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បព្វជិតឃើញនូវដំណើរនុ៎ះ ។ ពាក្យថា គប្បីសិក្សា បានដល់សិក្ខា ៣ គឺ អធិសីលសិក្ខា ១ អធិចិត្តសិក្ខា ១ អធិប្បញ្ញាសិក្ខា ១ ។

អធិសីលសិក្ខា តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល សង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈនិងគោចរៈ ឃើញភ័យក្នុង ទោសមានប្រមាណបន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ សីល-ក្ខន្ធតូច សីលក្ខន្ធធំ សីលទីតាំងខាងដើម ការប្រព្រឹត្ត ការសង្រួម ការរវាំង ប្រធាន ប្រមុខនៃការបានធម៌ជាកុសលទាំងឡាយ នេះអធិសីលសិក្ខា ។

អធិចិត្តសិក្ខា តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាម ស្ងាត់ចាកអកុសលធម៌ ចូលបឋមជ្ឈាន ប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈ មានបីតិនិងសុខកើតអំពីវិវេក ចូលទុតិយជ្ឈាន មិនមានវិតក្កៈ មិនមានវិចារៈ មានតែបីតិនិងសុខៈ ដែលកើតអំពីសមាធិ ប្រព្រឹត្តទៅខាងក្នុងសន្តាន ជាទីជ្រះថ្លាស៊ប់ គឺសទ្ធា មានសភាពជាចិត្តដ៏ខ្ពស់ឯក ព្រោះការរម្ងាប់នូវវិតក្កៈនិងវិចារៈ ចូលតតិយជ្ឈាន ចូលចតុត្ថជ្ឈាន នេះអធិចិត្តសិក្ខា ។

អធិប្បញ្ញាសិក្ខា តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានប្រាជ្ញា ប្រកបដោយប្រាជ្ញាជាគ្រឿងដឹងនូវការកើតឡើងនិងការវិនាសទៅ ជាប្រាជ្ញាដ៏ប្រសើរ អាចទម្លុះទម្លាយ ជាគ្រឿងដល់នូវការអស់ទុក្ខដោយប្រពៃ ភិក្ខុនោះក៏ដឹងច្បាស់តាមពិតថា នេះជាទុក្ខ ដឹងច្បាស់តាមពិតថា នេះជាហេតុកើតឡើងនៃទុក្ខ ដឹងច្បាស់តាមពិតថា នេះជាគ្រឿងរំលត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះជាបដិបទាជាគ្រឿងដល់នូវការលត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះជាអាសវៈ ដឹងច្បាស់តាមពិតថា នេះជាហេតុកើតឡើងនៃអាសវៈ ដឹងច្បាស់តាមពិតថា នេះជាគ្រឿងរលត់អាសវៈ ដឹងច្បាស់តាមពិតថា នេះជាបដិបទាជាគ្រឿងដល់នូវការរលត់អាសវៈ នេះអធិប្បញ្ញាសិក្ខា ។ ពាក្យថា មេថុនធម្ម សេចក្តីថា ដែលឈ្មោះថា មេថុនធម្ម បានខាងធម៌របស់អសប្បុរស ។បេ។ ព្រោះហេតុនោះ ទើបលោកហៅថា មេថុនធម្ម ។

ពាក្យថា បព្វជិតឃើញនូវដំណើរនុ៎ះហើយ គប្បីសិក្សាដើម្បីលះបង់មេថុនធម្ម បានសេចក្តីថា បព្វជិតគប្បីសិក្សាអធិសីលផង គប្បីសិក្សាអធិចិត្ត

ផង គប្បីសិក្សាអធិប្បញ្ញាផង ដើម្បីលះបង់ ដើម្បីរម្ងាប់ ដើម្បីរលាស់ចោល ដើម្បីរម្ងាប់នូវមេថុនធម្ម ។ គប្បីពិចារណាសិក្សាសិក្ខាទាំង ៣ នេះ គប្បីដឹងសិក្សា គប្បីឃើញសិក្សា គប្បីពិចារណាសិក្សា គប្បីអធិដ្ឋានចិត្តសិក្សា គប្បីចុះចិត្តស៊ប់ដោយសទ្ធាសិក្សា គប្បីផ្គងព្យាយាមសិក្សា គប្បីតម្កល់ស្មារតីសិក្សា គប្បីតម្កល់ចិត្តសិក្សា គប្បីដឹងច្បាស់ដោយប្រាជ្ញាសិក្សា គប្បីដឹងច្បាស់នូវធម៌ដែលគួរដឹងច្បាស់សិក្សា គប្បីកំណត់ដឹងធម៌ដែលគួរកំណត់ដឹងសិក្សា គប្បីលះបង់ធម៌ដែលគួរលះបង់សិក្សា គប្បីចម្រើនធម៌ដែលគួរចម្រើនសិក្សា គប្បីធ្វើឲ្យជាក់ច្បាស់ធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់សិក្សា គប្បីប្រព្រឹត្តទៅ ប្រព្រឹត្តដោយប្រពៃ ប្រព្រឹត្តកាន់យក ហេតុនោះ ( ទ្រង់ត្រាស់ថា ) បព្វជិតឃើញនូវដំណើរនុ៎ះហើយ គប្បីសិក្សាដើម្បីលះបង់មេថុនធម្ម ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

យសនិងកេរ្តិ៍ឈ្មោះណា ( ធ្លាប់មាន ) ក្នុងកាលមុន យស
និងកេរ្តិ៍ឈ្មោះនោះ របស់បុគ្គលនោះក៏សាបសូន្យទៅ បព្វជិត
ឃើញនូវដំណើរនុ៎ះហើយ គប្បីសិក្សាដើម្បីលះបង់មេថុន ។
[ ២៨៣ ] បព្វជិតនោះ ដែលត្រូវសង្កប្បៈទាំងឡាយ គ្រប
សង្កត់ហើយ រមែងសញ្ជប់សញ្ជឹង ដូចមនុស្សកំព្រា បព្វជិត
មានសភាពដូច្នោះ លុះឮពាក្យសំដីរបស់ពួកជនដទៃហើយ
រមែងអៀនអន់ ។

[២៨៤] ពាក្យថា បព្វជិតនោះ ដែលត្រូវសង្កប្បៈទាំងឡាយគ្របសង្កត់

ហើយ រមែងសញ្ជប់សញ្ជឹង ដូចមនុស្សកំព្រា អធិប្បាយថា បព្វជិតត្រូវសេចក្តីត្រិះរិះប្រកបដោយកាម ត្រូវសេចក្តីត្រិះរិះប្រកបដោយព្យាបាទ ត្រូវសេចក្តីត្រិះរិះប្រកបដោយវិហឹសា ត្រូវសេចក្តីត្រិះរិះប្រកបដោយទិដ្ឋិប៉ះពាល់ គ្របសង្កត់ ជ្រួតជ្រាប ប្រកបហើយ រមែងក្តុកក្តួល សញ្ជប់សញ្ជឹង ស្រពាប់ស្រពោន ជ្រុលជ្រប់ ដូចមនុស្សកំព្រា ឬដូចជាអ្នកល្ងង់ ឬក៏ដូចជាអ្នកវង្វេងទិស ។ មៀមកាលស្វែងរកកណ្តុរលើមែកឈើ រមែងក្តៅក្តួល សញ្ជប់សញ្ជឹង ស្រពាប់ស្រពោន ជ្រុលជ្រប់ យ៉ាងណា ចចកកាលស្វែងរកត្រី ទៀបច្នេរស្ទឹង រមែងក្តៅក្តួល សញ្ជប់សញ្ជឹង ស្រពាប់ស្រពោន ជ្រុលជ្រប់ យ៉ាងណា ឆ្មាកាលស្វែងរកកណ្តុរ ក្នុងទីជាចន្លោះតំណនៃផ្ទះនិងទីប្រកបដោយមន្ទិល ប្រកបដោយកក់និងច្នេរ រមែងក្តៅក្តួល សញ្ជប់សញ្ជឹង ស្រពាប់ស្រពោន ជ្រុលជ្រប់ យ៉ាងណា លាមានការដឹកនាំជាច់ហើយ ( គេប្រើមិនកើត ) រមែងក្តៅក្តួល សញ្ជប់សញ្ជឹង ស្រពាប់ស្រពោន ជ្រុលជ្រប់ ក្នុងទីជាចន្លោះតំណនៃផ្ទះ និងទីប្រកបដោយមន្ទិល ប្រកបដោយកក់និងច្នេរ យ៉ាងណា បុគ្គលជាអ្នកក្ងាត់នោះ ដែលត្រូវសេចក្តីត្រិះរិះប្រកបដោយកាម ត្រូវសេចក្តីត្រិះរិះប្រកបដោយព្យាបាទ ត្រូវសេចក្តីត្រិះរិះប្រកបដោយវិហឹសា ត្រូវសេចក្តីត្រិះរិះប្រកបដោយទិដ្ឋិប៉ះពាល់ គ្របសង្កត់ ជ្រួតជ្រាប ប្រកបហើយ រមែងក្តុកក្តួល សញ្ជប់សញ្ជឹង ស្រពាប់ស្រពោន ជ្រុលជ្រប់ ដូចមនុស្សកំព្រា ឬដូចជាអ្នកល្ងង់ ឬក៏ដូចជាអ្នកវង្វេងទិស យ៉ាងនោះដែរ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បព្វជិតនោះ ដែលត្រូវសង្កប្បៈទាំងឡាយ គ្របសង្កត់ហើយ រមែងសញ្ជប់សញ្ជឹង ដូចមនុស្ស

កំព្រា ។

[ ២៨៥ ] អធិប្បាយពាក្យថា បព្វជិតមានសភាពដូច្នោះ លុះឮពាក្យសំដីរបស់ជនដទៃហើយ ក៏រមែងអៀនអន់ ត្រង់ពាក្យថា ជនដទៃ បានដល់ ពួកជនជាឧបជ្ឈាយ៍ក្តី អាចារ្យក្តី បុគ្គលមានឧបជ្ឈាយ៍ស្មើគ្នាក្តី បុគ្គលមានអាចារ្យស្មើគ្នាក្តី មិត្តក្តី បុគ្គលដែលធ្លាប់ឃើញគ្នាមួយម្តាលក្តី បុគ្គលដែលធ្លាប់គប់រកគ្នាក្តី សម្លាញ់ក្តី ដាស់តឿនថា ម្នាលអាវុសោ អ្នកនោះពេញជាឥតលាភមែនការបាន ( អត្តភាពជាមនុស្ស ) អ្នកបានដោយកម្រ ព្រោះថាជាអ្នកបានគ្រូដ៏ថ្លៃថ្លាមានសភាពយ៉ាងនេះ បួសក្នុងធម៌វិន័យដែលព្រះមានព្រះភាគសម្តែងល្អហើយ យ៉ាងនេះ បានពួកព្រះអរិយៈ មានសភាពយ៉ាងនេះត្រឡាំងហើយពោលលាព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃនិងសិក្ខា ហើយត្រឡប់មកកាន់ភេទថោកទាប ព្រោះហេតុមេថុនធម្មដ៏ថោកទាប សូម្បីតែសទ្ធារបស់អ្នកក្នុងកុសលធម៌ក៏មិនមាន សូម្បីតែហិរិរបស់អ្នកក្នុងកុសលធម៌ក៏មិនមាន សូម្បីតែឱត្តប្បៈរបស់អ្នកក្នុងកុសលធម៌ក៏មិនមាន សូម្បីតែវិរិយរបស់អ្នកក្នុងកុសលធម៌ក៏មិនមាន សូម្បីតែសតិរបស់អ្នកក្នុងកុសលធម៌ក៏មិនមាន សូម្បីតែបញ្ញារបស់អ្នកក្នុងកុសលធម៌ក៏មិនមាន បុគ្គលអ្នកភ្លាត់នោះ លុះស្តាប់ ឮ រៀន ពិចារណាកំណត់នូវពាក្យ គន្លងពាក្យ ទេសនា ការប្រៀនប្រដៅរបស់ជនទាំងឡាយនោះ ក៏រមែងអៀនអន់ ចង្អៀតចង្អល់ ក្រៀមក្រំ ឈឺចាប់ តូចចិត្ត ។ ពាក្យថា បុគ្គលមានសភាពដូច្នោះ គឺបុគ្គលណា ជាអ្នកភ្លាត់ បុគ្គលនោះ ឈ្មោះថា មានសភាពដូច្នោះ ប្រាកដដូច្នោះ ឋិតនៅដូច្នោះ មានប្រការៈដូច្នោះ មានចំណែក

ប្រៀបដូច្នោះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បព្វជិតមានសភាពដូច្នោះ លុះឮពាក្យសំដីរបស់ពួកជនដទៃហើយ រមែងអៀនអន់ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

បព្វជិតនោះ ដែលត្រូវសន្ទប្បៈទាំងឡាយគ្របសង្កត់ហើយ
រមែងសញ្ជប់សញ្ជឹង ដូចមនុស្សកំព្រា បព្វជិតមានសភាព
ដូច្នោះ លុះឮពាក្យសំដីរបស់ពួកជនដទៃហើយ រមែងអៀន
អន់ ។

[ ២៤៦ ] លំដាប់នោះ បុគ្គលដែលត្រូវវាទៈជនដទៃដាស់តឿនហើយ រមែងធ្វើសស្ត្រាទាំងឡាយ នុ៎ះជាសេចក្តីជាប់ចំពាក់ធំ របស់បុគ្គលនោះ បុគ្គលនោះ រមែងផ្គងពាក្យកុហក ។

[ ២៤៧ ] អធិប្បាយពាក្យថា លំដាប់នោះ បុគ្គលដែលត្រូវវាទៈជនដទៃដាស់តឿនហើយ រមែងធ្វើសស្ត្រាទាំងឡាយ ត្រង់ពាក្យថា លំដាប់នោះ គឺជាពាក្យភ្ជាប់បទ ជាពាក្យជាប់ចំពាក់ដោយបទ ជាពាក្យបំពេញបទ ជាពាក្យប្រជុំអក្ខរៈ ជាពាក្យសម្រួលព្យញ្ជនៈ ពាក្យថា លំដាប់នោះ គឺជាពាក្យលំដាប់បទ ។ ពាក្យថា សស្ត្រា បានដល់សស្ត្រា ៣ យ៉ាងគឺ សស្ត្រាគឺកាយ ១ សស្ត្រាគឺវាចា ១ សស្ត្រាគឺចិត្ត ១ ។ កាយទុច្ចរិត ៣ ឈ្មោះថា សស្ត្រាគឺកាយ វចីទុច្ចរិត ៤ ឈ្មោះថា សស្ត្រាគឺវាចា មនោទុច្ចរិត ៣ ឈ្មោះថា សស្ត្រាគឺចិត្ត ។ ពាក្យថា បុគ្គលដែលត្រូវវាទៈជនដទៃដាស់តឿនហើយ គឺបុគ្គលជាឧបជ្ឈាយ៍ក្តី អាចារ្យក្តី បុគ្គលមានឧបជ្ឈាយ៍ស្មើគ្នាក្តី បុគ្គលមានអាចារ្យស្មើគ្នាក្តី មិត្ត

ក្តី បុគ្គលដែលធ្លាប់ឃើញគ្នាក្តី បុគ្គលដែលធ្លាប់គប់រកគ្នាក្តី សម្លាញ់ក្តី ជាស់តឿនបុគ្គលនោះ រមែងពោលពាក្យកុហកទាំងដឹងខ្លួន គឺពោលថា បពិត្រលោកដ៏ចម្រើន ខ្ញុំជាអ្នកត្រេកអរក្នុងបព្វជ្ជាហើយ តែថាខ្ញុំត្រូវចិញ្ចឹមមាតា ហេតុនោះ បានជាខ្ញុំវិលខុស ពោលថា ខ្ញុំត្រូវចិញ្ចឹមបិតា ហេតុនោះ បានជាខ្ញុំវិលខុស ពោលថា ខ្ញុំត្រូវចិញ្ចឹមបងប្អូនប្រុស ខ្ញុំត្រូវចិញ្ចឹមបងប្អូនស្រី ខ្ញុំត្រូវចិញ្ចឹមបុត្ត ខ្ញុំត្រូវចិញ្ចឹមធីតា ខ្ញុំត្រូវចិញ្ចឹមមិត្ត ខ្ញុំត្រូវចិញ្ចឹមអាមាត្យ ខ្ញុំត្រូវចិញ្ចឹមពួកញាតិ ខ្ញុំត្រូវចិញ្ចឹមសាលោហិត ហេតុនោះ បានជាខ្ញុំវិលខុស រមែងធ្វើឲ្យកើត ឲ្យកើតព្រម បង្កើត បង្កើតចំពោះនូវសស្ត្រាគឺវាចា ហេតុនោះ ( ទ្រង់ត្រាស់ថា ) លំដាប់នោះ បុគ្គលត្រូវវាទៈជនដទៃជាស់តឿនហើយ រមែងធ្វើសស្ត្រាទាំងឡាយ ។

[ ២៤៨ ] ពាក្យថា ន៊ុះជាសេចក្តីជាប់ចំពាក់ធំរបស់បុគ្គលនោះ គឺសភាពនោះឯង ជាសេចក្តីជាប់ចំពាក់ធំ ជាព្រៃធំ ជាញាតស្បាតធំ ជាផ្លូវជាប់ស្រយាលធំ ជាផ្លូវមិនស្មើ ( ចម្រូងចម្រាសធំ ) ជាផ្លូវវៀចធំ ជាផ្លូវ ល្បាប់ធំ ជាផ្លូវមានភក់ច្រើន ជាផ្លូវមានសេចក្តីខ្វល់ខ្វាយធំ ជាចំណងធំរបស់បុគ្គលនោះ គឺការពោលមុសាវាទទាំងដឹងខ្លួន របស់បុគ្គលនោះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) នោះជាសេចក្តីជាប់ចំពាក់ធំរបស់បុគ្គលនោះ ។

[ ២៤៩ ] ពាក្យថា បុគ្គលនោះ រមែងផ្គងពាក្យកុហក អធិប្បាយថា មុសាវាទ លោកហៅថា ពាក្យកុហក ។ បុគ្គលខ្លះ ក្នុងលោកនេះ ទៅកាន់រោងជាទីប្រជុំក្តី ទៅកាន់បរិស័ទក្តី ទៅក្នុងកណ្តាលញាតិក្តី ទៅក្នុងកណ្តាល

ពួកក្តី ទៅក្នុងកណ្តាលរាជត្រកូលក្តី ដែលគេនាំទៅសួរយកជាបន្ទាល់ថា ម្នាលបុរសដ៏ចម្រើន អ្នកចូរមក អ្នកដឹងហេតុណា ចូរពោលហេតុនោះ ។ បុរសនោះកាលមិនដឹង ពោលថា ខ្ញុំដឹងក្តី កាលដឹង ពោលថា ខ្ញុំមិនដឹងក្តី កាលមិនឃើញ ពោលថា ខ្ញុំឃើញក្តី កាលឃើញ ពោលថា ខ្ញុំមិនឃើញក្តី ពោលសម្បជានមុសាវាទ ព្រោះហេតុខ្លួនក្តី ព្រោះហេតុបុគ្គលដទៃក្តី ព្រោះហេតុអាមិសៈបន្តិចបន្តួចក្តី ដោយប្រការដូច្នេះ នេះលោកហៅថា ពាក្យកុហក ។ មួយទៀត មុសាវាទដោយអាការ ៣ យ៉ាង គឺមុសាវាទរបស់បុគ្គលនោះក្នុងកាលមុនថា អាត្មាអញនឹងពោលពាក្យកុហក ១ មុសាវាទរបស់បុគ្គលកំពុងពោលថា អាត្មាអញកំពុងពោលពាក្យកុហក ១ មុសាវាទរបស់បុគ្គលដែលពោលហើយថា អាត្មាអញពោលពាក្យកុហកហើយ ១ មុសាវាទដោយអាការៈ ៣ នេះ ។ មួយវិញទៀត មុសាវាទមានដោយអាការ ៤ យ៉ាង ។ ដោយអាការ ៥ យ៉ាង ។ ដោយអាការ ៦ យ៉ាង ។ ដោយអាការ ៧ យ៉ាង ។ មុសាវាទដោយអាការ ៨ យ៉ាង គឺមុសាវាទនៃបុគ្គលនោះ ក្នុងកាលមុនថា អាត្មាអញនឹងពោលពាក្យកុហក ១ មុសាវាទនៃបុគ្គលកំពុងពោលថា អាត្មាអញពោលពាក្យកុហក ១ មុសាវាទនៃបុគ្គលពោលហើយថា អាត្មាអញពោលពាក្យកុហកហើយ ១ ព្រោះលាក់ទុកនូវទិដ្ឋិ ១ ព្រោះលាក់ទុកនូវការចូលចិត្ត ១ ព្រោះលាក់ទុកនូវសេចក្តីពេញចិត្ត ១ ព្រោះលាក់ទុកនូវសញ្ញា ១ ព្រោះលាក់ទុកនូវការកើតឡើង ១ មុសាវាទដោយអាការៈ ៨ នេះ ។ ពាក្យថា រមែងផ្គងពាក្យកុហកគឺ ផ្គង ផ្គូរផ្គងទុក កំណាត់ទុក ចូលទៅកាន់ពាក្យកុហក

ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលនោះរមែងផ្គងពាក្យកុហក ។ ហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

លំដាប់នោះ បុគ្គលដែលត្រូវវាទជនដទៃជាស់តឿនហើយ
រមែងធ្វើសស្រ្តាទាំងឡាយ នុ៎ះជាសេចក្តីជាប់ចំពាក់ធំរបស់
បុគ្គលនោះ បុគ្គលនោះ រមែងផ្គងពាក្យកុហក ។

[ ២៥០ ] បុគ្គលដែលគេដឹងច្បាស់ហើយថាជាបណ្ឌិត អធិដ្ឋានការប្រព្រឹត្ត តែម្នាក់ឯង តែខាងក្រោយមក ជាអ្នកប្រកបក្នុងមេថុនធម្ម នឹងត្រជាបត្រដូស ដូចបុគ្គលល្ងង់ខ្លៅ ។

[ ២៥១ ] ពាក្យថា បុគ្គលដែលគេដឹងច្បាស់ហើយថា ជាបណ្ឌិតអធិប្បាយ ថា បុគ្គលខ្លះក្នុងលោកនេះ កាលនៅក្នុងភាពជាសមណៈក្នុងកាលមុន ជាអ្នក ពេញដោយកេរ្តិ៍ឈ្មោះនិងសេចក្តីសរសើរ ជាបណ្ឌិតវាងវៃ មានប្រាជ្ញា ជា ពហុស្សូត មានពាក្យដ៏វិចិត្រ មានប្រាជ្ញាល្អ ជាអ្នកដែលគេដឹងហើយ ដឹង ច្បាស់ហើយ ដឹងសុសសាយហើយ យ៉ាងនេះថា ជាអ្នកទ្រទ្រង់ព្រះសូត្រក្តី ទ្រទ្រង់វិន័យក្តី ជាធម្មកថិកក្តី ។បេ។ ជាអ្នកបាននេវសញ្ញានាសញ្ញាយតន សមាបត្តិក្តី ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលដែលគេដឹងច្បាស់ហើយថា ជាបណ្ឌិត ។

[ ២៥២ ] ពាក្យថា អធិដ្ឋានការប្រព្រឹត្តតែម្នាក់ឯង អធិប្បាយថា បុគ្គល អធិដ្ឋានការប្រព្រឹត្តតែម្នាក់ឯង ដោយហេតុ ២ គឺដោយចំណែកបព្វជ្ជាក្តី ដោយ ការលះបង់ពួកក្តី ។ បុគ្គលអធិដ្ឋានការប្រព្រឹត្តតែម្នាក់ឯង ដោយចំណែកបព្វជ្ជា

តើដូចម្តេច ។ បុគ្គលផ្តាច់បង់សេចក្តីខ្វល់ខ្វាយគឺយកវាសទាំងពួង ។បេ។ អធិដ្ឋានការប្រព្រឹត្តតែម្នាក់ឯង ដោយចំណែកបព្វជ្ជាយ៉ាងនេះឯង ។ បុគ្គលអធិដ្ឋានការប្រព្រឹត្តតែម្នាក់ឯង ដោយការលះបង់ពួក តើដូចម្តេច ។ បុគ្គលនោះបួសយ៉ាងនេះហើយ ជាអ្នកម្នាក់ឯង គប់សេនាសនៈស្ងាត់ គឺព្រៃតូច ព្រៃធំ ។បេ។ អធិដ្ឋានការប្រព្រឹត្តតែម្នាក់ឯង ដោយការលះបង់ពួកយ៉ាងនេះឯង ហេតុនោះ ( ទ្រង់ត្រាស់ថា ) អធិដ្ឋានការប្រព្រឹត្តតែម្នាក់ឯង ។

[ ២៥៣ ] ពាក្យថា តែខាងក្រោយមកជាអ្នកប្រកបក្នុងមេថុនធម្ម អធិប្បាយថា ឈ្មោះថា មេថុនធម្ម បានខាងធម៌របស់អសប្បុរស ។បេ។ ហេតុនោះទើបលោកហៅថា មេថុនធម្ម ។ ពាក្យថា តែខាងក្រោយមកជាអ្នកប្រកបក្នុងមេថុនធម្ម គឺសម័យខាងក្រោយ បុគ្គលនោះ ពោលលាព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃនិងសិក្ខា វិលមកដើម្បីភេទថោកទាប ប្រកបតាក់តែង ប្រជុំប្រជាប្រកបព្រមក្នុងមេថុនធម្ម ហេតុនោះ ( ទ្រង់ត្រាស់ថា ) តែខាងក្រោយមកជាអ្នកប្រកបក្នុងមេថុនធម្ម ។

[ ២៥៤ ] ពាក្យថា នឹងត្រជាបត្រដួស ដូចបុគ្គលល្ងង់ខ្លៅ អធិប្បាយថា បុគ្គលនោះ នឹងលំបាក ចង្អៀតចង្អល់ ស្មោហ្មង ដូចមនុស្សកំព្រា ឬដូចមនុស្សល្ងង់ខ្លៅ គឺរមែងសម្លាប់សត្វខ្លះ កាន់យកទ្រព្យដែលគេមិនឲ្យខ្លះ កាត់តំណ ( នៃផ្ទះ ) ខ្លះ វាយប្រហារទាំងប្លន់ខ្លះ ធ្វើអាការកំហែងក្នុងផ្ទះមួយខ្លះ ឈរចាំស្កាត់ដណ្តើមយកខ្លះ គប់រកប្រពន្ធរបស់ជនដទៃខ្លះ ពោលពាក្យកុហកខ្លះ នឹងលំបាក ចង្អៀតចង្អល់ ស្មោហ្មងយ៉ាងនេះខ្លះ ។ ព្រះរាជាទាំងឡាយឲ្យចាប់

បុគ្គលនោះឯងហើយ ឲ្យធ្វើកម្មករណ៍ផ្សេងៗ គឺឲ្យគេវាយដោយរំពាត់ខ្លះ ឲ្យគេវាយដោយផ្តៅខ្លះ ឲ្យគេវាយដោយដំបងខ្លីខ្លះ កាត់ដៃខ្លះ កាត់ជើងខ្លះ កាត់ទាំងដៃទាំងជើងខ្លះ កាត់ស្លឹកត្រចៀកខ្លះ កាត់ច្រមុះខ្លះ កាត់ទាំងស្លឹកត្រចៀកទាំងច្រមុះខ្លះ ធ្វើវិលង្គថាលិកកម្ម គឺអំពើដែលគេធ្វើក្បាលឲ្យដូចជាឆ្នាំងដាក់ទឹកជ្រក់ខ្លះ ធ្វើសង្ខមុណ្ឌកកម្ម គឺអំពើដែលគេធ្វើក្បាលឲ្យរលីងដូចជាសម្បកស័ង្ខខ្លះ ធ្វើរាហុមុខកម្ម គឺអំពើដែលគេធ្វើមាត់ឲ្យដូចជាមាត់រាហូខ្លះ ធ្វើជោតិមាលិកកម្ម គឺអំពើដែលគេដុតខ្លួនឲ្យមានរបៀបនៃអណ្តាតភ្លើងខ្លះ ធ្វើហត្ថប្បជោតិកកម្ម គឺអំពើដែលគេដុតដៃខ្លះ ធ្វើឯរកវត្តិកកម្ម គឺអំពើដែលគេធ្វើដូចជាពន្លាត់ស្បែកពពែខ្លះ ធ្វើចិរកវាសិកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាស្លៀកសំពត់សម្បកឈើខ្លះ ធ្វើឯណេយ្យកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាជើងសត្វទ្រាយខ្លះ ធ្វើពឡិសមំសិកកម្ម គឺអំពើដែលគេថ្ពក់មាត់ដោយកាង ឬសន្ទូចខ្លះ ធ្វើកហាបណកកម្ម គឺអំពើដែលគេធ្វើឲ្យខូចសរីរៈប្រមាណប៉ុនកហាបណៈមួយៗខ្លះ ធ្វើខារាបតច្ឆិកកម្ម គឺអំពើដែលគេយកទឹកផ្សាស្រោចខ្លះ ធ្វើបលិឃបរិវត្តិកកម្ម គឺអំពើដែលគេធ្វើដូចជាបង្វិលជើងគុល ឬសសរគោលខ្លះ ធ្វើបលាលបីឋកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាកណ្តាប់ចំបើងខ្លះ ស្រោចដោយប្រេងកំពុងក្តៅខ្លះ ឲ្យឆ្កែខាំខ្លះ ឲ្យដេកផ្ងារលើឈើអណ្តោតទាំងរស់ខ្លះ កាត់ក្បាលដោយដាវខ្លះ បុគ្គលនោះ នឹងលំបាក ចង្អៀតចង្អល់ សៅហ្មងដោយប្រការយ៉ាងនេះខ្លះ ។ មួយទៀត បុគ្គលដែលត្រូវកាមតណ្ហាគ្របសង្កត់ មានចិត្តគឺកាមតណ្ហារួបរឹត ស្វែងរកភោគៈទាំងឡាយចេញទៅកាន់មហាសមុទ្

ដោយទាវ៉ា ត្រូវត្រជាក់ចោមរោម ត្រូវកម្តៅចោមរោម លំបាកដោយសម្ផស្ស នៃរបោម មូស ខ្យល់ កម្តៅ ពស់តូច និងពស់ធំ ត្រូវសេចក្តីស្រេកឃ្លាន បៀតបៀន រមែងទៅកាន់ស្រុកគុម្ពៈ ទៅកាន់ស្រុកតក្កោលៈ ទៅកាន់ស្រុកតក្កសិលា ទៅកាន់ស្រុកកាលមុខៈ ទៅកាន់ស្រុកមរណបារៈ ទៅកាន់ស្រុកវេសុង្គ ទៅកាន់ស្រុកវេរាបថៈ ទៅកាន់ស្រុកជវៈ ទៅកាន់កមលិ ទៅកាន់ស្រុកវង្គៈ ទៅកាន់ស្រុកឯឡវទ្ធនៈ ទៅកាន់ស្រុកសុវណ្ណកូដៈ ទៅកាន់ស្រុកសុវណ្ណភូមិ ទៅកាន់ស្រុកតម្ពបណ្ណិ ទៅកាន់ស្រុកសុប្បារៈ ទៅកាន់ស្រុកភរុកៈ ទៅកាន់ស្រុកសុរដ្ឋៈ ទៅកាន់ស្រុកអង្គណេកៈ ទៅកាន់ស្រុកគង្គណៈ ទៅកាន់ស្រុកបរមគង្គណៈ ទៅកាន់ស្រុកយោនៈ ទៅកាន់ស្រុកបិនៈ ទៅកាន់ស្រុកអល្លសន្ទៈ ទៅកាន់មរុកន្តារៈ ទៅកាន់ផ្លូវដែលគេគប្បីទៅដោយជង្គង់ ទៅកាន់ផ្លូវដែលគេគប្បីទៅដោយចៀម ទៅកាន់ផ្លូវដែលគេគប្បីទៅដោយពពែ ទៅកាន់ផ្លូវជង្គត់ ទៅកាន់ផ្លូវដែលគេគប្បីទៅដោយឆត្រ ទៅកាន់ផ្លូវប្រកបដោយព្រៃឫស្សី ទៅកាន់ផ្លូវសត្វស្លាប ទៅកាន់ផ្លូវកណ្តុរ ទៅកាន់ផ្លូវជ្រោះ ទៅកាន់ផ្លូវមានបន្ទាផ្តៅ បុគ្គលនោះ នឹងលំបាក ចង្អៀតចង្អល់ សៅហ្មង ដោយប្រការយ៉ាងនេះខ្លះ ។ បុគ្គលកាលស្វែងរកមិនបាន រមែងទទួលទុក្ខនិងទោមនស្ស ដែលមានការមិនបានជាមូល បុគ្គលនោះ នឹងលំបាក ចង្អៀតចង្អល់ សៅហ្មង ដោយប្រការយ៉ាងនេះខ្លះ ។ បុគ្គលកាលស្វែងរកទ្រព្យបាន លុះបានហើយ ក៏ទទួលទុក្ខនិងទោមនស្ស មានការថែរក្សាជាមូលថា ធ្វើដូចម្តេចហ្ន៎ ព្រះរាជាទាំងឡាយនឹងមិននាំយកទៅ ចោរទាំងឡាយនឹងមិនលួចយក ភ្លើងនឹងមិនឆេះ

ទឹកនឹងមិនបន្សាត់ទៅ ជនជាទាយាទមិនជាទីស្រឡាញ់នឹងមិននាំយកភោគៈ ទាំងឡាយរបស់អញ កាលបុគ្គលនោះកំពុងរក្សា កំពុងគ្រប់គ្រងយ៉ាងនេះ ភោគៈទាំងឡាយក៏វិនាសទៅ ( បុគ្គលនោះ ) រមែងទទួលទុក្ខនិងទោមនស្ស មានការព្រាត់ប្រាសជាមូល បុគ្គលនោះនឹងលំបាក ចង្អៀតចង្អល់ សៅហ្មង ដោយប្រការយ៉ាងនេះខ្លះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលនឹងត្រជាប ត្រដូស ដូចជាបុគ្គលល្ងង់ខ្លៅ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

បុគ្គលដែលគេដឹងច្បាស់ហើយថា ជាបណ្ឌិត អធិដ្ឋានការ
ប្រព្រឹត្តម្នាក់ឯង តែខាងក្រោយមក ជាអ្នកប្រកបក្នុងមេថុន
ធម្មនឹងត្រជាបត្រដូស ដូចបុគ្គលល្ងង់ខ្លៅ ។

[ ២៥៥ ] មុនិក្នុងធម្មវិន័យនេះ ដឹងទោសនុ៎ះហើយ ក្នុងកាលមុននឹង កាលខាងក្រោយ គប្បីធ្វើការប្រព្រឹត្តម្នាក់ឯងឲ្យមាំ មិនគប្បីសេពសម មេថុន-ធម្មទេ ។

[ ២៥៦ ] អធិប្បាយពាក្យថា មុនិក្នុងធម្មវិន័យនេះ ដឹងទោសនុ៎ះហើយ ក្នុងកាលមុននឹងកាលខាងក្រោយ ត្រង់ពាក្យថា នុ៎ះ សេចក្តីថា យសនិងកេរ្តិ៍ ឈ្មោះក្នុងភាពនៃបុគ្គលជាសមណៈក្នុងកាលមុន អាប់យសនិងអាប់កេរ្តិ៍ឈ្មោះ នៃបុគ្គលពោលលាព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃនិងសិក្ខា ត្រឡប់មកកាន់ភេទ ថោកទាបក្នុងកាលខាងក្រោយ មុនិ ដឹង ស្គាល់ សួង់ ពិចារណា ឈ្វេងយល់ ធ្វើឲ្យជាក់ច្បាស់នូវសម្បត្តិនិងវិបត្តិនុ៎ះ ។ ពាក្យថា មុនិ សេចក្តីថា ញាណ លោកហៅថា មោនៈ បានខាងប្រាជ្ញា ការដឹងច្បាស់ ។បេ។ មុនិនោះ កន្លង

បណ្តាញជាគ្រឿងជាប់ចំពាក់ ។ ពាក្យថា ក្នុងធម្មវិន័យនេះ គឺក្នុងទិដ្ឋិនេះ ក្នុងការគួរនេះ ក្នុងសេចក្តីពេញចិត្តនេះ ក្នុងសេចក្តីប្រកាន់នេះ ក្នុងធម៌នោះ ក្នុងវិន័យនេះ ក្នុងធម៌វិន័យនេះ ក្នុងពាក្យជាប្រធាននេះ ក្នុងព្រហ្មចរិយៈនេះ ក្នុងសាសនានៃព្រះសាស្តានេះ ក្នុងអត្តភាពនេះ ក្នុងមនុស្សលោកនេះ ហេតុនោះ (ទ្រង់ត្រាស់ថា) មុនិក្នុងធម្មវិន័យនេះ ដឹងច្បាស់នូវទោសទុំះហើយ ក្នុងកាលមុននឹងកាលខាងក្រោយ ។

[ ២៥៧ ] ពាក្យថា គប្បីធ្វើការប្រព្រឹត្តម្នាក់ឯងឲ្យមាំ អធិប្បាយថា បុគ្គលគប្បីធ្វើការប្រព្រឹត្តម្នាក់ឯងឲ្យមាំ ដោយហេតុ ២២ គឺដោយចំណែកបព្វជ្ជា ឬ ដោយការលះបង់ពួក ។

បុគ្គលគប្បីធ្វើការប្រព្រឹត្តម្នាក់ឯងឲ្យមាំ ដោយចំណែកបព្វជ្ជា តើដូចម្តេច ។ បុគ្គលកាត់ការកង្វល់ គឺយាវាសទាំងអស់ កាត់ការកង្វល់គឺបុត្តភរិយា កាត់ការកង្វល់គឺញាតិ កាត់ការកង្វល់គឺមិត្តនិងអាមាត្យ កាត់ការកង្វល់គឺការសន្សំកោរសក់និងពុកមាត់ ស្លៀកដណ្តប់សំពត់ជ្រលក់ដោយទឹកចត់ ចេញចាកផ្ទះចូលទៅកាន់ផ្នួស ដល់នូវភាពនៃខ្លួនមិនមានកង្វល់ ត្រាច់ទៅសម្រាកសម្រាន្តសម្រេចឥរិយាបថ ប្រព្រឹត្តទៅ រក្សា រស់នៅ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅតែម្នាក់ឯង បុគ្គលគប្បីធ្វើការប្រព្រឹត្តម្នាក់ឯងឲ្យមាំដោយចំណែកបព្វជ្ជា យ៉ាងនេះ ។

បុគ្គលគប្បីធ្វើការប្រព្រឹត្តម្នាក់ឯងឲ្យមាំដោយការលះបង់ពួក តើដូចម្តេច ។ បុគ្គលនោះ បួសយ៉ាងនេះហើយ ជាបុគ្គលម្នាក់ឯង តែងគប់រកសេនាសនៈ

ស្ងាត់ គឺព្រៃតូចនិងព្រៃធំ មិនមានសំឡេង មិនមានការគឹកកង ជាទីប្រាស ចាកខ្យល់ដែលកើតអំពីកាយនៃជន ស្ងាត់កំបាំងរបស់មនុស្ស សមគួរដល់ការពួនសម្ងំ ។ បុគ្គលនោះ ដើរតែម្នាក់ឯង ឈរតែម្នាក់ឯង អង្គុយតែម្នាក់ឯង សម្រេចការដេកតែម្នាក់ឯង ចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាតតែម្នាក់ឯង ត្រឡប់មកវិញតែម្នាក់ឯង អង្គុយក្នុងទីស្ងាត់តែម្នាក់ឯង អធិដ្ឋានចង្ក្រមតែម្នាក់ឯង ត្រាច់ទៅ សម្រាកសម្រាន្ត សម្រេចឥរិយាបថ ប្រព្រឹត្តទៅ រក្សា រស់នៅ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅតែម្នាក់ឯង បុគ្គលគប្បីធ្វើការប្រព្រឹត្តម្នាក់ឯងឲ្យមាំ ដោយការលះបង់ពួកយ៉ាងនេះ ។ បុគ្គលគប្បីធ្វើនូវការប្រព្រឹត្តម្នាក់ឯងឲ្យមាំ ធ្វើឲ្យខ្ជាប់ខ្ជួន មានការសមាទានដ៏មាំ មានការសមាទានតាំងនៅក្នុងធម៌ជាកុសលទាំងឡាយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលគប្បីធ្វើការប្រព្រឹត្តម្នាក់ឯងឲ្យមាំ ។

[ ២៥៨ ] ពាក្យថា មិនគប្បីសេពសមមេថុនធម្ម សេចក្ដីថា ដែលឈ្មោះថា មេថុនធម្ម បានដល់ធម៌របស់អសប្បុរស ។បេ។ ហេតុនោះ ទើបលោកហៅថា មេថុនធម្ម ។ បុគ្គលមិនគប្បីសេព មិនគប្បីសេពសម មិនគប្បីសេពព្រម មិនគប្បីសេពចំពោះនូវមេថុនធម្ម ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនគប្បីសេពសមមេថុនធម្ម ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

> មុនិ ក្នុងធម្មវិន័យនេះ ដឹងទោសនុ៎ះហើយ ក្នុងកាលមុននឹង
> កាលខាងក្រោយ គប្បីធ្វើការប្រព្រឹត្តម្នាក់ឯងឲ្យមាំ មិនគប្បី
> សេពសមមេថុនធម្មទេ ។

[ ២៥៩ ] បុគ្គលគប្បីសិក្សាវិវេកតែម្យ៉ាង ( ព្រោះថា វិវេក ) នុ៎ះជាធម៌ដ៏ឧត្តមរបស់ព្រះអរិយៈទាំងឡាយ បុគ្គលមិនគប្បីសម្គាល់ថាខ្លួនប្រសើរដោយវិវេកនោះទេ បុគ្គលនោះ ( នឹងឋិតនៅ ) ក្នុងទីជិតព្រះនិព្វាន ។

[ ២៦០ ] ពាក្យថា បុគ្គលគប្បីសិក្សាវិវេកតែម្យ៉ាង សេចក្តីថា វិវេកមាន ៣ គឺកាយវិវេក ១ ចិត្តវិវេក ១ ឧបធិវិវេក ១ ។

កាយវិវេក តើដូចម្តេច ។បេ។ នេះឧបធិវិវេក ។ វិវេករបស់បុគ្គលទាំងឡាយ ដែលមានកាយចៀសចេញចាកពួក ត្រេកអរចំពោះនេក្ខម្ម ឈ្មោះថា កាយវិវេក ១ វិវេករបស់បុគ្គលទាំងឡាយ ដែលមានចិត្តបរិសុទ្ធ ដល់នូវសេចក្តីផូរផង់ដ៏ក្រៃលែង ឈ្មោះថា ចិត្តវិវេក ១ វិវេករបស់បុគ្គលទាំងឡាយ ដែលមិនមានឧបធិកិលេស ដល់នូវវិសង្ខារគឺព្រះនិព្វាន ឈ្មោះថា ឧបធិវិវេក ១ ។ ពាក្យថា សិក្សា បានដល់សិក្ខា ៣ គឺ អធិសីលសិក្ខា ១ អធិចិត្តសិក្ខា ១ អធិប្បញ្ញាសិក្ខា ១ ។បេ។ នេះអធិប្បញ្ញាសិក្ខា ។ ពាក្យថា គប្បីសិក្សាវិវេកតែម្យ៉ាង បានសេចក្តីថា គប្បីសិក្សា ប្រព្រឹត្ត ប្រព្រឹត្តព្រមសមាទាន ប្រព្រឹត្តទៅនូវវិវេក ហេតុនោះ ( ទ្រង់ត្រាស់ថា ) គប្បីសិក្សាវិវេកតែម្យ៉ាង ។

[ ២៦១ ] ពាក្យថា នុ៎ះជាធម៌ដ៏ឧត្តមរបស់ព្រះអរិយៈទាំងឡាយ សេចក្តីថា ព្រះពុទ្ធទាំងឡាយក្តី សាវកនៃព្រះពុទ្ធទាំងឡាយក្តី ព្រះបច្ចេកពុទ្ធទាំងឡាយក្តី លោកហៅថា ព្រះអរិយៈ គុណជាតណាដែលឈ្មោះថា វិវេកចរិយា គុណជាតនុ៎ះ ដ៏លើស ប្រសើរ ខ្ពង់ខ្ពស់ ជាប្រធាន ឧត្តម ថ្លៃថ្លា របស់ព្រះអរិយៈ

ទាំងឡាយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) នុ៎ះជាគុណជាតដ៏ឧត្តមរបស់ព្រះអរិយៈទាំងឡាយ ។

[ ២៦២ ] ពាក្យថា មិនគប្បីសម្គាល់ថា ខ្លួនប្រសើរដោយវិវេកនោះទេ គឺមិនគប្បីធ្វើការតម្កើង មិនគប្បីធ្វើអាការៈធ្មេងធ្មៃ មិនគប្បីធ្វើមានះ មិនគប្បីធ្វើសេចក្តីរឹងត្អឹងដោយវិវេកចរិយានោះ គឺមិនគប្បីញុំាងមានះឲ្យកើត មិនគប្បីធ្វើការជាប់ចំពាក់ដោយវិវេកនោះមិនគប្បីជាអ្នករឹងត្អឹង រឹងរូស មានក្បាលងើបឡើងហើយដោយវិវេកនោះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនគប្បីសម្គាល់ថា ខ្លួនប្រសើរដោយវិវេកនោះទេ ។

[ ២៦៣ ] ពាក្យថា បុគ្គលនោះ ( នឹងឋិតនៅ ) ក្នុងទីជិតព្រះនិព្វាន គឺបុគ្គលនោះ ( នឹងឋិតនៅ ) ក្នុងទីជិត ក្នុងទីជុំវិញ ក្នុងទីអែបនែប ក្នុងទីមិនឆ្ងាយ ក្នុងទីក្បែរព្រះនិព្វាន ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលនោះ ( នឹងឋិតនៅ ) ក្នុងទីជិតព្រះនិព្វាន ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

> បុគ្គលគប្បីសិក្សាវិវេកតែម្យ៉ាង ( ព្រោះថាវិវេក ) នុ៎ះ ជាធម៌
> ដ៏ឧត្តមរបស់ព្រះអរិយៈទាំងឡាយ បុគ្គលមិនគប្បីសម្គាល់ថា
> ខ្លួនប្រសើរដោយវិវេកនោះទេ បុគ្គលនោះ ( នឹងឋិតនៅ )
> ក្នុងទីជិតព្រះនិព្វាន ។

[ ២៦៤ ] ប្រជាជន ដែលជាប់ចំពាក់ក្នុងកាមទាំងឡាយ រមែងស្រឡាញ់មុនិ ដែលជាអ្នកទទេ អ្នកប្រព្រឹត្ត អ្នកមិនមានសេចក្តីអាឡោះអាល័យក្នុងកាមទាំងឡាយ អ្នកឆ្លងឱឃៈ ។

[ ២៦៥ ] អធិប្បាយពាក្យថា មុនិ ជាអ្នកទទេ អ្នកប្រព្រឹត្ត ត្រង់ពាក្យថា ជាអ្នកទទេ គឺជាអ្នកទទេ ស្ងាត់ ស្ងាត់ស្ងួន គឺថាជាអ្នកទទេ ស្ងាត់ ស្ងាត់ស្ងួន ចាកកាយទុច្ចរិត ជាអ្នកទទេ ស្ងាត់ ស្ងាត់ស្ងួនចាកវចីទុច្ចរិត ចាកមនោទុច្ចរិត ចាករាគៈ ទោសៈ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ មាយា សាថេយ្យៈ ថម្ភៈ សារម្ភៈ មានះ អតិមានះ មទៈ បមាទៈ កិលេសទាំងពួង ទុច្ចរិតទាំងពួង សេចក្តីក្រវល់ក្រវាយទាំងពួង សេចក្តីពេលពាលទាំងពួង សេចក្តីក្តៅក្រហាយទាំងពួង អកុសលាភិសង្ខារទាំងពួង ។ ពាក្យថា មុនិ សេចក្តីថា ញាណ លោកហៅថា មោនៈ បានខាងប្រាជ្ញា ការដឹងច្បាស់ ។បេ។ មុនិនោះ កន្លងបណ្តាញ គឺគ្រឿងជាប់ចំពាក់ ។ ពាក្យថា អ្នកប្រព្រឹត្ត អ្នកប្រព្រឹត្តសម្រាកសម្រាន្ត សម្រេចឥរិយាបថ ប្រព្រឹត្តទៅ រក្សា រស់នៅ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មុនិ ជាអ្នកទទេ អ្នកប្រព្រឹត្ត ។

[ ២៦៦ ] អធិប្បាយពាក្យថា អ្នកមិនមានសេចក្តីអាឡោះអាល័យក្នុងកាមទាំងឡាយ ត្រង់ពាក្យថា កាមទាំងឡាយ បើតាមឧទាន បានដល់ កាម ២ គឺវត្ថុកាម ១ កិលេសកាម ១ ។បេ។ នេះហៅថា វត្ថុកាម ។បេ។ នេះហៅថា កិលេសកាម ។ បុគ្គលកំណត់ដឹងវត្ថុកាម លះបង់ កម្ចាត់បង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាននូវកិលេសកាម មិនមានអាល័យក្នុងកាម មានកាមលះចោល មានកាមខ្ជាក់ចោល មានកាមដោះរួច មានកាមលះបង់ មានកាមរលាស់ចោលហើយ មានរាគៈលះបង់ មានរាគៈខ្ជាក់ចោល មានរាគៈដោះ

រូប មានរាគៈលះបង់ មានរាគៈរលាស់ចោលហើយ មិនមានប្រាថ្នា មានទុក្ខរលត់ ជាអ្នកមានចិត្តត្រជាក់ ទទួលសេចក្តីសុខ មានចិត្តដ៏ប្រសើរ ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកមិនមាន សេចក្តីអាឡោះអាល័យក្នុងកាមទាំងឡាយ ។

[ ២៦៧ ] អធិប្បាយពាក្យថា ប្រជាជនដែលជាប់ចំពាក់ក្នុងកាមទាំងឡាយ រមែងស្រឡាញ់ ( មុនិ ) អ្នកឆ្លងឱឃៈ ត្រង់ពាក្យថា ប្រជាជន គឺជាឈ្មោះរបស់សត្វ ប្រជាជនត្រេកអរ ជាប់ចំពាក់ ធ្លាក់ចុះ ផល់ផប់ ជ្រុលជ្រប់ ទាក់ថ្ពក់ ព័ន្ធព័ទ្ធក្នុងកាម ប្រជាជនទាំងនោះ រមែងប្រាថ្នា ត្រេកអរ រាប់រក ស្រឡាញ់ ក្ខួចកាន់ ( ចំពោះមុនិ ) ដែលឆ្លងអន្លង់គឺកាម ឆ្លងអន្លង់គឺភព ឆ្លងអន្លង់គឺទិដ្ឋិ ឆ្លងអន្លង់គឺអវិជ្ជា ឆ្លង ឆ្លងឡើង ឆ្លងចេញ កន្លង ឈានកន្លង ប្រព្រឹត្តរំលងនូវផ្លូវនៃសង្សារទាំងពួង ជាអ្នកទៅកាន់ត្រើយ ដល់ត្រើយ ទៅកាន់ទីបំផុត ដល់ទីបំផុត ទៅហើយកាន់ទីខាងចុង ដល់ទីខាងចុង ទៅកាន់ទីបំផុតជុំវិញ ដល់ទីបំផុតជុំវិញ ទៅកាន់ទីជាទីចប់ស្រេច ដល់ទីជាទីចប់ស្រេច ទៅកាន់ទីពំនាក់ ដល់ទីពំនាក់ ទៅកាន់ទីជ្រកកោន ដល់ទីជ្រកកោន ទៅកាន់ទីពឹង ដល់ទីពឹង ទៅកាន់ទីមិនមានភ័យ ដល់ទីមិនមានភ័យ ទៅកាន់ទីមិនច្យុត ដល់ទីមិនច្យុត ទៅកាន់ទីមិនស្លាប់ ដល់ទីមិនស្លាប់ ទៅកាន់ព្រះនិព្វាន ដល់ព្រះនិព្វាន ។ ពួកជនអ្នកចំពាក់បំណុល រមែងប្រាថ្នា ស្រឡាញ់នូវភាពជាអ្នកមិនមានបំណុលយ៉ាងណា ពួកជនមានជំងឺ រមែងប្រាថ្នា ស្រឡាញ់នូវភាពជាអ្នកមិនមានរោគយ៉ាងណា ពួកជនដែលជាប់ចំណង រមែងប្រាថ្នា ស្រឡាញ់នូវការរួចចាកចំណងយ៉ាងណា ពួកជនជាទាសៈ រមែងប្រាថ្នា ស្រឡាញ់នូវភាពនៃខ្លួនជាអ្នកជា

យ៉ាងណា ពួកជន ដែលចេញទៅកាន់ផ្លូវឆ្ងាយជាប់ស្រយាល រមែងប្រាថ្នា ស្រឡាញ់ទីដ៏ក្សេម យ៉ាងណា ពួកប្រជាជន ត្រេកអរ ជាប់ចំពាក់ ធ្លាក់ចុះ ងប់ងល់ ជ្រុលជ្រប់ ទាក់ ជ្លក់ ព័ន្ធព័ទ្ធក្នុងកាមទាំងឡាយ ប្រជាជនទាំងនោះ រមែងប្រាថ្នា ត្រេកអរ រាប់រក ក្ដួចកាន់ ( ចំពោះមុនិ ) ដែលឆ្លងអន្លង់គឺកាម ឆ្លងអន្លង់គឺភព ។បេ។ ទៅកាន់ព្រះនិព្វាន ដល់ព្រះនិព្វាន យ៉ាងនោះដែរ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ប្រជាជន ដែលជាប់ចំពាក់ក្នុងកាមទាំងឡាយ រមែងស្រឡាញ់មុនិ អ្នកឆ្លងឱឃៈ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ប្រជាជនដែលជាប់ចំពាក់ក្នុងកាមទាំងឡាយ រមែងស្រឡាញ់
មុនិដែលជាអ្នកទទេ អ្នកប្រព្រឹត្ត មិនមានសេចក្ដីអាឡោះ
អាល័យក្នុងកាមទាំងឡាយ អ្នកឆ្លងឱឃៈ ។

## ចប់ តិស្សមេត្តេយ្យសុត្តនិទ្ទេស ទី ៧

# អដ្ឋកថា

## តិស្សមេត្តេយ្យសុត្តនិទ្ទេសទី ៧

ក្នុងតិស្សមេត្តេយ្យសុត្តនិទ្ទេសទី ៧ មានវិនិច្ឆ័យដូចតទៅនេះថា

[ ២២៤ ] បទថា **មេថុនមនុយុត្តស្ស** សេចក្តីថា ជាអ្នកប្រកបរឿយៗ ក្នុងមេថុនធម្ម ។ បទថា **ឥតិ** សេចក្តីថា ព្រះតិស្សមេត្តេយ្យៈក្រាបទូលយ៉ាងនេះ ។ បទថា **អាយស្មា** ជាពាក្យសម្តែងសេចក្តីស្រឡាញ់ ។ បទថា **តិស្សោ** ត្រឹមតែជាឈ្មោះរបស់ព្រះថេរៈនោះ ព្រះថេរៈនោះ ប្រាកដដោយឈ្មោះថា តិស្សៈ ។ ព្រះថេរៈនេះ ប្រាកដដោយអំណាចនៃគោត្តនោះឯងថា **មេត្តេយ្យ** ព្រោះដូច្នោះ ក្នុងអត្ថុប្បត្តិកថា ទើបលោកពោលថា មានសម្ភារ៉ញ់ពីរនាក់ ឈ្មោះតិស្ស-មេត្តេយ្យៈ(១) ។

បទថា **វិឃាតំ** បានដល់ ចូលទៅប៉ះខ្ទប់ ។ បទថា **ព្រូហិ** បានដល់ សូមមេត្តាប្រាប់ឲ្យដឹង ។ បទថា **មារិស** ជាពាក្យសម្តែងសេចក្តីស្រឡាញ់ លោកអធិប្បាយថា អ្នកនិទ្ទុក្ខ ។ បទថា **សុត្វាន តវ សាសនំ** សេចក្តីថា ស្តាប់ព្រះតម្រាស់របស់ព្រះអង្គហើយ ។ បទថា **វិវេកេ សិក្ខិសាមសេ** សេចក្តីថា ព្រះតិស្សមេត្តេយ្យៈ ប្រារព្ធសម្ភារ៉ញ់ ក្រាបទូលអារាធនាឲ្យទ្រង់សម្តែងធម៌ ។ ព្រះថេរៈនោះជាអ្នកមានសិក្ខាដែលសិក្សាចប់ហើយនោះឯង ។

[ ២២៥ ] បទថា **មេថុនធម្មោ នាម** នេះជាបទឧទ្ទេសមេថុនធម្ម ដែលគប្បីប្រាប់ ។ បទថា **អសទ្ធម្មោ** បានដល់ ធម៌របស់អសប្បុរស គឺជនថោកថយ ។ បទថា **គាមធម្មោ** បានដល់ ធម៌ដែលពួកអ្នកស្រុកប្រព្រឹត្ត ។

---

១-ប្រវត្តិព្រះថេរៈទាំងពីរបានពោលហើយ ក្នុងសុត្តនិបាតតិស្សមេត្តេយ្យសូត្រឯណោះ ។

បទថា **វសលធម្មោ** បានដល់ ធម៌របស់បុគ្គលថោកថយ ម្យ៉ាងទៀត ឈ្មោះថា **វសលធម្មោ** ព្រោះអត្ថថា ជាធម៌អាក្រក់ ដូចភ្លៀង ព្រោះកិលេសលិចស្រោច ។

បទថា **ទុដ្ឋុល្លោ** សេចក្ដីថា ឈ្មោះថា **ទុដ្ឋុល្លោ** ព្រោះអត្ថថា ឈ្មោះថា **ទុដ្ឋុល្លោ** ព្រោះកិលេសប្រទូស្ដ ឈ្មោះថា **ទុដ្ឋុល្លោ** ព្រោះមិនល្អិត ព្រោះការឃើញក្ដី ការប្រកាន់ក្ដី ការស្ទាបអង្អែលក្ដី ការពាល់ត្រូវក្ដី ការប៉ះខ្ទប់ក្ដី ដែលជាបរិវារនៃធម៌នោះ អាក្រក់គ្រោតគ្រាត ព្រោះហេតុនោះ ទើបមេថុនធម្មនោះជាធម៌អាក្រក់ ។

បទថា **ឱទកន្តិកោ** សេចក្ដីថា ឈ្មោះថា **ឱទកន្តិកោ** ព្រោះអត្ថថា កាន់យកទឹក ដើម្បីសេចក្ដីបរិសុទ្ធ ( លាង ) ក្នុងទីបំផុតនៃធម៌នោះ ។ ឧទកន្ត: នោះឯង ជាឱទកន្តិក: ។ ឈ្មោះថា **រហស្សោ** ព្រោះជាធម៌គប្បីធ្វើក្នុងទីស្ងាត់ គឺក្នុងឱកាសដែលបិទបាំង បាឋៈក្នុងព្រះវិន័យថា **ទុដ្ឋុល្លំ ឱទកន្តិកំ រហស្សំ** ដូច្នេះក៏មាន ។ ក្នុងបទ ៣ នោះ គប្បីផ្លាស់បទ **យោ សោ** ប្រកបជា **យំ តំ** សេចក្ដីថា ធម៌ណាគ្រោតគ្រាត ធម៌នោះជាមេថុនធម្ម ធម៌ណាមានទឹកជាទីបំផុត ធម៌នោះជាមេថុនធម្ម ។ ធម៌ណាគប្បីធ្វើក្នុងទីកំបាំង ធម៌នោះជាមេថុនធម្ម តែក្នុងទីនេះ គប្បីជ្រាបការប្រកបសេចក្ដីយ៉ាងនេះថា ធម៌ណា ជាធម៌របស់អសប្បុរស ធម៌នោះជាមេថុនធម្ម ។បេ។ ធម៌ណាជាធម៌ដែលគប្បីធ្វើក្នុងទីស្ងាត់ ធម៌នោះជាមេថុនធម្ម ។ ឈ្មោះថា ធម៌ គឺការដល់ព្រមដោយធម៌របស់បុគ្គលដែលគូគ្នា ជាធម៌ដែលបុគ្គលគូៗ គប្បីដល់ព្រម ប្រកបសេចក្ដីក្នុងបទ

នោះថា ការដល់ព្រមដោយធម៌របស់បុគ្គលដែលគូគ្នានោះ ឈ្មោះថា មេថុនធម្ម ។ បទថា **កឹការណា វុច្ចតិ មេថុនធម្មោ** សេចក្តីថា បានឮថា មេថុនធម្ម ដោយហេតុដូចម្តេច ដោយបរិយាយដូចម្តេច ព្រះសារីបុត្តត្ថេរកាលនឹងសម្តែងហេតុនោះ ទើបពោលថា **ឧភិន្នំ រត្តានំ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **ឧភិន្នំ រត្តានំ** សេចក្តីថា នៃស្រីនិងបុរស ២ នាក់ ដែលទទឹកដោយរាគៈហើយ ។ បទថា **សារត្តានំ** បានដល់ ទទឹកហើយ ដោយវិសេសគឺដោយល្អ ។ បទថា **អវស្សុតានំ** សេចក្តីថា រួបរឹតហើយដោយកិលេស ។ បទថា **បរិយុដ្ឋិតានំ** សេចក្តីថា កម្ចាត់និងញ៉ាំញី អាចារៈដែលជាកុសលតាំងនៅ ដូចក្នុងប្រយោគថា **មគ្គេ ចោរា បរិយុដ្ឋិតា** ចោរប្លន់ក្នុងផ្លូវជាដើម ។ បទថា **បរិយាទិន្នចិត្តានំ** សេចក្តីថា ជាអ្នកមានចិត្តកម្ចាត់កុសលចិត្ត គឺធ្វើឲ្យអស់ទៅហើយតាំងនៅ ។ បទថា **ឧភិន្នំ សទិសានំ** សេចក្តីថា ទាំង ២ នាក់ មានកិលេសស្មើគ្នា ។ បទថា **ធម្មោ** បានដល់សភាវៈ ។ បទថា **តំការណា** សេចក្តីថា ព្រោះហេតុនោះ ។ ព្រះសារីបុត្តត្ថេរកាលនឹងញ៉ាំងសេចក្តីនោះឲ្យសម្រេចដោយឧបមា ទើបពោលថា **ឧភោ កលហការកា** ជាដើម ។

បណ្តាបទទាំងនោះ បទថា **ឧភោ កលហការកា** សេចក្តីថា ក្នុងកាលដែលជាខាងដើម ជន ២ នាក់ធ្វើនូវការឈ្លោះគ្នា ។ បទថា **មេថុនកាតិ វុច្ចន្តិ** សេចក្តីថា ហៅថាបុគ្គលដូចគ្នា ។ បទថា **ភណ្ឌនការកា** សេចក្តីថា ធ្វើនូវការប្រេះឆាក្នុងរឿងផ្សេងៗ ។ បទថា **ភស្សការកា** សេចក្តីថា ធ្វើនូវការឈ្លោះ

គ្នាដោយវាចា ។ បទថា **វិវាទការកា** សេចក្តីថា ធ្វើនូវពាក្យពោលផ្សេងៗ ។ បទថា **អធិករណការកា** សេចក្តីថា ធ្វើនូវហេតុពិសេសដែលត្រូវវិនិច្ឆ័យ ។ បទថា **វាទិនោ** សេចក្តីថា ពោលនិងពោលឆ្លើយឆ្លងគ្នា ។ បទថា **សល្លាបកា** សេចក្តីថា ពោលចរចា ។ បទថា **ឯវមេវ** ជាពាក្យប្រៀបធៀបដោយឧបមា ។

បទថា **យុត្តស្ស** សេចក្តីថា ប្រកបព្រម ។ បទថា **បយុត្តស្ស** សេចក្តីថា ប្រកបដោយអើពើ ។ បទថា **អាយុត្តស្ស** សេចក្តីថា ប្រកបជាពិសេស ។ បទថា **សមាយុត្តស្ស** សេចក្តីថា ប្រកបដោយភាពតែមួយ ។ បទថា **តព្ពរិតស្ស** សេចក្តីថា ធ្វើនូវមេថុនធម្មនោះ ។ បទថា **តព្ពហុលស្ស** សេចក្តីថា ធ្វើនូវមេថុនធម្មនោះឲ្យច្រើន ។ បទថា **តគ្គរុកស្ស** សេចក្តីថា ធ្វើមេថុនធម្មនោះឲ្យធ្ងន់ ។ បទថា **តន្និន្នស្ស** សេចក្តីថា មានចិត្តបង្អោនទៅក្នុងមេថុនធម្មនោះ ។ បទថា **តប្បោណស្ស** សេចក្តីថា មានកាយបង្អោនទៅក្នុងមេថុនធម្មនោះ ។ បទថា **តប្បព្ភារស្ស** សេចក្តីថា មានកាយបែរមុខទៅក្នុងមេថុនធម្មនោះ ។ បទថា **តទធិមុត្តស្ស** សេចក្តីថា មានចិត្តគ្រោចទៅក្នុងមេថុនធម្មនោះ ។ បទថា **តទាធិបតេយ្យស្ស** សេចក្តីថា ធ្វើនូវមេថុនធម្មនោះឲ្យជាធំ ឲ្យជាប្រធានប្រព្រឹត្តទៅ ។

[ ២២៧ ] បទថា **វិយាតំ** ជាបទឧទ្ទេសនៃបទដែលគប្បីចង្អុលបង្ហាញ ។ បទថា **វិយាតំ** សេចក្តីថា ការបៀតបៀន ។ បទថា **ឧបយាតំ** សេចក្តីថា ការបៀតបៀនយ៉ាងជិត ។ បទថា **បីឡនំ** សេចក្តីថា បៀតបៀន ។ បទថា **ឃដ្ដនំ** សេចក្តីថា ការគ្រុបសង្កត់ ។ បទទាំងអស់ជាវេវចនៈដល់គ្នានឹងគ្នា ។

*បទថា* **ឧបច្ចរំ** *សេចក្ដីថា ការបៀតបៀន ។ បទថា* **ឧបសគ្គំ** *សេចក្ដីថា អាការៈដែលចូលទៅបៀតបៀនក្នុងទីនោះៗ ។ បទថា* **ព្រូហិ** *បានដល់ សូមត្រាស់ប្រាប់ ។ បទថា* **អាចិក្ខ** *បានដល់ សូមវិសជ្ជនា ។ បទថា* **ទេសេហិ** *បានដល់ សូមសម្ដែង ។ បទថា* **បញ្ញាបេហិ** *បានដល់ សូមប្រាប់ឲ្យជ្រាប ។ បទថា* **បដ្ឋបេហិ** *បានដល់ សូមតាំងទុក ។ បទថា* **វិវរ** *បានដល់ សូមធ្វើឲ្យប្រាកដ ។ បទថា* **វិភជ** *បានដល់ សូមចែក ។ បទថា* **ឧត្តានីករោហិ** *បានដល់ សូមឲ្យដល់ត្រើយនាយ ។ បទថា* **បកាសេហិ** *បានដល់ សូមធ្វើឲ្យប្រាកដ ។*

*[ ២២៨ ] បទថា* **តុយ្ហំ វចនំ** *បានដល់ ព្រះតម្រាស់របស់ព្រះអង្គ ។ បទថា* **ព្យបថំ** *បានដល់ គន្លងព្រះតម្រាស់ ។ បទថា* **ទេសនំ** *បានដល់ ត្រាស់ប្រាប់ ។ បទថា* **អនុសាសនំ** *បានដល់ ព្រះឱវាទ ។ បទថា* **អនុសិដ្ឋឹ** *បានដល់ ព្រះតម្រាស់ប្រៀនប្រដៅរឿយៗ ។ បទថា* **សុត្វា** *សេចក្ដីថា ស្ដាប់ហើយដោយសោតវិញ្ញាណ ។ បទថា* **សុណិត្វា** *ជាវេវចនៈរបស់បទថា* **សុត្វា** *នោះឯង ។ បទថា* **ឧគ្គហេត្វា** *សេចក្ដីថា កាន់យកដោយប្រពៃ ។ បទថា* **ឧបធារយិត្វា** *សេចក្ដីថា មិនឲ្យភ្លេច ។ បទថា* **ឧបលក្ខយិត្វា** *សេចក្ដីថា កំណត់ទុក ។*

*[ ២៣០ ] បទថា* **មុស្សតេ វាបិ សាសនំ** *សេចក្ដីថា ពាក្យប្រៀនប្រដៅទាំងពីរយ៉ាង គឺបរិយត្តិនិងបដិបត្តិរមែងវិនាស ។ បទថា* **វាបិ** *ត្រឹមតែជាបទបូរណៈ ។ បទថា* **ឯតំ តស្មឹ អនាវិយំ** *សេចក្ដីថា នេះគឺមិច្ឆាបដិបទា ជា*

ធម៌ដែលមិនប្រសើរក្នុងបុគ្គលនោះ ។

[ ២៣១ ] បទថា **គារវាធិវចនំ** ជាពាក្យពោលដោយការគោរពចំពោះគ្រូដ៏ឧត្តម ជាសត្វដែលប្រសើរដោយគុណ ព្រោះហេតុនោះ ទើបបុរាណាចារ្យពោលថា

ពាក្យថា **ភគវា** ជាពាក្យប្រសើរបំផុត ពាក្យថា **ភគវា** ជាពាក្យឧត្តម ព្រោះព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់គួរដល់សេចក្តីគោរពដោយឋានៈជាគ្រូ ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា **ភគវា** ដូច្នេះ ។

មែនពិត នាមមាន ៤ យ៉ាងគឺអាវត្ថិកនាម ១ លិង្គិកនាម ១ នេមិត្តកនាម ១ អធិច្ចសមុប្បន្ននាម ១ ។

មានពាក្យអធិប្បាយថា នាមដែលតាំងឡើង តាមសេចក្តីប្រាថ្នា តាមវោហាររបស់សត្វលោក ឈ្មោះថា អធិច្ចសមុប្បន្ននាម ។

បណ្តានាមទាំងនោះ នាមជាដើមថា កូនគោ គោស្ទាវ គោដែលល្មមប្រើការ នេះឈ្មោះថា អាវត្ថិកនាម ។

នាមជាដើមថា បុគ្គលមានឈើច្រត់ បុគ្គលមានឆត្រ សត្វមានសិរ សត្វមានប្រមោយ យ៉ាងនេះឈ្មោះថា លិង្គិកនាម ។

នាមជាដើមថា បុគ្គលបានវិជ្ជា ៣ បុគ្គលបានអភិញ្ញា ៦ យ៉ាងនេះ ឈ្មោះថា នេមិត្តកនាម ។

នាមជាដើមថា ចម្រើនសិរី ចម្រើនទ្រព្យ តាំងឡើងដោយមិនបានសម្លឹង

អត្ថនៃពាក្យ យ៉ាងនេះឈ្មោះថា អធិច្ចសមុប្បន្ននាម ។

ព្រះនាមថា **ភគវា** នេះជានេមិត្តកនាម ព្រះនាងសិរិមហាមាយាក៏មិនបានថ្វាយ ព្រះបាទសុទ្ធោទនមហារាជក៏មិនបានថ្វាយ ព្រះញាតិ ៨ ម៉ឺនក៏មិនបានថ្វាយ ទេវតាវិសេសទាំងឡាយ មានសក្កទេវរាជនិងទេវសន្តុសិតទេវរាជជាដើម ក៏មិនបានថ្វាយ ។ មែនពិត ព្រះសារីបុត្តត្ថេរពោលទុកថា ព្រះនាមថា មានព្រះភាគនុ៎ះ មិនមែនព្រះមាតាធ្វើ ។បេ។ ព្រះនាមថា មានព្រះភាគនុ៎ះ របស់ព្រះពុទ្ធទាំងឡាយមានព្រះភាគ ជាព្រះនាមកើតក្នុងទីបំផុតនៃវិមោក្ខ គឺសេចក្ដីបញ្ញត្តថា មានព្រះភាគនេះ កើតអំពីការបានត្រាស់ដំណាលគ្នានឹងការបានចំពោះសព្វញ្ញុតញ្ញាណ ។បេ។ និងន័យមួយទៀតថា

ព្រះដ៏មានព្រះភាគ ទ្រង់មានជោគ ទ្រង់កាច់បំបាក់នូវកិលេស
ទ្រង់ប្រកដោយភគធម៌ ទ្រង់ចែកនូវធម៌ ទ្រង់គប់រកធម៌ និង
ទ្រង់ខ្ជាក់នូវកិលេសជាគ្រឿងទៅក្នុងភពទាំងឡាយបានហើយ
ហេតុនោះ ទើបទ្រង់ព្រះនាមថា ភគវា ដូច្នេះ ។

ក្នុងគាថានោះ លោកពោលនិរុត្តិសាស្ត្រទុក ៥ យ៉ាង គឺការចុះអក្ខរៈថ្មី ១ ការប្តូរអក្ខរៈ ១ ការផ្លាស់អក្ខរៈ ១ ការលុបអក្ខរៈ ១ និងការប្រកបដោយសេចក្ដីសម្បូរនៃអត្ថរបស់ធាតុទាំងឡាយ ១ បណ្ឌិតគប្បីកាន់យកលក្ខណៈនៃនិរុត្តិសាស្ត្រ ដែលលោកពោលទុកយ៉ាងនេះ ជ្រាបនូវសេចក្ដីសម្រេចនៃបទដោយប្រការដូច្នេះ ។

បណ្ដានិរុត្តិសាស្ត្រ ៥ យ៉ាងនោះ ការចុះអក្ខរៈដែលមិនមាន ដូចការចុះ

រ អក្ខរៈក្នុងប្រយោគនេះថា **ឆក្ខត្តាភិរិរ សារកានំ** ដូច្នេះ ឈ្មោះថា ការចុះអក្ខរៈថ្មី ។

ការផ្លាស់អក្ខរៈដែលមាន ដោយយកខាងមុខទុកខាងក្រោយ ដូចកាលគួរនឹងពោលថា **ហឹសនា ហឹសោ** បែរជាពោលថា **សីហោ** ដូច្នោះ ឈ្មោះថា ការប្តូរអក្ខរៈ ។

ការផ្លាស់អក្ខរៈឲ្យជាអក្ខរៈដទៃ ដូចការផ្លាស់ **អ** អក្ខរៈ ជា **ឯ** អក្ខរៈ ដូចក្នុងប្រយោគនេះថា **ឆវិច្ឆន្ទកេ ឆានេ ឱយតិ** ដូច្នេះ ឈ្មោះថា ការផ្លាស់អក្ខរៈ ។ ការលុបអក្ខរៈដែលមាន ដូចគួរពោលថា **ជីវនស្ស មុតោ ជីវន-មុតោ** គឺលុប **វ** អក្ខរៈនិង **ន** អក្ខរៈជា **ជីមុតោ** ដូច្នេះ ឈ្មោះថា ការលុបអក្ខរៈ ។

ការប្រកបអត្ថជាពិសេស តាមដែលប្រកបក្នុងទីនោះៗ ដូចការធ្វើពាក្យថា **បក្កុព្វមានោ** ដូចក្នុងប្រយោគនេះថា **ជរុសាហិ វាចាហិ បក្កុព្វមានោ អាសជ្ជ មំ ត្វំ វទសិ កុមារ** ឲ្យសម្រេចសេចក្តីថា **អតិភវមានោ** ដូច្នេះ ឈ្មោះថា ការប្រកបដោយសេចក្តីសម្បូរនៃអត្ថរបស់ធាតុទាំងឡាយ ។ ព្រោះហេតុដែលព្រះដ៏មានព្រះភាគ ទ្រង់មានភាគ្យៈ ដែលដល់ត្រើយ មានទាននិងសីលជាដើម ដែលឲ្យកើតលោកិយសុខនិងលោកុត្តរសុខ ហេតុនោះ កាលគួរថ្វាយព្រះនាមថា **ភាគ្យវា** តែក៏ថ្វាយព្រះនាមថា **ភគវា** គប្បីជ្រាបថា លោកកាន់យកលក្ខណៈនៃនិរុត្តិសាស្ត្រយ៉ាងនេះ ឬកាន់យកលក្ខណៈ គឺការបន្ថែមសព្ទតាមន័យ **តិសោទរ** សព្ទជាដើម ដោយន័យរបស់សព្ទសាស្ត្រ ។

ម្យ៉ាងទៀត ព្រោះព្រះដ៏មានព្រះភាគ បានកាច់បំបាក់នូវកិលេសជាគ្រឿងក្រវល់ក្រវាយ ជាគ្រឿងក្តៅក្រហាយគ្រប់យ៉ាងរាប់សែន មានលោភៈ ទោសៈ មោហៈ មនសិការវិបរិត្ត អហិរិកៈ អនោត្តប្បៈ កោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយ មាយា សាថេយ្យៈ ថម្ភៈ សារម្ភៈ មានះ អតិមានះ មទៈ បមាទៈ តណ្ហា អវិជ្ជា អកុសលមូល ៣ ទុច្ចរិត ៣ សង្កិលេស ៣ មលៈ ៣ វិសមញ្ញា ៣ វិតក្ក ៣ បបញ្ចៈ ៣ វិបរិយេសៈ ៤ អាសវៈ ៤ គន្ថៈ ៨ ឱឃៈ ៤ យោគៈ ៤ អគតិ ៤ តណ្ហា ៤ ឧបាទាន ៤ ចេតោខីលៈ ៥ វិនិពន្ធៈ ៥ នីវរណៈ ៥ អភិនន្ទៈ ៥ វិវាទមូល ៦ គំនរតណ្ហា ៦ អនុស័យ ៧ មិច្ឆត្តៈ ៨ តណ្ហាមូល ៩ អកុសលកម្មបថ ១០ ទិដ្ឋិ ៦២ តណ្ហាវិចរិត ១០៨ ឬដោយសង្ខេបនូវមារ ៥ គឺកិលេសមារ ខន្ធមារ អភិសង្ខារមារ មច្ចុមារនិងទេវបុត្តមារ ហេតុនោះ កាលគួរថ្វាយព្រះនាមថា **ភគ្គវា** ព្រោះទ្រង់កាច់បំបាក់នូវអន្តរាយទាំងនេះបានហើយ តែថ្វាយព្រះនាមថា **ភគវា** ។ ម្យ៉ាងទៀត លោកពោលទុកក្នុងទីនេះថា

ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់កាច់បំបាក់នូវរាគៈ ទោសៈ
មោហៈបានហើយ ទ្រង់មិនមានអាសវៈធម៌ ដ៏លាមកទាំង
ឡាយ ព្រះអង្គទ្រង់កាច់បំបាក់ហើយ ហេតុនោះ ទើបទ្រង់
ព្រះនាមថា ភគវា ដូច្នេះ ។

ម្យ៉ាងទៀត សម្បត្តិនៃរូបកាយរបស់ព្រះអង្គ ទ្រទ្រង់នូវបុញ្ញលក្ខណៈរាប់រយ ឈ្មោះថា លោកសម្តែងហើយដោយភាពដែលព្រះអង្គទ្រង់មានភាគ្យៈ ។

សម្បត្តិនៃធម្មកាយរបស់ព្រះអង្គ ឈ្មោះថា លោកសម្តែងហើយដោយកាពដែលព្រះអង្គទ្រង់កាច់បំបាក់នូវទោសបាន ។ ម្យ៉ាងទៀត ភាពដែលព្រះអង្គ ដែលលោកិយជនទិងអ្នកដឹងហេតុហ័សទាំងឡាយរាប់អានហើយច្រើន ជាបុគ្គលដែលគ្រហស្ថនិងបព្វជិតទាំងឡាយគប្បីចូលគាល់ ជាអ្នកអាចកម្ចាត់នូវទុក្ខកាយ ទុក្ខចិត្តរបស់បុគ្គលដែលចូលគាល់ទាំងនោះ ជាអ្នកមានឧបការៈដោយអាមិសទាននិងធម្មទាន ជាអ្នកអាចប្រកបជនទាំងនោះទុកដោយលោកិយសុខនិងលោកុត្តរសុខ ឈ្មោះថា លោកសម្តែងហើយ ។

ម្យ៉ាងទៀត ព្រោះ **ភគ** សព្ទ ប្រព្រឹត្តទៅក្នុងធម៌ ៦ ប្រការក្នុងលោក គឺឥស្សរិយៈ ធម៌ យស សិរី កាម និងសេចក្តីខ្វល់ខ្វាយ ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់មានឥស្សរិយៈក្នុងព្រះហឫទ័យរបស់ព្រះអង្គយ៉ាងក្រៃលែង ឬទ្រង់មានឥស្សរិយៈ បរិបូណ៌ដោយអាការៈទាំងពួង ដែលសត្វលោកដឹងហើយមានបាត់ខ្លួននិងរសាត់បាត់ជាដើម ។

ម្យ៉ាងទៀត ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់មានលោកុត្តរធម៌ ទ្រង់មានព្រះយសបរិសុទ្ធក្រៃលែង ដែលទ្រង់សម្រេចដោយព្រះគុណតាមសេចក្តីពិតដែលល្បីទៅក្នុងលោកទាំង ៣ ទ្រង់មានព្រះសិរីនៃអង្គាវយវៈតូចធំ គ្រប់ចំណែកបរិបូណ៌ដោយអាការៈទាំងពួង អាចញ៉ាំងសេចក្តីជ្រះថ្លាឲ្យកើតឡើងដល់ភ្នែកនិងចិត្តរបស់បុគ្គលដែលខ្វល់ខ្វាយ ក្នុងការសរសើរព្រះរូបកាយ ទ្រង់មានសេចក្តីប្រាថ្នាដែលដឹងហើយថា សេចក្តីសម្រេចប្រយោជន៍ដែលទ្រង់ប្រាថ្នា ព្រោះមិនជាប្រយោជន៍ណាមួយ ដែលព្រះអង្គទ្រង់បំណងទ្រង់ប្រាថ្នា ទោះជា

ប្រយោជន៍ខ្លួនក្តី ប្រយោជន៍អ្នកដទៃក្តី ប្រយោជន៍ទោះៗក៏សម្រេចបានដូច្នោះ ឯង ម្យ៉ាងទៀត ព្រះអង្គទ្រង់មានសេចក្តីខ្វល់ខ្វាយ ពោលគឺសេចក្តីព្យាយាម ប្រពៃ ដែលជាហេតុឲ្យកើតនូវភាពជាគ្រូរបស់លោកទាំងពួង ព្រោះហេតុនោះ ទើបបណ្ឌិតថ្វាយព្រះនាមថា ភគវា ដោយអត្ថនេះថា ព្រោះទ្រង់មានភគធម៌ ព្រោះ ទ្រង់ប្រកបដោយភគធម៌ទាំងនេះ ។

ម្យ៉ាងទៀត ព្រោះមានពាក្យពោលទុកថា ព្រះអង្គទ្រង់ចែក គឺទ្រង់បែងចែក បើកផ្ចារ សម្តែងដល់ធម៌ទាំងពួង ដោយប្រភេទ មានកុសលជាដើម ឬនូវធម៌ មានកុសលជាដើម ដោយប្រភេទជាដើមថា ខន្ធ អាយតនៈ ធាតុ សច្ចៈ ឥន្ទ្រិយនិងបដិច្ចសមុប្បាទ ឬនូវទុក្ខអរិយសច្ចៈ ដោយអត្ថថា បៀតបៀន ដែល បច្ច័យតាក់តែង ធ្វើឲ្យក្តៅក្រហាយនិងប្រែប្រួល នូវសមុទយអរិយសច្ចៈដោយ អត្ថថា ជាហេតុប្រមូលមក ជាហេតុប្រគល់ឲ្យនូវផល ជាហេតុប្រកបនិងជា ហេតុកង្វល់ ។ នូវនិរោធសច្ចៈ ដោយអត្ថថា ជាគ្រឿងរលាស់ចេញ ជាការ ស្ងាត់មិនមានបច្ច័យតាក់តែងនិងជាធម៌មិនស្លាប់ នូវមគ្គអរិយសច្ចៈដោយអត្ថ ថា ជាគ្រឿងនាំចេញ ជាហេតុ ជាទស្សនៈនិងជាធំ ព្រោះហេតុនោះ កាលគួរ ថ្វាយព្រះនាមថា **វិភត្តវា** តែថ្វាយព្រះនាមថា **ភគវា** ។

ម្យ៉ាងទៀត ព្រះអង្គទ្រង់គប់រក គឺទ្រង់សេព ទ្រង់ធ្វើឲ្យច្រើននូវទិព្វវិហារ ព្រហ្មវិហារនិងអរិយវិហារ នូវកាយវិវេក ចិត្តវិវេកនិងឧបធិវិវេក នូវសុញ្ញត- វិមោក្ខ អប្បណិហិតវិមោក្ខ អនិមិត្តវិមោក្ខនិងនូវឧត្តរិមនុស្សធម៌ដទៃ ទាំងជា លោកិយទាំងជាលោកុត្តរ ព្រោះហេតុនោះ កាលគួរថ្វាយព្រះនាមថា **ភត្តវា**

តែថ្វាយព្រះនាមថា **ភគវា** ។

ម្យ៉ាងទៀត ព្រោះទ្រង់ខ្ជាក់ចោលនូវការទៅ ពោលគឺតណ្ហាក្នុងភព ៣ ចេញហើយ ដូច្នោះ កាលគួរថ្វាយព្រះនាមថា **ភវេសុ វន្តគមនោ** ( ទ្រង់ខ្ជាក់កិលេសដែលជាគ្រឿងទៅក្នុងភពទាំងឡាយបានហើយ ) តែលោកកាន់លោកកាន់យក **ភ** អក្ខរៈ ចាក **ភវ** សព្ទ **គ** អក្ខរៈ ចាក **គមន** សព្ទ **វ** អក្ខរៈ ចាក **វន្ត** សព្ទ ធ្វើឲ្យជាទីឃៈហើយ ថ្វាយព្រះនាមថា **ភគវា** ដូចក្នុងផ្លូវលោក កាលគួរពោលថា **មេហនស្ស ខស្ស មាលា** ក៏ពោលថា **មេខលា** ជាដើម ។

ម្យ៉ាងទៀត ព្រះសារីបុត្តត្ថេរ កាលនឹងចង្អុលបង្ហាញនូវបរិយាយដទៃទៀត ទើបពោលថា **អបិច ភគ្គរាគោតិ ភគវា** ជាដើម ។ បណ្តាបទទាំងនោះ បទថា **ភគ្គរាគោ** ព្រោះទ្រង់ទម្លាយរាគៈបានហើយ ។ បទថា **ភគ្គទោសោ** ជាដើម ក៏ន័យនេះឯង ។

បទថា **កណ្ឌកោ** បានដល់ កិលេសនោះឯង ដោយអត្ថថា ចាក់ដោត ។ បទថា **ភជិ** សេចក្តីថា ទ្រង់ចែកចំណែកដោយអំណាចនៃឧទ្ទេស ។ បទថា **វិភជិ** សេចក្តីថា ទ្រង់ចែកជាចំណែកៗដោយអំណាចនៃនិទ្ទេស ។ បទថា **បដិភជិ** សេចក្តីថា ទ្រង់ចែកដោយវិសេស ដោយអំណាចនៃបដិនិទ្ទេស ទ្រង់ចែកដោយអំណាចនៃបុគ្គលដែលជាឧគ្ឃដិតញ្ញូ ទ្រង់ចែកវិសេសដោយអំណាចនៃបុគ្គលដែលជាវិបចិតញ្ញូ ទ្រង់ចែកវិសេសចំពោះ ដោយអំណាចនៃបុគ្គលដែលជានេយ្យៈ ។

បទថា **ធម្មរតនំ** សេចក្ដីថា ព្រះដ៏មានព្រះភាគទ្រង់ចែកធម្មរតនៈជា ៣ យ៉ាង ដែលលោកសរសើរទុកយ៉ាងនេះថា

គ្រឿងប្រើប្រាស់របស់សត្វដ៏កំពូល ធ្វើទុកស្អាតនិងមានតម្លៃ
ច្រើន មិនមានអ្វីប្រៀប ឃើញបានដោយក្រ ហៅថា រតនៈ
នោះឯង ដូច្នេះ ។

បទថា **ភវានំ អន្តករោ** សេចក្ដីថា ទ្រង់ធ្វើនូវកំណត់ គឺទីបំផុតជុំវិញ ផ្លូវជុំវិញនៃភព ៩ មានកាមភពជាដើម ។ បទថា **ភាវិតត្តយោ** សេចក្ដីថា មានព្រះកាយដែលឲ្យចម្រើនហើយ ក្នុងបទក្រៅអំពីនេះក៏ដូចគ្នា ។ បទថា **ភជិ** បានដល់ ទ្រង់សេពហើយ ។ បទថា **អរញ្ញវនបត្ថានិ** សេចក្ដីថា ផុតសសរខឿននៃស្រុកក្ដី នៃនគរក្ដី ចេញទៅ ឈ្មោះថា **អរញ្ញ** ដងព្រៃដែលហួសបរិវេណជុំវិញទីកដីមនុស្ស ឈ្មោះថា **វន** ។

បទថា **បន្តានិ** សេចក្ដីថា សេនាសនៈឆ្ងាយ មិនជាទីសាបព្រោះរបស់ពួកមនុស្ស តែអាចារ្យពួកខ្លះពោលថា បទថា **វនបត្ថានិ** សេចក្ដីថា ព្រោះខ្លាធំជាដើមមានក្នុងព្រៃណា ខ្លាធំជាដើមនោះ រមែងគ្រប់គ្រងរក្សាព្រៃនោះ ព្រោះហេតុនោះ សេនាសនៈទាំងនោះ ឈ្មោះថា **វនបត្ថ** ព្រោះមានខ្លាធំជាដើមនោះរក្សា ។ បទថា **សេនាសនានិ** សេចក្ដីថា ឈ្មោះថា **សេនាសនានិ** ព្រោះអត្ថថា ជាទីដេកនិងជាទីអង្គុយ ។

បទថា **អប្បសទ្ទានិ** សេចក្ដីថា មានសំឡេងតិច ដោយសំឡេងនិយាយ ។ បទថា **អប្បនិគ្ឃោសានិ** សេចក្ដីថា ប្រាសចាកសំឡេងខ្លាំង ដោយសំឡេង

កងរំពងក្នុងស្រុក ឬក្នុងនគរជាដើម ។ បទថា **វិជនវាតានិ** សេចក្ដីថា វៀរចាកខ្យល់សរីរៈរបស់ជនអ្នកធ្វើដំណើរខាងក្នុង ។ បាឋៈថា **វិជនវាទានិ** ក៏មាន សេចក្ដីថា វៀរចាកវាទៈរបស់ជនខាងក្នុង បាឋៈថា **វិជនចាតានិ** ក៏មាន សេចក្ដីថា ប្រាសចាកមនុស្សធ្វើដំណើរទៅមក ។ បទថា **មនុស្សរាហាស្សេយ្យកានិ** សេចក្ដីថា ជាទីធ្វើកម្មកំបាំងរបស់ពួកមនុស្ស ។ បទថា **បដិសល្លានសារុប្បានិ** សេចក្ដីថា សមគួរដល់វិវេក ។ បទថា **ភាគី វា** សេចក្ដីថា ឈ្មោះថា ភាគី ព្រោះអត្ថថា ទ្រង់មានចំណែក គឺចំណែកមានចីវរជាដើម ។ ឈ្មោះថា ភាគី ព្រោះអត្ថថា ទ្រង់មានចំណែកនៃអត្ថរសជាដើម ដោយអំណាចនៃការបានចំពោះ ។ បទថា **អត្ថរសស្ស** បានដល់ អត្ថរស ពោលគឺការដល់ព្រមនៃផលរបស់ហេតុ ។ បទថា **ធម្មរសស្ស** បានដល់ ធម្មរស ពោលគឺការដល់ព្រមនៃហេតុ សមដូចព្រះតម្រាស់ ( ក្នុងវិភង្គ ) ថា សេចក្ដីដឹងហេតុ ឈ្មោះថា ធម្មប្បដិសម្ភិទា សេចក្ដីដឹងផលនៃហេតុ ឈ្មោះថា អត្ថប្បដិសម្ភិទា ។ បទថា **វិមុត្តិរសស្ស** បានដល់ វិមុត្តិរស ពោលគឺការ ដល់ព្រមនៃផល សមដូចលោកពោលទុកថា ហៅថា រស ដោយអត្ថថា ការដល់ព្រមនៃកិច្ច ។ បទថា **ចតុន្នំ ឈានានំ** បានដល់ ឈាន ៤ មានបឋមជ្ឈានជាដើម ។ បទថា **ចតុន្នំ អប្បមញ្ញានំ** បានដល់ ព្រហ្មវិហារ ៤ មានមេត្តាជាដើម ដែលវៀរចាកប្រមាណក្នុងការផ្សាយ គឺផ្សាយទៅដោយមិនមានប្រមាណ ។ បទថា **ចតុន្នំ អរូបសមាបត្តីនំ** បានដល់ អរូបជ្ឈាន ៤ មានអាកាសានញ្ចាយតនឈានជាដើម ។ បទថា **អដ្ឋន្នំ វិមោក្ខានំ** បានដល់

វិមោក្ខ ៨ ដែលផុតចាកអារម្មណ៍ ដែលលោកពោលទុកដោយន័យ ( ក្នុងធម្មសង្គណិ ) ជាដើមថា បាននូវរូបជ្ឈានឃើញនូវពួករូប ដូច្នេះ ។

ក្នុងបទថា **អភិភាយតនានំ** នេះ ឈានទាំងឡាយឈ្មោះថា **អភិភាយតន** ព្រោះអត្ថថា ឈានទាំងនោះមានអាយតនៈយ៉ាងក្រៃលែង ។ បទថា **អាយតនានិ** បានដល់ ឈានមានកសិណជាអារម្មណ៍ ពោលគឺអាយតនៈ ព្រោះអត្ថថា ជាទីតាំងនៃអារម្មណ៍យ៉ាងមាំទាំ ។ មែនពិត បុគ្គលដែលក្រៃលែងដោយញាណ មានញាណបរិសុទ្ធ រមែងចូលសមាបត្តិ គ្របសង្កត់អារម្មណ៍ទាំងនោះថា អញគប្បីចូលសមាបត្តិក្នុងអារម្មណ៍នេះធ្វើអ្វី ភារៈក្នុងការធ្វើឯកគ្គតាចិត្ត មិនមានក្នុងអញ អធិប្បាយថា ធ្វើនូវអប្បនាឲ្យកើតក្នុងអារម្មណ៍នេះ មួយអន្ទើដោយការកើតឡើងនៃនិមិត្តនោះឯង ឈានដែលឲ្យកើតឡើងយ៉ាងនេះ ហៅថា **អភិភាយតន** នៃអភិភាយតនៈ ៨ នោះ ។ បទថា **នវន្នំ អនុបុព្វវិហារសមាបត្តីនំ** សេចក្តីថា ឈ្មោះថា អនុបុព្វវិហារសមាបត្តិ ព្រោះគប្បីនៅ គឺគប្បីចូលដល់មុន គឺតាមលំដាប់ អធិប្បាយថា គប្បីចូលដល់លំដាប់នៃអនុបុព្វវិហារសមាបត្តិ ៩ នោះ ។ បទថា **ទសន្នំ សញ្ញាភាវនានំ** បានដល់ សញ្ញាភាវនា ១០ មានអនិច្ចសញ្ញាជាដើម ដែលមកក្នុងគិរិមានន្ទសូត្រ[១] ។ បទថា **ទសន្នំ កសិណសមាបត្តីនំ** បានដល់ ឈាន ១០ មានបឋវីកសិណឈានជាដើម ពោលគឺកសិណ ដោយអត្ថថា ទាំងអស់ ។ បទថា **អានាបានស្សតិសមាធិស្ស** បានដល់ សមាធិដែលសម្បយុត្តដោយ

---

១-ទី១ះហៅថា អាពាធសូត្រ ។

អានាបានស្សតិ ។ បទថា **អសុភសមាបត្តិយា** បានដល់ ការចូលឈាន មានអសុភជាអារម្មណ៍ ។ បទថា **ទសន្នំ តថាគតពលានំ** បានដល់ ញាណ ដែលជាកម្លាំងរបស់ព្រះតថាគត ១០ ប្រការ ។ បទថា **ចតុន្នំ វេសារជ្ជានំ** បានដល់ វេសារជ្ជញ្ញាណ ៤ ដែលជាការចាស់ក្លា ។ បទថា **ចតុន្នំ បដិ-សម្ភិទានំ** បានដល់ បដិសម្ភិទាញាណ ៤ ។ បទថា **ឆន្នំ អភិញ្ញានំ** បានដល់ អភិញ្ញា ៦ មានឥទ្ធិវិធៈជាដើម ។ បទថា **ឆន្នំ ពុទ្ធធម្មានំ** បានដល់ ពុទ្ធធម៌ ៦ ដែលមកខាងមុខដោយន័យ ( ក្នុងចូឡនិទ្ទេស ) ជាដើមថា កាយកម្មទាំងអស់ រមែងប្រព្រឹត្តទៅតាមព្រះញាណរបស់ព្រះពុទ្ធមានព្រះភាគ ។ បណ្តាបទទាំងនេះ គប្បីជ្រាបថា ចីវរៈជាដើម លោកពោលដោយអំណាច នៃភាគ្យសម្បត្តិ ។ ពួក ៣ មានអត្តរសជាដើម លោកពោលដោយអំណាចនៃ ការបដិសេធ ពួក ៣ មានអធិសីលជាដើម លោកពោលដោយអំណាចនៃ ការបដិបត្តិ ពួក ៣ មានឈានជាដើម លោកពោលដោយអំណាចនៃរូបឈាន និងអរូបឈាន ។ ពួក ៣ មានវិមោក្ខជាដើម លោកពោលដោយអំណាច នៃសមាបត្តិ ។ ពួក ៤ មានសញ្ញាភាវនាជាដើម លោកពោលដោយអំណាច នៃឧបចារៈនិងអប្បនា ។ សតិប្បដ្ឋានជាដើម លោកពោលដោយអំណាច នៃពោធិបក្ខិយធម៌ ៣៧ ប្រការ ។ បទថា **តថាគតពលានំ** ជាដើម លោក ពោលដោយអំណាចនៃធម្មវិសេស ។

បន្ទាប់អំពីនេះ បទថា **ភគវាតិ នេតំ នាមំ** ជាដើម លោកពោលដើម្បី ឲ្យជ្រាបថា បញ្ញត្តិនេះប្រព្រឹត្តទៅតាមអត្ថ ។

បណ្ដាបទទាំងនោះ បទថា **សមណា** បានដល់ ពួកជនដែលបួស ។ បទថា **ព្រាហ្មណា** បានដល់ បុគ្គលដែលមានវាទៈថាចម្រើន គឺពួកជនដែលមានបាបស្ងប់ហើយ ឬមានបាបបន្សាត់ហើយ ។ បទថា **ទេវតា** បានដល់ សក្កៈទេវរាជជាដើមនិងព្រហ្មទាំងឡាយ ។ បទថា **វិមោក្ខន្តិកំ** បានដល់ វិមោក្ខ គឺអរហត្តមគ្គ ។ ទីបំផុតនៃវិមោក្ខ គឺអរហត្តផល ។ មានក្នុងទីបំផុតនៃវិមោក្ខនោះ ឈ្មោះថា វិមោក្ខន្តិកៈ ។ ដ្បិតថា ភាពជាសព្វញ្ញូ រមែងសម្រេចដោយអរហត្តមគ្គ គឺជាការសម្រេចហើយ ដោយការសម្រេចអរហត្តផល ព្រោះហេតុនោះ ទើបភាពជាសព្វញ្ញូមានក្នុងទីបំផុតនៃវិមោក្ខ ។ សូម្បីនេមិត្តកនាមនោះ ក៏ជានាមដែលមានក្នុងទីបំផុតនៃវិមោក្ខ ហេតុនោះ ទើបពោលថា **វិមោក្ខន្តិកមេតំ ពុទ្ធានំ ភគវន្តានំ** ដូច្នេះ ។ បទថា **ពោធិយា មូលេ សហ សព្វញ្ញុតញ្ញាណស្ស បដិលាភា** សេចក្ដីថា ជាមួយនឹងការបានចំពោះនូវសព្វញ្ញុតញ្ញាណ ក្នុងខណៈតាមដែលពោលហើយ ត្រង់មណ្ឌលមហាពោធិព្រឹក្ស ។ បទថា **សច្ឆិកា បញ្ញត្តិ** សេចក្ដីថា ជាបញ្ញត្តិដែលកើតដោយការធ្វើឲ្យជាក់ច្បាស់នូវអរហត្តផល ឬដោយការធ្វើឲ្យជាក់ច្បាស់នូវធម៌ទាំងពួង ។ បទថា **យទិទំ ភគវា** សេចក្ដីថា បញ្ញត្តិថា **ភគវា** នេះ ។

[ ២៣២ ] បទថា **ទ្វីហិ ការណេហិ** បានដល់ ដោយចំណែកពីរ ។ បទថា **បរិយត្តិសាសនំ** បានដល់ ពុទ្ធវចនៈ គឺព្រះត្រៃបិដក ។ បទថា **បដិបត្តិ** សេចក្ដីថា ឈ្មោះថា បដិបត្តិ ព្រោះអត្ថថា ជាគ្រឿងដល់ចំពោះ ។ បទថា **យំ តស្ស បរិយាបុដំ** សេចក្ដីថា ពាក្យប្រៀនប្រដៅណា ដែលបុគ្គលនោះ

សិក្សាហើយ គឺស្វាធ្យាយហើយ ។ បទថា **តស្ស** នោះ ជាឆដ្ឋីវិភត្តិ ចុះក្នុងនៃតតិយាវិភត្តិ បាឋៈថា **បរិយាបុដំ** ក៏មាន ។ បទថា **សុត្តំ** សេចក្តីថា គម្ពីរឧភតោវិភង្គ និទ្ទេស ខន្ធកៈ បរិវារ មង្គលសូត្រ រតនសូត្រ តុវដកសូត្រ ក្នុងសុត្តនិបាតនិងព្រះតម្រាស់របស់ព្រះតថាគត ដែលបានទាមថា សូត្រដទៃ គប្បីជ្រាបថា **សុត្ត** ។ បទថា **គេយ្យំ** បានដល់ ព្រះសូត្រដែលមានគាថាទាំងអស់ គប្បីជ្រាបថា ជាគេយ្យៈ ។ ដោយចំពោះសគាថវគ្គទាំងអស់ក្នុងសំយុត្តនិកាយ ។ បទថា **វេយ្យាករណំ** សេចក្តីថា ព្រះអភិធម្មបិដកទាំងអស់ ព្រះសូត្រដែលមិនមានគាថានិងព្រះពុទ្ធវចនៈ ដែលមិនបានសង្គ្រោះដោយអង្គ ៨ នោះគប្បីជ្រាបថា ជាវេយ្យាករណៈ ។ បទថា **គាថា** សេចក្តីថា គាថាធម្មបទ ថេរគាថា ថេរីគាថានិងគាថាសុទ្ធៗ ដែលមិនបានឈ្មោះថាសូត្រ ក្នុងសុត្តនិបាត គប្បីជ្រាបថា ជាគាថា ។ បទថា **ឧទានំ** បានដល់ ព្រះសូត្រ ៨២ ដែលបដិសំយុត្តដោយគាថា លាយឡំដោយសោមនស្សញ្ញាណ គប្បីជ្រាបថា ជាឧទាន ។ បទថា **ឥតិវុត្តកំ** បានដល់ ព្រះសូត្រ ១១០ ដែលប្រព្រឹត្តទៅដោយន័យជាដើមថា **វុត្តំ ហេតំ ភគវតា** ដូច្នេះ គប្បីជ្រាបថា ជាឥតិវុត្តកៈ ។ បទថា **ជាតកំ** បានដល់ ជាតក ៥៥០ រឿង មានអបណ្ណកជាតកជាដើម គប្បីជ្រាបថា ជាតក ។ បទថា **អព្ភូតធម្មំ** បានដល់ព្រះសូត្រដែលបដិសំយុត្តដោយអព្ភូតធម៌ គឺធម៌ដែលគួរអស្ចារ្យទាំងពួង ដែលប្រព្រឹត្តទៅដោយន័យជាដើមថា **ចត្តារោ មេ ភិក្ខវេ អច្ឆរិយា អព្ភូតធម្មា អានន្ទេ** ដូច្នេះ គប្បីជ្រាបថា ជាអព្ភូតធម៌ ។ បទថា **វេទល្លំ** បានដល់ ព្រះ

សូត្របែបសួរឆ្លើយ ដែលបុគ្គលសួរហើយសួរទៀត បានទាំងការដឹងនិងការពេញចិត្តទាំងអស់ មានចូឡវេទល្លសូត្រ មហាវេទល្លសូត្រ សម្មាទិដ្ឋិសូត្រ សក្កបញ្ហសូត្រ សង្ខារភាជនីយសូត្រនិងមហាបុណ្ណមសូត្រជាដើម គប្បីជ្រាបថាជាវេទល្លៈ ។ បទថា **ឥទំ បរិយត្តិសាសនំ** សេចក្ដីថា ព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដកដែលមានប្រការដូចពោលហើយនេះ ឈ្មោះថា ជាពាក្យប្រៀនប្រដៅតាមផ្លូវបរិយត្តិ ព្រោះធ្វើវិគ្គហៈថា ឈ្មោះថា **បរិយត្តិ** ព្រោះអត្ថថា គប្បីរៀន ឈ្មោះថា **សាសនំ** ព្រោះអត្ថថា ប្រៀនប្រដៅ ។ បទថា **តម្បិ មុស្សតិ** សេចក្ដីថា ពាក្យប្រៀនប្រដៅតាមបរិយត្តិនោះ រមែងសាបសូន្យ ។ បទថា **បរិមុស្សតិ** សេចក្ដីថា រមែងសាបសូន្យអំពីខាងដើម ។ បទថា **បរិពាហិរោ ហោតិ** បានដល់ បែរខ្នងឲ្យ ។

បទថា **គតមំ បដិបត្តិសាសនំ** សេចក្ដីថា ចំណែកខាងដើមអំពីលោកុត្តរធម៌ ឈ្មោះថា បដិបត្តិ ព្រោះអត្ថថា ដែលបុគ្គលបដិបត្តិដើម្បីលោកុត្តរធម៌នោះ ឈ្មោះថា **សាសនំ** ព្រោះអត្ថថា ជាធម៌ដែលសាស្ដាទ្រង់ប្រៀនប្រដៅវេនេយ្យសត្វទាំងឡាយ ។ បទថា **សម្មាបដិបទា** ជាដើម មានន័យដូចពោលហើយនោះឯង ។

បទថា **បាណម្បិ ហនតិ** សេចក្ដីថា សម្លាប់នូវឥន្ទ្រិយ គឺជីវិតខ្លះ ។ បទថា **អទិន្នម្បិ អាទិយតិ** សេចក្ដីថា កាន់យករបស់ដែលម្ចាស់គេហួងហែងខ្លះ ។ បទថា **សន្ធិម្បិ ឆិន្ទតិ** សេចក្ដីថា កាត់នូវទីតរបស់ផ្ទះខ្លះ ។ បទថា **និល្លោបម្បិ ហរតិ** សេចក្ដីថា ប្រហារអ្នកស្រុកទាំងឡាយ ធ្វើនូវការប្លន់ជំខ្លះ ។

បទថា **ឯកាគារិកម្បិ ករោតិ** សេចក្តីថា ព័ទ្ធចាប់ ឲ្យលោះដោយទ្រព្យក្នុងមនុស្សប្រមាណ ៥០ នាក់ខ្លះ ៦០ នាក់ខ្លះ ។ បទថា **បរិបន្ថេបិ តិដ្ឋតិ** សេចក្តីថា ធ្វើនូវការជិះតយកប្រាក់ត្រង់ផ្លូវដើរ ។ បទថា **បរទារម្បិ គច្ឆតិ** សេចក្តីថា ដល់នូវការប្រព្រឹត្តក្នុងភរិយារបស់អ្នកដទៃ ។ បទថា **មុសាបិ ភណតិ** សេចក្តីថា ពោលកុហក កាច់បំបាក់នូវប្រយោជន៍ ។

[ ២៣៤-២៣៥ ] បទថា **អនរិយធម្មោ** សេចក្តីថា មិនមែនសភាវៈដែលប្រសើរ ។

បទថា **ឯកោ បុព្វេ ចរិត្វាន** សេចក្តីថា ត្រាច់ទៅខាងដើម គឺក្នុងលោកដោយចំណែកបព្វជ្ជាក្តី ដោយការលះនូវការប្រឡូកប្រឡំដោយពួកគណៈក្តី ។ បទថា **យានំ ភន្តំវ តំ លោកេ ហីនមាហុ បុថុជ្ជនំ** សេចក្តីថា បណ្ឌិតទាំងឡាយ ពោលបុគ្គលនោះ គឺបុគ្គលដែលវិលទៅខុស ថាជាបុថុជ្ជនលាមក ដូចយានដែលក្អកដូច្នោះ ដោយការឡើងកាន់ផ្លូវដែលមិនរាបស្មើ មានកាយទុច្ចរិតជាដើម និងដោយការបំផ្លាញខ្លួនក្នុងនរកជាដើម និងដោយការធ្លាក់ក្នុងជ្រោះគឺជាតិជាដើម ដូចយានមានយានជំរំជាដើម ដែលមិនបានទូន្មាន រមែងឡើងកាន់ផ្លូវដែលមិនរាបស្មើ បំផ្លាញនូវអ្នកជិះខ្លះ ធ្លាក់ក្នុងជ្រោះខ្លះដូច្នោះ ។

[ ២៣៦ ] បទថា **បព្វជ្ជាសង្ខាតេន វា** សេចក្តីថា ដោយចំណែកបព្វជ្ជាក្តី ឬដោយការឡើងកាន់នូវការរាប់ថា ជាបព្វជិតក្តី ថាជាសមណៈក្តី ។ បទថា **គណាវវស្សគ្គដ្ឋេន វា** សេចក្តីថា ដោយការលះនូវការត្រេកអរក្នុងការប្រឡូកប្រឡំដោយពួកដែលត្រាច់ទៅក្តី ។ បទថា **ឯកោ បដិក្កមតិ** សេចក្តី

ថា ម្នាក់ឯងប៉ុណ្ណោះ ត្រឡប់អំពីស្រុក ។

[ ២៣៧ ] បទថា **យោ និសេវតិ** ជាពាក្យឧទ្ទេសនៃបទដែលនឹងត្រូវចង្អុលបង្ហាញ ។ បទថា **អបរេន សមយេន** សេចក្តីថា ក្នុងកាលដទៃ គឺក្នុងកាលដែលជាចំណែកដទៃទៀត ។ បទថា **ពុទ្ធំ** បានដល់ ព្រះពុទ្ធជាសព្វញ្ញូ ។ បទថា **ធម្មំ** បានដល់ ធម៌ដែលប្រកបដោយគុណ មានភាពជាធម៌ដែលព្រះដ៏មានព្រះភាគត្រាស់ល្អហើយជាដើម ។ បទថា **សង្ឃំ** បានដល់ ព្រះសង្ឃដែលប្រកបដោយគុណ មានភាពជាអ្នកបដិបត្តិល្អជាដើម ។ បទថា **សិក្ខំ** បានដល់ សិក្ខាដែលត្រូវសិក្សា មានអធិសីលសិក្ខាជាដើម ។ បទថា **បច្ចក្ខាយ** សេចក្តីថា បដិសេធព្រះពុទ្ធជាដើម ។ បទថា **ហីនាយ** សេចក្តីថា ដើម្បីភាពជាបុគ្គលថោកទាប គឺដើម្បីភាពជាគ្រហស្ថ ។ បទថា **អាវត្តិត្វា** បានដល់ ត្រឡប់ ។ បទថា **សេវតិ** សេចក្តីថា សេពម្តង ។ បទថា **និសេវតិ** សេចក្តីថា សេពច្រើនយ៉ាង ។ បទថា **សំសេវតិ** សេចក្តីថា សេពជោកជាំ ។ បទថា **បដិសេវតិ** សេចក្តីថា សេពរឿយៗ ។

[ ២៣៨ ] បទថា **ភន្តំ** សេចក្តីថា វិលទៅខុសផ្លូវ ( ភូក ) ។ បទថា **អទន្តំ** សេចក្តីថា មិនបាននាំចូលទៅកាន់ភាពជាសត្វដែលគេទូន្មានហើយ ។ បទថា **អការិតំ** សេចក្តីថា មិនបានទទួលការសិក្សា កិរិយាដែលសិក្សាល្អហើយ ។ បទថា **អវិនីតំ** សេចក្តីថា មិនបានសិក្សាដោយអាចារសម្បត្តិ ។ បទថា **ឧប្បថំ គណ្ហាតិ** សេចក្តីថា យានមានប្រការដូចពោលហើយ ប្រកបដោយភាពជាសត្វដែលគេមិនបានទូន្មានជាដើមវិលទៅ រមែងដល់ផ្លូវដែលមិន

រាបស្មើ ។ បទថា **វិសមំ ខាណុម្ហិ ចាសាណម្ហិ អភិរូហតិ** សេចក្តីថា រមែងឡើងលើដង្គត់គគីរជាដើមដែលតាំងនៅមិនរាបស្មើខ្លះ ដុំថ្មលើភ្នំដែលតាំងនៅមិនរាបស្មើយ៉ាងនោះខ្លះ ។ បទថា **យានម្ហិ អារោហកម្ហិ ភញ្ជតិ** សេចក្តីថា រមែងទម្លាយនូវយាន មានរថជាដើមខ្លះ ទម្លាយនូវជើងជាដើមរបស់អ្នកជិះ ឬអ្នកបរទៅខ្លះ ។ បទថា **បចាតេបិ បបតតិ** សេចក្តីថា រមែងធ្លាក់ទៅក្នុងជ្រោះ ឬញកភ្នំដែលដាច់មួយចំហៀងខ្លះ ។ បទថា **សោ វិភ្ភន្តកោ** សេចក្តីថា បុគ្គលនោះ ជាអ្នកថយក្រោយ ។ បទថា **ភន្តយានប្បដិភាគោ** សេចក្តីថា ដូចគ្នានឹងយានដែលមិនតាំងមាំ ។ បទថា **ឧប្បថំ គណ្ហាតិ** សេចក្តីថា ថយត្រឡប់ចាកកុសលកម្មបថ ចូលទៅក្រៅផ្លូវ គឺផ្លូវខុសដែលជាផ្លូវនៃអបាយ ។ បទថា **វិសមំ កាយកម្មំ អភិរូហតិ** សេចក្តីថា រមែងឡើងកាន់កាយកម្មដែលមិនស្មើ ពោលគឺកាយទុច្ចរិត ដែលជាបដិបក្ខចំពោះការស្មើ ។ ក្នុងបទដ៏សេសទាំងឡាយ ក៏ន័យនេះឯង ។ បទថា **និរយេ អត្តានំ ភញ្ជតិ** សេចក្តីថា ធ្វើនូវអត្តភាពឲ្យបែកខ្ទេចខ្ទីក្នុងនរក ពោលគឺមិនមានសេចក្តីត្រេកអរ ។ បទថា **មនុស្សលោកេ អត្តានំ ភញ្ជតិ** សេចក្តីថា រមែងទម្លាយ ដោយអំណាចកម្មករណៈមានបែបផ្សេងៗ ។ បទថា **ទេវលោកេ អត្តានំ ភញ្ជតិ** សេចក្តីថា ដោយអំណាចនៃទុក្ខ មានទុក្ខដែលកើតអំពីការព្រាត់ប្រាសចាករបស់ជាទីស្រឡាញ់ជាដើម ។ បទថា **ជាតិបចាតម្ហិ បបតតិ** សេចក្តីថា ធ្លាក់ទៅក្នុងជ្រោះ គឺជាតិខ្លះ ។ ក្នុងបទថា **ជរាបចាត** ជាដើម ក៏ន័យនេះឯង ។ ព្រះសារីបុត្តត្រាស់សម្តែងលោក ដែលបំណងក្នុងទីនោះឯង ដោយបទថា

មនុស្សលោកេ ។

[ ២៣៩ ] បទថា **បុថុជ្ជនា** ជាមាតិកានៃឧទ្ទេស ។ បណ្ដាបទទាំងនោះ បទថា **បុថុជ្ជនា** មានសេចក្ដីថា

ឈ្មោះថា បុថុជ្ជន ដោយហេតុទាំងឡាយ មានការញុំាងកិលេសក្រាស់ឲ្យកើតជាដើម ម្យ៉ាងទៀត ជននេះឈ្មោះថា មានកិលេសក្រាស់ ព្រោះឈមចុះខាងក្នុងជនដែលមានកិលេសក្រាស់ ដូច្នេះឯង ។

ជននោះឈ្មោះថាបុថុជ្ជន ដោយហេតុទាំងឡាយ មានការញុំាងកិលេសជាដើមដែលក្រាស់ គឺមានប្រការផ្សេងៗឲ្យកើតជាដើម ដើម្បីសម្ដែងបុថុជ្ជននោះដោយការចែក ទើបព្រះសារីបុត្តត្ថេរពោលពាក្យជាដើមថា **បុថុ កិលេសេ ជនេន្តិ** ដូច្នេះ ។ ក្នុងនិទ្ទេសនោះ ឈ្មោះថា បុថុជ្ជន ព្រោះអត្ថថា ញុំាងសក្កាយទិដ្ឋិទាំងនោះឲ្យកើត ឬដែលសក្កាយទិដ្ឋិទាំងនោះឲ្យកើត ព្រោះកម្ចាត់សក្កាយទិដ្ឋិមានប្រការផ្សេងៗ ជាច្រើនមិនទាន់បាន ម្យ៉ាងទៀត **ជន** សព្ទរមែងពោលដល់កិលេសដែលកម្ចាត់មិនទាន់បាននោះឯង ។

ក្នុងបទថា **បុថុ សត្ថារានំ មុខុល្លោកិកា** នេះ មានអត្ថនៃពាក្យថា ឈ្មោះថា បុថុជ្ជន ព្រោះអត្ថថា មានបញ្ញាចំពោះសាស្ដាទាំងឡាយ ដែលកម្ចាត់មិនទាន់បានច្រើន គឺផ្សេងៗ ។ ក្នុងបទថា **បុថុ សព្វគតីហិ អវុដ្ឋិតា** នេះ ឈ្មោះថា ជន ព្រោះអត្ថថា គប្បីឲ្យកើត ឬជាទីកើត បានដល់ គតិ ។ ឈ្មោះថា បុថុជ្ជន ព្រោះអត្ថថា មានជនគឺគតិច្រើន ។ ដទៃអំពីនេះឈ្មោះថា ជន

ព្រោះអត្ថថា ជាហេតុកើត បានដល់ អភិសង្ខារជាដើម ។ ឈ្មោះថា បុថុជ្ជន ព្រោះអត្ថថា មានអភិសង្ខារទាំងនោះ ។ គប្បីឃើញថា **ជន** សព្វ មានអត្ថ ថា តាក់តែងជាដើមនោះឯង ។ បទថា **នានាសន្តាបេហិ សន្តប្បន្តិ** សេចក្តី ថា ការក្តៅក្រហាយទាំងឡាយ មានភ្លើងគឺរាគៈជាដើម សេចក្តីក្តៅក្រហាយ ទាំងនោះឯង ឬការក្តៅក្រហាយ គឺកិលេសទាំងអស់ ។

បទថា **បុថុ បញ្ចសុ កាមគុណេសុ** នេះ ឈ្មោះថា ជន ព្រោះអត្ថថា កើត ។ ជននោះ មានយ៉ាងនេះថា ការត្រេកត្រអាល សេចក្តីត្រូវការច្រើន ឈ្មោះថា បុថុជ្ជន ព្រោះអត្ថថា មានការកើតតម្រេកច្រើន ។ម្យ៉ាងទៀត គប្បី ឃើញថា **ជន** សព្វ ចុះក្នុងអត្ថថា តម្រេកជាដើមនោះឯង យ៉ាងនេះថា កើត ហើយ ត្រេកត្រអាលហើយច្រើន ។ បទថា **បលិពុទ្ធា** សេចក្តីថា ចងទុក ។ បទថា **អាវុតា** សេចក្តីថា រួបរឹត ។ បទថា **និវុតា** សេចក្តីថា រារាំង ។ បទថា **ឱផុដា** សេចក្តីថា បិទខាងលើ ។ បទថា **បិហិតា** សេចក្តីថា បិទ ខាងក្រោម ។ បទថា **បដិច្ឆន្នា** សេចក្តីថា មិនប្រាកដ ។ បទថា **បដិកុជ្ជិតា** សេចក្តីថា គ្របសង្កត់ ។

ម្យ៉ាងទៀត ឈ្មោះថា បុថុជ្ជន ព្រោះឈមចុះខាងក្នុងនៃកិលេសទាំងឡាយ យ៉ាងក្រាស់ ឬរបស់ពួកជនដែលបែរខ្នងដាក់អរិយធម៌ ប្រព្រឹត្តអើពើតែក្នុង ធម៌ថោកទាបដែលហួសនឹងរាប់បាន ។ ឈ្មោះថា បុថុជ្ជន ព្រោះអត្ថថា បុគ្គល នេះមានកិលេសក្រាស់ខ្លះ ជាជនដល់នូវការរាប់ ចែកជាចំណែកដោយឡែក គឺចែកអំពីអរិយជនដែលប្រកបដោយគុណ មានសីលនិងសុតៈជាដើមខ្លះ ។

បុថុជ្ជនយ៉ាងនេះ បានដល់ បុថុជ្ជនពីរពួក ដែលលោកពោលថា ព្រះពុទ្ធជាផៅពង្សនៃព្រះអាទិត្យ ត្រាស់ថាបុថុជ្ជនមានពីរពួក គឺ អន្ធពាលបុថុជ្ជន ១ កល្យាណបុថុជ្ជន ១ ។ ក្នុងពីរពួកនោះ គប្បីជ្រាបថា អន្ធពាលបុថុជ្ជនជាបុគ្គលដែលលោកពោល ដល់ ដូច្នេះ ។

[ ២៤០ ] បទថា **យសោ កិត្តី ច** បានដល់ លាភសក្ការៈនិងការសរសើរ ។ បទថា **បុព្វេ** បានដល់ ក្នុងកាលជាបព្វជិត ។ បទថា **ហាយតេ វាបិ តស្ស សោ** សេចក្តីថា យសនោះផង កិត្តិនោះផង របស់ភិក្ខុនោះ គឺ របស់បុគ្គលដែលវិលទៅខុស រមែងវិនាសទៅ ។ បទថា **ឯតម្បិ ទិស្វា** សេចក្តីថា ឃើញនូវការបានយស និងកិត្តិក្នុងកាលមុន និងក្នុងការវិនាសក្នុងកាលក្រោយនោះ ។ បទថា **សិក្ខេថ មេថុនំ វិប្បហាតវេ** សេចក្តីថា គប្បីសិក្សាសិក្ខា ៣ ដើម្បីហេតុអ្វី ដើម្បីលះមេថុនធម្ម អធិប្បាយថា ដើម្បីលះមេថុនធម្ម ។

[ ២៤១ ] បទថា **កិត្តិវណ្ណភតោ** សេចក្តីថា ភិក្ខុអ្នកបានទទួលនូវការសរសើរនូវកិត្តិគុណ រមែងជាអ្នកលើកសំឡេងសរសើរនិងគុណដែលពណ៌នាឡើងពោល ។ ឈ្មោះថា **ចិត្តកថី** ព្រោះអត្ថថា មានការពោលដោយន័យផ្សេងៗពីរោះ ។ បទថា **កល្យាណប្បដិភាណោ** សេចក្តីថា មានបញ្ញាល្អ ។

បទថា **ហាយតិ** ជាមាតិកានៃឧទ្ទេស ។ បទថា **បរិហាយតិ** សេចក្តីថា រមែងវិនាសទៅដោយជុំវិញ ។ បទថា **បរិធំសតិ** សេចក្តីថារមែងធ្លាក់ទៅ

ខាងក្រោម ។ បទថា **បរិបតតិ** សេចក្តីថា រមែងទៅប្រាសដោយជុំវិញ ។ បទថា **អន្តរធាយតិ** សេចក្តីថា រមែងដល់នូវការឃើញមិនបាន ។ បទថា **វិប្បលុជ្ជតិ** សេចក្តីថា រមែងដាច់សូន្យ ។

[ ២៤២ ] បទថា **ខុទ្ទកោ សីលក្ខន្ធោ** បានដល់ អាបត្តិចុល្លច្ច័យជាដើម ។ បទថា **មហន្តោ សីលក្ខន្ធោ** បានដល់ បារាជិកនិងសង្ឃាទិសេស ។ បទថា **មេថុនធម្មស្ស បហានាយ** សេចក្តីថា ដើម្បីលះដោយតទង្គប្បហានជាដើម ។ បទថា **វូបសមាយ** សេចក្តីថា ដើម្បីចូលទៅស្ងប់នូវមន្ទិលទាំងឡាយ ។ បទថា **បដិនិស្សគ្គាយ** សេចក្តីថា ដើម្បីស្ទុះទៅ លះបង់និងលះផ្តាច់ ។ បទថា **បដិប្បស្សទ្ធិយា** សេចក្តីថា ដើម្បីផល ពោលគឺការស្ងប់រម្ងាប់ ។

[ ២៤៣ ] បព្វជិតណា មិនលះមេថុនធម្ម បព្វជិតនោះ ដែលត្រូវសង្កប្បៈទាំងឡាយគ្របសង្កត់ហើយ រមែងសញ្ជប់សញ្ជឹង ដូចមនុស្សកំព្រា បព្វជិតមានសភាពដូច្នោះ លុះឮពាក្យសំដីរបស់ពួកជនដទៃហើយ រមែងអៀនអន់ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បរេសោ** សេចក្តីថា ប្រកបព្រម ។ បទថា **បរេ សំនិគ្ឃោសំ** បានដល់ ពាក្យតិះដៀលរបស់ឧបជ្ឈាយ៍ជាដើម ។ បទថា **មង្កុ ហោតិ** សេចក្តីថា ជាបុគ្គលទោមនស្ស ។

[ ២៤៤ ] បទថា **កាមសង្កប្បេន** សេចក្តីថា ដែលវិតក្កបដិសំយុត្តដោយកាម ។ ក្នុងបទដែលរៀងគ្នាតមក ក៏មានន័យដូចគ្នា ។ បទថា **ដុដ្ឋោ**

សេចក្តីថា ដែលវិតក្កទាំងឡាយពាល់ត្រូវហើយ ។ បទថា **បរេតោ** សេចក្តីថា មិនវិនាសជុំវិញ ។ បទថា **សមោហិតោ** សេចក្តីថា ឈមចុះ គឺចូលទៅខាងក្នុងដោយប្រពៃ ។ បទថា **កបណោ វិយ** សេចក្តីថា ដូចមនុស្សកំព្រា ។ បទថា **មន្ទោ វិយ** សេចក្តីថា ដូចមនុស្ស មិនមានការចេះដឹង ។ បទថា **មោមូហោ វិយ** សេចក្តីថា ដូចមនុស្សវង្វេង ។ បទថា **ឈាយតិ** សេចក្តីថា រមែងគិត ។ បទថា **បជ្ឈាយតិ** សេចក្តីថា រមែងគិតធ្ងន់ ។ បទថា **និជ្ឈាយតិ** សេចក្តីថា រមែងគិតច្រើនយ៉ាង ។ បទថា **អវជ្ឈាយតិ** សេចក្តីថា រមែងគិតខាងក្រៅអំពីនោះ ។ បទថា **ឧលូកោ** បានដល់ សត្វមៀម ។ បទថា **រុក្ខសាខាយំ** សេចក្តីថា ត្រង់មែកដែលតាំងឡើងលើដើមឈើឬប្រគាប ។ បទថា **មូសិកំ គមយមានោ** សេចក្តីថា ស្វែងរកកណ្តុរ អាចារ្យពួកខ្លះពោលថា **មគ្គយមានោ** ដូច្នេះក៏មាន ។ បទថា **កោត្ថុ** បានដល់ ឆ្កែចចក ។ បទថា **ពិឡារោ** បានដល់ ឆ្មា ។ បទថា **សន្ធិសមលសង្កដីរេ** សេចក្តីថា ក្នុងរវាងផ្ទះពីរខ្នង ត្រង់លូទឹក កក់ ដែលចោលសំរាមនិងដែលជាទីទួល ។ បទថា **វហាច្ឆិន្នោ** សេចក្តីថា មានសាច់ខ្នងនិងកដាច់ទៅ ។ គាថាបន្ទាប់អំពីនេះ មានការទាក់ទងគ្នាជាក់ច្បាស់ហើយនោះឯង ។

[ ២៨៦ ] បទថា **សត្ថានិ** ក្នុងគាថានោះ បានដល់ កាយទុច្ចរិតជាដើម ឯកាយទុច្ចរិតជាដើមនោះ លោកហៅថាសស្ត្រា ព្រោះអត្ថថា កាត់ទាំងខ្លួននិងអ្នកដទៃ ភិក្ខុនេះកាលពោលថា ខ្ញុំសឹកព្រោះហេតុនេះ ឈ្មោះថា រមែងធ្វើសស្ត្រា គឺពោលកុហកអំពីខ្លួនមុនដោយវិសេស ។ ក្នុងបណ្តាទុច្ចរិតទាំងនោះ

ព្រោះហេតុនោះឯង ទើបព្រះដ៏មានព្រះភាគត្រាស់ថា **ឯស ខ្វស្ស មហាគេធោ មោសវជ្ជំ បគាហតិ** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **ឯស ខ្វស្ស** កាត់បទជា **ឯសោ ខោ អស្ស** ។ បទថា **មហាគេធោ** បានដល់ គ្រឿងចងធំ បើមានពាក្យសួរថា សេចក្តីនេះ ដូចម្តេច ឆ្លើយថា បានដល់ ការឈមចុះកាន់មុសាវាទ គឺភិក្ខុនោះរមែងឈមចុះ កាន់នូវភាពជាអ្នកនិយាយកុហក គប្បីជ្រាបថា ជាចំណងធំរបស់ភិក្ខុនោះ ។

[ ២៤៧ ] បទថា **តីណិ សត្ថានិ** បានដល់ គ្រឿងកាត់ ៣ យ៉ាង ។ កាយទុច្ចរិតទាំងឡាយ ឈ្មោះថា សស្ត្រាផ្លូវកាយ សូម្បីសស្ត្រាផ្លូវវាចាជាដើម ក៏ន័យនេះដូចគ្នា ។ដើម្បីនឹងសម្តែងសស្ត្រានោះជាចំណែកៗទើបព្រះសារីបុត្តត្ថេរពោលថា **តិវិធំ កាយទុច្ចរិតំ កាយសត្ថំ** ដូច្នេះ ។ បទថា **សម្បជានមុសា ភាសតិ** សេចក្តីថា ពោលវាចាកុហកទាំងដឹងខ្លួន ។ បទថា **អភិរតោ អហំ ភន្តេ អហោសឹ បព្វជ្ជាយ** សេចក្តីថា ខ្ញុំជាអ្នកមិនបានវៀរចាកនូវការត្រេកអរក្រៃលែងចំពោះបព្វជ្ជាក្នុងសាសនា ។ បទថា **មាតា មេ ចោសេតព្វា** សេចក្តីថា ខ្ញុំគប្បីចិញ្ចឹមមាតា ។ បទថា **តេនម្ហិ វិព្ភន្តោតិ ភណតិ** សេចក្តីថា ភិក្ខុនោះរមែងពោលថា ព្រោះហេតុនោះ ទើបខ្ញុំជាអ្នកឃានត្រឡប់គឺលាសិក្ខា ។ ក្នុងបទថា **បិតា មេ ចោសេតព្វោ** ជាដើម ក៏មានន័យដូចគ្នា ។

[ ២៤៨ ] បទថា **ឯសោ តស្ស មហាគេធោ** សេចក្តីថា ការពោលកុហកទាំងដឹងខ្លួននោះ ជាចំណងធំរបស់បុគ្គលនោះ ។ បទថា **មហាវនំ** បានដល់ព្រៃធំ ។ បទថា **គហនំ** បានដល់ ឈានកន្ទង់បានលំបាក ។ បទថា **កណ្តកោ**

*សេចក្តីថា ដូចគ្នានឹងចោរកន្ទារជាដើម ។ បទថា* **វិសមោ** *សេចក្តីថា មិនស្មើ ព្រោះនាម ។ បទថា* **កុជិលោ** *សេចក្តីថា ដូចគ្នានឹងឈើកោង ។ បទថា* **បង្កោ** *សេចក្តីថា ដូចគ្នានឹងល្បាប់ ។ បទថា* **បលិបោ** *សេចក្តីថា ដូចគ្នានឹងភក់ ។ បទថា* **បលិពោធោ** *សេចក្តីថា ទៅបានដោយលំបាក ។ បទថា* **មហាពន្ធំ** *សេចក្តីថា ចំណងធំដោះបានលំបាក ។ បទថា* **យធិទំ សម្បជានមុសាវាទោ** *សេចក្តីថា ការពោលកុហកទាំងដឹងខ្លួនឯណា ។*

*[ ២៤៩ ] បទថា* **សភគ្គតោ វា** *សេចក្តីថា តាំងនៅក្នុងទីប្រជុំក្តី ។ បទថា* **បរិសគ្គតោ វា** *សេចក្តីថា ក្នុងទីប្រជុំអ្នកស្រុកក្តី ។ បទថា* **ញាតិមជ្ឈគតោ វា** *សេចក្តីថា នៅត្រង់កណ្តាលទាយាទទាំងឡាយក្តី ។ បទថា* **បូគមជ្ឈគតោ វា** *សេចក្តីថា នៅត្រង់កណ្តាលកងទាហានក្តី ។ បទថា* **រាជកុលមជ្ឈគតោ វា** *សេចក្តីថា នៅត្រង់ទីវិនិច្ឆ័យធំកណ្តាល រាជត្រកូលក្តី ។ បទថា* **អភិនីតោ** *សេចក្តីថា ត្រូវនាំទៅដើម្បីត្រូវការសាកសួរ ។ បទថា* **សក្ខិបុដ្ឋោ** *សេចក្តីថា ត្រូវសួរដោយឲ្យធ្វើជាសាក្សី ។ បទថា* **ឯហិ ភោ បុរិស** *នេះ ជាពាក្យហៅ ។ បទថា* **អត្តហេតុ វា បរហេតុ វា** *សេចក្តីថា ព្រោះហេតុនៃអវយវៈ មានដៃនិងជើងជាដើមខ្លះ ព្រោះហេតុនៃទ្រព្យខ្លះ របស់ខ្លួនខ្លះ របស់អ្នកដទៃខ្លះ ។ បទ* **អាមិស** *ក្នុងបទថា* **អាមិសកិញ្ចិក្ខហេតុ វា** *នេះ លោកបំណងយកលាភ ។ បទថា* **កិញ្ចិក្ខំ** *សេចក្តីថា អាមិសណាមួយដែលមានប្រមាណតិច ដោយហោចត្រឹមសត្វទទា ចាប ដុំសប្បិ ដុំនវនីតជាដើម អធិប្បាយថា ព្រោះហេតុនៃលាភណាមួយ ។ បទថា* **សម្បជាន-**

**មុសា ភាសតិ** សេចក្ដីថា កំពុងដឹងនោះឯង ពោលនូវមុសាវាទ ។

ម្យ៉ាងទៀត ព្រះសារីបុត្តត្ថេរ កាលសម្ដែងបរិយាយដទៃទៀត ទើបពោលពាក្យជាដើមថា **តីហាការេហិ មុសាវាទោ ហោតិ បុព្វេវស្ស ហោតិ** ដូច្នេះ ។ បណ្ដាបទទាំងនោះ បទថា **តីហាការេហិ** សេចក្ដីថា ដោយហេតុ ៣ យ៉ាង ដែលជាអង្គរបស់សម្បជានមុសាវាទ ។ បទថា **បុព្វេវស្ស ហោតិ** សេចក្ដីថា ក្នុងកាលដែលជាចំណែកខាងដើមនោះឯង បុគ្គលនោះ មានការដឹងយ៉ាងនេះថា អញនឹងពោលកុហក ។ បទថា **ភណន្តស្ស ហោតិ** សេចក្ដីថា កាលកំពុងនិយាយក៏ដឹង ។ បទថា **ភណិតស្ស ហោតិ** សេចក្ដីថា កាលពោលហើយ បុគ្គលនោះ ក៏ដឹង អធិប្បាយថា កាលពោលពាក្យដែលគប្បីពោលនោះហើយក៏ដឹង ។ ម្យ៉ាងទៀត បទថា **ភណិតស្ស** សេចក្ដីថា កាលពោលទៅហើយ គឺពោលចប់ហើយក៏ដឹងក្នុងសេចក្ដីនេះ លោកសម្ដែងសេចក្ដីនេះដូច្នេះថា បុគ្គលណា ក្នុងកាលដែលជាចំណែកខាងដើមយ៉ាងនេះក៏ដឹង កំពុងពោលក៏ដឹង ក្រោយពោលក៏ដឹងថា អញពោលកុហកហើយ បុគ្គលនោះ កាលពោលយ៉ាងនេះ រមែងដល់នូវកម្មពន្ធ គឺពោលកុហក ។ ក្នុងសេចក្ដីនេះ លោកសម្ដែងសេចក្ដីទុកហើយក៏ពិត តែទោះជាយ៉ាងនោះ ក៏នៅមានអត្ថវិសេសដូចទៅតទៅនេះថា សួរថា កាលជាចំណែកខាងដើមថា អញនឹងពោលកុហកមាន កាលដែលជាចំណែកខាងក្រោយថា អញពោលកុហកហើយមិនមាន ។ ពិតហើយ បុគ្គលណាមួយ ក៏ភ្លេចពាក្យដែលទើបពោលចប់ក៏បាន តើជាមុសា-វាទដល់បុគ្គលនោះដែរឬទេ ពាក្យសួរនោះ លោកវិសជ្ជនាទុកហើយក្នុង

អដ្ឋកថាទាំងឡាយយ៉ាងនេះថា ក្នុងដំបូងកាលបុគ្គលដឹងថា អញនឹងពោល កុហក កាលពោលក៏ដឹងថា អញកំពុងពោលកុហកខាងក្រោយមិនអាចមិនដឹង ថា អញពោលកុហកហើយ ទោះបីមិនដឹង ក៏គង់ជាមុសាវាទនោះឯង ដ្បិតថា អង្គ ២ ដំបូងនោះឯងជាប្រមាណ ។ បុគ្គលណា ខាងដើមមិនតាំងចិត្តថា អញ នឹង ពោលកុហក តែកាលពោល ក៏ដឹងថាអញកំពុងពោលកុហក កាល ពោលហើយ ក៏ដឹងថា អញពោលកុហកហើយ មិនគប្បីកាត់ទោសបុគ្គល នោះ ដោយមុសាវាទ ព្រោះអង្គទី ១ ជាប្រមាណ កាលមិនមានការតាំងចិត្ត ( ពោលកុហក ) រមែងជាការពោលលេង ឬពោលភ្លាត់ទៅប៉ុណ្ណោះ ។

ម្យ៉ាងទៀត ក្នុងសេចក្ដីនេះ គប្បីលះភាវៈគឺញាណក្នុងមុសាវាទនោះ និង **ការប្រជុំនៃញាណ** ។ ពាក្យថា **គប្បីលះភាវៈគឺញាណក្នុងមុសាវាទនោះ** សេចក្ដីថា បុគ្គលរមែងដឹងថា អាត្មាអញនឹងពោលកុហកដោយចិត្តដួងណា មួយ រមែងដឹងថា អញពោលកុហក និងដឹងថា អញពោលកុហកហើយដោយ ចិត្តដួងនោះឯង រមែងដឹងដោយខណៈ ៣ ដោយចិត្តមួយដួងនោះឯង យ៉ាង នេះដោយប្រការដូច្នេះ ព្រោះហេតុនោះ ទើបគួរលះបង់ភាវៈ គឺញាណក្នុង មុសាវាទនោះចេញ ដ្បិតថា បុគ្គលមិនអាចដឹងចិត្តដួងនោះ ដោយចិត្តដួងនោះ ឯងបាន ដូចមិនអាចប្រើដាវកាប់នូវដាវខ្លួនឯងនោះបាន ចិត្តដួងដំបូងជាបច្ច័យ តាមដែលកើតឡើងរបស់ចិត្តដួងក្រោយៗ ហើយរលត់ទៅ ព្រោះហេតុ នោះ ទើបលោកពោលថា

កាលជាចំណែកខាងដើមនោះឯងជាប្រមាណ កាលជាចំណែក

ខាងដើមនោះមាន ពាក្យថា កាលទាំងពីរដែលសល់នឹងមិន
មាននោះរមែងមិនមាន វាចាប្រកបដោយអត្ថ ៣ ដោយប្រការ
ដូច្នេះ ។

ពាក្យថា **គប្បីលះការប្រជុំនៃញាណ** សេចក្ដីថា ចិត្ត ៣ ដួងនេះ មិនគប្បីកាន់យកថា កើតឡើងក្នុងខណៈតែមួយ ព្រោះឈ្មោះថាចិត្តនេះ

កាលចិត្តដួងទីមួយមិនទាន់រលត់ ចិត្តដួងក្រោយរមែងមិនកើត
ឡើង រមែងប្រាកដដូចដួងតែមួយ ព្រោះកើតឡើងជាប់តគ្នា
ដូច្នេះ ។

បន្ទាប់អំពីនេះ មានសេចក្ដីថា បុគ្គលនេះមិនដឹងពោលកុហក ទាំងដឹងដោយន័យជាដើមថា ខ្ញុំដឹង ព្រោះបុគ្គលនោះមានទិដ្ឋិយ៉ាងនេះថា នេះមិនពិត បុគ្គលនោះក៏មានលទ្ធិដូច្នេះប៉ុណ្ណោះ ម្យ៉ាងទៀត បុគ្គលនោះមានទិដ្ឋិនិងការចូលចិត្តយ៉ាងនេះថា នេះមិនពិត បុគ្គលនោះមានសញ្ញាយ៉ាងនេះ ចិត្តរបស់បុគ្គលនោះក៏មានសភាវៈយ៉ាងនេះប៉ុណ្ណោះថា នេះមិនពិត ។ តែកាលណាបុគ្គលនោះបំណងនឹងពោលកុហក កាលនោះ បុគ្គលនោះបិទបាំង គឺបោះបង់បិទនូវទិដ្ឋិនោះឯង១ៈ នូវការអត់ធន់ដោយទិដ្ឋិ១ៈ នូវការចូលចិត្ត ដោយទិដ្ឋិនិងការអត់ធន់១ៈ នូវការសម្គាល់ដោយទិដ្ឋិ ការអត់ធន់និងការចូលចិត្ត១ៈ នូវសេចក្ដីពិតដោយទិដ្ឋិ ការអត់ធន់ ការចូលចិត្តនិងសញ្ញា១ៈ រមែងពោលមិនពិត ព្រោះហេតុនោះ ដើម្បីនឹងសម្ដែងនូវប្រភេទនៃអង្គ ដោយអំណាចនៃទិដ្ឋិជាដើមនោះ ទើបព្រះសារីបុត្តត្ថេរពោលថា **អបិច ចតូហាការេហិ** ជាដើម ។

បទថា **វិធិធាយ ធិដ្ឋី** ក្នុងទីនេះ លោកពោលដោយអំណាចនៃការបិទបាំងនូវធម៌ដែលមានកម្លាំង ។ បទថា **វិធិធាយ ១ដ្ឋី** សេចក្តីថា លោកពោលដោយអំណាចនៃការបិទបាំងធម៌ដែលមានកម្លាំងតិចជាងនោះ ។ តែបទថា **វិធិ–ធាយ សញ្ញំ** នេះ លោកពោលដោយអំណាចនៃការបិទបាំងធម៌ដែលមានកម្លាំងតិចទាំងអស់ក្នុងទីនេះ ។ ការដែលបុគ្គលមិនបិទបាំង សូម្បីត្រឹមតែការសម្គាល់នឹងពោលកុហកទាំងដឹងខ្លួន នោះមិនមែនជាឋានៈដែលមានឡើយ ។

[ ២៥០ ] បទថា **មឡោវ បរិកិស្សតិ** សេចក្តីថា ធ្វើនូវការសម្លាប់សត្វជាដើម សោយនូវទុក្ខដែលមានហេតុកើតអំពីការសម្លាប់សត្វជាដើមនោះ នឹងធ្វើនូវការស្វែងរកនិងការរក្សាភោគសម្បត្តិ រមែងសៅហ្មងដូចបុគ្គលវង្វេង ។

[ ២៥៤ ] បទថា **តមេធំ រាជានោ គហេត្វា វិវិធា កម្មការណា ការេន្តិ** សេចក្តីថា ព្រះរាជាទាំងឡាយ ទ្រង់មិនបានធ្វើឯង ពួករាជបុរសដែលចាត់ចែងការងាររបស់ព្រះរាជា រមែងធ្វើកម្មករណៈមានប្រការផ្សេងៗ ។ បទថា **កសា–ហិបិ តាឡេន្តិ** សេចក្តីថា គំរាមដោយត្មោងខ្វះ ។ បទថា **វេត្តេហិ** បានដល់ដើមផ្តៅ ។ បទថា **អឌ្ឍទណ្ឌកេហិ** បានដល់ ព្រនង់ ឬដំបងដែលកាត់មួយកំណាត់ ៤ ហត្ថពីរកំណាត់ កាន់យកដើម្បីឲ្យសម្រេចការប្រហារ ។ បទថា **ពិលង្គថាលិកំ** បានដល់ កម្មករណៈបែបផ្ទាំងបបរ កាលធ្វើកម្មករណៈនោះ បើកលលាដ៍ក្បាលខាងលើ យកដង្កាបចាប់ដុំដែកដែលក្តៅក្រហម ដាក់ក្នុងក្បាលនោះ ធ្វើខួរឲ្យហៀរចេញ ព្រោះដុំដែកនោះ ។

បទថា **សង្ខមុណ្ឌិកំ** បានដល់ កម្មករណៈធ្វើឲ្យរលីងដូចស័ង្ខ កាលធ្វើ

កម្មករណៈនោះ គេចូតស្បែកកំណត់ខាងលើបបូរមាត់ដល់គុម្ពត្រចៀកសង ខាង វៀលជុំវិញក ហើយប្រមូលសក់ទាំងអស់ចងជាមួយកំណាត់ឈើ ភើចកន្ទ្រាក់ឡើង ស្បែកក្បាលនិងសក់ទាំងឡាយក៏របើកចេញ បន្ទាប់អំពីនោះ យកដុំថ្មគ្រើមខាត់លលាដ៍ក្បាល យកទឹកលាងធ្វើឲ្យមានពណ៌ដូចស័ង្ខ ។

បទថា **រាហុមុខំ** បានដល់ កម្មករណៈបែបមាត់រាហូ កាលធ្វើនូវកម្មករណៈនោះ គេខ្ទាស់មាត់ដោយដែកស្រួច យកភ្លើងដាក់ក្នុងមាត់ ឬយកពន្លាកដាប់តាំងពីគុម្ពត្រចៀកទាំងសងខាងរហូតដល់មាត់ ឈាមហូរពេញមាត់ ។

បទថា **ជោតិមាលិកំ** សេចក្ដីថា យកសំពត់ជ្រលក់ប្រេង រុំព័ទ្ធសរីរៈទាំងមូល ហើយយកភ្លើងដុត ។ បទថា **ហត្ថប្បជ្ជោតិកំ** សេចក្ដីថា យកសំពត់ជ្រលក់ប្រេងរុំដៃទាំងសងខាង ហើយឆួលភ្លើងឲ្យឆេះធ្វើជាប្រទីប ។ បទថា **ឯរកវត្តិកំ** បានដល់ កម្មករណៈប្រព្រឹត្តទៅបែបដេកលើដើមរៃទឹក កាលធ្វើកម្មករណៈនោះ បកស្បែកខ្នងតាំងអំពីកមកពាក់ទុកត្រង់កជើង លំដាប់នោះ យកខ្សែចងហើយអូសទៅ បុគ្គលនោះជាន់ស្បែកខ្នងឯង ក៏ដួលចុះ ។

បទថា **ចិរកវាសិកំ** បានដល់ កម្មករណៈបែបស្លៀកសំពត់ស្បូវក្លាំង កាលធ្វើកម្មករណៈនោះ រាជបុរសបកស្បែកខ្នងយ៉ាងនោះឯង រហូតដល់ត្រឹមចង្កេះ ហើយបកស្បែកតាំងអំពីចង្កេះរហូតដល់កជើង ស្បែកខាងលើដណ្ដប់សរីរៈខាងក្រោម ដូចស្លៀកសំពត់ស្បូវក្លាំង ។ បទថា **ឯណេយ្យកំ** បានដល់ កម្មករណៈដូចសត្វទ្រាយ កាលធ្វើកម្មករណៈនោះ រាជបុរសពាក់កងដែកត្រង់កែងដៃទាំងពីរនិងជង្គង់ទាំងពីរ ហើយដោតដោយដែកស្រួច លើក

ដាក់លើដែកស្រួចទាំង ៤ លំដាប់នោះ មនុស្សទាំងឡាយ ដាក់ភ្លើងជុំវិញខ្លួនបុរសនោះ ។ ក្នុងទីខ្លះលោកប្រាប់ថា ដូចសត្វទ្រាយដែលភ្លើងឆេះជុំវិញ ។ មនុស្សទាំងឡាយដកដែកស្រួចដែលដោតចេញ ដាក់បុរសនោះដោយចុងឆ្អឹង ៤ កំណាត់ប៉ុណ្ណោះ ។ ឈ្មោះថា ហេតុបែបនេះ គឺការដាក់ទោសដល់លំដាប់នេះមិនមាន ។

បទថា **ពឡិសមំសិកំ** សេចក្ដីថា យកសន្ទូចមុខពីរ ថ្ពក់ស្បែក សាច់សរសៃចេញមក ។ បទថា **កហាបណកំ** សេចក្ដីថា យកកាំបិតមុតឆ្កៀលសរីរៈទាំងមូល តាំងអំពីក្បាលជាវង្វង់ៗ ប៉ុនៗកហាបណៈនាំមកបុក ។

បទថា **ខារាបតច្ឆិកំ** សេចក្ដីថា ប្រើអាវុធផ្សេងៗចាក់សរីរៈតាមទីនោះៗ ហើយយកផេះដុសដោយច្រាសដែលធ្វើអំពីផ្ដៅ រហូតដល់ស្បែកសាច់សរសៃជ្រុះចេញអស់សល់តែគ្រោងឆ្អឹងប៉ុណ្ណោះ ។ បទថា **បលិឃបរិវត្តិកំ** សេចក្ដីថា ឲ្យដេកផ្អៀងហើយបោះដែកស្រួចត្រង់រន្ធត្រចៀកភ្ជាប់ទៅនឹងផែនដី បន្ទាប់អំពីនោះ ចាប់ជើងបង្វិលដោយជុំវិញ ។ បទថា **បលាលបីឋកំ** សេចក្ដីថា រាជបុរសដែលជំនាញបកស្បែកចេញ ហើយយកថ្មសំលៀងវាយឆ្អឹងទាំងឡាយចាប់សក់លើកឡើងជាគំនរសាច់តែមួយ បន្ទាប់អំពីនោះ ក៏យកសក់ខ្ចប់បុគ្គលនោះឯងទុក ធ្វើដូចជាតាំងស្លឹកឈើ ។

បទថា **សុនខេហិបិ** សេចក្ដីថា ឲ្យឆ្កែដែលកំពុងឃ្លាន ព្រោះបង្អត់នូវអាហារ ២-៣ ថ្ងៃ ខាំស៊ីមួយរំពេចប៉ុណ្ណោះ ពួកឆ្កែទាំងនោះ ក៏ខាំស៊ីសល់តែរាងឆ្អឹង ។ បទថា **ឯវម្បិ កិស្សតិ** សេចក្ដីថា រមែងដល់នូវការពិឃាដ

ដោយប្រការដូច្នេះ ។ បទថា **បរិកិស្សតិ** សេចក្តីថា រមែងដល់នូវសេចក្តីពិឃាដដោយចំណែកទាំងពួង ។ បទថា **បរិកិលិស្សតិ** សេចក្តីថា រមែងដល់នូវការតក់ស្លុត ។

ព្រះសារីបុត្តត្ថេរ កាលសម្តែងហេតុការណ៍ដទៃទៀត ទើបពោលពាក្យជាដើមថា **អថ វា កាមតណ្ហាយ អភិភូតោ** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កាមតណ្ហាយ** បានដល់ សេចក្តីលោភដែលប្រកបដោយកាមគុណ ៥ ។ បទថា **អភិភូតោ** សេចក្តីថា ញាំញីហើយ ។ បទថា **បរិយាទិន្នចិត្តោ** សេចក្តីថា មានចិត្តត្រូវកាមតណ្ហាទាញទុក ញុំាងអាចារៈដែលជាកុសលឲ្យអស់ទៅ ។ បទថា **ភោគេ បរិយេសន្តោ** សេចក្តីថា កាលស្វែងរកទ្រព្យ ។ បទថា **នាវាយ មហាសមុទ្ទំ បក្ខន្ទតិ** សេចក្តីថា ចូលទៅកាន់សាគរដែលមានអំបិលដោយសំពៅ ពោលគឺទូកធំ ។ បទថា **សីតស្ស បុរក្ខតោ** សេចក្តីថា ជួបនូវរងា ។ បទថា **ឧណ្ហស្ស បុរក្ខតោ** សេចក្តីថា ជួបនូវកម្តៅ ។ បទថា **ឌំស** បានដល់ រុយដែលមានពណ៌លឿងខ្ចី ។ បទថា **មកស** បានដល់ មូសនោះឯង ។ បទថា **រិស្សមានោ** សេចក្តីថា ត្រូវសម្ផស្សនៃរបោមជាដើមបៀតបៀន ។ បទថា **ខុប្បិបាសាយ បីឡិយមានោ** សេចក្តីថា ត្រូវគម្លាននិងសម្រេកគ្របសង្កត់ ។ បទ ២៤ មានបទថា **គុម្ពំ គច្ឆតិ** ជាដើម មានបទថា **មរុកន្តារំ គច្ឆតិ** ជាទីបំផុត លោកពោលទៅតាមឈ្មោះរបស់រដ្ឋ ។ បទថា **មរុកន្តារំ គច្ឆតិ** សេចក្តីថា ធ្វើដំណើរ តាមសមុទ្រខ្សាច់ដោយប្រើផ្កាយជាគ្រឿងសម្គាល់ ។ បទថា **ជណ្ណុបថំ** បានដល់ ផ្លូវដែលត្រូវ

ដើរដោយជង្គង់ទាំងពីរ ។ បទថា **អជបថំ** បានដល់ ផ្លូវដែលត្រូវទៅដោយពពែ ក្នុងផ្លូវដែលត្រូវទៅដោយចៀម ក៏ន័យនេះដូចគ្នា ។

បទថា **សង្កុបថំ** បានដល់ **ផ្លូវដែលត្រូវទៅដោយបង្គោល គឺត្រូវបោះបង្គោលទាំងឡាយ ហើយជាន់លើបង្គោលទាំងនោះ** កាលទៅផ្លូវនោះ ឈរត្រង់ជើងភ្នំ យកខ្សែចងតម្លក់ដែកបោះទៅទាក់ត្រង់ភ្នំហើយ បោះខ្សែឡើងទៅហើយយកដែកពន្លាក ដែលមានចុងរឹងដូចពេជ្រ ចោះភ្នំបោះបង្គោល ឈរលើបង្គោលនោះ ទាញដែកដែលមានងៀង ៣ ត្រឡប់មក ហើយបោះទៅខាងលើទៀត ឈរក្នុងទីនោះ ព្យួរនូវខ្សែស្បែកទុក បោះខ្សែស្បែកនោះ ចុះទៅចងត្រង់បង្គោលខាងក្រោម ដៃឆ្វេងចាប់ខ្សែ ដៃស្តាំចាប់ញញួរ ស្រាយខ្សែដកបង្គោលចេញហើយ ឡើងទៅលើទៀត ។ ដោយឧបាយនេះ បុរសនោះឡើងដល់កំពូលភ្នំខាងលើ ឆ្លងចុះទៅខាងមុខ បោះបង្គោលលើកំពូលភ្នំមុន ដោយន័យមុននោះឯង ចងខ្សែត្រង់ល្អីស្បែករុំបង្គោលទុក ខ្លួនឯងអង្គុយខាងក្នុងល្អី សម្រូតខ្សែចុះ ដូចអាការៈនៃសត្វពីងពាង ព្រោះហេតុនោះ ទើបលោកពោលថា ផ្លូវដែលត្រូវទៅដោយបង្គោល គឺត្រូវបោះបង្គោលទាំងឡាយ ហើយជាន់លើបង្គោលទាំងនោះ ។

បទថា **ឆត្តបថំ** បានដល់ ផ្លូវដែលត្រូវកាន់ឆត្រស្បែកលោតទៅ ដូចបក្សីទាំងឡាយ ។ បទថា **វំសបថំ** សេចក្តីថា បទថា **វំសបថំ គច្ឆតិ** គប្បីជ្រាបថា លោកពោលសំដៅយកផ្លូវដែលបុគ្គលកាលធ្វើផ្លូវ ប្រើកាំបិតសម្រាប់កាប់គុម្ពឫស្សី ប្រើពូថៅសម្រាប់ពុះដើមឈើធ្វើបង្អោងក្នុងព្រៃឫស្សីឡើងលើ

គុម្ពឫស្សី កាប់ឫស្សីឲ្យដួលសង្កត់លើគុម្ពឫស្សីដទៃ ហើយដើរទៅតាមចុងឫស្សីនោះឯង ។

បទថា **គវេសន្តោ ន វិន្ទតិ អលាភមូលកម្បិ ទុក្ខំ ទោមនស្សំ បដិសំវេទេតិ** សេចក្តីថា រមែងបានទទួលទុក្ខកាយ ទុក្ខចិត្ត មានការមិនបានជាមូល ។

បទថា **លទ្ធា** ស្មើគ្នានឹង **លភិត្វា** ។ បទថា **អារក្ខមូលកំ** សេចក្តីថា មានការរក្សាជាមូល ។ បទថា **កិន្តិ មេ ភោគេ** សេចក្តីថា ដោយឧបាយដូចម្តេចហ្ន៎ ទើបព្រះរាជាមិនរឹបអូសភោគទ្រព្យរបស់អញ ពួកចោរមិនលួច ភ្លើងមិនឆេះ ទឹកមិនក្បួចទៅ ពួកអ្នកទទួលមត៌កដែលមិនជាទីស្រឡាញ់ មិនជញ្ជូនយកទៅ ។ បទថា **គោបយតោ** សេចក្តីថា គ្រប់គ្រងដោយហិបជាដើម ។ បទថា **វិប្បលុជ្ជន្តិ** បានដល់ វិនាស ។

[ ២៥៥ ] បទថា **ឯតមាទីនវំ ញត្វា មុនិ បុព្វាបរេ ឥធ** សេចក្តីថា មុនីជ្រាបនូវទោសនោះ ដែលមានក្នុងកាលខាងក្រោយអំពីកាលមុន ដែលត្រាស់ទុកចាប់អំពីនេះថា យសនិងកេរ្តិ៍ឈ្មោះណាធ្លាប់មានក្នុងកាលមុន យសនិងកេរ្តិ៍ឈ្មោះនោះ របស់បុគ្គលនោះរមែងសាបសូន្យទៅ[១]ក្នុងភាពជាយាវាសអំពីកាលមុន គឺចាកភាពជាសមណៈ ក្នុងកាលដទៃក្នុងគាថានេះ ។

[ ២៥៧ ] បទថា **ឧដ្ឋំ ករេយ្យ** ជាមាតិកានៃនិទ្ទេស ។ បទថា **ថិរំ ករេយ្យ** សេចក្តីថា គប្បីធ្វើមិនឲ្យធូរថយ ។ បទថា **ឧដ្ឋសមានោ អស្ស**

១-គាថានេះ មានក្នុងលេខឃ្នាប ២៤០ ។

សេចក្តីថា គប្បីជាអ្នកមានប្រាជ្ញាមាំទាំ ។ បទថា **អវដ្ឋិតសមាធានោ** សេចក្តីថា មានប្រាជ្ញាតាំងចុះព្រម ។

[ ២៥៩ ] បទថា **ឯតទរិយានមុត្តមំ** សេចក្តីថា ការប្រព្រឹត្តស្ងប់ស្ងាត់នោះជាកិច្ចដ៏ឧត្តមរបស់ព្រះអរិយៈទាំងឡាយ មានព្រះពុទ្ធជាដើម អធិប្បាយថា ព្រោះដូច្នោះ អ្នកទាំងឡាយគប្បីសិក្សាវិវេកនោះឯង ។ បទថា **ន តេន សេដ្ឋោ មញ្ញេថ** សេចក្តីថា មិនគប្បីសម្គាល់ខ្លួនថា អញជាបុគ្គលប្រសើរបំផុតដោយការស្ងាត់នោះ លោកអធិប្បាយថា បុគ្គលមិនគប្បីសម្គាល់ថា ខ្លួនប្រសើរដោយវិវេកនោះទេ ។

[ ២៦២ ] បទថា **ឧណ្ណតី** បានដល់ ការលើកឡើង ។ បទថា **ឧណ្ណាមំ** បានដល់ ការតាំងខ្លួនឡើងទុកយ៉ាងខ្ពស់ ។ បទថា **មានំ** បានដល់ ការប្រកាន់ថា ជាខ្លួនរបស់អញ ។ បទថា **ថម្ភំ** បានដល់ ធ្វើតាមទំនើងចិត្ត ។ បទថា **ពន្ធំ** បានដល់ ហេតុនៃការចង ។ បទថា **ថទ្ធោ** បានដល់ មិនទទន់ភ្លន់ ។ បទថា **បត្ថទ្ធោ** បានដល់ មិនទទន់ភ្លន់ដោយពិសេស ។ បទថា **បគ្គហិត-សិរោ** បានដល់ មានក្បាលអើតឡើងខ្ពស់ ។

[ ២៦៣ ] បទថា **សាមន្តា** បានដល់ មិនឆ្ងាយ ។ បទថា **អាសន្នេ** បានដល់ មិនឆ្ងាយ ។ បទថា **អវិទូរេ** បានដល់ ជិត ។ បទថា **ឧបកដ្ឋេ** បានដល់ ក្នុងសម្នាក់ ។

[ ២៦៤ ] បទថា **វិត្តស្ស** បានដល់ ស្ងាត់ គឺវៀរចាកកាយទុច្ចរិតជាដើម ។ បទថា **ឱឃតិណ្ណស្ស បិហយន្តិ កាមេសុ គធិតា បជា** សេចក្តីថា

សត្វទាំងឡាយដែលជាប់ចំពាក់ក្នុងវត្ថុកាម រមែងស្រឡាញ់ចំពោះមុនីនោះ ដែលឆ្លងឱឃៈ ៤ បានហើយ ដូចបុគ្គលដែលមានបំណុល ស្រឡាញ់ចំពោះបុគ្គលដែលមិនមានបំណុលដូច្នោះ ព្រះដ៏មានព្រះភាគ ទ្រង់បញ្ចប់ទេសនាដោយកំពូលគឺអរហត្ត ដោយប្រការដូច្នេះ ។

[ ២៦៥ ] បទថា **វិត្តស្ស** បានដល់ ទទេចាកកិលេសសព្វយ៉ាង ។ បទថា **វិវិត្តស្ស** បានដល់ សូន្យ ។ បទថា **បវិវិត្តស្ស** បានដល់ ម្នាក់ឯង ។

ឥឡូវនេះ ព្រះសារីបុត្តត្ថេរ កាលនឹងសម្តែងកិលេសទាំងឡាយ ដែលមុនីវៀរចាក ទើបពោលពាក្យជាដើមថា **កាយទុច្ចរិតេន វិត្តស្ស** ដូច្នេះ ។

ក្នុងបទទាំងនោះ គប្បីជ្រាបការទទេ ២ យ៉ាង គឺតាមលំដាប់កិលេស ១ តាមលំដាប់មគ្គ ១ ។ គប្បីជ្រាបតាមលំដាប់កិលេសមុន មុនីជាអ្នកឆ្ងាយចាកកិលេស ៦ គឺរាគៈ មោហៈ ថម្ភៈ សារម្ភៈ មានះ មទៈ ដោយអរហត្តមគ្គ ។ ជាអ្នកទទេចាកកិលេស ៤ យ៉ាងនោះ គឺទោសៈ កោធៈ ឧបនាហៈ បមាទៈ ដោយអនាគាមិមគ្គ ។ ជាអ្នកទទេចាកកិលេស ៧ គឺអតិមានះ មក្ខៈ បលាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋេយ្យៈ ដោយសោតាបត្តិមគ្គ ។

ចំណែកតាមលំដាប់មគ្គ គប្បីជ្រាបដូចតទៅនេះ មុនី ជាអ្នកទទេចាកកិលេស ៧ យ៉ាង គឺ អតិមានះ មក្ខៈ បលាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋេយ្យៈដោយសោតាបត្តិមគ្គ ។ ជាអ្នកឆ្ងាយចាកកិលេស ៤ គឺទោសៈ កោធៈ ឧបនាហៈ បមាទៈដោយអនាគាមិមគ្គ ។ ជាអ្នកទទេចាកកិលេស ៦ គឺរាគៈ មោហៈ ថម្ភៈ សារម្ភៈ មានះ មទៈ ដោយអរហត្តមគ្គ ។ កិលេស

ដ៏សេសទាំងឡាយ គប្បីប្រកបតាមដែលប្រកបទុកដោយន័យជាដើមថា **តីណិ ទុច្ចរិតានិ សព្វកិលេសេហិ** ដូច្នេះ ។

[ ២៦៦ ] បទថា **វត្ថុកាមេ បរិជានិត្វា** សេចក្តីថា ដឹងនូវវត្ថុកាមទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដោយអំណាចចូលដល់ហើយដោយញាណ-តប្បរិញ្ញា និងតីរណប្បរិញ្ញា ។ បទថា **កិលេសកាមេ បហាយ** សេចក្តីថា លះកិលេសកាមទាំងឡាយ មានឆន្ទៈជាដើម ដោយបហានប្បរិញ្ញា ។ បទថា **ព្យន្តីករិត្វា** សេចក្តីថា ធ្វើឲ្យមានទីបំផុតទៅប្រាសហើយ គឺឲ្យប្រាសចាកទីបំផុត ។

[ ២៦៧ ] បទថា **កាមោឃំ តិណ្ណស្ស** សេចក្តីថា ឆ្លងនូវកាមោឃៈ ពោលគឺ ការវិលវល់តាំងនៅដោយអនាគាមិមគ្គ ។ បទថា **ភវោឃំ** សេចក្តីថា ឆ្លងនូវភវឱឃៈដោយអរហត្តមគ្គ ។ បទថា **ទិដ្ឋោឃំ** សេចក្តីថា ឆ្លងនូវទិដ្ឋឱឃៈដោយសោតាបត្តិមគ្គ ។ បទថា **អវិជ្ជោឃំ** សេចក្តីថា ឆ្លងអវិជ្ជាឱឃៈដោយអរហត្តមគ្គ ។ បទថា **សព្វសំសារបថំ** សេចក្តីថា ឆ្លងផ្លូវ ពោលគឺលំដាប់ខន្ធ ធាតុ និងអាយតនៈទាំងពួង ហើយតាំងនៅដោយអរហត្តមគ្គនោះឯង ។

ឆ្លងដោយសោតាបត្តិមគ្គ ឆ្លងឡើងដោយសកទាគាមិមគ្គ ឆ្លងចេញចាកកាមធាតុដោយអនាគាមិមគ្គ កន្លងភពទាំងពួងដោយអរហត្តមគ្គ ឈានកន្លងដោយអំណាចនៃផលសមាបត្តិ ។ បទថា **ចារំ គតស្ស** ជាដើម លោកពោលដោយអំណាចនៃព្រះនិព្វាន ។ បទថា **យថា ឥណាយិកា អាណណ្យំ** សេចក្តីថា ពួកអ្នកជំពាក់បំណុលដែលមានការប្រាក់រមែងប្រាថ្នានូវការអស់បំណុល ។

បទថា **បត្ថេន្តិ** សេចក្តីថា ញុំាងនូវការប្រាថ្នាឲ្យកើតឡើង ។ បទថា **អាពាធិកា អារោគ្យំ** សេចក្តីថា ជាអ្នកសោប់សោល់ព្រោះរោគប្រមាត់ជាដើម រមែងប្រាថ្នានូវការស្ងប់រោគ គឺការមិនមានរោគដោយការប្រកបភេសជ្ជៈ ។ បទថា **យថា ពន្ធនពទ្ធា** សេចក្តីថា ក្នុងថ្ងៃនក្ខត្តឫក្ស ពួកជនដែលជាប់ក្នុងគុក រមែងប្រាថ្នានូវការរួចផុតអំពីគុក ។ បទថា **យថា ទាសា ភុជិស្សំ** សេចក្តីថា ព្រោះបុគ្គលដែលជាអ្នកជា រមែងធ្វើអ្វីមួយបានតាមប្រាថ្នា មិនមានបុគ្គលណាមួយឲ្យបុគ្គលនោះត្រឡប់នូវការធ្វើនោះបាន ដោយកម្លាំងបាយ ព្រោះហេតុនោះ ទើបទាសៈទាំងឡាយ ប្រាថ្នាភាពជាអ្នកជា ។ បទថា **យថា កន្តារទ្ធានំ បក្ខន្ទា** សេចក្តីថា ព្រោះពួកមនុស្សដែលមានកម្លាំងចាប់ដំរី ត្រៀមអាវុធ មួយអន្លើដោយបរិវារ ធ្វើដំណើរឆ្លងកន្តារ ពួកចោរឃើញជនទាំងនោះហើយ រមែងគេចអំពីចម្ងាយ ពួកជនទាំងនោះផុតផ្លូវកន្តារ ដល់នូវដែនក្សេមដោយសួស្តី រមែងត្រេកអរដូច្នោះ ពួកអ្នកដើរផ្លូវកន្តារ ទើបប្រាថ្នានូវទីដែលក្សេម ។

ក្នុងពេលចប់ទេសនា ព្រះតិស្សមេត្តេយ្យត្ថេរសម្រេចសោតាបត្តិផល ខាងក្រោយបួស បានធ្វើឲ្យជាក់ច្បាស់នូវព្រះអរហត្តដូច្នេះឯង ។

## អដ្ឋកថា តិស្សមេត្តេយ្យសុត្តនិទ្ទេសទី ៧ ចប់

# បសូរសុត្តនិទ្ទេស ទី ៨

[ ២៦៨ ] ( ព្រះមានព្រះភាគទ្រង់ត្រាស់ថា ) ពួកសមណៈព្រាហ្មណ៍ដ៏ច្រើន តែងពោលនូវការស្អាតក្នុងធម៌របស់ខ្លួននេះ មិនពោលនូវការស្អាតក្នុងធម៌ដទៃ អាស្រ័យសភាវៈណា រមែងពោលថាល្អ ក្នុងសភាវនោះ ជាអ្នកតាំងនៅមាំក្នុងពួកសច្ចៈដោយឡែក ។

[ ២៦៩ ] ពាក្យថា តែងពោលនូវការស្អាតក្នុងធម៌របស់ខ្លួននេះ អធិប្បាយថា ( សមណព្រាហ្មណ៍ទាំងឡាយ ) តែងពោល សម្តែង ពណ៌នា បំភ្លឺ ថ្លែងនូវការស្អាត ស្អាតវិសេស បរិសុទ្ធិ ការរួច រួចវិសេស រួចស្រឡះក្នុងធម៌នេះថា លោកទៀង ពាក្យនេះជាពាក្យពិត ពាក្យដទៃជាមោឃៈ ពោលសម្តែងពណ៌នា បំភ្លឺ ថ្លែងនូវការស្អាត ស្អាតវិសេស បរិសុទ្ធិ ការរួច រួចវិសេសរួចស្រឡះថា លោកមិនទៀង លោកមានទីបំផុត លោកមិនមានទីបំផុត ជីវៈនោះ សរីរៈនោះ ជីវៈដទៃ សរីរៈដទៃ សត្វបន្ទាប់អំពីសេចក្តីស្លាប់កើតទៀតក៏មាន សត្វបន្ទាប់អំពីសេចក្តីស្លាប់ មិនកើតទៀតក៏មាន សត្វបន្ទាប់អំពីសេចក្តីស្លាប់ កើតទៀតក៏មាន មិនកើតទៀតក៏មាន សត្វបន្ទាប់អំពីសេចក្តីស្លាប់ មិនកើតទៀតក៏មិនមែន កើតទៀតក៏មិនមែន ពាក្យនេះ ជាពាក្យពិត ពាក្យដទៃជាមោឃៈ បានពោល សម្តែង ពណ៌នា បំភ្លឺ ថ្លែងនូវការស្អាត ស្អាតវិសេសបរិសុទ្ធិ ការរួច រួចវិសេស រួចស្រឡះ ដូច្នេះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) តែងពោលនូវការស្អាតក្នុងធម៌របស់ខ្លួននេះ ។

[ ២៧០ ] ពាក្យថា មិនពោលនូវការស្អាតក្នុងធម៌ដទៃ គឺលើកតម្កើងនូវគ្រូរបស់ខ្លួន នូវធម៌ដែលគ្រូនោះពោលហើយ នូវគណៈ នូវទិដ្ឋិ នូវបដិបទា

និងមគ្គ ហើយបោះបោល លើកបោល ទម្លាក់បោលនូវវាទៈដទៃទាំងអស់ថា សាស្តានោះ មិនមែនជាសព្វញ្ញូ ធម៌សាស្តានោះ មិនមែនសម្តែងដោយប្រពៃទេ គណៈមិនមែនប្រតិបត្តិដោយប្រពៃទេ ទិដ្ឋិមិនមែនចម្រើនទេ បដិបទាមិនមែនបញ្ញត្តដោយប្រពៃទេ មគ្គមិនមែនជាទីស្រោចស្រង់សត្វទេ ការស្អាត ឬស្អាតវិសេស ឬសេចក្តីបរិសុទ្ធិ ការរួច ឬរួចវិសេស ឬរួចស្រឡះ មិនមានក្នុងធម៌នុ៎ះឡើយ ពួកសត្វរមែងមិនស្អាត ឬមិនស្អាតវិសេស ឬមិនបរិសុទ្ធិ មិនរួច ឬមិនរួចវិសេស ឬមិនរួចស្រឡះ ក្នុងធម៌នោះឡើយ ទិដ្ឋិនោះថោកទាប ទន់ អន់ ទន់ទាប លាមក អាក្រក់ តិចតួច ពួកសមណព្រាហ្មណ៍ ពោលយ៉ាងនេះ សម្តែងយ៉ាងនេះ ពណ៌នាយ៉ាងនេះ បំភ្លឺយ៉ាងនេះ ថ្លែងយ៉ាងនេះ ដោយប្រការដូច្នេះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនពោលនូវការស្អាតក្នុងធម៌ដទៃ ។

[ ២៧១ ] អធិប្បាយពាក្យថា អាស្រ័យសការៈណា រមែងពោលថា ល្អក្នុងសការៈនោះ ត្រង់ពាក្យថា អាស្រ័យសការៈណា គឺអាស្រ័យ ពឹងផ្អែក ជាប់ស្អិត ជល់ស៊ប់ ចុះស៊ប់ ជឿជាក់នូវគ្រូ ធម៌ដែលគ្រូនោះពោលហើយ គណៈ ទិដ្ឋិ បដិបទា មគ្គណា ។ ពាក្យថា ក្នុងសការៈនោះ គឺក្នុងទិដ្ឋិរបស់ខ្លួន សេចក្តីគួររបស់ខ្លួន សេចក្តីគាប់ចិត្តរបស់ខ្លួន លទ្ធិរបស់ខ្លួន ។ ពាក្យថា ពោលថាល្អ គឺពោលថាល្អ ពោលថាស្អាត ពោលថាជាបណ្ឌិត ពោលថាជាអ្នកប្រាជ្ញ ពោលថារបស់គួរដឹង ពោលថាជាហេតុ ពោលថាជាលក្ខណៈ ពោលថាជាការណ៍ ពោលថាជាឋានៈក្នុងលទ្ធិរបស់ខ្លួន ហេតុនោះ ( ទ្រង់

ត្រាស់ថា ) អាស្រ័យសភាវណា រមែងពោលថាល្អ ក្នុងសភាវនោះ ។

[ ២៧២ ] ពាក្យថា ពួកសមណព្រាហ្មណ៍ដ៏ច្រើន ជាអ្នកតាំងនៅមាំក្នុងពួកសច្ចៈដោយឡែក សេចក្តីថា ពួកសមណព្រាហ្មណ៍ដ៏ច្រើន ជាអ្នកមុតមាំ តាំងនៅ ជាប់ស្អិត ជល់ស៊ប់ ចុះស៊ប់ ជឿជាក់ក្នុងពួកសច្ចៈដោយឡែកដ៏ច្រើន គឺជាអ្នកមុតមាំ តាំងនៅជាប់ស្អិត ជល់ស៊ប់ ចុះស៊ប់ ជឿជាក់ថា លោកទៀងនេះជាពាក្យពិត ពាក្យដទៃជាមោឃៈ ជាអ្នកមុតមាំ តាំងនៅ ជាប់ស្អិត ជល់ស៊ប់ ជឿជាក់ថា លោកមិនទៀង ។បេ។ សត្វបន្ទាប់ អំពីសេចក្តីស្លាប់ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន នេះជាពាក្យពិត ពាក្យដទៃជាមោឃៈ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ពួកសមណព្រាហ្មណ៍ដ៏ច្រើន ជាអ្នកតាំងនៅមាំក្នុងពួកសច្ចៈដោយឡែក ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ពួកសមណព្រាហ្មណ៍ដ៏ច្រើន តែងពោលនូវការស្អាតក្នុងធម៌
របស់ខ្លួននេះ មិនពោលនូវការស្អាត ក្នុងធម៌ដទៃ អាស្រ័យ
សភាវណា រមែងពោលថាល្អក្នុងសភាវនោះ ជាអ្នកតាំងនៅ
មាំក្នុងពួកសច្ចៈដោយឡែក ។

[ ២៧៣ ] ជនទាំងនោះ ជាអ្នកប្រាថ្នាវាទៈ ចុះកាន់បរិស័ទ ជាជនមានគូដុតគ្នាទៅវិញទៅមក ថាពាល ជនទាំងនោះអាស្រ័យសភាពដទៃ ពោលពាក្យឥតឱជា ជាអ្នកប្រាថ្នាការសរសើរ មានវាទៈដ៏ឈ្លាស ។

[ ២៧៤ ] អធិប្បាយពាក្យថា ជនទាំងនោះ ប្រាថ្នាវាទៈ ចុះកាន់បរិស័ទ ត្រង់ពាក្យថា ជនទាំងនោះប្រាថ្នាវាទៈ គឺជនទាំងនោះ ប្រាថ្នានូវវាទៈ ត្រូវការ

ដោយវាទៈ ប៉ុនប៉ងនូវវាទៈ ធ្វើវាទៈឲ្យតាំងនៅខាងមុខ ត្រាច់ទៅស្វែងរកវាទៈ ។ ពាក្យថា ចុះកាន់បរិស័ទ គឺចុះទៅ លុកទៅ ចុះសំដៅ ចូលទៅរកខត្តិយបរិស័ទ ព្រាហ្មណ៍បរិស័ទ គហបតិបរិស័ទ សមណបរិស័ទ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជនទាំងនោះប្រាថ្នាវាទៈ ចុះកាន់បរិស័ទ ។

[ ២៧៥ ] អធិប្បាយពាក្យថា ជាជនមានគូ ដុតគ្នាទៅវិញទៅមក ថាពាល ត្រង់ពាក្យថា ជាជនមានគូ គឺគ្នាពីរនាក់ គឺថាអ្នកធ្វើនូវជម្លោះពីរនាក់ អ្នកធ្វើនូវការប្រកួតប្រកាន់ពីរនាក់ អ្នកធ្វើនូវតិរច្ឆានកថាពីរនាក់ អ្នកធ្វើនូវវិវាទពីរនាក់ អ្នកធ្វើនូវអធិករណ៍ពីរនាក់ អ្នកល្មោកនិយាយពីរនាក់ អ្នកចរចាទៅមកពីរនាក់ ជនទាំងនោះ តែងដុត មើលឃើញ ក្រឡេកមើល សម្លឹងមើល ពិចារណាមើលនូវគ្នានឹងគ្នា ថាពាល ថោកទាប ថោកទាបពេក ទន់ទាប លាមក អាក្រក់ តិចតួច ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជាជនមានគូ ដុតនូវគ្នាទៅវិញទៅមក ថាពាល ។

[ ២៧៦ ] ពាក្យថា ជនទាំងនោះ អាស្រ័យសកាវដទៃ ពោលពាក្យឥតឱជា គឺអាស្រ័យ ពឹងផ្អែក ជាប់ស្អិត ដល់ស៊ប់ ចុះស៊ប់ ជឿជាក់នូវសាស្តា ធម៌ដែលសាស្តានោះសម្តែងហើយ គណៈ ទិដ្ឋិ បដិបទា មគ្គដទៃ ។ ការឈ្មោះ ការប្រកួតប្រកាន់ ទាស់ទែង វិវាទ បែកខ្ញែកគ្នា លោកហៅថា ពាក្យឥតឱជា ។ មួយទៀត ពាក្យថា ពាក្យឥតឱជា គឺសំដីនោះ មិនមានឱជា ។ ជនទាំងនោះ ពោលពាក្យមិនមានឱជារស គឺពោលជម្លោះ ពោលការប្រកួតប្រកាន់ ពោលការទាស់ទែង ពោលវិវាទ ពោល ពណ៌នា បំភ្លឺ ថ្លែង នូវ

ការបែកខ្ញែកគ្នា ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជនទាំងនោះ អាស្រ័យសភាវ ដទៃ ពោលពាក្យឥតឱជា ។

[ ២៧៧ ] ពាក្យថា ជាអ្នកប្រាថ្នាការសរសើរ មានវាទៈដ៏ឈ្លាស ត្រង់ពាក្យថា ជាអ្នកប្រាថ្នាការសរសើរ គឺប្រាថ្នាការសរសើរ ត្រូវការការសរសើរ ប៉ុនប៉ងការសរសើរ ធ្វើការសរសើរ ឲ្យតាំងនៅខាងមុខ ត្រាច់ស្វែងរកការសរសើរ ។ ពាក្យថា ជាអ្នកមានវាទៈដ៏ឈ្លាស គឺមានវាទៈដ៏ឈ្លាស មានវាទៈជាបណ្ឌិត មានវាទៈជាអ្នកប្រាជ្ញ មានវាទៈប្រកបដោយញាណ មានវាទៈជាហេតុ មានវាទៈជាលក្ខណៈ មានវាទៈជាការណ៍ មានវាទៈជាឋានៈ ក្នុងលទ្ធិរបស់ខ្លួន ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជាអ្នកប្រាថ្នាការសរសើរ មានវាទៈដ៏ឈ្លាស ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ជនទាំងនោះ ជាអ្នកប្រាថ្នាវាទៈ ចុះកាន់បរិស័ទ ជាជនមានគូ
ដុតគ្នាទៅវិញទៅមកថាពាល ជនទាំងនោះ អាស្រ័យសភាវ
ដទៃ ពោលពាក្យឥតឱជា ជាអ្នកប្រាថ្នាការសរសើរ មានវាទៈ
ដ៏ឈ្លាស ។

[ ២៧៨ ] បុគ្គលណា ប្រកបការពោលក្នុងកណ្តាលបរិស័ទ ប្រាថ្នាសេចក្តីសរសើរ បុគ្គលនោះរមែងចង្អៀតចិត្ត កាលបើគេបំបាត់សំដីហើយ រមែងអៀនអន់ បុគ្គលអ្នកស្វែងរកទោសនោះ រមែងខឹងព្រោះការនិន្ទា ។

[ ២៧៩ ] ពាក្យថា ប្រកបការពោលក្នុងកណ្តាលបរិស័ទ គឺប្រកប ប្រកបរឿយៗ ប្រកបទូទៅ ប្រកបទូទៅព្រម ប្រកបរឿយៗព្រមក្នុងពាក្យរបស់ខ្លួន

ដើម្បីពោលក្នុងកណ្តាលខត្តិយបរិស័ទក្តី ព្រាហ្មណ៍បរិស័ទក្តី គហបតិបរិស័ទក្តី សមណបរិស័ទក្តី ហេតុនោះ ( ទ្រង់ត្រាស់ថា ) ប្រកបការពោលក្នុងកណ្តាលបរិស័ទ ។

[ ២៨០ ] អធិប្បាយពាក្យថា ប្រាថ្នាសេចក្តីសរសើរ បុគ្គលនោះ រមែងចង្អៀតចិត្ត ត្រង់ពាក្យថា ប្រាថ្នាសេចក្តីសរសើរ គឺប្រាថ្នា ត្រេកអរ ប៉ុនប៉ង ស្រឡាញ់ ជាប់ចិត្ត នូវសេចក្តីសរសើរ សេចក្តីស្ញើច កេរ្តិ៍ឈ្មោះ សេចក្តីចម្រើនដោយគុណ ។ ពាក្យថា រមែងចង្អៀតចិត្ត គឺមានសេចក្តីសង្ស័យនឹងការចរចា រមែងចង្អៀតចង្អល់មុនថា អាត្មាអញនឹងមានជ័យឬ ឬថាអាត្មាអញនឹងបរាជ័យ អាត្មាអញនឹងធ្វើការផ្ចញផ្ចាល់ដូចម្តេចហ្ន៎ នឹងធ្វើការបន្ទយដូចម្តេចហ្ន៎ នឹងធ្វើឲ្យវិសេសដូចម្តេចហ្ន៎ នឹងធ្វើឲ្យវិសេសតបវិញដូចម្តេចហ្ន៎ នឹងធ្វើឲ្យធ្ងះធ្ងាយដូចម្តេចហ្ន៎ នឹងធ្វើឲ្យធ្ងះធ្ងាយរហូតដូចម្តេចហ្ន៎ នឹងធ្វើឲ្យជាប់ដូចម្តេចហ្ន៎ នឹងធ្វើឲ្យមានមណ្ឌលដូចម្តេចហ្ន៎ ជាអ្នកមានសេចក្តីសង្ស័យ នឹងការចរចា រមែងចង្អៀតចង្អល់មុនយ៉ាងនេះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ប្រាថ្នាសេចក្តីសរសើរ បុគ្គលនោះរមែងចង្អៀតចិត្ត ។

[ ២៨១ ] ពាក្យថា កាលបើគេបំបាត់សំដីហើយ រមែងអៀនអន់ អធិប្បាយថា ពួកជនណាជាបរិស័ទ អ្នកពិចារណានូវប្រស្នា មានសេចក្តីអាណិត ជនទាំងនោះតែងបំបាត់ គឺបំបាត់ព្រោះអត្ថថា លោកពោលប្រាសចាកអត្ថ បំបាត់ព្រោះព្យញ្ជនៈថា លោកពោលប្រាសចាកព្យញ្ជនៈ បំបាត់ព្រោះអត្ថនិងព្យញ្ជនៈថា លោកពោលប្រាសចាកអត្ថនិងព្យញ្ជនៈបំបាត់ថា អត្ថលោកនាំចេញខុសព្យញ្ជនៈ

លោកលើកឡើងខុស អត្ថនិងព្យញ្ជនៈ លោកនាំចេញខុស លើកឡើងខុស លោកធ្វើការសង្កត់សង្កិនមិនកើតទេ លោកធ្វើការបន្ថយខុស លោកធ្វើឲ្យវិសេសមិនកើតទេ លោកធ្វើឲ្យវិសេសតបវិញខុស លោកធ្វើឲ្យផ្ទុះផ្ដាយមិនកើតទេ លោកធ្វើឲ្យផ្ទុះផ្ដាយរហូតខុស លោកធ្វើឲ្យដាច់មិនកើតទេ លោកធ្វើឲ្យមានមណ្ឌលខុស សម្ដែងមិនល្អទេ ពណ៌នាមិនល្អទេ ចរចាមិនល្អទេ និយាយមិនល្អទេ ថ្លែងមិនល្អទេ ។ ពាក្យថា កាលបើគេបំបាត់សំដីហើយ រមែងអៀនអន់ បានសេចក្ដីថា កាលបើគេបំបាត់សំដីហើយ រមែងអៀនអន់ គឺមានសេចក្ដីលំបាកចិត្ត ចង្អៀតចង្អល់ចិត្ត តឹងចិត្ត ទោមនស្ស ហេតុនោះ ( ទ្រង់ត្រាស់ថា ) កាលបើគេបំបាត់សំដីហើយ រមែងអៀនអន់ ។

[ ២៨២ ] អធិប្បាយពាក្យថា បុគ្គលអ្នកស្វែងរកទោសនោះ រមែងខឹងព្រោះការនិន្ទា ត្រង់ពាក្យថា ព្រោះការនិន្ទា គឺព្រោះការនិន្ទា ព្រោះការតិះដៀល ព្រោះការបន្អាប់ ព្រោះការមិនចម្រើនដោយគុណ ។ ពាក្យថា រមែងខឹង គឺរមែងខឹង ប្រទូស្ត ក្រេវក្រោធ ធ្វើសេចក្ដីក្រោធផង ទោសៈផង សេចក្ដីមិនត្រេកអរផងឲ្យប្រាកដ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលនោះ រមែងខឹង ព្រោះការនិន្ទា ។ ពាក្យថា ស្វែងរកទោស គឺស្វែងរកទោស ស្វែងរកទោសផ្សេងៗ ស្វែងរកកំហុស ស្វែងរកសេចក្ដីភ្លាំងភ្លាត់ ស្វែងរកសេចក្ដីឃ្លៀងឃ្លាត ស្វែងរកចន្លោះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលអ្នកស្វែងរកទោសនោះរមែងខឹងព្រោះការនិន្ទា ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

បុគ្គលណា ប្រកបការពោលក្នុងកណ្ដាលបរិស័ទ ប្រាថ្នា

សេចក្ដីសរសើរ បុគ្គលនោះ រមែងចង្អៀតចិត្ត កាលបើគេ
បំបាត់សំដីហើយ រមែងអៀនអន់ បុគ្គលអ្នកស្វែងរកទោស
នោះរមែងខឹង ព្រោះការនិន្ទា ។

[ ២៨៣ ] ពួកជន អ្នកពិចារណាប្រស្នា បានពោលវាទៈ របស់ជននោះ ថាថោកទាប ថាគួរបំបាត់ចោល បុគ្គលអ្នកមានវាទៈថោកទាប រមែងយំរៀបរាប់ សោកស្ដាយ ត្អូញត្អែរថា គេកន្លងអាត្មាអញ ។

[ ២៨៤ ] ពាក្យថា ពោលវាទៈរបស់ជននោះ ថាថោកទាប គឺពោលយ៉ាងនេះ សម្ដែងយ៉ាងនេះ ពណ៌នាយ៉ាងនេះ បំភ្លឺយ៉ាងនេះ ថ្លែងយ៉ាងនេះ នូវវាទៈរបស់បុគ្គលនោះ ថាថោកទាប ទន់អន់ ទន់ទាប សាបសូន្យ មិនបរិបូណ៌ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ពោលវាទៈរបស់ជននោះ ថាថោកទាប ។

[ ២៨៥ ] ពាក្យថា ពួកជនអ្នកពិចារណានូវប្រស្នា... ថា គួរបំបាត់ចោល គឺពួកបរិស័ទណាជាអ្នកពិចារណាប្រស្នា មានសេចក្ដីអាណិត ពួកបរិស័ទនោះតែងបំបាត់ គឺបំបាត់ព្រោះអត្ថថា លោកពោលប្រាសចាកអត្ថ បំបាត់ព្រោះព្យញ្ជនៈថា លោកពោលប្រាសចាកព្យញ្ជនៈ បំបាត់ព្រោះអត្ថនិងព្យញ្ជនៈថា លោកពោលប្រាសចាកអត្ថនិងព្យញ្ជនៈ បំបាត់ថា អត្ថលោកនាំចេញខុស ព្យញ្ជនៈលោកលើកឡើងខុស អត្ថនិងព្យញ្ជនៈ លោកនាំចេញខុស លើកឡើងខុស លោកធ្វើការសង្កត់សង្កិនមិនកើតទេ ធ្វើការបន្ថយខុស លោកធ្វើឲ្យវិនាសមិនកើតទេ លោកធ្វើឲ្យវិនាសតបវិញខុស លោកធ្វើឲ្យធ្លុះធ្លាយមិន

កើតទេ លោកធ្វើឲ្យផ្ទុះធ្លាយរហូតខុស លោកធ្វើឲ្យដាច់មិនកើតទេ លោកធ្វើឲ្យមានមណ្ឌលខុស សម្លេងមិនល្អទេ ពណ៌នាមិនល្អទេ ចរចាមិនល្អទេ និយាយមិនល្អទេ ថ្លែងមិនល្អទេ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ពួកជនអ្នកពិចារណាប្រស្នា... ថា គួរបំបាត់ចោល ។

[ ២៨៦ ] អធិប្បាយពាក្យថា បុគ្គលអ្នកមានវាទៈដ៏ថោកទាប រមែងយំរៀបរាប់ សោកស្ដាយ ត្រង់ពាក្យថា រមែងយំរៀបរាប់ គឺចរចាដោយវាចា ការចរចារឿយៗ ការយំរៀបរាប់ អាការយំរៀបរាប់ ភាពនៃការយំរៀបរាប់ណា មានសភាពយ៉ាងនេះថា អាត្មាអញនឹកឃើញរបស់ដទៃ គិតឃើញរបស់ដទៃ ចាំទុករបស់ដទៃ កត់ត្រាទុករបស់ដទៃ បុគ្គលនោះជាអ្នកមានពួកច្រើន មានបរិស័ទច្រើន មានបរិវារច្រើន ឯបរិស័ទនេះ ជាពួកមិនព្រមព្រៀងគ្នា ទាំងការចរចាដោយពាក្យដើម្បីសេចក្ដីព្រមព្រៀងគ្នា ចូរមានចុះ អាត្មាអញនឹងបំបែកវិញ ហេតុនោះ ( ទ្រង់ត្រាស់ថា ) រមែងយំរៀបរាប់ ។ ពាក្យថា សោកស្ដាយ គឺសោកស្ដាយថា គេមានជ័យ សោកស្ដាយថា អាត្មាអញបរាជ័យ សោកស្ដាយថា គេមានលាភ សោកស្ដាយថា អាត្មាអញឥតលាភ សោកស្ដាយថា គេមានយស សោកស្ដាយថា អាត្មាអញ ឥតយស សោកស្ដាយថា គេបានសេចក្ដីសរសើរ សោកស្ដាយថា អាត្មាអញបាននិន្ទា សោកស្ដាយថា គេបានសុខ សោកស្ដាយថា អាត្មាអញបានទុក្ខ សោកស្ដាយ លំបាកចិត្ត យំរៀបរាប់ យំគក់ទ្រូង ដល់នូវសេចក្ដីវង្វេងថា បុគ្គលនោះ មានគេធ្វើសក្ការៈ គោរព រាប់អាន បូជា កោតក្រែង ជាអ្នកបានចីវរ បិណ្ឌបាត សេនាសនៈ

និងគិលានប្បច្ចយភេសជ្ជបរិក្ខារ អាត្មាអញ គេមិនធ្វើសក្ការៈ មិនគោរព មិនរាប់អាន មិនបូជា មិនកោតក្រែង មិនបានចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារទេ ហេតុនោះ ( ទ្រង់ត្រាស់ថា ) យំរៀបរាប់សោកស្តាយ ។ ពាក្យថា មានវាទៈដ៏ថោកទាប គឺមានវាទៈដ៏ថោកទាប មានវាទៈទន់អន់ មានវាទៈ សាបសូន្យ មានវាទៈខ្វះខាត មានវាទៈមិនបរិបូណ៌ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលមានវាទៈថោកទាប រមែងយំរៀបរាប់សោកស្តាយ ។

[ ២៨៧ ] ពាក្យថា ត្អូញត្អែរថា គេកន្លងអាត្មាអញ គឺត្អូញត្អែរថា គេបំពានរំលោភលើ ប្រព្រឹត្តកន្លង រំលងពីលើ រំលោភពីលើវាទៈដោយវាទៈនឹងអញ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ត្អូញត្អែរថា គេកន្លងអាត្មាអញ យ៉ាងនេះខ្លះ ។ មួយទៀត ត្អូញត្អែរថា បុគ្គលនោះ គ្របសង្កត់ ពន្លិចពន្លង់ រួបរឹត ញាំញីនូវវាទៈដោយវាទៈនឹងអញ ហើយត្រាច់ទៅ សម្រាន្តនៅ ញុំាងឥរិយាបថឲ្យប្រព្រឹត្តទៅ ញុំាងការប្រព្រឹត្តឥរិយាបថឲ្យកើតឡើង រក្សាឥរិយាបថបំពេញឥរិយាបថ បន្ត្រប់ឥរិយាបថ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ត្អូញត្អែរថា គេកន្លងអាត្មាអញយ៉ាងនេះខ្លះ ។ ការបរបាដោយវាចា ការបរបាផ្សេង ៗ ការយំរៀបរាប់ អាការយំរៀបរាប់ ភាពនៃការយំរៀបរាប់ លោកហៅថា ការត្អូញត្អែរ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ត្អូញត្អែរថា គេកន្លងអាត្មាអញ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ពួកជន អ្នកពិចារណាប្រស្នា បានពោលវាទៈ របស់ជននោះ

ថាថោកទាប ថាគួរបំបាត់ចោល បុគ្គលអ្នកមានវាទៈដ៏ថោកទាប រមែងយំរៀបរាប់ សោកស្តាយ ត្អូញត្អែរថា គេកន្លងអាត្មាអញ ។

[ ២៨៨ ] វិវាទទាំងនុ៎ះកើតក្នុងពួកសមណៈ កិរិយាធូរចិត្តនិងការតឹងចិត្ត រមែងមានព្រោះវាទៈទាំងនេះ បុគ្គលឃើញទោសនេះហើយ ត្រូវវៀរបង់សំដីមិនឱជាដ្បិតប្រយោជន៍ដទៃ មិនមានព្រោះកិរិយាបានពាក្យសរសើរទេ ។

[ ២៨៩ ] អធិប្បាយពាក្យថា វិវាទៈទាំងនោះ កើតក្នុងពួកសមណៈ ត្រង់ពាក្យថា ពួកសមណៈ គឺពួកជនណាមួយ ដែលចូលទៅកាន់ផ្នួស ជាបរិព្វាជកចូលទៅរកបរិព្វាជកខាងក្រៅអំពីសាសនានេះ ជម្លោះព្រោះទិដ្ឋិ ការប្រកួតប្រកាន់ព្រោះទិដ្ឋិ ការទាស់ទែងព្រោះទិដ្ឋិ ការវិវាទព្រោះទិដ្ឋិ ការបែកខ្ញែកគ្នាព្រោះទិដ្ឋិទាំងនុ៎ះ កើត កើតព្រម លេចឡើង លេចឡើងប្រាកដ កើតប្រាកដក្នុងពួកសមណៈ ហេតុនោះ ( ទ្រង់ត្រាស់ថា ) វិវាទទាំងនុ៎ះ កើតក្នុងពួកសមណៈ ។

[ ២៩០ ] ពាក្យថា កិរិយាធូរចិត្តនិងការតឹងចិត្ត រមែងមានព្រោះវាទៈទាំងនេះ អធិប្បាយថា ជ័យនិងបរាជ័យរមែងមាន លាភនិងឥតលាភរមែងមាន យសនិងឥតយសរមែងមាន និន្ទានិងសេចក្តីសរសើររមែងមាន សុខនិងទុក្ខរមែងមានសោមនស្ស និងទោមនស្សរមែងមាន របស់ជាទីប្រាថ្នានិងមិនជាទីប្រាថ្នារមែងមាន សេចក្តីត្រេកអរនិងការថ្នាំងថ្នាក់រមែងមាន កិរិយាធូរចិត្តនិងការតឹងចិត្តរមែងមាន សេចក្តីត្រេកអរនិងការខឹងរមែងមាន ចិត្តធូរព្រោះ

ការឈ្នះ ចិត្តតឹងព្រោះការចាញ់ ចិត្តធូរព្រោះលាភ ចិត្តតឹងព្រោះឥតលាភ ចិត្តធូរព្រោះយស ចិត្តតឹងព្រោះឥតយស ចិត្តធូរព្រោះសេចក្តីសរសើរ ចិត្តតឹងព្រោះនិន្ទា ចិត្តធូរព្រោះសុខ ចិត្តតឹងព្រោះទុក្ខ ចិត្តធូរព្រោះសោមនស្ស ចិត្តតឹងព្រោះទោមនស្ស ចិត្តធូរព្រោះការប៉ោងឡើង ចិត្តតឹងព្រោះការត្រូវចុះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ការធូរចិត្តនិងការតឹងចិត្ត រមែងមានព្រោះវាទៈទាំងនេះ ។

[ ២៩១ ] អធិប្បាយពាក្យថា បុគ្គលឃើញទោសនេះហើយ ត្រូវវៀរបង់សំដីមិនមានឱជា ត្រង់ពាក្យថា ឃើញទោសនេះ គឺឃើញ យល់ ថ្លឹង ត្រិះរិះ ធ្វើឲ្យច្បាស់ ធ្វើឲ្យប្រាកដនូវទោសនេះ ក្នុងការឈ្លោះព្រោះទិដ្ឋិ ក្នុងការប្រកួតប្រកាន់ព្រោះទិដ្ឋិ ក្នុងការទាស់ទែងព្រោះទិដ្ឋិ ក្នុងការវិវាទព្រោះទិដ្ឋិ ក្នុងការបែកខ្ញែកគ្នាព្រោះទិដ្ឋិ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ឃើញទោសនេះ ។ ពាក្យថា ត្រូវវៀរបង់សំដីមិនមានឱជា គឺជម្លោះ ការប្រកួតប្រកាន់ ការទាស់ទែង ការវិវាទ ការបែកខ្ញែកគ្នា លោកហៅថា សំដីមិនមានឱជា ។ មួយទៀត ពាក្យមិនមានឱជានោះ ហៅថា សំដីមិនមានឱជា ។ បុគ្គលមិនគប្បីធ្វើសំដីមិនមានឱជា គឺមិនគប្បីធ្វើជម្លោះ មិនគប្បីធ្វើការប្រកួតប្រកាន់ មិនគប្បីធ្វើការទាស់ទែង មិនគប្បីធ្វើការវិវាទ មិនគប្បីធ្វើការបែកខ្ញែកគ្នា គប្បីលះបង់ គប្បីបន្ទោបង់ គប្បីធ្វើឲ្យវិនាស គប្បីឲ្យដល់នូវការមិនកើតមានជម្លោះ ការប្រកួតប្រកាន់ ការទាស់ទែង ការវិវាទនិងការបែកខ្ញែកគ្នា ។ បុគ្គលគប្បីជាអ្នកឆ្ងាយ វៀរស្រឡះ វៀរចំពោះចៀសវាង លះបង់ ផុតស្រឡះ ប្រកប ប្រាសចាក

ជម្លោះ ការប្រកួតប្រកាន់ ការទាស់ទែង ការវិវាទនិងការបែកខ្ញែកគ្នាហើយ សម្រាន្តនៅដោយចិត្ត ដែលប្រាសចាកដែនគឺកិលេស ហេតុនោះ ( ទ្រង់ត្រាស់ថា ) ឃើញទោសនេះហើយ ត្រូវវៀរបង់សំដីមិនមានឱជា ។

[ ២៩២ ] ពាក្យថា ដ្បិតប្រយោជន៍ដទៃមិនមាន ព្រោះការបានសេចក្ដីសរសើរ សេចក្ដីថា ប្រយោជន៍ដទៃមិនមាន ព្រោះការបានសេចក្ដីសរសើរ គឺប្រយោជន៍របស់ខ្លួនក្ដី ប្រយោជន៍របស់បុគ្គលដទៃក្ដី ប្រយោជន៍ទាំងពីរក្ដី ប្រយោជន៍បច្ចុប្បន្នក្ដី ប្រយោជន៍ក្នុងលោកខាងមុខក្ដី ប្រយោជន៍រាក់ក្ដី ប្រយោជន៍ជ្រៅក្ដី ប្រយោជន៍លាក់ក្ដី ប្រយោជន៍កំបាំងក្ដី ប្រយោជន៍ដែលត្រូវដឹកនាំក្ដី ប្រយោជន៍ដែលដឹកនាំហើយក្ដី ប្រយោជន៍មិនមានទោសក្ដី ប្រយោជន៍មិនមានកិលេសក្ដី ប្រយោជន៍ផូរផង់ក្ដី ប្រយោជន៍មានអត្ថដ៏ឧត្ដមក្ដី រមែងមិនមាន មិនមានព្រម មិនកើតមាន ហេតុនោះ ( ទ្រង់ត្រាស់ថា ) ដ្បិតប្រយោជន៍ដទៃមិនមាន ព្រោះការបានសេចក្ដីសរសើរ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

វិវាទទាំងនុ៎ះ កើតក្នុងពួកសមណៈ កិរិយាជូរចិត្តនិងការតឹងចិត្ត រមែងមានព្រោះវិវាទទាំងនេះ បុគ្គលឃើញទោសនេះហើយ ត្រូវវៀរបង់សំដីមិនមានឱជា ដ្បិតប្រយោជន៍ដទៃមិនមាន ព្រោះការបានពាក្យសរសើរទេ ។

[ ២៩៣ ] មួយទៀត បុគ្គលនោះពោលវាទៈក្នុងកណ្ដាលបរិស័ទត្រូវគេសរសើរក្នុងសភាវៈនោះហើយ រមែងរីករាយ ក្រអឺតក្រអោង ដោយហេតុ

នោះ ដល់នូវប្រយោជន៍នោះ ហើយជាបុគ្គលមានចិត្តតាំងនៅដូចដើម ។

[ ២៩៤ ] ពាក្យថា ក្នុងសភាវៈនោះ របស់ពាក្យថា មួយទៀត ត្រូវគេសរសើរហើយក្នុងសភាវៈនោះ គឺត្រូវគេសរសើរ លើកតម្កើង ប្រកាសគុណ ពណ៌នាគុណក្នុងទិដ្ឋិរបស់ខ្លួន ក្នុងការគួររបស់ខ្លួន ក្នុងសេចក្ដីពេញចិត្តរបស់ខ្លួន ក្នុងលទ្ធិរបស់ខ្លួន ហេតុនោះ ( ទ្រង់ត្រាស់ថា ) មួយទៀត ត្រូវគេសរសើរហើយក្នុងសភាវៈនោះ ។

[ ២៩៥ ] ពាក្យថា ពោលវាទៈក្នុងកណ្ដាលបរិស័ទ គឺពោលប្រាប់វាទៈរបស់ខ្លួន ពោល ប្រាប់ បំពេញ ចម្រើន សម្ដែង បំភ្លឺ ថ្លែង កំណាត់អនុវាទៈរបស់ខ្លួន ក្នុងកណ្ដាលខត្តិយបរិស័ទក្ដី ព្រាហ្មណបរិស័ទក្ដី គហបតិបរិស័ទក្ដី សមណបរិស័ទក្ដី ហេតុនោះ ( ទ្រង់ត្រាស់ថា ) ពោលវាទៈក្នុងកណ្ដាលបរិស័ទ ។

[ ២៩៦ ] ពាក្យថា បុគ្គលនោះ រមែងរីករាយ ក្រអឺតក្រអោងដោយហេតុនោះ គឺបុគ្គលនោះ រមែងត្រេកអររីករាយ ស្រស់ស្រាយ មានចិត្តត្រេកអរ មានចិត្តត្រិះរិះពេញលេញ ដោយប្រយោជន៍គឺការឈ្នះនោះ ។ មួយទៀត បុគ្គលកាលសើចបញ្ចេញធ្មេញ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលនោះរីករាយ ។ ពាក្យថា ក្រអឺតក្រអោងដោយហេតុនោះ គឺបុគ្គលនោះមានចិត្តប៉ោងឡើង មានចិត្តខ្ពស់ឡើង មានចិត្តដូចជាទង់ជ័យ មានចិត្តផ្គងឡើង ភាពនៃចិត្តមានសេចក្ដីប្រាថ្នាដូចជាទង់ ដោយប្រយោជន៍គឺការឈ្នះនោះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលនោះ រីករាយ ក្រអឺតក្រអោង ដោយហេតុនោះ ។

[ ២៩៧ ] ពាក្យថា ដល់នូវប្រយោជន៍នោះ ជាអ្នកមានចិត្តតាំងនៅ ដូចដើម គឺដល់ លុះ សម្រេច បាន បានចំពោះនូវប្រយោជន៍ គឺការឈ្នះនោះ ។ ពាក្យថា ជាអ្នកមានចិត្តតាំងនៅដូចដើម គឺជាអ្នកមានចិត្តដូចដើម មានគំនិតដូចដើម មានសេចក្តីត្រិះរិះដូចដើម មានការដឹងដូចដើម ហេតុនោះ ( ទ្រង់ត្រាស់ថា ) បានដល់នូវប្រយោជន៍នោះ ជាអ្នកមានចិត្តតាំងនៅដូចដើម ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

មួយទៀត បុគ្គលនោះ ពោលវាទៈក្នុងកណ្តាលបរិស័ទ ត្រូវ
គេសរសើរហើយក្នុងសភាវៈនោះរមែងរីករាយ ក្រអឺតក្រអោង
ដោយហេតុនោះ ដល់នូវប្រយោជន៍នោះហើយ ជាបុគ្គលមាន
ចិត្តតាំងនៅដូចដើម ។

[ ២៩៨ ] ការប៉ោងឡើងណា ការប៉ោងឡើងនោះ ជាភូមិនៃសេចក្តីចង្អៀតចង្អល់របស់បុគ្គលនោះ មួយទៀត បុគ្គលនុ៎ះ រមែងពោលនូវមានៈនិងអតិមានៈ បុគ្គលឃើញទោសនោះហើយ មិនគួរវិវាទទេ ដ្បិតជនអ្នកឈ្លាសទាំងឡាយមិនពោលនូវការស្អាត ដោយវិវាទនោះឡើយ ។

[ ២៩៩ ] ពាក្យថា ការប៉ោងឡើងណា ការប៉ោងឡើងនោះ ជាភូមិនៃសេចក្តីចង្អៀតចង្អល់របស់បុគ្គលនោះ គឺការប៉ោងឡើង ការខ្ពស់ឡើង ចិត្តដូចទង់ជ័យ ការផ្គងឡើង ភាពនៃចិត្តមានប្រាថ្នាដូចជាទង់ណា នោះជាភូមិនៃការចង្អៀតចង្អល់ ជាភូមិនៃសេចក្តីតានតឹង ជាភូមិនៃការបៀតបៀន ជាភូមិនៃសេចក្តីខ្ទាំងខ្ទប់ ជាភូមិនៃឧបទ្រព ជាភូមិនៃឧបសគ្គរបស់បុគ្គលនោះ ហេតុនោះ

( ទ្រង់ត្រាស់ថា ) ការប៉ោងឡើងណា ការប៉ោងឡើងនោះ ជាភូមិនៃសេចក្តីចង្អៀតចង្អល់របស់បុគ្គលនោះ ។

[ ៣០០ ] ពាក្យថា មួយទៀត បុគ្គលនោះ រមែងពោលនូវមានះ និងអតិមានះ គឺបុគ្គលនោះ ពោលនូវមានះផង ពោលនូវអតិមានះផង ហេតុនោះ ( ទ្រង់ត្រាស់ថា ) មួយទៀត បុគ្គលនោះ រមែងពោលនូវមានះ និងអតិមានះ ។

[ ៣០១ ] ពាក្យថា បុគ្គលឃើញទោសនេះហើយ មិនគួរវិវាទទេ សេចក្តីថា បុគ្គលឃើញ យល់ ថ្លឹង ពិចារណា ធ្វើឲ្យជាក់ច្បាស់ ធ្វើឲ្យប្រាកដនូវទោសនេះ ក្នុងជម្លោះព្រោះទិដ្ឋិ ក្នុងការប្រកួតប្រកាន់ព្រោះទិដ្ឋិ ក្នុងការទាស់ទែងព្រោះទិដ្ឋិ ក្នុងការវិវាទព្រោះទិដ្ឋិ ក្នុងការបែកខ្ញែកគ្នាព្រោះទិដ្ឋិ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលឃើញទោសនេះ ។ ពាក្យថា មិនគួរវិវាទទេ គឺមិនគួរធ្វើជម្លោះ មិនគួរធ្វើការប្រកួតប្រកាន់ មិនគួរធ្វើការទាស់ទែង មិនគួរធ្វើការវិវាទ មិនគួរធ្វើការបែកខ្ញែកគ្នា គប្បីលះបង់ គប្បីបន្ទោបង់ គប្បីធ្វើឲ្យវិនាស គប្បីធ្វើមិនឲ្យកើតមាននូវជម្លោះ ការប្រកួតប្រកាន់ ការទាស់ទែង ការវិវាទនិងការបែកខ្ញែកគ្នា ។ គឺជាអ្នកឆ្ងាយ វៀរស្រឡះ វៀរចំពោះ វៀរចេញ លះបង់ ផុតស្រឡះ ការប្រកបប្រាសចាកជម្លោះ ការប្រកួតប្រកាន់ ទាស់ទែង ការវិវាទនិងការបែកខ្ញែកគ្នា គប្បីសម្រេចនៅដោយចិត្តដែលប្រាសចាកដែនគឺកិលេស ហេតុនោះ ( ទ្រង់ត្រាស់ថា ) ឃើញទោសនេះហើយ មិនគួរវិវាទទេ ។

[ ៣០២ ] អធិប្បាយពាក្យថា ដ្បិតជនអ្នកឈ្លាសទាំងឡាយ មិនពោលនូវការស្អាតដោយវិវាទនោះទេ ត្រង់ពាក្យថា អ្នកឈ្លាសទាំងឡាយគឺ ពួកជនណា ជាអ្នកឈ្លាសក្នុងខន្ធ ឈ្លាសក្នុងធាតុ ឈ្លាសក្នុងអាយតនៈ ឈ្លាសក្នុងបដិច្ចសមុប្បាទ ឈ្លាសក្នុងសតិប្បដ្ឋាន ឈ្លាសក្នុងសម្មប្បធាន ឈ្លាសក្នុងឥទ្ធិបាទ ឈ្លាសក្នុងឥន្ទ្រិយ ឈ្លាសក្នុងពលៈ ឈ្លាសក្នុងពោជ្ឈង្គ ឈ្លាសក្នុងមគ្គ ឈ្លាសក្នុងផល ឈ្លាសក្នុងនិព្វាន ជនអ្នកឈ្លាសទាំងនោះ មិនពោល មិនសម្ដែង មិនពណ៌នា មិនបំភ្លឺ មិនថ្លែងនូវការស្អាត ស្អាតវិសេស បរិសុទ្ធិ ការរួច រួចវិសេស រួចស្រឡះ ដោយជម្លោះព្រោះទិដ្ឋិ ដោយការប្រកួតប្រកាន់ព្រោះទិដ្ឋិ ដោយការទាស់ទែងព្រោះទិដ្ឋិ ដោយការវិវាទព្រោះទិដ្ឋិ ដោយការបែកខ្ញែកគ្នាព្រោះទិដ្ឋិ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជនអ្នកឈ្លាសទាំងឡាយ មិនពោលនូវការស្អាតដោយការវិវាទនោះទេ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

> ការប៉ោងឡើងណា ការប៉ោងឡើងនោះ ជាភូមិនៃសេចក្ដី
> ចង្អៀតចង្អល់របស់បុគ្គលនោះ មួយទៀត បុគ្គលនោះ រមែង
> ពោលនូវមានះនិងអតិមានះ បុគ្គលឃើញទោសនេះហើយ
> មិនគួរវិវាទទេ ដ្បិតជនអ្នកឈ្លាសទាំងឡាយ មិនពោលនូវ
> ការស្អាតដោយវិវាទនោះឡើយ ។

[ ៣០៣ ] ដូចបុគ្គលអ្នកក្លៀវក្លា ដែលគេចិញ្ចឹមដោយខាទនីយភោជនីយាហាររបស់ព្រះរាជា កាលប្រាថ្នា បុគ្គលអ្នកក្លៀវក្លាតប រមែងគំរាមចូល

មក ម្នាលអ្នកក្លៀវក្លា បុគ្គលអ្នកលុះក្នុងទិដ្ឋិនោះ ( នៅ ) ក្នុងទីណា អ្នកឯងចូរទៅក្នុងទីនោះចុះ ដ្បិតអំពើដែលប្រព្រឹត្តទៅដើម្បីតយុទ្ធគ្នា មិនមានតាំងអំពីដើមមក ។

[ ៣០៤ ] អធិប្បាយពាក្យថា ដូចជាបុគ្គលអ្នកក្លៀវក្លា ដែលគេចិញ្ចឹមដោយខាទនីយភោជនីយាហាររបស់ព្រះរាជា ត្រង់ពាក្យថា អ្នកក្លៀវក្លា គឺបុគ្គលអ្នកក្លៀវក្លា អ្នកប្រឹងប្រែង អ្នកខ្មីឃ្មាត មិនរន្ធត់ មិនរំភើប មិនតក់ស្លុត មិនរត់ ។ ពាក្យថា ដែលគេចិញ្ចឹមដោយខាទនីយភោជនីយាហាររបស់ព្រះរាជា គឺគេចិញ្ចឹម រក្សា បីបាច់ ថែទាំ ឲ្យចម្រើនដោយខាទនីយៈរបស់ព្រះរាជាដោយភោជនីយៈរបស់ព្រះរាជា ហេតុនោះ ( ទ្រង់ត្រាស់ថា ) ដូចជាបុគ្គលអ្នកក្លៀវក្លា ដែលគេចិញ្ចឹមដោយខាទនីយភោជនីយាហាររបស់ព្រះរាជា ។

[ ៣០៥ ] ពាក្យថា កាលប្រាថ្នាបុគ្គលអ្នកក្លៀវក្លាតប រមែងគំរាមចូលមក គឺបុគ្គលនោះ កាលគំរាម កាលសង្ឃ្រក កាលសន្ធឹកចូល ដើរចូលទៅ ឈានចូលទៅ ដើរចូលទៅជិត កាលចង់ ត្រេកអរ ប្រាថ្នា ស្រឡាញ់ ជាប់ចិត្តនូវបុគ្គលអ្នកក្លៀវក្លាតប នូវបុរសជាសត្រូវ នូវសត្រូវតប នូវអ្នកជាល់តប់តប ហេតុនោះ ( ទ្រង់ត្រាស់ថា ) កាលប្រាថ្នាបុគ្គលអ្នកក្លៀវក្លា រមែងគំរាមចូលមក ។

[ ៣០៦ ] ពាក្យថា ម្នាលអ្នកក្លៀវក្លា បុគ្គលអ្នកលុះក្នុងទិដ្ឋិនោះ ( នៅ ) ក្នុងទីណា អ្នកចូរទៅក្នុងទីនោះចុះ សេចក្តីថា បុគ្គលលុះក្នុងទិដ្ឋិនោះ ( នៅ ) ក្នុងទីណា អ្នកចូរទៅក្នុងទីនោះ ចូរឈានទៅក្នុងទីនោះ ចូរដើរទៅក្នុងទីនោះ

ចូរដើរតម្រង់ទៅក្នុងទីនោះ បុគ្គលនោះជាអ្នកក្លៀវក្លាតប ជាបុរសសត្រូវ ជាសត្រូវតប ជាអ្នកជាល់តប់តបរបស់អ្នក ហេតុនោះ ( ទ្រង់ត្រាស់ថា ) ម្នាលអ្នកក្លៀវក្លា បុគ្គលអ្នកលុះក្នុងទិដ្ឋិនោះ ( នៅ ) ក្នុងទីណា អ្នកចូរទៅក្នុងទីនោះចុះ ។

[ ៣០៧ ] ពាក្យថា ដ្បិតអំពើដែលប្រព្រឹត្តទៅដើម្បីតយុទ្ធគ្នាមិនមានតាំងអំពីដើមមក អធិប្បាយថា កិលេសទាំងឡាយណា ធ្វើជាសេនាតប ធ្វើទំនាស់ ធ្វើជាបទ្វាតប ធ្វើជាបដិបក្ខ កិលេសទាំងឡាយនោះ មិនមាន មិនកើត មិនមានព្រម មិនកើតមាន គឺតថាគត លះបង់ ផ្តាច់ផ្តិល រម្ងាប់ គ្របសង្កត់ ធ្វើមិនគួរឲ្យកើតបាន ដុតបំផ្លាញដោយភ្លើងគឺញាណហើយជិតគល់ពោធិព្រឹក្សតាំងអំពីដើមមក ។ ពាក្យថា អំពើដែលប្រព្រឹត្តទៅដើម្បីតយុទ្ធគ្នា គឺអំពើណាប្រព្រឹត្តទៅដើម្បីប្រយោជន៍តយុទ្ធគ្នា ដើម្បីប្រយោជន៍ដល់ជម្លោះ ដើម្បីប្រយោជន៍ដល់ការប្រកួតប្រកាន់ ដើម្បីប្រយោជន៍ដល់ការទាស់ទែង ដើម្បីប្រយោជន៍ដល់ការវិវាទ ដើម្បីប្រយោជន៍ដល់ការបែកខ្ញែកគ្នា ហេតុនោះ ( ទ្រង់ត្រាស់ថា ) អំពើដែលប្រព្រឹត្តទៅដើម្បីតយុទ្ធគ្នា មិនមានតាំងអំពីដើមមក ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ដូចបុគ្គលអ្នកក្លៀវក្លា ដែលគេចិញ្ចឹមដោយខាទនីយភោជនី-
យាហាររបស់ព្រះរាជា កាលប្រាថ្នាបុគ្គលអ្នកក្លៀវក្លាតប រមែង
គំរាមចូលមក ម្នាលអ្នកក្លៀវក្លា បុគ្គលអ្នកលុះក្នុងទិដ្ឋិនោះ
( នៅ ) ក្នុងទីណា អ្នកឯងចូរទៅក្នុងទីនោះចុះ ដ្បិតអំពើ

ដែលប្រព្រឹត្តទៅដើម្បីតយុទ្ធគ្នា មិនមានតាំងអំពីដើមមក ។

[ ៣០៨ ] ពួកជនណាប្រកាន់ទិដ្ឋិហើយ រមែងទាស់ទែងគ្នា មួយទៀត តែងពោលថា នេះឯងជាពាក្យពិត អ្នកចូរពោលនឹងពួកជននោះចុះ កាលដែលវាទៈកើតហើយ កិលេសទាំងឡាយណា ធ្វើជាសេនាតប កិលេសទាំងឡាយនោះមិនមានក្នុងទីនេះទេ ។

[ ៣០៩ ] ពាក្យថា ពួកជនណាប្រកាន់ទិដ្ឋិហើយ រមែងទាស់ទែងគ្នា សេចក្តីថា ពួកជនណា ប្រកាន់ ក្តួចកាន់ ទទួលយក ស្ទាបអង្អែល ជឿស៊ប់នូវទិដ្ឋិ ៦២ ទិដ្ឋិណាមួយហើយ រមែងទាស់ទែងគ្នា ធ្វើជម្លោះ ធ្វើការប្រកួតប្រកាន់ ធ្វើការទាស់ទែង ធ្វើការវិវាទ ធ្វើការបែកខ្ញែកគ្នាថា អ្នកមិនដឹងច្បាស់នូវធម្មវិន័យនេះទេ ខ្ញុំដឹងច្បាស់នូវធម្មវិន័យនេះ អ្នកដឹងច្បាស់នូវធម្មវិន័យនេះដូចម្តេចបាន អ្នកជាបុគ្គលប្រតិបត្តិខុស ខ្ញុំជាអ្នកប្រតិបត្តិត្រូវសំដីរបស់ខ្ញុំ ប្រកបដោយប្រយោជន៍ សំដីរបស់អ្នកមិនប្រកបដោយប្រយោជន៍ សំដីដែលត្រូវនិយាយមុន អ្នកបែរជានិយាយក្រោយ សំដីដែលត្រូវនិយាយក្រោយ អ្នកបែរជានិយាយមុន ពាក្យដែលអ្នកសន្សំមកអង្វែងហើយ ត្រូវខ្ញុំឲ្យវិលត្រឡប់ហើយ វាទៈ ( ទោស ) ខ្ញុំលើកដាក់លើអ្នកហើយ អ្នកជាបុគ្គលត្រូវខ្ញុំផ្ចញ់ផ្ចាល់បានហើយ អ្នកចូរត្រាច់ទៅដើម្បីដោះវាទៈចុះ ឬបើអ្នកអាចចូរដោះចុះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ពួកជនណា ប្រកាន់ទិដ្ឋិហើយ រមែងទាស់ទែងគ្នា ។

[ ៣១០ ] ពាក្យថា មួយទៀត តែងពោលថា នេះឯងជាពាក្យពិត គឺ

តែងពោល និយាយ ពណ៌នា បំភ្លឺ ថ្លែងថា លោកទៀង ពាក្យនេះ ជាពាក្យពិត ពាក្យដទៃជាមោឃៈ តែងពោល និយាយ ពណ៌នា បំភ្លឺ ថ្លែងថា លោកមិនទៀង ។បេ។ សត្វបន្ទាប់អំពីសេចក្តីស្លាប់កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន នេះជាពាក្យពិត ពាក្យដទៃជាមោឃៈ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មួយទៀត តែងពោលថា នេះជាពាក្យពិត ។

[ ៣១១ ] ពាក្យថា អ្នកចូរពោលនឹងពួកជននោះចុះ កាលដែលវាទៈកើតហើយ កិលេសទាំងឡាយណា ធ្វើជាសេនាតប កិលេសទាំងឡាយនោះមិនមានក្នុងទីនេះទេ អធិប្បាយថា អ្នកចូរនិយាយ ពាក្យផ្ទុញផ្ទាល់ ដោយពាក្យផ្ទុញផ្ទាល់ ពាក្យតបត ដោយពាក្យតបត ពាក្យវិសេស ដោយពាក្យវិសេស ពាក្យវិសេសតប ដោយពាក្យវិសេសតប ពាក្យទម្ងុះទម្ងាយ ដោយពាក្យទម្ងុះទម្ងាយ ពាក្យដោះស្រាយ ដោយពាក្យដោះស្រាយ ពាក្យកាត់ផ្តាច់ដោយពាក្យកាត់ផ្តាច់ ពាក្យមានមណ្ឌល ដោយពាក្យមានមណ្ឌលនឹងជនដែលប្រកបដោយទិដ្ឋិទាំងនោះ ( ព្រោះថា ) ជនទាំងនោះ ជាអ្នកក្បៀវក្លាតប ជាបុរសសត្រូវ ជាសត្រូវតប ជាអ្នកជាល់តប់តបនឹងអ្នក ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកចូរពោលនឹងជនទាំងនោះចុះ ។ ពាក្យថា កាលដែលវាទៈកើតហើយ កិលេសទាំងឡាយណាធ្វើជាសេនាតប កិលេសទាំងឡាយនោះមិនមានក្នុងទីនេះទេ គឺកាលដែលវាទៈកើតមាន កើតព្រមកើតឡើង កើតច្បាស់កើតប្រាកដហើយ កិលេសទាំងឡាយណា ធ្វើជាសេនាតប ជាទំនាស់ ជាចម្រូងជាសត្រូវ គប្បីធ្វើជម្លោះ ធ្វើការប្រកួតប្រកាន់ ធ្វើការទាស់ទែង ធ្វើការវិវាទ

ធ្វើការបែកខ្ញែកគ្នា កិលេសទាំងឡាយនោះ មិនមាន មិនកើត មិនមានព្រម មិនកើតមាន គឺតថាគតលះបង់ ផ្តាច់ផ្តិល រម្ងាប់ គ្របសង្កត់ មិនគួរឲ្យកើតបាន បានដុតបំផ្លាញដោយភ្លើងគឺញាណហើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកចូរពោលនឹងពួកជននោះចុះ កាលដែលវាទៈកើតហើយ កិលេសទាំងឡាយណាធ្វើជាសេនាតប កិលេសទាំងឡាយនោះមិនមានក្នុងទីនេះទេ ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

ពួកជនណាប្រកាន់ទិដ្ឋិហើយ រមែងទាស់ទែងគ្នា មួយទៀត
តែងពោលថា នេះឯងជាពាក្យពិត អ្នកចូរពោលនឹងពួកជន
នោះចុះ កាលដែលវាទៈកើតហើយ កិលេសទាំងឡាយណា
ធ្វើជាសេនាតបកិលេសទាំងឡាយនោះមិនមានក្នុងទីនេះទេ ។

[ ៣១២ ] មួយទៀត ពួកជនណា ធ្វើសេនាឲ្យវិនាសហើយ ប្រព្រឹត្តទៅ ពួកជននោះ មិនប្រទូស្តទិដ្ឋិដោយទិដ្ឋិទាំងឡាយ ម្នាលអ្នកជាបុគ្គលក្លៀវក្លាតប ការប្រកាន់ថា ក្រៃលែងក្នុងលោកនេះ នៃពួកជនណាមិនមាន អ្នកគប្បីបានអ្វីក្នុងពួកជននោះ ។

[ ៣១៣ ] ពាក្យថា មួយទៀត ពួកជនណា ធ្វើសេនាឲ្យវិនាសហើយ ប្រព្រឹត្តទៅ អធិប្បាយថា មារសេនា លោកហៅថា សេនា ។ កាយទុច្ចរិតជាមារសេនា វចីទុច្ចរិតជាមារសេនា មនោទុច្ចរិតជាមារសេនា រាគៈជាមារសេនា ទោសៈ ជាមារសេនា មោហៈជាមារសេនា កោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋេយ្យៈ ថម្ភៈ សារម្ភៈ មានះ អតិមានះ មទៈ

បមាទៈ កិលេសទាំងអស់ ទុច្ចរិតទាំងអស់ ការក្រវល់ក្រវាយទាំងអស់ សេចក្តីក្តៅក្រហាយទាំងអស់ សេចក្តីអន្ទះអន្ទែងទាំងអស់ អកុសលាភិសង្ខារទាំងអស់ ជាមារសេនា ។ សមដូចព្រះពុទ្ធដីកានេះ ដែលព្រះមានព្រះភាគទ្រង់ត្រាស់ថា កាមទាំងឡាយជាសេនាទីមួយរបស់អ្នក អរតិ លោកហៅថាជាសេនាទី ២ របស់អ្នក ។បេ។ លុះតែបុគ្គលឈ្នះសេនានោះ ទើបបានសេចក្តីសុខ ។ ព្រោះមារសេនាទាំងអស់នឹងកិលេស ធ្វើសេនាតបទាំងអស់ ពួកជនទាំងនោះ បានឈ្នះ បានផ្ចាញ់ បានកាច់បំបាក់ បានកម្ទេចកម្ទី ដោយអរិយមគ្គទាំង ៤ ជាសភាពមានមុខក្នុងទីដទៃ ហេតុនោះ លោកពោលថា ធ្វើសេនាឲ្យវិនាស ។ ពាក្យថា ពួកជនណា បានដល់ ព្រះអរហន្តខីណាស្រព ។ ពាក្យថា ប្រព្រឹត្តទៅ គឺប្រព្រឹត្តទៅ សម្រាន្តនៅ ញុំាងឥរិយាបថឲ្យប្រព្រឹត្តទៅ ញុំាងការប្រព្រឹត្តឥរិយាបថឲ្យកើត រក្សាឥរិយាបថ បំពេញឥរិយាបថ បង្គ្រប់ឥរិយាបថ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មួយទៀត ពួកជនណា ធ្វើសេនាឲ្យវិនាសហើយប្រព្រឹត្តទៅ ។

[ ៣១៤ ] ពាក្យថា មិនប្រទូស្តទិដ្ឋិ ដោយទិដ្ឋិទាំងឡាយ គឺទិដ្ឋិទាំង ៦២ ពួកជននោះ បានលះបង់ ផ្តាច់ផ្តិល រម្ងាប់ គ្របសង្កត់ ធ្វើមិនគួរឲ្យកើតបាន ដុតបំផ្លាញដោយភ្លើងគឺញាណ ពួកជននោះ មិនប្រទូស្ត មិនខ្វាំងខ្វប់ មិនបង្អៀតបង្អល់ មិនទង្គិកទិដ្ឋិដោយទិដ្ឋិទាំងឡាយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនប្រទូស្តទិដ្ឋិដោយទិដ្ឋិទាំងឡាយ ។

[ ៣១៥ ] ពាក្យថា ម្នាលអ្នកជាបុគ្គលក្លៀវក្លាតប អ្នកគប្បីបានអ្វីក្នុង

ពួកជននោះ សេចក្តីថា ម្នាលអ្នកជាបុគ្គលក្លៀវក្លាតប ជាបុរសសត្រូវ ជាសត្រូវតប ជាអ្នកដាល់តប់តប អ្នកនឹងបានអ្វីក្នុងពួកព្រះអរហន្តខីណាស្រពនោះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ម្នាលអ្នកជាបុគ្គលក្លៀវក្លា អ្នកគប្បីបានអ្វីក្នុងពួកជននោះ ។

[ ៣១៦ ] ពាក្យថា ការប្រកាន់ថាក្រៃលែងក្នុងលោកនេះនៃពួកជនណាមិនមាន គឺការប្រកាន់ ការស្ទាបអង្អែល ការចុះចិត្តស៊ប់ ការបង្អោនទៅថារបស់នេះក្រៃលែង ជាកំពូល ប្រសើរ ប្រសើរវិសេស ជាប្រធាន ដ៏ឧត្តមប្រសើរក្រៃលែងដូច្នេះ នៃពួកព្រះអរហន្តខីណាស្រពណា មិនមាន មិនមានព្រម មិនកើតមាន គឺលោកលះបង់ ផ្តាច់ផ្តិល រម្ងាប់ គ្រប់សង្កត់ មិនគួរឲ្យកើតបាន ដុតបំផ្លាញដោយភ្លើងគឺញាណហើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ការប្រកាន់ថាក្រៃលែងក្នុងលោកនេះនៃពួកជនណាមិនមាន ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

មួយទៀត ពួកជនណា ធ្វើសេនាឲ្យវិនាស ហើយប្រព្រឹត្តទៅ
ពួកជននោះ មិនប្រទូស្តទិដ្ឋិដោយទិដ្ឋិទាំងឡាយ ម្នាលអ្នកជា
បុគ្គលក្លៀវក្លាតប ការប្រកាន់ថាក្រៃលែងក្នុងលោកនេះ នៃ
ពួកជនណាមិនមាន អ្នកគប្បីបានអ្វីក្នុងពួកជននោះ ។

[ ៣១៧ ] មួយទៀត អ្នកត្រិះរិះហើយមក កាលគិតនូវទិដ្ឋិទាំងឡាយដោយចិត្ត ហើយមកជួបជុំជាគូនឹងព្រះពុទ្ធអ្នកមានប្រាជ្ញាកម្ចាត់ អ្នកមិនអាចដើម្បីដល់នូវគូទេ ។

[ ៣១៨ ] អធិប្បាយពាក្យថា មួយទៀត របស់បទថា មួយទៀត អ្នកត្រិះរិះហើយមក ត្រង់ពាក្យថា មួយទៀត គឺជាពាក្យតបទ ជាពាក្យជាប់ដោយបទ ជាពាក្យបំពេញបទ ជាពាក្យប្រជុំអក្ខរៈ ជាពាក្យសម្រួលព្យញ្ជនៈ ពាក្យថា មួយទៀត នុ៎ះជាលំដាប់បទ ។ ពាក្យថា ត្រិះរិះហើយមក គឺអ្នកកាលត្រិះរិះត្រិះរិះផ្សេងៗ ត្រិះរិះព្រម ថាអាត្មាអញនឹងមានជ័យជម្នះឬ ឬថាអាត្មាអញនឹងបរាជ័យ អាត្មាអញនឹងធ្វើការសង្កត់សង្កិតដូចម្តេច នឹងធ្វើការដោះតបតដូចម្តេច នឹងធ្វើឲ្យវិសេសដូចម្តេច នឹងធ្វើឲ្យវិសេសតបដូចម្តេច នឹងធ្វើឲ្យផ្ទុះធ្លាយដូចម្តេច នឹងធ្វើនូវការដោះស្រាយដូចម្តេច នឹងធ្វើឲ្យដាច់ដូចម្តេច នឹងធ្វើឲ្យមានមណ្ឌលដូចម្តេច ត្រិះរិះ ត្រិះរិះផ្សេងៗ ត្រិះរិះព្រមយ៉ាងនេះហើយមក ចូលមកដល់មក មកជួបជុំជាមួយនឹងតថាគត ហេតុនោះ ( ទ្រង់ត្រាស់ថា ) មួយទៀត អ្នកត្រិះរិះហើយមក ។

[ ៣១៩ ] អធិប្បាយពាក្យថា កាលគិតនូវទិដ្ឋិទាំងឡាយដោយចិត្ត ត្រង់ពាក្យថា ចិត្ត បានដល់ចិត្ត គំនិត បំណងក្នុងចិត្ត ហឫទ័យ កវង្គចិត្ត មនៈ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោវិញ្ញាណធាតុ កើតអំពីវិញ្ញាណក្ខន្ធនោះ ។ កាលគិត កាលគិតផ្សេងៗ នូវទិដ្ឋិទាំងឡាយដោយចិត្តថាលោកទៀង ឬថាលោកមិនទៀង ។បេ។ ឬថាសត្វបន្ទាប់អំពីសេចក្តីស្លាប់ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ហេតុនោះ ( ទ្រង់ត្រាស់ថា ) កាលគិតនូវទិដ្ឋិទាំងឡាយដោយចិត្ត ។

[ ៣២០ ] ពាក្យថា មគ្គជួបជុំជាគូនឹងព្រះពុទ្ធអ្នកមានប្រាជ្ញាកម្ចាត់ អ្នក

មិនអាចដើម្បីដល់នូវគួឡើយ អធិប្បាយថា បញ្ញា លោកហៅថាប្រាជ្ញាកម្ចាត់ បានខាន់ប្រាជ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញប្រពៃ ។ ប្រាជ្ញាដែលលោកហៅថា ប្រាជ្ញាកម្ចាត់ តើព្រោះហេតុអ្វី ។ កាយទុច្ចរិតបុគ្គលកម្ចាត់បង់ផង លាងផង លាងសម្អាតផង កម្ចាត់ចេញផង ដោយប្រាជ្ញានោះ ។បេ។ អកុសលាភិសង្ខារទាំងអស់ បុគ្គលកម្ចាត់បង់ផង លាងផង លាងសម្អាតផង កម្ចាត់ចេញផង ។ មួយទៀត មិច្ឆាទិដ្ឋិ បុគ្គលកម្ចាត់បង់ផង លាងផង លាងសម្អាតផង កម្ចាត់ចេញផង ដោយសម្មាទិដ្ឋិ ។បេ។ មិច្ឆាវិមុត្តិ បុគ្គលកម្ចាត់បង់ផង លាងផង លាងសម្អាតផង កម្ចាត់ចេញផង ដោយសម្មាវិមុត្តិ ។ មួយទៀត អកុសលទាំងអស់ ទុច្ចរិតទាំងអស់ សេចក្ដីក្រវល់ក្រវាយទាំងអស់ សេចក្ដីក្ដៅក្រហាយទាំងអស់ សេចក្ដីអន្ទះអន្ទែងទាំងអស់ អកុសលាភិសង្ខារទាំងអស់ បុគ្គលកម្ចាត់បង់ផង លាងផង លាងសម្អាតផង កម្ចាត់ចេញផង ដោយមគ្គមានអង្គ ៨ ដ៏ប្រសើរ ។ ព្រះមានព្រះភាគទ្រង់ចូលទៅដល់ ចូលទៅដល់ព្រម ចូលទៅជិត ចូលទៅជិតព្រម ចូលទៅកៀក ចូលទៅកៀកព្រម ប្រកបដោយធោនេយ្យធម៌ទាំងនេះ ហេតុនោះ ព្រះមានព្រះភាគព្រះនាមថា មានប្រាជ្ញាកម្ចាត់ ។ ព្រះមានព្រះភាគនោះ ទ្រង់បានកម្ចាត់រាគៈ កម្ចាត់បាប កម្ចាត់កិលេស កម្ចាត់សេចក្ដីក្ដៅក្រហាយ ហេតុនោះទ្រង់ព្រះនាមថា មានប្រាជ្ញាកម្ចាត់ ។ ពាក្យថា មកជួបជុំជាគួនឹងព្រះពុទ្ធ អ្នកមានប្រាជ្ញាកម្ចាត់ អ្នកឯងមិនអាចដើម្បីដល់នូវគួឡើយ បានសេចក្ដីថា អ្នកជាបរិព្វាជក អ្នកមានសេចក្ដីក្ងៀវក្លា មកជួប មកប្រទះ ជាគួនឹងព្រះពុទ្ធមាន

ព្រះភាគ មានប្រាជ្ញាកម្ចាត់ មិនអាចនឹងផ្គូសាកសួរចរចាទៅមក ដល់ព្រមនូវការសាកសួរទេ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ព្រោះថា អ្នកជាបរិព្វាជកមានសេចក្ដីក្ដៅក្លា ជាបុគ្គលថោកទាប ទន់ខ្សោយ ទន់ទាប លាមក អាក្រក់កម្ទេចមនុស្ស ។ ចំណែកព្រះមានព្រះភាគនោះ ជាកំពូលផង ប្រសើរផង ប្រសើរវិសេសផង ជាប្រធានផង ប្រសើរក្រៃលែងផង ។ ទន្សាយបានមកជួប មកប្រទះជាគូគ្នានឹងដំរីសារដែលចុះប្រេង មិនអាចផ្គូបានយ៉ាងណា ចចកមកជួប មកប្រទះជាគូគ្នានឹងសីហៈ ជាមិគរាជ មិនអាចផ្គូបានយ៉ាងណា កូនគោនៅតូចកំពុងបៅមេ បានមកជួប មកប្រទះជាគូគ្នានឹងគោឧសភៈដែលមានបូកដ៏មាំ មិនអាចផ្គូបាន យ៉ាងណា ក្អែកបានមកជួប មកប្រទះជាគូគ្នានឹងគ្រុឌវេនតេយ្យ មិនអាចផ្គូបានយ៉ាងណា មនុស្សចណ្ឌាល បានមកជួប មកប្រទះជាគូគ្នានឹងស្ដេចចក្រពត្តិ មិនអាចផ្គូបានយ៉ាងណា បង្សុបិសាច បានមកជួប មកប្រទះជាគូគ្នានឹងព្រះឥន្ទជាស្ដេចទេវតា មិនអាចផ្គូបានយ៉ាងណា អ្នកជាបរិព្វាជក មានសេចក្ដីក្ដៅក្លា បានមកជួប មកប្រទះជាគូគ្នានឹងព្រះពុទ្ធមានព្រះភាគ អ្នកមានប្រាជ្ញាកម្ចាត់ មិនអាចនឹងផ្គូសាកសួរ ចរចាទៅមក ដល់នូវការសាកសួរ ក៏យ៉ាងនោះដែរ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ព្រោះអ្នកជាបរិព្វាជក មានសេចក្ដីក្ដៅក្លា តែមានប្រាជ្ញាថោកទាប មានប្រាជ្ញាទន់អន់ មានប្រាជ្ញាទន់ទាប មានប្រាជ្ញាលាមក មានប្រាជ្ញាអាក្រក់ មានប្រាជ្ញាតិចតួច ។ ចំណែកព្រះមានព្រះភាគអង្គនោះ ទ្រង់មានប្រាជ្ញាច្រើន មានប្រាជ្ញាក្រាស់ មានប្រាជ្ញារីករាយ មានប្រាជ្ញារហ័ស មានប្រាជ្ញាមុត មានប្រាជ្ញាជាគ្រឿង

ទម្ងន់ទម្ងាយ ទ្រង់ឈ្លាសក្នុងប្រភេទប្រាជ្ញា ទ្រង់បែកព្រះញាណ ទ្រង់បាន សម្រេចបដិសម្ភិទា ទ្រង់ដល់នូវចតុវេសារជ្ជញ្ញាណ ទ្រទ្រង់នូវកម្លាំង ១០ ជា បុរសអាសភៈ ជាបុរសសីហៈ ជាបុរសនាគ ជាបុរសអាជានេយ្យ ជាបុរស អាចនាំទៅនូវធុរៈបាន មានអានន្តញ្ញាណ មានតេជៈមិនមានទីបំផុត មានយស មិនមានទីបំផុត ទ្រង់ស្តុកស្តម្ភ មានទ្រព្យច្រើន មានធន ជាអ្នកណែនាំទូន្មាន ប្រៀនប្រដៅ ពន្យល់ ឲ្យពិនិត្យ សម្លឹង ឲ្យរំពឹក ។ ព្រោះថា ព្រះមាន ព្រះភាគអង្គនោះ ទ្រង់ជាអ្នកញ៉ាំងមគ្គដែលមិនទាន់កើត ឲ្យកើតឡើង ញ៉ាំង មគ្គដែលមិនទាន់កើតព្រម ឲ្យកើតព្រម ប្រាប់ផ្លូវដែលគេមិនធ្លាប់ប្រាប់ ទ្រង់ ស្គាល់ផ្លូវ ជ្រាបច្បាស់នូវផ្លូវ វាងវៃក្នុងផ្លូវ ។ មួយទៀត ឥឡូវនេះ ពួក សាវ័កនៃព្រះមានព្រះភាគនោះ ជាអ្នកដើរតាមផ្លូវប្រកប ( ដោយគុណ ) ក្នុង កាលជាខាងក្រោយ ។ ព្រោះព្រះមានព្រះភាគនោះ ទ្រង់ជ្រាបហេតុ ដែល គួរជ្រាប ទ្រង់ឃើញហេតុ ដែលគួរឃើញ ព្រះអង្គមានចក្ខុ មានញាណ មាន ធម៌ ព្រះអង្គជាបុគ្គលប្រសើរ ពោលធម៌ ពោលដោយប្រការផ្សេងៗ ទ្រង់ នាំចេញនូវប្រយោជន៍ ទ្រង់ឲ្យអមតៈ ជាធម្មស្សាមី ជាតថាគត ។ ការមិន ដឹង មិនឃើញ មិនយល់ច្បាស់ មិនធ្វើឲ្យជាក់ច្បាស់ មិនប៉ះពាល់ដោយប្រាជ្ញា នៃព្រះមានព្រះភាគនោះ មិនមានទេ ។ ធម៌ទាំងអស់ ដែលអាស្រ័យអតីតៈ អនាគតនិងបច្ចុប្បន្ន រមែងមកកាន់គន្លងចំពោះមុខព្រះញាណរបស់ព្រះពុទ្ធមាន ព្រះភាគដោយអាការសព្វគ្រប់ ។ ធម្មជាតិអ្វីមួយដែលគួរដឹងត្រូវដឹង ។ ប្រយោជន៍ខ្លួនផង ប្រយោជន៍បុគ្គលដទៃផង ប្រយោជន៍ទាំងពីរផង ប្រយោជន៍

ជាបច្ចុប្បន្នផង ប្រយោជន៍ក្នុងខាងមុខផង ប្រយោជន៍រាក់ផង ប្រយោជន៍ជ្រៅផង ប្រយោជន៍លាក់ផង ប្រយោជន៍កំបាំងផង ប្រយោជន៍ដែលត្រូវនាំចេញផង ប្រយោជន៍ដែលនាំចេញហើយផង ប្រយោជន៍មិនមានទោសផង ប្រយោជន៍មិនមានកិលេសផង ប្រយោជន៍ផូរផង់ផង ប្រយោជន៍ដ៏ក្រៃលែងផង ធម្មជាតិទាំងអស់នោះ រមែងប្រព្រឹត្តទៅក្នុងខាងក្នុងពុទ្ធញ្ញាណ ។ កាយកម្មទាំងអស់ រមែងប្រព្រឹត្តទៅតាមព្រះញាណរបស់ព្រះពុទ្ធមានព្រះភាគ វចីកម្មទាំងអស់ រមែងប្រព្រឹត្តទៅតាមព្រះញាណ មនោកម្មទាំងអស់ រមែងប្រព្រឹត្តទៅតាមព្រះញាណរបស់ព្រះមានព្រះភាគ ។ ព្រះញាណរបស់ព្រះមានព្រះភាគមិនទើសទាល់ក្នុងអតីតកាល ព្រះញាណរបស់ព្រះមានព្រះភាគ មិនទើសទាល់ក្នុងអនាគតកាល ព្រះញាណរបស់ព្រះពុទ្ធមានព្រះភាគ មិនទើសទាល់ក្នុងបច្ចុប្បន្នកាល របស់ដែលត្រូវដឹងមានចំនួនប៉ុន្មាន ព្រះញាណក៏មានចំនួនប៉ុណ្ណោះ ព្រះញាណមានចំនួនប៉ុន្មាន របស់ដែលត្រូវដឹងក៏មានចំនួនប៉ុណ្ណោះ ព្រះញាណមានរបស់ដែលត្រូវដឹងជាទីបំផុត របស់ដែលត្រូវដឹងមានព្រះញាណជាទីបំផុត ។ ព្រះញាណមិនប្រព្រឹត្តកន្លងរបស់ដែលត្រូវដឹង ឯគន្លងដែលត្រូវដឹងក៏មិនកន្លងព្រះញាណ ។ ធម៌ទាំងនោះ ឋិតនៅក្នុងទីបំផុតនៃគ្នានឹងគ្នា ។ បាតស្មុគទាំងពីរដែលគេគ្របយ៉ាងជិតស្និទ្ធ បាតស្មុគខាងក្រោម រមែងមិនប្រព្រឹត្តកន្លងបាតស្មុគខាងលើ បាតស្មុគខាងលើ រមែងមិនប្រព្រឹត្តកន្លងបាតស្មុគខាងក្រោម បាតស្មុគទាំងពីរ ឋិតនៅក្នុងទីបំផុតនៃគ្នានឹងគ្នា យ៉ាងណាមិញ របស់ដែលត្រូវដឹង នឹងព្រះញាណរបស់ព្រះពុទ្ធមានព្រះភាគ ឋិតនៅក្នុង

ទីបំផុតនៃគ្នានឹងគ្នា ក៏យ៉ាងនោះដែរ របស់ដែលត្រូវដឹងមានចំនួនប៉ុន្មាន ព្រះញាណក៏មានចំនួនប៉ុណ្ណោះ ព្រះញាណមានចំនួនប៉ុន្មាន របស់ដែលត្រូវដឹង ក៏មានចំនួនប៉ុណ្ណោះ ព្រះញាណមានរបស់ដែលត្រូវដឹងជាទីបំផុត របស់ដែលត្រូវដឹងមានព្រះញាណជាទីបំផុត ព្រះញាណមិនប្រព្រឹត្តកន្លងរបស់ដែលត្រូវដឹង ឯគន្លងដែលត្រូវដឹង ក៏មិនកន្លងព្រះញាណ ធម៌ទាំងនោះ ឋិតនៅក្នុងទីបំផុតនៃគ្នានឹងគ្នា ។ ព្រះញាណរបស់ព្រះពុទ្ធមានព្រះភាគប្រព្រឹត្តទៅក្នុងធម៌ទាំងពួង ធម៌ទាំងអស់ ជាប់ចំពោះដោយការនឹក ជាប់ដោយការប្រាថ្នា ជាប់ដោយការធ្វើទុកក្នុងចិត្ត ជាប់ដោយចិត្តុប្បាទរបស់ព្រះពុទ្ធមានព្រះភាគ ។ ព្រះញាណរបស់ព្រះពុទ្ធមានព្រះភាគប្រព្រឹត្តទៅក្នុងសត្វទាំងអស់ ។ ព្រះមានព្រះភាគទ្រង់ជ្រាបអធ្យាស្រ័យ ជ្រាបអនុស័យ ជ្រាបចរិត ជ្រាបការចុះចិត្តស៊ប់របស់សត្វទាំងអស់ ជ្រាបពួកសត្វមានធូលីក្នុងភ្នែកតិច មានធូលីក្នុងភ្នែកច្រើន មានឥន្ទ្រិយក្លៀវក្លា មានឥន្ទ្រិយទន់ មានអាការល្អ មានអាការអាក្រក់ ឲ្យដឹងដោយងាយ ឲ្យដឹងដោយលំបាក មានភ័ព្វនិងឥតភ័ព្វ ។ លោកព្រមទាំងទេវលោក មារលោក ព្រហ្មលោក ពួកសត្វព្រមទាំងសមណព្រាហ្មណ៍ មនុស្សជាសម្មតិទេពនិងមនុស្សដ៏សេស រមែងប្រព្រឹត្តទៅខាងក្នុងព្រះពុទ្ធញាណ ។ ពួកត្រីនិងអណ្តើកណាមួយ រាប់យកត្រីឈ្មោះតិមិតិមិង្គល ដោយហោចទៅ រមែងប្រព្រឹត្តទៅក្នុងខាងក្នុងមហាសមុទ្ទយ៉ាងណា លោកព្រមទាំងទេវលោក មារលោក ព្រហ្មលោក ពួកសត្វព្រមទាំងសមណព្រាហ្មណ៍ មនុស្សជាសម្មតិទេពនិងមនុស្សដ៏សេស រមែងប្រព្រឹត្តទៅក្នុងខាងក្នុងពុទ្ធញាណយ៉ាង

នោះដែរ ។ ពួកបក្សីណាមួយ រាប់យកគ្រុឌវេនតេយ្យជោយទីបំផុត រមែង ប្រព្រឹត្តទៅក្នុងប្រទេសនៃអាកាសយ៉ាងណា ជនទាំងឡាយណា មានប្រាជ្ញា ស្មើនឹងព្រះសារីបុត្តជនទាំងនោះ រមែងប្រព្រឹត្តទៅក្នុងប្រទេសនៃពុទ្ធញាណ យ៉ាងនោះដែរ ព្រះពុទ្ធញាណផ្សាយទៅគ្របសង្កត់នូវប្រាជ្ញានៃទេវតានិងមនុស្ស ។ ទោះបីជនពួកណា ជាខត្តិយបណ្ឌិតក្តី ព្រាហ្មណបណ្ឌិតក្តី គហបតិបណ្ឌិត ក្តី សមណបណ្ឌិតក្តី មានបញ្ញាល្អិត ស្គាល់វាទៈរបស់ជនដទៃ កាលទម្លាយ ទិដ្ឋិទាំងឡាយរបស់ជនដទៃ ដោយប្រាជ្ញារបស់ខ្លួន ទំនងដូចជាខ្មាន់ធ្នូស្ទាត់ បាញ់រោមទ្រាយ ពួកជននោះ តាក់តែងរឿយៗនូវប្រស្នា រួចចូលទៅសួរព្រះ តថាគត ។ ប្រស្នាទាំងនោះ ដែលព្រះមានព្រះភាគទ្រង់សម្តែងដោះស្រាយ ហើយផង ជាប្រស្នាមានហេតុ ដែលសម្តែងចេញហើយផង ជាប្រស្នាដែល ដាក់ហើយផង ។ បណ្ឌិតទាំងនោះ បានសម្រេច ( សម្បត្តិជាសាវ័ក ឬ ឧបាសកដោយការដោះស្រាយ ) របស់ព្រះមានព្រះភាគ លំដាប់នោះ ព្រះ មានព្រះភាគ ទ្រង់រុងរឿងដោយបញ្ញាក្នុងកណ្តាលបរិស័ទនោះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មកជួបជុំជាគូនឹងព្រះពុទ្ធ ព្រះអង្គជានា អ្នកមិនអាច ដើម្បីជល់នូវគូទេ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

មួយទៀត អ្នកត្រិះរិះហើយមក កាលគិតនូវទិដ្ឋិទាំងឡាយ
ដោយចិត្ត ហើយមកចួបជុំជាគូនឹងព្រះពុទ្ធ ទ្រង់មានប្រាជ្ញា
កម្ចាត់ អ្នកឯងមិនអាចដើម្បីជល់នូវគូទេ ។

**ចប់ បសូរសុត្តនិទ្ទេសទី ៨**

# អដ្ឋកថា

# បសូរសុត្តនិទ្ទេស ទី ៨

[ ២៦៨ ] ក្នុងបសូរសុត្តនិទ្ទេសទី ៨ គប្បីជ្រាបសេចក្តីសង្ខេបនៃគាថាដំបូងសិន ។ មេលទ្ធិទាំងនេះ រមែងពោលថា សេចក្តីបរិសុទ្ធរមែងមានក្នុងធម៌នេះប៉ុណ្ណោះ សំដៅយកទិដ្ឋិរបស់ខ្លួន តែមិនបានពោលសេចក្តីបរិសុទ្ធវិសេសក្នុងធម៌ដទៃទេ ព្រោះហេតុដែលសមណព្រាហ្មណ៍ជាច្រើន អាស្រ័យសាស្តារបស់ខ្លួនជាដើម ជាអ្នកពោលថាស្អាតក្នុងសាស្តារបស់ខ្លួនជាដើមនោះឯង យ៉ាងនេះថា វាទៈនេះស្អាត តាំងមាំក្នុងបច្ចេកសច្ចៈថា លោកទៀងជាដើម ។

[ ២៧០ ] បទថា **សព្វេ បវាទេ ខិបន្តិ** សេចក្តីថា រមែងបោះបង់លទ្ធិដទៃទាំងអស់ ។ បទថា **ឧក្ខិបន្តិ** សេចក្តីថា បោលទៅឆ្ងាយ ។ បទថា **បរិក្ខិបន្តិ** សេចក្តីថា បោលទៅដោយជុំវិញ ។

[ ២៧១ ] បទថា **សុភវាទា** ជាមាតិកានៃនិទ្ទេស ។ បទថា **សោភណ-វាទា** បានដល់ ពោលថា ស្អាតយ៉ាងនេះ ។ បទថា **បណ្ឌិតវាទា** សេចក្តីថា ពោលយ៉ាងនេះថា ពួកយើងជាបណ្ឌិត ។ បទថា **ធីរវាទា** បានដល់ពោលថា ពួកយើងពោលវាទៈដែលប្រាសចាកទោស ។ បទថា **ញាយវាទា** បានដល់ ពោលថា ពួកយើងពោលនូវវាទៈដែលត្រឹមត្រូវ ។ បទថា **ហេតុ-វាទា** បានដល់ ពោលថា ពួកយើងពោលវាទៈដែលប្រកបដោយហេតុ ។ បទថា **លក្ខណវាទា** បានដល់ ពោលថា ពួកយើងពោលនូវវាទៈ ដែលគួរ

*កំណត់ ។ បទថា* **ការណវាទា** *បានដល់ ពោលថា ពួកយើងពោលវាទៈដែលប្រកបដោយឧទាហរណ៍ ។ បទថា* **ឋានវាទា** *បានដល់ ពោលថា ពួកយើងពោលនូវវាទៈដែលមិនអាចចៀសវាងបាន ។*

*[ ២៧២ ] បទថា* **និវិដ្ឋា** *សេចក្តីថា ចូលទៅខាងក្នុង ។ បទថា* **បតិដ្ឋិតា** *សេចក្តីថា តាំងនៅក្នុងបច្ចេកសច្ចៈនោះឯង ឈ្មោះថាតាំងមាំ ដោយប្រការដូច្នេះឯង ។*

*[ ២៧៣ ] គាថាទី ២ ថា* **តេ វាទកាមា** *ជាដើម គប្បីជ្រាបដូចតទៅនេះថា បណ្តាបទទាំងនោះ បទថា* **ពាលំ ទហន្តិ មិថុ អញ្ញមញ្ញំ** *សេចក្តីថា ជនទាំង ២ ពួកចោទគ្នានឹងគ្នាថាជាពាល គឺរមែងឃើញ រមែងពោលដោយភាពជាពាល ជាពាលយ៉ាងនេះថា បុគ្គលនេះជាពាល បុគ្គលនេះជាពាល ។*

*បទថា* **តេ អញ្ញសិតា កថោជ្ជំ** *សេចក្តីថា សមណព្រាហ្មណ៍ទាំងនោះអាស្រ័យសាស្តាជាដើម ពោលនូវជម្លោះដល់គ្នានឹងគ្នា ។*

*បទថា* **បសំសកាមា កុសលាវទានា** *សេចក្តីថា ទាំង ២ ពួកជាអ្នកមានសេចក្តីត្រូវការភាពសរសើរ មានការសម្គាល់យ៉ាងនេះថា ពួកយើងពោលថា ខ្លួនជាបុគ្គលឈ្លាស គឺពោលថាជាបណ្ឌិត ។*

*[ ២៧៤ ] បទថា* **វាទត្ថិកា** *សេចក្តីថា មានសេចក្តីត្រូវការដោយវាទៈ ។ បទថា* **វាទាធិប្បាយា** *សេចក្តីថា មានការប្រាថ្នានូវវាទៈ ។ បទថា* **វាទ-បុរេក្ខារា** *សេចក្តីថា ធ្វើនូវវាទៈនោះឯងទុកអំពីខាងមុខត្រាច់ទៅ ។ បទថា* **វាទបរិយេសនំ ចរន្តា** *សេចក្តីថា ត្រាច់ស្វែងរកវាទៈនោះឯង ។*

បទថា **វិគ្គយ្ហ** សេចក្តីថា ចូលទៅហើយ ។ បទថា **ឱគ្គយ្ហ** សេចក្តីថា ឈមចុះហើយ ។ បទថា **អជ្ឈោគាហេត្វា** សេចក្តីថា លិចហើយ ។ បទថា **បវិសិត្វា** សេចក្តីថា ទៅខាងក្នុង ។

[ ២៧៦ ] បទថា **អនោជវន្តី** សេចក្តីថា មិនមានឱជៈ អធិប្បាយថា វៀរចាកតេជះ ។ បទថា **សា កថា** បានដល់ វាចានេះ ។ បទថា **កថោជ្ជំ វទន្តិ** សេចក្តីថា ពោលពាក្យដែលមិនមានតេជះ ។

[ ២៧៨ ] បណ្តាពួកបុគ្គលដែលពោលយ៉ាងនេះ កំណត់ជាបុគ្គលម្នាក់ប៉ុណ្ណោះ ទើបមានគាថាថា **យុត្តោ កថាយំ** ជាដើម ។ បណ្តាបទទាំងនោះ បទថា **យុត្តោ កថាយំ** សេចក្តីថា ជាអ្នកខ្វល់ខ្វាយក្នុងការពោលវាទៈ ។ បទថា **បសំសមិច្ឆំ វិនិឃាតិ ហោតិ** សេចក្តីថា កាលប្រាថ្នានូវការសរសើរដើម្បីខ្លួន មុនអំពីពោលរមែងជាអ្នកសង្ស័យក្នុងពាក្យ ជាអ្នករាវែកចិត្តដោយន័យជាដើមថា អាត្មាអញនឹងសង្កត់សង្កិនបុគ្គលនេះដូចម្តេចហ្ន៎ ។

បទថា **អថាយាតស្មឹ** សេចក្តីថា ក្នុងកាលវាទៈរបស់ខ្លួនត្រូវបុគ្គលពិចារណាបញ្ហាជំទាស់ឲ្យធ្លាក់ទៅដោយន័យជាដើមថា អ្នកពោលពាក្យប្រាសចាកអត្ថពោលពាក្យប្រាសចាកព្យញ្ជនៈ ។

បទថា **និន្ទាយ សោ កុប្បតិ** សេចក្តីថា ក្នុងកាលវាទៈត្រូវគេជំទាស់នរជននោះរមែងអាក់អន់ ព្រោះការតិះដៀលដែលកើតឡើង ។

បទថា **រន្ធមេសី** សេចក្តីថា ស្វែងរកកំហុសរបស់អ្នកដទៃនោះឯង ។

[ ២៨០ ] បទថា **ថោមនំ** បានដល់ ពាក្យពោលសរសើរ ។ បទថា **កិត្តី**

*បានដល់ ធ្វើឲ្យប្រាកដ ។ បទថា* **វណ្ណហារិយំ** *សេចក្តីថា សរសើរនូវគុណ ។ បទថា* **បុព្វេ សហាថា** *សេចក្តីថា មុននឹងឆ្លើយឆ្លងគ្នានោះឯង ។ ឈ្មោះថា* **កថំកថី** *ព្រោះអត្តវិគ្គហៈថា សេចក្តីសង្ស័យថា នេះដូចម្តេច មានដល់បុគ្គលនោះ ។*

*បទថា* **ជយោ នុ ខោ មេ** *សេចក្តីថា យើងឈ្នះ ។ បទថា* **កថំ និគ្គហំ** *សេចក្តីថា សង្កត់ដោយប្រការណាមួយ ។ បទថា* **បដិក្កម្មំ ករិស្សាមិ** *សេចក្តីថា យើងនឹងធ្វើលទ្ធិរបស់យើងឲ្យបរិសុទ្ធ ។ បទថា* **វិសេសំ** *សេចក្តីថា ក្រៃលែងពេក ។ បទថា* **បដិវិសេសំ** *សេចក្តីថា វិសេសរឿយៗ ។ បទថា* **អាវេឋិយំ ករិស្សាមិ** *សេចក្តីថា នឹងធ្វើនូវការចងទុក ។ បទថា* **និព្វេឋិយំ** *សេចក្តីថា ចាក់ធ្លុះ គឺការផុតការចេញទៅរបស់យើង ។ បទថា* **ឆេទំ** *សេចក្តីថា ការកាត់នូវវាទៈ ។ បទថា* **មណ្ឌលំ** *បានដល់ ការធ្វើឲ្យមានជុំវិញវាទៈ ។*

*[ ២៨១ ] បទថា* **ចារិសជ្ជា** *សេចក្តីថា បុគ្គលដែលចូលទីប្រជុំ ។ បទថា* **ចាសនិកា** *សេចក្តីថា ជាអ្នកមានសេចក្តីករុណា ។ បទថា* **អបហារន្តិ** *សេចក្តីថា រមែងហាម ។ បទថា* **អត្ថាបគតំ** *សេចក្តីថា ប្រាសចាកអត្ថ អធិប្បាយថា មិនមានអត្ថ ។ បទថា* **អត្ថតោ អបហារន្តិ** *សេចក្តីថា រមែងហាមព្រោះអត្ថ ។ បទថា* **អត្ថោ តេ ទុន្នីតោ** *សេចក្តីថា អ្នកមិនបាននាំនូវអត្ថចូលទៅដោយប្រពៃ ។ បទថា* **ព្យញ្ជនន្តេ ទុរោបិតំ** *សេចក្តីថា អ្នកតាំងនៅក្នុងព្យញ្ជនៈមិនល្អ ។ បទថា* **និគ្គហោ តេ អកតោ** *សេចក្តីថា អ្នកមិនធ្វើនូវការសង្កត់សង្កិន ។ បទថា* **បដិកម្មន្តេ ទុក្កដំ** *សេចក្តីថា ការតាំងលទ្ធិ*

របស់ខ្លួន អ្នកធ្វើមិនល្អ គឺធ្វើមិនរៀបរយ ។ បទថា **ទុក្កថិតំ** សេចក្តីថា អ្នកពោលមិនត្រឹមត្រូវ ។ បទថា **ទុព្ភណិតំ** សេចក្តីថា កាលពោល ក៏ពោលមិនល្អ ។ បទថា **ទុល្លបិតំ** សេចក្តីថា ចន្លោលបង្ហាញមិនប្រពៃ ។ បទថា **ទុរុត្តំ** សេចក្តីថា ពោលដោយប្រការដទៃ ។ បទថា **ទុព្ភាសិតំ** សេចក្តីថា ពោលខុសប្រក្រតី ។

[ ២៨២ ] បទថា **និន្ទាយ** សេចក្តីថា ព្រោះការតិះដៀល ។ បទថា **គរហាយ** សេចក្តីថា ពោលទោស ។ បទថា **អកិត្តិយា** សេចក្តីថា ពោលវត្ថុដែលមិនមែនជាគុណ ។ បទថា **អវណ្ណហារិកាយ** សេចក្តីថា ការមិនសរសើរគុណ ។ បទថា **កុប្បតិ** សេចក្តីថា លះនូវប្រក្រតីភាពហើយញាប់ញ័រ ។ បទថា **ព្យាបជ្ជតិ** សេចក្តីថា ដល់នូវភាវៈខូចដោយអំណាចនៃទោសៈ ។ បទថា **បតិត្ថីយតិ** សេចក្តីថា ដល់នូវការបង្អៀតចង្អល់ ដោយអំណាចនៃសេចក្តីក្រោធ ។

បទថា **កោបញ្ច** បានដល់ សេចក្តីក្រោធ ។ បទថា **ទោសញ្ច** បានដល់ សេចក្តីប្រទូស្ត ។ បទថា **អបច្ចយញ្ច** សេចក្តីថា អាការមិនត្រេកអរ ។ បទថា **បាតុករោតិ** សេចក្តីថា ធ្វើឲ្យប្រាកដ ។ បទថា **រន្ធមេសី** សេចក្តីថា ស្វែងរកចន្លោះ ។ បទថា **វិរន្ធមេសី** សេចក្តីថា ស្វែងរកឱកាស ។ បទថា **អបរន្ធមេសី** សេចក្តីថា នាំនូវគុណចេញហើយ ស្វែងរកទោសប៉ុណ្ណោះ ។ បទថា **ខលិតមេសី** សេចក្តីថា ស្វែងរកនូវការភ្លាំងភ្លាត់ ។ បទថា **គឡិ-តមេសី** សេចក្តីថា ស្វែងរកនូវការធ្លាក់ទៅ ។ បាឋៈថា **យដ្ឋិតមេសី** ក៏មាន

សេចក្ដីនៃបាឋៈនោះថា ស្វែងរកនូវការគ្រប់សង្កត់ ។ បទថា **វិវរមេសី** សេចក្ដីថា ស្វែងរកទោស ។

[ ២៨៣ ] ម្យ៉ាងទៀត បុគ្គលនោះមិនមែនក្រោធតែម្យ៉ាង តែគប្បីបន្ថែមទៀតនូវគាថាថា **យមស្ស វាទំ** ជាដើម ។ បណ្ដាបទទាំងនោះ បទថា **បរិហីនមាហុ អបាហតំ** សេចក្ដីថា រមែងពោលថាអាក្រក់ ជំទាស់ឲ្យធ្លាក់ទៅដោយអត្ថនិងព្យញ្ជនៈជាដើម ។ បទថា **បរិទេវតិ** សេចក្ដីថា បន្ទាប់អំពីនោះ បុគ្គលនោះរវើរវាយដល់និមិត្តដោយន័យថា វត្ថុដែលអញគិតហើយត្រឡប់ជាដទៃជាដើម ។

បទថា **សោចតិ** សេចក្ដីថា រមែងសោកប្រារព្ធថា គេឈ្នះហើយជាដើម ។ បទថា **ឧបច្ចគា មន្តិ អនុត្ថុនាតិ** សេចក្ដីថា រវើរវាយក្រៃលែងដោយន័យជាដើមថា គេឈានកន្លងអញដោយវាទៈ ។

[ ២៨៤ ] បទថា **បរិហាបិតំ** សេចក្ដីថា មិនជាវាទៈចម្រើន ។

[ ២៨៦ ] បទថា **អញ្ញំ មយា អាវជ្ជិតំ** សេចក្ដីថា ហេតុដទៃដែលអញគិតក៏ធ្លាក់ទៅ ។ បទថា **ចិន្តិតំ** សេចក្ដីថា ពិចារណា ។ បទថា **មហាបក្ខោ** សេចក្ដីថា ឈ្មោះថា **មហាបក្ខោ** ព្រោះអត្ថថា មានពួកញាតិច្រើន ។ បទថា **មហាបរិសោ** សេចក្ដីថា មានបរិស័ទដោយភាពជាបរិវារច្រើន ។ បទថា **មហាបរិវារោ** សេចក្ដីថា មានទាសៈនិងទាសីជាបរិវារច្រើន ។ បទថា **បរិសាចាយំ វគ្គា** សេចក្ដីថា បរិស័ទនេះជាពួកៗ មិនមូលតែមួយ ។ បទថា **បុនភញ្ជិស្សាមិ** សេចក្ដីថា នឹងធ្វើឲ្យបែកទៀត ។

[ ២៨៨ ] ក្នុងបទថា **ឯកេ វិវាទា សមណេសុ** នេះ ពួកបរិព្វាជកខាងក្រៅ ហៅថាសមណៈ ។ បទថា **ឯកេសុ ឧគ្ឃាតិនិឃាតិ ហោតិ** សេចក្ដីថា កាលដល់នូវភាពដែលចិត្តត្រេកអរ ឬមិនត្រេកអរដោយអំណាចនៃការចាញ់និងការឈ្នះជាដើម ឈ្មោះថា ត្រេកអរនិងមិនត្រេកអរ រមែងមានព្រោះវាទៈទាំងនេះ ។ បទថា **វិរមេ កថោជ្ជំ** សេចក្ដីថា គប្បីលះនូវការទាស់ទែងចេញ ។

បទថា **ន ហញ្ញទត្ថត្ថិ បសំសលាភា** សេចក្ដីថា ព្រោះថាប្រយោជន៍ដទៃចាកការបាននូវសេចក្ដីសរសើរក្នុងវិវាទនេះរមែងមិនមាន ។

[ ២៩២ ] បទថា **ឧត្តានោ វា** សេចក្ដីថា មិនជ្រៅ ដូចក្នុងប្រយោគថា ម្នាលភិក្ខុទាំងឡាយ កាមគុណនេះមាន ៥ យ៉ាង ជាដើម ។

បទថា **គម្ភីរោ** សេចក្ដីថា ចូលទៅបានលំបាក តាំងនៅមិនបាន ដូចបដិច្ចសមុប្បាទ ។ បទថា **គូឡ្ហោ** សេចក្ដីថា បិទបាំងទុក ដូចក្នុងប្រយោគថា ម្នាលនន្ទ អ្នកចូរត្រេកអរចុះ តថាគតជាអ្នកធានាឲ្យអ្នកជាដើម ។

បទថា **បដិច្ឆន្នោ** សេចក្ដីថា មិនប្រាកដ ដូចក្នុងប្រយោគថា បុគ្គលសម្លាប់តណ្ហាដូចជាមាតាផង សម្លាប់អស្មិមានះដូចបិតាផង ជាដើម ។

បទថា **នេយ្យោ វា** សេចក្ដីថា ដែលគួរពោលលម្អិតចេញមក ដូចក្នុងប្រយោគថា នរជនណាមិនជឿអ្នកដទៃផង ស្គាល់ព្រះនិព្វានផង ជាដើម ។

បទថា **នីតោ វា** សេចក្ដីថា គប្បីពោលដោយទំនងនៃបាលី ដែលព្រះមានព្រះភាគតាំងទុក ដូចក្នុងប្រយោគថា ម្នាលភិក្ខុទាំងឡាយ អរិយវង្ស ៤

*យ៉ាងនេះ ជាដើម ។ បទថា* **អនវជ្ជោ វា** *សេចក្តីថា ប្រយោជន៍ដែលប្រាស ចាកទោស ដូចក្នុងប្រយោគថា ធម៌ទាំងឡាយជាកុសលជាដើម ។*

*បទថា* **និក្កិលេសោ វា** *សេចក្តីថា វៀរចាកកិលេសដោយវិបស្សនា ។ បទថា* **វោទានោ វា** *សេចក្តីថា បរិសុទ្ធិដូចលោកុត្តរ ។ បទថា* **បរមត្ថោ វា** *សេចក្តីថា ប្រយោជន៍ឧត្តម គឺប្រយោជន៍ដែលជាប្រយោជន៍ឧត្តម ដូចជាខន្ធ ធាតុ អាយតនៈ និងព្រះនិព្វាន ។*

*[ ២៩៣ ] គាថាទី ៦ មានសេចក្តីដូចតទៅនេះថា ព្រោះប្រយោជន៍ដទៃចាកការបានទូវការសរសើររមែងមិនមាន ដូច្នោះ កាលបានលាភក្រៃលែងរមែងបានទទួលនូវការសរសើរ ព្រោះទិដ្ឋិនោះថា បុគ្គលនេះល្អ ក៏សម្តែងវាទៈនោះក្នុងកណ្តាលបរិស័ទ បន្ទាប់អំពីនោះ ចូលដល់នូវការត្រេកអរ ឬញញឹមញញែម រមែងសើចដោយសភាពនៃការឈ្នះនោះ និងប៉ោងឡើងដោយមានះ ព្រោះហេតុអ្វី ព្រោះសម្រេចប្រយោជន៍ គឺការឈ្នះនោះ តាមដែលចិត្តប្រាថ្នា ។*

*[ ២៩៥ ] បទថា* **ឧន្នមិត្វា** *សេចក្តីថា ឲ្យពេញ ។ បទថា* **ព្រូហយិត្វា** *សេចក្តីថា ឲ្យចម្រើន និទ្ទេសនៃគាថានេះ មានអត្ថងាយយល់ហើយ ។*

*[ ២៩៨ ]ម្យ៉ាងទៀត កាលប៉ោងឡើងយ៉ាងនេះ គប្បីជ្រាបគាថាថា* **យា ឧណ្ណតី** *ជាដើម ដូចតទៅនេះថា*

*បណ្តាបទទាំងនោះ បទថា* **មានាតិមានំ វទតេ បនេសោ** *សេចក្តីថា បុគ្គលនោះមិនដឹងថា ការប៉ោងឡើងនោះជាភូមិសម្រាប់ញាំញី ទើបពោលនូវការប្រកាន់ខ្លួននិងការមើលងាយ និទ្ទេសនៃគាថានេះ មានអត្ថងាយយល់*

ហើយ ។

[ ៣០៣ ] កាលសម្តែងទោសក្នុងវាទៈយ៉ាងនេះហើយ ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់មិនទទួលវាទៈរបស់បរិព្វាជកនោះ ទើបត្រាស់គាថាថា **សូរោ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **រាជខាទាយ** បានដល់ ដោយរបស់គួរទំពាដែលជារបស់ព្រះរាជទាន អធិប្បាយថា កត្តាហារ ។ បទថា **អភិគជ្ជមេតិ បដិសូរមិច្ឆំ** សេចក្តីថា ព្រះមានព្រះភាគទ្រង់សម្តែងថា អ្នកក្លៀវក្លានោះ កាលប្រាថ្នាជួបបុគ្គលក្លៀវក្លាដែលជាសត្រូវបន្លឺ ( សីហនាទ ) រមែងបានជួបយ៉ាងណា មេលទ្ធិរមែងជួបមេលទ្ធិ ក៏យ៉ាងនោះ ។

បទថា **យេនេវ សោ តេន បលេហិ** សេចក្តីថា បុគ្គលក្លាហានដែលជាសត្រូវចំពោះបុគ្គលនោះ មានទីណា ចូរអ្នកទៅទីនោះ ។ បទថា **បុព្វេវ នត្ថិ យទិទំ យុធាយ** សេចក្តីថា ព្រះមានព្រះភាគទ្រង់សម្តែងថា សេចក្តីលំបាកនេះគប្បីមានដើម្បីការច្បាំង សេចក្តីលំបាកដើម្បីការច្បាំងក្នុងកាលមុននោះ ក្នុងទីនេះរមែងមិនមាន គឺសេចក្តីលំបាកនោះ តថាគតលះហើយត្រង់មណ្ឌលពោធិព្រឹក្សនោះឯង ។

[ ៣០៤ ] បទថា **សូរោ** ជាមាតិកានៃនិទ្ទេស អធិប្បាយថា បុគ្គលមានចិត្តល្អ ឈ្មោះថា **សូរោ** អធិប្បាយថា លះបង់ជីវិត ថ្វាយជីវិត ។ បទថា **វីរោ** បានដល់ មានសេចក្តីប្រឹងប្រែង ។ បទថា **វិក្កន្តោ** សេចក្តីថា ចូលកាន់សង្គ្រាម ។ បទថា **អភិរុ** ជាដើម មានន័យដូចពោលហើយនោះឯង ។

បទថា **បុដ្ឋោ** ជាមាតិកានៃនិទ្ទេស ។ បទថា **ចោទិតោ** សេចក្តីថា ធ្វើឲ្យមានកម្លាំង ។ បទថា **អាចាទិតោ** សេចក្តីថា ចូលទៅ ចិញ្ចឹម ។ បទថា **បដិចាទិតោ វេឋិតោ** សេចក្តីថា ឲ្យបម្រើនក្រៃលែងឡើងៗ ។

[ ៣០៥ ] បទថា **គជ្ជន្តោ** សេចក្តីថា គ្គាំគ្គង ដោយបទនៃមនុស្សល្ងង់ ។ បទថា **ឧគ្គជ្ជន្តោ** សេចក្តីថា ធ្វើនូវការហ៊ោកញ្ជៀវ ។ បទថា **អភិគជ្ជន្តោ** សេចក្តីថា ធ្វើនូវសីហនាទ ។ បទថា **ឯតិ** សេចក្តីថា រមែងមក ។ បទថា **ឧបេតិ** សេចក្តីថា ទៅជិតជាងនោះ ។ បទថា **ឧបគច្ឆតិ** សេចក្តីថា ទៅឆ្ងាយជាងនោះហើយមិនត្រឡប់ ។ បទថា **បដិសូរំ** បានដល់ មិនមានការខ្លាច ។ បទថា **បដិបុរិសំ** សេចក្តីថា បុរសដែលជាសត្រូវ ។ បទថា **បដិ-សត្តុំ** សេចក្តីថា ជាសត្រូវឈរចំពោះមុខ ។ បទថា **បដិមល្លំ** សេចក្តីថា ជាអ្នកប្រយុទ្ធប្រឆាំង ។ បទថា **ឥច្ឆន្តោ** បានដល់ សង្ឃឹម ។

[ ៣០៦ ] បទថា **បលេហិ** សេចក្តីថា ចូរដើរទៅ ។ បទថា **វជ** សេចក្តីថា ចូរកុំឈរ ។ បទថា **គច្ឆ** សេចក្តីថា ចូលទៅរកក្បែរៗ ។ បទថា **អភិក្កម** សេចក្តីថា ចូរធ្វើនូវការប្រឹងប្រែង ។

[ ៣០៧ ] បទថា **ពោធិយា មូលេ** សេចក្តីថា ទីជិតមហាពោធិព្រឹក្ស ។ បទថា **យេ បដិសេធិកា កិលេសា** បានដល់ កិលេសពួកណាដែលធ្វើនូវភាពជាបដិបក្ខ ។ បទថា **បដិលោមកា** សេចក្តីថា ធ្វើនូវការវិនាស ។ បទថា **បដិកណ្តកកា** សេចក្តីថា ធ្វើនូវការចាក់ទម្លុះ ។ បទថា **បដិបក្ខកា** សេចក្តីថា ធ្វើជាសត្រូវ គាថាដ៏សេសអំពីនេះ មានអត្ថទាក់ទងប្រាកដហើយ

នោះឯង ។

[ ៣០៨ ] បណ្ដាបទទាំងនោះ បទថា **វិវាទយន្តិ** សេចក្ដីថា រមែងប្រកែកប្រណាំងគ្នា ។ បទថា **បដិសេនិកត្តា** សេចក្ដីថា កិលេសដែលធ្វើនូវការប្រឆាំងគ្នា ។

[ ៣០៩ ] ពាក្យដែលប្រជែងគ្នាដោយន័យថា អ្នកមិនដឹងនូវធម្មវិន័យនេះជាដើម ឈ្មោះថា វិវាទ ។ បទថា **សហិតមេ** សេចក្ដីថា ពាក្យរបស់ខ្ញុំប្រកបដោយប្រយោជន៍ ។ បទថា **អសហិតន្តេ** សេចក្ដីថា ពាក្យរបស់អ្នកមិនប្រកបដោយប្រយោជន៍ ។ បទថា **អធិចិណ្ណន្តេ វិបរាវត្តំ** សេចក្ដីថា ពាក្យដែលប្រើប្រចាំនោះ ជាពាក្យស្ទាត់ជំនាញដោយអំណាចប្រើអស់កាលយូរ ពាក្យនោះ សាបរលាបទៅហើយ ព្រោះអាស្រ័យវាទៈរបស់ខ្ញុំ ។

បទថា **អារោបិតោ តេ វាទោ** សេចក្ដីថា ខ្ញុំលើកទោសអ្នកទុកអំពីខាងលើ ។ បទថា **ចរ វាទប្បមោក្ខាយ** សេចក្ដីថា ចូរអ្នកកាន់យកកញ្ចប់បាយចូលទៅរកអ្នកទាំងនោះ ត្រាច់ស្វែងរកឲ្យក្រៃលែងឡើង ដើម្បីដោះវាទៈ ឬចូរដោះស្រាយ ។ម្យ៉ាងទៀត ចូរអ្នកដោះខ្លួនឲ្យផុតចាកទោសដែលខ្ញុំលើកឡើង ។ បទថា **សចេ បហោសិ** សេចក្ដីថា បើអ្នកអាច ។

[ ៣១១ ] បទថា **អាវេឋិយាយ អាវេឋិយំ** សេចក្ដីថា លើកវាទៈឲ្យត្រឡប់ដោយការចងឲ្យត្រឡប់ ។ បទថា **និព្ពេឋិយាយ និព្ពេឋិយំ** សេចក្ដីថា លើកវាទៈដោយការដោះ ដោយការដោះចាកទោស ។ បទនេះថា **ជេនេន ជេធំ** គប្បីប្រកបសេចក្ដីដែលគួរប្រកបព្រោះមានន័យដូចពោលហើយខាងដើមនោះ

ឯង ។

[ ៣១២ ] បទថា **វិសេនិកត្វា** សេចក្ដីថា ញុំាំងកងទ័ពកិលេសឲ្យវិនាស ។ បទថា **កឹ លភេថោ** បានដល់ អ្នកគប្បីបានការឆ្លើយអ្វី ។ ព្រះមានព្រះភាគត្រាស់ហៅបរិព្វាជកនោះថា **បសូរ** ។ គាថានេះថា **យេសីធ នត្ថិ** ក៏មាននិទ្ទេស ក៏មានអត្ថងាយយល់ដូចគ្នា ។

[ ៣១៧ ] បទថា **បវិតក្កំ** សេចក្ដីថា វិតក្កថា អញនឹងមានជ័យជម្នះ ឬហ្នឹជាដើម ។ បទថា **ធោនេន យុគំ សមាគមា** សេចក្ដីថា ដល់នូវការចាប់គូជាមួយព្រះពុទ្ធ ដែលកម្ចាត់កិលេសហើយ ។

បទថា **ន ហិ ត្វំ សក្ខសិ សម្បយាតវេ** សេចក្ដីថា អ្នកនឹងមិនអាចចាប់គូជាមួយព្រះពុទ្ធដែលជាអ្នកមានបញ្ញាជាគ្រឿងកម្ចាត់ ប្រៀបផ្ទឹមស្មើជាមួយតថាគត គឺមិនអាចចាប់គូប្រៀបធៀបជាមួយតថាគតបានឡើយ ដូចចចកជាដើម មិនអាចចាប់គូប្រៀបធៀបជាមួយរាជសីហ៍ជាដើមបានឡើយ ។

[ ៣១៩ ] បទថា **មនោ** ជាមាតិកានៃនិទ្ទេស ។ បទថា **យំ ចិត្តំ** សេចក្ដីថា ឈ្មោះថា **ចិត្តំ** ព្រោះចិត្តវិចិត្រ ។ ឈ្មោះថា **មនោ** ព្រោះអត្ថថា ដឹង គឺជ្រាបអារម្មណ៍ ។ បទថា **មានសំ** បានដល់ ចិត្តនោះឯង ធម៌ដែលសម្បយុត្តដោយចិត្ត ហៅថា **មានស** ដូចក្នុងប្រយោគថា **អន្តលិក្ខចរោ បាសោ យ្វាយំ ចរតិ មានសោ** អន្ទាក់ គឺរាគៈណា ដែលត្រាច់ទៅលើអាកាស ដូច្នេះ ។ ព្រះអរហន្ត ហៅថា **មានស** ដូចក្នុងគាថានេះថា

**កថញ្ហិ ភគវា តុយ្ហំ សាវកោ សាសនេ រតោ**

**អប្បត្តមានសោ សេក្ខោ    កាលំ កយិរា ជនេសុតា ។**

បពិត្រព្រះមានព្រះភាគ អ្នកល្បីក្នុងប្រជុំជន សាវ័ករបស់ព្រះ
អង្គជាសេក្ខបុគ្គល មានបំណងមិនទាន់សម្រេច នៅត្រេកអរ
ក្នុងសាសនា គប្បីធ្វើមរណកាលដូចម្តេចបាន ដូច្នេះ ។

តែក្នុងទីនេះ **មានស** គឺចិត្តនោះឯង ។ បទថា **មានសំ** លោកពង្រីកដោយអំណាចនៃព្យញ្ជនៈ ។ បទថា **ហទយំ** បានដល់ ចិត្ត ។ ដើមទ្រូងហៅថា **ហទយ** ដូចក្នុងប្រយោគនេះថា **ចិត្តំ វា តេ ខិបិស្សាមិ ហទយំ វា តេ ផាលេស្សាមិ** យើងនឹងធ្វើចិត្តលោកឲ្យរវើរវាយ ឬហែកហឫទ័យ ( ដើមទ្រូង ) របស់លោក ។ ចិត្ត ហៅថា **ហទយ** ដូចក្នុងប្រយោគជាដើមថា **ហទយាហទយំ មញ្ញេ អញ្ញាយ តច្ឆតិ** សមីតិមាណពនេះហាក់ជាដឹងចិត្តដោយចិត្តហើយទើបចាំង ( នូវឈើ ) ។ ហទយវត្ថុ ( បេះដូង ) ហៅថា **ហទយ** ដូចក្នុងប្រយោគជាដើមថា **វក្កំ ហទយំ** ទាច បេះដូង ។ តែក្នុងទីនេះ ចិត្តនោះឯងហៅថា **ហទយ** ដោយអត្ថថា នៅខាងក្នុងចិត្តនោះឯង ឈ្មោះថា **បណ្ឌរំ** ដោយអត្ថថា បរិសុទ្ធិ ។ **បណ្ឌរ** នេះ លោកពោលសំដៅយកភវង្គចិត្ត ដូចព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភវង្គចិត្តនេះមានរស្មីផ្សាយចេញ ប៉ុន្តែចិត្តនោះឯង ត្រូវឧបក្កិលេសទាំងឡាយជាអាគន្តុកចូលមកធ្វើឲ្យសៅហ្មងដូច្នេះ ។ សូម្បីអកុសល ក៏ហៅថា **បណ្ឌរ** ដូចគ្នា ព្រោះចេញចាកចិត្តនោះ ដូចទឹកស្ទឹងគង្គា ហូរចេញអំពីស្ទឹងគង្គា និងដូចទឹកស្ទឹងគោធាវរីហូរចេញអំពីស្ទឹងគោធាវរី ។ តែសព្ទថា **មនោ មនាយតនំ** ក្នុងទីនេះជា **មនាយតន** លោក

ពោលដើម្បីសម្ដែងភាពជាអាយតនៈនៃចិត្ត ។ ព្រោះហេតុនោះ ទើបលោកសម្ដែង **មនោ** សព្ទនោះថា មនោ សព្ទនេះ ឈ្មោះថាមនាយតនៈ ព្រោះជាលំនៅនៃចិត្ត ដូចលំនៅនៃទេវតាក៏មិនមែន ដែលពិត អាយតនៈ គឺមនៈឈ្មោះថា មនាយតនៈ ។ ក្នុងពាក្យនេះ គប្បីជ្រាបថា ឈ្មោះថា អាយតនៈដោយអត្ថថា ជាទីនៅអាស្រ័យ ដោយអត្ថថា ជាប្រភពកើត ដោយអត្ថថាជាទីប្រជុំ ដោយអត្ថថា ជាប្រទេសដែលកើត និងដោយអត្ថថា ជាហេតុ ។ ពិតហើយ ទីនៅអាស្រ័យក្នុងលោក ហៅថា **អាយតន** ដូចក្នុងប្រយោគជាដើមថា **ឥស្សរាយតនំ វាសុទេវាយតនំ** លំនៅរបស់ព្រះឥសូរ លំនៅរបស់វាសុទេព ។ ប្រភពកើត ហៅថា **អាយតន** ដូចក្នុងប្រយោគជាដើមថា **សុវណ្ណាយតនំ រជតាយតនំ** ប្រភពកើតមាស ប្រភពកើតប្រាក់ ។ តែក្នុងសាសនាទីប្រជុំ ហៅថា **អាយតនៈ** ដូចក្នុងប្រយោគជាដើមថា **មនោរមេ អាយតនេ សេវន្តិ នំ វិហង្គមា ឆាយំ ឆាយត្ថិកា យន្តិ ផលត្ថា ផលភោជិនោ ។** ( ដើមឈើធំ ) ជាទីរីករាយចិត្ត ពួកសត្វដែលត្រូវការម្លប់ ក៏ទៅជ្រកម្លប់ ពួកសត្វដែលត្រូវការផ្លែ ក៏បរិភោគផ្លែ ។ ប្រទេសដែលកើត ហៅថា **អាយតន** ក្នុងប្រយោគជាដើមថា **ទក្ខិណាបថោ គុន្នំ អាយតនំ** ទក្ខិណាបថ ជាបទេសកើតនៃគោទាំងឡាយ ។ ហេតុ ហៅថា **អាយតន** ដូចក្នុងប្រយោគជាដើមថា **តត្រតត្រេវ សក្ខិព្វត បាបុណាតិ សតិ សតិអាយតនេ** កាលបើហេតុមាន រមែងដល់នូវភាពគួរជាបន្ទាល់ ក្នុងការដឹងនិងការឃើញនោះៗ ។ ក្នុងទីនេះ ប្រព្រឹត្តទៅទាំង ៣ យ៉ាង គឺដោយអត្ថថា

ប្រទេសដែលកើត ១ ដោយអត្ថថា ទីជាប្រជុំ ១ ដោយអត្ថថា ហេតុ ១ ។ **មនាយតន** នេះ គប្បីជ្រាបថាជា **អាយតន** ដោយអត្ថថា ជាប្រទេសដែលកើត ដូចក្នុងប្រយោគជាដើមថា ធម៌ទាំងឡាយមានផស្សៈជាដើម រមែងកើតក្នុងមនៈនេះ ។ គប្បីជ្រាបថា **អាយតន** ដោយអត្ថថា ទីជាប្រជុំដូចក្នុងប្រយោគជាដើមថា រូប សំឡេង ក្លិន រស ផោដ្ឋព្វ ដែលជាអារម្មណ៍ខាងក្រៅរមែងប្រជុំចុះក្នុងមនៈនេះតាមសភាវៈ ។ គប្បីជ្រាបថា **អាយតន** ដោយអត្ថថា ជាហេតុ ព្រោះភាពជាហេតុ ដោយអត្ថថា ជាបច្ច័យ មានសហជាតប្បច្ច័យជាដើម នៃធម៌ទាំងឡាយមានផស្សៈជាដើម ។ បទថា **មនិន្ទ្រិយំ** មានសេចក្តីដូចពោលហើយនោះឯង ។ ឈ្មោះថា **វិញ្ញាណំ** ព្រោះអត្ថថា ដឹងច្បាស់ ។ ខន្ធ គឺ វិញ្ញាណ ឈ្មោះថា **វិញ្ញាណក្ខន្ធោ** ។ គប្បីជ្រាបអត្ថនៃវិញ្ញាណក្ខន្ធនោះដោយអំណាចនៃគំនរជាដើម ។ លោកពោលខន្ធ ដោយអត្ថថា គំនរ ដូចក្នុងប្រយោគជាដើមថា **អសង្ខេយ្យា អប្បមេយ្យា មហាឧទក ក្ខន្ធោត្វេវ សង្ខំ គច្ឆតិ** គំនរទឹកធំ ដែលបុគ្គលរាប់មិនបានប្រមាណមិនអស់ យ៉ាងណាមិញ ។ មកក្នុងអត្ថថា គុណ ដូចក្នុងប្រយោគជាដើមថា **សីលក្ខន្ធោ សមាធិក្ខន្ធោ** គុណគឺសីលគុណគឺសមាធិ ។ មកក្នុងអត្ថថា បញ្ញត្តិ ដូចក្នុងប្រយោគជាដើមថា **អទ្ទសា ខោ ភគវា មហន្តំ ទារុក្ខន្ធំ** ព្រះមានព្រះភាគទ្រង់បានទតឃើញកំណាត់ឈើដ៏ធំ កំពុងអណ្តែតតាមខ្សែទឹក ។ តែក្នុងទីនេះ លោកពោលខន្ធដោយ **រុឡ្ហី** សព្ទ គឺសព្ទដែលនិយាយផ្សេងតែមានន័យផ្សេង ។ ចំណែកមួយនៃវិញ្ញាណក្ខន្ធ ជាវិញ្ញាណ ១ ដួង ដោយ

អត្ថថាជាគំនរ ព្រោះហេតុនោះ វិញ្ញាណសូម្បី ១ ដួង ជាចំណែកមួយនៃវិញ្ញាណក្ខន្ធ លោកក៏ពោលថា **វិញ្ញាណក្ខន្ធ** ដោយ **រុក្ខេកទេសេ** សព្វ ដូចកាត់ចំណែកមួយនៃដើមឈើ ដែលហៅថាកាត់នូវដើមឈើ ដូច្នោះ ។ បទថា **តជ្ជា មនោវិញ្ញាណធាតុ** សេចក្ដីថា មនោវិញ្ញាណធាតុដែលសមគួរដល់ធម៌មានផស្សៈជាដើមនោះ ។ ក្នុងបទនេះ ចិត្ត ១ ដួងនោះឯង ហៅឈ្មោះជា ៣ គឺ **មន** ដោយអត្ថថា ដឹង **វិញ្ញាណ** ដោយអត្ថថា ដឹងច្បាស់ **ធាតុ** ដោយអត្ថថា សភាវៈខ្លះ ដោយអត្ថថា មិនមែនសត្វ មិនមែនបុគ្គលខ្លះ ។

[ ៣២០ ] បទថា **សទ្ធឹ យុគំ សមាគមំ** សេចក្ដីថា រួមជាដៃគូគ្នា ។ បទថា **សមាគន្ត្វា** សេចក្ដីថា ដល់ហើយ ។ បទថា **យុគគ្គាហំ គណ្ហិត្វា** សេចក្ដីថា ធ្វើជាគូប្រណាំងប្រជែងគ្នា ។ បទថា **សាកច្ឆេតុំ** សេចក្ដីថា ដើម្បីពោលជាមួយគ្នា ។ បទថា **សល្លបិតុំ** សេចក្ដីថា ដើម្បីធ្វើនូវការសន្ទនាប្រាស្រ័យគ្នា ។ បទថា **សាកច្ឆំ សមាបជ្ជិតុំ** សេចក្ដីថា ដើម្បីឲ្យការពោលប្រព្រឹត្តទៅរួមគ្នា ។

ម្យ៉ាងទៀត ដើម្បីសម្ដែងហេតុក្នុងភាពដែលបសូរបរិព្វាជកជាអ្នកមិនអាច ទើបព្រះសារីបុត្តពោលពាក្យថា **តំ កិស្ស ហេតុ បសូរោ បរិព្វាជកោ ហីនោ** ដូច្នេះជាដើម ។

បទថា **សោ ហិ ភគវា អគ្គោ ច** សេចក្ដីថា ព្រះមានព្រះភាគអង្គនោះឈ្មោះថា **អគ្គោ** ព្រោះមិនមានអ្នកណាដូច គឺព្រោះមិនមានអ្នកណាមានបញ្ញាស្មើ ។

បទថា **សេដ្ឋោ ច** សេចក្តីថា ឈ្មោះថា **សេដ្ឋោ** ដោយអត្ថថា មិនមានបុគ្គលណាប្រៀបដោយគុណទាំងពួង ។ បទថា **មោក្ខោ ច** សេចក្តីថា ឈ្មោះថា **មោក្ខោ** ព្រោះផុតចាកកិលេសព្រមទាំងវាសនា ។ បទថា **ឧត្តមោ ច**[1] សេចក្តីថា ឈ្មោះថា **ឧត្តមោ** ព្រោះមិនមានបុគ្គលដែលក្រៃលែងជាងព្រះអង្គ ។ បទថា **បវរោ ច** សេចក្តីថា ឈ្មោះថា **បវរោ** ព្រោះជាបុគ្គលដែលសត្វលោកទាំងពួងប្រាថ្នាក្រៃលែង ។

បទថា **មត្តេន មាតង្គេន** បានដល់ ដំរីចុះប្រេង ។ បទថា **កោត្ថុកោ** បានដល់ ឆ្កែចចកចាស់ ។ បទថា **សីហេន មិគរញ្ញា សទ្ធឹ** សេចក្តីថា ជាមួយស្តេចសីហៈដែលជាមិគរាជ ។ បទថា **តរុណកោ** សេចក្តីថា ខ្លួនតូច ។ បទថា **ធេនុបកោ** សេចក្តីថា នៅបៅដោះនៅឡើយ ។ បទថា **ឧសភេន** សេចក្តីថា គោដែលគេសន្មតថា ជាមង្គល ។ បទថា **ពលក្កកុធា សទ្ធឹ** សេចក្តីថា គោដែលមានបូកកម្រើកបាន ។ បទថា **ធង្កោ** បានដល់ សត្វក្អែក ។ បទថា **គរុឡេន** ក្នុងបទថា **គរុឡេន វេនតេយ្យេន សទ្ធឹ** នេះ ជាឈ្មោះដោយអំណាចនៃជាតិ ។

បទថា **វេនតេយ្យេន** ជាឈ្មោះដោយអំណាចនៃគោត្ត ។ បទថា **ចណ្ឌាលោ** បានដល់ ចណ្ឌាលដោយកំណើត ។ បទថា **រញ្ញោ ចក្កវត្តិនា** បានដល់ ស្តេចចក្រពត្តិដែលគ្រប់គ្រងទ្វីបទាំង ៤ ។ បទថា **បំសុបិសាចកោ** បានដល់ យក្ខដែលកើតក្នុងទីចាក់សំរាម ។ បទថា **ឥន្ទេន ទេវរញ្ញា សទ្ធឹ**

---

១-ក្នុងបាលីមហានិទ្ទេសមិនមានបទនេះ តែក្នុងអដ្ឋកថាមាន ។

សេចក្តីថា ជាមួយនឹងសក្កទេវរាជ ។ បទ ៦ មានបទថា **សោ ហិ ភគវា មហាបញ្ញោ** ជាដើម បានពោលពិស្តារហើយខាងដើម ។

បណ្តាបទទាំងនោះ បទថា **បញ្ញាបភេទកុសលោ** សេចក្តីថា ជាអ្នកឈ្លាសក្នុងប្រភេទនៃបញ្ញា ដែលមានវិកប្បមិនមានទីបំផុតរបស់ព្រះអង្គ ។

បទថា **បភិន្នញ្ញាណោ** សេចក្តីថា ទ្រង់មានញាណដែលមិនមានទីបំផុត កាលមានភាពជាអ្នកឈ្លាសក្នុងប្រភេទនៃបញ្ញា លោកក៏សម្តែងឲ្យឃើញថា បញ្ញាទាំងនោះ មានប្រភេទមិនមានទីបំផុត ដោយបទថា **បភិន្នញ្ញាណោ** នេះ ។

បទថា **អធិគតប្បដិសម្ភិទោ** សេចក្តីថា បានចំពោះនូវបដិសម្ភិទាញាណដ៏ប្រសើរ ៤ យ៉ាង ។

បទថា **ចតុវេសារជ្ជប្បត្តោ** សេចក្តីថា សម្រេចញាណ ពោលគឺជាអ្នកក្លៀវក្លា ៤ យ៉ាង ដូចព្រះតម្រាស់ ( ក្នុងអង្គុត្តរនិកាយចតុក្កបាត ) ថា

> ម្នាលភិក្ខុទាំងឡាយ តថាគតមិនឃើញនូវនិមិត្តគឺធម៌ ឬបុគ្គលនុ៎ះថា សមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី បុគ្គលណាមួយក្នុងលោកក្តី នឹងចោទតថាគតដោយពាក្យប្រកបដោយធម៌ ក្នុងហេតុនោះថា លោកប្តេជ្ញាខ្លួនថាជាអ្នកត្រាស់ដឹងឯងដោយប្រពៃ ប៉ុន្តែធម៌ទាំងអម្បាលនេះ លោកមិនបានត្រាស់ដឹងទេ ម្នាលភិក្ខុទាំងឡាយ កាលតថាគតមិនឃើញនូវនិមិត្តនុ៎ះឯង ទើបដល់នូវសេចក្តីក្សេម ដល់នូវភាព

ជាអ្នកមិនមានភ័យ ដល់នូវភាពជាអ្នកក្លៀវក្លា ១ ។ ម្នាល ភិក្ខុទាំងឡាយ តថាគតមិនឃើញនូវនិមិត្តគឺធម៌ ឬបុគ្គលនុ៎ះថា សមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី បុគ្គលណា មួយក្នុងលោកក្តី នឹងចោទតថាគតដោយពាក្យប្រកបដោយ ធម៌ ក្នុងហេតុនោះថា លោកប្តេជ្ញាខ្លួនថាជាអ្នកអស់អាសវៈ ហើយ ប៉ុន្តែអាសវៈទាំងអម្បាលនេះ មិនទាន់អស់ទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ តថាគតមិនឃើញនូវនិមិត្តគឺធម៌ ឬបុគ្គល នុ៎ះថាសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី បុគ្គល ណាមួយក្នុងលោកក្តី នឹងចោទតថាគតដោយពាក្យប្រកប ដោយធម៌ ក្នុងហេតុនោះថា ធម៌ទាំងឡាយណា ដែលលោក ពោលថាធម៌ជាគ្រឿងធ្វើនូវអន្តរាយ ។បេ។ ម្នាលភិក្ខុទាំងឡាយ តថាគតមិនឃើញនូវនិមិត្តគឺធម៌ ឬបុគ្គលនុ៎ះថា សមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី បុគ្គលណាមួយក្នុង លោកក្តី នឹងចោទតថាគតដោយពាក្យប្រកបដោយធម៌ ក្នុង ហេតុនោះថា ធម៌ដែលលោកសម្តែងហើយ ដើម្បីប្រយោជន៍ ដល់គុណវិសេសណា គុណវិសេសនោះ មិនអាចស្រោច ស្រង់ ដើម្បីឲ្យអស់ទៅនៃទុក្ខដោយប្រពៃដល់អ្នកធ្វើតាមនូវ ធម៌នោះទេ ម្នាលភិក្ខុទាំងឡាយ កាលតថាគតឃើញនូវនិមិត្ត នុ៎ះឯង ទើបដល់នូវសេចក្តីក្សេម ដល់នូវភាពជាអ្នកមិនមាន

ភ័យ ដល់នូវភាពជាអ្នកក្លៀវក្លា ១ ដូច្នេះ ។

បទថា **ទសពលពលធារី** សេចក្តីថា ឈ្មោះថា **ទសពល** ព្រោះអត្ថថា មានកម្លាំង ១០ ។ កម្លាំងទាំងឡាយរបស់ព្រះទសពល ឈ្មោះថា **ទសពល** ។ ឈ្មោះថា **ទសពលពលធារី** ព្រោះអត្ថថា ទ្រទ្រង់នូវកម្លាំងទាំងនោះ អធិប្បាយថា ទ្រទ្រង់នូវកម្លាំងនៃញាណរបស់ព្រះទសពល ។ លោកសម្តែងត្រឹមមាតិកាប្រភេទធម៌ដែលគួរទូន្មាន ដែលមានប្រភេទជាច្រើន មិនមានទីបំផុត ដោយបទ ៣ នេះ ។ ព្រះមានព្រះភាគអង្គនោះឯង ឈ្មោះថា **បុរិសាសភោ** ដោយអត្ថថា សន្មតថា ជាមង្គលក្រៃលែងដោយអំណាចប្រកបដោយបញ្ញា ។ ឈ្មោះថា **បុរិសសីហោ** ដោយអត្ថថា មិនតក់ស្លុត ។ ឈ្មោះថា **បុរិសនាគោ** ដោយអត្ថថា ធំ ។ ឈ្មោះថា **បុរិសាជញ្ញោ** ដោយអត្ថថា ដឹងព្រម ។ ឈ្មោះថា **បុរិសធោរយ្ហោ** ដោយអត្ថថា នាំលោកធុរៈទៅ ។

លំដាប់នោះ ព្រះសារីបុត្តត្ថេរបំណងនឹងសម្តែងគុណវិសេសដែលបានអំពីញាណមិនមានទីបំផុត មានតេជះជាដើម កាលសម្តែងភាពដែលតេជះជាដើមទាំងនោះ មានញាណមិនមានទីបំផុតជាមូល ទើបពោលថា **អនន្តញ្ញាណោ** ហើយពោលថា **អនន្តតេជោ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **អនន្តញ្ញាណោ** សេចក្តីថា មានញាណវៀរចាកទីបំផុត ដោយអំណាចនៃគុណនិងដោយអំណាចនៃសភាវៈ ។ បទថា **អនន្តតេជោ** សេចក្តីថា មានតេជះកើតអំពីញាណមិនមានទីបំផុត ដោយការកម្ចាត់ងងឹត គឺមោហៈក្នុងសន្តានរបស់វេនេយ្យសត្វ ។ បទថា **អនន្តយសោ**

សេចក្តីថា សំឡេងសរសើរដែលមិនមានទីបំផុត ដែលផ្សាយទៅក្នុងលោក ៣ ដោយបញ្ញាគុណនោះឯង ។ បទថា **អត្ថេ្ញា** សេចក្តីថា ជាអ្នកសម្រេចដោយការសម្រេចនៃទ្រព្យ គឺបញ្ញា ។ បទថា **មហាធ្មុនោ** សេចក្តីថា ឈ្មោះថា **មហាធ្មុនោ** ព្រោះអត្ថថា មានទ្រព្យ គឺបញ្ញា ប្រព្រឹត្តទៅច្រើន ដោយការច្រើនតាមសភាវៈ ដោយការច្រើននៃទ្រព្យ គឺបញ្ញា ។ បាឋៈថា **មហាធនោ** ក៏មាន ។ បទថា **ធនវ៉ា** សេចក្តីថា ដែលប្រព្រឹត្តទៅដោយទ្រព្យ គឺបញ្ញាដែលគប្បីសរសើរ ដែលប្រព្រឹត្តទៅដោយទ្រព្យ គឺបញ្ញាដែលប្រកបទុកជានិច្ច ដែលប្រព្រឹត្តទៅដោយទ្រព្យ គឺបញ្ញា ដោយជាសេចក្តីល្អក្រៃលែង ឈ្មោះថា **ធនវ៉ា** ។ បុគ្គលដឹងនូវសត្វ រមែងប្រាថ្នាពាក្យនេះក្នុងអត្ថ ៣ នេះ ។

ព្រះសារីបុត្តត្ថេរ កាលសម្តែងសេចក្តីសម្រេចនូវអត្តសម្បត្តិរបស់ព្រះមានព្រះភាគ ដោយបញ្ញាគុណយ៉ាងនេះហើយ កាលនឹងសម្តែងសេចក្តីសម្រេចនូវលោកហិតសម្បត្តិ ដោយបញ្ញាគុណនោះឯងទៀត ទើបពោលពាក្យថា **នេតា** ជាដើម ។

បណ្តាបទទាំងនោះ ព្រះមានព្រះភាគទ្រង់ជាអ្នកណែនាំវេនេយ្យសត្វ អំពីទីមានភ័យ ពោលគឺសង្សារវដ្តទៅកាន់ទីដែលផុតភ័យ ពោលគឺព្រះនិព្វាន ។ បណ្តាបទទាំងនោះ ទ្រង់ជាអ្នកទូន្មានពួកវេនេយ្យសត្វដោយអំណាចនៃសំវរវិន័យនិងបហានវិន័យក្នុងកាលជាទីទូន្មាននោះឯង ។ ទ្រង់ជាអ្នកប្រៀនប្រដៅដោយការកាត់សេចក្តីសង្ស័យក្នុងពេលទ្រង់សម្តែងធម៌នោះឯង ។ កាលទ្រង់កាត់សេចក្តីសង្ស័យហើយឲ្យដឹងប្រយោជន៍ដែលគួរឲ្យដឹង ឈ្មោះថា ទ្រង់

ពន្យល់ ។ ទ្រង់ឲ្យពិនិត្យដោយហេតុនៃការសម្រេចចិត្តដល់ប្រយោជន៍ដែលឲ្យដឹងយ៉ាងនោះ ។ ទ្រង់សម្ងឹងដោយអំណាចនៃការប្រកបការបដិបត្តិដើម្បីប្រយោជន៍ដែលទ្រង់ឲ្យពិនិត្យហើយ យ៉ាងនោះ ។ ទ្រង់ឲ្យរំឭកដោយផលនៃការបដិបត្តិក្នុងប្រយោជន៍ ដែលប្រព្រឹត្តទៅហើយយ៉ាងនោះ ។ **ហិ** សព្ទក្នុងបទថា **សោ ហិ ភគវា** ជានិបាត ដែលបញ្ជាក់ដល់ហេតុនៃប្រយោជន៍ដែលពោលទុកក្នុងលំដាប់ជាប់គ្នា ។

បទថា **អនុប្បន្នស្ស មគ្គស្ស ឧប្បាទេតា** សេចក្តីថា ទ្រង់ធ្វើអរិយមគ្គដែលជាហេតុនៃអសាធារណញ្ញាណ ៦ ដែលមិនធ្លាប់កើតឡើងក្នុងសន្តានរបស់ព្រះអង្គឲ្យកើតឡើង ក្នុងសន្តានរបស់ព្រះអង្គត្រង់មណ្ឌលពោធិព្រឹក្សដើម្បីអនុគ្រោះដល់សត្វលោក ។

បទថា **អសញ្ជាតស្ស មគ្គស្ស សញ្ជនេតា** សេចក្តីថា ទ្រង់ធ្វើនូវមគ្គដ៏ប្រសើរ ដែលជាហេតុនៃសាវកបារមីញាណ ដែលមិនធ្លាប់កើតព្រមក្នុងសន្តានរបស់វេនេយ្យសត្វ ឲ្យកើតព្រមក្នុងសន្តានរបស់វេនេយ្យសត្វ ចាប់តាំងអំពីទ្រង់ញុំាងធម្មចក្កឲ្យប្រព្រឹត្តទៅរហូតដល់កាលសព្វថ្ងៃនេះ ។ ព្រះមានព្រះភាគ ឈ្មោះថា ទ្រង់ឲ្យកើតព្រម ព្រោះទ្រង់ធ្វើអរិយមគ្គឲ្យកើតព្រមក្នុងសន្តានរបស់ពួកសាវក ដែលជាវេនេយ្យតាមព្រះតម្រាស់ ដែលព្រះមានព្រះភាគត្រាស់ទុកនោះឯង ។

បទថា **អនក្ខាតស្ស មគ្គស្ស អក្ខាតា** សេចក្តីថា ត្រាស់ប្រាប់នូវមគ្គគឺបារមីធម៌ឬអរិយមគ្គ ដែលគប្បីកើតឡើងត្រង់មណ្ឌលពោធិព្រឹក្ស ដោយ

ត្រឹមតែការព្យាករថា បុគ្គលនេះនឹងជាព្រះពុទ្ធដែលជាផ្លូវដែលព្រះពុទ្ធអង្គខ្លះទ្រង់ឲ្យពាក្យព្យាករណ៍នូវភាពជាព្រះពុទ្ធ តែទ្រង់មិនធ្លាប់ប្រាប់ដល់ពួកពោធិសត្វដែលសាងអភិនីហារ ដើម្បីភាពជាព្រះពុទ្ធទុកហើយ ដែលប្រកបដោយធម៌ ៨ ប្រការ ។ ន័យនេះរមែងប្រើក្នុងការព្យាករបច្ចេកពោធិសត្វផងដែរ ។

បទថា **មគ្គញ្ញូ** សេចក្តីថា ទ្រង់ដឹងអរិយមគ្គដែលកើតឡើងដល់ព្រះអង្គដោយអំណាចនៃការពិចារណា ។ បទថា **មគ្គវិទូ** សេចក្តីថា ឈ្លាសក្នុងអរិយមគ្គដែលគប្បីឲ្យកើតក្នុងសន្តានរបស់វេនេយ្យសត្វ ។

បទថា **មគ្គក្ខាយី** សេចក្តីថា ឃើញច្បាស់ក្នុងមគ្គដែលគួរប្រាប់ដល់ពួកពោធិសត្វ ។ ម្យ៉ាងទៀត ទ្រង់ស្គាល់ផ្លូវជាគ្រឿងសម្រេចអភិសម្ពោធិញ្ញាណ ។ ទ្រង់ជ្រាបច្បាស់នូវផ្លូវជាគ្រឿងសម្រេចបច្ចេកពោធិញ្ញាណ ។ ទ្រង់វាងវៃក្នុងផ្លូវជាគ្រឿងសម្រេចសាវកពោធិញ្ញាណ ។ ម្យ៉ាងទៀត ពួកសត្វរមែងធ្វើការប្រកបក្នុងទីនេះតាមលំដាប់ ដោយអំណាចនៃមគ្គរបស់ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធនិងព្រះសាវកក្នុងអតីត អនាគត និងបច្ចុប្បន្ន តាមដែលប្រកបមានសេចក្តីតាមបាលី ( សំយុត្តនិកាយមហាវារវគ្គ ) ថា

> ជនទាំងឡាយឯណា បានធ្វើហើយក្នុងកាលមុនក្តី ធ្វើក្នុងកាលឥឡូវនេះក្តី នឹងធ្វើក្នុងខាងមុខក្តី នូវអន្ទង់ ( មានកាមជាដើម ) តាមផ្លូវនេះឯង ដូច្នេះ ។

ដោយអំណាចនៃសុញ្ញតមគ្គ អនិមិត្តមគ្គ និងអប្បណិហិតមគ្គ ដោយអំណាចនៃមគ្គរបស់ឧគ្ឃដិតញ្ញូបុគ្គល វិបចិតញ្ញូបុគ្គល និងនេយ្យបុគ្គល ។ បទថា

**មគ្គានុគា ច បនស្ស** សេចក្តីថា ជាអ្នកប្រព្រឹត្តតាមមគ៌ដែលព្រះមានព្រះភាគទ្រង់យាងហើយ ។ **ច** សព្ទ ក្នុងទីនេះ ជានិបាត ចុះក្នុងអត្ថថា ហេតុដោយ **ច** សព្ទនេះ ឈ្មោះថា ព្រះមានព្រះភាគត្រាស់ហេតុហើយ ដើម្បីសម្រេចនូវគុណ មានការកើតឡើងនៃមគ្គជាដើម ។ **បន** សព្ទ ជានិបាតចុះក្នុងអត្ថថា ធ្វើហើយ រមែងជាការត្រាស់នូវការធ្វើមគ្គ ដែលព្រះមានព្រះភាគអង្គនោះទ្រង់ធ្វើហើយ ។

បទថា **បច្ឆា សមន្នាគតា** សេចក្តីថា ប្រកបដោយគុណ មានសីលជាដើម ខាងក្រោយព្រះមានព្រះភាគទ្រង់យាងទៅមុនហើយ ។

ព្រោះគុណទាំងឡាយ មានសីលជាដើម របស់ព្រះមានព្រះភាគទាំងអស់អាស្រ័យអរហត្តមគ្គប៉ុណ្ណោះមកហើយ ព្រោះហេតុនោះ ទើបព្រះថេរៈពោលគុណអាស្រ័យអរហត្តមគ្គប៉ុណ្ណោះ ដោយបទថា **អនុប្បន្នស្ស មគ្គស្ស ឧប្បាទេតា** ជាដើម ដោយប្រការដូច្នេះ ។

បទថា **ជានំ ជានាតិ** សេចក្តីថា ទ្រង់ដឹងនូវធម៌ដែលទ្រង់គប្បីដឹង អធិប្បាយថា ទ្រង់ដឹងនូវធម៌ឯណាមួយដែលគួរដឹងដោយបញ្ញា និងធម៌ដែលជាផ្លូវដែលគួរណែនាំគ្រប់យ៉ាងដោយបញ្ញា ព្រោះភាពជាព្រះសព្វញ្ញូ ។ បទថា **បស្សំ បស្សតិ** សេចក្តីថា ទ្រង់ឃើញធម៌ដែលគួរឃើញ អធិប្បាយថា ទ្រង់ឃើញផ្លូវដែលគួរណែនាំនោះឯងដោយបញ្ញាចក្ខុ ទ្រង់ធ្វើឲ្យដូចជាឃើញដោយចក្ខុព្រោះជាអ្នកឃើញសព្វយ៉ាង ។

ម្យ៉ាងទៀត បុគ្គលពួកខ្លះ កាលប្រកាន់វិបរិត ទោះជាដឹងក៏មិនជាការដឹង

ឃើញក៏មិនជាការឃើញ យ៉ាងណា ព្រះមានព្រះភាគទ្រង់មិនដូច្នោះទេ តែទ្រង់កាន់យកតាមសភាវៈ កាលទ្រង់ដឹង ក៏ជាការដឹងនោះឯង កាលទ្រង់ឃើញក៏ជាការឃើញនោះឯង ។ ព្រះមានព្រះភាគអង្គនេះ ព្រះអង្គមានចក្ខុ ដោយអត្ថថា ជាបរិនាយកនៃការឃើញ ទ្រង់មានញាណ ដោយអត្ថថា ជាអ្នកធ្វើឲ្យដឹងច្បាស់ ទ្រង់មានធម៌ ដោយអត្ថថា មានសភាវៈមិនវិបរិត ឬព្រោះអត្ថថា សម្រេចដោយធម៌ដែលទ្រង់ត្រិះរិះដោយព្រះហឫទ័យហើយ ទ្រង់បន្លឺដោយព្រះវាចា ដោយទ្រង់ប្រកាសបរិយត្តិធម៌ ព្រះអង្គជាបុគ្គលប្រសើរ ដោយអត្ថថា ប្រសើរ ។

ម្យ៉ាងទៀត ទ្រង់មានចក្ខុ ព្រោះអត្ថថា ដូចចក្ខុ ។ ទ្រង់មានញាណ ព្រោះអត្ថថា ដូចព្រះញាណ ។ ទ្រង់មានធម៌ ព្រោះអត្ថថា ដូចធម៌ ។ ព្រះអង្គជាបុគ្គលប្រសើរ ព្រោះអត្ថថា ដូចបុគ្គលប្រសើរ ។ ព្រះមានព្រះភាគអង្គនេះ ទ្រង់ជាអ្នកពោលធម៌ ព្រោះត្រាស់ប្រាប់ធម៌ ឬត្រាស់ប្រៀនប្រដៅនូវធម៌ ។ ទ្រង់ជាអ្នកពោលដោយប្រការផ្សេងៗ ព្រោះត្រាស់ប្រាប់ ឬត្រាស់ប្រៀនប្រដៅដោយប្រការផ្សេងៗ ។ ទ្រង់ជាអ្នកនាំចេញ ព្រោះទ្រង់នាំអត្ថចេញមកសម្តែង ។ ទ្រង់ឲ្យអមតៈ ព្រោះទ្រង់សម្តែងបដិបទាដើម្បីសម្រេចអមតធម៌ ឬព្រោះឲ្យសត្វសម្រេចអមតធម៌ ដោយព្រះធម្មទេសនាដែលប្រកាសអមតធម៌ ។ ជាធម្មស្សាមី ព្រោះអត្ថថា ជាធំក្នុងធម៌ទាំងឡាយ ព្រោះជាអ្នកញុំាងនូវលោកុត្តរធម៌ឲ្យកើតឡើង និងព្រោះប្រទានលោកុត្តរធម៌តាមសប្បាយ ដោយអនុលោមដល់វេនេយ្យសត្វ បទថា **តថាគតោ** មានអត្ថដូចពោលហើយខាងដើម ។

ឥឡូវនេះ ព្រះថេរៈបំណងនឹងសម្ដែងគុណ ដែលពោលទុកដោយបទថា **ជាតំ ជាតាតិ** ជាដើមឲ្យវិសេស ព្រោះព្រះមានព្រះភាគទ្រង់ជាព្រះសព្វញ្ញូ កាលញ៉ាំងភាពជាសព្វញ្ញូឲ្យសម្រេច ទើបពោលថា **ឯត្ថ** ជាដើម ។

ឈ្មោះថា **អញ្ញាតំ** គឺវត្ថុដែលទ្រង់មិនដឹង រមែងមិនមានដល់ព្រះមានព្រះភាគអង្គនោះយ៉ាងនោះ ព្រោះទ្រង់ប្រាសចាកការវង្វេង ព្រមទាំងវាសនាក្នុងធម៌ទាំងពួង ដោយអរហត្តមគ្គញាណ ដែលសម្រេចអំពីអំណាចផលបុណ្យបារមី ព្រោះដឹងនូវធម៌ទាំងពួង ដោយមិនវង្វេង ។ ឈ្មោះថា **អទិដ្ឋំ** គឺវត្ថុដែលទ្រង់មិនឃើញ រមែងមិនមានយ៉ាងនោះឯង ព្រោះទ្រង់ឃើញនូវធម៌ទាំងពួង ដោយញាណចក្ខុ ដូចឃើញដោយចក្ខុ ។ ឈ្មោះថា **អវិទិតំ** គឺវត្ថុដែលទ្រង់មិនជ្រាបច្បាស់ រមែងមិនមាន ព្រោះទ្រង់សម្រេចហើយដោយព្រះញាណ ។ ឈ្មោះថា **អសច្ឆិកតំ** គឺវត្ថុដែលទ្រង់មិនធ្វើឲ្យជាក់ច្បាស់ រមែងមិនមាន ព្រោះទ្រង់ធ្វើឲ្យជាក់ច្បាស់ហើយ ដោយការធ្វើឲ្យជាក់ច្បាស់នូវការមិនវង្វេង ។ ឈ្មោះថា **អផុសិតំ** គឺវត្ថុដែលទ្រង់មិនបានពាល់ត្រូវដោយបញ្ញា រមែងមិនមាន ព្រោះទ្រង់ពាល់ត្រូវហើយដោយបញ្ញាដែលមិនវង្វេង ។ បទថា **បច្ចុប្បន្នំ** បានដល់ កាល ឬធម៌ដែលកើតឡើងចំពោះមុខ ។ បទថា **ឧបាទាយ** បានដល់ កាន់យក អធិប្បាយថា ធ្វើទុកខាងក្នុង ។ សូម្បីព្រះនិព្វានដែលផុតកាលក៏ឈ្មោះថា កាន់យកហើយនោះឯង ដោយពាក្យថា **ឧបាទាយ** នោះឯង ។ បទថា **អតីតំ** ជាដើម រមែងទាក់ទងដោយពាក្យថា **ឯត្ថ** ជាដើមខ្លះ ដោយពាក្យថា **សព្វេ ធម្មា** ជាដើមខ្លះ ។ បទថា **សព្វេ ធម្មា** បានដល់ ការសរុប

សង្ខតធម៌និងអសង្ខតធម៌ទាំងអស់ ។ បទថា **សព្វាការេន** បានដល់ ការសរុប អាការគ្រប់យ៉ាង មានអាការមិនទៀងជាដើមនៃធម៌នីមួយៗក្នុងធម៌ទាំងពួង ។

បទថា **ញាណមុខេ** បានដល់ ចំពោះមុខព្រះញាណ ។ បទថា **អាបាថំ អាគច្ឆន្តិ** សេចក្តីថា ចូលដល់នូវការប្រជុំគ្នា ។ បទថា **ជានិតព្វំ** លោកពោលដើម្បីលម្អិតសេចក្តីនៃពាក្យថា **នេយ្យំ** ។ **វា** សព្ទ ក្នុងបទជាដើមថា **អត្តត្ថោ វា** មានអត្ថថា រួបរួម ។ បទថា **អត្តត្ថោ** បានដល់ ប្រយោជន៍របស់ខ្លួន ។ បទថា **បរត្ថោ** បានដល់ ប្រយោជន៍របស់អ្នកដទៃ គឺរបស់ត្រៃលោក ។ បទថា **ឧភយត្ថោ** បានដល់ ប្រយោជន៍ទាំង ២ ចំណែក ក្នុងគ្រាតែមួយនោះឯង គឺទាំងរបស់ខ្លួននិងរបស់អ្នកដទៃ ។ បទថា **ទិដ្ឋធម្មិកោ** បានដល់ ប្រយោជន៍ដែលប្រកបក្នុងបច្ចុប្បន្ន ឈ្មោះថា ប្រយោជន៍ក្នុងទិដ្ឋធម៌ ។ ប្រយោជន៍ ឈ្មោះថា **សម្បរាយិកោ** ព្រោះអត្ថថា ប្រកបខាងមុខ ឈ្មោះថា សម្បរាយប្រយោជន៍ ។ ក្នុងបទថា **ឧត្តានោ** ជាដើម ប្រយោជន៍ដែលគប្បីពោលដល់បានដោយអំណាចនៃវោហារ ឈ្មោះថា **ឧត្តានោ** ព្រោះកើតបានងាយ ។ ប្រយោជន៍ដែលបដិសំយុត្តដោយសុញ្ញតា ដែលផុតចាកវោហារដែលគប្បីពោលដល់ឈ្មោះថា **គម្ភីរោ** គឺជាលោកុត្តរ ព្រោះកើតបានដោយក្រ ។ ឈ្មោះថា **គូឡ្ហោ** ព្រោះក្រៅអំពីការឃើញដោយឥតសេសសល់ ។ ឈ្មោះថា **បដិច្ឆន្នោ** ព្រោះត្រូវបិទបាំងទុកដោយការមិនទៀងជាដើម និងដោយឃនៈ ( ការសម្គាល់ថាដុំ ) គឺមោហៈជាដើម ។ ប្រយោជន៍ដែលគប្បីពោលដល់ ដោយវោហារមិនចម្រើន ឈ្មោះថា **នេយ្យោ** ព្រោះមិនកាន់

យកតាមដែលពោលហើយនាំចេញដល់បំណង ។ ប្រយោជន៍ដែលគប្បីពោលដល់ដោយវោហារចម្រើន ឈ្មោះថា **ធីរោ** ព្រោះនាំចេញដល់បំណងបានដោយត្រឹមតែវាចាប៉ុណ្ណោះ ប្រយោជន៍របស់សីល សមាធិនិងវិបស្សនាដែលបរិសុទ្ធល្អ ឈ្មោះថា **អនវជ្ជោ** ព្រោះវៀរចាកទោសដោយអំណាចនៃតទង្គប្បហាននិងវិក្ខម្ភនប្បហាន ។ ប្រយោជន៍នៃអរិយមគ្គ ឈ្មោះថា **និក្កិលេសោ** ព្រោះកាត់នូវកិលេសបានជាសមុច្ឆេទ ។ ប្រយោជន៍នៃអរិយផល ឈ្មោះថា **វោទានោ** ព្រោះកិលេសស្ងប់រម្ងាប់ហើយ ។ ព្រះនិព្វាន ឈ្មោះថា **បរមត្ថោ** ព្រោះជាធម៌ដ៏ប្រសើរ ក្នុងសង្ខតធម៌និងអសង្ខតធម៌ទាំងឡាយ ។ បទថា **បរិវត្តតិ** សេចក្តីថា រមែងប្រព្រឹត្តទៅ ជ្រួតជ្រាប ឬប្រជាប់ដោយជុំវិញ ឬដោយពិសេសខាងក្នុងព្រះពុទ្ធញាណ ព្រោះមិនបាននៅខាងក្រៅចាកភាវៈវិស័យនៃព្រះពុទ្ធញាណ ។

ភាពជាវិស័យនៃញាណរបស់ព្រះមានព្រះភាគ ដោយបទថា **សព្វំ កាយកម្មំ** ជាដើម ។

បទថា **ញាណានុបរិវត្តតិ** សេចក្តីថា រមែងប្រព្រឹត្តទៅតាមព្រះញាណ អធិប្បាយថា រមែងមិនវៀរចាកព្រះញាណ ព្រះថេរៈសម្តែងនូវការប្រាសចាកការជាប់ជំពាក់ ដោយបទថា **អប្បដិហតំ** ។

ព្រះថេរៈបំណងនឹងញ៉ាំងភាពជាព្រះសព្វញ្ញូ ឲ្យសម្រេចដោយឧបមាទៀត ទើបពោលពាក្យថា **យាវតកំ** ជាដើម ។

បណ្តាបទទាំងនោះ ឈ្មោះថា **នេយ្យំ** ព្រោះអត្ថថា គួរដឹង ។ ឈ្មោះថា

**នេយ្យបរិយន្តិកំ** ព្រោះអត្ថថា ព្រះញាណនោះ មានចំណែកបំផុតជុំវិញនៃបទធម៌ដែលគួរនាំចេញ គឺមានទីបំផុតនៃបទធម៌ដែលគួរនាំចេញ ឯទីបំផុតនៃបទធម៌ដែលគួរនាំចេញនោះឯង រមែងមិនមានដល់បុគ្គលដែលមិនមែនសព្វញ្ញូ ។ សូម្បីក្នុងបទថា **ញាណបរិយន្តិកេ** ក៏មានន័យនេះដូចគ្នា ។ ក្នុងគូដំបូងមានអត្ថដូចពោលហើយនោះឯង ។ ព្រះថេរៈសម្តែងឲ្យវិសេសដោយគូនេះ ។ សម្តែងកំណត់ដោយអំណាចបដិសេធដោយគូទី ៣ ។ ក្នុងទីនេះ បទធម៌ដែលគួរនាំចេញ ឈ្មោះថា **នេយ្យបថោ** ព្រោះជាផ្លូវនៃញាណ ។ បទថា **អញ្ញមញ្ញបរិយន្តដ្ឋាយិនោ** សេចក្តីថា មានប្រក្រតីតាំងនៅក្នុងចំណែកបំផុតជុំវិញនៃគ្នានឹងគ្នា ដោយជ្រួតជ្រាបទាំងបទធម៌ដែលគួរនាំចេញនិងព្រះញាណ ។

បទថា **អាវជ្ជនប្បដិពទ្ធា** សេចក្តីថា អាស្រ័យនូវការគិតតាមមនោទ្វារ អធិប្បាយថា រមែងដឹងក្នុងលំដាប់នៃអាវជ្ជនៈនោះឯង ។

បទថា **អាកង្ខប្បដិពទ្ធា** សេចក្តីថា អាស្រ័យការពេញចិត្ត អធិប្បាយថា រមែងដឹងដោយជវនញ្ញាណក្នុងលំដាប់អាវជ្ជនៈ ។ ២ បទក្រៅអំពីនេះ លោកពោលដើម្បីប្រកាសអត្ថតាមលំដាប់របស់បទ ២ នោះ ។ ឈ្មោះថា **អាសយំ** ក្នុងបទថា **អាសយំ ជានាតិ** នេះ ព្រោះអត្ថថា ជាទីពឹង គឺទីអាស្រ័យនៃពួកសត្វ ។ បទនេះជាឈ្មោះនៃសន្តានដែលបានទទួលអប់រំដោយមិច្ឆាទិដ្ឋិខ្លះ ដោយសម្មាទិដ្ឋិខ្លះ ដោយកាមជាដើមខ្លះ ដោយនេក្ខម្មៈជាដើមខ្លះ ។

ឈ្មោះថា **អនុសយំ** ព្រោះអត្ថថា ដេកត្រាំ គឺប្រព្រឹត្តទៅតាមសន្តានរបស់សត្វ ពាក្យនេះជាឈ្មោះនៃកាមរាគៈជាដើមដែលមានកម្លាំង កថាពោល

ដោយអនុស្ស័យថា **អនុសយំ ជាឆាតិ** ដូច្នេះ បានពោលទុកហើយក្នុងខាងដើមនោះឯង ។

បទថា **ចរិតំ** បានដល់ កុសលកម្មនិងអកុសលដែលធ្វើទុកក្នុងកាលមុន ។ បទថា **អធិមុត្តឹ** បានដល់ ការបណ្តោយចិត្តទៅក្នុងកុសលក្តី ក្នុងអកុសលក្តី ។ បទថា **អប្បរជក្ខេ** សេចក្តីថា ឈ្មោះថា មានធូលី គឺកិលេសតិចក្នុងចក្ខុ ព្រោះអត្ថថា មានធូលី គឺកិលេសមានរាគៈជាដើម ក្នុងចក្ខុដែលសម្រេចដោយបញ្ញាតិច ។ម្យ៉ាងទៀត ឈ្មោះថា ជាអ្នកមានធូលី គឺកិលេសតិចក្នុងចក្ខុ ព្រោះអត្ថថា មានធូលី គឺកិលេសមានរាគៈជាដើមតិច ។

បទថា **មហារជក្ខេ** សេចក្តីថា ឈ្មោះថា **មហារជក្ខេ** ព្រោះអត្ថថា មានធូលី គឺកិលេសមានរាគៈជាដើម ក្នុងចក្ខុដែលសម្រេចដោយញាណច្រើន ។ ម្យ៉ាងទៀត ឈ្មោះថា **មហារជក្ខេ** ព្រោះអត្ថថា មានធូលី គឺកិលេស មានរាគៈជាដើមច្រើន ។

បទថា **តិក្ខិន្ទ្រិយេ មុទិន្ទ្រិយេ** សេចក្តីថា ឈ្មោះថា **តិក្ខិន្ទ្រិយេ** ព្រោះអត្ថថា មានឥន្ទ្រិយមានសទ្ធាជាដើមចាស់ក្លា ឈ្មោះថា **មុទិន្ទ្រិយេ** ព្រោះអត្ថថា មានឥន្ទ្រិយមានសទ្ធាជាដើមទន់ ។ បទថា **ស្វាការេ ទ្វាការេ** សេចក្តីថា ឈ្មោះថា **ស្វាការេ** ព្រោះអត្ថថា មានអាការ គឺកោដ្ឋាស មានសទ្ធាជាដើមដែលជាធម៌ល្អ ឈ្មោះថា **ទ្វាការេ** ព្រោះអត្ថថា មានអាការ គឺកោដ្ឋាស មានសទ្ធាជាដើមដែលជាធម៌គួរខ្ពើម គួរតិះដៀល ។

បទថា **សុវិញ្ញាបយេ ទុវិញ្ញាបយេ** សេចក្តីថា សត្វទាំងឡាយណា

កំណត់ហេតុដែលពោលហើយ អាចឲ្យដឹងច្បាស់ដោយងាយ សត្វទាំងនោះ ឈ្មោះថា **ស្វាវិញ្ញាបយេ** សត្វទាំងឡាយដែលផ្ទុយគ្នានឹងសត្វទាំងនោះ ឈ្មោះថា **ទុវិញ្ញាបយេ** ។

បទថា **ភព្វាភព្វេ** បានដល់ ជាភព្វសត្វនិងអភព្វសត្វ ។ ឈ្មោះថា ភព្វសត្វ ព្រោះអត្ថថា កើត គឺកើតក្នុងអរិយជាតិ ជាពាក្យបច្ចុប្បន្នកាល ចុះក្នុងអត្ថថា ជិត ដែលកំពុងប្រព្រឹត្តទៅ ។ ម្យ៉ាងទៀត ឈ្មោះថា ជាភព្វសត្វ ព្រោះអត្ថថា នឹងជា ឬនឹងកើត សេចក្តីថា ជាភាជនៈ ។ សត្វពួកណា ជាអ្នកសមគួរ គឺដល់ព្រមដោយឧបនិស្ស័យនៃការចាក់ធ្លុះអរិយមគ្គ សត្វទាំងនោះ ជាភព្វសត្វ ។ ពួកសត្វដែលផ្ទុយនឹងសត្វដែលពោលហើយ ជាអភព្វសត្វ ។ បទថា **សត្តេ ជានាតិ** សេចក្តីថា ទ្រង់ជ្រាបនូវពួកសត្វដែលជាប់ចំពាក់ក្នុងអារម្មណ៍មានរូបជាដើម ។

បទថា **សទេវកោ លោកោ** ជាដើម សេចក្តីថា ព្រមដោយទេវតាទាំងឡាយ ឈ្មោះថា **សទេវកោ** ។ ព្រមដោយមារឈ្មោះថា **សមារកោ** ព្រមដោយព្រហ្មឈ្មោះថា **សព្រហ្មកោ** ព្រមដោយសមណព្រាហ្មណ៍ទាំងឡាយ ឈ្មោះថា **សស្សមណព្រាហ្មណី** ។ ឈ្មោះថា **បជា** ព្រោះភាពជាពួកសត្វ ។ មួយអន្លើដោយទេវតានិងមនុស្សទាំងឡាយ ឈ្មោះថា **សទេវមនុស្សា** ។ បទថា **បជា** នេះ ជាពាក្យសម្តែងដល់សត្វលោក ។ បណ្តាបទទាំងនោះ ដោយបទថា **សទេវកោ** សំដៅយកទេវតា ៥ ជាន់ ក្នុងកាមាវចរ ។ ដោយបទថា **សមារកោ** សំដៅយកទេវតាជាន់កាមាវចរទី ៦ ។ ដោយបទថា

**សព្រហ្មកោ** សំដៅយកព្រហ្ម មានព្រហ្មកាយិកជាដើម ។ ដោយបទថា **សស្សមណព្រាហ្មណី** សំដៅយកសមណព្រាហ្មណ៍ដែលជាសត្រូវជាបច្ចាមិត្ត ចំពោះសាសនា និងសំដៅយកសមណព្រាហ្មណ៍ដែលស្ងប់បាប ដែលបន្សាត់បាបហើយ ។ ដោយបទថា **បជា** សំដៅដល់យកសត្វលោក ។ ដោយបទថា **សទេវមនុស្សា** ព្រោះសំដៅយកសម្មតិទេពនិងពួកមនុស្សដ៏សេស ក្នុងទីនេះ គប្បីជ្រាបថា ឱកាសលោក កាន់យក ៣ បទ សត្វលោកដោយអំណាច **បជា** កាន់យក ២ បទ ដោយប្រការដូច្នេះ ។

ន័យម្យ៉ាងទៀត អរូបាវចរលោក កាន់យកដោយសព្ទថា **សទេវកោ** ។ ឆកាមាវចរលោក កាន់យកដោយសព្ទថា **សមារកោ** ។ រូបាវចរព្រហ្មលោក កាន់យកដោយបទថា **សព្រហ្មកោ** ។ មនុស្សលោក មួយអន្លើដោយសម្មតិទេព ដោយអំណាចនៃបរិស័ទ ៤ ឬសត្វលោកដ៏សេស កាន់យកដោយសព្ទថា **សស្សមណព្រាហ្មណី** ជាដើម ។

ម្យ៉ាងទៀត ការកំណត់យ៉ាងឧក្រិដ្ឋ ដោយពាក្យថា **សទេវក** ក្នុងទីនេះ រមែងញ៉ាំងការប្រព្រឹត្តទៅខាងក្នុងពុទ្ធញ្ញាណ ឲ្យសម្រេចដល់លោកទាំងពួង ។ បន្ទាប់អំពីនោះ ពួកជនណា មានសេចក្ដីសង្ស័យថា មារមានអានុភាពច្រើន ជាធំក្នុងស្ថានសួគ៌ជាន់កាមាវចរ ៦ ជាអ្នកញ៉ាំងអំណាចឲ្យប្រព្រឹត្តទៅមារនោះប្រព្រឹត្តទៅខាងក្នុងពុទ្ធញ្ញាណបានដូចម្ដេច ព្រះថេរៈកាលកម្ចាត់សេចក្ដីសង្ស័យនៃជនទាំងនោះ ទើបពោលថា **សមារកោ** ដូច្នេះ ។

ម្យ៉ាងទៀត ជនពួកណា គប្បីមានសេចក្ដីសង្ស័យថា ព្រហ្មមាននូវអានុភាព

ច្រើន ផ្សាយពន្លឺទៅក្នុងមួយពាន់ចក្កវាឡ ដោយម្រាមដៃ ១ ពីរពាន់ចក្កវាឡ ដោយម្រាមដៃ ២ ។បេ។ មួយម៉ឺនចក្កវាឡដោយម្រាមដៃ ១០ និងសោយសុខដែលកើតអំពីឈានសមាបត្តិ ដែលមិនមានសុខដទៃក្រៃលែងជាងព្រហ្មទាំងនោះ ប្រព្រឹត្តទៅក្នុងពុទ្ធញាណបានដូចម្ដេច ព្រះថេរៈកាលកម្ចាត់សេចក្ដីសង្ស័យនៃជនទាំងនោះ ទើបពោលថា **សព្រហ្មកោ** ដូច្នេះ បន្ទាប់អំពីនោះ ជនពួកណា គប្បីមានសេចក្ដីសង្ស័យថា សមណព្រាហ្មណ៍ជាច្រើនដែលជាសត្រូវចំពោះព្រះសាសនា សមណព្រាហ្មណ៍ទាំងនោះ ប្រព្រឹត្តទៅក្នុងពុទ្ធញាណបានដូចម្ដេច ព្រះថេរៈកាលកម្ចាត់សេចក្ដីសង្ស័យនៃជនទាំងនោះ ទើបពោលថា **សស្សមណព្រាហ្មណី បជា** ដូច្នេះ ។ ព្រះថេរៈកាលប្រកាសការប្រព្រឹត្តទៅក្នុងពុទ្ធញាណនៃពួកសត្វដែលឧក្រិដ្ឋយ៉ាងនេះហើយ បន្ទាប់អំពីនោះ កាលនឹងប្រកាស ការប្រព្រឹត្តទៅក្នុងពុទ្ធញាណរបស់សត្វលោកដ៏សេសដោយអំណាចនៃការកំណត់យ៉ាងឧក្រិដ្ឋ រួមទាំងសម្មតិទេពនិងមនុស្សដ៏សេស ទើបពោលថា **សទេវមនុស្សា** ដូច្នេះ ។ ក្នុងសេចក្ដីនេះ មានលំដាប់អនុសន្ធិដូចតទៅនេះថា

បុរាណាចារ្យទាំងឡាយ ពោលថា បទថា **សទេវកោ** បានដល់ សត្វលោកដ៏សេសខាងក្រោមនិងទេវតាទាំងឡាយ ។ បទថា **សមារកោ** បានដល់ សត្វលោកដ៏សេសព្រមទាំងមារ ។ បទថា **សព្រហ្មកោ** បានដល់ សត្វលោកដ៏សេសព្រមទាំងព្រហ្មទាំងឡាយ ។ ព្រះថេរៈកាលដាក់ពួកសត្វដែលចូលដល់គត ៣ ទាំងអស់ ចូលក្នុង ៣ បទ ដោយអាការ ៣ ហើយទើប

ពោលថា **សស្សមណព្រាហ្មណា បជា សទេវមនុស្សា** ដើម្បីកាន់យកដោយអាការ ២ ទៀត ។ ធាតុ ៣ នោះឯង រមែងឈ្មោះថា លោកកាន់យកហើយដោយអាការនោះៗ ដោយបទទាំង ៥ ដោយប្រការដូច្នេះ ។

បទថា **អន្តមសោ** សេចក្ដីថា ដោយហោចខាងលើ ។ ក្នុងបទថា **តិមិ-តិមិង្គលំ** នេះ មច្ឆជាតិមួយប្រភេទឈ្មោះតិមិ មច្ឆជាតិមួយប្រភេទឈ្មោះតិមិង្គលៈ ខ្លួនធំជាងត្រីតិមិនោះ អាចលេបត្រីតិមិបាន ។ មច្ឆជាតិមួយប្រភេទឈ្មោះតិមិតិមិង្គលៈ បណ្ដោយប្រមាណ ៥០០ យោជន៍ អាចលេបត្រីតិមិង្គលៈបាន ។ ក្នុងទីនេះ គប្បីជ្រាបថា លោកធ្វើឯកវចនៈដោយសព្ទថា ជាតិ ( ប្រភេទ ) ។ ក្នុងបទថា **គរុឡំ វេនតេយ្យំ** នេះ ។

បទថា **គរុឡំ** នេះ ពាក្យថា **គរុឡំ** ជាឈ្មោះដោយជាតិ ។ ពាក្យថា **វេនតេយ្យំ** ជាឈ្មោះដោយគោត្ត ។ បទថា **បទេសេ** បានដល់ ផ្ទៃអាកាសមួយចំណែក ។ បទថា **សារិបុត្តសមា** គប្បីជ្រាបថា លោកពោលរួមយកព្រះថេរៈដែលជាធម្មសេនាបតីរបស់ព្រះពុទ្ធទាំងឡាយ ដ្បិតថា សាវកដ៏សេសទាំងឡាយ មានបញ្ញាស្មើនឹងព្រះធម្មសេនាបតីមិនមាន ដូចព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកភិក្ខុអ្នកមានប្រាជ្ញាច្រើន ដែលជាសាវករបស់តថាគត ស្រេចនឹងសារីបុត្ត ដូច្នេះ ។ ក្នុងអដ្ឋកថាលោកពោលថា

> ពួកសត្វដទៃៗ វៀរព្រះលោកនាថចេញ រមែងមានបញ្ញាមិន
> ដល់ចម្រៀកទី ១៦ ដែលគេច្រៀក ១៦ ដងនៃព្រះសារីបុត្ត
> ឡើយ ដូច្នេះ ។

បទថា **ជវិត្វា** សេចក្តីថា ព្រះពុទ្ធញ្ញាណសម្រេចដល់បញ្ហារបស់ទេវតានិងមនុស្សទាំងពួង គឺផ្សាយគ្របដណ្តប់នូវបញ្ហារបស់ទេវតានិងមនុស្សទាំងពួងនោះ តាំងនៅដោយឋានៈ ។ បទថា **អភិភវិត្វា** សេចក្តីថា ឈានកន្លងបញ្ហារបស់ទេវតានិងមនុស្សទាំងពួង គ្របសង្កត់បទធម៌ដែលគួរទូន្មានទាំងអស់ថា ជាវិស័យនៃទេវតានិងមនុស្សទាំងនោះតាំងនៅ តែបាឋៈក្នុងបដិសម្ភិទាមគ្គថា **អតិឃំសិត្វា** អធិប្បាយថា បុក គឺដុសខាត់ ព្រះថេរៈសម្តែងហេតុដែលប្រចក្សរបស់ការផ្សាយគ្របដណ្តប់តាំងនៅយ៉ាងនេះ ដោយបទថា **យេបិ តេ** ជាដើម ។ បណ្តាបទទាំងនោះ បទថា **បណ្ឌិតា** សេចក្តីថា ប្រកបដោយភាពជាបណ្ឌិត ។ បទថា **និបុណា** សេចក្តីថា ល្អិតល្អន់ គឺអាចចាក់ធ្លុះក្នុងរវាងអត្ថដែលសុខុមនៃអ្នកមានបញ្ញាសុខុម ។ បទថា **កតបរប្បវាទា** សេចក្តីថា ដឹងនូវវាទៈនៃអ្នកដទៃ និងលើកវាទៈជាមួយអ្នកដទៃមកហើយ ។ បទថា **វាលវេធិរូបា** សេចក្តីថា ដូចគ្នានឹងខ្មាន់ធ្នូ អ្នកបាញ់រោមកន្ទុយសត្វបាន ។ បទថា **វោភិន្ទន្តា មញ្ញេ ចរន្តិ បញ្ញាគតេន ទិដ្ឋិគតានិ** សេចក្តីថា ត្រាច់ទៅដូចទម្លាយទិដ្ឋិនៃបុគ្គលដទៃ សូម្បីល្អិត ដូចរោមកន្ទុយសត្វ ដោយបញ្ញារបស់ខ្លួន ។ ម្យ៉ាងទៀត **បញ្ញាគត** គឺបញ្ញានោះឯង **ទិដ្ឋិគត** គឺទិដ្ឋិនោះឯង ដូចក្នុងប្រយោគថា លាមកមូត្រ ( **គូថគតំ មុត្តគតំ** ) ជាដើម ។ បទថា **បញ្ហេ អភិសង្ខរិត្វា អភិសង្ខរិត្វា** សេចក្តីថា ចងនូវពាក្យសួរ ២ បទខ្លះ ៣ បទខ្លះ ៤ បទខ្លះ ពោល ២ ដង ដើម្បីប្រមូលបញ្ហាទាំងអស់ ព្រោះបញ្ហាទាំងនោះច្រើនពន់ពេក បាឋៈដ៏សេសថា សេចក្តីដែលកំបាំងនឹងបិទ

ប៉ាំងក៏មាន ។

ព្រោះព្រះមានព្រះភាគ ទ្រង់ឃើញវិន័យនៃបណ្ឌិតទាំងនោះយ៉ាងនេះហើយ មានព្រះពុទ្ធបំណងយ៉ាងនេះថា ចូរសួរប្រស្នាដែលខ្លួនចងទុកចុះ ទើបបណ្ឌិតទាំងនោះទូលសួរបញ្ហា តែព្រះមានព្រះភាគមិនប្រទានឱកាស ដើម្បីសួរដល់អ្នកដទៃឡើយ ទ្រង់សម្ដែងធម៌ដល់បុគ្គលដែលចូលគាល់ ដូចព្រះតម្រាស់ ( ក្នុងមជ្ឈិមនិកាយមូលបណ្ណាសក ) ថា

ខត្តិយបណ្ឌិតទាំងនោះចងប្រស្នាដោយគិតថា ពួកយើងនឹងចូលទៅគាល់ព្រះសមណគោតម ហើយក្រាបបង្គំទូលសួរប្រស្នានេះ បើយើងក្រាបបង្គំទូលប្រស្នាយ៉ាងនេះហើយ ព្រះអង្គមុខជានឹងព្យាករយ៉ាងនេះ ពួកយើងនឹងលើកទោសព្រះសមណគោតមនោះយ៉ាងនេះ បើយើងបានក្រាបបង្គំទូលសួរប្រស្នាយ៉ាងនេះហើយ ព្រះអង្គមុខជានឹងព្យាករយ៉ាងនេះ ពួកយើងនឹងលើកទោសព្រះសមណគោតមនោះ យ៉ាងនេះវិញ ។ ខត្តិយបណ្ឌិតទាំងនោះ ឮដំណឹងដូច្នេះថា ព្រះសមណគោតមដ៏ចម្រើន ទ្រង់ពុទ្ធដំណើរមកដល់ស្រុកឬនិគមឯណោះ ។ ទើបខត្តិយបណ្ឌិតទាំងនោះចូលទៅគាល់ព្រះសមណគោតម ។ ព្រះសមណគោតម ទ្រង់ញុំាងខត្តិយបណ្ឌិតទាំងនោះ ឲ្យយល់ឲ្យកាន់យកឲ្យក្លាហាន ឲ្យរីករាយ ដោយធម្មីកថា ពួកខត្តិយបណ្ឌិតនោះ ដែលព្រះសមណគោតម ទ្រង់ឲ្យយល់ឲ្យ

កាន់យក ឲ្យក្លាហាន ឲ្យរីករាយដោយធម្មីកថាហើយ ក៏មិន
អាចទូលសួរប្រស្នានឹងព្រះសមណគោតមបានឡើយ នឹងលើក
ទោសព្រះសមណគោតមដូចម្តេចបាន តាមពិតនឹងសម្រេច
ទៅជាសាវ័ករបស់ព្រះសមណគោតមវិញ ដូច្នេះ ។

បើនឹងសួរថា ព្រោះហេតុអ្វី ទើបបណ្ឌិតទាំងនោះមិនទូលសួរបញ្ហា បាន ឮថា ព្រះមានព្រះភាគ កាលទ្រង់សម្តែងធម៌ក្នុងកណ្តាលបរិស័ទ ទ្រង់រមែង ត្រួតពិនិត្យអធ្យាស្រ័យរបស់បរិស័ទ ។ លំដាប់នោះ ទ្រង់ជ្រាបថា បណ្ឌិត ទាំងនេះ មករកដោយធ្វើបញ្ហាអាថ៌កំបាំងជាគ្រឿងចងបណ្ឌិតទាំងនោះ មិនទាន់ សួរឡើយ ទ្រង់ជ្រាបថា ក្នុងការសួរបញ្ហាមានទោសប៉ុណ្ណេះ ក្នុងការវិសជ្ជនា មានទោសប៉ុណ្ណេះ ក្នុងអត្ថ បទ អក្ខរៈ មានទោសប៉ុណ្ណេះ ទ្រង់ជ្រាបថា កាល សួរបញ្ហានេះ គប្បីសួរយ៉ាងនេះ កាលវិសជ្ជនា គប្បីវិសជ្ជនាយ៉ាងនេះ ទើប ទ្រង់ដាក់បញ្ហាទាំងឡាយដែលពួកបណ្ឌិតនាំមកធ្វើជាគ្រឿងចង ព្រះអង្គចូល ទៅក្នុងរវាងធម្មីកថា សម្តែងដោយប្រការដូច្នេះ ។ បណ្ឌិតទាំងនោះ រមែងនាំ គ្នាត្រេកអរថា ជាការល្អរបស់ពួកយើងហ្ន៎ ដែលពួកយើងមិនទូលសួរបញ្ហា ទាំងនេះ បើពួកយើងទូលសួរព្រះសមណគោតមគប្បីបន្សាត់ ឲ្យពួកយើង តម្កល់ខ្លួនមិនបាន ដូច្នេះ ។ ម្យ៉ាងទៀត ធម្មតាព្រះពុទ្ធទាំងឡាយ កាលទ្រង់ សម្តែងធម៌ រមែងផ្សាយមេត្តាទៅកាន់បរិស័ទ មហាជនរមែងមានចិត្តជ្រះថ្លាក្នុង ព្រះទសពលព្រោះការផ្សាយមេត្តានោះ ធម្មតាព្រះពុទ្ធទាំងឡាយ រមែងដល់ នូវភាពជាបុគ្គលប្រសើរដោយរូប សម្បូរដោយទស្សនៈ មានសំឡេងពីរោះ

មានជិវ្ហាទន់ មានបបូរព្រះឱស្ឋជិតស្និទ្ធ ត្រាស់ធម៌ដូចស្រោចហទយៈដោយទឹកអម្រឹត ក្នុងសេចក្តីនោះ ពួកបណ្ឌិតដែលមានចិត្តជ្រះថ្លា ដោយការផ្សាយមេត្តាទាំងនោះ រមែងគិតយ៉ាងនេះថា ពួកយើងមិនអាចធ្វើជាដៃគូនឹងព្រះមានព្រះភាគដែលត្រាស់នូវកថាមិនបែកជាពីរ ជាកថាមិនសោះសូន្យ ជាកថានាំចេញចាកទុក្ខបែបនេះ ទើបមិនទូលសួរបញ្ហា ព្រោះការជ្រះថ្លារបស់ខ្លួននោះឯង ។

បទថា **កថិតា ច វិសជ្ជិតា ច** សេចក្តីថា បញ្ហាទាំងនោះ រមែងឈ្មោះថា ព្រះមានព្រះភាគត្រាស់ដល់ហើយនោះឯង ដោយការលើកឡើងនូវប្រស្នាដែលពួកបណ្ឌិតមិនទូលសួរថា ពួកអ្នកចូរសួរយ៉ាងនេះ បញ្ហាទាំងនោះ ឈ្មោះថា ទ្រង់វិសជ្ជនាហើយនោះឯង ដោយប្រការដែលគួរវិសជ្ជនា ។

បទថា **និទ្ទិដ្ឋការណា** សេចក្តីថា បញ្ហាទាំងនោះ រមែងមានហេតុដែលព្រះមានព្រះភាគទ្រង់សម្តែងដោយវិសជ្ជនា ធ្វើឲ្យមានហេតុយ៉ាងនេះថា ដោយការណ៍នេះ ដោយហេតុនេះ ទើបជាយ៉ាងនេះ ទ្រង់ដោះស្រាយហើយ ។ បទថា **តេ ភគវតោ សម្បជ្ជន្តិ** សេចក្តីថា ពួកបណ្ឌិតជាក្សត្រជាដើម ដែលត្រូវបបួលចូលទៅជិតព្រះមានព្រះភាគ រមែងជាសាវកជ្រះថ្លាខ្លះ ជាឧបាសកជ្រះថ្លាខ្លះ ដោយការវិសជ្ជនារបស់ព្រះមានព្រះភាគនោះឯង មានអធិប្បាយថា រមែងដល់នូវសម្បត្តិរបស់សាវកខ្លះ សម្បត្តិរបស់ឧបាសកខ្លះ ។

បទថា **អថ** ចុះក្នុងអត្ថថា មិនមានចន្លោះ សេចក្តីថា ជិតបំផុតចំពោះសម្បត្តិដែលទ្រង់ដាក់បញ្ចូលដល់បណ្ឌិតទាំងនោះឯង ។ បទថា **តត្ថ** សេចក្តី

ថា ក្នុងឋានៈនោះ ឬក្នុងអធិការនោះ ។ បទថា **អតិរោចតិ** សេចក្តីថា ទ្រង់រុងរឿងក្រៃលែង ។ បទថា **យទិទំ បញ្ញាយ** សេចក្តីថា ព្រះបញ្ញារបស់ព្រះមានព្រះភាគនេះឯណា ដោយព្រះបញ្ញានោះ អធិប្បាយថា ព្រះមានព្រះភាគទ្រង់រុងរឿងក្រៃលែង ។ **ឥតិ** សព្ទ ចុះក្នុងអត្ថថា ហេតុ សេចក្តីថា ព្រោះហេតុនោះ ។ ពាក្យដ៏សេសប្រាកដច្បាស់ហើយក្នុងទីទាំងពួងនោះឯង ។

## អដ្ឋកថា បសូរសុត្តនិទ្ទេសទី ៨ ចប់

# សុត្តន្តបិដក

# ខុទ្ទកនិកាយ មហានិទ្ទេស

# ទុតិយភាគ

# មាគន្ទិយសុត្តនិទ្ទេសទី ៩

[ ១ ] ( ព្រះមានព្រះភាគទ្រង់ត្រាស់ថា ) ឯចំណង់ក្នុងមេថុនមិនមាន ( ដល់តថាគត ) ព្រោះឃើញនាងតណ្ហា នាងអរតីនិងនាងរាគាឡើយ ( ចំណង់ក្នុងមេថុននឹងមានដល់តថាគតព្រោះឃើញ ) នូវសរីរៈនៃធីតារបស់អ្នកនេះ ដ៏ពេញដោយមូត្រនិងករីស ដូចម្ដេចកើត តថាគតមិនត្រូវការដើម្បីប៉ះពាល់នូវសរីរៈនៃធីតានោះ សូម្បីដោយជើងឡើយ ។

[ ២ ] ពាក្យថា ឯចំណង់ក្នុងមេថុនមិនមាន ( ដល់តថាគត ) ព្រោះឃើញនាងតណ្ហា នាងអរតីនិងនាងរាគាឡើយ សេចក្ដីថា ចំណង់ក្ដី តម្រេកក្ដី សេចក្ដីស្រឡាញ់ក្ដី ក្នុងមេថុនធម្មមិនមាន ព្រោះឃើញ ព្រោះប្រទះនូវមារធីតាឈ្មោះតណ្ហា ១ អរតី ១ រាគា ១ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ឯចំណង់ក្នុងមេថុនមិនមាន ( ដល់តថាគត ) ព្រោះឃើញនាងតណ្ហា នាងអរតី និងនាងរាគាឡើយ ។

[ ៣ ] ពាក្យថា ( ចំណង់ក្នុងមេថុននឹងមានដល់តថាគត ព្រោះឃើញ ) នូវសរីរៈនៃធីតារបស់អ្នកនេះ ដ៏ពេញដោយមូត្រនិងករីសដូចម្ដេចកើត តថាគតមិនត្រូវការដើម្បីប៉ះពាល់នូវសរីរៈនៃធីតានោះ សូម្បីដោយជើងឡើយ អធិប្បាយថា ( ចំណង់ក្នុងមេថុននឹងមានដល់តថាគត ព្រោះឃើញ ) នូវសរីរៈនេះ

ដ៏ពេញដោយមូត្រ ពេញដោយករីស ពេញដោយស្លេស្ម ពេញដោយឈាម មានរាងឆ្អឹង រឹតរួតដោយសរសៃ លាបដោយឈាមនិងសាច់ ពាសដោយស្បែក បិទបាំងដោយសម្បុរថ្ងៃ មានប្រហោងតូចប្រហោងធំ តែងហូរចេញហូរចូល ជាលំនៅនៃពួកដង្កូវ ដ៏ពេញដោយមន្ទិលមិនស្អាតផ្សេងៗ ដូចម្តេចបាន តថាគតមិនត្រូវការដើម្បីជាន់ដោយជើងឡើយ ការនៅរួម ឬការសមាគមមានមកពីណា ហេតុនោះ ( ទ្រង់ត្រាស់ថា ) ( ចំណង់ក្នុងមេថុននឹងមានដល់តថាគតព្រោះឃើញ ) នូវសរីរៈនេះ ដ៏ពេញដោយមូត្រនិងករីសដូចម្តេចកើត តថាគតមិនត្រូវការដើម្បីប៉ះពាល់នូវសរីរៈនៃធីតានោះ សូម្បីដោយជើងឡើយ ។ ហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ហើយថា

ឯចំណង់ក្នុងមេថុនមិនមាន ( ដល់តថាគត ) ព្រោះឃើញនាងតណ្ហា នាងអរតី និងនាងរាគាឡើយ ( ចំណង់ក្នុងមេថុននឹងមានដល់តថាគតព្រោះឃើញ ) នូវសរីរៈនៃធីតារបស់អ្នកនេះ ដ៏ពេញដោយមូត្រនិងករីស ដូចម្តេចកើត តថាគតមិនត្រូវការដើម្បីប៉ះពាល់នូវសរីរៈនៃធីតានោះ សូម្បីដោយជើងឡើយ ។

[ ៤ ] ( មាគន្ទិយព្រាហ្មណ៍សួរថា ) បើព្រះអង្គមិនត្រូវការនារីរតន៍បែបនុ៎ះ ដែលពួកអ្នកនរិន្ទ្រមានប្រមាណច្រើន ប្រាថ្នាហើយទេ តើព្រះអង្គពោលនូវទិដ្ឋិ សីល វត្ត ជីវិត កិរិយាកើតក្នុងភពបែបណាវិញ ។

[ ៥ ] ( ព្រះមានព្រះភាគត្រាស់ថា ម្នាលមាគន្ទិយៈ ) ការជ្រើស

រើស ហើយប្រកាន់ក្នុងធម៌ទាំងឡាយថា អាត្មាអញ ពោលនូវពាក្យនេះដូច្នេះ មិនមានដល់តថាគតនោះទេ ព្រោះតថាគតឃើញ ( ទោស ) ក្នុងទិដ្ឋិទាំងឡាយ មិនប្រកាន់ហើយ បានពិចារណាឃើញនូវសេចក្ដីស្ងប់ខាងក្នុង ។

[ ៦ ] ពាក្យថា តថាគតពោលពាក្យនេះ របស់បទថា អាត្មាអញពោលពាក្យនេះ ដូច្នេះមិនមានដល់តថាគតនោះទេ សេចក្ដីថា តថាគតពោលពាក្យនេះ ពោលពាក្យនុ៎ះ ពោលពាក្យមានប្រមាណប៉ុណ្ណេះ ពោលពាក្យមានប្រ-មាណប៉ុណ្ណោះ ពោលទិដ្ឋិនេះថា លោកទៀងដូច្នេះក្ដី ។បេ។ សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនដូច្នេះក្ដី ។ ពាក្យថាមិនមានដល់តថាគតនោះ គឺមិនមានដល់តថាគតទេ ហេតុនោះ ( ទ្រង់ត្រាស់ថា ) អាត្មាអញពោលពាក្យនេះដូច្នេះ មិនមានដល់តថាគតនោះទេ ។ ពាក្យថា ម្នាលមាគន្ទិយៈ គឺព្រះមានព្រះភាគត្រាស់ហៅព្រាហ្មណ៍នោះ ដោយចំណោះ ។ ពាក្យថាព្រះមានព្រះភាគ គឺជាពាក្យហៅដោយគោរព ។បេ។ ការបញ្ញត្តថា ព្រះមានព្រះភាគនេះ កើតដោយការត្រាស់ដឹង ហេតុនោះលោកពោលថា ព្រះមានព្រះភាគត្រាស់ហៅថាមាគន្ទិយៈ ។

[ ៧ ] ពាក្យថា ក្នុងធម៌ទាំងឡាយនៃបទថា ការជ្រើសរើសហើយប្រកាន់ក្នុងធម៌ទាំងឡាយ គឺក្នុងទិដ្ឋិ ៦២ ។ ពាក្យថាជ្រើសរើស គឺការជ្រើសរើស ពិចារណា រិះរក រិះគិត ថ្លឹងមើល លៃលក ធ្វើឲ្យច្បាស់លាស់ ធ្វើឲ្យប្រាកដ ហើយប្រកាន់ដោយជួរ ប្រកាន់ដោយចន្លោះ ប្រកាន់ថាប្រសើរ ប្រកាន់ដោយចំណែក ប្រកាន់ដោយគំនរ ប្រកាន់ដោយគំនរធំ ប្រកាន់បបោសអង្អែល

ចូលចិត្ត ចុះចិត្ត ចុះចិត្តស៊ប់ថា ពាក្យនេះជាពាក្យទៀង ជាពាក្យពិត ពាក្យប្រាកដ ពាក្យមែន ពាក្យទៀងទាត់ ពាក្យមិនប្រែប្រួលដូច្នេះ មិនមាន មិនមានព្រម តថាគតមិនបាន តថាគតលះបង់ ផ្តាច់បង់ ឲ្យស្ងប់រម្ងាប់ហើយ ធ្វើមិនគួរឲ្យកើតឡើងទៀត ដុតដោយភ្លើងគឺញាណហើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ការជ្រើសរើស ហើយប្រកាន់ក្នុងធម៌ទាំងឡាយ ។

[ ៨ ] ពាក្យថាតថាគតឃើញ ( ទោស ) ក្នុងទិដ្ឋិទាំងឡាយ មិនប្រកាន់ អធិប្បាយថា តថាគតកាលឃើញទោសក្នុងទិដ្ឋិទាំងឡាយ មិនប្រកាន់ មិនបបោសអង្អែល មិនជាប់ចិត្តនូវទិដ្ឋិទាំងឡាយ ឬថាទិដ្ឋិទាំងឡាយ តថាគតមិនគប្បីប្រកាន់ មិនគប្បីបបោសអង្អែល មិនគប្បីជាប់ចិត្ត ហេតុនោះ ( ទ្រង់ត្រាស់ថា ) តថាគតឃើញ ( ទោស ) ក្នុងទិដ្ឋិទាំងឡាយ មិនប្រកាន់ដោយប្រការយ៉ាងនេះឯង ។ មួយទៀត ដំណើរគឺទិដ្ឋិ សេចក្តីប្រកាន់គឺទិដ្ឋិ ផ្លូវឆ្ងាយគឺទិដ្ឋិ ចម្រូងគឺទិដ្ឋិ ការអន្ទះអន្ទែងគឺទិដ្ឋិ សំយោជនៈគឺទិដ្ឋិនុ៎ះថា លោកទៀង ពាក្យនេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ឯទិដ្ឋិនេះប្រកបដោយទុក្ខ ប្រកបដោយសេចក្តីថ្នាំងថ្នាក់ ប្រកបដោយសេចក្តីចង្អៀតចង្អល់ ប្រកបដោយសេចក្តីក្រហល់ក្រហាយ មិនប្រព្រឹត្តទៅព្រមដើម្បីសេចក្តីនឿយណាយទេ ដើម្បីប្រាសចាកតម្រេកទេ ដើម្បីសេចក្តីរលត់ទុក្ខទេ ដើម្បីសេចក្តីស្ងប់រម្ងាប់ទេ ដើម្បីអភិញ្ញាទេ ដើម្បីកិរិយាត្រាស់ដឹងទេ ដើម្បីព្រះនិព្វានទេ តថាគតឃើញទោសក្នុងទិដ្ឋិទាំងឡាយដូច្នេះ ទើបមិនប្រកាន់យក មិនបបោសអង្អែល មិនជាប់ចិត្តនូវទិដ្ឋិទាំងឡាយ ឬថាទិដ្ឋិទាំងឡាយ តថាគតមិនគប្បីប្រកាន់យក

*មិនគប្បីបបោសអង្អែល មិនគប្បីជាប់ចិត្ត ហេតុនោះ ( ទ្រង់ត្រាស់ថា ) តថាគតឃើញទោសក្នុងទិដ្ឋិទាំងឡាយ មិនប្រកាន់ដោយប្រការយ៉ាងនេះឯង ។ ដំណើរគឺទិដ្ឋិ ការប្រកាន់គឺទិដ្ឋិ ផ្លូវឆ្ងាយគឺទិដ្ឋិ ចម្រូងគឺទិដ្ឋិ សេចក្តីអន្ទះអន្ទែង គឺទិដ្ឋិ សំយោជនៈគឺទិដ្ឋិនុ៎ះថា លោកមិនទៀង លោកមានទីបំផុត លោកមិនមានទីបំផុត ជីវៈនោះ សរីរៈនោះ ជីវៈដទៃ សរីរៈដទៃ សត្វស្លាប់ហើយកើតទៀត សត្វស្លាប់ហើយមិនកើតទៀត សត្វស្លាប់ហើយកើតទៀតក៏មាន មិនកើតទៀតក៏មាន សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ពាក្យនេះ ឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ឯទិដ្ឋិនេះប្រកបដោយទុក្ខ ប្រកបដោយសេចក្តីចង្អៀតចង្អល់ ប្រកបដោយសេចក្តីថ្នាំងថ្នាក់ ប្រកបដោយសេចក្តីក្រហល់ក្រហាយ មិនប្រព្រឹត្តទៅព្រមដើម្បីសេចក្តីនឿយណាយទេ ដើម្បីសេចក្តីប្រាសចាកតម្រេកទេ ដើម្បីសេចក្តីរលត់ទុក្ខទេ ដើម្បីសេចក្តីស្ងប់រម្ងាប់ទេ ដើម្បីអភិញ្ញាទេ ដើម្បីកិរិយាត្រាស់ដឹងទេ ដើម្បីព្រះនិព្វានទេ តថាគតឃើញទោសក្នុងទិដ្ឋិទាំងឡាយដូច្នេះ ទើបមិនប្រកាន់ មិនបបោសអង្អែល មិនជាប់ចិត្តនូវទិដ្ឋិទាំងឡាយ ឬថាទិដ្ឋិទាំងឡាយ តថាគតមិនគប្បីប្រកាន់យក មិនគប្បីបបោសអង្អែល មិនគប្បីជាប់ចិត្ត ហេតុនោះ ( ទ្រង់ត្រាស់ថា ) តថាគតឃើញទោសក្នុងទិដ្ឋិទាំងឡាយ មិនប្រកាន់ដោយប្រការយ៉ាងនេះឯង ។ មួយទៀត តថាគតឃើញទោសក្នុងទិដ្ឋិទាំងឡាយថា ទិដ្ឋិទាំងនេះដែលតថាគត ប្រកាន់យ៉ាងនេះ បបោសអង្អែលយ៉ាងនេះ មានគតិយ៉ាងនេះ មានលោកខាងមុខយ៉ាងនេះ ទើបមិនប្រកាន់ មិនបបោសអង្អែល មិនជាប់ចិត្តនូវទិដ្ឋិទាំង*

ឡាយ ឬថាទិដ្ឋិទាំងឡាយ តថាគតមិនគប្បីប្រកាន់ មិនគប្បីបបោសអង្អែល មិនគប្បីជាប់ចិត្ត ហេតុនោះ ( ទ្រង់ត្រាស់ថា ) តថាគតឃើញទោសក្នុងទិដ្ឋិទាំងឡាយ មិនប្រកាន់ដោយប្រការយ៉ាងនេះឯង ។ មួយទៀត តថាគតឃើញទោសក្នុងទិដ្ឋិទាំងឡាយថា ទិដ្ឋិទាំងនេះប្រព្រឹត្តទៅដើម្បីនរក ប្រព្រឹត្តទៅដើម្បីតិរច្ឆានកំណើត ប្រព្រឹត្តទៅដើម្បីបិត្តិវិស័យ ទើបមិនប្រកាន់ មិនបបោសអង្អែល មិនជាប់ចិត្តនូវទិដ្ឋិទាំងឡាយ ឬថាទិដ្ឋិទាំងឡាយ តថាគតមិនគប្បីប្រកាន់ មិនគប្បីបបោសអង្អែល មិនគប្បីជាប់ចិត្ត ហេតុនោះ ( ទ្រង់ត្រាស់ថា ) តថាគតឃើញទោសក្នុងទិដ្ឋិទាំងឡាយ មិនប្រកាន់ដោយប្រការយ៉ាងនេះឯង ។ មួយទៀត តថាគតឃើញទោសក្នុងទិដ្ឋិទាំងឡាយថា ទិដ្ឋិទាំងនេះមិនទៀង គឺបច្ច័យតាក់តែងឡើងហើយ អាស្រ័យបច្ច័យកើតឡើងហើយ មានកិរិយាអស់ទៅជាធម្មតា មានកិរិយាសូន្យទៅជាធម្មតា មានកិរិយាប្រាសទៅជាធម្មតា មានកិរិយារលត់ទៅជាធម្មតា ទើបមិនប្រកាន់ មិនបបោសអង្អែល មិនជាប់ចិត្តនូវទិដ្ឋិទាំងឡាយ ឬថាទិដ្ឋិទាំងឡាយ តថាគតមិនគប្បីប្រកាន់ មិនគប្បីបបោសអង្អែល មិនគប្បីជាប់ចិត្ត ហេតុនោះ ( ទ្រង់ត្រាស់ថា ) តថាគតឃើញទោសក្នុងទិដ្ឋិទាំងឡាយ មិនប្រកាន់ដោយប្រការយ៉ាងនេះឯង ។

[ ៩ ] ពាក្យថា បានពិចារណាឃើញនូវសេចក្តីស្ងប់ខាងក្នុង គឺសេចក្តីស្ងប់រាគៈ សេចក្តីស្ងប់ទោសៈ សេចក្តីស្ងប់មោហៈ ប្រព្រឹត្តទៅខាងក្នុង និងសេចក្តីស្ងប់ សេចក្តីស្ងប់រម្ងាប់ សេចក្តីរលត់ សេចក្តីស្ងប់ស្ងៀមនៃកោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋេយ្យៈ ថម្ភៈ សារម្ភៈ

មានៈ អតិមានៈ មទៈ បមាទៈ និងកិលេសទាំងអស់ ទុច្ចរិតទាំងអស់ សេចក្ដីក្រវល់ក្រវាយទាំងអស់ សេចក្ដីក្រហល់ក្រហាយទាំងអស់ សេចក្ដីអន្ទះសាទាំងអស់ អភិសង្ខារជាអកុសលទាំងអស់ ។ ពាក្យថា បានពិចារណា គឺកាលពិចារណា កាលត្រិះរិះ កាលរំពឹង កាលថ្លឹង កាលលៃលក កាលបំភ្លឺ កាលធ្វើឲ្យច្បាស់ថា សង្ខារទាំងឡាយទាំងពួងមិនទៀង កាលពិចារណា កាលត្រិះរិះ កាលរំពឹង កាលថ្លឹង កាលលៃលក កាលបំភ្លឺ កាលធ្វើឲ្យច្បាស់ថា សង្ខារទាំងឡាយទាំងពួងជាទុក្ខ ថាធម៌ទាំងឡាយទាំងពួងជាអនត្តា ។បេ។ កាលពិចារណា កាលត្រិះរិះ កាលរំពឹង កាលថ្លឹង កាលលៃលក កាលបំភ្លឺ កាលធ្វើឲ្យច្បាស់ថា វត្ថុណាមួយមានសភាពកើតឡើងហើយ វត្ថុទាំងអស់នោះមានកិរិយារលត់ទៅវិញជាធម្មតា ។ ពាក្យថាបានឃើញ គឺបានជួប បានយល់ បានប្រទះ បានត្រាស់ដឹង ហេតុនោះ ( ទ្រង់ត្រាស់ថា ) បានពិចារណាឃើញនូវសេចក្ដីស្ងប់ខាងក្នុង ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

> ការជ្រើសរើសហើយប្រកាន់ក្នុងធម៌ទាំងឡាយថា អាត្មាអញ
> ពោលនូវពាក្យនេះដូច្នេះ មិនមានដល់តថាគតនោះទេ ព្រោះ
> តថាគតឃើញ ( ទោស ) ក្នុងទិដ្ឋិទាំងឡាយ មិនប្រកាន់
> ហើយ បានពិចារណាឃើញនូវសេចក្ដីស្ងប់ខាងក្នុង ។

[ ១០ ] ( មាគន្ទិយព្រាហ្មណ៍សួរថា ) ធម្មជាតិជាគ្រឿងជ្រើសរើសណាដែលបុគ្គលកំណត់ហើយ ព្រះអង្គជាមុនិ មិនប្រកាន់នូវធម្មជាតិជាគ្រឿងជ្រើសរើសទាំងនោះ ហើយត្រាស់សេចក្ដីណាថា សេចក្ដីស្ងប់ខាងក្នុង

សេចក្តីនោះអ្នកប្រាជ្ញទាំងឡាយ សម្តែងហើយដូចម្តេចហ្ន៎ ។

[ ១១ ] ទិដ្ឋិ ៦២ លោកហៅថា ធម្មជាតិជាគ្រឿងជ្រើសរើសរបស់បទថា ធម្មជាតិជាគ្រឿងជ្រើសរើសដែលគេកំណត់ហើយ ។

ពាក្យថា គេកំណត់ហើយ គឺគេសម្រេច តែងតាំង រៀបចំ គេតែងតាំងដូច្នេះខ្លះ ឬថាមិនទៀង បច្ច័យតាក់តែង អាស្រ័យបច្ច័យហើយទើបកើតឡើង មានកិរិយាអស់ទៅជាធម្មតា សូន្យទៅជាធម្មតា ប្រាសទៅជាធម្មតា រលត់ទៅជាធម្មតា ប្រែប្រួលទៅជាធម្មតា គេតែងតាំងដូច្នេះខ្លះ ហេតុនោះ ( ព្រាហ្មណ៍ពោលថា ) ធម្មជាតិជាគ្រឿងជ្រើសរើសណា ដែលគេកំណត់ហើយ ។ ពាក្យថាដូច្នេះ ក្នុងបទថា មាគន្ទិយព្រាហ្មណ៍ពោលដូច្នេះ គឺជាបទសន្ធិ ។បេ។ ពាក្យថាដូច្នេះ នុ៎ះជាលំដាប់បទ ។ ពាក្យថា មាគន្ទិយៈ ជានាម ជាកិរិយារាប់ ជាឈ្មោះ ជាពាក្យហៅព្រាហ្មណ៍នោះ ហេតុនោះមានពាក្យថា មាគន្ទិយព្រាហ្មណ៍ពោល ដូច្នេះ ។

[ ១២ ] ពាក្យថានូវធម៌ទាំងនោះ ក្នុងបទថា ព្រះអង្គជាមុនី មិនប្រកាន់នូវធម៌ទាំងនោះ ហើយត្រាស់នូវសេចក្តីណាថា សេចក្តីស្ងប់ខាងក្នុង គឺបានដល់ទិដ្ឋិ ៦២ ។ ញាណហៅថាមោនៈ ក្នុងបទថាមុនិ ។បេ។ មុនិនោះកន្លងបណ្តាញជាគ្រឿងជាប់ចំពាក់ ។ ពាក្យថាមិនប្រកាន់ គឺព្រះអង្គប្រកាន់ថាតថាគតឃើញទោសក្នុងទិដ្ឋិទាំងឡាយ មិនប្រកាន់ មិនបបោសអង្អែល មិនជាប់ចិត្តនូវទិដ្ឋិទាំងឡាយ ទាំងត្រាស់ថា សេចក្តីស្ងប់ខាងក្នុង ។ ពាក្យថានូវសេចក្តីណា គឺព្រះអង្គជាមុនិ មិនប្រកាន់នូវធម៌ទាំងនោះ ត្រាស់នូវសេចក្តីដ៏

ឧត្តមណាថា មានសេចក្ដីស្ងប់ខាងក្នុង ហេតុនោះ ( ព្រាហ្មណ៍ពោលថា ) នូវសេចក្ដីណា ។

[ ១៣ ] ពាក្យថាដូចម្ដេចហ្ន៎ ក្នុងបទថា ដែលអ្នកប្រាជ្ញទាំងឡាយសម្ដែងហើយ ដូចម្ដេចហ្ន៎ គឺជាការសួរដោយសង្ស័យ សួរដោយងឿងឆ្ងល់ សួរដោយមន្ទិល សួរដោយចំណែកច្រើន ដោយពាក្យថា យ៉ាងនេះឬហ្ន៎ មិនមែនទេហ្ន៎ ដូចម្ដេចហ្ន៎ ដោយប្រការដូចម្ដេចហ្ន៎ ហេតុនោះ ( ព្រាហ្មណ៍ពោលថា ) ដូចម្ដេចហ្ន៎ ។ ពាក្យថាអ្នកប្រាជ្ញទាំងឡាយ គឺបណ្ឌិតអ្នកមានបញ្ញា មានបញ្ញាជាគ្រឿងត្រាស់ដឹង អ្នកមានញាណ អ្នកមានការយល់ច្បាស់ អ្នកមានប្រាជ្ញាជាគ្រឿងពុះពារទាំងឡាយ ។ ពាក្យថាសម្ដែងហើយ គឺពន្យល់ សម្ដែងប្រាប់ បង្ហាញ បញ្ញត្ត តាំងទុក បង្ហើប វែកញែក ធ្វើឲ្យរាក់ ប្រកាសហើយ ហេតុនោះព្រាហ្មណ៍ពោលថា អ្នកប្រាជ្ញទាំងឡាយ សម្ដែងហើយដូចម្ដេចហ្ន៎ ។ ហេតុនោះព្រាហ្មណ៍នោះទូលថា

ធម្មជាតិជាគ្រឿងជ្រើសរើសណា ដែលបុគ្គលកំណត់ហើយ
ព្រះអង្គជាមុនិ មិនប្រកាន់ធម៌ទាំងនោះ ហើយត្រាស់នូវ
សេចក្ដីណាថា សេចក្ដីស្ងប់ខាងក្នុង សេចក្ដីនោះ អ្នកប្រាជ្ញ
ទាំងឡាយសម្ដែងហើយដូចម្ដេចហ្ន៎ ។

[ ១៤ ] ( ព្រះមានព្រះភាគត្រាស់តបថា ម្នាលមាគន្ទិយៈ ) អ្នកប្រាជ្ញមិនពោលនូវសេចក្ដីបរិសុទ្ធ ព្រោះការឃើញទេ ព្រោះការឮទេ ព្រោះការដឹងទេ ព្រោះសីលនិងវត្តទេ ទាំងមិន ( ពោលនូវសេចក្ដីបរិសុទ្ធ ) ព្រោះការ

មិនឃើញ ព្រោះការមិនឮ ព្រោះការមិនដឹង ព្រោះមិនមានសីល ព្រោះមិនមានវត្តនោះទេ ទាំងលះបង់ មិនប្រកាន់ធម៌ទាំងនោះ ជាអ្នកស្ងប់មិនអាស្រ័យ មិនគប្បីប្រាថ្នាភព ។

[ ១៥ ] ពាក្យថាព្រោះការឃើញទេ ព្រោះការឮទេ ព្រោះការដឹងទេ អធិប្បាយថា អ្នកប្រាជ្ញមិនពោល មិនថ្លែង មិនពណ៌នា មិនពន្យល់ មិនសម្តែងនូវសេចក្តីស្អាត ស្អាតវិសេស បរិសុទ្ធិ ការផុត ផុតស្រឡះ ផុតជុំវិញ ព្រោះការដែលឃើញ ។ មិនពោល មិនថ្លែង មិនពណ៌នា មិនពន្យល់ មិនសម្តែងនូវសេចក្តីស្អាត ស្អាតវិសេស បរិសុទ្ធិ ការផុត ផុតស្រឡះ ផុតជុំវិញ ព្រោះការដែលឮ ។ មិនពោល មិនថ្លែង មិនពណ៌នា មិនពន្យល់ មិនសម្តែងនូវសេចក្តីស្អាត ស្អាតវិសេស បរិសុទ្ធិ ការផុត ផុតស្រឡះ ផុតជុំវិញ ព្រោះការឃើញទាំងការឮ ។ មិនពោល មិនថ្លែង មិនពណ៌នា មិនពន្យល់ មិនសម្តែងនូវសេចក្តីស្អាត ស្អាតវិសេស បរិសុទ្ធិ ការផុត ផុតស្រឡះ ផុតជុំវិញ ព្រោះការដឹង ហេតុនោះ ( ទ្រង់ត្រាស់ថា ) ព្រោះការឃើញទេ ព្រោះការឮទេ ព្រោះការដឹងទេ ។ ពាក្យថាមាគន្ទិយៈ គឺព្រះមានព្រះភាគ ត្រាស់ហៅព្រាហ្មណ៍នោះដោយចំណោះ ។ ពាក្យថាព្រះមានព្រះភាគ ជាពាក្យហៅដោយគោរព ។បេ។ សេចក្តីបញ្ញត្តថា ព្រះមានព្រះភាគនេះ ( កើត ) អំពីការត្រាស់ដឹង ហេតុនោះ ( មានពាក្យថា ) ព្រះមានព្រះភាគត្រាស់ហៅថា មាគន្ទិយៈ ។

[ ១៦ ] ពាក្យថា អ្នកប្រាជ្ញមិនពោលនូវសេចក្តីបរិសុទ្ធ ព្រោះសីលនិងវត្តទេ សេចក្តីថាអ្នកប្រាជ្ញមិនពោល មិនថ្លែង មិនពណ៌នា មិនពន្យល់ មិន

សម្តែងនូវសេចក្តីស្អាត ស្អាតវិសេស បរិសុទ្ធិ ការផុត ផុតស្រឡះ ផុតជុំវិញ សូម្បីព្រោះសីលទេ ។ អ្នកប្រាជ្ញមិនពោល មិនថ្លែង មិនពណ៌នា មិនពន្យល់ មិនសម្តែងនូវសេចក្តីស្អាត ស្អាតវិសេស បរិសុទ្ធិ ការផុត ផុតស្រឡះ ផុតជុំវិញ សូម្បីព្រោះវត្តទេ ។ អ្នកប្រាជ្ញមិនពោល មិនថ្លែង មិនពណ៌នា មិនពន្យល់ មិនសម្តែងនូវសេចក្តីស្អាត ស្អាតវិសេស បរិសុទ្ធិ ការផុត ផុតស្រឡះ ផុតជុំវិញ សូម្បីព្រោះសីលនិងវត្តទេ ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកប្រាជ្ញមិនពោលនូវសេចក្តីបរិសុទ្ធ សូម្បីព្រោះសីលនិងវត្តទេ ។

[ ១៧ ] ពាក្យថាទាំងមិន ( សម្តែងនូវសេចក្តីបរិសុទ្ធ ) ព្រោះការមិនឃើញ ព្រោះការមិនឮ ព្រោះការមិនដឹង ព្រោះមិនមានសីល ព្រោះមិនមានវត្តនោះទេ អធិប្បាយថា ទិដ្ឋិដែលគួរប្រាថ្នាក៏មាន បានដល់សម្មាទិដ្ឋិ មានវត្ថុ ១០ គឺទានដែលបុគ្គលឲ្យហើយមានផល ការបូជាធំមានផល ការបូជាតូចមានផល ផលវិបាករបស់កម្មដែលបុគ្គលធ្វើល្អនិងធ្វើអាក្រក់មាន លោកនេះមាន លោកដទៃមាន មាតាមានគុណ បិតាមានគុណ ពួកសត្វជាឱបបាតិកៈមាន ពួកសមណព្រាហ្មណ៍អ្នកប្រព្រឹត្តត្រូវ ប្រតិបត្តិត្រូវ ធ្វើឲ្យជាក់ច្បាស់ ត្រាស់ដឹងលោកនេះនិងលោកខាងមុខ ដោយបញ្ញាដ៏ក្រៃលែង ដោយខ្លួនឯងមានក្នុងលោក ។ ការស្តាប់ដែលគួរប្រាថ្នាក៏មាន បានដល់ការឃោសនាអំពីសម្នាក់បុគ្គលដទៃ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភូតធម៌ វេទល្លៈ ។ ញាណដែលគួរប្រាថ្នាក៏មាន គឺកម្មស្សកតញ្ញាណ សច្ចានុលោមិកញ្ញាណ អភិញ្ញាញាណ សមាបត្តិញ្ញាណ ។ សីលដែលគួរប្រាថ្នាក៏មាន បាន

ដល់បាតិមោក្ខសំវរសីល ។ វត្តដែលគួរប្រាថ្នាក៏មាន បានដល់ធុតង្គទាំង ៨ គឺអារញ្ញិកង្គៈ ១ បិណ្ឌបាតិកង្គៈ ១ បំសុកូលិកង្គៈ ១ តេចីវរិកង្គៈ ១ សបទានចារិកង្គៈ ១ ខលុបច្ឆាភត្តិកង្គៈ ១ នេសជ្ជិកង្គៈ ១ យថាសន្ថតិកង្គៈ ១ ។ ពាក្យថាទាំងមិន ( សម្តែងនូវសេចក្តីបរិសុទ្ធ ) ព្រោះការមិនឃើញ ព្រោះការមិនឮ ព្រោះការមិនដឹង ព្រោះមិនមានសីល ព្រោះមិនមានវត្តនោះទេ បានសេចក្តីថា បុគ្គលដែលដល់សេចក្តីស្ងប់ខាងក្នុង មិនមែនត្រឹមតែយល់ត្រូវ មិនមែនត្រឹមតែឮ មិនមែនត្រឹមតែដឹង មិនមែនត្រឹមតែសីល មិនមែនត្រឹមតែវត្ត ឬថាដល់សេចក្តីស្ងប់ខាងក្នុង ព្រោះវៀរចាកធម៌ទាំងនេះ ក៏មិនមែនដែរ មួយទៀតធម៌ទាំងនេះ ជាសម្ភារៈដើម្បីដល់ ដើម្បីបាន ដើម្បីប៉ះពាល់ ដើម្បីធ្វើឲ្យជាក់ច្បាស់ សេចក្តីស្ងប់ខាងក្នុង ហេតុនោះ ( ទ្រង់ត្រាស់ថា ) ទាំងមិន ( សម្តែងនូវសេចក្តីបរិសុទ្ធ ) ព្រោះការមិនឃើញ ព្រោះការមិនឮ ព្រោះការមិនដឹង ព្រោះមិនមានសីល ព្រោះមិនមានវត្តនោះទេ ។

[ ១៨ ] ពាក្យថាលះ មិនប្រកាន់ធម៌ទាំងនុ៎ះ អធិប្បាយថា ការលះបង់ដោយការគាស់រំលើងនូវធម៌ជាពួកខ្មៅ ដោយធម៌ទាំងនុ៎ះ ត្រូវតែប្រាថ្នា ។ ការមិនមានចំណង់ក្នុងធម៌ទាំងឡាយជាកុសល ប្រព្រឹត្តទៅក្នុងធាតុបីគប្បីប្រាថ្នា ។ ធម៌ទាំងឡាយជាពួកខ្មៅ ដែលលះបង់ហើយ ដោយការលះបង់ ដោយការគាស់រំលើងឫសគល់ហើយ ធ្វើមិនឲ្យមានទីកើត ដូចជាទីកើតនៃដើមត្នោត ដល់នូវការមិនមាន មានការមិនកើតឡើងតទៅជាធម្មតា ទាំងមិនមានចំណង់ក្នុងធម៌ទាំងឡាយជាកុសល ប្រព្រឹត្តទៅក្នុងធាតុបី ដោយហេតុណា សប្បុរស

មិនប្រកាន់ មិនបបោសអង្អែល មិនជាប់ចិត្ត ដោយហេតុមានប្រមាណប៉ុណ្ណេះឯង ឬថាធម៌ជាពួកខ្មៅទាំងឡាយ សប្បុរសមិនគប្បីប្រកាន់ មិនគប្បីបបោសអង្អែល មិនគប្បីជាប់ចិត្ត ហេតុនោះ ( ទ្រង់ត្រាស់ថា ) លះមិនប្រកាន់នូវធម៌ទាំងនុ៎ះ ដោយប្រការយ៉ាងនេះឯង ។ តណ្ហា ទិដ្ឋិនិងមានះ សប្បុរសលះបង់ហើយ ផ្តាច់ផ្តិលឫសគល់ហើយ ធ្វើមិនឲ្យមានទីកើត ដូចជាទីកើតនៃដើមត្នោត ដល់នូវការមិនមាន មានការមិនកើតឡើងតទៅជាធម្មតា ដោយហេតុណា សប្បុរសមិនប្រកាន់ មិនបបោសអង្អែល មិនជាប់ចិត្ត ដោយហេតុមានប្រមាណប៉ុណ្ណេះឯង ហេតុនោះ ( ទ្រង់ត្រាស់ថា ) លះមិនប្រកាន់ដោយប្រការយ៉ាងនេះ ។ បុញ្ញាភិសង្ខារ អបុញ្ញាភិសង្ខារ និងអានេញ្ជាភិសង្ខារ សប្បុរសលះបង់ហើយ ផ្តាច់ផ្តិលឫសគល់ហើយ ធ្វើមិនឲ្យមានទីកើត ដូចជាទីកើតនៃដើមត្នោត ដល់នូវការមិនមាន មានការមិនកើតតទៅជាធម្មតា ដោយហេតុណា សប្បុរសមិនប្រកាន់ មិនបបោសអង្អែល មិនជាប់ចិត្ត ដោយហេតុមានប្រមាណប៉ុណ្ណេះឯង ហេតុនោះ ( ទ្រង់ត្រាស់ថា ) លះមិនប្រកាន់ធម៌ទាំងនុ៎ះ ដោយប្រការយ៉ាងនេះឯង ។

[ ១៩ ] អធិប្បាយពាក្យថា ជាអ្នកស្ងប់មិនអាស្រ័យហើយ មិនគប្បីប្រាថ្នាភពត្រង់ពាក្យថា ជាអ្នកស្ងប់ សេចក្តីថា ជាអ្នកស្ងប់ព្រោះស្ងប់រាគៈ ជាអ្នកស្ងប់ព្រោះស្ងប់ទោសៈ ជាអ្នកស្ងប់ព្រោះស្ងប់មោហៈ ជាអ្នកស្ងប់ រម្ងាប់ រំលត់ ស្ងប់ រម្ងាប់ ព្រោះស្ងប់ រម្ងាប់ ចូលជិតរម្ងាប់ ផុត រំលត់ ឲ្យទៅប្រាសស្ងប់រម្ងាប់នូវកោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ មាយា

សាថេយ្យៈ ថម្ភៈ សារម្ភៈ មានះ អតិមានះ មទៈ បមាទៈ កិលេសទាំងពួង ទុច្ចរិតទាំងពួង សេចក្តីក្រវល់ក្រវាយទាំងពួង សេចក្តីក្រហល់ក្រហាយទាំងពួង សេចក្តីក្តៅក្រហាយទាំងពួង អភិសង្ខារជាអកុសលទាំងពួង ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជាអ្នកស្ងប់ ។ ពាក្យថាមិនអាស្រ័យ បានដល់ការអាស្រ័យ ២ គឺតណ្ហានិស្ស័យ ១ ទិដ្ឋិនិស្ស័យ ១ ។បេ។ នេះតណ្ហានិស្ស័យ ។បេ។ នេះទិដ្ឋិនិស្ស័យ ។ បុគ្គលលះតណ្ហានិស្ស័យ រលាស់ចោលទិដ្ឋិនិស្ស័យ មិនអាស្រ័យភ្នែក មិនអាស្រ័យត្រចៀក មិនអាស្រ័យច្រមុះ មិនអាស្រ័យអណ្តាត មិនអាស្រ័យកាយ មិនអាស្រ័យចិត្ត មិនអាស្រ័យ មិនប្រកាន់ មិនបរបោស អង្អែល មិនជាប់ចិត្តនូវរូប សំឡេង ក្លិន រស ផ្សព្វ ត្រកូល គណៈ អាវាស លាភ យស សេចក្តីសរសើរ សុខ ចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ កាមធាតុ រូបធាតុ អរូបធាតុ កាមភព រូបភព អរូបភព សញ្ញាភព អសញ្ញាភព នេវសញ្ញានាសញ្ញាភព ឯកវោការភព ចតុវោការភព បញ្ចវោការភព អតីត អនាគត បច្ចុប្បន្ន និងធម៌ទាំងឡាយ ដែលឃើញ ឮ ប៉ះពាល់ ឬគប្បីដឹង ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជាអ្នកស្ងប់មិនអាស្រ័យ ។ ពាក្យថាមិនគប្បីប្រាថ្នាភព សេចក្តីថា មិនគប្បីប្រាថ្នាកាមភព មិនគប្បីប្រាថ្នារូបភព មិនគប្បីប្រាថ្នា មិនគប្បីប្រាថ្នាដោយប្រការៈ មិនគប្បីប្រាថ្នាចំពោះអរូបភព ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជាអ្នកស្ងប់ មិនអាស្រ័យ មិនគប្បីប្រាថ្នាភព ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ហើយថា

( ម្នាលមាគន្ទិយៈ ) អ្នកប្រាជ្ញ មិនពោលនូវសេចក្តីបរិសុទ្ធ

ព្រោះការឃើញទេ ព្រោះការឮទេ ព្រោះការដឹងទេ ព្រោះសីលនិងវត្តទេ ទាំងមិន ( ពោលនូវសេចក្តីបរិសុទ្ធ ) ព្រោះការមិនឃើញ ព្រោះការមិនឮ ព្រោះការមិនដឹង ព្រោះមិនមានសីល ព្រោះមិនមានវត្តនោះទេ ទាំងលះមិនប្រកាន់នូវធម៌ទាំងនុ៎ះ ជាអ្នកស្ងប់មិនអាស្រ័យ ហើយមិនគប្បីប្រាថ្នាភព ។

[ ២០ ] ( មាគន្ទិយព្រាហ្មណ៍ ទូលដូច្នេះថា ) ប្រសិនបើអ្នកប្រាជ្ញមិនពោលនូវសេចក្តីបរិសុទ្ធព្រោះការឃើញទេ ព្រោះការឮទេ ព្រោះការដឹងទេ ព្រោះសីលនិងវត្តទេ ទាំងមិន ( ពោលនូវសេចក្តីបរិសុទ្ធ ) ព្រោះការមិនឃើញ ព្រោះការមិនឮ ព្រោះការមិនដឹង ព្រោះមិនមានសីល ព្រោះមិនមានវត្តនោះទេ ខ្ញុំព្រះអង្គសម្គាល់ធម៌ ( របស់ព្រះអង្គថាជាធម៌ ) នាំសត្វឲ្យវង្វេងជ្រប់ សមណព្រាហ្មណ៍ពួកខ្លះ ជឿសេចក្តីបរិសុទ្ធព្រោះទិដ្ឋិ ។

[ ២១ ] ពាក្យថាប្រសិនបើ ( អ្នកប្រាជ្ញ ) មិនពោល ( នូវសេចក្តីបរិសុទ្ធ ) ព្រោះការឃើញទេ ព្រោះការឮទេ ព្រោះការដឹងទេ អធិប្បាយថា អ្នកប្រាជ្ញមិនពោល គឺមិនថ្លែង មិនពណ៌នា មិនបំភ្លឺ មិនពន្យល់នូវសេចក្តីស្អាត ស្អាតវិសេស សេចក្តីបរិសុទ្ធ ការផុត ការផុតស្រឡះ ការផុតដោយជុំវិញ សូម្បីដោយការឃើញទេ ។ អ្នកប្រាជ្ញមិនពោល គឺមិនថ្លែង មិនពណ៌នា មិនបំភ្លឺ មិនពន្យល់នូវសេចក្តីស្អាត ស្អាតវិសេស សេចក្តីបរិសុទ្ធ ការផុត ការផុតស្រឡះ ការផុតដោយជុំវិញ សូម្បីដោយការឮទេ ។ អ្នកប្រាជ្ញមិនពោល គឺមិនថ្លែង មិនពណ៌នា មិនបំភ្លឺ មិនពន្យល់នូវសេចក្តីស្អាត ស្អាតវិសេស

សេចក្ដីបរិសុទ្ធ ការផុត ការផុតស្រឡះ ការផុតដោយជុំវិញ សូម្បីដោយការឃើញទាំងការឮទេ ។ អ្នកប្រាជ្ញមិនពោល គឺមិនថ្លែង មិនពណ៌នា មិនបំភ្លឺ មិនពន្យល់នូវសេចក្ដីស្អាត ស្អាតវិសេស សេចក្ដីបរិសុទ្ធ ការផុត ការផុតស្រឡះ ការផុតដោយជុំវិញ សូម្បីដោយការដឹងទេ ហេតុនោះ ( ព្រាហ្មណ៍ពោលថា ) ប្រសិនបើ ( អ្នកប្រាជ្ញ ) មិនពោល ( នូវសេចក្ដីបរិសុទ្ធ ) ព្រោះការឃើញទេ ព្រោះការឮទេ ព្រោះការដឹងទេ ។ ពាក្យថា ដូច្នេះ របស់បទថា មាគន្ទិយៈទូលដូច្នេះ ជាបទសន្ធិ ។បេ។ ពាក្យថា ដូច្នេះ នុ៎ះជាលំដាប់បទ ។ ពាក្យថា មាគន្ទិយៈ ជាឈ្មោះព្រាហ្មណ៍នោះ ហេតុនោះ មានពាក្យថា មាគន្ទិយៈ ( ទូល ) ដូច្នេះ ។

[ ២២ ] ពាក្យថា អ្នកប្រាជ្ញមិនពោលនូវសេចក្ដីបរិសុទ្ធ ព្រោះសីលនិងវត្តទេ សេចក្ដីថា អ្នកប្រាជ្ញមិនពោល គឺមិនថ្លែង មិនពណ៌នា មិនបំភ្លឺ មិនពន្យល់នូវសេចក្ដីស្អាត ស្អាតវិសេស សេចក្ដីបរិសុទ្ធ សូម្បីដោយសីលទេ នូវសេចក្ដីស្អាត ស្អាតវិសេស សេចក្ដីបរិសុទ្ធ សូម្បីដោយវត្តទេ នូវសេចក្ដីស្អាត ស្អាតវិសេស សេចក្ដីបរិសុទ្ធ ការផុត ការផុតស្រឡះ ការផុតដោយជុំវិញ សូម្បីដោយសីលនិងវត្តទេ ហេតុនោះ ( ព្រាហ្មណ៍ពោលថា ) អ្នកប្រាជ្ញមិនពោលនូវសេចក្ដីបរិសុទ្ធព្រោះសីលនិងវត្តទេ ។

[ ២៣ ] ពាក្យថា ទាំងមិន ( ពោលនូវសេចក្ដីបរិសុទ្ធ ) ព្រោះការមិនឃើញ ព្រោះការមិនឮ ព្រោះការមិនដឹង ព្រោះមិនមានសីល ព្រោះមិនមានវត្តនោះទេ សេចក្ដីថា ព្រះអង្គពោលយ៉ាងនេះថា ទិដ្ឋិដែលគួរប្រាថ្នាក៏មាន

ព្រះអង្គពោលយ៉ាងនេះថា ការស្តាប់ដែលគួរប្រាថ្នាក៏មាន ព្រះអង្គពោលយ៉ាងនេះថា ការដឹងដែលគួរប្រាថ្នាក៏មាន ព្រះអង្គពោលយ៉ាងនេះថា សីលដែលគួរប្រាថ្នាក៏មាន ព្រះអង្គពោលយ៉ាងនេះថា វត្តដែលគួរប្រាថ្នាក៏មាន ព្រះអង្គមិនអាចដើម្បីយល់តាមដោយដាច់ខាត ព្រះអង្គមិនអាចដើម្បីបដិសេធដោយដាច់ខាត ហេតុនោះ ( ព្រាហ្មណ៍ពោលថា ) ទាំងមិន ( ពោលនូវសេចក្តីបរិសុទ្ធ ) ព្រោះការមិនឃើញ ព្រោះការមិនឮ ព្រោះការមិនដឹង ព្រោះមិនមានសីល ព្រោះមិនមានវត្តនោះទេ ។

[ ២៤ ] ពាក្យថា ខ្ញុំព្រះអង្គសម្គាល់ធម៌ ( របស់ព្រះអង្គថាជាធម៌ ) នាំសត្វឲ្យវង្វេងជ្រប់ សេចក្តីថា ខ្ញុំព្រះអង្គសម្គាល់យ៉ាងនេះ ដឹងយ៉ាងនេះ ដឹងច្បាស់យ៉ាងនេះ យល់ច្បាស់យ៉ាងនេះថា ធម៌របស់ព្រះអង្គនេះ ជាធម៌ញ៉ាំងសត្វឲ្យវង្វេង ជាធម៌ពាល ជាធម៌ងងឹត ជាធម៌ប្រាសចាកញាណ ជាអមរាវិក្ខេបធម៌ ហេតុនោះ ( ព្រាហ្មណ៍ពោលថា ) ខ្ញុំព្រះអង្គសម្គាល់ធម៌ ( របស់ព្រះអង្គថាជាធម៌ ) នាំសត្វឲ្យវង្វេងជ្រប់ ។

[ ២៥ ] ពាក្យថា សមណព្រាហ្មណ៍ពួកខ្លះ ជឿសេចក្តីបរិសុទ្ធព្រោះការឃើញ សេចក្តីថា សមណព្រាហ្មណ៍ទាំងឡាយពួកខ្លះជឿថា សេចក្តីស្អាត ស្អាតវិសេស សេចក្តីបរិសុទ្ធ ការផុត ការផុតស្រឡះ ការផុតដោយជុំវិញ ព្រោះការឃើញ ។ សមណព្រាហ្មណ៍ពួកខ្លះជឿថា សេចក្តីស្អាត ស្អាតវិសេស សេចក្តីបរិសុទ្ធ ការផុត ការផុតស្រឡះ ការផុតដោយជុំវិញ ព្រោះការឃើញថា លោកទៀង ពាក្យនេះឯងពិត ពាក្យដទៃជាមោឃៈ ។ សមណព្រាហ្មណ៍ពួក

ខ្លះជឿថា សេចក្តីស្អាត ស្អាតវិសេស សេចក្តីបរិសុទ្ធ ការផុត ការផុតស្រឡះ ការផុតដោយជុំវិញ ព្រោះការឃើញថា លោកមិនទៀង ។បេ។ សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ពាក្យនេះឯងពិត ពាក្យដទៃជាមោឃៈ ហេតុនោះ ( ព្រាហ្មណ៍ពោលថា ) សមណព្រាហ្មណ៍ពួកខ្លះជឿសេចក្តីបរិសុទ្ធ ព្រោះការឃើញ ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា

ប្រសិនបើអ្នកប្រាជ្ញមិនពោលនូវសេចក្តីបរិសុទ្ធ ព្រោះការឃើញទេ ព្រោះការឮទេ ព្រោះការដឹងទេ ព្រោះសីលនិងវត្តទេ ទាំងមិន ( ពោលនូវសេចក្តីបរិសុទ្ធ ) ព្រោះការមិនឃើញ ព្រោះការមិនឮ ព្រោះការមិនដឹង ព្រោះមិនមានសីល ព្រោះមិនមានវត្តនោះទេ ខ្ញុំព្រះអង្គសម្គាល់ធម៌ ( របស់ព្រះអង្គថាជាធម៌ ) នាំសត្វឲ្យវង្វេងជ្រប់ សមណព្រាហ្មណ៍ពួកខ្លះ ជឿសេចក្តីបរិសុទ្ធព្រោះទិដ្ឋិ ។

[ ២៦ ] ( ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលមាគន្ទិយៈ ) អ្នកអាស្រ័យទិដ្ឋិទាំងឡាយហើយ ទើបសួររឿយៗ អ្នកដល់នូវសេចក្តីក័ន្តប្រឡំក្នុងទិដ្ឋិទាំងឡាយ ដែលប្រកាន់ហើយ មិនបានឃើញសញ្ញាសូម្បីតិចតួច អំពីធម៌នេះហេតុនោះទើបអ្នកយល់ថាជាធម៌នាំសត្វឲ្យវង្វេងជ្រប់ ។

[ ២៧ ] ពាក្យថា អ្នកអាស្រ័យទិដ្ឋិទាំងឡាយហើយ ទើបសួររឿយៗ សេចក្តីថា មាគន្ទិយព្រាហ្មណ៍ អាស្រ័យទិដ្ឋិហើយសួរទិដ្ឋិ អាស្រ័យការជាប់ចំពាក់ហើយសួរការជាប់ចំពាក់ អាស្រ័យចំណងហើយសួរចំណង អាស្រ័យ

បលិពោធហើយសួរបលិពោធ ។ ពាក្យថា សួររឿយៗ គឺសួរញឹកញយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកអាស្រ័យទិដ្ឋិទាំងឡាយហើយ ទើបសួររឿយៗ ។ ពាក្យថា មាគន្ទិយៈ គឺព្រះមានព្រះភាគត្រាស់ហៅនូវព្រាហ្មណ៍នោះដោយចំណោះ ។ ពាក្យថា ព្រះមានព្រះភាគ ជាពាក្យហៅដោយគោរព ។បេ។ សេចក្ដីបញ្ញត្តថា ព្រះមានព្រះភាគនេះ ( កើត ) អំពីការត្រាស់ដឹង ហេតុនោះ ( មានពាក្យថា ) ព្រះមានព្រះភាគត្រាស់ហៅថាមាគន្ទិយៈ ។

[ ២៨ ] ពាក្យថា អ្នកដល់នូវសេចក្ដីភ័ន្តច្រឡំក្នុងទិដ្ឋិទាំងឡាយដែលប្រកាន់ហើយ សេចក្ដីថា ទិដ្ឋិណាដែលអ្នកប្រកាន់ បបោសអង្អែល ចូលចិត្ត ចុះចិត្ត ចុះចិត្តស៊ប់ អ្នកជាបុគ្គលវង្វេង វង្វេងជ្រប់ វង្វេងស៊ប់ ជាអ្នកដល់នូវសេចក្ដីវង្វេង ដល់នូវសេចក្ដីវង្វេងជ្រប់ ដល់នូវសេចក្ដីវង្វេងស៊ប់ ជាអ្នកស្ទុងទៅកាន់សេចក្ដីងងឹតងងល់ក្នុងទិដ្ឋិនោះឯង ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកដល់នូវការភ័ន្តច្រឡំក្នុងទិដ្ឋិទាំងឡាយដែលប្រកាន់ហើយ ។

[ ២៩ ] ពាក្យថា អ្នកមិនបានឃើញសញ្ញា សូម្បីបន្តិចបន្តួចអំពីធម៌នេះ សេចក្ដីថា អ្នកមិនបានសញ្ញាដែលគួរហើយក្ដី សញ្ញាដែលដល់ហើយក្ដី សញ្ញាជាគ្រឿងចំណាំក្ដី សញ្ញាជាហេតុក្ដី សញ្ញាជាទីតាំងក្ដី អំពីធម៌ដែលមានសេចក្ដីស្ងប់ខាងក្នុងនេះក្ដី អំពីសេចក្ដីបដិបត្តិនេះក្ដី អំពីធម្មទេសនានេះក្ដី តើញាណ ( នឹងមានមក ) អំពីណា ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកមិនបានឃើញសញ្ញា សូម្បីបន្តិចបន្តួចអំពីធម៌នេះ ដោយប្រការយ៉ាងនេះឯង ។ មួយវិញទៀត អ្នកមិនបានសញ្ញាថា បញ្ចក្ខន្ធមិនទៀង ឬអនុលោមតាមសញ្ញា

ថា បញ្ចក្ខន្ធមិនទៀង សញ្ញាថា បញ្ចក្ខន្ធជាទុក្ខ ឬអនុលោមតាមសញ្ញាថា បញ្ចក្ខន្ធជាទុក្ខ សញ្ញាថា បញ្ចក្ខន្ធជាអនត្តា ឬអនុលោមតាមសញ្ញាថា បញ្ចក្ខន្ធជាអនត្តា កិច្ចត្រឹមតែកិរិយាញុំាងសញ្ញាឲ្យកើតឡើង ឬនិមិត្តក្នុងសញ្ញា តើញាណនឹងមានមកអំពីណា ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនបានឃើញសញ្ញាសូម្បីបន្តិចបន្តួចអំពីធម៌នេះ ។

[ ៣០ ] ពាក្យថាហេតុនោះ ទើបអ្នកយល់ថា ជាធម៌នាំសត្វឲ្យវង្វេងជ្រប់ ត្រង់ពាក្យថាហេតុនោះគឺព្រោះហេតុដូច្នោះ ព្រោះការណ៍នោះ ព្រោះហេតុនោះ ព្រោះបច្ច័យនោះ ព្រោះនិទាននោះ ទើបអ្នកយល់ឃើញ ក្រឡេកឃើញ រំពឹងឃើញ ពិចារណាឃើញ ថាជាធម៌ញុំាងសត្វឲ្យវង្វេងជ្រប់ ថាជាធម៌ពាល ថាជាធម៌កន្ត្រប្រឡំ ថាជាធម៌ប្រាសចាកញាណ ថាជាអមរាវិក្ខេបធម៌ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ហេតុនោះ ទើបអ្នកយល់ថា ជាធម៌ញុំាងសត្វឲ្យវង្វេងជ្រប់ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

អ្នកអាស្រ័យទិដ្ឋិទាំងឡាយហើយសួររឿយៗ ដល់នូវសេចក្តី
កន្ត្រប្រឡំក្នុងទិដ្ឋិទាំងឡាយ ដែលប្រកាន់យកហើយ មិនបាន
ឃើញសញ្ញាសូម្បីបន្តិចបន្តួចអំពីធម៌នេះ ហេតុនោះទើបអ្នក
យល់ថា ជាធម៌នាំឲ្យវង្វេងជ្រប់ ។

[ ៣១ ] បុគ្គលណាសម្គាល់ថាស្មើ ថាប្រសើរ ឬថាថោកទាប បុគ្គលនោះគប្បីនិយាយទទឹងទាស់ ដោយសេចក្តីសម្គាល់នោះ បុគ្គលណាមិនញាប់ញ័រក្នុងមានះ ៣ យ៉ាង ការប្រកាន់ថាស្មើ ថាប្រសើរ ( ឬថាថោកទាប ) នៃ

បុគ្គលនោះមិនមានឡើយ ។

[ ៣២ ] ពាក្យថាបុគ្គលណាសម្គាល់ថាស្មើ ថាប្រសើរ ឬថាថោកទាប បុគ្គលនោះគប្បីនិយាយទទឹងទាស់ដោយសេចក្ដីសម្គាល់នោះ អធិប្បាយថា បុគ្គលណាសម្គាល់ថា អាត្មាអញប្រហែលនឹងគេក្ដី ថាអាត្មាអញប្រសើរក្ដី ថាអាត្មាអញថោកទាបក្ដី បុគ្គលនោះគប្បីធ្វើជម្លោះ គប្បីធ្វើការទាស់ទែង គប្បីធ្វើការប្រកាន់ខុស គប្បីធ្វើវិវាទ គប្បីធ្វើការប្រកួតប្រកាន់ ព្រោះមានះនោះ ព្រោះទិដ្ឋិនោះ ឬព្រោះបុគ្គលនោះថា អ្នកមិនចេះធម្មវិន័យនេះទេ ខ្ញុំចេះដឹងធម្មវិន័យនេះ អ្នកនឹងចេះធម្មវិន័យនេះដូចម្ដេចបាន អ្នកជាបុគ្គលប្រតិបត្តិខុស ខ្ញុំប្រតិបត្តិត្រូវ ពាក្យរបស់ខ្ញុំទើបប្រកបដោយប្រយោជន៍ ពាក្យរបស់អ្នកមិនប្រកបដោយប្រយោជន៍ទេ ពាក្យដែលគេត្រូវនិយាយមុន អ្នកនិយាយក្រោយ ពាក្យដែលគេត្រូវនិយាយក្រោយ អ្នកនិយាយមុន ពាក្យដែលអ្នកសន្សំមកយូរហើយ ត្រូវយើងឲ្យវិលត្រឡប់ហើយ វាទៈរបស់អ្នកយើងលើកចោលហើយ អ្នកត្រូវយើងសង្កត់សង្កិនបានហើយ អ្នកចូរត្រាច់ទៅដើម្បីដោះវាទៈចុះ ឬបើអ្នកអាច អ្នកចូរដោះចុះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលណាសម្គាល់ថាស្មើ ថាប្រសើរ ឬថាថោកទាប បុគ្គលនោះ គប្បីនិយាយទទឹងទាស់ដោយសេចក្ដីសម្គាល់នោះ ។

[ ៣៣ ] ពាក្យថា បុគ្គលណាមិនញាប់ញ័រក្នុងមានះ ៣ យ៉ាង ការប្រកាន់ថាស្មើ ថាប្រសើរ ( ឬថាថោកទាប ) មិនមានដល់បុគ្គលនោះ សេចក្ដីថា មានះទាំងឡាយបីយ៉ាងនុ៎ះ បុគ្គលណាលះបង់ ផ្ដាច់បង់ ស្ងប់រម្ងាប់

កម្ចាត់បង់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ បុគ្គលនោះរមែងមិនញាប់ញ័រ មិនរំជួលក្នុងមានះទាំង ៣ កាលបើបុគ្គលមិនញាប់ញ័រហើយ ( រមែងមិនមានសេចក្តីប្រកាន់ថា ) អាត្មាអញជាបុគ្គលស្មើនឹងគេដូច្នេះផង ជាបុគ្គលប្រសើរជាងគេដូច្នេះផង ជាបុគ្គលថោកទាបជាងគេ ដូច្នេះផង ។ ពាក្យថា មិនមានដល់បុគ្គលនោះ សេចក្តីថា មិនមានដល់តថាគត ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលមិនញាប់ញ័រក្នុងមានះ ៣ យ៉ាង ( ការប្រកាន់ថា ) ស្មើ ថាប្រសើររមែងមិនមានដល់បុគ្គលនោះ ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

បុគ្គលណាសម្គាល់ថាស្មើ ថាប្រសើរ ឬថាថោកទាប បុគ្គល
នោះគប្បីនិយាយទទឹងទាស់ដោយសេចក្តីសម្គាល់នោះ បុគ្គល
ណាមិនញាប់ញ័រក្នុងមានះ ៣ ការប្រកាន់ថាស្មើ ថាប្រសើរ
( ឬថាថោកទាប ) មិនមានដល់បុគ្គលនោះឡើយ ។

[ ៣៤ ] ព្រាហ្មណ៍នោះគប្បីពោលថា ( សេចក្តីយល់ ) នេះ ត្រូវពិតដូចម្តេចបាន ឬក៏ព្រាហ្មណ៍នោះគប្បីពោលទទឹងទាស់ថា ( ពាក្យរបស់អ្នក ) ជាពាក្យកុហកដោយប្រការដូចម្តេចបាន សេចក្តីសម្គាល់ថាស្មើ ឬមិនស្មើ មិនមានក្នុងព្រះខីណាស្រពអង្គណា ព្រះខីណាស្រពអង្គនោះ គប្បីផ្សាយវាទៈដោយប្រការដូចម្តេចបាន ។

[ ៣៥ ] អធិប្បាយពាក្យថា ព្រាហ្មណ៍នោះគប្បីពោលថា សេចក្តីយល់នេះត្រូវពិតដូចម្តេចបាន ត្រង់ពាក្យថាព្រាហ្មណ៍ គឺបុគ្គលឈ្មោះថាព្រាហ្មណ៍

ព្រោះបន្សាត់បង់ធម៌ ៧ ។បេ។ ជាបុគ្គលមិនអាស្រ័យ ជាតាទិបុគ្គល បុគ្គលនោះលោកហៅថាព្រាហ្មណ៍ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ព្រាហ្មណ៍នោះ ( គប្បីពោលថា ) សេចក្តីយល់នេះត្រូវពិត ។ ពាក្យថាគប្បីពោលដូចម្តេចបាន សេចក្តីថា ព្រាហ្មណ៍គប្បីពោលដូចម្តេច គប្បីថ្លែងដូចម្តេច គប្បីពណ៌នាដូចម្តេច គប្បីបំភ្លឺដូចម្តេច គប្បីពន្យល់ដូចម្តេចថា លោកទៀង ពាក្យនេះឯងពិត ពាក្យដទៃជាមោឃៈ ។ គប្បីពោលដូចម្តេច គប្បីថ្លែងដូចម្តេច គប្បីពណ៌នាដូចម្តេច គប្បីបំភ្លឺដូចម្តេច គប្បីពន្យល់ដូចម្តេចថា លោកមិនទៀង ។បេ។ សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ពាក្យនេះឯងពិត ពាក្យដទៃជាមោឃៈ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ព្រាហ្មណ៍នោះគប្បីពោលថា ( សេចក្តីយល់ ) នេះត្រូវពិតដូចម្តេចបាន ។

[ ៣៦ ] ពាក្យថា ព្រាហ្មណ៍នោះគប្បីពោលទទឹងទាស់ថា ( ពាក្យរបស់អ្នក ) ជាពាក្យកុហកដោយប្រការដូចម្តេចបាន សេចក្តីថា ព្រាហ្មណ៍គប្បីធ្វើជម្លោះ គប្បីធ្វើការទាស់ទែង គប្បីធ្វើសេចក្តីប្រកាន់ខុស គប្បីធ្វើវិវាទ គប្បីធ្វើសេចក្តីប្រកួតប្រកាន់ថា អ្នកមិនចេះដឹងធម្មវិន័យនេះទេ ។បេ។ បើអ្នកអាច អ្នកចូរដោះចុះ ដោយមានះដូចម្តេច ដោយទិដ្ឋិដូចម្តេច ឬដោយបុគ្គលដូចម្តេចថា ពាក្យរបស់ខ្ញុំពិត ពាក្យរបស់អ្នកកុហក ហេតុនោះ ( ទ្រង់ត្រាស់ថា ) ព្រាហ្មណ៍នោះ គប្បីពោលទទឹងទាស់ថា ( ពាក្យរបស់អ្នក ) ជាពាក្យកុហកដោយប្រការដូចម្តេចបាន ។

[ ៣៧ ] ពាក្យថា សេចក្តីសម្គាល់ថាស្មើក្តី មិនស្មើក្តី មិនមានក្នុង

ព្រះខីណាស្រពអង្គណា សេចក្ដីថា ព្រះអរហន្តខីណាស្រពអង្គណាមិនមាន សេចក្ដីប្រកាន់ថា អាត្មាអញជាបុគ្គលស្មើនឹងគេ មិនមានសេចក្ដីប្រកាន់ខ្ពស់ ថាអាត្មាអញជាបុគ្គលប្រសើរជាងគេ មិនមាន មិនមានព្រម មិនគប្បីបាននូវ សេចក្ដីប្រកាន់ទាបថា អាត្មាអញជាបុគ្គលថោកទាបជាងគេ គឺថាកិលេសជាត នោះ ព្រះខីណាស្រពលះបង់ ផ្ដាច់ផ្ដិល រម្ងាប់ ស្ងប់រម្ងាប់ មិនគួរឲ្យកើតឡើង បាន ដុតដោយភ្លើងគឺញាណហើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) សេចក្ដី សម្គាល់ថាស្មើក្ដី មិនស្មើក្ដី មិនមានក្នុងព្រះខីណាស្រពអង្គណា ។

[ ៣៨ ] ពាក្យថា ព្រះខីណាស្រពអង្គនោះ គប្បីផ្សាយវាទៈដោយប្រការ ដូចម្ដេចបាន សេចក្ដីថា ព្រះខីណាស្រពអង្គនោះ គប្បីផ្សាយ គប្បីផ្សព្វផ្សាយ វាទៈ គប្បីធ្វើជម្លោះ គប្បីធ្វើសេចក្ដីទាស់ទែង គប្បីធ្វើការប្រកាន់ខុស គប្បី ធ្វើវិវាទ គប្បីធ្វើសេចក្ដីប្រកួតប្រកាន់ថា អ្នកមិនចេះធម្មវិន័យនេះទេ ។បេ។ ឬ បើអ្នកអាច ចូរអ្នកដោះចុះ ដោយមានះដូចម្ដេច ដោយទិដ្ឋិដូចម្ដេច ឬក៏ដោយ បុគ្គលដូចម្ដេចបាន ហេតុនោះ ( ទ្រង់ត្រាស់ថា ) ព្រះខីណាស្រពអង្គនោះ គប្បីផ្សាយវាទៈដោយប្រការដូចម្ដេចបាន ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ហើយថា

ព្រាហ្មណ៍នោះ គប្បីពោលថា ( សេចក្ដីយល់ ) នេះត្រូវពិត
ដូចម្ដេចបាន ឬក៏ព្រាហ្មណ៍នោះ គប្បីពោលទទឹងទាស់ថា
( ពាក្យរបស់អ្នក ) ជាពាក្យកុហកដោយប្រការដូចម្ដេច
សេចក្ដីសម្គាល់ ថាស្មើក្ដី មិនស្មើក្ដី មិនមានក្នុងព្រះខីណា

ស្រពអន្ទណា ព្រះទីណាស្រពអន្ទនោះ គប្បីផ្សាយវាទៈ

ដោយប្រការដូចម្ដេចបាន ។

[ ៣៩ ] អ្នកប្រាជ្ញលះបង់លំនៅ មិនមានការរឭកអាល័យចំពោះលំនៅ មិនធ្វើសេចក្ដីស្និទ្ធស្នាលក្នុងកាម ជាអ្នកទំនេរចាកកាមទាំងឡាយ មិនធ្វើវគ្គៈឲ្យជាប្រធាន មិនធ្វើជំទាស់នូវពាក្យជាមួយជនទេ ។

[ ៤០ ] គ្រានោះឯង ហាលិទ្ទកានិគហបតី បានចូលទៅរកព្រះមហាកច្ចានៈមានអាយុ លុះចូលទៅដល់ហើយ ទើបថ្វាយបង្គំព្រះមហាកច្ចានៈមានអាយុ ហើយអង្គុយនៅក្នុងទីសមគួរ លុះហាលិទ្ទកានិគហបតី អង្គុយក្នុងទីសមគួរហើយ ទើបពោលចំពោះព្រះមហាកច្ចានៈមានអាយុយ៉ាងនេះថា បពិត្រព្រះកច្ចានៈដ៏ចម្រើន ពាក្យនេះព្រះមានព្រះភាគទ្រង់ត្រាស់ទុកហើយក្នុងមាគន្ទិយ-បញ្ហាអដ្ឋកវគ្គថា

អ្នកប្រាជ្ញលះបង់លំនៅ មិនមានការរឭកអាល័យចំពោះលំនៅ
មិនធ្វើសេចក្ដីស្និទ្ធស្នាលក្នុងកាម ជាអ្នកទំនេរចាកកាមទាំង
ឡាយ មិនធ្វើវគ្គៈឲ្យជាប្រធាន មិនធ្វើជំទាស់នូវពាក្យជាមួយ
ជនទេ ។

បពិត្រព្រះកច្ចានៈដ៏ចម្រើន សេចក្ដីនៃពាក្យនេះ ដែលព្រះមានព្រះភាគទ្រង់សម្ដែងហើយដោយសេចក្ដីសង្ខេប តើលោកម្ចាស់យល់ឃើញដោយសេចក្ដីពិស្ដារដោយប្រការដូចម្ដេចហ្ន៎ ។ ម្នាលគហបតី រូបធាតុ ជាលំនៅរបស់វិញ្ញាណ ឯវិញ្ញាណដែលមានកិរិយាជាប់ទាក់ទងដោយរាគៈក្នុងរូបធាតុ

ហៅថាវេទកអាល័យលំនៅ ម្នាលគហបតី វេទនាធាតុ ម្នាលគហបតី សញ្ញាធាតុ ម្នាលគហបតី សង្ខារធាតុសឹងជាលំនៅរបស់វិញ្ញាណ ឯវិញ្ញាណដែលមានកិរិយាជាប់ទាក់ទងដោយរាគៈក្នុងសង្ខារធាតុ ហៅថា ការវេទកអាល័យលំនៅ ម្នាលគហបតី វិញ្ញាណទឹកអាល័យទីលំនៅយ៉ាងនេះឯង ។ ម្នាលគហបតី ព្រះតថាគត មិនមានការវេទកអាល័យលំនៅតើដូចម្តេច ។ ម្នាលគហបតី ចំណង់ តម្រេក សេចក្តីរីករាយ សេចក្តីប្រាថ្នា ឧបាយនិងឧបាទាន ការតាំងស៊ប់សេចក្តីប្រកាន់មាំនិងការដេកត្រាំនៅនៃចិត្តណាក្នុងរូបធាតុកិលេសទាំងនោះ ព្រះតថាគតលះបង់ ផ្តាច់ផ្តិលឫសគល់ ធ្វើមិនឲ្យមានទីកើត ដូចជាទីកើតនៃដើមត្នោត ដល់នូវការមិនមាន ជាធម៌មិនមានការកើតតទៅទៀត ហេតុនោះ ព្រះតថាគតគេហៅថា មិនមានវិញ្ញាណវេទកអាល័យលំនៅ ។ ម្នាលគហបតី ចំណង់ តម្រេក សេចក្តីរីករាយ សេចក្តីប្រាថ្នា ឧបាយនិងឧបាទាន ការតាំងស៊ប់ សេចក្តីប្រកាន់មាំ និងការដេកត្រាំនៅនៃចិត្តណាក្នុងវេទនាធាតុ ម្នាលគហបតី ក្នុងសញ្ញាធាតុ ម្នាលគហបតី ក្នុងសង្ខារធាតុ ម្នាលគហបតី ក្នុងវិញ្ញាណធាតុ កិលេសទាំងនោះ ព្រះតថាគតលះបង់ ផ្តាច់ផ្តិលឫសគល់ហើយ ធ្វើមិនឲ្យមានទីកើត ដូចជាទីកើតនៃដើមត្នោត ដល់នូវការមិនមាន ជាធម៌មិនមានការកើតតទៅទៀត ហេតុនោះ ព្រះតថាគតគេហៅថា មិនមានវិញ្ញាណវេទកអាល័យលំនៅ ម្នាលគហបតី ព្រះតថាគតគេហៅថា មិនមានវិញ្ញាណវេទកអាល័យលំនៅយ៉ាងនេះឯង ។ ម្នាលគហបតី វិញ្ញាណវេទកអាល័យលំនៅតើដូចម្តេច ។ ម្នាលគហបតី វិញ្ញាណមានការវេទក

អាល័យនិងការជាប់ចំពាក់ក្នុងរូបដែលជានិមិត្ត ជាទីរឭកអាល័យ លោកពោលថា ការរឭកអាល័យលំនៅ ។ ម្នាលគហបតី វិញ្ញាណមានការរឭកអាល័យនិងការជាប់ចំពាក់ក្នុងសំឡេង ដែលជានិមិត្ត ក្លិនដែលជានិមិត្ត រសដែលជានិមិត្ត ផោដ្ឋព្វៈដែលជានិមិត្ត ធម្មារម្មណ៍ដែលជានិមិត្ត ជាលំនៅ លោកពោលថា ការរឭកអាល័យលំនៅ ម្នាលគហបតី វិញ្ញាណមានការរឭកអាល័យលំនៅយ៉ាងនេះឯង ។ ម្នាលគហបតី ព្រះតថាគតមិនមានការរឭកអាល័យលំនៅតើដូចម្ដេច ។ ម្នាលគហបតី ការរឭកនិងការជាប់ចំពាក់ក្នុងរូបដែលជានិមិត្ត ជាលំនៅ ព្រះតថាគតលះបង់ ផ្ដាច់ផ្ដិលឫសគល់ ធ្វើមិនឲ្យមានទីកើត ដូចជាទីកើតនៃដើមត្នោត ដល់នូវការមិនមាន ជាធម៌មិនមានការកើតតទៅទៀត ហេតុនោះ ព្រះតថាគតគេហៅថា មិនមានការរឭកអាល័យលំនៅ ។ ម្នាលគហបតី ការរឭកនិងការជាប់ចំពាក់ក្នុងសំឡេងដែលជានិមិត្ត ក្លិនជានិមិត្ត រសជានិមិត្ត ផោដ្ឋព្វៈជានិមិត្ត ធម្មារម្មណ៍ជានិមិត្ត ព្រះតថាគតលះបង់ ផ្ដាច់ផ្ដិលឫសគល់ ធ្វើមិនឲ្យមានទីកើត ដូចជាទីកើតនៃដើមត្នោត ដល់នូវការមិនមាន ជាធម៌មិនមានការកើតតទៅទៀត ហេតុនោះ ព្រះតថាគតគេហៅថា មិនមានការរឭកអាល័យលំនៅ ម្នាលគហបតី ព្រះតថាគតមិនមានការរឭកអាល័យលំនៅយ៉ាងនេះឯង ។ ម្នាលគហបតី បុគ្គលជាអ្នកស្និទ្ធស្នាលក្នុងកាមតើដូចម្ដេច ។ ម្នាលគហបតី ភិក្ខុៈក្នុងសាសនានេះ ជាអ្នកប្រឡូកប្រឡំដោយគ្រហស្ថទាំងឡាយ មានសេចក្ដីរីករាយជាមួយ មានសោកជាមួយ កាលបើគ្រហស្ថទាំងឡាយដល់នូវសុខ ក៏ដល់នូវសុខ កាល

បើគ្រហស្ថទាំងឡាយដល់នូវទុក្ខ ក៏ដល់នូវទុក្ខ កាលបើកិច្ចការដែលគ្រហស្ថទាំងឡាយគប្បីធ្វើកើតឡើងហើយ ក៏ដល់នូវការចូលទៅប្រកប ( ជួយ ) ដោយខ្លួនឯង ម្នាលគហបតី ភិក្ខុជាអ្នកស្និទ្ធស្នាលក្នុងកាមយ៉ាងនេះឯង ។ ម្នាលគហបតី ភិក្ខុជាអ្នកមិនស្និទ្ធស្នាលក្នុងកាមតើដូចម្តេច ។ ម្នាលគហបតី ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនប្រឡូកប្រឡំដោយគ្រហស្ថទាំងឡាយ មិនរីករាយជាមួយ មិនមានសោកជាមួយ មិនដល់នូវសុខជាមួយនឹងគ្រហស្ថដែលដល់នូវសុខ មិនដល់នូវទុក្ខ ជាមួយនឹងគ្រហស្ថដែលដល់នូវទុក្ខ កាលបើកិច្ចការដែលគ្រហស្ថគប្បីធ្វើកើតឡើងហើយ ក៏មិនដល់នូវការចូលទៅប្រកបដោយខ្លួនឯងឡើយ ម្នាលគហបតី ភិក្ខុជាអ្នកមិនស្និទ្ធស្នាលក្នុងកាមទាំងឡាយយ៉ាងនេះឯង ។ ម្នាលគហបតី ភិក្ខុមិនទំនេរចាកកាមទាំងឡាយ តើដូចម្តេច ។ ម្នាលគហបតី ភិក្ខុពួកខ្លះក្នុងសាសនានេះ ជាអ្នកមិនប្រាសចាករាគៈ មិនប្រាសចាកឆន្ទៈ មិនប្រាសចាកសេចក្តីស្រឡាញ់ មិនប្រាសចាកសេចក្តីស្រេកឃ្លាន មិនប្រាសចាកសេចក្តីអន្ទះអន្ទែង មិនប្រាសចាកសេចក្តីប្រាថ្នាក្នុងកាមទាំងឡាយ ម្នាលគហបតី ភិក្ខុមិនទំនេរចាកកាមទាំងឡាយយ៉ាងនេះឯង ។ ម្នាលគហបតី ភិក្ខុជាអ្នកទំនេរចាកកាមទាំងឡាយតើដូចម្តេច ។ ម្នាលគហបតី ភិក្ខុក្នុងធម្មវិន័យនេះ ជាអ្នកប្រាសចាករាគៈ ប្រាសចាកឆន្ទៈ ប្រាសចាកសេចក្តីស្រឡាញ់ ប្រាសចាកសេចក្តីស្រេកឃ្លាន ប្រាសចាកសេចក្តីអន្ទះអន្ទែង ប្រាសចាកសេចក្តីប្រាថ្នាក្នុងកាមទាំងឡាយ ម្នាលគហបតី ភិក្ខុជាអ្នកទំនេរចាកកាមទាំងឡាយយ៉ាងនេះឯង ។ ម្នាលគហបតី ភិក្ខុអ្នកធ្វើវដ្តៈឲ្យជាប្រធានតើដូច

ម្តេច ។ ម្នាលគហបតី ភិក្ខុពួកខ្លះក្នុងសាសនានេះ មានសេចក្តីប្រាថ្នាយ៉ាងនេះថា អាត្មាអញសូមឲ្យមានរូបយ៉ាងនេះក្នុងអនាគតកាល ទើបញ៉ាំងសេចក្តីរីករាយឲ្យប្រព្រឹត្តទៅរឿយៗក្នុងរូបនោះ អាត្មាអញសូមឲ្យមានវេទនាយ៉ាងនេះ សូមឲ្យមានសញ្ញាយ៉ាងនេះ សូមឲ្យមានសង្ខារយ៉ាងនេះ សូមឲ្យមានវិញ្ញាណយ៉ាងនេះក្នុងអនាគតកាល ទើបញ៉ាំងសេចក្តីរីករាយឲ្យប្រព្រឹត្តទៅរឿយៗក្នុងខន្ធ មានវេទនាជាដើមនោះ ម្នាលគហបតី ភិក្ខុអ្នកធ្វើវដ្តៈឲ្យជាប្រធានយ៉ាងនេះឯង ។ ម្នាលគហបតី បុគ្គលអ្នកមិនធ្វើវដ្តៈឲ្យជាប្រធានតើដូចម្តេច ។ ម្នាលគហបតី ភិក្ខុក្នុងធម្មវិន័យនេះ មិនមានសេចក្តីប្រាថ្នាយ៉ាងនេះថា អាត្មាអញសូមឲ្យមានរូបយ៉ាងនេះក្នុងអនាគតកាល ទាំងមិនញ៉ាំងសេចក្តីរីករាយឲ្យប្រព្រឹត្តទៅរឿយៗក្នុងរូបនោះ ( មិនមានសេចក្តីប្រាថ្នាយ៉ាងនេះថា ) អាត្មាអញសូមឲ្យមានវេទនាយ៉ាងនេះ សូមឲ្យមានសញ្ញាយ៉ាងនេះ សូមឲ្យមានសង្ខារយ៉ាងនេះ សូមឲ្យមានវិញ្ញាណយ៉ាងនេះ ក្នុងអនាគតកាល ទាំងមិនញ៉ាំងសេចក្តីរីករាយឲ្យប្រព្រឹត្តទៅរឿយៗក្នុងខន្ធ មានវេទនាជាដើមនោះ ម្នាលគហបតី ភិក្ខុជាអ្នកមិនធ្វើវដ្តៈឲ្យជាប្រធានយ៉ាងនេះឯង ។ ម្នាលគហបតី ភិក្ខុជាអ្នកធ្វើជំទាស់នូវពាក្យដោយជន តើដូចម្តេច ។ ម្នាលគហបតី ភិក្ខុពួកខ្លះក្នុងសាសនានេះ ជាអ្នកធ្វើពាក្យមានសភាពយ៉ាងនេះថា អ្នកមិនយល់ធម្មវិន័យនេះទេ ។បេ។ ឬប្រសិនបើអ្នកអាច អ្នកចូរដោះចុះ ម្នាលគហបតី ភិក្ខុជាអ្នកធ្វើជំទាស់នូវពាក្យដោយជនយ៉ាងនេះឯង ។ ម្នាលគហបតី ភិក្ខុអ្នកមិនធ្វើទទឹងទាស់នូវពាក្យដោយជន តើដូចម្តេច ។ ម្នាលគហបតី ភិក្ខុ

ក្នុងធម្មវិន័យនេះ ជាអ្នកមិនធ្វើពាក្យមានសភាពយ៉ាងនេះថា អ្នកមិនយល់ធម្មវិន័យនេះទេ ។បេ។ ឬបើអ្នកអាច អ្នកចូរដោះចុះ ម្នាលគហបតី ភិក្ខុអ្នកមិនធ្វើទទឹងទាស់នូវពាក្យដោយជនយ៉ាងនេះឯង ។ ម្នាលគហបតី ពាក្យដែលព្រះមានព្រះភាគទ្រង់ត្រាស់ទុកក្នុងមាគន្ទិយបញ្ហា ក្នុងអដ្ឋកវគ្គិកៈយ៉ាងនេះឯង ។

អ្នកប្រាជ្ញលះបង់លំនៅ មិនមានការរពឹងអាល័យចំពោះលំនៅ
មិនធ្វើសេចក្តីស្និទ្ធស្នាលក្នុងកាម ជាអ្នកទំនេរចាកកាមទាំង
ឡាយ មិនធ្វើវដ្តៈឲ្យជាប្រធាន មិនគប្បីធ្វើជំទាស់នូវពាក្យ
ដោយជនទេ ។

ម្នាលគហបតី សេចក្តីនៃពាក្យនេះឯង ដែលព្រះមានព្រះភាគត្រាស់ហើយដោយសង្ខេប អ្នកគប្បីយល់ដោយសេចក្តីពិស្តារយ៉ាងនេះចុះ ។ ហេតុនោះព្រះមានព្រះភាគត្រាស់ហើយថា

អ្នកប្រាជ្ញលះបង់លំនៅ មិនមានការរពឹងអាល័យចំពោះលំនៅ
មិនធ្វើសេចក្តីស្និទ្ធស្នាលក្នុងកាម ជាអ្នកទំនេរចាកកាមទាំង
ឡាយ មិនធ្វើវដ្តៈឲ្យជាប្រធាន មិនគប្បីធ្វើជំទាស់នូវពាក្យ
ដោយជនទេ ។

[ ៨១ ] នាគស្ងាត់ចាកធម៌ទាំងឡាយណា ប្រព្រឹត្តទៅក្នុងលោក មិនគប្បីពោលប្រកាន់ទិដ្ឋិទាំងនោះទេ ឯលម្ពុជាត កណ្តកវារិជាត មិនប្រឡាក់ដោយទឹកផង ដោយភក់ផងយ៉ាងណាមិញ មុនិជាអ្នកពោលនូវសេចក្តីស្ងប់

មិនប្រាថ្នា មិនប្រឡាក់ក្នុងកាមផង ក្នុងលោកផង ក៏យ៉ាងនោះឯង ។

[ ៨២ ] ពាក្យថា នាគស្ងាត់ចាកធម៌ទាំងឡាយណា ប្រព្រឹត្តទៅក្នុងលោក ត្រង់ពាក្យថា ចាកធម៌ទាំងឡាយណា គឺចាកទិដ្ឋិទាំងឡាយ ។ ពាក្យថា ស្ងាត់ គឺស្ងាត់ ស្ងាត់វិសេស ស្ងាត់ដោយប្រការចាកកាយទុច្ចរិត ចាកវចីទុច្ចរិត ចាកមនោទុច្ចរិត ចាករាគៈ ។បេ។ ស្ងាត់ ស្ងាត់វិសេស ស្ងាត់ដោយប្រការចាកអភិសង្ខារជាអកុសលទាំងពួង ។ ពាក្យថា ប្រព្រឹត្តទៅ គឺត្រាច់ នៅ ទៅ ប្រព្រឹត្ត រក្សា ប្រព្រឹត្តទៅ ឲ្យប្រព្រឹត្តទៅ ។ ពាក្យថា ក្នុងលោក បានដល់មនុស្សលោក ហេតុនោះ ទ្រង់ត្រាស់ថា ស្ងាត់ចាកធម៌ទាំងឡាយណា ប្រព្រឹត្តទៅក្នុងលោក ។

[ ៨៣ ] អធិប្បាយពាក្យថា នាគមិនគប្បីពោលប្រកាន់នូវទិដ្ឋិទាំងនោះទេ ត្រង់ពាក្យថានាគ សេចក្តីថា ឈ្មោះថា នាគ ព្រោះហេតុមិនធ្វើបាប ។ ឈ្មោះថានាគ ព្រោះមិនលុះ ។ ឈ្មោះថា នាគព្រោះមិនមក ។ ចុះឈ្មោះថា នាគព្រោះមិនធ្វើបាបតើដូចម្តេច ។ អកុសលធម៌ទាំងឡាយដ៏លាមក មានសេចក្តីសៅហ្មងព្រម មានកិរិយាញ៉ាំងសត្វឲ្យកើតក្នុងភពទៀត ប្រកបដោយសេចក្តីក្រវល់ក្រវាយ មានសេចក្តីទុក្ខជាផល ជាបច្ច័យនៃជាតិ ជរានិងមរណៈ ទៅក្នុងអនាគត លោកហៅថាបាប ។

( ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលសភិយៈ ) បុគ្គល
មិនធ្វើបាបតិចតួចក្នុងលោក ស្រាយនូវចំណងទាំងឡាយ
ក្នុងកិលេសជាគ្រឿងប្រកបទាំងពួង មិនជាប់នៅក្នុងកិលេស

ទាំងពួង ជាបុគ្គលផុតស្រឡះហើយ ហេតុនោះលោកហៅថា
នាគ ជាតាទិបុគ្គល មានខ្លួនដ៏ទៀង បុគ្គលឈ្មោះថា នាគ
ព្រោះមិនធ្វើបាបយ៉ាងនេះឯង ។

ចុះបុគ្គលឈ្មោះថា នាគ ព្រោះមិនលុះតើដូចម្តេច ។ បុគ្គលមិនលុះឆន្ទាគតិ មិនលុះទោសាគតិ មិនលុះមោហាគតិ មិនលុះភយាគតិ មិនលុះដោយអំណាចរាគៈ មិនលុះដោយអំណាចទោសៈ មិនលុះដោយអំណាចមោហៈ មិនលុះដោយអំណាចមានះ មិនលុះដោយអំណាចទិដ្ឋិ មិនលុះដោយអំណាចឧទ្ធច្ចៈ មិនលុះដោយអំណាចវិចិកិច្ឆា មិនលុះដោយអំណាចអនុស័យ មិនប្រព្រឹត្តទៅ មិននាំទៅ មិនរសាត់ទៅ មិននាំទៅព្រមដោយធម៌ទាំងឡាយជាពួក បុគ្គលឈ្មោះថា នាគ ព្រោះមិនលុះយ៉ាងនេះឯង ។

ចុះបុគ្គលឈ្មោះថា នាគ ព្រោះមិនមកតើដូចម្តេច ។ កិលេសទាំងឡាយណា ដែលលោកលះបង់ហើយដោយសោតាបត្តិមគ្គ លោកមិនមក គឺមិនវិលមក មិនត្រឡប់មកកាន់កិលេសទាំងឡាយនោះទៀតទេ កិលេសទាំងឡាយណាដែលលោកលះបង់ហើយដោយសកទាគាមិមគ្គ ដោយអនាគាមិមគ្គ ដោយអរហត្តមគ្គ លោកមិនមក គឺមិនវិលមក មិនត្រឡប់មកកាន់កិលេសទាំងឡាយនោះទៀតទេ បុគ្គលឈ្មោះថា នាគ ព្រោះមិនមកយ៉ាងនេះ ។ ពាក្យថា នាគមិនគប្បីពោលប្រកាន់នូវទិដ្ឋិទាំងនោះទេ បានសេចក្តីថា នាគគប្បីមិនកាន់យក មិនប្រកាន់យក មិនទទួលយក មិនបបោសអង្អែល មិនជាប់ចិត្តហើយ ពោល ថ្លែង ពណ៌នា បំភ្លឺ ពន្យល់នូវទិដ្ឋិទាំងឡាយនោះទេ គឺមិនគប្បីពោល ថ្លែង

ពណ៌នា បំភ្លឺ ពន្យល់ថា លោកទៀង លោកមិនទៀង ។បេ។ សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ពាក្យនេះឯងពិត ពាក្យដទៃជាមោឃៈ ហេតុនោះ ( ទ្រង់ត្រាស់ថា ) នាគមិនគប្បីពោលប្រកាន់នូវទិដ្ឋិទាំងនោះទេ ។

[ ៤៤ ] ពាក្យថា ឯលម្ពុជាត កណ្ដកវារិជាត មិនប្រឡាក់ដោយទឹកផង ដោយភក់ផង យ៉ាងណាមិញ អធិប្បាយថា ទឹកលោកហៅថាឯលៈ ។ ទឹកហៅថាអម្ពុ ។ ឈូកហៅថាអម្ពុជាត ។ បន្លាហៅកណ្ដកៈ ។ ទឹកហៅថា វារិ ។ ឈូកកើតក្នុងវារិ មានវារិជាដែនកើត ហៅថាវារិជាត ។ ទឹកហៅថា ជលៈ ។ ភក់ហៅថាបង្កៈ ។ ឈូកកើតក្នុងវារិ មានវារិជាដែនកើត មិនប្រឡាក់ មិនជាប់ មិនទទឹក មិនប្រឡាក់ មិនជាប់ មិនទទឹកហើយដោយទឹកផង ដោយភក់ផង យ៉ាងណាមិញ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ឯលម្ពុជាត កណ្ដក-វារិជាត មិនប្រឡាក់ដោយទឹកផង ដោយភក់ផងយ៉ាងណាមិញ ។

[ ៤៥ ] អធិប្បាយពាក្យថា មុនិជាអ្នកពោលនូវសេចក្ដីស្ងប់ មិនប្រាថ្នា មិនប្រឡាក់ក្នុងកាមផង ក្នុងលោកផង យ៉ាងនោះឯង ត្រង់ពាក្យថា យ៉ាងនោះ ជាពាក្យញុំាងឧបមាឲ្យសម្រេច ។ ពាក្យថា មុនិ សេចក្ដីថា ញាណហៅថាមោនៈ ។បេ។ មុនិនោះកន្លងហើយនូវបណ្ដាញជាគ្រឿងជាប់ចំពាក់ ។ ពាក្យថា ពោលនូវសេចក្ដីស្ងប់ សេចក្ដីថា មុនិពោលនូវសេចក្ដីស្ងប់ ពោលនូវទីពឹង ពោលនូវទីជ្រក ពោលនូវទីរឭក ពោលនូវទីមិនមានភ័យ ពោលនូវទីមិនច្យុត ពោលនូវទីមិនស្លាប់ ពោលនូវព្រះនិព្វាន ហេតុនោះ ( ទ្រង់ត្រាស់ថា )

មុនិជាអ្នកពោលនូវសេចក្តីស្ងប់យ៉ាងនេះ ។ ពាក្យថា មិនប្រាថ្នា អធិប្បាយថា តណ្ហាលោកហៅថា សេចក្តីប្រាថ្នា បានដល់ តម្រេក តម្រេកខ្លាំង ។បេ។ អភិជ្ឈា លោភៈអកុសលមូល ។ សេចក្តីប្រាថ្នានោះ បុគ្គលណា លះបង់ ផ្តាច់បង់ ឲ្យស្ងប់ ឲ្យរម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺញាណហើយ បុគ្គលនោះ លោកហៅថាមិនប្រាថ្នា ។ បុគ្គលនោះ មិនប្រាថ្នាក្នុងរូប មិនប្រាថ្នាក្នុងសំឡេង ក្លិន រស ផ្សព្វ ត្រកូល ពួក អាវាស លាភ យស សេចក្តីសរសើរ សុខ ចីវរ បិណ្ឌបាត សេនាសនៈ បរិក្ខារគឺថ្នាំជាបច្ច័យសម្រាប់អ្នកជំងឺ កាមធាតុ រូបធាតុ អរូបធាតុ កាមភព រូបភព អរូបភព សញ្ញាភព អសញ្ញាភព នេវសញ្ញានាសញ្ញាភព ឯកវោការភព ចតុវោការភព បញ្ចវោការភព អតីត អនាគត បច្ចុប្បន្ន ក្នុងធម៌ទាំងឡាយដែលឃើញ ឮ ប៉ះពាល់ ឬគប្បីដឹង មិនជាប់ មិនចំពាក់ មិនជ្រប់ មិនលង់ មានសេចក្តីប្រាថ្នាទៅប្រាសហើយ មានសេចក្តីប្រាថ្នាឃ្លាតចេញហើយ មានសេចក្តីប្រាថ្នាខ្ជាក់ចោលហើយ មានសេចក្តីប្រាថ្នាផុតហើយ មានសេចក្តីប្រាថ្នាលះបង់ហើយ មានសេចក្តីប្រាថ្នាកម្ចាត់បង់ហើយ មានរាគៈទៅប្រាសហើយ មានរាគៈឃ្លាតចេញហើយ មានរាគៈខ្ជាក់ចោលហើយ មានរាគៈផុតហើយ មានរាគៈលះបង់ហើយ មានរាគៈកម្ចាត់បង់ហើយ មិនមានសេចក្តីប្រាថ្នា រលត់ហើយ មានត្រជាក់ មានកិរិយាសោយសុខជាប្រក្រតី មានខ្លួនដ៏ប្រសើរ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មុនិជាអ្នកពោលនូវសេចក្តីស្ងប់ មិនប្រាថ្នាយ៉ាងនេះ ។ ពាក្យថា កាម ក្នុងបទថា មិនប្រឡាក់ក្នុងកាមផង ក្នុងលោកផង សេចក្តីថា

តាមឧទ្ទាន កាមមាន ២ គឺវត្ថុកាម ១ កិលេសកាម ១ ។បេ។ ទាំងនេះហៅថា វត្ថុកាម ។បេ។ ទាំងនេះហៅថា កិលេសកាម ។ ពាក្យថា លោក បានដល់ អបាយលោក មនុស្សលោក ទេវលោក ខន្ធលោក ធាតុលោក អាយតនលោក ។ ពាក្យថា ប្រឡាក់ បានដល់ ការប្រឡាក់ ២ គឺការប្រឡាក់គឺតណ្ហា ១ ការប្រឡាក់គឺទិដ្ឋិ ១ ។បេ។ នេះការប្រឡាក់គឺតណ្ហា ។បេ។ នេះការប្រឡាក់គឺទិដ្ឋិ ។ អ្នកប្រាជ្ញលះបង់ការប្រឡាក់គឺតណ្ហា រលាស់ចោលការប្រឡាក់គឺទិដ្ឋិ មិនប្រឡាក់ មិនប្រឡាក់ព្រម មិនជាប់នៅក្នុងកាមផង ក្នុងលោកផង មិនប្រឡាក់ មិនប្រឡាក់ព្រម មិនជាប់ ចេញ រលាស់ចេញ ផុតស្រឡះ ប្រាសចេញ មានចិត្តប្រកបដោយកិលេស ដូចជាទំនប់ទៅប្រាសហើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មុនិពោលនូវសេចក្តីស្ងប់ មិនប្រាថ្នាក្នុងកាមផង ក្នុងលោកផង យ៉ាងនេះ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

> នាគស្ងាត់ចាកធម៌ទាំងឡាយណា ប្រព្រឹត្តទៅក្នុងលោក មិនគប្បីពោលប្រកាន់ទិដ្ឋិទាំងឡាយនោះទេ ឯលម្ពុជាត កណ្ដកវារិជាត មិនប្រឡាក់ដោយទឹកផង ដោយភក់ផង យ៉ាងណាមិញ មុនិជាអ្នកពោលនូវសេចក្តីស្ងប់ មិនប្រាថ្នា មិនប្រឡាក់ក្នុងកាមផង ក្នុងលោកផង យ៉ាងនោះឯង ។

[ ៨៦ ] វេទគូបុគ្គលនោះ មិនលុះមានះព្រោះទិដ្ឋិទេ ព្រោះការប៉ះពាល់ទេ ដ្បិតវេទគូបុគ្គលនោះ មិនសម្រេចដោយមានះនោះ ជាបុគ្គលដែលកម្មដឹកនាំមិនបាន ដែលសុតៈដឹកនាំមិនបាន វេទគូបុគ្គលនោះ មិនជាប់

ចំពាក់ក្នុងលំនៅទាំងឡាយ ។

[ ៤៧ ] អធិប្បាយពាក្យថា វេទគូបុគ្គលនោះ មិនលុះមានះព្រោះទិដ្ឋិទេ ព្រោះការប៉ះពាល់ទេ ត្រង់ពាក្យថា មិន គឺជាពាក្យហាមឃាត់ ។ ពាក្យថា វេទគូ សេចក្តីថា ញាណ បញ្ញា បញ្ញិន្ទ្រិយ បញ្ញាពលៈ ធម្មវិចយៈ សម្មោជ្ឈង្គៈ វីមំសា វិបស្សនា សម្មាទិដ្ឋិក្នុងមគ្គ ៤ លោកហៅថាវេទ ។ បុគ្គលទៅកាន់ទីបំផុត ដល់ទីបំផុត ទៅកាន់ទីខាងចុង ដល់ទីខាងចុង ទៅកាន់ទីបំផុតដោយជុំវិញ ដល់ទីបំផុតដោយជុំវិញ ទៅកាន់ទីអវសាន ដល់ទីអវសាននៃជាតិ ជរា មរណៈ ទៅកាន់ទីពឹងពួន ដល់ទីពឹងពួន ទៅកាន់ទីជ្រកកោន ដល់ទីជ្រកកោន ទៅកាន់ទីរឭក ដល់ទីរឭក ទៅកាន់ទីមិនមានភ័យ ដល់ទីមិនមានភ័យ ទៅកាន់ទីមិនច្យុត ដល់ទីមិនច្យុត ទៅកាន់ទីអមតៈ ដល់ទីអមតៈ ទៅកាន់ព្រះនិព្វាន ដល់ព្រះនិព្វានដោយវេទទាំងឡាយនោះ ។ មួយទៀត បុគ្គលឈ្មោះថា វេទគូ ព្រោះដល់នូវទីបំផុតនៃវេទទាំងឡាយ ឬឈ្មោះថា វេទគូ ព្រោះដល់នូវទីបំផុតដោយវេទទាំងឡាយ ឬឈ្មោះថា វេទគូ ព្រោះដឹងច្បាស់នូវធម៌ទាំងឡាយ ៧ ប្រការ គឺដឹងច្បាស់នូវសក្កាយទិដ្ឋិ ១ ដឹងច្បាស់នូវវិចិកិច្ឆា ១ ដឹងច្បាស់នូវសីលព្វតបរាមាស ១ ដឹងច្បាស់នូវរាគៈ ១ ដឹងច្បាស់នូវទោសៈ ១ ដឹងច្បាស់នូវមោហៈ ១ ដឹងច្បាស់នូវមានះ ១ ។ អកុសលធម៌ទាំងឡាយដ៏លាមក អកុសលជាគ្រឿងញុំាងសត្វឲ្យសៅហ្មងព្រម ជាធម៌ញុំាងសត្វឲ្យកើតក្នុងភពថ្មីទៀត ប្រកបដោយសេចក្តីក្រវល់ក្រវាយ មានសេចក្តីទុក្ខជាផល ជាទីតាំងនៃជាតិ ជរា មរណៈតទៅទៀត សុទ្ធតែជាធម៌ គឺវេទគូបុគ្គលដឹង

ច្បាស់ហើយ ។

( ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលសភិយៈ ) វេទគូបុគ្គល គប្បីពិចារណានូវវេទទាំងអស់ ដែលជារបស់ពួកសមណព្រាហ្មណ៍ វេទគូបុគ្គលនោះ មានរាគៈទៅប្រាសហើយ ក្នុងវេទទាំងពួង កន្លងបង់នូវវេទទាំងពួង ។

ពាក្យថា មិន ( លុះមានះ ) ព្រោះទិដ្ឋិទេ សេចក្ដីថា ទិដ្ឋិទាំងឡាយ ៦២ វេទគូបុគ្គលនោះលះបង់ ផ្ដាច់បង់ ឲ្យស្ងប់ ឲ្យរម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ បុគ្គលនោះ ទិដ្ឋិឲ្យទៅមិនបាន នាំទៅមិនបាន បន្សាត់ទៅមិនបាន នាំទៅព្រមមិនបានព្រោះទិដ្ឋិ ទាំងមិនជឿ មិនប្រកាន់នូវទិដ្ឋិនោះ ថាជាខ្លឹមសារ ហេតុនោះ ( ទ្រង់ត្រាស់ថា ) វេទគូបុគ្គល មិន ( លុះមានះ ) ព្រោះទិដ្ឋិទេ ។ ពាក្យថា វេទគូបុគ្គលនោះ មិនលុះមានះព្រោះការប៉ះពាល់ទេ សេចក្ដីថា មិនលុះ គឺមិនទៅជិត មិនចូលទៅ មិនប្រកាន់ មិនបបោសអង្អែល មិនជាប់ចិត្តនូវមានះ ព្រោះរូបដែលប៉ះពាល់ ឬព្រោះការឃោសនារបស់បុគ្គលដទៃ ឬក៏ព្រោះសេចក្ដីសម្មតិរបស់មហាជន ហេតុនោះ ( ទ្រង់ត្រាស់ថា ) វេទគូបុគ្គលនោះ មិនលុះមានះព្រោះទិដ្ឋិទេ ព្រោះការប៉ះពាល់ទេ ។ ពាក្យថា វេទគូបុគ្គលនោះ មិនសម្រេចដោយមានះនោះ សេចក្ដីថា មិនមែនជាបុគ្គលសម្រេចដោយមានះនោះ មានមានះនោះជាធំ មានមានះនោះប្រព្រឹត្តទៅក្នុងខាងមុខ ដោយអំណាចតណ្ហា ដោយអំណាចទិដ្ឋិទេ ។ តណ្ហាក្ដី ទិដ្ឋិក្ដី មានះក្ដី វេទគូបុគ្គលលះបង់ ផ្ដាច់ផ្ដិលឫសគល់ហើយ ធ្វើមិនឲ្យមាន

ទីកើត ដូចជាទីកើតនៃដើមត្នោត ដល់នូវការមិនមាន ជាធម៌មិនមានការកើតតទៅទៀត ដោយហេតុណា វេទគូបុគ្គលនោះ មិនសម្រេចដោយមានះនោះ មិនមានមានះនោះជាធំ មិនមានមានះនោះប្រព្រឹត្តទៅក្នុងខាងមុខ ដោយហេតុមានប្រមាណប៉ុណ្ណោះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ព្រោះវេទគូបុគ្គលនោះ មិនសម្រេចដោយមានះនោះ ។

[ ៤៨ ] អធិប្បាយពាក្យថា ជាបុគ្គលដែលកម្មនាំទៅមិនបាន ដែលសុតៈនាំទៅមិនបាន ត្រង់ពាក្យថា ដែលកម្មនាំទៅមិនបាន គឺដែលបុញ្ញាភិសង្ខារក្តី អបុញ្ញាភិសង្ខារក្តី អានេញ្ជាភិសង្ខារក្តី ឲ្យទៅមិនបាន នាំទៅមិនបាន បន្សាត់ទៅមិនបាន នាំទៅព្រមមិនបាន ហេតុនោះ ( ទ្រង់ត្រាស់ថា ) ដែលកម្មនាំទៅមិនបាន ។ ពាក្យថា ដែលសុតៈនាំទៅមិនបាន គឺដែលសេចក្តីបរិសុទ្ធព្រោះការឮក្តី ដែលការឃោសនារបស់បុគ្គលដទៃក្តី ដែលការសម្មតិរបស់មហាជនក្តី ឲ្យទៅមិនបាន នាំទៅមិនបាន បន្សាត់ទៅមិនបាន នាំទៅព្រមមិនបាន ហេតុនោះ ( ទ្រង់ត្រាស់ថា ) ដែលកម្មនាំទៅមិនបាន ដែលសុតៈនាំទៅមិនបាន ។

[ ៤៩ ] អធិប្បាយពាក្យថា វេទគូបុគ្គលនោះមិនជាប់ចំពាក់ក្នុងលំនៅទាំងឡាយ ត្រង់ពាក្យថា ជាប់ចំពាក់ បានដល់ការជាប់ចំពាក់ ២ យ៉ាង គឺការជាប់ចំពាក់គឺតណ្ហា ១ ការជាប់ចំពាក់គឺទិដ្ឋិ ១ ។បេ។ នេះការជាប់ចំពាក់គឺតណ្ហា ។បេ។ នេះជាការជាប់ចំពាក់គឺទិដ្ឋិ ។ ការជាប់ចំពាក់គឺតណ្ហា វេទគូបុគ្គលនោះលះបង់ហើយ ការជាប់ចំពាក់គឺទិដ្ឋិ វេទគូបុគ្គលរលាស់ចោលហើយ

ព្រោះលះបង់ការជាប់ចំពាក់គឺតណ្ហា រលាស់ចោលការជាប់ចំពាក់គឺទិដ្ឋិហើយ វេទគូបុគ្គលនោះ ឈ្មោះថា មិនជាប់ចំពាក់ មិនចូលទៅប្រឡាក់ មិនចូលទៅជិត មិនជក់នៅ មិនលង់នៅក្នុងលំនៅទាំងឡាយ គឺចេញទៅ រលាស់ចេញ ផុតស្រឡះ ប្រាសចេញ មានចិត្តប្រកបដោយកិលេស ដូចជាទំនប់ទៅប្រាស ហើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) វេទគូបុគ្គលនោះ មិនជាប់ចំពាក់ក្នុង លំនៅទាំងឡាយ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

> វេទគូបុគ្គលនោះមិនលុះមានះព្រោះទិដ្ឋិទេ ព្រោះការប៉ះពាល់ទេ
> ដ្បិតវេទគូបុគ្គលនោះ មិនសម្រេចដោយមានះនោះ ជាបុគ្គល
> ដែលកម្មដឹកនាំមិនបាន ដែលសុតៈដឹកនាំមិនបាន វេទគូបុគ្គល
> នោះ មិនជាប់ចំពាក់ក្នុងលំនៅទាំងឡាយ ។

[ ៥០ ] កិលេសជាគ្រឿងចាក់ស្រែះទាំងឡាយនៃបុគ្គល ដែលប្រាសចាកសញ្ញាមិនមានទេ មោហៈទាំងឡាយនៃបុគ្គល ដែលផុតស្រឡះដោយបញ្ញាមិនមានទេ បុគ្គលទាំងឡាយណា ប្រកាន់យកសញ្ញានិងទិដ្ឋិហើយ បុគ្គលទាំងនោះ រមែងបន្ត ( នូវអត្តភាព ) ប្រព្រឹត្តទៅក្នុងលោក ។

[ ៥១ ] ពាក្យថា កិលេសជាគ្រឿងចាក់ស្រែះទាំងឡាយនៃបុគ្គលដែលប្រាសចាកសញ្ញាមិនមានទេ អធិប្បាយថា បុគ្គលណាចម្រើនអរិយមគ្គ មានសមថៈជាប្រធាន បុគ្គលនោះឈ្មោះថា ធ្វើសមាធិខាងដើមឲ្យកើតហើយសង្កត់សង្កិនកិលេសជាគ្រឿងចាក់ស្រែះទាំងឡាយ ។ ក្នុងកាលសម្រេចព្រះអរហត្តហើយ ព្រះអរហន្តលះបង់កិលេសជាគ្រឿងចាក់ស្រែះទាំងឡាយ មោហៈទាំង

ឡាយ នីវរណៈទាំងឡាយ កាមសញ្ញា ព្យាបាទសញ្ញា វិហឹសាសញ្ញានិងទិដ្ឋិសញ្ញា លោកបានផ្តាច់បង់ឫសគល់ហើយ ធ្វើមិនឲ្យមានទីកើត ដូចជាទីកើតនៃដើមត្នោត ដល់នូវការមិនមាន ជាធម៌មិនមានការកើតទៀត ហេតុនោះ (ទ្រង់ត្រាស់ថា) កិលេសជាគ្រឿងចាក់ស្រែះទាំងឡាយនៃបុគ្គលដែលប្រាសចាកសញ្ញាមិនមានទេ ។

[ ៥២ ] ពាក្យថា មោហៈទាំងឡាយនៃបុគ្គលដែលផុតស្រឡះដោយបញ្ញាមិនមានទេ អធិប្បាយថា បុគ្គលណាចម្រើនអរិយមគ្គ មានវិបស្សនាជាប្រធាន បុគ្គលនោះឈ្មោះថា ធ្វើសមាធិខាងដើមឲ្យកើត សង្កត់សង្កិននូវមោហៈ ។ ក្នុងកាលសម្រេចព្រះអរហត្តហើយ ព្រះអរហន្តលះបង់មោហៈទាំងឡាយ កិលេសជាគ្រឿងចាក់ស្រែះទាំងឡាយ នីវរណៈទាំងឡាយ កាមសញ្ញា ព្យាបាទសញ្ញា វិហឹសាសញ្ញានិងទិដ្ឋិសញ្ញា ផ្តាច់ឫសគល់ហើយ ធ្វើមិនឲ្យមានទីកើត ដូចជាទីកើតនៃដើមត្នោត ដល់នូវការមិនមាន ជាធម៌មិនមានការកើតតទៅទៀត ហេតុនោះ ( ទ្រង់ត្រាស់ថា ) មោហៈទាំងឡាយនៃបុគ្គលដែលផុតស្រឡះដោយបញ្ញាមិនមានទេ ។

[ ៥៣ ] ពាក្យថា បុគ្គលទាំងឡាយណា ប្រកាន់យកសញ្ញានិងទិដ្ឋិហើយ បុគ្គលទាំងនោះរមែងបន្ត ( នូវអត្តភាព ) ប្រព្រឹត្តទៅក្នុងលោក អធិប្បាយថា បុគ្គលទាំងឡាយណា ប្រកាន់យកសញ្ញា គឺកាមសញ្ញា ព្យាបាទសញ្ញា វិហឹសាសញ្ញា បុគ្គលទាំងឡាយនោះ រមែងប៉ះពាល់ ប៉ះទង្គិចដោយអំណាចសញ្ញា ។ ពួកព្រះរាជា រមែងទាស់ទែងនឹងពួកព្រះរាជា ពួកក្សត្រិយ៍ រមែង

ទាស់ទែងនឹងពួកក្សត្រិយ៍ ពួកព្រាហ្មណ៍រមែងទាស់ទែងនឹងពួកព្រាហ្មណ៍ ពួកគហបតីរមែងទាស់ទែងនឹងពួកគហបតី មាតារមែងទាស់ទែងនឹងបុត្ត បុត្តរមែងទាស់ទែងនឹងមាតា បិតារមែងទាស់ទែងនឹងបុត្ត បុត្តរមែងទាស់ទែងនឹងបិតា បងប្អូនប្រុសរមែងទាស់ទែងនឹងបងប្អូនប្រុស បងប្អូនស្រីរមែងទាស់ទែងនឹងបងប្អូនស្រី បងប្អូនប្រុសរមែងទាស់ទែងនឹងបងប្អូនស្រី បងប្អូនស្រីរមែងទាស់ទែងនឹងបងប្អូនប្រុស សម្លាញ់រមែងទាស់ទែងនឹងសម្លាញ់ ។ ជនទាំងនោះដល់នូវជម្លោះ ប្រកួតប្រកាន់ ការទាស់ទែង ប្រហារគ្នានឹងគ្នាដោយដៃខ្លះ ប្រហារដោយដុំដីទាំងឡាយខ្លះ ប្រហារដោយដំបងទាំងឡាយខ្លះ ប្រហារដោយគ្រឿងសស្ត្រាទាំងឡាយខ្លះ ក្នុងហេតុនោះ ។ ជនទាំងនោះដល់នូវសេចក្តីស្លាប់ខ្លះ នូវទុក្ខទៀបស្លាប់ខ្លះ ក្នុងហេតុនោះ ។ ជនទាំងឡាយណា ប្រកាន់យកនូវទិដ្ឋិថា លោកទៀងដូច្នេះក្តី ។បេ។ សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ដូច្នេះក្តី ជនទាំងនោះរមែងបៀតបៀន បៀតបៀនព្រមដោយអំណាចទិដ្ឋិ រមែងបៀតបៀនសាស្តាព្រោះសាស្តា បៀតបៀនធម៌ដែលសាស្តាសម្តែងហើយ ព្រោះធម៌ដែលសាស្តាសម្តែងហើយ បៀតបៀនពួកព្រោះពួក បៀតបៀនទិដ្ឋិព្រោះទិដ្ឋិ បៀតបៀនបដិបទាព្រោះបដិបទា បៀតបៀនមគ្គព្រោះមគ្គ ។ មួយទៀត ជនទាំងនោះរមែងទាស់ទែង ធ្វើជម្លោះ ធ្វើសេចក្តីប្រកួតប្រកាន់ ធ្វើសេចក្តីប្រកាន់ខុសធ្វើវិវាទ ធ្វើការជណ្តើមយកឈ្នះថា អ្នកមិនចេះធម្មវិន័យនេះទេ ។បេ។ ឬបើអ្នកអាចអ្នកចូរដោះចុះ ។ អភិសង្ខារទាំងឡាយ គឺបុគ្គលទាំងនោះមិនបាន

លះបង់ ព្រោះការមិនបានលះបង់អភិសង្ខារទាំងឡាយ ទើបបុគ្គលទាំងនោះរមែងលំបាកក្នុងគតិ លំបាកក្នុងនរក លំបាកក្នុងកំណើតតិរច្ឆាន លំបាកក្នុងប្រេតវិស័យ លំបាកក្នុងមនុស្សលោក លំបាកក្នុងទេវលោក លំបាកខ្ជាប់នូវគតិដោយគតិ នូវការកើតដោយការកើត នូវបដិសន្ធិដោយបដិសន្ធិ នូវភពដោយភព នូវសង្សារដោយសង្សារ នូវវដ្តៈដោយវដ្តៈ កាលលំបាក រមែងត្រាច់ទៅ រមែងទៅ រមែងញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ។ ពាក្យថា លោក គឺ អបាយលោក មនុស្សលោក ទេវលោក ខន្ធលោក ធាតុលោក អាយតនលោក ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលទាំងឡាយណា ប្រកាន់យកសញ្ញានិងទិដ្ឋិ បុគ្គលទាំងនោះឈ្មោះថា បន្ទ ( នូវអត្តភាព ) ប្រព្រឹត្តទៅក្នុងលោក ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

កិលេសជាគ្រឿងចាក់ស្រេះទាំងឡាយ នៃបុគ្គលដែលប្រាសចាកសញ្ញាមិនមានទេ មោហៈទាំងឡាយនៃបុគ្គលដែលផុតស្រឡះដោយបញ្ញាមិនមានទេ បុគ្គលទាំងឡាយណា ប្រកាន់យកសញ្ញានិងទិដ្ឋិហើយ បុគ្គលទាំងនោះរមែងបន្ទ ( នូវអត្តភាព ) ប្រព្រឹត្តទៅក្នុងលោក ។

## ចប់ មាគន្ទិយសុត្តនិទ្ទេសទី ៩

# អដ្ឋកថា
# មាគណ្ឌិយសុត្តនិទ្ទេស ទី ៩

ក្នុងមាគណ្ឌិយសុត្តនិទ្ទេសទី ៩ មានវិនិច្ឆ័យដូចតទៅនេះថា

[ ១ ] គប្បីជ្រាបអត្ថ ក្នុងគាថាដំបូងថា ត្រឹមតែការពេញចិត្តក្នុងមេថុន ក៏មិនមាន ព្រោះឃើញមារធីតា គឺនាងតណ្ហា នាងអរតីនិងនាងរាគាដែលនិម្មិតរូបផ្សេងៗដែលគួរប្រាថ្នាក្រៃពេក ត្រង់គល់អជបាលនិគ្រោធ តើនឹងពេញចិត្តក្នុងមេថុន ព្រោះឃើញរូបដែលពេញដោយមូត្រនិងករីសរបស់ទារិកានេះដូចម្តេចកើត តថាគតមិនប្រាថ្នានឹងពាល់ត្រូវរូបនោះដោយប្រការទាំងពួងសូម្បីដោយជើង ការនៅរួមជាមួយរូបនោះនឹងមានអំពីណា ។

[ ៣ ] បទថា **មុត្តបុណ្ណំ** សេចក្តីថា ពេញដោយមូត្រ ដែលពេញខាងក្នុងតម្រងបស្សាវៈ ដោយអំណាចនៃអាហារនិងរដូវ ។ បទថា **ករីស-បុណ្ណំ** សេចក្តីថា ពេញដោយវច្ចៈដែលតាំងនៅខាងចុងពោះវៀនធំ កម្ពស់ប្រមាណ ៨ អង្គុលី ត្រង់ចន្លោះផ្ចិតនិងឆ្អឹងខ្នងខាងក្រោយ ពោលគឺក្រពះអាហារចាស់ ។ បទថា **សេម្ហបុណ្ណំ** សេចក្តីថា ពេញដោយស្លេស្មប្រមាណមួយនាឡិ តាំងនៅក្នុងផ្ទៃពោះ ។

បទថា **រុហិរបុណ្ណំ** សេចក្តីថា ពេញដោយឈាម ២ យ៉ាង ពោលគឺឈាមដែលសន្សំទុកប្រមាណមួយបាត្រ ពេញចំណែកខាងក្រោមរបស់ថ្លើម ហើយហូរសន្សើមៗ ទៅលើបេះដូង ទាចនិងសួត ធ្វើទាច បេះដូង ថ្លើម និងសួតឲ្យសើមតាំងនៅ ១ ពោលគឺឈាមដែលមានចលនាផ្សាយពេញសរីរៈ

ដែលមានចិត្តគ្រប់គ្រង ដោយជ្រួតជ្រាបទៅតាមសរសៃឈាម វៀរសក់ រោម ក្រចក ធ្មេញ ដែលដុះផុតចេញអំពីសាច់និងស្បែកក្រិន ស្បែកស្ងួត តាំងនៅ ១ ។

បទថា **អដ្ឋិសង្ឃាដំ** សេចក្តីថា ក្នុងសរីរៈទាំងមូលជាប់តគ្នាហើយដោយឆ្អឹងជាង ៣០០ កំណាត់ តាំងនៅលើនៃឆ្អឹងទាំងឡាយផ្នែកខាងក្រោម ។

បទថា **ន្ហារុសម្ពន្ធំ** សេចក្តីថា ក្នុងសរីរៈទាំងមូលមានសរសៃ ៩០០ ចងទុកនូវឆ្អឹងទាំងឡាយ គឺចងដោយសរសៃទាំងនោះ ។

បទថា **រុធិរមំសាវលេបនំ** សេចក្តីថា សរីរៈដែលបូកលាបដោយឈាមជាគ្រឿងស្អុះទៅនិងដោយដុំសាច់ ៩០០ ដុំ ដែលតាំងនៅ បូកលាបឆ្អឹងជាង ៣០០ កំណាត់ ។

បទថា **ចម្មាវនទ្ធំ** សេចក្តីថា ស្បែកដែលតាំងនៅក្រោមសម្បុរថ្លៃលើភាវដែលប្រាកដ បិទបាំងសរីរៈទាំងមូល ដែលស្បែកនោះស្រោប គឺបិទបាំងទុក បាលីថា **ចម្មាវនទ្ធំ** ដូច្នេះក៏មាន ។

បទថា **ឆវិយា បដិច្ឆន្នំ** សេចក្តីថា ដែលសម្បុរស្បែកដ៏ល្អិតក្រៃលែងបិទបាំង គឺស្រោបពីខាងក្រៅ ។

បទថា **ឆិទ្ទាវឆិទ្ទំ** សេចក្តីថា មានប្រហោងមិនមែនតិច ។ បទថា **ឧគ្ឃរិ** សេចក្តីថា ហូរចេញតាមភ្នែកនិងមាត់ជាដើម ។ បទថា **បគ្ឃរិ** សេចក្តីថា ហូរចេញតាមចំណែកខាងក្រោម ។ បទថា **កិមិសង្ឃនិសេវិតំ** សេចក្តីថា ដែលពួកសត្វមានជីវិតផ្សេងៗ មានមាត់រីងដូចម្ជុលជាដើមអាស្រ័យហើយ ។

បទថា **នានាកលិមលបរិបូរំ** សេចក្តីថា ពេញទៅដោយចំណែកដែលមិនស្អាតច្រើនយ៉ាង ។

[ ៤ ] លំដាប់នោះ មាគណ្ឌិយព្រាហ្មណ៍ពោលគាថាទី ២ ដើម្បីទូលសួរថា ធម្មតាបព្វជិតទាំងឡាយលះកាមដែលជារបស់មនុស្សហើយ រមែងបួសដើម្បីកាមដែលជាទិព្វ សមណៈនេះមិនប្រាថ្នាកាមជាទិព្វ គឺឥត្ថីរតនៈនេះ សមណៈនេះមានទិដ្ឋិដូចម្តេចហ្ន៎ ។

បណ្តាបទទាំងនោះ បទថា **ឯតាទិសញ្ចេ រតនំ** សេចក្តីថា មាគណ្ឌិយព្រាហ្មណ៍ ពោលសំដៅយកស្រីកែវថាជាទិព្វ ។

បទថា **នារឹ** បានដល់ សំដៅយកកូនស្រីរបស់ខ្លួន ។ បទថា **ទិដ្ឋិគតំ សីលវតំ នុ ជីវិតំ** បានដល់ ទិដ្ឋិ សីល វត្តនិងជីវិត ។ បទថា **ភវូប-បត្តិញ្ច វទេសិ កីទិសំ** សេចក្តីថា ឬលោកពោលឧបបត្តិភពរបស់ខ្លួនថាដូចមេ[illegible]។

[ ៥ ] ២ គាថាបន្ទាប់អំពីនេះ មានការទាក់ទងគ្នាប្រាកដហើយនោះឯងព្រោះប្រព្រឹត្តទៅដោយន័យរបស់ការវិសជ្ជនានិងបុច្ឆា ។ បណ្តាគាថា ២ នោះ គាថាទី ១ មានសេចក្តីសង្ខេបថា ម្នាលមាគណ្ឌិយៈ ការធ្លាក់ចុះក្នុងធម៌គឺទិដ្ឋិ ៦២ ហើយប្រកាន់មាំថា តថាគតពោលវត្ថុនេះយ៉ាងនេះថា វត្ថុនេះប៉ុណ្ណោះពិត វត្ថុដទៃទទេដូច្នេះមិនមាន គឺរមែងមិនមាន មិនមានដល់តថាគត ព្រោះហេតុអ្វី ព្រោះកាលតថាគតឃើញទោសក្នុងទិដ្ឋិទាំងឡាយ មិនប្រកាន់មាំក្នុងទិដ្ឋិណាមួយ កាលជ្រើសរើសនូវសច្ចៈទាំងឡាយ បានឃើញនិព្វាន ពោលគឺការស្ងប់

ខាងក្នុង ព្រោះភាពដែលកិលេសទាំងឡាយមានរាគៈជាដើមខាងក្នុងស្ងប់ហើយ ។

[ ៨ ] បទថា **អាធីនវំ** បានដល់ ឧបទ្រព ។ បទថា **សទុក្ខំ** សេចក្តីថា មានទុក្ខដោយទុក្ខផ្លូវកាយ ។ បទថា **សវិឃាតំ** សេចក្តីថា មានទុក្ខដោយទុក្ខផ្លូវចិត្ត ។ បទថា **សឧបាយាសំ** សេចក្តីថា ប្រកបដោយការចង្អៀតចង្អល់ ។ បទថា **សបរិឡាហំ** សេចក្តីថា ប្រព្រឹត្តទៅដោយការក្រវល់ក្រវាយ ។ បទថា **ន និព្វិទាយ** សេចក្តីថា មិនប្រព្រឹត្តទៅដើម្បីការនឿយណាយក្នុងវដ្តៈ ។

បទថា **ន វិរាគាយ** សេចក្តីថា មិនប្រព្រឹត្តទៅដើម្បីប្រាសចាកតម្រេកក្នុងវដ្តៈ ។ បទថា **ន និរោធាយ** សេចក្តីថា មិនប្រព្រឹត្តទៅដើម្បីរំលត់វដ្តៈ ។ បទថា **ន ឧបសមាយ** សេចក្តីថា មិនប្រព្រឹត្តទៅដើម្បីចូលទៅស្ងប់វដ្តៈ ។ បទថា **ន អភិញ្ញាយ** សេចក្តីថា មិនប្រព្រឹត្តទៅដើម្បីដឹងក្រៃលែងនូវវិវដ្ត គឺព្រះនិព្វាន ។ បទថា **ន សម្ពោធាយ** សេចក្តីថា មិនប្រព្រឹត្តទៅដើម្បីដឹងច្បាស់នូវវដ្តៈ ដោយសម្រេចដល់ការរំលត់កិលេស ។ បទថា **ន និព្វានាយ** សេចក្តីថា មិនប្រព្រឹត្តទៅដើម្បីអមតនិព្វាន ។ បទថា **និព្វិទាយ** ក្នុងទីនេះ បានដល់វិបស្សនា ។ ពាក្យថា **វិរាគាយ** បានដល់ មគ្គ ។ ពាក្យថា **និរោ–ធាយ ឧបសមាយ** បានដល់ និព្វាន ។ ពាក្យថា **អភិញ្ញាយ សម្ពោធាយ** បានដល់ មគ្គ ។ ពាក្យថា **និព្វានាយ** បានដល់ និព្វាននោះឯង ដោយប្រការដូច្នេះ ។ វិបស្សនា លោកពោលក្នុងឋានៈ ១ មគ្គលោកពោលក្នុងឋានៈ ៣ និព្វានលោកពោលក្នុងឋានៈ ៣ គប្បីជ្រាបកថាពោលដោយការកំណត់ដោយប្រការដូច្នេះ ។ តែដោយបរិយាយ បទទាំងអស់នេះ រមែង

ជាវេចនៈនៃមគ្គផង ជាវេវចនៈនៃនិព្វាននោះឯងផង ។

[ ៩ ] បទថា **អជ្ឈត្តំ រាគស្ស សន្តឹ** សេចក្តីថា បានឃើញនិព្វាន ពោលគឺការស្ងប់ខាងក្នុង ព្រោះភាពដែលរាគៈខាងក្នុងស្ងប់ហើយ រំលត់ហើយ ។ ក្នុងបទថា **ទោសស្ស សន្តឹ** ជាដើមក៏ន័យនេះឯង ។

បទថា **បចិនំ** ជាបទឧទ្ទេសនៃបទដែលត្រូវចង្អុលបង្ហាញ ។ បទថា **វិចិ–នន្តោ** បានដល់ ញុំាងសច្ចៈទាំងឡាយឲ្យចម្រើន គឺឲ្យជាក់ច្បាស់ ។ បទថា **បវិចិនន្តោ** សេចក្តីថា ញុំាងសច្ចៈទាំងនោះឯងឲ្យជាក់ច្បាស់ជាផ្នែកៗ ។ អាចារ្យពួកខ្លះពណ៌នាទុកថា ស្វែងរក ។ បទថា **អទស្សំ** សេចក្តីថា សម្លឹងមើលហើយ ។ បទថា **អទក្ខឹ** សេចក្តីថា ចាក់ធ្លុះហើយ ។ បទថា **អជស្សឹ** សេចក្តីថា ពាល់ត្រូវដោយបញ្ញា ។ បទថា **បដិវិជ្ឈឹ** សេចក្តីថា បានធ្វើឲ្យប្រចក្សដោយញាណ ។

[ ១០ ] គាថាទី ២ មានសេចក្តីសង្ខេបថា មាគណ្ឌិយព្រាហ្មណ៍ពោលថា ទិដ្ឋិទាំងនេះដែលត្រាស់ថា **វិនិច្ឆយា** ព្រោះពួកសត្វនោះៗ សម្រេចចិត្តកាន់យកហើយ និងត្រាស់ថា **បកប្បិតានិ** ដោយន័យមានការៈដែលបច្ច័យទាំងឡាយរបស់ខ្លួនតាក់តែងជាដើម មុនីមិនកាន់យកធម៌ គឺទិដ្ឋិទាំងនោះឡើយ ពោលអត្ថនោះថា **អជ្ឈត្តសន្តិ** សូមទ្រង់មេត្តា ពោលគឺប្រាប់សេចក្តីនោះថា ធីរៈជនទាំងឡាយប្រាប់ឲ្យដឹងហើយគឺ ធីរៈជនទាំងឡាយប្រកាសទុកហើយ ដូចម្តេចដល់ខ្ញុំព្រះអង្គផង ។ និទ្ទេសនៃគាថានេះ ក្រៅអំពីបទដែលជាបរមត្ថ មានអត្ថងាយយល់ហើយ ។

[ ១២ ] បណ្តាបទទាំងនោះ បទថា **យំ បរមត្ថំ** បានដល់ និព្វាន ដ៏ឧត្តម ។

[ ១៤ ] លំដាប់នោះ ព្រះមានព្រះភាគកាលទ្រង់សម្តែងឧបាយដែលជីវជនទាំងឡាយប្រើជាគ្រឿងប្រកាសអត្ថនោះ ព្រមទាំងធម៌ដែលជាចំណែកផ្ទុយដល់ព្រាហ្មណ៍នោះ ទើបត្រាស់គាថាថា **ន ទិដ្ឋិយា** ជាដើម ។

បណ្តាបទទាំងនោះ ព្រះមានព្រះភាគទ្រង់បដិសេធសីលនិងវត្តខាងក្រៅចាកញាណដែលបានអំពីសមាបត្តិ ដោយព្រះតម្រាស់ថា **ន ទិដ្ឋិយា** ជាដើម បណ្ឌិតគប្បីនាំបទ ៣ ទៅប្រកបជាមួយពាក្យថា **អាហ** ដែលត្រាស់ទុកក្នុងពាក្យនេះថា **សុទ្ធិមាហ** និងសព្ទថា **ន** ក្នុងទីគ្រប់អន្លើ ហើយគប្បីជ្រាបអត្ថយ៉ាងនេះថា មិនពោល គឺមិនប្រាប់នូវការបរិសុទ្ធដោយទិដ្ឋិ ។ ក្នុងបទនេះយ៉ាងណា សូម្បីក្នុងបទតទៅ ក៏យ៉ាងនោះ ។

ម្យ៉ាងទៀត ក្នុងបទទាំងនោះ បទថា **អទិដ្ឋិយា នាហ** សេចក្តីថា មិនពោល ( សេចក្តីបរិសុទ្ធ ) វៀរសម្មាទិដ្ឋិមានវត្ថុ ១០ ។ បទថា **អស្សុតិយា** ក៏ដូចគ្នា សេចក្តីថា មិនពោលវៀរនូវការស្តាប់ ។ បទថា **អញាណា** សេចក្តីថា វៀរកម្មស្សកតាញាណនិងសច្ចានុលោមិកញ្ញាណ ។ បទថា **អសីលតា** សេចក្តីថា វៀរនូវបាតិមោក្ខសំវរៈ ។ បទថា **អព្វតា** សេចក្តីថា វៀរធុតង្គវត្ត ។ បទថា **នោបិ តេន** គប្បីជ្រាបអត្ថយ៉ាងនេះថា តថាគតមិនពោលសូម្បីដោយធម៌ ត្រឹមតែទិដ្ឋិជាដើមមួយ ក្នុងធម៌ទាំងនោះ ។

បទថា **ឯតេ ច និស្សជ្ជ អនុគ្គហាយ** សេចក្តីថា លះនូវធម៌ចំណែក

ខ្មៅ ប្រភេទទិដ្ឋិជាដើម ដែលមានក្នុងខាងដើមទាំងនោះ ដោយការដកឡើង និងមិនប្រកាន់មាំក្នុងធម៌ជាចំណែកស ប្រភេទជា ( សម្មា ) ទិដ្ឋិជាដើម ដែលមានខាងក្រោយ ដោយការដល់នូវការមិនចាំបាច់ដកឡើង ។

បទថា **សន្តោ អនិស្សាយ ភវំ ន ជប្បេ** សេចក្តីថា ជាអ្នកស្ងប់ដោយការចូលទៅស្ងប់រាគៈជាដើម ដោយការបដិបត្តិនេះ មិនអាស្រ័យធម៌ណាមួយក្នុងចក្ខុជាដើម មិនគប្បីសង្ឃឹមសូម្បីតែភពមួយ គឺគប្បីជាបុគ្គលអាចដើម្បីមិនត្រេកអរ គឺមិនប្រាថ្នា អធិប្បាយថា នេះជាការស្ងប់ខាងក្នុងរបស់បុគ្គលនោះ ។

[ ១៧ ] បទថា **សវនម្បិ ឥច្ឆិតព្វំ** សេចក្តីថា ធ្វើនូវការស្តាប់ដោយអំណាចនៃសុត្តៈជាដើម ក៏គប្បីសង្ឃឹម ។ បទថា **សម្ភារា ឥមេ ធម្មា** សេចក្តីថា ធម៌ទាំងនេះ មានសម្មាទិដ្ឋិជាដើមជាសម្ភារៈ ដោយអត្ថថា ជាឧបការៈ ។

[ ១៨ ] បទថា **កណ្ហាបក្ខិកានំ** សេចក្តីថា ធម៌ដែលប្រព្រឹត្តទៅក្នុងចំណែកអកុសល ។ បទថា **សមុគ្ឃាតតោ បហានំ ឥច្ឆិតព្វំ** សេចក្តីថា គប្បីសង្ឃឹមនូវការលះដោយការកម្ចាត់ គឺការដកឡើងជាសមុច្ឆេទដោយប្រពៃ ។

បទថា **តេធាតុកេសុ កុសលេសុ ធម្មេសុ** សេចក្តីថា ធម៌ដែលកើតអំពីការឈ្លាស ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ពោល គឺកាមភូមិ រូបភូមិនិងអរូបភូមិ ។ បទថា **អតម្មយតា** បានដល់ ប្រាសចាកតណ្ហា ។

[ ២០ ] កាលព្រះមានព្រះភាគត្រាស់យ៉ាងនេះហើយ មាគណ្ឌិយព្រាហ្មណ៍មិនបានកំណត់អត្ថរបស់ព្រះតម្រាស់ ទើបពោលគាថាថា **នោ ចេ កិរ** ជា

ដើម ។ ពាក្យថា ការឃើញ ( ទិដ្ឋិយា ) ជាដើមមានន័យដូចពោលហើយនោះឯង ។ មាគន្ទិយព្រាហ្មណ៍ពោលពាក្យនេះទុកក្នុងទីទាំងពីរ សំដៅយកធម៌ចំណែកខ្មៅនោះឯង ។ ម្យ៉ាងទៀត គប្បីប្រកប **អាហា** សព្ទ និង **ឆោ ចេ ក៌រ** សព្ទ ហើយឃើញអត្ថយ៉ាងនេះថា បានឮថា បើបណ្ឌិតមិនពោល គឺបានឮថា បើបណ្ឌិតមិនពោល ដូច្នេះ ។

បទថា **មោមុហំ** បានដល់ ការវង្វេងក្រៃលែង ឬការវង្វេង ។ បទថា **បច្ចេន្តិ** សេចក្តីថា រមែងដឹង ។ និទ្ទេសនៃគាថានេះងាយយល់ហើយ ។

[ ២៦ ] លំដាប់នោះ ព្រះមានព្រះភាគកាលទ្រង់បដិសេធពាក្យសួរអាស្រ័យទិដ្ឋិនោះ របស់ព្រាហ្មណ៍នោះ ទើបត្រាស់គាថាថា **ទិដ្ឋីសុ និស្សាយ** ជាដើម គាថានោះមានអត្ថថា ម្នាលមាគណ្ឌិយៈ អ្នកអាស្រ័យទិដ្ឋិសួររឿយៗទិដ្ឋិទាំងឡាយណាដែលអ្នកជកឡើងហើយ អ្នកមកកាន់ភាពវង្វេងក្នុងទិដ្ឋិដែលអ្នកជកឡើងទាំងនោះឯង អ្នកមិនឃើញសញ្ញាដែលគួរ សូម្បីបន្តិចបន្តួចអំពីធម៌នេះ គឺអំពីការស្ងប់ខាងក្នុងដែលតថាគតពោលហើយ ឬអំពីការបដិបត្តិ ឬអំពីធម្មទេសនា ព្រោះហេតុនោះ ទើបអ្នកឃើញធម៌នេះអំពីការវង្វេង ។

[ ២៧ ] បទថា **លគ្គនំ និស្សាយ លគ្គនំ** សេចក្តីថា ជាប់ស្អិត គឺជាប់ស្អិតដោយទិដ្ឋិ សួរទាក់ទងដោយទិដ្ឋិ ។ បទថា **ពន្ធនំ** បានដល់ ការចងដោយទិដ្ឋិ ។ បទថា **បលិពោធំ** បានដល់ សេចក្តីកង្វល់ក្នុងទិដ្ឋិ ។

[ ២៨ ] បទថា **អន្ធការំ បក្ខន្ទោសិ** សេចក្តីថា លោកជាអ្នកចូលទៅកាន់ការងងឹត ។

[ ២៩ ] បទថា **យុត្តសញ្ញំ** សេចក្ដីថា សញ្ញាដែលគួរក្នុងសមណធម៌ ។ បទថា **បត្តសញ្ញំ** សេចក្ដីថា សញ្ញាដែលបានចំពោះហើយក្នុងសមណធម៌ ។ បទថា **លក្ខណាសញ្ញំ** សេចក្ដីថា សញ្ញាដែលឲ្យដឹង ។ បទថា **ការណាសញ្ញំ** សេចក្ដីថា សញ្ញាក្នុងហេតុ ។ បទថា **ឋានសញ្ញំ** សេចក្ដីថា សញ្ញាក្នុងការណ៍ ។ បទថា **ន បដិលភសិ** សេចក្ដីថា រមែងមិនជួប ។ បទថា **កុតោ ញាណំ** សេចក្ដីថា អ្នកនឹងបានមគ្គញាណដោយហេតុណា ។ បទថា **អនិច្ចំ វា** សេចក្ដីថា បញ្ចក្ខន្ធ ឈ្មោះថា មិនទៀង ព្រោះអត្ថថា មានហើយ ប្រែជាមិនមាន ។

បទថា **អនិច្ចសញ្ញានុលោមំ វា** សេចក្ដីថា សញ្ញាដែលកើតឡើងថា បញ្ចក្ខន្ធទាំងឡាយមិនទៀង ឈ្មោះថា អនិច្ចសញ្ញា ញាណដែលអនុលោម គឺមិនផ្ទុយគ្នាដល់សញ្ញានោះ ឈ្មោះថា ញាណដែលអនុលោមដល់អនិច្ចសញ្ញា ញាណនោះ គឺអ្វី គឺវិបស្សនាញាណ ។ សូម្បីញាណដែលអនុលោមដល់ទុក្ខសញ្ញានិងអនត្តសញ្ញា ក៏ន័យនេះដូចគ្នា ។

[ ៣១ ] កាលទ្រង់សម្ដែងដល់វិវាទដោយការវង្វេងក្នុងទិដ្ឋិ ដែលប្រកាន់ដល់មាគណ្ឌិយព្រាហ្មណ៍យ៉ាងនេះហើយឥឡូវនេះ ព្រះមានព្រះភាគកាលទ្រង់សម្ដែងភាពដែលព្រះអង្គប្រាសចាកការវង្វេងក្នុងធម៌ទាំងនោះ និងធម៌ដទៃជាអ្នកមិនមានវិវាទ ទើបត្រាស់គាថាថា **សមោ វិសេសី** ជាដើម គាថានោះមាន សេចក្ដីថា បុគ្គលណាតែងសម្គាល់ដោយការប្រកាន់ខ្លួនក្ដី ដោយទិដ្ឋិក្ដី ដោយបុគ្គលក្ដី ដោយចំណែក ៣ យ៉ាងនោះ បុគ្គលនោះគប្បីវិវាទដោយការ

ប្រកាន់ខ្លួនដោយទិដ្ឋិនោះ ឬដោយបុគ្គលនោះ តែបុគ្គលណាដូចតថាគត មិនញាប់ញ័រក្នុងការប្រកាន់ខ្លួន ៣ យ៉ាង ការសម្គាល់ថា អញស្មើគេ អញប្រសើរជាងគេ រមែងមិនមានដល់បុគ្គលនោះ ។ បាឋៈដ៏សេសថា **ន ច ហីនោ** ( អញអន់ជាងគេរមែងមិនមាន ) ។ និទ្ទេសនៃគាថានេះ មានអត្ថងាយយល់ដូចគ្នា ។

[ ៣៨ ] ទីងសម្តែងឲ្យក្រៃលែងឡើងទៀតថា គាថាថា **សច្ចន្តិ សោ** ជាដើមនោះ មានសេចក្តីថា បុគ្គលជាព្រាហ្មណ៍ដោយន័យមានភាពជាអ្នកបន្សាត់បាបហើយជាដើមនោះ គឺបែបនោះ បានដល់ លះនូវមានះនិងទិដ្ឋិបានហើយដូចតថាគត គប្បីពោលវត្ថុណា គឺគប្បីពោលរឿងអ្វី ឬគប្បីពោលដោយហេតុអ្វីថា វត្ថុនេះប៉ុណ្ណោះពិត ឬគប្បីទាស់ទែងដោយមានះ ដោយទិដ្ឋិ ឬដោយបុគ្គលណាមួយថា របស់អញពិត របស់អ្នកមិនពិត ការសម្គាល់ថា ស្មើគេដោយប្រព្រឹត្តទៅថា អញស្មើគេ ឬក៏សម្គាល់ថា មិនស្មើគេ ប្រព្រឹត្តទៅដោយភាព ២ យ៉ាង គឺល្អជាងគេនិងអន់ជាងគេ ក្រៅអំពីនេះ មិនមានក្នុងព្រះខីណាស្រពណា គឺដូចតថាគតខីណាស្រពនោះ គប្បីឆ្លើយដោយវាទៈ ដោយហេតុមានភាពជាអ្នកប្រកាន់ខ្លួនថា ស្មើគេជាដើម ។ និទ្ទេសនៃគាថានេះមានអត្ថងាយយល់ហើយ ។

[ ៣៩ ] បុគ្គលបែបនេះ គប្បីជ្រាបយ៉ាងច្បាស់នោះឯងមិនមែនឬ គាថាថា **ឱកម្បហាយ** ជាដើម គប្បីជ្រាបដូចតទៅនេះថា

បណ្តាបទទាំងនោះ បទថា **ឱកម្បហាយ** សេចក្តីថា រូបធាតុជាដើម

*ដែលជាលំនៅនៃវិញ្ញាណ លះដោយការលះនូវឆន្ទរាគៈ ក្នុងរូបធាតុជាដើម នោះ ។ បទថា* **អនិកេតសារី** *សេចក្តីថា មិនត្រាច់ទៅកាន់ទីអាស្រ័យ គឺរូបនិមិត្តជាដើម ដោយអំណាចនៃតណ្ហា ។ បទថា* **កាមេ អក្កុព្វំ មុនិ សន្ថវានិ** *សេចក្តីថា មិនធ្វើនូវការជិតស្និទ្ធក្នុងកាមដូចគ្រហស្ថ ។ បទថា* **កាមេហិ រិត្តោ** *សេចក្តីថា ជាអ្នកវៀរចាកកាមទាំងពួង ព្រោះមិនមានឆន្ទរាគៈក្នុងកាមទាំងឡាយ ។ បទថា* **អបុរេក្ខរានោ** *សេចក្តីថា មិនញុំាងអត្តភាពឲ្យកើតក្រៃលែងតទៅ ។ បទថា* **កថំ ន វិគ្គយ្ហ ជនេន កយិរា** *សេចក្តីថា មិនគប្បីពោលពាក្យជំទាស់ជាមួយពួកជន ។*

*[ ៤០ ] បទថា* **ហាលិទ្ទកានិ** *សេចក្តីថា គហបតីដែលមានឈ្មោះយ៉ាងនេះ ។*

*បទថា* **យេន** *ក្នុងប្រយោគថា* **យេនាយស្មា មហាកច្ចានោ តេនុបសង្កមិ** *ជាតតិយាវិភត្តិ ចុះក្នុងអត្ថនៃសត្តមីវិភត្តិ ព្រោះហេតុនោះ គប្បីឃើញអត្ថក្នុងទីនេះយ៉ាងនេះថា ព្រះមហាកច្ចានៈនៅក្នុងទីណា គហបតីចូលទៅរកក្នុងទីនោះ ។*

*ម្យ៉ាងទៀត គប្បីឃើញអត្ថក្នុងទីនេះ យ៉ាងនេះថា ទេវតានិងមនុស្សទាំងឡាយចូលទៅរកព្រះមហាកច្ចានៈ ដោយហេតុណា គហបតីក៏ចូលទៅរកដោយហេតុនោះ ។ ម្យ៉ាងទៀត គហបតីចូលទៅរកព្រះមហាកច្ចានៈដោយហេតុណា ដោយបំណងក្នុងការសម្រេចគុណវិសេស មានប្រការផ្សេងៗ ដូចដើមឈើធំដែលចេញផ្កាផ្លែជានិច្ច ដែលហ្វូងបក្សីទាំងឡាយចូលទៅរកដោយ*

បំណាំងស៊ីផ្លែដែលល្អ ។

បទថា **ឧបសង្កមិ** អធិប្បាយថា ចូលទៅជិត ។ បទថា **ឧបសង្កមិត្វា** ជាបទសម្តែងទីបំផុតនៃការចូលទៅរកម្យ៉ាងទៀត លោកអធិប្បាយថា ទៅយ៉ាងនោះ បន្ទាប់អំពីនោះ ទៅកាន់ទីជិតក្រៃលែង ពោលគឺទីជិតព្រះមហាកច្ចានៈ ។

បទថា **អភិវាទេត្វា** សេចក្តីថា ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ឥឡូវនេះ គហបតីបំណាំងនឹងសួរដល់បំណាំងដែលជាហេតុឲ្យខ្លួនមកកាន់ទីបម្រើព្រះមហាកច្ចានៈ ទើបអង្គុយផ្គងអញ្ជលីដ៏រុងរឿងដោយប្រជុំនៃម្រាម ១០ លើសិរសា ក្នុងទីសមគួរនាចំណែកម្ខាង ។

បទថា **ឯកមន្តំ** ជាការសម្តែងដោយភាវៈនបុំសកលិង្គ ដូចក្នុងប្រយោគថា **វិសមំ ចន្ទិមសុរិយា បរិវត្តំ** ព្រះចន្ទនិងព្រះអាទិត្យ ក៏គោចរទៅមិនស្មើដែរ ដូច្នេះជាដើម ព្រោះហេតុនោះ គប្បីឃើញអត្ថក្នុងទីនេះ យ៉ាងនេះថា បុគ្គលជាអ្នកអង្គុយក្នុងចំណែកម្ខាង អង្គុយយ៉ាងណា ក៏អង្គុយយ៉ាងនោះ ម្យ៉ាងទៀត បទថា **ឯកមន្តំ** នេះ ជាទុតិយាវិភត្តិ ចុះក្នុងអត្ថនៃសត្តមីវិភត្តិ ។

បទថា **និសីទិ** សេចក្តីថា សម្រេចនូវការអង្គុយ ពិតហើយ ទេវតានិងមនុស្សទាំងឡាយ ដែលជាបណ្ឌិតចូលទៅរកបុគ្គលដែលជាទីតាំងនៃការគោរព រមែងអង្គុយក្នុងទីសមគួរនាចំណែកម្ខាង ព្រោះភាពជាអ្នកឈ្លាសក្នុងការអង្គុយ គហបតីនេះ ក៏ជាអ្នកឈ្លាសម្នាក់ បណ្តាបណ្ឌិតទាំងនោះ ព្រោះហេតុនោះ ទើបអង្គុយក្នុងទីសមគួរនាចំណែកម្ខាង អង្គុយដូចម្តេច ឈ្មោះថា អង្គុយក្នុងទីសមគួរនាចំណែកម្ខាង ដែលវៀរទោសនៃការអង្គុយ ៦ យ៉ាង គឺអង្គុយ

ឆ្ងាយពេក ១ ជិតពេក ១ លើខ្យល់ ១ ទីខ្ពស់ ១ចំពីមុខពេក ១ ពីក្រោយពេក ១ ។ អង្គុយឆ្ងាយពេក បើត្រូវការសួរ នឹងត្រូវសួរដោយសំឡេងខ្លាំង អង្គុយជិតពេក នឹងធ្វើនូវការជ្រៀតជ្រៀត អង្គុយលើខ្យល់ នឹងបៀតបៀនដោយក្លិនខ្លួន អង្គុយទីខ្ពស់ ប្រកាសនូវការមិនគោរព អង្គុយចំពីមុខពេក បើត្រូវការមើល នឹងត្រូវប៉ះភ្នែកគ្នា អង្គុយក្រោយពេក បើត្រូវការមើល ក៏នឹងត្រូវងាកក ព្រោះហេតុនោះ ទើបគហបតីនេះអង្គុយវៀរទោសនៃការអង្គុយ ៦ យ៉ាងនោះ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគពោលថា **ឯកមន្តំ និសីទិ** អង្គុយក្នុងទីសមគួរនាចំណែកម្ខាង ។

បទថា **ឯតទវោច** សេចក្តីថា បានពោលពាក្យនេះថា **វុត្តមិទំ ភន្តេ កច្ចាន ភគវតា អដ្ឋកវគ្គិយេ មាគណ្ឌិយប្បញ្ហេ** ដូច្នេះ ។ ឈ្មោះថា មាគណ្ឌិយប្បញ្ហា មានក្នុងអដ្ឋកវគ្គ ក្នុងបញ្ហានោះ ។

បទថា **រូបធាតុ** បំណងយករូបក្ខន្ធ ។ បទថា **រូបធាតុរាគវិនិពន្ធំ** សេចក្តីថា ចងទុកក្នុងរូបធាតុដោយរាគៈ ។ បទថា **វិញ្ញាណំ** បានដល់ កម្មវិញ្ញាណ ។

បទថា **ឱកសារី** សេចក្តីថា ត្រាច់ទៅកាន់លំនៅមានផ្ទះជាដើម ។ សួរថា ហេតុអ្វី ទើបព្រះមហាកច្ចានៈមិនពោលក្នុងទីនេះថា **វិញ្ញាណធាតុ ខោ គហបតិ** ឆ្លើយថា ដើម្បីកម្ចាត់នូវការវង្វេង ។ បទថា **ឱកោ** ដោយអត្ថលោកពោលដល់បច្ច័យ ។ កម្មវិញ្ញាណដែលកើតមុន រមែងជាបច្ច័យដល់កម្មវិញ្ញាណផង ដល់វិបាកវិញ្ញាណផង ដែលកើតឯក្រោយ ហើយវិបាកវិញ្ញាណ

ដែលកើតមុន រមែងជាបច្ច័យទាំងដល់វិបាកវិញ្ញាណ ទាំងដល់កម្មវិញ្ញាណដែលកើតឯក្រោយ ហេតុនោះ គប្បីមានសេចក្ដីវង្វេងថា វិញ្ញាណក្នុងទីនេះ វិញ្ញាណដូចណាហ្ន៎ ដើម្បីកម្ចាត់នូវការវង្វេងនោះ ទើបព្រះមហាកច្ចានៈមិនកាន់យកវិញ្ញាណនោះ ហើយធ្វើនូវការសម្ដែងមិនឲ្យលាយឡំគ្នា ។ ម្យ៉ាងទៀត លោកពោលអភិសង្ខារនិងវិញ្ញាណដ្ឋិតិ ៤ ដោយអំណាចជាអារម្មណ៍របស់វិបាក ទើបមិនកាន់យកវិញ្ញាណក្នុងទីនេះ ដើម្បីសម្ដែងអភិសង្ខារនិងវិញ្ញាណដ្ឋិតិទាំងនោះផង ។

បទថា **ឧបាយុបាទានា** សេចក្ដីថា ឧបាយ ២ ដោយអំណាចនៃតណ្ហាឧបាយនិងទិដ្ឋិឧបាយ ឧបាទាន ៤ មានកាមុបាទានជាដើម ។ បទថា **ចេតសោ អធិដ្ឋានាភិនិវេសានុសយា** សេចក្ដីថា ជាហេតុប្រកាន់មាំ ជាហេតុកាន់យកមាំ និងជាហេតុដេកត្រាំនៃអកុសលចិត្ត ។ បទថា **តថាគតស្ស** បានដល់ ព្រះសម្មាសម្ពុទ្ធ ពិតហើយ ការពេញចិត្តជាដើមនោះ ដែលព្រះខីណាស្រពទាំងឡាយទាំងពួងលះបានហើយដូចគ្នា តែភាពជាព្រះខីណាស្រពរបស់ព្រះសាស្ដាប្រាកដច្បាស់ក្នុងលោក ហេតុនោះ ទើបលោកពោលពាក្យថា **តថាគតស្ស** នេះ ដោយជាចំណុចចុងក្រោយ ។

សួរថា ព្រោះហេតុអ្វី ទើបលោកកាន់យកវិញ្ញាណក្នុងបទថា **វិញ្ញាណធាតុយា** នេះ ឆ្លើយថា ដើម្បីសម្ដែងនូវការលះកិលេស ព្រោះក្នុងខន្ធ ៤ មិនទាន់លះកិលេសបានអស់នោះឯង រមែងលះក្នុងខន្ធ ៥ នោះឯង ហេតុនោះ ទើបលោកកាន់យកដើម្បីសម្ដែងនូវការលះកិលេស ។

*បទថា* **ឯវំ ខោ គហបតិ អនោកសារី ហោតិ** *សេចក្ដីថា បុគ្គលមិនត្រាច់ទៅកាន់លំនៅដោយកម្មវិញ្ញាណ ទើបឈ្មោះថា ជាអ្នកមិនត្រាច់ទៅកាន់លំនៅដោយប្រការដូច្នេះ ។*

*បទថា* **រូបនិមិត្តនិកេតសារវិនិពន្ធា** *សេចក្ដីថា រូបនោះឯង ឈ្មោះថា និមិត្ត ដោយអត្ថថា ជាបច្ច័យនៃកិលេសទាំងឡាយ ឈ្មោះថា* **និកេត** *ដោយអត្ថថា ជាលំនៅ ពោលគឺជាការធ្វើនៃអារម្មណ៍ ព្រោះហេតុនោះ ទើបឈ្មោះថា* **រូបនិមិត្តនិកេត** *។ ការត្រាច់ទៅ (* **សារ** *) ផង ការជាប់ចំពាក់ (* **វិនិពន្ធ** *) ផង ឈ្មោះថា* **សារវិនិពន្ធា** *លោកពោលកាលដែលកិលេសទាំងឡាយផ្សាយទៅ និងការជាប់ចំពាក់របស់កិលេសទាំងឡាយដោយបទទាំងពីរ ។ ការត្រាច់ទៅនិងការជាប់ចំពាក់មាននៅក្នុងទីអាស្រ័យរូបនិមិត្ត ឈ្មោះថា* **រូបនិមិត្តនិកេតសារវិនិពន្ធា** *។ ព្រោះហេតុនោះ ទើបជាការត្រាច់ទៅនិងការជាប់ចំពាក់ក្នុងទីអាស្រ័យគឺរូបនិមិត្ត អធិប្បាយថា ដោយការត្រាច់ទៅរបស់កិលេស និងដោយការជាប់ចំពាក់របស់កិលេសដែលកើតឡើងក្នុងទីអាស្រ័យគឺរូបនិមិត្ត ។*

*បទថា* **និកេតសារីតិ វុច្ចតិ** *សេចក្ដីថា ហៅថា ការត្រាច់ទៅរកទីអាស្រ័យដោយអត្ថថា ជាទីនៅអាស្រ័យដោយអំណាចនៃការធ្វើឲ្យជាអារម្មណ៍ ។*

*បទថា* **បហីនា** *សេចក្ដីថា ការត្រាច់ទៅនិងការជាប់ចំពាក់របស់កិលេសក្នុងទីអាស្រ័យ គឺរូបនិមិត្តទាំងនោះ ដែលព្រះតថាគតលះបានហើយ ។*

*ហេតុអ្វី ក្នុងទីនេះ ទើបលោកហៅបញ្ចក្ខន្ធថា* **ឱកោ** *ហៅអារម្មណ៍ ៦*

ថា **និកេត** ។ ឆ្លើយថា ព្រោះឆន្ទរាគៈមានកម្លាំងច្រើននិងមានកម្លាំងតិច ។ ទោះបីមានភាពពិសេស ដោយអត្ថថា ជាលំនៅ ( ឱក ) របស់បញ្ចក្ខន្ធទាំងនោះក្តី តែលោកក៏ហៅផ្ទះពិតៗ ដោយត្រង់ថា ទីលំនៅ ។ បទថា **និកេតំ** បានដល់ ឧទ្យានដែលជាទីនៅអាស្រ័យ ( **និកេត** ) ជាដើម របស់បុគ្គលដែលសន្យាទុកថា ថ្ងៃនេះពួកយើងនឹងដើរលេងក្នុងទីនោះ ក្នុងសេចក្តីនោះ ឆន្ទរាគៈក្នុងផ្ទះដែលប្រកបដោយបុត្ត ភរិយានិងស្រូវ រមែងមានកម្លាំងយ៉ាងណា ក្នុងខន្ធទាំងឡាយដែលប្រព្រឹត្តទៅក្នុងខាងក្នុង ក៏យ៉ាងនោះ តែឆន្ទរាគៈត្រង់ឧទ្យានជាដើម មានកម្លាំងតិចជាងឆន្ទរាគៈក្នុងផ្ទះនោះ យ៉ាងណា ក្នុងអារម្មណ៍ ៦ ខាងក្រៅ ក៏យ៉ាងនោះ ព្រោះហេតុនោះ គប្បីជ្រាបថា លោកសម្តែងទេសនាយ៉ាងនេះ ព្រោះឆន្ទរាគៈ មានកម្លាំងច្រើននិងមានកម្លាំងតិច ។

បទថា **សុខិតេសុ សុខិតោ** សេចក្តីថា កាលពួកឧបដ្ឋាកមានសេចក្តីសុខ ដោយអំណាចការបានទ្រព្យនិងស្រូវជាដើម រមែងជាអ្នកមានសេចក្តីសុខ ដោយសេចក្តីសុខអាស្រ័យផ្ទះថា ឥឡូវនេះ អាត្មាអញនឹងបានចីវរដែលគាប់ចិត្ត ភោជនដែលគាប់ចិត្ត សោយសម្បត្តិដែលមានហើយដល់ឧបដ្ឋាកទាំងនោះដោយខ្លួនឯង ។

បទថា **ទុក្ខិតេសុ ទុក្ខិតោ** សេចក្តីថា កាលសេចក្តីទុក្ខកើតឡើងដល់ឧបដ្ឋាកទាំងនោះ ដោយហេតុណាមួយ ខ្លួនឯងរមែងមានសេចក្តីទុក្ខទ្វេដង ។

បទថា **កិច្ចករណីយេសុ** បានដល់ កាលករណី ពោលគឺកិច្ចការ ។ បទថា **វោយោគំ អាបជ្ជតិ** សេចក្តីថា ខ្លួនឯងរមែងដល់នូវការបំពេញ

*ប្រយោជន៍ គឺភាពដែលកិច្ចទាំងនោះដែលខ្លួនឯងគប្បីធ្វើ ។ បទថា* **កាមេសុ** *បានដល់ វត្ថុកាម ។ បទថា* **ឯវំ ខោ គហបតិ កាមេហិ អរិត្តោ ហោតិ** *សេចក្តីថា ជាអ្នកមិនទទេចាកកិលេសកាមទាំងឡាយ គឺមិនទទេ ព្រោះមានកិលេសខាងក្នុងយ៉ាងនេះ ។ ក្នុងចំណែកស គប្បីជ្រាបថា ជាបុគ្គលទទេ គឺទំនេរ ព្រោះមិនមានកិលេសទាំងនោះ ។*

*បទថា* **បុរេក្ខរានោ** *សេចក្តីថា ធ្វើនូវវដ្តៈទុកខាងមុខ ។ បទថា* **ឯវំរូបោ សិយំ** *ជាដើម សេចក្តីថា រមែងប្រាថ្នាក្នុងរូបទាំងឡាយ មានរូបខ្ពស់ ទាប ខ្មៅ សជាដើមថា សូមអញមានរូបយ៉ាងនេះ រមែងប្រាថ្នាក្នុងវេទនាទាំងឡាយ មានសុខវេទនាជាដើមថា សូមអញមានវេទនាយ៉ាងនេះ រមែងប្រាថ្នាក្នុងសញ្ញាទាំងឡាយ មាននីលសញ្ញាជាដើមថា សូមអញមានសញ្ញាយ៉ាងនេះ រមែងប្រាថ្នាក្នុងសង្ខារទាំងឡាយ មានបុញ្ញាភិសង្ខារជាដើមថា សូមអញមានសង្ខារយ៉ាងនេះ រមែងប្រាថ្នាក្នុងវិញ្ញាណទាំងឡាយ មានចក្ខុវិញ្ញាណជាដើមថា សូមអញមានវិញ្ញាណយ៉ាងនេះ ។*

*បទថា* **អបុរេក្ខរានោ** *សេចក្តីថា មិនធ្វើនូវវដ្តៈទុកខាងមុខ ។ បទថា* **សហិតម្មេ អសហិតន្តេ**[១] *សេចក្តីថា ពាក្យរបស់អ្នកមិនមានប្រយោជន៍ មិនពីរោះ ពាក្យរបស់ខ្ញុំមានប្រយោជន៍ពីរោះ ផ្អែមដូចទឹកឃ្មុំ ។*

*បទថា* **អធិចិណ្ណន្តេ វិបរាវត្តំ** *សេចក្តីថា ពាក្យណាដែលអ្នកសន្សំទុកនានអស់កាលយូរ ស្ទាត់ល្អ ពាក្យទាំងអស់នោះ ប្រែប្រួលទៅមួយជួរខណៈ*

---

*១-បទនេះមានក្នុងលេខឃ្នាប ៣០៩ ឯបទ ៤ បន្ទាប់ក៏ដូចគ្នា ។*

ព្រោះអាស្រ័យវាទៈរបស់ខ្ញុំ ។ បទថា **អារោបិតោ តេ វាទោ** សេចក្ដីថា ខ្ញុំលើកទោសរបស់អ្នកឡើងហើយ ។ បទថា **ចរ វាទប្បមោក្ខាយ** សេចក្ដីថា អ្នកចូរទៅរកអាចារ្យនោះៗ ស្វែងរកចំណុចល្អៗ ធ្វើដំណើរត្រាច់ទៅដើម្បីដោះវាទៈនេះ ។ បទថា **និព្វេធេហិ វា សចេ បហោសិ** សេចក្ដីថា បើអ្នកអាចឯង ក៏ចូរដោះស្រាយក្នុងទីនេះចុះ ។

[ ៤១ ] គាថាថា **យេហិ វិវិត្តោ** ជាដើម គប្បីជ្រាបដូចតទៅនេះថា បណ្ដាបទទាំងនោះ បទថា **យេហិ** សេចក្ដីថា ចាកធម៌ពួកណាមានទិដ្ឋិជាដើម ។ បទថា **វិវិត្តោ វិចរេយ្យ** សេចក្ដីថា ស្ងាត់ហើយគប្បីត្រាច់ទៅ ។ បទថា **ន តានិ ឧគ្គយ្ហ វទេយ្យ នាគោ** សេចក្ដីថា បុគ្គលឈ្មោះថា នាគ មិនគប្បីប្រកាន់នូវទិដ្ឋិទាំងនោះ ពោលដោយន័យថា មិនធ្វើនូវសេចក្ដីអាក្រក់ជាដើម ។ បទថា **ឯលម្ពុជំ** សេចក្ដីថា កើតក្នុងទឹក ពោលគឺឯឡូៈ ។ បទថា **កណ្ដកវារិជំ** សេចក្ដីថា ផ្កាឈូកមានទងជាបន្លា អធិប្បាយថា បទុម ។ បទថា **យថា ជលេន បង្កេន ច នូបលិត្តំ** សេចក្ដីថា ផ្កាឈូកនោះ ដែលទឹកនិងភក់មិនចូលទៅជាប់ យ៉ាងណា ។ បទថា **ឯវំ មុនិ សន្តិវាទោ អគិទ្ធោ** សេចក្ដីថា មុនីដែលពោលនូវការស្ងប់ខាងក្នុង មិនជាប់ជំពាក់ ព្រោះមិនមានការជាប់ជំពាក់ ។ បទថា **កាមេ ច លោកេ ច អនូបលិត្តោ** សេចក្ដីថា ជាបុគ្គលមិនចូលទៅជាប់ក្នុងកាម ២ យ៉ាង និងក្នុងលោក មានអបាយជាដើម ដោយកិលេសទាំង ២ ។

[ ៤៣ ] បទថា **អាគុំ ន ករោតិ** សេចក្ដីថា មិនធ្វើទោស មាន

អកុសលជាដើម ។ បទថា **ន គច្ឆតិ** សេចក្ដីថា រមែងមិនធ្វើទៅដោយអំណាចអគតិ ។ បទថា **នាគច្ឆតិ** សេចក្ដីថា មិនចូលដល់កិលេសដែលលះហើយ ។ បទថា **ចាបកា** បានដល់ ថោកទាប ។ បទថា **អកុសលា** សេចក្ដីថា ដែលកើតអំពីការមិនឈ្លាស ។ បទថា **តេ កិលេសេ ន បុនេតិ** សេចក្ដីថា កិលេសពួកណាដែលបុគ្គនោះលះបានហើយ បុគ្គលនោះរមែងមិនមកកាន់កិលេសទាំងនោះទៀត ។ បទថា **ន បច្ចេតិ** សេចក្ដីថា មិនត្រឡប់ចូលដល់ ។ បទថា **ន បច្ចាគច្ឆតិ** បានដល់ មិនត្រឡប់មកទៀត ។

[ ៤៤ ] បទថា **ខរទណ្ឌា** សេចក្ដីថា ទងរបស់ស្លឹកគ្រោតគ្រោត គឺទងគ្រោតគ្រោត ។

[ ៤៥ ] បទថា **ចត្តគន្ថោ** សេចក្ដីថា លះនូវការជាប់ជំពាក់ ។ បទថា **វន្តគន្ថោ** សេចក្ដីថា ខ្ជាក់នូវការជាប់ជំពាក់ ។ បទថា **មុត្តគន្ថោ** សេចក្ដីថា កាត់នូវការជាប់ជំពាក់ដែលជាគ្រឿងចង ។ បទថា **បហីនគន្ថោ** សេចក្ដីថា លះនូវការជាប់ជំពាក់ ។ បទថា **បដិនិស្សដ្ឋគន្ថោ** សេចក្ដីថា លះបង់នូវការជាប់ជំពាក់ដោយមិនឲ្យដុះឡើងកាន់ចិត្តទៀត ។ សូម្បីក្នុងបទថា **វីតរាគា** ជាដើម ក៏មានន័យដូចគ្នា បទទាំងអស់នោះឯង ជាវេចនៈនៃភាវៈដែលលះបង់នូវការប្រកាន់ដែលប្រកាន់ទុក ។

[ ៤៦ ] នៅមានពាក្យអធិប្បាយបន្តិចបន្តួចទៀត បទថា **ន វេទគូ** ជាដើម គប្បីជ្រាបដូចតទៅនេះថា បណ្ដាបទទាំងនោះ បទថា **ន វេទគូ ទិដ្ឋិយា** សេចក្ដីថា មុនីដែលដល់នូវវេទ គឺមគ្គ ៤ ដូចតថាគត រមែងជាអ្នកមិនទៅ

ដោយទិដ្ឋិ គឺរមែងមិនទៅដោយទិដ្ឋិ ឬមិនធ្លាក់មកកាន់ទិដ្ឋិនោះ ដោយសារៈ ។ ក្នុងពាក្យទាំងនោះ មានអត្ថនៃពាក្យដូចតទៅនេះថា

ឈ្មោះថា **ទិដ្ឋិយាយក** ព្រោះអត្ថថា ដោយទិដ្ឋិ ជាតតិយាវិភត្តិ ។ ឈ្មោះថា **ទិដ្ឋិយាយក** ព្រោះអត្ថថា ទៅកាន់ទិដ្ឋិ ជាទុតិយាវិភត្តិ ។ សូម្បីជាឆដ្ឋីវិភត្តិជា **ទិដ្ឋិយា** ព្រោះអត្ថថា ការទៅរបស់ទិដ្ឋិក៏មាន ។ បទថា **ន មុតិយា ស មានមេតិ** សេចក្តីថា មុនីនោះ រមែងមិនមកកាន់នូវការប្រកាន់ខ្លួន ដោយអារម្មណ៍ដែលជ្រាប មានប្រភេទនៃរូបដែលជ្រាបជាដើម ។ បទថា **ន ហិ តម្មយោ សោ** សេចក្តីថា ជាអ្នកមិនមានតណ្ហានិងទិដ្ឋិ គឺជាអ្នកមិនមានតណ្ហានិងទិដ្ឋិនោះជាទីទៅខាងមុខ ដោយអំណាចនៃតណ្ហានិងទិដ្ឋិ តែបុគ្គលនេះ មិនដូច្នោះឡើយ ។ បទថា **ន កម្មុនា នោបិ សុតេន នេយ្យោ** សេចក្តីថា មុនីនោះ រមែងជាអ្នកដែលកម្មមានបុញ្ញាភិសង្ខារជាដើម ឬសំឡេងដែលបានឮ មានការបរិសុទ្ធដោយសំឡេងដែលបានឮជាដើមនាំទៅបាន ។ បទថា **អនូបនីតោ ស និវេសនេសុ** សេចក្តីថា មុនីនោះ ជាបុគ្គលដែលមិនត្រូវចូលទៅហើយក្នុងទីអាស្រ័យ គឺតណ្ហានិងទិដ្ឋិទាំងពួង ព្រោះលះនូវការនាំចូលទៅទាំង ២ បានហើយ ។

[ ៤៧ ] ក្និន រសេនិងផោដ្ឋព្វៈ ឈ្មោះថា រូបដែលជ្រាបហើយ ក្នុងបទថា **មុតរូបេន វា** នេះ ។ បទថា **មានំ នេតិ** សេចក្តីថា រមែងមិនដល់នូវអស្មិមានះ គឺការប្រកាន់ថាជាអញ ។ បទថា **ន ឧបេតិ** សេចក្តីថា រមែងមិនមកកាន់ទីជិត ។ បទថា **ន ឧបគច្ឆតិ** សេចក្តីថា រមែងមិនចូលទៅតាំង

*ទៅ ។ បទថា* **តម្មយោ** *បានដល់ ធ្វើនូវការក្អែត ។*

[ ៥០ ] *គាថាថា* **សញ្ញាវិរត្តស្ស** *ជាដើម គប្បីជ្រាបដូចតទៅនេះថា បណ្តាបទទាំងនោះ បទថា* **សញ្ញាវិរត្តស្ស** *សេចក្តីថា ដល់មុនីដែលលះនូវកាមសញ្ញាជាដើម ដោយភាវនាដែលមាននេក្ខម្មសញ្ញាជាសភាវៈដល់មុន ។ ដោយបទនេះ លោកបំណងយកបុគ្គលដែលមានសមថៈយានិក ហើយជាឧភតោភាគវិមុត្តិ ។ បទថា* **បញ្ញាវិមុត្តស្ស** *សេចក្តីថា ដល់មុនីដែលរួចផុតចាកកិលេសទាំងពួងដោយភាវនា ដែលមានវិបស្សនាជាសភាវៈដល់មុន ។ ដោយបទនេះ លោកបំណងយកបុគ្គលជាសុខវិបស្សកៈ ។ បទថា* **សញ្ញញ្ច ទិដ្ឋិញ្ច យេ អគ្គហេសុំ តេ ឃដ្ដមានា វិចរន្តិ លោកេ** *សេចក្តីថា ជនពួកណាប្រកាន់សញ្ញា មានកាមសញ្ញាជាដើម ជនទាំងនោះដោយចំពោះពួកគ្រហស្ថនៅប្រកាន់ទិដ្ឋិ មានកាមជាហេតុ ( មូលវិវាទ ) ប៉ុណ្ណោះ ជនទាំងនោះដោយចំពោះពួកបព្វជិត រមែងពោលប៉ះទង្គិចគឺវិវាទដល់គ្នានឹងគ្នា មានធម៌ជាដើមហេតុ ។*

[ ៥១ ] *បទថា* **យោ សមថបុព្វង្គមំ អរិយមគ្គំ ភាវេតិ** *សេចក្តីថា បុគ្គលណា ធ្វើសមថៈឲ្យជាសភាវៈដល់មុន គឺឲ្យប្រព្រឹត្តទៅខាងមុខ ចម្រើនអរិយមគ្គមួយអន្លើដោយវិបស្សនា អធិប្បាយថា ញុំាងសមាធិឲ្យកើតឡើងមុន ញុំាងអរិយមគ្គមួយអន្លើដោយវិបស្សនាឲ្យកើតឡើងខាងក្រោយ ។ បទថា* **តស្ស អាទិតោ** *សេចក្តីថា ដែលបុគ្គលនោះសង្កត់សង្កិនហើយអំពីបឋមជ្ឈានជាដើម ។ បទថា* **ឧគ្គហាយ** *សេចក្តីថា ពឹងហើយអាស្រ័យហើយ ។*

បទថា **គន្ថា វិក្ខម្ភិតា ហោន្តិ** សេចក្តីថា កិលេសជាគ្រឿងរួបរឹត រមែងជារបស់ដែលបុគ្គលនោះធ្វើឲ្យឆ្ងាយហើយ ។ បទថា **អរហត្តប្បត្តេ** សេចក្តីថា សម្រេចអរហត្តផលហើយ ។ បទថា **អរហតោ** សេចក្តីថា តាំងនៅក្នុងអរហត្តផល ។ កិលេសទាំងពួង មានគន្ថៈនិងមោហៈជាដើម រមែងជាសភាវៈដែលព្រះអរហន្តលះបង់ហើយ ។

[ ៥២ ] បទថា **យោ វិបស្សនាបុព្វង្គមំ អរិយមគ្គំ ភាវេតិ** សេចក្តីថា បុគ្គលណាធ្វើវិបស្សនាឲ្យជាសភាវៈដល់មុន គឺឲ្យប្រព្រឹត្តទៅខាងមុខ ចម្រើនអរិយមគ្គ អធិប្បាយថា ញុំាងវិបស្សនាឲ្យកើតឡើងមុន ចម្រើនសមាធិដែលសម្បយុត្តក្នុងអរិយមគ្គខាងក្រោយ ។ បទថា **តស្ស អាធិតោ ឧបាទាយ** សេចក្តីថា ដែលបុគ្គលនោះអាស្រ័យវិបស្សនា ចាប់តាំងអំពីឃើញច្បាស់ ។ បទថា **វិក្ខម្ភិតា** ក្នុងបទថា **មោហា វិក្ខម្ភិតា ហោន្តិ** នេះ សេចក្តីថា ឲ្យដល់ទីឆ្ងាយ ។

[ ៥៣ ] បទថា **សញ្ញាវសេន ឃដ្តេន្តិ** សេចក្តីថា ជនពួកណានៅប្រកាន់កាមសញ្ញាជាដើម ជនទាំងនោះរមែងបៀតបៀនគ្នាដោយអំណាចនៃសញ្ញា ។ បទថា **សង្ឃដ្តេន្តិ** សេចក្តីថា រមែងបៀតបៀនគ្នាជាងនោះ ។

ឥឡូវនេះ ដើម្បីសម្តែងពួកជនដែលបៀតបៀនគ្នា ទើបព្រះសារីបុត្តត្ថេរពោលសេចក្តីពិស្តារ ដោយន័យថា **រាជានោបិ រាជូហិ វិវទន្តិ** ជាដើម ។

ក្នុងបទថា **អញ្ញមញ្ញំ បាណីហិបិ ឧបក្កមន្តិ** នេះ សេចក្តីថា រមែងប្រទូស្តគ្នានឹងគ្នាដោយដៃទាំង ២ ។ បទថា **លេឌ្ឌូហិ** បានដល់ ដោយអំបែង

ដែលដុត ។ បទថា **ឧណ្ហាហិ** បានដល់ ដោយដំបងខ្វី ។ បទថា **សត្តេហិ** បានដល់ ដោយសស្ត្រាដែលមានមុខ ២ ។ បទថា **អភិសង្ខារានំ អប្ប-ហីនត្តា** សេចក្ដីថា ព្រោះភាពដែលមិនទាន់លះបុញ្ញាភិសង្ខារជាដើមបាន ។ បទថា **គតិយា យន្តេន្តិ** សេចក្ដីថា រមែងបៀតបៀនគ្នា គឺរមែងដល់នូវការប៉ះទង្គិចគ្នា ក្នុងគតិដែលជាទីតាំងនៅនិងដែលត្រូវទៅ ។ សូម្បីក្នុងបទថា **និរយ** ជាដើម ក៏ន័យនេះដូចគ្នា ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយយល់ហើយ ព្រោះមានន័យដូចពោលហើយនោះឯង ។៚

## អដ្ឋកថា មាគណ្ឌិយសុត្តនិទ្ទេសទី ៩
## សទ្ធម្មប្បជ្ជោតិកា អដ្ឋកថា មហានិទ្ទេស ចប់

# ក្បាលទី ៥៣

# សុត្តន្តបិដក ចាលីប្រែ -៦៤

## សន្ទឹកចង្អុលប្រាប់មាតិកា

មាតិកា ទំព័រ


កាមសុត្តនិទ្ទេសទី ១ .......... .......... ............ ....... ២

អារម្ភកថា ............ .......... ............ ...... ៣៦

អដ្ឋកថា កាមសុត្តនិទ្ទេស .......... .......... ........... ...... ៥៣

អត្ថរបស់ មានសៈ សព្ទ .......... .......... ........... ....... ៧៤

អត្ថរបស់ ហទយៈ សព្ទ .......... .......... ........... ....... ៧៥

អត្ថរបស់ អាយតនៈ សព្ទ .......... .......... ........... ........ ៧៦

អត្ថរបស់ ខន្ធ សព្ទ .......... .......... ........... ....... ៧៧

អត្ថរបស់ សហគតៈ សព្ទ .......... .......... .......... .......... ៧៩

អត្ថរបស់ សំសដ្ឋៈ សព្ទ .......... .......... ........... ........ ៨០

គុហដ្ឋកសុត្តនិទ្ទេសទី ២ .......... .......... .......... ........ ២០៩

អដ្ឋកថា គុហដ្ឋកសុត្តនិទ្ទេសទី ២ .......... .......... .......... ........ ២៦៨

តថាគត ៨ យ៉ាង .......... .......... .......... ........ ៤៣៤

ទុដ្ឋដ្ឋកសុត្តនិទ្ទេសទី ៣ .......... .......... .......... ......... ៤៥៨

អដ្ឋកថា ទុដ្ឋដ្ឋកសុត្តនិទ្ទេសទី ៣ .......... .......... .......... ......... ៤៩៣

សុទ្ធដ្ឋកសុត្តនិទ្ទេសទី ៤ .......... .......... .......... ......... ៥៤១

អដ្ឋកថា សុទ្ធដ្ឋកសុត្តនិទ្ទេសទី ៤ .......... .......... .......... ......... ៥៧០

បរមដ្ឋកសុត្តនិទ្ទេសទី ៥ .......... .......... .......... ....... ៦១៧

អដ្ឋកថា បរមដ្ឋកសុត្តនិទ្ទេសទី ៥ .......... .......... .......... ......... ៦៤០

ជរាសុត្តនិទ្ទេសទី ៦ ......... ......... .......... .......... ៦៥៤

អដ្ឋកថា ជរាសុត្តនិទ្ទេសទី ៦ .......... .......... ........... ......... ៦៨៨
តិស្សមេត្តេយ្យសុត្តនិទ្ទេសទី ៧ .......... .......... ........... ......... ៧១៤
អដ្ឋកថា តិស្សមេត្តេយ្យសុត្តនិទ្ទេសទី ៧ ......... ........... ........... ......... ៧៤៩
បសូរសុត្តនិទ្ទេសទី ៨ .......... .......... ........... ......... ៧៩១
អដ្ឋកថា បសូរសុត្តនិទ្ទេសទី ៨ .......... .......... .......... .......... ៨២២
អត្ថរបស់ មានស សព្ទ .......... ........... ............ ....... ៨៣៣
អត្ថរបស់ ហទយ សព្ទ .......... ........... ............ ........ ៨៣៤
អត្ថរបស់ បណ្ឌរ សព្ទ .......... ........... ............ ........ ៨៣៤
អត្ថរបស់ អាយតន សព្ទ .......... ........... ............ ........ ៨៣៥
អត្ថរបស់ ខន្ធ សព្ទ .......... ........... ............ ........ ៨៣៦

## សុត្តន្តបិដក បាលីប្រែ -៦៥

មាគន្ទិយសុត្តនិទ្ទេសទី ៩ .......... .......... ........... ......... ៨៦១
អដ្ឋកថា មាគណ្ឌិយសុត្តនិទ្ទេសទី ៩ .......... .......... ........... .......... ៩០៣